បណ្ឌិតសភាចារ្យ **ខ្លុត ធីតា**
Academician Khlot Thyda

# គតិបណ្ឌិត

## សម្រាប់

# ពុទ្ធសាសនិក

រក្សាសិទ្ធិ

ព.ស.២៥៦០ គ.ស.២០១៧

បណ្ឌិតសភាចារ្យ **ខ្លុត ធីតា**
Academician Khlot Thyda

# គតិបណ្ឌិត

## សម្រាប់

# ពុទ្ធសាសនិក

**រក្សាសិទ្ធិ**

**ព.ស.២៥៦០ គ.ស.២០១៧**

**បោះពុម្ពលើកទី២**

2nd EDITION

# គតិបណ្ឌិតសម្រាប់ពុទ្ធសាសនិក

ពិនិត្យ រៀបចំសម្រិតសម្រាំងនិងបោះពុម្ពដោយ បណ្ឌិតសភាចារ្យ **ខ្លូត ធីតា**

- ពិនិត្យអក្ខរាវិរុទ្ធដោយ **មន់ សម្បត្តិ** : មន្ត្រីក្រសួងសាធារណការ ( ចូលនិវត្តន៍ )
- អ្នកវាយកុំព្យូទ័រដោយ : លោកស្រី **ខ្លូត ចល័ក្ខណ៍**

លោកស្រី **រស់ សុខរ៉ាន់**

បោះពុម្ពលើកទី២ ចំនួន ៥០០ក្បាល

រាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០១៧ ព.ស.២៥៦០

កម្មសិទ្ធិបញ្ញារបស់អ្នករៀបរៀង







© Debby Lee Jagerman




© Debby Lee Jagerman


ពិធីប្រគល់គោរម្យងារ ជាកិត្តិព្រឹទ្ធបណ្ឌិត នៃរាជបណ្ឌិត្យសភាកម្ពុជា
ជូនលោកជំទាវ បណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន
វិមានសន្តិភាព ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១១

# កំណត់សម្គាល់របស់អ្នកបោះពុម្ពទី១ (Publishers’s Note)

ការបោះពុម្ពសៀវភៅផ្សាយលើកទីមួយនេះ បានធ្វើឡើងនៅក្នុងឆ្នាំ១៩៨៣ ដើម្បីរំលឹកខួបលើកទី២១នៃការបង្កើតសង្គមសាសនទូតព្រះពុទ្ធសាសនា (the Buddhist Missionary Society)។ សង្គមសាសនទូតព្រះពុទ្ធសាសនាចាប់ផ្ដើមប្រមូលនិងបោះពុម្ពផ្សាយអត្ថបទផ្សេងៗចំពោះទិដ្ឋភាពខុសៗគ្នារបស់ព្រះពុទ្ធសាសនាដែលបាននិពន្ធទៅតាមបែបសាមញ្ញនិងខ្លីៗ។ អ្នកចូលរួមវិភាគទានសំខាន់គឺជាទីប្រឹក្សាសាសនាគឺលោក **ម៉ែន បណ្ឌិត ក.ស្រីធម្មានន្ទ នាយក មហាថេរ:** (Ven. Dr. K. Sri Dhammananda Nayaka Maha Thera) **ជ.ស.ម** (J.S.M) ជាសង្ឃនាយកនៃ*ប្រទេសម៉ាឡេស៊ី* និង *សាំងហ្គាពួរ* ។

អ្នកប្រាជ្ញព្រះពុទ្ធសាសនាធំៗជាច្រើនទៀត នៅទូទាំងពិភពលោកក៏ចូលរួមធ្វើធម្មទានសប្បុរសជាមួយនេះដែរ សូមថ្លែងអំណរគុណចំពោះលោក **ម៉ែន បណ្ឌិត ក.ស្រីធម្មានន្ទ** អ្នកជំនួយការដ៏ល្អរបស់លោក និង ផលប្រយោជន៏ចម្រើនរុងរឿងនៅក្នុងព្រះពុទ្ធសាសនា ការបោះពុម្ពផ្សាយរបស់សង្គមសាសនទូតព្រះពុទ្ធសាសនាបាន រីកសាយភាយពាសពេញប្រទេសនិងពិភពលោក។ យើងបានទទួលសំបុត្រជាច្រើនពីគ្រប់មជ្ឈដ្ឋាននៅទូទាំងពិភពលោកក្នុងការវាយតម្លៃចំពោះកូនសៀវភៅទាំងនេះហើយក៏មានការស្នើសុំឱ្យមានការថតចម្លងកាន់តែច្រើនផងដែរ។ យើងដឹងច្បាស់ថា កូនសៀវភៅទាំងនេះបានបម្រើជាកូនសោរដែលអាចបើកចំហរស្មារតីរបស់មនុស្សមួយចំនួនធំឱ្យយល់ពីព្រះពុទ្ធសាសនា។ តម្លៃនៃការបោះពុម្ពកូនសៀវភៅទាំងនេះបានកើតឡើងដោយអ្នកបរិច្ចាកសប្បុរសជាច្រើនដែលបានផ្ដល់ជូនដោយឥតគិតថ្លៃទៅតាមប្រពៃណី មេត្តា ករុណានៃព្រះពុទ្ធសាសនាសម្រាប់ជាប្រយោជន៏សាធារណៈ។ កូនសៀវភៅនេះត្រូវបានបកប្រែនិងសំណៅសៀវភៅនីមួយៗមានចំនួនជាង១០ម៉ឺនក្បាលត្រូវបានបោះពុម្ពឡើងវិញហើយចែកជូនពាសពេញពិភពលោក។

ឥឡូវនេះត្រូវសម្រេចចិត្តដើម្បីធ្វើបទបង្ហាញពីសៀវភៅទាំងនេះ ដល់ភាពជាអ្នកអានកាន់តែទូលំទូលាយនៅក្នុងអត្ថបទកាន់តែស៊ីជម្រៅឡើងៗ ដើម្បីឱ្យ *ព្រះពុទ្ធរតនៈគតិបណ្ឌិត* (gems of Buddhist wisdom) ទាំងនេះអាចត្រូវបានធ្វើបទបង្ហាញកាន់តែប្រសើរសម្រាប់ជំនាន់ក្រោយៗ។ អត្ថបទជាច្រើនអាចត្រូវបានគេធ្វើការកែប្រែ ហើយបោះពុម្ពផ្សាយឡើងវិញទោះជានៅទីណាក៏ដោយតាមតែអាចធ្វើទៅបានដើម្បីជៀសវាងតម្រាប់ដដែលៗមិនចាំបាច់ពោល គឺកំហុសខាងភាសាវិទ្យានិងអក្ខរាវិរុទ្ធ។

សៀវភៅនេះមិនមានបំណងឱ្យគេអានពីដើមទៅដល់ចប់នៅមួយកន្លែងនោះទេ។ សង្ឃឹមថា អ្នកអាននឹងប្រព្រឹតទៅតាមអត្ថបទនីមួយៗ ដោយយកចិត្តទុកដាក់ប៉ុន្តែនៅពេលទំនេរសូមគិតទៅលើទឡ្ហីករណ៍នានា ដែលបានរៀបរាប់បង្ហាញដោយអ្នកនិពន្ធនីមួយៗមុននឹងចូលទៅអត្ថបទមួយទៀត។ អត្ថបទក៏មិនត្រូវបានរៀបចំទៅតាមដំណើរតក្កវិជ្ជាស្មុគស្មាញដើម្បីឱ្យពួកវាអាចត្រូវបានអានទៅតាមលំដាប់លំដោយហើយមិនចាំបាច់ដូចគេធ្វើបទបង្ហាញនៅទីនេះនោះទេ។

អ្នកនិពន្ធបានតំណាលនៅក្នុងសៀវភៅនេះ គឺជាអ្នកនិពន្ធអភិប្រាយល្បីឈ្មោះដ៏មានសារៈសំខាន់បំផុតទៅលើព្រះពុទ្ធសាសនាដែលមានការគោរពយ៉ាងខ្ពង់ខ្ពស់នៅក្នុងវិទ្យាស្ថានសិក្សាលើពិភពលោក។ ផ្ទុយទៅវិញសេចក្តីគោរពដ៏ធំធេងរបស់ពួកគេត្រូវបានឆ្លុះបញ្ចាំងទៅតាមលទ្ធភាពរបស់ពួកគេ ដើម្បីសរសេរស្តីអំពីទិដ្ឋភាពដ៏ធ្ងន់ធ្ងរបំផុតនៃសាសនារបស់យើងទៅតាមបែបសាមញ្ញនិងត្រង់ៗទៅវិញដោយមិនក្រអឺតក្រទមណាមួយឡើយ ពោលគឺរចនាបទ្ទសរសេរហួសសម័យឬក្រអឺតក្រទម។ អត្ថបទខ្លីៗដូចជា អត្ថបទដែលបានបោះពុម្ពនៅក្នុងសៀវភៅនេះបានដាក់បញ្ចូលនូវព្រះពុទ្ធឱវាទល្អៗបំផុតទៅដល់ការចាប់យកបានរបស់មនុស្សម្នាក់ៗ។ ពួកគេជាច្រើនបានសម្តែងឱ្យឃើញពីគំនិតគួរឱ្យចង់សើច (a charming sense of humor) និងសេចក្តីវៃឆ្លាតរួមជាមួយនឹងដំណោះស្រាយមិនហួសហេតុពេកចំពោះបញ្ហាស្មុគស្មាញរបស់មនុស្សជាតិ។

តាមរយៈការដកស្រង់ដែលអ្នកនិពន្ធបានប្រើប្រាស់ អ្នកអានដែលជាគ្រហស្ថ (the lay reader) ក៏អាចចែករំលែកគំនិតអ្នកនិពន្ធធំៗទាំងពួកបស្ចិមប្រទេសនិងអាស៊ីបានដែរ ករណីដូចជា Bertrand Russell និង Radhakrishnan ជាដើម។ សង្ឃឹមថា អ្នកទាំងនេះនឹងបំពេញចិត្តដល់អ្នកអានឱ្យវិលទៅរកអត្ថបទដើម ដើម្បីរួមចំណែកជាមួយនឹងគតិបណ្ឌិតធំៗរបស់មនុស្សជាតិ។

ដូចគេអានអត្ថបទទាំងនេះ គេអាចទទួលបាននូវការយល់ដឹងចំពោះចំនួនតម្រាប់តាមដដែលៗ មិនត្រឹមតែយល់ដឹងចំពោះគំនិតដែលបានធ្វើបទបង្ហាញរួចមកហើយនោះប៉ុណ្ណោះទេ ប៉ុន្តែក៏មានការយល់ដឹងពីការដកស្រង់ចេញពីអត្ថបទពិសិដ្ឋៗបានផងដែរ។ គេសង្ឃឹមថា អ្នកអានល្អៗនឹងយល់បានពីហេតុដែលរឿងនេះមានលក្ខណៈដូច្នេះ។ អ្នកនិពន្ធមិនមែនជាទីអាស្រ័យទៅលើផ្ទៃរឿងជាក់លាក់ណាមួយទេ។ ការពិតពួកគេជាច្រើនបានចែកដាច់គ្នាស្រឡះទៅតាមកាលនិងលំហ។ ឧទាហរណ៍ យ៉ាងហោចណាស់ក៏មានមួយអត្ថបទក្នុងចំណោមនេះមានអាយុប្រហែល៣៥ឆ្នាំដែរ នៅពេលដែលអត្ថបទដទៃទៀតត្រូវបានគេសរសេរកាលពីពេលថ្មីៗនេះបំផុតនៅ *ម៉ាឡេស៊ី ស្រីលង្កា* និង *អឺរ៉ុប* ។

តែទោះជាយ៉ាងណាក៏ដោយ គេអាចចាប់ផ្តើមមើលឃើញពីគោលបំណងរួមមួយដែលកើតឡើងដោយសារតែសំណេរខុសៗគ្នាទាំងនេះដែរគឺថា ដើម្បីបញ្ជាក់ឱ្យច្បាស់ពីចំនួននៃការយល់ខុសចំពោះព្រះពុទ្ធសាសនាហើយក៏ដើម្បីសង្កត់ធ្ងន់ភាពមានតែមួយនៃការបង្រៀនរបស់

ព្រះពុទ្ធផងដែរ។ ឧទាហរណ៍គេអាចអានម្តងហើយម្តងទៀតអំពីសូត្រ (Kala-ma) ដែលបង្ហាញឱ្យឃើញថា មានតែព្រះពុទ្ធតែមួយអង្គគត់ក្នុងចំណោមគ្រូប្រដៅសាសនាពិភពលោកដែលបានអះអាងថា គ្មានអ្នកណាម្នាក់ត្រូវតែទទួលយកការបង្រៀនរបស់ព្រះអង្គ ដោយគ្មានការវាយតម្លៃទៅលើការបង្រៀនទាំងនោះដោយខ្វះបញ្ញានោះទេ។ It is often refered to as (តែងតែសំដៅ) the *Magna Carta* នៃព្រះពុទ្ធសាសនា។

សេចក្តីសំអាងដ៏រឹងមាំក៏ត្រូវបានធ្វើឡើងចំពោះចតុរារិយសច្ច អដ្ឋង្គិកមគ្គនិងត្រៃលក្ខណៈ (អនិច្ចៈ ទុក្ខ អនត្តៈ)។ លក្ខណៈទាំងបីនេះគឺជាការបំភ្លឺដ៏ត្រចះត្រចង់បំផុតដែលមាននៅក្នុងគំនិតទស្សនវិជ្ជាទាំងមូលដែលរកឃើញមាននៅក្នុងសាសនា។ គ្មានការពិភាក្សាអំពីមាគ៌ាជីវិតព្រះពុទ្ធសាសនាណាអាចត្រូវបានបង្កើតឡើង ដោយគ្មានសេចក្តីសំអាងចំពោះលក្ខណៈទាំងនេះពោលគឺខ្លឹមសារនៃការបង្រៀនរបស់ព្រះពុទ្ធនោះឡើយ។

ពុទ្ធសាសនិកជនមិនដែលធុញទ្រាន់នឹងផ្សព្វផ្សាយថា តើមានតែពួកគេទេដែលគ្មានប្រវត្តិបង្ហូរឈាមគ្នាសោះដូចម្តេចនៅក្នុងការផ្សព្វផ្សាយសាសនារបស់ពួកគេនោះទេ។ ពួកគេឱ្យតម្លៃទៅលើព្រះពុទ្ធដែលហាមឃាត់មិនឱ្យមានអំពើហិង្សាដោយរូបភាពណាមួយឡើយ ហើយដកស្រង់ព្រះពុទ្ធិដិកាចេញពី the Dhammapada សម្រាប់គោលបំណងនេះ។ ហើយពួកគេបានជជែកយ៉ាងវែងអំពីអធិរាជអសោកដើម្បីបញ្ជាក់ថា ព្រះធម៌អាចត្រូវបានគេប្រតិបត្តិជាមាគ៌ាជីវិតជាតិមួយ (a national way of life)។ ពួកគេក៏ចង់សំដៅចំពោះសូត្រ Sigalovada ដើម្បីធ្វើឱ្យព្រះពុទ្ធឱវាទលេចធ្លោរឡើង នៅចំពោះអ្នកដែលមិនទាន់ជ្រះស្រឡះពីពិភពលោកនេះនៅឡើយ។

អំណានស្រដៀងគ្នា មួយក្នុងចំណោមអត្ថបទទាំងនេះ និងយ៉ាងជាក់ស្តែងដល់អ្នកណាម្នាក់ដែលព្រះពុទ្ធសាសនាអាចក្រោកឈរទល់នឹងការពិនិត្យសង្កេតដ៏រឹងមាំរបស់វិទ្យាសាស្ត្រ និងវិវាទនានា ខណៈពេលជាមួយគ្នានេះទៅហួសពីវិទ្យាសាស្ត្រ ដែលត្រូវផ្តល់ដល់មនុស្សនូវគោលបំណងមួយនៅក្នុងជីវិត និងដើម្បីជួយពួកគេឱ្យយល់ពីធម្មជាតិនៃបទពិសោធន៍របស់គេ។

វាអាចនឹងមានការចាំបាច់ដើម្បីពន្យល់នៅទីនេះថា ពេលពាក្យបាលីឬសំស្ក្រឹតត្រូវបានគេយកមកប្រើប្រាស់ អ្នកនិពន្ធបានជ្រើសយកការប្រកបវាទៅតាមបែបខុសៗគ្នា (ឧទាហរណ៍ *Gotama គោតម Gautama គោតម, Sutta សុត្ត Sutra សូត្រ Dhamma ធម្ម Dharma ធម៌ Nirvana និព្វាន, Kamma កម្ម Karma កម៌ Bodhisatta ពោធិសត្ត Bodhisatva*

*ពោធិសត្វ* Tipitaka *ព្រះត្រៃបិដក* Tripitaka *ព្រះត្រៃបិដក*ជាដើម ។ល ។) ប៉ុន្តែពាក្យទាំងអស់នេះមិនមានវិធីអ្វីដែលត្រូវជ្រៀតជ្រែកជាមួយនឹងការយល់ដឹងពីអ្វីដែលគេកំពុងនិយាយនោះទេព្រោះការបកប្រែភាសាអង់គ្លេសត្រូវបានផ្តល់ជូនជាទូទៅ ។ អ្នកនិពន្ធមួយចំនួនពេញចិត្តនឹងប្រើអក្សរធំសម្រាប់ការបញ្ចេញខ្យល់ដោយសំដៅចំពោះ *ព្រះពុទ្ធ* ឯអ្នកខ្លះទៀតមិនដូច្នេះទេ ។ ជាថ្មីម្តងទៀតអ្នកនិពន្ធខ្លះសំដៅចំពោះ “*ព្រះពុទ្ធ*” ឯអ្នកផ្សេងទៀតហៅព្រះអង្គធម្មតា ៗ ។

យើងផ្តល់ជូនលោកអ្នកដោយសុភាពរាបសានូវ *ព្រះពុទ្ធរតនៈគតិបណ្ឌិត*ទាំងនេះដោយក្តីសង្ឃឹមថា បើទោះជា លោក-អ្នកមិនចូលរួមជាមួយនឹងទស្សនៈរបស់យើងក៏ដោយ ក៏យ៉ាងហោចណាស់លោកអ្នកវាយតម្លៃទៅលើការបង្រៀនរបស់ព្រះពុទ្ធដែរ ហើយការប្រតិបត្តិព្រះពុទ្ធសាសនាមិនមានការលំអៀងនិងរើសអើងអ្វីដែរ ។

សង្គមសាសនទូតព្រះពុទ្ធសាសនា មានចិត្ត*កត្តញ្ញូកត្តវេទិតា* យ៉ាងជ្រាលជ្រៅដល់អស់លោកអ្នកប្រាជ្ញនិងអ្នកនិពន្ធទាំងអស់ចំពោះវិភាគទានក្នុងការជួយផ្តល់អត្ថបទដ៏មានតម្លៃរបស់ពួកគេ ហើយក៏មានចិត្ត*កត្តញ្ញូកត្តវេទិតា* យ៉ាងជ្រាលជ្រៅផងដែរចំពោះ Messrs Quah Swee Kheng, Eddy Yu, Mrs Goh Kim Mong, Alison Cheok, Daphne Chua, James Moran, Linda Moran, Ken Lee, Amelia Low (*ហុងកុង*) និង Vijaya Samarawickrama ដោយមិនគិតសេវាផ្ទាល់ខ្លួនដើម្បីជួយរៀបចំចងក្រងសៀវភៅនេះនិងសូមថ្លែងអំណរគុណជាពិសេសផងដែរចំពោះ Ch-ong Hong Choo ក្នុងការជួយរៀបចំប្លង់ក្របសៀវភៅនេះ ។

**Tan Teik Beng**

ប្រធានសង្គមសាសនទូតព្រះពុទ្ធសាសនា កូឡាឡាំពួរ ម៉ាឡេស៊ី ១៩៩៥

## អារម្ភកថារបស់អ្នកបកប្រែនិងរៀបរៀង

ខ្ញុំជាអ្នកស្រាវជ្រាវផ្នែក "*ទស្សនវិជ្ជាព្រះពុទ្ធសាសនា*" ក្រោយពីខ្ញុំបានឃើញឯកសារនេះ ខ្ញុំយល់ថាពិតជាងាយអានងាយយល់ណាស់ ប្រសិនបើប្រៀបទៅពេលដែលខ្ញុំធ្លាប់ស្រាវជ្រាវរយៈពេល២០ឆ្នាំ គឺពីឆ្នាំ១៩៩០ (តាំងពីជានិស្សិតបណ្ឌិតនិងជាបណ្ឌិត នៅទីក្រុងហាណូយ ប្រទេសវៀតណាមខាងជើង ទីក្រុងកូឡំបូ ប្រទេសស្រីលង្កា នៅបណ្ណាល័យមួយនៃប្រទេសឥណ្ឌានិងនៅបណ្ណាល័យជាតិ បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យវត្តឧណ្ណាឡោម បណ្ណាល័យរណសិរ្សជាតិ) ដល់បច្ចុប្បន្ន រួមទាំងខ្ញុំជាអ្នកធ្វើការក្នុងការងារនេះផងដែរ (ទីប្រឹក្សាផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ទទួលបន្ទុកការងារធម្មការនិងសាសនា) ព្រមទាំងជាអតីតនិស្សិតថ្នាក់មធ្យមពុទ្ធិកៈមហាវិទ្យាល័យតាំងពីឆ្នាំ១៩៦៣ទៀតផង ។

ខ្ញុំបានគិតទៀតថា សៀវភៅនេះពុទ្ធសាសនិក និងសាសនិកទាំងឡាយអាចងាយយល់ងាយស្រាវជ្រាវមិនថាថ្នាក់ណាឬថ្នាក់ណាទេ ឱ្យតែព្យាយាមអានសារចុះសារឡើងឱ្យបានពីរឬបីចប់នោះ គឺពិតជាយល់អំពីខ្លឹមនៃព្រះពុទ្ធសាសនាហើយក៏អាចចេះរស់រួមជាមួយគ្នាដោយរីករាយគ្រប់សាសនាទាំងអស់ ថែមទាំងអាចកាត់បន្ថយបានច្រើននូវកង្វល់ឥតព្រំដែនរបស់យើងទាំងអស់គ្នាបានផង ។ មានន័យថាអ្វីដែលយើងចង់បាននោះៗ បានបង្ហាញនៅក្នុងអត្ថបទនេះអស់ហើយៗរួមទាំងសំណួរទាំងចម្លើយទៀតផង ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមជម្រាបបញ្ជាក់ជាថ្មីម្ដងទៀតថា ក្នុងការប្រែសម្រួលពីភាសាអង់គ្លេសមកជាភាសាជាតិយើង តែងមានការឆ្នៃពាក្យពេចន៍ ឃ្លាប្រយោគខ្លះជាធម្មតា ប៉ុន្តែទោះជាយ៉ាងណាក៏ខ្ញុំឥតមានថែមថយសាច់រឿងឬពន្លើសពាក្យសម្ដីទេ មានតែកាត់បន្ថយខ្លះព្រោះកន្លែងខ្លះបាលីច្រើនពេកដែលនាំឱ្យអ្នកមិនធ្លាប់បួសពិបាកអានពិបាកយល់ ។

ហេតុនេះសូមមិត្តអ្នកអាន អ្នកស្រាវជ្រាវមេត្តាយោគយល់ខ្ញុំផង ។

**សូមឧទ្ទិសឯកសារនេះដល់ពុទ្ធសាសនិកទាំងអស់ដែលលោកបានចែកស្ថានទៅហើយៗ រួមទាំងលោកឪពុក អ្នកម្ដាយនិងក្រុមគ្រួសាររបស់ខ្ញុំដែលបានបាត់បង់នៅសម័យប៉ុលពតនិងសម័យបច្ចុប្បន្នផងដែរ ។**

ខ្ញុំរង់ចាំទទួលនូវមតិរិះគន់និងកែលម្អ

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៩

បណ្ឌិត **ខួត ធីតា**

ទីប្រឹក្សាផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ទទួលបន្ទុកការងារធម្មការនិងសាសនា និងជាអនុប្រធានរាជបណ្ឌិតសភាកម្ពុជា

## ជំពូកទី១

## ស្ថានភាពទូទៅនៃព្រះពុទ្ធសាសនា

(General Views of Buddhism)

### ១-សាសនាជាអ្វី?(What is this Religion?) By Ven. Dr. K. Sri Dhammananda

មនុស្សរាល់រូបត្រូវតែប្រកាន់យកសាសនាមួយ ជាពិសេសសាសនាដែលត្រូវការស្មារតីបញ្ញា។ មនុស្សម្នាក់ដែលមិនបានពិនិត្យលើគោលការណ៍សាសនា នឹងធ្វើឱ្យមានការគ្រោះថ្នាក់ដល់សង្គម។ ជាការពិតកាលណាគ្មានមន្ទិលសង្ស័យថា អ្នកវិទ្យាសាស្ត្រ និងចិត្តវិទូបានពង្រីកវិសាលភាពបញ្ញារបស់យើង ប៉ុន្តែពួកគេមិនអាចប្រាប់យើងពីគោលដៅនៃជីវិតរបស់ យើងបានឡើយ មានតែសាសនាទេដែលអាចប្រាប់យើងបាន។

មនុស្សត្រូវតែជ្រើសរើសយកសាសនាមួយ ដែលបណ្តុះការពិចារណា និងមានអត្ថន័យស្របតាមជំនឿរបស់គេដោយមិនផ្អែកទៅលើតែជំនឿ ប្រពៃណី ទំនៀមទម្លាប់ និងទ្រឹស្តីប៉ុណ្ណោះនោះឡើយ។ គ្មាននរណាម្នាក់មានសិទ្ធិ បង្ខំគេឱ្យទទួលយកសាសនាណាមួយឡើយ។ គ្មាននរណាម្នាក់ត្រូវកេងប្រវ័ញ្ចលើភាពក្រីក្រ ភាពមិនចេះអក្សរឬទាក់ទាញទឹកចិត្តដើម្បីជំរុញឱ្យទទួលយកសាសនាណាមួយឡើយ ។ សាសនាត្រូវតែជាជម្រើសដោយសេរី។

មនុស្សត្រូវតែមានសេរីភាពក្នុងការជ្រើសរើសសាសនាផ្ទាល់ខ្លួន អាស្រ័យទៅតាមចំណូលចិត្ត និងសមត្ថភាពបញ្ញារបស់គេ។ ការដើរតាមសាសនាមួយដោយងងឹតងងុល ដោយគ្មានការយល់ដឹងនឹងក្លាយទៅជាការដកហូតពីសាសនានោះ នូវតម្លៃស្មារតីហើយដកហូតពីបរិស័ទនោះនូវសេចក្តីថ្លៃថ្នូរជាមនុស្ស។ មនុស្សមានបញ្ញា និងមានសុភវិនិច្ឆ័យក្នុងការបែងចែករវាងអ្វីដែលខុសនិងអ្វីដែលត្រូវ ។គេអាចសម្របខ្លួនទៅតាមកាលៈទេសៈបាន។ ដូច្នេះគេអាចជ្រើសរើសយកសាសនាមួយដែលសមរម្យចំពោះគេ ហើយត្រូវនឹងកម្រិតបញ្ញារបស់គេ។ គេត្រូវទទួលការដឹកនាំយ៉ាងត្រឹមត្រូវ ហើយបន្ទាប់មកគេបានទទួលឱកាសដើម្បីសម្រេចចិត្តដោយសេរីដោយគ្មានការបង្ខិតបង្ខំ។

**ផ្លូវកណ្តាល** (The Middle-Way)

សាសនាដែលត្រូវលើកយកមកបង្ហាញនៅទីនេះ គឺជាប្រព័ន្ធអប់រំបែបប្រតិបត្តិចំពោះវប្បធម៌បញ្ញា ដែលបានបង្ហាញខ្លួនឡើងចំពោះពិភពលោកកាលពី២៥ សតវត្សរ៍កន្លងទៅដោយព្រះបរមគ្រូដែលបាន*ត្រាស់ដឹងដោយពេញលេញ* និងប្រកបដោយមេត្តាករុណា។ សាសនានេះ

ត្រូវបានគេស្គាល់ដោយសារ "*ផ្លូវកណ្ដាល*" ដែលជាផ្លូវត្រូវសម្រាប់ជីវិត ជាប្រព័ន្ធសីលទស្សនវិជ្ជាមួយ និងជាសាសនាសេរីភាព និងវិចារណញ្ញាណ។ សាសនានេះបង្រៀនយើងឱ្យធ្វើអំពើសំខាន់បីគឺ "*ជៀសវាងពីអំពើអាក្រក់ធ្វើអំពើល្អ* និង *ធ្វើចិត្តឱ្យបរិសុទ្ធ* "។

ខ្លឹមសារនេះមានលក្ខណៈសាមញ្ញ មានន័យជ្រាលជ្រៅ និងមានលក្ខណៈប្រតិបត្តិបំផុត ប៉ុន្តែមនុស្សជួបការលំបាកនៅពេលគេយកខ្លឹមសារនេះទៅអនុវត្ត ដោយសារតែភាពទន់ខ្សោយដែលនៅជាប់នឹងខ្លួនគេ។ អាកប្បកិរិយាសីលធម៌ របស់មនុស្សមានជាផ្នែកសំខាន់បំផុតនៅក្នុងសាសនានេះ។ ព្រះបរមគ្រូមានពុទ្ធដីកាថា "*ការប្រៀនប្រដៅរបស់តថាគតមិនមែនត្រូវទទួលហើយជឿនោះទេប៉ុន្តែត្រូវទទួលដោយការពិចារណាហើយអនុវត្ត*"។ ពុទ្ធដីកានេះលើកទឹកចិត្តមនុស្សឱ្យសិក្សាព្រះធម៌យ៉ាងពេញលេញដើម្បីយកមកវិនិច្ឆ័យមុន នឹងសម្រេចចិត្តថា តើគេគួរទទួលយកការប្រៀនប្រដៅនេះឬមិនគួរ។ គ្មានជនណាម្នាក់ត្រូវគេស្នើឱ្យទទួលយកហើយ ដើរតាមសាសនា នេះដោយគ្មានការយល់ដឹងជាមុននូវខ្លឹមសារនៃព្រះធម៌ទេ។

ទំនៀមទម្លាប់ដ៏ច្រើនហួសពីសេចក្ដីត្រូវការមិនមានតម្លៃសាសនា ឬសារៈសំខាន់ពិតប្រាកដទេ។មិនមានជំនឿនិងការប្រតិបត្តិបែបអធិធម្មជាតិឬលទ្ធិអាថ៌កំបាំងនៅក្នុងសាសនានេះឡើយ។ អ្វីៗទាំងអស់បានបើកចំហរដើម្បីការជ្រើសរើសរបស់អ្នកដើរតាម ដែលមានសេរីភាពដើម្បីឱ្យគេស៊ើបសួរអំពីព្រះធម៌ និងសួរសំណួរណាដែលគេចង់សួរដើម្បីបំបាត់ការងឿងឆ្ងល់របស់គេ។ តាមទស្សនៈរបស់អ្នកបង្កើតសាសនានេះ គេមិនគួរជឿលើអ្វីមួយដោយសារតែអ្នកប្រាជ្ញល្បីៗបានលើកឡើងឬដោយសារតែគេធ្វើតាមទំនៀមទម្លាប់នោះទេ ប៉ុន្តែគេគួរតែប្រើប្រាស់សុភវិនិច្ឆ័យ និងបញ្ញារបស់គេមុន នឹងទទួលយកដើម្បីពិនិត្យមើលថា តើសមនឹងទទួលយកឬទេ។

សាសនានេះបង្រៀនពីអរិយមគ្គទាំង៨ដែលរួមមាន ការយល់ដឹង ការគិត ការនិយាយ ការប្រព្រឹត្ត ការចិញ្ចឹមជីវិត ការព្យាយាម ការភ្ញាក់រលឹកនិងការតាំងចិត្តត្រឹមត្រូវ។ផ្លូវកណ្ដាលដែលល្អឯកនេះបង្កលក្ខណៈឱ្យអ្នកដទៃមានជីវភាពថ្លៃថ្នូរ និងប្រកបដោយសន្តិភាព។

ផ្លូវកណ្ដាលនេះមិនមែនជាគន្លងផ្លូវអស្លីលរូប ឬជាគន្លងផ្លូវទំនៀម មិនមែនជាគម្ពីរនិយម ឬសង្ស័យនិយម មិនមែនការបំពេញចំណង់តណ្ហារបស់ខ្លួន ឬការធ្វើបាបខ្លួនមិនមែនជាលទ្ធិគ្មានទីបញ្ចប់ ឬលទ្ធិគ្មានសាសនា មិនមែនជាលទ្ធិទុទិដ្ឋិនិយមឬសុទិដ្ឋិនិយមតែជាមាគ៌ានៃការត្រាស់ដឹងជាមធ្យោបាយចាកចេញពីទុក្ខកង្វល់។ សាសនានេះមិនទទួលស្គាល់ថា មនុស្សជាតិដែលរងទុក្ខសព្វថ្ងៃព្រោះតែអំពើខុសឆ្គងរបស់បុព្វបុរសរបស់គេទេ ប៉ុន្តែផ្ទុយទៅវិញគឺ ព្រោះតែមនុស្ស

គ្រប់រូបប្រកាន់យកកុសលឬអកុសលរបស់ខ្លួន។ មនុស្សខ្លួនឯងទទួលខុសត្រូវតែម្នាក់ឯងចំពោះសេចក្តីឈឺចាប់ ឬសេចក្តីរីករាយផ្ទាល់ខ្លួន។

អ្នកដែលដើរតាមផ្លូវកណ្តាលនៃមជ្ឈិមភាព (ការមិនប្រព្រឹត្តឱ្យហួសហេតុ) នឹងរកឃើញសន្តិភាព និងសុភមង្គលពិតប្រាកដ ហើយនឹងដឹកនាំជីវិតដែលទទួលការគោរពដោយសារភាពមិនធ្លាក់ជាទាសករនៃអារម្មណ៍របស់ខ្លួននេះហើយ ជាការរួមវិភាគទានចំពោះសន្តិភាព និងភាពសុខដុមរបស់ពិភពលោក ។

**ទទួលនូវអ្វីដែលគេបានសាបព្រោះ** (Reap what you Sow)

សាសនានេះគាំទ្រសេចក្តីប្រាថ្នាដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់របស់មនុស្ស ហើយអាចស៊ូទ្រាំនឹងសេចក្តីទុក្ខកង្វល់ក្នុងជីវភាពរាល់ថ្ងៃរបស់មនុស្ស ដោយការជួយគេឱ្យបានជួប នឹងមិត្តភក្តិរបស់គេ និងបង្ហាញដល់គេនូវគោលដៅនៃជីវិត។ សាសនានេះមិនបំពាក់បំប៉នសេចក្តីភ័យខ្លាចដល់មនុស្សទេ។ "*ធ្វើល្អបានល្អធ្វើអាក្រក់បានអាក្រក់*" "*រាល់អំពើតែងមានផលរបស់វា*" ។ ទាំងនេះជាច្បាប់សកល ។សាសនានេះយល់ស្របទាំងស្រុងនឹងច្បាប់នេះដោយអប់រំឱ្យមនុស្សត្រូវតែ "*ទទួលនូវអ្វីដែលខ្លួនបានសាង*" ។ អំពើអាក្រក់ត្រូវបានប្រព្រឹត្តដោយមនុស្ស ព្រោះតែលោភៈ ទោសៈ និងមោហៈរបស់គេ។ គុណវិបត្តិទាំងនេះអាចយកឈ្នះបានដោយការយល់ដឹងអំពីខ្លួនឯង។ ការសប្បាយរីករាយ និងការឈឺចាប់ដែលមនុស្សមានក្នុងលោកនេះ មិនមែនបណ្តាលមកពីឥទ្ធិពលខាងក្រៅទេ ប៉ុន្តែបណ្តាលមកពីអំពើល្អ និងអំពើអាក្រក់ ពាក្យសម្តី និងទង្វើដែលគេបានប្រព្រឹត្ត។ ដោយមូលហេតុនេះហើយទើបសាសនានេះប្រៀនប្រដៅថា "*យើងធ្វើយ៉ាងណាទទួលផលយ៉ាងនោះយើងនឹងធ្វើយ៉ាងណានឹងទទួលផលយ៉ាងនោះ*" ។

តាមការប្រៀនប្រដៅនេះ ហេតុនិងផលគឺជាផ្នែកសំខាន់បំផុតក្នុងជីវិតរបស់យើង។ នៅក្នុងវដ្តនៃហេតុ និងផល ហេតុទី១ មិនអាចស្ថិតនៅឱ្យមើលឃើញទេ ពីព្រោះហេតុបានក្លាយជាផល ហើយផលដល់វេនក្លាយជាហេតុមួយទៀត។

**បរមសុខនៃស្ថានសួគ៌** (Heavenly Bliss)

ពុទ្ធបរិស័ទមិនចាត់ទុកថា "ពួកគេជាមនុស្សពិសេស ដែលអាចទៅដល់បរមសុខនៃស្ថានសួគ៌ឡើយ។ គេមានជំនឿជាទូទៅថា មនុស្សបង្កើតឋានសួគ៌ ឬឋាននរកដោយខ្លួនគេផ្ទាល់ទៅតាមរបៀបរបបរស់នៅរបស់គេ ហើយគេជឿថាសេចក្តីទុក្ខលំបាកនៅឋាននរក ឬការស្គាល់បរមសុខនៃស្ថានសួគ៌អាចទទួលបាននៅក្នុងជីវិតលោកិយនេះ មិនចាំដល់ជាតិក្រោយទេ។ ព្រះ

សាស្តានេះមិនដែលផ្តល់ការទូន្មាន ដោយការបន្លាចមនុស្សជាមួយនឹងភ្លើងនរកឬដោយការលួងលោមជា មួយនឹងជីវិតអមតៈនៅឋានសួគ៌នោះទេ ប៉ុន្តែដោយការបង្ហាញឱ្យឃើញសច្ចភាព។ អាស្រ័យដោយការបង្រៀននេះ នរណាម្នាក់ក៏អាចរីករាយ នឹងបរមសុខនៃស្ថានសួគ៌បានដែរ ដរាបណាគេរស់នៅតាមផ្លូវត្រូវ។ ស្ថានសួគ៌មិនមែនបម្រុងទុក ឬទទួលផ្តាច់មុខដោយនិកាយពិសេសណាមួយ ឬក៏សហគមន៍សាសនាណាមួយទេ។ ស្ថានសួគ៌ត្រូវបើកចំហរ សម្រាប់មនុស្សទាំងឡាយណាដែលដឹកនាំជីវិតតាមមាគ៌ាខ្ពង់ខ្ពស់ "។

ការអធ្យាស្រ័យអំណត់ និងការយោគយល់គឺជាគុណធម៌ដ៏មានតម្លៃ ដែលទ្រទ្រង់ដោយអ្នកដើរតាមសាសនាព្រះពុទ្ធ។ មេត្តា ករុណា មុទិតា និងឧបេក្ខាចំពោះអ្នកដទៃ គឺមិនកំណត់ត្រឹមមនុស្សជាតិទេ ប៉ុន្តែរហូតដល់ភាវៈរស់ទាំងអស់ដោយហេតុថា ការបៀតបៀនជីវិតមនុស្ស ឬសត្វជាអំពើឃោរឃៅ និងមិនត្រឹមត្រូវ ហើយវាប្រឆាំងនឹងការអប់រំរបស់សាសនានេះ ។

សាសនានេះក៏អប់រំឱ្យអ្នកដើរតាមគោរពទស្សនៈរបស់អ្នកដទៃផងដែរ ដើម្បីទទួលបាននូវជីវភាពសុខដុមរមនា។

**មាគ៌ាជីវិត** (Way of Life)

សាសនានេះមានភាពច្បាស់លាស់សមហេតុផល ហើយផ្តល់នូវចម្លើយពេញលេញចំពោះផ្នែកសំខាន់ៗទាំងអស់និង ចំពោះបណ្តាសំណួរអំពីជីវិតរបស់យើង។ សាសនានេះផ្តល់នូវមូលដ្ឋានដ៏រឹងមាំមួយ ដើម្បីជួយឱ្យមនុស្សជាតិ ធ្វើដំណើរឆ្ពោះទៅរកជីវភាពរស់នៅប្រកបដោយវិជ្ជមានភាព និងកាន់តែប្រសើរឡើង ។

សាសនានេះមិនបែងចែកមនុស្សជាពួកជាក្រុម "*ក្រុមត្រូវជួយសង្គ្រោះ* (the saved)" និង *ក្រុមត្រូវបោះបង់* (the lost)" នោះទេ ព្រោះជាសាសនាមានអារ្យធម៌ខ្ពង់ខ្ពស់ និងមានការយល់ដឹងជ្រាលជ្រៅ ដែលបង្រៀនយើងពីវិធីផ្សាំងសត្វព្រៃ និងដុសខាត់សត្វដែលសាំងហើយ។

ពុទ្ធសាសនិកមិនផ្តេកផ្តួលខ្លួនទៅលើការសូត្រធម៌បន់ស្រន់ឬសុំខមាទោសទេ។ គេមានជំនឿលើសារៈសំខាន់នៃការខំប្រឹងប្រែងដោយខ្លួនឯង ហើយនិងប្រសិទ្ធភាពនៃការធ្វើសមាធិដែលនាំខ្លួនឱ្យឈ្នះលើខ្លួនឯង ត្រួតពិនិត្យខ្លួនឯងធ្វើខ្លួនឱ្យបរិសុទ្ធដោយខ្លួនឯងសម្រាលទុក្ខ និងបំភ្លឺខ្លួនដោយខ្លួនឯង ពីព្រោះការធ្វើសមាធិត្រូវបានប្រើប្រាស់ជាថ្នាំលើកកម្លាំង (អាយតពលភាព) ចំពោះចិត្តនិងសតិ ។

**មនុស្សអាចច្នៃជីវិតរបស់ខ្លួនបាន** (Man can mould his Life)

សាសនាព្រះពុទ្ធអះអាងថា *ចិត្ត* គឺជាកម្លាំងនៃអំណាចទាំងអស់ ជាអ្នកបង្កើតនិងជាអ្នកបំផ្លាញមនុស្ស និងជាស្ថាបត្យករចំពោះវាសនាមនុស្ស ។ ដូច្នេះ មនុស្សមានលទ្ធភាពអាចច្នៃអ្វីមួយក៏បានល្អីកណាគេដឹងពីវិធីធ្វើ និងប្រើប្រាស់ចិត្តរបស់គេបានត្រឹមត្រូវ ។

ជាការពិត សាសនានេះជាភ្លើងហ្វា (lighthouse) ដ៏ល្អឥតខ្ចោះសម្រាប់បង្ហាញផ្លូវ មនុស្សជាតិឆ្ពោះទៅរកសន្តិភាព សុភមង្គល និងបរមសុខគ្មានទីបំផុត ។ តាមតថភាពជាក់ស្តែង ពិភពលោកបច្ចុប្បន្នស្ថិតក្នុងចំណោទបញ្ហានៃភាពមិនយល់គ្នាក្នុងបញ្ហាពូជសាសន៍នយោបាយសហគមន៍ និងមនោគមវិជ្ជា។ ដើម្បីដោះស្រាយចំណោទបញ្ហាដ៏ស្មុគស្មាញនេះ មនុស្សត្រូវតែហ្វឹកហាត់ទឹកចិត្តមេត្តាប្រណី (សុជនភាព) និងអធ្យាស្រ័យចំពោះគ្នាទៅវិញទៅមក ហើយទឹកចិត្តនេះអាចបណ្តុះបាននៅក្រោមការបង្ហាញផ្លូវនៃសាសនានេះ ដែលត្រូវបណ្តុះស្មារតីសហាការប្រកបដោយសីលធម៌ដើម្បីកុសលធម៌ទូទាំងសកលលោក ។មនុស្សត្រូវតែយល់ដឹងថាដើម្បីសុភមង្គល និងសុខុមាលភាពពិតប្រាកដរបស់មនុស្សជាតិការអភិវឌ្ឍន៍ ទឹកចិត្តមានសារៈសំខាន់ជាងសមិទ្ធកម្មនៃការអភិវឌ្ឍន៍សម្ភារៈ ។ មនុស្សត្រូវតែប្រតិបត្តិផងដែរនូវសច្ចធម៌ សេវាកម្មសប្បុរសធម៌ និងសេចក្តីស្រឡាញ់ ប្រសិនបើគេត្រូវប្រែក្លាយពិភពលោកនេះទៅជា ទីកន្លែងដ៏ប្រសើរមួយសម្រាប់ការរស់នៅ ។

**ភាពជាក់ស្តែង** (Actuality)

តាមរយៈ ការត្រាស់ដឹងព្រះពុទ្ធបរមគ្រូប្រកាសថា :

- គុណធម៌ដែលប្រសើរបំផុត គឺគុណធម៌ដែលទទួលបាននៅក្នុងការបណ្តុះមេត្តាធម៌ចំពោះសព្វសត្វ ។
- សុភមង្គលឧត្តមបំផុត គឺជាសុភមង្គលដែលបានមកពីភាពស្ងប់នៃគំនិត (មានសិក)
- សច្ចភាពដាច់ខាត គឺសច្ចភាពដែលទទួលបានតាមរយៈការយល់ដឹងពីមូលហេតុនៃទុក្ខ
- សាសនាដែលខ្ពង់ខ្ពស់បំផុត គឺសាសនាដែលបង្រៀនពីការអភិវឌ្ឍន៍បញ្ញា សីលធម៌ និងការធ្វើឱ្យចិត្តមានភាពបរិសុទ្ធ ។
- ទស្សនវិជ្ជាដែលឧត្តុង្គឧត្តមបំផុតគឺទស្សនវិជ្ជាដែលបង្ហាញពីជីវិតប្រតិបត្តិ ដែលអាចអនុវត្តបាន ដោយមិនពឹង ផ្អែកតែទៅលើទ្រឹស្តី និងជំនឿ ។

សាសនានេះមិនបន្ទុចបង្អាក់នរណាម្នាក់មិនឱ្យអានឬ សិក្សាការប្រៀនប្រដៅនៃសាសនាដទៃឡើយ ហើយក៏មិនអនុញ្ញាតឱ្យមានជំនឿងប់ងុលដោយខ្វះការពិចារណាដែរ ។ អ្នកមានជំនឿងប់ងុល មិនអាចទទួលការណែនាំពីវិចារណញ្ញាណ ឬពីគោលការណ៍វិទ្យាសាស្ត្រអំពីការសង្កេត និងវិភាគឡើយ ។ ដូច្នេះអ្នកដើរតាមសាសនានេះ គឺជាអ្នកមានសេរីភាពប្រកបដោយសតិសេរី ហើយមិននៅក្រោមបង្គាប់នរណាម្នាក់ ដើម្បីការអភិវឌ្ឍន៍ចិត្តរបស់គេនោះឡើយ ។

ប្រសិនបើអ្នកយកចិត្តទុកដាក់សិក្សាបន្ថែមទៀតអំពីព្រះវិន័យ ឬក្រមសីលធម៌នៃសីលវិជ្ជា (ethics) និងអំពីការហ្វឹកហ្វឺនបញ្ញារបស់សាសនានេះ អ្នកនឹងត្រូវបន្សាត់ចេញនូវសេចក្តីមន្ទិលទាំងឡាយដែលមានពីមុនមកចំពោះសាសនានេះ ។គេមិនគួរវិនិច្ឆ័យតម្លៃនៃសាសនាមួយតាមការសង្កេតលើការប្រតិបត្តិមួយចំនួនរបស់អ្នកដើរតាមដែលស្រពេចស្រពិលនោះឡើយ ។ផ្ទុយទៅវិញគេគួរតែព្យាយាមជានិច្ចសិក្សាឱ្យបានស៊ីជម្រៅនូវការអប់រំជាមូលដ្ឋាននៃសាសនានោះ ។

**ជំនឿជឿជាក់ចំពោះបញ្ញារបស់មនុស្ស** (Credit to Man's Intelligence)

ផ្ទុយពីការដាក់ឱ្យមនុស្ស និងវាសនារបស់គេស្ថិតនៅក្រោមការត្រួតពិនិត្យតាមតែអំពើចិត្តរបស់ភ្នាក់ងារមិនស្គាល់នៅក្នុងពិភពខាងក្រៅ ហើយធ្វើឱ្យគេស្ថិតក្នុងភាពរណបចំពោះអំណាចដ៏ខ្ពង់ខ្ពស់បំផុតនោះ ព្រះពុទ្ធសាសនាបានលើកកំពស់ឋានៈរបស់មនុស្សជាតិហើយ ព្រមព្រៀងឱ្យមនុស្សជឿលើខ្លួនគេអាស្រ័យដោយបញ្ញារបស់គេ។ សាសនានេះបង្រៀនមនុស្ស ពីវិធីបណ្តុះសក្តានុពលជាមនុស្សដែលនៅកប់ក្នុងខ្លួនគេ ។

សាសនានេះបង្រៀនយើងអំពីវិធីយកអាសារអ្នកដទៃដោយមិនគិតប្រយោជន៍ផ្ទាល់ខ្លួន ។ អ្នកដើរតាមសាសនានេះ ជៀសវាងអំពើអាក្រក់មិនមែនដោយសារតែការភ័យខ្លាចចំពោះការដាក់ទោសពីភាវៈដែលមើលមិនឃើញនោះទេ ប៉ុន្តែដោយសារតែការយល់ដឹងថា អំពើអាក្រក់នោះ នឹងនាំមកនូវទុក្ខចំពោះភាវៈរស់ទាំងឡាយ ។

កម្លាំងជំរុញរបស់គេក្នុងការធ្វើអំពើល្អ ក៏មិនមែនដើម្បីបំពេញចិត្តភាវៈខ្ពង់ខ្ពស់ណាមួយដោយទន្ទឹងចាំរង្វាន់នោះដែរ ប៉ុន្តែគឺអាស្រ័យដោយអារម្មណ៍នៃសេចក្តីករុណា និងបំណងរំដោះខ្លួនគេឱ្យរួចចាកទុក្ខ ។

នៅក្នុងព្រះពុទ្ធសាសនានេះទៀតសោត អ្នកអាចរកឃើញវិធីសម្រិតសម្រាំងកុសលធម៌និងបញ្ញាដោយមិនចាំបាច់មានជំនួយណាមួយពីពិភពខាងក្រៅទេ ។ អ្នកអាចសម្រេចបាន បញ្ញាខ្ពស់បំផុតតាមរយៈការយល់ដឹងមិនមែនចាំបាច់តែតាមរយៈការធ្វើឱ្យដឹង( ស្រុតិ=revelation)

នោះទេ។ អ្នកអាចទទួលបាននូវការរំដោះបាប (redemption) ដោយគ្មានជំនួយ ពីអ្នករំដោះបាប ជំនួសនោះបានឡើយ។ អ្នកអាចទទួលបាននូវការជួយសង្គ្រោះក្នុងជាតិនេះដោយការហ្វឹកហាត់ ពិចារណាយ៉ាងហ្មត់ចត់របស់ញាណសក្តិ (កម្លាំងកាយ ឬចិត្ត) ផ្ទាល់របស់អ្នកដោយគ្មានរង់ចាំ ដល់ជាតិក្រោយ។ សាសនានេះបង្រៀនថា មនុស្សមិនមែនធ្វើអ្វីៗដើម្បីសាសនានោះទេ ប៉ុន្តែ សាសនានេះធ្វើអ្វីៗដើម្បីមនុស្ស។ ទស្សនៈនេះមានន័យថា "*ដោយមិនធ្វើជាទាសករសាសនាណា មួយមនុស្សត្រូវតែព្យាយាមប្រើប្រាស់សាសនាមួយដើម្បីភាពប្រសើរឡើង និងសេរីភាពរបស់ ខ្លួន*"។

**តើអាចទៅរួចដែរឬទេ** ? (Is it Possible?)

តើជីវិតអាចធន់ទ្រាំដោយគ្មានការសប្បាយខាងឥន្ទ្រិយារម្មណ៍បានដែរឬទេ ?

-តើមនុស្សអាចមានសីលធម៌ដោយគ្មានជំនឿក្នុងភាពមិនចេះសូន្យ(immortality)បានដែរឬទេ?

-តើមនុស្សអាចបោះជំហានទៅរកភាពត្រឹមត្រូវដោយគ្មានជំនួយពីភ្នាក់ងារខាងក្រៅបានដែរឬទេ ?

-តើមនុស្សអាចរស់នៅតាមគន្លងសាសនាដោយគ្មានទំនៀមទម្លាប់ប្រពៃណីបានដែរឬទេ ?

-តើមនុស្សអាចប្រតិបត្តិសាសនាមួយដោយគ្មានសេចក្តីទុកចិត្តនិងជំនឿខាងផ្លូវចិត្តបានដែរឬទេ ?

-តើមនុស្សអាចមានសេរីភាព ដោយគ្មានទណ្ឌកម្មណាមួយពីសាសនាបានដែរឬទេ ?

-តើមនុស្សអាចដើរតាមគោលការណ៍សាសនាជាក់លាក់ណាមួយ ដោយគ្មានសេចក្តីភ័យខ្លាចបាន ដែរឬទេ ?

-តើយើងអាចបង្រៀនសាសនាត្រឹមត្រូវ មួយដោយគ្មានការប្រើកម្លាំង និងការគម្រាមកំហែង ចំពោះអ្នកដទៃបានដែរឬទេ ?

-តើគេអាចធ្វើឱ្យសង្គមមនុស្សដឹកនាំជីវិតតាមគន្លងសាសនា ដោយគ្មានជំនឿអធិធម្មជាតិ និង គំនិតតាមគម្ពីរសាសនាបានដែរឬទេ ?

-តើមនុស្សអាចឱ្យតម្លៃសាសនា និងតម្កើងសាសនា ដោយគ្មានសិល្បវិធីនៃអធិធម្មជាតិ មន្ត អាគម និងបព្វជិតបានដែរឬទេ ?

-"បាន"នេះជាចម្លើយរបស់ព្រះពុទ្ធ ដែលជាអ្នកបង្កើតសាសនានេះ។ បញ្ហាទាំងឡាយនេះអាច បញ្ចប់ដោយសេវាកម្មភាពបរិសុទ្ធ វិន័យ និងបញ្ញា។

ការយល់ដឹងអំពីច្បាប់នៃហេតុនិងផលដែលបានពន្យល់ក្នុងសាសនានេះបានបញ្ជាក់ច្បាស់ និងជួយដោះស្រាយចំណោទនៃទុក្ខរបស់មនុស្សអាចិកំបាំងនៃវាសនា និងការកំណត់វាសនាទុក

ជាមុនហើយជាពិសេសវិសមភាពរបស់មនុស្ស ។ការយល់ពីច្បាប់នេះផ្តល់ដល់មនុស្សនូវការលួងលោមចិត្តសេចក្តីសង្ឃឹមសេចក្តីទុកចិត្តលើខ្លួនឯង និងសេចក្តីក្លាហានប្រកបដោយសីលធម៌ ។

**សាសនាទំនើប** (Modern Religion)

ព្រះពុទ្ធសាសនាមិនមែនជាទ្រឹស្តីមួយឬសាសនាមួយសម្រាប់តែជឿតាមប៉ុណ្ណោះទេ ប៉ុន្តែគឺជាមាគ៌ាជីវិតដ៏ពិតប្រាកដ និងដ៏ប្រសើរ ។ នេះជាសាសនាមានវ័យចំណាស់ជាងគេបំផុត ក្នុងប្រវត្តិសាស្ត្រដែលនាំមកនូវវប្បធម៌ និងការធ្វើឱ្យប្រសើរឡើងផ្តល់ដល់មនុស្សជាតិ ប៉ុន្តែជាសាសនាទំនើបបំផុតគ្រប់ជ្រុងជ្រោយ បើប្រៀបនឹងសមិទ្ធផលទំនើបទាំងឡាយ ។ មានការទូន្មានថា មនុស្សមិនត្រូវធ្វើជាទាសករចំពោះអំណាចខាងក្រៅណាមួយទេ ប៉ុន្តែត្រូវប្រើប្រាស់ការប្រឹងប្រែង និងបញ្ញាផ្ទាល់ខ្លួនដើម្បីដោះស្រាយចំណោទបញ្ហារបស់ខ្លួន ។

ព្រះពុទ្ធសាសនាមានគ្រប់លក្ខណៈជាសាសនាប្រកបដោយវិចារណញ្ញាណមួយ ដែលនឹងសមស្របចំពោះពិភពលោកបច្ចុប្បន្ន និងអនាគត ។ សាសនានេះប្រកបដោយវិចារណញ្ញាណ (សនិទានីយ) ភាពរីកចម្រើនជាលំដាប់និងភាពសមហេតុផល ។ ប្រយោជន៍នឹងកើតមានចំពោះអ្នកដែលសិក្សានិងយល់ដឹង ពីតម្លៃនៃសាសនានេះក្នុងពិភពជឿនលឿន ។ សាសនានេះត្រូវគេទទួលស្គាល់ថា មានលក្ខណៈវិទ្យាសាស្ត្រជាងវិទ្យាសាស្ត្រ និងរីកចម្រើនជាងធាតុរីកចម្រើនទាំងប៉ុន្មាននៅក្នុងវិស័យផ្លូវចិត្ត ។ សាសនានេះជាមធ្យោបាយមានប្រសិទ្ធភាពបំផុត ដែលត្រូវប្រើដើម្បីថែទាំពិភពសន្តិភាព សុខដុម និងពិភពនៃការយល់គ្នា ។

**គ្មានការរើសអើង** (No Discrimination)

ជាដំបូងបង្អស់ក្នុងប្រវត្តិសាស្ត្រពិភពលោក ព្រះពុទ្ធសាសនាជាសាសនាដែលប្រឆាំង នឹងប្រព័ន្ធវណ្ណៈដ៏អាប់ឱន ហើយបង្រៀនពីសមភាពរបស់មនុស្សជាតិ ដែលអាស្រ័យនឹងសមភាពឱកាសសម្រាប់ទាំងអស់គ្នាក្នុងការស្គាល់ខ្លួនគេនៅគ្រប់ជំហាននៃជីវិត ។ នេះក៏ជាសាសនាដែលផ្តល់សេរីភាពមុនគេចំពោះស្ត្រី ដោយលើកទឹកចិត្តគេឱ្យសិក្សា និងប្រតិបត្តិសាសនាដែលផ្តល់មកនូវសមភាពសង្គម ។

ព្រះបរមគ្រូប្រកាសថា "*ទ្វារទៅកាន់ជោគជ័យនិងវិបុលភាពបានបើកចំហរសម្រាប់ទាំងអស់គ្នាចំពោះរាល់ស្ថានភាពនៃជីវិត ទោះខ្ពស់ឬទាប សន្តបុគ្គលឬឧក្រិដ្ឋជន ដែលយកចិត្តទុកដាក់ស្វែងរក និងប្រាថ្នាសុក្រឹតភាព ។ ព្រះពុទ្ធមិនបានបង្ខិតបង្ខំឱ្យអ្នកដើរតាមព្រះអង្គធ្វើជា*

*ទាសកររបស់ព្រះអង្គឬការប្រៀនប្រដៅរបស់ព្រះអង្គឡើយ ប៉ុន្តែលោកប្រទានដល់ពួកគេនូវសេរីភាពនៃគំនិត និងការពិនិត្យពិច័យដើម្បីឱ្យគេមានទំនុកចិត្តលើខ្លួនគេ"* ។

សាសនានេះក៏បង្រៀនយើងផងដែរថា រាល់សមាសធាតុត្រូវតែ ប្រែប្រួលហើយមានទំនាស់ដោយយោលទៅតាមលក្ខខណ្ឌលោកិយ ឬច្បាប់សកល ។

គោលការណ៍សង្កេតដោយសាសនានេះមិនមែនជាសេចក្តីបង្គាប់បញ្ជាទេ ។ ដោយសង្កេតទៅលើសិក្ខាបទមានដូចជាការជៀសវាងការសម្លាប់ការលួចការប្រព្រឹត្តខុសក្នុងកាមការនិយាយកុហកនិងការសេពគ្រឿងស្រវឹង អ្នកដែលដើរតាមទាំងឡាយអាចធ្វើខ្លួនឱ្យបរិសុទ្ធហើយបង្កលក្ខណៈឱ្យអ្នកដទៃរស់នៅដោយសុខសន្តិភាព ។

**គោលបំណងរបស់យើង** (Our Aim)

គោលបំណងរបស់យើងក្នុងការផ្សាយសៀវភៅនេះ មិនមែនញុំាងឱ្យអ្នកដទៃប្តូរជំនឿរបស់ខ្លួនមកយកជំនឿរបស់យើងទេ ប៉ុន្តែយើងចង់បំភ្លឺដល់ពួកគេអំពីវិធីស្វែងរកសន្តិភាព និងសុភមង្គល ហើយប្រតិបត្តិជំនឿសាសនារបស់គេផ្ទាល់ដោយមិនពឹងផ្អែកលើជំនឿបែបងងឹតងងុល ។ យើងលើកទឹកចិត្តឱ្យមនុស្សគ្រប់រូបប្រតិបត្តិសាសនារបស់គេផ្ទាល់ដោយត្រឹមត្រូវ ប្រសិនបើគេអាចស្វែងរកឃើញសច្ចភាព សន្តិភាព សុភមង្គល បញ្ញា និងការសង្គ្រោះក្នុងសាសនានោះយ៉ាងពិតប្រាកដ ។ អ្វីដែលយើងចង់បានគឺការរស់នៅតាមគន្លងសាសនាដ៏គួរគោរពរបស់មនុស្សដោយមិនរំលោភលើសេចក្តីថ្លៃថ្នូរ ជាមនុស្សរបស់ខ្លួន ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ព្រះពុទ្ធសាសនាអាចជាចម្លើយ ចំពោះចំណោទបញ្ហាខាងសាសនា ចំណោទបញ្ហាខាងផ្លូវចិត្ត និងចំណោទបញ្ហារបស់មនុស្ស ឬក៏អាចផ្តល់ទិសដៅថ្មីដល់ការគិតរបស់អ្នកលើបញ្ហាសាសនា និងបញ្ហាទស្សនវិជ្ជាបាន ។ សាសនានេះក៏អាចជួយអ្នកផងដែរឱ្យយល់ពីវិធីនៃជីវិត និងមតិកវប្បធម៌របស់អាស៊ី ។ ក្នុងសាសនានេះ អ្នកអាចរកឃើញផងដែរ នូវការគ្រប់គ្រងចិត្តដែលពិភពលោកសម័យទំនើបត្រូវការ ។

សាសនានេះនាំមកឱ្យពិភពលោកនូវស្មារតីថ្មី សេចក្តីសង្ឃឹមថ្មី មាគ៌ាថ្មី សេចក្តីពិត ហើយនិងភាពចាំបាច់នៃអ្វីមួយដែលត្រូវបានមើលឃើញ និងដឹងឮសព្វថ្ងៃថាវាចាស់ ។ សាសនាដ៏ឧត្តុង្គឧត្តម ដែលយើងបានលើកមកនិយាយនោះគឺ *"ព្រះពុទ្ធសាសនា"* ហើយអ្នកបង្កើតសាសនានេះគ្មាននរណាក្រៅពី *"ព្រះពុទ្ធសមណគោត្តម "*ឡើយ ។

ទោះបីអ្នកមានគោលបំណងអ្វីក៏ដោយ  យើងសូមអញ្ជើញលោក-អ្នកខិតចូលទៅសម្លឹងមើលសាសនានេះនិងឧត្តមគតិនៃអ្នកបង្កើត ។យើងត្រៀមខ្លួននឹងជួយលោក-អ្នកក្នុងការស្រាវជ្រាវរបស់លោក-អ្នកដើម្បីការពិត ។ ដូច្នេះ ហើយសូមកុំមានចិត្តលំអៀង សូមជៀសវាងការធ្វើបុរេវិនិច្ឆ័យសាសនាសូមស្វែងរកការពិត ។

## ២.ពុទ្ធឱវាទគ្មានទីបញ្ចប់? (The Timeless Message?) By Ven. Piyadassi Thera

អ្នកខ្លះចូលចិត្តហៅ *ការប្រៀនប្រដៅ* របស់ព្រះពុទ្ធថាជា *សាសនាមួយ* ឯអ្នកខ្លះទៀតចូលចិត្តហៅការប្រៀនប្រដៅនេះថាជា *ទស្សនវិជ្ជា* ទៅវិញឯអ្នកមួយចំនួនទៀតចូលចិត្តហៅថាទាំង *សាសនា* និង*ទស្សនវិជ្ជា*។ ប៉ុន្តែទោះ ជាយ៉ាងណាក៏ដោយបើហៅឱ្យបាន ត្រឹមត្រូវជាងគេវិញនោះគឺត្រូវហៅថា *មាគ៌ាជីវិត* (Way of Life) ។ ប៉ុន្តែការហៅបែបនេះមិនមានន័យថា *ព្រះពុទ្ធសាសនា* (Buddhism) គ្មានអ្វីក្រៅពី *ច្បាប់សីលធម៌* នោះទេ ។ មើលឱ្យវែងឆ្ងាយទៅ *ពាក្យប្រៀនប្រដៅ* នេះគឺជា*មាគ៌ាអប់រំសីលធម៌ផ្លូវចិត្ត* និង *បញ្ញា* ដែលដឹកនាំទៅរក *សេរីភាពស្មារតី* (freedom of mind) ដោយបរិបូរ ។ *ព្រះពុទ្ធ* ទ្រង់ហៅ *ពាក្យប្រៀនប្រដៅ* របស់ព្រះអង្គនេះថា ‘*Dhamma-vinaya*’ ជា*លទ្ធិ* (the Doctrine) ហើយនិង *វិន័យ* (the Discipline) ។ ប៉ុន្តែការដែលហៅ *ព្រះពុទ្ធសាសនា* នេះបើនិយាយ ឱ្យចំមែនទែនទៅមិនអាចហៅថាជា *សាសនា មួយ* បានទេពីព្រោះប្រសិនបើតាមរយៈ*សាសនា* ត្រូវមានន័យថា*អំពើ* (action) ឬ*ឥរិយាបថ* (conduct) ដែលចង្អុលបង្ហាញពី *ជំនឿ* (belief in) *ការពឹងផ្អែក* (reverence for) ហើយ និង *តម្រូវ ការ*ដើម្បីផ្គាប់ចិត្តពោលគឺ *អាទិទេពមួយអង្គ* (a divine) ដែលគ្រប់គ្រង*អំណាច* អត្ថិភាព ឬការប្រារព្ធធ្វើពិធីរីត៍ (rites) ឬបុណ្យសាសនានានាដែល បញ្ជាក់ពីនេះ...មានការទទួលស្គាល់ទៅលើផ្អែករបស់មនុស្សចំពោះអំណាចអាថ៌កំបាំងខ្ពស់ៗមួយចំនួនដែលជាការត្រួតត្រាលើវាសនារបស់គេ ហើយដែលគេតម្រូវឱ្យមានការគោរពតាម ពឹងផ្អែកលើហើយនិងគោរពបូជា ។ ឯចំណែក *ព្រះពុទ្ធសាសនា* តាមពិតទៅមិនមែនជា *សាសនា* បែបនេះទេ ។

នៅក្នុង*គំនិតព្រះពុទ្ធសាសនា* មិនមានការយល់ដឹងឬជឿជាក់ទៅលើ*អត្ថិភាព* របស់*ព្រះជាម្ចាស់* (Creator) ទៅតាមទម្រង់ណាមួយដែលផ្តល់រង្វាន់ និងដាក់ទណ្ឌកម្មទៅលើ*អំពើល្អ* ឬ*អំពើអាក្រក់*របស់ *សត្វលោក* ដែលបានបង្កើតនោះឡើយ ។ *ពុទ្ធសាសនិកជន* សូមជ្រកក្រោមម្លប់ *ព្រះពុទ្ធ* (*ពុទ្ធំ សរណំ គច្ឆាមិ Buddham saranam gacchami*) ប៉ុន្តែមិនមែននៅក្នុងសេចក្តី

សង្ឃឹមថា *ព្រះពុទ្ធ* ទ្រង់ចាំជួយពួកគេនោះទេ។*ព្រះពុទ្ធ* ទ្រង់គ្រាន់តែជា *ព្រះបរមគ្រូមួយអង្គ* ប៉ុណ្ណោះដែលចង្អុលបង្ហាញពី *មាគ៌ា* និងដឹកនាំ *បរិស័ទ* ទៅរក *ទីរំដោះបុគ្គល* របស់ពួកគេ។

*ក្តារសញ្ញា* (a sign-board) បង្ហាញប្រាប់ផ្លូវនៅត្រង់កន្លែងចែកផ្លូវ ជាឧបមាវាចង្អុលប្រាប់ពី*ទិសដៅ* ដែលត្រូវទៅហើយវាទុកឱ្យ *អ្នកដំណើរ* ដើរទៅតាមផ្លូវដោយប្រុងប្រយ័ត្ន។ តាមពិតទៅ*ក្តារសញ្ញានេះ* មិនបាននាំ*អ្នកដំណើរ* នោះទៅដល់គោលដៅចង់បានរបស់គាត់នោះទេ។

*វេជ្ជបណ្ឌិតម្នាក់* ធ្វើរោគវិនិច្ឆ័យទៅលើ *ជម្ងឺ* ហើយនិងចេញវេជ្ជបញ្ជាវាទុកឱ្យ *អ្នកជម្ងឺនោះធ្វើតែស្តទៅលើវេជ្ជបញ្ជា* នោះ។ ឯតិរិយាបថរបស់ *ព្រះពុទ្ធ* ចំពោះ *បរិស័ទ* របស់ព្រះអង្គក៏មានលក្ខណៈដូចគ្រូ ឬគ្រូពេទ្យនោះដែរ។

ការគោរពបូជាដ៏ខ្ពង់ខ្ពស់បំផុតគឺ ជាការគោរពបូជា ដែលធ្វើឡើងចំពោះភាពដ៏ប្រសើរបំផុតរបស់*មនុស្សនានា* ពោលគឺ *ទឹកចិត្តក្លាហាន* និង*ដ៏អស្ចារ្យ* ទាំងនោះដែលមានមកជាប់ជាមួយនូវ*ការយល់ដឹងចាក់ទម្លាយ* និងទូលំទូលាយចំពោះ*តថភាព* កម្ចាត់បង់*អវិជ្ជា និងភាពសៅហ្មង* នានា។ មនុស្សទាំងឡាយដែលមើលឃើញពី*សច្ចភាព* នោះទើបជា*អ្នកជួយពិត* ប៉ុន្តែ*ពុទ្ធសាសនិកជន* មិនបានយកចិត្តទុកដាក់ចំពោះវាទេ។ ពួកគេគ្រាន់តែយកចិត្តទុកដាក់ចំពោះអ្នកបង្ហាញឱ្យឃើញពី*សច្ចភាព* ដែលចង្អុលបង្ហាញឱ្យឃើញពី*មាគ៌ា* ទៅរក*សុភមង្គល* និង*ការជួយសង្គ្រោះពិតប្រាកដ*។ *សុភមង្គល* គឺជាអ្វីដែលគេត្រូវតែសម្រេចឱ្យបានដោយខ្លួនគេគ្មានអ្នកណាម្នាក់ក្រៅពីខ្លួនគេអាចធ្វើឱ្យកាន់តែប្រសើរឬកាន់តែអាក្រក់នោះទេ។"*ភាពបរិសុទ្ធ* និង*ភាពមិនបរិសុទ្ធ*ពឹងផ្អែកទៅលើ*ខ្លួនឯង*"។ គេមិនអាចធ្វើឱ្យអ្នកណាម្នាក់ល្អបរិសុទ្ធឬមិនបរិសុទ្ធនោះបានឡើយ។

**ការស្វែងរកសច្ចភាព** (In Search of Truth)

នៅពេលទ្រង់ទម្រេតទៅលើ *ព្រះទែនបន្ទំបរិនិព្វាន* (death-bed) នៅចន្លោះដើមរាំងភ្នំ (Sala tree) ពីរដើមនៅ*កុសិនគរ* ឬ *កុសិនារា*(Kusinara) *ព្រះពុទ្ធ* ក្នុងព្រះជន្ម៨០ វស្សាទតឃើញផ្កាដែលគេបានថ្វាយព្រះអង្គៗទ្រង់ត្រាស់ ទៅកាន់ព្រះអានន្ទដូច្នេះថា "ម្នាលអានន្ទអ្នកទាំងឡាយណាដែលបរិបូណ៌ដោយភាពត្រឹមត្រូវនៅក្នុងជីវិត រស់នៅដោយអាស្រ័យនឹង *ព្រះធម៌* គឺជាអ្នកដែលមានកិត្តិយស មានការគោរពបូជាដោយត្រឹមត្រូវ ហើយធ្វើសក្ការៈចំពោះតថាគត [ជាអ្នកសុក្រឹតមួយអង្គ (the Perfect One)]"ដែលមានអភិវន្ទនាការដ៏មានតម្លៃបំផុត (worthiest homage) ។ដូច្នេះម្នាលអានន្ទអ្នកគួរបរិបូរដោយភាពត្រឹមត្រូវនៅក្នុងជីវិតរស់នៅដោយអាស្រ័យ

នឹង *ព្រះធម៌* នេះឯង។ ដូចនេះអ្នកគួរតែហ្វឹកហាត់ខ្លួនអ្នក"។ ការលើកទឹកចិត្តរបស់ព្រះពុទ្ធទៅលើ *ការរស់នៅ* ដោយអាស្រ័យនឹង *ព្រះធម៌* បានបង្ហាញយ៉ាងច្បាស់ថា អ្វីដែលមានសារៈសំខាន់ខ្ពស់បំផុតនោះគឺ *ការអប់រំឥរិយាបថកាយ វាចារ* និង *ចិត្ត* មិនមែនគ្រាន់តែជាការថ្វាយផ្កាដល់ *អ្នកដែលបានត្រាស់ដឹងនោះ*ទេ។ សេចក្តីសង្កត់ធ្ងន់របស់ទ្រង់ គឺស្ថិតនៅត្រង់ថាការធ្វើឱ្យ *ជីវិតរស់នៅ* ប្រកបដោយ *ភាពត្រឹមត្រូវ* នេះឯង។

ឯចំពោះពាក្យថា *ព្រះពុទ្ធសាសនា* គឺជា *ទស្សនវិជ្ជានោះ* គឺវាពឹងផ្អែកទៅលើ *និយមន័យ* របស់ *ពាក្យ* ហើយនិងថា តើពាក្យនេះអាចមានលទ្ធភាពនឹងផ្តល់និយមន័យមួយ ដែលនឹងគ្របដណ្តប់លើ *ប្រព័ន្ធគំនិតទស្សនវិជ្ជាដែល មានអត្ថិភាពទាំងអស់* ដែលកំពុងតែមានមន្ទិលសង្ស័យនោះបានដែរឬទេ។ ខ្លឹមសារដើមរបស់ *ទស្សនវិជ្ជា* មានន័យថា *ស្នេហា* ឬ *ស្រឡាញ់* (ក្រិកថា Philein) ហើយពាក្យថា *គតិបណ្ឌិត* (sophia)។ *"ទស្សនវិជ្ជាមានលក្ខណៈទាំងពីរទាំងការស្វែងរកគតិបណ្ឌិតហើយ និងទាំងគតិបណ្ឌិតដែលគេបានស្វែងរក"*។ នៅក្នុងគំនិតរបស់ជនជាតិឥណ្ឌា *ទស្សនវិជ្ជា* ត្រូវបានគេឱ្យឈ្មោះថា darsana មានន័យថា *ការមើលឃើញពីសច្ចភាព* (vision of truth)។ ជារួមគោលបំណងរបស់ *ទស្សនវិជ្ជា* គឺត្រូវស្វែង *សច្ចភាពខ្ពស់បំផុត* (the ultimate truth)។

*ព្រះពុទ្ធសាសនា* ក៏គាំទ្រដល់ *ការស្វែងរកសច្ចភាព* នេះផងដែរ។ ប៉ុន្តែវាមិនមែនគ្រាន់តែជាការបង្ហាញហេតុផលស្មានៗជារចនាសម្ព័ន្ធទ្រឹស្តីមួយគ្រាន់តែជាការទទួលបាន និងផ្ទុកចំណេះដឹងមួយនោះទេ។ *ព្រះពុទ្ធ* ទ្រង់បានបញ្ជាក់ពីទិដ្ឋភាពប្រតិបត្តិ *ការប្រៀនប្រដៅ* របស់ទ្រង់ការអនុវត្តនី *ចំណេះដឹង* ចំពោះ *ជីវិត* ដោយសម្លឹងមើលទៅលើ *ជីវិត* ហើយមិនត្រឹមតែសម្លឹងមើលចំពោះវានោះប៉ុណ្ណោះទេ។

ចំពោះ *ព្រះពុទ្ធ* ពាក្យប្រៀនប្រដៅទាំងស្រុងគ្រាន់តែជាការយល់ដឹងអំពី *ធម្មជាតិទោមនស្ស* នៃគ្រប់ *អត្ថិភាពបាតុភូត* ទាំងអស់ហើយនិងការអប់រំអំពី *មាគ៌ា* ដែលនាំឱ្យជៀសផុតពី *ភាពទោមនស្ស* ទាំងនេះប៉ុណ្ណោះ។ នេះគឺជា *"ទស្សនវិជ្ជា"* របស់ព្រះអង្គ។

នៅក្នុង *គតិបណ្ឌិត ឬបញ្ញាព្រះពុទ្ធសាសនា* គឺមានសារៈសំខាន់ខ្ពស់បំផុត ព្រោះ *ចិត្តបរិសុទ្ធ* (purification) មកតាមរយៈ *បញ្ញា* តាមរយៈការយល់ដឹងនេះឯង។ ប៉ុន្តែ *ព្រះពុទ្ធ* មិនដែលសរសើរត្រឹមតែ *បញ្ញា* នេះប៉ុណ្ណោះទេ។ បើតាមព្រះអង្គ *ចំណេះដឹង* ត្រូវប្រព្រឹត្តទៅស្របជាមួយនឹង *ចិត្តបរិសុទ្ធ* ជាមួយ នឹង *សីលឧត្តមភាព* (*vijjacarana-sampanna*)។ បញ្ញាដែលទទួលបានមកតាមរយៈ *ការយល់ដឹង* ហើយនិងការអភិវឌ្ឍន៏ *គុណភាពស្មារតី* និង *ចិត្ត* (qualities of

mind) គឺជា *បញ្ញា* ស្មើនឹង *ឧត្តមភាព* (*bhavanamaya panna*) ។ វាជួយដល់ *ចំណេះដឹង* មិនត្រឹមតែ *ការប៉ាន់ស្មាន* (speculation) *តក្កវិជ្ជា* ឬ *ការពិចារណា* ដោយកំបាំងភ្នែកនោះប៉ុណ្ណោះទេ ។ ដូច្នេះ វាបញ្ជាក់ច្បាស់ថា *ព្រះពុទ្ធសាសនា* មិនមែនទាំងពីរ *សេចក្តីស្នេហា*ក៏មិនមែនការទាក់យក *ការស្វែងរក* បន្ទាប់ពី *គតិបណ្ឌិត* ក៏មិនមែន ឬ *ជំនឿស៊ុប* (បើទោះជាវាមានសារៈសំខាន់ និងគាំទ្រដល់មនុស្សក៏ដោយ)ប៉ុន្តែការលើកទឹកចិត្តចំពោះការប្រតិបត្តិអំពី *ពាក្យទូន្មាន* ដែលដឹកនាំសាវ័កទៅរក *ភាពអស់កង្វល់ការត្រាស់ដឹង* និង *ការជួយសង្គ្រោះ* ចុងក្រោយ ។

*"អ្វីក៏ដោយសុទ្ធតែមានដំណើរមកពីហេតុ ? តថាគត* (the Tathagata) *បានពន្យល់អំពីហេតុហើយទ្រង់ក៏បានពន្យល់អំពីទីរលត់របស់វាផងដែរនេះគឺជាពាក្យប្រៀនប្រដៅរបស់លោកអ្នកប្រាជ្ញដ៏ខ្ពង់ខ្ពស់ ។"*

Upatissa យល់ពីខ្លឹមសារកំណាព្យនេះភ្លាម ហើយក៏ទទួលបាននូវដំណាក់កាលយល់ដឹងដំបូងដោយយល់ថា *"អ្វីក៏ដោយសុទ្ធតែធម្មជាតិតាក់តែងឱ្យកើតឡើង ហើយអ្វីទាំងអស់នោះក៏សុទ្ធតែធម្មជាតិមានទីបញ្ចប់វិញដែរ "* ។

**ព្រះបរមគ្រូប្រតិបត្តិ** (The Practical Teacher)

គ្មានការជជែកនិងពិភាក្សារួមណាដែលមិនបាននាំទៅរក *ការយល់ដឹងត្រឹមត្រូវ* នឹងដឹកនាំយើងទៅរកទីសង្គ្រោះនោះទេ ។ អ្វីដែលគេត្រូវការនោះគឺ *ការបង្រៀន* និង *ការយល់ត្រឹមត្រូវ*។ យើងអាចទាញយក *ការបង្រៀនត្រឹមត្រូវ* ចេញមកពី *ធម្មជាតិ* មកពី *ដើមឈើ* និង *ផ្កា* មកពី *ថ្ម* និង *ស្មឹង* បាន ។ មានការឧបមាជាច្រើនដែលមនុស្ស ទទួលបាននូវ *ការត្រាស់ដឹង* និងរំដោះខ្លួន ចេញផុតពី *គ្រឿងសៅហ្មង* (taints) ដោយគ្រាន់តែសម្លឹងមើលទៅ *ស្លឹកឈើ* ឬ *ទឹកធ្លាក់ ភ្លើង ព្រៃ ការផ្ទុះអំពូល* ប៉ុណ្ណោះ ។ រឿងនេះបានធ្វើឱ្យគេចាប់អារម្មណ៍ទៅលើវា ហើយការយល់ដឹងពី *ធម្មជាតិវត្តមិនទៀងទាត់* ពួកគេទទួលបាននូវការសង្គ្រោះ ។ ជាការពិតហើយ *ផ្កាឈូក* រង់ចាំ *ពន្លឺព្រះអាទិត្យ* ហើយមិនយូរប៉ុន្មាន *ព្រះអាទិត្យ* ក៏រះឡើងហើយបន្ទាប់មក *ផ្កាឈូក* ចាយឡើងហើយនាំយក *ក្លិន* (delight) ទៅគ្រប់អ្វីៗទាំងអស់ ។

*ព្រះពុទ្ធ* មិនខ្វល់នឹង *បញ្ហាអស្លិរូបវិជ្ជានានា* ដែលគ្រាន់តែធ្វើឱ្យ *មនុស្ស* យល់ច្រឡំហើយធ្វើឱ្យ *ចិត្ត* លែងមានលំនឹងអស់ប៉ុណ្ណោះ ។ ដំណោះស្រាយបញ្ហាទាំងនេះនឹងមិនធ្វើឱ្យ *មនុស្ស* គេចផុតពី *ទុក្ខវេទនា* ដោយស្រួលនោះឡើយ ។ នេះគឺជាហេតុដែល *ព្រះពុទ្ធ* រារែកនឹងឆ្លើយសំណួរបែបនេះ ហើយជាច្រើនដងទ្រង់បានទប់មិនពន្យល់បញ្ហាទាំងឡាយ ដែលតែងតែកើត

ឡើងខុសទំនង។ *ព្រះពុទ្ធ* គឺជា *គ្រូប្រតិបត្តិមួយ*។ គោលបំណងតែមួយរបស់ព្រះអង្គគឺត្រូវបក ស្រាយពន្យល់ឱ្យបានលំអិតអំពី *បញ្ហាទុក្ខ* (*dukkha*) *ការពិតសាកល*នៃ *ជីវិត* ដើម្បីឱ្យមនុស្ស ទាំងឡាយមានអារម្មណ៍រឹងមាំពេញបរិបូណ៌ហើយនិងដើម្បីជឿជាក់លើវា។ ព្រះអង្គបានត្រាស់ បង្គាប់ប្រាប់យើងដោយច្បាស់លាស់ពីអ្វី ដែលទ្រង់ពន្យល់ហើយនិងអ្វីដែលទ្រង់ពន្យល់។

មានពេលមួយនោះ *ព្រះពុទ្ធ*កំពុងតែគង់ប្រថាប់នៅ *កុសម្ពី* (Kosambi)(នៅជិត Allahabad) នៅក្នុងចំការ simsapa។ នៅពេលនោះទ្រង់បានបេះស្លឹកឈើពីរបីសន្លឹកនៅនឹង ព្រះហស្តទ្រង់ ព្រះពុទ្ធទ្រង់មានពុទ្ធដិកាទៅកាន់ *សង្ឃទាំងឡាយ* ថា ÷

ម្នាលសង្ឃទាំងឡាយ តើអ្នកគិតយ៉ាងដូចម្តេច អ្វីដែលមានទំហំធំធេងខាងបរិមាណ

*ស្លឹក* simsapa មួយក្តាប់ ដែលតថាគតបានបេះមកនេះ ឬតើមានអ្វីខ្លះនៅក្នុងព្រៃ ?

-មិនមានច្រើនទេ មានបន្តិចបន្តួចព្រះគុណម្ចាស់ គឺជាស្លឹកនៅក្នុងព្រះហស្តដែលព្រះគុណម្ចាស់ បានបេះមកឯស្លឹក ដែលមានច្រើនគឺស្លឹកនៅក្នុងព្រៃ ។

-ពិតដូច្នេះហើយម្នាលសង្ឃទាំងឡាយមានវត្ថុជាច្រើនគឺជាវត្ថុដែលតថគតបានយល់ច្បាស់ដោយ បរិបូណ៌ប៉ុន្តែ *តថាគត* នៅមិនទាន់បានបង្រៀនអ្នកហើយវត្ថុតិចតួចបំផុត ដែល*តថាគត*បាន ប្រៀនប្រដៅ ចុះហេតុអ្វីម្នាលសង្ឃទាំងអស់បានជាតថាគតមិនប្រាប់អ្នកឱ្យដឹង ? តាមពិតទៅ វត្ថុទាំងអស់នោះមិនមានប្រយោជន៍មិនសំខាន់ចំពោះ *ជីវិតបរិសុទ្ធ* នោះទេ វាមិននាំទៅរកការ ស្អប់ខ្ពើមភាពគ្មានកង្វល់ (dispassion) ការរំលត់ភាពស្ងប់ស្ងាត់ទៅរកការយល់ពេញលេញ ការ ត្រាស់ដឹងឬទៅរកនិព្វាននោះទេ។ នោះគឺជាហេតុដែលតថាគតមិនបង្រៀនអំពីវា ។

-ចុះមានអ្វីទៅដែលតថាគតត្រូវបង្រៀននោះ ? នោះគឺទុក្ខដែលតថាគតត្រូវបង្រៀន។ នេះគឺ ជាការកើតឡើងនៃសេចក្តីទុក្ខដោយហេតុតែវាមានទើបតថាគតបង្រៀន។ នេះគឺជាមាគ៌ាដែល នាំទៅរកការរំលត់ទុក្ខដោយហេតុតែវាមានទើបតថាគតបង្រៀន។

-ចុះហេតុអ្វីបានជាតថាគតត្រូវបង្រៀនពីសច្ចភាពទាំងនេះ ? តាមពិតវាមានប្រយោជន៍វាមាន លក្ខណៈចាំបាច់ចំពោះ *ជីវិតបរិសុទ្ធ* វានាំទៅរកការស្អប់ខ្ពើមភាពគ្មានកង្វល់ (dispassion) ការ រំលត់ភាពស្ងប់ស្ងាត់ ទៅរកការយល់ពេញលេញ ការត្រាស់ដឹងឬទៅរកនិព្វាននោះបាន។ នោះគឺ ជាហេតុដែលតថាគតបង្រៀនអំពីវា។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ *អ្នកប្រាជ្ញ* មួយចំនួនមិនបានវាយតម្លៃឥរិយាបថរបស់ព្រះ បរមគ្រូរូបនេះទេពួកគេមានមន្ទិលសង្ស័យចំពោះ *ការត្រាស់ដឹង* របស់គេហើយដាក់ឈ្មោះឱ្យ

ព្រះអង្គថា *អទេវវិទូ* (an agnostic)។ អ្នកប្រាជ្ញទាំងនោះធ្លាប់ប្រឆាំងនិងគិតមកហើយ។ នេះមិនមែនជាបញ្ហាថ្ងៃនេះ ឬក៏ថ្ងៃស្អែកនោះដែរ ពោលគឺពួកគេបានលើក ឡើងតាំងពីសម័យព្រះពុទ្ធមកម៉្លេះ។ សូម្បីតែ Sakuludayi ជាអ្នកវង្វេងផ្លូវម្នាក់ (wanderer) ជាឧបមាបានសួរអំពី *អតីតកាល* និង *អនាគត* ហើយ *ព្រះពុទ្ធ* ទ្រង់បានផ្តល់ឱវាទដោយមានលក្ខណៈជាប្រភេទស័ព្ទថា :

អំពី *អតីតកាល* អំពី *អនាគត តថាគត* នឹងប្រៀនប្រដៅអ្នកនូវ *ព្រះធម៌* ដែលមានខ្លឹមសារដូចតទៅ :

បើ *នេះមាននោះក៏មាន* បើ *នេះកើតឡើងនោះក៏កើតឡើង* ដែរបើ *នេះគ្មាននោះក៏គ្មាន* ដែរបើ *នេះរលត់នោះក៏រលត់* ដែរ។

សេចក្តីជាសង្ខេបនេះគឺជា *លទ្ធិ* របស់ *ព្រះពុទ្ធ* អំពី *លក្ខខណ្ឌ* (conditionality) ឬ *ការកើតឡើងអាស្រ័យនឹងគ្នា* (Dependent arising) ឬហៅជាភាសាបាលីថា *បដិច្ចសមុប្បាទ* (paticca samuppada)។ ហើយទ្រឹស្តីនេះបង្កើតរូបរាងជាមូលដ្ឋានគ្រឹះអំពី *អរិយសច្ចៈបួន* ពោលគឺជាការយល់ដឹងស្នូលរបស់ *ព្រះពុទ្ធសាសនា*។

**វេជ្ជបណ្ឌិតដ៏ប្រសើរបំផុត** (The Peerless Doctor)

គេបានដឹងថា *ព្រះពុទ្ធ* គឺជា *គ្រូពេទ្យដ៏ប្រសើរបំផុត* (bhisakko) ពោលគឺជា *សល្យពេទ្យកំពូល* *(the supreme surgeon/sallakatto anuttaro)*។ តាមពិតព្រះអង្គគឺជា *អ្នកផ្សះជម្ងឺដ៏ខ្ពស់បំផុតមួយអង្គ*។ *វិធី* នៃការពន្យល់អំពី *អរិយសច្ចៈបួន* អាចប្រៀបប្រដូចទៅនឹង *វិធី* របស់ *គ្រូពេទ្យ* បាន។ ក្នុងឋានៈជា *គ្រូពេទ្យម្នាក់* ជាដំបូងព្រះអង្គធ្វើរោគវិនិច្ឆ័យទៅលើ *ជម្ងឺ* បន្ទាប់មកទ្រង់បានស្រាវជ្រាវរកហេតុនៃ *ជម្ងឺ* នោះរួចក៏ទ្រង់គិតពិចារណាទៅលើវិធីព្យាបាលវាជាចុងក្រោយដាក់ថ្នាំព្យាបាល ។

*ទុក្ខ* *(dukkha)* គឺជា *ជម្ងឺ* *តណ្ហា* *(tanha)* គឺជា *កំណើត* ឬជា *ឫសគល់* ដែលបណ្តាលឱ្យមាន *ជម្ងឺ* *(samu-daya)*។ តាមរយៈការបំបាត់ *តណ្ហា ជម្ងឺ* ត្រូវបានព្យាបាលហើយដែលជា *ការព្យាបាល* *(nirodha = nibbana)*។ *មគ្គទាំង៨* *(magga)* គឺជា *ឱសថ*។

អ្នកជម្ងឺត្រូវដឹងពីជម្ងឺ របស់ខ្លួនគាត់គួរកត់សម្គាល់ពីវាក្រែងលោវាមាន ជម្ងឺកើតឡើងបន្ទាប់មកគាត់គួរគិតពីវិធីកម្ចាត់ *ហេតុ* របស់វាជាមួយនឹងគោលបំណងនេះ បើតាមគិតគាត់ត្រូវទៅជួប *លោកគ្រូពេទ្យ* ដើម្បីធ្វើរោគវិនិច្ឆ័យ និងចេញ *វេជ្ជបញ្ជា* ទិញថ្នាំ។ តាមរយៈប្រសិទ្ធភាពថ្នាំ *អ្នកជម្ងឺ* បានជាសះស្បើយពី *ជម្ងឺ*។ នេះគឺជាការព្យាបាលរោគ។ ដូច្នេះ *ទុក្ខ* មិនមែនគេ

មិនដឹងនោះទេ ប៉ុន្តែគេត្រូវដឹង (*abhinneyya*) ពីវា ពីព្រោះវាជា*ជម្ងឺបន្ទាន់* ។ *តណ្ហា* ដែលជា*ហេតុបណ្តាល* គេត្រូវព្យាបាល ឬកម្ចាត់វាចោល គេត្រូវប្រតិបត្តិតាម *អដ្ឋង្គិកមគ្គ* គេត្រូវអប់រំ (*bhavetabba*) ព្រោះវាគឺជា*ឱសថ*។ ជាមួយនឹងការយល់ដឹងពី *ទុក្ខ* ជាមួយ នឹងការកម្ចាត់ *តណ្ហា* តាមរយៈការប្រតិបត្តិតាម *មគ្គទាំង៨* ភាពពិតអំពី*និព្វាន* ត្រូវបានគេយល់ច្បាស់។ វាគឺជា*ការព្យាបាល ការរំលត់ពេញបរិបូណ៌ ការរួចផុត* ពី *តណ្ហា* ។

*ព្រះពុទ្ធ* ទ្រង់ដោះស្រាយចម្ងល់ Sela ជា *ព្រាហ្មណ៏ម្នាក់* (the brahmin) ដែលមានមន្ទិលចំពោះ*ការត្រាស់ដឹង* របស់ *ព្រះបរមគ្រូ* មានសារៈសំខាន់ថា "*តថាគត*ដឹងពីអ្វីដែលគេគួរដឹងអ្វីដែលគេគួអប់រំដែល*តថាគត*បានអប់រំអ្វីដែលគេគួរកម្ចាត់ចោលដែល*តថាគត* បានកម្ចាត់ហើយដូចនេះ*ម្នាលព្រាហ្មណ៏ តថាគត* គឺជា*ព្រះពុទ្ធ* ជា*អ្នកដឹងខ្លួនមួយរូប* (the Awakened One) "។

ចំពោះ *សច្ចភាព* ទាំងនេះមានលក្ខណៈប្រទាក់ប្រទងគ្នាហើយអាស្រ័យគ្នាជាដរាប ការមើលឃើញពីសច្ចភាពមួយឬច្រើនក្នុងចំណោម សច្ចភាពទាំង៤ក៏ដូចបញ្ជាក់ឱ្យឃើញពីសច្ចភាពដទៃទៀតដែរ។ ចំពោះអ្នកដែលបដិសេធសេចក្តីទុក្ខ មាគ៌ា ការប្រតិបត្តិតាម ដែលគេទទួលបាននូវការរំដោះរួចផុតពីទុក្ខនោះគឺជាការឥតន័យមួយ។ និយាយដោយខ្លីការបដិសេធន៏ចំពោះសច្ចភាពទោលមួយក៏ដូចជាការបដិសេធន៏ សច្ចភាពបីទៀតដែរ ហើយក៏ដូចជាបដិសេធ ពាក្យទូន្មានទាំងស្រុងរបស់ព្រះពុទ្ធដែរ។

ចំពោះ*អ្នកសម្ភារៈនិយមពិតម្នាក់* ដែលនិយាយថា "ខ្ញុំមិនចង់ជឿលើ*រឿងមិនសមហេតុផលនេះ* ទេ" *ការប្រៀនប្រដៅនេះ*មានល្ខណៈគួរឱ្យធុញគួរឱ្យឆ្ងល់និងអស់កន្លែង ប៉ុន្តែចំពោះអ្នកទាំងឡាយណាដែលខិតខំអប់រំទៅលើ*ទស្សនៈប្រាកដនិយម* ចំពោះ*ជីវិត* រឿងនេះមិនមែនជា *ទេវកថា* ជា *រឿងព្រេងប្រឌិត* ដែលគេនិទានប្រាប់មនុស្សឆ្កួតនោះទេ។

ចំពោះអ្នកទាំងឡាយណាដែលមើលឃើញពី *ពិភពវេទយិទ* (the sentient world) ចេញពី*ជ្រុងត្រឹមត្រូវ* នោះគឺជា*ការស្គាល់ខុសត្រូវពិតប្រាកដ*វិត្ថុមួយមានលក្ខណៈច្បាស់លាស់ក្រៃលែងមានតែបញ្ហាមួយប៉ុណ្ណោះនៅក្នុង លោកនេះនោះគឺ *ទុក្ខ* (*dukkha*)។ ដូច *ព្រះពុទ្ធ* ទ្រង់ត្រាស់ថា *ពិភពលោក* ត្រូវបានបង្កើតនៅលើ *ទុក្ខ* សង់នៅលើ *ទុក្ខ*។ ប្រសិនបើអ្វីមួយក្លាយ ទៅជា*បញ្ហាមួយ*ឃ្លួមទៅជា *ទុក្ខ* ទៅជា *ទោមនស្ស* ឬប្រសិនបើយើងចូលចិត្ត ប៉ះទង្គិចនោះគឺការប៉ះទង្គិចរវាង *ចំណង់បាន* របស់យើងនិង*ការពិតនៃជីវិត*។

ចំពោះបញ្ហាទោលនេះយើងឱ្យឈ្មោះខុសៗគ្នាថា *បញ្ហាសាសនា ចិត្តវិទ្យានយោបាយ សង្គមនិងបញ្ហាសេដ្ឋកិច្ច* ។ តើបញ្ហាទាំងអស់នេះមិនកើតចេញមកពីបញ្ហាទោលមួយ (ទុក្ខ) ពោលគឺ *ទោមនស្ស* ឬ? ប្រសិនបើគ្មាន *ទោមនស្ស*នេះទេ តើហេតុអ្វីបានជាយើងត្រូវការដោះស្រាយវា? តើការមិនដោះស្រាយបញ្ហាមួយបញ្ជាក់ពីការកាត់បន្ថយ *ទោមនស្ស*នេះឬ? បញ្ហាទាំងអស់សុទ្ធតែបង្កើតឱ្យមាន *ទោមនស្ស* ហើយការខិតខំព្យាយាមបញ្ចប់វា ប៉ុន្តែវាបង្កើតឱ្យគ្នាទៅវិញទៅមក។ *ហេតុជានិច្ច*ជាកាលមិនមែនមកពីខាងក្រៅនោះទេ ប៉ុន្តែវាមាននៅក្នុងខ្លួនវានេះតែម្តងវាគឺជា *ប្រធានវិស័យមួយ* ។ ជានិច្ចជាកាលយើងតែងតែគិតថា យើងបានដោះស្រាយបញ្ហាចំពោះ *សោមនស្ស* នៃ *គ្រប់បញ្ហា* ដែលគេខ្វល់ ប៉ុន្តែបញ្ហាទាំងនេះជានិច្ចជាកាលតែងកើតឡើងនៅក្នុង *ទម្រង់ដទៃទៀត* ទៅតាមរបៀបខុសៗគ្នា។ វាហាក់ដូចជាធ្វើឱ្យយើងប្រឈមមុខដោយជៀសមិនផុតជាមួយនឹង*បញ្ហាថ្មីៗ* ហើយយើងក៏មាន*ការខិតខំថ្មីៗ*ដើម្បីដោះស្រាយ វាដូច្នេះ*បញ្ហា* ហើយនិង *ដំណោះស្រាយ*ចំពោះវាប្រព្រឹត្តទៅមិនចេះចប់។ បញ្ហានេះគឺជា*ធម្មជាតិ* នៃ*ទុក្ខ* ដែលជា*លក្ខណៈអត្ថិភាពវេទយិតសកល* (the universal characteristic of sentient existence)។ *ទុក្ខ*កើតមានឡើងហើយរលត់ទៅវិញគ្រាន់តែដើម្បីកើតឡើងវិញនៅក្នុង*ទម្រង់ផ្សេងៗទៀត*ប៉ុណ្ណោះ ។បញ្ហាទាំងនេះមានលក្ខណៈជា*ចិត្តសាស្ត្រ*ផងជា *រូបសាស្ត្រ* ផងហើយ *មនុស្សមួយចំនួន* មានលទ្ធភាពអាចអត់ទ្រាំនឹងបញ្ហាមួយបានជាងបញ្ហាដទៃទៀត។

**ការពិតនៃជីវិត** (Facts of Life)

បើតាម *ព្រះពុទ្ធសាសនាជីវិត* គឺ *ទុក្ខ ទុក្ខ* គ្របសង្កត់លើ *ជីវិត* គ្រប់យ៉ាង។ វាគឺជា *បញ្ហាមូលដ្ឋាន* ចំពោះ *ជីវិត*។ *ពិភពលោក* គឺ *ទុក្ខ* ហើយនិងធ្វើឱ្យ*ទុក្ខ*កើតឡើង គ្មាន *ភាវៈណាមួយ* រួចផុតពី *ចំណង* នៃ *សេចក្តីវេទនា* នេះបានឡើយហើយនេះគឺជា *សច្ចភាពសាកល* ដែល*គ្មានសត្វលោក* (sensible man) ណាមួយមើលឃើញពី *វត្តនានា* តាម *ទស្សនវិស័យសមស្រប* របស់ពួកគេអាចបដិសេធបានឡើយ។ តែទោះជាយ៉ាងណាក៏ដោយការយល់ដឹងពិតចំពោះ *ការពិតសាកលនេះ*មិនមែនជា*ការបដិសេធទូទៅ* ចំពោះ*សេចក្តីរីករាយ* ឬ*សុភមង្គល* នោះឡើយ។ *ព្រះពុទ្ធ ព្រះគុណម្ចាស់*ទ្រង់ឈ្នះលើទុក្ខមិនដែលបដិសេធ *សុភមង្គល* នៅក្នុងជីវិតពេលព្រះអង្គទ្រង់សម្តែងអំពី *សាកលភាព* នៃ *ទុក្ខ*។ នៅក្នុង *Anguttara Nikaya* មានការរៀបរាប់យ៉ាងវែងមួយអំពី *សុភមង្គល* ដែលភាវៈទាំងឡាយមានលទ្ធភាពអាចសប្បាយបាន។

ក្នុងការដោះស្រាយបញ្ហារបស់ *Mahali Licchavi* *ព្រះពុទ្ធ* ទ្រង់ត្រាស់ថា " ម្នាល Mahali ប្រសិនបើ *ទម្រង់ញាណ* (visible forms) ដូចជា *សម្លេង* *ក្លិនរស* ហើយនិង *វត្ថុវិញ្ញាណ* ( ដូចលោក-អ្នកដឹងស្រាប់វត្ថុទាំងនេះជា *វត្ថុញាណ* ដែល *មនុស្ស* ទទួលបានបទពិសោធន៍តាមរយៈ *ឥន្ទ្រិយារម្មណ៍* (sense faculties) របស់អ្នក) សុទ្ធតែស្ថិតនៅក្រោម *ទុក្ខ* ទាំងអស់ ហ៊ុមព័ទ្ធ ទៅដោយ *ទុក្ខ* ហើយធ្វើឱ្យលែងមាន *សេចក្តីសប្បាយ* និង *សុភមង្គល* ទាំងស្រុង *ភាវៈ* នឹង មិនទទួលបាននូវ *សេចក្តីរីករាយ* នៅក្នុង *វត្ថុញាណទាំងនេះ* ឡើយប៉ុន្តែម្នាល Mahali ក៏ព្រោះតែ មាន *សេចក្តីសប្បាយ* និង *សុភមង្គល* នៅក្នុង *វត្ថុញាណទាំងនេះភាវៈទាំងឡាយ* ទទួលបានសេចក្តីរីករាយនឹងវា ហើយតោងជាប់លើវាដោយសារតែ *ការតោងជាប់* នេះហើយដែលពួកវាធ្វើឱ្យសៅហ្មងលើខ្លួនវា " ។

តាមរយៈ *ឥន្ទ្រិយារម្មណ៍មនុស្ស* បានជាប់ជំពាក់ចិត្តទៅនឹងវត្ថុញាណរីករាយនឹងវាហើយឃ្លាតចេញពី *ការសប្បាយរីករាយ* (assada) ។ វាគឺជាការពិតមួយដែលគេមិនអាចបដិសេធបានព្រោះលោក-អ្នកទទួលបានបទពិសោធពីវា ។តែទោះជាយ៉ាងណាក៏ដោយវត្ថុរីករាយក៏មិនមែន *ការសប្បាយរីករាយ* ក៏មិនមែននៅទីបញ្ចប់ ។ ពួកវាឈឺចាប់នឹងបំលាស់ប្តូរ ។ ឥឡូវនេះពេល *មនុស្ស* គ្មានលទ្ធភាពអាចហ៊ឹកហាត់សារឡើងវិញបាន ឬត្រូវឃ្លាតឆ្ងាយពី *សេចក្តីរីករាយ* ដែលធ្វើឱ្យគេសប្បាយ គេតែងតែមានទុក្ខព្រួយនិងគ្មានអំណរសាទរ ។ ពួកគេមិនពេញចិត្ត នឹង *ភាពដដែលៗ* (mo-notony) ព្រោះការខ្វះខាតនូវភាពប្លែកៗ ដែលធ្វើឱ្យគេមិនរីករាយហើយក៏ស្វែងរក *សេចក្តីរីករាយថ្មីៗ* ប្រៀបដូច *បសុសត្វធំៗ* (cattle) ដែលស្វែងរក *វាលស្មៅថ្មីៗ* ប៉ុន្តែ *សេចក្តីរីករាយទាំងនេះ* ក៏ជាការបង្ហាឱ្យឃើញពីការកន្លងផុតទៅយ៉ាងឆាប់រហ័សផងដែរ ។ ដូច្នេះ *សេចក្តីរីករាយ* ទាំងអស់ តើយើងចូលចិត្តវាដែរឬក៏អត់នោះគឺជាចំណាប់ផ្តើមចំពោះ *ជម្ងឺនិងការស្អប់ខ្ពើមនានា*។ *សេចក្តីរីករាយលោកិយ* មានលក្ខណៈ *ឆាប់រហ័សបំផុត* ប្រៀបដូច *គ្រាប់ថ្នាំពុលលាបស្ករ* ដែលវាបំភន្ត័ភ្នែក និងធ្វើឱ្យយើងមានទុក្ខទោស ។

ចំណីអាហារដែលមិនអាចឯកភាពបាន ភេសជ្ជៈមិនគួរជាទីរីករាយ អត្តចរិតមិនគួរឱ្យស្រឡាញ់ ហើយនិងរបស់ឥតប្រយោជន៍មួយរយផ្សេងទៀតសុទ្ធតែនាំមកឱ្យយើងនូវជម្ងឺ និង *សេចក្តីទោមនស្ស* ទោះជា *ពុទ្ធសាសនិកជន* ក្តី មិនមែន *ពុទ្ធសាសនិក* ក្តី *អ្នកមាន* ក្តី *អ្នកក្រ* ក្តី *អ្នកខ្ពស់* ក្តី *អ្នកទាប* ក្តី *អ្នកចេះ* ក្តី *អ្នកល្ងង់* ក្តី ។ Shakespeare គ្រាន់តែផ្តល់សម្លេងចំពោះពាក្យរបស់

*ព្រះពុទ្ធ* ពេលលោកតែងរឿង Hamlet ដូច្នេះថា "ពេល *សេចក្តីទុក្ខ* ចូលមកដល់ *សេចក្តីទុក្ខ* ទាំងនោះចូលមកមិនមែនជា *ចារបុរស-នារី* ម្នាក់ៗ (single spies) នោះទេ ប៉ុន្តែជា *កងវរសេនាតូច* " ។

ឥឡូវពេលមនុស្ស មើលមិនឃើញពី *ទិដ្ឋភាពនៃជីវិត* នេះភាពមិនទៀងទាត់នៃ *សេចក្តីរីករាយ* នេះគេក៏ទៅជា *ខកចិត្ត* អាចប្រព្រឹត្តទៅដោយ *ល្ងីល្ងើ* ដោយគ្មានវិញ្ញាណឬការវិនិច្ឆ័យ ហើយដែលធ្វើឱ្យបាត់ *លំនឹងស្មារតី*។ នេះគឺជា *គ្រោះថ្នាក់* ពោលគឺ *វិបាកអាក្រក់* (*adinava*) ។ *មនុស្ស* តែងតែប៉ះទង្គិចជាមួយនឹង *រូបភាពជីវិតទាំងពីរនេះ* ជារឿយៗ។ ផ្ទុយទៅវិញ *មនុស្ស* ដែលខិតខំប្រឹងប្រែងកម្ចាត់ *ជំនក់ចិត្ត* ដ៏ជ្រាលជ្រៅរបស់គេចំពោះ *វត្ថុនានា* ទោះ *មានជីវិតក្តី មិនមានជីវិតក្តី* ហើយមើលឃើញ *ជីវិត*ពោរពេញទៅដោយ *ទស្សនវិស័យ*ដាច់ដោយឡែកមួយ អ្នកដែលមើលឃើញ *វត្ថុនានា*ទៅតាម *ទស្សនវិស័យសមស្រប*របស់គេ ដែល *ការអប់រំវប្បធម៌* របស់គេជម្រុញឱ្យ គេមាន *ចិត្តស្ងប់* ក្រោម *ដំណើរប្រែប្រួល*សព្វយ៉ាងរបស់ *ជីវិត អ្នក*ដែលអាចញញឹមពេល *វត្ថុនានា* ប្រព្រឹត្តទៅ ដោយខុសឆ្គងហើយរក្សា *លំនឹងផ្លូវចិត្ត* បានដោយគេច ផុតពី *របស់ចូលចិត្ត* និង *របស់មិនចូលចិត្ត* គឺថា គេមិន ដែលខ្វល់ខ្វាយឡើយ ប៉ុន្តែគេមាន *សេរីភាព* (*nissarana*) ។ ទិដ្ឋភាពទាំងបី *assada*) *adinava* និង *nissarana* ឬ *ការ សប្បាយរីករាយ វិបាកអាក្រក់* និង *សេរីភាព* របស់ពួកគេគឺជា *ការពិត* នៃ *បទពិសោធន៍* ពោល គឺ *រូបភាពពិត* នៃអ្វីដែលយើងឱ្យឈ្មោះថា *ជីវិត* នោះ។

ក្នុងការដោះស្រាយចម្លើយរបស់ Mahali *ព្រះពុទ្ធ* ទ្រង់បានត្រាស់បន្តថា : "ម្នាល Mahali ប្រសិនបើ *ទម្រង់មើលឃើញ* ដូចជា *សម្លេង ក្លិន រស* ហើយនិង *វត្ថុញាណ*នានាស្ថិតនៅក្រោម *សេចក្តីរីករាយ*ទាំងស្រុងហ៊ុមព័ទ្ធទៅដោយ *សេចក្តីរីករាយ* នៅមាន *ជម្ងឺ សត្វលោកទាំងឡាយ* (beings) នឹងមិនត្រូវបានស្អប់ខ្ពើមជាមួយ នឹង *វត្ថុញាណ* នានាឡើយប៉ុន្តែម្នាល Mahali ដោយសារតែមាន *ជម្ងឺ* ហើយគ្មាន *សេចក្តីរីករាយគង់បានយូរ* ទៅលើ *វត្ថុញាណ* ទាំងនេះទេ ពួកគេមានអារម្មណ៍ស្អប់ខ្ពើមការដែលត្រូវគេស្អប់ខ្ពើម ពួកវាមិនធ្វើឱ្យសប្បាយ ហើយតោងជាប់ទៅនឹងពួកវា ប្រសិនបើមិនតោងជាប់នោះទេ ពួកវាបន្សល់ទុកលើខ្លួនវា" ។

ឥឡូវនេះមាន ទិដ្ឋភាពទុក្ខបីគឺ ÷

-ទុក្ខ នៅក្នុងទម្រង់ជាក់ស្តែងសាមញ្ញបំផុតរបស់វា *(dukkha-dukkhata)*

-ទុក្ខឬ ទោមនស្សភាពនៃ ភាពមានលក្ខខណ្ឌ (*sankhara-dukkhata*)

-ទុក្ខដែលបានបណ្តាលឡើងដោយ ការប្រែប្រួល (*viparinama dukkhata*)

*ទុក្ខ* ខាង *រូបកាយ* និងខាង *ខួរក្បាល*ដូចជា *ជាតិ ជរា* (ageing) *ព្យាធិមរណៈ* សុទ្ធតែជាប់ទាក់ទងជាមួយ នឹង*ភាពមិនគួរឱ្យស្រឡាញ់* (the unloved), ការឃ្លាតឆ្ងាយពី *ភាពគួរឱ្យស្រឡាញ់* (the loved) ការមិនទទួលបាននូវអ្វីដែលគេចង់បានគឺជា *សាមញ្ញទុក្ខ* ចំពោះ*ជីវិតប្រចាំថ្ងៃ* ហើយដែលគេឱ្យឈ្មោះថា *dukkha-dukkhata* ។ វិទ្យាសាស្ត្រ មិនច្រើនប៉ុន្មានទេ ដែលគេត្រូវការយល់ដឹងពី *ការពិត*នៃ *ជីវិតនេះ*។

*Sankhara-dukkhata* *ទោមនស្សភាព* នៃភាពមានលក្ខខណ្ឌគឺជា *ភាពសំខាន់*ខាង*ទស្សនវិជ្ជា*។ បើទោះជាពាក្យថា *Sankhara* បញ្ជាក់ពី *អ្វីៗសព្វយ៉ាង*សុទ្ធតែស្ថិតនៅក្រោម*ហេតុ*និង *ផល*ក៏ដោយ ក៏នៅទីនេះនៅក្នុងបរិបទនៃ *ទុក្ខ* (*dukkha*) ដែល *ក្រុម៥* ឬ *បញ្ចខន្ធ* (*pancak khandha*) ត្រូវមានន័យស្រាប់ ។ពួកវាទាំងនេះគឺជា *បន្សំនៃរូបធាតុ* (នៅក្នុងករណីនេះ *រូបរាងទម្រង់* ពិតប្រាកដ និងអាចមើលឃើញបាន) គឺជា *ឥន្ទ្រិយារម្មណ៍* គឺជា *ការយល់ដឹង*ដោយវិញ្ញាណគឺជា*សង្ខារ* (mental formation) ហើយនិង*វិញ្ញាណ* (consciousness) ។ ពួកវាត្រូវគេស្គាល់ជា *សង្ខេបថា នាមរូប (nama-rupa)*ពោលគឺ*អង្គ រូប-ចិត្ត* (the psycho-physical entity) ។ *រូប (rupa)*មានរួមបញ្ចូល ទាំង *បន្សំរូប* (the physical aggregate) និង*នាម (nama)* គឺជា*បន្សំសំណល់៤*(the remaining four aggre-gates)ទៀត ។ បន្សំនៃ*ខន្ធ៥បង្កើត* បានជា *សត្វលោក* (sentient being)នេះឡើង ។

*ភាវៈមួយ* ហើយនិង*ពិភពពិសោធន៍* សុទ្ធតែ*ប្រែប្រួល*ជារឿយៗ ។ ពួកវាកកើតជា*ភាវៈ* ហើយក៏ *បាត់បង់* ទៅវិញ ។ ទាំងអស់នេះគឺជា *ដំណើរវិលវល់មួយ* (a whirl) គ្មានអ្វីគេចផុតពី*ការប្រែប្រួលជានិរន្តដាច់ខាត* នេះបានឡើយហើយដោយសារតែ*ធម្មជាតិមិនទៀងទាត់* នេះហើយទើបគ្មានអ្វីមួយដែលមាន *ការសប្បាយពិតប្រាកដ* នោះ ។ មាន*សុភមង្គល* ប៉ុន្តែវាមាន*លក្ខណៈមួយខណៈ*។ វារលត់បាត់ទៅវិញប្រៀបដូចជា *ដុំទឹកកកមួយដុំតូច* (a flake of snow) ដូច្នេះដែរហើយក៏លេចឡើងនូវ *ទោមនស្សភាព*នេះ ។

*Viparinama dukkhata* កើតមានឡើងនៅក្រោមប្រភេទនៃ *ទោមនស្សភាព* ដោយហេតុតែ*ភាពមិនស្ថិតស្ថេរ* (impermanence) ។ *គ្រប់អារម្មណ៍រីករាយ* និង*សុភមង្គល*ដែល*មនុស្ស* អាចទទួលបានបទពិសោធន៍ត្រូវឃ្លាតឆ្ងាយបន្តិចម្តងៗ ហើយក៏លិចបាត់ទៅ ។ *ដូចព្រះពុទ្ធ*ទ្រង់មានពុទ្ធដិកាថា សូម្បីតែ *អារម្មណ៍នានា*ដែល *យោគី* (a yogi) ឬ *អ្នកចម្រើនភាវនា* (meditator) ម្នាក់ទទួលបានបទពិសោធន៍តាមរយៈការសម្រេចបាននូវ *ការបញ្ច្រាបចម្រើនភាវនា* (jhana) បួន

យ៉ាងក្រោមប្រភេទនៃ Viparinama dukkhata ពីព្រោះពួកវាមានលក្ខណៈជា *បណ្ដោះអាសន្ន* (anicca) ពោលគឺ dukkhata ហើយនិងស្ថិតនៅក្រោម *ការប្រែប្រួល* (viparinama dhamma)។ ប៉ុន្តែ dukkhata ដែលយើងបានបង្ហាញនៅទីនេះ មិនមែន*ជាជម្ងឺ* ដោយពិតៗនោះទេ ហើយនិង *ទុក្ខ* ដែលមនុស្សទូទៅស៊ូទ្រាំ។ អ្វីដែល*ព្រះពុទ្ធ*ទ្រង់ត្រាស់សម្ដែងនោះគឺថា *វត្ថុ* ទាំងអស់ដែលមានលក្ខណៈ *មិនអចិន្ត្រៃយ៍* នោះមានលក្ខណៈ *ទោមនស្ស*។

ពួកគេមានទុក្ខចំពោះ *ការប្រែប្រួល* ជារឿយៗ ហើយ*ការប្រែប្រួល* នេះបង្កើតឱ្យមាន *ទោមនស្សភាព ព្រោះអ្វីក៏ដោយដែលសុទ្ធតែមានលក្ខណៈ មិនអចិន្ត្រៃយ៍*គឺសុទ្ធតែពោរពេញទៅដោយ *ទោមនស្សភាព* (yadaniccam tam dukkham) ពោលគឺគ្មាន *បរមសុខជានិរន្តរ៍*(lasting bliss) នោះទេ។ *ព្រះពុទ្ធ* មិនមានការសម្ដែងទឹកមុខស្រពាប់ស្រពោន (a funereal express ion) នៅលើទឹកមុខរបស់ព្រះអង្គ ពេលព្រះអង្គពន្យល់ចំពោះសាវ័ករបស់ទ្រង់អំពី *សច្ចភាពនៃ ទុក្ខ* នោះទេ ឃ្លាតឆ្ងាយពីនេះ *ព្រះភក្ត្រព្រះអង្គជានិច្ចកាល សប្បាយ ស្ងប់ស្ងៀម* ហើយនិង *ញញឹម* ចំពោះវាដែលបង្ហាញពី *ទឹកព្រះទ័យរីករាយ : "តាមពិតយើងរស់នៅដោយ សប្បាយរីករាយ យើងគ្មានភារៈលើសេចក្ដីត្រេកអរ ដែលយើងធ្លាប់បំប៉ននោះទេ ប្រៀបបានទៅ នឹងទេពធិតាដ៏ស្រស់ប្រិមប្រិយដូច្នេះដែរ"*។

ព្រះអង្គលើកទឹកចិត្ត *សាវ័ក* របស់ទ្រង់មិនឱ្យ *ខូចសតិ*នោះទេ ប៉ុន្តែព្រះអង្គអប់រំទៅលើ *គុណភាពសប្បាយសំខាន់ៗ* ទាំងអស់ដែលជាកត្តាមួយនៃ*ការត្រាស់ដឹង*។ ការសិក្សា *ព្រះពុទ្ធសាសនា* ដោយឥតកង្វល់នឹងបង្ហាញប្រាប់យើងថា វាគឺជាការទូន្មានមួយដែលបំភ្លឺពី *ការត្រេកអរ*ហើយនិង*សេចក្ដីសង្ឃឹម*ហើយមិនមែនជា*ទស្សនវិជ្ជាទុទិដ្ឋិនិយម*ដែលគួរឱ្យជឿជាក់នោះទេ។

## ៣-ព្រះពុទ្ធសាសនាសម្រាប់ថ្ងៃនេះនិងថ្ងៃស្អែក

(Buddhism for Today and Tomorrow) By Dr. Nandadeva Wijesekera

វាជាការមិនគួរឱ្យមានមន្ទិលសង្ស័យសោះឡើយថា គេត្រូវការ *ព្រះពុទ្ធសាសនា*នៅក្នុង *ពិភពទំនើប*បើទោះជា *ព្រះពុទ្ធសាសនា* នេះត្រូវបានប្រកាសផ្សព្វផ្សាយជាង *២៥០០ឆ្នាំ* កន្លងទៅហើយក៏ដោយ។ នេះក៏ព្រោះតែ*ពាក្យប្រៀនប្រដៅ* របស់សាសនានេះមាន *ប្រយោជន៍គ្រប់សម័យកាល* (ageless)។ *ព្រះពុទ្ធសាសនា* និយាយពី*សេចក្ដីស្រឡាញ់ សេចក្ដីមេត្តាការ សប្បាយរីករាយ* និង*សន្តិភាព*។*សន្តិភាព* ជា*គុណភាពមួយ* ដែល*ពិភពលោក* កំពុងតែពិភាក្សា ហើយមេដឹកនាំប្រទេស និងអង្គការនានានៅទូទាំងពិភពលោក ចង់បានសន្តិភាពយ៉ាងខ្លាំង។ ប៉ុន្តែនៅតែមាន *ប្រជាជនជាច្រើន* ដែលមិនទាន់យល់ច្បាស់អំពី *ទ្រឹស្ដី* របស់*ព្រះពុទ្ធ*។

នៅពេលដែលទ្វីបនានា ត្រូវបានបែងចែកទៅតាមលក្ខណៈភូមិសាស្ត្រ ភាសានិងជាតិសាសន៍នោះគេបានបង្រៀន អំពីពាក្យប្រៀនប្រដៅ*សន្តិភាព សេចក្តីស្រឡាញ់ សុភមង្គល* ដល់*មនុស្សគ្រប់រូប*។ លក្ខណៈភូមិសាស្ត្រដាច់ឆ្ងាយពីគេទំនាក់ទំនងយឺតយ៉ាវ និងមានកម្រិតបានធ្វើឱ្យប៉ះពាល់ដល់តំបន់នោះ។ ដូច្នេះ *អបិយជំនឿ* កាន់តែសម្បូរហើយ *ពុទ្ធិ* ក៏មានលក្ខណៈមិនអាចផ្លាស់ប្តូរបាន។ ដូច្នេះនៅក្នុងស្ថានភាពបែបនេះ *អ្នកមិនចេះ* (the unknown) មានចំនួន ច្រើនជាង*អ្នកចេះ* (the known)។ តាមបច្ចេកវិទ្យា និងវិទ្យាសាស្ត្រតំបន់អភិវឌ្ឍន៍នៃពិភពទំនើបបច្ចុប្បន្ន មិនទាន់ត្រូវបានអភិវឌ្ឍន៍ឬកំពុងត្រូវបានអភិវឌ្ឍន៍។ អាស្រ័យហេតុនេះប្រជាជនដែលរស់នៅតាមទ្វីបនានាទាំងនោះ មិនមានឱកាសដឹងនិងយល់ពីសារសំខាន់នៃទ្រឹស្តី ព្រះពុទ្ធសាសនានៅឡើយ។

មានកត្តាមួយទៀតដែលប្រឆាំង នឹងការរីករាលដាលទ្រឹស្តីព្រះពុទ្ធនោះគឺ វិធីទប់ស្កាត់មិនឱ្យផ្សព្វផ្សាយសាសនា។ ពេលនោះសាសនាបានរីករាលដាលដោយចុងដាវ និងចម្បាំង។ បើប្រៀបធៀបទៅនឹងបញ្ហានេះព្រះពុទ្ធសាសនាជាសាសនាមួយដែលមិនត្រូវការកម្លាំងទ័ពឬទាមទារឱ្យមានសត្រូវក្នុងការបណ្តុះបណ្តាលសាសនារបស់ខ្លួនឡើយ។

ផ្ទុយទៅវិញនេះក៏ព្រោះតែកត្តាទាំងអស់នេះហើយទើប *ព្រះពុទ្ធសាសនា* បានផ្សព្វផ្សាយទៅគ្រប់ប្រទេសទាំងអស់ ដែលប្រទេស *ឥណ្ឌា* ធ្លាប់មានទំនាក់ទំនងជាមួយនៅសម័យនោះ។ *ព្រះពុទ្ធសាសនា* បានផ្សព្វផ្សាយយឺតៗ ប៉ុន្តែច្បាស់លាស់តាមផ្លូវធ្វើដំណើរទៅកាន់ប្រទេស *ទីបេ ចិន កូរ៉េ ជប៉ុន* និង *ទួរគីស្តង់កណ្តាល*។ ព្រះបាទ *អសោក* ក៏បានបញ្ជូន*ពុទ្ធបេសកទូត* (Buddhist Missions) មកកាន់ព្រះរាជាណាចក្រនៅ *ភាគខាងកើត* និង *ខាងលិច* តាមរយៈ*ព្រះសង្ឃ* និង *សាវ័កព្រះពុទ្ធសាសនា*។ ព្រះអង្គបានបញ្ជូន*ព្រះធម៌* ទៅប្រទេស *ស្រីលង្កា* តាមរយៈបុត្រាឈ្មោះ Mahinda និងបុត្រីឈ្មោះ Sanghamitta។ កូនដើម *ពោធិព្រឹក្ស* (Budhi tree) ដែលព្រះពុទ្ធបានត្រាស់ដឹងដោយបរិបូណ៌ត្រូវបាននាំយកមកប្រទេស *ស្រីលង្កា* ដោយ Sanghamitta។ *ដើមពោធិនេះ* នៅរស់រហូតដល់សព្វថ្ងៃនេះ ដែលជាដើមប្រវត្តិសាស្ត្រចំណាស់បំផុត នៅលើពិភពលោក។ *ដើមនេះ* គឺជា*និមិត្តរូប*នៃ *ការត្រាស់ដឹង* ចំពោះគ្រប់*ពុទ្ធសាសនិកជន* ទាំងអស់។ ចេញពីប្រទេស *ស្រីលង្កា និងឥណ្ឌាព្រះពុទ្ធសាសនា* ត្រូវបាននាំយកទៅប្រទេស *ភូមា ថៃ ឡាវ វៀតណាម កម្ពុជា* និង *ឥណ្ឌូនេស៊ី*។

សព្វថ្ងៃនេះ *ពិភពលោក* បានរួញទំហំមកតូចហើយ ។ *ប្រទេសកំពុងអភិវឌ្ឍ* និង *ប្រទេសមិនទាន់អភិវឌ្ឍ* មានការរីកចម្រើនខាង *បច្ចេកវិទ្យា* និង *វិទ្យាសាស្ត្រ* នៅពេលដែល *ផ្ទៃដីអភិវឌ្ឍ* បានក្លាយជា *តំបន់គ្មានការអភិវឌ្ឍន៍*។ នៅក្នុងសម័យនេះ *ការធ្វើដំណើរ*មានភាពងាយស្រួលរហ័សនិងគ្មានឧបសគ្គ ។ ការប្រាស្រ័យទាក់ទងគ្នាកើតឡើងបានភ្លាមៗ ។ ដូច្នេះហើយ *សម្បត្តិចំណេះដឹងគឺជា មតិកទូទៅ* របស់ *មនុស្សគ្រប់រូប* ហើយគ្មានហេតុផលអ្វីសម្រាប់ពួកគេដែលត្រូវស្ថិតនៅក្នុង *អវិជ្ជា* ចំពោះ *ពាក្យប្រៀនប្រដៅ* របស់ *ព្រះពុទ្ធនោះ* ទេ ។

**ការរិះគន់នានា** (Criticisms)

ផ្ទុយទៅវិញ សូម្បីតែជាមួយ *ចំណេះដឹង*ចំពោះការបោះចោលរបស់មនុស្សម្នាក់ៗក៏ដោយ ក៏នៅតែមាន *ការរិះគន់*ជាច្រើនប្រឆាំងនឹង *ព្រះពុទ្ធសាសនា* ក៏ដូចជា *ការភ័ន្តច្រឡំ* និង យល់ខុសចំពោះ *ពុទ្ធឱវាទ*។ មាន *អ្នកសិក្សា* ជាច្រើនដែលព្យាយាមគិតថា *ព្រះពុទ្ធសាសនា* និង *ហិណ្ឌូសាសនា* ដូចគ្នា ។ ក៏មានមនុស្សជាច្រើនទៀតដែរដែលគិតអំពី *ព្រះពុទ្ធសាសនា* ថាមិនខុសអីអំពី *សាសនាទេវៈ* ផ្សេងៗទៀតឡើយ ។ អ្នកខ្លះនិយាយថា *ព្រះពុទ្ធសាសនា* ពោរពេញទៅដោយ *ជំនឿ* និង *ការអនុវត្តន៍អរូបិយ៍*។ បើមើលពីខាងក្រៅបញ្ហាទាំងនេះទំនងជាមានលក្ខណៈផ្ទុយ ដែលបិទបាំងនូវ *ការបង្រួមបង្រួមមនោគមវិជ្ជា*។ បញ្ហាដែលហាក់ដូចជា ខុសគ្នាទាំងនេះគឺអាស្រ័យ ដោយមាន *ការយល់ខុសការផ្តល់ព័ត៌មានខុស* ហើយ និងមាន *ការបកស្រាយ ខុស* ចំពោះ *ឌីណាមិុកសង្គម* (social dynamics) និង *មតិកវប្បធម៌* ដែល *គំរូស្មុគស្មាញរបស់វា* មានអត្ថិភាពរួម ទៅតាមលក្ខណៈស្ងាត់ៗ (unobstrusive manner) ទៅតាមសង្គមផ្សេងគ្នាទៅតាមវិធីផ្សេងគ្នា ។ អាស្រ័យហេតុនេះដើម្បីយល់អំពី *ធម្មជាតិនៃពុទ្ធឱវាទ* វាជាការចាំបាច់ និងមានសារៈសំខាន់ដែលត្រូវសិក្សាពី *ភាពខុសគ្នា* រវាង *ព្រះពុទ្ធសាសនា* និង *សាសនា* ដែលមានអត្ថិភាពណាមួយដើម្បីឱ្យយើងអាចយល់ច្បាស់អំពី *ពុទ្ធឱវាទ*។

សាសនាដទៃទៀត មានការរៀបចំគម្រោងយ៉ាងល្អដើម្បីបំពេញចិត្តលើ *សកម្មភាពចិត្តសាស្ត្រ* (psychological predis-position) *ឥរិយាបថ* និង *ការចង់ដឹងចង់ឮចំណោទបញ្ហារបស់មនុស្សដទៃវិធីគិត* និង *ការជឿ* របស់ពួកគេមានច្រើនដើម្បីឱ្យ *ការសង្ស័យដែលអាចគិតដល់បំផុត* នាំមកនូវ *ការពន្យល់*ដែលមានលទ្ធភាពប្រសើរបំផុត ។សេចក្តីពន្យល់មួយចំនួនក្នុងចំណោមសេចក្តីពន្យល់ទាំងនេះគឺផ្តោតទៅលើ *សព្វញ្ញូភាព*របស់ *អាទិទេព* (a Creator’s omni science) ដូចជា *សេចក្តីស្រឡាញ់*និង *សេចក្តីមេត្តាសកល* របស់ទ្រង់ជាដើម ។ គេក៏បាននិយាយផងដែរថា កត្តាមូលដ្ឋាន

មួយចំនួនក្នុងចំណោមកត្តាទាំងនេះមិនត្រូវឱ្យគេសួរនោះទេ។ *អ្នកខ្លះ* ទទួលយក*សាសនា*ដែលមាន*ជំនឿងងឹតងងុលអ្នកខ្លះទៀត* ទទួលយក*សាសនា*ដែលមាន*ទ្រឹស្តីជាគម្ពីរនិយម*។ តែទោះជាយ៉ាងណាក៏ ដោយការសន្មតទុកទាំងនេះបានបំពេញចិត្ត *អ្នក ជឿងប់ងុល*។ ចំណោទសួរមិនមែនសម្រាប់ពួកគេនោះទេ។ *តក្កវិជ្ជា* និង *ហេតុផល* សម្រាប់ផ្តល់នូវ *មធ្យោបាយល្អ* ចំពោះ *ជំនឿស៊ុប* នៅក្នុង*សាសនា*។*សនិទានកម្ម* (rationalisa-tion) *ការបកស្រាយបែបវិទ្យាសាស្ត្រ* និង *ការឯកភាព* តាមបែប *តក្កវិជ្ជា* មានលក្ខណៈខុសគ្នាពី*សាសនាមួយ* ទៅ*សាសនាមួយ*។ គេអះអាងថា *វិធី* និង *ភាពប៉ិនប្រសព្វ* *របស់វិទ្យាសាស្ត្រ ទំនើបទាំងនេះ*គ្មានអ្នកណាគេគ្រោងទុកហើយក៏គ្មានអ្នកណាគេអាចអនុវត្តបាននៅក្នុង*ករណីសាសនា*នោះទេ។គេបានគិតថា *សាសនា* មានលក្ខណៈខុសប្លែកជាសំខាន់ពី *វិទ្យាសាស្ត្រ*។ គេឧបមាថា មានការនិយាយមួយអំពីពាក្យថា *ព្រះអាទិទេព* (god)។ វាផ្ទុយទៅនឹង *ព្រះពុទ្ធសាសនា* ដែលអញ្ជើញស្វាគមន៍ និងលើកទឹកចិត្តដល់ *ការពិនិត្យអង្កេតការសាកសួរ* និង*អត្តពិគ្រោះ* (introspection) ទៅតាមបែប*តក្កវិជ្ជា* *ហេតុផល* និង *វិទ្យាសាស្ត្រ*។ រឿងនេះគេបាន បង្ហាញ នៅក្នុង *Kalama Sutta* ដែល*ព្រះពុទ្ធ*បានមានពុទ្ធដិកាថា : "*អូ Kalama: មិនត្រូវជឿលើអ្វី ដែលគេទទួលបានដោយការស្តាប់ឮដដែលៗ ឬក៏ទៅលើប្រពៃណី ឬទៅលើពាក្យចចាមអារាមឬទៅលើស្វ័យសត្យ (axiom) ឬទៅលើហេតុផលបំភ័ន្តភ្នែក ឬទៅលើភាពលំអៀង ចំពោះសញ្ញាណមួយ ដែលគេបានសញ្ជឹងគិត ឬទៅលើលទ្ធភាពសម្តែងរបស់អ្នកណាម្នាក់ ទៀតឬក៏ទៅលើ ការពិចារណានោះទេ ពោលគឺ ព្រះសង្ឃជាគ្រូរបស់យើង*"។

គេតែងតែនិយាយប្រឆាំងចំពោះ*ពុទ្ធសាសនិកជន*ថាពួកគេជឿលើ*ទេវតា* (gods) ទទួលយក *ជំនឿសាមញ្ញ* គោរព*ដើមឈើ* និង *រូបបដិមា*។ គេក៏បាននិយាយដោយមានការបង្ខូច ផងដែរថា ប្រជាជនដែលជឿលើសាសនានេះភាគច្រើនគោរព*ធាតុនានា* ដូចជា *ឋានសួគ៌ ផែនដី ព្រះចន្ទ ផ្កាយ*...។ នៅត្រង់នេះ *អ្នករិះគន់*មានការយល់ ខុសចំពោះ *តម្លៃវប្បធម៌ចម្រុះ ទំនៀមទម្លាប់សង្គម និងជំនឿប្រពៃណី របស់ប្រជាជនក្នុងដំណាក់កាលនៃ ការវិវត្តន៍សង្គមផ្សេងៗ*។ *អ្នករិះគន់* ប្រហែលជាភ្លេចឬពួកគេមិនដឹងថា *ព្រះពុទ្ធសាសនា* មិនដែលប៉ុនប៉ងលុបបំបាត់ *មាគ៌ាជីវិត* ដែលមានហើយនិង*តម្លៃវប្បធម៌*របស់ខ្លួនតាមរយៈ *មាគ៌ាជីវិតបែបប្រលោមលោក* ទៅលើ*មនុស្ស* ដែលគ្មានឆន្ទៈនោះទេ។ នៅក្នុងកិរិយាបថដូចគ្នានេះប្រសិនបើមាន *មនុស្សមានចម្ងល់* និង*មានសំណួរបែបហ្នឹង* *អ្នករិះគន់* ឬអ្នកពិនិត្យសង្កេតគឺត្រូវចោទសួរ *ឯកត្ត*

*ជនពុទ្ធសាសនា*អំពី *សង្គមពុទ្ធសាសនា*ដូច្នេះថា តើគេជឿទៅលើ *គំនិតចម្រុះ* (a medley of concepts) បែបហ្នឹង ឬទេគេនឹងឆ្លើយថា *"បាទ"* ហើយនិង *"ទេ"* ពីព្រោះ*គំនិត*របស់ *មនុស្សដែលជឿ* មានសារប្រយោជន៍បំផុត។ បើយោងទៅតាម *សមាសភាពខួរក្បាល* (mental make-up) របស់គេ គឺគ្មានអ្វីក្រៅពី *ភាពគ្មានតក្កវិជ្ជា* (illogical)នៅក្នុង *វិធីគិត*របស់គេនោះទេ ពោលគឺនៅក្នុង *តក្កវិជ្ជា* និងនៅក្នុង *ការរៀបចំកម្លាំង*ហើយនិង *អំណាចធាតុ* (elemental power) របស់ *របស់ ចាស់* និង *ថ្មីរបស់មិនស្គាល់* ហើយនិង *របស់អាថិកំបាំង* ជាដើម។ ចំពោះ *បុគ្គល* នេះ *ព្រះពុទ្ធ សាសនា* ហើយនិង *សិក្ខាបទ* របស់ខ្លួនសម្តែងឱ្យឃើញ (stand above) ពីការយកមកជំនួស *ជំនឿចាស់ៗបីបែប* (the substratum of the pyramid of old beliefs) ហើយ និង*អបិយជំនឿ* (superstitions) ជាមួយនឹង *ក្រមសីលធម៌* និង *ត្រៃរតនៈ ?"Tiratana"* [*ព្រះពុទ្ធ, ព្រះធម៌ និងព្រះសង្ឃ* (Sangha)] ត្រូវបានគេតម្កល់យ៉ាង ខ្ពស់នៅលើកំពូល *ពីរ៉ាមីត* (the peak of pyramid) ។

មានកំណត់សម្គាល់មួយក្នុងចំណោម កំណត់សម្គាល់ខ្លាំងជាងគេបំផុតដែលបានធ្វើឡើងចំពោះ *ព្រះពុទ្ធសាសនា* គឺថា *ពុទ្ធសាសនិកជន*មានជំនឿទៅលើ *ទេវតា* នៅក្នុងសង្គមរបស់ពួកគេ។ *ពុទ្ធសាសនិកជនម្នាក់*បែបនេះ ពេលគេបួងសួង គេមិនត្រូវយល់ច្រឡំជាមួយនឹង *ពុទ្ធសាស និកជនពិតប្រាកដម្នាក់* ដែលកំពុងតែស្វែងរក *និព្វាន* នោះទេ។ គេមិនត្រូវធ្វើបដិរូបកម្ម (personify) ជាមួយ *ព្រះពុទ្ធសាសនា*នោះឡើយពោលគឺ*ព្រះធម៌*ដែល *ព្រះពុទ្ធទ្រង់*បានបង្រៀន។ វាជាការយល់ច្រឡំមួយរបស់*អ្នកសង្កេតហើយនិងអ្នករិះគន់* ដែលចាត់ទុកចំពោះ*អ្នកជឿ* ដែលយល់ដឹងដោយពេញលេញពី *រចនាសម្ព័ន្ធពីរ៉ាមីត* របស់គេអំពី*ជំនឿសាសនា* របស់គេ។ គេជឿថា មាន *ចិត្តល្អ* និងមាន*ចិត្តអាក្រក់ ទេវតាល្អ* (beneficient deities) ហើយនិង *អំណាចមេត្តាខ្ពង់ខ្ពស់*។ គេក៏ជឿផងដែរថា *ព្រះពុទ្ធ* ទ្រង់មាន *ឋានៈខ្ពស់បំផុត*លើ *ទេវតានានា* តាមលំដាប់ស័ក្តិ។ ជាមួយនឹង*ពុទ្ធិវិទ្យាសាស្ត្រមានកំណត់* របស់គេ គេជឿដោយប្រហាក់ប្រហែលថា បែបបទនៃការជួយ ទាំងអស់អាចត្រូវបានគេផ្តល់អំណាចឱ្យអំឡុងពេលមាន *វិបត្តិ* ចំពោះ*ជីវិត*។ អាស្រ័យហេតុនេះ គេត្រូវធ្វើវត្ថុជាច្រើនសម្រាប់ *គោលបំណង* របស់គេហើយនិងនៅក្នុងទំនាក់ទំនងទៅនឹង *ការយល់ច្បាស់ពីតម្រូវការបន្ទាន់* របស់ *មនុស្ស* ក្នុងអំឡុងពេលមាន *ទុក្ខព្រួយខាងស្មារតី*។ ប៉ុន្តែ មិនដែលមានបុគ្គលបែបនេះណាមួយសុំឱ្យ *ព្រះពុទ្ធ* ហើយនិង *សាវ័កព្រះអង្គ* ធ្វើអន្តរាគមនោះទេ។ *ពុទ្ធសាសនិកជន* ដែលជាអ្នកគិតមិនសុំ ក្តីមេត្តាបែបនោះទេ។ គេយល់ទៅតាមធម្មជាតិថា *តម្លៃប្រពៃណី* នៅក្នុងសង្គមជាក់ស្តែងមួយនានាបានបង្កើតរូបរាង

*មូលដ្ឋានគ្រឹះនៃអត្ថិភាព* និង *និរន្តរភាព* (continuation) របស់*មនុស្ស*។ ហើយគេក៏យល់ផង ដែរថា*គ្រប់សង្គមទាំងអស់* សុទ្ធតែមាន*កេរតំណែលប្រពៃណីបុរាណ*របស់វា។ ដូច្នេះវាមិនមែន មិនអាចចំពោះ *ជំនឿប្រពៃណី* ទាំងនេះដែលគេត្រូវទទួលយក ហើយនិងត្រូវអនុវត្តស្របតាម *ព្រះពុទ្ធសាសនា* នោះទេ។ វាជា*មាគ៌ានៃជីវិត*។

អ្វីដែល *ព្រះពុទ្ធសាសនា* មិនបានធ្វើ *សាសនាដទៃ* ធ្វើហើយនិងប៉ុនប៉ងធ្វើ។ នៅក្នុង *ចំណង់ងប់ងុល* ដើម្បីផ្លាស់ប្តូរ*សាសនទូត*នៃ*សាសនាដទៃទៀត* បានបំផ្លាញ*ស្មារតីសង្គម* ហើយ ធ្វើឱ្យ*ស្មារតីទាំងនោះ* រេចរិលទៅៗហើយនិងធ្វើឱ្យ*គំរូដើម*នៃ*ជាតិសាសន៍* និង*វប្បធម៌បរទេស* ស្រអាប់គ្មានរស្មី។ ចំណង់ផ្លាស់ប្តូរ *តម្លៃវប្បធម៌* *ជំនឿប្រពៃណី* និង *គំរូសង្គមរបស់ពួកគេ* *ទទួលយកទម្រង់ទ្រង់ទ្រាយ*និង*ការប៉ុនប៉ងខាងស្មារតី* ដើម្បីបង្ខំឱ្យ*សាសនាបរទេស* ដែលមាន *ការតុបតែងជាវប្បធម៌បរទេស*តាមអ្វីដែលគេគិតថាជា*ក្រុមអន់ជាង*។ ដូច្នេះពួកគេបានប៉ុនប៉ង ផ្លាស់ប្តូរ*ព្រលឹងជាតិ* និង*វប្បធម៌សង្គម* របស់*ក្រុមមនុស្សមួយក្រុម*។ ស្ថានភាពបែបនេះបង្កើត ឱ្យមានការខូចខាតមិនអាចកែប្រែបានជាសង្គមនិងជាស្មារតី ពីព្រោះ*សាសនាទូត* បានទប់ស្កាត់ កម្លាំងជំរុញក្នុងការរស់នៅហើយជាត្រឡប់មកវិញពួកគេបានញ៉ាំង*ឆន្ទៈ* ឱ្យប្តូរសាសនាដើម្បីឱ្យ ចម្រើនឡើង ។បើមើលពីសំបកខាងក្រៅ*ការធ្វើបរិវត្តន៍សាសនា*បែបនេះអាចទទួលបានជោគជ័យ ។ ប៉ុន្តែបើមើលពីខ្លឹមខាងក្នុងវិញ*សាសនាផ្លូវចិត្ត របស់មនុស្សដែលជាជំនឿ និងតម្លៃពីបុរាណ មកនៅតែមានបើទោះជាមានជំនឿទៅលើសាសនាថ្មី*ក៏ដោយ ។ដូច្នេះនៅក្នុង*សង្គមនេះ*នឹងបង្ក ឱ្យមាន*ការប៉ះទង្គិចគ្នាមួយ*មិនត្រឹមតែទៅលើ*វប្បធម៌* និង*ពូជសាសន៍* ប៉ុណ្ណោះទេប៉ុន្តែក៏ចំពោះ *សាសនានេះ* ផងដែរ ។

ទោះជានៅទីណាក៏ដោយ *ព្រះពុទ្ធសាសនា* បានរកឃើញពីវិធីរបស់ខ្លួន ឬត្រូវបានណែ នាំដោយ *ព្រះសង្ឃការបង្រៀន* របស់ *ព្រះពុទ្ធ* មិនដែលមានជំទាស់នឹង *តម្លៃប្រពៃណី* របស់ *សង្គមថ្មីៗ* នោះទេ។ *អ្នកចាស់* និង*អ្នកថ្មី* *អ្នកបុរាណ* និង *អ្នកទំនើប* មានអត្ថិភាពទាំងសង ខាង។ នៅពេល *គំនិត*មានការរីកចម្រើន ហើយមាន *ពុទ្ធិឈានមុខផ្នែកវេទមន្ត* និង*ជំនឿងប់ ផ្តាំពេទ្យ* និង*វិទ្យាសាស្ត្របានថយចុះ*។ ដូច្នេះ ចំពោះអ្នកសង្កេតមើលដោយសើៗចំពោះ *អ្នករិះ គន់ដាច់ខាត* (die-hard) ហើយនិងចំពោះ *សាសនទូត* បញ្ហាទាំងនេះកើតមានឡើងជាប្រចាំ ដែលមិនអាចឈានទៅរកការព្រមព្រៀងគ្នាបាន។ ជាលទ្ធផលពួកគេបានថ្កោលទោស *ព្រះពុទ្ធ សាសនា* ដោយសារតែ*អវិជ្ជា* និងភាពខុសគ្នាជាបែបបទ ដែលពួកគេមានទស្សនៈទៅលើ*ការ*

*បង្រៀន* របស់ *ព្រះពុទ្ធ* ។ ពួកគេបកស្រាយពីចំណងទាក់ទងទៅនឹង *វេទមន្ត* ក៏ដូចជា *មធ្យោបាយ* នៃ *យន្តការបណ្ដោះអាសន្ន*របស់ *មនុស្ស* ដើម្បីបំពេញនូវ *ភាពគ្មានគឹងផ្អែកចិត្តសាស្ត្រ* ឬ *វិបត្តិការរំភើបចិត្ត* ដែលជា*សាសនាខុសមិនសំខាន់* (unwarranted irreligion) ។ ហើយគេបានបន្ថែមចំពោះករណីនេះ គឺជាការពិតដ៏ហួសហេតុដែលពួកគេបានទទួលយកថា *តម្រូវការ* របស់មនុស្សចំពោះ *ការរស់នៅ*ដែលត្រូវសម្រេចឱ្យបាននូវ *សភាពខ្ពស់បំផុត*ចំពោះ *សន្តិភាព* និង*សុភមង្គល* ដែលគេគ្រាន់តែអាចសម្រេចបានតាមរយៈ *ការលុបបំបាត់អំពើអាក្រក់ចោល* ប៉ុណ្ណោះ ។ ផ្ទុយទៅវិញ *ពុទ្ធសាសនិកជន* ដឹងថា *ភាវៈទាំងអស់*មានលក្ខណៈ *អនិច្ចតាធម៌ទោមនស្ស* ហើយនិងមានលក្ខណៈ *គ្មានព្រលឹង*។

**ការយល់ដឹងអំពីការប្រៀនប្រដៅរបស់ព្រះពុទ្ធ** (The Understanding of Buddha’s Message)

ចំពោះការអះអាងដែលថា *សាសនា* មានលក្ខណៈខុសឆ្គងជាមូលដ្ឋានពី *សនិទានកម្មវិទ្យាសាស្ត្រ* យើងអាចឆ្លើយបានតាមរយៈ *អភិធម្ម* (Abhidhamma) ។ ជាមូលដ្ឋាន *ការបង្រៀនដ៏ខ្ពស់*របស់ *ព្រះពុទ្ធនេះ* នាំទៅរក*ពិភពនៃការគិតវិទ្យាសាស្ត្រ* ចំពោះ *នាមរូប* *(nama-rupa)* ។ ការបង្រៀនជាមូលដ្ឋានគ្រឹះរបស់ *ព្រះពុទ្ធ* គឺ " *វៀរចាកអំពើអាក្រក់ ធ្វើតែអំពើល្អ និងធ្វើចិត្តឱ្យបរិសុទ្ធ*" ។ ចំពោះករណីនេះគេបានបន្ថែមថា *គ្រប់វត្ថុដែលបានតាក់តែងឡើងទាំងអស់* ជាប្រធានចំពោះ*ច្បាប់ប្រែប្រួល* និង *អនិច្ចៈ (anicca)* *ទុក្ខៈ (dukkha)* *អនត្តៈ (anatta)* ។ អាស្រ័យហេតុនេះ*ភាវៈមួយ*គឺគ្មានអ្វីក្រៅពី "*នាម-រូប*" នេះទេ ។ *រូប (rupa)* គឺជាការបញ្ចេញឱ្យឃើញនូវ *កម្លាំង* និង *គុណភាព* ។ ចាស់បុរាណបានទទួលស្គាល់ *រូប*នេះថាជា *អាតូម (paramanu)* ។ *ព្រះពុទ្ធ*ឱ្យឈ្មោះពាក្យនេះថាជា *ក្រុមរូបធាតុមូលដ្ឋាន*។ ចេញពីករណីនេះ យើងដឹងថា *ព្រះពុទ្ធសាសនា*មានលក្ខណៈទាន់សម័យទៅនឹង*របកគំហើញវិទ្យាសាស្ត្រចុងក្រោយបំផុត*ចំពោះ *ធម្មជាតិនៃភាវៈរស់* ។

*កំណើត*នៅក្នុង*គំនិតព្រះពុទ្ធសាសនា* ត្រូវបានគេឱ្យឈ្មោះថាជា*ចំណាប់ផ្ដើម*។ អាស្រ័យហេតុនេះដំណើរការនៃការកកើតនៅក្នុងរយៈពេលមិនយូរប៉ុន្មាន អវិជ្ជាដែលនៅជាប់ នឹងខ្លួនជា *បដិច្ចសមុប្បាទ* (paticcasam- uppada) ។

ជាធម្មតា ប្រសិនបើ *ហេតុ* ឈប់កើត *ផល*ក៏នឹងឈប់កើតដែរ នេះមានន័យថា ប្រសិនបើ *អវិជ្ជា*អាចត្រូវបានលុបបំបាត់ទាំងស្រុងនោះនឹងឈានទៅដល់ការឈប់មាន*កំណើត*និង *មរណៈ*។

ដោយមានការពន្យល់ពី*ប្រភពដើម*នៃ*វត្ថុរូបធាតុចំណង់ខួរក្បាល* និង*ការរំជួលចិត្ត* របស់*មនុស្ស ព្រះពុទ្ធសាសនា* មានបំណងពន្យល់ពី *ការប្រែប្រួល*នៃ *ជីវិត* ដែលជា *វដ្តបន្តគ្នាមួយ*នៃ*ភាវៈ*និង*ការកកើត* (be-coming) ។ ដំណើរនេះមានលក្ខណៈជា *ទុក្ខ* (unsatisfactory) ។ ដូច្នេះបញ្ហានេះបង្ហាញច្បាស់ថាសូម្បីតែ*សមិទ្ធផល* នៃ *ការរីកចម្រើន* ខាង *បច្ចេកវិទ្យា* ដ៏ខ្ពស់បំផុតនៃ*ពិភពទំនើបនេះ* នៅតែជាប្រធានបទចំពោះ*ច្បាប់សកលនេះ* ឬ*ព្រះធម៌* ។ *ជីវិតខ្លួនវា* គឺជា*ប្រធានបទ* ចំពោះ *ច្បាប់នេះ*។ *គ្មានភាវៈណា* អាចជៀសផុតពី *ច្បាប់នេះ*បានទេ ។

ដូច្នេះចេញពីដំណាក់កាលនេះ *ព្រះពុទ្ធ* ទ្រង់បានវិភាគអំពី *សភាពភាវៈបច្ចុប្បន្ន* ហើយស្វែងរក*វិធីមួយ* ដើម្បីបញ្ចប់នូវ *ទោមនស្សភាព* ហើយនិង*ភាពមិនស្ថិតស្ថេរ* នៃ*គ្រប់វត្ថុដែលបានតាក់តែងឡើង*ទាំងអស់ ។ ហេតុនេះ*ទ្រឹស្តី* របស់ព្រះអង្គមានលក្ខណៈ *ច្បាស់លាស់ណាស់* ។ វាមិនមែនជា*ទ្រឹស្តី* ដែលគេត្រូវរត់គេចចេញដោយ*ភ័យខ្លាច* ដោយសារតែ *ខ្វះសេចក្តីក្លាហាន* និង*ការខិតខំប្រឹងប្រែង* របស់*មនុស្ស*ទេ ។ វាជាវិធីស្វែងរកដំណោះស្រាយបញ្ហាហើយ វាជាវិធីយល់នូវរបៀបគេចចេញពី*ស្ថានភាពគ្រោះថ្នាក់*។ *ស្ថានភាពបែបនេះ*តែងតែមានវត្តមាននៅលើលោកយើងនេះនៅពេលនេះ និងពេលខាងមុខពួកវាអាចត្រូវបានគេពិពណ៌នាបានយ៉ាងល្អបំផុតអំពី*ការប្រើការអធិប្បាយជារូបាធិដ្ឋានមនុស្សណា* ដែលត្រូវ *ភ្លើងឆេះ* (enveloped) អាចរត់គេចបានតែត្រឹមតាមរយៈការគេចផុតចេញពីវាប៉ុណ្ណោះ ហើយមិនមែនអត់ទ្រាំនៅក្នុង វានោះទេ ។ វិធីដើម្បីរស់នៅគេចផុតពី *ទឹកជំនន់* ឬ *ឆ្លងទន្លេ* ដោយប្រើក្បូន ឬរបស់អណ្តែត លើទឹកដើម្បី*សុវត្ថភាព*។ វិធីដើម្បីយកឈ្នះលើ *ពស់* និងសត្វសាហាវផ្សេងៗបាន ។

ដូច្នេះ *ភ្លើងកំហឹង* ត្រូវជៀសវាងហើយលុបបំបាត់វាដោយ*សេចក្តីស្រឡាញ់*។ *ទឹកជំនន់* នៃ *ឧបាទាន* ត្រូវយកឈ្នះដោយ *ការលះបង់* (detachment) ហើយ *ទន្លេ* នៃ *សំសារៈ* “samsara” ត្រូវឆ្លងដោយ*ការសំអាតចិត្តមិនបរិសុទ្ធ*។ *សេចក្តីឈឺចាប់* ដោយ *ការភ័ន្តច្រឡំ* អាចត្រូវលុបបំបាត់ ដោយការអភិវឌ្ឍន៍ *គុណភាពយល់ដឹង*។ នៅក្នុងការមើលឃើញដែល *ព្រះពុទ្ធ* ទ្រង់បានបង្រៀននេះគេមិនត្រូវប្រកាន់យកនូវ*អច្ចន្តភាព* (extreme) នោះទេ ប៉ុន្តែគេត្រូវដើរតាម *វិធីប្រតិបត្តិវិចារណញ្ញាណ* ដែលជា*ផ្លូវកណ្តាល*។ ដើម្បីរក្សានូវ*អច្ចន្តភាពទុក្ខមួយ* ឬ *អច្ចន្តភាពវិករាយ*ផ្សេងៗទៀតអាចនឹងនាំ *ភាវៈ* ទៅរក*គ្រោះថ្នាក់* បាន ។ *ភាពគ្រោះថ្នាក់ស្មារតីនេះ* នៅតែជា*លក្ខណៈទូទៅ* នៅក្នុង*ពិភពទំនើប*។ វាមិនកម្រិតទៅលើ*សម័យបុរាណ*នោះទេ ហើយ

*វិទ្យាសាស្ត្រ*និង*បច្ចេកវិទ្យាទំនើប*មិនអាចយកឈ្នះលើវាបានទេព្រោះវាទាក់ទងនឹងផ្នែក*ស្មារតី* មិនមែនទាក់ទងនឹងផ្នែក*សម្ភារៈ*ទេ។

អាស្រ័យហេតុនេះ *ផ្លូវពិបាក* និង *ពិតប្រាកដ* នោះគឺ *ផ្លូវកណ្តាល*។ នេះគឺជា *មាគ៌ាត្រឹមត្រូវ* ឬគេអាចហៅបានម្យ៉ាងទៀតថា *អរិយមគ្គ៨*។ វាគឺជាដំណោះស្រាយមួយចំពោះ *បញ្ហា* របស់ *មនុស្សយើង*។ វាមាន *គុណធម៌៨*ដែលរៀបចំជា *បីប្រភេទ* គឺ *សីលសមាធិ* និង *បញ្ញា*។ នៅក្នុង*សីល*ត្រូវបានចាត់ជាក្រុមរួមមាន *សម្មាវាចា សម្មាកម្មន្ត សម្មាអាជីវៈ*។ នៅក្នុង *សម្មាធិ* ត្រូវបានចាត់ជាក្រុមរួមមាន *សម្មវាយាម សម្មាសតិ សម្មាសមាធិ*។ នៅក្នុង *បញ្ញា* ត្រូវបានចាត់ជាក្រុមរួមមាន*សម្មាទិដ្ឋិ សម្មាសង្កប្បៈ*។ ការយល់ច្បាស់អំពីបញ្ហានេះ នឹងនាំឱ្យទទួលបាននូវ *ព្រះនិព្វាន*។

នៅក្នុងដំណាក់កាលនេះគេលើកជាសំណួរថា ហេតុអ្វីបានជា *មនុស្ស* ចង់បដិសេធ *ខ្លួនគេ* ឱ្យចេញផុតពី *វត្ថុប្រសើរបំផុតនានា*នៅក្នុង*ជាតិនេះ* ពីព្រោះ *អរិយមគ្គ៨* នេះពិបាកប្រតិបត្តិតាមឬ ? ហេតុអ្វីបានជាពួកគេមិនរីករាយជាមួយ នឹង*សេចក្តីរីករាយ* នៅលើលោកនេះប្រកបដោយ *សុភមង្គលសព្វយ៉ាង*របស់វា ? ពីព្រោះបន្ទាប់ពី *ស្លាប់* តើវាមានបញ្ហាអ្វីដែលអ្វីមួយកើតមានឡើងចំពោះអ្នកណាម្នាក់ ? តើនរណាដឹង ? តើនរណាអាចប្រាប់បាន ? កាលពីដើមដំបូង*មនុស្ស* ជា*សត្វសង្គមមួយ*។ គេជា*សត្វមានវិចារណញ្ញាណ*ពាលគឺជា *ក្រុមមួយប្រភេទ* ដែលបានជម្រុញឱ្យ *ចំណេះវិជ្ជា* ដ៏ពេញលេញរបស់វាគ្របដណ្តប់លើ *បរិស្ថាន* របស់វាទាំងក្នុង *លំហ* និងក្រៅ*លំហ*។ នៅក្នុង*សង្គមបែបនេះមនុស្ស*មិនអាចរស់នៅដោយ*ខ្លួនគេ* បានទេ។ គេត្រូវតែរស់ នៅជាមួយ*គ្រួសារគេក្រុមរបស់គេ*។ ហើយ*ជីវិត*អាចនឹងមិនមាន *សុភមង្គល* ដោយរៀបរយនោះបានទេប្រសិនបើ *មនុស្សម្នាក់ៗ*រស់នៅក្នុង*សេចក្តីភ័យខ្លាចចំពោះគ្នា* នោះ។

អាស្រ័យហេតុនេះ *ក្រមសីលធម៌* មានសារៈសំខាន់ណាស់សម្រាប់ *មនុស្ស* ដើម្បីរស់នៅដោយ*សន្តិភាព*នៅក្នុង*សង្គម* របស់គេ។ សព្វថ្ងៃនេះ*គុណធម៌*ដែលមានច្រើនបំផុតនៅក្នុង*ស្មារតីភាវៈរស់ទាំងអស់*នោះគឺជា*ក្រមសីលធម៌*ដែលបានសម្តែងដោយ*ស្ថាបនិកសាសនានានា*។ហើយជាងនេះទៅទៀត*ពិភពលោក*បានយល់ដឹងពី*គ្រោះថ្នាក់* ដែលប្រឈមមុខនឹង *កំណើនប្រជាជនទីក្រុង*ព្រោះតែ*ភ័យខ្លាច*នឹង *សង្គ្រាមពូជសាសន៍និយម* *វិសមភាព* និង*ភាពក្រីក្រ*។ បញ្ហាទាំងនេះមានអន្តរទំនាក់ទំនងគ្នា ដែលគេរកឃើញហើយដែលពិបាកបែងចែក *អំពើអាក្រក់មួយ* ចេញពី *អំពើអាក្រក់ផ្សេងៗទៀត*។ *មនុស្ស* និយាយអំពី*សន្តិភាព* ប៉ុន្តែពួកគេមិនមែនមិនពេញ

ចិត្តនឹង*សង្គ្រាម* ហើយនិងទទួលយកនូវ *ការរស់* នៅនោះទេ។ *ជីវិត* ជា*អំណោយដ៏ថ្លៃថ្លា* របស់ *ធម្មជាតិ*។ នៅក្នុងលក្ខខណ្ឌនៃ*ធាតុជីវិត* មានភាពខុសគ្នាបន្តិចបន្តួចរវាងប្រភេទទាំង២នេះ។ ដូច្នេះវាមានលក្ខណៈលាក់កំបាំងក្នុងការនិយាយពី *សន្តិភាព* ដោយមិននិយាយពីការវៀរចាកពីការ ទទួលយកនូវទម្រង់ណាមួយនៃជីវិត។ ដូចនេះតើហេតុអ្វីបានជា *មនុស្សលោកទាំងអស់* ត្រូវរាប់បញ្ចូល*ទ្រឹស្តីសន្តិភាព* ដើម្បីការពារទប់ស្កាត់ទុក្ខ? តើវាព្រោះតែ*មនុស្ស* គឺជា*សត្វថ្នាក់ខ្ពស់* ហើយនិង*ស្ញប់ស្ញែង*តិចជាង*សត្វនានា*ឬ? តើវាព្រោះតែ*មនុស្ស*គ្មានលទ្ធភាព ហើយនឹងរស់នៅដោយសារតែ*ទំប៉ុងមួយ*ឬ? តើវាព្រោះតែ*មនុស្ស* ត្រូវតែខិតខំឬធ្វើឱ្យចម្រើនដោយសុខចិត្តលះបង់ចំពោះ *សត្វ* ដែល*ជាមិត្តរបស់គេឬ?* បើតាម ផ្លូវចិត្តនេះគឺជាការអះអាងដូចគ្នាដែលជះឥទ្ធិពលទៅលើ*គំនិតអ្នកដឹកនាំប្រទេស* ដែលព្យាយាម លុបបំបាត់ *ស្មារតីអ្នកដឹកនាំខ្សោយៗ* ពោលគឺ *អ្នកខ្លាំងជាង* និង*អ្នកខ្សោយជាង* (the less strong) នេះឯង។ វាជា*ច្បាប់ព្រៃច្បាប់*នៃ*ការរស់នៅ* ដោយសមរម្យបំផុតនៅក្នុងលក្ខខណ្ឌ *អំណាច* *រូបសាស្ត្រ* និង *គីមីសាស្ត្រ* និង *ជីវសាស្ត្រ*។

វាដូចគ្នាទៅនឹងគុណធម៌ផ្សេងៗទៀតដែរ ពោលគឺ វៀរចាកនូវការប្រព្រឹត្តិខុសក្នុងកាម វៀរចាកការភូតកុហក និងវៀរចាកការសេពគ្រឿងស្រវឹង។ នៅពេលដែលសង្គមវិវត្តន៍និងនៅពេលដែលតម្លៃសីលធម៌មានសារៈសំខាន់សីល៥ នឹង ផ្តល់នូវវិធីរស់នៅសម្រាប់មនុស្សនៅក្នុងសង្គមនាពេលបច្ចុប្បន្ននិងទៅអនាគត។ សត្វដែលមានវិចារណញ្ញាណត្រូវតែបោះបង់ចោលនូវវិធីរស់នៅអសីលធម៌ដើម្បីរស់នៅស្រុះស្រួលគ្នាក្នុងសង្គមរបស់គេ។ អ្នកខ្លះទទួលយកនិងសម្រេចបានមាគ៌ាសីលធម៌ឆាប់ជាងអ្នកផ្សេងៗទៀត។ អ្នកខ្លះសម្រេចបានមួយចំនួនអ្នក ខ្លះសម្រេចបានទាំងស្រុង ប៉ុន្តែនៅចុងបញ្ចប់មនុស្សនឹងទទួលយកអំពើសីលធម៌គ្រប់ៗគ្នា។ ធ្វើបែបនេះមនុស្សអាចរស់នៅប្រកបដោយគុណធម៌សមរម្យ។

អ្វីដែលមនុស្សប្រាថ្នាចង់បាន គឺសុភមង្គល។ មនុស្សដែលជាសត្វគួរតែផ្លាស់ប្តូរទៅជាមនុស្សដែលមានសីលធម៌។ គ្រប់ជាតិសាសន៍ទាំងអស់និយាយពីសន្តិភាព ហើយមនុស្សគ្រប់រូបនៅក្នុងចិត្តរបស់គេចង់បានសន្តិភាពសម្រាប់ខ្លួនគេ។ ប៉ុន្តែអ្នកដែលនៅជិតឆ្ងាយចង់ បានដែរ ឬទេ ? អ្នកដឹកនាំនិយាយឡើងស្អកក និងស្រែករកសន្តិភាពតាមរយៈគោលនយោបាយរបស់គេ។ ប៉ុន្តែគុណធម៌នេះវាកើតឡើងក្នុងចិត្តរបស់បុគ្គល គ្មានមនុស្សឬប្រទេសណាអាចសង្ឃឹមថាមានសន្តិភាព នៅក្នុងសហគមន៍នៅផ្ទះឬនៅបរទេសទេ។ វាជាសញ្ញាណគួរឱ្យ សប្បាយរីក

វាយក្នុងការឃើញពីលក្ខណៈយល់ដឹងក្នុងចិត្តគំនិតរបស់មនុស្សដែលកំពុងវាយប្រហារ បង្ហូរឈាមគ្នាយ៉ាងឃោរឃៅនិងប្រទេសដែលមានអាវុធប្រល័យលោក។ ជាមួយនឹងការយល់ បញ្ហានេះគុណធម៌ផ្សេងៗទៀតដូចជា មេត្តា ករុណា មុទិតា ក៏នឹងរីកចម្រើនឡើងដែរ។ មនុស្សអាចមានសន្តិភាពពេញលេញ និងស្រឡាញ់សន្តិភាពនៅពេលណា ដែលគេបានសម្រេចនូវគុណធម៌ទាំងនេះនិងនៅពេលដែលគេយល់ច្បាស់និងអនុវត្តពួកវា។ខណៈនោះគេខិតកាន់តែជិតដល់ការយល់ដឹងច្បាស់លាស់អំពីសុភមង្គលផ្លូវចិត្តនៅក្នុងលោកនេះនិងបរលោក។

**ការប្រៀនប្រដៅរបស់ព្រះពុទ្ធ** (The Perfect State of Buddha's Message)

ឥឡូវនេះគេអាចសួរសំណួរថា ហេតុអ្វីបានជាយើងនិយាយអំពីបញ្ហានេះនៅពេល ដែលមនុស្សបានកើតដល់ទីបញ្ចប់ដោយ គ្មានដំណោះស្រាយពីអង្គការណាមួយនៅក្នុងពិភពលោក ? និយាយឱ្យខ្លីទៅហេតុអ្វីបានជាទុទិដ្ឋិនិយមបែបនេះ ? តើមានពិភពលោកមួយនៅឯនាយឬ? តើវាជាធម្មជាតិនៃពិភពលោកអ្វី ? ចម្លើយសាមញ្ញគឺថាមានឋានសួគ៌ និងឋាននរក។ រឿងនេះមិនមែនជាចម្លើយចុងក្រោយទេនៅក្នុងព្រះពុទ្ធសាសនា។ មនុស្សមិនអាចឈប់កកើតទេដរាបណាគេទទួលបាននូវសភាពល្អនៃសុភមង្គលផ្លូវចិត្ត។ គេអាចទទួលបានសុភមង្គលផ្លូវចិត្តដោយសម្អាតចិត្តកុំឱ្យមានការប្រមាថ រាគៈ(*raga*) ទោសៈ(*dosa*) និងមោហៈ(*moha*)។ គេអាចទទួលវាបានក្នុងពិភពលោក នេះតាមរយៈអ្នកទាំងឡាយណាដែល បានកំពុងប្រមូលសភាពផ្លូវចិត្តដោយឈានទៅរកសុភមង្គលផ្លូវចិត្ត។ វាអាចស្ថិតនៅក្នុងរយៈពេលកំណត់មួយក្នុងអំឡុងពេលកកើតនៅថ្ងៃណាមួយការកកើតនឹងឈប់។ តើវាកកើតឡើងដូចម្តេច ? ហើយវាដំណើរការដូចម្តេច? អំពើរបស់គេអាចល្អឬអាក្រក់កុសលឬអកុសល។ គំនិតរបស់គេអាចរីកចម្រើនឬមិនរីកចម្រើន។ ការទទួលរបស់គេអាចលឿនឬយឺត។ ភារៈបន្តនូវជាតិ និងចាប់ជាតិជាថ្មីនៅទីនេះឬកន្លែងណាផ្សេងអាស្រ័យទៅលើអំពើរបស់គេផ្ទាល់ (*kar-ma*)។ យោងតាមច្បាប់កម្មផលភារៈត្រូវបានចាប់កំណើតជាថ្មីក្នុងវាលវដ្តសង្សារ(samsara)។ការបន្តជីវិតការបន្តគំនិតនិងរូបសភាពប្រែប្រួលផ្អែកស្មារតីនេះអាស្រ័យដោយកម្លាំងកម្ម និងផលដែលបានបង្កើតភារៈឡើងវិញក្នុងជីវិតជាបន្តបន្ទាប់។ ដំណើរការធ្វើចិត្តឱ្យបរិសុទ្ធគួរតែបន្ត។ ដំណាក់កាលទទួលបាននូវផ្លូវអារម្មណ៍គួរតែអភិវឌ្ឍរហូតដល់គំនិត មនុស្សស្អាតល្អ និងគេក្លាយជាមនុស្សល្អ និងទទួលបាននូវសន្តិភាពគឺ *ព្រះនិព្វាន*។

## ៤-ព្រះពុទ្ធសាសនានិងបញ្ហាបច្ចុប្បន្ន? (Buddhism and Problems of The Modern Age)

By. Dr. G. P. Malalasekera and ( *សូមមើលបណ្ឌិត**ខ្លូត ធីតា** មូលដ្ឋានគ្រឹះសីលធម៌សាកលលោក បោះពុម្ពលើកទី៧ ទំព័រ១៧៥-២០០ ដែលបកប្រែ នៅថ្ងៃ ទី០៩ ខែវិច្ឆិកា ឆ្នាំ ២០០០ ពីសៀវភៅព្រះតេជព្រះគុណ បណ្ឌិត ក.ស្រីធម្មានន្ទក្នុងឋានៈព្រះអង្គ ជាចៅអធិការនៃពុទ្ធិកមហាវិហារព្រះតេជព្រះគុណអង្គនេះ មានព្រះនាមប្រជាប្រិយល្បីល្បាញ នៅក្នុងពិភពពុទ្ធសាសនា ដោយ ឈន អៀម រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា* )

*ព្រះពុទ្ធសាសនា* បានដាក់*ការសង្គ្រោះ* ឬ *និព្វាន* ទាំងស្រុងទៅលើ *ការឈានចាប់បានរបស់មនុស្ស*។ តែទោះជាយ៉ាងណាក៏ដោយ *ការសង្គ្រោះ* ឬ *និព្វាន* នេះមិនបានរត់ មករកគេជា*អំណោយ* មកពីក្រៅ*ខ្លួនគេ*នោះទេ ។គេត្រូវតែយកឈ្នះលើវា ។ គ្មាននរណាម្នាក់ដែលស្វែងរកខ្លួនគេហើយព្យាបាលការឈឺចាប់របស់គេមកពី *តម្លៃខ្ពស់បំផុត* នោះទេ ។ ម្យ៉ាងវិញទៀត *ព្រះពុទ្ធសាសនា*គ្មានកន្លែងសម្រាប់*អ្នកជួយជីវិត* ដែលជួយខ្លួនគេរួចផុតពី *បាបកម្ម* នានារបស់អ្នកដទៃហើយទទួលបានចំពោះវានូវ *បាបកម្ម* តាំងពីពេលនោះៗទេ ។

**ទេវៈ** (Devas)

*ព្រះពុទ្ធសាសនា* បានទទួលយក *អត្ថិភាពទេពតាជាច្រើនប្រភេទ* ដែលគេនិយមឱ្យហៅថា *ទេវៈ* (devas) ឬ *ទេពតា* ដែលមាន *រស្មី* (radiant ones) ។ តែទោះជាយ៉ាងណាក៏ដោយ *គ្មាន ទេវៈណាមួយ* ក្នុងចំណោមនេះមានលក្ខណៈជា *អចិន្ត្រៃយ៍* និង *គ្មានទីបញ្ចប់* នោះទេ ។ *ទេវៈទាំងនេះ*តែងសង្កេតឃើញមាន *អត្ថិភាព* ទៅតាមកម្រិតខុសៗគ្នា ។ *ទេវៈខ្លះ*មាន*ជីវិត*វែងជាង*ទេវៈដទៃ* ទៀត ។ បើទោះជា*គ្មានទេវៈណាមួយ* ក្នុងចំណោមនេះ *គ្មានអំណាចច្រើន* (almighty) ក៏ដោយ ក៏*ទេវៈមួយចំនួន*ត្រូវបានគេជឿ ប្រកបដោយ*ឫទ្ធានុភាពក្រៃលែង* ហើយការពេញចិត្តរបស់ពួកគេអាចត្រូវបានគេយកឈ្នះ បើទោះជាមិនតាមរយៈ *អ្នកបន់ស្រន់* ឬ *ការបូជាខ្លួន* ក៏ដោយ ។ បើតាម*ព្រះពុទ្ធសាសនាអ្នកជឿ* អាចចែករំលែក*បុណ្យកុសល* និង*គំនិតជ្រះថ្លា* នៃ*សេចក្តីមេត្តា* ចំពោះ *ទេវៈទាំងនោះ* ដើម្បីសុំឱ្យជួយការពារពួកគេ ។

*អត្ថិភាព*របស់ពួកគេទៅលើ *ពិភពទេវៈ* ហើយនិង *ប្រវែងជីវិត*របស់ពួកគេនៅទីនោះវាពឹងផ្អែកទៅលើ*អំពើល្អ* ដែលពួកគេបានធ្វើនៅក្នុង*ជាតិមុន*ហើយនិងនៅពេល" *ការសន្សំបុណ្យ* (store of merit)" ត្រូវបានបញ្ចប់ពួកគេមិនសម្តែងឡើងមកពី *ទីបរមសុខ* របស់ពួកគេនោះទេ ហើយនិងចាប់កំណើតនៅទីដទៃទៀត ។ *ទេវៈ*ជាច្រើនគឺជា*សាវ័ក* របស់*ព្រះពុទ្ធ* ដែល*ទេវភាព*

របស់ពួកគេៗដឹង។ ពួកគេមិនមានសំណាងដូច *មនុស្សលោក* ទេ ពីព្រោះនៅក្នុង*ពិភពមនុស្ស* គ្មានឱកាសច្រើនសម្រាប់ *កសាងអំពើល្អ* ជាងនៅក្នុង*ស្ថានទេវៈ* នោះទេ។ *មនុស្ស*អាច *"ចែករំលែក" បុណ្យកុសល*ដែលពួកគេសម្រេចបានតាមរយៈ*អំពើល្អ*របស់ពួកគេចំពោះ*ទេវៈ* នានា។

**ការចែករំលែកបុណ្យកុសល** (Sharing of Merit)

*លទ្ធិ* ស្តីអំពី *"ការចែករំលែកបុណ្យកុសល"* គឺជាផ្នែកមួយនៃការបង្រៀនរបស់ព្រះពុទ្ធ។ *ការចែករំលែកបែប* នេះត្រូវកើតមានឡើងដោយ *អ្នកធ្វើអំពើល្អ*ដែលដោះស្រាយថា "អ្នកណាធ្វើ យ៉ាងណាទទួលផលបែបនោះ (so and so)" អាចរួមបញ្ចូលជាមួយនឹង *"បុណ្យ"*របស់ *អ្នកធ្វើ ល្អ*របស់គេបាន។ *ការចែករំលែក* មានប្រសិទ្ធភាពដោយជាក់លាក់នៅពេល *អ្នកទទួលមានបំណង* បានយល់ដឹងពី *អំពើល្អ* ត្រេកអរនៅក្នុង *អំពើបុណ្យ* នោះដែរ។ នេះគេឱ្យឈ្មោះថា *អនុមោទនា (anumodana)*។ *ការអនុមោទនា* អាចត្រូវបានគេធ្វើឡើងបើទោះ ជាមិនបានដឹងអំពី *អ្នកធ្វើអំពើ* ក៏ដោយ។ ការធ្វើសនិទានកម្ម (rationalization) នៅពីក្រោយខ្នងនៅត្រង់ថាពេលអ្នកណាម្នាក់រកឃើញ *សេចក្តីត្រេកអរ* នៅក្នុង *អំពើល្អ*របស់អ្នកម្នាក់ទៀតទោះជា *អ្នកនោះ*ដឹង ឬមិនដឹងក្តី (with or without the knowledge of the latter) ពោលគឺ *គំនិតផ្ទាល់* របស់គេ*ស្អាតនិងបរិសុទ្ធ* ហើយនេះបង្កើតឡើងនូវ*ផលដ៏គួររីករាយផ្ទាល់* របស់វា។ *ការអនុមោទនា* អាចត្រូវបានធ្វើដោយ*អ្នកណាម្នាក់*ដែលជា*អំពើ* ប្រកបដោយ*មនសិការ*មួយ។ *"ការចែករំលែកបុណ្យកុសល"* គឺជា *អំពើល្អ* ដោយខ្លួនឯងដោយហេតុដូច្នេះ ហើយបានជាត្រូវ បន្ថែមទៅលើ *"បុណ្យកុសល"* នៃ*អំពើល្អ*ដែលគេបានធ្វើរួចហើយ។ *"អ្នកដែលចែករំលែក"* មិនត្រឹមតែមិនបាត់បង់អ្វីនោះទេ ប៉ុន្តែថែមទាំងបានបន្ថែមទៅលើ *គំនរបុណ្យកុសល* របស់គេនោះទៀតផង។

មាន *ទេវៈ* ឬ *ទេពតា*ដែលមានឫទ្ធានុភាពពិសេសៗក្រៃលែង ដែលគេគិតថាជា *អ្នកការពារព្រះពុទ្ធសាសនា*។ *ប្រទេស* កាន់ *ពុទ្ធសាសនាមួយៗ*មាន *ទេវឋានផ្ទាល់* របស់ខ្លួន ដែលមាន *ដែនឥទ្ធិពល*របស់វាមានលក្ខណៈតំបន់ទូលំទូលាយ បើទោះជាមាន*ទេពតាបីបួនអង្គ* ដែលអាច ត្រូវបានគេគោរពបូជានៅកន្លែងណាមួយហើយក៏ដោយ។ *ទេវតា* រក្សាតំបន់ជាច្រើនត្រូវបាន គេទទួលយកមកពី *អ្នកកាន់សាសនាដទៃ* (the followers of other faiths) ជាពិសេសមកពី *សាសនាហិណ្ឌូ*នៅក្នុងករណីទីឋាន *ថេរវាទ* (Theravada lands)។ នៅប្រទេស *ភូមា* ជាឧបមា *ពុទ្ធសាសនិក*កឃើញពីការពេញចិត្តមួយចំពោះទេពតា *ណាត* (The Nats)ដែលនៅចាំថែរក្សា

លើវាសនារបស់ *ប្រជាជនភូមា*។ម្យ៉ាងវិញទៀត នៅក្នុងប្រទេស *ជប៉ុនព្រះពោធិសត្វផ្សេងៗ* (Buddha Aspirants) ក៏ត្រូវបានគេគោរពបូជាដែរ។

មាន*ស្តូបផ្សេងៗ* (shrines) បានឧទ្ទិសចំពោះ *ទេវភាពទាំងនេះ* ដែលនៅទីនោះ *អ្នកមានជំនឿស៊ុប* ធ្វើការគោរពថ្វាយ*ផ្លែឈើ* និង*ផ្កា* ដែលជា*និមិត្តរូបគោរពបូជា* (the token of homage) ហើយនិងមាន *ចម្រៀង* ច្រៀងលើកសរសើរផងឬក៏*សូត្រ* ហើយនិងសំណើសុំបង្កើតចំពោះ *ការពេញចិត្តរបស់ពួកគេផង ។គ្មានសត្វណាមួយដែលគេត្រូវគោរពបូជានោះទេ។ ទម្រង់នៃការគោរពបូជានេះ* បានទទួលឥទ្ធិពលយ៉ាងខ្លាំងដោយការប្រតិបត្តិនៃ*សាសនាទេវៈ*។ នេះវាឆ្លើយតបទៅ នឹងអ្វីដែល*ព្រះពុទ្ធ* បានមានដិកាពេលព្រះអង្គអះអាងថា នៅពេលមាន *ការ ឈឺចាប់* ឬនៅពេល*ថប់អារម្មណ៍មនុស្ស*បានធ្វើការរៀបចំទៅកន្លែងណាមួយដើម្បីស្វែងរក*ការការពារ*។ ប៉ុន្តែការបំពេញចិត្តនេះគេស្វែងរកនោះវាមានជាប់ខ្វល់ខ្វាយទៅនឹង *កិច្ចការលោកិយ*។ *គ្មានពុទ្ធសាសនិកណាម្នាក់* ដែលមានជំនឿថា *ការគោរពបូជាទេវតា* តែទោះជា យ៉ាងណា ក៏ដោយក៏នៅតែមាន *កម្លាំង* ដដែលដែលនាំទៅរក*ការអភិវឌ្ឍន៍ផ្លូវចិត្តនេះឯង*។

**សទ្ធា/ជំនឿ** (Faith)

សំណួរតែងតែត្រូវបានចោទឡើង ចំពោះអ្វីដែលតម្រង់ទៅពាក្យថា Faith (បាលីថា សទ្ធា) នោះកើតមានឡើងនៅក្នុង *ព្រះពុទ្ធសាសនា* ។ វាអាចជាការមានប្រយោជន៍នៅក្នុងចំណងទាក់ទងនេះដើម្បីរំលឹកឡើងវិញថា នៅក្នុង*អត្ថបទសាសនបញ្ញត្តិបាលីដើម* (the original Pali canonical texts) គ្មានពាក្យណាមួយដែលមានតម្លៃស្មើទៅនឹងស័ព្ទ ‘Budhhist’ នេះទេ។ *មនុស្ស* ត្រូវបានបែងចែកទៅជា*ប្រភេទផ្សេងៗគ្នា* ដោយអនុលោមទៅតាម *កម្រិតអភិវឌ្ឍផ្លូវចិត្ត* របស់ពួកគេ។ ដូច្នេះយើងមាន*មនុស្សធម្មតានោះ*ជា*អ្នកស្រុកម្នាក់*ក្នុងចំណោម "អ្នកប្រជា-ប្រិយច្រើន (puthujjana)" ដូចជា*មនុស្សល្អ*(kalyana-puthujjana) *អរិយបុគ្គល* (ariya) និង*ព្រះអរហន្ត* (arahant) *អត្ថបទ* នេះនិយាយអំពី*មនុស្ស* ដែលធ្វើដំណើរទៅរក*ព្រះពុទ្ធគឺការបង្រៀនរបស់*ព្រះអង្គ (Dhamma) ហើយ និង*អរិយសាវ័ក* (the Sangha) សម្រាប់ជា"*សារណៈ*"។ នៅក្នុង *ព្រះពុទ្ធសាសនា* គ្មានការប្រារព្ធ ធ្វើ "*ពិធីជ្រមុជទឹកលាងបាប* (act of baptism) ជាផ្លូវការនេះទេ បើទោះជាមាន*រូបមន្តគុំរូមួយ* ដែល *ពុទ្ធសាសនិកជន*ប្រើនៅក្នុង*ទីឋានព្រះ ពុទ្ធសាសនា*ដើម្បីសម្តែងឱ្យឃើញពីទង្វើរបស់គេចំពោះ "*ការយកធ្វើជាទីជម្រក*" ដែលគ្រាន់តែមានន័យថា *អ្នកជឿ* ទទួលយក*ព្រះពុទ្ធ* ជា*គ្រូ* ឬជា *មគ្គុទេសក៍* យក*លទ្ធិ* ធ្វើជា*ទស្សនវិជ្ជា* និងជា*មាគ៌ាជីវិត*

របស់គេហើយនិងយក*សង្ឃហ:* [the Sangha (សហគមន៍ សង្ឃ)] ធ្វើជា*គំរូ* នៃ*មាគ៌ាជីវិត* នេះប៉ុណ្ណោះ។

*គុណភាពសទ្ធា* នៅក្នុង*ព្រះពុទ្ធសាសនា*មានន័យ *ការទទួលយក* នៅក្នុង *ជំនឿ* និង*ពុទ្ធិ* នេះថា*ជម្រកទាំងនេះ* មានតម្លៃចំពោះ*ការទទួលយកបែបនេះ*។ "*គ្មានសទ្ធាងងឹតងងុល* ដែលជាប់ទាក់ទងគ្មានករណីចំពោះ *ការជឿ* ឬត្រូវគេធ្វើឱ្យ *វិនាសអន្តរាយ* សោះឡើយ"។ *ព្រះពុទ្ធ* ទ្រង់បានឯកភាពថាមាន *គ្រូប្រដៅ* ជាច្រើនហើយ *មាគ៌ាជីវិត*ជាច្រើនដែលពួកគេបានប្រៀនប្រដៅហើយមាន*អ្នកជឿគ្រូបែបនេះ*ជាច្រើនហើយនិង*មាគ៌ាជីវិត* របស់ពួកគេ។ មនុស្សម្នាក់ៗមាន សេរីភាពទាំងស្រុងក្នុងការជ្រើសរើស គ្មានការដាក់កម្រិតទៅលើ *ស្វ័យភាព* របស់*បុគ្គលម្នាក់ៗ*សោះឡើយនៅក្នុង*ការគោរពនេះ*។ តាមពិតមានករណីជាច្រើនពេល*សាវ័ក* នៃ*គ្រូប្រដៅដទៃៗទៀត* បានបោះបង់ពួកគេចោល ហើយទៅស្វាមីភ័ក្ដ្រចំពោះ *ព្រះពុទ្ធ* ព្រះអង្គបានធ្វើឱ្យពួកគេបាក់ទឹកចិត្តហើយសុំឱ្យពួកគេទាំងនោះ ផ្ដល់បញ្ហាចំពោះគំនិតបន្ថែម។ ពេលពួកគេជំនះបន្ថែមទៀតព្រះអង្គបានផ្ដល់ដំបូន្មានដល់ពួកគេឱ្យបន្តធ្វើ*សេចក្ដីល្អៗ*ចំពោះ *គ្រូដើម* របស់ពួកគេ។

មាន *វគ្គដ៏ល្បីល្បាញមួយ* នៅក្នុង *Kalama Sutta* ជាវគ្គដែលគេតែងតែដកស្រង់ជារឿយៗនៅក្នុងបរិបទនេះគឺជាភស្តុតាងឥតសង្ស័យនៃសេរីភាពជ្រើសរើសនេះ។ វគ្គនេះអះអាងយ៉ាងជាក់លាក់ថា គ្មានអ្វីដែលគេគួរតែទទួលយកដោយត្រឹមតែទៅលើ *មូលបទប្រពៃណី* (the grounds of tradition) ឬ *អំណាច* របស់ *គ្រូ* ឬក៏ព្រោះតែ *ទស្សនៈ* របស់មនុស្សមួយចំនួនធំ មានលក្ខណៈប្លែកៗ ឬផ្សេងពីនេះនោះទេ។ *អ្វីៗសុទ្ធតែត្រូវ ថ្លឹងថ្លែងមើលពិនិត្យផ្ទៀងផ្ទាត់* និង*ធ្វើវិនិច្ឆ័យ*ថា តើវា *ត្រូវ* ឬ *ខុស* នៅក្នុង *ពន្លឺនៃវិនិច្ឆ័យ* (conviction) របស់គេទាំងអស់។ ប្រសិនបើគិតពិចារណាទៅមើលឃើញថា *ខុស* ពួកគេមិនគួរត្រូវបានទាត់ចោលភ្លាមៗនោះទេ ត្រូវទុកពិចារណាបន្ថែមទៀត។ មិនត្រឹមតែមានមន្ទិលសង្ស័យមិនពិចារណាទៅលើអំពើបាបយង់ឃ្នងមួយប៉ុណ្ណោះទេ វាត្រូវបានគេលើកទឹកចិត្តដោយវិជ្ជមានទៀតផង។

**សម្មាទិដ្ឋិ និងមិច្ឆាទិដ្ឋិ** (Right Views & Wrong Views)

*ពុទ្ធសាសនិកជន*មិនមានការកំណត់ន័យជាក់លាក់ចំពោះស័ព្ទ*សម្មាទិដ្ឋិ (sammaditthi)* និងស័ព្ទ*មិច្ឆាទិដ្ឋិ (micchaditthi)*នោះឡើយ។ ពួកគេសំដៅចំពោះ *ទស្សនៈ*ដែលមានលក្ខណៈ*ត្រឹមត្រូវ* ឬ*ខុសឆ្គង*ផ្នែកខាងក្នុងថា តើត្រូវរែកពុនដោយ *ពុទ្ធសាសនិកជន* ឬដោយ*អ្នកដទៃ*។ គ្មានទស្សនៈណាមួយគេត្រូវគិតពិចារណាយ៉ាងពិសិដ្ឋនិងទៅហួសពី*សំណួរ*។ *សេរីភាពគំនិត*គឺជា

បញ្ហាមួយនៃ*សេចក្តីថ្លៃថ្នូរ*របស់*មនុស្ស*។ សូម្បីតែ *សុពលភាព* នៃ *អំណះអំណាងផ្ទាល់*របស់ *ព្រះពុទ្ធ* ក៏អាចត្រូវបានគេចោទសួរដែរ។ *ព្រះពុទ្ធ*មិនអះអាងអំពី *អាជ្ញា* សម្រាប់ *លទ្ធិរបស់*ព្រះអង្គលើកលែងតែ*បទពិសោធន៍ផ្ទាល់ខ្លួនផ្ទាល់*របស់ព្រះអង្គ។ *អំណាចពិត*គឺជា*អំណាច* ដែល *សច្ចភាពខ្លួនឯង*មានគឺជា *សច្ចភាព*ដែលបង្ហាញពី*ភាពត្រឹមត្រូវខ្លួនឯង*នោះ។ *សច្ចភាព* បែបនេះមាន *កម្លាំងធំធេង* សូម្បីតែ*អំណាច* នៃការសម្តែង *អព្ភូតហេតុ* (*saccakiriya*) ដូចមានបង្ហាញ ជូននៅក្នុងរឿង Jataka ជាច្រើនក៏ដោយ ដែលជាផ្នែកមួយនៃ *មតិកវប្បធម៌ព្រះពុទ្ធសាសនា*។ ដូច្នេះ *សទ្ធា* គួរតែត្រូវបកស្រាយកាន់តែប្រសើរដូច*ការទុកចិត្ត* (confidence) *ការទុកចិត្ត* (trust) ឬ *ជំនឿស៊ប់* (conviction) ជាជាង*ជំនឿ* (faith) នេះ ពីព្រោះ*ជំនឿ*នេះមានន័យលាក់កំបាំងគេរកមិនឃើញនៅក្នុងបញ្ញត្តិ *សទ្ធា* (Saddha) នេះទេ។

**សុភមង្គលនៃគ្រប់ភាវៈទាំងអស់** (Happiness of All Being)

*មាគ៌ាជីវិត* ដែល *ព្រះពុទ្ធ* បានបង្រៀននោះ ដែលពេលខ្លះគេបានស្នើឡើងនោះមិនមានន័យជាក់លាក់សម្រាប់ តែអ្នកទាំងឡាយណាដែលរស់នៅៗក្នុង *ជីវិតជាបព្វជិត*នោះទេ។ វាជាការត្រឹមត្រូវណាស់ថា *ភាពទាក់ទងខាងផ្លូវចិត្ត* (spirituality) នៃ *ការគ្មានឧបាទាន* ដែលគេគួរតែអភិវឌ្ឍដើម្បីសម្រេចបាន *និព្វាន* នោះអាចសម្រេចបានយ៉ាង រហ័សបំផុតក្នុងសភាពជា *ព្រះសង្ឃ* ច្រើនជាងក្នុងសភាពជា *គ្រហស្ថ*។ ប៉ុន្តែវាជាការមិនត្រឹមត្រូវដែលត្រូវនិយាយថា *សេរីភាពពេញបរិបូណ៌* អាចត្រូវបានគេសម្រេចបានតែក្នុងសភាពជា *ព្រះសង្ឃ* ហើយមិនមែនក្នុងសភាពជា *គ្រហស្ថ* ដែលរស់នៅក្នុង *ជីវិតជាអ្នកមានគ្រួសារ* នោះ។ *ធម្មទេសនា* របស់*ព្រះពុទ្ធ* ដែលគេបានប្រមូលពិនិត្យផ្ទៀងផ្ទាត់ដោយ *ក្រុមប្រឹក្សាច្បងៗ* (the council of Elder) ដែលបានជួបប្រជុំគ្នាបន្ទាប់ពី*ព្រះពុទ្ធ* យាងចូលនិព្វានទៅមាន*ធម្មទេសនា* ជាច្រើនដែលបាននិយាយពី*ព្រះសង្ឃ* ពីព្រោះនោះគឺពួកអ្នកដែលធ្វើឱ្យអ្នកស្តាប់ភ្លាមៗរបស់ទ្រង់កើតឡើងយ៉ាងសំខាន់។ ប៉ុន្តែក៏មាន *ធម្មទេសនាជាច្រើន* និយាយពី*គ្រហស្ថ* ដែរ។ ជួនកាលធម្មទេសនាទាំងនោះក៏បាននិយាយពី*បុគ្គលតែម្នាក់*។

នៅក្នុង *ធម្មទេសនាដំបូងបំផុត* របស់ព្រះអង្គ ដែលគេឱ្យឈ្មោះថា *ការស្ថាបនាវិន័យត្រឹមត្រូវ* (Establish-ment of the Rule of Righteousness) ព្រះអង្គបានអភិវឌ្ឍគំនិត អំពី *សុខុមាលភាព* និង*សុភមង្គល* នៃ*គ្រប់ភាវៈទាំងអស់* ដែលគ្មានរើសអើងចំពោះអ្នកណាមួយឡើយថា "ដោយសារតែ *សេចក្តីមេត្តា* ចំពោះ *ពិភពលោកដោយមិនរើសមុខ* (the but world)"។ វាជា

លើកដំបូងនៅក្នុង *ប្រវត្តិសាស្ត្រមនុស្សលោក* ដូចយើងបានដឹងស្រាប់ថា *គំនិតចំពោះ* *អំពើល្អទូទៅមួយ* ឬចំពោះ *អំពើល្អមួយ* ត្រូវបានគេគិតទុកក្នុងចិត្តនោះ ពោលគឺការមានឥទ្ធិពលមិនត្រឹមតែទៅលើ *មនុស្សធម្មតាម្នាក់*នោះទេ ប៉ុន្តែក៏មានឥទ្ធិពលទៅលើ *មនុស្សទូទៅ* នៅលើពិភព លោក ជាពិសេសចំពោះ *សត្វលោកទាំងមូល* (the inhabitant of the universe) តែម្តង។ វាក៏ត្រូវគេបកស្រាយផងដែរថាជា *ការបង្រៀនមួយ* ដែលផ្តល់នូវលទ្ធផលជាច្រើននៅក្នុង *ជាតិនេះ*។ ដោយគ្មានការបង្អែបង្អង់ឡើយមានន័យថា គ្រប់ពេលទាំងអស់ពោលគឺការពិនិត្យសង្កេតទោះចង់ក្តី (inviting) មិនចង់ក្តី (verifiable) ។

**សាមគ្គីភាពរបស់មនុស្សជាតិ** (Unity of Mankind)

*ព្រះពុទ្ធ* ទ្រង់បានបង្រៀនមិនត្រឹមតែពី *ភាពចាំបាច់* នៃ *ដំណើរប្រែប្រួលខាងក្នុង*របស់ *បុគ្គល* ម្នាក់ៗចំពោះ *សុភមង្គល* របស់ *មនុស្ស*តែមួយនោះប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏បានបង្រៀនពី *តម្រូវការ* ចំពោះ *ការប្រែប្រួលខាងក្រៅ*នៅក្នុង*ជីវិតសង្គម* ផងដែរ ។ ដូច្នេះជាឧបមាព្រះអង្គបានសម្តែង ពី*ភាពឯកោ* (oneness)និង *សាមគ្គីភាព* របស់ *មនុស្សជាតិ* *ការមិនរើសអើង* នៃ *ពណ៌សម្បុរ* ឬ *ពូជសាសន៍* ឬ *លក្ខណៈសរីរសាស្ត្រ*ដទៃទៀត ដូចជានៅក្នុងករណីរបស់ *សត្វនានា* ជាដើមបង្កើត ឱ្យមាន*ដំណើរវិវត្តន៍*មួយចំពោះ*ការលុបបំបាត់ប្រព័ន្ធវណ្ណៈ* ដែលរីកសាយភាយនៅក្នុងប្រទេស *ឥណ្ឌា* នៅសម័យព្រះអង្គ។ ដើម្បីចង្អុលបង្ហាញពីគំនិតរបស់ព្រះអង្គអំពី *ភាពឯកោ* របស់ *មនុស្សជាតិ* ព្រះអង្គបានធ្វើការផ្លាស់ប្តូរមិនត្រឹមតែចំពោះ *ស្តេច* និង *ពួកនាយទុន* និង *ស្ត្រីអភិជន* នោះទេ ប៉ុន្តែក៏ចំពោះ*អ្នកក្របំផុតអ្នកសុំទាន* និង*សត្វ* (scavengers) *ពួកចោរប្លន់*និង*ពួកស្រីពេស្យាចារ* ទៀតផង។

ព្រះអង្គបានបញ្ចូលទៅជា *ក្រុមរបៀបរយមួយ* (the Sangha) ដែលព្រះអង្គបានស្ថាបនាឡើង*បុរស*និង*ស្ត្រី* មកពី *គ្រប់កម្រិតសង្គម* ទាំងអស់ដោយមិនគិតពី*ជាតិកំណើត*និង *ប្រភព* នោះឡើយ ។ព្រះអង្គបានជួយផ្គត់ផ្គង់ដល់*អ្នកជម្ងឺ*និង *អ្នកទីទ័លក្រ* លួងលោមចំពោះ *អ្នកភ័យខ្លាច* (the stricken) ហើយនាំយក*សុភមង្គល* មកឱ្យ*អ្នកក្រ*។ គេបាននិយាយថា *មន្ទីរពេទ្យដំបូង* នៅក្នុង*ប្រវត្តិសាស្ត្រ*ត្រូវបានរៀបចំឡើងនៅក្រោម*ការដឹកនាំ* របស់ព្រះអង្គ។ ព្រះអង្គមិនបានគេចព្រះកាយចេញពី*ពិភពលោក* បន្ទាប់ពី*ត្រាស់ដឹងនោះទេ* ព្រះអង្គទ្រង់គង់នៅអស់រយៈពេល *៤៥ព្រះវស្សា* នៅក្នុងចំណោម*ព្រះសង្ឃ* ដើម្បីស្វែងរកអ្នកដែលព្រះអង្គអាចជួយបាន ។

**ប្រជាធិបតេយ្យភាព** (Democracy)

ព្រះអង្គឱ្យតម្លៃយ៉ាងធំធេងទៅដល់ *សិទ្ធិសេរីភាព* របស់ *បុគ្គលម្នាក់ៗ*ពោលគឺ *សេរីភាព* ក្នុង *ការគិត* និង *ការសម្តែងមតិ* ហើយនិង *ឧត្តមភាពប្រជាធិបតេយ្យ*។ ការកំណត់ចំពោះ *ព្រះពុទ្ធសាសនា* មិនមានលក្ខណៈផ្តុយទៅ នឹង*ការបើកចំហ* នោះទេ។ *ក្រុមសង្ឃៈ* ត្រូវបានគេចាត់ទុក ថាជា *ស្ថាប័នប្រជាធិបតេយ្យដ៏មានចំណាស់បំផុត* នៅក្នុង *ពិភពលោក* ហើយក្រុមនេះត្រូវបាន រៀបចំជា*គំរូមួយ*សម្រាប់ *ការរៀបចំគ្រហស្ថ*ដោយមានរួមទាំង *ស្ថាប័ននយោបាយ* ផង។ *រដ្ឋ* ប្រសើរបំផុតដែលបានរៀចំនៅក្នុង *ព្រះពុទ្ធសាសនាគឺ ប្រជាធិបតេយ្យភាព* ដែលបម្រើដល់*សុខុមាលភាពផ្លូវចិត្ត*និង*កាយ* របស់ *មនុស្ស*ដែលធានាដល់ *សេរីភាពផ្ទាល់ខ្លួនសាសនា* និង*នយោបាយ*ក៏ដូចជា *សុវត្ថិភាពសេដ្ឋកិច្ច*ប្រកបដោយការងារពេញលេញផងដែរ។

**សុខុមាលភាពសេដ្ឋកិច្ច** (Economic Welfare)

ការរៀបចំសម្រាប់ *សុខុមាលភាពសេដ្ឋកិច្ច* មានបញ្ជាក់យ៉ាងច្បាស់លាស់ដូចនៅក្នុងផ្នែក *មុខងារ* របស់ *ស្តេច* និង *រដ្ឋ* ដែរ។ *ព្រះពុទ្ធ*ទ្រង់បានសម្តែងថា "នៅពេល *កត្តាសុខុមាលភាពសេដ្ឋកិច្ច* នេះត្រូវបានគេរៀបចំដោយសមរម្យ *មនុស្សទាំងឡាយ* (the inhabitants) បេសកកម្ម ផ្ទាល់របស់គេនីមួយៗដូចតទៅនោះនឹងមិននាំឱ្យប៉ះពាល់ដល់ *រដ្ឋ* នោះឡើយ ពោលគឺ *ចំណូលរដ្ឋ* នឹងកើនឡើង *ប្រទេស* នឹងស្ងប់ស្ងាត់ ហើយនឹងមាន *សុខសន្តិភាព* ហើយ *ប្រជាជនតូចទាប* រីករាយជាមួយគ្នាដូចជា ការរាំច្រៀងជាមួយគ្នាដោយសុខសាន្ត។" *អត្ថបទព្រះពុទ្ធសាសនាមួយ* ដែលមានចំណងជើងថា *Mahavastu* ចែងថា "*ពិភពលោក* ពឹងផ្អែកទៅលើមូលដ្ឋានពីរ *ការទទួលបានទ្រព្យនិងការថែរក្សាអ្វីដែលគេរកបាន*"។ ដូច្នេះដើម្បីទទួលបាន *ទ្រព្យ* ហើយនិងថែរក្សានូវអ្វី ដែលអ្នកបានរកមកសុទ្ធតែនៅក្នុងដែននៃ *ភាពត្រឹមត្រូវ*ទាំងអស់។

**ភាពជាម្ចាស់លើទ្រព្យសម្បត្តិ** (Ownership of Property)

*ភាពជាម្ចាស់នៃទ្រព្យសម្បត្តិសាធារណៈ* ត្រូវបានគេពេញចិត្តជាច្រើនផ្នែកនៅក្នុង *ពិភពលោក* ជាពិសេសនៅទីកន្លែងដែល *គោលការណ៍សង្គមនិយម* ត្រូវបានគេទទួលយក។ ដរាបណាគេមានការយល់ដឹងពី *ការអនុវត្តគោលការណ៍* នៃ*ភាពជាម្ចាស់រួម* ចម្រើនថេរនិងមិនប្រែប្រួលលើកទីមួយនៅក្នុងរបប *កុម្មុយនីស្ត* ឬ*សង្គមនិយម* ជាក់លាក់ មួយគឺគេត្រូវរកឃើញនៅក្នុង*ការគ្រប់គ្រងវិញ្ញាណ* ដែលគ្រប់គ្រងលើ*សណ្តាប់ធ្នាប់*នៃ *សង្ឃៈព្រះពុទ្ធសាសនា* ដែលនៅទីនោះ *ទ្រព្យសម្បត្តិទាំងអស់* ទោះជាមានចលនាក្តី មិនមានចលនាក្តីដែលមាន*តម្លៃសេដ្ឋកិច្ច*

*សំខាន់ណាមួយ* សុទ្ធតែស្ថិតនៅក្នុងជំនឿចិត្តរួមគ្នាដោយគ្មាន *ប្រភេទបង្ខិតបង្ខំណាមួយ*ឡើយ *ជីវិត*នៅក្នុង *សង្គហៈ* គឺជា *ជីវិតរួមមួយ* ដែលពឹងផ្អែកទៅលើ *គោលការណ៍សហប្រតិបត្តិការ* ដោយ *ស្ម័គ្រចិត្ត*។

**ព្រះពុទ្ធសាសនា និងមនុស្សជាតិ** (Buddhism and Mankind)

ចេញអំពីអ្វីដែលគេបាននិយាយរួចមកហើយ គេនឹងមើលឃើញថា *ព្រះពុទ្ធសាសនា*ចាប់អារម្មណ៍យ៉ាងខ្លាំងបំផុត ចំពោះ *ពិភពលោកនេះ* ហើយនិងចំពោះ *ជីវិត*ដែលរស់នៅក្នុងនោះ។ នេះគឺជា*សាសនាមួយ* ដែលមិនបដិសេធពិភពលោក (world-denying religion)។ *ព្រះពុទ្ធ* ទ្រង់បានរៀបរាប់អំពី *ការបង្រៀន* របស់ព្រះអង្គថាជា *Sanditthi-ka* ការបារម្ភជាចម្បងជា មួយនឹង *ពិភពលោកនេះ* នោះគឺការបារម្ភជាមួយនឹង *ជីវិតនេះ*តែម្តង។ សូម្បីតែជាមួយនឹង*សុភមង្គលខ្ពស់បំផុត*ពេលគឺ *សេចក្តីសុខ* ជាមួយនឹង *ព្រះនិព្វាន* គឺគេត្រូវខិតខំប្រឹងប្រែងតស៊ូចំពោះ *ជីវិត*នេះតែម្តង។ វាពឹងផ្អែកយ៉ាងខ្លាំងបំផុតទៅលើ*តម្រូវការពិតប្រាកដ* សម្រាប់*ភាពប្រសើរបំផុតនាពេលបច្ចុប្បន្នបន្ទាន់ជានិច្ច*នេះដែលត្រូវធ្វើឱ្យច្បាស់លាស់ថា*អនាគត*ត្រូវបានត្រួតត្រាសម្រាប់*សុខុមាលភាព*របស់យើង។*អតីតកាល* ត្រូវធ្វើដំណើរទៅហួសមិនអាចវិលត្រឡប់វិញបាន។ មានតែ *បច្ចុប្បន្ន* ទេដែលមានប្រយោជន៍ចំពោះយើងសម្រាប់កសាង *ជីវិត* ឱ្យបានប្រសើរឡើង។ ផ្ទុយទៅវិញ*អនាគត* មិនទាន់ឈានមកដល់នៅឡើយទេហើយអ្វីដែលយើង ត្រូវបង្កើតអំពីវានោះគឺពឹងទៅលើយើងទាំងស្រុង។

*ពុទ្ធសាសនិកជន*មិនបានចាត់ទុក *ពិភពលោក* ថាជា *ពន្ធនាគារមួយ* ដែល *មនុស្ស* ត្រូវរត់គេចចេញហើយរត់ចូលក្នុង *ឋានសួគ៌*នោះទេ។ តាមពិតគេស្វែងរក *ឋានសួគ៌*នៅទីនេះ។ គេមិនមែនជា *អ្នករូបធាតុ* ហើយក៏គេមិនមើលស្រាលលើ *ផលប្រយោជន៍* នៃ*អរិយធម៌សម្ភារៈ* នោះដែរ។ *បញ្ហា* របស់គេមិនមែនជាបញ្ហាចំពោះ *ការជ្រើសរើស* រវាង*ឥន្ទ្រិយារម្មណ៍* និង*ផ្លូវចិត្ត* នោះទេ ប៉ុន្តែជា*ការគ្រប់គ្រងសង្កត់ផ្លូវចិត្ត* ទៅវិញ*ឧត្តមភាពព្រះពុទ្ធ សាសនា*គឺដើម្បីស្ថាបនា*លំនឹង*រវាង*ខាងក្រៅ* និង*ខាងក្នុង* រវាង*ភាពខាងក្រៅធម្មជាតិ* និង *ពិភពលោក* ដែលនៅជុំវិញយើងហើយ និង*ការរីកចម្រើនផ្លូវចិត្ត* តាមរយៈ*ការយកឈ្នះលើភាពកំណាញ់ស្វិត*។ ចំពោះគេដែលជា *ពុទ្ធសាសនិកម្នាក់ជីវិត* គឺជា*ដំណើរផ្សងព្រេងដ៏ធំមួយ* ដែលជានិច្ចកាលវាគឺជា *ដំណើរផ្សងព្រេងដ៏គ្រោះថ្នាក់បំផុត*។ *បញ្ហាសំខាន់* គឺថាតើ*ដំណើរផ្សងព្រេងដ៏ធំបំផុតទាំងអស់នេះ*អាចដឹកនាំ*មនុស្ស* ទៅរក *ទីបំផុតដោយរីករាយ* យ៉ាងដូចម្តេចប៉ុណ្ណោះ។

**សុក្រឹតភាព/អរហត្ត** (Perfection)

*ឧត្តមភាពព្រះពុទ្ធសាសនាគឺ ឧត្តមភាព* នៃ*ព្រះអរហន្តភាព* (arahantship) មានន័យថា *សុក្រិតភាព( ព្រះអរហត្ត)*ដើម្បីសម្រេចបាន *ឧត្តមភាព* នេះ *កត្តាទាំងអស់នោះ* ដែលប្រយុទ្ធប្រឆាំងទល់នឹង *សុខុមាលភាព* បែបនេះត្រូវតែគេកម្ចាត់ចោលមិនមែនត្រឹមតែចំពោះ *ខ្លួនឯង* នោះប៉ុណ្ណោះទេ ប៉ុន្តែក៏ចំពោះ*វត្ថុទាំងអស់* ដែលមាន*ជីវិតរស់រានា*នោះផងដែរ ។*ពុទ្ធសាសនិកជន* មិនអាចស្វែងរក *សុខុមាលភាព* តែចំពោះ*ផ្ទាល់ខ្លួនឯង* ដោយបដិសេធ *សុខមាលភាព*របស់*អ្នកដទៃ* នោះទេ *សុខុមាលភាពផ្ទាល់ខ្លួនគេត្រូវចងភ្ជាប់* យ៉ាងស្អិតរមួតជាមួយនឹង *សុខុមាលភាព*របស់*ពិភពលោកទាំងមូល*។ ដូច្នេះ *ដំបូន្មាន* របស់*ព្រះពុទ្ធ* ថា*មនុស្សល្អត្រូវតែជា* sabba-*panabhu tahitanukampi* ដែលបានចាប់អារម្មណ៍យ៉ាងជ្រាលជ្រៅជាមួយ ហើយនិងធ្វើការយ៉ាងសកម្មសម្រាប់ *សុភមង្គល* និង*សុខុមាលភាព* មិនត្រឹមតែចំពោះ *មនុស្សលោកប៉ុណ្ណោះទេ* ប៉ុន្តែក៏ចំពោះ *សត្វមានជីវិតទាំងអស់* ផងដែរ ។

នៅទីកន្លែងណាក៏ដោយ*ព្រះពុទ្ធសាសនា* បានរកឃើញ *មាគ៌ា*របស់វា វាលើកកំពស់ដល់*ការរីកចម្រើន*នៃ*អរិយធម៌មួយ* ហើយ*វប្បធម៌មួយ* បានបង្កើតឡើងដោយ*ការអត់ឱនមនុស្សធម៌សមានចិត្ត* និង*ការយល់យោគគ្នា* *គុណធម៌ជាគូរនៃករុណា* និង*បញ្ញា* (*panna*) ដែលបង្កើតឱ្យមាន*គ្រឹះសំខាន់ពីរ* នៃ*លទ្ធិព្រះពុទ្ធសាសនា*។

**ពិភពធំនើប** (The Modern World)

លក្ខណៈខុសគ្នានៃ *ពិភពទំនើប* គឺ*ល្បឿន* និង*ទំហំ* នៃ*ដំណើរប្រែប្រួល*។ សព្វថ្ងៃនេះយើងមាន*បំលាស់ប្តូរដ៏មិនគួរឱ្យជឿ* ជាភស្តុតាងនៅក្នុង*ដំណើរបំលែងវិវត្តន៍* និង *ដ៏គំហុក*នៃ*គ្រប់ស្ថាប័នមនុស្សទាំងអស់*នៅរាល់ *វិស័យ*នៃ *សកម្មភាពមនុស្ស*។ វាជាការពិតថា *ដំណើររីកចម្រើន ដ៏អស្ចារ្យរបស់ វិទ្យាសាស្ត្រ* និង *បច្ចេកវិទ្យា* បានបំផ្លាញចំណងដ៏រឹងមាំនៃ *មាគ៌ាជីវិតដ៏ត្រឹមត្រូវ* ដែលមាន *លក្ខណៈសីលធម៌ផ្ទាល់* របស់វាហើយរីកសាយភាយ នៅក្នុងចំណោម*ហ្វូងមនុស្ស* ដ៏ធំទូលាយបណ្តោយទៅតាមកម្មនៅក្នុង *ពិភពលំបាកវេទនា* និងដ៏ចម្លែក ។ *ពិភពលោក* កំពុងតែប្រែប្រួលយ៉ាងលឿនដោយសារតែ*ការយល់ដឹង*។

ប៉ុន្តែ *ដំណើរជឿនលឿន* ទាំងនេះក៏បានជួយរំដោះចំពោះ *មនុស្សធម៌* ទៅតាម*ទិសដៅជាច្រើន*ផងដែរ ។ ពួកវាបានផ្តល់ឱ្យយើងនូវ*ផលបញ្ញា*និង*សង្គមដ៏ធំធេង*ហើយ និង*មធ្យោបាយដែលនាំទៅបំផ្លាញចោលទុគ៌តភាព និងភាពអត់ឃ្លាន ។* សង្គមត្រូវបានចាក់ចូលគ្នាយ៉ាងជិត

ជាងពីមុនហើយបានឆ្លើយតបកាន់តែច្រើនឡើងចំពោះតម្រូវការនិង*ការទាមទារ*របស់ *មនុស្ស*។ *កំហុស*នឹងមិនស្ថិតនៅក្នុង *ផលិតផល*នៃ *ដំណើរជឿនលឿន*ខាងផ្នែក *បច្ចេកវិទ្យា* និងខាងផ្នែក *វិទ្យាសាស្ត្រ ប៉ុន្តែនៅក្នុង កំហុស* របស់យើងត្រូវប្រើប្រាស់ពួកគេដោយ *ឆ្លាតវាងវៃ* និងដោយ *សមរម្យ*។

នៅក្នុងករណីជាច្រើន យើងមិនអាចបញ្ឈប់ *ពិភពលោក* បានទេ វានឹងនៅតែបន្ត*ការផ្លាស់ប្តូរ*នេះតទៅទៀត ចំពោះ*ការផ្លាស់ប្តូរនេះព្រះពុទ្ធទ្រង់*បានសម្តែងថា វាគឺជា *ការពិតមូលដ្ឋាន*ចំពោះ*ជីវិត*។ *គ្មានបដិវត្តន៍ណា* អាចបញ្ឈប់ចំពោះ*ការផ្លាស់ប្តូរ*ខ្លួនវានេះបានឡើយ ។ នេះគឺជា *សោភ័ណភាព*នៃ*ការផ្លាស់ប្តូរ*។ បើគ្មាន *បំលាស់ប្តូរ* ជានិរន្តនេះទេ *បដិវត្តន៍* នៃ *ថ្ងៃម្សិលម៉ិញ* ក្លាយទៅជា *កិច្ចព្រមព្រៀង* (convention) របស់ *ថ្ងៃនេះ* ហើយ *កិច្ចព្រមព្រៀង*របស់*ថ្ងៃនេះ*គឺជា *ការសង្កត់សង្កិនរបស់ថ្ងៃស្អែក*។ *ជីវិតរស់នៅ* របស់យើងត្រូវចងភ្ជាប់ទៅនឹង*ការផ្លាស់ប្តូរ*នេះ ។ នេះគឺជាទីកន្លែងដែល *មនុស្សទំនើប*ត្រូវតែស្វែងរក *ព្រះពុទ្ធសាសនា*ដើម្បីភ្ជាប់*អាយុជីវិត*របស់គេដាច់ដោយឡែកតែឯង ។ *ព្រះពុទ្ធសាសនា*ទទួលយក*ការផ្លាស់ប្តូរ* នេះតាមពិត *ព្រះពុទ្ធសាសនា* បានកសាងនៅលើ *សច្ចភាព*នៃ *ការផ្លាស់ប្តូរ*និង *ដំណើរជោ-នាចជានិរន្ត*នេះ ។ យើងត្រូវតែរៀនយក *ស្ទឹង-ទន្លេ*ដែលតែងតែហូរទៅ ។

យើងត្រូវតែអប់រំ *គុណភាព*នៃ *ភាពយឺនយូរ លទ្ធភាព*ដែលត្រូវ*ទទួលយក ប្រែប្រួល* និង *បត់បែន* ទៅតាម ។ ឱកាសដែលយើងត្រូវឈានមកដល់ *សេចក្តីសន្និដ្ឋាន* ដោយតឹងរឹងហើយនិងត្រូវបដិសេធដើម្បីគិតពិចារណាលើ *ទស្សនៈខុសៗគ្នា* ពោលគឺយើងត្រូវបញ្ឈប់មិនឱ្យមានបញ្ញា (we cease to be intelligent) ។*ទស្សនៈ* របស់យើងមានទំនោរទៅរកភាពពង្រឹងចូលទៅក្នុង*គម្ពីរនិយម* ហើយ *គម្ពីរនិយមនេះធ្វើ* ឱ្យយើងមានភាព*រឹងរូស* ចូលទៅក្នុង*អស្មិមានៈ* (obstinacy)របស់យើង ។*ការខិតខំប្រឹងប្រែងថ្មី* (challenge) ទាមទារនូវ*ចម្លើយតបថ្មី* (respon-se) ។ ប្រសិនបើ*បុគ្គលម្នាក់ៗ*ខ្វល់ខ្វាយដើម្បីជៀសវាងពី*គម្ពីរនិយម*នោះ*សហគមន៍ទាំងមូល*នឹងក្លាយទៅជា*សង្គមបើកចំហមួយ* ដែលធ្វើឱ្យ *ជីវិតល្អងាយស្រួល* ឡើង ។

**បញ្ហាប្រឈមមុខចំពោះមនុស្សជាតិ** (Problems Facing Mankind)

មានបញ្ហាជាច្រើន ដែលកំពុងប្រឈមមុខទល់នឹង *មនុស្សជាតិ*។ យើងមាន *បញ្ហាចំណីអាហារ ឧស្សាហកម្ម កម្មករ ប្រាក់ឈ្នួល ការអត់ការងារធ្វើ វិសមភាពនៃ ឱកាស*គំលាតរវាង*អ្នកមាន* និង*អ្នកក្រ* ដែលត្រូវលើកឡើងប៉ុន្តែមានតែពីរបីប៉ុណ្ណោះ ។ វាមានលក្ខណៈស្មុគស្មាញ

បំផុត បើតាមតែវាមានពិតនោះប៉ុន្តែ *មហិច្ឆតា*របស់ *មនុស្សទូទៅ* គឺជា *មហិច្ឆតាសាមញ្ញមួយ*។ ពួកគេគ្រាន់តែប្រាថ្នាឱ្យមានលទ្ធភាពរស់នៅដោយ *សន្តិភាព* និងដោយ *សុភមង្គលមានសេរីភាព ដើម្បីកសាង ពិភពតូចមួយ* ដោយផ្ទាល់របស់គេក្នុង *សេចក្តីថ្លៃថ្នូរ* មួយប៉ុណ្ណោះ។

គេក៏ត្រូវការមាន *មិត្តភក្រ្ត* ហើយនិង *ការយល់ដឹង* និង *សេចក្តីស្រឡាញ់* ហើយអ្វីមួយ ដែលនឹងនាំមកនូវ *សេចក្តីសង្ឃឹម*សម្រាប់*ខ្លួនគេនិងសម្រាប់កូនរបស់គេ ទាំងចំពោះជីវិតរបស់* គេ និងទាំងអ្នកនៅជិតខាងរបស់គេ។ នៅក្នុងផ្នែកជាច្រើននៃ *ពិភពលោក*នេះ សូម្បីតែតម្រូវការជាមូលដ្ឋានទាំងនេះក៏ដោយ ក៏គ្មានប្រយោជន៍ដែរ។ ទាំង*សន្តិសុខ* និង *យុត្តិធម៌* គឺត្រូវគេរកឃើញទូទាំងពិភពលោក។ *ភាពស្រពេចស្រពិល* និង*ភាពអសន្តិសុខ*បានក្លាយទៅជាបញ្ហាស្លាប់រស់ស្ទើរតែទូទាំងពិភពលោក ទាំងក្នុងចំណោម *អ្នកមាន* និង*អ្នកក្រ* ពេលខ្លះបង្កើតដោយគួរឱ្យចាប់អារម្មណ៍ពេលខ្លះព្រងើយកន្តើយ ពេលខ្លះរំជើបរំជួលតានតឹងនិងធ្វើបដិវត្តន៍។ *វិទ្យាសាស្ត្រ* រកមិនឃើញពី*សុភមង្គលអាថ៌កំបាំង*នេះទេ។ *ជ័យជំនះនៃធម្មជាតិ* (the Conquest of nature) មិនទទួលបានជោគជ័យក្នុងការសម្រេចបាន*ភាពសម្បូរបែប* ឬ*សន្តិភាព*។ នេះមិនជាការគួរឱ្យភ្ញាក់ផ្អើលចំពោះយើងនោះទេពីព្រោះ *ព្រះពុទ្ធបាន*ទូន្មានប្រាប់យើងហើយថា*សុភមង្គល* គឺគេ ត្រូវរកឃើញនៅក្នុង *ការរស់នៅ* ដោយស្របទៅតាម *ព្រះធម៌* នេះមានន័យថា ទៅតាម *ធម្មជាតិ* ទៅតាម *សោភ័ណភាព* និង *សេចក្តីថ្កុំថ្កើង*។ *សច្ចភាពគឺ មនុស្សជាតិទាំងមូល* មានទុគ៌តដោយអស់សង្ឃឹម និងដោយអពមង្គល។

ដូច្នេះស្ថានភាព បានសម្តែងឡើងយ៉ាងស្មុគស្មាញបំផុត ហើយប្រហែលជាមិនអាចដោះស្រាយបាន។ផ្ទុយទៅវិញប្រសិនបើយើងសាកល្បងពិនិត្យមើលទៅលើបញ្ហាដោយប្រុងប្រយ័ត្នដោយបញ្ញា និងដោយមានការយល់ដឹង យើងគួរតែយល់ឱ្យច្បាស់ថា បញ្ហាសម័យទំនើបរបស់យើងមិនមែនខុសប្លែកជាមូលដ្ឋានពីបញ្ហាយូរអង្វែង មកហើយដែលធ្វើឱ្យមនុស្សក្តៅក្រហាយគ្រប់ពេល និងគ្រប់អាកាសធាតុ។ ប្រសិនបើ បញ្ហាសម័យទំនើបរបស់យើងខុសប្លែកពីបញ្ហាមុនៗនោះវាគឺជាបញ្ហាដ៏ធំធេងរបស់យើង។

ឥឡូវនេះការបង្រៀនជាមូលដ្ឋានរបស់ព្រះពុទ្ធ ដូចយើងបានដឹងរួចមកហើយស្រាប់គឺជាការបង្រៀនគ្មានអ្វី កើតឡើងទេលើកលែងតែ លទ្ធផលនៃហេតុនានាប៉ុណ្ណោះ។ មានពេលម្តងហេតុនានាត្រូវបានពិនិត្យសង្កេត និងយល់ដឹងឯដំណោះស្រាយក៏អាចត្រូវបានគេរកឃើញដែរ។ ជារឿយៗគេតែងតែស្មានថាការបង្រៀនរបស់ អ្នកប្រាជ្ញបុរាណមានព្រះពុទ្ធជាដើមមានលក្ខណៈ

សាមញ្ញបំផុតដែលត្រូវមានលក្ខណៈស័ក្តិសិទ្ធិ  គ្រប់គ្រាន់ដើម្បីជួយយើងនៅក្នុងដំណោះស្រាយបញ្ហាស្មុគស្មាញដ៏លើសលុប  ដែលមានឥទ្ធិពលមកលើបុគ្គលម្នាក់ៗនិងសង្គមនៅក្នុងជីវិតសហ្សសម័យនេះ។ ពាក្យទូន្មានរបស់  ព្រះពុទ្ធបានសម្តែងចំពោះ  ស្ថានការណ៍ខ្វល់ខ្វាយរបស់មនុស្សជា មូលដ្ឋានហើយនេះវាមានលក្ខណៈអមតៈ និងត្រូវនៅគ្រប់សម័យកាល។ វាគឺជាមគ្គុទេសក៏មួយចំពោះ អំពើនៅក្នុងក្របខណ្ឌ គំនិត សម្តី និង អំពើ។ ជំនាន់ជោគជ័យនីមួយៗ អាច ហើយនិងត្រូវតែរកឱ្យឃើញឡើងវិញពីចំណងទាក់ទងនៃពាក្យប្រៀនប្រដៅនោះចំពោះដំណោះស្រាយនៃបញ្ហាផ្ទាល់របស់វា។

**សុភមង្គលកំពូល** (Highest Happiness)

ការបង្រៀនរបស់ ព្រះពុទ្ធថា សុភមង្គលកំពូលគឺ សេចក្តីស្ងប់ (peace) ហើយនិងថា គ្មានសេចក្តីសុខណាស្មើសេចក្តីស្ងប់នោះទេ។ ពិភពលោកពោរពេញទៅដោយ  ទុក្ខក្រៀមក្រំចំពោះភាពភ័យខ្លាច និងភាពហួងហែងដោយភ្លើងសង្គ្រាម។ ប្រទេសទាំងឡាយដែលជាប់ទាក់ទងនឹងសង្គ្រាមទាំងនេះបានក្លាយទៅជា បន្ទាយដែកយោធា ដ៏គួរឱ្យភ័យខ្លាចការធ្វើឱ្យ ពាណិជ្ជកម្មបន្តដោយពិតប្រាកដហើយ  និងប្រាក់ចំណូលដល់ពាណិជ្ជករសាកសព (merchant of death) ហើយនិងការបំផ្លិចបំផ្លាញ  ការប៉ះទង្គិចមនោគមវិជ្ជាគ្នា មិនត្រឹមតែបុគ្គលិកយោធាប៉ុណ្ណោះទេ ប៉ុន្តែរួមទាំងមនុស្សគ្មានទោសរាប់ពាន់នាក់  ទាំងបុរស  ទាំងស្ត្រីក្មេងៗត្រូវបានគេសម្លាប់  ដោយគ្មានមេត្តា  ហើយការខូចខាតមិនអាចគណនាបានក៏ត្រូវបានប៉ះពាល់គ្នានៅលើដីធ្លី  និងនៅលើទ្រព្យសម្បត្តិ។ គ្មានអ្វីគេចរួចអំពីទោសៈ ហើយនិងការវក់វីនឹងចម្បាំងគ្នា តើត្រូវមានអ្វីដើម្បីបញ្ចប់វាបាន ? ព្រះពុទ្ធ ទ្រង់បានសម្តែងថា កំហឹងមិនដែលរំលត់ដោយកំហឹងនោះ ឡើយប៉ុន្តែមានតែសេចក្តីស្រឡាញ់ប៉ុណ្ណោះជាថ្មីម្តងទៀតជ័យជំនះ សាបព្រួស ទោសៈ ពីព្រោះ អ្នកឈ្នះ (the conquered) គឺគ្មានសេចក្តីសុខ។ នៅក្នុងផ្នែកជាច្រើនដទៃទៀតនៃ  ពិភពលោកពពកសង្គ្រាម (war-clouds) ហួងហែងនៅជិតៗបង្អើយ។ ឥរិយាបថ  (the air) ពោរពេញទៅដោយ  កំហឹងនៅក្នុងគំនិតសម្តី និងអំពើ។

ដូច្នេះនេះគឺជា  ភារកិច្ចរបស់សាសនាពោលគឺ  គ្រប់សាសនាទាំងអស់។  មានតែសាសនាមួយប៉ុណ្ណោះដែល អាចមានឥទ្ធិពលទៅលើបំលាស់ប្តូរចាំបាច់នៃ ចិត្តបានពោលគឺសាសនា ដែលមិនមាននៅក្នុងការសម្តែងនៃ  បុណ្យ  និងពិធីនានា  ហើយនិង  ការសម្តែងធម្មទេសនានោះទេ

ប៉ុន្តែនៅក្នុងជីវិតមួយដ៏បរិសុទ្ធហើយ និងសេចក្តីស្ងប់នៅក្នុងចិត្តហើយដែលផ្តល់លទ្ធផលឈាន ទៅរកស្មារតីទម្លាក់អាវុធចុះ ដែលជាការទម្លាក់ពិតប្រាកដតែមួយប៉ុណ្ណោះ ។

**មូលហេតុឫសគល់នៃសង្គ្រាម** (Root-causes of War)

ព្រះពុទ្ធក៏បានបង្រៀនយើងផងដែរថា មានតែវិធីសម្រេចឱ្យបានសេចក្តីស្ងប់ទេ ដែលអាចលុបបំបាត់ មូលហេតុឫសគល់នៃសង្គ្រាមបានពោលគឺ អំពើការស្អប់ និងអវិជ្ជាបាន។ សព្វថ្ងៃនេះពិភពលោកត្រូវបែងចែកទៅជាមនុស្សដែលមានមនោគមផ្សេងៗគ្នាដោយមាន *ពួកប្លុកអំណាច*(power-blocs) របស់ពួកគេជាពួកដែលភក្តីភាពចំពោះ ពួកដែល *ស្មារតី* និងថាមពលភាគ ច្រើនចំពោះ*ភាពគ្មានអំណោយផលល្អ* (the sterile) ជាអវិជ្ជមាន ពាណិជ្ជកម្មសង្គ្រាមព្រៃផ្សៃ។ ពិភពលោកមិនអាចមានសេចក្តីស្ងប់បានទេ លុះត្រាតែមនុស្ស និងជាតិនានាលះបង់ចោលនូវតម្រូវការអត្តទត្ថបុគ្គលការរើសអើងពូជសាសន៍ហើយសំអាតខ្លួនគេពីការត្រេកត្រអាលនឹងប្រយោជន៍ផ្ទាល់ខ្លួន ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួននិងអំណាច។ មនោគមវិជ្ជាបាន បែងចែកពោលគឺវាបង្កើតឱ្យមានការប៉ះទង្គិចគ្នានេះឯង ។មនោគមវិជ្ជាបង្កើតទម្រង់ជាច្រើនប្រការមានដូចជា នយោបាយ សាសនា សេដ្ឋកិច្ច សង្គម ហើយនិងការអប់រំជាដើម។ មនោគមវិជ្ជាគឺជាការគេចឱ្យផុតពីតថភាព។ វាគម្រាមគំហែងដល់មនុស្សហើយនិងធ្វើឱ្យគេទៅជាសេវភាពចំពោះជំនឿងប់ងុល និងអំពើហិង្សា។

ជាគំនិតរបស់មនុស្សដែលថា ការប៉ះទង្គិចមនោគមវិជ្ជាគ្នាត្រូវបានចាប់កំណើតឡើងការទទួលលទ្ធផលទៅលើភាពតានតឹង និងសង្គ្រាមហើយដោយសារតែចេញពី ស្មារតីរបស់មនុស្សនេះដែរដែលការប៉ះទង្គិចទាំងនេះ ក៏គួរតែត្រូវបំផ្លាញចោលផងដែរដើម្បីឱ្យ ភាពត្រូវអាចត្រូវបានបំពេញជាមួយនឹង គំនិតចុះសម្រុងគ្នាហើយ និងសេចក្តីស្ងប់នេះ។ ព្រះពុទ្ធទ្រង់បានសម្តែងថា ស្មារតីមានលក្ខណៈចម្បងជាងគេបំផុតពោលគឺជា អ្នកនាំមុខវត្ថុនានាទាំងអស់ទោះល្អក្តីអាក្រក់ក្តី ហើយនិងថា កាលណាស្មារតីត្រូវបានរួចស្រឡះពីអំពើអាក្រក់សេចក្តីស្ងប់ និងសេចក្តីសុខក៏កើតមានឡើងដែរ។

*សាសនា* បើសាសនានោះជា *សាសនាត្រឹមត្រូវ*ត្រូវតែទទួលយក *មនុស្សទាំងអស់* (the whole of man) ជា *អាណាខេត្តរបស់ខ្លួន* មិនត្រឹមតែទិដ្ឋភាពជាក់ស្តែងនៃជីវិតរបស់គេប៉ុណ្ណោះនោះទេ។ មនុស្សល្អមានន័យថា មនុស្សដែលដើរតាមសាសនារបស់គេៗដឹងថា គ្មានសេចក្តីស្ងប់ និងសេចក្តីសុខណានៅលើផែនដីនេះដរាបណាមាន ភាពក្រីក្រទុរ្គតក្ស ភាពអយុត្តិធមិការ

*សង្កត់សង្កិននីតិកម្មប្រកាន់ពូជសាសន៍ ការប្រកាន់ពូជសាសន៍អសមត្ថភាព*និង *វិសមភាពសង្គម សេចក្តី ភ័យខ្លាច*ដែលនាំទៅរក *ការវិនាស ការមិនជឿទុកចិត្តគ្នា* និង *ការមានមន្ទិលសង្ស័យគ្នា* នោះឡើយ ។ *ការគោរពខ្លួនឯង* (self-respect) គឺជាការចាំបាច់ចំពោះ *សេចក្តីសុខ* ដូច *ចំណីអាហារ* ដែរហើយគ្មាន *ការគោរពខ្លួនឯងណា*ក្នុងចំណោមអ្នកដែលមិនមានឱកាសដើម្បីសម្រេចបាន*ភាពជាមនុស្សដ៏* ខ្ពង់ខ្ពស់ពេញបរិបូរណ៍នោះទេ ។

**បញ្ហាពិភពលោក** (World Problems)

*បញ្ហា* ដែលប្រឈមមុខនឹង *មនុស្សជាតិ*សព្វថ្ងៃ ហើយដែលគំរាមគំហែងដល់ *វចនាសម្ព័ន្ធមនុស្សធម៌*នោះគឺ *បញ្ហាពិភពលោក* (world-problems) ហើយដែលនៅមិនឆ្ងាយពីនេះ ឬតំបន់ភូមិសាស្ត្រនោះឡើយ ។*ដូច្នេះដំណោះស្រាយ* ត្រូវបានគេស្វែងរកឃើញនៅក្នុង*លក្ខខណ្ឌពិភពលោក* (world-terms) នេះឯង ។ ករណីនេះជាប់ទាក់ទងជាមួយនឹង *ការយល់ដឹងថ្មី* ចំពោះ *ទំនាក់ទំនង* របស់មនុស្សនៅលើផែ្ទករបស់យើងមិនមែនត្រឹមតែនៅក្នុង *គ្រួសារនិងផ្ទះសម្បែង ទីក្រុង* របស់យើង *ភូមិនិងប្រទេស* របស់យើងនោះប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងបរិបទ*ពិភពលោក*នេះតែម្តង ។ គ្មានតម្រូវការណាមួយដែលត្រូវអប់រំបុរស និងស្ត្រីឱ្យស្រឡាញ់ អំពើអាក្រក់ចំពោះជាតិនិយមសង្កៀតចង្អល់ *ជាតិសាសន៍និយមពណ៌សម្បុរនិងជំនឿសាសនា*។ *ការមិនអត់ឱនការប្រកាន់ ឬកពា* ហើយនិង*ការឆ្កួតនឹងសាសនា* ដែលឈានទៅរកការប្រមាថមើលងាយ និងបណ្តុះបង្អាប់ *មនុស្ស វប្បធម៌ សាសនា មាគ៌ាជីវិត*ដទៃដែលខុសប្លែកពីរបស់ខ្លួននោះទាំងនេះត្រូវតែលុបបំបាត់ចោលប្រសិនបើយើងមានបំណងចង់ស្វែងរក*សេចក្តីស្ងប់ឬសន្តិភាព*នោះ ។

**អតីតកាលដ៏គួរឱ្យខ្លាច** (Sinister Past)

គេបានព្រមទទួលថា *សាសនា* បើតាមដែលគេធ្លាប់បានគោរព មាន *អតីតកាលដ៏គួរឱ្យខ្លាចមួយ*ដែលត្រូវជួយ សង្គ្រោះ (redeem) ។ ជាញឹកញយបំផុតនេះ *បេសកកម្ម*របស់វាចំពោះ *មនុស្សជាតិ*ត្រូវបានគេដាក់ស្មើឡើងចំពោះ *តម្រូវការបន្ទាន់ៗ*នៃ *នយោបាយជាតិ ឬខេត្ត* ហើយនិង *ផែនការកំណាចឃោរឃៅ*សម្រាប់ *ការពង្រីក* និង *ការយកជ័យជំនះ*។ កាលពីនៅ *សម័យដើម បំផុតសង្គ្រាមជាតិ* ក៏ជា *សង្គ្រាមសាសនា* ដែរ ។ ជារឿយៗបំផុត *សាសនា*ក៏បានកប់ខ្លួនឯងជាមួយនឹង*សេចក្តីលំអិតនៃបុណ្យ* (details of ritual) ហើយនិង*គម្ពីរនិយម*គឺបញ្ហាចំពោះ *អង្គការមន្ត្រី* ហើយនិង *ភាពមិនភ្លាំងភ្លាត់នៃសៀវភៅ* ហើយនិង *មនុស្ស*។ ដូច្នេះវាធ្វើឱ្យខ្លួនឯង

ត្រូវចុះរួមតូចចំពោះpriestcraft និងsacredotalismមើលថែទាំ*ទាយជ្ជទាន* (endowments) និង *ការស្ថាបនានានា* របស់វា ។

**អាណាចក្រភាព** (Secularization)

ដូច្នេះ *មនុស្សសម័យទំនើប* មានសិទ្ធិត្រូវចោទសួរអ្វីដែលប្រើសាសនាមានសម្រាប់យើងនៅក្នុងយុគសម័យនេះ ។ ពួកគេបានជជែកតវ៉ាថា *សាសនា* បម្រើ *គោលបំណង*របស់វា ដូច្នេះវាគួរតែស្លាប់ ។នេះគឺជាហេតុចម្បងនៃ*អាណាចក្រភាព* (secularization)ដែល *សាសនា*ត្រូវប្រឈមមុខនៅគ្រប់ទីកន្លែង ។ពីព្រោះបញ្ហាដែលបានកើតឡើងមកពី*អាណាចក្រភាព*នេះកាន់តែទូទៅ ឬកាន់តែតិចឡើងចំពោះ *គ្រប់សាសនាពិភពលោក* ទាំងអស់ពេលគឺគ្មានតម្រូវការណាមួយដែលត្រូវផ្ទៀងផ្ទាត់លើវាដោយជាក់លាក់នៅទីនេះ ។

តែទោះជាយ៉ាងណាក៏ដោយ*ភាពធ្ងន់ធ្ងរ* របស់ពួកវាគឺជា បញ្ហាដែលមានទាក់ទងជាមួយនឹង *យុវវ័យ* របស់ *ពិភពលោក*ដែលធ្វើឱ្យ*ការបារម្ភណ៍* ជាច្រើនមានអត្ថិភាពក្នុងចំណោមជំនាន់មុនៗជាសំខាន់ក្នុងចំណោម*មេដឹកនាំសាសនាផ្សេងៗ*។*ការបារម្ភណ៍ទាំងនេះ*សំដៅយកជាសំខាន់នៅជុំវិញអំពើហិង្សាទូទៅក្នុងចំណោមចលនាយុវជនជាច្រើនហើយ និង*ការប្រើប្រាស់ជាតិអាភៀន* Narcotics និង*ថ្នាំញៀន*ដោយយុវជនមានចំនួនកាន់តែធំឡើងៗ ។ កត្តាទាំងពីរនេះហាក់ដូចជារោគសញ្ញានៃ*ជម្ងឺ* ដែលបានចាក់ឫសយ៉ាងជ្រៅមួយដូចជា *ជម្ងឺដទៃទៀត* ទាំងអស់ដែលត្រូវតែជា*លទ្ធផល*នៃ *ហេតុពិតប្រាកដ*។ វាគឺជាហេតុ ដែលយើងត្រូវតែរកឱ្យឃើញមុនពេលយើងគិតអំពី *ឱសថព្យាបាល* វា ។

**កម្រិតវប្បធម៌** (Strata of Culture)

នៅស្ទើរគ្រប់ *ប្រទេស* ទាំងអស់ក្នុង*ពិភពទំនើប* ហាក់ដូចជាមានបីពេលគឺ*កម្រិតនៃវប្បធម៌* ដែលខុសប្លែកគ្នាពិតប្រាកដ ។ *ទី១ មានវប្បធម៌ប្រពៃណីអំពីគុណសម្បត្តិធម្មតាកិច្ចសន្ទនា* នៅក្នុង*ទស្សនវិស័យ*ដែលគេអាចហៅបានថា *វប្បធម៌* នៃ *ប្រក្រតីភាព* (culture of normalcy) ដែលខិតខំដើម្បីថែរក្សា *តម្លៃបុរាណ* ដែលគេបានពិនិត្យផ្ទៀងផ្ទាត់នៅក្នុង *នៃបទពិសោធន៍* (experience) ។ *ទី២* គឺជា*សង្គម* ដែលបានរៀបចំតាម*បច្ចេកវិទ្យា ទំនើបសេរីភាព* នៅក្នុង*ទស្សនវិស័យ*ការព្យាយាមតម្រូវទៅតាមខ្លួនវាដើម្បីធ្វើការផ្លាស់ប្តូរ ដែលកើតមានឡើងនៅជុំវិញខ្លួនវាដោយមានភាពរហ័សដ៏អស្ចារ្យបំផុត ។*ទី៣*គឺជាអ្វីដែលគេឱ្យឈ្មោះថា*អ្នកគណនា* (counter) *ពោលគឺ វប្បធម៌* ការតំណាងនៅក្នុង *គំនិតប្រជាប្រិយ* តាមរយៈ so-called hippies

ជាមួយនឹង*សក់វែង* របស់ពួកគេរូបរាងមិនស្អាតបាតការចោទសួរអំពី *ជំនឿ* និង*តម្លៃ* ជាមួយនឹង*ការចូលចិត្តចំពោះ តន្ត្រីរ៉ក់សេរីភាពផ្លូវភេទ*ការមិនប្រកាន់ទោសនៅក្នុងអាភៀនNarcotics និងគ្រឿងញៀនជាមួយនឹង *បាតុកម្មអឹងកង* ការវិលទៅរក *របៀបរស់នៅ* ជា *កុលសម្ព័ន្ធ* និង *ភូមិឃុំ* ការវិលទៅរក *ធម្មជាតិ* នៅក្នុងអ្វីដែលពួកគេហៅថា " *សោភ័ណនិយមពិត១* " ។

*ក្រុមវប្បធម៌ផ្ទុយគ្នានេះ* (this counter-culture group) ជាទូទៅត្រូវបានគេមើលមកដោយ*ភាពភ័យខ្លាច* ហើយខ្ចីមរអើមដោយ *វប្បធម៌ពីរផ្សេងទៀត*។ តែទោះជាយ៉ាងណាក៏ដោយ បើគេសិក្សាឱ្យបានដិតដល់អំពី *វប្បធម៌ផ្ទុយគ្នា* ក៏អ្នកទាំងឡាយដែលអះអាងថា *ធម្មារម្មណ៍ប្រជាប្រិយ* (popular image) មានលក្ខណៈខុសឆ្គង ពោលគឺ *រាក់កំផែល* ហើយ *សេរី១*បំផុតហើយនិងការអះអាងថា *សីលធម៌មិនត្រឹមត្រូវ*របស់ពួកគេគ្រាន់តែជា*មធ្យោបាយប្រឆាំងមួយ* ចំពោះ *សង្គម* ដែលគេបានបង្កើតឡើង ដែលពួកគេចាត់ទុកថា បានបណ្តាលមកដោយពេញលេញដោយ *ការប្រកាន់ ពូជសាសន៍* និង *ចំណាប់អារម្មណ៍ខ្លួនឯង* ប៉ុណ្ណោះ ។

នៅក្នុងពន្លឺនៃអ្វីដែលគេបានអះអាងយ៉ាងដូច្នេះអ្វីដែលគួរតែជា*សីលធម៌សាសនា*ចំពោះ *សីលធម៌* នៃ*យុគសម័យទំនើប* តើនរណាដែលត្រូវរកឃើញនៅគ្រប់ទីកន្លែង ទៅតាមចំនួនធំក្តី ឬតូចក្តី ? តាមពិតទៅវាគួរតែជាសីលធម៌ *អត់ឱន* និង *សមានចិត្ត* មួយជាពិសេស ចំពោះ *ការយល់យោគគ្នា ភាពទន់ភ្លន់* ហើយនិង*ការផ្លាស់ប្តូរ* តាម ។

យើងមិនគួរភ្លេចទេថា *អ្នកដឹកនាំសាសនាមួយចំនួន* ធ្វើបដិវត្តលើខ្លួនឯង ។ ជាឧបមាដូចជា*ព្រះពុទ្ធ*គឺជា*អ្នកប្រឆាំងមួយ*ក្នុងចំណោម*អ្នកប្រឆាំងកំពូល១* នៅក្នុងប្រវត្តិសាស្ត្រមនុស្សលោក ។ ព្រះអង្គបានបដិសេធការប៉ាន់ស្មាន ដែលសាសនានៅក្នុង *សម័យរបស់ព្រះអង្គ* ត្រូវពឹងផ្អែកទៅលើ ហើយនិងផ្តល់ឱ្យ*ការស្វែងរក* ខាង*សាសនានូវ ការដឹកនាំថ្មីទាំងស្រុងមួយ*។ ព្រះអង្គបានបដិសេធមិនទទួលយកនូវ *ភាពស្មោះត្រង់* នៃ *វេទ* (the sincerity of the Vedas) ឬ *អំណាច*នៃ *ភាពជាបព្វជិត* (the power of priesthood) ។ ព្រះអង្គបានបដិសេធ *មាយាការ* ដែល*បញ្ហារបស់មនុស្ស*អាចត្រូវបានដោះស្រាយដោយ *ពិធីបុណ្យបូជាស័ក្តិសិទ្ធិ* ហើយនិង*មន្តគាថា*។ ព្រះអង្គ ទ្រង់ជា*សត្រូវគួរឱ្យស្អប់មួយអង្គ* ចំពោះ *ប្រព័ន្ធវណ្ណៈ*ដែល *រចនាសម្ព័ន្ធទាំងមូល* នៃ *សង្គមឥណ្ឌា* ពឹងផ្អែកលើនោះ ។ ព្រះអង្គត្រូវបានគេចំអកឡកឡឺយ និងធ្វើទុក្ខបុកម្នេញហើយការខិតខំប្រឹងប្រែងត្រូវបានបង្កើតឡើងនៅលើ *ជីវិត*របស់ទ្រង់ ។

**លក្ខណៈលេចធ្លោ** (Salient Characteristics)

អំឡុងពេល២៥០០ឆ្នាំ នៃប្រវត្តិសាស្ត្ររបស់ខ្លួន ព្រះពុទ្ធសាសនាបានប្រឈមមុខទៅនឹងបញ្ហាដែលចោទចំពោះខ្លួនដោយជោគជ័យ ។ ការធនទ្រាំនឹងការប៉ះទង្គិចហើយ និងការអត់ឱនត្រូវបានស្ថិតនៅក្នុងចំណោម*លក្ខណៈលេចធ្លោនានា*។ *ព្រះពុទ្ធសាសនា*គ្មានស្ថាប័នឋានានុក្រម ហើយនិងគ្មាន*សិទ្ធាន្តតឹងតែង* នោះទេ ។*ឥទ្ធិពលករុណា* របស់សាសនានេះអំពី*មនុស្សធម៌*មានបញ្ជាក់ដោយ*វប្បធម៌* និង *អរិយធម៌* ដែលបានរីកចម្រើននៅក្នុង*ប្រទេសនានា* ដែលសាសនានេះបានផ្សព្វផ្សាយចូលទៅ ។ *ព្រះពុទ្ធសាសនា* មានពាក្យទូន្មានមួយសម្រាប់ *មនុស្សសម័យទំនើប*មានកម្លាំងដូចនៅសម័យរបស់ *ព្រះពុទ្ធ*ដែរ *ព្រះពុទ្ធសាសនា* មិនបានសន្យាថា*ជម្ងឺ* ដែល*មនុស្សធម៌*ព្រួយបារម្ភអាចត្រូវបានគេធ្វើឱ្យស្រាកស្រានទៅតាមវិធីមូលដ្ឋានណាមួយដោយ*អង្គការសង្គម* ទាំងមូលណាមួយឡើយ ។ ពេលការបដិសេធ *ភាពបាបពីកំណើត* ណាមួយ នៅក្នុង*មនុស្ស* វាអះអាងថា *ការសង្គ្រោះ*គឺជា *កិច្ចការបុគ្គលម្នាក់ៗ* ហើយវាអាចត្រូវគេសម្រេចបានតែតាមរយៈ*ឥរិយាបថ*ប្រកបដោយ *សីលធម៌* និង *វប្បធម៌ខួរក្បាល*ប៉ុណ្ណោះ ។ ការទូន្មានទាំងស្រុងរបស់វាត្រូវ *ព្រះពុទ្ធសម្ដែង* ដោយខ្លីថា "ការជៀសវាងនូវ *អំពើបាប*ទាំងឡាយ *អំពើល្អត្រូវកើនឡើងភាពបរិសុទ្ធ* នៃចិត្តរបស់គេក៏កើតឡើងដែរនេះគឺជាពាក្យទូន្មានរបស់ព្រះពុទ្ធ" ។

**អាណានិគមនិយម** (Colonialism)

អំឡុងពេល *បួន* ឬ *ប្រាំសតវត្សរ៍* ក្រោយនេះ *ព្រះពុទ្ធសាសនា*ទទួលរងនូវ*ទុក្ខវេទនា*មកពី *អាណានិគមនិយម* នៅក្នុងប្រទេស *អាស៊ី* ជាច្រើន ដោយ*សង្គ្រាម*ខាងក្នុង និងខាងក្រៅនិង*ការខំប្រឹងប្រែង*ដោយឆន្ទៈនៃ *អ្នកកាន់សាសនា* ដទៃទៀតដែលត្រូវធ្វើឱ្យចុះខ្សោយ និងបំផ្លិចបំផ្លាញលើវា ។*សហគមន៍សង្ឃ*បានថែរក្សា *ពាក្យទូន្មាន* ឱ្យនៅគង់វង្សហើយដែលបានសប្បាយរីករាយនឹងការគាំទ្រចំពោះ *ពាក្យទូន្មាន* ទាំងនោះឱ្យនៅមានអំណាចនោះត្រូវបានធ្វើឱ្យបែកខ្ញែក និងចុះខ្សោយដែលជា *លទ្ធផលនៃកម្លាំងមួយ* ទៅហួសពីការគ្រប់គ្រងរបស់វាទៅទៀត ។

ប៉ុន្តែ *ទស្សនវិស័យ*កាន់តែភ្លឺចិញ្ចាច ។ *ការសាមគ្គីភាពព្រះពុទ្ធសាសនា* ត្រូវបានដំច្រុងដោយអង្គការដូចជា *ភាតរភាព* នៃ*ពុទ្ធសាសនិកជនពិភពលោក* និង*ក្រុមប្រឹក្សាសង្ឃៈពិភពលោក* ជាដើមដែលបានធ្វើការរួមគ្នារវាង *ព្រះពុទ្ធសាសនាមហាយាន* និង*ព្រះពុទ្ធសាសនាថេរវាទ* ដើម្បីដើរតាម *កម្មវិធីប្រតិបត្តិរួមគ្នា* មួយ ។ មានចំណោះស្រាយធំមួយអំពី *ភាពមិនចេះអក្សរ* និង*ភាពក្រីក្រ* ក្នុងចំណោម *គ្រហស្ថ* ដែលគេត្រូវយកឈ្នះ ។ *សង្ឃៈ* ត្រូវតែធ្វើការ

អប់រំដើម្បីសម្រេចឱ្យបាននូវ *តម្រូវការទំនើបៗ*។ *ព្រះពុទ្ធសាសនា*មិនដែលអសកម្មឡើយពោល គឺជា*សាសនាស្ងួត*។ *ព្រះពុទ្ធសាសនា*គឺជាកម្លាំងមួយក្នុងចំណោមកម្លាំងអារ្យធម៌កំពូលៗនៅក្នុង ពិភពលោក ។

ប៉ុន្តែយើងយល់ហើយថា ខ្លឹមសារនៃទ្រឹស្តីណាមួយទោះល្អយ៉ាងណាក៏ដោយប្រសិនបើ អ្នកប្រតិបត្តិមិនចេះប្រើនោះពិតជាអាចទទួលផលមិនល្អដែរ ។

## ៥.ព្រោះអ្វីបានជាគេហៅថាព្រះពុទ្ធសាសនា ? (Why Buddhism?)

By. Ven. Dr. K. Sri Dhammananda

មុននឹងយើងធ្វើការពិភាក្សាទៅលើប្រធានបទ *"ហេតុអ្វីបានជាហៅព្រះពុទ្ធសាសនា?"* នេះ យើងត្រូវរកឱ្យឃើញថាតើគំនិតអំពី *សាសនា* បានចាប់ផ្តើមនៅក្នុង *គំនិតមនុស្ស* កាលពីដើម ដំបូងយ៉ាងដូចម្តេចជាមុនសិន ។ តាំងពីរាប់ពាន់ឆ្នាំកន្លងមកហើយពេល *មនុស្ស* ចាប់ផ្តើមគិត អំពី*ប្រភេទ*នៃ *បាតុភូតធម្មជាតិខុសៗគ្នា* នៅក្នុងលោកនេះ *មនុស្ស* បានធ្វើការកត់សម្គាល់ពី *ព្រឹត្តិការណ៍អស្ចារ្យៗ*។ នៅពេល *កម្លាំងធម្មជាតិពិតប្រាកដ* ឬ *បាតុភូតនានា* មិនអំណោយផល ដល់គេ គេក៏កើត *ទុក្ខកង្វល់* ឡើង។ គេបានមើលឃើញពី *ភយន្តរាយ* ហើយ *ភិតភ័យជាខ្លាំង* អំពី*ឧប្បត្តិហេតុ* នានា។ នៅពេលនោះ *មនុស្ស* ចាប់ផ្តើមគិតថាតើគេអាចការពារ *លក្ខខណ្ឌមិន អំណោយផល* ទាំងនេះ ដែលបង្កើតឱ្យមាន *ការភ័យខ្លាចមន្ទិលសង្ស័យអសន្តិសុខ ភាពតានតឹង* ហើយនិង *សេចក្តីទុក្ខ* យ៉ាងដូចម្តេច។ គេដឹងថា *វត្ថុជាច្រើនទាំងនេះ*នាំទៅហួសពី *យល់បាន* របស់មនុស្សដោយហេតុដូច្នេះ ហើយបានជាគេគិតថា ត្រូវតែមាន *កម្លាំងអធិធម្មជាតិដ៏មាន អំណាចអាថ៌កំបាំងមួយចំនួន* (some invisible powerful supernatural forces) ឬ *មនុស្ស* នៅ ពីក្រោយ *បាតុភូតទាំងអស់នេះ* ជាមិនខាន។ ព្រឹត្តិការណ៍ពិបាកយល់ទាំងនេះត្រូវបានគេគិតថា ជា*កិច្ចការ* របស់ *"ទេវៈខុសៗគ្នា"*។ គេចាប់ផ្តើមធ្វើ *ការគោរពបូជា*ចំពោះ*ទេវៈទាំងនោះ* ហើយ ចាប់ផ្តើមធ្វើ*ពិធីបូជាសត្វ* ដោយសង្ឃឹមថាដើម្បីធ្វើឱ្យ*អំណាចអធិធម្មជាតិ* ទាំងនេះសប្បាយ រីករាយ ។បាតុភូតទាំងនេះ*(បាតុភូតដែលពិបាកយល់)* ត្រូវបានគេគិតឱ្យទៅជាកិច្ចការអំពី *"ទេវៈ"* ផ្សេងៗគ្នា។ គេចាប់ផ្តើមគោរពបូជាលើ *ទេវៈ* ទាំងនោះ ហើយគេក៏ចាប់ផ្តើមប្រារព្ធធ្វើពិធី *បូជាសត្វ* (animal sacrifice) ដើម្បីធ្វើឱ្យ *កម្លាំងអធិធម្មជាតិទាំងនេះ* សប្បាយចិត្ត។ គេក៏ ចាប់ផ្តើមបួងសួង និងគោរពបូជាដោយសេចក្តីអរគុណនៅពេលដែល *បាតុភូតជាក់ស្តែង* បំពេញ តាមសំណូមពររបស់គេ ដោយការអរគុណថា ទាំងនេះគឺជា *អំពើ* របស់ *ទេវៈ*។ *គោលបំណង* នៃ*ការប្រតិបត្តិទាំងនេះ* គឺដើម្បីទទួលបាននូវ *ការការពារ* និង*ពរជ័យ* ពី *ទេវៈ* ទាំងនោះដើម្បី

*រស់នៅ* នៅក្នុង*លោកនេះ* កុំឱ្យមាន*ទុក្ខវេទនាផ្សេងៗ*។ នៅពេលគំនិតទាំងនេះចម្រើនឡើង ហើយតាមពិតទៅ*ការប្រតិបត្តិសំខាន់* ផ្សេងៗទៀតក៏ចាប់ផ្ដើមកើតឡើងដែរ។ ការប្រតិបត្តិទាំងនោះរួមមាន*ពិធីបុណ្យ*(rites[1]) *ក្បួនវិធី* (rituals)និង*ពិធី* (ceremonies) ឬ *បុណ្យទានា* (festivals) (ដូចជាបុណ្យ*អុំទូក* ជាដើម)។ *សហគមន៍ ដោយឡែកៗ*បានរៀប ចំពួកគេដោយអនុលោមទៅតាម *តម្រូវការផ្ទាល់* របស់ពួកគេទៅតាម *តំបន់ភូមិសាស្ត្រផ្ទាល់* របស់ពួកគេ។ នៅពេលមាន*របរាងពិធី* និង*គំនិតទស្សនវិជ្ជាធំគ្រប់គ្រាន់"សាសនា"* បានក្លាយទៅជា *ផ្នែកស្នូល* នៃ *គ្រប់អរិយធម៌* ទាំងអស់។

មូលដ្ឋានរបស់*សាសនា*ត្រូវបានរៀបចំឡើងដោយ *មនុស្ស* តាំងតែពីដើមដំបូងមកសម្រាប់*ការពារខ្លួន* (self-preservation) ពី *ភាពភ័យខ្លាច ភាពមន្ទិលសង្ស័យ ភាពអន្តិសុខការយល់ខុស*ចំពោះ *ជីវិត* និង*បាតុភូតធម្មជាតិ*។ ទាំងអស់នេះបានបម្រើជា *មូលដ្ឋានសាសនា* ដែលមានសម្ភារៈដូចជា *ឥដ្ឋ ថ្ម ខ្សាច់ ស៊ីម៉ង់* និង *ផែនដី*ជាដើមត្រូវបានគេយកមកប្រើសម្រាប់រៀបចំធ្វើជា*មូលដ្ឋានអាគារ*។

បន្ទាប់ពីនោះមក *មនុស្ស* បានរៀបចំតុបតែង*អាគារសាសនានេះ*ដោយការប្រើប្រាស់ *ជំនឿ ការសែនព្រេន* (offering) *អ្នកឧទ្ទិស ការសច្ចា ទោសបញ្ញត្តិ* (penalties) *សីលធម៌* និង *សីលវិជ្ជា* ក្នុងនាម *អាទិទេព* ដើម្បីគ្រប់គ្រង *មនុស្សជាតិ*ហើយក៏ដើម្បីរកឱ្យឃើញពី *កន្លែងគ្មានទីបញ្ចប់* ដែលគេឱ្យឈ្មោះថា *ស្ថានសួគ៌*សម្រាប់ *សេចក្ដីសុខ* និង *សេចក្ដីស្ងប់អមតៈ*នៃ *ព្រលឹង*ផងដែរ។

**មូលដ្ឋានគ្រឹះនៃព្រះពុទ្ធសាសនា** (Foundation of Buddhism)

ក្រោយមកទៀត *សាសនា* មួយទៀតដែលគេឱ្យឈ្មោះថា *ព្រះពុទ្ធសាសនា* នោះក៏ចាប់មានអត្ថិភាពឡើង ប៉ុន្តែយើងបានរកឃើញថា *ព្រះពុទ្ធ* បានប្រើ *ជំនឿសម័យចាស់ៗ* (age-old beliefs)។ ព្រះអង្គមិនបានមាន *គំនិតអំពីអាទិទេព ទ្រឹស្ដីព្រលឹងឋាននរក* (eternal hell)ឬ *ឋានសួគ៌អមតៈ* (eternal heaven) ដើម្បីបង្កើត*ព្រះពុទ្ធសាសនា*នោះឡើយ។ ព្រះអង្គមិនបានបំភ័យ ឬប្រើទស្សនៈប្លែកពីធម្មតា (distorted view) ចំពោះ *បាតុភូតធម្មជាតិ* ដើម្បីឱ្យមកជឿលើ*សាសនា*របស់ព្រះអង្គឡើយ។ ព្រះអង្គមិនពឹងផ្អែកទៅលើ *ជំនឿងងឹតងងុល ឬពិធីបុណ្យមិនចាំបាច់*អ្វីនោះទេ។ ព្រះអង្គមិនជឿទៅលើ *ការធ្វើទារុណកម្មខ្លួនការដាក់ទោសបញ្ញត្តិ* ឬ *សេចក្ដីបង្ខាប់នៅក្នុងការផ្សព្វផ្សាយព្រះពុទ្ធសាសនា*ឡើយ។ ព្រះអង្គក៏មិនបានស្វែងរកនូវ *អំណាច*នៃ

[1] បុណ្យយ៉ាងឱឡារិកតាមបែបសាសនា ឬប្រពៃណីដូចជា បុណ្យសព ឬពិធីមង្គលការជាដើម

*អ្នកតំណាងអាទិទេព* ខាងក្រៅខ្លួនដើម្បីពង្រឹងអំណះអំណាងរបស់ព្រះអង្គនោះដែរ។ ព្រះអង្គប្រើ *គំនិតឬរូបធាតុ* ដូចជា *សម្មាទិដ្ឋិ* ចំពោះ *ជីវិតពិភពលោក* និង *បាតុភូតធម្មជាតិ* ឬ *សណ្តាប់ធ្នាប់លោកធាតុ* និង *លក្ខណៈពិតនៃ* *ចិត្ត* និង *រូបកាយ* *ធាតុនានា*និង *ថាមពល* *សីលធម៌* និង *ការអភិវឌ្ឍន៍ផ្លូវចិត្តវិន័យការអប់រំ* និង *ការធ្វើឱ្យខួរក្បាល* *ល្អបរិសុទ្ធ* *គតិបណ្ឌិត* *ចំណេះដឹងនិងការត្រាស់ដឹង* ទាំងស្រុងដើម្បីសាងសង់សាសនានេះ ដែលគេឱ្យឈ្មោះថា *ព្រះពុទ្ធសាសនា*នេះ។ វាជាការពិតថា ព្រះអង្គប្រើ *រូបធាតុសាសនាពិត* (certain religious materials) ដែលបានប្រើដោយអ្នកសាសនាដទៃទៀតនៅសម័យកាលនោះដូចជា *កម្ម*(Karma) *អំពើ* និង *ការធ្វើប្រតិកម្ម* *ការចាប់កំណើតឡើងវិញ* និង *គោលការណ៍សីលធម៌ពិតៗ* ប៉ុន្តែព្រះអង្គ មិនបានធ្វើដូច្នេះនៅក្នុង ឥរិយាបថឬស្មារតីដូចគ្នានោះទេ។ ព្រះអង្គសំអិតសំអាងលាងជម្រះវាហើយបកស្រាយពន្យល់វាទៅតាមបែបមាន *ហេតុផល* និងដោយ *វិទ្យាសាស្ត្រ* យ៉ាងច្បាស់លាស់។

**សាសនាឯករាជ្យមួយ** (An Independent Religion)

*ព្រះពុទ្ធសាសនា*មិនមែនជា *បន្សំសាសនា* ឬជា *បន្សំគំនិតសាសនាផ្សេងៗ* នោះទេ។ *ព្រះពុទ្ធ* មិនបានប្រមូលសម្ភារៈមកពី *សាសនាដទៃ្ទ* *គំនិតទស្សនវិជ្ជា* មកពីទីនេះឬទីនោះនោះទេ។ *ព្រះពុទ្ធសាសនា*មាន *ចរិតលក្ខណៈ* និង *អត្តសញ្ញាណផ្ទាល់* របស់ខ្លួន។ បើតាមការយល់ដឹងថា គ្មាន *គ្រូសាសនាដទៃណា* ដែលបានរកឃើញពី *សច្ចភាពដាច់ខាត* (the Absolute Truth) និង *រូបមន្តចុងក្រោយ* សម្រាប់ *ការជួយសង្គ្រោះចុងក្រោយ*របស់ *មនុស្ស* នោះទេ ព្រះអង្គពន្យល់បង្ហាញថា *អ្នកគិតដទៃទៀត* បានអភិវឌ្ឍតែទៅលើ *អំណាចលោកីយ៍ពិតៗ* ហើយនិងអាចគ្រប់គ្រងដើម្បីសម្រេចឱ្យបានតែដំណាក់កាលពិតនៃ *ការអភិវឌ្ឍន៍ផ្លូវចិត្ត*ដោយ គ្មាន *ចិត្តបរិសុទ្ធពេញបរិបូរណ៍* រួចផុតពី *ជំនឿអបិយជំនឿ* (super-stitious beliefs) សព្វយ៉ាង *គ្មានភាពបរិសុទ្ធមាយាការ* (យល់ច្រឡំ) *វង្វេងវង្វាយអណ្តែតអណ្តូង* និង *អវិជ្ជា*។

*ខ្លឹមសារ* ឬ *គោលបំណងពិត* របស់ *សាសនា*អាចត្រូវបានគេយល់ដឹងពេលយើងសិក្សាថាតើ *ព្រះពុទ្ធ* បានពន្យល់បង្ហាញពី *"មាគ៌ាជីវិតសាសនាប្រសើរខ្ពង់ខ្ពស់"* យ៉ាងដូចម្តេចហើយ។ ប្រសិនបើយើងប្រើពាក្យ *"សាសនា"* ពេលការពិភាក្សាទៅលើ *ការបង្រៀន* របស់ *ព្រះពុទ្ធ* យើងក៏ត្រូវតែយល់ផងដែរពីការបកស្រាយខុសៗគ្នាដែលគេបានឱ្យចំពោះពាក្យនេះដោយអ្នកសាសនាដទៃទៀត។ ដូចនេះអ្នកណាម្នាក់ដែលអាចយល់បានពី *"ហេតុអ្វីបានជាហៅព្រះពុទ្ធសាសនា?"*

ដែល គេត្រូវការនៅពេលមានសាសនាជាច្រើនដទៃទៀតបែបនេះរួចស្រេចទៅ ហើយនៅក្នុងលោកនេះ ។

**មិនគម្ពីរនិយម** (No Dogmas)

*ព្រះពុទ្ធ* បានធ្វើការផ្លាស់ប្តូរការយល់ច្រឡំពិត១ ដែលប្រជាជនធ្លាប់ជឿអស់រយៈពេលរាប់ពាន់ឆ្នាំមកហើយ ។ ជំនឿថា *ព្រលឹង* គឺជា *អង្គឯកភាពអចិន្ត្រៃយ៍មួយ* ដែល *ព្រះអាទិទេព* បានបង្កើតឡើងនោះត្រូវបានគេបោះបង់ចោលនៅពេល *ព្រះពុទ្ធ* ទ្រង់បានផ្តល់នូវ ហេតុផលរឹងមាំមួយពីហេតុថាវាគឺជា *គំនិតមិនត្រឹមត្រូវមួយ* ហើយនិងហេតុថាមិនមានវត្ថុដែលជា *អង្គឯកភាពអចិន្ត្រៃយ៍* បែបនេះឡើយ ។ បើតាម *ព្រះពុទ្ធ* វាគ្រាន់តែជា *សុបិន្ត* មួយប៉ុណ្ណោះ ។ ជំនឿនេះមានអត្ថិភាពនៅក្នុង *ចិត្តមនុស្ស* ប្រៀបដូចជា *ពណ៌ឥន្ទធ្នូ* ដែលជាវត្ថុមើលឃើញដោយភ្នែកដែលការពិតវាមិនមានលក្ខណៈពិតនោះឡើយ ។ *ព្រះពុទ្ធ* បានពន្យល់ថា គំនិតអំពី *ព្រលឹង* គឺគ្រាន់តែជា *ការយល់ច្រឡំនៃ វិញ្ញាណ* របស់ *មនុស្សតែ* ប៉ុណ្ណោះ ។ *គំនិតអំពីព្រលឹងនេះ* គឺជាបញ្ហាសំខាន់បំផុតមួយនៅក្នុងគ្រប់សាសនាទាំងអស់ប៉ុន្តែមានតែ *ព្រះពុទ្ធមួយអង្គ* ប៉ុណ្ណោះដែលបានអះអាងដោយច្បាស់១ថា ចំពោះយើងទោះជាអ្វីក៏ដោយមិនមានហេតុផលណា ដែលត្រូវជឿទៅលើ *អត្ថិភាព* របស់វានោះទេ ។ ជាឧទាហរណ៍នៅក្នុងសម័យនោះ *មនុស្សម្នាក់១* មានជំនឿថា *ព្រះអាទិត្យ* និង *ព្រះច័ន្ទ* វិលជុំវិញ *ផែនដី* រៀងរាល់ថ្ងៃ ។ *មនុស្ស* មានជំនឿនេះសមស្របទៅតាម *កង្វះខាតពុទ្ធិត្រឹមត្រូវ* ចំពោះ *ប្រព័ន្ធព្រះអាទិត្យ* ។ ប៉ុន្តែនៅពេល Copernicus បានពន្យល់បង្ហាញភស្តុតាងថាវាមិនមែនជា *ព្រះអាទិត្យ* និង *ព្រះច័ន្ទ* ដែលត្រូវវិលជុំវិញផែនដីនោះ ទេប៉ុន្តែការណ៍ នេះគឺផែនដីទេដែលត្រូវវិលជុំវិញព្រះអាទិត្យ ដូចនេះបន្តិចម្តង១មនុស្ស បានយល់ពិតពីសច្ចភាពនេះ ។

ដូចនេះ មនុស្សក៏ចាប់លែងយល់ខុសទៅលើ ផែនដីនេះទៀតហើយ ។ អស់រយៈពេលរាប់ពាន់ឆ្នាំមនុស្សមានជំនឿថា ផែនដីមានរាងសំប៉ែត ។ Galileo បានពន្យល់ការពិតថា ផែនដី មានរាងមូល ។ ក្រោយមកមនុស្សទទួលយកនូវសច្ចភាពនោះ ។

នៅពេលលោក *កូពិចណិច* (Copernicus) បានរកឃើញថា ព្រះអាទិត្យគឺជាមជ្ឈមណ្ឌលនៃ ប្រព័ន្ធព្រះអាទិត្យមនុស្សបានបោះបង់ចោលជំនឿចាស់បូរាណថា ផែនដីគឺជាមជ្ឈមណ្ឌលនៃចក្រវាឡ (universe) របស់យើង ។

*ជំនឿ* ដែល ទស្សនវិទូបូរាណជាច្រើនមានរហូតមកដល់សតវត្សទី១៩ ដែលថា អាតូមគឺជាធាតុតូចបំផុត នៃរូបធាតុ (the ultimate entity of matter) ហើយ ដែលគេមិនអាចញែកវាឱ្យ

តូចទៅទៀតបានឡើយនោះត្រូវបានគេបោះបង់ចោលនៅពេល ដែលអ្នកវិទ្យាសាស្ត្រនុយក្លេអ៊ែរអាចញែកវាបាន។

ទ្រឹស្ដីវិវត្តន៍ដែលបានបង្កើតឡើងដោយ Charles Darwin បានបង្ហាញឱ្យឃើញថា ខុសចំពោះទ្រឹស្ដីបង្កើតសត្វលោក ដែលមានប្រជាប្រិយភាពនាពេលនោះដែលថា ជីវិតត្រូវបានបង្កើតឡើងដោយអាទិទេព។ ភូគព្ភវិទូ (geologist) ជីវវិទូអ្នកសរីរសាស្ត្រ (physiologist) ក៏បានពន្យល់យ៉ាងច្បាស់ផងដែរថា អស់រយៈពេលរាប់លានឆ្នាំ មកហើយចំពោះ ការកើតឡើង នៃជីវិតដំបូងដែលមានរូបរាងនៅលើផែនដី។ របកគំហើញទាំងនេះមិនដែលជំទាស់ ជាមួយ នឹងការបង្រៀនរបស់ ព្រះពុទ្ធទៅតាមបែបណាមួយឡើយ។ របកគំហើញសម័យទំនើបចំពោះ ការអភិវឌ្ឍន៍បន្តិចម្ដងៗនៃជីវិតខនិជ (mineral life) ជីវិតរុក្ខជាតិ និងវត្ថុមានជីវិតដទៃទៀតហើយ និងមនុស្សលោកគឺ សុទ្ធតែសមស្របទៅតាមការបង្រៀនរបស់ព្រះពុទ្ធ។

នៅពេលយើងសិក្សាពី ការពន្យល់របស់ ព្រះពុទ្ធចំពោះ លោកធាតុយើងនឹងរកឃើញថាព្រះអង្គបានបញ្ជាក់ទៅលើអត្ថិភាពនៃ ភាវៈមានជីវិតជាក់ស្ដែងទាំងមានភព្វនិងឥតភព្វមិនមែនតែនៅក្នុងលោកនេះទេ ប៉ុន្តែក៏នៅក្នុងភពដទៃទៀតដែរ។

អ្នកវិទ្យាសាស្ត្រនិង តារាវិទូ សម័យទំនើបសុទ្ធតែផ្ដោតទៅលើប្រធានបទនេះ ហើយសុទ្ធតែឯកភាពទៅលើ លទ្ធភាពចំពោះ អត្ថិភាពនៃ ភាវៈរស់មួយចំនួននៅក្នុងភពដទៃៗទៀត។

ជំនឿប្រពៃណីជាច្រើនមានលក្ខណៈ ដូចជំនឿមនុស្សយុគសម័យដំបូងមែនទែនអំពីប្រព័ន្ធពិភពលោក និងដើមកំណើតជីវិត។ ប៉ុន្តែការបង្រៀនរបស់ ព្រះពុទ្ធអះអាងឱ្យឃើញពី របកគំហើញថ្មី។

ព្រះពុទ្ធទ្រង់មិនគាំទ្រជំនឿថា ពិធីបុណ្យសាសនាគ្រាន់តែជាមធ្យោបាយសម្រាប់ មនុស្សដើម្បីរកឱ្យឃើញពី ការជួយសង្គ្រោះតែប៉ុណ្ណោះ។ បើតាមព្រះពុទ្ធ ការអភិវឌ្ឍន៍ធម្មចរិយាការធ្វើសមាធិ ការធ្វើចិត្តឱ្យបរិសុទ្ធគឺជាទិដ្ឋភាពសំខាន់នៅក្នុង ជីវិតសាសនាដែលដឹកនាំទៅរកការជួយសង្គ្រោះចុងក្រោយ។

ព្រះអង្គបានចង្អុលបង្ហាញថា មនុស្ស ដែលមានសាសនាម្នាក់ត្រូវតែដឹកនាំទៅរក ជីវិតឥតទុក្ខទោសគ្មានប្រទូស្តរាយ គួរឱ្យគោរពល្អត្រឹមត្រូវប្រសើរថ្លៃថ្លានិងល្អបរិសុទ្ធ។ អំពើដែល គ្រាន់តែជាការបួងសួងឬ បន់ស្រន់ ឬសែនព្រេនមិនមែនធ្វើឱ្យ មនុស្សមានសាសនាឬសម្រេចបាននូវភាពបរិសុទ្ធឬ ការជួយសង្គ្រោះរបស់គេនោះឡើយ។

ព្រះពុទ្ធ ទ្រង់ក៏បានប្រៀនប្រដៅដល់ មនុស្ស ឱ្យគេចផុតពី ការប្រតិបត្តិលើផ្លូវ អាក្រក់ផងដែរ។ ហេតុផលសម្រាប់ការគេចផុតពី អំពើអាក្រក់នោះគឺពិតជា សុខុមាលភាពរបស់ សត្វលោកទាំងអស់មិនមែនព្រោះតែ ការភ័យខ្លាចឬព្រោះតែ អាទិទេពឬព្រោះតែ ការដាក់ទណ្ឌកម្មនោះទេ។ នៅពេលដូចគ្នានេះព្រះអង្គបានឱ្យដំបូន្មានដល់យើងថា ត្រូវអប់រំ គុណភាពមនុស្សល្អត្រូវអនុវត្តអំពើល្អហើយនិងត្រូវជួយអ្នកដទៃដោយមិនមានចំណង់អត្តទត្ថភាពណាមួយឡើយ។

ព្រះពុទ្ធ គឺជាគ្រូសាសនាតែមួយគត់ ដែលឱ្យតម្លៃដល់បញ្ញាមនុស្ស។ ព្រះអង្គបានឱ្យដំបូន្មានដល់យើងមិនឱ្យក្លាយទៅជា ទាសករ ចំពោះអ្នកនៅខាងក្រៅខ្លួនឡើយប៉ុន្តែឱ្យអភិវឌ្ឍកម្លាំងលាក់កំបាំងរបស់យើងដោយស្វ័យទំនួលខុសត្រូវ ។

ព្រះអង្គក៏បានចង្អុលបង្ហាញផងដែរថា មនុស្សមានទំនួលខុសត្រូវចំពោះ អ្វីៗទាំងអស់នៅក្នុងលោកនេះ។ ជម្ងឺនិង សេចក្តីរីករាយរបស់គេគឺ ខ្លួនគេជាអ្នកកសាងឡើង គេមានលទ្ធភាពកម្ចាត់ សេចក្តីទុក្ខហើយនិងថែរក្សា សេចក្តីស្ងប់សុភមង្គល និងគតិបណ្ឌិតដោយការខំប្រឹងប្រែងរបស់គេដោយមិនពឹងផ្អែកទៅលើកម្លាំងក្រៅខ្លួនឡើយ។ ចិត្តមនុស្ស ដែលមិនបានទទួលនូវការអប់រំគឺត្រូវទទួលខុសត្រូវចំពោះ បញ្ហាសព្វបែបយ៉ាង ដែលយើងកំពុងប្រឈមមុខសព្វថ្ងៃ។ នៅពេលដូចគ្នានេះដែរ ចិត្តមនុស្សប្រសិនបើគេប្រើដោយសមស្រប អាចផ្លាស់ប្តូរ ស្ថានភាពដ៏អភ័ព្វនេះហើយអាចបង្កើត ពិភពរីករាយវិបុលភាពនិង សុខសន្តិភាពសម្រាប់យើងទាំងអស់គ្នារស់នៅបាន។ នេះអាចធ្វើឡើងតែតាមរយៈថាមពលខួរក្បាលបរិសុទ្ធនៃបញ្ញាហ្វឹកហាត់ប៉ុណ្ណោះ។

**ការពិតចំពោះមុខ** (Face Facts)

នេះគឺជា សាសនាមួយ ដែលតែងតែលើកទឹកចិត្ត មនុស្ស ដើម្បីប្រឈមមុខទល់នឹង ការពិតនៃជីវិតដោយមិនសម្តែងអំពើជាមនុស្សលាក់ពុត (hypocrite) ហើយត្រូវទទួលយកសច្ចភាពអ្វីក៏ដោយដែលវាអាចមានពិត។ ដូចនេះពុទ្ធសាសនិកទាំងឡាយឥតបដិសេធ ការពិត ដែលជាប់ទាក់ទងទៅនឹង បញ្ហាលោកិយ៍ ដែលអ្នកគិត និងអ្នកវិទ្យាសាស្ត្រធំៗ បានរកឃើញនេះឡើយ។ បើទោះជាព្រះពុទ្ធ បានយកព្រះទ័យទុកដាក់ច្រើនទៅលើការអភិវឌ្ឍន៍ផ្លូវចិត្តក៏ដោយ ក៏ព្រះអង្គមិនដែលបំភ្លេចចោលនូវវឌ្ឍនភាពលោកិយ៍របស់ មនុស្សឡើយ។ នៅក្នុងការបង្រៀនរបស់ព្រះអង្គយើងអាចរកឃើញដំបូន្មានប្រតិបត្តិសមរម្យមួយចំនួនសម្រាប់មនុស្សដើម្បីធ្វើការងារដោយសមរម្យ ដោយមិនបំផ្លាញពេលវេលា និងការខំប្រឹងប្រែងដ៏មានតម្លៃនោះឡើយ ហើយព្រះអង្គខិតខំធ្វើដោយឆ្លាត វៀងវៃសម្រាប់វឌ្ឍនភាពរបស់ មនុស្សជាតិ។ ព្រះអង្គទ្រង់ត្រាស់សម្តែងថា

មនុស្សគួរតែបំពេញករណីយកិច្ចរបស់គេចំពោះ គ្រួសារបងប្អូនសាច់សាលោហិត មិត្តភក្រ្ត សហគមន៍ ប្រទេស និងពិភពលោកទាំងមូលរបស់គេ។

ដូច្នេះ ពុទ្ធសាសនិកជនទាំងឡាយមិនគួរបំភ្លេចចោល ករណីយកិច្ចនិង កាតព្វកិច្ច របស់ពួកគេដើម្បីធ្វើឱ្យ ពិភពលោកនេះមាន សន្តិភាព និង សុភមង្គលដោយចែករំលែកទៅតាមសមត្ថភាពផ្ទាល់របស់ពួកគេនោះឡើយ។ ព្រះអង្គក៏មិនបានជ្រៀតជ្រែក នឹងកិច្ចការរបស់ រដ្ឋាភិបាលឬជាមួយនឹងច្បាប់ដែលមានហេតុផលគ្រប់គ្រាន់ដែលរដ្ឋាភិបាលបានដាក់ឱ្យគេគោរពនោះឡើយ ។ ព្រះអង្គក៏មិនបានប្រឆាំងនឹង ទំនៀមទម្លាប់និង ប្រពៃណីសង្គមណាមួយ នោះឡើយប្រសិនបើវា មិនបង្កទុក្ខទោស ហើយនិងមានប្រយោជន៍ចំពោះសង្គម។ ដូចគ្នានេះដែរ ព្រះអង្គមិនដែលខិតខំស្វែងរក អំណាចនយោបាយឬ យោធា ដើម្បីផ្សព្វផ្សាយពី មាគ៌ាជីវិតសាសនារបស់ព្រះអង្គឡើយបើទោះជា ស្តេចនិង រដ្ឋមន្ត្រីគឺជា សាវ័ករបស់ព្រះអង្គក៏ដោយ។

នេះគឺជា សាសនាមួយដែលបង្រៀនយើងឱ្យបម្រើ អ្នកដទៃ ឱ្យធ្វើពលីកម្ម ផាសុខភាពផ្ទាល់របស់យើងដើម្បី មនុស្សជាតិដែលមានទុក្ខ ហើយនិងឱ្យប្រតិបត្តិតាម សិក្ខាបទឬ វិន័យសាសនាដោយស្ម័គ្រចិត្ត ប៉ុន្តែមិនមែនជា បទបញ្ជា ដែលបានគោរពដោយ អំណាចដែលគ្មានការយល់ដឹងណាមួយនោះទេ។ តាមការប្រតិបត្តិតាម គោលការណ៍ល្អបែបនេះ បើតាមការជឿជាក់ផ្ទាល់របស់យើង មិនត្រឹមតែយើងទទួលបាននូវភព្វសំណាងឱ្យបានសុក្រិតនោះទេ ប៉ុន្តែយើងថែមទាំងបានជួយ អ្នកដទៃ ឱ្យរស់ដោយ សុខសន្តិភាពទៀតផង។

សុក្រឹតភាពនេះ គឺជាគោលបំណងខ្ពស់បំផុត ដែលមនុស្សម្នាក់ ត្រូវតែសម្រេចឱ្យបានដើម្បីទទួលបាននូវការជួយសង្គ្រោះរបស់គេ។ គេមិនអាចទទួលបានវាតាមរយៈឥទ្ធិពលរបស់អាទិទេពឬដោយ សន្ធាការី (អ្នកនាំសម្រុះសម្រួល) (mediator[2]) ណាមួយឡើយ។

បើតាម សាសនានេះយើងអាចយល់បានថា លទ្ធផលនៃ អំពើល្អ ឬ អាក្រក់ របស់យើងភាគច្រើនមាននៅក្នុង ជាតិនេះ និង ពេលនេះតែម្តង។ បរមសុខសួគ៌ាឬបរមសុខព្រះនិព្វាន អាចត្រូវធ្វើពិសោធន៍នៅក្នុងជាតិនេះ។ ដោយមិនចាំបាច់រង់ចាំមើល លទ្ធផលតែនៅ ក្រោយពេលស្លាប់ឬនៅជាតិក្រោយ ដែលសាសនាដទៃជាច្រើនបានបង្រៀននោះទេ។

នេះគឺជាហេតុដែល ព្រះពុទ្ធតែងតែស្វាគមន៍ចំពោះ មនុស្សទាំងឡាយដែលចូលមកស្តាប់ការបង្រៀនរបស់ព្រះអង្គ ប៉ុន្តែមិនមែនចូលមកដើម្បីជឿតែម្តងនោះទេ។ ព្រះអង្គក៏តែងតែឱ្យ

---

[2] អ្នកនាំសម្រុះសម្រួល

ដំបូន្មានដល់មនុស្សទាំងឡាយ ធ្វើការជ្រើសរើស សាសនាសមរម្យមួយដោយ ការគិតពិចារណាដោយពិនិត្យសង្កេតទៅតាមបែបផ្សេងៗ ដោយគ្មានការទទួលយកអ្វីមួយតាមរយៈការរំជួលចិត្ត ឬដោយជំនឿងងឹតងងុលនោះឡើយ។ នេះគឺជាហេតុដែល ព្រះពុទ្ធសាសនាត្រូវបានគេឱ្យឈ្មោះថា លទ្ធិវិភាគ។ នៅត្រង់នេះនៅក្នុងសាសនានេះ យើងអាចមើលឃើញពី ការវិភាគចិត្តសាស្ត្រ និង វិទ្យាសាស្ត្រចំពោះ ចិត្តនិងរូបកាយ ដែលអ្នកគិតសម័យទំនើបអាចវាយតម្លៃបាន។

**ច្បាប់សាកល** (Universal Laws)

ព្រះពុទ្ធ គឺជាគ្រូដែលបានរកឃើញធម្មជាតិពិតនៃច្បាប់លោកធាតុសកលហើយឱ្យដំបូន្មានដល់មនុស្ស ដើម្បីរស់នៅដោយអនុលោមទៅតាមច្បាប់នេះ។ ព្រះអង្គបានបញ្ជាក់ថា អ្នកណាដែលបំពារបំពានលើច្បាប់នេះដូចជាទៅប្រឆាំងនឹង ធម្មជាតិការដឹកនាំ ជីវិតអសីលធមិជាដើម ពិតជានឹងត្រូវប្រឈមមុខទល់នឹង ផលវិបាកជាមិនខាន។

យើងអាចមើលឃើញពីភស្តុតាង ដ៏ធំធេងអំពីបញ្ហានេះនាពេលសព្វថ្ងៃ។ពីព្រោះ បដិវត្តន៍ឧស្សាហកម្ម កាលពីសតវត្សកន្លងមកផ្នែកដ៏ធំធេងរបស់ផែនដីត្រូវបានបំផ្លាញសមុទ្រ និងស្ទឹងទន្លេត្រូវបានបំពុលចំពោះវិសាល ភាពបែបនេះដែលយើងមិនអាចមានលទ្ធភាពស្តារប្រភពធនធានធម្មជាតិរបស់យើង ដែលគេបានធ្វើឱ្យខូចខាតនេះឡើងវិញបានឡើយ។ បញ្ហានេះត្រូវបានបង្កដោយផ្ទាល់តាមរយៈការលោភលន់បំពារបំពានរបស់ មនុស្សចំពោះទ្រព្យសម្ភារៈហើយសមទៅនឹងកង្វះខាតការយល់ដឹងរបស់គេចំពោះ តុល្យការល្អរវាងមនុស្ស និងធម្មជាតិនេះឯង។

គេមិនអាចរត់គេចចេញពី ការមានប្រតិកម្មនៃ ច្បាប់លោកធាតុ បែបនេះជាធម្មតា ដោយបួងសួងអាទិទេពនោះបានឡើយ ពីព្រោះ ច្បាប់សកលនេះមានលក្ខណៈ មិនលំអៀង (unbiased)។ ប៉ុន្តែ ព្រះពុទ្ធទ្រង់បានបង្រៀនយើងឱ្យចេះពីរបៀបដើម្បីបញ្ចប់ ប្រតិកម្មនៃ ការប្រតិបត្តិអាក្រក់ជាក់ស្តែងដោយធ្វើ អំពើកាន់តែល្អឡើងៗ ដោយហ្វឹកហាត់ចិត្ត ហើយនិងបំផ្លាញ គំនិតអាក្រក់ៗពីក្នុង ចិត្តឱ្យអស់បន្ទាប់ពីការរំលោភទៅលើ សណ្តាប់ធ្នាប់ លោកធាតុ ហើយ គ្មានវិធីដទៃណា ដើម្បីកម្ចាត់ការប្រតិកម្មលើកលែងតែតាមរយៈការពួតដៃគ្នាជាមួយនឹង ច្បាប់លោកធាតុដូចគ្នា។ អត្តទត្ថភាពត្រូវតែជំនួសដោយ ភាពគិតពីអ្នកដទៃ (selfishlessness)។ សេចក្តីលោភត្រូវតែជំនួសដោយចិត្តសប្បុរស(generosity)។

កម្ម ដែល ព្រះពុទ្ធទ្រង់បានសម្តែង ត្រូវបានទទួលយកដោយ ចិត្តវិទូល្បីល្បាញនៃពិភពលោក Carl Jung ដែលជាការយកចិត្តទុកដាក់រួម។ នេះគ្មានអ្វីក្រៅពី ឃ្លាំងកម្មដែលដុះដាល

នៅក្នុងថាមពលខួរក្បាលនោះទេ (this is nothing but the depository of Karma seeds in mental energy) ។ ដរាបណាវិញ្ញាណប្រមូលផ្តុំ (the colle-ctive consciousness) និង "មានបំណងរស់នៅ (will to live)"នៅតែមាននៅក្នុង ចិត្តដូចដែល ទស្សនវិទូនានា បានបញ្ជាក់ដែរនោះ ការចាប់កំណើតថ្មីនិងកើតមានឡើងថាតើ មនុស្សជឿវាដែរឬទេ។ ធាតុនានានៃ រូបកាយអាច បែកធ្លាយទៅបាន ប៉ុន្តែចរន្តខួរក្បាល(mental current) នៅរួមគ្នាជាមួយនឹង "មានបំណងរស់នៅ" នឹងត្រូវបានបញ្ជូនមកហើយ ជីវិតមួយទៀត នឹងត្រូវបានបង្កលក្ខខណ្ឌឡើង ដោយអនុលោមទៅតាមវិញ្ញាណប្រមូលផ្តុំនោះ ។

កម្លាំងទំនាញនិងច្បាប់រក្សាថាមពល ត្រូវបានរកឃើញដោយ អ្នកវិទ្យាសាស្ត្រសម័យទំនើបដូចជា Newton គាំទ្រលទ្ធិកម្មឬអំពើនិង ការធ្វើប្រតិកម្មដែលបានណែនាំដោយព្រះពុទ្ធ។

បើតាម ព្រះពុទ្ធ មនុស្សអាចក្លាយទៅជា អាទិទេពប្រសិនបើគេដឹកនាំ មាគ៌ាជីវិតត្រឹមត្រូវមិននឹកគិតដល់ ជំនឿសាសនារបស់គេ ប៉ុន្តែ សាសនាដទៃគ្រាន់តែឱ្យដំបូន្មានដល់ មនុស្ស ឱ្យបួងសួងដល់ អាទិទេពដើម្បីទទួលបានបរមសុខ។ ពួកគេក៏បានសម្តែងផងដែរថា មានតែក្រោយពេល ស្លាប់ទេដែលអាចទៅដល់ ឋានសួគ៌ បានប៉ុន្តែ បរមសុខ ឬបទពិសោធន៍សួគ៌ានោះមិនមានន័យថាមនុស្សក៏អាចមានសិទ្ធិក្លាយទៅជាអាទិទេពផងដែរនោះទេ ។តែទោះជាយ៉ាងណាក៏ដោយគំនិតព្រះពុទ្ធសាសនាអំពីអាទិទេពនេះខុសប្លែកពីគំនិតរបស់សាសនាដទៃទៀត។

គ្មានអ្នកបង្កើតសាសនាណាមួយ ធ្លាប់បាននិយាយថា សាវ័កក៏អាចមាន ភព្វសំណាង នៅថ្ងៃណាមួយដើម្បីសម្រេចបាន គតិបណ្ឌិតដូចគ្នា ទីកន្លែងដូចគ្នា សុភមង្គល និងការជួយសង្គ្រោះដូចដែល មេសាសនានោះទទួលបានដែរ។ ប៉ុន្តែព្រះពុទ្ធបាននិយាយថា អ្នកណាម្នាក់អាចក្លាយទៅជាព្រះពុទ្ធមួយអង្គបានប្រសិនបើអ្នក នោះអាចប្រតិបត្តិបាននូវសុក្រឹតភាពដូចគ្នា វិធីដូចគ្នាដូចព្រះអង្គប្រតិបត្តិនោះ។

**ធម្មជាតិនៃចិត្ត** (The Nature of Mind)

ការប្រែប្រួលនៃចិត្តដ៏ឆាប់រហ័សហើយនិងធាតុ នៃរូបកាយ ត្រូវបានលើកយកមកពន្យល់នៅក្នុង ព្រះពុទ្ធសាសនា។ បើតាមព្រះពុទ្ធនៅគ្រប់វិនាទីចិត្ត តែងតែកើតឡើងនិងរលត់បាត់ទៅវិញ។ ជីវវិទ្យាសរីរវិទ្យានិង ចិត្តវិទ្យាក៏បង្រៀនធម្មជាតិនៃ ការផ្លាស់ប្តូរនៅក្នុងជីវិតដូចគ្នាដែរ។ ដូច្នេះ ជីវិតមិនមែនមិនប្រែប្រួល (static) នោះទេ។

ចិត្តវិទូលោកសាស្ត្រាចារ្យ William James បានពន្យល់ពីខណៈនៃវិញ្ញាណ (point-moment of cons-ciousness)។ លោកបានពិភាក្សាថាតើ វិញ្ញាណកើតមានហើយៗរលត់ទៅវិញម្តងហើយម្តងទៀត ជាបន្តបន្ទាប់មិនដាច់យ៉ាងលឿនបំផុតយ៉ាងដូចម្តេច។

បើតាម ធម្មជាតិដែលបង្កើតឱ្យមាន ដំណើរចិត្តបន្តៗគ្នា ចិត្តកើតយ៉ាងលឿនបំផុតវាផ្តល់កំណើតដល់ ចិត្តមួយទៀតហើយក៏រលត់ទៅវិញ។ ចិត្តដែលកើតឡើងត្រឡប់ទៅជាឱ្យ កំណើតដល់ ចិត្តមួយទៀតហើយក៏រលត់ទៅវិញជាដើម ។ល។

ចំពោះចំណោទថា តើគំនិតអាក្រក់កើតឡើងនៅក្នុងចិត្តមនុស្សយ៉ាងដូចម្តេចកាលពីចាប់ផ្តើមនោះគេអាចរកឃើញចម្លើយរបស់វានៅក្នុង សាសនានេះ។ ហេតុនៃ គំនិតអាក្រក់ទាំងនោះគឺជាកម្លាំងជម្រុញអត្តទត្ថភាពរបស់មនុស្សដែលមានអត្ថិភាពព្រោះតែតណ្ហាចង់បានអត្ថិភាព ហើយនិងក្នុងជំនឿរបស់គេទៅលើអត្តនិច្ចភាព(permanent ego) ដែលចង់បាននូវសោមនស្សភាពនៃឥន្ទ្រិយារម្មណ៍។

ពេលយើងសិក្សាទៅលើ ជីវិតហើយនិង ការបង្រៀនរបស់ព្រះពុទ្ធយើងអាចយល់បានថាអ្វីៗសុទ្ធតែបើកចំ ហរទៅរកអ្នកទាំងអស់គ្នា។ គ្មានលទ្ធិអាថិកំបាំងនោះទេ។

ព្រឹត្តិការណ៍ដែលកើតមានឡើងក្នុងអំឡុង ពេញមួយជីវិតរបស់ព្រះអង្គ គឺមានលក្ខណៈបើកចំហ ហើយគ្មាន ឧប្បត្តិហេតុអធិធម្មជាតិឬ លាក់កំបាំងអ្វីនោះឡើយ។ នៅក្នុងក្រសែចក្ខុរបស់ ព្រះពុទ្ធអំណាចអធិធម្មជាតិ ចំពោះមនុស្សជាច្រើនមិនមានលក្ខណៈ អធិធម្មជាតិនោះទេ ប៉ុន្តែមានតែ បាតុភូតធម្មជាតិប៉ុណ្ណោះដែល មនុស្សធម្មតា មិនអាចយល់ដឹងបាន។ ដូចជា ចំណេះដឹងនិង ការយល់ដឹងរបស់ មនុស្សចំពោះ ពិភពលោកបានពង្រីក ជំនឿរបស់ គេទៅលើ ដំណើរថយចុះអធិធម្មជាតិ។ ចំពោះមនុស្សសម័យដើម "ផ្គរលាន់ និងផ្លេកបន្ទោរ" គឺជាការសម្តែងពីការខឹងសម្បាររបស់អាទិទេព។ សព្វថ្ងៃនេះយើងដឹងថាវាគ្រាន់តែជាបន្ទុកអគ្គីសនីប៉ុណ្ណោះ។

ប្រសិនបើ វត្ថុបន្សំនានា គឺជាប្រធានបទមួយចំពោះ ច្បាប់ផ្លាស់ប្តូរធម្មជាតិ ការចុះទ្រុឌទ្រោមហើយនិងស្លាប់ទៅវិញតើយើងអាចពន្យល់ពីវាថាជាកម្លាំងអធិធម្មជាតិបានយ៉ាងដូចម្តេច?

សូម្បីតែកំណើតការត្រាស់ដឹង និងការយាងចូលនិព្វាន្តរបស់ព្រះពុទ្ធក៏កើតឡើងដោយបើកចំហដែរ។ ព្រះអង្គគង់នៅជាគ្រូសាសនាធម្មតាហើយ និងជាមនុស្សពិតៗទៀតផង។

ព្រះពុទ្ធទ្រង់ចង្អុលបង្ហាញថា ដំណើរនៃការវិវត្តពីជីវិតសត្វទៅដល់ ឋានៈជាមនុស្សហើយនិងពី ឋានៈជាមនុស្សទៅដល់ឋានៈជាទេវតា។ ជីវិតជាទេវតាបន្តទៅ ភាពជាព្រហ្មនិងជីវិតជា

ព្រះពុទ្ធឈានចូលទៅក្នុងជីវិតសុក្រឹត។ គេក៏អាចបន្តមកពីជីវិតបរិសុទ្ធប្រសើរថ្លៃថ្លាដោយផ្ទាល់ចូលទៅដល់ជីវិតបរិសុទ្ធសុក្រឹតមួយ ។ព្រះពុទ្ធបានចង្អុលបង្ហាញពីសណ្តាប់ធ្នាប់ថយក្រោយពោលគឺទៅពីជីវិតជាមនុស្សចូលទៅក្នុងជីវិតជាសត្វ ។

**មាគ៌ាជីវិតកណ្តាល** (Moderate Way of Life)

ព្រះពុទ្ធបានផ្តល់ដំបូន្មានដល់ មនុស្សឱ្យដើរតាម មាគ៌ាកណ្តាល នៅគ្រប់ទិដ្ឋភាពរស់នៅរបស់ពួកគេ។ ប៉ុន្តែមនុស្សជាច្រើន មិនយល់ការពិតពីខ្លឹមសារនិង សារៈប្រយោជន៍ពិតនៃមាគ៌ាកណ្តាលដ៏ប្រសើរខ្ពង់ខ្ពស់នេះឡើយ។ អត្ថន័យជ្រាលជ្រៅនៃមាគ៌ាកណ្តាល នេះមិនមែនគ្រាន់តែជា មាគ៌ាជីវិតខាងសាសនា តែមួយនោះប៉ុណ្ណោះទេ មិនមែនគ្រាន់តែជៀសវាង អច្ចន្តភាព នៃជីវិតពីរយ៉ាងមិនគ្រាន់តែដឹកនាំជីវិតជាកណ្តាលនោះទេ ប៉ុន្តែក៏ត្រូវរៀនសូត្រថាតើត្រូវប្រើញាណមនុស្សឬឥន្ទ្រិយារម្មណ៍ ដោយគ្មានការប្រើខុសឬការបំភ័ន្តវាយ៉ាងដូចម្តេចទៀតផង។ ខ្លឹមសារនៃការបង្កើតឡើងនៃ អារម្មណ៍ទាំងនេះ គឺដើម្បីការពារជីវិតយើង ដើម្បីជៀសឱ្យផុតពិការគ្រោះជាក់ស្តែង និងដើម្បីរកសម្មាអាជីវៈរបស់យើងឱ្យឃើញ។ ជាអភព្វមនុស្សជាច្រើនបានចំណាយការរស់នៅ របស់ពួកគេតែទៅលើការបំពេញនៃឥន្ទ្រិយារម្មណ៍ទាំងនេះប៉ុណ្ណោះ ហើយបានប្រើពួកវាខុសតែដើម្បីបំពេញ តម្រេកតណ្ហា របស់ពួកគេទៅវិញ។ ជាចុងក្រោយតណ្ហារបស់ពួកគេបានមានកម្លាំងកាន់តែខ្លាំងឡើងៗ ប៉ុន្តែពួកគេមិន ដែលទទួលបាននូវ ការពេញចិត្តតាមដែលពួកគេចង់បាននោះទេ។ មានការប្រតិបត្តិអសីលធមិជាច្រើនដូចជាអំពើឃោរឃៅ សេចក្តីរំខានក្នុងខួរក្បាល ការខូចសសៃប្រសាទ ការប្រកួតប្រជែងគ្មានសុខភាព អាយតនភាព (tension) និងកោលាហល (unrest) ដែលមានជាទូទៅនៅក្នុងសង្គមទំនើបនោះក៏ព្រោះតែចិត្តទោមនស្សនេះ ដែលប្រើឥន្ទ្រិយារម្មណ៍ខុសនេះឯង។ បន្ទាប់មកកម្លាំងសភាវៈគតិនៃ ឥន្ទ្រិយារម្មណ៍ទាំងនេះក៏បានចាប់ផ្តើមបន្តិចម្តងៗទៅរក ភាពទ្រុឌទ្រោមហើយប្រភេទជម្ងឺ ជាច្រើនក៏ចាប់កើតឡើងនៅក្នុងសរីរាង្គមនុស្សដែរ។ នេះគឺជាលក្ខណៈដែលមនុស្សបានចំណាយតម្លៃចំពោះការប្រើប្រាស់ខុស ឬទាញយកប្រយោជន៍ច្រើនពេក (over-taxing) ទៅលើឥន្ទ្រិយារម្មណ៍ទាំង៥ របស់គេ។ ប្រសិនបើមានឧបាទានច្រើនពេកទៅលើ សេចក្តីរីករាយខាងឥន្ទ្រិយារម្មណ៍នៅក្នុងលោក នេះហើយយើងគ្មានពេលដុះខាត់និងរៀបចំសម្រាប់ជីវិតអនាគត របស់យើងឬសម្រាប់លោក ខាងមុខទេ នោះជីវិត នឹងជួបសេចក្តីវេទនាជាមិនខាន។

ព្រះពុទ្ធ ទ្រង់បានឱ្យដំបូន្មានថា វាមានលក្ខណៈ ឃោរឃៅ និងមិនត្រឹមត្រូវចំពោះយើង ដើម្បីបំផ្លាញសត្វលោកណាមួយ ទោះជាវាតូចយ៉ាងណាក៏ដោយ។ ប៉ុន្តែឥរិយាបថដ៏សុភាពរាបសានេះមិនត្រូវបានយល់ដោយ គ្រូប្រដៅសាសនាដទៃជាច្រើនទៀត ដែលបង្រៀនត្រឹមតែថា ជាការមិនត្រឹមត្រូវដើម្បីធ្វើឱ្យ មនុស្សម្នាក់ទៀតរងទុក្ខទោស។ ការបំផ្លាញការរស់នៅរបស់ សត្វលោកដទៃទៀត មិនមែនជាវិធីរំដោះខ្លួនឱ្យរួចផុតពីភាពសៅហ្មងក្នុងចិត្ត ដែលបានបង្កើតឡើងដោយពួកគេនោះទេ។

គោលបំណង របស់ព្រះពុទ្ធសាសនាគឺដើម្បីធ្វើឱ្យ មនុស្សជាតិរលឹកដឹងខ្លួនដើម្បីចាប់យកសុភមង្គលខ្ពស់បំផុតតាមរយៈការយល់ដឹងច្បាស់លាស់ចំពោះ ជីវិត និងធម្មជាតិ។ គោលបំណងរបស់សាសនានេះគឺមិនមែន ដើម្បីបង្កើតការស្រមើលស្រមៃឬក៏ធ្វើឱ្យការរំជួលចិត្តរបស់មនុស្សរំជួលរីករាយឡើង ឬដើម្បីផ្តេកផ្តួលទៅក្នុងចំណង់លោកីយ៍មិនច្បាស់លាស់នោះទេ។ សាសនានេះក៏សន្យាពីសេចក្តីរីករាយលោកីយ៍គ្មានទីបញ្ចប់ថា នៅកន្លែងណានោះដែរ។

ព្រះពុទ្ធសាសនាបានផ្តល់នូវរូបភាពច្បាស់លាស់មួយចំពោះផ្នែកទាំងពីរនៃជីវិត។ ធម្មជាតិពិតនៃ ជីវិត ហេតុនៃ ទុក្ខនិងហេតុនៃសុភមង្គល។ ទ្រឹស្តីវេជ្ជសាស្ត្រវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាមិនទាន់បានរកឃើញឱសថណាមួយ សម្រាប់ជម្ងឺខួរក្បាលការរសាយចិត្តទោមនស្សភាពនៃជីវិតរបស់មនុស្សនៅឡើយទេ។

**តើគតិបណ្ឌិតជាអ្វី** (What is Wisdom?)

តាម *ទស្សនៈព្រះពុទ្ធសាសនាគតិបណ្ឌិត* ពឹងផ្អែកទៅលើ *សម្មាទិដ្ឋិសម្មាសង្កប្បនិង ការយល់ដឹងពិតចំពោះ ច្បាប់សាកល* ហើយនិង*ការអភិវឌ្ឍន៍បញ្ញា* មិនមែនគ្រាន់តែមើលឃើញពី*សច្ចភាព*នោះប៉ុណ្ណោះទេតែក៏ដើម្បីទទួលបាននូវមាគ៌ាមួយសម្រាប់*រំដោះខ្លួន*រួចផុតពី*ទោមនស្សភាព*នៃ*ជីវិត* នោះផងដែរ។

ដូចនេះ*គតិបណ្ឌិតពិត*គមិនអាចរកឃើញនៅក្នុង*ស្ថាប័នសិក្សា*ឬក៏នៅក្នុង*មន្ទីរពិសោធន៍*នៃ*ការស្រាវជ្រាវវិទ្យាសាស្ត្រ* ឬនៅក្នុង *ទីកន្លែងគោរពសក្ការៈ មួយ* ដែលមនុស្សតែងតែទៅគោរពឬទៅធ្វើ*ពិធីបុណ្យនានា* នោះទេ។ *គតិបណ្ឌិត* គឺស្ថិតនៅក្នុង*ចិត្ត*។កាលណា*បទពិសោធន៍ការយល់ដឹងការយល់ច្បាស់* និង*ការធ្វើឱ្យចិត្តបរិសុទ្ធ* ត្រូវបានគេបំពេញគ្រប់គ្រាន់*គតិបណ្ឌិតនេះ* គឺការឈានទៅដល់*សុក្រឹតភាពខ្ពស់បំផុត* អាចត្រូវបានគេមើលឃើញ។ *គោលបំណងជីវិត*គឺត្រូវសម្រេចឱ្យ*បាននូវគតិបណ្ឌិតនេះឯង* ។ ជំនួសឱ្យការស្រាវជ្រាវរកអ្វី ដែលមាននៅក្នុង

*លំហខាងក្រៅមនុស្សត្រូវតែធ្វើការខិតខំប្រឹងប្រែងដើម្បីរកឱ្យឃើញពី* *ធម្មជាតិ* នៃ*លំហខាងក្នុងផ្ទាល់* របស់គេដើម្បីឈានទៅដល់ *គោលបំណងចុងក្រោយរបស់គេ។*

*មនុស្សអាចកម្ចាត់ កម្លាំងធម្មជាតិលោកីយ៍ ដែលមិនជាទីពេញចិត្តចំពោះគេដោយ ការពង្រឹងនិងការធ្វើឱ្យចិត្តរបស់គេល្អបរិសុទ្ធដើម្បី ទៅឱ្យហួសពីព្រំដែននៃសុភមង្គលលោកីយ៍* (supra- mundane state of happiness) ដែល *កម្លាំងទាំងនេះ* គ្មាន *អំណាច*មកបៀតបៀនដល់អ្នកណាមួយបាន។

*ទស្សនវិទូម្នាក់* បាននិយាយថា *សាសនា* ជំទាស់អ្វីៗសព្វយ៉ាងទាំងអស់ដែល *មនុស្ស* ធ្លាប់បានទទួលបទពិសោធន៍។ ប្រសិនបើវាដូច្នេះមែន*ព្រះពុទ្ធសាសនា* មិនស្ថិតនៅក្នុង*ប្រភេទសាសនា*ទាំងនោះឡើយពីព្រោះ *ព្រះពុទ្ធ*ទ្រង់បានបង្រៀនអ្វីៗប្រាប់យើងតាមរយៈ*បទពិសោធន៍ផ្ទាល់* របស់ព្រះអង្គដែលជានិច្ចកាលជា *មនុស្ស* នៅក្នុង *ធម្មជាតិ*។

មាន *ទស្សនវិទូអ្នកគិតធំៗ* និង*អ្នកវិទ្យាសាស្ត្រជាច្រើន*ប្រើប្រាស់តែ *ពុទ្ធិ កម្លាំងគិត* និង *គតិបណ្ឌិតលោកីយ៍* ប៉ុណ្ណោះដើម្បីរកឱ្យឃើញវត្ថុជាច្រើន ហើយពួកគេបានសម្តែង *ទស្សនៈ* របស់ពួកគេដោយសមស្របទៅតាមនោះដែរ។ សូម្បីតែជាមួយ *ពុទ្ធិបញ្ញាវន្ត* បែបនេះក៏ដោយក៏វាមិនអាចយល់បានទៅលើ *ធម្មជាតិពិត*នៃ *ធាតុភូត*ដោយមិនបាន*ធ្វើចិត្ត*ឱ្យបរិសុទ្ធនោះដែរ។ នៅពេលយើងសិក្សាទៅលើ *អំណះអំណាងពិត* ដែល*អ្នកប្រាជ្ញមួយចំនួន*បានបង្កើតឡើង យើងអាចមើលឃើញពី *សច្ចភាពមួយចំនួន*នៅក្នុង *សុភាសិត*របស់ពួកគេ។ ប៉ុន្តែ *សុភាសិតជាច្រើនទាំងនោះ*ក៏នៅតែជា*ទស្សនវិជ្ជារឹងស្ងួត*ដែល ពីព្រោះពួកគេប្រើប្រាស់តែ*ខួរក្បាល*ដែល *មាយាការ*និង *អត្តទត្តភាព* ប៉ុណ្ណោះ។ *ប៉ុន្តែព្រះពុទ្ធបានប្រើខួរក្បាលនិង បេះដូង របស់ព្រះអង្គជាបញ្ហាមនុស្សបរិសុទ្ធរួមគ្នាជាគូជាមួយ នឹងសេចក្តីមេត្តាករុណាហើយនិងគតិបណ្ឌិតដើម្បីយល់វត្ថុនានា ទៅតាមចក្ខុវិស័យដ៏បរិបូណ៌ត្រឹមត្រូវរបស់វា។ នេះគឺជាហេតុដែល ការបង្រៀនរបស់ព្រះអង្គ ដែលក្លាយទៅជាទស្សនវិជ្ជា ឬ ទ្រឹស្តីមិនចេះរឹងស្ងួតនោះ* ប៉ុន្តែជា *វិធីប្រតិបត្តិ* ដើម្បីដោះស្រាយ *បញ្ហាមនុស្ស*។

នេះជា*សាសនាតែមួយគត់* ដែលបានពន្យល់ដល់ *មនុស្សជាតិ*តាមរយៈ *បទពិសោធន៍ការយល់ពិតគតិបណ្ឌិត* និង *ការត្រាស់ដឹង* របស់ *អ្នកបង្កើត*។ សាសនានេះមិនមែនផ្តល់ជា *សេចក្តីបង្រៀន*មកពី *អាទិទេព* នោះទេ។ បញ្ហាមនុស្សត្រូវតែមានការយល់ដឹងដោយមនុស្សតាមរយៈបទពិសោធន៍មនុស្សដោយការអភិវឌ្ឍន៍គុណធម៌មេត្តាដ៏ធំធេង។ ជាគ្រូម្នាក់របស់មនុស្សត្រូវ

តែរកឱ្យឃើញពីដំណោះស្រាយ ដើម្បីដោះបញ្ហាមនុស្សតាមរយៈបន្សុទ្ធិកម្មនិង ការអភិវឌ្ឍន៍ស្មារតីមនុស្ស។ នេះគឺជាហេតុដែលព្រះពុទ្ធមិនបានបង្ហាញព្រះអង្គជា អ្នកជួយជីវិតអធិធម្មជាតិនោះទេ។ បើតាមព្រះអង្គមានតែខ្លួនយើងប៉ុណ្ណោះ ទើបអាចជួយខ្លួនយើងបាន។

**តើសាសនាពិតជារាំងដល់ដំណើររីកចម្រើនពិភពលោកមែនឬ?**

*ទស្សនវិទូអ្នកគិតធំៗ និងអ្នកវិទ្យាសាស្ត្រជាច្រើន* បានទទួលយល់ស្របជាមួយនឹង*ភរិយាបថប្រឆាំងមួយ*ចំពោះ*សាសនា*។ពួកគេនិយាយថា *សាសនារារាំងដល់ការរីកចម្រើនរបស់មនុស្ស*ជាតិហើយនិងដឹកនាំពួកគេខុសតាមរយៈការណែនាំបង្ហាញជំនឿ និងការប្រតិបត្តិអបិយជំនឿនិងគួរឱ្យចំអកនិងខិតខំព្យាយាមទប់មនុស្សចេញពីការពិតដែលអ្នកវិទ្យាសាស្ត្របានរកឃើញ។ ជាការពិត Karl Marx បាននិយាយថា "*សាសនាគឺជាអាភៀនរបស់មនុស្ស* " ប៉ុន្តែពេលយើងស្រាវជ្រាវរកឃើញនូវអ្វីដែលពួកគេចង់និយាយតាម *សាសនា* នោះ យើងអាច យល់បានថាព្រះពុទ្ធសាសនាមិនមែនស្ថិតនៅក្នុងក្រុមសាសនាទាំងនោះទេ។ ដូច្នេះដល់ពេលត្រូវមកដល់ហើយបើបញ្ញាជនមានជោគជ័យក្នុងការបដិសេធន៍ សាសនា ហើយវាមិនអាចប្រព្រឹត្តទៅបានចំពោះពួកគេដើម្បីបោះបង់ចោល *ព្រះពុទ្ធសាសនា* ជា សាសនាខុសនោះទេ ពីព្រោះព្រះពុទ្ធទ្រង់បានសម្តែងពីសច្ចភាពដាច់ខាត។ ប្រសិនបើមានសច្ចភាពនៅទីណាមួយវានៅតែជាសច្ចភាពជារៀងរហូត។ ប្រសិនបើសច្ចភាពណាមួយអាចផ្លាស់ប្តូរបានក្រោមលក្ខខណ្ឌពិតនានា នៅពេលនោះវាមិនមែនជា សច្ចភាពដាច់ខាតនោះទេ។ នោះគឺជាហេតុដែលសច្ចភាព ដែលព្រះពុទ្ធទ្រង់បានសម្តែង គេឱ្យឈ្មោះថាអរិយសច្ចៈ។ សច្ចភាពនោះដឹកនាំមនុស្សឱ្យក្លាយទៅជាមនុស្សប្រសើរខ្ពង់ខ្ពស់ម្នាក់។ ដូច្នេះវានៅតែមាន មាគ៌ាជីវិតត្រឹមត្រូវនិង ប្រសើរខ្ពង់ខ្ពស់ដែលមានលក្ខណៈរឹងមាំគ្រប់គ្រាន់ដើម្បីប្រឈមមុខទល់នឹងជម្លោះវិទ្យាសាស្ត្រ និងបញ្ញាជនណាមួយ។ នៅក្នុងទិដ្ឋភាពនោះ ពាក្យទូន្មានរបស់ព្រះពុទ្ធមានលក្ខណៈរឹងមាំ។ តាមពិតបញ្ញាជនធ្វើការគោរពដោយ ត្រឹមត្រូវចំពោះមាគ៌ាជីវិតនេះ ប្រសិនបើពួកគេពិតជាអាចយល់ បានពីអ្វីដែលព្រះពុទ្ធទ្រង់បានបង្រៀន។ ដូច្នេះការបង្រៀនរបស់ព្រះពុទ្ធ នឹងនៅតែបន្តជាមាគ៌ា ជីវិតមួយនៅតែបន្តដើម្បីប្រាថ្នាចង់បានចំពោះជីវិតខ្ពង់ខ្ពស់ជីវិតសុក្រឹតនិងល្អពិសិដ្ឋជីវិតសុខសាន្តនិងសុភមង្គលថាតើ យីហោសាសនាមានអត្ថិភាព ឬអត់។

**ជាសាសនាសេរីភាពមួយ** (A Free Religion)

*សេរីភាព*ដែល *អ្នកដើរតាមព្រះពុទ្ធ*សប្បាយរីករាយជាមួយនៅក្នុងលោកនេះនោះ មានលក្ខណៈគួរឱ្យសរសើរណាស់។ ជាការពិត *ពុទ្ធសាសនិកជន* ជាច្រើននៅមិនទាន់យល់ច្បាស់ពីរឿងនេះនៅឡើយទេ។ យើងមាន *សេរីភាព ពេញលេញ* ដើម្បីធ្វើការវិនិច្ឆ័យ និងគិតដោយទទួលយកក្តីឬបដិសេធចោលក្តី។ យើងមិនត្រូវបានចាប់បង្ខំឱ្យទទួលយកអ្វីមួយក្នុងនាមសាសនាជាធម្មតាដោយគិតថាជា *គួសាសនាល្បីល្បាញ* ឬដោយគិតថាវាជា *ករណីយកិច្ច* របស់យើងដើម្បីទទួលយក ពីព្រោះការបង្រៀនទាំងនោះត្រូវបានគេរកឃើញនៅក្នុង គម្ពីរស័ក្តិសិទ្ធិ ឬក៏ព្រោះតែការបង្រៀនទាំងនោះ គឺជាប្រពៃណី ឬទំនៀមទម្លាប់ របស់យើងនោះឡើយ។ ពុទ្ធសាសនិកជនមាន សេរីភាពដើម្បីពិនិត្យសង្កេត និងដើម្បីទទួលយកលុះត្រាតែអ្វីមួយ នោះអាចសមស្របជាមួយនឹងការគិតផ្ទាល់របស់ពួកគេ។ ពុទ្ធសាសនិកជនមិនទទួលយក ឬបដិសេធអ្វីមួយដោយគ្មានហេតុផលសមរម្យនោះទេ។ ពួកគេមិនដែលនិយាយថា ពួកគេត្រូវ បានហាមឃាត់ត្រូវធ្វើនេះ ឬធ្វើនោះនោះឡើយ។ ពួកគេនិយាយថា ពួកគេមិនចូលចិត្តធ្វើអ្វីមួយក៏ព្រោះតែវាបណ្តាលឱ្យមានបញ្ហាឬឥតបានការ ឬមានជម្ងឺឬឆាឆៅក្នុងចំណោមមនុស្សនានានោះទេ។ ពួកគេធ្វើអំពើល្អច្បាស់លាស់មិនមែន ព្រោះតែព្រះពុទ្ធសាសនាតម្រូវឱ្យពួកគេធ្វើបែបនេះនោះទេប៉ុន្តែព្រោះតែពួកគេយល់ច្បាស់ពីតម្លៃ និងអត្ថន័យនៃការប្រតិបត្តិល្អបែបនេះសម្រាប់សុខុមាលភាពរបស់អ្នកដទៃ។ នេះគឺជាសាសនាសេរីភាពមួយដែលមិនមានដាក់កម្រិត ទៅលើកិច្ចការផ្ទាល់ខ្លួនរបស់មនុស្សប្រសិនបើពួកគេមានសីលធម៌ឬសុខស្រួល ។ពុទ្ធសាសនិកជនមានសេរីភាពពេញលេញដើម្បីរៀបចំកិច្ចការគ្រួសាររបស់ពួកគេដោយ មិនបំពារបំពានទៅ លើគោលការណ៍សាសនាមូលដ្ឋានឡើយ។ សាសនានេះប្រៀបដូចជា *រ៉ែមាស* (a gold mine) ចំពោះ *បញ្ញវន្ត* ដើម្បីធ្វើការស្រាវជ្រាវណាមួយ និងដើម្បីរកឱ្យឃើញនូវ *ទិដ្ឋភាពជ្រាលជ្រៅ* ខាង *ចិត្តសាស្ត្រទស្សនវិជ្ជាវិទ្យាសាស្ត្រ*និង*ច្បាប់សកល*សម្រាប់*ការអភិវឌ្ឍន៍ផ្លូវចិត្ត*និងសម្រាប់ សេរីភាពរបស់មនុស្សជាតិពីទោមនស្សភាព និងកោលាហល ។ នេះគឺជាហេតុផលចំពោះព្រះពុទ្ធ*សាសនា*ដែលមានរយៈពេល*ជាង២៥០០ឆ្នាំ* អាចគ្រប់គ្រងដើម្បីឱ្យជឿជាក់ដល់មនុស្សនានា នៅក្នុង *បណ្តាប្រទេសអាស៊ាន* ស្ទើរតែទាំងអស់នៅសម័យកាលនោះ *ប្រជាជន* បានទទួលយកនិងស្វាគមន៏ចំពោះ*ការបង្រៀន* របស់*ព្រះពុទ្ធ* ជា*ការទូន្មានសុខសន្តិភាព* ឬជា*ការទូន្មាន* ដោយ*សុឆន្ទៈ*។ នេះគឺជាហេតុ *ដែលពុទ្ធសាសនិកជនអាចលៃលកស្គាល់ចំពោះសាសនា* នេះដោយ គ្មាន *ការ*

*លំបាកណាមួយ*គ្មានការទទួលយកប្រភេទប្រយោជន៍ណាមួយ(any kind of exploitation) ដោយគ្មានទំនាស់ចំពោះ *ការប្រតិបត្តិវិប្បធម៌* ដែលបានមានជីវិតរួចទៅហើយនោះទេ។

**ហេតុនៃបញ្ហារបស់យើង** (The Cause of Our Problems)

មានទិដ្ឋភាពសំខាន់មួយទៀតនៅក្នុង *សាសនានេះ* គឺការពន្យល់អំពី *ហេតុសំខាន់នៃបញ្ហាមនុស្ស* និង *សេចក្ដីទុក្ខ*។ បើតាមព្រះពុទ្ធយើងកំពុងតែប្រឈមមុខទល់ នឹងបញ្ហាទាំងនេះនៅក្នុង លោកីយ៍យើងនេះដោយហេតុតែតណ្ហាដ៏ខ្លាំងក្លា របស់យើងដែលមានអត្ថិភាពនៅក្នុងចិត្តយើងនេះឯង។ ព្រះពុទ្ធទ្រង់បានសម្ដែងថា មានប្រភេទកម្លាំងតណ្ហាចំនួន៣ នៅក្នុងចិត្តរបស់យើង ហើយទាំងនេះមានការទទួលខុសត្រូវសម្រាប់ អត្ថិភាពការចាប់កំណើតថ្មី ហើយនិងបញ្ហារាប់ពាន់ដទៃទៀត និងការរំខានខួរក្បាលរបស់យើង។ បញ្ហាទាំងនេះរួមមានចំណង់ចំពោះអត្ថិភាព ចំណង់ចំពោះការបំពេញបំណង ខាងឥន្ទ្រិយារម្មណ៍និងខាងលោកីយ៍។ ចំណង់ចំពោះ ការគ្មានអត្ថិភាពជាដើម។ ដើម្បីយល់ពីអត្ថន័យពិតចំពោះបញ្ហាទាំងនេះ យើងត្រូវតែគិតអំពីរឿងនេះ ដោយប្រុងប្រយ័ត្ន និងដោយឆ្លាតវៃជាទីបំផុត រហូតដល់មានការយល់ដឹងច្បាស់លេចឡើងចំពោះយើង។

ទស្សនវិទូ និងចិត្តវិទូល្បីៗ ខ្លាតអន្តរជាតិក៏បានពន្យល់ដូចគ្នាទៅលើកម្លាំងបីទៅតាមភាសាខុសៗគ្នាដែលជា ហេតុបណ្ដាលឱ្យមាន អត្ថិភាព។ Arthur Schopenhauer បានពន្យល់ពីកម្លាំងទាំងបីនេះដូចជា ភេទ(sexuality) ស្វ័យអភិរក្ស (self-preservation) និង អត្តឃាតកម្ម (suicide) ។ ចិត្តវិទូដូចជា Sigmund Freud ជាដើមបាន ពន្យល់វត្ថុតែមួយនេះថាជា កាមតម្រេក (libido) សភាវគតិអត្តៈ(ego instinct) និងសភាវគតិស្លាប់ (death instinct) ។ ទស្សនវិទូម្នាក់ទៀតគឺលោក Carl Jung បាននិយាយថា "ពីប្រភពសភាវគតិបង្កើតឱ្យមានអ្វីៗដោយប្រឌិត" ។ ឥឡូវសូមមើលថាតើបញ្ញាជនល្បីៗត្រូវបានរៀបចំគាំទ្រសច្ចភាព ដែលព្រះពុទ្ធទ្រង់បានសម្ដែងអស់រយៈពេល ២៥សតវត្សមកហើយ។ តែទោះជាយ៉ាងណាក៏ដោយ ពិនិត្យមើលទៅលើការពន្យល់ទាំងនេះ យើងអាចយល់បានថា ព្រះពុទ្ធទ្រង់បានយាងទៅហួស ពីសមត្ថភាពយល់ដឹងរបស់អ្នកគិតធំៗដទៃទៀតចំពោះបញ្ហានេះ ។

# ជំពូកទី២

# ព្រះពុទ្ធ និងការបង្រៀនរបស់ព្រះអង្គ

The Buddha and His Teaching

**១-ព្រះពុទ្ធ** ( The Buddha) By.Ven. Narada Mahathera

លោក Bertrand Russell បានហៅ *ព្រះពុទ្ធ* យ៉ាងត្រឹមត្រូវថា *"មហាអទេវវិទូនៃគ្រប់សម័យកាលទាំងអស់* (the greatest atheist of all times)" ។

ប៉ុន្តែលទ្ធិ *អទេវនិយម*មិនគួរគេយល់ខុសថា ជាសទិសន័យជាមួយនឹងពាក្យ *ភាពមិនជឿសាសនា* នោះទេ។ ដើម្បីកសាង*សន្តិភាព* និង *សុភមង្គលពិតប្រាកដ* រវាង *មនុស្សជាតិការពញ្ញាក់* ខាង*សាសនាស្មោះត្រង់មួយ* គឺជាការចាំបាច់បំផុតនៅក្នុង *ពិភពអសីលធម៌នេះ* (this morally bankrupt world) ។អ្វីដែលជាការសំខាន់នោះគឺមិនមែនត្រឹមតែជំនឿទៅលើ *គោលជំនឿគម្ពីរនិយមស្លាប់ក្រឡា* ឬក៏គ្រាន់តែជាការប្រតិបត្តិតាម *ពិធីបុណ្យសាសនា* ដែលមានគុណប្រយោជន៍ចំពោះមនុស្សនានា នោះប៉ុណ្ណោះទេប៉ុន្តែ *ជីវិតមានប្រយោជន៍* និងល្អស្អាតចំពោះ *សេចក្តីស្រឡាញ់ហេតុផល* និង*យុត្តិធម៌* ដែលផ្អែកលើ *គោលការណ៍ខ្ពង់ខ្ពស់* នៃ *គ្រូគួរឱ្យគោរព* របស់ពួកគេនោះទៀតផង។

លោកសាស្ត្រាចារ្យ Joad និយាយថា "នៅក្នុង *សតវត្សទី៦មុនគ.ស.* មានកើតឡើងនៅ *ឥណ្ឌា* និងនៅ *ចិន* នូវ *គ្រូធំៗចំនួនតិចតួច* ដែលខិតខំព្យាយាមធ្វើឱ្យ *មនុស្ស* យល់ឃើញថា វាជាការមានសារៈសំខាន់ ដែលត្រូវធ្វើអ្វីមួយដែលមានលក្ខណៈ*ល្អត្រឹមត្រូវ* សម្រាប់ជាប្រយោជន៍ផ្ទាល់របស់ខ្លួនដោយឡែកគឺថាតើមាន*អាទិទេព* ឬក៏អត់រវាងពួកគេអ្នក ដែលសំខាន់បំផុតនោះគឺជា *ព្រះពុទ្ធសមណៈគោត្តម* នេះឯង" ។

*ព្រះពុទ្ធ* ទ្រង់បានបញ្ជាក់ពីភាពសំខាន់នៃ*សីលធម៌* ដែលជា *មធ្យោបាយមួយ* ឈានទៅរក*គោលដៅ*។ ព្រះអង្គបានផ្តល់ដំបូន្មានថា យើងគួរតែហ្វឹកហាត់ *សម្មាសង្កប្បៈ* ចំពោះ*ភាពមិនមែនខ្លួន*(selflessness) *សេចក្តីស្រឡាញ់អស់ពីចិត្ត* (loving-kindness) និង *ការមិនមានទុក្ខទោស* (harmlessness) *សម្មាវាចា* ដែលធ្វើឱ្យគេមាន លទ្ធភាពត្រួតពិនិត្យលើ *សម្តីវប៉ិលវប៉ូចសម្មាកម្មន្ត* តាមរយៈការទប់ខ្លួនមិន *សម្លាប់មនុស្ស* ឬ *សត្វ* មិនលួចដោយមធ្យោបាយផ្ទាល់ ឬដោយ ប្រយោលនិងមិនប្រព្រឹត្តខុសក្នុងផ្លូវកាម ហើយនិង*សម្មាអាជីវៈ* ដែលត្រូវរំដោះចេញ

ឱ្យផុតពី *អាជីវកម្មការមិនសម្រេបតាម* ឬ *មធ្យោបាយមិនស្របច្បាប់ណាមួយ* ក្នុងការទទួលបាន*ទ្រព្យសម្បត្តិ*។ ទាំងអស់នេះបង្កើតឱ្យមាន *មូលដ្ឋានគ្រឹះសីលធម៌*។

នៅក្នុងទម្លាប់ប្រចាំថ្ងៃ ព្រះអង្គតែងតែសម្លឹងមើលទៅលើ *បុគ្គលនានា* ដែលត្រូវការឱ្យព្រះអង្គជួយ ព្រះអង្គបានបង្រៀន និងក្រើនរំលឹកដល់ *សាវ័កបួស១* ដែលបានមក ប្រជុំគ្នាដើម្បីស្តាប់ព្រះអង្គហើយនិង *ទេវៈ* (*devas=the gods*) ដែលបានមកស្តាប់ *ព្រះធម៌* ព្រះអង្គ។ ព្រះអង្គបានបង្រៀន *ព្រះធម៌* ដល់ *មនុស្សម្នា* និង *បញ្ញជនទាំងឡាយ* តាមពិតទៅ *ការជ្រៀន* របស់ព្រះអង្គបានទុក *ទឹកដោះ* សម្រាប់ *ទារក* និង *សាច់* សម្រាប់ *យុវវ័យ* (contained milk for the babe and meat for the adult)។ មុនពេលព្រះអង្គសម្តែង ធម្មទេសនា *ព្រះពុទ្ធ* យល់ចំពោះវាថា បើ *ឃ្លាន* គេ ត្រូវផ្តល់ចំណី ព្រោះ *ចំណីអាហារ* សម្រាប់ *រាងកាយ* មានលក្ខណៈចាំបាច់ដូច *ចំណីអាហារ* សម្រាប់ *ស្មារតី* ដែរ។ ព្រះអង្គបានមើលថែទាំ *អ្នកជម្ងឺ* ដោយព្រះហស្តទាំងពីរផ្ទាល់របស់ព្រះអង្គ ហើយទ្រង់សម្តែងឱ្យដឹងថា "អ្នកណាដែលមើលថែទាំចំពោះ *អ្នកជម្ងឺ* ប្រៀបដូចអ្នកនោះមើលថែទាំ *តថាគត* ដូច្នេះដែរ។

*ព្រះពុទ្ធ*ទ្រង់បានស្ថាបនា*សង្គមគ្មានវណ្ណៈ* ដោយបើកទ្វារ*សហគមន៍សង្ឃ* ដល់*គ្រប់បុគ្គលដ៏សមគួរទាំងអស់* ដោយមិនមានការធ្វើឱ្យខុសប្លែកគ្នារវាង*វណ្ណៈ*និង*វណ្ណៈ* នោះឡើយ។ ភាពខុសប្លែកគ្នាមានតែនៅក្នុងការបួសចាស់វស្សាជាង (the seniority of ordination) ដូចជា*លោកនេន* (*samanera*) *ព្រះភិក្ខុសង្ឃ ព្រះថេរៈ និងព្រះមហាថេរៈ* និងសមិទ្ធផលលំដាប់ៗនៃ *មាគ៌ា* supram undane *បួន* ប៉ុណ្ណោះ។ Sangharajas និង Nayaka Theras គឺជាការកែប្រែថ្មីក្រោយ។ សូម្បីតែ *ធម្មនុញ្ញ* របស់*សហគមន៍សង្ឃ* ក៏ត្រូវបង្កើតឡើងដោយ *ប្រជាធិបតេយ្យ* ដែរ។ ឈរលើចំណង ទាក់ទងនេះ លោក Lord Zetland និយាយថា *"វាអាចជាការភ្ញាក់ផ្អើលមួយចំពោះមនុស្សជាច្រើន ដែលត្រូវសិក្សាដោយហេតុថា នៅក្នុងសភារបស់ពុទ្ធសាសនិកជននៅប្រទេសឥណ្ឌាអស់រយៈពេលជាង២០០០ ឆ្នាំកន្លងមកហើយ ដែលគេបានរកឃើញពី បឋមវិធាននៃការអនុវត្តន៍សភារបស់យើងនាពេលសព្វថ្ងៃនេះ"*។

ដូចគ្នានេះដែរកាលពីគ្រាដំបូងនៅក្នុងប្រវត្តិសាស្ត្រ*ព្រះពុទ្ធ*បានបង្កើត*វិន័យដូនជីសាសនា* សម្រាប់ស្ត្រីៗដោយមិនគោរពទៅតាម *វណ្ណៈ* នោះឡើយ។ ដូចនេះព្រះអង្គបានផ្តល់ *សមភាព* ដល់*ភាពជាស្ត្រី* សម្រាប់ *ការអភិវឌ្ឍន៍ផ្លូវចិត្ត*។

*ព្រះពុទ្ធ* ក៏ជា*មនុស្សដំបូង* ផងដែរនៅក្នុងប្រវត្តិសាស្ត្រដែលគេបានដឹងថា ព្រះអង្គប៉ុន ប៉ងលុបចោល *របបទាសភាព* ដោយណែនាំឱ្យស្គាល់ពីគំនិត *ភាពជាបងប្អូន* និង *សេចក្តីថ្លៃថ្នូរ* របស់*មនុស្សជាតិ*។ *ព្រះពុទ្ធ*បានសម្តែងធម្មទេសនាប្រឆាំងចំពោះ *ពិធីបូជាយញ្ញសត្វអភ៊ូ*ដែលជាការថ្វាយ និងនាំពួកគេចូលទៅក្នុង *ដែនកម្លាំង* នៃ *សេចក្តីស្រឡាញ់* (the ambit of loving kindness) ។ *ពុទ្ធសាសនិកជនពិតម្នាក់* ប្រតិបត្តិ *សេចក្តីស្រឡាញ់* នេះចំពោះ *គ្រប់សត្វមានជីវិតទាំងអស់* ដោយគ្មានការខុសប្លែកគ្នាទេ។

*សេចក្តីស្រឡាញ់* ដែលគួរតែបង្កើតឡើងនូវ *មូលដ្ឋាន* សម្រាប់ *ភាពជាបងប្អូន* របស់ជាតិនានា ឬ *ភាពជាបងប្អូន* ខាង*សាសនា*ដែលគួរតែកំទេចចោលនូវគ្រប់ *រនាំងទាំងអស់* ដែលបែងចែក *ជាតិមួយ* ចេញពី *ជាតិមួយ* ឬ *ការហៅសាសនាមួយ* ចេញពី *ការហៅសាសនាមួយទៀត*។ប្រសិនបើ *សាវ័កដែលមាន ជំនឿខុសៗគ្នា* មិនអាចឬនឹងមិនជួបគ្នានៅលើ *វេទិការួមមួយ* ដូចជា*បងប្អូនស្រីប្រុស* នឹងគ្នាដោយសាមញ្ញទេនោះ ពីព្រោះពួកគេមាន*សាសនាខុសៗគ្នា* នៅពេលនោះពិតជា*គ្រូប្រដៅសាសនាធំៗ* នឹងត្រូវទទួលបរាជ័យនៅក្នុង*បេសកកម្មធំៗ* របស់ពួកគេចំពោះ *ហេតុផលមនុស្សធម៌* ជាមិនខាន។

*ព្រះពុទ្ធ*មាន *ការអត់ឱន*ជាទីបំផុត។ *ការមិនអត់ឱន* គឺជា*សត្រូវសាសនាធំបំផុត*។ ដូច្នេះ *ព្រះពុទ្ធ* បានឱ្យដំបូន្មានដល់ *សាវ័ក* របស់ព្រះអង្គកុំឱ្យមានការ *ក្រេវក្រោធខឹង, មិនពេញចិត្ត ឬ មិនសប្បាយចិត្ត* ពេល *អ្នកដទៃ* និយាយ*បញ្ឆី* អំពីព្រះអង្គ*ការបង្រៀន* ឬអំពី*ព្រះភិក្ខុសង្ឃ* របស់ព្រះអង្គ។ *ព្រះពុទ្ធ* ទ្រង់ត្រាស់សម្តែងថា *"ប្រសិនបើអ្នកសម្តែងឱ្យឃើញពីការមិនសប្បាយចិត្តអ្នកមិនត្រឹមតែនាំខ្លួនឯង ឱ្យធ្លាក់ចូលទៅក្នុង ការគ្រោះថ្នាក់បាត់បង់ផ្លូវចិត្តនោះប៉ុណ្ណោះទេ ប៉ុន្តែអ្នកនឹងមិនមានលទ្ធភាព ធ្វើវិនិច្ឆ័យថាតើ អ្វីដែលអ្នកដទៃនិយាយ ត្រឹមត្រូវឬផ្សេងពីនេះទៀតផង។"* បណ្ឌិត S.Radhakrishnan មានប្រសាសន៍ថា *"មនោសញ្ចេតនាដែលមានការត្រាស់ដឹងបំផុត សូម្បីតែក្រោយ ពីត្រាស់ដឹងអស់ពេល ២៥០០ឆ្នាំ ហើយក៏ដោយ"* ។

*ព្រះពុទ្ធ* ទ្រង់មិនបានធ្វើអត្ថាធិប្បាយពន្យល់ពី *គម្ពីរនិយម (dogmas)* ដែលគេត្រូវតែ*ជឿដោយងងឹតងងុល* មិនបានអត្ថាធិប្បាយពី *គោលជំនឿ ឬ ជំនឿ* ដែលគេត្រូវតែទទួលយកដោយ *គ្មានហេតុផល* មិនបានអត្ថាធិប្បាយពី *ពិធី*និង *បុណ្យអបិយជំនឿ* ដែលគេត្រូវប្រតិបត្តិតាម សម្រាប់ការចូលជាផ្លូវការទៅក្នុងជំនឿ *(for formal entry into the fold)*ឡើយ ហើយក៏មិនបានអធិប្បាយពី *ពិធីបូជាយញ្ញនិងការសុំខមាទោស* (penances) *ឥតន័យខ្លឹមសារ* សម្រាប់

*ភាពបរិសុទ្ធ*របស់អ្នកណាមួយឡើយ ។ *ព្រះពុទ្ធ*ទ្រង់បកស្រាយពី*សច្ចធម៌សាមញ្ញៗ* ដល់ *មនុស្ស*ទាំង ឡាយហើយនិង*ការបង្រៀនទស្សនវិជ្ជាជ្រៅៗ* ដល់*បញ្ញវន្តធំៗ*។ ព្រះអង្គបានផ្ដល់ឱវាទដល់ *អ្នកស្វែងរកសច្ចភាព* មិនឱ្យទទួលយក*អ្វីមួយ* ព្រោះតែ *អំណាច* របស់*អ្នកដទៃ* នោះទេ ប៉ុន្តែឱ្យពួកគេធ្វើលំហាត់*វិចារណញ្ញាណ* ដោយផ្ទាល់របស់ពួកគេ ហើយនិងឱ្យ*វិនិច្ឆ័យ* ចំពោះខ្លួនគេថាតើវា*ត្រឹមត្រូវ ឬខុស*។

អំឡុងពេល *ដំណើរសន្តិភាព* នៃ *ការបង្រៀន* របស់ព្រះអង្គអស់រយៈពេល *២៥០០ឆ្នាំ* ការផ្សព្វផ្សាយ *ព្រះធម៌*ប្រព្រឹត្តទៅដោយមិនមានការបង្ហូរឈាមគ្នាសូម្បីតែមួយដំណក់ ។ *ការផ្លាស់ប្ដូរជំនឿសាសនា* (conversion) ធ្វើឡើងដោយមិនប្រើ *កម្លាំង* ឬដោយ *វិធីចាប់ជម្រុញ* អ្វីឡើយ ។ ផ្ទុយទៅវិញ *ព្រះពុទ្ធ* គឺជា *សាសនទូតធំជាងគេ* និង*មុនគេ* ដែលធ្លាប់រស់នៅៗលើផែនដីនេះ ។

*ការបង្រៀន*ដ៏វិសេសបំផុតរបស់ *ព្រះពុទ្ធ* បានរីកសាយភាយ និងនៅតែធ្វើការវាយលុកដោយ *សន្តិភាព*ចូលទៅ ក្នុងប្រទេសនានាកាន់តែច្រើនឡើងៗ នៅក្នុងពិភពលោក ព្រោះហេតុតែមាន*សនិទានភាព* (rationality) *លទ្ធិប្រតិបត្តិភាព* (practicability) *ប្រសិទ្ធភាព* (efficacy) *មិនសង្កត់សង្កិន* (non-aggressiveness) *អធ្យាស្រ័យ* (to-lerance) និង *សកលភាព* (universality) ។ *ព្រះពុទ្ធ ព្រះធម៌*បានផ្ដល់វិភាគទានយ៉ាងធំធេងដល់ *វឌ្ឍនភាពវប្បធម៌នៅក្នុងប្រទេសអាស៊ីជាច្រើន*។ តាមពិតគ្រប់*ប្រទេសកាន់ព្រះពុទ្ធសាសនាទាំងអស់*សុទ្ធតែចម្រើនឡើងនៅក្នុង*កំណើតព្រះពុទ្ធសាសនាទាំងអស់* (the cradle of Buddhism) ។

*ប្រជាជាតិនានា*ទៅមក *កិត្យានុភាព* (empire)ដែលបានកសាងឡើងនៅលើ *អានុភាព* និង*កម្លាំង*សុទ្ធតែរីកចម្រើននិងលិចបាត់ទៅវិញប៉ុន្តែ*កិត្យានុភាពព្រះធម៌*(empire of the dhamma) ដែល *ព្រះពុទ្ធ* ទ្រង់បានបង្កើតឡើង ដោយឈរលើ *សេចក្ដីស្រឡាញ់ មេត្តាករុណា ហេតុផល* នៅតែរីកចម្រើនហើយនឹងបន្តរីកចម្រើនតទៅមុខទៀតជាដរាប ។

## ២.គុណធម៌ធំៗរបស់ព្រះសម្មាសម្ពុទ្ធ

(Great Virtues of the Buddha) By. Ven. Dr. K. Sri Dhammananda

*ព្រះពុទ្ធ* គឺជាការតំណាងឱ្យ *គុណធម៌ធំៗទាំងអស់*។ ចំពោះព្រះអង្គគឺជា *ការតំណាងឱ្យធម្មចរិយាខ្ពស់បំផុត* (សីល) (highest morality, *Sila*) *សមាធិជ្រៅបំផុត* (deepest concentration, *Samadhi*) និង*បញ្ញាមុតស្លះ* (penetrative wisdom, *Panna*) ពោលគឺ *គុណភាព* មិន

អាចប្រៀបផ្ទឹមបាននៅក្នុង *ប្រវត្តិសាស្ត្រមនុស្សជាតិ*។ *គុណភាពដ៏ប្រសើរធំៗ* ទាំងនេះមានចែងនៅក្នុង *ក្រាំងពិសិដ្ឋៗ* ដែលជាប់ទាក់ទងជាមួយ នឹង *ការសម្តែងនានា* របស់ព្រះអង្គ ។

ការបកប្រែ *វគ្គបាលីសង្ខេបមួយ* ដែលមានខ្លឹមសារដូចតទៅ ៖-

"ការពិតបែបនេះ (such indeed) គឺជា *អរហំ* ដ៏ធំធេង (the great *Araham*) ពោលគឺ *សុក្រឹត្យភាព* និង *តម្លៃ* នៃ *អភិវន្ទនាការ* (perfect and worthy of homage) *សម្មាសម្ពុទ្ធោ* ប្រកបដោយ *សព្វញ្ញុភាព* (omniscient) *វិជ្ជា-ចរណ-សម្បន្នោ* ផ្តល់នូវ *ចក្ខុវិស័យច្បាស់លាស់* (clear vision) ហើយមាន *កិរិយាល្អប្រពៃ សុគតោ* ពោលគឺ *ប្រព្រឹត្តល្អ* (well done) *វាចាល្អ* (well spoken) *លោកវិទូ* ពោលគឺ *មានបញ្ញាវៃឆ្លាតក្នុងលោក* (wise in the knowledge of the world) *អនុត្តរោ បុរិស ទម្ម-សារថិ* ពោលគឺជា *គ្មានគ្រូអាចារ្យណាប្រដៅព្រះអង្គ* (peerless trainer of the untameable ones) *សត្ថា ទេវ មនុស្សានំ* ជា *គ្រូនៃ មនុស្សនិង ទេវតា* (teacher of gods and men) *ពុទ្ធោ* *ត្រាស់ដឹង* និងបង្ហាញ *ផ្លូវត្រាស់ដឹង* (enlightened and showing the path to Enlightenment) *ភគវាតិ* មាន *ពរជ័យ* (blessed) ។

**១-អរហំ** (Araham)

*ព្រះពុទ្ធ* ត្រូវបានគេពិពណ៌នាថាជា *ព្រះអរហន្ត* (an Arahant) មួយអង្គនៅក្នុង *ទិដ្ឋភាព៥យ៉ាង* គឺ ៖-

- ព្រះអង្គរួចចាកផុតពី *អំពើសៅហ្មងទាំងឡាយ* (he has discarded all defilements)
- ព្រះអង្គឈ្នះអស់ *មារសត្រូវ* ដែលទាក់ទងជាមួយនឹង *ការកម្ចាត់* នៃ *អំពើសៅហ្មង* (he has suppressed all the enemies connected with the eradication of defilements)
- ព្រះអង្គបំផ្លាញ *វដ្តអត្ថិភាព* (he destroyed the spokes of the wheel of existence)
- ព្រះអង្គមានតម្លៃចំពោះការដែលគេបានផ្តល់ឱ្យនូវ *ដង្វាយ* និងធ្វើ *សក្ការៈបូជា* (he is worthy of being given offerings and paid homage)
- ព្រះអង្គស្មោះត្រង់មិនលាក់កំបាំងនៅក្នុង *ចរិត* ឬនៅក្នុង *ការបង្រៀន* របស់ព្រះអង្គ (he withheld no secrets in his character or in his teachings) ។

*ព្រះពុទ្ធ* គឺជា *ធម្មានុរូប* (figure) ធំបំផុតនៅក្នុង *ប្រវត្តិសាស្ត្រមនុស្សលោក* មាន *ជីវិតសុក្រឹត* មិនចេះភ្លាំងភ្លាត់គ្មានទុក្ខទោសនិងមិនប្រថុយប្រថាន ។ នៅត្រង់គល់ *ដើមពោធិព្រឹក្ស* ព្រះអង្គកម្ចាត់ *អំពើអាក្រក់គ្រប់បែបយ៉ាង* ហើយសម្រេចបានដំណាក់កាលខ្ពស់បំផុតនៃ *សន្តភាព* (sanctity) ។ ព្រះអង្គបានបញ្ចប់ *ទុក្ខសព្វយ៉ាង* ពោលគឺព្រះអង្គ សម្រេចបាន *ព្រះនិព្វាន*។ ព្រះអង្គគឺជា *អ្នក*

*មានកិត្តិយស* ក្នុងលោកមានអភិវឌ្ឍន៍បំផុត។ ការបង្រៀនរបស់ព្រះអង្គ គ្មានភាពអាថ៌កំបាំង ឬសម្ងាត់អ្វីឡើយ ប្រៀបដូចជាសៀវភៅបើកចំហសម្រាប់ *គ្រប់គ្នា* ចូលមកមើល។

**២. សម្មា-សម្ពុទ្ធោ** (Samma-Sambuddho)

*ព្រះពុទ្ធ*ត្រូវបានគេចាត់ទុកថាជា*សម្មា-សម្ពុទ្ធោ* ពីព្រោះព្រះអង្គបានយល់ដឹងពី*អត្ថិភាព*នៃ*ពិភពលោក* នៅក្នុង*ទស្សនវិស័យត្រឹមត្រូវ*ហើយបានរកឃើញ*ចតុរារិយសច្ច* តាមរយៈការយល់ដឹងផ្ទាល់របស់ព្រះអង្គ។ ប្រសូត្រមកជាព្រះអង្គម្ចាស់មួយអង្គព្រះអង្គលះបង់ពិភពលោក ហើយតស៊ូអស់រយៈពេល៦ឆ្នាំដើម្បីស្វែងរក *ការត្រាស់ដឹង*។ នៅក្នុងអំឡុងពេលនេះ ព្រះអង្គបានឈានទៅដល់គ្រូល្បីៗ ទាំងអស់នៅក្នុងថ្ងៃនោះ ហើយបានខិតខំព្យាយាមគ្រប់វិធីទាំងអស់ ដែលគ្រូរបស់ព្រះអង្គអាចបង្រៀនទ្រង់បាន។ បើទោះជាព្រះអង្គចេះដូចគ្រូ ព្រះអង្គហើយក៏ដោយក៏ព្រះអង្គនៅតែរកមិនឃើញពី *គោលដៅត្រាស់ដឹង* ដ៏លំបាកនេះឡើយ។ ជាចុងក្រោយ ការពឹងផ្អែកទៅលើ*ការស្រាវជ្រាវ* របស់ព្រះអង្គទៅលើ *ការយល់ដឹងមានហេតុផល* និងការធ្វើដំណើរលើ*ផ្លូវកណ្តាល*ដែលងាកចេញពី *មាគ៌ាប្រពៃណី* នៃ *ជំនឿ* និង*ការប្រតិបត្តិសាសនាពីព្រេងនាយ* ព្រះអង្គបានរកឃើញ *ដំណោះស្រាយចុងក្រោយ* ចំពោះ *បញ្ហាសកលៈទោមនស្ស ជម្លោះការខកចិត្ត*(ទុក្ខ)នេះឡើង។ ព្រះអង្គបានរកឃើញ *ទ្រឹស្តីបដិច្ចសមុប្បាទ* ពោលគឺ*ច្បាប់ហេតុ*និង*ផល*ដែល ព្រះអង្គបានអះអាងថាជា *តថភាព*នៃ *ពិភពលោក* ដោយហេតុនេះ ហើយបានជាព្រះអង្គបាន ក្លាយទៅជា *អ្នកត្រាស់ដឹងដ៏ខ្ពង់ខ្ពស់មួយអង្គ* នោះ។

**៣. វិជ្ជា-ចរណ-សម្បន្នោ** (Vijja-Carana Sampanno)

ស័ព្ទ "*វិជ្ជា-ចរណ-សម្បន្នោ*" នេះមានន័យថា *ព្រះពុទ្ធ* ត្រូវបានផ្តល់ជូននូវ *ចក្ខុវិស័យសុក្រឹតច្បាស់លាស់* (perfect clear vision) ហើយនិង *ការប្រព្រឹត្តគួរយកជាគំរូល្អ*(exemplary good conduct)។ មាន*ទិដ្ឋភាពសំខាន់ៗពីរ* ដែលចង្អុលបង្ហាញនៅក្នុង*ពុទ្ធិ៣*(the threefold knowledge) ហើយនិង*គតិបណ្ឌិត៨* (eightfold wisdom)។ *ពុទ្ធិ* ដែលមាន៣នោះមាន ដូចខាងក្រោម :

- ទី១ *ព្រះពុទ្ធ*ទ្រង់អាចរំលឹកបានពី*អតីតជាតិ* របស់ព្រះអង្គបានហើយនិងបង្ហាញប្រាប់ពី *អត្ថិភាពមុនៗ*របស់ ព្រះអង្គក៏ដូចជា *អត្ថិភាព*របស់អ្នកដទៃដែរ។
- ទី២ ដោយឡែកពីការដែលអាចរំលឹកពី *អតីតកាល*បាន ព្រះអង្គអាចប្រមើលមើលពី *អនាគត*និង *ពិភពលោកទាំងមូល*នៅខណៈតែមួយ។

- ទី៣ ព្រះអង្គទ្រង់មាន *ពុទ្ធិជ្រៅ*ទៅលើ *អរហន្តភាព* (Arahanthood) ។

ចំណែកឯ *គតិបណ្ឌិតវិញ* *ព្រះពុទ្ធ*ត្រូវបានរៀបចំជាបញ្ជីជាការមាន *អំណោយបញ្ញាតែមួយ* (the unique gift of insight) មាន *ឫទ្ធានុភាព*ក្នុងការសម្តែងពី *តេជដៃមិនធម្មតា* (supernormal feats) មាន *ត្រចៀកទិព្វ*(a divine ear) មាន *ឫទ្ធានុភាព*មើលឃើញពី *គំនិត* របស់ *អ្នកដទៃ*(the power of reading other’s thoughts) មាន *ឫទ្ធានុភាពរូបកាយផ្សេងៗ* (various physical powers) មានលទ្ធភាពប្រមូលឡើងវិញនូវ *អតីតជាតិ* (reco-llect past births) មាន *ទិព្វចក្ខុ*(a divine eye)ហើយនិងមាន *ពុទ្ធិល្អ*ដែលជាប់ទាក់ទង ទៅនឹង *ជីវិតបរិសុទ្ធស្ងប់ស្ងាត់* (a life of serene holiness) ។

ដោយចាត់ទុកពាក្យថា "*ចរណ*(Carana)"ឬ*ការប្រព្រឹត្តល្អ* ទិដ្ឋភាពនេះត្រូវបានបែងចែកជា*ប្រភេទគុណធម៌ខុសៗគ្នាចំនួន៥* ដែលគេជឿជាក់ចំពោះ*ព្រះពុទ្ធ*ដោយពេញបរិបូរណ៍ ។*គុណធម៌*បន្ថែមទាំងអស់នេះគឺជាការ ដែលគេបានធ្វើចំណាត់ថ្នាក់ជាការទប់ *កាយ* (deed)និង *វាចា* (word) ការទប់*ជំនក់នៃឥទ្ធិពលវិញ្ញាណ* (the ab-sorption of sense effects) ការចេះប៉ាន់ប្រមាណទៅក្នុង *ការបរិភោគអាហារ* (the consumption of food) ការជៀសវាងពី *ការទទួលទានដំណេកហួសប្រមាណ* (excessive sleep)ថែរក្សា *ចក្ខុវិស័យភ្លឺថ្លា* ដូចគ្រីស្តាល់ (cry- stal clear vision) នៅក្នុង*ជំនឿ* មាន*សេចក្តីអៀនខ្មាស* ក្នុង *ការប្រព្រឹត្តអំពើអាក្រក់* (shame in committing evil) មាន *សេចក្តីភ័យខ្លាច* ក្នុង*ការប្រព្រឹត្តអំពើអាក្រក់* (fear in committing evil) ស្រេកឃ្លាន *ពុទ្ធិ* (know-ledge) *ថាមពល*(energy) *សតិ*(mindfulness) និង*ទិដ្ឋិ* (understanding) ពោលគឺ*ទំនោរ៤* (four trends) ទាក់ទងទៅ នឹង*ទំហំរូបធាតុ* (the material sphere). *បញ្ញា* (Panna) និង*ករុណា* (Karuna) ត្រូវឆ្លុះបញ្ចាំងជា *គតិបណ្ឌិត* និង*សេចក្តីអាណិត* កត្តាទាំងពីរនេះគឺជា*កូនក្លោះសំខាន់* ខណៈពេលដែល *ករុណា* ផ្តល់អំណោយ (bestow) ដល់ព្រះអង្គប្រកបដោយ*សេចក្តីអាណិត*ដែល ជាសេវាកម្មមួយដល់ *មនុស្សជាតិ*។ ព្រះអង្គបានយល់ច្បាស់តាមរយៈ *គតិបណ្ឌិត*របស់ព្រះអង្គ អ្វីដែល*ល្អ* និងអ្វីដែល*មិនល្អ* សម្រាប់សព្វសត្វទាំងអស់ ហើយនិងតាមរយៈ *សេចក្តីអាណិត* របស់ព្រះអង្គៗបានបង្ហាញផ្លូវ *សាវ័ក* ព្រះអង្គឱ្យចេញឆ្ងាយពី *អំពើអាក្រក់* និង *ទុគ៌តភាព* (misery) ។ *គុណធម៌* ដ៏ធំធេងរបស់ *ព្រះពុទ្ធ* ធ្វើឱ្យព្រះអង្គមានលទ្ធភាពបង្អោរចុះមកនូវ *កម្រិតចែកចាយខ្ពស់បំផុត* (the highest degree of dispensation) ចំពោះ *ភាពជាបងប្អូនប្រុស*(brotherhood)និង *គុណ សម្បត្តិដ៏ប្រសើរ* ចំពោះ *សព្វសត្វ* ទាំងអស់ ។

**៤. សុគតោ** *(Sugato)*

*ព្រះពុទ្ធ*ក៏ត្រូវបានគេកំណត់ថាជា *សុគតោ* (Sugato) ដែលមានន័យថា *មាគ៌ា* (path) របស់ព្រះអង្គមានលក្ខណៈ *ល្អគោលដៅ* (destination) *ប្រសើរថ្លៃថ្លា*ហើយ *ពាក្យ*(words)និង *វិធី*(methods)ដែលបានប្រើដើម្បីបង្ហាញពី *មាគ៌ា* នោះគឺ *គ្មានទុក្ខទោស* (harmless)និង *ប្រទូសរាយ*(blameless) ។ *មាគ៌ា* របស់ *ព្រះពុទ្ធ*ចំពោះការសម្រេចបាន *បរមសុខ*(bliss) មានលក្ខណៈ *ត្រឹមត្រូវ* (correct) *ល្អបរិសុទ្ធ*(pure) *ត្រង់*(uncurving) *ផ្ទាល់*(direct) និង *ពិតប្រាកដ* (certain) ។

*សម្ដី*របស់ព្រះអង្គមានលក្ខណៈ *ល្អវិសេសវិសាល*និង *មិនចេះភ្លាំងភ្លាត់*។ *ប្រវត្តិវិទូល្បីៗ* និង *អ្នកវិទ្យាសាស្ត្រធំៗ* ជាច្រើនបានសម្ដែងថា មានតែ *ការបង្រៀនសាសនា*មួយប៉ុណ្ណោះដែល បានបន្សល់ទុកនូវភាពមិនប្រទូសរាយដោយ *វិទ្យាសាស្ត្រ* ហើយនិង *អ្នកគិតឯករាជ្យ*គឺជា *ពុទ្ធ ដិកា* (the Buddha-word) ។

**៥.លោកវិទូ** (Lokavidu)

ស័ព្ទ *លោកវិទូ* (Lokavito) ត្រូវបានគេអនុវត្តចំពោះ *ព្រះពុទ្ធ* ដែលជាអ្នកមាន *ការយល់ដឹងពី ពិភពលោក* នេះល្អវិសេសណាស់។ ជា*ព្រះបរមគ្រូ* ដែលមាន *បទពិសោធន៍ចេះដឹង* ហើយ និង*ចាក់ទម្លុះចូលជ្រៅ* ទៅក្នុង *គ្រប់ទិដ្ឋភាពនៃជីវិតលោកីយ៍*ទាំងអស់ពោលគឺទាំង*កាយ* និង*ចិត្ត*។ ព្រះអង្គគឺ ជា*ជនទីមួយ*ដែលបានធ្វើការពិនិត្យសង្កេតថា មាន*ប្រព័ន្ធពិភពលោករាប់ពាន់ ឆ្នាំ* (thousands of world systems)នៅក្នុង*សាកលលោក*។ ព្រះអង្គ គឺជា*ជនទី១* ដែលបាន អះ អាងថា *ពិភពលោក* គ្មានមានអ្វីក្រៅពី *បញ្ញត្តិ* (conceptual) ។ នៅក្នុង *ពុទ្ធដិកា* របស់ព្រះអង្គវាជាការឥតប្រយោជន៍ដែលត្រូវពិចារណាទៅលើ *ប្រភពដើមកំណើត* (the origin) ហើយនិង *ទីបញ្ចប់នៃ ពិភពលោក*ឬ *ចក្រវាឡ*(the end of the world/universe) ។ ដូច្នេះព្រះអង្គទ្រង់ស្វែងយល់ឃើញថា *ប្រភពកំណើតពិភពលោកទីបញ្ចប់របស់វា* ហើយនិង *មាគ៌ា*ទៅរក *ទីរំលត់* គឺគេត្រូវរកឃើញនៅក្នុង *រង្វាស់ជម្រៅ*(the fathom) ពោលគឺ *រាងកាយយូរអង្វែង*(longbody) គឺ *សត្វលោក* ដែលមាន *ការយល់ដឹង* (perception)និង *មនសិការ* (consciousness) នេះឯង ។

**៦ .អនុត្តរោ បុរិស ទម្ម.សារថិ** (Anuttaro Purisa Damma-Sarathi)

*អនុត្តរោ*បានសេចក្ដីថា *មិនអាចប្រៀបផ្ទឹមបាន* (matchless)និង*ប្រសើរ* ឬ *អស្ចារ្យលើសគេ* (unsurpas-sed) ។ *បុរិសទម្ម* សំដៅចំពោះ *បុគ្គល* ដែល *អំណោយព្រះធម៌* (the gift of the Dhamma) ដែលគេត្រូវគេផ្ដល់ចំពោះចំណែកឯ *សារថិ* មានន័យថា *អ្នកដឹកនាំផ្លូវ*(a leader) ។

*ស័ព្ទទាំងបី* នេះផ្សំបញ្ចូលគ្នាបញ្ជាក់ពី *អ្នកដឹកនាំ គ្មានគូប្រៀប* (incomparable leader) ដែលអាចនាំ *មនុស្សចចេសរឹងរូស* (wayward men) ទៅរក *ផ្លូវត្រូវ* បាន។ ក្នុងចំណោមអ្នកដែលត្រូវបញ្ចុះបញ្ចូលឱ្យដើរតាម *មាគ៌ាព្រះធម៌*ហើយដើម្បីជៀសចេញពី *អំពើអាក្រក់គឺឃាតករល្បីៗ* មានដូចជា *អង្គុលីមារ* (Angulimala) *អាឡាវាកៈ* (Alavaka) និង *ណាលាគិរី* (Nalakiri) *ចោរប្លន់រាប់រយមនុស្សសាហាវ ឃោរឃៅ*(cannibals) និង *មនុស្សចចេសរឹងរូស* (recalcitrants) ដូចជា Saccake ជាដើម។ ពួកគេទាំងអស់នេះ ត្រូវបាននាំឱ្យលុះចូលទៅក្នុង*របត់ព្រះធម៌*(the fold of Dhamma)ហើយអ្នកខ្លះទៀត សម្រេចបាន *សន្តភាព*(sainthood)នៅក្នុង *ឆាកជីវិត* របស់ពួកគេ។ សូម្បីតែ Devadatta ដែល ជា*សត្រូវសំខាន់ជាងគេ* របស់ *ព្រះពុទ្ធ* ក៏ត្រូវព្រះអង្គធ្វើឱ្យបានល្អប្រសើរតាមរយៈ *មហាមេត្តា* (great compassion) របស់ព្រះអង្គដែរ។

**៧ ~ សត្ថា ទេវ~មនុស្សានំ** (Satta Deva-Manussanam)

ការបកប្រែពាក្យនេះគឺថា *ព្រះពុទ្ធ* ជា *គ្រូ*នៃ *ទេពតា*និង *មនុស្ស*។ គេត្រូវកត់ចំណាំថា "*ទេវៈ(Devas)*"ដែល មានប្រើនៅក្នុងបរិបទនេះសំដៅចំពោះ *សត្វលោក*(beings)ដែល (បើតាម *កម្មល្អផ្ទាល់* របស់ពួកគេ) វិវត្តន៏ទៅហួសពី *ដំណាក់កាលមនុស្ស*(the human stage) ដែល មិនត្រូវបានគេចាត់ទុកថាជា *ដំណាក់កាលចុងក្រោយ* នៃ *ការវិវត្តជីវវិទ្យា* (biological evolution) ។ *ទេវៈ* នៅក្នុង *បរិបទព្រះពុទ្ធសាសនា* មិនមែនទាក់ទងទៅនឹង *ទេវកថា ទេវវិទ្យាប្រពៃណី បុរាណ* (ancient traditional theological myths) នោះទេ។ *ព្រះពុទ្ធ* គឺជា*ព្រះរមគ្រូដ៏ចំណាន* ដែលមានលក្ខណៈទន់ភ្លន់ បត់បែន ហើយមានលទ្ធភាពបង្កើតនូវ *ភាពប៉ិនប្រសប់នានាជាច្រើន* (diverse te-chniques) ដែលសមទៅតាម *សមត្ថភាព*(calibre)និង *ប្រាជ្ញា* (mentalities) ខុសៗ គ្នានៃ*មនុស្ស* និង*ទេពតា*។ ព្រះអង្គបានបង្រៀន *មនុស្សម្នាក់ៗ* ឱ្យដឹកនាំទៅរក *មាគ៌ាជីវិតត្រឹមត្រូវមួយ*។ *តាមពិតទៅព្រះពុទ្ធ*គឺជា*គ្រូសាកលមួយរូប* (a universal Teacher) ។

**៨~ពុទ្ធោ** (Buddho)

វិសេសស័ព្ទ (epithet) ពិសេសពោលគឺ *ពុទ្ធោ* សម្តែងឡើងទៅជា *តម្រាប់តាមដដែលៗ* នៅលើកទី២នៅក្នុងប្រភេទនេះបើទោះ ជាស័ព្ទនេះមានន័យលាក់កំបាំងផ្ទាល់របស់វាក៏ដោយ។ ពាក្យ *ពុទ្ធោ* នេះមានន័យថា *គ្រូ* (the Mater) ប្រកបដោយ *សព្វញ្ញូភាព*(omniscient), មាន *ឫទ្ធានុភាពប្លែកពីធម្មតា* (extraordinary powers) ដែលអាចធ្វើឱ្យ អ្នកដទៃដែលជារបកគំហើញធំៗ (others of His great discovery) ជឿជាក់តាមរយៈ *សិល្បៈបង្រៀនព្រះធម៌*របស់

ព្រះអង្គដល់ *អ្នកដទៃ* យ៉ាងល្អប្លែក (exquisite art of teaching)។ *ភាពប៉ិនប្រសប់* របស់ព្រះអង្គអស្ចារ្យលើស គ្រូដទៃទៀត។ ពាក្យថា *ពុទ្ធោ* នេះមានន័យជាបន្ទាប់ទៀត ដែលបានបកប្រែថា *"ភ្ញាក់រលឹក* (Awakened)"ព្រោះ *សភាពធម្មតា*របស់ *មនុស្ស*ជារឿយៗ ស្ថិតនៅក្នុងសភាពជា *ភាពធេងធោង* (a state of stupor)។ *ព្រះពុទ្ធ*គឺជា *ជនទី១* ដែលបាន*"ភ្ញាក់រលឹកដឹងខ្លួន"* ហើយដែលភ័យខ្លាច នឹង*សភាពធេងធោង*។ ជារឿយៗព្រះអង្គតែងតែធ្វើឱ្យ*អ្នកដទៃ*ជឿជាក់ដើម្បីភ្ញាក់រលឹកហើយ និងដើម្បីកាច់ចង្កូតងាកចេញពី*សភាព*នៃ *ការលង់លក់* ឬ *ភាពវង្វេងវង្វាន់សំសារៈខ្ជិលច្រអូស* (the state of lethargic samsaric sleep of stupor)នេះ។

**៩.ភគវា** (Bhagava)

គ្រប់ស័ព្ទដែលបានប្រើដើម្បីពិណ៌នាពី *ព្រះពុទ្ធ*ពាក្យថា *ពុទ្ធោ* និងពាក្យថា *ភគវា* នេះប្រើដាច់ពីគ្នា ឬក៏ប្រើរួមគ្នាជា"*ពុទ្ធោភគវា*" មានន័យថា"*អ្នកមានពរជ័យ* (the Blessed One)" មានប្រជាប្រិយដាច់គេ និងមានប្រយោជន៍ទូទៅ។

ការសមនឹងទទួលបាន *សេចក្តីស្ញើច* (awe) និង *សេចក្តីគោរពការមានពរជ័យ* គឺជា *ព្រះនាម* របស់ព្រះអង្គ។ដូច្នេះពាក្យថា*"ភគវា"* មានន័យផ្សេងៗដែលបានស្នើសុំដោយ*អ្នកអត្ថាធិប្បាយ*មួយចំនួន។ *ព្រះពុទ្ធ*ត្រូវបានគេឱ្យឈ្មោះថា *"ភគវា"* ឬ"*អ្នកមានពរជ័យ* (the Blessed One)"ពីព្រោះព្រះអង្គមាន *សេចក្តីសុខ* (the happiest) និង មាន *ភព្វសំណាងបំផុត* (most fortunate) ក្នុងចំណោម *មនុស្សនានា*ក្នុងការបង្រ្កាប *អំពើអាក្រក់សព្វយ៉ាង* ក្នុងការអធិប្បាយ *ព្រះធម៌ខ្ពស់ បំផុត*និងផ្តល់នូវ *អំណាចបញ្ញាផុតមនុស្ស*។

*គុណសម្បត្តិទាំង៩*របស់*ព្រះពុទ្ធ* អាចបម្រើជា*ប្រធានបទមួយ* សម្រាប់*ការចម្រើនភាវនា* ប្រសិនបើការបកស្រាយស័ព្ទពិសេសៗ ផ្សេងៗនីមួយៗត្រូវបានពិចារណា ដោយប្រុងប្រយ័ត្ន ហើយបំណង និងខ្លឹមសារពិតរបស់វាត្រូវបានគេយល់។ គ្រាន់តែការបញ្ចប់វគ្គ ដោយមិនបានយល់ពេញលេញមិនអាចត្រូវបានគេគិតថា មានប្រសិទ្ធភាពសូម្បីតែជាអត្ថបទ ជំនឿស៊ុប (a devotional tract)ក៏ដោយ។ *វិធីប្រសើរបំផុត*គេត្រូវសូត្រដដែលៗ ហើយនៅពេលជា មួយគ្នានេះត្រូវ យល់ពីអត្ថន័យពេញលេញនៃការពិត (utterance)ទាំងនេះ។ ខណៈពេលធ្វើបែបនេះគេក៏គួរតែសមាធិទៅលើ *គុណសម្បត្តិ* ដ៏ប្រសើរៗទាំងនេះជា *គុណធម៌ពិតៗ* ដែលត្រូវប្រកួតប្រជែងដោយ *សាវ័ក* ទាំងអស់របស់ *ព្រះពុទ្ធ* ។

អរិយសច្ចមានន័យថា សច្ចៈឬការពិតដ៏ខ្ពង់ខ្ពស់គួរគោរព គួរជឿ គួរដឹង គួរចេះ។ គម្ពីរពុទ្ធិនិយមបានពន្យល់ថា អរិយសច្ចមាន៤ យ៉ាងគឺ :

១-ទុក្ខអរិយសច្ច ២-សមុទយអរិយសច្ច ៣-និរោធអរិយសច្ច ៤-មគ្គអរិយសច្ច

**១.ទុក្ខអរិយសច្ច** តាមទ្រឹស្តីពុទ្ធនិយមមនុស្សសត្វកើតមកតែងជួបប្រទះនឹងទុក្ខពិតប្រាកដ ចៀសពុំផុតឡើយ ។

**២-សមុទយអរិយសច្ច :** អំពីហេតុដែលនាំឱ្យកើតទុក្ខ បានសេចក្តីថា ទុក្ខកើតឡើងមកពីមានហេតុមានឫសគល់ជាប្រាកដ។ តាមលទ្ធិពុទ្ធនិយមឫសគល់នៃទុក្ខមាន២យ៉ាងគឺ : ១-អវិជ្ជា ២-តណ្ហា

**៣-និរោធអរិយសច្ច :** និរោធមានន័យថារលត់។ ព្រះពុទ្ធបានថែងថា បើចង់បំបាត់ទុក្ខត្រូវ បំបាត់អវិជ្ជាលះបង់តណ្ហា រំលត់រំលាយតណ្ហាកុំឱ្យសេសសល់។ អវិជ្ជានិងតណ្ហាជាឫសគល់នៃទុក្ខ។ កាលបើអស់វិជ្ជា វិជ្ជា ដែលជាពន្លឺយល់ច្បាស់នូវប្រយោជន៍ និព្វានក៏កើតមានឡើង តណ្ហាការជាប់ជំពាក់ នឹងប្រយោជន៍លោកិយប្រយោជន៍ ក្នុងឋានសួគ៌ក៏ត្រូវរលាយរលត់ថែមទៀតទុក្ខទាំងពួងមានជាតិទុក្ខ ជរាទុក្ខព្យាធិទុក្ខ មរណទុក្ខជា ដើមនឹងវិនាស ជាប្រាកដប្រៀបដូចអ្នកធ្វើចំការដែលគាស់រំលើងឫសឈើ ឫសស្មៅសម្អាតដីដាំដំណាំ បើកាត់តែមែកឈើជម្រះតែស្មៅលើៗរុក្ខជាតិទាំងនេះនឹងដុសឡើងវិញផលដំណាំនឹងស្វិតឬក្រិនជាមិនខាន។ ដូច្នេះទស្សនៈសមុទយអរិយសច្ចបញ្ជាក់ថា ទុក្ខគឺពិតជាអាចរំលត់រំលាយបានជាប្រាកដ។

**៤-មគ្គអរិយសច្ច :** គឺផ្លូវសម្រាប់រំលត់ទុក្ខ។ មគ្គអរិយសច្ចមានន័យថា ផ្លូវសម្រាប់ប្រតិបត្តិដើម្បីបំបាត់ទុក្ខមានពិតប្រាកដមែន។ សច្ចៈនេះ គឺជាសច្ចៈខ្ពង់ខ្ពស់មែន។ ដើម្បីរំលត់ទុក្ខត្រូវតែដើរតាមផ្លូវនេះ។

**មគ្គឬផ្លូវរំលត់ទុក្ខមាន ៨ យ៉ាងដែលមានឈ្មោះថា អដ្ឋង្គិកមគ្គ មានជាអាទិ៍គឺ :**

**១-សម្មាទិដ្ឋិ:** ការយល់ឃើញត្រូវ ។

**២-សម្មាសង្កប្បៈ** ការត្រិះរិះត្រូវ ។

**៣-សម្មាវាចា** : ពាក្យសម្តីត្រូវ ។

**៤-សម្មាកម្មន្តៈ** ការងារត្រូវ ។

**៥-សម្មាអាជីវៈ** ការចិញ្ចឹមជីវិតត្រូវ ។

**៦-សម្មាវាយាមៈ**ការព្យាយាមត្រូវ ។

**៧-សម្មាសតិ :** ការភ្ញាក់រឭកនឹកឃើញត្រូវ ។

**៨-សម្មាសមាធិ :** ការធ្វើសមាធិត្រូវ ។

## ៣-តើកម្មគឺជាអ្វី ? (What Kamma Is? ) By. Ven. U. Thittila

*កម្ម (Kamma)*គឺជា *ពាក្យបាលីនិង កម៌ (Karma)*ជាពាក្យ *សំស្ក្រឹត* ដែលមានន័យថា *អំពើ (action)* ។ នៅក្នុងខ្លឹមសារទូទៅរបស់វា*កម្ម* មានន័យថា*អំពើល្អ*និង*អំពើអាក្រក់* សព្វយ៉ាង ។ ពាក្យនេះគ្របដណ្តប់លើ *អំពើចេតនាគ្រប់ប្រភេទ*ទោះដោយ *កាយ វាចា*ឬ*ចិត្តក្តី* ។ នៅក្នុងខ្លឹមសារខ្ពស់បំផុត *កម្ម* មានន័យថា*សីលចេតនា*និង*សីលអចេតនា(moral and immoral volition)* ។ *ព្រះពុទ្ធ*ទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ *ចេតនាដោយចិត្ត(mental volition)* គឺអ្វីដែល *តថាគត* ឱ្យឈ្មោះថា *អំពើ (Kamma)*នោះឯង ។ ការមាន *ចេតនា*គេប្រព្រឹត្តដោយ *កាយ វាចា* និងដោយ *ចិត្ត*។

*កម្ម* មិនមែនជា *លទ្ធិកម្មវាសនានិយម* (fatalism)ហើយក៏មិនមែន *ការកំណត់វាសនា* (predetermina-tion) នោះដែរ ។ *អតីតកាល*មានឥទ្ធិពលមកលើ *បច្ចុប្បន្នកាល*ប៉ុន្តែមិនបានគ្រប់គ្រងវានោះទេ ព្រោះ *កម្ម* គឺជា *អតីតកាល*ក៏ដូចជា *បច្ចុប្បន្ន* នោះដែរ ។ *អតីតកាល*និង*បច្ចុប្បន្ន*មានឥទ្ធិពលទៅលើ *អនាគតកាល*។ *អតីតកាល*គឺជា សាវតារមួយ (background)ដែល*ជីវិត*ត្រូវបន្តទ្រាំពីខណៈមួយទៅខណៈមួយ ។*អនាគត*ក៏នៅមិនទាន់ចូលមកដល់ទៀត ។ មានតែ*បច្ចុប្បន្ន* ប៉ុណ្ណោះដែលមានអត្ថិភាពហើយ និង *ការទទួលខុសត្រូវ*ក្នុងការប្រើប្រាស់ *ឱកាសបច្ចុប្បន្ន* សម្រាប់*អំពើល្អ* ឬសម្រាប់*ការនិយាយញុះញង់*ចំពោះគ្នា ។

រាល់ *អំពើទាំងឡាយ* សុទ្ធតែបង្កើត*ផលមួយ* (an effect) ហើយ *ផលនេះ*ក៏ជា *ហេតុមួយ* ដំបូងហើយនិង*ផល* ជាបន្តបន្ទាប់ទៀត ។ ដូច្នេះការដែលយើងនិយាយអំពី*កម្ម* គឺយើងនិយាយអំពី *"ច្បាប់ហេតុនិងផល"*នេះឯង ។ ការគប់ *ថ្មមួយដុំ*ជាឧទាហរណ៍គឺជា*អំពើមួយ*។ *ដុំថ្ម*នោះ បានទៅចំ*បង្អួចកញ្ចក់*មួយហើយធ្វើឱ្យបង្អួចកញ្ចក់នោះ បែក ។ "*ការបែក*" គឺជា*ផលមួយ*នៃ*អំពើគប់*ប៉ុន្តែវាមិនមែនជា*ការបញ្ចប់*នៅត្រឹមនេះនោះទេ ។ *បង្អួចបែក* (the broken window) ឥឡូវនេះក្លាយទៅជា *ហេតុ*នៃ *បញ្ហា*ជាបន្ទាប់ទៀត ។ *លុយ*មួយចំនួនរបស់ *អ្នកណាមួយ* នឹងត្រូវ ចំណាយដើម្បីជួសវា ហេតុនេះគេមិនអាចសន្សំ *លុយ*ឬក៏យក *លុយ*នេះទៅទិញអ្វី ដែលគេចង់បានសម្រាប់ *គោលបំណង* ផ្សេងមួយចំនួនទៀតនោះទេ ហើយ *ផល*ប៉ះពាល់ដល់គេ នោះគឺ *ការមានអារម្មណ៍មិនសប្បាយ*នេះឯង ។ រឿងនេះអាចធ្វើឱ្យគេក្តៅក្រហាយ ហើយប្រសិន

បើគេមិនបានប្រុងប្រយ័ត្នទេនោះ គេអាចនឹងបណ្ដាលឱ្យមាន*ភាពខឹងសម្បារ*ក្លាយទៅជា *ហេតុ* ធ្វើអ្វីមួយទៀតដែល *ខុសឆ្គង*។ល។ *លទ្ធផល* នៃ *អំពើ* កើតមានគ្មានទីបញ្ចប់ *កម្ម*នៅតែបន្ត ជានិច្ចដូច្នេះយើង ម្នាក់ៗត្រូវតែប្រុងប្រយ័ត្នជានិច្ចអំពី *អំពើ*របស់យើងដើម្បីឱ្យ *ផល*របស់យើង បាន *ល្អប្រសើរ*។ ដូច្នេះវាជា ការចាំបាច់ចំពោះយើងដែលត្រូវ *ធ្វើអំពើល្អ អំពើមានប្រយោជន៍* ដែលនឹងត្រូវផ្ដល់ត្រឡប់មកយើងវិញនូវ*កម្មល្អ* និងធ្វើឱ្យយើងមាន*កម្លាំងគ្រប់គ្រាន់*ដើម្បីចាប់ផ្ដើម*កម្មកាន់តែប្រសើរឡើង*។

សូមបោះ *ថ្មមួយដុំ* ចូលទៅក្នុង *ត្រពាំង*មួយ ហើយសូមសង្កេតមើលពីផលរបស់វា។ មាន *ការខ្ទាយទឹក* (a splash) ហើយនិង *រលករទឹកមូលៗតូចៗមួយចំនួន* (a number of little rings) កើតឡើងនៅជុំវិញកន្លែងវាធ្លាក់នោះ។ *សូមមើលពីរលករទឹកមូលៗតូចៗមួយចំនួន* ទាំង នោះកាន់តែរីកធំឡើងៗរហូតដល់ធំទៅៗតូចឡើងៗ ចំពោះភ្នែកយើងដែលត្រូវទៅតាមវាយ៉ាងណា។ *ថ្មមួយដុំតូច* ធ្វើឱ្យ*ទឹក* នៅក្នុង*បឹងរំជួយ*បាន ប៉ុន្តែកិច្ចការរបស់វានៅមិនទាន់ចប់នៅឡើយទេ។ ពេល*រលកតូចៗ*ត់ទៅដល់ *មាត់ត្រពាំង* *ទឹក*ក៏ធ្វើចលនាត្រឡប់ក្រោយវិញរហូត ដល់វាត្រឡប់ទៅដល់ *ថ្ម*ដែលបង្កឱ្យវារំជួយនោះវិញ។

*ផល* នៃ *អំពើ* របស់យើងក៏ត្រឡប់មករកយើងដូចគ្នានឹង *រលកទឹក* ចំពោះ*ថ្ម*នោះដែរ ដរាបណាយើងធ្វើ*អំពើ* របស់យើងប្រកបដោយ *បំណងអាក្រក់រលកនៃផលថ្មី*បានវិល ត្រឡប់រក យើងវិញហើយរំខានដល់យើងជាមិនខានឡើយ។ ប្រសិនបើយើងមានចិត្ត*សប្បុរស* ហើយរក្សា *ខ្លួនយើង*ដោយ *សេចក្ដីស្ងប់រលកបញ្ហាត្រឡប់វិញ* នឹងត្រូវចុះខ្សោយបន្តិចម្ដងៗរហូតដល់ វាបាត់អស់ហើយ*កម្មល្អ*របស់យើងនឹងត្រឡប់មករកយើងវិញដោយសុខសាន្ត។ ប្រសិនបើយើងដាំ *គ្រាប់ស្វាយមួយគ្រាប់* ជាឧបមា *ដើមស្វាយ* នឹងដុះឡើង ហើយផ្ដល់ផលជា *ស្វាយ* ហើយប្រសិន បើយើងសាប *គ្រាប់ម្ទេស* *ដើមម្ទេស*នឹងដុះឡើង ហើយឱ្យផ្កាផ្លែជា *ម្ទេស*។ *ព្រះពុទ្ធទ្រង់ត្រាស់* សម្ដែងថា : "*គេសាបព្រោះគ្រាប់ពូជអ្វី គេពិតជាទទួលផ្លែផ្កាពីគ្រាប់ ពូជនោះ* (*According to the seed that's sown, So is the fruit ye reap there from*) *ជនណាប្រព្រឹត្តអំពើល្អជននោះ នឹងទទួលបានផលល្អ* (Doer of good will gather good,) *ជនណាប្រព្រឹត្តអំពើអាក្រក់ជននោះនឹងទទួលបានផលអាក្រក់* (Doer of evil, evil reaps)" ។

អ្វីៗដែលកើតមានចំពោះយើងសុទ្ធតែមានលក្ខណៈត្រឹមត្រូវ ។ពេលអ្វីមួយដែលសប្បាយរីករាយកើតមានចំពោះ យើងហើយធ្វើឱ្យយើងសប្បាយ យើងអាចនឹងច្បាស់ក្នុងចិត្តថា *កម្ម*

របស់យើងសម្តែងបង្ហាញប្រាប់យើងពីអ្វីដែលយើងបានប្រព្រឹត្តនោះមានលក្ខណៈ *ល្អត្រឹមត្រូវ*។ ពេលអ្វីមួយមិនគួរជាទីរីករាយកើតមាន ចំពោះយើងធ្វើឱ្យយើងឈឺចាប់ឬធ្វើឱ្យយើងមិនសប្បាយរីករាយ *កម្ម* របស់យើងបានសម្តែងប្រាប់យើងពី *កំហុស* របស់យើង។ យើងមិន ត្រូវភ្លេចទេថា *កម្ម* ជានិច្ចកាលមានលក្ខណៈ*ត្រឹមត្រូវ*។ *កម្ម*មិនមែនជា *សេចក្តីស្រឡាញ់* ហើយក៏មិនមែនជា *សេចក្តីស្អប់* ដែរ មិនមែនជារង្វាន់ហើយក៏មិនមែនជាទណ្ឌកម្មដែរ។ វាមិនមែនជា *កំហឹង* ហើយ ក៏មិនមែនជា *សេចក្តីសប្បាយដែរ* *កម្ម*មានលក្ខណៈ*ធម្មតា*ជា *ច្បាប់ហេតុនិង ផល*។

*កម្ម*មិនស្គាល់អ្វីអំពីយើងនោះទេ។ តើ *ភ្លើង* ស្គាល់យើងដែរឬទេនៅពេលវាឆេះយើង? ទេវាគឺជា*ធម្មជាតិ*របស់ *ភ្លើង*ដែលត្រូវឆេះ ដែលត្រូវផ្តល់ *កំដៅ*។ ប្រសិនបើយើងប្រើវាដោយត្រឹមត្រូវវានឹងផ្តល់ឱ្យយើងនូវ *ពន្លឺ*ចំអិន *ចំណីអាហារ*សម្រាប់យើង ឬដុតអ្វីមួយដែលយើងចង់បានប្រយោជន៍ពីវា ប៉ុន្តែបើយើងប្រើវាដោយ *ខុស*វិញ វានឹងដុតរំលាយ យើង ហើយនិង *ទ្រព្យសម្បត្តិ*របស់យើង។ *ការងារ* របស់វាគឺ *ដុតឯការងារ*របស់យើងគឺត្រូវប្រើវាទៅតាម *ផ្លូវត្រូវ*នេះឯង។ យើងពិតជាភ្លីភ្លើប្រសិនបើយើងក្រោធខឹង និងស្តីបន្ទោសវាពេលវារលាកយើងព្រោះយើងយល់ខុសចំពោះវា។

មាន*វិសមភាព*(equalities)និង*វាសនាមនុស្សច្រើនបែប*នៅក្នុងលោកនេះ។ជាឧទាហរណ៍ អ្នកមួយមានឋានៈអន់តូចទាប ឯអ្នកមួយទៀតមានឋានៈខ្ពង់ខ្ពស់។ អ្នកមួយអន់តូចទាបនៅក្នុងវ័យ *កុមារភាព* ឯអ្នកមួយទៀតនៅ វ័យ*អាយុ៨០* ឬនៅអាយុ *១០០ឆ្នាំ*។ អ្នកមួយមាន *ជម្ងឺច្រើន* និង *ខ្សោយ* ឯអ្នកមួយទៀត *រឹងមាំ*និងមាន *សុខភាពល្អ*។ អ្នកមួយរស់នៅក្នុងសភាព *ឆើតឆាយ* ឯអ្នកមួយទៀតរស់នៅក្នុងសភាព *ទុគ៌ត*។ អ្នកមួយមានកើតមកជា *សេដ្ឋី* ឯអ្នកមួយទៀតកើតមក*ក្រតោកយ៉ាក*។អ្នកមួយមាន*ទេពកោសល្យ*ឯអ្នកមួយទៀត*ល្ងង់ខ្លៅ*។

តើអ្វីដែលជាហេតុបណ្តាលឱ្យ *វិសមភាព* មានអត្ថិភាពនៅក្នុងលោកនេះ? *ពុទ្ធសាសនិកជន*មិនអាចមានជំនឿថា *ការប្រែប្រួលនេះ* (variation) គឺជា *លទ្ធផល*នៃ *ភ័ព្វសំណាងងងឹតងងុល* (the result of blind chance) នោះទេ។ តាមពិតទៅ *វិទ្យាសាស្ត្រ*ខ្លួនឯងសុទ្ធតែប្រឆាំងចំពោះ *ទ្រឹស្តី "វាសនា"* (the theory of "chance")នៅក្នុង ពិភពនៃ *អ្នកវិទ្យាសាស្ត្រ* កិច្ចការទាំងអស់សុទ្ធតែអនុលោមទៅតាម *ច្បាប់ហេតុ* និង *ផល*ទាំងអស់។ *ពុទ្ធសាសនិកជន* មិនជឿលើ *វិសមភាព* (unevenness) នៃពិភពលោកព្រោះតែ*អាទិទេព-អ្នកបង្កើត*នេះឡើយ។

## ៤.គុណធម៌ដ៏ប្រសើរនៃព្រះធម៌ ( Great Virtues of the Buddha ) K.SriDhammananda

ការទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធជាទូទៅគេហៅថា " ព្រះធម៌ " (Dhamma រឺ Dharma) ។ វាមិនមែនជាការសម្តែងរបស់ភាពព្រះ (វិវរណ) ហើយក៏មិនមែនជាការពិចារណាខាងទេវវិជ្ជាទេ ។ វាគឺជាសច្ចភាពដែលស្ថិតនៅក្នុងសកលលោក ហើយដែលព្រះបរមគ្រូបានត្រាស់ដឹងដោយអង្គឯង ។ បន្ទាប់ពីព្រះអង្គបានត្រាស់ដឹងហើយ គេហៅព្រះធម៌នេះថា "ពុទ្ធសាសនា" ជាពាក្យទំនើប ។ ព្រះសមណគោតមបានត្រាស់ដឹងសេចក្តីពិតហើយប្រកាសចំពោះសកលលោកយើងនេះ ។ប៉ុន្តែមនុស្សសាមញ្ញមានការលំបាកក្នុងការស្វែងយល់ពីសេចក្តីប្រកាសរបស់ព្រះអង្គព្រោះគេមានមោហៈខ្លាំងពេក ។

ព្រះធម៌(Dhamma) មានគុណធម៌ជាច្រើនយ៉ាងដែលមានអត្ថន័យខ្ពង់ខ្ពស់និងឥតខ្ចោះ ។ ទោះជាយ៉ាងណាក៏ដោយព្រះធម៌មានទិដ្ឋភាពទាំង**៣** ដែលគួរឱ្យកត់សំគាល់ ។ទី**មួយ** គឺទ្រឹស្តីបរិសុទ្ធដែលយើងត្រូវរៀន ។ ទី**ពីរ** គឺការប្រតិបត្តិតាមធម៌វិន័យរបស់ព្រះពុទ្ធ ដោយលះបង់នូវអំពើបាបហើយប្រតិបត្តិអំពើល្អនិងជម្រះចិត្តគំនិត ។ ទី**បី**គឺការបណ្តុះស្មារតីបញ្ញា និងការស្វែងយល់ពីតថភាពនៃបាតុភូតទាំងឡាយ ។ ក្នុងចំណោមគុណធម៌ជាច្រើនព្រះធម៌មានលក្ខណៈ**៦** យ៉ាងច្បាស់លាស់ ដែលបានកត់ត្រាក្នុងអត្ថបទសំខាន់ៗ ។ ការរៀបរាប់នៃគុណធម៌ ទាំងនោះជាភាសាបាលីមានដូចជា Svakkhato Bhagavata Dhammo, Sanditthiko, Akaliko, Ehipassiko, Opanayiko, and Paccattam Veditabbo Vinnuhi. ការរៀបរាប់លំអិត និងអធិប្បាយនៃលក្ខណៈទាំងនេះមានដូចតទៅ :

**១. (Savakkhato Bhagavata Dhamma)**

ពាក្យនេះមានន័យថា ព្រះធម៌ត្រូវបានរកឃើញ និងផ្សព្វផ្សាយដោយព្រះពុទ្ធ ។ នោះជាគុណធម៌ទូទៅនៃទិដ្ឋភាពទាំង **៣** របស់ព្រះធម៌ គឺទ្រឹស្តីការប្រតិបត្តិ និងបញ្ញាដ៏ពេញលេញ ។ ពាក្យបាលីផ្សេងៗទៀតនៅខាងលើនោះពាក់ព័ន្ធទៅនឹងឋានបរលោកដែលមាន **៨** ជាន់នៃអារហន្ត ហើយនិងនិព្វានដែលគេគិតថា ជាពិភពដ៏ល្អប្រសើរបំផុតរបស់ព្រះពុទ្ធសាសនា ។ ព្រះបរម គ្រូបានបកស្រាយអធិប្បាយអំពីព្រះធម៌យ៉ាងច្បាស់លាស់ គឺទ្រង់បានពន្យល់យ៉ាងក្បោះក្បាយឥតខ្ចោះល្អតាំងពីដើមដល់ពាក់កណ្តាលរហូតដល់បញ្ចប់ដោយគ្មានភាពច្រំដែលប្រែប្រួល និងមិនល្មៀងចេញពីអ្វីដែលទ្រង់កំពុងពន្យល់នោះទេ ។ ប្រៀបដូចជាដំណក់ទឹកនៃ មហាសមុទ្រដែលមានរសជាតិតែមួយ៉ាងគឺប្រៃរីឯព្រះធម៌ក៏មានរសជាតិតែមួយ៉ាងដែរគឺសេចក្តីសុខនៃនិព្វាន ។

ព្រះធម៌ គឺជាសេចក្តីពិតប្រាកដទាំងក្នុងអក្សរនិងអត្ថន័យ ។ ចំណុចសំខាន់នៃព្រះធម៌ គឺចាប់ផ្តើមចេញពីសីល(Sila)ដែលមានន័យថាការធ្វើល្អជាមូលដ្ឋានរបស់សមាធិ(Samadhi) គឺភាពស្ងប់ ។បន្ទាប់ពីសមាធិបានសម្រេចហើយនោះនឹងកើតមានបញ្ញា(Panna)ដោយប្រពៃ ។

ការដែលយល់ពីព្រះធម៌ គឺត្រូវចាប់ផ្តើមឡើងដោយការសិក្សាអំពីព្រះធម៌ ដោយការស្តាប់ធម្មទេសនា និងការអធិប្បាយរបស់អ្នកប្រាជ្ញ និងដោយការស្វែងយល់ពីវិធីសាស្ត្រត្រឹមត្រូវដែលត្រូវប្រតិបត្តិតាមនិងអនុវត្ត ។ ការប្រព្រឹត្តតាមយ៉ាងខ្ជាប់ខ្ជួននោះ យើងនឹងអាចកំចាត់នូវភាពសៅហ្មងដែលកើតមាននៅក្នុងចិត្តគំនិតរបស់យើង ព្រមទាំងមានភាពស្ងប់ និងសេចក្តីសុខសាន្តដែលអាចនាំយើងឱ្យមានប្រាជ្ញាដ៏ខ្ពង់ខ្ពស់គឺហៅថា"វិបស្សនា(Vipassana)" ។ បើសិនយើងមានការអភិវឌ្ឍផ្នែកប្រាជ្ញាឱ្យខ្លាំងនិងទៀងទាត់នោះ យើងនឹងទទួលបានសិរីរុងរឿងនៃការត្រាស់ដឹងសូម្បីតែក្នុងរយៈពេលនៃការរស់នៅក្នុងលោកយើងនេះ ។

ការអធិប្បាយបកស្រាយរបស់ព្រះពុទ្ធ អំពីពិភពលោក និងវត្ថុសព្វសារពើរ គឺជាព្រះបន្ទូលដែលនៅទីបំផុតមនុស្សអាចយល់ ។ ព្រះអង្គស្វែងរកនិងពិនិត្យមើល ហើយគិតពិចារណាអំពីខ្លឹមសារនៃព្រះធម៌ទៅតាមវិធីសាស្ត្រសមហេតុសមផល ដែលចាកឆ្ងាយពីផ្នត់គំនិត និងទម្លាប់នៅក្នុងសម័យកាលនោះ ។ហេតុនេះហើយទើបទ្រង់បានសម្រេចនូវតថភាពពិតប្រាកដដែលមាននៅក្នុងបាតុភូតទាំងអស់ ។ ដោយភាពអង្គឯង ហើយព្រះអង្គក៏បានប្រកាសអំពីព្រះធម៌នេះ ដែលជាការប្រៀនប្រដៅមួយមានកម្រិតខ្ពង់ខ្ពស់លើសពីការទូន្មានផ្សេងៗ ទាំងឡាយ ។

ព្រះធម៌នេះគ្មានជាប់ទាក់ទងចំពោះព្រះបារមីរបស់ទេវតាណាឡើយ ។ ព្រះពុទ្ធគ្រាន់តែ ណែនាំមនុស្សម្នាក់ៗ ឱ្យចេះគិតពិចារណាដោយខ្លួនឯង ហើយសម្រេចចិត្តដោយសេរីភាព គឺទទួលមាគ៌ាឆ្ពោះទៅកាន់សេចក្តីសង្គ្រោះខ្លួនឯងដោយគ្មានរកជំនួយពីអ្នកដទៃឡើយ ។

ព្រះធម៌មានលក្ខណៈជាសកល និងញ៉ាំងឱ្យមនុស្សទាំងឡាយឱ្យចូលចិត្តនៅគ្រប់ទិសទីនិងគ្រប់ពេលវេលា ។ ជាពិសេសមួយទៀតគឺព្រះអង្គបានប្រទានឱ្យមានការបកស្រាយអធិប្បាយពាក្យពិបាកទាំងអស់របស់ទស្សនវិទូ ដែលគេធ្លាប់ប្រើប្រាស់ពីមុនមកឱ្យទៅជាពាក្យថ្មី ដើម្បីងាយស្រួលពេលព្រះអង្គទូន្មានប្រៀនប្រដៅអំពីព្រះធម៌ ។ឧទាហរណ៍ពាក្យថា"កម្ម(Kamma)" ដែលធ្លាប់តែមានន័យមួយថា "ជាអំពើដែលគេអាចមើលឃើញតាមរយៈខាង ក្រៅ"តែពាក្យនេះព្រះអង្គទ្រង់បានប្រទានអត្ថន័យផ្សេងមួយទៀតគឺមានន័យថា"បំណងប្រាថ្នា ដែលនាំមកឱ្យការធ្វើអំពើអ្វីមួយ" ។

ព្រះធម៌ដ៏ប្រសើរនេះបានឆ្លើយតបប្រឆាំងទៅ នឹងអំពើអយុត្តិធម៌នៅក្នុងសង្គមយ៉ាងខ្លាំងដូចជាប្រព័ន្ធវណ្ណៈដ៏តឹងរឹងគឺការប្រើប្រាស់មនុស្សជាខ្ញុំបម្រើ ហើយមិនចេះគោរពសិទ្ធិស្ត្រី។ ព្រះពុទ្ធទ្រង់មិនមែនជាអ្នកផ្ដាច់ការទេ ហើយព្រះអង្គគឺជាព្រះបរមគ្រូដែលបាននាំឧត្តមគតិនៃប្រជាធិតេយ្យ ។

ការចាប់ផ្ដើមជាមួយត្រៃរតនៈ (Tisarana) រហូតដល់បានសេចក្ដីសុខដ៏បរិបូរនៃនិព្វានធ្វើឱ្យពុទ្ធបរិស័ទបានសេចក្ដីសុខសប្បាយយ៉ាងខ្លាំង ដោយសារបានយល់អំពីព្រះធម៌ដែលបានទូន្មានពីសេចក្ដីប្រកាសល្អ (Svakkhato)។

**២. (Sanditthiko)**

ពាក្យ Sanditthiko មានន័យថា បើសិនយើងឧស្សាហ៍ព្យាយាមសិក្សាពីព្រះធម៌ ហើយខំប្រឹងប្រតិបត្តិតាមនោះយើងនឹងបានកុសលជាច្រើនក្នុងលោកនាពេលបច្ចុប្បន្ននេះ។

ឧទាហរណ៍ : ទោះបីជាមនុស្សអាក្រក់ដែលធ្លាប់ធ្វើអំពើបាបចំពោះខ្លួនឯងនិងសង្គមក៏ដោយ បើសិនជាគេជឿលើព្រះពុទ្ធនិងព្រះធម៌នោះជីវិតរបស់គេនឹងចាប់ផ្ដើមសារជាថ្មី ហើយអាចបំបាត់រាល់បញ្ហានិងសេចក្ដីទុក្ខវេទនាទាំងឡាយ ដែលកើតមានចំពោះគេឱ្យវិនាសបាត់បង់ទៅបាន។យើងមានឧទាហរណ៍មួយដ៏ល្អស្ដីពីជីវិតរបស់ស្ដេចAsoka ដែលបានទទួលជឿសាសនាព្រះពុទ្ធ ហើយអាចកែប្រែស្ដេចអង្គនេះពីការ ដែលមានព្រះហឫទ័យអាក្រក់ (Candasoka) ទៅជា ស្ដេចដែលមានព្រះហឫទ័យល្អប្រសើរត្រឹមត្រូវ (Dhammasoka) ។

**៣. (Akaliko)**

ពាក្យAkaliko មានន័យថា ជាប្រសិទ្ធិភាពនិងផលប្រយោជន៍នៃការប្រព្រឹត្តិតាមព្រះធម៌ដោយមិនអាចពន្យាពេលបានឡើយ។ ទោះបីជាព្រះធម៌ត្រូវបានផ្សព្វផ្សាយក្នុងរយៈពេលវេលាយូរយារណាស់មកហើយក៏ដោយ ក៏ព្រះធម៌នៅតែបរិសុទ្ធនិងគ្មានអ្វីប្រៀបផ្ទឹមបានឡើយ។ ព្រះធម៌នៅតែល្អប្រពៃហើយត្រូវជាមួយនឹងទស្សនវិទ្យាសាស្រសម័យទំនើបដដែរ។ ប្រសិនបើមានភាពសច្ចៈពិតប្រាកដ សេចក្ដីពិតនឹងមិនអាចបាត់បង់ទៅបានទេ។

ព្រះធម៌ គឺជាសច្ចៈពិតប្រាកដ ដែលមិនអាចបាត់បង់បាន ពីព្រោះវាបានរៀបរាប់ពីតថភាពសភាវៈធាតុភូតទាំងឡាយ នៅក្នុងវាលវដ្ដសង្សា (Samsara)។ ព្រះធម៌បានថែងថាពិភពលោកនេះជាពិភពដែលមិនអាច បំពេញចិត្តយើងបាន ព្រោះការលោភលន់របស់យើង

កើតឡើងឥតឈប់ឈរ ។រីឯថ្នាំសម្រាប់ព្យាបាលជំងឺលោភលន់នេះគឺត្រូវតែបំបាត់កិលេសតណ្ហា ហើយប្រតិបត្តិតាមមាគ៌ាទាំង **៨** （The Noble Eightfold Path ） ។

**៤. (Ehipassiko)**

ពាក្យនេះមានន័យថា ការបើកជាចំហរឱ្យមនុស្សទាំងឡាយមកចូលសិក្សា ហើយចេះត្រិះរិះពិចារណាពីព្រះធម៌ បើមានបញ្ហាខុសឆ្គងត្រូវហ៊ានរិះគន់មុន នឹងទទួលជឿព្រោះថាព្រះធម៌គ្មានការលាក់កំបាំងឡើយ ។ ព្រះធម៌មានភាពបរិសុទ្ធ និងច្បាស់លាស់ ដូចជាមាសរឹងដែលស្អាតល្អបរិសុទ្ធ ។ ព្រះពុទ្ធមានពុទ្ធដីការដោយអង្គឯងថា "កុំជឿនូវអ្វីៗ ដែលខ្ញុំបាននិយាយដោយសារតែគោរពខ្ញុំ ។ ដូចជាមាសសុទ្ធដែលទទួលបានក្រោយពីការរលាយ និងខាត់ដោយថ្ម ដុះ យ៉ាងណាមិញព្រះធម៌ក៏ត្រូវទទួលបានក្រោយពីការគិតពិចារណាយ៉ាងល្អិតល្អន់នោះដែរ" ។ ព្រះ បន្ទូលរបស់ទ្រង់បានបញ្ជាក់អនុញ្ញាតការពិនិត្យ និងពិភាគពីព្រះធម៌ដូចនេះ សំគាល់ភាពអស្ចារ្យរបស់ព្រះពុទ្ធ និងភាពពិតប្រាកដឥតខ្ចោះរបស់ព្រះធិដ៏ខ្ពង់ខ្ពស់ ។

**៥. (Opanayiko)**

ពាក្យនេះមានន័យថា មនុស្សទាំងអស់ដែលធ្វើតាមព្រះធម៌ដោយចិត្តស្មោះត្រង់ នឹងដើរ ទៅតាមផ្លូវដែលឱ្យគេឆ្ពោះទៅកាន់សេចក្តីសុខសាន្ត និងសប្បាយរីករាយជានិច្ច ។ ព្រះធម៌អះអាងថាបើប្រតិបត្តិតាមបន្តិចម្តងៗទៅ យើងនឹងទៅដល់បួនដំណាក់កាលនៃសេចក្តីសប្បាយ និងភាពជ្រះថ្លាក្នុងចិត្ត ។ព្រះធម៌ណែនាំពុទ្ធបរិស័ទ្ធពីដំណាក់កាលមួយទៅដំណាក់កាលមួយ លុះត្រាតែគេរកឃើញការសង្គ្រោះដ៏ពេញលេញដែលអាចរំដោះពីចំណងនៃជីវិត ។

**៦. (Paccattam Veditabbo Vinnuhi)**

សំនួនពាក្យនេះមានន័យថា ព្រះធម៌ត្រូវបានត្រាស់ដឹងដោយបុគ្គល ដែលមានប្រាជ្ញា ។ គ្មានអ្នកណាទទួលព្រះធម៌សម្រាប់អ្នកដទៃបានទេ ប្រៀបដូចជាគ្មានបុគ្គលណាម្នាក់ដែលឱ្យអ្នកដទៃឈប់ស្រេកទឹកដោយខ្លួនឯងជាអ្នកផឹកនោះទេ ។ យើងសង្កេតឃើញមានពីរចំណុចយ៉ាងសំខាន់នៅក្នុងពាក្យបាលីនេះទី**មួយ**គឺការត្រាស់ដឹងមានលក្ខណៈជាឯកត្តភាពទី**ពីរ**ព្រះធម៌ត្រូវបានយល់តែចំពោះអ្នកប្រាជ្ញ ។ ព្រះពុទ្ធមិនមែនជាព្រះសង្គ្រោះទេ គឺជាព្រះសាមណគោត្តមដែលបានបង្ហាញពី មាគ៌ាដើម្បីឱ្យអ្នកដទៃប្រតិបត្តិតាមតែប៉ុណ្ណោះ ។ បុគ្គលម្នាក់ៗត្រូវរក្សាសីល(Sila)គឺធ្វើអំពើល្អត្រឹមត្រូវ និងធ្វើសម្មាធិ(Samadhi)ត្រឹមត្រូវ ហើយខិតខំព្យាយាម

ចំរើនបញ្ញា (Panna) នៅទីបំផុតនឹងនាំឱ្យបុគ្គលនោះ ឆ្ពោះទៅកាន់ការរំដោះសេរីភាពដោយការខំប្រឹងខ្លួនឯង ។

## ៥.មាគ៌ាទៅកាន់បរមសុខដ៏ឧត្តម

(The Path to Supreme Bliss.) Adapted from Various sources

មនុស្សគ្រប់រូបចង់បាននូវសេចក្តីសប្បាយរីករាយ ។គេទាំងអស់គ្នាបានស្វែងរកសុភមង្គល ។ ការស្វែងរកសុភមង្គលរបស់មនុស្សបានបន្តពីរយៈពេលមួយទៅរយៈពេលមួយ តែគេមិនអាចស្វែងរកឃើញ ក្នុងវិធីសម្របសម្រួលតែលក្ខខណ្ឌខាងក្រៅដោយមិនរវល់ពីពិភពខាងក្នុងនៃគំនិតនោះទេ។ ប្រវត្តិនៃវិទ្យាសាស្ត្របានបង្ហាញថា ទោះបីជាកំណែទម្រង់ច្បាប់ នយោបាយមានបំណងល្អ និងរិះគិតត្រឹមត្រូវក៏ដោយ ក៏នៅតែមិនអាចនាំមកនូវសុភមង្គលពេញលេញ និងពិតប្រាកដជូនមនុស្សជាតិបានដែរ ។

នៅពេលមានលក្ខខណ្ឌ មិនពេញចិត្តលេចឡើងត្រូវបានគេលុបបំបាត់ បញ្ហាមួយទៀតនឹងលេចឡើងហើយនៅពេលបញ្ហានេះត្រូវបានបំបាត់ទៀតបញ្ហាមួយទៀតនៅតែលេចឡើង ។ ការបង្ហាញនេះគឺ សំខាន់សម្រាប់លក្ខខណ្ឌនានា និងបញ្ហាលោកិយទាំងមូល ។ មិនមានសេចក្តីសុខកើតមានពិតច្រើននោះទេវាជាការពឹងពាក់អាស្រ័យគ្នានិងទាក់ទងគ្នាទៅវិញទៅមក ។ នៅកម្រិតខ្ពស់បំផុត គេមានមុខងារតំណាល គ្នាគេមិនធ្វើតាមហើយអនុវត្តន៍ជាបន្តបន្ទាប់តាមលំដាប់លំដោយនោះ ។ សូម្បីកត្តាមួយៗដែលមានកម្រិតទាប ក៏គួរតែបន្ថែមជាមួយកម្រិតមួយចំនួននៃការយល់ដឹងត្រូវដែរព្រោះវាជាបញ្ហាសំខាន់នៃព្រះពុទ្ធសាសនា ។

ក្នុងព្រះបន្ទូលរបស់ព្រះពុទ្ធដ៏តឹងតែង បានទូន្មានសាវក័របស់ព្រះអង្គដូចខាងក្រោម :

ទោះបីព្រះអង្គរៀបរាប់អត្ថបទសំខាន់ច្រើន តែមិនឱ្យធ្វើសកម្មភាពស្របតាមនោះទេ ប្រៀបដូចជាការរាប់គោក្របីអ្នកដទៃ( គេមិនទទួលបានផលពីគោនោះទេ) ។ គេមិនទទួលបានផលពីអ្នកប្រាជ្ញ នោះទេ។

ទោះបីព្រះអង្គរៀបរាប់អត្ថបទសំខាន់តិចមែនតែឱ្យធ្វើសកម្មភាពស្របទៅតាមពាក្យទន្មាន របស់ព្រះអង្គដោយបោះបង់ចោលកាមបុច្ឆាភាពស្អប់ ដោយបណ្តុះនូវការយល់ដឹងត្រូវ ។

ការសម្រេចគោលដៅ ចុងក្រោយនៃព្រះពុទ្ធសាសនា (Nibbana) មិនត្រូវការចំណេះចំណានទៅលើទស្សនវិជ្ជាជ្រៅជ្រះ និងពិបាកយល់នៃព្រះពុទ្ធសាសនាទេគឺតម្រូវតែការអភិវឌ្ឍផ្នែកគំនិតតាមរយៈ ដំណើការនៃសីល(Moral conduct) និងការធ្វើសមាធិពោលគឺព្រះពុទ្ធបានមានព្រះបន្ទូលថា( បើគេបង្កើតសីលនិងធ្វើសមាធិគេនឹងដឹងថាពុទ្ធិនាំទៅរកការជួយសង្គ្រោះ) ។

**សីល** (Ethical conduct )

ឥឡូវនៅក្នុងសីល ( *សិលា* ) ដែលពឹងផ្អែកលើសេចក្ដីស្រលាញ់ និងមេត្តាធម៌ រួមមានកត្តាបីក្នុងចំនោមមាគ៌ាខ្ពង់ទាំងប្រាំបី(eightfold path)ពោលគឺការនិយាយត្រឹម(Right Speech) អំពើត្រូវ (Right Action) និងការចិញ្ចឹមជីវិតត្រូវ (Right livelihood) ។ ព្រះពុទ្ធ បានរៀបរាប់នូវការបង្រៀនរបស់ព្រះអង្គសម្រាប់ភាពត្រឹមត្រូវ និងសេចក្ដីសុខជាច្រើនក្រៅពីមេត្តាធម៌សម្រាប់ពិភពលោក ។

សីល( *សិលា* )ជាដំណាក់ការដំបូងនៃមាគ៌ាដែលពឹងផ្អែកលើមេត្តាធម៌នៃសេចក្ដីស្រលាញ់។ ហេតុ អ្វីបានជាមនុស្សមិនធ្វើអំពើអាក្រក់និងលួចឆក់ប្លន់អ្នកដទៃ ? តើវាមិនដោយសារតែការស្រលាញ់ខ្លួនឯង និងអ្នកដទៃទេឬ ? ហេតុអ្វីបានជាគេជួយសង្គ្រោះអ្នកក្រ អ្នកដែលត្រូវការ និងអ្នកដែលជួបទុក្ខអាសន្ន ? តើមិនមែនក្រៅពីមេត្តាធម៌ចំពោះពួកគេទេឬ ?

ការជៀសវាងពីអំពើបាប និងធ្វើអំពើល្អជាមុខងារនៃសីលដែលក្រមសីលធម៌ត្រូវបានគេបង្រៀនក្នុងពុទ្ធសាសនា។ មុខងារនេះជាការស្រលាញ់មេត្តាធម៌។ សីលបញ្ចូលក្នុងមេត្តាធម៌ផ្អែកគុណភាពនៃ ចិត្តដូចជាសេចក្ដីស្រលាញ់ ការដាក់ខ្លួន ការអត់ឱន ភាពអាណិតអាសូរ សេចក្ដីសប្បុរស និងសេចក្ដីសុខនៅពេលទទួលបានជោគជ័យពីអ្នកដទៃ។

យោងតាមពុទ្ធសាសនាមនុស្សឥតខ្ចោះមានលក្ខណៈពីរយ៉ាង ដែលគេគួរតែអភិវឌ្ឍន៍ឱ្យបានស្មើៗគ្នា គឺមេត្តាធម៌( ករុណា) មួយ និងគតិបណ្ឌិត (បញ្ញា) មួយទៀត។ នៅទីនេះមេត្តាធម៌តំណាងឱ្យសេចក្ដី ស្រលាញ់សេចក្ដីសប្បុរស ចិត្តល្អ ការអត់ឱនហើយលក្ខណៈខ្ពង់ខ្ពស់បែបនេះសំដៅលើផ្នែកចិត្តនិងគុណភាពនៃចិត្តីវិឯគតិបណ្ឌិតតំណាងឱ្យផ្នែកបញ្ញាឬគុណភាពនៃគំនិត។ ប្រសិនបើគេអភិវឌ្ឍចិត្ត ដោយមិនយកចិត្តទុកដាក់នឹងបញ្ញា គេនឹងក្លាយជាមនុស្សចិត្តល្អតែល្ងង់ តែបើគេអភិវឌ្ឍតែផ្នែកបញ្ញាដោយមិនយកចិត្តទុកដាក់នឹងផ្លូវចិត្ត គេនឹងធ្លាក់ចូលទៅក្នុងបញ្ញាដែលគ្មានមេត្តាករុណាគ្មានភាពស្និទ្ធស្នាលចំពោះអ្នកដទៃ។ ដូចនេះមនុស្សឥតខ្ចោះត្រូវតែអភិវឌ្ឍផ្នែកទាំងពីរនេះឱ្យបានស្មើគ្នា។

**សម្មាវាចា : ពុំនោលត្រូវ** (Right Speech) មានន័យថា ត្រូវជៀសវាង :

- ការនិយាយកុហក

- ការនិយាយដើមគេ មួលបង្កាច់គេ និងនិយាយអ្វីនាំមកនូវភាពសំអប់ភាពជាសត្រូវ ភាពគ្មានឯកភាព និងមិនស៊ីចង្វាក់រវាងបុគ្គល និងក្រុមមនុស្ស។

- ភាពយង់ឃ្នង ឈ្លើយ អសីលធម៌ ភាសាព្យាបាទ ឬ ភាសាប្រមាថ

-ខ្ជិលច្រអូសឥតប្រយោជន៍ និងនិយាយពាក្យរសឹបរសៀវគ្មានន័យ ។ នៅពេលគេគេច ពីទម្រង់អស់ទាំងនេះជាធម្មតាគេត្រូវ តែនិយាយការពិតប្រើពាក្យពេចន៍ទន់ភ្លន់ចិត្តបុណ្យមាន ន័យ និងមានប្រយោជន៍ ។ គេមិនគួរនិយាយខ្វះការប្រុងប្រយត្ន័ទេ ពោលគឺត្រូវតែនិយាយទៅ តាមពេល និងទីកន្លែងត្រឹងត្រូវ ។ ប្រសិនបើគេមិនអាចនិយាយអ្វី ដែលមានប្រយោជន៍បានទេ គេគួរតែរក្សាភាពស្ងប់ស្ងាត់ឱ្យបានខ្ពស់បំផុត ។

**សម្មាកម្មន្តៈ** : **អំពើត្រូវ** (Right Acion) គឺត្រូវជៀសវាង :

- ការសម្លាប់សត្វ ការលួចឆក់ប្លន់

- ការបណ្តោយខ្លួនក្នុងផ្លូវកាមខុស ផ្ទុយទៅវិញត្រូវរស់នៅប្រកបដោយភាពបរិសុទ្ធ ទាំងកាយ ទាំងចិត្ត ។

**សម្មាអាជីវៈ** : **ការចិញ្ចឹមជីវិតត្រូវ** (Right Livelihood)

គឺបោះបង់នូវវិធីខុសឆ្គងនៃការរស់នៅ ដែលនាំមកនូវផលអាក្រក់ចំពោះអ្នកដទៃ និង ធ្វើឱ្យអ្នកដទៃរងទុក្ខវេទនាដែលមានការជួញដូរ :

- ការជួញអាវុធ ឬគ្រឿងផ្ទុះដែលបណ្តាលឱ្យស្លាប់

- សត្វសំរាប់កាប់សម្លាប់ ការជួញដូរមនុស្សជាតិ ឬធ្វើជាទាសករ

- ភេសជ្ជៈដែលធ្វើឱ្យស្រវឹង ជាតិពុល ហើយត្រូវរស់នៅដោយវិជ្ជាជីវៈមួយផុតការ តិះដៀលដោយមិនធ្វើឱ្យអ្នកដទៃនិងខ្លួនឯងខូចខាតឡើយ ។គេអាចយល់ឃើញយ៉ាងច្បាស់នៅ ទីនេះថាព្រះពុទ្ធសាសនាគឺប្រឆាំងដាច់ខាតចំពោះប្រភេទណាមួយនៃសង្គ្រាម ។ព្រះអង្គប្រកាស់ ថា ពាណិជ្ជកម្មអាវុធយុទ្ធភណ្ឌដែលបណ្តាលឱ្យស្លាប់ជាអំពើអាក្រក់ និងជាមធ្យោបាយពុំត្រឹម ត្រូវក្នុងការចិញ្ចឹមជីវិត ។

គេគួរតែដឹងថា ក្រមសីលនៃព្រះពុទ្ធមានបំណងលើកកំពស់ជីវិតរស់នៅឱ្យ សប្បាយ រីករាយ និងស្រុះស្រួលគ្នា ទាំងសម្រាប់បុគ្គល ទាំងសម្រាប់សង្គម ។ សីលនេះត្រូវបានគេចាត់ថា ជាមូលដ្ឋានគ្រឹះដ៏សំខាន់ សម្រាប់ការសម្រេចជោគជ័យផ្នែកស្មារតីខ្ពង់ខ្ពស់គ្រប់យ៉ាង ។ គ្មានការ អភិវឌ្ឍផ្នែកស្មារតីណាអាចទៅរួចទេ ប្រសិនបើគ្មានមូលដ្ឋានសីលការឯកភាពគ្នា ស្រុះស្រួលគ្នា និងទំនាក់ទំនងល្អរវាងមនុស្សនានានោះទេ ។ នៅក្នុងព្រះពុទ្ធសាសនា សីលមិនមែនជាគោល បំណងទេវាគ្រាន់តែជាមធ្យោបាយឈានទៅរកគោលបំណងប៉ុណ្ណោះ ។ ព្រះពុទ្ធបានប្រៀបធៀប

ការបង្រៀនរបស់ព្រះអង្គទៅតាមក្បួន ដែលយើងប្រើប្រាស់ និសសារាទាតតហាយាសម្រាប់គោលបំណងនៃការឆ្លងកាត់សុវត្ថិភាព និងនាងាហានាតតហាយាមិនមែនសម្រាប់គោលបំណងនៃការចងចាំទេ។ នៅពេលដែលយើងបានឈានដល់ចន្ទល់មួយទៀត យើងមិនចាំបាច់អនុវត្តនីក្បួននេះជាមួយយើងទេ។ ក្បួននេះត្រូវបានគេដាក់ទៅម្ខាង។

**សម្មាសមាធិ ៖ សមាធិសិក្ខា** (Mental Discopline)

បន្ទាប់មក ឈានចូលដល់សមាធិសិក្ខា ដែលក្នុងនោះត្រូវបានគេបញ្ចូលនូវកត្តាបីទៀតនៃមាគ៌ាទាំងប្រាំបីពោលគឺការព្យាយាមត្រូវ (Right Effort) ស្មារតីរលឹកត្រូវ (Right Mindfulness) និង តម្កល់ចិត្តត្រូវ (Right Concentration)។

**សម្មាវាយាមៈ ៖ ការព្យាយាមត្រូវ** (Right Effort )

ការព្យាយាមត្រូវ គឺព្យាយាមហើយព្យាយាមទៀតដើម្បីទប់ស្កាត់ការលេចឡើង នៃគំនិតអាក្រក់និងគំនិតអសុជីវធម៌ឬធ្វើឱ្យខូចសុខភាពដែលមិនទាន់កើតឡើងក្នុងគំនិតមនុស្ស។

- ការបោះបង់ចោលគំនិតអាក្រក់ដែលកើតមានឡើងរួចមកហើយ

- បង្កើតនិងអភិវឌ្ឍគំនិតល្អដែលមិនទាន់កើតមានឡើងហើយលើកកំពស់ និងថែរក្សាវាដែលបង្ហាញរួចមកហើយ។

ដូចនេះមុខងារនៃការព្យាមត្រូវចាំបាច់ត្រូវតែប្រុងប្រយត្ន័ និងពិនិត្យនូវគំនិត ដែលធ្វើឱ្យខូចសុខ ភាពទាំងអស់ ហើយបណ្តុះនូវគំនិតជាសុខភាព គំនិតបរិសុទ្ធឱ្យកើតឡើងក្នុងគំនិតមនុស្ស ។មនុស្សមានការប្រុងប្រយត្ន័ដែលគ្រប់គ្រងសកម្មភាពសំដីរបស់ខ្លួន និងរាងកាយរបស់ខ្លួនតាមរយៈសីល ( Ethical Conduct) ឥឡូវធ្វើការប្រឹងប្រែងយ៉ាងខ្លាំងដើម្បីពិនិត្យគំនិតរបស់ខ្លួនឆន្ទៈផ្លូវចិត្តរបស់គាត់ និងដើម្បីជៀសវាងគំនិតបែកឆ្វេង។

**សម្មាសតិ ៖ ស្មារតីរលឹកត្រូវ** (RightMindfulness) ៖ ចាំបាច់ត្រូវដឹងច្បាស់ភ្ញាក់រលឹក និងយកចិត្ត ទុកដាក់ចំពោះ

- សកម្មភាពនានានៃរូបកាយ កាយា

- វេទនារម្មណ៍ឬអារម្មណ៍ (វដោនា)

- សកម្មភាពនានានៃចិត្ត ( ចិតតា )

- គំនិតនានា ការគិតនានា បញ្ញត្តិកម្ម និងបញ្ហាផ្សេងៗ (ដហាមមា)

ការអនុវត្តលើការប្រមូលផ្តុំនៃការដកដង្ហើម (anapanaati) ជាការហ្វឹកហាត់មួយក្នុងចំណោមការហ្វឹកហាត់ដ៏ល្បីល្បាញដែលពាក់ពន្ធ័នឹងរាងកាយសម្រាប់ការអភិវឌ្ឍផ្លូវចិត្ត។ មានវិធីដទៃទៀតជាច្រើន នៃការអភិវឌ្ឍការយកចិត្តទុកដាក់ទាក់ទង នឹងរាងកាយដូចជារបៀបតាំងសមាធិ ។

ទាក់ទងនឹងវេទនារម្មណ៏គេគួរតែដឹងច្បាស់ គ្រប់រូបភាពនៃវេទនារម្មណ៍សប្បាយ មិនសប្បាយ និងអព្យាក្រិតពីលក្ខណៈដែលកើតឡើង និងបាត់ទៅវិញក្នុងខ្លួនរបស់គេ ។

ចំពោះសកម្មភាពនៃចិត្តគេគួរតែដឹងថា តើចិត្តរបស់គេត្រេកត្រអាលឬអត់ គេផ្តល់នូវភាពស្អប់ ខ្ពើមឬអត់ បែកស្មារតី ឬប្រមូលផ្តុំស្មារតី.... ។ល។ ក្នុងវិធីនេះគេគួរតែដឹងចលនាទាំងអស់នៃគំនិតរបៀបដែលវាកើត និងបាត់ទៅវិញ។

ទាក់ទងជាមួយគំនិត ការគិតបញ្ញត្តិកម្ម និងបញ្ហាផ្សេងៗទៀតគេគួរតែដឹងនូវធម្មជាតិរបស់វារបៀបកើតឡើងនិងបាត់ទៅវិញរបៀបដែលត្រូវគេអភិវឌ្ឍទប់និងបំផ្លាញ...។ កត្តាទីបីនិងកត្តាចុង ក្រោយបង្អស់នៃសមាធិ គឺត្រូវតម្កល់ចិត្តត្រូវដែលនាំទៅរកដំណាក់ទីបួននៃ ឈានញហានាដែលជាទូទៅហៅថា ការអណ្តែតអណ្តូង។

ក្នុងដំណាក់កាលទីមួយនៃឈាន ញហានា ដែលជាចំណង់ធ្វើឱ្យរំជួលអារម្មណ៍និងគំនិតដែលធ្វើឱ្យ ខូចផាសុខភាព និងសុជីវធម៌ ដូចកាមបុច្ឆាដែលធ្វើឱ្យកំរើកអារម្មណ៏ អឆន្ទៈភាពអស់សង្ឃឹមព្រួយបារម្ភ រសាប់រសល់ និងការសង្ស័យត្រូវគេបោះបង់ចោល រីឯអារម្មណ៏រីករាយនិងសុខត្រូវបានគេរក្សាទុកស្របជាមួយសកម្មភាពផ្លូវចិត្តពិត។ ដំណាក់ការទីពីរនៃសកម្មភាពបញ្ញាទាំងអស់ត្រូវបានទប់ រីឯអារម្មណ៏នៃសេចក្តីសប្បាយ និងសុខនៅតែត្រូវទុក។ ក្នុងដំណាក់ការទីបី អារម្មណ៏រីករាយដែលជាវេទនារម្មណ៍សកម្មក៏បាត់ដែរ នៅពេលមានការលះបង់សេចក្តីសុខសំដៅទៅរកភាពស្ងប់ស្ងាត់ខាងផ្លូវគំនិត។ នៅក្នុងដំណាក់កាលទីបួននៃឈាននេះញហានាវេទនារម្មណ៏ទាំងអស់សូម្បីសុខ ឬទុក្ខក៏បាត់ដែរមានតែការយល់ដឹងបរិសុទ និងភាបស្ងប់ស្ងាត់ទេ។

**សម្មាសង្កប្បៈ ៈ បញ្ញា** (Wisdom)

កត្តាទីពីរ ដែលនៅតែមានគឺការយល់ដឹងត្រូវ និងគំនិតត្រូវដែលបង្កើតបញ្ញា។ គំនិតរួមមាន គំនិតនៃការលះបង់ សុឆន្ទៈ រឺសេចក្តីមេត្តាការមិនធ្វើឱ្យមានទោស។ គេចាំបាច់ត្រូវតែបណ្តុះគំនិតទាំងនេះហើយបង្ហាញដល់ភាវៈមានជីវិតទាំងអស់ដោយមិនប្រកាន់ពូជសាសន៍វណ្ណៈបក្សសម្ពន្ធ័ឬគោលជំនឿឡើយ។ បើគេប្រកាន់យកបញ្ហាទាំងអស់នេះមិនមានលក្ខខណ្ឌសម្រប

សម្រួលទេ។ការផ្តល់នូវអារម្មណ៍កក់ក្តៅនៃគំនិត ខ្ពង់ខ្ពស់បែបនេះវាពិបាកណាស់សម្រាប់មនុស្សអាត្មានិយម។

យោងតាមពាក្យទូន្មានរបស់ព្រះពុទ្ធ មនុស្សដែលឆ្លាតមានវិជ្ជាជ្រៅជ្រះ និងបានរៀនសូត្រតែខ្វះការគិតត្រឹមត្រូវគេ នឹងទៅជាមនុស្សភ្លីភ្លើ (bala)។ ប្រសិនបើយើងគិតបញ្ហាដោយការយល់ដឹងច្បាស់ លាស់យើងនឹងយល់ថាចំណង់អាត្មានិយម សេចក្តីស្អប់ និងអំពើហិង្សាមិនអាចត្រូវគ្នានឹងបញ្ញាពិតបានទេ។ ការយល់ដឹងត្រូវ ឬបញ្ញាតែងតែជ្រាបចូលជាមួយគំនិតត្រូវហើយមិនដែលចេះអស់ទេ។

**សម្មាទិដ្ឋិៈ ការយល់ដឹងត្រូវ** (Right understanding)

ការយល់ដឹងត្រូវ ជាការយល់ដឹងបញ្ហាផ្សេងៗពិតហើយវាជាសច្ចភាព ខ្ពង់ខ្ពស់ដែលពន្យល់បញ្ហា ទាំងឡាយដូចបញ្ហានោះមានពិត។ ការយល់ដឹងត្រូវ ត្រូវបានកាត់បន្ថយមកត្រឹមការយល់ដឹងសច្ចភាពខ្ពង់ខ្ពស់ទាំងបួន(The four noble truths)។ការយល់ដឹងនេះជាបញ្ញាខ្ពង់ខ្ពស់បំផុតដែលយល់ដឹងសច្ចភាពចុងក្រោយ។

យោងតាមព្រះពុទ្ធសាសនាលោកថាមានការយល់ដឹងពីរប្រភេទ ពោលគឺអ្វីដែលយើងហៅថាពុទ្ធិ(knowledge) ដែលមានការចងចាំច្រើន ការយល់ច្បាស់ផ្នែកបញ្ញានៃមុខវិជ្ជានីមួយៗយោងតាមទិន្នន័យដែលគេផ្តល់ឱ្យ។ ការយល់ដឹងនេះហៅថា (knowing accordingly) (anubodha)។វាមិនជ្រៅណាស់ណាទេ ។ ការយល់ដឹងពិតគេហៅថា សេចក្តីវាងវៃ (pativedha) ដោយមើលឃើញវត្ថុមួយ ស្ថិតក្នុងធម្មជាតិពិតរបស់វាដោយគ្មានឈ្មោះឬងាទេ។ ការយល់ដឹងនេះអាចទៅរួចទាល់តែចិត្តរួចស្រលះ មិនជំពាក់ទាក់ទងនឹងអ្វី ហើយអភិវឌ្ឍពេញលេញតាមសមាសមាធិ។ ការយល់ដឹងត្រូវឬបញ្ញាវាងវៃ បានមកពីការអនុវត្តសមាធិនឹងនរ មាំទាំ និងជាបន្តបន្ទាប់ឬការបណ្តុះគំនិតដោយយកចិត្តទុកដាក់។ចំពោះមនុស្សដែលមានទេពកោសល្យយល់ដឹងត្រូវ គឺយល់ច្បាស់ ពីសុភាវធម៌ហើយសម្រេចបាននូវការផ្តល់ឱ្យទៀងទាត់ពី គំនិត (akuppa ceto vimutti)។

**រក្សាខ្លួនទៅតាមគន្លងមាគ៌ា** (Keep to the Path)

ព្រះបន្ទូលរបស់ព្រះពុទ្ធបានរៀបរាប់ពីមុខងារ និងគោលបំណងនៃការបណ្តុះសីលសមាធិសិក្ខានិងបញ្ញា។ ការផ្តល់នូវមធ្យោបាយរស់នៅស្តីពីការបំបាត់ឬសគល់អំពើអាក្រក់ទាំង

បី ពោលគឺ លោភៈ ទោសៈ និងមោហៈ ដែលធ្វើឱ្យចិត្តមនុស្សវង្វេងវង្វន់។ បុព្វហេតុឫសគល់ទាំងនេះត្រូវបានគេបំបាត់តាមរយៈសីល សមាធិសិក្ខា និងបញ្ញានេះឯង។

ដូចនេះវាច្បាស់ណាស់ថា ពាក្យទូន្មានរបស់ព្រះពុទ្ធមានបំណងធ្វើឱ្យស្អាតបរិសុទ្ធខ្ពស់បំផុត និងមានសុខភាពផ្លូវចិត្តឥតខ្ចោះ ដែលរួចចាកផុតពីកម្លាំងជំរុលចិត្តដែលនាំមកនូវសេចក្ដីសៅហ្មង។

ឥឡូវការជួយសង្គ្រោះពីភាពសៅហ្មងខាងចិត្ត ការរួចចាកផុតពីជំងឺ ស្ថិតនៅក្នុងដៃផ្ទាល់របស់មនុស្ស។ព្រះពុទ្ធដ៏ប្រសើរមិនអាចជួយមនុស្សពីគ្រឿងហាមប្រាមនៃការកើតមានទេ លើកលែងតែការបង្ហាញមាគ៌ាទៅគាត់។ មាគ៌ា សីល សមាធិ បញ្ញា គឺសំដៅការបណ្ដុះបណ្ដាលមាគ៌ាចម្បងទាំងបីហើយ គ្មានមាគ៌ាណាមួយមានគោលបំណងនៅក្នុងខ្លួនវាផ្ទាល់នោះទេ វាគ្រាន់តែជាមធ្យោបាយឆ្ពោះទៅរកគោលបំណងប៉ុណ្ណោះ។ មនុស្សមិនអាចមានតួនាទីឯករាជ្យពីអ្នកដទៃបានទេ គេមិនអាចធ្វើកិច្ចការដោយគ្មាន ការគាំទ្រពីអ្នកដទៃបានទេ ហេតុនេះគេត្រូវជួយគ្នា និងគាំទ្រគ្នាទៅវិញទៅមក សីលពង្រឹងសមាធិសិក្ខា ហើយសមាធិសិក្ខាពង្រឹងបញ្ញា។ បញ្ញាជួយមនុស្សឱ្យចាកផុតពីបញ្ហាស្មុកស្មាញ ដោយមើលឃើញជីវិតពិត និងបញ្ហាទាំងអស់ដែលទាក់ទងនឹងជីវិតខណៈកើតឡើង និងបាត់ទៅវិញ។ សូម្បីពុទ្ធិខាងវិទ្យាសាស្ត្រីកចម្រើនក៏ដោយ ក៏ប្រជាជននៅក្នុងសកលលោកកំពុងច្រាស់ច្រាល់រសាប់រសល់ភ័យបារម្ភ និងមិនពេញចិត្តដែរ ។

ពួកគេស្រើងនឹងចំណង់ចង់បានកេរ្តិ៍ឈ្មោះ ទ្រព្យសម្បត្តិ អំណាចនិងការសប្បាយខាងអារម្មណ៍ ចំពោះពិភពពោពេញដោយបញ្ហាគេនៅតែកញ្ច្រោល នឹងភាពស្អប់ មិនទុកចិត្តអាត្មានិយមនិងអំពើហិង្សា។ មាគ៌ាខ្ពង់ខ្ពស់ទាំងប្រាំ៨ របស់ព្រះពុទ្ធនាំទៅរកការយល់ដឹងនៃនិព្វាន្ត។ គ្រាន់តែចំណេះដឹងខាង មាគ៌ាទោះបីជាមានពេញលេញក៏មិនអាចធ្វើបានដែរ។ ក្នុងករណីនេះមុខងាររបស់យើងចាំបាច់ត្រូវអនុវត្ត តាមមាគ៌ា និងរក្សាមាគ៌ាឱ្យត្រឹមត្រូវ។

មាគ៌ាទាំងនេះតាមពិតគឺពិបាកយល់ តែបើយើងប្រកាន់ខ្ជាប់ខ្លួនយើងនឹងសម្រេចក្ដីប៉ងប្រាថ្នារបស់ខ្លួន។ ក្មេងដែលទើបតែរៀនដើរនិងឈរ ជាបណ្ដើរៗនឹងមានការលំបាក។ ហេតុនេះភាពខ្ពង់ខ្ពស់ទាំងអស់ តែងវិវត្តន៍ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀតឆ្លង កាត់ការបរាជ័យផ្ទួនៗទើបសម្រេច ជោគជ័យតាមក្រោយ។ វាជាមាគ៌ាដែលនាំទៅរកការយល់ដឹងពី

តថភាពខ្ពស់ និងសុភមង្គល សន្តិភាព ពេញលេញតាមយៈភាពឥតខ្ចោះផ្នែកបញ្ញា ស្មារតី និង សីលធម៌ ។

ពីរឿងរ៉ាវដ៏សង្ខេបនៃមាគ៌ានេះ គេប្រហែលជាយល់ថា មាគ៌ានេះ ជាវិធីមួយនៃជីវិត ដែលបុគ្គលម្នាក់ៗត្រូវអនុវត្តតាម ។ មាគ៌ានេះជាស្វ័យវិន័យក្នុងរាងកាយពាក្យពេចន៍ចិត្តគំនិត ការអភិវឌ្ឍខ្លួននិងធ្វើខ្លួនឱ្យល្អបរិសុទ្ធដោយមិនចាំបាច់ធ្វើជាមួយជំនឿធ្វើការបួងសួងនិងធ្វើពិធីទេ ។

**ហេតុការណ៍នៃជីវិត** (FACT OF LIFE)

យើងរស់នៅក្នុងពិភពមិនស្មើគ្នា ជាពិភពគ្មានក្តីសង្ឃឹម ហើយក៏មិនពោពេញដោយភាពស្មុគស្មាញដែរ ។ ផ្កាកូលាបមានភាពស្រទន់ស្រស់ស្អាត និងក្រអូបតែទងរបស់វាវិញ គឺពោពេញដោយបន្លា ។ ដោយសារតែផ្កាកូលាបគេអត់ធ្មត់នឹងបន្លា ។ ទោះយ៉ាងណាគេមិនបន្ទោសបង្អាប់កូលាបដោយសារតែបន្លា នោះទេ ។

តាមអ្នកសុទិដ្ឋិនិយមថា ពិភពលោកនេះពោពេញដោយក្តីសង្ឃឹម រីឯអ្នកទុទិដ្ឋិនិយមវិញថា ពិភពលោកនេះ គ្មានក្តីសង្ឃឹមពេញលេញ ហើយក៏មិនមានបញ្ហាស្មុគស្មាញទាំងស្រុងនោះដែរ ។ ពិភពលោកនេះប្រៀបដូចជាកូលាបដ៏ស្រស់ស្អាត និងមានបន្លា ។

បុគ្គលដែរមានការយល់ដឹងមិនស្រើបស្រាលនឹងសម្រស់ផ្កាទេ គ្រាន់តែមើលវាក្នុងលក្ខណៈធម្មតាប៉ុណ្ណោះ ។ បុគ្គលដែលយល់ដឹងជ្រៅជ្រះពីធម្មជាតិនៃបន្លា ប្រយត្ន័ណាស់មិនឱ្យទទួលការឈឺចាប់ពីបន្លាទេ ។

ដូចប៉ោលដែលធ្វើចលនាអចិន្ត្រៃពីស្តាំទៅឆ្វេង ។ក្នុងពិភពលោកនេះមានលក្ខខណ្ឌដែលមនុស្ស ចង់បានបួនយ៉ាង និងមិនចង់បានបួនយ៉ាង ហើយមនុស្សទាំងនោះត្រូវតែប្រឈមមុខនឹងលក្ខខណ្ឌទាំងនេះ ក្នុងជីវិតរស់នៅ ។ លក្ខខណ្ឌទាំងនោះមាន :

១ ប្រយោជន៍ និងបាត់បង់ (*Gain and Loss*)

២ កិត្តិយស និងអាប់ឱន (Honour and Dishonour)

៣ សសើរ និងបន្ទោស ( Praise and Blame)

៤ សុខ និងទុក្ខ (Happiness and Sorrow)

**ប្រយោជន៍ និងបាត់បង់** (Gain and Loss) :តាមច្បាប់អ្នករកស៊ី អាចមានទាំងចំណេញ និងខាតប្រយោជន៍ ។ តាមធម្មជាតិគេមិនខ្វល់ទេ នៅពេលគេទទួលប្រយោជន៍ឬចំណេញនោះ ។ វាគ្មានអ្វីដែលមិនត្រឹមត្រូវនោះទេ ប្រាក់ចំណេញបែបនេះ បង្កើតឱ្យមានសេចក្តីសប្បាយ ដែល

មនុស្សមានវិយកណ្ដាលស្វែងរក។ បើគ្មាន ពេលរីករាយបែបនោះទេជីវិតមិនមែនជាការរស់នៅដោយសុភមង្គលនោះទេ។ក្នុងពិភពដ៏ច្របូកច្របល់ និងប្រកួតប្រជែងនេះ វាជាការត្រឹមត្រូវហើយដែលមនុស្សគួរស្វែងរកប្រភេទសុខមួយ ចំណួយដែលធ្វើឱ្យចិត្តគេរីករាយ។ ទោះបីផ្នែកសម្ភារៈក្ដីក៏សុខបែបនេះអាចទទួលយកបាន ដើម្បីសុខភាព និងភាពយឺនយូរដែរ។

បញ្ហាកើតឡើងក្នុងករណីខាតបង់។ ធម្មតាមនុស្សទទួលយកនូវភាពចំណេញ ដោយភាពរីករាយ ដែលផ្ទុយពីការខាតបង់ដែលធ្វើឱ្យគេមិនសប្បាយចិត្ត។ ការខាតបង់ជារឿយៗនាំឱ្យមានការឈឺចាប់ផ្នែកផ្លូវចិត្ត ហើយពេលខ្លះអាចឈានទៅដល់ការធ្វើអត្តឃាដផងដែរប្រសិនបើការខាតបង់នោះមានសភាព ធ្ងន់ធ្ងរពេកស្ថិតក្នុងកាលៈទេសៈបែបនេះគេគួតែបង្ហាញនូវភាពក្លាហានផ្នែកសីលធម៌ខ្ពស់ ហើយរក្សានូវលំ នឹងចិត្តឱ្យបានសមរម្យ។ យើងទាំងអស់គ្នាតែងតែមានការឡើង និងការចុះជាការធម្មតាទេចំពោះការប្រយុទ្ធជាមួយនឹងជីវិតនេះ។ មនុស្សគួរៀបចំនូវអ្វីល្អ និងអ្វីអាក្រក់បន្ទាប់មកគេនឹងមានការខកចិត្តតិច។

ក្នុងសម័យព្រះពុទ្ធ ស្ត្រីដ៏ប្រសើរម្នាក់បានផ្ដល់អាហារទៅដល់ Sariputta ដ៏គួឱ្យគោរព និង ព្រះសង្ឃមួយចំនួន ហើយខណៈពេលដែលនាងកំពុងបំរើព្រះសង្ឃ នាងបានទទួលនូវកំណត់សំគាល់មួយ ដែលបង្ហាញថា សំណាងអាក្រក់ពិតជាបានប៉ះពាល់ដល់គ្រួសាររបស់នាង។ ពេលនោះនាងរក្សាភាពស្ងប់ស្ងៀមហាក់គ្មានខ្វាយខ្វល់ពីអ្វីសោះហើយធ្វើការបំរើព្រះសង្ឃដូចធម្មតា។

ថ្ងៃមួយព្រះពុទ្ធបានទៅបិណ្ឌបាតក្នុងភូមិមួយ ហើយព្រះអង្គអត់បានទទួលនូវចង្ហាន់សោះ ដោយសារបទអន្តរាគមន៍របស់នាង Mara ដែលជាមនុស្សអាក្រក់។ ពេលនោះនាងក៏បានសួរព្រះអង្គថា តើព្រះអង្គខឹងនឹងនាង ឬអត់លេនោះព្រះអង្គក៏បានពន្យល់ដោយតិរិយាបថផ្លូវចិត្តយ៉ាងស្ងប់ ហើតឆ្លើយថា យើងរស់នៅដោយភាពរីករាយគ្មានឧបសគ្គអ្វីទេ។ ព្រះអង្គថា អ្នកទាំងឡាយណាដែលផ្ដល់អាហារ ដោយភាពរីករាយ យើងចាត់ទុកថា ជាព្រះ The Radian Realm ។

នាឱកាសមួយទៀត ព្រះពុទ្ធ និងសាវ៉ៈរបស់ព្រះអង្គបានអង្កេតនូវអំឡុងភ្លៀងធ្លាក់(វស្សា)ក្នុងភូមិមួយតាមការអញ្ជើញរបស់ព្រាហ្មណ៏ម្នាក់ ដែលទោះជាលោកបានភ្លេចនូវភារកិច្ចរបស់លោកចំពោះការចូលរួមនូវតម្រូវការរបស់ព្រះអង្គនិង Sangha ។ ពេញអំឡុងពេលញបីខែ ទោះបី Moggallana ដ៏ប្រសើរស្មគ្រ័ចិត្តផ្ដល់ចង្ហាន់ដោយអំណាចផ្លូវចិត្ត (អ្នកដែលមាន

ភ្នែកឬត្រចៀកទិព្វ) ក៏ព្រះអង្គមិនមានការតវ៉ាដែរផ្ទុយទៅវិញព្រះអង្គពេញចិត្ត នឹងចំណីក្រៀម របស់សត្វសេះដែលផ្ដល់ដោយឈ្មួញសេះ ។

មនុស្សត្រូវទ្រាំនឹងភាពបាត់បង់ទាំងឡាយ ព្រោះមនុស្សតែងតែទទួលនូវការបាត់បង់ច្រើន។ មនុស្សត្រូវប្រឈមនឹងការខាតបង់ដោយចិត្តនឹង ហើយចាត់ទុកថា វាជាឱកាសមួយក្នុងការបណ្ដុះសីលធម៌ដ៏ប្រសើរ ។

**កត្តិយស និងភាពអាប់ឱន** (Honour and Dishonour): កត្តិយសនិងភាពអាប់ឱនជាលក្ខខណ្ឌពិភពលោកដែលមនុស្សមិនអាចជៀស ផុតក្នុង ជីវិតរស់នៅប្រចាំថ្ងៃ។ មនុស្សចង់បានកត្តិយសតែគេមិនចង់បានសេចក្ដីអាប់ឱនទេ ។គេតែងតែចង់ធ្វើជាអ្នកល្បីល្បាញ ។យើងតែងទទឹងរង់ចាំនូវរូបភាពរបស់យើងនៅក្នុងកាសែត ។ យើងសប្បាយយ៉ាងខ្លាំងនៅ ពេលសកម្មភាពរបស់យើងត្រូវបានគេផ្ដល់កត្តិយសចំពោះសាធារណៈ តែពេលខ្លះយើងក៏ស្វែងរកវាលើសកម្រិតដែរ ។

មនុស្សជាច្រើនអន្ទះសាចង់ឃើញរូបភាពរបស់គេនៅក្នុងទស្សនាវដ្ដីនូវតម្លៃណាមួយ ។ ដើម្បីបានកត្តិយសខ្លះផ្ដល់អំណោយដ៏ច្រើនទៅដល់អ្នកដែលមានអំណាច ។ ដើម្បីជាប្រយោជន៍សាធារណៈ ខ្លះបង្ហាញភាពសប្បុរសរបស់គេដោយផ្ដល់ទានទៅព្រះសង្ឃ តែគេមិនគិតចំពោះការឈឺចាប់របស់អ្នកក្រ និងអ្នកជិតខាងដែលត្រូវការជាចាំបាច់នោះទេ ។

ទាំងអស់នេះជាភាពទន់ខ្សោយរបស់មនុស្ស ។មនុស្សភាគច្រើនមានចំណង់អាថិកំបាំង ។ មនុស្សដែលគិតប្រយោជន៍រួមធ្វើសកម្មភាពមិនលំអៀងកំរណាស់នៅក្នុងពិភពលោក ។ ដូចនេះតើនណាទៅគឺជា មនុស្សឥតខ្ចោះនោះ? តើមានភាពឥតខ្ចោះប៉ុន្មាននៅក្នុងចំណង់របស់គេ? តើមានប៉ុន្មាននាក់ដែលគិតពី ប្រយោជន៍គេទាំងស្រុងនោះ ?

ប្រសិនបើយើង គឺជាតម្លៃនៃកត្តិយស វានឹងនាំឱ្យយើងស្វែងរក ។ ផ្កាទាក់ទាញឃ្មុំដោយសារវាផ្ទុកនូវទឹកឃ្មុំ ហើយផ្កាមិនបានអញ្ជើញឃ្មុំឱ្យក្រេបវានោះទេ ។

ជាការពិតយើងធម្មតាចង់សប្បាយហើយសប្បាយខ្លាំងនៅពេលដែលកេរ្តិ៍ឈ្មោះយើងរីករាលដាលកាន់តែខ្លាំងនិងទូលំទូលាយតែយើងគួដឹងថា កេរ្តិ៍ឈ្មោះ និងភាពល្បីល្បាញប្រកាន់តែជាការឆ្លងកាត់ នូវដំណាក់កាលបន្តបន្ទាប់ប៉ុណ្ណោះ វានឹងរសាត់បាត់ទៅក្នុងខ្យល់នៅពេលឆាប់ៗនេះ ។

ចុះភាពអាប់ឱនដូចម្ដេចដែរ? វាមិនគួឱ្យចូលចិត្តទាំងចិត្តទាំងត្រចៀក។ យើងមាន ការឈឺ ចាប់យ៉ាងខ្លាំងនៅពេលដែលរបាយការណ៍ ដែលគេហៅនោះមានការក្លែងបន្លំមិន ត្រឹមត្រូវ។

ជាធម្មតាគេចំណាយពេលច្រើនក្នុងការសាងអាគាធំ។ ក្នុងមួយនាទី ឬពីនាទីអាវុធ ប្រល័យ ទំនើបអាចកំទេចយ៉ាងស្រួល។ ពេលខ្លះត្រូវចំណាយពេលច្រើន ឬពេញមួយជីវិត ទើបអាចកសាងកេរ្តិ៍ឈ្មោះល្អបាន។គេមិនអាចបំផ្លាញនូវកេរ្តិ៍ឈ្មោះដែលយើងរកបានដោយ កំរនោះបានទេ។ អ្នកអាចរស់នៅក្នុងជីវិតនៃព្រះពុទ្ធ តែអ្នកមិនអាចជៀសផុតពីការរិះគន់ ការវាយប្រហារ និងការធ្វើឱ្យអាម៉ាស់ណាស់។

ព្រះពុទ្ធល្បីល្បាញបំផុត ហើយជាគ្រូដ៏ប្រសប់ផុត។ អ្នកប្រឆាំងព្រះពុទ្ធជាច្រើនបាន និយាយ ពាក្យចចាមអារាមពាស់វាលពាស់កាលថា ស្ត្រីម្នាក់ធ្លាប់ចំណាយពេលនៅពេល យប់ក្នុងវត្ត។ ដោយការបរាជ័យនៅក្នុងការប៉ុនប៉ងចម្បងនេះគេក៏ប្រឹឌិតដំណឹងមិនប្រាកដ ដោយចោទប្រកាន់សាវ៉ៈរបស់ព្រះអង្គថា បានសម្លាប់ស្ត្រីម្នាក់ ហើយលាក់សាកសពរបស់ នាងទុកនៅក្នុងគំនផ្កានៅក្នុងវត្ត។ ក្រោយមកអ្នករួមគំនិតប្រព្រឹត្តទុចរិតក៏បានសារភាពថា ពួកគេគឺប្រព្រឹត្តខុស។

នៅពេលបេសកម្មជាប្រវត្តិសាស្ត្ររបស់ព្រះអង្គទទួលជោគជ័យ ហើយនៅពេល ដែលមនុស្ស ភាគច្រើនស្វែងរកការបួសតាមព្រះពុទ្ធនោះ បច្ចាមិត្រព្រះអង្គបានមួលបង្កាច់ ថា ព្រះអង្គកំពុងតែប្លន់ ម្ដាយពីកូនគេ ដោយដកហូតប្រពន្ធពីប្ដីរបស់គេ ហើយថាព្រះអង្គ ធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍប្រទេសជាតិ។

ដោយបរាជ័យក្នុងការប៉ុនប៉ងដើម្បីបំផ្លាញលក្ខណៈដ៏ប្រសើររបស់ព្រះអង្គ បងប្អូន ជីដូនមួយ ផ្ទាល់របស់ព្រះអង្គ ឈ្មោះ Devadatta ដែលជាសាវ៉ៈព្រះអង្គបានប៉ុនប៉ងសម្លាប់ ព្រះអង្គដោយប្រមៀលថ្មពីខាងលើតែត្រូវបរាជ័យទៀត។

ព្រះអង្គមានព្រះបន្ទូលថាបើអ្នកឡើងភ្នំកាន់តែខ្ពស់ អ្នកនឹងលេចត្រដែតជាងគេក្នុង ចក្ខុរបស់អ្នកដទៃ។ ផ្នែកខាងក្រោយរបស់អ្នកត្រូវលាតត្រដាង តែផ្នែកខាងមុខវិញត្រូវលាក់ ជិត។ ពិភពដែលស្វែងរកតែកំហុសបានកើតឡើងនូវរយៈពេលខ្លីណាស់។

គេមិនចាំបាច់ចំណាយពេលឥតប្រយោជន៍ ក្នុងកាកែតម្រូវរបាយការណ៍មិនពិតទេ ប្រសិនបើ កាលៈទេសៈមិនបង្ខំអ្នកឱ្យបង្ហាញពីភាពចាំបាច់នោះទេ។ សត្រូវសប្បាយណាស់នៅពេលឃើញអ្នកត្រូវរបួស ដែលនោះហើយជាអ្វីដែលគេរំពឹងគិត។ ប្រសិនបើអ្នកមិនបារម្ភទេ ការផ្ដល់ព័ត៌មានមិនពិតនឹងធ្លាក់ទៅលើត្រចៀកដែលថ្លង់។

- នៅក្នុងការមើលឃើញកំហុសអ្នកដទៃ យើងគួប្រព្រឹត្តដូចមនុស្សខ្វាក់
- បើឮការរិះគន់មិនត្រឹមត្រូវពីអ្នកដទៃ ត្រូវប្រព្រឹត្តដូចជាមនុស្សថ្លង់
- ក្នុងការនិយាយដើមអ្នកដទៃ យើងគួប្រព្រឹត្តដូចមនុស្សគ

- គេមិនអាចបញ្ឈប់ការចោទប្រកាន់មិនពិត ពត៌មានមិនពិត ឬពាក្យចចាមអារ៉ាមមិនពិតបានទេ។ ពិភពលោកគឺពោរពេញដោយបន្លា និងគ្រួសហើយគេមិនអាចយកបន្លានិងគ្រួសនេះចេញបានទេ។ តែប្រសិនបើយើងចាំបាច់ត្រូវដើរទោះបី មានឧបសគ្គជំនួសឱ្យការជំនះឧបសគ្គ យើងអាចពាក់ស្បែកជើងដើរដែលមិនសូវធ្វើឱ្យយើងឈឺចាប់។ ព្រះធម៌បានបង្រៀនថា :

- ចូរធ្វើដូចតោដែលញ័រមិនមែននៅត្រង់សូរសំលេង
- ចូរធ្វើដូចខ្យល់ដែលមិនស្អិតជាប់នឹងសំណាញ់
- ចូរធ្វើដូចដើមឈូក ដែលមិនត្រូវកង្វក់ដោយសារភក់ពីផ្ទៃកណាមួយដែលវាលូតឡើងទេ

- ជាស្ដេចព្រៃតោគឺមិនចេះភ័យខ្លាច។ ពួកវាមិនភ័យខ្លាចនឹងសំលេងរបស់សត្វដទៃទៀតនោះទេ។ ក្នុងពិភពលោកមានការក្លែងបន្លំ ការចោទប្រកាន់មិនពិត ហេតុនេះយើងមិនគួស្ដាប់វាទេ។

- ឆ្កែព្រុះ តែអ្នកដំណើរធ្វើដំណើរយ៉ាងស្រួល។ យើងរស់នៅក្នុងពិភពមិនស្អាតស្អំ។ ដើម ឈូកជាច្រើនលូតឡើង ដូចនេះបើគ្មានការប្រលាក់ពីភក់ទេ វានឹងធ្វើឱ្យពិភពលោកស្រស់ស្អាត។ ដូចដើមឈូកដែរ យើងគួដឹកនាំជីវិតរបស់យើងឱ្យខ្ពង់ខ្ពស់ និងគ្មានការស្ដីបន្ទោស។

- ទោះបីការលំបាកយ៉ាងណាក៏ដោយ យើងគួតែបណ្ដុះនូវការមិនជាប់ជំពាក់ចិត្ត។ យើងមកតែ ឯង ទៅក៏តែឯងដែរ។ ការមិនជាប់ជំពាក់ចិត្ត ជាសុភមង្គលក្នុងពិភពលោក។

- វាចំលែកដែរមនុស្សអស្ចារ្យត្រូវគេមួលបង្កាច់ ឆ្កាង បំពុលឬបាញ់សម្លាប់។ សូក្រាតដ៏អស្ចារ្យត្រូវគេឱ្យផឹកថ្នាំបំពុល យេស៊ូ គ្រិស្ត ត្រូវបានគេឆ្កាង *Mahatma Gandhi* ត្រូវគេបាញ់សម្លាប់។ តើភាពល្អខ្លាំងពេកពិតជានាំឱ្យមានគ្រោះថ្នាក់ឬ ?

ជាការពិតក្នុងអំឡុងជីវិតពួកគេពួកគេត្រូវបានរិះគន់វាយប្រហារនិងសម្លាប់..។ បន្ទាប់ពី ស្លាប់ទៅទើបពួកគេត្រូវបានគេលើកយកមកបង្ហាញ ហើយឱ្យតម្លៃ។ គេមិនខ្វល់ទេនៅពេលគេរិះគន់។ គេធ្វើការមិនមែនសំរាប់កេរ្តិ៍ឈ្មោះ ឬកត្តិយសនោះទេ គេមានសិទ្ធិធ្វើការងារតែគេមិនសំដៅលើលទ្ធផលនោះទេ។

**ការសរសើរ និងការស្តីបន្ទោស** ( *Praise and Blame*) : ការសរសើរ និងការស្តីមន្ទោសជាលក្ខខណ្ឌនៃពិភពលោក ពីទៀតដែលប៉ះពាល់ដល់មនុស្សជាតិ។ ជាធម្មតាមនុស្សសប្បាយនៅពេលគេសរសើរ ហើយគេកង្វល់នៅពេលត្រូវបានគេបន្ទោស។ ក្នុងចំណោមការបន្ទោស និងការសរសើរព្រះពុទ្ធបានមានព្រះបន្ទូលថា អ្នកប្រាជ្ញមិនបង្ហាញនូវការសប្បាយ ឬកង្វល់ទេ។ប្រៀបដូចថ្មដែលរឹង ដែលមិនរង្គើរដោយសារតែកម្លាំងខ្យល់ឡើយ។ ការសរសើរប្រសិនបើមាន តម្លៃគឺវាធ្វើឱ្យសប្បាយត្រចៀក តែបើគ្មានតម្លៃដូច ជាក្នុងករណីបញ្ជោរទោះជាសប្បាយក៏វាជាការបោកប្រាស់ដែរ។ តែលក្ខណៈទាំងអស់នឹងគ្មានឥទ្ធិពលទេ ប្រសិនបើមិនឮដល់ត្រចៀករបស់យើង។

ការសរសើរតិចតួច គឺគេអាចទទួលយកយ៉ាងងាយ។ ការសរសើរពីគុណសម្បត្តិគឺគ្រប់គ្រាន់ ហើយចំពោះការទាក់ទាញទស្សនិកជនមុននឹងគេនិយាយស្តី។ ប្រសិនបើនៅដើមដំបូងវាគ្មិនសរសើរទស្សនិកជនគេនិងយកចិត្តទុកដាក់ស្តាប់គាត់តែប្រសិនបើគាត់រិះគន់នៅដើមដំបូងវិញការឆ្លើយតបនឹងមិនពេញចិត្ត។

អ្នកដែលបានអប់រំមិនទោរទន់ទៅរកការបញ្ជោរនោះទេ ហើយគេក៏មិនចង់ឱ្យនណាបញ្ជោរគេដែរ។

មនុស្សភាគច្រើនដែលស្គាល់ព្រះពុទ្ធបានសរសើរ គុណធម៌របស់ព្រះអង្គក្នុងវិធីផ្ទាល់របស់ពួកគេ។ Upali ដែលជាមហាសេដ្ឋី និងជាសាវៈថ្មីនោះបានសរសើរព្រះពុទ្ធនូវការរៀបរាប់ ពីគុណធម៌រាប់រយដែលមិនបានព្រាងទុក។ គុណធម៌ដ៏ប្រសើរទាំង៩ ដែលជាចរន្តក្នុងពេលរបស់ព្រះអង្គ គឺនៅតែត្រូវបានគេសូត្រ ដោយសារៈរបស់ព្រះអង្គដែលសំឡឹងមើលរូបភាពរបស់ព្រះអង្គ។ គុណធម៌ដែលមានលក្ខណៈសម្បត្តិល្អ គឺនៅតែជាការជំរុញចិត្តដ៏ធំចំពោះសាវៈរបស់ព្រះអង្គ។

ចុះការបន្ទោសយ៉ាងណាដែរ ? ព្រះពុទ្ធបានមានព្រះបន្ទូលថា អ្នកនិយាយតិចក៏មានការស្តីបន្ទោសអ្នកនិយាយច្រើនក៏មានការស្តីបន្ទោសហើយអ្នក ដែលមិននិយាយក៏ដូចនេះដែរ។

នៅក្នុងពិភពលោកនេះ គឺគ្មាននណាដែលមិនត្រូវបានគេបន្ទោសនោះទេ ។ ការបន្ទោសជាបញ្ហាទូទៅរបស់មនុស្សជាតិ។ មនុស្សជាច្រើននៅក្នុង ពិភពលោកដែលគាត់សំគាល់ព្រះពុទ្ធគឺ គ្មានសណ្តាប់ធ្នាប់។ ប្រៀបដូចដំរីនៅក្នុងសមរភូមិដែលអត់ធ្មត់ពីព្រួញទាំង អស់ដែលគេបាញ់ដាក់វាដូចព្រះពុទ្ធដែលរងនូវការប្រមាថគ្រប់បែបយ៉ាង។

មានតែព្រះពុទ្ធទេដែលល្អឥតខ្ចោះក្រៅពីនោះគ្មាននណាមួយដែលល្អទាំងអស់ឬអាក្រក់ទាំងអស់នោះទេ។ វាមានភាពល្អនៅក្នុងភាពអាក្រក់នៃយើង ហើយ មានភាពអាក្រក់នៅក្នុងភាពល្អនៃយើង ។ ព្រះពុទ្ធដាស់តឿនថា អ្នកដែលមានភាពស្ងប់ស្ងាត់ នៅពេលគេវាយប្រហារគេប្រមាថ និងបំពារបំពាន នោះហើយវត្តមាននៃនិព្វាន ទោះបីជាគាត់មិនទាន់ទទួលបាននិព្វន្តក៏ដោយ។

នៅក្នុងរឿងច្រើននៃ Jataka បានបង្ហាញថា Guttila ជាអ្នកតន្ត្រីដែលបានបង្រៀនអ្វីៗគ្រប់ យ៉ាងដែលលោកដឹងទៅឱ្យសិស្សរបស់លោកដោយឥតមានលាក់ទុកឡើយ តែបុរសក្មេងនោះព្យាយាម បំពេញជាមួយគ្រូរបស់ខ្លួនដោយបរាជ័យហើយក៏បំផ្លាញគ្រូ។

នាឱកាសមួយព្រាហ្មណ៍បានអញ្ជើញព្រះអង្គសម្រាប់ជាទានទៅផ្ទះរបស់លោក ។ដោយត្រូវបានគេអញ្ជើញព្រះពុទ្ធក៏បានទៅផ្ទះនោះ។ ជំនួសឱ្យការកំសាន្តលោកក៏បានប្រើពាក្យសម្តីមិនសមរម្យ។ ឃើញដូចនេះព្រះអង្គក៏បានសួរដោយគួសមថា ព្រាហ្មណ៍ដ៏ចម្រើនតើអ្នកទាំងអស់នោះមកលេងផ្ទះរបស់អ្នកឯងឬ ? ព្រាហ្មណ៍ពិតណាស់ តើអ្នកធ្វើអ្វីនៅពេលដែលពួកគេមក ? យើងរៀបចំនូវបុណ្យធំ ? ព្រាហ្មណ៍ ដ៏ចម្រើនអ្នកបានអញ្ជើញខ្ញុំសម្រាប់ទាន ហើយអ្នកបានធ្វើឱ្យខ្ញុំសប្បាយដោយប្រើពាក្យបំពាបំពានខ្ញុំមិនទទួលយកទេអ្នកយកទៅវិញចុះ ។ព្រះពុទ្ធមិនសងសឹកទេ តែដាស់តឿនថា ភាពស្អប់មិនធូស្បើយតាមរយៈការស្អប់ទេគឺ មានតែការស្រលាញ់តែមួយគត់ដែលអាចបន្ធូបាន។

មិនមានគ្រូល្បីណាត្រូវបានគេសរសើរខ្ពស់រិះគន់ បន្ទោសខ្លាំងដូចព្រះអង្គទេ ។បែបនេះជាវាសនានៃមនុស្សអស្ចារ្យ។

ព្រះពុទ្ធត្រូវគេចោទថា បានសម្លាប់ស្ត្រីម្នាក់ ដែលជួយដោយសាវ៍ៈរបស់ព្រះអង្គ។ ព្រះពុទ្ធបាន សួរទៅអានន្ត Ananda ថាយ៉ាងមេចដែរបើអ្នកភូមិទាំងនោះបំពាបំពានយើងនោះ ? អានន្តថាយើងនឹងបន្តទៅភូមិមួយទៀត។ បន្ទាប់មកព្រះអង្គមានបន្ទូលថាអានន្តប្រទេសឥណ្ឌាទាំងមូលនេះគ្មានកន្លែងសម្រាប់យើងទេ ចូរអត់ធ្មត់បញ្ហាទាំងអស់នេះ នឹងរលត់ទៅវិញដោយ

ឯង៧។ ពុំនោះទៀតមានស្ត្រីម្នាក់ទៀតខឹងព្រះពុទ្ធ បានជួលអ្នកស្រវឹងម្នាក់មកប្រមាថព្រះអង្គនៅសាធារណៈ តែព្រះអង្គនៅតែរក្សាចិត្ត នឹងបានល្អណាស់។ ការរិះគន់ គឺច្រើនតែជាមនុស្សសាមញ្ញ។ យើងធ្វើការកាន់តែច្រើនយើងកាន់តែអស្ចារ្យ។ សូក្រាត ត្រូវបានរិះគន់ផ្ទាល់ដោយប្រពន្ធរបស់លោក។ នៅពេលលោកចេញទៅក្រៅដើម្បីជួយអ្នកដទៃប្រពន្ធដែលមិនមានការអត់ឱនរបស់លោកបានស្តីបន្ទោសលោក។ នៅពេលដែលនាងឈឺនាងមិនបាន បង្ហាញនូវភាពគ្មានសណ្តាប់ធ្នាប់របស់នាងទេពេលនោះសូក្រាតបានដើរចេញពីផ្ទះដោយទឹកមុខក្រៀមក្រំពេលនោះមិត្តរបស់សូក្រាតសួថា ហេតុអ្វីបានជាលោកក្រៀមក្រំ ? សូក្រាតថាប្រពន្ធរបស់លោកមិនបានបន្ទោសលោកទេព្រោះនាងឈឺ។ ព្ញដូចនោះមិត្តសូក្រាតអញ្ជើងលោកគួតែសប្បាយចិត្តពេលនោះសូក្រាត ឆ្លើយថា ទេនៅពេលដែលនាងបន្ទោសខ្ញុំមានឱកាសអនុវត្តនូវភាពអត់ធ្មត់។ ថ្ងៃនេះខ្ញុំបាត់ឱកាសនោះនេះហើយដែលធ្វើឱ្យខ្ញុំមានទុក្ខព្រួយ (ទស្សនវិទូសូក្រាតឆ្លើយ)។

ទាំងនេះគឺជាមេរៀនចងចាំសម្រាប់អ្នកទាំងអស់គ្នា។ នៅពេលគេប្រមាថ យើងគួតែគិតថា គេផ្តល់ឱកាសឱ្យយើងមួយដើម្បីអនុវត្តភាពអត់ធ្មត់។ ជំនួសឱ្យការខឹងយើងគួតែដឹងគុណចំពោះបច្ចាមិត្តរបស់យើង។

**សុខ និងទុក្ខ** (Happiness and Sorrow) : សុខនិងទុក្ខជាពាក្យពីរផ្ទុយគ្នា។ វាជាកត្តាដ៏មានឥទ្ធិពលបំផុតប៉ះពាល់ដល់មនុស្សជាតិ។ អ្វីដែលយើងទ្រាំបានយ៉ាងស្រួលគឺសុខហើយអ្វីដែលយើងពិបាកទ្រាំ គឺទុក្ខ។ សុខធម្មតាជាការសប្បាយចិត្ត នៃការប៉ងប្រាថ្នានៅពេល ដែលយើងទទួលបាននូវបញ្ហា ដែលយើងចង់បានបន្ទាប់ មកយើងចង់បានសុខប្រភេទផ្សេងទៀត។ ហេតុនេះចំណង់អាត្មានិយមរបស់យើង មិនចេះស្កប់ស្កល់ឡើយ។

ភាពរីករាយ និងការសប្បាយផ្នែកអារម្មណ៍ជាសុខខ្ពស់បំផុត និងសំដៅតែបុគ្គលវ័យកណ្តាល។ គ្មានការសង្ស័យថា មានសុខរយៈពេលខ្លីក្នុងការសង្ឃឹមទុកការពេញចិត្ត និងការចងចាំផ្នែកសំភាៈបែបនេះទេ។ តើទ្រព្យសម្បត្តិខាងសំភារៈអាចផ្តល់ឱ្យមនុស្សនូវសុខពិតទេ? បើពិតនោះមហាសេដ្ឋីតែងពេញចិត្តនឹងជីវិត។ ក្នុងបណ្តាប្រទេសមួយចំនួន ដែលឈានដល់កំពូលផ្នែកការរីកចម្រើនខាងសំភារៈនៅតែមានបញ្ហាមួយចំនួនដែលរងគ្រោះពីបញ្ហាផ្លូវចិត្ត។ បើទ្រព្យសម្បត្តិតែមួយអាចផ្តល់នូវសុខ ហេតុអ្វីក៏ដូចនេះទៅវិញ។ តើអំណាចនៅលើពិភពលោកទាំងមូលអាចបង្កើតសុខពិតទេ ? អាឡិចហ្សង់ឌឺដែល ទទួលបានជោគជ័យលើប្រទេសឥណ្ឌាក្នុងច្បាំងដណ្តើមយកទឹកដីតាមវិធីនេះ ឥតឃើញទទូលបានច្រើននូវ បំណែកទឹកដីច្រើនចំពោះការ

ច្បាំងនោះទេ។ ជីវិតរដ្ឋបុរស ដែលកាន់អំណាចអាចមានផលអាក្រក់ជារឿយៗ។ ករណីដែល គួអាណិតនៃ Mahatma Gandhi និង John F.Kennedy ជាឧទាហរណ៍ពន្យល់ស្រាប់។

គេរកសុខឃើញនៅទីនេះ ហើយគេមិនសំដៅទៅលើទ្រព្យសម្បត្តិ អំណាច កេរ្តិ៍ឈ្មោះ កត្តិយសឬជ័យជំនះនៃការច្បាំងទេ។ ប្រសិនបើគេទទួលយកបង្ខំនូវកម្មសិទ្ធបែបនេះ នោះវាជាប្រភពឈឺចាប់និងទុក្ខលោកសម្រាប់អ្នកកាន់កាប់ហើយ ។អ្វីដែលជាសុខសម្រាប់គេប្រហែលជាទុក្ខសម្រាប់អ្នកដទៃអ្វីជាសាច់ឬភេសជៈសម្រាប់គេវាអាចជាថ្នាំពុលសម្រាប់អ្នកដទៃ ។ព្រះពុទ្ធមានបន្ទូលថា សុខសម្រាប់ឧបាសកមាន៤ ប្រភេទ ។ សុខទាំងនោះជាសុខនៃការមានកម្មសិទ្ធដែលមាន : សុខភាព ទ្រព្យ អាយុយឺនយូរ មានសម្រស់ ស្អាត មានភាពរីករាយ កំលាំងពលំ បុត្រធីតា ...។ល។ ប្រភពទី២ នៃសុខគឺបានមកពីភាពរីករាយនឹងការ មានកម្មសិទ្ធបែបនេះ។ ធម្មតាបុគ្គលប្រុសស្រីចង់សប្បាយដោយខ្លួនគេផ្ទាល់។ ព្រះពុទ្ធមិនបានប្រៀនប្រដៅឱ្យបុគ្គលទាំងអស់លះបង់នូវការសប្បាយពេញលេញរបស់គេហើយចូលនិវត្តន៍ដោយភាពឯកោស្ងប់ស្ងាត់ទេ។

ភាពរីករាយនឹងទ្រព្យសម្បត្តិមិនមែន ស្ថិតក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិសម្រាប់ខ្លួនយើងផ្ទាល់នោះទេ គឺស្ថិតក្នុងការផ្តល់ទ្រព្យសម្បត្តិដើម្បីសុខមាលភាពអ្នកដទៃ ។យើងចាំរហូតនូវអំពើល្អរបស់យើង ដែលបានធ្វើជាមួយកម្មសិទ្ធទាំងអស់នោះ។

ការមិនធ្លាក់ចូលទៅក្នុងបំណុលជា ប្រភពនៃការសប្បាយមួយផ្សេងទៀត។ ប្រសិនបើយើងទ្រាំ នឹងអ្វីដែលយើងមាន ហើយសន្សំថែនោះយើងមិនធ្លាក់ចូលទៅក្នុងបំណុលរបស់នណាមួយឡើយ។ អ្នកជំពាក់បំណុលរស់នៅក្នុងក្តីឈឺចាប់ផ្នែកផ្លូវចិត្ត ហើយស្ថិតក្រោមកូនបំណុលរបស់គេ ។ទោះជាក្រយ៉ាងណាក៏ដោយនៅពេលដែលយើងមិនជំពាក់បំណុលគេនោះយើងនឹងមានអារម្មណ៍ធូរស្រាលហើយផ្លូវចិត្តរបស់យើងនឹងរីករាយ ។

ការនាំទៅរកជីវិតផុតការបន្ទោសជាប្រភព ពិសេសមួយនៃសុភមង្គលសម្រាប់មនុស្សយើង។ មនុស្សដែលផុតការស្តីបន្ទោស ជាការប្រសិទ្ធពរមួយចំពោះខ្លួនគេនិងអ្នកដទៃ។ បុគ្គលនោះត្រូវបានមនុស្សទាំងអស់សរសើរ ហើយគេនឹងមានអារម្មណ៍កាន់តែសប្បាយឡើង។ ទោះយ៉ាងណាវាលំបាកណាស់ ក្នុងការទទួលបានកេរ្តិ៍ឈ្មោះល្អពីមនុស្សទាំងអស់។ មនុស្សមានភាពវិសេសខ្ពស់ផុតការតិះដៀលនៃមនុស្សទាំងពួងហើយមិនអើពើនឹងការយល់ព្រមពីពិភពខាងក្រៅ។

ភាគច្រើននៃមនុស្សក្នុងលោកនេះ សប្បាយចិត្តនឹងទទួលសេចក្តីសប្បាយ នៅពេលដែលអ្នកខ្លះ ទៀតស្វែងរកការសប្បាយកក្នុងការលះបង់ខ្លួនពួកគេ។ ការមិនជំពាក់ចិត្តនៃក្តី

សប្បាយផ្នែកផ្លូវចិត្តជា សេចក្ដីសុខខាងផ្លូវចិត្ត។ បរមសុខនៃនិព្វាន្ត ដែលជាបរមសុខនៃដំណើរផុតស្បើយពីប្រភពនៃការឈឺចាប់ គឺជាទម្រង់ខ្ពស់បំផុត។ សុខធម្មតាយើងស្វាគមន៍ តែទុក្ខវិញយើងពិបាកទ្រាំណាស់។ ទុក្ខ ឬ ប្រភពនៃ សេចក្ដីសុខមាន អាការៈក្រៅផ្សេងៗគ្នា។ យើងមានការឈឺចាប់ពេលយើងចាស់ជរា ដែលជា ធម្មជាតិ។ ជាមួយភាពចិត្ត នឹងយើងត្រូវតែទ្រាំ នឹងការឈឺចាប់ពីចាស់ជរា។ ការឈឺចាប់ច្រើន ជាងការឈឺចាប់ដោយចាស់ជរាបង្កឡើងដោយសារជំងឺ។ សូម្បីយើងឈឺធ្មេញដ៏ស្រាលឬឈឺក្បាល តិចតួចពេលខ្លះយើងសឹងទ្រាំមិនបាន។ នៅពេលយើងមានជំងឺ ដោយមិនមានការព្រួយបារម្ភ យើងត្រូវតែលួងចិត្តខ្លួនយើងដោយគិតថា យើងគេចផុតពីជំងឺធ្ងន់ធ្ងរយ៉ាងច្រើន។

ជារឿយៗ យើងត្រូវគេពង្រាត់ពីមនុស្សជាទីស្រលាញ់ ឬអ្នកដែលនៅក្បែរយើង។ សេចក្ដីព្រាត់ប្រាស់នាំឱ្យមានការឈឺចាប់ខាងផ្លូវចិត្តយ៉ាងខ្លាំង។ យើងគួគិតថាកាជួបជុំទាំងឡាយគឺបង្កប់នូវភាពព្រាត់ព្រាស់។ ទីនេះជាឱកាសល្អដើម្បីហ្វឹកហាត់ភាពចិត្តនឹង។ លើសពីនេះទៅទៀតគេមិនបង្ខំយើងឱ្យរស់នៅក្នុងភាពឯកោជាមួយភាពមិនសប្បាយដែលយើងស្អប់នោះទេ។ ប្រហែលជាយើងកំពុងច្រូតកាត់ នូវផលកម្មរបស់យើងពីអតីតកាល ឬបច្ចុប្បន្នហើយ។ យើងគួព្យាយាមធ្វើឱ្យខ្លួនយើងស្របទៅតាមស្ថានការណ៍ថ្មីឬក៏ព្យាយាមជំនះឧបសគ្គតាមមធ្យោបាយផ្សេងទៀត។

សូម្បីព្រះពុទ្ធដែលជាភាវៈឥតខ្ចោះ ដែលបានបំផ្លាញនូវអំពើអាក្រក់គ្រប់បែបយ៉ាងក៏នៅទ្រាំអត់ធ្មត់ការឈឺចាប់ខាងរាងកាយដែលបង្កដោយជីវិតនិងគ្រោះថ្នាក់នានាដែរ។ ព្រះអង្គទទួលរងការឈឺ ចាប់ផ្នែកជំងឺឈឺក្បាលជាបន្តបន្ទាប់។ ជំងឺចុងក្រោយរបស់ព្រះអង្គធ្វើឱ្យព្រះអង្គរងការឈឺចាប់យ៉ាងខ្លាំង។ ដោយសារតែ *Devadatta* ប្រមៀលថ្មដើម្បីសម្លាប់ព្រះអង្គធ្វើឱ្យព្រះអង្គរងរបួសជើងពីកំទេចថ្ម។ ពេលខ្លះព្រះអង្គត្រូវបង្ខំបង្អត់អាហារ។ ដោយសារតែការមិនស្ដាប់សាវៈរបស់ព្រះអង្គ ព្រះអង្គត្រូវបង្ខំចិត្តចូលព្រៃរយៈបីខែ។ ទោះបីនៅក្នុងព្រៃនេះជួបការលំបាកយ៉ាងណាក្ដីក៏ ព្រះអង្គនៅរក្សាចិត្តនឹងបានយ៉ាងប្រសើរ។ មរណភាពជាទុក្ខសោកខ្លាំងបំផុត ដែលយើងត្រូវបង្ខំទទួលយកនៅពេលដែលយើងវង្វេងវង្វាន់ក្នុងសំសារា។

នៅពេលគេសួរម្ដាយម្នាក់ដែលមិនយំនៅពេលកូនខ្លួនស្លាប់នោះ គាត់ឆ្លើយថា កូនគាត់កើតមកដោយគ្មានការអញ្ជើញមកទេ ហេតុគេចាកចេញទៅវិញក៏មិនគួរប្រាប់ឱ្យដឹងដែរ។ នៅពេលដែលគេមកគេក៏ត្រូវចេញទៅវិញ តើចាំបាច់យំធ្វើអ្វី ? តើការយំមានប្រយោជន៍អ្វី ?

ដូចផ្លែឈើធ្លាក់ពីលើដើម ដោយសារ ទុំ ផុយ ឬចាស់ ក៏ដូចយើងស្លាប់ក្នុងកុមារភាពពេញវ័យ ឬក្នុងពេលចាស់។ ព្រះអាទិត្យរះក្នុងទិសខាងកើត គ្រាន់តែកំណត់ទិសខាងលិចផ្តារិកពេលព្រឹក ដើម្បីរោយក្នុងពេលល្ងាច។ មនុស្សមិនអាចជៀសផុតពីកាស្លាប់បានទេ ហេតុនេះយើងត្រូវប្រឈមមុខនឹងភាពចិត្តនឹងឥតខ្ចោះ។

ប្រៀបដូចជាផែនដីអ្វីដែលគេសង្ស័យថា តើវាជូឬផ្អែមមិនល្អមិនអាក្រក់ចំពោះមនុស្សមិនបង្ហាញភាពស្អប់ និងមិត្តភាពហេតុនេះល្អឬអាក្រក់មានតុល្យភាពគ្នា។ ព្រះពុទ្ធមានព្រះបន្ទូលថា នៅពេលលក្ខខណ្ឌនៃពិភពលោកជ្រៀតជ្រែកចិត្តអារហន្តនៅនឹងដែរ។ ហេតុនេះទោះប្រឈមមុខ នឹងបញ្ហាណាក៏ដោយយើងត្រូវរក្សាចិត្តឱ្យបាន នឹងមិនត្រូវឱ្យផ្នែកណាមួយមករំខានចិត្តយើងទេ។

# ជំពូកទី៣

# ព្រះពុទ្ធសាសនា និងជីវិត

Buddhism and Life

**១-ការពិតនៃជីវិត** (Facts of Life By.Ven.Narada Mahathera )

យើងរស់នៅក្នុងពិភពមិនស្មើគ្នា ជាពិភពគ្មានក្តីសង្ឃឹមហើយក៏មិនពោរពេញដោយភាពស្មុគស្មាញដែរ។ ផ្កាកូលាបមានភាពស្រទន់ស្រស់ស្អាត និងក្រអូប តែទងរបស់វាវិញគឺ ពោរពេញដោយបន្លា។ ដោយសារតែផ្កាកូលាបគេអត់ធ្មត់ នឹងបន្លា។ ទោះយ៉ាងណាគេមិនបន្ទោសបង្អាប់កូលាបដោយសារតែបន្លានោះទេ។

តាមអ្នកសុទិដ្ឋិនិយមថា ពិភពលោកនេះពោរពេញដោយក្តីសង្ឃឹម រីឯអ្នកទុទិដ្ឋិនិយមវិញថា ពិភពលោកនេះគ្មានក្តី សង្ឃឹមពេញលេញ ហើយក៏មិនមានបញ្ហាស្មុគស្មាញទាំងស្រុងនោះដែរ។ ពិភពលោកនេះប្រៀបដូចជា កូលាបដ៏ស្រស់ស្អាតនិងមានបន្លា។

បុគ្គលដែលមានការយល់ដឹង មិនស្រើបស្រាលនឹងសម្រស់ផ្កាទេ គ្រាន់តែមើលវាក្នុងលក្ខណៈធម្មតាប៉ុណ្ណោះ។ បុគ្គល ដែលយល់ដឹងជ្រៅជ្រះពីធម្មជាតិនៃបន្លាប្រយត្ន័ណាស់មិនឱ្យទទួលការឈឺចាប់ពីបន្លាទេ។

ដូចប៉ោលដែលធ្វើចលនាអចិន្ត្រៃយ៍ពីស្តាំទៅឆ្វេង។ ក្នុងពិភពលោកនេះមានលក្ខខណ្ឌដែលមនុស្សចង់បានបួនយ៉ាង និងមិនចង់បានបួនយ៉ាង ហើយមនុស្សទាំងនោះត្រូវតែប្រឈមមុខនឹងលក្ខខណ្ឌទាំងនេះ ក្នុងជីវិតរស់នៅ។ លក្ខខណ្ឌទាំង នោះមាន :

១- លាភៈ និង ឥតលាភ (*labha and alabha*)

២- យសៈ និងអាប់យស (*yasa and ayasa)*

៣- សរសើរ និងនិន្ទា *(pasamsa and ninda)*

៤- សុខៈ និងទុក្ខ *(Sukha and dukkha)*

**លាភ និងឥតលាភ** (Gain and Loss) : តាមច្បាប់អ្នករកស៊ី អាចមានទាំងចំណេញនិងខាតប្រយោជន៍។ តាមធម្មជាតិគេមិនខ្វល់ទេ នៅពេលគេទទួលប្រយោជន៍ឬចំណេញនោះ។ វាគ្មានអ្វីដែលមិនត្រឹមត្រូវនោះទេ ប្រាក់ចំណេញបែបនេះបង្កើតឱ្យមានសេចក្តីសប្បាយ ដែលមនុស្សមានវ័យកណ្តាលស្វែងរក។ បើគ្មានពេលរីករាយបែបនោះទេ ជីវិតមិនមែនជាការរស់នៅដោយសុភមង្គលនោះទេ។ ក្នុងពិភពដ៏ច្របូកច្របល់និងប្រកួតប្រជែងនេះវាជាការត្រឹមត្រូវ

ហើយដែលមនុស្សគួរស្វែងរកប្រភេទសុខ មួយចំនួន ហើយធ្វើឱ្យចិត្តគេរីករាយ។ ទោះបីផ្នែកសម្ភារៈក្តីក៏សុខបែប នេះអាចទទួលយក បានដើម្បីសុខភាពនិងភាពយឺនយូរដែរ។

បញ្ហាកើតឡើងក្នុងករណីខាតបង់។ធម្មតាមនុស្សទទួលយកនូវភាពចំណេញដោយ ភាពរីករាយ ដែលផ្ទុយពីការខាតបង់ដែលធ្វើឱ្យគេមិនសប្បាយចិត្ត។ ការខាតបង់ជារឿយៗ នាំឱ្យមានការឈឺចាប់ផ្នែកផ្លូវចិត្ត ហើយពេលខ្លះអាចឈាន ទៅដល់ការធ្វើអត្តឃាដផងដែរ ប្រសិនបើការខាតបង់នោះមានសភាពធ្ងន់ធ្ងពេកស្ថិតក្នុងកាលៈទេសៈបែបនេះគេគួរតែបង្ហាញនូវភាពក្លាហានផ្នែកសីលធមិខ្ពស់ ហើយរក្សានូវលំនឹងចិត្តឱ្យបានសមរម្យ។ យើងទាំងអស់គ្នាតែងតែមានការឡើងនិងការចុះជាការធម្មតាទេចំពោះការប្រយុទ្ធជាមួយនឹងជីវិតនេះ។មនុស្សគួររៀបចំនូវអ្វីល្អ និងអ្វីអាក្រក់បន្ទាប់មកគេនឹងមានការខកចិត្តតិច។

ក្នុងសម័យព្រះពុទ្ធស្ត្រីដ៏ប្រសើរម្នាក់បានផ្តល់អាហារទៅដល់ព្រះសារីបុត្ត (Sariputta) ដ៏គួរឱ្យគោរពនិងព្រះសង្ឃមួយចំនួន។ ខណៈពេលដែលនាងកំពុងបម្រើព្រះសង្ឃនាងបានទទួលនូវកំណត់សំគាល់មួយដែលបង្ហាញថា សំណាង អាក្រក់ ពិតជាបានប៉ះពាល់ដល់គ្រួសាររបស់នាង។ ដោយមិនមានការអាក់អន់ស្រពន់ចិត្តនាងបានធ្វើការកត់សំគាល់ដោយស្ងៀមស្ងាត់ មួយនៅក្នុង waist-pouch របស់នាង ហើយធ្វើការបម្រើព្រះសង្ឃដូចធម្មតាហាក់ដូចជា មិនមានអ្វីកើតឡើង។ ស្ត្រីបម្រើដែលកំពុងតែយួរភាជន៍អាហារមួយ ដើម្បីយកទៅប្រគេនព្រះសង្ឃបានរអិលដួលដោយមិនបានប្រុងប្រយ័ត្នធ្វើឱ្យភាជន៍អាហារនោះបែកអស់។ ការគិតថាស្ត្រីនោះមានអារម្មណ៍សោកស្តាយជាធម្មតាចំពោះរបស់ដែលខូចខាតនោះ ព្រះសារីបុត្តបាន លួងលោមនាង ដោយនិយាយថា គ្រប់វត្ថុងាយៗទាំងអស់សុទ្ធតែត្រូវបែកទាំងអស់។ ស្ត្រីឆ្លាត បានកត់សំគាល់ឃើញថា "*Bhante* តើការបាត់បង់តូចតាចនេះគឺជាអ្វី? ខ្ញុំទើបតែបានទទួលការកត់ចំណាំមួយដែលអះអាងពីអកុសលជាក់ស្តែងបាន កើតឡើងនៅក្នុងគ្រួសារខ្ញុំ។ ខ្ញុំមិន បានទទួលយកពីការបាត់បង់តុល្យការរបស់ខ្ញុំទេ។ ខ្ញុំកំពុងតែបម្រើអ្នកទាំងអស់គ្នា បើទោះជាដំណឹងអាក្រក់ក៏ដោយ។"

សេចក្តីក្លាហានបែបនេះទៅលើផ្នែកនៃស្ត្រីក្លាហានបែបនេះគួរត្រូវបានគេពន្យល់យ៉ាងខ្ពស់។

ថ្ងៃមួយព្រះពុទ្ធបានទៅបិណ្ឌបាតក្នុងភូមិមួយហើយព្រះអង្គអត់បានទទួលនូវចង្ហាន់សោះដោយសារបទអន្តរាគមន៍របស់នាង Mara ដែលជាមនុស្សអាក្រក់។ ពេលនោះនាងក៏បានសួរព្រះអង្គថា តើព្រះអង្គខឹងនឹងនាង ឬអត់ទេ ? នោះ ព្រះអង្គក៏បានពន្យល់ដោយ ឥរិយាបថផ្លូវ

ចិត្តយ៉ាងស្ងប់ហើយឆ្លើយថា យើងរស់នៅដោយភាពរីករាយគ្មានឧបសគ្គអ្វីទេ។ ព្រះអង្គថាអ្នកទាំងឡាយណាដែលផ្តល់អាហារដោយភាពរីករាយយើងចាត់ទុកថាជាព្រះ The Radian Realm ។

នាឱកាសមួយទៀត ព្រះពុទ្ធ និងសាវ័ករបស់ព្រះអង្គបានអង្កេតនូវអំឡុងភ្លៀងធ្លាក់ (វស្សា) ក្នុង ភូមិមួយតាមការ អញ្ជើញរបស់ព្រាហ្មណ៍ម្នាក់ ដែលទោះជាលោកបានភ្លេចនូវភារកិច្ចរបស់លោកចំពោះ ការចូលរួមនូវតម្រូវការរបស់ព្រះអង្គ និង (Sangha)។ ពេញអំឡុងពេលបីខែទោះបី Moggallana ដ៏ប្រសើរស្ម័គ្រចិត្តផ្តល់ចង្ហាន់ដោយអំណាចផ្លូវចិត្ត (អ្នកដែលមានភ្នែកឬត្រចៀកទិព្វ) ក៏ព្រះអង្គមិនមានការតវ៉ាដែរ ផ្ទុយទៅវិញព្រះអង្គពេញចិត្តនឹង ចំណីក្រៀមរបស់សត្វសេះ ដែលផ្តល់ដោយឈ្មួញសេះ។

មនុស្សត្រូវទ្រាំ នឹងភាពបាត់បង់ទាំងឡាយ ព្រោះមនុស្សតែងតែទទួលនូវការបាត់បង់ច្រើន។ មនុស្សត្រូវប្រឈម នឹងការខាតបង់ដោយចិត្តនឹងធ៌ ហើយចាត់ទុកថា វាជាឱកាសមួយក្នុងការបណ្តុះ សីលធមិដ៏ប្រសើរ។

**យសនិងអាប់យស** (Honour and Dishonour) : កត្តិយស និងភាពអាប់ឱនជាលក្ខខណ្ឌពិភពលោកដែលមនុស្សមិនអាចជៀសផុតក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ មនុស្សចង់បានកត្តិយសតែគេមិនចង់បានសេចក្តីអាប់ឱនទេ។ គេតែងតែចង់ធ្វើជាអ្នកល្បីល្បាញ។ យើងតែងទទឹងរង់ចាំនូវរូបភាពរបស់យើងនៅក្នុងកាសែត ។យើងសប្បាយយ៉ាងខ្លាំងនៅពេលសកម្មភាពរបស់យើងត្រូវបានគេផ្តល់កត្តិយសចំពោះសាធារណជនតែពេលខ្លះ យើងក៏ស្វែងរកវាលើសកម្រិតដែរ។

មនុស្សជាច្រើនអន្ទះសារចង់ឃើញ រូបភាពរបស់គេនៅក្នុងទស្សនាវដ្តីនូវតម្លៃណាមួយ។ ដើម្បីបានកត្តិយសខ្លះផ្តល់អំណោយដ៏ច្រើនទៅដល់អ្នកដែលមានអំណាច។ ដើម្បីជាប្រយោជន៍សាធារណៈ ខ្លះបង្ហាញភាពសប្បុរសរបស់គេដោយ ផ្តល់ទានទៅព្រះសង្ឃ តែគេមិនគិតចំពោះការឈឺចាប់របស់អ្នកក្រ និងអ្នកជិតខាងដែលត្រូវការជាចាំបាច់នោះទេ។

ទាំងអស់នេះជាភាពទន់ខ្សោយរបស់មនុស្ស។ មនុស្សភាគច្រើនមានចំណង់អាថិកំបាំង។ មនុស្សដែលគិតប្រយោជន៍ រួមធ្វើសកម្មភាពមិនលំអៀងកម្រណាស់ នៅក្នុងពិភពលោកនេះ។ ដូចនេះ តើនរណាទៅគឺជាមនុស្សឥតខ្ចោះនោះ ? តើមានភាព ឥតខ្ចោះប៉ុន្មាននៅក្នុងចំណង់របស់គេ ? តើមានប៉ុន្មាននាក់ដែលគិតពីប្រយោជន៍គេទាំងស្រុងនោះ ?

ប្រសិនបើយើងមានតម្លៃកិត្តិយស វានឹងនាំឱ្យយើងស្វែងរក។ ផ្កាទាក់ទាញឃ្មុំដោយសារវាផ្ទុកនូវទឹកឃ្មុំ ហើយផ្កា មិនបានអញ្ជើញឃ្មុំឱ្យក្រេបវានោះទេ។

ជាការពិតយើងធម្មតាចង់សប្បាយ ហើយសប្បាយខ្លាំងនៅពេលដែលកេរ្តិ៍ឈ្មោះយើងរីករាល ដាលកាន់តែខ្លាំងនិងទូលំទូលាយតែយើងគួរដឹងថា កេរ្តិ៍ឈ្មោះនិងភាពល្បីល្បាញគ្រាន់តែជាការឆ្លងកាត់នូវដំណាក់កាលបន្តបន្ទាប់ប៉ុណ្ណោះវា នឹងរសាត់បាត់ទៅក្នុងខ្យល់នៅពេលឆាប់ៗនេះ។

ចុះភាពអាប់ឱនដូចម្ដេចដែរ? វាមិនគួរឱ្យចូលចិត្តទាំងចិត្ត ទាំងត្រចៀក។ យើងមានការឈឺចាប់យ៉ាងខ្លាំងនៅ ពេលដែលរបាយការណ៍ដែលគេហៅនោះ មានការក្លែងបន្លំមិនត្រឹមត្រូវ។

ជាធម្មតាគេចំណាយពេលច្រើនក្នុងការសាងអាគារធំៗ។ក្នុងមួយនាទីឬពីរនាទីអាវុធប្រល័យ ទំនើបអាចកម្ទេចយ៉ាងស្រួល។ ពេលខ្លះត្រូវចំណាយពេលច្រើន ឬពេញមួយជីវិតទើបអាចកសាងកេរ្តិ៍ឈ្មោះល្អបាន។ គេមិនអាចបំផ្លាញនូវកេរ្តិ៍ឈ្មោះដែលយើងរកបានដោយកម្រនោះបានទេ។ អ្នកអាចរស់នៅក្នុងជីវិតនៃព្រះពុទ្ធតែអ្នកមិនអាចជៀសផុតពីការរិះគន់ការវាយប្រហារ និងការធ្វើឱ្យអាម៉ាស់។

ព្រះពុទ្ធល្បីល្បាញបំផុត ហើយជាគ្រូដ៏ប្រសប់បំផុត។ អ្នកប្រឆាំងព្រះពុទ្ធជាច្រើនបាននិយាយពាក្យចចាមអារាម ពាសវាលពាសកាលថា ស្ត្រីម្នាក់ធ្លាប់ចំណាយពេល នៅពេលយប់ក្នុងវត្ត។ ដោយការបរាជ័យនៅក្នុងការប៉ុនប៉ងចម្បងនេះ គេក៏ប្រឌិតដំណឹងមិនប្រាកដដោយចោទប្រកាន់សាវ៉ករបស់ ព្រះអង្គថាបានសម្លាប់ស្ត្រីម្នាក់ ហើយលាក់សាកសពរបស់នាងទុកនៅក្នុងគំនរផ្កានៅក្នុងវត្ត។ ក្រោយមកអ្នករួមគំនិតប្រព្រឹត្តទុច្ចរិតក៏ បានសារភាពថា ពួកគេគឺប្រព្រឹត្តខុស។

នៅពេលបេសកកម្មជាប្រវត្តិសាស្ត្ររបស់ព្រះអង្គទទួលជោគជ័យហើយ នៅពេលដែលមនុស្សភាគច្រើនស្វែងរកការបួសតាមព្រះពុទ្ធ ប៉ុន្តែបច្ចាមិត្រព្រះអង្គក៏បានមួលបង្កាច់ថា ព្រះអង្គកំពុងតែប្លន់ ម្ដាយពីកូនគេ ដោយដកហូតប្រពន្ធពីប្ដីរបស់គេហើយថា ព្រះអង្គធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍន៍ប្រទេសជាតិ។

ដោយបរាជ័យក្នុងការប៉ុនប៉ង ដើម្បីបំផ្លាញលក្ខណៈដ៏ប្រសើររបស់ព្រះអង្គ បង ប្អូនជីដូនមួយផ្ទាល់របស់ព្រះ អង្គឈ្មោះទេវទត្ត Devadatta ដែលជាសាវ៉ះព្រះអង្គបានប៉ុនប៉ងសម្លាប់ព្រះអង្គដោយប្រមៀល ថ្មពីខាងលើតែត្រូវបរាជ័យទៀត។

បើជាវាសនាស្រពាប់ស្រពោននៃភាពគ្មានកំហុសបែបនេះ ព្រះពុទ្ធបរមគ្រូតើអ្វីទៅដែលអាចជាវាសនានៃមនុស្សមិនសុក្រឹតធម្មតានោះ ?

ព្រះអង្គមានព្រះបន្ទូលថា បើអ្នកឡើងភ្នំកាន់តែខ្ពស់ អ្នកនឹងលេចត្រដែតជាងគេក្នុងចក្ខុរបស់អ្នកដទៃ។ ផ្នែកខាង ក្រោយរបស់អ្នកត្រូវវាលាតត្រដាង តែផ្នែកខាងមុខវិញត្រូវលាក់ជិត។ ពិភពដែលស្វែងរកតែកំហុសបានបង្ហាញឱ្យឃើញពីកំហុស ប៉ុន្តែមិនដឹងពីគុណធម៌ របស់អ្នកទេ។ កង្ហារបក់ខ្យល់បក់សំបកស្រូវ ប៉ុន្តែបន្សល់ទុក នូវគ្រាប់ អង្ករ ផ្ទុយទៅវិញ តម្រងវាបន្សល់ទុកនូវកាកសំណល់គ្រោះគ្រើម ប៉ុន្តែវាច្រោះយកទឹក ផ្អែមទៅបាត់អស់។ ភាពដែល មានការអប់រំ (the cultured) ទទួលយកនូវភាពល្អិតល្អន់ (the subtle) ហើយកម្ចាត់ចោលនូវភាពគ្រោះគ្រើម (the gross) ភាពដែលមិនមានការអប់រំ (the uncultured) ទទួលយកភាព គ្រោះគ្រើម (the gross) ប៉ុន្តែច្រានចោលនូវភាពល្អិតល្អន់ទៅវិញ។

ពេលអ្នកត្រូវគេធ្វើឱ្យយល់ខុសដោយចេតនាឬផ្សេងពីនោះសូមចាំដំបូន្មានរបស់ Epictectus ដើម្បីគិត ឬនិយាយថា "អូ ដោយការស្គាល់គ្នាតិចតួច និងចំណេះដឹងមិនសូវភ្លឺថ្លា អំពីខ្លួនខ្ញុំ ខ្ញុំត្រូវបានគេរិះគន់តិចៗ។ ប៉ុន្តែប្រសិនបើខ្ញុំ ត្រូវបានគេស្គាល់កាន់តែខ្លាំងការប្រកាន់ ចំពោះក៏កាន់តែខ្លាំង និងធ្ងន់ធ្ងរដែរ។"

គេមិនចាំបាច់ចំណាយពេលឥតប្រយោជន៍ ក្នុងការកែតម្រូវរបាយការណ៍មិនពិតទេប្រសិនបើកាលៈទេសៈមិនបង្ខំអ្នក ឱ្យបង្ហាញពីភាពចាំបាច់នោះទេ។ សត្រូវសប្បាយណាស់នៅពេលឃើញអ្នកត្រូវរបួស ដែលនោះហើយជាអ្វីដែលគេរំពឹងគិត។ ប្រសិនបើអ្នកមិនបារម្ភទេការផ្តល់ព័ត៌មានមិនពិត នឹងធ្លាក់ទៅលើត្រចៀកដែលថ្លង់។

- នៅក្នុងការមើលឃើញកំហុសអ្នកដទៃ (យើងគួរប្រព្រឹត្តដូចមនុស្សខ្វាក់)
- បើឮការរិះគន់មិនត្រឹមត្រូវពីអ្នកដទៃ (ត្រូវប្រព្រឹត្តដូចជាមនុស្សថ្លង់)
- ក្នុងការនិយាយដើមអ្នកដទៃ (យើងគួរប្រព្រឹត្តដូចមនុស្សគ)
- គេមិនអាចបញ្ឈប់ការចោទប្រកាន់មិនពិត ព័ត៌មានមិនពិត ឬពាក្យចចាមអារ៉ាមបានមិនពិតបានទេ។

ពិភពលោកពោរពេញដោយបន្លា និងគ្រួស ហើយគេមិនអាចយកបន្លា និងគ្រួសនេះចេញបានទេ។ តែប្រសិនបើយើងចាំបាច់ត្រូវដើរ ទោះបីមានឧបសគ្គ ជំនួសឱ្យការជំនះ ឧបសគ្គ យើងអាចពាក់ ស្បែកជើងដើរដែលមិនសូវធ្វើឱ្យយើង ឈឺចាប់។ ព្រះធម៌បានបង្រៀនថា :

- ចូរធ្វើដូចតោដែលញញ័រមិនមែននៅត្រង់សូរសម្លេង

- ចូរធ្វើដូចខ្យល់ដែលមិនស្អិតជាប់នឹងសំណាញ់

- ចូរធ្វើដូចដើមឈូក ដែលមិនត្រូវប្រឡាក់ដោយសារភក់ពីផ្នែកណាមួយ ដែលវាលូតឡើងទេ

- អ្នកត្រាច់ចរឯកោប្រៀបដូចសត្វរមាសជាស្តេចព្រៃតោគឺមិនចេះភ័យខ្លាច។ តាមធម្មជាតិពួកវាមិនភ័យខ្លាច នឹងសម្លេងរបស់សត្វដទៃទេ។ នៅក្នុងលោកនេះមានការក្លែងបន្លំការចោទប្រកាន់មិនពិតហេតុ នេះយើងមិនគួរស្តាប់ទេ ប្រៀបដូចសត្វតោ យើងមិនគួរស្តាប់វាទេ។

- ឆ្កែព្រុះ តែអ្នកដំណើរធ្វើដំណើរយ៉ាងស្រួល។ យើងរស់នៅក្នុងពិភពមិនស្អាតស្អំ។

- ផ្កាឈូកជាច្រើនលូតឡើងដូចនេះបើគ្មានការប្រឡាក់ពីភក់ទេ វានឹងធ្វើឱ្យពិភពលោកស្រស់ស្អាត។ ដូចផ្កាឈូកដែរ យើងគួរដឹកនាំជីវិតរបស់យើងឱ្យខ្ពង់ខ្ពស់ និងគ្មានការស្តីបន្ទោស

- យើងគួរតែសង្ឃឹមថា ភក់ត្រូវគេគប់មកដាក់យើងជំនួសឱ្យផ្កាកូលាប។ ដូច្នេះនឹង គ្មានការខកចិត្តអ្វីឡើយ

- ទោះបីការលំបាកយ៉ាងណាក៏ដោយយើងគួរតែបណ្តុះនូវការមិនជាប់ជំពាក់ចិត្ត។ យើងមកតែឯងទៅក៏តែឯងដែរ។ ការមិនជាប់ជំពាក់ចិត្ត ជាសុភមង្គលក្នុងពិភពលោក។

- ការធ្វេសប្រហែសចំពោះព្រួញពិសវាចម្លែងដែរមនុស្សអស្ចារ្យត្រូវគេមួលបង្កាច់ ឆ្កាងបំពុល ឬបាញ់សម្លាប់។ សូក្រាត ដ៏អស្ចារ្យត្រូវគេឱ្យផឹកថ្នាំ បំពុល *Mahatma Gandhi* ត្រូវគេបាញ់សម្លាប់។

តើភាពល្អខ្លាំងពេកពិតជានាំឱ្យមានគ្រោះថ្នាក់ឬ ?

មនុស្សអស្ចារ្យៗមិនខ្វល់ខ្វាយនឹងការផ្តល់កិត្តិយស ឬរិះគន់នោះទេ។ ពួកគេមិនតូចចិត្តពេលពួកគេរិះគន់មួលបង្កាច់បង្ខូចនោះទេព្រោះពួកគេមិនមែនធ្វើការដើម្បីកេរ្តិ៍ឈ្មោះឬកិត្តិយសនោះទេ។ ពួកគេមិនខ្វល់ថាតើអ្នកដទៃយល់ដឹងពី សេវាកម្មរបស់ពួកគេ ឬអត់ប៉ុណ្ណោះ។ ដើម្បីធ្វើការងារ ពួកគេមានសិទ្ធិ ប៉ុន្តែមិនសំដៅលើលទ្ធផលនោះទេ។

**ការសរសើរ និងការនិន្ទា** (Praise and Blame) :ការសរសើរ និងការស្តីមបន្ទោសជាលក្ខខណ្ឌនៃពិភពលោក ដែលប៉ះពាល់ដល់មនុស្សជាតិ។ ជាធម្មតាមនុស្សសប្បាយ នៅពេលគេសរសើរ ហើយគេកង្វល់នៅពេលត្រូវបានគេបន្ទោស។ ក្នុងចំណោមការបន្ទោស និងការ

សរសើរព្រះពុទ្ធបានមានព្រះបន្ទូលថា អ្នកប្រាជ្ញមិនបង្ហាញនូវការសប្បាយឬកង្វល់ទេ។ ប្រៀប ដូចថ្មដែលរឹង ដែលមិនរង្គើដោយសារតែកម្លាំងខ្យល់ឡើយ។

ការសរសើរ ប្រសិនបើមានតម្លៃគឺវាធ្វើឱ្យសប្បាយត្រចៀក តែបើគ្មានតម្លៃ ដូចជា ក្នុងករណីបញ្ចោរទោះជាសប្បាយក៏វាជាការបោកប្រាស់ដែរ។ តែលក្ខណៈទាំងអស់នឹងគ្មានឥទ្ធិពលទេ ប្រសិនបើមិនឮដល់ត្រចៀករបស់យើង។

ចេញពីទស្សនលោកិយពាក្យលើកសរសើរបានធ្វើដំណើរលើផ្លូវដ៏វែងឆ្ងាយ។ តាមរយៈការសរសើរតិចតួចការពេញចិត្តអាចត្រូវបានទទួលយកយ៉ាងងាយ។ ការសរសើរពីគុណសម្បត្តិ គឺគ្រប់គ្រាន់ដើម្បីទាក់ទាញទស្សនិកជនមុននឹង គេនិយាយស្តី។ ប្រសិនបើនៅដើមដំបូង វាគ្មិនសរសើរទស្សនិកជន គេនឹងយកចិត្តទុកដាក់ស្តាប់គាត់តែប្រសិនបើគាត់រិះគន់នៅដើមដំបូងវិញការឆ្លើយតបនឹងមិនពេញចិត្ត។

អ្នកដែលបានអប់រំមិនទោរទន់ទៅរកការបញ្ចោរនោះទេ ហើយគេក៏មិនចង់ឱ្យនរណាបញ្ចោរគេដែរ។ ការលើកសរសើរ ពួកគេសរសើរដោយគ្មានការច្រណែន។ ការបន្ទុះបង្អាប់ពួកគេបន្ទុះបង្អាប់មិនមែនមើលងាយ ប៉ុន្តែដោយសារតែការអាណិតស្រឡាញ់ ដោយបំណងអប់រំ ឬកែលំអពួកគេ។

មានមនុស្សជាច្រើន ដែលស្គាល់ព្រះពុទ្ធ បានសរសើរគុណធម៌របស់ព្រះអង្គក្នុងវិធី ផ្ទាល់របស់ពួកគេ។ Upali ដែលជា មហាសេដ្ឋី និងជាសាវ័កថ្មីនោះបានសរសើរព្រះពុទ្ធនូវការរៀបរាប់ពីគុណធម៌រាប់រយដែលមិនបានព្រាងទុក។ គុណធម៌ដ៏ប្រសើរទាំង៩ ដែលជាចរន្តក្នុងពេលរបស់ព្រះអង្គគឺនៅតែត្រូវបានគេសូត្រដោយសាវ័ករបស់ព្រះអង្គដែលសម្លឹងមើលរូបភាពរបស់ព្រះអង្គ។ គុណធម៌ដែលមានលក្ខណៈសម្បត្តិល្អ គឺនៅតែជាការជំរុញចិត្តដ៏ធំចំពោះសាវ័ករបស់ព្រះអង្គ។ ចុះការបន្ទោសយ៉ាងណាដែរ ?

ព្រះពុទ្ធបានមានព្រះបន្ទូលថា "អ្នកនិយាយតិចក៏មានការស្តីបន្ទោស អ្នកនិយាយច្រើនក៏មានការស្តីបន្ទោស ហើយអ្នកដែលមិននិយាយក៏ដូចនេះដែរ។ នៅក្នុងពិភពលោកនេះគឺ គ្មាននរណាដែលមិនត្រូវបានគេបន្ទោសនោះទេ"។ ការបន្ទោសជាបញ្ហាទូទៅរបស់មនុស្សជាតិ។

មនុស្សជាច្រើននៅក្នុងពិភពលោកដែលគាត់សំគាល់ព្រះពុទ្ធគឺគ្មានសណ្តាប់ធ្នាប់ ។ប្រៀបដូចដំរីនៅក្នុងសមរភូមិ ដែលអត់ធ្មត់ពីព្រួញទាំងអស់ដែល គេបាញ់ដាក់វា ដូចព្រះពុទ្ធ ដែលរងនូវការប្រមាថគ្រប់បែបយ៉ាង។

ការបោកបញ្ឆោត និងភាពកាចឃោរឃៅធ្វើឱ្យឆាប់រកឃើញតែពីភាពក្រខ្វក់ របស់អ្នកដទៃ ប៉ុន្តែរកមិនឃើញពីភាពល្អ និងសោភ័ណភាពនោះឡើយ ។

វាមានភាពល្អនៅក្នុងភាពអាក្រក់នៃយើងហើយមានភាពអាក្រក់នៅក្នុងភាពល្អនៃយើង ។

ព្រះពុទ្ធដាស់តឿនថា "អ្នកដែលមានភាពស្ងប់ស្ងាត់នៅពេល គេវាយប្រហារគេប្រមាថ និងបំពារបំពាននោះហើយវត្តមាននៃនិព្វាន ទោះបីជាគាត់មិនទាន់ទទួលបាននិព្វានក្តីដោយ" ។

គេអាចធ្វើការដោយមានកម្លាំងជម្រុញដ៏ប្រសើរបំផុត ។ ប៉ុន្តែពិភពខាងក្រៅជានិច្ចកាល តែងតែនាំគេឱ្យយល់ខុស ហើយនឹងទម្លាក់ទោសដល់កម្លាំងជម្រុញ ដោយគេមិនដែលសុបិនឃើញឡើយ ។

គេអាចបម្រើ និងជួយដល់អ្នកដទៃឱ្យអស់ពីលទ្ធភាព ជួនកាលដោយការលោះបំណុលលក់សិទ្ធិ (articles)ឬទ្រព្យរបស់អ្នកណាមួយដើម្បីសង្គ្រោះមិត្តដែលមានបញ្ហា ប៉ុន្តែក្រោយមកពាក្យបោកបញ្ឆោតក៏ត្រូវបង្កបង្កើតទៅជាថា មនុស្សទាំងនោះឯងដែលគេបានជួយនោះ នឹងរកឃើញពីកំហុសរបស់គាត់ ពោលគឺគម្រាមគាត់រកប្រយោជន៍ធ្វើឱ្យសៅហ្មងដល់ចរិតល្អរបស់គាត់ ហើយសប្បាយរីករាយទៅលើភាពអន្តរាយរបស់គេ ។

នៅក្នុងរឿងជាតក (Jataka) បានបង្ហាញថា Guttila ជាអ្នកតន្ត្រីដែលបានបង្រៀនអ្វីៗគ្រប់យ៉ាងដែលលោកដឹង ទៅឱ្យសិស្សរបស់លោកដោយឥតមានលាក់ទុកឡើយ តែបុរសក្មេងនោះព្យាយាមបំពេញជាមួយគ្រូរបស់ខ្លួនដោយបរាជ័យហើយក៏បំផ្លាញគ្រូ ។

នាឱកាសមួយព្រាហ្មណ៍បានអញ្ជើញ ព្រះអង្គសម្រាប់ជាទានទៅផ្ទះរបស់លោក ។ ដោយត្រូវបានគេអញ្ជើញព្រះពុទ្ធក៏បានទៅផ្ទះនោះដែរ ។

ជាការយាងនិមន្ត ព្រះពុទ្ធបានយាងទៅលេងនៅផ្ទះរបស់គាត់ ។ ជំនួសឱ្យការកំសាន្តជាមួយគាត់ គាត់ក៏បានប្រើពាក្យសម្តីមិនសមរម្យ ។

ឃើញដូចនេះព្រះអង្គក៏បានសួរដោយគួរសមថា "ឱព្រាហ្មណ៍ដ៏ចម្រើន តើអ្នកមកលេងផ្ទះរបស់អ្នកឬ ? "ពិតណាស់" គាត់ឆ្លើយតប" "តើអ្នកធ្វើអ្វីនៅពេលពួកគេមក?" អូ! យើងរៀបចំនូវបុណ្យធំ?" "ប្រសិនបើពួកគេរកមិនឃើញ ?" "ហេតុអ្វីបានជាយើង សេពគប់ជាមួយនឹងវាដោយរីករាយ ។" "ព្រាហ្មណ៍ដ៏ចម្រើនអ្នកបានអញ្ជើញខ្ញុំសម្រាប់ទាន ហើយអ្នកបានធ្វើឱ្យខ្ញុំសប្បាយដោយប្រើពាក្យបំពារបំពាន ខ្ញុំមិនទទួលយកទេ សូមអ្នកយកទៅវិញចុះ ។"

ព្រះពុទ្ធមិនសងសឹកទេ។ តែដាស់តឿនថា ភាពស្អប់មិនធូរស្បើយតាមរយៈការស្អប់ទេ គឺមានតែការស្រឡាញ់តែមួយគត់ដែលអាចបន្ទូរបាន ។

មិនមានគ្រូសាសនាណាត្រូវបានគេសរសើរទេ។ បែបនេះជាជីវិតនៃមនុស្ស។

ព្រះពុទ្ធត្រូវគេចោទថាបានសម្លាប់ស្ត្រីម្នាក់ ដែលជួយដោយសាវ័ករបស់ព្រះអង្គ។ អ្នកមិនមែនព្រះពុទ្ធសាសនាបាន រិះគន់ព្រះពុទ្ធ ហើយសាវ័ករបស់ព្រះអង្គចំពោះ វិសាលភាពបែបនេះ ព្រះអានន្ទបានសុំយាងព្រះពុទ្ធទៅភូមិមួយទៀត។

ព្រះពុទ្ធបានសួរទៅអានន្ទថា "យ៉ាងម៉េចដែរ ម្នាលអានន្ទ បើអ្នកភូមិទាំងនោះបំពារបំពានយើងនោះ ? អានន្ទថា យើងនឹងបន្តទៅភូមិមួយទៀត។"

"បើអញ្ចឹង ម្នាលអានន្ទប្រទេសឥណ្ឌាទាំងមូលនេះគ្មានកន្លែងសម្រាប់យើងទេ ចូរអត់ធ្មត់ បញ្ហាទាំងអស់នេះនឹងរលត់ ទៅវិញដោយឯង១។"

Magandinya ជាស្ត្រីស្នំ (a lady of the harem) ម្នាក់ ទៀតខឹងព្រះពុទ្ធបានជួលអ្នកស្រវឹងម្នាក់មកប្រមាថព្រះអង្គនៅទីសាធារណៈ តែព្រះអង្គនៅតែរក្សាចិត្តនឹងបានល្អណាស់។

ការរិះគន់គឺច្រើនតែជាមនុស្សសាមញ្ញ។ អ្នកធ្វើការកាន់តែច្រើនយើងកាន់តែអស្ចារ្យ។

សូក្រាតត្រូវបានរិះគន់ផ្ទាល់ដោយប្រពន្ធរបស់លោក។ នៅពេលលោកចេញទៅក្រៅដើម្បីជួយអ្នកដទៃ ប្រពន្ធ ដែលមិនមានការអត់ឱនរបស់លោកបានស្តីបន្ទោសលោក។ នៅថ្ងៃនោះសូក្រាតបានដើរចេញពីផ្ទះដោយទឹកមុខក្រៀមក្រំ។ មិត្តរបស់សូក្រាតសួរពីហេតុដែលគាត់ក្រៀមក្រំ ។សូក្រាតថាប្រពន្ធរបស់គាត់មិនបានបន្ទោសគាត់នៅថ្ងៃនោះទេ ព្រោះនាងឈឺ។

"ដូចនោះ អ្នកគួរតែសប្បាយចិត្ត ព្រោះតែមិនបានទទួលនូវការស្តីបន្ទោសនោះ មិត្តរបស់គាត់បានសំគាល់មើល។ អូ ! ទេ ពេលនាងស្តីបន្ទោសខ្ញុំ ខ្ញុំគ្មានមានឱកាសនោះទេ។ នោះហើយគឺជាហេតុផលដែលខ្ញុំមានទុក្ខព្រួយ។ ទស្សនវិទូសូក្រាតឆ្លើយ។ ទាំងនេះគឺជាមេរៀនចងចាំសម្រាប់អ្នកទាំងអស់គ្នា។

នៅពេលគេប្រមាថយើងគួរតែគិតថា គេផ្តល់ឱកាសឱ្យយើងមួយដើម្បី អនុវត្តភាព អត់ធ្មត់ ជំនួសឱ្យការខឹង។ យើងគួរតែដឹងគុណចំពោះបច្ចាមិត្តរបស់យើង។

**សុខនិងទុក្ខ** (Happiness and Sorrow) : សុខនិងទុក្ខជាពាក្យពីរផ្ទុយគ្នា ។វាជាកត្តាដ៏មានឥទ្ធិពលបំផុតប៉ះពាល់ដល់មនុស្សជាតិអ្វីដែលយើងទ្រាំបានយ៉ាងស្រួលគឺសុខហើយអ្វីដែលយើង

ពិបាកទ្រាំគឺទុក្ខ ។ សុខធម្មតាជាការសប្បាយចិត្ត នៃការប៉ងប្រាថ្នានៅពេល ដែលយើងទទួលបាននូវបញ្ហា ដែលយើងចង់បានបន្ទាប់មកយើងចង់បានសុខប្រភេទផ្សេងទៀត។ ហេតុនេះចំណង់អាត្មា និយមរបស់យើងមិនចេះស្កប់ស្កល់ឡើយ ។

ភាពរីករាយ និងការសប្បាយផ្អែកអារម្មណ៍ជាសុខខ្ពស់បំផុត និងសម្តៅតែបុគ្គលវ័យកណ្តាលប៉ុណ្ណោះ ។ គ្មានការសង្ស័យថា មានសុខរយៈពេលខ្លីក្នុងការសង្ឃឹមទុកការពេញចិត្ត និងការចងចាំផ្អែកសម្ភារៈបែបនេះទេ ។សេចក្តីសុខប្រភេទនេះត្រូវបានលើកសសើរច្រើនពីសំណាក់ឥន្ទ្រីយារម្មណ៍និយម ប៉ុន្តែវាគ្រាន់តែជាការបំភ័ន្តភ្នែក និងបណ្តោះអាសន្នប៉ុណ្ណោះ ។

តើទ្រព្យសម្បត្តិខាងសម្ភារៈ អាចផ្តល់ឱ្យមនុស្សនូវសុខពិតទេ ? បើពិតនោះមហាសេដ្ឋីតែងពេញចិត្តនឹងជីវិត ។ ក្នុងបណ្តាប្រទេសមួយចំនួនដែលឈានដល់កំពូល ផ្នែកការរីកចម្រើនខាងសម្ភារៈនៅតែមានបញ្ហា មួយចំនួនដែលរងគ្រោះពីបញ្ហាផ្លូវចិត្ត ។ បើទ្រព្យសម្បត្តិ តែមួយអាចផ្តល់នូវសុខ ហេតុអ្វីក៏ ដូចនេះទៅវិញ? ។

តើអំណាចនៅលើពិភពលោក ទាំងមូលអាចបង្កើតសុខពិតទេ? អាឡិចហ្សង់ដែលទទួលបានជោគជ័យលើប្រទេស ឥណ្ឌាក្នុងច្បាំងដណ្តើមយកទឹកដីតាមវិធីនេះ ឥតឃើញទទួលបានច្រើននូវ បំណែកទឹកដីចំពោះការច្បាំងនោះទេ ។

ជីវិតរដ្ឋបុរសដែលកាន់អំណាចអាចមានផលអាក្រក់ជារឿយៗ។ ករណីដែលគួរអាណិតនៃ Mahatma Gandhi និង John F.Kennedy ជាឧទាហរណ៍ពន្យល់ស្រាប់ ។

គេរកសុខឃើញនៅទីនេះ ហើយគេមិនសំដៅទៅលើទ្រព្យសម្បត្តិ អំណាច កេរ្តិ៍ឈ្មោះកិត្តិយស ឬជ័យជំនះនៃការច្បាំងទេ ។

ប្រសិនបើគេទទួលយកបង្ខំនូវកម្មសិទ្ធបែបនេះ នោះវាជាប្រភពឈឺចាប់និងទុក្ខសោកសម្រាប់អ្នកមានទ្រព្យ ។

អ្វីដែលជាសុខសម្រាប់គេប្រហែលជាទុក្ខសម្រាប់អ្នកដទៃអ្វីជាសាច់ឬភេសជៈសម្រាប់ គេ វាអាចជាថ្នាំពុលសម្រាប់អ្នកដទៃ ។

ព្រះពុទ្ធមានបន្ទូលថា សុខសម្រាប់ឧបាសកមាន៤ ប្រភេទ ។ សុខទាំងនោះជាសុខនៃការមានកម្មសិទ្ធិដែលមាន : សុខភាព ទ្រព្យ អាយុយឺនយូរ មានសម្រស់ ស្អាត មានភាពរីករាយ កម្លាំងពលំ បុត្រធីតា ... ។ល ។

ប្រភពទី២ នៃសុខគឺបានមកពីភាពរីករាយនឹងការមានកម្មសិទ្ធិបែបនេះ។ ធម្មតាបុគ្គលប្រុសស្រីចង់សប្បាយដោយខ្លួនគេផ្ទាល់ ។ជាធម្មតាបុរសនិងស្ត្រីចង់ឱ្យខ្លួន គេសប្បាយរីករាយ។ ព្រះពុទ្ធមិនបានប្រៀនប្រដៅឱ្យបុគ្គលទាំងអស់លះបង់នូវការសប្បាយពេញលេញរបស់គេហើយចូលនិវត្តន៍ដោយភាពឯកោស្ងប់ស្ងាត់ទេ។

ភាពរីករាយនឹងទ្រព្យសម្បត្តិមិនមែនស្ថិត ក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិសម្រាប់ខ្លួនយើងផ្ទាល់នោះទេ គឺស្ថិតក្នុងការផ្តល់ទ្រព្យសម្បត្តិដើម្បីសុខុមាលភាពអ្នកដទៃ។ អ្វីដែលយើងបរិភោគនោះគឺគ្រាន់តែមានលក្ខណៈបណ្តោះអាសន្ន។ អ្វីដែលយើងការពារនោះយើងត្រូវឃ្លាត (leave and go)។ អ្វីដែលយើងឱ្យ យើងយកជាប់ជាមួយនឹងយើង។ យើងចាំរហូតនូវអំពើល្អរបស់យើង ដែលបានធ្វើជាមួយកម្មសិទ្ធិទាំងអស់នោះ។

ការមិនធ្លាក់ចូលទៅក្នុងបំណុលជាប្រភព នៃការសប្បាយមួយផ្សេងទៀត។ ប្រសិនបើយើងទ្រាំ នឹងអ្វីដែលយើងមានហើយសន្សំសំចៃ នោះយើងមិនធ្លាក់ចូលទៅក្នុងបំណុលរបស់នរណាមួយឡើយ។ អ្នកជំពាក់បំណុលរស់នៅក្នុងក្តីឈឺចាប់ផ្នែកផ្លូវចិត្ត ហើយស្ថិតក្រោមកូនបំណុលរបស់គេ។ ទោះជាក្រយ៉ាងណាក៏ដោយនៅពេល ដែលយើងមិនជំពាក់បំណុលគេ នោះយើងនឹងមានអារម្មណ៍ធូរស្រាលហើយផ្លូវចិត្តរបស់យើងនឹងរីករាយ។

ការនាំទៅរកជីវិតផុតការស្តីបន្ទោសជា ប្រភពពិសេសមួយនៃសុភមង្គលសម្រាប់មនុស្សយើង។ មនុស្សដែលផុតការស្តីបន្ទោសជាការប្រសិទ្ធពរមួយចំពោះខ្លួនគេ និងអ្នកដទៃ។ បុគ្គលនោះត្រូវបាន មនុស្សទាំងអស់សរសើរហើយគេនឹងមានអារម្មណ៍កាន់តែសប្បាយឡើង។ ទោះយ៉ាងណាវាលំបាកណាស់ក្នុងការទទួលបានកេរ្តិ៍ឈ្មោះល្អពីមនុស្សទាំងអស់។ មនុស្ស មានភាពវិសេសខ្ពស់ផុតការតិះដៀលនៃមនុស្សទាំងពួងហើយមិនអើពើនឹងការយល់ព្រមពីពិភពខាងក្រៅ។

ភាគច្រើននៃមនុស្សក្នុងលោកនេះ សប្បាយចិត្តនឹងទទួលសេចក្តីសប្បាយនៅពេល ដែលអ្នកខ្លះទៀតស្វែងរកការ សប្បាយក្នុងការលះបង់ខ្លួនពួកគេ។ ការមិនជំពាក់ចិត្ត ឬការពុះពារចំពោះក្តីសប្បាយខាងសម្ភារៈជា សេចក្តីសប្បាយដល់ផ្លូវចិត្ត។ បរមសុខនៃនិញ្វាន ដែលជាបរមសុខនៃដំណើរធូរស្បើយពីប្រភពនៃការឈឺចាប់គឺ ជាទម្រង់ខ្ពស់បំផុត។

សុខធម្មតាយើងស្វាគមន៍ ប៉ុន្តែមិនមែនគូបដិបក្ខរបស់វានោះទេ ពោលគឺទុក្ខយើងពិបាកទ្រាំណាស់។ ទុក្ខ ឬក្តីព្រួយមានអាការៈក្រៅផ្សេងៗគ្នា។ យើងមានការឈឺចាប់ពេលយើងចាស់ជរា ដែលជាធម្មជាតិ។ ជាមួយភាពចិត្តនឹងយើងត្រូវតែទ្រាំនឹងការឈឺចាប់ពីចាស់ជរា ។

ការឈឺចាប់ច្រើនជាងការឈឺចាប់ដោយចាស់ជរាបង្កឡើងដោយសារជំងឺ។ សូម្បីយើងឈឺធ្មេញដ៏ស្រាលឬឈឺក្បាលតិចតួចពេលខ្លះយើងសឹងទ្រាំមិនបាន។

នៅពេលយើងមានជំងឺដោយមិនមានការព្រួយបារម្ភយើងត្រូវតែលួងចិត្តខ្លួនយើងដោយគិតថា យើងគេចផុតពីជំងឺធ្ងន់ធ្ងរយ៉ាងច្រើន។

ជារឿយៗយើងត្រូវគេពង្រាត់ពីមនុស្សជាទីស្រឡាញ់ឬអ្នកដែលនៅក្បែរយើង។សេចក្តីព្រាត់ប្រាស់នាំឱ្យមានការ ឈឺចាប់ខាងផ្លូវចិត្តយ៉ាងខ្លាំង។ យើងគួរគិតថា ការជួបជុំទាំងឡាយគឺបង្កប់នូវភាពព្រាត់ប្រាស់។ ទីនេះជាឱកាសល្អដើម្បី ហ្វឹកហាត់ភាពចិត្តនឹង។ លើសពីនេះទៅទៀតគេមិនបង្ខំយើងឱ្យរស់នៅក្នុងភាពឯកោជាមួយភាពមិនសប្បាយដែលយើងស្អប់នោះទេ។ ប្រហែលជាយើងកំពុងច្រូតកាត់នូវផលកម្ម របស់យើងពីអតីតកាលឬបច្ចុប្បន្នហើយ។ យើងគួរព្យាយាមធ្វើឱ្យខ្លួនយើងស្របទៅតាមស្ថានការណ៍ថ្មីឬក៏ព្យាយាមជំនះឧបស័គ្គតាមមធ្យោបាយផ្សេងទៀត។

សូម្បីព្រះពុទ្ធដែលជាភាវៈឥតខ្ចោះ ដែលបានបំផ្លាញនូវអំពើអាក្រក់គ្រប់បែបយ៉ាងក៏នៅទ្រាំអត់ធ្មត់ ការឈឺចាប់ខាងរាងកាយដែលបង្កដោយជីវិត និងគ្រោះថ្នាក់នានាដែរ។

ព្រះអង្គទទួលរងការឈឺចាប់ផ្នែកជំងឺឈឺក្បាលជាបន្តបន្ទាប់។ ជំងឺចុងក្រោយរបស់ ព្រះអង្គធ្វើឱ្យព្រះអង្គរងការឈឺចាប់យ៉ាងខ្លាំង។ ដោយសារតែទេវទត្ត ប្រមៀលថ្មដើម្បី សម្លាប់ព្រះអង្គធ្វើឱ្យព្រះអង្គរងរបួសជើងពីកម្ទេចថ្ម។ ពេលខ្លះព្រះអង្គត្រូវបង្ខំបង្អត់អាហារ។ ដោយសារតែការមិនស្តាប់សាវ័ករបស់ព្រះអង្គ ព្រះអង្គត្រូវបង្ខំ ចិត្តចូលព្រៃរយៈបីខែ។ ទោះ បីនៅក្នុងព្រៃនេះជួបការលំបាកយ៉ាងណាក្តីក៏ ព្រះអង្គនៅរក្សាចិត្តនឹងបាន យ៉ាងប្រសើរ។

មរណភាពជាទុក្ខសោកខ្លាំងបំផុត ដែលយើងត្រូវបង្ខំទទួលយក នៅពេលដែលយើងវង្វេងវង្វាន់ក្នុងសំសារៈ។ ជួនកាលសេចក្តីស្លាប់ចូលមកមិនមែនតែឯកឯងទេ ប៉ុន្តែចូលមកជាចំនួនដែលធ្វើឱ្យគេពិបាកទប់ទល់។

នៅពេលគេសួរម្តាយម្នាក់ដែលមិនយំនៅពេលកូនខ្លួនស្លាប់នោះ គាត់ឆ្លើយថា កូនគាត់កើតមកដោយគ្មានការអញ្ជើញមកទេហេតុ ដែលគេចាកចេញទៅវិញក៏មិនគួរប្រាប់ឱ្យដឹងដែរ។ នៅពេលដែលគេមកគេក៏ត្រូវចេញទៅវិញតើចាំបាច់យំធ្វើអ្វី?តើការយំមានប្រយោជន៍អ្វី ?

ដូចផ្លែឈើធ្លាក់ពីលើដើមដោយសារ ទុំ ផុយ ឬចាស់ក៏ដូចយើងស្លាប់ក្នុងកុមារភាពពេញវ័យឬក្នុងពេលចាស់។ ព្រះអាទិត្យរះនៅទិសខាងកើត គឺគ្រាន់តែកំណត់ទិសខាងលិចប៉ុណ្ណោះ។

ផ្ការីកពេលព្រឹកហើយរុះរោយក្នុងពេលល្ងាច ។មនុស្សមិនអាចជៀសផុតពីការស្លាប់បានទេហេតុនេះយើងត្រូវប្រឈមមុខនឹងភាពពិត នឹងឥតខ្វះ ។ "ប្រៀបដូចផែនដីអ្វីដែលត្រូវមកការាំងស្រេចតែនាងថាតើផ្អែម ឬស្មោកគ្រោក មិនល្អមិនអាក្រក់គឺសុទ្ធតែដូចគ្នា មិនបង្ហាញភាពស្អប់ ឬមិត្តភាពហេតុនេះល្អឬអាក្រក់មាន *តុល្យភាពគ្នា*។

ព្រះពុទ្ធមានព្រះបន្ទូលថា នៅពេលលក្ខខណ្ឌទាំងឡាយនៃពិភពលោកជ្រៀតជ្រែកចិត្ត១ អារហន្តនៅនឹងដែរ ( ទទួលដូចគ្នា ) ។

ហេតុនេះ ទោះប្រឈមមុខនឹងបញ្ហាណាក៏ដោយ យើងត្រូវរក្សាចិត្តឱ្យបានមិនត្រូវឱ្យផ្នែកណាមួយមករំខានចិត្តយើងទេ ។

## ២-អត្ថន័យនៃជីវិត (The Meaning of Life) Ven. Narada Mahathera

តើមនុស្សជានរណា ? តើមនុស្សមានប្រភពដូចម្តេច ? តើមនុស្សនឹងធ្វើដំណើរទៅទីកន្លែងណា? អ្វីជាគោលបំណងនៃជីវិត? ទាំងអស់នេះជាសំណួរដ៏សំខាន់ដែលប៉ះពាល់ដល់មនុស្សជាតិទាំងអស់ ។

ចូរយើងបន្តស្វែងរកអ្វីដែលច្បាស់លាស់ ដែលយើងអាចយល់ដឹងគ្រប់យ៉ាង ។ តើមនុស្សជានរណា?

មនុស្សមានរាងកាយដែលគេមើលឃើញដោយវិញ្ញាណឬដោយសារបរិធាន ។ រូបរាងរូបធាតុរួមមានកម្លាំង និងគុណភាពដែលជាសភាពមួយប្រែប្រួលជានិច្ច ។

អ្នកវិទ្យាសាស្ត្រពុំអាចកំណត់បានអំពីរូបធាតុទេ ។ ទស្សនវិទូមួយចំនួនកំណត់ថា រូបធាតុដូចមាននៅក្នុងសភាពនោះដែរ វាបន្តប្រែប្រួល ដែលគេហៅថាចលនា ហើយចលនាដូចជាការផ្លាស់ប្តូរដែលមានជាបន្តក្នុងរូបធាតុ ។

ពាក្យបាលី រូបធាតុគឺរូបំ *(rupa)* ។ រូបំនេះត្រូវបានគេពន្យល់ថា អ្វីដែលផ្លាស់ប្តូរ និងបែកជាបំណែក ។ តែជាក់ស្តែងឥឡូវ វាត្រូវបានគេពន្យល់មួយផ្សេងទៀត ។

យោងតាមព្រះពុទ្ធសាសនាធាតុ រូបធារុដែលជាមូលធាតុសំខាន់ទាំងបួនគឺ : Pathavi, Apo, Tejo nig Vayo ។

*Pathavi* មានន័យថាធាតុនៃវិសាលភាព ឬសារធាតុរូបធាតុ ។ បើគ្មានវាទេវត្ថុមិនអាចមានក្នុងលំហទេ ។ គុណភាពនៃភាពរឹង និងភាពទន់ដែលមានទំនាក់ទំនងគ្នា យ៉ាងបរិសុទ្ធជាលក្ខខណ្ឌពីរនៃ ធាតុនេះ ។ ធាតុនៃវិសាលភាពនេះមាន ទឹក ដី ភ្លើង ខ្យល់ ឧទាហរណ៍ ទឹកនៅ

ពីលើគាំទ្រទឹកនៅពីក្រោម ។វាជាធាតុនៃវិសាលភាព ដែលទាក់ទងជាមួយធាតុចលនា *(Vayo)* ដែលបង្កើតសំពាធខាងលើ ។

*Apo* ជាធាតុសម្ពន្ធ័ភាព *Apo* មិនដូច *Pathavi* ទេ ។ វាមិនអាចដឹងដោយការប៉ះបានទេ ។ ធាតុនេះធ្វើឱ្យអាតូមនៃរូបធាតុដែលបែកបាក់ប្រមូលផ្ដុំគ្នាឡើងវិញ ដែលផ្ដល់ឱ្យយើងនូវគំនិតនៃរូបរាង ។

*Tejo* ជាធាតុកំដៅ ។ ធាតុត្រជាក់ក៏ជាទម្រង់ *Tejo* ដែរ ។ ទាំងកំដៅ ទាំងត្រជាក់គឺមាននៅក្នុង *Tejo* ពីព្រោះវា មានថាមពលធ្វើឱ្យរាងកាយចាស់ទុំ ឬធ្វើឱ្យស្វាហាប់ ។ ការរក្សា និងការពុកផុយគឺ ដោយសារតែធាតុនេះ ។

*Vayo*ជាធាតុចលនា ។ ចលនាគឺបង្កឡើងដោយធាតុនេះ ។ ចលនាត្រូវចាត់ទុកថា ជាកម្លាំង ឬអ្នកបង្កើតកំដៅ ។ ទាំងចលនា និងកំដៅនៅក្នុងផ្នែកសម្ភារៈស្របតាមមនសិកា និងកម្មក្នុងចិត្ត ។

កត្តាកម្លាំងទាំងបួននេះជាការជំរុញចិត្តនិងមានទំនាក់ទំនងគ្នាទៅវិញទៅមក ។តែមានធាតុមួយដែលមានឥទ្ធិពល លើធាតុដទៃទៀតដូចជា ធាតុវិសាលភាពមានឥទ្ធិពលលើផែនដី ធាតុសម្ពន្ធ័ភាពក្នុងទឹក កំដៅក្នុងភ្លើងហើយ ចលនាក្នុងខ្យល់ ។

ដូចនេះរូបធាតុរួមមានកម្លាំង និងរូបធាតុដែល ផ្លាស់ប្ដូរជាបន្តបន្ទាប់ឥតឈប់ឈរ ។ នៅពេលចាប់កំណើតបើតាមជីវវិទ្យា មនុស្សទទួលមរតកពីឪពុកម្ដាយរបស់គេនូវ កោសិការមួយនាទីយ៉ាងតិចក៏៣០ លានផ្នែកនៃកោសិការដែលឆ្លងកាត់ចំនួនតិចតួចនេះដែរ ។ ក្នុងរយៈពេល ៩ ខែកម្មេចល្អិច១នេះលូតលាស់១៥.០០០ លានដងនូវទំហំនៃកោសិការសំនៅ ច្រើនជាងនៅពេលដំបូងទៅទៀត ។ កោសិការរូប-គីមីជាមូលដ្ឋានរូបនៃមនុស្ស ។ បើយោងទៅតាមព្រះពុទ្ធសាសនាភេទគឺត្រូវបានកំណត់នូវខណៈនៃការចាប់កំណើត ។

រួមជាមួយរូបធាតុវាមានកត្តាសំខាន់ មួយទៀតនៅក្នុងប្រពន្ធ័រៀបចំស្មុគស្មាញនៃមនុស្សទៀត ។ វាគឺគំនិត ។ វាគួរឱ្យរីករាយចំពោះអ្នកនិពន្ធដែលបានរៀនមួយចំនួននិយាយថា មនុស្សមិនមែនគំនិតបូកនឹងរាងកាយទេ តែជាកាយចិត្ត ។ អ្នកវិទ្យាសាស្ត្រប្រកាសថា ជីវិតកើតចេញមកពីរូបធាតុ ហើយចិត្តកើតចេញមកពីជីវិត ។ តែគេមិនផ្ដល់ឱ្យយើង នូវការពន្យល់ដ៏ពេញចិត្តជាមួយការពាក់ពន្ធ័ និងការអភិវឌ្ឍន៍នៃចិត្តទេ ។ មិនដូចរាងកាយដែលជារូបធាតុទេ ចិត្តដែលមិនមែនជារូបធាតុ គឺមិនអាចមើលឃើញតែវាអាច ត្រូវគេយល់ដឹងបានដោយផ្ទាល់ ។ កំណាព្យ

ដ៏មានវ័យចំណាស់មួយ ត្រូវបានរៀបចំដូចខាងក្រោម "អ្វីជាគំនិតគ្មានរូបធាតុ" "អ្វីជារូបធាតុគ្មានគំនិត "។

យើងដឹងគំនិត និងអារម្មណ៍របស់យើង ហើយជឿដោយឥន្ទ្រិយារម្មណ៍ផ្ទាល់របស់យើង ហើយយើងពិចារណាការកើតមានរបស់វាក្នុងផ្នែកដទៃទៀតដោយសទិសភាព ដោយផ្ដើមពីរូបារម្មណ៍ជាប្រភព។

មានពាក្យបាលីជាច្រើនសម្រាប់ចិត្ត។ *Mana*,ចិត្ត *(Citta)*, វិញ្ញាណ *(Vinnana)* ជាកត្តាសំខាន់បំផុត។ ប្រៀបធៀបបាលី ឬសគល់មនុស្ស (ការប្រកបសម្រាប់ : ចុងជួនជាមួយការលេងពាក្យ) ។ពាក្យបាលីមនុស្ស*(Manussa)*មានន័យថា អ្នកដែលបានអភិវឌ្ឍមនសិការ។

ក្នុងព្រះពុទ្ធសាសនា គ្មានការខុសប្លែកគ្នារវាងចិត្តនិងមនសិការទេ ទាំងពីរនេះត្រូវបានគេប្រើជាសព្ទសទិសន័យ។ ចិត្តប្រហែលជាត្រូវគេកំណត់ធម្មតាថា ជាការយល់ដឹងនៃវត្ថុមួយពីព្រោះគ្មានភ្នាក់ងារ ឬព្រលឹងដែលចង្អុលបង្ហាញសកម្មភាពទាំងអស់ទេ។ ចិត្តរួមមានសភាពចិត្តដ៏រហ័សដែលកើតឡើងជា បន្តបន្ទាប់ ហើយបាត់បង់ទៅវិញជាមួយនឹងការធ្លាក់ ចុះយ៉ាងលឿន។ ការយល់ដឹងមួយខណៈពេលនៃ លំហូជីវិតដែលប្រែប្រួលនេះ បញ្ជូននូវថាមពលទាំងស្រុងរបស់វា ចំពោះអ្នកបន្តរបស់វា។ ដូចនេះគ្រប់ការយល់ដឹងថ្មីរួមមានសក្តានុភាព នៃបុព្វការីជនរបស់វាហើយពេលខ្លះមានលើសនេះទៅទៀត។ ការចាប់អារម្មណ៍ទាំងអស់ត្រូវបានគេកត់ត្រាទុកនៅក្នុងចិត្ត ហើយសក្តានុភាពទាំងអស់ត្រូវបញ្ជូនពីជីវិតមួយទៅ ជីវិតមួយទៀត។ ប្រសិនបើជាការចងចាំពឹងផ្អែកតែទៅលើកោសិការខួរក្បាលវាមិនអាចទៅរួចទេ។

ដូចជាអគ្គីសនី ចិត្តជាកម្លាំងថាមពលដែលមានទាំងកសាង និងបំផ្លាញ។ ចិត្តដូចជាអាវុធមុខពីរ ដែលអាចប្រើទាំង សម្រាប់អ្វីល្អ ទាំងសម្រាប់អ្វីអាក្រក់។ គំនិតតែមួយដែលកើតឡើងក្នុងចិត្តមើលមិនឃើញអាចសង្គ្រោះ ឬបំផ្លាញនូវពិភពលោក។ គំនិតបែបនេះធ្វើឱ្យមានមនុស្សនៅឬធ្វើមិនឱ្យមានមនុស្សនៅក្នុងប្រទេសទាំងមូល ។ចិត្តដែលបង្កើតនរករបស់មនុស្ស។

Ouspensky បានសរសេរថា :"ពាក់ពន្ធ័នឹងថាមពលកំបាំងដែលមាននៅ ក្នុងបាតុភូតនៃមនសិការដូចជា ក្នុងចិត្តអារម្មណ៍ចំណង់ យើងរកឃើញថា សក្តានុភាពរបស់វាគឺថែមទាំងមិនអាចវាស់បាន គ្មានព្រំដែន។ ពីបទពិសោធន៍ផ្ទាល់ខ្លួន ពីការអង្កេតពីប្រវត្តិសាស្ត្រ យើងដឹងថា គំនិត អារម្មណ៍ចំណង់ ដែល សំដែងនូវខ្លួនពួកគេផ្ទាល់អាចបញ្ចេញថាមពល បរិមាណដ៏ច្រើនលើសលុប និងបង្កើតបាតុភូតគ្មានកំណត់ជាបន្តបន្ទាប់។ គំនិតអាចតំណាងឱ្យប្រទេស និង

សហស្សវត្សជាច្រើន ហើយនៅតែលូតលាស់ និងកាន់តែជ្រៅទៅ ដោយធ្វើឱ្យមាននូវបាតុភូតថ្មីជាបន្តបន្ទាប់ ដោយបញ្ចេញនូវថាមពលស្រស់បំព្រង។ យើងដឹងថា គំនិតបន្តរស់នៅ និងធ្វើសកម្មភាពនៅពេល ដែលឈ្មោះមនុស្សគ្រប់រូបដែលបង្កើតឱ្យពួកគេបានផ្លាស់ប្តូរនូវជំនឿ ដូចឈ្មោះអ្នកបង្កើត ស្នាដៃកំណាព្យពីបូរាណកាល ដូចជា វីរបុរស ថ្នាក់ដឹកនាំ និងព្យាការី។ ពាក្យពេចន៍របស់គេត្រូវបានគេថាឡើងវិញ លើបបូរមាត់ច្រើនរាប់មិនអស់គំនិតរបស់គេត្រូវបានសិក្សា និងអធិប្បាយពន្យល់។

"ដោយគ្មានសង្ស័យទេ គំនិតស្តីពីកំណាព្យនិមួយៗ មានកម្លាំងសក្តានុពលលើសលុប ដូចថាមពល មានក្នុងបំណែកធ្យូងថ្ម និងកោសិការរស់នៅ តែកាន់តែល្អិតល្អន់គ្មានទីបំផុត មិនអាចថ្លឹងបាន និងមានអំណាច"។ ឧទាហរណ៍ សូមសង្កេតមើលកម្លាំងសក្តានុពល ដែលស្ថិតនៅក្នុងពាក្យពេចន៍ ដ៏សំខាន់ ខាងក្រោមរបស់ព្រះពុទ្ធ÷

ចិត្តកើតមុនអំពើ ចិត្តជាកត្តាចម្បង តាមព្រះពុទ្ធចិត្ត ឬមនសិការកើតឡើងគ្រប់ពេលនៃកំណើតរួមជាមួយរូបធាតុដូចនេះ មនសិការមានក្នុងទារកក្នុងផ្ទៃ។ មនសិការដំបូងនេះត្រូវបានគេដឹងថា ជាមនសិការកំណើតថ្មី ឬមនសិការដែលទាក់ទងឡើងវិញ ដែលកំណត់ដោយកម្មចាស់របស់មនុស្សដែលពាក់ពន្ធ័។ភាពខុសប្លែកគ្នាខាងបញ្ញាចិត្តសីលធម៌ដ៏ខ្ពង់ខ្ពស់ដែលមានក្នុងបណ្តាមនុស្សជាតិគឺដោយសារតែកម្មនេះកំណត់មនសិការដែលជាកត្តាទីពីរនៃមនុស្ស។

ដើម្បីបំពេញផ្នែកទាំងបីដែលបង្កើតឱ្យមានមនុស្សមាន កត្តាទីបីដែលជាបាតុភូតនៃជីវិតដែលធ្វើឱ្យស្វាហាប់ទាំង ចិត្តទាំងរូបធាតុ។ ដោយសារតែវត្តមានជីវិត ការបង្កើតឡើងវិញក៏កើតមានឡើង។ ជីវិតបង្ហាញយ៉ាងច្បាស់លាស់នូវខ្លួនវាផ្ទាល់ទាំងបាតុភូតផ្ទាល់និងផ្លូវចិត្ត។ នៅក្នុងពាក្យបាលីទម្រង់ទាំងពីរនៃជីវិតត្រូវបានគេដាក់ឈ្មោះថានាមជីវិតិន្ទ្រីយ៍និងរូបជីវិតិន្ទ្រីយ៍។

ដូចនេះរូបធាតុ ចិត្ត និងគំនិត ជាកត្តាបីខុសគ្នាដែលរួមគ្នាកើតជាមនុស្ស។ មនុស្សបានក្លាយជាអ្នកបង្កើត និងបំផ្លាញផ្ទាល់របស់គេ។ នៅក្នុងខ្លួនគេត្រូវរកឃើញទាំងអំពើ បាបទាំងគុណធម៌។ នៅក្នុងខ្លួនគេ ត្រូវបានមើលឃើញភាពកក់ក្តៅ កម្រាលភាពជាមនុស្សជា អ្នកខ្ពង់ខ្ពស់ ទេវៈ ព្រះព្រហ្ម។ទាំងទំនោរឧក្រិដ្ឋកម្មនិងបុគ្គលិកលក្ខណៈសន្តភាព (saintlycharacteristics) សុទ្ធតែកប់នៅក្នុងខ្លួនគេទាំងអស់។ គេអាចជាបរមសុខ (blessing) ឬជាបណ្តាសារ (curse) ចំពោះខ្លួនគេផង និងចំពោះអ្នកដទៃ។ តាមពិតទៅមនុស្សគឺជាពិភពមួយដោយខ្លួនគេ។ តើមនុស្សមានកំណើតមកពីណា ? នេះគឺជាសំណួរទី២ របស់យើង។

ពិតជាមានការចាប់ផ្តើមសម្រាប់មនុស្សផង និងការមិនចាប់ផ្តើមផងដែរ។ អ្នកដែលជានិកាយដំបូងអះអាងថា ហេតុទី១ ថាតើជាកម្លាំងលោកធាតុ ឬដូចភាវៈ Almighty ។ អ្នកដែលជានិកាយទីពីរ បដិសេធហេតុដំបូងដែលកើតឱ្យមានផល ហើយផលកើតជាហេតុវិញ ដែលនៅក្នុងរង្វង់នៃហេតុ និងផលហេតុដំបូងគឺមិនអាចគិតដល់។

បើតាមអតីតកាល ជីវិតមានការចាប់ផ្តើមមួយ រីឯក្រោយមកទៀតជីវិតមិនមានការចាប់ផ្តើមទេ។ នៅក្នុងទស្សនេះមួយចំនួន បញ្ញត្តិកម្មនៃហេតុដំបូង គួរចង់ឱ្យសើចដូចត្រីកោណមូល (a round triangle) ដែរ។

បើតាមទស្សនៈវិទ្យាសាស្ត្រ មនុស្សកើតចេញផ្ទាល់ពីទឹកកាមនៃកោសិកាពង ដែលឪពុកម្តាយគេផ្តល់ឱ្យ។ អ្នកវិទ្យាសាស្ត្រនៅពេលដែលអះអាងថា *'Omne vivum exviro'* ពោលគឺ គ្រប់ជីវិតទាំងអស់កើតមកពីជីវិតដោយអះអាងថា ចិត្តនិងជីវិតវិវត្តន៍ មកពីភាពគ្មានជីវិត (the lifeless)។

ឥឡូវនេះទាញចេញពីទស្សនៈវិទ្យាសាស្ត្រ មនុស្សមានកំណើតមកពីឪពុកម្តាយយ៉ាងពិតប្រាកដ។ ជីវិតបែបនេះ កើតមានមុនជីវិត។ ចំពោះដើមកំណើតមូលជីវធាតុជីវិត (the protoplasm of life)វិញ ឬ"ជាតិអន្ទិល (colloid)" (មួយណាក៏បានតាមតែយើងពេញចិត្តហៅថា) អ្នកវិទ្យាសាស្ត្រមិនបានដឹង (plead ignorance)។

តាមព្រះពុទ្ធសាសនា មនុស្សកើតចេញមកពីកន្លែងនៃអំពើ (kamma)។ ឪពុកម្តាយគ្រាន់ តែផ្តល់ឱ្យមនុស្ស នូវស្រទាប់រូបធាតុ។ ដូចនេះភាវៈបន្តជាភាវៈ។ វាជាកម្មចាស់ដែលកំណត់នូវការយល់ ដឹងដំបូងដែលធ្វើឱ្យគភ៌ស្វាហាប់។ វាជាថាមពលកម្មមិនអាចជៀសផុតបន្តពីជាតិមុនដែលបង្កើតបាតុភូតចិត្ត និងបាតុភូតជីវិតនៅក្នុងបាតុភូតរូបចំពោះការបំពេញ ផ្នែកទាំងបីដែលបង្កើតមនុស្ស។ទាក់ទងជាមួយបញ្ញត្តិកម្មនៃភាវៈព្រះពុទ្ធមានព្រះបន្ទូលថា :

"ទីណាដែលផ្នែកទាំងបីនេះត្រូវបានគេមើលឃើញថា រួមបញ្ចូលគ្នានោះទើបមាន ភាពចាប់ផ្តើមនៃជីវិតកើតឡើង។ ប្រសិនបើម្តាយនិងឪពុកត្រូវគ្នា តែវាមិនមែនជាអំឡុងពេលរបស់ម្តាយនោះភាវៈដែលកើតមកមិនបង្ហាញទេ។ហេតុនេះគ្មានការចាប់ផ្តើមនៃជីវិត។ ប្រសិនបើឪពុក និងម្តាយរួមគ្នា ហើយជាអំឡុងពេលរបស់ម្តាយ តែភាវៈដែលកើតមកមិន បង្ហាញនោះក៏ឥតមានការចាប់ផ្តើមនៃជីវិតដែរ។ ប្រសិនបើម្តាយនិង ឪពុករួមគ្នាហើយជាអំឡុងពេល

របស់ម្ដាយហើយភាវៈដែលកើតមកក៏បង្ហាញដោយការរួមបញ្ចូលគ្នាផ្នែកទាំងបី នោះនាំឱ្យមានការចាប់ផ្ដើមនៃជីវិត។

នៅទីនេះ Gandhabba (gantabba) សំដៅលើភាវៈដ៏សមរម្យត្រៀមខ្លួនកើតនៅក្នុងស្បូន។ ពាក្យនេះត្រូវបាន គេប្រើប្រាស់តែនៅក្នុងការទាក់ទងជាពិសេសហើយមិនត្រូវយល់ខុសចំពោះព្រលឹងអចិន្ត្រៃយ៍ទេ។សម្រាប់ភាវៈដែលកើតមកទីនេះ ភាវៈនេះត្រូវតែស្លាប់នៅទីណាមួយ។ កំណើតនៃភាវៈស្មើ នឹងការស្លាប់នៃភាវៈក្នុងជាតិមុន។ ប្រៀបដូចជាការរះនៃព្រះអាទិត្យក្នុងទីណាមួយ មានន័យថា ការលេចនៃព្រះអាទិត្យក្នុងទីមួយផ្សេងទៀត។

ព្រះពុទ្ធមានបន្ទូលថា "ការចាប់ផ្ដើមដំបូងនៃភាវៈ ដែលរាំងស្ទះដោយការមិនដឹង និងការព្រម ដោយចំណង់ខ្លាំង ត្រេកត្រអាល និងការចូលចិត្ត គឺគេមិនដឹងទេ"។

ខ្សែជីវិត (life-stream) នេះហូរនាំ *ad infinitum* ដរាបណាវាត្រូវបានចិញ្ចឹមជា មួយទឹកភក់នៃអវិជ្ជា និងតណ្ហា (muddy waters of ignorance)។ នៅពេលដែលវត្ថុទាំងពីរ នេះត្រូវបានកាត់ផ្ដាច់ដោយបរិបូណ៌ហើយ នៅពេលនោះមាន តែខ្សែជីវិតទេដែលត្រូវឈប់ ហូរ។ ការចាប់កំណើតថ្មីបានបញ្ចប់ទៅតាមករណីរបស់ព្រះពុទ្ធ និងព្រះអរហន្ត។ ការចាប់ផ្ដើមខ្សែជីវិតចុងក្រោយនេះមិនអាចត្រូវកំណត់បានទេ គឺជាដំណាក់កាលមួយដែលគេមិនអាចដឹងបាន នៅពេលកម្លាំងជីវិតនេះពោរពេញដោយការដឹង និងចំណង់ខ្លាំង។

នៅទីនេះព្រះពុទ្ធសំដៅគ្រាន់តែចំពោះ ការចាប់ផ្ដើមនៃខ្សែជីវិតភាវៈរស់ប៉ុណ្ណោះ។ អ្នកវិទ្យាសាស្ត្រមិនគិតពីការប្រមើលពីប្រភពដំបូង និងការវិវត្តនៃចក្រវាឡ។

នៅដើមដំបូងគេអះអាងថា ព្រះពុទ្ធមិនព្យាយាមដោះស្រាយនូវបញ្ហាទស្សនវិជ្ជា និងសីលធម៌ដែលធ្វើឱ្យ ច្រឡំដល់មនុស្សជាតិ។ ហើយព្រះអង្គទាក់ទងដល់ការប្រថុយប្រហ៊ាន (speculation) និងទ្រឹស្ដីដែលមិនទោរទន់ទៅរកការកសាង ឬការត្រាស់ដឹងនោះទេ។ ព្រះអង្គក៏មិនទាមទារឱ្យជឿទាំងងងឹតងងុល ពីអ្នកជឿរបស់ព្រះអង្គស្ដីពីហេតុទី១នោះដែរ។ ព្រះអង្គយកចិត្តទុកដាក់ជាចម្បងជាមួយបញ្ហាប្រតិបត្តិ និងច្បាស់លាស់ ពោលគឺបញ្ហាទុក្ខ និងការវិនាសហិនហោចរបស់វា គ្រប់បញ្ហាបន្ទាប់បន្សំទាំងអស់សុទ្ធតែគេមិនបាន យល់ដោយគ្រប់ជ្រុងជ្រោយទាំងអស់។

នាឱកាសមួយព្រះភិក្ខុដែលមានឈ្មោះថា *Malunkyaputta* ដែលមិនទទួលនូវការដឹកនាំជីវិតបរិសុទ្ធ ហើយសម្រេចការដោះលែងរបស់គាត់ដោយកម្រិតនានា នោះបានទៅដល់

ព្រះពុទ្ធ ហើយសុំឱ្យព្រះអង្គដោះស្រាយបញ្ហាមិនប្រាកដ បន្ទាន់មួយចំនួនជាមួយនឹងការគំរាមកំហែងចំពោះការបោះបង់ចោលស្បង់ចីវរប្រសិនបើគ្មានចម្លើយពេញចិត្តត្រូវបានគេផ្ដល់ឱ្យ។

លោកនិយាយថា "ព្រះជាម្ចាស់ទ្រឹស្ដីទាំងនេះមិនត្រូវបានពន្យល់ មិនត្រូវបានគេដាក់ទៅប្រគេន ហើយបដិសេធដោយបរមគ្រូ (the Blessed One)ថាតើពិភពលោកនេះមានទីបញ្ចប់ឬអត់ ? ថាតើពិភពលោកនេះមានកំណត់ ឬក៏គ្មានកំណត់ ? ប្រសិនបើ បរមគ្រូពន្យល់សំណួរនេះចំពោះខ្ញុំ នោះខ្ញុំនឹងដឹកជីវិតបរិសុទ្ធតាមលោក តែប្រសិនបើអត់ទេ នោះខ្ញុំនឹងបោះបង់ សិក្ខាបទចោល ហើយត្រឡប់ទៅរកជីវិតជាគ្រហស្ថ។

"ប្រសិនបើព្រះបរមគ្រូ ដឹងថាពិភពលោកគ្មានទីបញ្ចប់ ព្រះបរមគ្រូនឹងពន្យល់ប្រាប់ខ្ញុំថា ពិភពលោកគ្មានទីបញ្ចប់ ប្រសិនបើព្រះបរមគ្រូដឹងថា ពិភពលោកមានទីបញ្ចប់វិញនោះព្រះបរមគ្រូនឹងពន្យល់ប្រាប់ថា ពិភពលោកមានទីបញ្ចប់ ពោលគឺនៅក្នុងករណីយនេះ ជាការពិត ចំពោះអ្នកដែលមិនបានដឹង និងខ្វះបញ្ញា មានតែវត្ថុទៀងត្រង់ត្រូវនិយាយថា ខ្ញុំ មិនដឹងទេ ពោលគឺខ្ញុំគ្មានបញ្ញា។

ព្រះពុទ្ធបានសួរដោយរាបសាដល់ភិក្ខុដែលយល់ច្រឡំ ថាតើការអនុម័តរបស់គាត់ ចំពោះជីវិតបរិសុទ្ធស្ថិតនៅក្នុងមាគ៌ាណាមួយដែលមានលក្ខខណ្ឌទៅលើដំណោះស្រាយបញ្ហាបែបនេះ ។ ព្រះគុណម្ចាស់ ព្រះភិក្ខុឆ្លើយតប។

ពេលនោះព្រះពុទ្ធក្រើនរំលឹកព្រះអង្គ កុំឱ្យចំណាយពេលឥតប្រយោជន៍ និងថាមពលទៅលើការប៉ាន់ស្មានគ្មានប្រយោជន៍ ដែលធ្វើឱ្យខាតប្រយោជន៍ដល់ការអភិវឌ្ឍន៍សីលធម៌ហើយបាននិយាយថា : "អ្នកណាក៏ដោយ Malunkyaputta គួរនិយាយ 'ខ្ញុំនឹងមិនដឹកនាំជីវិតបរិសុទ្ធតាមព្រះបរមគ្រូលុះត្រាតែព្រះបរមគ្រូពន្យល់សំណួរទាំងនោះដល់ខ្ញុំ ថាមនុស្សនឹង ស្លាប់មុនៗ សំណួរទាំងនេះត្រូវបានពន្យល់ដោយអ្នកដែលបានបំពេញរួច។

វាហាក់ដូចជាមនុស្សម្នាក់ត្រូវបានទម្លុះទម្លាយ ដោយព្រួញពិសយ៉ាងក្រាស់ ហើយមិត្តនិងញាតិមិត្តរបស់គាត់ត្រូវ យកទៅឱ្យពេទ្យវះកាត់ ហើយនៅពេលនោះគាត់ត្រូវនិយាយថា "ខ្ញុំនឹងមិនមានព្រួញនេះដែលគេបានយកចេញលុះត្រាតែ ខ្ញុំដឹងសេចក្ដីលំអិតអំពីមនុស្សនោះដែលខ្ញុំបានត្រូវគេធ្វើឱ្យរបួសពោលគឺ ធម្មជាតិព្រួញដែលខ្ញុំត្រូវគេបាញ់ឱ្យរបួសនោះ" ។ មនុស្សនោះនឹងស្លាប់មុននេះត្រូវបានគាត់ធ្លាប់ស្គាល់។

"ជាការពិតវិធីដូចគ្នាអ្នកណាដែលគួរនិយាយថា ខ្ញុំនឹងមិននាំជីវិតពិសិដ្ឋតាមព្រះបរមគ្រូទេ លុះត្រាតែព្រះអង្គ ពន្យល់ប្រាប់ខ្ញុំថាតើពិភពលោកគ្មានទីបញ្ចប់ ? ឬក៏មាន ថាតើពិភពលោកមានកំណត់ ឬក៏គ្មានពោលគឺ។ មនុស្សនោះស្លាប់ មុនពេលសំណួរទាំងនេះធ្លាប់ត្រូវបានពន្យល់ដោយអ្នកដែលបានបំពេញរួច។

"ប្រសិនបើវាជាជំនឿដែលថា ពិភពលោកនេះមានទីបញ្ចប់ តើមានការអង្កេតពីជីវិតបរិសុទ្ធឬទេ? នៅក្នុងករណីនេះពោលគឺគ្មានទេ!។ ប្រសិនបើជាជំនឿគ្មានទីបញ្ចប់ក៏គ្មានដែរ។ តែមានការកើត មានការចាស់ជរា និងការស្លាប់ ដែលជាការវិនាសនៃផ្នែកណាមួយក្នុងជីវិតវាផ្ទាល់ដែលវាបានដឹង។

Malunkyaputta ខ្ញុំមិនលាតត្រដាងថា តើពិភពលោកនេះមានទីបញ្ចប់ ឬអត់នោះទេ ថាតើពិភពលោកមានកំណត់ឬក៏អត់។ ហេតុអ្វីបានជាខ្ញុំមិនបរិយាយបញ្ហាទាំងនេះ? ព្រោះទាំងនោះទាំងនេះមិនសមស្របមិនពាក់ព័ន្ធ នឹងមូលដ្ឋាននៃភាពបរិសុទ្ធមិននាំឱ្យមានភាព ស្អប់ខ្ពើមភាពគ្មានតណ្ហាការឈប់ភាពសុខសាន្ត គតិបណ្ឌិតសភាវគតិការត្រាស់ដឹង ឬព្រះនិព្វាន។ ដូច្នេះខ្ញុំមិនបរិយាយទាំងនេះទេ។"តើមនុស្សនឹងទៅទីកន្លែងណា ? នេះគឺជាចម្ងល់ទីបីរបស់យើង។

យោងតាមអ្នករូបធាតុនិយមបូរាណ ដែលនៅក្នុងបាលី និងសំស្ក្រឹតត្រូវគេដឹងថា ជាលោកធាតុ *(Lokayata)* ពោល គឺមនុស្សត្រូវសាបសូន្យក្រោយពីស្លាប់ ដោយចាកចេញទៅក្រោយគេនូវកម្លាំងណាមួយ ដែលបានបង្កើតឡើងដោយគេ។ មនុស្សត្រូវបានតាក់តែងឡើងដោយធាតុបួនយ៉ាង។ ពេលមនុស្សស្លាប់ ធាតុដី (the earthly element) ត្រឡប់ចូលទៅក្នុង *ដី* (the earth) ធាតុទឹក(watery element) វិលត្រឡប់ចូលទៅក្នុង ទឹក ធាតុភ្លើង (fiery element) វិលត្រ ឡប់ចូលទៅក្នុង ភ្លើង(fire) ហើយ និងធាតុខ្យល់ (airy element) វិលត្រឡប់ទៅរកខ្យល់ (the air)វិញ។ វិញ្ញាណនានា (the senses) ឆ្លងចូលទៅក្នុងលំហ (space)។ មនុស្សឆ្លាតនិងមនុស្សល្ងង់ក៏ដូចគ្នាដែរ (ពេលរូបកាយរលាយបាត់) ត្រូវរលត់បាត់ស្លាប់បាត់ឥតមានអត្ថិភាពអ្វីតទៅទៀតឡើយ។ មិនមានភពដ៏ទៃទៀតទេ។ ការស្លាប់ជាការបញ្ចប់នៃអ្វីទាំងអស់។ ពិភពបច្ចុប្បន្នជាពិភពពិតដែលហៅថា ឋានសួគ៌និងឋាននរក គ្មានទីបំផុតនោះ គឺជាការប្រឌិតរបស់មនុស្សទេ។

អ្នករូបធាតុនិយមជឿតែអ្វីដែលយល់ដឹងដោយវិញ្ញាណ។ ដូចនេះមានតែរូបធាតុទេដែលពិត។គោលការណ៍កំពូលគឺធាតុបួនរួមមាន ទឹក (water) ដី (earth) ភ្លើង (fire) និងខ្យល់

(air)។ ជីវិតស្វ័យញាណ (the self-conscious life)សុទ្ធតែលេចចេញមកពីពួកវា ដោយអាថិកំបាំង ប្រៀបដូចជា ទេពារក្ស(genie)បង្ហាញខ្លួនពេល Aladdin ជូតចង្កៀង របស់គាត់។ អាថិកំបាំងខួរក្បាលគឺដូចជា ថ្លើមលាក់កំបាំងទឹកប្រមាត់ដូច្នេះដែរ។

ក្នុងទស្សនៈអ្នករូបធាតុនិយមជំនឿដទៃទៀតដូច Sri Radhakrishan អះអាងដែរ "គឺជាសញ្ញាមួយនៃការកុហក លក្ខណៈជាស្ត្រី ភាពខ្សោយ កំសាក និងមិនស្មោះត្រង់។"

បើតាមសាសនាមួយដែលគ្មានអតីតកាលសម្រាប់មនុស្សទេ។ បច្ចុប្បន្នគឺគ្រាន់តែជា ការរៀបចំមួយសម្រាប់អនន្ត ភាពពីរចំពោះឋានសួគ៌ និងឋាននរក។ ថាតើពួកវាត្រូវបានមើលឃើញថាជាទីកន្លែង ឬសភាពនានា ពោលគឺមនុស្សមានសម្រាប់អនាគតរបស់គេនូវសេចក្ដីទុក្ខមិនចេះចប់នៅក្នុងឋាននរក។ ដូចនេះមនុស្សមិនសាបសូន្យទេក្រោយពីការស្លាប់ តែសារជាតិរបស់គេបន្តទៅអនន្តភាព។

"អ្នកណាក៏ដោយដូចជា Schopenhaeur និយាយ ដែលចាត់ទុកខ្លួនឯងថា មិនបានក្លាយជាអ្វីសោះ ត្រូវគិតថាគេមិនក្លាយជាអ្វីថ្មីទៀតទេ។ ព្រោះថា អនន្តភាពបានរំលងទៅមុនពេលគេមាន ហើយនៅពេលនោះអនន្តភាពបន្ទាប់បានចាប់ផ្ដើម ដែលគេមិនអាចបញ្ឈប់ទៅជាអ្វីបាននោះគឺជាគំនិតដ៏ក្រៃលែង។"

ក្រុមគំនិតមួយដែលជឿអតីតកាល និងបច្ចុប្បន្នកាល មិនអះអាងថា មនុស្សសូន្យទេក្រោយពីស្លាប់ ឬក៏ពួកគេនិយាយថា មនុស្សត្រូវមានជាបន្តទៀតមិនដាច់បន្ទាប់ពីស្លាប់។ ពួកគេជឿទៅលើកំណើតអតីតកាលនិងអនាគតបន្តបន្ទាប់មិនចេះចប់។ ក្នុងទស្សនៈរបស់គេលំហូរជីវិតមនុស្ស ហូរ *ad infinitum* គ្មានទីបំផុតដរាបណា វាត្រូវបើកទៅមុខដោយ កម្លាំងកម្មចាស់ (អំពើរបស់គេ)។ នៅក្នុងទិសដៅសមស្រប សារជាតិរបស់មនុស្សអាចត្រូវ ទទួលយកឡើងវិញនៅក្នុង តថភាពកំពូល *(Paramatma)* ដែលព្រលឹងរបស់គេបានបាច ចេញមក។

ព្រះពុទ្ធជឿក្នុងបច្ចុប្បន្ន។ ដោយបច្ចុប្បន្នជាមូលដ្ឋាន ដែលគេជជែកវែកញែកពីអតីតកាល និង អនាគតកាល។ ប្រៀបដូចជាភ្លើងអគ្គិសនី គឺភាយចេញពីសញ្ញានៃថាមពលដែលមើលពុំឃើញ សូម្បីមនុស្សគឺគ្រាន់តែចេញពីសញ្ញានៃថា មពលដែលមើលមិនឃើញ ដែលគេដឹងថាជាកម្ម។ អំពូលអាចបែក ហើយពន្លឺ អាចរលត់តែចរន្តនៅមាន ហើយពន្លឺអាចបង្កើតឡើងវិញនៅក្នុងអំពូលដទៃទៀត។ នៅក្នុងវិធីដដែល នេះដែរកម្លាំងកម្មនៅមានដែលមិនត្រូវរាំងស្ទះដោយការ បែកជាបំណែកតូចនៃរាងកាយផ្នែករូបទេ ហើយការកន្លងផុតទៅនៃការ

យល់ឃើញបច្ចុប្បន្ន នាំទៅរកការកើតឡើងនៃ មនុស្សថ្មី ក្នុងកំណើតដទៃ ទៀត។ នៅទីនេះ ចរន្តអគ្គិសនីដូចកម្លាំង ហើយអំពូលត្រូវប្រៀបនឹងកោសិការសុតដែលផ្តល់ ដោយឪពុកម្តាយ។

កម្មចាស់កំណត់ដោយកំណើតបច្ចុប្បន្ន ហើយកម្មបច្ចុប្បន្នស្ថិតនៅត្រង់ការរួមបញ្ចូល ជាមួយកម្មចាស់ពោលគឺកំណត់អនាគតកាល។ បច្ចុប្បន្នគឺជាកូនចៅរបស់អតីតកាល ហើយក្លាយជាឪពុកនៃអនាគត។

កំណើតជាថ្មីដែលពុទ្ធសាសនិក មិនចាត់ទុកគ្រាន់តែជាទ្រឹស្តី តែចាត់ទុកថាជាការអះអាងពិតនោះបានបង្កើតនូវ គោលសំខាន់នៃលទ្ធិសាសនា ទោះបីគោលបំណងរបស់វា គឺនិញ្វន្តកំណត់នៅក្នុងជីវិត ផ្ទាល់នេះក៏ដោយ។ ឧត្តមគតិពោធិសត្វ និងលទ្ធិដែលជាប់ទាក់ទងគ្នានៃសេរីភាពចំពោះការសម្រេច ភាពឥតខ្ចោះទាំងស្រុងគឺ មូលដ្ឋានលើលទ្ធិនៃកំណើត។

កំណត់ត្រាឯកសារបង្ហាញថា ជំនឿក្នុងកំណើតថ្មីនេះ មើលឃើញថាជាសង្សារវដ្ត ឬការចាប់បដិសន្ធិជាថ្មី ត្រូវទទួលយកដោយទស្សនវិទូ ពី Pythagoras និង Plato កវីដូចជា Shelley, Tennyson និង Wordsworth និង មនុស្សធម្មតា១ជាច្រើននៅខាងបូព៌ាប្រទេស ក៏ដូចជានៅខាងបស្ចិមប្រទេស។

លទ្ធិពុទ្ធសាសនាកំណើតថ្មីគួរញែកឱ្យឃើញភាព ខុសប្លែកពីទ្រឹស្តីសង្សារវដ្ត និងការចាប់បដិសន្ធិថ្មីនៃប្រពន្ធ័ដទៃទៀត ពីព្រោះពុទ្ធសាសនាបដិសេធការកើតមាននៃព្រលឹងអចិន្ត្រៃយ៍ នៃវដ្តសង្សារ ដែលបង្កើតឡើងដោយព្រះ ឬការភាយចេញពី Paramatma (សារជាតិព្រះ)។

ភាពជាក់ស្តែងបច្ចុប្បន្ន មិនចាំបាច់បង្ហាញភស្តុតាងផ្ទាល់ខ្លួនទេ។ ការបង្ហាញអតីតកាលពឹងផ្អែកទៅលើការចងចាំ និងការរាយការណ៍ហើយការបង្ហាញអនាគតពឹងផ្អែកលើការគិតទុកជាមុន និងការសន្និដ្ឋាន។

គេប្រហែលប្រឆាំងថា ជីវិតពិតជាមានការចាប់ផ្តើមក្នុងអតីតកាលដែលគ្មានព្រំដែន និងជាការចាប់ផ្តើម ឬហេតុដំបូងជាអ្នកបង្កើត។

ក្នុងករណីនោះគ្មានហេតុផលថា ហេតុអ្វីបានជាតម្រូវការដូចគ្នាមិនត្រូវបានបង្កើតពីអ្នកបង្កើត។

"លើសពីនោះទៅទៀត ប្រសិនបើកំណើតគឺចាប់ផ្តើមដាច់ខាត បន្ទាប់មកការស្លាប់ ពិតជាបញ្ចប់ ហើយការសន្មតថា មនុស្សកើតចេញពីភាពទទេនាំឱ្យមានការសន្មតថា ការស្លាប់ជាទីបញ្ចប់ដាច់ខាតរបស់គេ"។

ដូចនេះការស្លាប់មិនមែន ជាការបំផ្លាញទាំងស្រុងនៃមនុស្សទេ។ សម្រាប់ការ គិតថា រយៈពេលនៃជីវិតណាមួយពី ដើមដល់ចប់ត្រូវបានបញ្ចប់ កម្លាំងដែលធ្វើឱ្យនេះឡើងរហូតដល់ពេលនេះមិនត្រូវបានបំផ្លាញទេ។

បន្ទាប់ពីការស្លាប់ដំណើរប្រែប្រួលនៃជីវិតមនុស្សបន្ត គ្មានទីបំផុតដរាបណា វាជោរជន់ដោយភាពល្ងង់ខ្លៅ និងចំណង់។ នៅក្នុងសព្ទទូទៅមនុស្សមិនចាំបាច់ កើតមកជាមនុស្សទេ ពីព្រោះមនុស្សមិនមែនជា ភាវៈដែលមានត្រឹមតែជីវិត មួយប៉ុណ្ណោះទេ។ លើសពីនេះទៀត ផែនដីដែលជាកម្មេចល្អិតស្ទើរគ្មាន ប្រយោជន៍ក្នុងចក្រវាឡ គឺមិនគ្រាន់តែជាកន្លែងមួយដែល គេនឹងស្វែងរកកំណើតថ្មីនោះទេ។ គេប្រហែលជាកើតក្នុងប្រភពនានាដទៃទៀត ដែលអាចរស់នៅបានទៀតផង។

ប្រសិនបើមនុស្សចង់កំណត់ទីបញ្ចប់ ចំពោះកំណើតមួយចំនួនដដែល១នោះ គេអាចធ្វើដូចជាព្រះពុទ្ធនិងព្រះអារហន្ត ដែលយល់ច្បាស់ពីនិញ្វនពោលគឺការរំលត់ចំណង់គ្រប់ ទម្រង់ទាំងអស់។

តើមនុស្សពិតជាទៅឯណា ? គេអាចទៅទីណាដែលគេចង់ទៅ ឬចូលចិត្តប្រសិនបើគេសមសម្រាប់វា។ ប្រសិនបើគេចាកចេញពីមាតាដែលត្រូវរៀបចំដោយរយៈពេលនៃព្រឹត្តិការណ៍ គេនឹងទៅកន្លែង ឬសភាពដែលគេសមនឹងទទួលយ៉ាងពេញលេញស្របនឹងកម្មរបស់គេ។

បើតាមគោលការណ៍ទេវវិទ្យា បានប្រឆាំងចំពោះ Spencer Lewis ថា "មនុស្សត្រូវបានបង្កើតឡើងតាមអំពើចិត្ត ដោយគ្មានតម្រូវការរបស់គេទេ ហើយខណៈពេលនៃការបង្កើតមានលក្ខណៈជាមានភ័ព្វផង និងឥតភ័ព្វផង ប្រសើរថ្លៃថ្លាផងនិងទុយិសផងតាំងពីជំហានដំបូងនៅក្នុងដំណើរនៃការបង្កើតរូបដល់ពេលនៃដង្ហើមចុងក្រោយរបស់គេ ដោយមិនគិតដល់តម្រូវការសេចក្តីសង្ឃឹម មហិច្ឆតា ការពុះពារឯកត្តភូត ឬអ្នកគោរពបូជាឡើយ។ លក្ខណៈបែបនេះមានឈ្មោះថា កម្មវាសនានិយមទេវវិទ្យា (theological fatalism)"។

"លទ្ធិដែលថា មនុស្សទាំងអស់ជាអ្នកមានបាបកម្ម ហើយមានកម្មសំខាន់នៃ Adam ជាការប្រជែងនឹងយុត្តិធម៌ សេចក្តីស្រឡាញ់ និងភាពសមរម្យដែលមានកម្លាំងមហិមា។"

Huxley និយាយថា ប្រសិនបើយើងចាំបាច់សន្មតថា នរណាម្នាក់បានកំណត់នូវចក្រវាឡដ៏អស្ចារ្យវាច្បាស់ណាស់ចំពោះខ្ញុំដែលថា គាត់មានបំណងអាក្រក់ និងអយុត្តិធម៌។

តាម Einstein "ប្រសិនបើភាវៈ(God)មានកម្លាំងមហិមា នោះគ្រប់ការកើតឡើង ដែលរួមមានសកម្មភាពមនុស្ស គំនិតមនុស្ស និងបំណងប្រាថ្នាជាស្នាដៃរបស់ព្រះអង្គផងដែរ។ តើអាចទៅរួចរបៀបណាចំពោះការអះអាងថា មានមនុស្សទទួលខុសត្រូវពីអំពើរបស់គេហើយ គំនិតនេះមានមុនភាវៈ Almighty ? ។"

ការបែងចែកទោស និងការផ្តល់រង្វាន់ត្រូវឆ្លងកាត់ការវិនិច្ឆ័យលើខ្លួនលោកផ្ទាល់ ។តើការ រួមបញ្ចូលភាពល្អ និង ភាពត្រឹមត្រូវអាចសន្មតចំពោះលោកដូចម្តេច ? "

យោងតាម Charles Bradlaught "ការកើតមានអំពើអាក្រក់ជាផ្នែកខុសចំពោះអ្នក ទេវវិទ្យា។ ការឈឺចាប់ ទុគតិភាព ឧក្រិដ្ឋកម្ម ភាពក្រីក្រប្រឈមជាមួយការគាំទ្រនៃអំពើល្អ ខាងក្នុង ហើយប្រជែងជាមួយភាពមានឥទ្ធិពល ដែលមិនអាចឆ្លើយបានពោលគឺការអះអាង របស់លោកចំពោះទេវភាពដែលល្អឥតខ្ចោះ (all-good) សព្វញ្ញូតញ្ញាណ (all-wise) និងសព្វឫ ទ្ធិចេស្តារ (all-powerful) ។

ការអធិប្បាយអំពី សេចក្តីទុក្ខរបស់មនុស្ស និងអាទិទេព លោកសាស្ត្រាចារ្យ J. B. S. Haldane បានសរសេរថា :

"ការឈឺចាប់ជាការចាំបាច់ចំពោះលក្ខណៈមនុស្សឥតខ្ចោះ ។អាទិទេពមិនមែនជា Ammighty ទេ។ ទ្រឹស្តីពីមុនបង្ហាញឱ្យដឹងខុសដោយហេតុថា មនុស្សមួយចំនួនបានរងទុក្ខតិច តែមានភព្វ ក្នុងខ្សែស្រឡាយរបស់គេ ហើយការអប់រំមានលក្ខណៈល្អ។ ការជំទាស់ចំពោះផ្នែក ទីពីរនេះ គឺថា វាគ្រាន់តែទាក់ទងជាមួយចក្រវាឡទាំងស្រុងមិនមែនគម្លាតណាមួយត្រូវបានបំពេញដោយ ការអះអាងរបស់ព្រះទេ។ អ្នកបង្កើត អាចបង្កើតអ្វីដែលគេចង់ ឬចូលចិត្ត។"

ក្នុងចំណងជើងមួយថា "ភាពអស់សង្ឃឹម" ជាកំណាព្យនៃយុគសម័យចាស់របស់លោក (Lord Tennyson) បានរិះគន់ ព្រះអាទិទេពយ៉ាងខ្លាំង ដូចការកត់ត្រាក្នុង Isaiah និយាយ ថា "ខ្ញុំបង្កើតសន្តិភាពហើយបង្កើតអំពើបាប ។"

"តើអ្វីទៅដែលខ្ញុំគួរតែអះអាងថា សេចក្តីស្រឡាញ់គ្មានទីបំផុតបានបម្រើយើងល្អនោះ ? ភាពឃោរឃៅ គ្មានទីបញ្ចប់ ប្រសើរជាងឋាននរកគ្មានទីបញ្ចប់ ។"

អ្នកសរសេរគម្ពីរនិយមបានប្រកាសជាផ្លូវការពីមុនថា ព្រះអាទិទេពបង្កើតមនុស្សបន្ទាប់ ពីរូបភាពផ្ទាល់របស់ព្រះអង្គ។ អ្នកគិតទំនើបខ្លះអះអាងផ្ទុយថា មនុស្សបង្កើតអាទិទេពបន្ទាប់ ពីរូបភាពផ្ទាល់របស់លោក។ មានការរីកចម្រើនអរិយធម៌ បញ្ញត្តិកម្មរបស់មនុស្សនៃព្រះ

អាទិទេពកាន់តែច្រើនឡើង ដែលត្រូវបានគេចម្រាញ់។ បច្ចុប្បន្នមានទំនោរភាពចំពោះការជំនួសព្រះផ្ទាល់ខ្លួននេះដោយអាទិទេពមិនផ្ទាល់មួយ។

លោក Voltaire អះអាងថា ព្រះអាទិទេពជាការបង្កើតដ៏ខ្ពង់ខ្ពស់បំផុតរបស់មនុស្ស។ យ៉ាងណាក៏ដោយ មិនអាចទៅរួចទេចំពោះការស្រមើលស្រមៃពីភាវៈ ដែលមានកម្លាំងមហិមា និងមានគ្រប់ទីកន្លែងបែបនេះបំពេញអ្វីៗដែលល្អទាំងក្នុងនិងក្រៅចក្រវាឡ។

អ្វីជាគោលបំណងនៃជីវិត? នោះជាសំណួរចុងក្រោយរបស់យើង និងជាសំណួរដែលមានការខ្វែងគ្នាផងដែរ។អ្វីជាទស្សនៈរូបធាតុនិយម? អ្នកវិទ្យាសាស្ត្រឆ្លើយថា *"តើជីវិតមានគោលបំណងដែរឬទេ ? ជាអ្វីនៅទីណាពេលណា ? ដោយសារលំហកើតនូវចក្រវាឡ ព្រះអាទិត្យ ផែនដី ជីវិត មនុស្ស និងអ្វីៗផ្សេងទៀតជាច្រើន។ ប៉ុន្តែដើម្បីគោលបំណង : របស់អ្នកណាពីពេលណា ? ហេតុអ្វី គឺគ្មានអ្នកណាសោះ។"*

ដូចអ្នករូបធាតុកំណត់ខ្លួនគេយ៉ាងច្បាស់ ចំពោះការយល់ដឹងតាមវិញ្ញាណ និងសុខុមាលភាពសម្ភារៈបច្ចុប្បន្នដោយព្រងើយកន្តើយនឹងតម្លៃស្មារតី។គេលើកឡើងប្រឆាំងនឹងអ្នកសីលធម៌។ នៅក្នុងទស្សនៈរបស់គេគ្មានគោលបំណងទេ ពោលគឺ ដូច្នេះមិនអាចមានជាគោលបំណងទេ។

"តើនរណាជាអ្នកលាបពណ៌ក្លោកល្អយ៉ាងនេះ ? នរណាជាអ្នកធ្វើឱ្យមាន់រងាវពិរោះ? នេះជាទឡ្ហីករណ៍ ដ៏ចម្បងរបស់អ្នករូបធាតុចំពោះការរួមចំណែកអ្វីៗ គ្រប់យ៉ាងចំពោះសណ្តាប់ធ្នាប់ធម្មជាតិនៃវត្ថុ។

"ការបរិភោគ ផឹក និងការសប្បាយរីករាយ សុទ្ធតែសម្រាប់ការស្លាប់ចូលមកដល់ទាំងអស់ដោយបញ្ចប់ជីវិតរបស់យើង" ហាក់ដូចជា ឧត្តគតិសីលធម៌នៃប្រព័ន្ធរបស់ពួកគេ។ ក្នុងទស្សនរបស់ពួកគេដូច Sri Radhakrishnan សរសេរថា គុណធម៌មិនជាការបោកប្រាស ហើយភាពរីករាយជាតថភាពតែមួយ។ ការស្លាប់ជាគោលបំណងចុង ក្រោយនៃជីវិត។ សាសនាជាជំងឺផ្លូវចិត។ មានការសង្ស័យពីអ្វីៗដែលល្អ ខ្ពស់បរិសុទ្ធនិងអាណិតអាសូរ។ ទ្រឹស្តីតំណាងឱ្យអ្នកត្រេកត្រអាល និងភាពអាត្មានិយម ហើយការអះអាងដោយកម្រនៃឆន្ទៈខ្លាំងខ្លា។ មិនចាំបាច់គ្រប់គ្រងចំណង់ និងសភាវគតិទេ ពីព្រោះពួកនេះជាកេរតំណែលពីធម្មជាតិរបស់មនុស្ស។ Sarvadarasana Sangraha និយាយថា "នៅពេលជីវិតជារបស់អ្នក ចូររស់នៅដោយសប្បាយ។ គ្មាននរណាអាចជៀសផុតពីការស្លាប់បានទេ។ អ្វីដែលយើងមាននឹងបាត់ទៅវិញ។ តើវាត្រឡប់មកវិញម្តេចកើត ?"

នៅពេលជីវិតនៅតែអនុញ្ញាតឱ្យមនុស្សរស់នៅដោយស្រួល ចាំបាច់ត្រូវតែមានចិត្តមេត្តា ទោះបីប្រឈមមុខនឹងបំណុលក៏ដោយ។ ឥឡូវចូរយើងត្រឡប់ទៅរកវិទ្យាសាស្ត្រ ដើម្បីទទួលបាននូវដំណោះស្រាយចំពោះចម្ងល់ថា "ហេតុអ្វី?"

វាគួរត្រូវបានគេកត់សំគាល់ថា "វិទ្យាសាស្ត្រ ជាការសិក្សាពីវត្ថុផ្សេងៗ ពោលគឺជាការសិក្សាពីអ្វីដែលមានសាសនាគឺជាការសិក្សាពីគំនិតពោលគឺសិក្សាពីអ្វីដែលគួរតែជារបស់នោះ"។

Sir J. ArthurTompson អះអាងថា វិទ្យាសាស្ត្រមិនពេញលេញ ព្រោះវាមិនអាចផ្តល់ចម្លើយនូវសំណួរ "ហេតុអ្វី ? "

ទាក់ទងជាមួយបំណងលោកធាតុ Bertrand Russell បានអះអាងប្រភេទបីយ៉ាង : វេទនិយមអ្នកដែលជឿ ឬធ្វើសក្ការៈគ្រប់អាទិទេពនិងអ្វីដែលផុសឡើង។

អ្នកសរសេរដំបូងលើកឡើងថាព្រះអាទិទេពបង្កើតពិភពលោកហើយដាក់បញ្ជានូវច្បាប់ធម្មជាតិ ពីព្រោះព្រះអង្គដឹងមុនថា ជាពេលដែលភាពល្អត្រូវបានធ្វើឱ្យចម្រើនឡើង។ នៅក្នុងទស្សនៈនេះគោលបំណងមានក្នុងចិត្តអ្នកបង្កើត ដែលនៅតែគ្មានទីបំផុតចំពោះការបង្កើតរបស់ព្រះអង្គ។

នៅក្នុងទម្រង់ប៉ង់តេអ៊ីស ព្រះអាទិទេពមិនមែនគ្មានទីបញ្ចប់ចំពោះចក្រវាឡទេ គ្រាន់តែចក្រវាឡត្រូវគេចាត់ទុកថា ជាភាពធំទូលាយ។ ដូចនេះមិនអាចជាអំពើ នៃការច្នៃប្រឌិតទេ តែមានប្រភេទនៃកម្លាំងបង្កើតក្នុងចក្រវាឡដែលជា មូលហេតុឱ្យវាអភិវឌ្ឍតាមផែនការ ដែលត្រូវបានគេនិយាយថា មាននៅក្នុងគំនិត។

"នៅក្នុងទម្រង់លេចឡើង គោលបំណងមានលក្ខណៈកាន់តែងងឹត។ នៅក្នុងដំណាក់កាលដើមគេ គ្មានអ្វីនៅក្នុង ចក្រវាឡមើលឃើញពីដំណាក់ចុងក្រោយគេនោះទេ ប៉ុន្តែ ប្រភេទនៃងងឹត (blind impulsion) ដឹកនាំទៅរកបំលាស់ប្តូរទាំងអស់នោះដែលនាំឱ្យមានទម្រង់អភិវឌ្ឍកាន់តែច្រើនឡើងៗចូលទៅក្នុងអត្ថិភាព ដូច្នេះនៅក្នុងស្មារតីរាងងងឹតបន្តិច ណាមួយទីបញ្ចប់មានលក្ខណៈបញ្ជាក់ទាំងស្រុងនៅក្នុងចំណុចចាប់ផ្តើម។"

ទាំងនេះគ្រាន់តែជា ទស្សនៈនៃអ្នកសាសនាខុសគ្នា និងអ្នកគិតដ៏ខ្ពង់ខ្ពស់។ ការបង្ហាញនូវទស្សនៈផ្ទាល់របស់លោកអំពីបំណងលោកធាតុ Russell បានប្រកាសថា "ហេតុអ្វីបានជាក្នុងករណីណាមួយ មានការលើកតម្កើងមនុស្ស? ចុះតោ និងខ្លាយ៉ាងម្តេចដែរ? ពួកវាបំផ្លាញសត្វតិចជាង ឬជីវិតមនុស្សច្រើនជាងតើពួកវាល្អជាងយើងទេ ? ចុះសត្វស្រមោចដូចម្តេចដែរ ?

ពួកវាគ្រប់គ្រង រដ្ឋប្រតិបត្តិ ការបានល្អច្រើនជាងពួកហ្វាសស៊ីស (Fascist) ដែរឬទេ ? ។ តើមិនមែនពិភពបក្សី និងសត្វក្ដាន់ល្អជាងពិភពមនុស្សដែល ពោរពេញដោយភាពអយុត្តិធមិសង្គ្រាមឃោរឃៅឬ? ។ អ្នកជឿទៅលើគោលបំណងរូបធាតុមានច្រើនចំពោះបញ្ហា ប្រសិនបើខ្ញុំត្រូវបានគេផ្ដល់ឱ្យនូវ សព្វានុភាពរាប់លានឆ្នាំដើម្បីធ្វើពិសោធន៍ទៅលើវាប្រហែលខ្ញុំយល់ពីវាហើយមើលទៅ" ។ ឥឡូវតើព្រះពុទ្ធសាសនាឆ្លើយនឹងសំណួរថា "ហេតុអ្វី" នេះយ៉ាងណា ?

ព្រះពុទ្ធសាសនាបដិសេធការកើតមាននៃអ្នកបង្កើត ។ ចេញពីទស្សនៈនេះព្រះពុទ្ធមិនអាចមានគោលបំណងដែលកំណត់ទុកជាមុនទេ ព្រះពុទ្ធមិនគាំទ្រជំនឿលើសាសនា ការកំណត់និយម ដែលគ្រប់គ្រងអនាគតរបស់ មនុស្សផ្ដាច់ចេញពីសកម្មភាព សេរីរបស់គេទេ ។ នៅក្នុងករណីបែបនេះឆន្ទៈសេរីក្លាយជាកម្លាំងដាច់ខាត ហើយជីវិតក្លាយជាយន្តការសុទ្ធសាធ ។

ចំពោះសកម្មភាពរបស់មនុស្ស ដែលមានវិសាលភាពទូលំទូលាយមួយមានលក្ខណៈ តិចឬច្រើនទទួលឥទ្ធិពលដោយអំពើរបស់គេ បរិស្ថាន និងជំនឿ តែមនុស្សអាចហ្វឹកហាត់នូវឆន្ទៈសេរីរបស់ខ្លួន ។ ឧទាហរណ៍ មនុស្សធ្លាក់ពីលើភ្នំ នឹងត្រូវទាញមកក្រោម ។

នៅទីនេះគេមិនអាចប្រើឆន្ទៈសេរីរបស់គេទេ ទោះបីគាត់មានគំនិតមិនដូចថ្មក៏ដោយ ។ ប្រសិនបើគេចាំបាច់ត្រូវ ឡើងច្រាំងភ្នំគាត់អាចប្រើប្រាស់ឆន្ទៈសេរី ហើយធ្វើសកម្មភាពដូចដែលគាត់ចូលចិត្ត ដែលផ្ទុយពីថ្ម ។ មនុស្សមានអំណាច ជ្រើសរើសអ្វីដែលត្រូវ និងអ្វីដែលខុសល្អនិងអាក្រក់ ។ មនុស្សអាចធ្វើជាសត្រូវ ឬធ្វើជាមិត្តចំពោះខ្លួនគាត់ និងអ្នកដទៃ ។ ទាំងអស់ពឹងផ្អែកទៅលើគេ និងការអភិវឌ្ឍន៍របស់វា ។

ទោះបីគ្មានគោលបំណងច្បាស់លាស់ក្នុងអត្ថិភាពរបស់មនុស្ស តែមនុស្សមានសេរីភាពក្នុង ការជ្រើសរើសគោលបំណងមួយចំនួនក្នុងជីវិត ។ ដូចនេះ តើអ្វីទៅជាអត្ថន័យនៃជីវិត?

Ouspensky សរសេរថា : ខ្លះនិយាយថា អត្ថន័យជីវិត គឺស្ថិតនៅក្នុងទង្វើ ក្នុងការចុះចាញ់ ចំពោះអត្តៈក្នុងស្វ័យពលិកម្មក្នុងពលិកម្មនៃអ្វីៗ គ្រប់យ៉ាងសូម្បីជីវិតខ្លួនវាក៏ដោយ ។ អ្នកឯទៀតប្រកាសថា អត្ថន័យនៃជីវិតគឺ ស្ថិតនៅក្នុងភាពរីករាយរបស់វាប្រឆាំងទល់នឹង "ក្ដីអស់សង្ឃឹម ចំពោះការស្អប់ខ្ពើមចំពោះសេចក្ដីស្លាប់ចុងក្រោយស្លាប់" ។ អ្នកខ្លះថា អត្ថន័យនៃជីវិតស្ថិតនៅ ក្នុងភាពឥតខ្ចោះ ហើយការបង្កើតនូវអនាគតដ៏ប្រសើរហួសពីផ្នូរខ្មោច(the grave) ឬនៅក្នុងជីវិតអនាគតសម្រាប់ខ្លួនយើង ។ អ្នកដទៃទៀតថា អត្ថន័យនៃជីវិតស្ថិតនៅក្នុងការឈានដល់ការគ្មានអត្ថិភាពអ្នកដទៃទៀតថា ខ្លឹមសារជីវិតស្ថិតនៅលើសុក្រិតភាពនៃពូជសាសន៍ ។

ការរិះគន់ទស្សនៈទាំងអស់នេះ អ្នកនិពន្ធបាននិយាយថា កំហុសនៃការពន្យល់ទាំងអស់នេះមាននៅក្នុងហេតុដែលថា គេទាំងអស់ប៉ុនប៉ងរកឱ្យឃើញនូវអត្ថន័យនៃជីវិត ក្រៅពីខ្លួនវាផ្ទាល់ ទាំងនៅក្នុងធម្មជាតិមនុស្សទាំងនៅក្នុងការកើត មាននូវបញ្ហាមួយចំនួនដែលសំខាន់។ មនុស្សគួរសម្លឹងមើលខ្លួនគេ ហើយយល់ថា នៅក្នុងតថភាពអត្ថន័យនៃជីវិត មិនមែនបន្ទាប់ពីអ្វីដែលពិបាកយល់នោះទេ គឺវារួមមាននៅក្នុងពុទ្ធិ។

តាមទស្សនៈពុទ្ធសាសនិក អត្ថន័យនៃជីវិតគឺ សម្ពោធិ (Sambodhi) ដូចជាការដឹងខ្លួនឯងពិត។ នេះប្រហែលជា ត្រូវបានសម្រេចតាមរយៈសីលវប្បធម៌ផ្លូវចិត្ត និងការយល់ដឹងធ្លុះឬក្នុងពាក្យដទៃទៀតតាមរយៈទង្វើ និងភាពឥតខ្ចោះ។

នៅក្នុងការបម្រើរួមបញ្ចូលនូវការស្រឡាញ់ករុណាធម៌ និងមេត្តាធម៌គ្មានព្រំដែនហើយមិនគិតពី ខ្លួនឯងដែលជំរុញឱ្យមនុស្សធ្វើចំពោះអ្នកដទៃ។ ភាពឥតខ្ចោះដែលទាក់ទងទៅនឹងភាពបរិសុទ្ធនិងគតិបណ្ឌិត។

### ៣-បំណងនៃជីវិត (The Purpose of Life) By Ven. Dr. K. Sri Dhammananda

តើអ្វីជាបំណងនៃជីវិត ? នេះគឺជាសំណួរដ៏សាមញ្ញបំផុតដែលមនុស្សយើងតែងតែសួរ។ វាមិនមែនជា ការងាយស្រួលទេដើម្បីផ្តល់នូវចំលើយពេញចិត្តមួយចំពោះសំណួរ ដែលនៅតែស្មុគស្មាញ ហើយមើលទៅហាក់ដូចជាសាមញ្ញនេះ។ ទោះបីជាមានមនុស្សបានផ្តល់នូវចម្លើយជាក់លាក់ទៅតាមរបៀបគិតរបស់ពួកគេរៀងៗ ខ្លួនក្តីក៏វាហាក់ដូចជាថា វាមិនមែនជាចម្លើយជាទីពេញចិត្តចំពោះអ្នកប្រាជ្ញទាំងឡាយឡើយ។ ហេតុផលគឺថា ពួកគេមិនបានសិក្សាឱ្យដឹងពីជីវិតប្រកបដោយគោលបំណង និងយល់នូវទស្សនៈត្រឹមត្រូវនៃជីវិតឡើយ។ ពួកគេបានបង្កើតនូវការស្រមើស្រមៃពីជីវិត តាមរយៈការយល់ដឹងដែលមានកំរិតរបស់ពួកគេ។ ព្រមពេលជាមួយគ្នានេះដែរ យើងយល់ថា គ្រូបង្រៀនសាសនាជាច្រើនទស្សនវិទូដ៏ល្បីៗកវីដ៏ល្បីល្បាញ និងអ្នកគិតដ៏ល្បីៗទាំងឡាយ ក៏មិនបានធ្វើឱ្យមានការពេញចិត្តពេញថ្លើម អំពីធម្មជាតិនៃជីវិតនេះដែរ។ អ្នកខ្លះបាននិយាយថា ជីវិតគឺពោរពេញដោយការឈឺចាប់មិនមានភាពទៀងទាត់ និងមិនមានភាពស្កប់ស្កល់។ អ្នកខ្លះបាននិយាយថា *"វាជាការប្រសើរ ប្រសិនបើយើងមិនមានកំណើតមក"*។ អ្នកខ្លះទៀតបានសួរថា : " ហេតុអ្វីបានជាយើងកើតមក លើពិភពលោកនេះដើម្បីឈឺចាប់ដោយគ្មានន័យយ៉ាងនេះ ? "។

ផ្អែកលើការនិយាយរបស់ពួកគេ យើងអាចយល់បានថា ពួកគេគឺជាមនុស្សដែលបានសិក្សាយល់ដឹងពី ជីវតប្រកបដោយគោលបំណង ដូចដែលវាមានពិត។ ប៉ុន្តែមនុស្សសាមញ្ញតែងមើលឃើញជីវិតដូចដែលវា បង្ហាញយ៉ាងរាក់កំផែល មិនមែនដូចដែលវាមានពិតនោះទេ។ " ជីវិតគឺមិនមែនជាអ្វីដែលយើងគិតថា ជីវិតនោះទេ ប៉ុន្តែអ្វីដែលយើងគិតក្លាយជាជីវិត "។

នេះគឺជាសំដីមួយទៀត របស់អ្នកគិតដ៏ល្បីល្បាញម្នាក់។

អ្នកខ្លះនិយាយថា មិនមានគោលបំណងជាក់លាក់នៅក្នុងជីវិតទេ ប៉ុន្តែគេអាចប្រើវាសម្រាប់គោលបំណងណាមួយ។ វាមានអ្វីម្យ៉ាងនៅក្នុងសំដីនេះសំរាប់ឱ្យយើងត្រិះរិះ ប្រកបដោយគតិបណ្ឌិត : ដើម្បីឱ្យមានការប្រើប្រាស់ជីវិតសម្រាប់គោលបំណង ដែលមានប្រយោជន៍ចំពោះខ្លួនយើង និងចំពោះមនុស្សជាតិជំនួសឱ្យការទុកវាចោលដោយល្ងីល្ងើ។ នៅក្នុងលក្ខណៈនេះគេអាចនិយាយថា គោលបំណងជីវិតគឺផ្អែកលើវិធីដែលយើងដោះស្រាយនិងប្រើប្រាស់វា។ ប្រសិនបើយើងប្រើវាខុស ដោយការរំលោភលើគុណសម្បត្តិដែលចេះជួយ សង្គ្រោះគ្នាដ៏ល្អរបស់យើង ដោយការបំពានលើសេចក្តីថ្លៃថ្នូរជាមនុស្សរបស់យើង និងការប្រព្រឹត្តសកម្មភាព មិនសមរម្យដោយការផ្តល់ វិធីដល់ភាពខ្សោយរបស់យើង នោះវាមិនអាចទៅរួចទេសំរាប់យើងដើម្បីសម្រេចនូវ អ្វីដែលមានប្រយោជន៍ និងសេចក្តីថ្លៃថ្នូរដូចបំណងនៃជីវិតរបស់យើង។ ប៉ុន្តែប្រសិនបើយើងប្រព្រឹត្តអំពើប្រកបដោយគតិបណ្ឌិតនិងយកចិត្តទុកដាក់ដោយការប្រតិបត្តិតាមគោលការណ៍ដែលត្រឹមត្រូវ និងប្រកបដោយសីលធម៌ដែលបានទទួលស្គាល់ជាសកល ការហាត់អត់ធ្មត់ ការអត់ឱនការអាណិតអាសូរការបន្ទាបខ្លួន និងភាពសប្បុរស នោះវាបង្កើតនូវការយល់ដឹងនិងផ្តល់នូវការបម្រើ ដែលមិនគិតពីខ្លួនឯងហើយហ្វឹកហ្វឺនគំនិតឱ្យទទួលបាននូវគតិបណ្ឌិតដែលយើងអាចសំរេចនូវអ្វីដែលមានប្រយោជន៍ និងប្រកបដោយសេចក្តីថ្លៃថ្នូរចំពោះទាំងអស់គ្នាដូចគោលបំណងនៃជីវិតរបស់យើង។ ទាំងអស់នោះដែលជាអ្នកបង្កើតនូវគុណធម៌ ទាំងនេះនឹងធ្វើពិសោធ សន្តិភាព សុភមង្គល ការស្ងប់ស្ងាត់ សេចក្តីពេញចិត្ត និងភាពស្ងប់។ ដូច្នេះជីវិតមានប្រយោជន៍វាជាសេចក្តីរីករាយសម្រាប់ការរស់នៅ !

**ធម្មជាតិនៃជីវិត** ( Nature of Life )

អ្នកសិក្សាម្នាក់និយាយថា " ជីវិតបំផ្លាញខ្លួនឯងនៅពេលដែលយើងត្រៀមដើម្បីរស់ "។ អ្នកសិក្សាម្នាក់ទៀតនិយាយថា "ជម្ងឺចាស់ជរានិងទុក្ខវេទនាគឺជាការលះបង់ដែលយើងកំពុងធ្វើដើម្បីទទួលបាននូវខ្លួនប្រាណដូច ជាផ្ទះមួយអញ្ចឹងដែរ "។ " យើងត្រូវតែចំណាយតម្លៃនៃ

ការភ័យខ្លាច និងសេចក្តីព្រួយបារម្ភដើម្បីរស់នៅជាមនុស្ស "។ នេះគឺជាសំដីមួយទៀតរបស់អ្នកសាសនាម្នាក់ ។នៅពេលដែលយើងគិតពិចារណាពីទស្សនៈទាំងអស់នេះ យើងអាចរកឃើញនូវធម្មជាតិនៃជីវិត និងការសន្និដ្ឋានប្រសិនបើមានគោលបំណងណាមួយនៃជីវិត ។

ប្រសិនបើយើងបំពេញចិត្តតែចំពោះវិញ្ញាណ របស់យើងជាគោលបំណងនៃជីវិតរបស់យើង នោះយើងត្រូវត្រៀមខ្លួនដើម្បីប្រឈមមុខនឹងបញ្ហាផ្សេងៗដែលកើតឡើងពីបញ្ហានោះ នៅពេលដែលគ្មាននរណាម្នាក់ អាចទទួលយកនូវសេចក្តីសប្បាយរីករាយដោយ គ្មានប្រឈមមុខនឹងបញ្ហាទាំងឡាយ ។

ទោះបីជាអ្នកវិទ្យាសាស្ត្រ បានរកឃើញនូវវត្ថុដ៏អស្ចារ្យជាច្រើននៅក្នុងលោកនេះក្តី ក៏ពួកគេនៅតែមិន ដឹងពីគោលបំណងនៃជីវិតដែរ ។

ចំពោះចរិយាមាយាទរបស់មនុស្សវិញ អ្នកប្រាជ្ញមួយរូបបាននិយាយថា : " មនុស្សមិនមែនអ្វីដែលជា គាត់នោះទេ មនុស្សគឺជាអ្វីដែលមិនមែនជាគាត់ " ( " Man is not what he is, man is what he is not ") តាមគាត់ មនុស្សមិនប្រព្រឹត្តចរិយាជា "*មនុស្ស*" ពិតប្រាកដម្នាក់នោះទេ។ តាមពុទ្ធសាសនា មនុស្សមិនមែន ជាអង្គនាមសត្វដែលមិនប្រែប្រួលនោះទេ ប៉ុន្តែជាការបញ្ជាក់បង្ហាញ ដែលមានន័យត្រង់ៗតែពីពេលវេលាមួយ ទៅពេលវេលាមួយដោយផ្អែកលើមូលដ្ឋាននៃថាមពល ។ អ្នកប្រាជ្ញម្នាក់ទៀតនិយាយថា : " *គ្មានការកែប្រែចំពោះកំណើត និងការស្លាប់ឡើយតែ គឺរក្សាទុកដើម្បីទទួលបាននូវរយៈពេលចន្លោះនេះ* " ។

យើងមិនអាចយល់ពីធម្មជាតិពិតនៃជីវិតបានទេ ដោយសារចំណង់ខ្លាំង និងភាពអវិជ្ជារបស់យើង ។ នោះជាមូលហេតុដែលយើងនៅទីនេះដើម្បីឈឺចាប់ ។ នោះជាមូលហេតុដែលមានការលំបាកចំពោះយើងដើម្បីរកឃើញថា តើមានគោលបំណងជាក់លាក់ណា មួយនៅក្នុងជីវិតនៅក្នុងលោកនេះ និងនៅក្នុងទម្រង់នេះ ឬ ទម្រង់នោះខុសឬយ៉ាងណា ។

ជីវិតត្រូវបានបកស្រាយថា ជាការរួមផ្សំនៃគំនិត និងរូបធាតុ ។ ជាលទ្ធផលនៃការរួមផ្សំនេះភាវៈមួយបានកើតមានឡើង ហើយវាធ្វើដំណើរលើការប្រែប្រួលរហូតដល់វារលាយបាត់ទៅវិញ ។ ទោះជាយ៉ាងណាក៏ដោយថាមពលគំនិតប្រាជ្ញាដែលបានស្លាប់ទៅ បានរួមផ្សំឡើងវិញជាមួយធាតុទាំងឡាយ ឬរូបធាតុដែលបង្ហាញឡើងវិញនៅក្នុងទម្រង់ផ្សេងៗ និងនៅក្នុងគោលផ្សេងគ្នាជាជីវិតដែលអនុលោមទៅតាមធម្មជាតិនៃជីវិត ពីមុនរបស់នរណាម្នាក់ ។ និរន្តភាពនៃ

ខ្សែជីវិតនេះប្រព្រឹត្តទៅសារចុះសារឡើងជារហូតដំរាបណាកម្លាំងនៃកម្ម (Karmic energy) និងចំណង់ខ្លាំងចំពោះជីវិតនៅតែមាន ។

**ខន្ធទាំង៥** ( The Five Aggregates )

តាម Dhamma ជីវិតមានធាតុទាំងអស់ប្រាំ ។ ធាតុទាំងនេះមាន : Rupa រូបក្ខន្ធ ( matter ) / Vedana វេទនាក្ខន្ធ ( feeling ) / Sanna - សញ្ញាក្ខន្ធ ( perception )/ Sankhara - សង្ខារខន្ធ ( mental formation ) និង Vinnana - វិញ្ញាណក្ខន្ធ ( consciousness ) ។ បួនប្រភេទនៃធាតុទាំងឡាយដូចជា ភាពប្រាកដប្រជា ( solidity ) ការប្រែប្រួល ( fluidity ) កំដៅ ( heat) និងចលនារួមនឹងរូប ។ រូបរួមផ្សំនឹងកត្តាទាំងឡាយនៃខួរក្បាល៤ ដែលបានបែងចែក ខាងលើ ដូចជា វេទនាក្ខន្ធ សញ្ញាក្ខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ រួមផ្ដុំគ្នាទាំងអស់បង្កើតបានជាជីវិត ។ ធម្មជាតិពិតនៃខន្ធទាំង៥នេះគឺត្រូវបានពន្យល់បកស្រាយ នៅក្នុងការបង្រៀនរបស់ព្រះពុទ្ធដូចតទៅ រូបក្ខន្ធប្រៀបបានទៅនឹងដុំពពុះ វេទនាក្ខន្ធគឺដូចជាខ្យល់ សញ្ញាក្ខន្ធត្រូវបានបកស្រាយថាជាមិរិចិកា( ក្ដីស្រមៃដែលមិនអាចក្លាយជាការពិត) សង្ខារក្ខន្ធគឺដូចជាដើមចេកហើយវិញ្ញាណក្ខន្ធគឺគ្រាន់តែជាមាយាកា (ដំណើរភាន់នៃវិញ្ញាណឬគំនិត) ។ ជាមួយនឹងការវិភាគពីជីវិតនេះ គឺវាមានការលំបាកដើម្បីធ្វើឱ្យដឹងប្រាកដពីភាពជាក់លាក់ ឬបំណងនៃជីវិតថាជាអ្វីនោះ ។

ការវិភាគពីជីវិតនេះបានធ្វើឱ្យមានទំនាស់ដ៏ធំចំពោះជំនឿសាសនា និងទស្សនវិជ្ជាច្រើននៅសម័យ នោះ ។

គ្មានវត្ថុណាមានជីវិតជាអមតៈ ដែលស្ថិតនៅដោយគ្មានការប្រែប្រួលនិងគ្មានការរលាយទៅវិញនោះឡើយ ។

រូបគឺគ្មានអ្វីទាំងអស់ ប៉ុន្តែជាឱកាសកម្មអរូបីសំរាប់ការប្រែប្រួល ជាដំរាបនូវការរួមផ្សំនៃធាតុគីមី ។ មនុស្សចាប់ផ្ដើមមើលឃើញជីវិតផ្ទាល់របស់ខ្លួនជាទឹកមួយដំណក់នៅក្នុងទន្លេដែលហូរឥតឈប់ឈរហើយមានសេចក្ដីរីករាយដើម្បីចូលរួមចំណែកចំពោះខ្សែជីវិតដ៏វែងឆ្ងាយ ។

**ពិភពនៃវដ្តសង្សារ** ( A World of Waves )

ការវិភាគបែបវិទ្យាសាស្ត្រអំពីសាកលលោកបង្ហាញថា ពិភពលោកគឺគ្មានអ្វីទាំងអស់ប៉ុន្តែមានចលនា ឥតឈប់ឈរដែលមិនអាចបំបាត់បាន ។ Dr. Einstein បាននិយាយថា : គ្រប់រូបធាតុទាំងអស់គឺកើតឡើងពីវដ្តសង្សារ (Waves) ហើយយើងរស់នៅក្នុងពិភពនៃវដ្តសង្សារ ។

*" យើងជាផ្នែកនៃវដ្តសង្សារដូចគ្នា ។ (" We are part of the same waves) ។ ប្រសិនបើមនុស្សម្នាក់អាចដឹង : If a man can be aware "* ។

-ពីស្ថានភាពនៃរាងកាយរបស់គេ *of the states of his body,*

-ពីអារម្មណ៍របស់គេ *of his feelings,*

-ពីស្ថានភាពនៃគំនិត និង *of the states of his mind and*

-ពីស្ថានភាពនៃកម្មវត្ថុទាំងឡាយខាងគំនិតប្រាជ្ញរបស់គេ, *of the states of mental objects,* ការយល់ដឹងបែបនេះនឹងនាំគេឱ្យរកឃើញថាតើមានគោលបំណងណាមួយនៅក្នុងជីវិត ”។ such an awareness will lead him to find out whether there is any purpose in life.")

**កែប្រែខ្លួនអ្នក** ( Change Yourself )

តើអ្នកអាចសម្រេចនូវសុក្រឹតភាពដោយការកែប្រែពិភពលោកបានទេ? គឺមិនអាច។ គឺមានតែអ្នកប៉ុណ្ណោះដែល អាចដឹងពីតុច្ឆភាពរបស់ខ្លួន និងបង្ក្រាបអត្តទត្ថភាពរបស់ខ្លួនបាន។ អ្នកនឹងត្រូវចងជាប់ទៅនឹងកង់នៃសង្សារ ( *Samsara* )។ ប៉ុន្តែតាមរយៈការកែប្រែខ្លួនឯង តាមរយៈការដឹងនូវធម្មជាតិខ្លួនដោយបរិច្ចាគ ស្វ័យវិន័យ និងការខំប្រឹងប្រែងដោយខ្លួនឯង នោះអ្នកអាចសម្រេចបាននូវសុក្រឹតភាព។ តាមរយៈការសំរេចនូវសុក្រឹតភាព នេះ គឺអ្នកកំពុងផ្តល់នូវការបម្រើចំពោះមនុស្សជាតិដ៏ធំធេង។ មនុស្សនឹងត្រូវបានអូសទាញដោយឧទាហរណ៍ របស់អ្នកហើយពួកគេនឹងដើរតាមអ្នក និងសម្រេចនូវគោលដៅជីវិតផងដែរ។

មនុស្សសព្វថ្ងៃគឺជាលទ្ធផលរាប់លាននៃសកម្មភាព និងគំនិតកន្លងមករបស់គេ។គេមិនទាន់ត្រូវបានកសាងរួចរាល់នៅឡើយទេ គេកំពុងក្លាយនិងបន្តក្លាយជាមនុស្ស។ ចរិតលក្ខណៈរបស់គេគឺត្រូវបានកំណត់ ដោយការគិតផ្ទាល់របស់គេ។ តាមធម្មជាតិ មនុស្សគឺមិនមានសុក្រឹតទេ គេត្រូវតែហ្វឹកហាត់ខ្លួនគេដើម្បីបានសុក្រឹត។

ជីវិតមិនមែនជាកម្មសិទ្ធិតែចំពោះមនុស្សមួយនោះទេ។ ទម្រង់ជាច្រើនទៀតនៃជីវិតគឺមានអត្ថិភាពនៅក្នុងសាកលលោកនេះ។ តែទោះជាយ៉ាងណាក៏ដោយ គឺមនុស្សមានអំណាចវិចារណញ្ញាណ និងការគិតប្រសើរជាង។ ហេតុនេះពួកគេមានលក្ខណៈខ្ពស់ជាងភាវៈមានជីវិតដទៃទៀត ព្រោះពួកគេមានបញ្ញាដើម្បីអប់រំផ្លូវ ជីវិតរបស់គេក្នុងគោលបំណងកំចាត់ចេញនូវការឈឺចាប់ផ្នែកលោកិយរបស់ខ្លួន។ ដូច្នេះប្រសិនបើគោលបំណង នៃជីវិតគឺគ្រាន់តែដើម្បីកំចាត់ចេញនូវការឈឺចាប់ទេ អញ្ចឹងមនុស្សអាចសម្រេចបំណងនោះតាមរយៈការប្រឹង ប្រែងផ្ទាល់របស់ខ្លួន។ប៉ុន្តែជីវិតនឹងទទួលបរាជ័យប្រសិនបើវាមិនត្រូវបានប្រើឱ្យបានត្រឹមត្រូវទេនោះ។

ព្រះពុទ្ធបានសង្កត់ធ្ងន់លើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងនិយាយពីតម្លៃមនុស្ស។ ព្រះអង្គបានគូររូបភាព មនុស្សដ៏ប្រណិតបំផុត ដែលបង្ហាញពីការខិតខំ និងការពុះពារយ៉ាងខ្លាំង

ដើម្បីរស់ក្នុងការស្វែងរកសុក្រឹតភាពរបស់គេ។ ជីវិតគឺជាបទពិសោធន៍ប្លែកមួយ។ មិនមានអ្វីដែលអាចប្រៀបជាមួយនឹងវាបានទេ មិនមានរង្វាស់ពីតម្លៃរបស់វាដូចវត្ថុខ្លះទៀតឡើយហើយលុយមិនអាចទិញវាបានឡើយ។ ប៉ុន្តែមនុស្សជាច្រើនមិនបានរៀនពី អ្វីដែលត្រូវធ្វើជាមួយនឹងរបស់ដែលមិនអាចកាត់ថ្លៃបាន (priceless pearl) នេះឡើយ។ នៅទីនេះជីវិតមិនមានន័យគ្រាន់តែជារូបកាយខាងរូបវិទ្យា ឬវិញ្ញាណទាំងឡាយនោះឡើយប៉ុន្តែជាសតិមនុស្សប្រកបដោយបញ្ញា។

**បួនប្រភេទនៃមនុស្ស** ( Four Types of Men )

ព្រះពុទ្ធបានបែងចែកមនុស្សជាតិទាំងអស់ជា៤ក្រុម :

- អ្នកដែលធ្វើដើម្បីសេចក្តីល្អខ្លួនឯង ប៉ុន្តែមិនដើម្បីសេចក្តីល្អរបស់អ្នកដទៃ
- អ្នកដែលធ្វើដើម្បីសេចក្តីល្អអ្នកដទៃ ប៉ុន្តែមិនដើម្បីសេចក្តីល្អរបស់ខ្លួន
- អ្នកដែលធ្វើមិនដើម្បីសេចក្តីល្អខ្លួនឯង និងអ្នកដទៃ
- និងអ្នកដែលធ្វើដើម្បីសេចក្តីល្អខ្លួនឯង និងអ្នកដទៃ

តើនរណាជាមនុស្សដែលធ្វើដើម្បីសេចក្តីខ្លួនឯង ប៉ុន្តែមិនដើម្បីសេចក្តីល្អអ្នកដទៃ ? គឺមនុស្សដែលខំ ប្រឹងដើម្បីរំងាប់សេចក្តីលោភសេចក្តីស្អប់ និងសេចក្តីភាន់ខាងវិញ្ញាណ ឬគំនិតនៅក្នុងខ្លួន ប៉ុន្តែគេមិនបានជំរុញ ឱ្យអ្នកផ្សេងរំងាប់សេចក្តីលោភ សេចក្តីស្អប់ និងសេចក្តីភាន់ខាងវិញ្ញាណឬគំនិតនោះទេ ហើយក៏មិនធ្វើអ្វីដើម្បីសុខុមាលភាពអ្នកដទៃដែរ។

តើនរណាជាមនុស្សដែលធ្វើដើម្បីសេចក្តីល្អអ្នកដទៃ ប៉ុន្តែមិនដើម្បីសេចក្តីល្អខ្លួនឯង? គឺមនុស្សដែល ជំរុញអ្នកដទៃឱ្យបំបាត់ភាពខ្សោយរបស់មនុស្ស និងធ្វើការបំរើខ្លះចំពោះអ្នកទាំងនោះ ប៉ុន្តែខ្លួនឯងមិនបានព្យាយាមដើម្បីបំបាត់ភាពខ្សោយរបស់ខ្លួនឡើយ។

តើនរណាជាមនុស្ស ដែលមិនធ្វើដើម្បីសេចក្តីល្អខ្លួនឯង និងអ្នកដទៃ? គឺមនុស្សដែលមិនព្យាយាមដើម្បី បំបាត់ភាពខ្សោយរបស់ខ្លួន និងមិនជំរុញឱ្យអ្នកដទៃបំបាត់ភាពខ្សោយផ្សេងទៀត និងមិនបានធ្វើការបំរើខ្លះចំពោះអ្នកទាំងនោះ។

តើនរណាជាមនុស្សដែលធ្វើដើម្បីសេចក្តីល្អខ្លួនឯង និងអ្នកដទៃ? គឺមនុស្សដែលបំបាត់គំនិតអាក្រក់ ចេញពីក្នុងគំនិតរបស់ខ្លួន ហើយព្រមពេលជាមួយគ្នានោះដែរគឺជួយអ្នកដទៃឱ្យបានប្រសើរឡើង។

**ជីវិតជាការឈឺចាប់**

ប្រសិនបើយើងគិតឱ្យបានស៊ីជម្រៅ យើងត្រូវតែយល់ស្របជាមួយនឹងគំនិតថា ជីវិតជាការឈឺចាប់។ គ្រប់ពេលវេលា គឺយើងកំពុងឈឺចាប់ ទាំងខាងរាងកាយ និងខួរក្បាល។

តើយើងអាចរកមនុស្សណាម្នាក់នៅក្នុងពិភព លោកដែលគេចផុតពីការឈឺចាប់ខាងរាងកាយ និងខួរក្បាលបានទេ ? គឺវាជាការពិបាកណាស់។ សូម្បីតែអ្នក ដែលបានសំរេចភាពសន្ត (ភាពដូចព្រះ) ក៏រមែងគេចមិនផុតពីការឈឺចាប់ខាងរាងកាយដែរដ៏រាបណាពួកគេ នៅមានរូបកាយខាងរូបវិទ្យារបស់គេ។

ប្រសិនបើមាននរណាម្នាក់សួរថា " *តើអ្វីជាវត្ថុមិនប្រាកដបំផុតនៅ ក្នុងពិភពលោកនេះ?* " ចម្លើយដែលត្រឹមត្រូវគួរតែជា " *ជីវិតគឺជាវត្ថុដែលមិនប្រាកដបំផុត* "។ រាល់អ្វីៗដែលយើងធ្វើនៅក្នុងលោកនេះគឺដើម្បី គេចផុតពីការឈឺចាប់ និងការស្លាប់។ ប្រសិនបើយើងមិនអើពើពីជីវិតនេះសូម្បីតែ១វិនាទី គឺយើងនឹងបាត់បង់វាយ៉ាងច្រើន។ ភាគច្រើននៃកិច្ចការប្រចាំថ្ងៃរបស់យើងដូចជា ការធ្វើការងារ ការហូបចុក ការផឹក ការព្យាបាលជម្ងឺ ការដេក និងការដើរ គឺជាវិធី និងមធ្យោបាយដែលយើងធ្វើដើម្បីចៀសវាងពីការឈឺចាប់ និងការស្លាប់។ ទោះបីជាយើងមានសេចក្តីរីករាយខាងលោកិយ ខ្លះក្នុងការបំពេញចំណង់របស់យើងក្តី នៅពេលក្រោយវត្ថុដែលផ្តល់ក្តីរីករាយដល់យើងនោះអាចធ្វើឱ្យយើងឈឺចាប់បាន។ ដូច្នេះ រតនសម្បត្តិដ៏ប្រសើរនៃសន្តិភាព និងសុភមង្គលមិនមែនថាត្រូវតែមាននៅក្នុងដៃអ្នកមាននោះទេ ប៉ុន្តែគឺមាននៅក្នុងមនុស្សដែលបានលះបង់វត្ថុលោកិយទាំងឡាយ។

អ្វីៗដែលជាប់ទាក់ទង នឹងជីវិតរបស់យើងគឺជាមេដែលនាំឱ្យមានការផ្លាស់ប្តូរ និងការមិនពេញចិត្ត។ នោះជាមូលហេតុដែលព្រះពុទ្ធបានពន្យល់ថា ដ៏រាបណាមានចំណង់ខ្លាំងចំពោះសេចក្តីរីករាយ ឬសេចក្តីប្រាថ្នា ខាងលោកិយសំរាប់ការរស់នៅ ដ៏រាបនោះវាមិនមានការគេចផុតពីការឈឺចាប់ខាងរាងកាយ និងខួរក្បាលឡើយ។ សេចក្តីប្រាថ្នាគឺមានសារៈសំខាន់សម្រាប់ការរស់នៅ។ នៅពេលដែលការរស់នៅកើតមាន ការឈឺចាប់គឺ មិនអាចចៀសរួចឡើយ។

មនុស្សជាច្រើនចម្រើនភាវនាស្វែងរកជីវិតដែលគ្មានទីបញ្ចប់ តែជាការខកចិត្ត អ្នកស្វែងរកនូវអមត ភាពជាច្រើនរកឃើញថា ជីវិតគឺធ្វើឱ្យធុញទ្រាន់ណាស់ ដែលពួកគេមិនបានដឹងសូម្បីតែរបៀបដែលត្រូវរស់ឆ្លងមួយថ្ងៃៗផង ! តាមព្រះពុទ្ធចំណង់ខ្លាំងខាងអមតភាពនេះគឺជាបុព្វហេតុមួយក្នុងចំណោមបុព្វហេតុទាំងឡាយចំពោះគំនិតអាត្មានិយម និងខ្លាចសេចក្តីស្លាប់។

" វាជាការងាយដើម្បីបានសប្បាយរីករាយ (" It is easy enough to be pleasant ប្រសិនបើជីវិតប្រព្រឹត្តទៅស្រួលដូចបទចំរៀងមួយ When life flows along like a song ប៉ុន្តែមនុស្ស

ដែលបានការ But the man worthwhile គឺមនុស្សដែលអាចញញឹម Is the man who can smile នៅពេលដែលជីវិតប្រព្រឹត្តទៅមានបញ្ហាច្រើន - When life goes dead wrong.")

សុភមង្គលបន្តិចបន្តួចនេះគឺ បានមកដោយការព្រមទទួលយកការខកចិត្ត ការបរាជ័យ និងការចុះចាញ់ផ្សេងៗ។ មនុស្សមិនអាចរកបានជីវិតដែលគ្មានការរំខានបញ្ហាផ្សេងៗ វិបត្តិភ័យ ការមិនពេញចិត្ត ការរសាយចិត្ត ការភ័យខ្លាច អសន្តិសុខ ការបាត់បង់ គ្រោះកាច ការស្តីបន្ទោសជម្ងឺចាស់ជរា និងស្ថានភាពទាំងឡាយ ដែលមិនមានមកពីកំណើតរាប់ពាន់ទៀតឡើយ។ ទាំងថ្ងៃទាំងយប់ មនុស្សខិតខំដើម្បីកំចាត់នូវស្ថានភាពអកុសលទាំងនេះ។ គេកាន់តែខិតខំដើម្បីគេចចេញពីស្ថានភាពមិនរីករាយនៃកិច្ចការនៅក្នុងវិធីលោកិយនេះ គឺគេកាន់តែធ្វើឱ្យខ្លួនគេជាប់ជំពាក់ជាមួយ នឹងបញ្ហាផ្សេងទៀត។ នៅពេលដែលគេរៀបចំកំចាត់បញ្ហាមួយចង់មិនចង់គេ នឹងបង្កើតបញ្ហាផ្សេងៗទៀតចំពោះខ្លួនគេ។ ដូច្នេះតើឯណាជាទីបញ្ចប់នៃបញ្ហាទាំងនេះ? ចំពោះការរស់នៅផ្ទាល់របស់យើង យើងត្រូវតែព្រមទទួលយកនូវការលំបាក និងការឈឺចាប់នេះដោយគ្មានការតវ៉ាព្រោះ គ្មានជម្រើសផ្សេងទៀតឡើយ។ សេចក្តីឈឺចាប់នឹងនៅមានជានិច្ច! ប៉ុន្តែសេចក្តីឈឺចាប់ និងអបមង្គលគឺចៀសបាន។ ព្រះពុទ្ធមានពុទ្ធដីកាថា សេចក្តីឈឺចាប់គឺជាជម្ងឺមួយដូច្នេះគេអាចព្យាបាលវាឱ្យជាសះស្បើយនៅពេលសម្រេចបានសុក្រឹតភាព។

ឡៅស៊ឺ ( Lao Tze ) (ជាគ្រូសាសនាចិនដ៏ល្បីល្បាញ) បាននិយាយថា : " ខ្ញុំមានការឈឺចាប់ពីព្រោះ ខ្ញុំមានរូបកាយ។ បើខ្ញុំមិនមានរូបកាយខាងរូបវិទ្យាទេ តើខ្ញុំអាចឈឺចាប់យ៉ាងដូចម្តេចកើត? "

នៅពេលដែលអ្នកក្រឡេកមើលពីរបៀប ដែលមនុស្សទទួលការឈឺចាប់នៅក្នុងលោកនេះ នោះអ្នកអាចមើលឃើញពីស្ថានភាពពិតនៃជីវិតលោកិយនេះ។ ហេតុអ្វីបានជាពួកគេត្រូវទទួលការឈឺចាប់របៀបនេះ? ហើយនរណាជាអ្នកទទួលខុសត្រូវចំពោះសេចក្តី ឈឺចាប់ទាំងនេះ? តាមព្រះពុទ្ធគឺមនុស្សម្នាក់ៗជាអ្នកទទួលខុសត្រូវចំពោះសេចក្តីឈឺចាប់របស់ខ្លួន។ មនុស្សទទួលការឈឺចាប់សព្វថ្ងៃ ដោយសារចំណង់ខ្លាំងសំរាប់រស់នៅរបស់ពួកគេ។ នេះគឺជាបុព្វហេតុចម្បងនៃសេចក្តីឈឺចាប់។ វាបានចំណាយពេលជាង២៥០០ ឆ្នាំសម្រាប់ទស្សនវិទូ និងអ្នកចិត្តវិទ្យាជាច្រើនយល់ថា អ្វីដែលព្រះពុទ្ធបានមានពុទ្ធដីកាគឺជាការពិត។ អ្នកកវីម្នាក់និយាយថា :

" សត្វមមាចហើរទៅរកភ្លើង (" To the fire flies the moth ដោយមិនដឹងថាវានឹងស្លាប់។ Knows not she will die. កូនត្រីស៊ីសន្ទូច Little fish bites in the hook. ដោយមិន

ដឹងពីគ្រោះថ្នាក់ Knows not of the danger. ប៉ុន្តែទោះបីដឹងច្បាស់ពីគ្រោះថ្នាក់ But though knowing well the danger នៃសេចក្តីរីករាយខាងលោកិយដ៏អាក្រក់ទាំងនេះក្តី Of these evil worldly pleasures, ក៏យើងនៅតែប្រកាន់ខ្ជាប់ចំពោះវាយ៉ាងដាច់ខាតដែរ ។ We still cling to them so firmly អូរ ម្តេចក៏យើងល្ងិល្ងើរម្លេះទំ ! Oh how great is our folly ! ") ។

**ធម្មជាតិនៃជីវិតដែលមិនឋិតថេរ**

ពុទ្ធសាសនាបង្ហាញថា រយៈពេលនៃវិសាលគមជីវិតរបស់យើងគឺខ្លីណាស់ ដូច្នេះយើងគួរតែធ្វើការ ដោយពិចារណាឱ្យបានត្រឹមត្រូវប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់សម្រាប់ការសង្គ្រោះរបស់យើង ។

" មនុស្សអាចមិនដែលដឹង (" People can never really understand ថា យើងមានជីវិតមែន ប៉ុន្តែមានរយៈពេលខ្លី ។ That we are here but for a little spell. ប៉ុន្តែអ្នកដែលដឹងពីសច្ចភាពនេះច្បាស់ But they who grasp this truth indeed ធ្វើឱ្យសេចក្តីវេទនា និងទំនាស់ទាំងអស់ចុះថយ " ។ Suffer all strife and quarrels to abate." )

នេះជារបៀបដែល Davis ជាកវីប្រមាណមើលពីជីវិតមិនឋិតថេរ ។

" ដោយពោរពេញទៅដោយការការពារ តើជីវិតជាអ្វី (" What is this life, so full of care, ទើបយើងមិនមានពេលឈរមើលអ្វីៗ? We have no time to stand and stare គ្មានពេលឈរលេងក្រោមម្លប់ឈើ No time to stand beneath boughs ហើយសម្លឹងមើលសត្វចៀម និងគោរត់ចុះរត់ឡើងឡើយ ។ And stare as long as sheep and cows. គ្មានពេលមើលអ្វីនៅពេលយើងដើរកាត់ព្រៃឡើយ No time to see, when woods we pass, ដែលទីនោះកំប្រុកពួកស៊ីសណ្តែកនៅក្រោមស្មៅ ។ Where squirrels hide their nuts in grass. គ្មានពេលមើលឱ្យឃើញទាំងកណ្តាលថ្ងៃ No time to see, in broad daylight, ដែលមានផ្កាយព្រោងព្រាត ដូចពេលយប់ទេ ។ Streams full of stares, like skies at night. គ្មានពេលងាកមើលរស្មីរបស់សោភណ័ភាព No time to turn at beauty's glance, ហើយមើលជើងរបស់នាង ថាតើពួកគេអាចរាំយ៉ាងដូចម្តេចទេ ។ And watch her feet, how they can dance. គ្មានពេលរង់ចាំរហូតដល់មាត់របស់នាងអាច No time to wait still her mouth can ធ្វើឱ្យញញឹមភ្នែកនាងបើកនោះឡើយ ។ Enrich that smile her eyes began. ពោរពេញដោយការការពារ ជីវិតក្រីក្រប្រសិនបើ A poor life this if, full of care, យើគ្មានពេលដើម្បីឈរមើលអ្វីនោះ " ។ We have no time to stand and stare.")

**សមរភូមិ**

សាកលលោកទាំងមូលជាទីលានប្រយុទ្ធដ៏ធំល្វឹងល្វើយ។ ការរស់នៅគឺគ្មានអ្វីក្រៅពីការតស៊ូដែលឥតបានការនោះឡើយគឺ ធាតុទាំងឡាយប្រឆាំងនឹងធាតុទាំងឡាយកម្លាំងប្រឆាំងកម្លាំងប្រុសប្រឆាំងប្រុស ស្រីប្រឆាំងស្រី មនុស្សប្រឆាំងសត្វ សត្វប្រឆាំងមនុស្សមនុស្សប្រឆាំងធម្មជាតិ ធម្មជាតិប្រឆាំងមនុស្ស ហើយក្នុងនោះ ប្រព័ន្ធរូបវិទ្យាខ្លួនឯងជាសមរភូមិដ៏ធំមួយ។ គំនិតស្មារតីខ្លួនឯងគឺជាសមរភូមិដ៏ធំបំផុត។

មនុស្សដែលមិនមានសន្តិភាពនៅនឹងខ្លួនឯង គឺមិនអាចមានសន្តិភាពនឹងពិភពលោកឡើយ ហើយសង្គ្រាមខាងក្រៅត្រូវតែបន្តដើម្បីបិទបាំងទង្វើចេញពីបុគ្គលទាំងឡាយ ដែលសង្គ្រាមពិតគឺនៅខាងក្នុង។ សព្វថ្ងៃសំណូមពរសំខាន់បំផុតរបស់មនុស្សជាតិគឺសន្តិភាព ប៉ុន្តែមិនអាចមានសន្តិភាពនៅក្នុងពិភពលោកដែលហែកហួរ ដោយសារសង្គ្រាមនេះឡើយ រហូតដល់ទំនាស់របស់មនុស្សជាមួយនឹងខ្លួនឯងត្រូវបានបញ្ចប់។

នៅក្នុងព្រះនេត្ររបស់ព្រះពុទ្ធ សត្វលោកទាំងឡាយដែលមានជីវិតភ័យញ័រ ដូចត្រីនៅក្នុងអួរដែលរៀបរីងស្ងួតសត្វលោកគឺនៅក្នុងគំនាបនៃចំណង់ខ្លាំង ដែលលោតចុះលោតឡើងដូចទន្សាយជាប់អន្ទាក់ ឬបាត់ ដូចព្រួញបាញ់ពេលយប់។ ព្រះអង្គទតឃើញថា ការតស៊ូនៃអ្វីៗទាំងអស់ប្រឆាំងគ្នា ដែលធ្វើឱ្យមានអំពើបំផ្លិចបំផ្លាញមិនសមហេតុជាបន្តបន្ទាប់ ហើយដែលក្នុងនោះគេសង្គ្រោះអ្នកដទៃ ហើយដល់ពេលអ្នកដទៃនោះសង្គ្រោះគេវិញ។ សង្គ្រាមបង្កើតឡើងដោយគំនិតមនុស្ស ហើយគំនិតមនុស្សដូចគ្នានេះអាចបង្កើតសន្តិភាព ដែលមានយុត្តិធម៌ ប្រសិនបើមនុស្សប្រើគំនិតមិនលំអៀងរបស់ខ្លួន។

ប្រវត្តិសាស្ត្រសាកលលោកបង្ហាញយើងថា ការប្រកាន់ពូជសាសន៍ រនាំងពណ៌សម្បុរ ការនិយមសាសនាហួសហេតុ និងការលោភចំពោះអំណាចខាងនយោបាយ និងទ្រព្យសម្បត្តិបានធ្វើឱ្យមានទុក្ខវេទនា និង មហន្តរាយដ៏ធំធេងនៅក្នុងពិភពលោកនេះ និងទទួលទម្ងន់ជីវិតដ៏ធ្ងន់នៅក្នុងផ្លូវអាក្រក់។ របស់ទាំងអស់នេះមិន ដែលជួយផ្តល់អ្វីដល់ការអភិវឌ្ឍពិភពលោកឡើយ។ មនុស្សដែលស្រេកឃ្លានអំណាចនិងទ្រព្យសម្បត្តិ និង ស្រវឹងនឹងក្តីច្រណែន គឺតែងតែបង្កើតបញ្ហា ហើយជួនកាលខំបង្ហាញពីការសមហេតុសមផលនូវទង្វើរអាក្រក់ ទាំងឡាយរបស់គេដោយការនិយាយសំដីមិនសមហេតុសមផលក្នុងនាមនៃសន្តិភាព និងយុត្តិធម៌។ យើងកំពុង

រស់នៅក្នុងពិភពលោកមួយដែលបានរួមផ្គុំបែបរូបសាស្ត្រ ប៉ុន្តែបែកខ្ញែកខាងគំនិត ហើយនៅពេលជាមួយគ្នានោះ ដែរវាបានរួមផ្គុំខាងគំនិតប៉ុន្តែបែកខ្ញែកខាងរូបសាស្ត្រ ។

" យើងរស់នៅ ហើយធ្វើការងារ និងសុបិន (" We live and work and dream, ម្នាក់ៗមានគ្រោងការណ៍របស់ខ្លួន Each has his little scheme, ជួនកាលយើងសើច Sometimes we laugh; ជួនកាលយើងយំ ។ Sometimes we cry. ដូច្នេះហើយមួយថ្ងៃៗចេះតែកន្លងទៅ " ។ And thus the days go by.") ។

**ទំនាស់ជាច្រើន**

យើងធ្វើកិច្ចការលំបាក និងធ្វើខ្ញុំបម្រើដើម្បីថែរក្សាខ្លួនយើង ។ យើងធ្វើអំពើអាក្រក់ទាំងឡាយដើម្បីបំពេញតម្រូវការ និងចំណង់ខ្លាំងរបស់ខ្លួនយើង ។ យើងបានស្វែងរកកិត្តិនាម និងការចេញជាសាធារណៈដើម្បីបំពេញអាត្មា ដែលជាប់ជាមួយយើង ។ យើងធ្វើកិច្ចការជាច្រើនដើម្បីលើកកំពស់អ្វីដែលគេហៅថា កិត្យានុភាព តែនៅពេលមរណភាពមកដល់ ការចុះអាប់ឳនក៏បញ្ចុះទៅក្នុងផ្នូរ ឬឈាបនដ្ឋាន ហើយពេលនោះខ្លួនយើងត្រូវរលាយសោះសូន្យ ។

នៅក្នុងជីវិត យើងបានបង្កើតទំនាស់ជាច្រើនចំពោះខ្លួនយើង ។ យើងក៏ធ្វើវានៅពេលស្លាប់ដែរ ។ ការពណ៌នាបែបកំណាព្យរបស់ Khantipalo ពីទំនាស់ហួរហេតុ ដែលយើងបង្កើតឡើងមានដូចតទៅ :

" ទំនាស់ជាច្រើន (" A lot of fuss មនុស្សជាច្រើន A lot of people ពេលជាច្រើន A lot of time បញ្ហាជាច្រើន A lot of trouble ទឹកភ្នែកជាច្រើន A lot of tears លុយជាច្រើន A lot of money -តើទាំងអស់នេះសម្រាប់ធ្វើអ្វី? And all for what? ខ្លួនតូច ! A little body ! ប្រូតេអ៊ីនតិចតួច A blob of proteins មិនមានការដាច់ខ្យល់លឿន Fast unwinding, សពតិចតួច A little corpse ការចុះអាប់ឳនលឿន ។ Quick decaying. វាមិនមានអ្វីទៀតទេ No longer is it លោកឪពុក អ្នកម្តាយជាទីគោរព Dear Father, mother ឬអ្នកណាផ្សេងទៀតស្រលាញ់ ។ Or any darling other. ទោះបីជាដូច្នេះក្តី In spite of this យើងត្រូវតែមាន We must have ការលួងចិត្ត និងក្តារមឈូស Consolations and coffins ដំណើរការ និងថ្មដាក់នៅក្បាលផ្នូរ Processions and Tombstones ពិធីបុណ្យ និងការកាន់ទុក្ខ Parties and mourning រីត៌ និងក្បួនរីត៌ Rites and rituals បញ្ចុះឬបូជា Buried or burnt អប់សពឱ្យបានរហូត Embalmed for ever, ទាំងអស់សម្រាប់ភាពបន្តិចបន្តួចទាំងនេះ All for these little ខ្លួនដែលឡើងប៉ោងទាំងនេះ ។

Bloated bodies. កូនប្រុសទាំងឡាយមានការចងចាំ Sons remember, ចៅមានការចងចាំងតិចតួច Grandsons little, ហើយបន្ទាប់ពីពួកគេ And after them គឺភ្លេចអស់ Are the dead forgetting, នៅសល់តែថ្ម និងឆ្អឹងប៉ុណ្ណោះ។ Stones and bones alone remaining. ដូច្នេះតើនេះមិនមែនជា So is this no ការត្រឹមត្រូវជាច្រើនទេឬ ? A lot of nonsense? ")

**តម្លៃខាងស្មារតី**

Julian Huxley និយាយថា : ជីវិតគួរតែនាំទៅរកការបំពេញនូវលទ្ធភាពច្រើនអនេក ដូចជា ខាងរូបកាយ ខាងខួរក្បាល ស្មារតីជាដើម ដែលមនុស្សអាចធ្វើទៅបាន។ មនុស្សជាតិអាចកាន់តែប្រសើរឡើង និងខ្ពង់ខ្ពស់ឡើង។

អ្នកកើតមកលើលោកនេះដើម្បីធ្វើអំពើល្អ ដោយមិនត្រូវទុកពេលវេលាឱ្យឥតប្រយោជន៍នោះឡើយ។ ប្រសិនបើអ្នកមិនធ្វើអ្វីទេ នោះអ្នកជាបន្ទុកមួយសំរាប់លោកនេះ។ អ្នកត្រូវតែជានិច្ចពីការលេចឡើងកាន់តែ ខ្ពស់នៅក្នុងកុសល និងបញ្ញាញាណ។ អ្នកនឹងកំពុងតែរំលោភបុព្វសិទ្ធិនៃការក្លាយជាមនុស្សប្រសិនបើអ្នកមិនបានបង្ហាញថា ខ្លួនមានតម្លៃបណ្តាលមកពីគុណសម្បត្តិរបស់អ្នកផ្តល់ឱ្យទេនោះ។ ដើម្បីបោះបង់អត្តិភាពមនុស្ស ទៅក្នុងក្តីទុកព្រួយកន្លងមកក្នុងភាពឥតបានការនិងភាពច្វេសប្រហែសគឺត្រូវបង្ហាញភាពមិនសមរម្យរបស់គេ នៅក្នុងលោកនេះ។ ដើមឈើនៃអរិយធម៌មានឫសទាំងឡាយរបស់វានៅក្នុងតម្លៃស្មារតី ដែលមនុស្សយើងភាគច្រើនមិនបានដឹង។ បើគ្មានឫសទាំងនេះទេ នោះស្លឹកទាំងឡាយនឹងជ្រុះហើយដើមឈើនឹងក្លាយជាដង្គត់ដែលគ្មានជីវិត។

" ប្រសិនបើភ្នំទាំងអស់ជាសៀវភៅ បឹងទាំងអស់ជាទឹកថ្នាំ ហើយដើមឈើទាំងអស់ជាប៊ិចក៏ដោយក៏វានៅតែមិនគ្រប់គ្រាន់ដើម្បីពណ៌នាពីទុក្ខវេទនាទាំងអស់នៅក្នុងលោកនេះដែរ "។ ( Jacob Boehme )

នោះជាមូលហេតុ ដែលគ្រូសាសនាសម្រេចសម្មាសម្ពោធិញ្ញាណដូចជាព្រះពុទ្ធ បន្ទាប់ពីឈ្វេងយល់ថាជីវិតនេះឋិតនៅក្នុងទស្សនៈត្រឹមត្រូវរបស់វាដោយមិនមានអាត្មានិយមឬហេតុជំរុញអត្តទត្ថនិយមនោះ បានពន្យល់ថា មិនមានបំណងពិតប្រាកដនៃជីវិតនេះទេ ប្រសិនបើយើងបណ្តោយឱ្យជីវិតនេះប្រព្រឹត្តវិលវល់នៅក្នុង វដ្តសង្សារនៃការកើតស្លាប់ នោះវានឹងធ្វើឱ្យមានការឈឺចាប់ខាងរូបកាយ និងខួរក្បាល។ ប៉ុន្តែយើងអាចប្រើ ជីវិតនេះសំរាប់គោលបំណងល្អដោយការជួយអ្នកដទៃ ដោយការបណ្តុះសីលធម៌ ដោយការហ្វឹកហាត់គំនិត និងការរស់នៅ

ជាមនុស្សមានវប្បធម៌សន្តិភាព និងចុះសម្រុងជាមួយនឹងពិភពឯទៀត។ តាមព្រះពុទ្ធ មនុស្សលោកមិនមែនជាតុក្កតាដែលគ្មានទំនួលខុសត្រូវសោះនោះទេ។ មនុស្សគឺជាផ្លែដែល ខ្ពង់ខ្ពស់លើសគេរបស់ដើមឈើវិវឌ្ឍន៍។ តែទោះជាយ៉ាងណាក៏ដោយ ទស្សនវិជ្ជាបុរានរបស់យើងបង្ហាញពីគោលបំណងនៃជីវិតថា "ជាការដឹកនាំពីភាពងងឹតទៅភ្លឺ ពីគ្មានសច្ចភាពទៅ សច្ចភាព និងពីការស្លាប់ទៅអមតភាព"។ ទាំងនេះមាន លក្ខណៈសមញ្ញ នៅមិនទាន់មានន័យគ្រប់គ្រាន់ឱ្យយើងមានទុនសម្រាប់គំនិតនៅឡើយ។

**សេចក្តីស្លាប់ និងអមតភាព**

រាល់សំណួរដែលមនុស្សសួរអំពីជីវិតរបស់ខ្លួន គឺទាក់ទងនឹងតថភាពនៃសេចក្តីស្លាប់ វាទំនងជាថា មនុស្សខុសពីសត្វលោកដទៃទៀតត្រង់ដឹងពីជីវិតផ្ទាល់របស់ខ្លួន និងមិនដែលផ្សះផ្សារឱ្យបានពេញលេញក្នុងការចែករំលែក វាសនាពីធម្មជាតិនៃអ្វីៗ ដែលមានជីវិតរស់នៅឡើយ។ ប្រសិនបើមានមនុស្សណាម្នាក់អាចយល់ថា ជីវិតមានរយៈពេលខ្លី ហើយថាសេចក្តីស្លាប់ជារឿងដែលមិនអាចចៀសរួច នោះគេអាចដោះស្រាយបញ្ហាដែលទាក់ទង ទៅនឹងជីវិតបានច្រើន។ នៅក្នុងការតស៊ូជាមួយនឹងសេចក្តីស្លាប់របស់ខ្លួន មនុស្សបានសំរេចការពន្យាជីវិតបាន ខ្លះប្រៀបដូចទៅ នឹងកូនក្មេងលេងនៅឆ្នេរសមុទ្រ ដែលធ្វើការយ៉ាងខ្លាំងដើម្បីកសាងប្រាសាទខ្សាច់របស់គេមុន នឹងរលកបករំលាយវា។ មនុស្សច្រើនតែធ្វើឱ្យរឿងសេចក្តីស្លាប់ជាបញ្ហាសំខាន់ខាងសាសនា ដោយធ្វើការបួងសួងសុំឱ្យទទួលបានជីវិតអមតៈ។

សេចក្តីស្លាប់គឺ កើតមានលើរាល់ភាវៈមានជីវិតទាំងអស់ ប៉ុន្តែមានតែមនុស្សទេ ដែលបានបង្កើតបំណងមួយដើម្បីឱ្យជីវិតឋិតថេរប្រាស់ចាកការគម្រាមកំហែងឥតឈប់ឈរពីសេចក្តីស្លាប់។ ហើយក្រៅពីសេចក្តីប្រាថ្នា ចំពោះនិរន្តភាព និងអមតភាពមនុស្សបានបង្កើតសាសនាឡើងដើម្បីធ្វើឱ្យទីបញ្ចប់សំរាប់ជីវិតកាន់តែមានន័យថែមទៀត។

ទោះបីជាសាសនិកនៃសាសនាជាច្រើនជឿថា មានឋានសួគ៌ ដែលជាកន្លែងជីវិតនឹងទទួលបានបរមសុខរហូតក្តី ក៏យើងនៅមិនទាន់ឮថា សាសនិកដែលជឿស៊ប់នឹងសាសនានៃសាសនាពិសេសណាមួយមានបំណង នឹងបោះបង់ជីវិត និងវត្ថុលោកិយដែលពួកគេមានដើម្បីនៅឋានសួរនោះដែរ។ ដូចគ្នានេះដែរល្គឹកណាគេមានជីវិត អ្នកកាន់ពុទ្ធសាសនាទាំងឡាយក៏នឹងប្រកាន់យកជីវិតលោកិយដ៏មានតម្លៃរបស់ពួកគេដែរ ទោះបីពួកគេដឹងថា ជីវិតនៅក្នុងលោកិយនេះគ្មានអ្វីក្រៅពីការឈឺចាប់និងទីបរមសុខខ្ពស់បំផុតជា Nibbana (និព្វាន?) ក៏ដោយ

។ ប៉ុន្តែ តើមានប៉ុន្មាននាក់ដែលសំរេចបាន Nibbana (និព្វាន) តាមរយៈការបោះបង់ចំណង់ខ្លាំងចោលនោះ?

បញ្ហាធំបំផុតដែលប្រទេសជាច្រើន កំពុងប្រឈមមុខសព្វថ្ងៃនេះគឺបញ្ហានៃការកើនឡើងចំនួនប្រជាជន឵ឆាប់រហ័ស។ គេបានរកឃើញវិធី និងមធ្យោបាយផ្សេងៗដើម្បីទប់ស្កាត់កំណើនឥតឈប់ឈរនៃលំហូរជីវិតនេះ។ មនុស្សរាប់លាននេះត្រូវការចំណីជម្រកផាសុខភាព និងសន្តិសុខ។ ចំពោះមនុស្សទាំងនេះសំណួរគឺមិនមែនថា "តើអ្វីជាបំណងនៃជីវិត" នោះទេប៉ុន្តែគឺ "តើត្រូវធ្វើដូចម្តេចចំពោះជីវិត "។ ចម្លើយដ៏សាមញ្ញគឺថា គេគួរប្រើជីវិតឱ្យបានល្អបំផុត ហើយស្វែងរកសុភមង្គលអ្វីក៏ដោយដែលគេអាចចាប់បាននៅក្នុងលក្ខណៈត្រឹមត្រូវនិងមានប្រយោជន៍ជាជាងការខ្វល់ខ្វាយហួសហេតុអំពីសំណើរបែបបរិមត្ថវិជ្ជា នៃបំណងជីវិតប្រកបដោយអាថិកំបាំង។ តែទោះជាយ៉ាងណាក្តី សាសនាឈានទៅរកការលួងលោមផ្លូវចិត្តមនុស្ស ឬធ្វើឱ្យមនុស្សដឹងការពិតដែលថា ជីវិតគឺមិនអាប់អួរ និងគ្មានសង្ឃឹមដូចដែលវាមានពីរូបកាយដើមខាងរូបវិទ្យានោះឡើយ។ មានសេចក្តីសង្ឃឹមមួយចំពោះជីវិតល្អមួយ។

រាល់ការរីកចំរើននៅលើពិភពលោកនេះគឺមនុស្សជាអ្នកបង្កើតឡើង ដោយសារការពិតដែលគេដឹងថា គេនឹងស្លាប់ហេតុនេះគេចង់បន្សល់ទុកឥទ្ធិពលរបស់គេបន្ទាប់ពីគេស្លាប់ទៅ។ ប្រសិនបើមនុស្សសំរេចបានអមតភាព ហើយជីវិតនៅលើផែនដីរបស់គេគ្មានទីបញ្ចប់នោះ គេនឹងងាកទៅចាប់យកអ្វីៗយ៉ាងងាយ ហើយបាត់បង់ ការលើកទឹកចិត្ត ឬការផ្តួចផ្តើមគំនិតដើម្បីរីកចម្រើន គេនឹងគ្មានចំណង់ដើម្បីធ្វើឱ្យពិភពលោកមានការរីកចំរើន តិចតួចជាងដែលគេបានឃើញនោះឡើយ ។ប្រសិនបើមិនមានសេចក្តីស្លាប់ទេនោះជីវិតនឹងទៅជាអាប់អួរមិនរីកចម្រើនដដែលៗ ហើយមានការធុញថប់ និងបន្ទុកដ៏ធ្ងន់ធ្ងរហួសវាចារនឹងថ្លែង។ ប្រសិនបើមនុស្សទទួលបាន ការយល់ធ្លុះជ្រៅដើម្បីយល់ និងដឹងពីពេលវេលានៃសេចក្តីស្លាប់របស់គេ នោះគេនឹងធ្វើទង្វើយ៉ាងច្បាស់លាស់ខុសពីអ្វីដែលគេកំពុងធ្វើបច្ចុប្បន្ន។

**"រូបកាយរបស់មនុស្សក្លាយទៅជីធូលី,ប៉ុន្តែឥទ្ធិពលរបស់គេឋិតនៅ "** ( Buddha ) ទោះបីដូនតារបស់យើងស្លាប់បាត់ទៅហើយក្តី យើងអាចសន្មត់ថា ពួកគាត់ឋិតនៅជាមួយពួកយើងនៅឡើយ មិនមែនជារូបកាយទេ ប៉ុន្តែតាមរយៈឥទ្ធិពលដែលគាត់បានបង្កើត ឡើងពីមួយជំនាន់ទៅមួយជំនាន់នោះគឺឥទ្ធិពលនៅមាន។ ចំពោះពាក្យថា ដូនតា ( ancestors )នេះ គឺយើងមិនមែនសំដៅតែទៅលើជីដូនជីតា ( progenitors ) របស់យើងប៉ុណ្ណោះទេ ប៉ុន្តែគឺសំដៅទៅ

លើមនុស្សទាំងអស់ដែលបានរួមចំណែកចំពោះសុខុមាលភាព និងសុភមង្គលផងដែរ។ ក្នុងន័យនេះយើងអាចនិយាយបានថា វីរជនបណ្ឌិត និងកវីដែលបានស្លាប់ទៅ គឺនៅតែឋិតនៅជាមួយពួកយើងតាមរយៈឥទ្ធិពលរបស់ពួកគាត់។ នៅពេលដែលយើងភ្ជាប់ខ្លួនយើងទៅនឹងទុក្ករបុគ្គល និងអ្នកគិតទាំងនេះគឺយើងចូលរួមចំណែកផ្តល់គំនិតដ៏ត្រឹមត្រូវបំផុតពោលគឺឧត្តមគតិល្អប្រសើរ និងការធ្វើឱ្យជាប់ចិត្តនឹងតន្ត្រីនៃសតវត្ស។

ការយំស្រែកនៃចិត្តរបស់មនុស្សចំពោះបំណងមួយ គឺជាការទទួលស្គាល់ស្រពិចស្រពិលនៃធម្មជាតិជីវិត។ នៅពេលដែលមនុស្សដឹងពីអាទិទេព ឬធម្មជាតិល្អរបស់គេនោះគេមិនស្រែកយំចំពោះបំណងជីវិតទៀតទេ ព្រោះគេដឹងថា គឺគេខ្លួនឯងជាបំណងនោះ។

ចូរគិតថា មនុស្សបានដឹងថា មេរៀនប្រវត្តិសាស្ត្រមនុស្សជាតិត្រូវ បានកំណត់មិនមែនដោយអ្វីដែលកើតឡើងនៅក្នុងមេឃនេះទេ ប៉ុន្តែដោយអ្វីដែលកើតឡើងនៅក្នុងគំនិតមនុស្ស។

ព្រះពុទ្ធបានមានពុទ្ធដីកាថា *"មិនមានសត្វលោកអធិធម្មជាតិណា ដែលប្រសើរជាងមនុស្សដែលល្អឥតខ្ចោះនោះឡើយ"*។

**ត្រូវប្រើប្រាស់ជីវិតឱ្យបានល្អបំផុត**

ចំណុចសំខាន់អំពីជីវិតគឺថា យើងមានវា ដូច្នេះហើយយើងត្រូវតែប្រើប្រាស់វាឱ្យបានល្អ។ នេះជាតម្លៃប្រសើរបំផុត នៃជីវិតជាឱកាសប្រើប្រាស់វាឱ្យបានល្អបំផុត។ មនុស្សជាច្រើនដឹងនាំជីវិតមានលក្ខណៈចង្អៀត មានដែនកំណត់គ្មានក្តីរីករាយ និងកៀបសង្កត់ជីវិត ព្រោះពួកគេមិនបានព្យាយាមប្រើប្រាស់វាឱ្យបានល្អបំផុតឡើយ។ ប៉ុន្តែបញ្ហានេះធ្វើឡើងដោយការមាន និងស្តាប់តាមឧត្តមគតិ។ ដូច្នេះ តើឧត្តមគតិយើងគួរមានលក្ខណៈយ៉ាងណា ? វាត្រូវបណ្តុះនូវគុណភាពដែលចេះជួយសង្គ្រោះគ្នា ហើយដឹងនាំជីវិតប្រកបដោយក្តីរីករាយ និងសន្តិភាព។ ផ្លូវជីវិតបែបនេះអាចចាត់ទុកថាជាជីវិតត្រឹមត្រូវថ្លៃថ្នូរប្រកបដោយវប្បធម៌ និងមានលក្ខណៈសាសនាដែល គ្រប់គ្នាគោរពតាម។ មនុស្សមិនអាចដឹកនាំជីវិតបានរីករាយដោយមិន ធ្វើឱ្យអ្នកដទៃរីករាយនោះទេ។

មនុស្សត្រូវព្យាយាមធ្វើវាឱ្យបានល្អបំផុត ហើយជាមួយគ្នានេះដែរ នៅពេលមានជំទាស់ដោយការ ប្រឆាំងឬផ្តល់ជារង្វាន់ដោយជោគជ័យផ្នែកខ្លះនោះ មនុស្សត្រូវនិយាយទៅកាន់ខ្លួនឯងថា "ខ្ញុំបានធ្វើវាល្អបំផុតហើយ " ហើយនៅពេលដែលការប្រឆាំងបាត់បង់ យើងនឹង

ចងចាំថាវិធីនៃការសង្គ្រោះមិនមែនមាននៅ ក្នុងជ័យជំនះទេ ប៉ុន្តែគឺនៅក្នុងការទទួលស្គាល់នៃការប្រឆាំង ។

"ដើមឈើដែលមានមែកផ្ទុកដោយផ្លែជាច្រើន " The fruit tree's heavy-laden bough ទន្លេដែលផ្ទុកដោយដីមានជីជាតិ The river's load of fertile soil ការយ៉ាងច្រើននូវទឹកដោះគោ The richly flowing milk of cows មនុស្សល្អមានកិច្ចការលំបាកឥតស្រាកស្រាណ The good man's unremitting toil; ភាពសម្បូរនេះមានន័យថា ការងារនេះធ្វើរួចហើយ This wealth is meant, this work is done, ចំពោះសេចក្តីល្អអ្នកដទៃ មិនមែនសម្រាប់របស់គេទេ " For other's good, not for their own." ។

ដូច្នេះវាជាលទ្ធិទំនើបនៃសេវាសង្គមដែលអាចនិយាយបានដែរថា ជាមូលដ្ឋានសីលធម៌នៃសាសនាដ៏ ល្អប្រសើរទាំងអស់ ។

**និព្វាន** ( Nibbana )

" ប្រសិនបើការបង្រៀនពីនិព្វាន ( Nirvana ) ណាមួយថា ដើម្បីបញ្ឈប់នោះនិយាយបែបនេះគឺពួកគេកុហក់ប្រសិនបើការបង្រៀនពីនិព្វាន ( Nirvana ) ណាមួយថាដើម្បីរស់នៅនោះនិយាយបែបនេះគឺពួកគេខុស "។ *( Sir Edwin Arnold in The Light of Asia )* និយមន័យពីជីវិតកន្លងមកគួរតែសមល្មមឱ្យអ្នកណាម្នាក់យល់ទស្សនៈនៃការទទួលបាននិព្វាន( Nib bana ) ដែលជាកន្លែងលែងមានការឈឺចាប់ខាងរូបកាយ និងស្មារតីទៀត ពោលគឺនិព្វានជាសញ្ញាបញ្ចប់នូវការឈឺចាប់ ។គោលបំណងនៃជីវិតរបស់យើងគឺដើម្បីបំបាត់និងធ្វើឱ្យទៅជាអប្បបរិមានូវការឈឺចាប់ ហើយស្វែងរកសុភមង្គល។ ប្រសិនបើយើងចង់បានសុភមង្គល ដែលគ្មានទីបញ្ចប់ពិតមែន នោះគឺជាសុភមង្គលដែលយើង ទទួលបាននៅពេលដែលគំនិតរបស់យើងរួចចាកស្រឡះពីការរំខានទាំងឡាយ ពោលគឺយើងត្រូវរៀនពីរបៀបដើម្បីទទួលបានវា។ ដោយការទទួលបានទ្រព្យសម្បត្តិអំណាចនិងលក្ខខណ្ឌលោកិយផ្សេងទៀតច្រើនឡើងយើងអាចមិនទទួលបាននូវសេចក្តីពេញចិត្តការសប្បាយចិត្តសន្តិភាពនៃគំនិត និងសុភមង្គលដែលឋិតថេរ ដែលហៅថាការធ្វើឱ្យវិញ្ញាណស្ងប់ស្ងាត់និងការកាត់បន្ថយសេចក្តីប្រមាថដ៏ធំធេងនៅក្នុងគំនិតរបស់យើង។

ចូរចាំថា គ្មាននរណាបង្ខំយើងឱ្យធ្វើសកម្មភាពតាមផ្លូវពិសេសណាមួយឡើយ ។ គ្មាននរណាដាក់ទណ្ឌកម្ម ឬផ្តល់រង្វាន់ដល់យើងឡើយ ។ វាជាសេរីភាពនៃឆន្ទៈ និងជំរើសផ្ទាល់របស់យើង។ ប្រសិនបើអ្នកគិតថា អ្នកអាចទ្រាំបានរាល់ការឈឺចាប់ខាងរូបកាយ និងស្មារតីនោះអ្នក

នៅតែឋិតក្នុងវដ្តសង្សារនៃការកើតស្លាប់ ហើយបន្តការយំស្រែកការសោកស្តាយ ការឈឺចាប់ ការជេរប្រទេច ការរអ៊ូរទាំ ការវាយប្រហារគ្នា ការខ្វល់ខ្វាយ និងការតស៊ូសំរាប់ការរស់នៅ គឺការធ្វើការងារដូចទាសកររាល់យប់រាល់ថ្ងៃការប្រឈមមុខនឹងបញ្ហានិងឧបសគ្គជាច្រើនអាណែក។ តាមពិតក្នុងអំឡុងពេលនៃជីវិតរស់នៅទាំងមូលរបស់យើង យើងចំណាយពេលវេលា ថាមពល និងគំនិតនៅក្នុងទីលានប្រយុទ្ធ ពោលគឺការប្រយុទ្ធដើម្បីការរស់នៅ ដើម្បីអំណាចផលចំណេញ កេរ្តិ៍ឈ្មោះសេចក្តីសប្បាយរីករាយ និងការប្រយុទ្ធដើម្បីឱ្យគេចផុតពីវត្ថុដែលមានគ្រោះផ្សេងៗទៀត។ យូរៗម្តងយើងទទួលបានបន្តិចបន្តួចនូវសេចក្តីរីករាយក្នុងរយៈ ខ្លីជារយៈពេលបន្ទាន់មួយ។ គ្រប់សេចក្តីរីករាយបញ្ចប់ជាមួយនឹងការឈឺចាប់។

ចូរក្រឡេកមើលពិភពលោកនេះ ហើយអ្នកអាចមើលឃើញថាតើមនុស្សប្រយុទ្ធប្រឆាំងគ្នាយ៉ាងដូចម្តេចខ្លះ ការសម្លាប់ ការដុតបំផ្លាញ ការបំផ្ទុះគ្រាប់បែក ការចាប់ជំរិត ការប្លន់យន្តហោះ និងការវាយប្រហារគ្នា ទៅវិញទៅមក។ ការកំចាត់សមាជិកមនុស្សលោករបស់ពួកគេបានក្លាយទៅជាការកំសាន្តឬការរីករាយ ។ពិភពលោកទាំងមូលគឺដូចជាពេទ្យវិកលចរិត។ មនុស្សបានភ្លេចនូវចរិតលក្ខណៈជាមនុស្សល្អរបស់ខ្លួន ហើយបណ្តោយឱ្យ គំនិតអាក្រក់ សំដីអាក្រក់ និងអំពើអាក្រក់គ្របដណ្តប់លើខ្លួនរបស់គេ។ មើលទៅប្រហែលជាគ្មាន បន្ទប់នៅក្នុងគំនិតមនុស្សដើម្បីបណ្តុះនូវគំនិត និងអំពើល្អឡើយ។ ដូច្នេះតើគេអាចរកឃើញសន្តិភាព និងសុភមង្គលយ៉ាងដូចម្តេចនៅក្នុងទីលានប្រយុទ្ធ ដែលគេកំពុងបន្តប្រយុទ្ធគ្នាដើម្បីទទួលបានផលចំណេញ និងគេចចេញ ពីគ្រោះថ្នាក់នោះ ? "តិរិយាបទអមនុស្សធម៌របស់មនុស្សចំពោះមនុស្សបង្កើតឱ្យមានទុក្ខច្រើនអាណែក "។

ប្រសិនបើអ្នកអាចយល់នូវភាពមិនឋិតថេរនៃជីវិត និងគ្រោះថ្នាក់នៃពិភពលោកនេះ ដូច្នេះអ្នកអាច យល់នូវអត្ថន័យនៃការសម្រេចបាននិព្វាន ( Nibbana )។ អ្នកនឹងមិនពន្យាការខិតខំប្រឹងប្រែងរបស់អ្នកសម្រាប់ ការសម្រេចបាននូវទីបរមសុខឡើយ។ សព្វថ្ងៃនេះអ្នកកំពុងតែតស៊ូប្រយុទ្ធដើម្បីគេចចេញពីការឈឺចាប់តាម របៀបលោកិយ។ ប៉ុន្តែវាជាការប្រយុទ្ធខាតបង់មួយ ។វានឹងនាំឱ្យមានការខកចិត្ត។ ទោះជាយ៉ាងណាក៏ដោយប្រសិនបើអ្នកព្យាយាមកម្ចាត់ការឈឺចាប់ដោយការអភិវឌ្ឍផ្នែកស្មារតីនៃជីវិតរបស់អ្នកនោះអ្នកអាចរកឃើញ សន្តិភាពពិតប្រាកដ។ នោះគឺនិព្វាន ( Nibbana )។

## សេចក្តីរីករាយក្នុងលោកិយ

យើងដឹងថា មានមនុស្សជាច្រើននៅក្នុងពិភពលោកនេះដែលមិនបានត្រៀមដើម្បីធ្វើឱ្យសម្រេចបាននូវនិព្វានឡើយ សូម្បីតែពុទ្ធសាសនិកក៏ដោយ។ ដច្នេះហើយទើបអ្នក ខ្លះអធិប្បាយថា និព្វានជាឋានសួគ៌ដែលមនុស្ស អាចទទួលបាននូវសេចក្តីរីករាយគ្មានទីបញ្ចប់។ ការអធិប្បាយបែបនេះនឹងអូសទាញអ្នកដែលមិនសូវមានការ យល់ដឹងអំពីជីវិតរបស់ខ្លួន និងវត្ថុនានាក្នុងលោកិយ និងចំពោះអ្នកដែលមានចំណង់ខ្លាំងហើយជំពាក់ចិត្តទៅ នឹងជីវិតរបស់ខ្លួនព្រមទាំងសេចក្តីរីករាយក្នុងលោកិយនេះផងដែរ។ ពួកគេមិនអាចយល់ថាដំណើរនៃនិព្វានយ៉ាងដូចម្តេចឡើយ ប៉ុន្តែពួកគេយល់ថាជាការយល់សប្តិ។ តែយ៉ាងណាក៏ដោយ មនុស្សលោកតែងតែគិត និងអង្វរសុំនូវនិព្វាននេះ។ ម្យ៉ាងទៀតមានមនុស្សដែលគិតថា រស់នៅក្នុងពិភពលោកនេះវាល្អជាងទោះបីជាជីវិតរបស់គេ មានការឈឺចាប់គ្រប់បែបគ្រប់យ៉ាងក៏ដោយ។ ពួកគេមិនបានយល់ទេថាដោយសារចំណង់ខ្លាំង និងការជំពាក់ចិត្តរបស់ខ្លួនដែលពួកគេបានបង្ករឡើងនោះ ពួកគេមិនអាចយល់បាននូវបរមសុខ នៃនិព្វានទាំងស្រុងបាននោះទេ។ វត្ថុលោកិយទាំងឡាយផ្សេងទៀតដែលគេចាត់ទុកថាជាសុភមង្គលនោះ មិនអាចជួយគេឱ្យបានស្បើយ ពីការឈឺចាប់ខាងរូបកាយ និងស្មារតីបានឡើយ។

តាមព្រះពុទ្ធ គឺដោយសារការមិនអើពើដែលមនុស្សចង់រស់នៅក្នុងវដ្តសង្សា (Samsara) ដែលជា ការវិលកើតវិលស្លាប់ នៅពេលដែលមានការឈឺចាប់ និងការរត់តាមមរិចិកាក្នុងការស្វែងរកអ្វីៗគ្មានទីបញ្ចប់ ដើម្បីបំពេញអារម្មណ៍របស់ពួកគេ។ ពួកគេគួរតែរៀនធ្វើឱ្យអារម្មណ៍របស់គេស្ងប់ជំនួសឱ្យការធ្វើឱ្យវាស្ងប់ដោយ ការបណ្តោយខ្លួនដែលមិនឋិតថេរ។

ប្រពន្ធ័ពិភពលោកដែលគ្មានទីបញ្ចប់ អ្នកខ្លះគិតថា ប្រសិនបើយើងសម្រេចបាននិព្វានទាំងអស់គ្នា នោះពិភពលោកនេះនឹងទៅជាកន្លែងទទេរ ហើយគ្មាននរណាធ្វើការសំរាប់ការអភិវឌ្ឍពិភពលោកនេះឡើយ។ នេះជាគំនិតរាក់ៗដែលកើតមានឡើងនៅក្នុងគំនិត មនុស្សដែលខ្វះចំណេះដឹងពិតអំពីអត្ថិភាព។

ពួកគេគួរយល់ថា ពិភពលោកនេះនឹងមិនក្លាយទៅជាទទេរ នោះឡើយពីព្រោះមានមនុស្សមានបញ្ញា តិចណាស់ដែលអាចសម្រេចបាននិព្វាន។ ចំពោះប្រពន្ធ័ពិភពលោកដែលគេបានយកចិត្តទុកដាក់នេះគឺវាគ្មានដែនកំណត់ឡើយ។ វាមិនមានអ្វីដែលជាការចាប់ផ្តើម និងការបញ្ចប់នូវប្រពន្ធ័ពិភពលោក និងចក្រវាឡឡើយ។ ប្រពន្ធ័ពិភពលោកទាំងឡាយ តែងតែលេច

ឡើង និងបាត់ទៅវិញ។ នៅពេលដែលប្រពន្ធ័ពិភពលោកមួយបាត់ទៅប្រពន្ធ័ផ្សេង ទៀតជាច្រើនឋិតនៅ។ ជាមួយគ្នានេះប្រពន្ធ័ពិភពលោកទាំងឡាយដែលបានបែកខ្ញែកក៏លេច ឡើងវិញជាថ្មីដោយសារការរួមផ្សំនូវបណ្តុធាតុ និងថាមពលទាំងឡាយ។ សត្វលោកទាំងឡាយដែលបានចាក ចេញពីប្រពន្ធ័ពិភពលោកផ្សេងៗក៏ត្រឡប់មកមានអត្ថិភាពវិញដែរ ដោយសារការរួមផ្សំនូវបណ្តុធាតុ រូបធាតុ និងថាមពលព្រមទាំងទំនោរខាងស្មារតីរបស់គេ។ គេមិនគួរគិតថាមានការកំណត់ចំនួនសត្វលោកដែលប្រព្រឹត្ត ទៅវិលវល់នៅក្នុងលោកនេះឡើយ។ សត្វលោកគឺមិនមានកំណត់ និងគ្មានទីបំផុត។

វឌ្ឍនភាព និងការបំពុល ( Progress and Pollution ) តើយើងពិតជាកំពុងធ្វើការងារដើម្បីវឌ្ឍនភាពនៃពិភពលោកនេះមែនឬ? យើងគិតថា យើងកំពុងធ្វើការងារ ដើម្បីវឌ្ឍនភាពនៃពិភពលោកនេះ ប៉ុន្តែយើងកំពុងតែបំផ្លាញពិភពលោកនេះយ៉ាងប្រាកដ។ យើងបានរកឃើញគ្រឿងម៉ាស៊ីនជាច្រើនដើម្បីបំផ្លាញពិភពលោកនេះ។ ដើម្បីបំពេញបំណងរបស់យើង យើងកំពុងតែបំផ្លាញ ពិភពលោកនេះដោយការជីកកកាយ ការកាប់ឆ្ការ ការធ្វើឱ្យអន្តរាយ និងការបំផ្លាញសោភណ្ឌភាពបែបធម្មជាតិនៃផែនដីនេះ។ យើងកំពុងតែបំពុលបរិយាកាសទន្លេនិងសមុទ្រ។ យើងកំពុងតែបំផ្លាញជីវិតរុក្ខជាតិព្រមទាំង ជីវិតសត្វដែលកម្រ។ យើងមិនដែលគិតទេថា នៅក្នុងជីវិតរុក្ខជាតិមានតម្លៃជាថ្នាំព្យាបាល ឬជាចំណីអាហារ នោះឡើយ។ រាល់សត្វលោកទាំងអស់បានរួមចំណែកសម្រាប់ថែរក្សាបរិស្ថាន។ យើងមិនគួរសន្មត់ថា យើងជាមនុស្សលោកដែលមានសិទ្ធិរស់នៅលើផែនដីនេះទេ។គ្រប់សត្វលោកទាំងអស់មានសិទ្ធិស្មើគ្នាដើម្បីរស់នៅទីនេះ។ ប៉ុន្តែយើងបានដកហូតសិទ្ធិរបស់សត្វដទៃទៀត ។ មិនត្រឹមតែប៉ុណ្ណោះទេ សូម្បីតែនៅក្នុងសហគមន៍ មនុស្សរបស់យើងផ្ទាល់ក៏សាសន៍មួយព្យាយាម ដើម្បីបំផ្លាញសាសន៍ដទៃទៀតដែរ ដោយការរារាំងវឌ្ឍនភាព របស់គេ និងមិនអនុញ្ញាតឱ្យសាសន៍ដទៃបានរស់ក្នុងសន្តិភាព។ ពួកគេប្រកាសសង្គ្រាម ហើយចាប់ផ្តើមសម្លាប់អ្នកម្ខាងទៀតក្នុងនាមជាការស្នេហាជាតិ។

ល្គឹកណាមនុស្សលោកមានគំនិតបំពុលមានអត្ថិភាពនៅក្នុងលោកនេះ នោះនឹងគ្មានសន្តិភាពនៅលើផែនដីនេះឡើយ។ ដោយសារតែមានអត្ថិភាពនៃសត្វលោកបែបនេះ ហើយទើបផែនដីនេះបានក្លាយទៅជាកន្លែងចលាចល។ សព្វថ្ងៃនេះយើងឃើញមានការសម្លាប់រង្គាលនៅទូទាំងពិភពលោក។ មនុស្សម្នាក់ៗកំពុងតែមានគម្រោងដើម្បីបោកប្រាសអ្នកទៃ។ គំនិតអាត្មានិយមតែងតែមាននៅគំនិតរបស់ពួកគេជានិច្ច។ មនុស្សម្នាក់មិនអាចទុកចិត្តមនុស្សម្នាក់

ទៀតឡើយ។ ពួកគេមើលអ្នកផ្សេងដោយការសង្ស័យនៅក្នុងបេះដូងរបស់គេ។ គេមិនអាចយល់នូវចរិតលក្ខណៈ ឬទំនោរពិតប្រាកដរបស់មនុស្សម្នាក់ទៀតឡើយ។ ទោះបីជាមនុស្សអាចគេចផុតពី សត្វផ្សេងៗក៏ដោយ ក៏វាពិបាកនឹងគេចឱ្យផុតពីមនុស្សដែរ។

មនុស្សគឺមានទំនួលខុសត្រូវ មនុស្សតែងតែនិយាយអំពីភាពមិន ទៀងទាត់នៃស្ថានភាពពិភពលោក។ តើនរណាជាអ្នកទទួលខុសត្រូវចំពោះ ស្ថានភាពដ៏គួរឱ្យសោកស្តាយនេះ? តើមាននរណាផ្សេងទៀតក្រៅពីអ្វីដែលគេហៅថា មនុស្សឆ្លាតនោះទេ ? តើយើងអាចសង្ឃឹមថា ពិភពលោកនឹងប្រកបដោយសន្តិភាព ហើយបានប្រសើរឡើងយ៉ាងដូចម្តេច បើមនុស្សមានចរិតលក្ខណៈអាក្រក់ជាងសត្វទៅទៀតនោះ? តើយើងអាចគាប់ចិត្តនឹងជីវិតរបស់យើងនៅក្នុងពិភពលោកដែល មិនគួរឱ្យទុកចិត្តនេះម្តេចនឹងកើត? អ្នកវិទ្យាសាស្ត្រទាំងឡាយខិតខំស្វែងរកផ្លូវដើម្បីគ្របសង្កត់ធម្មជាតិចំពោះ រូបធាតុចុងក្រោយ (material ends )។ ទស្សនវិជ្ជាបូព៌ាប្រទេសទាមទារឱ្យរស់នៅដោយសុខដុមរមនាជាមួយ នឹងធម្មជាតិសំរាប់សន្តិភាពខាងគនិតនិងការសំរេចខាងស្មារតី ( peace of mind and spiritual achieve- ment )។ អ្នកមិនអាចកែស្ថានភាពពិភពលោកឱ្យទៅតាមបំណងរបស់អ្នកបានឡើយ ប៉ុន្តែអ្នកអាចកែគំនិត របស់អ្នកដើម្បីបង្កើតការសប្បាយចិត្តក្នុងការស្វែងរកសុភមង្គល។ មនុស្សម្នាក់ដែលស៊ប់តែទៅនឹងការបំពេញចិត្តខាងលោកិយនោះ នឹងមិនឈានទៅដល់ចំនេះដឹងខ្ពង់ខ្ពស់ឡើយ ប៉ុន្តែវាអាចត្រូវសំរេចបានដោយមិនមានការស្រាវជ្រាវខ្លាំងខ្លា។ សម្ភារៈនិយមធ្វើឱ្យមនុស្សធ្លាក់ទៅក្នុងស្ថានភាពជាសត្វតិរច្ឆាន ប៉ុន្តែសាសនាលើកមនុស្សឱ្យទៅជាអាទិទេព ឬជាមនុស្សថ្លៃថ្នូរ។ នៅក្នុងរបបសម្ភារៈនិយម មនុស្សក្លាយទៅជាទាសករចំពោះ ញាណរបស់ខ្លួន។ តាមធម្មជាតិ មនុស្សមិនចូលចង់ដឹងពីព្រឹត្តិការណ៍ពិតនៃជីវិតឡើយ។ ពួកគេចូលចិត្តលួងខ្លួន ឯងឱ្យមានសន្តិសុខដោយការយល់សប្តិ ការស្រមើស្រមៃ និងការចាប់យកស្រមោលខ្លឹមសារ។ ព្រះពុទ្ធមានឥរិយាបទ ចំពោះអំណាចលោកិយ និងសេចក្តីរីករាយខាងអារម្មណ៍ដូចតទៅ " ជាជាងអធិបតេយ្យភាពដាច់ខាតនៅលើផែនដី ជាជាងការទៅឋានសួគ៌ ជាជាងភាពជាម្ចាស់នៅទូទាំងពិភពលោក នោះគឺជាលទ្ធផលនៃអ្នកដែលឈ្មោះជាហូរហែរដែលជាដំណាក់កាលដំបូងនៃសុក្រិតភាព"។ដោយចំណាយជីវិតរបស់គេតែទៅលើការ អភិវឌ្ឍផ្នែកលោកិយខាងសម្ភារៈដើម្បីបំពេញចំណង់នោះ នោះមនុស្សមិនអាចរកឃើញទីចុងបញ្ចប់នៃភាព មិនជាទីពេញចិត្ត ( unsatisfactoriness ) នៃជីវិតរបស់គេឡើយ។ តាមព្រះពុទ្ធពិភពលោកនេះពោរពេញ ដោយជម្លោះការរង្កៀសចិត្តគ្នា ឬភាព

មិនជាទីពេញចិត្ត។ ដោយដឹងពីធម្មជាតិពិតនៃស្ថានភាពពិភពលោកនេះ ព្រះពុទ្ធក៏មានពុទ្ធដិកាដែរថា គេមិនធ្វើការសរសើរពិភពលោកនេះទេ នៅពេលដែលវាមិនជាទីពេញចិត្ត និងមិនឋិតថេរ។ ព្រះអង្គបន្ថែមទៀតថា ផ្លូវនាំទៅរកការចំណេញខាងលោកិយគឺជាផ្លូវមួយហើយទៅរកទិដៅ ចុងក្រោយដែលជានិព្វាន្តនោះគឺជាផ្លូវមួយផ្សេងទៀត។

មនុស្ស និងអ្នកជាទីស្រលាញ់របស់គេ ( The Man and His Honey ) នេះគឺជាការអធិប្បាយជារូបាធិដ្ឋានតូច មួយសម្រាប់យើងដើម្បីយល់ពីធម្មជាតិជីវិត និងសេចក្តីសប្បាយលោកិយ : មនុស្សបានបោះបង់ផ្លូវរបស់ខ្លួនចោលនៅពេលដែលគេកំពុងធ្វើដំណើរឆ្លងកាត់ព្រៃក្រាស់មួយដែលពោរពេញ ទៅដោយបន្លា និងថ្ម។ បន្ទាប់មកគេមានបញ្ហាដោយសត្វដំរីដ៏ធំមួយបានដេញគេ។ គេចាប់ផ្តើមរត់ដើម្បីជីវិតរបស់គេរស់។ នៅពេលដែលគេកំពុងរត់គេបានឃើញអណ្តូងមួយហើយគេគិតថា នេះជាកន្លែងដ៏ល្អសម្រាប់ឱ្យគេគេចខ្លួនចេញពីសត្វដំរីនោះ។ ប៉ុន្តែជាអកុសលបំផុត គេបានឃើញពស់មានពិសធំមួយនៅបាតអណ្តូងនោះ។

តែទោះជាយ៉ាងណាក្តី នៅពេលដែលគ្មានវិធីណាផ្សេងដើម្បីគេចចេញពីសត្វដំរីនេះ គេបានលោតចូល ទៅក្នុងអណ្តូរ ហើយចាប់វល្លិដែលដុះនៅនឹងជញ្ជាំងម្ខាងរបស់អណ្តូង។ នៅពេលដែលគេកំពុងតោងវល្លិ គេបានឃើញកណ្តុរពីរក្បាល គឺពណ៌សមួយ និងពណ៌ខ្មៅមួយ។ គេមានការភ័យខ្លាចថា សត្វកណ្តុរពីរក្បាលនេះនឹងកាត់វល្លិដែលគេកំពុងតោងនេះបន្តិចម្តង១។ គេក៏បានឃើញផងដែរនូវសម្បុកឃ្មុំមួយដែលនៅជិតគេហើយយូរ១ម្តងទឹកវាបានស្រក់ធ្លាក់ចុះ។

ខណៈពេលប្រឈមមុខ ចំពោះសេចក្តីស្លាប់របស់ខ្លួននៅក្នុងកន្លែងមានគ្រោះថ្នាក់បីយ៉ាងបែបនេះ គេចាប់ផ្តើមទទួលរស់ជាតិដំណក់ទឹកឃ្មុំ។ ដោយមើលឃើញពីស្ថានភាពដ៏គួរឱ្យអាណិតអាសូរនៃបុរសក្រីក្រនេះ ប្រភេទមនុស្សមួយទៀតដែលបានកើតឡើង ដើម្បីចៀសរួចនោះបានស្ម័គ្រចិត្តហុចដៃដើម្បីជួយសង្គ្រោះជីវិតរបស់គាត់។ ប៉ុន្តែមនុស្សឆ្កួត និងពោរពេញដោយសេចក្តីលោភលន់នេះមិនព្រមស្តាប់គាត់ឡើយ ដោយសារតែ គេចូលចិត្តនឹងរស់ជាតិទឹកឃ្មុំនេះ។ រស់ជាតិទឹកឃ្មុំនេះបានធ្វើឱ្យគាត់វង្វេងដោយមិនខ្វល់ពីទីកន្លែងគ្រោះថ្នាក់ ដែលគេកំពុងជួបនោះឡើយ។

នៅក្នុងការអធិប្បាយប្រៀបធៀបនេះ ផ្លូវដែលមានបន្លានៅក្នុងព្រៃគឺ ប្រៀបបានទៅនឹង Samsara ជាវដ្តនៃអត្ថិភាព។ ផ្លូវដែលមានបន្លានៃ Samsara នេះគឺជាផ្លូវមួយដែលមិនទៀងទាត់ និងជាហេតុកង្វល់មួយដ៏ធំ។ វាមិនមែនជាការងាយស្រួលទេសម្រាប់ ឱ្យមនុស្ស

ប្រព្រឹត្តជីវិតរបស់ខ្លួនឆ្លងកាត់ព្រៃដែលប្រកបដោយបន្លា និងរដឹបរដុបនៃ Samsara នេះ។ សត្វដ៏រីនៅទីនេះគឺតំណាងឱ្យសេចក្ដីស្លាប់។ សេចក្ដីស្លាប់តែងតែតាមយើងពី ក្រោយជានិច្ច និងធ្វើឱ្យយើងមិនបានសប្បាយ ហើយអាយុចាស់ក៏ធ្វើឱ្យយើងមិនមានសុភមង្គល និងអសន្តិសុខ នៅក្នុងស្ថានតឹផងដែរ។ វល្លិគឺកំណើតរបស់យើង។ ជាតិជាវល្លិគឺបន្តការលូតលាស់ និងដុះពទ្ធ័ជុំវិញដើមឈើផ្សេងៗ ដូច្នេះកំណើតរបស់យើងក៏បន្តការចំរើនឡើង ការពឹងអាស្រ័យចំពោះអ្វីៗ ជាច្រើនទៀតនៅលើពិភព លោកនេះដែរ។ សត្វកណ្ដុរពីរ គឺតំណាងឱ្យថ្ងៃ និងយប់។ ចាប់តាំងពីថ្ងៃដែលយើងកើតមកនៅក្នុងលោកនេះ វដ្ដថ្ងៃនិងយប់បានបង្រួញ និងកាត់វិសាលគមជីវិតរបស់យើងជានិច្ច។ ដំណក់ទឹកឃ្មុំទាំងឡាយជាសេចក្ដីរីក រាយបែបលោកិយខាងអារម្មណ៍មិនឋិតថេរ ដែលធ្វើឱ្យមនុស្សចង់រស់នៅក្នុងពិភពលោក ដែលមិនទៀងទាត់ និងមិនអចិន្ត្រៃនេះ។ ប្រភេទមនុស្សដែលមកហុចដៃជួយដើម្បីបង្ហាញគេនូវផ្លូវត្រឹមត្រូវនិងធ្វើឱ្យស្ថានភាពគ្រោះរបស់គេវិនាសខ្ទាត់ខ្ទាយនោះ គឺព្រះពុទ្ធជាម្ចាស់។

មនុស្សដែលគិតថា ការរស់នៅក្នុងពិភពលោកនេះ វាជាការប្រសើរសំរាប់គេដើម្បីសេចក្ដីសប្បាយនឹង ជីវិតលោកិយដោយមិនមានការព្យាយាមដើម្បីសំរេចនិព្វាននោះ គឺពិតជាដូចមនុស្សដែលមិនព្រមគេចចេញពី ស្ថានភាពគ្រោះថ្នាក់ជីវិតរបស់គេ ដោយគ្រាន់តែបានភ្លក់រស់ជាតិទឹកឃ្មុំបន្តិចបន្តួចនោះអញ្ចឹងដែរ។ គោលបំណងនៃជីវិត គឺដើម្បីទទួលបានការរំដោះចេញពីបន្ទុកខួរក្បាល និងរាងកាយ។

**ជីវិតមិនទៀងទាត់ សេចក្ដីស្លាប់ទៀងទាត់** (By Ven. Dr. K. Sri Dhammananda)

" *ជីវិតមិនទៀងទាត់ សេចក្ដីស្លាប់គឺទៀងទាត់* "។ នេះជាសំដីដ៏ល្បីល្បាញរបស់ពុទ្ធសាសនា។ ការដឹងយ៉ាងច្បាស់ថា សេចក្ដីស្លាប់គឺទៀងទាត់ ហើយជាបាតុភូតធម្មជាតិដែលគ្រប់រូបត្រូវតែប្រឈមមុខនោះ ដូច្នេះ យើងមិនគួរភ័យខ្លាចសេចក្ដីស្លាប់ទេ។ ប៉ុន្តែយើងទាំងអស់គ្នាភ័យខ្លាចសេចក្ដីស្លាប់ដោយសារតែយើងមិនគិតពី ភាពមិនអាចចៀសផុតរបស់វា។ យើងមានបំណងប្រកាន់ខ្ជាប់រាងកាយ និងជីវិតរបស់យើងហើយបង្កើតតណ្ហានិងការជំពាក់ចិត្តជាច្រើន។

ក្មេងម្នាក់ចាប់កំណើតក្នុងពិភពលោកនេះ ដែលនាំមកនូវក្ដីរីករាយ និងសុភមង្គលដល់អ្នកជិតខាង និងជាទីស្រឡាញ់ទាំងអស់។ សូម្បីតែអ្នកម្ដាយដែលត្រូវទទួលស៊ូទ្រាំពីមាតុភាពក៏រីករាយសប្បាយដែរ។គាត់មានអារម្មណ៍ថាបញ្ហាលំបាកនិងភាពឈឺចាប់ក្នុងការផ្ដល់កំណើតគឺមានតម្លៃ។ ទោះយ៉ាងណាតាមរយៈការយំ ក្មេងទំនងជាបង្ហាញថា វាមានចំណែកនៃទុក្ខរបស់វាក្នុងការមកយកកំណើតក្នុងពិភពលោក។ ក្មេងរីកចម្រើន ទៅធំហើយពេញវ័យ ដែលធ្វើនូវ

អំពើទាំងល្អ និងអាក្រក់គ្រប់ប្រភេទ។ គាត់វិវត្តទៅចាស់ហើយទីបំផុត លាចាកលោកនេះ ដោយទុកឱ្យញាតិសន្តាននៅសោកសៅ។ ទាំងហ្នឹងជាអត្ថិភាពរបស់មនុស្សលោក។ មនុស្ស ព្យាយាមគេចពីការក្តោបក្តាប់នៃសេចក្តីស្លាប់ ប៉ុន្តែមិនមាននរណាម្នាក់អាចធ្វើទៅរួចទេ។ នៅ ពេលជិតស្លាប់ ពួកគេមានគំនិតរបស់ពួកគេដែលហោះហើរលើគំនរទ្រព្យសម្បត្តិ ដែលរកបាន របស់ពួកគេ ការព្រួយបារម្ភពីកូនសំឡាញ់ដែលនៅជុំវិញពួកគេហើយជា ចុងបញ្ចប់តែមិន តិចតួចនោះដែរ គឺការបង្ហាញឱ្យឃើញការព្រួយ អំពីរាងកាយរបស់ពួកគេដែលទោះបីជាបាន ថែទាំយ៉ាងណាក៏កាន់តែរិចរិល និងអស់ថាមពលទៅ។ វាទាញបេះដូងចេញពីរាងកាយ។ វាមិន អាចអត់ធន់បាន ទោះបីមិនអាចចៀសផុតបានក៏ដោយ។ វាជាផ្លូវដែលមនុស្សជា ច្រើនចាក ចេញពីពិភពលោកដោយសម្លេងថ្ងូរ និងត្អូញត្អែរ។ ការឈឺចាប់នៃសេចក្តីស្លាប់ ត្រូវបានកំណត់ គួរឱ្យខ្លាចដែលជាឥរិយាមួយដែលរក្សាដោយភាពអវិជ្ជា។

**ការភ័យខ្លាចសេចក្តីស្លាប់** ( Fear of Death )

មនុស្សមិនត្រូវបានរំខានដោយវត្ថុខាងក្រៅទេ គឺដោយជំនឿ និងការស្រមើស្រមៃ ដែលពួកគេរៀបចំវត្ថុ និងការរស់នៅរបស់ពួកគេ។ ឧទាហរណ៍ សេចក្តីស្លាប់វាមិនគួរឱ្យខ្លាច ដោយខ្លួនវាទេ តែភាពគួរឱ្យខ្លាចវាស្ថិតក្នុង គំនិតរបស់យើងតែម្យ៉ាងគត់ ។ ការទទួចផ្អែកលើ សេចក្តី ពិតនៃទុក្ខប្រហែលទំនងគួរឱ្យភ័យខ្លាចចំពោះគំនិត ដែលមិនអាចប្រឈមមុខនឹង សច្ចភាព ប៉ុន្តែជួយកាត់បន្ថយ ឬបោះចោលនូវភាពគួរឱ្យខ្លាច ឬភាពភ័យខ្លាច ដោយការយល់ ដឹងពីរបៀបដើម្បីប្រឈមមុខនឹងសេចក្តីស្លាប់។ ជីវិតមួយត្រូវបានចាប់ផ្តើមធ្វើដូចជាគ្រាប់ កាំ ភ្លើងមួយគ្រាប់វាប្រញាប់ទៅកាន់គោលដៅរបស់វា គឺសេចក្តីស្លាប់។ ការដឹងដូច្នេះ យើងត្រូវ តែប្រឈមមុខ នឹងការកើតឡើងជាធម្មជាតិដោយក្លាហាន។ ដើម្បីឱ្យមានសេរីភាពក្នុងជីវិត យើងត្រូវតែមានសេរីភាពចេញ ពីការភ័យខ្លាចនៃសេចក្តីស្លាប់។ ចូរចងចាំអ្វីដែលវិទ្យាសាស្ត្រ បង្ហាញយើងអំពីដំណើរនៃការស្លាប់។ វាគ្រាន់តែ ជាសំណើកសរីរសាស្ត្រនៃរាងកាយមនុស្ស ប៉ុណ្ណោះ។ យើងមិនគួរបោកប្រាស់ខ្លួនឯងដោយសេចក្តីខ្លាច ដែលស្រមៃឬស្មាននោះទេ ដែល ជាការស្រមៃដែលមិនដែលកើតឡើង។ ក្នុងនាមជារូបវិទូដ៏ល្បីល្បាញលោក Sir Williams Oslet ថា " តាមបទពិសោធន៍ នៃមន្ទីរព្យាបាលមនុស្សភាគច្រើនស្លាប់ដោយគ្មានការ ឈឺចាប់ ឬភ័យខ្លាចយ៉ាងពិតប្រាកដ "។

ពេលមួយគិលានុបដ្ឋាយិកាជើង ចាស់ម្នាក់បាននិយាយថា : " វាតែងតែហាក់ដូចជាសោកនាដកម្មដ៏ធំធេងសម្រាប់ខ្ញុំដែលមនុស្សជាច្រើន ធ្វើដំណើរទៅតាមជីវិតដែលត្រូវបានបន្លាចដោយការភ័យខ្លាចនៃសេចក្តីស្លាប់ គឺគ្រាន់តែដើម្បីស្វែងរកពេលណាដែលវាមកដល់ចំណុចថាវាធម្មជាតិដូចជីវិតវាផ្ទាល់។ ចំពោះមនុស្សពីរ បីរូបខ្លាចស្លាប់នៅពេលដែលពួកគេជិតទៅដល់ទីបញ្ចប់។ តាមបទពិសោធន៍ទាំងអស់របស់ខ្ញុំមានតែមួយ ប៉ុណ្ណោះទំនងជាមានអារម្មណ៍តក់ស្លុតខ្លាំង គឺស្ត្រីម្នាក់ដែលបានធ្វើរឿងអាក្រក់ ដែលវាយឺតណាស់ទៅហើយ ដើម្បីឱ្យទៅល្អចំពោះប្អូនស្រីរបស់គាត់ "។

"អ្វីដែលចំឡែក និងស្រស់ស្អាតកើតឡើងចំពោះបុរស និងស្ត្រីនៅពេលដែលពួកគេមកដល់ទីបញ្ចប់នៃផ្លូវ ។ទាំងការភ័យខ្លាចទាំងភាពគួរឱ្យខ្លាចមិនកើតឡើង។ ខ្ញុំជារឿយៗមើលឃ្លកពានៃមន្ទិល ត្រេកអរ ដែលមានក្នុងក្រសែភ្នែករបស់ពួកគេនៅពេលពួកគេដឹងថា នេះជាការពិត។ វាជាផ្នែកទាំងអស់ នៃសេចក្តីល្អនៃធម្មជាតិ។" ការចងភ្ជាប់ទៅនឹងជីវិតលើផែនដីបង្កើតនូវការភ័យខ្លាចដែលមិនមែនជាធម្មជាតិនៃសេចក្តីស្លាប់។ វាបង្កើតនូវកង្វល់ជាខ្លាំងនៅក្នុងជីវិតដែលឱ្យផលចំពោះមនុស្សដែល នឹងមិនចាប់យកភយន្តរាយសូម្បីចំពោះអ្វីដែលត្រឹមត្រូវ។ គាត់រស់នៅក្នុងភាពតក់ស្លុតទាបបំផុត ដែលគ្រោះថ្នាក់ឬជំងឺមួយចំនួនបញ្ចប់នូវជីវិតដ៏តូចដែលមានតម្លៃដែលគាត់ស្រឡាញ់ជាទីបំផុត ។ការដឹងច្បាស់ថា សេចក្តីស្លាប់គឺមិនអាចចៀសរួចនោះអ្នកដែល ស្រឡាញ់ជីវិតលើ ផែនដីនឹងទៅជាអ្នកបួងសួងដែលងប់នឹងសាសនា ដែលបញ្ជាក់សេចក្តីសង្ឃឹមថាវិញ្ញាណរបស់ គាត់នឹងរស់នៅលើឋានសួគ៌។ គ្មានមនុស្សណាម្នាក់អាចរីករាយដោយពោរពេញដោយ សេចក្តីភ័យខ្លាច និងសេចក្តីសង្ឃឹមនោះទេ។ ប៉ុន្តែវាពិបាកក្នុងការស្អប់ឬមិនអើពើនឹងការសម្តែងនៃសភាវគតិចំពោះការការពារខ្លួនឯងទាំងនេះណាស់។ ទោះយ៉ាងណាមានវិធីសាស្ត្រនៃការពុះពារនឹងសេចក្តីភ័យខ្លាចនេះ។ បំភ្លេចបញ្ញត្តិខ្លួនឯង ហើយបង្វែរសេចក្តីស្រឡាញ់ក្នុងការផ្តល់នូវ ការបម្រើមនុស្សជាតិ និងក្នុងការបង្ហាញសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ។ នៅពេលអ្នកស្លួងក្នុងការបម្រើអ្នកដទៃនោះអ្នកនឹងដោះលែងខ្លួនឯងពីភាពអាត្មានិយមការជំពាក់ចិត្តនិងសេចក្តី សង្ឃឹមដ៏ខ្លាំងក្លាហើយនិងតម្លៃ និងភាពត្រឹមត្រូវផ្ទាល់ខ្លួន។

**ជំងឺ និងសេចក្តីស្លាប់** ( Illness and Death )

ទាំងជំងឺ និងសេចក្តីស្លាប់ជាហេតុធម្មជាតិនៃការណ៍នៅក្នុងជីវិត ហើយត្រូវតែទទួលស្គាល់ដោយការយល់ដឹង។ យោងតាមទ្រឹស្តីចិត្តវិទ្យាទំនើប ការតានតឹងផ្លូវចិត្តក៏រឹតទាបកើត

មកពីការបដិសេធទៅនឹងការ ប្រឈមមុខនិងការទទួលស្គាល់ពីភាពពិតនៃជីវិត។ ការតានតឹងនេះបង្កទៅជាជំងឺផ្លូវចិត្តធ្ងន់ធ្ងរ (លុះត្រាតែជំនះឬបង្កាទើបមិនបង្កទៅជាជំងឺផ្លូវចិត្តធ្ងន់ធ្ងរ )។ ការរក្សាទឹកចិត្តបារម្ភ និងអស់សង្ឃឹមខ្លាំងលើសពីជំងឺ ទៀតនោះនឹងប្រាកដជាធ្វើឱ្យវាកាន់តែអាក្រក់។ ព្រោះថាសេចក្តីស្លាប់ វាត្រូវតែមិនត្រូវបានខ្លាចដោយអ្នក ដែលមានអំពើ និងចិត្តបរិសុទ្ធទេ។ យើងទាំងអស់គ្នាគឺ មិនមែនជាអ្វីទាំងអស់ក្រៅតែពីការបញ្ចូលគ្នានៃគំនិត និងបញ្ហា ហើយបែបហ្នឹងជាការពិតមិនមានភាពឯកត្តជនស្លាប់នោះទេ។ អន្តរកម្មអាក្រក់នៃកម្មដែលកើត ចេញពីអំពើអាក្រក់ពីអតីតកាលប្រហែលពន្យាការចាប់កំណើតរបស់យើង ដូច្នេះបណ្តាលឱ្យយើងរែកពន់ទុក្ខ នៃកម្មក្នុងជីវិតថ្មីមួយ។ យថាហេតុមួយបែបហ្នឹង អាចត្រូវចៀសផុត បើយើងប្រឹងប្រែងធ្វើបុណ្យដោយការធ្វើ ឱ្យជីវិតប្រកបដោយគុណធម៌ និងអំពើបុណ្យដោយពេល និងកន្លែងណាក៏ដោយតាមដែលអាចធ្វើបាន។ តាមរយៈការធ្វើដូច្នោះ យើងអាចប្រឈមនឹងវាដោយក្លាហាន និងជាក់ស្តែង ព្រោះយោងតាមឱវាទពុទ្ធសាសនា គ្មានអ្នកជួយសង្គ្រោះដែលទទួលភារៈរបស់យើង ដើម្បីធ្វើឱ្យធូរស្រាលពីវិបាកនៃអំពើ ខុសឆ្គងរបស់យើងនោះទេ។ យើងគួរតែរំឭកខ្លួនឯងពីឱវាទព្រះពុទ្ធៈ " ចូរអ្នកជ្រកពួន និងធ្វើឱ្យទៅជាកោះជិតខ្លួនអ្នក ហើយអនុវត្ត ដោយយកចិត្តទុកដាក់។" ពុទ្ធសាសនិកមិនគួរសោកសង្រេងខ្លាំងក្លា នឹងការស្លាប់របស់សាច់ញាតិ ឬមិត្តភក្តិទេ។ មិនមានការបញ្ឈប់ដំណើរនៃទេសកាលបានទេ។ នៅពេលដែលមនុស្សម្នាក់ស្លាប់ ការបន្តកម្មនៃឥរិយាបថ របស់គាត់ឆ្លងទៅកាន់ភាវៈថ្មីមួយ។ ទាំងនោះដែលត្រូវបានទុកចោលតាមក្រោយគួរតែស៊ូទ្រាំនឹងការរលត់ទៅ ដោយស្ងៀមស្ងាត់ និងយល់ដឹង។ សេចក្តីស្លាប់ជាដំណើរដែលមិនអាចចៀសផុតនៃពិភពលោកនេះ។ នោះជា វត្ថុមួយដែលពិតក្នុងចក្រវាឡនេះ។ ព្រៃអាចត្រូវបានប្រែក្លាយទៅជាទីក្រុង ហើយទីក្រុងទៅជាផ្នូកខ្សាច់។ កន្លែងដែលមានភ្នំអាចមានបឹង។ ភាពមិនពិតមានគ្រប់ទីកន្លែង តែសេចក្តីស្លាប់គឺពិត។ ទាំងអស់ផ្សេងទៀត ជាពេលមួយ។ យើងមានបុព្វបុរសរបស់យើង ហើយក្នុងការត្រឡប់របស់ពួកគេពួកគេមានរបស់ខ្លួន ប៉ុន្តែពួក គេនៅឯណា! ពួកគេចាកចេញទៅ។

ការធ្វើមិនឱ្យជឿនលឿនសន្មតជាមុនថា ទស្សនៈទុទិដ្ឋិនិយមនៃជីវិតកំពុងត្រូវបានបង្ហាញនៅទីនេះ។ នេះជាទស្សនៈប្រាកដបំផុតរបស់ក្រុមប្រាកដនិយមទាំងអស់។ តើហេតុអ្វីយើងមិនប្រាកដហើយធ្វើឱ្យងងឹតចំពោះតថភាពពិត? តើសេចក្តីស្លាប់មិនបំផ្លាញអ្វីៗគ្រប់យ៉ាងទេឬ? វាបំផ្លាញ។ បណ្តោយឱ្យគំនិតនេះមិនត្រូវ បានបំភ្លេច។ តួនាទីនៃសេចក្តីស្លាប់ គឺការធ្វើ

ឱ្យមនុស្សដឹងពីវាសនារបស់ខ្លួន ហើយទោះគាត់អាចត្រូវបានផ្លាស់ ប្តូរដោយជំនួយអ្វីក៏ដោយ ទាំងផ្នែកបច្ចេកវិជ្ជា ឬវិទ្យាសាស្ត្រឱសថសាស្ត្រដែលគាត់មានក៏ដោយ ក៏ទីបញ្ចប់ របស់គាត់គឺដូចគ្នាទាំងអស់ គឺនៅក្នុងមឈូស ឬនៅសល់តែផេះមួយក្តាប់។ តើយើងគួរតែពាក់សំពត់បាវដើម្បី កាន់ទុកជីវិតដែលប្រែក្លាយទៅជាផេះឬទេ ? ទេ នេះមិនមែនជាគោលបំណងនៃជីវិត ឬសេចក្តីស្លាប់ទេ។ដំណើរនៃការចាប់កំណើតជាដំណើរបន្តមួយរហូតដល់យើងក្លាយទៅជាឥតខ្ចោះ។

**ឥទ្ធិពលរបស់មនុស្សស្ថិតនៅ** ( Man’s Influence Persists )

ព្រះពុទ្ធមានពុទ្ធដីកាថា: " រាងកាយរបស់មនុស្សក្លាយទៅជាធូលី ប៉ុន្តែកេរ្តិ៍ឈ្មោះ ឬឥទ្ធិពលរបស់គាត់ស្ថិតនៅ។" ឥទ្ធិពលនៃជីវិតពីអតីតកាលជូនកាលឈានទៅឆ្ងាយជាង និងមានសក្តានុពលជាង ដែលត្រូវបានប្រកាន់ដោយរាងកាយ ដែលស្ថិតនៅជាមួយនឹងការកំណត់ជាក់លាក់។ ជានិច្ចកាលធ្វើអំពើទៅលើគំនិតដែលត្រូវ បានបំផុសដោយភាពជាបុគ្គលដែលសំណល់នៃការស្លាប់របស់គេប្រែទៅជាធូលី។ ក្នុងស្មាដៃរបស់យើងគំនិតបែបហ្នឹងក៏ដើរតួនាទីសំខាន់ដែរ។ មនុស្សមានជីវិតគ្រប់រូបត្រូវបានចាត់ទុកថាជាការរួមផ្សំនៃដូនតារបស់គាត់ ដែលបានចាកឋានមុនគាត់។ក្នុងន័យនេះយើងអាចសន្មតថា វីរបុរស ទស្សនវិទូ វិញ្ញូជនអ្នកកំណាព្យ និង តន្ត្រីករពីអតីតៈនៃគ្រប់ជាតិសាសន៍គឺនៅតែស្ថិតនៅជាមួយយើង។ ខណៈដែលយើងភ្ជាប់ខ្លួនឯងទៅនឹងអ្នកគិត និងទុក្ករបុគ្គលពីអតីតកាល នោះយើងអាចចូលរួមគំនិតឆ្នើមរបស់ពួកគេ ឧត្តមគតិខ្ពង់ខ្ពស់របស់ពួកគេ ហើយសូម្បីតែតន្ត្រីឋិតថេររបស់ពួកគេនៅជំនាន់នោះ។ បើទោះបីជារាងកាយរបស់ពួកគេបានស្លាប់តែឥទ្ធិពលរបស់ពួកគេស្ថិតនៅ។ រាងកាយគឺទទេលើកលែងឱភាសកម្មអរូបីមួយចំពោះការផ្លាស់ប្តូរ ការបញ្ចូលគ្នានៃធាតុគីមីផ្សេងៗប៉ុណ្ណោះ។ មនុស្សដឹងច្បាស់ថាជីវិតរបស់គេគឺ គ្មានអ្វីក្រៅពីដំណក់ទឹកមួយតក់នៅក្នុងទន្លេ ដែលហូរខាងលើមួយ ហើយរីករាយក្នុងការបរិច្ឆាកផ្នែក របស់គាត់ទៅដល់ខ្សែទឹកដ៏ធំ ដែលត្រូវបានហៅថាជីវិត។ មនុស្ស ដែលមិនដឹងពីធម្មជាតិនៃជីវិតរបស់គេប្រៀបដូចជាប់ផុងក្នុងភក់នៃពិភពនេះ។ គាត់យំគាត់ស្រែក ហើយជូនកាលញញឹមគ្រាន់តែដើម្បីយំម្តងទៀត។ ប៉ុន្តែនៅពេលដែលគាត់ដឹងពីអ្វីជាធម្មជាតិពិតរបស់គាត់ គាត់ក៏បោះបង់វត្ថុមិនឋិតថេរទាំងអស់ចោល ហើយស្វែងរកពិភពខាងក្រៅ។ ជាចម្បងដើម្បីសម្រេចពិភពខាងក្រៅគាត់ ត្រូវតែប្រឈមមុខសេចក្តីស្លាប់ម្តងហើយម្តងទៀត។ ដោយសារសេចក្តីស្លាប់ផ្ទាល់មិនអាចអត់ទ្រាំបាន តើ មនុស្សមិនគួរព្យាយាមពុះពារបន្តការកើត និងស្លាប់ឡើងវិញទេឬ?

យោងតាមពុទ្ធសាសនា នេះមិនមែនជាជីវិតដំបូង និងចុងបញ្ចប់ដែលយើងមានក្នុងពិភពលោកនេះទេ។ បើអ្នកធ្វើល្អដោយភាពជឿជាក់ អ្នកនឹងអាចទទួលបានជីវិតនាអនាគតដែលល្អប្រសើរជាង។ ម្យ៉ាងទៀត បើអ្នកមានអារម្មណ៍ថាអ្នកមិនចង់កើតម្តងហើយម្តងទៀត អ្នកត្រូវតែបំពេញការងារសំដៅទីបញ្ចប់នេះដោយ ការបំបាត់ភាពមិនបរិសុទ្ធនៃគំនិត។

**ទស្សនវិជ្ជាពុទ្ធសាសនា** ( Buddhist Philosophy )

សន្តបុគ្គលជាន់ខ្ពស់ ដែលបានសម្រេចឈាននៃភាពឥតខ្ចោះខ្ពស់បំផុតមិនសោកសង្រេងនៅពេលអ្នកជាទីស្រឡាញ់ និងអ្នកជិតស្និទ្ធលាចាកទៅទេ ព្រោះពួកគេបានលះបង់វេទនារម្មណ៍នៃមនុស្សរបស់ពួកគេទាំង ស្រុងទៅហើយ។ Ven Anuruddha ជាមនុស្សបន្ទាប់ពី Arahant ដែលមិនសោកសង្រេងនៅពេលដែលព្រះពុទ្ធលាចាកទៅ។ ទោះយ៉ាងណាVen Ananda ជាអ្នកដែលជា Sotapanna ម្នាក់គត់នៅពេលនោះហើយក៏ជាអ្នកដែលសម្រេចបានត្រឹមតែឈានដំបូងនៃភាពជាសន្តបុគ្គលក៏មិនអាចសោកសង្រេងបានដែរ តែអាចបង្ហាញទុក្ខព្រួយរបស់គាត់។ ការយំភិក្ខុ (bhikkhu) ចាំបាច់ត្រូវបានដាស់តឿនពីគំនិតរបស់ព្រះពុទ្ធពីស្ថានភាព នៃធម្មជាតិនេះដូចតទៅ :

" អានន្ត តើព្រះពុទ្ធមិនបានប្រាប់យើងទេថា អ្វីជាកំណើត អ្វីដែលមកជាភាវៈ អ្វីដែលត្រូវបានរួម បញ្ចូលគ្នា និងអ្វីដែលជាកម្មវត្ថុទៅកាន់ការរលាយ ? នោះជាធម្មជាតិនៃទម្រង់លក្ខខណ្ឌទាំងអស់ដើម្បីកើត និងបាត់បង់ (ការមានរបស់ម្យ៉ាងត្រូវបានកើតឡើងពួកវាត្រូវតែបាត់បង់) ហើយនៅពេលដែលទម្រង់បែប ហ្នឹងបញ្ឈប់សព្វគ្រប់ហើយ នោះភាពស្ងប់សុខខ្ពស់បំផុត (Peace Supreme) មានមក។" ពាក្យទាំងនេះ ពណ៌នាពីការកសាងលើ អ្វីដែលទម្រង់នៃទស្សនវិជ្ជាពុទ្ធសាសនាត្រូវបានស្ថាននា។

**ហេតុនៃទុក្ខព្រួយ** ( Cause of Sorrow )

តាមទម្រង់របស់វាទាំងអស់ ហេតុនៃទុក្ខព្រួយ និងភាពក្រៀមក្រំរបស់យើងគឺ ការជំពាក់ចិត្ត (តណ្ហា Tanha) ។ បើយើងចង់បញ្ឈប់ទុក្ខព្រួយ យើងចាំបាច់ត្រូវបោះបង់ការជំពាក់ចិត្ត ដែលការជំពាក់មិនមែន ត្រឹមតែបុគ្គលទេគឺទាំងកម្មសិទ្ធិផងដែរ។ នេះជាការពិតហើយនេះជាមេរៀនដែលថា សេចក្តីស្លាប់មានន័យ។ ការជំពាក់ចិត្តផ្តល់ឱ្យយើងនូវរបស់ជាច្រើនដើម្បីធ្វើឱ្យស្កប់វេទនារម្មណ៍របស់យើង និងដើម្បីនាំជីវិតដោយលោកិយ។ លុះត្រាយើងបានសិក្សាមេរៀននេះ ទើបយើងដឹងថាសេចក្តីស្លាប់អាចប្រហារយើង និងធ្វើឱ្យយើងពោរពេញដោយសេចក្តីតក់ស្លុត។ តថភាពត្រូវបានបង្ហាញយ៉ាងច្បាស់ដោយព្រះពុទ្ធ ដែលព្រះអង្គត្រាស់

ថា : " សេចក្តីស្លាប់នឹងនាំគាត់ចេញទៅ បើទោះបីជាគាត់ជាប់ជំពាក់នឹងកូន និងកម្មសិទ្ធិរបស់គាត់ក៏ដោយ គឺប្រៀបដូច ទឹកជំនន់ក៏ធំមួយនាំយកអ្នកភូមិ ដែលកំពុងលុងលក់មួយទៅបាត់ដូច្នោះដែរ ។"

សម្តីនេះបង្ហាញថាបើអ្នកភូមិមិនលុងលក់ទេ ដោយនៅដឹងខ្លួន ហើយប្រុងប្រយ័ត្ននោះ នោះមហន្តរាយដែលកើតដោយទឹកជំនន់នឹងត្រូវបានបញ្ចៀស ។

**សេចក្តីស្លាប់គឺសាកល** ( Death is Universal )

ពេលនេះសូមឱ្យយើងពិនិត្យមធ្យោបាយ ដែលព្រះពុទ្ធដោះស្រាយបញ្ហានេះចំពោះមនុស្សពីរនាក់ដែល ( តាមរយៈការជំពាក់ចិត្ត ) ត្រូវបានធ្វើឱ្យព្រួយជាខ្លាំងដោយសេចក្តីស្លាប់ ។ មនុស្សទីមួយគឺ Kisagotami ។ កូនរបស់នាងបានស្លាប់បន្ទាប់ពីត្រូវបានពស់ចិក ។ នាងបានទៅរកព្រះពុទ្ធដោយបីកូនដែលស្លាប់របស់នាងក្នុងដៃទៅសុំការជួយ ។ ព្រះពុទ្ធបានឱ្យនាងទៅគ្រាប់ពូជស្ពៃខ្មៅពីបីគ្រាប់ពីគ្រួសារមួយ ដែលមិនមាននរណាម្នាក់ស្លាប់ ។ ប៉ុន្តែនាងមិនអាចរកបានគ្រួសារបែបហ្នឹងទេ ។ គ្រប់ផ្ទះទាំងអស់សុទ្ធតែមានទុក្ខព្រួយ ឬធ្លាប់មានទុក្ខព្រួយចំពោះសេចក្តីស្លាប់ម្តងឬលើសពីហ្នឹង ។ ពេលនោះនាងដឹងពីសេចក្តីពិត ដែលល្វីងជូរចត់ថាសេចក្តីស្លាប់ គឺសាកល ។ សេចក្តីស្លាប់វាយប្រហារគ្រប់គ្នាហើយមិនបន្ធូរបន្ថយនរណាម្នាក់ទេ ។ ភាពទុក្ខព្រួយជាមរតករបស់មនុស្សគ្រប់រូប ។

មនុស្សម្នាក់ផ្សេងទៀតដែលព្រះពុទ្ធបានទូន្មានគឺ Patacara ។ ករណីរបស់គាត់កំសត់ជាង ។ ជាមួយ នឹងពេលវេលាដ៏ខ្លីនាងបានបាត់បង់ដល់ទៅកូនពីរនាក់ ប្តី បងប្រុស ឪពុក-ម្តាយ និងទ្រព្យសម្បត្តិរបស់នាង ទាំងអស់ ។ ដោយការបាត់បង់សតិ នាងបានរត់ដោយកាយអាក្រាត និងដូចជាសត្វព្រៃតាមផ្លូវរហូតដល់ជួបព្រះពុទ្ធ ។ ព្រះពុទ្ធបានធ្វើឱ្យនាងដឹងសតិវិញ ដោយការពន្យល់ថា សេចក្តីស្លាប់ត្រូវតែចាត់ថា ជាបាតុភូតធម្មជាតិចំពោះភាវរសទាំងអស់ ។

" អ្នកមានទុក្ខពីស្ថានភាពស្រដៀងគ្នាមិនមែនតែម្តងទេ គឺជាច្រើនដងកំឡុងពេលអត្ថិភាពពីមុនរបស់អ្នក ។ អស់រយៈពេលជាយូរមកហើយអ្នកមានទុក្ខដោយសេចក្តី ស្លាប់របស់ឪពុក-ម្តាយ កូន និងសាច់ញាតិ ។ ជាការពិតដូច្នេះក្នុងពេលដែលអ្នកកំពុងមានទុក្ខអ្នកស្រក់ទឹកភ្នែក ច្រើនជាងទឹកនៅមហាសមុទ្រទៅទៀត ។"

ក្រោយពីការជជែកចប់ Patacara ដឹងពីភាពមិនទៀងទាត់នៃជីវិត ។ ទាំង Patacara និង Kisagotami បានយល់ពីទុក្ខ និងការសិក្សាតាមរយៈបទពិសោធន៍ដែលពោរដោយទុក្ខ ។

ដោយការយល់ស៊ី ជម្រៅពីទុក្ខអរិយសច្ចៈ ដូច្នេះអរិយសច្ចៈបីទៀតក៏ត្រូវបានយល់ផងដែរ។ ព្រះពុទ្ធត្រាស់ថា " ដូច្នេះសង្ឃដែល យល់ពីទុក្ខ ក៏យល់ពីការកើតនៃទុក្ខ ការបញ្ឈប់នៃទុក្ខ និងគន្លងនាំទៅដល់ការបញ្ឈប់នៃទុក្ខ។"

**ធាតុផ្សំនៃវិចារណ៍** ( The Five Aggregates )

ដូចដែលបានកំណត់ក្នុងអត្ថបទពុទ្ធសាសនា សេចក្តីស្លាប់ជាការរលាយនៃខន្ធ។ ខន្ធជាការរួមផ្សំធាតុ ទាំងប្រាំនៃសញ្ញា វេទនារម្មណ៍ និម្មិតកម្មគំនិត ស្មារតី និងរាងកាយ ឬសារធាតុ។ ធាតុផ្សំបួនដំបូង ជាធាតុផ្សំផ្នែកគំនិត ឬ *នាមា* ដែលបង្កើតក្រុមស្មារតី។ ទីប្រាំ *រូបា* ជាធាតុផ្សំរូបធាតុឬសារធាតុ។ ការរួមគ្នារូប-ចិត្តនេះត្រូវបានឱ្យឈ្មោះថា ឯកត្តជន បុគ្គល ឬអាត្មា។ ដូច្នេះអ្វីដែលមានមិនមែនឯកត្តដូចបែបហ្នឹងទេ លើកលែងធាតុចម្បងពីរនៃ *នាមា* និង *រូបា* ដែលជាបាតុភូតកម្រ។ យើងមិនឃើញថាធាតុផ្សំទាំងប្រាំជាបាតុភូតទេ តែជាអត្ថិភាពមួយដោយសារតែគំនិត ដែលធ្វើឱ្យយល់ខុសរបស់យើង ហើយគំនិតដែលមានពីកំណើតរបស់យើងប្រាថ្នាចាត់ទុកកត្តាទាំងនេះជាខ្លួនឯងដើម្បីផ្គាប់ចិត្តភាពសំខាន់ផ្ទាល់របស់យើង។

យើងនឹងបានឃើញវត្ថុជាខ្លួនវាយ៉ាងពិតប្រាកដ បើយើងមានភាពអត់ធ្មត់ និងចេតនាធ្វើ។បើយើងងាកទៅរកការសម្រាកនៃគំនិតរបស់យើងហើយកត់ចំណាំ នឹងការចូលរួមដោយគ្មានលាក់លៀមនោះ (Sati) ហើយកត់ចំណាំដោយគ្មានបំណងធ្វើឱ្យអាត្មាចូលទៅកាន់ដំណើរ ហើយបន្ទាប់មកគណនាការប្រតិបត្តិនេះ ចំពោះកាលដ៏វែងនៃទុក្ខ (ដូចដែលត្រូវបានបង្ហាប់ដោយព្រះពុទ្ធក្នុង Sati Patthana Sutta) នោះយើងនឹងបានឃើងធាតុផ្សំទាំងប្រាំនេះមិនមែនគ្រាន់តែជាអត្ថិភាពមួយនោះទេ តែគឺជាក្រុមមួយនៃដំណើរផ្នែកគំនិត និងរូប។ បន្ទាប់យើងនឹងមិនច្រឡំភាពសើៗចំពោះភាពពិតទេ។ ដូច្នេះយើងនឹងឃើញថាធាតុផ្សំទាំងនេះ កើតឡើង និងលិចបាត់ក្នុងការទទួលតគ្នាយ៉ាងឆាប់រហ័សដោយមិនដែលដូចគ្នាចំពោះឱកាសជាប់គ្នាពីរនោះទេ មិនដែលឋិតិវន្តតែតែងតែស្ថិតក្នុងស្ថានភាពជំនោរ មិនដែលអត្ថិភាព តែតែងតែក្លាយទៅជា។

**ការចាប់កំណើតជាថ្មី** ( Rebirth )

ក្រៅពីធាតុផ្សំផ្នែកគំនិតបួន viz ស្មារតី និងក្រុមកត្តាផ្នែកគំនិតបីទៀតដែលបង្កើត Nama ឬ ក្រុមនៃស្មារតីបន្តកើតឡើង និងលិចបាត់ដោយមិនឈប់ឈរដូចពីមុន ប៉ុន្តែមិនស្ថិតក្នុងការចាត់ដូចគ្នាទេ ដោយសារថាការចាត់គឺគ្មានថែមទៀត។ ពួកគេត្រូវតែស្វែងរកទីតាំងរូបថ្មីជាបន្ទាន់ខណៈវាធ្លាប់ជាទ្រនាប់រូបធាតុថ្មី ដែលសក្តិសម និងសមរម្យសម្រាប់ធាតុផ្សំទាំងអស់ដើម្បីដើរតួនាទីឱ្យត្រូវគ្នា។

ច្បាប់កម្មផលនៃពន្ធភាពធ្វើកិច្ចការនេះ ហើយការចាត់ឡើងវិញនៃធាតុផ្សំចូលមក ជំនួសយ៉ាងឆាប់រហ័ស ហើយយើងហៅថាការចាប់កំណើតជាថ្មី។

ប៉ុន្តែវាត្រូវតែត្រូវបានយល់ថាដោយយោងតាមជំនឿពុទ្ធសាសនាមិនមានវដ្តប្រវេសន៍ នៃព្រលឹង ឬ សារធាតុណាមួយពីរាងកាយមួយទៅរាងកាយមួយទេ។ យោលតាមទស្សនវិជ្ជា ពុទ្ធសាសនាអ្វីដែលកើតឡើងគឺថា Javana ចុងក្រោយដំណើរគំនិតសកម្មនៃមនុស្សស្លាប់ដោះ លែងកម្លាំងពិតដែលយោលទៅតាមបរិសុទ្ធ ភាពផ្សេងៗនៃទេសកាសគំនិតប្រាំក្នុងក្រុមនោះ។ (ប្រាំ ជំនួសឱ្យទេសកាសគំនិត Javana ប្រាំពីរដែលធម្មតា)។កម្លាំងទាំងនេះត្រូវបានហៅថា Kamma Vega ឬ ថាមពលនៃកម្មដែលទាញខ្លួនវាឱ្យទៅជាទ្រនាប់ រូបធាតុមួយដែលបង្កើត ដោយឪពុក-ម្តាយនៅក្នុងផ្ទៃម្តាយ។ ធាតុផ្សំរូបធាតុនៅក្នុងការផ្សំគ្នានៃជីវាណូនេះ ត្រូវតែ ក្តោបក្តាប់នូវលក្ខណៈដែលសក្តិសមសម្រាប់ទទួលលក្ខណៈពិសេសនៃថាមពលកម្ម។ ការទាក់ ទាញក្នុង លក្ខណៈនៃប្រភេទផ្សេងៗនៃធាតុផ្សំផ្នែករូប ដែលត្រូវបានបង្កើតដោយឪពុក-ម្តាយ នេះកើតឡើងតាមរយៈការ ចូលរួមនៃសេចក្តីស្លាប់ និងផ្តល់ការចាប់កំណើតជាថ្មីដែលគួរជាទី ពេញចិត្តដល់មនុស្សស្លាប់។ គំនិតដែលមិន ត្រឹមត្រូវមួយផ្តល់នូវការចាប់កំណើតជាថ្មីដែលមិន គួរជាពេញចិត្តមួយ។

**បាច់នៃធាតុ និងថាមពល** ( A Bundle of Elements and Energies )

ជាសង្ខេប ការបញ្ចូលគ្នានៃធាតុផ្សំទាំងប្រាំត្រូវបានហៅថាការចាប់កំណើត។ អត្ថិភាព នៃធាតុផ្សំទាំង នេះជាបាច់មួយត្រូវបានហៅថាជីវិត។ ការរលាយនៃវត្ថុទាំងនេះហៅថាសេចក្តី ស្លាប់។ ហើយការរួមបញ្ចូលគ្នា ជាថ្មីនៃធាតុផ្សំទាំងនេះត្រូវបានហៅថាការចាប់បដិសន្ធិជាថ្មី។ ទោះយ៉ាងណាវាមិនងាយស្រួលទេចំពោះមនុស្ស សាមញ្ញម្នាក់ក្នុងការយល់ពីរបៀបដែលទាំង នេះដែលត្រូវបានហៅថាការរួមបញ្ចូលធាតុផ្សំជាថ្មី។ ការយល់ដឹង សមស្របពីធម្មជាតិនៃធាតុ ថាមពលកម្ម និងគំនិត និងការរួមគ្នានៃថាមពលលោកធាតុមានសារៈសំខាន់ ចំពោះការគោរព នេះ។ ចំពោះអ្នកខ្លះ (ការកើតឡើងជាធម្មជាតិ និងធម្មតានេះ) សេក្តីស្លាប់មានន័យថាការ បញ្ចូលនៃធាតុប្រាំនឹងធាតុប្រាំដូចគ្នា ហើយក្រោយមកមិនសល់អ្វីទាំងអស់។ ចំពោះអ្នកខ្លះ វា មានន័យថាជា វដ្តប្រវេសន៍នៃព្រលឹងពីរាងកាយមួយទៅរាងកាយមួយទៀត ហើយនិងរាង កាយផ្សេងៗទៀតនិងតាមន័យម្យ៉ាងទៀតវាមានន័យថាជាការឈប់បណ្តោះអាសន្នគ្មានកំណត់ នៃព្រលឹងដែលរង់ចាំថ្ងៃនៃការកាត់សេចក្តី។ ចំពោះពុទ្ធសាសនិក សេចក្តីស្លាប់គឺទទេ ប៉ុន្តែជាទី

បញ្ចប់បណ្ដោះអាសន្ននៃបាតុភូតបណ្ដោះអាសន្ន។ វាមិនមែន ជាការធ្វើឱ្យសូន្យទាំងស្រុងនៃភាវៈដែលធ្លាប់បានហៅនេះទេ។

**មូលហេតុនៃសេចក្ដីស្លាប់** ( Causes of Death )

យោងតាមពុទ្ធសាសនា សេចក្ដីស្លាប់អាចកើតឡើងចំពោះគ្រប់គ្នាតាមវិធីបួននេះ។

១.វាអាចយោលទៅតាមការលេះអស់ នៃចំណែកជីវិតដែលត្រូវបានចាត់ទៅជាភាវៈនៃប្រភេទ (species) ជាពិសេសនោះ។ ប្រភេទនៃសេចក្ដីស្លាប់នេះហៅថា Ayukkhaya ។

២.វាអាចយោលទៅតាមការរលេះអស់នៃថាមពលកម្មផល ដែលបង្កឱ្យមានការកើតនៃសេក្ដីស្លាប់។ ត្រង់នេះហៅថា Kamma-kkhaya ។

៣.វាអាចយោលទៅតាមការរលេះអស់នៃទាំងពីរ ខាងលើដែលបង្ហាញនូវហេតុពីរដោយដំណាលគ្នាដែលហៅថា Ubhayakkhaya ។

៤. ចុងក្រោយវាអាចយោលទៅតាមស្ថានភាពខាងក្រៅពោលគឺថៃដន្យការកើតឡើងដោយមិនកំណត់កាល-កិច្ចការនៃបាតុភូតធម្មជាតិ ឬកម្មនៃអត្ថិភាពពីមុនដែលមិនសំដៅ ដល់ចំណុចទីពីរទេ ត្រូវបានហៅថា Upacchedaka ។

មានការប្រដូចដត្រឹមត្រូវ មួយក្នុងការពន្យល់ប្រភេទនៃសេចក្ដីស្លាប់ទាំងបួននេះ។ វាគឺជាការប្រដូច នៃចង្កៀងប្រេងមួយ។ ពន្លឺភ្លើងក្នុងចង្កៀងប្រេងអាចត្រូវបានពន្លត់ដោយហេតុមួយនៃហេតុទាំងបួន។

1. ប្រឆេះក្នុងចង្កៀងធ្វើឱ្យឆេះឡើង។ ចំណុចនេះត្រូវបានប្រដូចទៅនឹងសេចក្ដីស្លាប់តាម រយៈការរលេះអស់នៃចំណែកជីវិត។

2. ការប្រើប្រាស់ប្រេងក្នុងចង្កៀងត្រូវបាន ប្រដូចទៅនឹងសេចក្ដីស្លាប់តាមរយៈការរលេះអស់ នៃថាមពលកម្ម។

3. ការប្រើប្រាស់ប្រេងក្នុងចង្កៀង និងការឆេះអស់នៃប្រឆេះក្នុងពេលជាមួយគ្នាត្រូវបាន ប្រដូចទៅនឹងសេចក្ដីស្លាប់ដែលកើតឡើងតាមរយៈ ការរួមគ្នានៃហេតុដែលត្រូវបានពណ៌នាក្នុង (១) និង (២) ដែលកើតឡើងក្នុងពេលជាមួយគ្នា។

4. ផលនៃកត្តាខាងក្រៅដូចជាខ្យល់ដែលបក់ពន្លត់ភ្លើង ត្រូវបានប្រដូចទៅនឹងសេចក្ដីដែល បណ្ដាលមកពីកត្តាខាងក្រៅ។

ដូច្នេះ កម្មតែម្យ៉ាងមិនមែនជាបុព្វហេតុនៃសេចក្ដីស្លាប់។ វាមានបុព្វហេតុខាងក្រៅផងដែរ។ នៅ Anguttara Nikaya និងកន្លែងផ្សេងៗទៀតព្រះពុទ្ធមានពុទ្ធដីកាថា កម្មមិនមែនសំដែងគ្រប់ការកើតមានឡើងទេ។

**ការទទួលស្គាល់តថភាព** ( Face Facts )

តើគេគួរប្រឈមនឹងព្រឹត្តិការណ៍ ដែលមិនអាចចៀសផុតនេះដោយប្រសើរបំផុតយ៉ាងដូចម្ដេច? ដោយតាមរយៈការ ដែលត្រូវបានដាស់តឿនជាមុន ដោយការគិតថាសេចក្ដីស្លាប់នឹងកើតឡើង ហើយត្រូវតែកើតឡើងដោយឆាប់ជាង ឬយឺតជាងប៉ុណ្ណោះ។ នេះមិនមែនមានន័យថាពុទ្ធសាសនិកគួរតែគន់មើលជីវិតជាមួយភាពស្រងេះស្រងោចទេ។ សេចក្ដីស្លាប់ គឺពិតហើយត្រូវ តែប្រឈមមុខ ហើយពុទ្ធសាសនាជាសាសនាមួយនៃវិចារណញ្ញាណ ដែលបង្រៀនសាវ័កឱ្យទទួលស្គាល់តថភាពទោះបីជាពួកគេប្រហែលជាមិនរីករាយយ៉ាងណាដោយ ។Guru Nanak ថា"ពិភពលោកខ្លាចសេចក្ដីស្លាប់ចំពោះខ្ញុំវានាំមកនូវបរមសុខ។"វាបង្ហាញយ៉ាងច្បាស់ថាមនុស្សជាន់ខ្ពស់ ហើយឆ្នើមមិនខ្លាចសេចក្ដីស្លាប់ទេ តែពួកគេត្រៀមទទួលវា។ មនុស្សឆ្នើមជាច្រើនបានលះបង់ជីវិតរបស់ពួកគេដើម្បីសុខមាលភាព និងសុភមង្គលរបស់មនុស្សជាតិ។ ឈ្មោះរបស់ពួកគេត្រូវបានកត់ត្រាទុកក្នុងប្រវត្តិសាស្ត្រ ពិភពលោកក្នុងក្រាំងមាសសម្រាប់ជំនាន់ក្រោយ។ ជនជាតិអាមេរិចជំនាន់ក្រោយ Saul Alinksy ថា " វត្ថុសំខាន់បំផុតតែមួយនេះដែលខ្ញុំធ្លាប់បានសិក្សាគឺថា ខ្ញុំនឹងស្លាប់។ បើអ្នកទទួលស្គាល់សេចក្ដីស្លាប់អ្នកក៏ស្រាប់តែ មានសេរីភាពក្នុងការរស់នៅភ្លាម។ អ្នកលែងយកចិត្តទុកដាក់ទៀតហើយលើកលែងតែរហូតពេលនេះខណៈជីវិតរបស់អ្នកអាចត្រូវបានប្រើយ៉ាងប៉ិនប្រសប់ដើម្បី បង្ហាញហេតុមួយដែលអ្នកជឿជាក់។" នេះជាវិធីដែលអ្នកគិតឆ្នើមៗគិតពីបញ្ញត្តិនៃសចេក្ដីស្លាប់។

**សេចក្ដីស្លាប់គឺចៀសមិនរួច** ( Death is Inevitable )

វាគឺការយកលំនាំតាមទ្រឹស្ដីជាជាង ដែលទោះបីជារឿយៗយើងឃើញថាសេចក្ដីស្លាប់ហួតយកតម្លៃរបស់ជីវិត ក៏ដោយ ក៏យើងកម្រផ្អាកក្នុងការគិតថាយើងភ្លាមៗអាចស្រដៀង នឹងជនរងគ្រោះនៃសេចក្ដីស្លាប់ផងដែរ។ ដោយការជំពាក់ចិត្តដ៏ខ្លាំងក្លាចំពោះជីវិត យើងមិនពេញចិត្តដាក់ជាប់ខ្លួននូវគំនិតដែលមានជំងឺដែលថាសេចក្ដី ស្លាប់គឺទៀងទាត់ ទោះបីជាសច្ចភាពក៏ដោយ។ យើងមានចេតនាដាក់គំនិតនេះឱ្យនៅឆ្ងាយបំផុតតាមដែលអាច ធ្វើបានដែលបោកបញ្ឆោតខ្លួនឯងថាសេចក្ដីស្លាប់ជាបាតុភូតនៅឆ្ងាយមួយកុំព្រួយបារម្ភពីវា។ យើងគួរតែអង់អាចគ្រប់គ្រាន់ក្នុងការប្រឈមមុខនឹងតថាភាព។ យើងត្រូវតែត្រៀមដើម្បីប្រឈមនឹងសច្ចភាព។

សេចក្តីស្លាប់ ជាការកើតឡើងពិតមួយ ។ សេចក្តីស្លាប់ជាសច្ចភាពមួយ ។ បើយើងឱ្យតម្លៃយថាភាពបែបហ្នឹងហើយផ្គត់ផ្គង់ខ្លួនឯងដោយការដឹងថា សេចក្តីស្លាប់ជាដំណើរប្រព្រឹត្តិដែលមិនអាចចៀសផុត ដែលត្រូវតែត្រូវបានទទួល ស្គាល់ជាការកើតឡើងធម្មតាមួយ ហើយមិនមែនជាហេតុការណ៍ដែលភ័យខ្លាចទេ នោះយើងនឹងគួរតែអាច ប្រឈមនឹងវានៅពេលដែលវាមកដល់ជាយថាហេតុដោយភាពស្ងប់ស្ងាត់អង់អាចនិងជឿជាក់ ។

**ភារកិច្ចនិងការទទួលខុសត្រូវរបស់យើង** ( Our Duties and Responsibilities )

ដោយការយល់ដឹងថាសេចក្តីស្លាប់នឹងមកដល់យើងនៅថ្ងៃណាមួយ ដូច្នេះយើងគួរតែសម្រេចចិត្តបន្ធូរបន្ថយភារកិច្ច និងការទទួលខុសត្រូវឆ្ពោះទៅអ្នកក្នុងបន្ទុកផ្ទាល់របស់យើងដោយភាពស្ងប់ស្ងាត់ អង់អាច និងជឿជាក់ ។ យើងមិនគួរពន្យាពេលទៀតទេ ។ យើងមិនគួរទុកបញ្ហាទៅថ្ងៃស្អែកខណៈយើងអាចធ្វើបាននៅពេល នេះទេ ។ យើងគួរតែធ្វើប្រយោជន៍ពេលវេលាបានល្អប្រសើរ ហើយប្រើប្រាស់ជីវិតរបស់យើងប្រកបដោយប្រយោជន៍ ។ ភារកិច្ចរបស់យើងចំពោះភរិយាស្វាមី និងកូនគួរតែត្រូវបានធ្វើតាមពេលវេលាសមគួរ ។ យើងគួរប្រតិបត្តិបំណង និងមរតកសាសន៍ចុងក្រោយរបស់យើងដោយមិនរង់ចាំវិនាទីចុងក្រោយទេ ដូច្នេះយើងនឹងមិនធ្វើឱ្យមានបញ្ហានិងការលំបាកដែលមិនសមគួរទៅតាមការប្រមាទរបស់យើងទេ ។សេចក្តីស្លាប់នឹងដង្ហោយ ហៅនៅគ្រប់ពេល វាមិនមែនជាអ្នកគោរពពេលវេលាទេ ។ យើងគួរតែអាចប្រឈមមុខនឹងភាពចុងក្រោយ ដោយក្លាហាន និងដោយភាពស្ងប់ស្ងាត់ ។

**ចំណង់ និងភាពល្ងង់ខ្លៅ** ( Craving and Ignorance )

តើសេចក្តីអាចទទួលបានជ័យជំនះឬទេ? ចម្លើយ គឺអាច ! សេចក្តីស្លាប់មានអត្ថិភាពដោយសារមានកំណើត ។ មានតំណពីរនៅក្នុងវដ្តនៃអត្ថិភាព ដែលគេស្គាល់ថា *Paticca Samuppada* ។ ទាំងអស់មានចំណង១២នៅ ក្នុងវដ្តនេះដែលខ្លះជា *Klesas* ឬ ភាពមិនបរិសុទ្ធ។ *Kammas* ឬសកម្មភាពខ្លះបណ្តាលឱ្យមាន *vipakas* ឬ លទ្ធផល (នៅក្នុងវដ្ត-កើតជាថ្មីនេះ) និង *vipakas* ម្តងហើយម្តងទៀត ។ ការកើតម្តងហើងម្តងទៀតដែល រាប់មិនអស់នេះហៅថាវដ្តសង្សារ( *Samsara*) ។ ប្រសិនបើវដ្តនៃអត្ថិភាពនេះត្រូវបញ្ឈប់នោះវាអាចត្រឹម តែបញ្ឈប់នូវដំណាក់មិនបរិសុទ្ធប៉ុណ្ណោះ នោះគឺ *Avijja* (ភាពល្ងង់ខ្លៅ) និង *Tanha* (ចំណង់) ។ វាទាំងនេះជា ឬសគល់នៅក្នុងវដ្តនៃការកើត ដែលត្រូវតែលុបបំបាត់ ។ ដូច្នេះបើយើងបំបាត់ចំណង់ និងភាពល្ងង់ខ្លៅបាននោះ កំណើតបានទទួលជោគជ័យ *Samsara* ត្រូវគ្រប់សង្កត់បានហើយសម្រេចបាននូវនិព្វាន ។

យើងគួរយល់ថាអ្វីៗនៅក្នុងលោកនេះគឺមិនបិតថេរឡើយ។ អត្ថិភាពគឺគ្រាន់តែជាការមើលឃើញឬជាមាយាការមួយប៉ុណ្ណោះ។ នៅពេលដែលយើងគិតវិភាគអ្វីៗទាំងជាលក្ខណៈវិទ្យាសាស្ត្រ ឬទស្សនវិជ្ជា ដោយមិនមានតម្រូវការអាត្មានិយមនោះ នៅទីបំផុតយើងមិនបានឃើញអ្វីទាំងអស់ក្រៅពីភាពទទេ។

# ជំពូកទី៤

## តើត្រូវជំនះឧបសគ្គយ៉ាងដូចម្តេច ?

*(ដោយភិក្ខុ Dr.K. Sri Dhammananda និងDr.K.T THYDAមូលដ្ឋានគ្រឹះនៃសីលវិទ្យាសកលលោក ជំពូកទី៣)*

**១-សេចក្តីខ្លាច និងសេចក្តីកង្វល់ចិត្ត** : សេចក្តីភ័យខ្លាច និងសេចក្តីកង្វល់ចិត្តកើតចេញមកពីសភាវៈស្រមើស្រមៃចិត្ត ដែលត្រូវបរិស្ថានជីវិតលោកីយ៍ជះឥទ្ធិពលមកលើ។ ភ័យខ្លាច និងកង្វល់ចិត្ត មានឫសគល់នៅក្នុងតណ្ហា និងឧបាទាន ។ តាមពិត ជីវិតប្រៀបដូចរូបភាពយន្ត (ឬកុន) ដែលនៅក្នុងរូបភាពយន្ត (ឬកុន) នេះអ្វីៗទាំងអស់តែងចល័ត និងប្រែប្រួលជាប្រចាំ ។ គ្មានអ្វីនៅក្នុងលោកនេះឋិតថេរឬឋិតនៅនឹងថ្កល់ទេ។ អ្នកទាំងឡាយណា ដែលមានវ័យនៅក្មេងមានកម្លាំមាំមួនតែងមានសេចក្តីភ័យខ្លាចស្លាប់ទាំងនៅក្មេង ។ អ្នកទាំងឡាយណា ដែលមានវ័យចាស់ ហើយមានជំងឺផង តែងព្រួយកង្វល់ចិត្តអំពីជីវិតរស់នៅយូរពេក ។ ឋិតនៅក្នុងចន្លោះមនុស្សទាំងពីរក្រុមនេះ គឺពពួកអ្នករវក់តែ និងសេចក្តីសប្បាយពីមួយឆ្នាំទល់មួយឆ្នាំ។

សេចក្តីសង្ឃឹម ប្រកបដោយសេចក្តីរីករាយរបស់ពួកអ្នកសប្បាយចិត្ត ហាក់ដូចកន្លងទៅឆាប់ពេក។ សេចក្តីរង់ចាំប្រកបដោយសេចក្តីភ័យខ្លាចរបស់ពួកអ្នកមិនសប្បាយ ចិត្តបង្កើតឱ្យមានសេចក្តីព្រួយកង្វល់ចិត្ត ដែលហាក់ដូចជាមិនព្រមឃ្លាតទៅណាសោះ។ អារម្មណ៍ទាំងឡាយបែបនេះ គឺជាសភាវៈធម្មតា ។ ជីវិតរស់នៅប្រែប្រួលម្តងចុះ ម្តងឡើងបែបនេះដើរតួ ដោយអត្តៈឬជីវមាយា ដូចរូបតុក្កតាដែលញាក់ទៅតាមខ្សែ។ ប៉ុន្តែចិត្តគឺដូចជាសភាវៈដ៏ប្រសើរដោយខ្លួនឯងផ្ទាល់។ ការហ្វឹកហ្វឺនចិត្ត ដែលគេហៅម្យ៉ាងទៀតថា ចិត្តវប្បកម្ម គឺជាជំហានដំបូងឆ្ពោះទៅរកការបង្ក្រាបសភាវៈច្របូកច្របល់នៃចិត្ត ។

ព្រះពុទ្ធបន្ទូលថា "សេចក្តីទុកព្រួយកើតចេញពីតណ្ហា" សេចក្តីភ័យខ្លាចកើតចេញពីតណ្ហា សម្រាប់អ្នកដែលរំដោះ ផុតពីតណ្ហាបានទាំងស្រុងហើយ សេចក្តីទុក្ខព្រួយ សេចក្តីភ័យខ្លាចសូម្បីតែតិចតួចមិនមានទេ" ។

សេចក្តីជាប់ជំពាក់ចិត្តគ្រប់យ៉ាង (ឧបាទាន) និងបញ្ចប់នៅត្រឹមសេចក្តីសោកស្តាយ ។ មិនមែនទឹកភ្នែកទាំងមិនមែន ការឱបរឹតសាសងលាគ្នាដ៏យូរអាចបញ្ចប់អនិច្ចភាពនៃជីវិតបានទេ ។ សង្ខារវត្ថុទាំងអស់ មិនឋិតថេរជាអចិន្ត្រៃយ៍ទេ។

ទាំងចាស់ ទាំងក្មេង រងទុក្ខដូចគ្នានៅក្នុងជីវិតនេះ។ គ្មាននរណាម្នាក់ ត្រូវបានលើកលែងឡើយ ។ ពួកក្មេងៗជាច្រើនកំពុងមានសេចក្តីឈឺចាប់ខ្លាំងឡើងៗ ដោយពួកគេមិនមែនជាកង្កែប ឬជាកូនក្អាត់ ។ ពួកយុវជនមានបទពិសោធន៍យល់ដឹងតិច ក្នុងការកសាងទំនាក់ទំនងជាប់លាប់ជាមួយសមាជិកមានភេទផ្ទុយគ្នា ។ ពួកគេខិតខំបង្អួតសម្រស់របស់គេ ដើម្បីខិតខំទាក់ ទាញចិត្តយុវជនមានភេទផ្ទុយគ្នាដែលកំពុងស៊ីជោរដោយមើលឃើញខ្លួនឯងថា ជាកម្មវត្ថុនៃភេទ។ភេទទាំងពីរបានខិតខំធ្វើឬកពាដែលពួកគេយល់ថា ជាឫកពាមនុស្សពេញវ័យ។ ពួកគេភ័យខ្លាច ថាបើគេធ្វើឫកពាធម្មតាទៅពួកគេនឹងត្រូវគេសើចចំអក។ ឫកពាដូចនេះ មានសក្តានុពលសម្រេចជោគជ័យ។ គេមានសេចក្តីបារម្ភខ្លាចការបដិសេធន៍ក៏ដូចជាសេចក្តីព្រួយកង្វល់ចិត្តអំពីអត្តភាពរបស់គេស្រុតចុះ។ សេចក្តីស្នេហាមិនបាន សម្រេចជាញឹកញយតែ "ទម្លុះទម្លាយ" បេះដូងយុវជនជាច្រើនពីព្រោះពួកគេមានអារម្មណ៍ថាពួកគេជាមនុស្សឆោតល្ងង់។ យុវជនខ្លះឈានរហូតដល់ធ្វើអត្តឃាត ។ប៉ុន្តែជំងឺផ្លូវចិត្តបែបនេះអាចជៀសវាងបានប្រសិនបើជីវិតត្រូវបានគេមើលឃើញតាមធម្មជាតិពិតរបស់វា ។ គេត្រូវផ្តល់ដល់យុវ-ជននូវវិធីដោះស្រាយបញ្ហាជីវិត តាមបែបបទពុទ្ធសាសនាដើម្បីឱ្យពួកយុវជនអាចប្រកាន់ យកមាគ៌ាត្រឹមត្រូវឈាន ចូលទៅក្នុងដំណាក់កាលមានចិត្តចាស់ទុំ ។

ព្រះពុទ្ធទ្រង់មានបន្ទូលថា "ក្នុងទីណាមានសេចក្តីភ័យខ្លាចកើតឡើង វាកើតឡើងក្នុងមនុស្សទុប្បញ្ញា មិនមែននៅក្នុងបណ្ឌិតឡើយ"។ សេចក្តីភ័យខ្លាចគ្មានអ្វីក្រៅតែពីស្ថានភាពនៃចិត្តទេ។ ស្ថានភាពនៃចិត្តរបស់បុគ្គលម្នាក់ ត្រូវតែស្ថិតនៅក្រោម ការត្រួតត្រានិងការតម្រង់ទិស ការប្រើប្រាស់គំនិតខុសបែបបទ បង្កើតចេញនូវសេចក្តីភ័យខ្លាច ការប្រើប្រស់គំនិតបានត្រឹមត្រូវរមែងបង្កើតបានសេចក្តីសង្ឃឹមនិងឧត្តមគតិ។ ជម្រើសឋិតនៅក្នុងដៃយើងទាំងស្រុង។ មនុស្សម្នាក់មានសមត្ថភាពដើម្បីត្រួត ត្រាចិត្តរបស់ខ្លួនឯងដោយផ្ទាល់ធម្មជាតិ បានប្រគល់មកឱ្យមនុស្សនូវការត្រួតត្រាដាច់ខាតទៅលើចិត្ត.គំនិត។ អ្វីៗដែលមនុស្សបង្កើតឡើងគឺ ចាប់ផ្តើមក្នុងទ្រង់ទ្រាយនៃគំនិត ។ នេះគឺជាកូនសោរ ដើម្បីជួយបុគ្គលណាម្នាក់ឱ្យយល់នូវគោលការណ៍ដើម្បីអាចយកមកប្រើសម្រាប់ម្ចាស់ការលើសេចក្តីភ័យខ្លាច ។ កាយវិភាគវិទូ (Anatomist) សញ្ជាតិអង់គ្លេសដ៏ល្បីល្បាញម្នាក់មានពេលមួយនោះត្រូវបាននិស្សិតម្នាក់ចោទសួរថា តើអ្វីជាឱសថដ៏ប្រសើរបំផុត សម្រាប់ព្យាបាលសេចក្តីភ័យខ្លាចបន្ទាប់មកលោកបានឆ្លើយថា "ចូរខិតខំធ្វើអ្វីមួយសម្រាប់អ្នកណាម្នាក់" ។

និស្សិតនោះមានសេចក្ដីជឿងឆ្ងល់យ៉ាងខ្លាំងចំពោះចម្លើយនោះ ហើយបានសុំសេចក្ដីបំភ្លឺទូលំទូលាយជាងនេះទៀត។ ពេលនោះលោកសាស្ត្រាចារ្យបាននិយាយថា "អ្នកឯងមិនអាចមានគំនិតពីរបែបផ្ទុយពីគ្នានៅក្នុងចិត្តរបស់អ្នកឯងនៅពេលតែមួយ និងដដែលបានទេ" ។ គំនិតមួយបែប នឹងបណ្ដេញគំនិតមួយបែបផ្សេងទៀតចេញជានិច្ច ។

យកជាឧទាហរណ៍ : ប្រសិនបើចិត្តរបស់លោក-អ្នក ជាប់ជំពាក់ទាំងស្រុងដោយចំណងបរទត្ថភាពដើម្បីជួយជនណា ម្នាក់ លោក-អ្នកមិនអាចរក្សានៅក្នុងចិត្ត របស់ លោក-អ្នកនូវគំនិតភ័យខ្លាចអ្វីមួយនៅពេលដដែលបានទេ។

សេចក្ដីព្រួយកង្វល់ ធ្វើឱ្យឈាមហួតឆាប់ជាងវ័យ" (គឺធ្វើឱ្យរូបកាយឆាប់ចាស់ជាងអាយុ)។ សេចក្ដីភ័យខ្លាច និងសេចក្ដីព្រួយកង្វល់មិនហួសប្រមាណ គឺជាសភាវគតិធម្មតានៃកិច្ចការពារឬថែរក្សាខ្លួន។ ប៉ុន្តែសេចក្ដីភ័យខ្លាចឥតហេតុ-ផលជាប្រចាំ និងសេចក្ដីព្រួយកង្វល់ចិត្តរយៈពេលយូរគឺជាសត្រូវដ៏គ្រោះថ្នាក់ចំពោះសរីរាង្គមនុស្ស។ វាបង្កវិបត្តិដល់ដំណើរប្រព្រឹត្តទៅជាធម្មតារបស់សរីរាង្គ។

## ២-អ្នកត្រូវមានទំនួលខុសត្រូវ

(You are Responsible By. Ven. Dr. K. Sri Dhammananda)

អ្នកអាចប្រាថ្នាគិតថា *ទុក្ខព្រួយ* និង *ទុគ៌តភាព* របស់អ្នកសុទ្ធតែបណ្ដាលមកពី *ពាក្យលាមកត្រកូល* (a fa-mily curse)ដែលបានមកពីជំនាន់មួយទៅជំនាន់មួយទៀត។ ឬទំនងជាពួកវាកើតមានឡើងដោយសារតែ *បាបកម្មមួយចំនួន*(some sins)ដែលបានប្រព្រឹត្តដោយ *បុព្វបុរស*តាំងពីយូរយារ (a distant ancestors) មកដែលឥឡូវនេះបានវិលត្រឡប់មកពី *ខ្មោច* (grave)ទៅជាធ្វើទារុណកម្ម (torment) ចំពោះអ្នកទៅវិញ ឬប្រហែលជា *ទុក្ខព្រួយ* របស់អ្នកត្រូវបង្កើតឡើងដោយ *អាទិទេស*ឬដោយ *រាជភូត*[១] (The Devid)។

ផ្ទុយទៅវិញ តើអ្នកបានគិតពិចារណាអស់មួយខណៈហើយថា *ហេតុ* ពិតជាអាចបន្ទំជាមួយ*ខ្លួនអ្នក!* ពិតមែនហើយគឺពិតជា *ខ្លួនអ្នកមែន! អ្នកបាន*បណ្ដាលឱ្យមាន*ការបរាជ័យ* ផ្ទាល់របស់អ្នក ពោលគឺ*សេចក្ដីវេទនា*(hard-ship)ហើយនិង *អពមង្គល*នេះឯង។ ប៉ុន្តែវាមិនមែនជាការងាយស្រួលនោះទេពោលគឺ *"ធម្មជាតិមនុស្ស"* ដែលលោកអាចនិយាយថា ដើម្បី*រិះគន់* ទៅលើ *អ្នកដទៃ* ជាជាងមើលឃើញ*ខ្លួនអ្នក* ជាការ *ទទួលខុសត្រូវ* ចំពោះពួកវា?

---

[១] ខ្មោច, បិសាច

ជារឿយៗពេល *មនុស្សម្នាក់*ប្រឈមមុខទល់នឹងការមើលឃើញពី *ភាពទន់ខ្សោយ* ផ្ទាល់របស់គេ គេខិតខំបញ្ចៀសវា ហើយគេខិតខំបោកប្រាស *ខ្លួនគេ* (and instead gives in to self-deceit) ។ គេនឹងរិះរកការសុំទោសសូម្បីតែការសុំទោសពុំគួរឱ្យជឿបានក៏ដោយដើម្បីធ្វើយុត្តិកម្មលើ *អំពើរបស់គេ*។ គេអាចទទួលបានជោគជ័យក្នុងការធ្វើនេះ ។ពេលខ្លះគេទទួល បានជោគជ័យយ៉ាងប្រពៃក្នុងការខិតខំបោកបញ្ឆោត *អ្នកដទៃ* ដែលគេសូម្បីតែបោកបញ្ឆោត ខ្លួនគេជាមួយនឹងខ្មោចពិតៗដែលបានបង្កើតឡើងដោយចិត្តរបស់គេក៏ដោយ ។

*មនុស្សម្នាក់*អាចបោកបញ្ឆោត *មនុស្សមួយចំនួន*នៅពេលណាមួយបាន ប៉ុន្តែមិនមែនគ្រប់ ពេលគ្រប់មនុស្សទាំងអស់នោះទេ ។ បើតាម *ព្រះពុទ្ធ* "*អ្នកបោកបញ្ឆោត* ដែលមិនបានអនុញ្ញាតថា គេជា *អ្នកបោកបញ្ឆោតម្នាក់*គឺជា *អ្នកបោកបញ្ឆោតពិតម្នាក់*។ ហើយ *អ្នកបោកបញ្ឆោត*ដែលអនុញ្ញាតថាគេគឺជា *អ្នកបោកបញ្ឆោត*ដែលឆ្លាតវាងវៃចំពោះវិសាលភាពនោះ" ។

ប្រសិនបើអ្នកបង្កើតឱ្យមានកំហុស នៅពេលនោះអនុញ្ញាតឱ្យវា ។ តាមពិត អ្នកត្រូវការសេចក្តីក្លាហានដើម្បីអនុញ្ញាតថាអ្នកបានបរាជ័យចំពោះ *ជនរងគ្រោះ* (victim) ចំពោះវាហើយធ្វើការអនុញ្ញាតនោះដោយគ្មានបញ្ហាថាតើ ការអនុញ្ញាតអាចមិនរីករាយយ៉ាងណា ។ អ្នកក៏ត្រូវការ *គតិបណ្ឌិត* ដើម្បីមើលឃើញពី *កំហុសផ្ទាល់*របស់អ្នក ។

*ព្រះពុទ្ធ*ទ្រង់ត្រាស់សម្តែងថា "*គេងាយនឹងមើលឃើញពី កំហុសរបស់ អ្នកដទៃណាស់ ប៉ុន្តែពិតជាពិបាកនឹងមើល ឃើញពីកំហុសផ្ទាល់របស់ខ្លួនឯង*" ។ អ្នកមិនគួរគេចខ្លួនចេញពី *ស្វ័យទំនួលខុសត្រូវ*(self-responsibility)ចំពោះ *អំពើផ្ទាល់*ខ្លួនរបស់អ្នកដោយស្តីបន្ទោសវាទៅលើ *កាលៈទេសៈ*នោះឡើយ ។នៅពេលជួបនឹង*ការលំបាកនានា*និង*ខណៈពេលខិតខំ*ត្រូវដោះស្រាយវាដោយសាទរកុំសម្តែងឱ្យឃើញពី*ទឹកមុខក្តៅក្រហាយ*ឱ្យសោះ ។ត្រូវក្លាហានផ្លាស់ប្តូរវាប្រសិនបើការផ្លាស់ប្តូរនោះមានការចាំបាច់ សូមអត់ធ្មត់ ហើយទទួលយកអ្វីដែលអ្នកមិនអាចផ្លាស់ប្តូរបានហើយត្រូវវ៉ៃឆ្លាតចេះដឹងពី *ភាពខុសប្លែកគ្នា*។

សូមកុំគិតថា*អ្នកគ្មានសំណាង*ឬជា *អ្នកអភ័ព្វ*ឱ្យសោះ ។ សូមប្រឈមមុខទល់នឹង *កំហុស* (shortcomings) នានារបស់អ្នក ។ អ្នកត្រូវតែយល់ឱ្យច្បាស់ថាចិត្តរបស់អ្នកបានបង្កើតឱ្យមាន *លក្ខខណ្ឌ*ដែលនាំឱ្យកើតឡើងនូវ *ទុគ៌តភាព* និង *សេចក្តីលំបាកនានា*ដែលអ្នកកំពុងតែមានបទពិសោធន៍ ។ វាគ្រាន់តែនៅពេលក្រោយមកអ្នកនឹងយល់ដោយពិតពីការពិតនេះ ហើយមិនសុខ

ចិត្តចាញ់ចំពោះ *ការបោកបញ្ឆោតខ្លួនឯង* ដែលអ្នកអាចចាប់ផ្តើមបង្កើត *លក្ខខណ្ឌ*ចាំបាច់ចំពោះ *សុភមង្គល* របស់អ្នក។

**ហេតុនៃបញ្ហារបស់អ្នក** (Cause of Your Troubles)

បើតាម ព្រះពុទ្ធ មនុស្សបានកសាង វាសនាដោយខ្លួនឯង។ គេមិនគួរស្តីបន្ទោស អ្នកណាមួយចំពោះបញ្ហារបស់ខ្លួនឡើយ ព្រោះមានតែ ខ្លួនគេប៉ុណ្ណោះដែលត្រូវ ទទួលខុសត្រូវចំពោះជីវិតរបស់គេទោះ ល្អក្តី អាក្រក់ក្តី។

មនុស្សបង្កើតអ្វីៗ ពោលគឺសេចក្តីសោកសៅនិងភាពឥតព្រេងវាសនាក៏ដូចជា សុភមង្គល និង ជោគជ័យរបស់គេ។ អ្នកដទៃអាចប្រើឥទ្ធិពលមកលើ ជីវិតរបស់គេ ផ្ទុយទៅវិញវាជាអ្នកដែលកសាង កម្ម *(Karma)* ផ្ទាល់ខ្លួន របស់គេដោយពិតៗទៅវិញទេ (តាមរយៈប្រតិកម្មចេតនារបស់គេ)។ ដូច្នេះគេត្រូវតែ ទទួលខុសត្រូវ ចំពោះ ផលរបស់គេ។ គេមានការយល់ដឹងបែបនេះ គ្មានមនុស្សណា ឬ ទេវៈ*(Deva)*ណាដែលអាចដឹកនាំ ឬត្រួតត្រាលើ ការជួយស្រោចស្រង់ឬ ការវិនាសហិនហោច ខ្ពស់បំផុតរបស់ មនុស្សនោះបានទេ។ ការប្រព្រឹត្តដោយ ចិត្ត និង ស្មារតីបរិសុទ្ធពោលគឺសម្តីនិងអំពើសព្វយ៉ាងរបស់គេល្អបរិសុទ្ធ។ តែទោះជាយ៉ាងណា ក៏ដោយ ការប្រព្រឹត្តដោយចិត្តក្រខ្វក់ គេនៅតែបន្តបង្កើត អំពើអាក្រក់ដែលនឹងលេចរូបរាងឡើងនៅក្នុងចរិតលក្ខណៈនិងវាសនារបស់គេ។

អ្នកអាចជា មនុស្សម្នាក់ដែលល្អប្រពៃ និងមិនបង្កទុក្ខទោសដោយធម្មជាតិ ផ្ទុយទៅវិញ អ្នកត្រូវ អ្នកដទៃស្តីបន្ទោស។ អ្នកមានចំណែកលំបាក និងការខកចិត្តបើទោះជា អ្នកបានជួយសង្គ្រោះអ្នកដទៃដោយគ្មានគំនិតអំពី ខ្លួនឯងក៏ដោយ។ នៅពេលនោះអ្នកអាចសួរថា *"បើធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ តើហេតុអ្វីបានជាខ្ញុំត្រូវទទួលរងទុក្ខ ពេលខ្ញុំប្រព្រឹត្តល្អដោយបរិបូណ៌ហើយនោះ? តើហេតុអ្វីបានជាខ្ញុំទទួលរងសេចក្តីលំបាកនិងការខកចិត្តខ្លាំងម្ល៉េះ? ហេតុអ្វីបានជា គេស្តីបន្ទោសឱ្យខ្ញុំ បើទោះជាការងារល្អរបស់ខ្ញុំមានហើយនោះ?"*

ចម្លើយគឺជា ចម្លើយសាមញ្ញមួយ : អ្នកមិនបានដឹងថា ឥឡូវនេះអ្នកកំពុងតែប្រឈមមុខទល់នឹង កម្មអាក្រក់ ពីអតីតកាល ដែលកំពុងតែឱ្យផលនោះទេ។ សូមអ្នកបន្ត ការងារល្អរបស់អ្នកតទៅទៀតហើយមិនយូរប៉ុន្មានអ្នកនឹងរំដោះខ្លួនផុតពីបញ្ហាបែបនេះជាមិនខាន។ អ្នកបានកសាង ការខកចិត្ត ដោយខ្លួនអ្នក ហើយមានតែអ្នកម្នាក់ឯងប៉ុណ្ណោះ ដែលអាចយកឈ្នះ

លើវាតាមរយៈការយល់ច្បាស់ពី ធម្មជាតិនៃអំពើរបស់អ្នកពោលគឺ *កម្ម* ដែលព្រះពុទ្ធទ្រង់បានបង្រៀន។

បញ្ហានិង សេចក្ដីលំបាក របស់អ្នកពិតជាបណ្ដាលឡើងដោយស្វ័យប្រវត្តិ។ វាកើតឡើងមកពី អំពើដែលបានចាក់ ឬសគល់នៅក្នុងសេចក្ដី លោភៈ ទោសៈនិងមោហៈ។ តាមពិតទុក្ខគឺជា តម្លៃដែលអ្នកចំណាយចំពោះ តណ្ហាសម្រាប់អត្ថិភាព និងសេចក្ដីសប្បាយខាងកាមរាគៈ។

តម្លៃដែលមកជា ជម្ងឺរូបកាយនិង ជម្ងឺផ្លូវចិត្តគឺជាជម្ងឺធ្ងន់ធ្ងរមួយដែលគេត្រូវសង។ វាប្រៀបដូចជាការសងថ្លៃឈ្នួលឬ ថ្លៃពន្ធទៅលើ ផ្ទះសម្ដែងដែលអ្នករស់នៅអញ្ចឹង។ "ថ្លៃឈ្នួល" គឺជា ជម្ងឺរូបកាយនិងជា ជម្ងឺផ្លូវចិត្តដែល អ្នកត្រូវស៊ូទ្រាំ នៅពេល "ផ្ទះសម្ដែង" គឺជា រូបកាយរូប (physical body) របស់អ្នកដែលតាមរយៈនេះអ្នកអាចមានបទពិសោធន៍ទៅលើ សេចក្ដីសប្បាយលោកិយ៍ខាង ឥន្ទ្រីយារម្មណ៍។ អ្នកត្រូវតែសងតម្លៃចំពោះសេចក្ដីរីករាយគ្មានអ្វីដែលមិនត្រូវសងដោយពិតប្រាកដនោះទេ។

ដរាបណាអ្នកធ្លាក់ចូលទៅក្នុង ដង្ហៀបតណ្ហាហើយអ្នកទទួលបានបទពិសោធន៍ជម្ងឺកាយនិង ចិត្ត។ តែទោះជាយ៉ាងណាក៏ដោយបើអ្នកប្រាថ្នាចង់បន្ថយ ឬបំបាត់ ជម្ងឺនោះ អ្នកត្រូវតែពង្រាបហើយបើត្រូវលះបង់តណ្ហាដ៏រឹងមាំរបស់អ្នក ចំពោះសេចក្ដីសប្បាយខាងឥន្ទ្រីយារម្មណ៍។ អ្នកបានប្រឈមមុខទល់នឹងជម្រើសមួយ : ដើម្បីសប្បាយរីករាយជាមួយ សេចក្ដីសប្បាយខាងឥន្ទ្រីយារម្មណ៍អ្នកត្រូវតែប្រៀបធៀបទៅ នឹងបទពិសោធន៍ទុក្ខឬត្រូវលះបង់តណ្ហាដើម្បីសប្បាយនៅក្នុង សុភមង្គលផ្លូវចិត្ត។ គ្មានផ្លូវពីរសម្រាប់ដោះស្រាយវានោះទេ។

**តើអ្នកណាជាអ្នកទទួលខុសត្រូវ?** (Who is Responsible?)

មានភាសិតចាស់មួយដែលនិយាយអំពីនេះ :"មនុស្សដែលមិនបានទទួល ការអប់រំ*(the uncultured man)*ជានិច្ចកាលតែងតែស្ដីបន្ទោស*គេឯងមនុស្សដែលមានការអប់រំត្រឹមតែពាក់កណ្ដាល (semi-cultivated man)ស្ដីបន្ទោសខ្លួនឯង ហើយមនុស្សដែលមានការអប់រំដោយបរិបូណ៌ (the fully-cultured man)គឺមិនស្ដីបន្ទោសអ្នកណាទាំងអស់*"។ អ្នកត្រូវតែរៀនប្រឈមមុខនិងទទួលយកបញ្ហារបស់អ្នកដូច *អ្នក*ដែលមាន *ការអប់រំពេញបរិបូណ៌* នៅក្នុងឃ្លាដកស្រង់ខាងលើនេះ។ សូមកុំព្យាយាមស្វែងរក *កំហុសស្រាលៗរបស់អ្នកដទៃ* (convenient scapegoat) ដែលត្រូវដាក់លើបញ្ហារបស់អ្នកដូចមនុស្សជាច្រើនមានទំនោរធ្វើ។ មនុស្សជាច្រើន

ស្វែងរក *កំហុស* (scapegaots) នៅក្នុង *មនុស្សម្នាក់ ឬ ក្រុមមនុស្ស*ដោយងាយស្រួលបំផុត ប៉ុន្តែគេពិបាកនឹងរកឱ្យឃើញពី *កំហុស* នៅចំពោះខ្លួនគេណាស់។

*"ត្រូវហើយ"*អ្នកអាចនិយាយថា *"ខ្ញុំនឹងមិនស្តីបន្ទោសអ្នកណាឡើយ ខ្ញុំត្រូវតែស្តីបន្ទោសតែខ្លួនឯងមួយប៉ុណ្ណោះ"*។ ទេអ្នកមិនត្រូវស្តីបន្ទោសខ្លួនឯងទេ។ ការស្តីបន្ទោសដាក់គេ ឬដាក់ខ្លួនឯងមានលក្ខណៈអវិជ្ជមានហើយមិននាំអ្នកខិតទៅរក*ដំណោះស្រាយបញ្ហា*របស់អ្នកឡើយ។ សូមរកមើលកំហុសម្តងទៀត។ ជាជាងការមានសេចក្តីក្លាហាន និងការយល់ដឹង។ ការអប់រំ *អារម្មណ៍វិជ្ជមាន* នឹងជួយដោះស្រាយបញ្ហាជាច្រើនរបស់អ្នកហើយ នឹងជួយធ្វើឱ្យពិភពលោកក្លាយទៅជាទីកន្លែងកាន់តែស្រួលរស់នៅសម្រាប់មនុស្សម្នាក់ៗ។

បើអ្នកគេចពីការស្តីបន្ទោសបាន ទាំងខ្លួនអ្នក និងអ្នកដទៃ នៅពេលនោះអ្នកអាចចាប់ផ្តើមយល់ច្បាស់ថា អ្នកគឺជាជនតែមួយជាមួយនឹងពិភពលោក។ អ្នកគឺជាផ្នែក និងជាកញ្ចប់ (parcel)នៃ *អ្វីៗទាំងអស់* ហើយមិនអាចឃ្លាតពីពិភពលោកបានឡើយ។ ដូច្នេះ *ពិភពលោកនឹងល្អប្រសិនបើ អ្នកល្អ ហើយ ពិភពលោកអាក្រក់ប្រសិនបើអ្នកអាក្រក់*។ សូមអ្នកកុំព្យាយាមរត់គេចពី *បញ្ហាដោយស្តីបន្ទោសពិភពលោក ដោយនិយាយថាពិភពលោកខុសឯ ខ្លួនអ្នកត្រឹមត្រូវ*។

ពេលអ្នកចាប់ផ្តើមមើលឃើញ *អ្វីៗ*តាមដែលវាមាន មិនមែនតាមដែលវាសម្តែង ឡើង នោះអ្នកនឹងយល់ថា ពិតជាគ្មានអ្នកណាគួរឱ្យស្តីបន្ទោសឡើយ។ ផ្ទុយទៅវិញនៅក្នុងស្មារតីខ្ពស់បំផុតវាទទួលបាន*គតិបណ្ឌិត*ដែលត្រូវយល់ច្បាស់ថា *ខ្លួនអ្នក*គឺជា*អ្នកទទួលខុសត្រូវ*ចំពោះ*អ្វីៗ*។

**មធ្យោបាយកាត់បន្ថយបញ្ហារបស់អ្នក** (Ways to Reduce Your Troubles)

ចាប់ពីចំណុចនេះតទៅមុខ អ្នកអាចរកឃើញឱវាទមានប្រយោជន៍មួយចំនួនទៅលើថា តើត្រូវយកឈ្នះលើ *សេចក្តីលំបាក* របស់អ្នកយ៉ាងដូចម្តេច ហើយអ្នកអាចរកឃើញ *សេចក្តីចុះសម្រុងគ្នា សន្តិភាព*និង *សុភមង្គល*ជាមួយអ្នក និងជាមួយអ្នកដទៃយ៉ាងណា។

១- *ការប្រឈមមុខនឹងបញ្ហារបស់អ្នក* (Facing your problems) ៖ដរាបណា *សេចក្តីលំបាក*និង *បញ្ហាជាក់ស្តែង*កើតមានឡើង *មនុស្ស*គួរខិតខំព្យា យាមយល់ពីវានៅក្នុង *បរិបទធម្មជាតិអត្ថិភាព* (the nature of existence)។ គេមិនអាចសង្ឃឹមលើ *វត្តមាន*ថា *សុក្រឹតលក្ខខណ្ឌត្រូវគ្នា* (conditions congenial) ហើយគ្រប់គម្រោងរបស់គេសុទ្ធតែប្រព្រឹត្តទៅដោយរលូនគ្រប់ពេលនោះទេ ផ្ទុយទៅវិញទាំង អស់នេះ

សុទ្ធតែជា*វត្ថុដែល*គេប្រាថ្នាចង់បាន។ *សច្ចភាព*គឺថា *ការចង់បានដ៏ច្រើន*ដែលគេមាន ចំពោះ *វត្ថុ*មិនឱ្យមាន *ការប្រែប្រួល*ឱ្យមាន *ដំណើរត្រូវវត្ត*និង *សុក្រឹតភាព* ចំណង់ដ៏ធំ បែបនេះនឹងក្លាយទៅជា*ការខកចិត្ត*របស់គេពេល *ដំណើរបញ្ច្រាស* កើតមានឡើង។ ប្រៀបដូចជា*ដំណើររីកធំឡើង*(waxing)និង*ដំណើរហោចទៅ* (waning) នៃ*ព្រះច័ន្ទវត្ត* ទាំងអស់សុទ្ធតែ*ប្រែប្រួល*មិនមែនជាទិសដៅដែលចង់បានជានិច្ចកាលនោះទេ។

*សភាពវាសនាជោរនាចនេះ កាលៈទេសៈ*និង *សភាព*នៃ *ចិត្ត*សុទ្ធតែជានិមិត្តរូប *លក្ខខណ្ឌលោកិយ៍*ទាំងអស់។ *ព្រះពុទ្ធ* ទ្រង់សម្តែងអំពី *លក្ខខណ្ឌលោកិយ៍ចំនួន៨*ដែលមាននៅក្នុងលោកនេះ : *ជោគជ័យ* និង *បរាជ័យ* (gain and loss) *មានយស*និង *ឥតយស* (honor and dishonor), *លើកសរសើរ* និង *ស្តីបន្ទោស* (praise and blame) *សុភមង្គល*និង *សេចក្តីទុក្ខ* (happiness and sorrow)។ធម្មជាតិពិភពលោកគឺបែបនេះដែលគេមិនអាចនឹកស្មឹមនឹងទទួលបានបទពិសោធន៍ចំពោះ *លក្ខខណ្ឌល្អៗ* គ្រប់ពេលនោះទេ។

ពេល *លក្ខខណ្ឌ*មានលក្ខណៈមិនគួរឱ្យពេញចិត្ត អ្នកអាចមានអារម្មណ៍អំឡុងពេល បែបនេះដែលអ្នកបានមកដល់ *ទីបញ្ចប់ផ្លូវ*(road-end) ហើយ *ពិភពលោកទាំងមូលកំពុង*តែប្រឆាំងចំពោះអ្នក។ ប៉ុន្តែមុនពេលបណ្តោយឱ្យអ្វីៗដែលនៅជុំវិញខ្លួនអ្នកដួលរលំបាន គ្រាន់តែធ្វើការប្រៀបធៀប *កម្រិតឈឺចាប់* ដែលកើតទុក្ខជាមួយ *កម្រិតឈឺចាប់*ដែលធ្លាប់មានបទពិសោធន៍ដោយ *អ្នកដទៃ*ដែល *អភព្វ*ជាង *ខ្លួនអ្នក* តែប៉ុណ្ណោះ។ ប្រសិនបើអ្នកខ្វល់ខ្វាយចិត្តចំពោះការបាត់*កាបូបលុយ*ព្រោះតែ*ចោរលួចហោប៉ៅ*សូមអ្នកគិតពី*ទុក្ខ*ដែលបានស៊ូទ្រាំដោយ*មនុស្ស*ដែលបានបាត់ *ផ្ទះសម្បែងរបស់*ពួកគេ ហើយនិង *ការជួយសង្គ្រោះជីវិត* (life-saving)ទាំងស្រុងចេញពី *ភ្លើងឆេះ ទឹកជំនន់*។ ប្រសិនបើអ្នកមានអារម្មណ៍ក្រៀមក្រំមនឹងមុខមិន ស្រស់ស្រាយ សូមអ្នកគិតពី *មនុស្ស*ជាច្រើនដទៃទៀតដែលបានកើតឡើង *ខ្វាក់* និង *ថ្លង់ ពិការ*និង *វិកលចរិត*។ គេធ្វើការប្រៀបធៀបជាមួយនឹង *បញ្ហា*របស់ *អ្នកដទៃបញ្ហា* របស់អ្នកបានក្លាយទៅជា *មិនសំខាន់*ទៅវិញ។ម្យ៉ាងទៀតប្រសិនបើអ្នកត្រូវផ្លាស់ប្តូរឥរិយាបថរបស់អ្នកដើម្បីគិតពីមង្គល (blessind) របស់អ្នកជំនួសឱ្យ *បញ្ហា* នោះ អ្នកពិតជានឹងរកឃើញពីខ្លួនអ្នកប្រសើរជាងអ្នកដទៃ ជាច្រើនទៀតជាមិនខាន។

ដូច *សុភាសិតបុរាណចិនមួយ* ឃ្លាថា *"ប្រសិនបើអ្នកមានបញ្ហាធំមួយសូមអ្នកកាត់បន្ថយវាឱ្យទៅជាបញ្ហាតូចតាចមួយវិញ ។ ប្រសិនបើអ្នកមាន បញ្ហាតូចមួយវិញ សូមបន្ថយឱ្យទៅជាគ្មានបញ្ហាវិញ"* អ្នកនឹងត្រូវគេមានការភ្ញាក់ផ្អើលថា តើក្តីកង្វល់របស់អ្នកប៉ុន្មានដែលរលាយបាត់ពេលបញ្ហាត្រូវបានគេមើល ឃើញនៅក្នុង *ទស្សនវិស័យសមរម្យ*របស់វានោះ ។ អ្នកចង់រំលឹកមើលពី *បទពិសោធន៍មុនៗ*របស់អ្នកទៅលើថា តើអ្នកមានលទ្ធភាពយកឈ្នះលើ *សេចក្តីលំបាក* របស់អ្នកនៅ *គំនិតដំបូង*ដែលមិនអាចយកឈ្នះបានយ៉ាងណា ។ តាមរយៈការធ្វើ បែបនេះអ្នកនឹងមិនរន្ធត់ចំពោះ *បញ្ហានានា* ឡើយ ហើយអ្នកនឹងមានលទ្ធ ភាពដោះស្រាយ *បញ្ហាទាំងនោះ* ដោយ *ធនធានកាយ*និង *ចិត្ត*របស់អ្នក ។ គ្រាន់តែគិតថា*បញ្ហា*ដែលអ្នកកំពុងប្រឈមមុខនោះមិនមានលក្ខណៈ *អាក្រក់បំផុត*ដែលអាចកើតមានឡើងនោះទេ ហើយដែលអ្នកធ្លាប់ឆ្លងកាត់*បញ្ហាធំៗ*កាលពីមុន ។ បន្ទាប់មកសូមប្រឈមមុខចំពោះបញ្ហារបស់អ្នកទ្វេគុណហើយសូមប្រើ *វីរកម្មខួរក្បាល*របស់អ្នកដើម្បីយកឈ្នះ យកចាញ់គេចចេញ ឬមានប្រៀបលើបញ្ហា ។ *បញ្ហាជាច្រើន*របស់អ្នកនឹងត្រូវរលាយចូលទៅក្នុងខ្យល់ប្រសិនបើអ្នក មានដំណោះស្រាយបែបនេះ ។ បើទោះជា*បញ្ហា*ទៅជា*អាក្រក់*ហួសពីការស្មានរបស់អ្នកពេលអ្នកលេចធ្លោឡើងដោយសារវា*ស្វ័យទំនុកចិត្ត*របស់អ្នក នឹងរីកចម្រើនទៅតាម *ចំណេះដឹង* ដែលអ្នកពិតជា ខ្លាំងជាងអ្នកបានគិតថាអ្នកខ្លាំងនោះទៅទៀត ។

*មនុស្សម្នាក់ៗ*សុទ្ធតែប្រឈមមុខ *នឹងបញ្ហា* បើទោះជាម្នាក់ៗនឹងមានប្រតិកម្ម និងកែតម្រូវ ចំពោះវាដោយខុសគ្នាក៏ដោយ ។ គេបានផ្តល់ឱ្យបញ្ហាប្រហាក់ប្រហែលគ្នាមួយឈុតបញ្ហាខ្លះកើតមានចំពោះគេដោយស្រាលៗមានទំនងជាខ្លាំងៗនិងធ្ងន់ធ្ងរ ។ ខ្លះសង្ឃឹមលើ *បញ្ហា* ដោយការគិតពិចារណាទៅលើវាជា *"ជម្លោះ"* ដែលអាចជម្រុញឱ្យពួកគេប្រើ *ថាមពលកាយ* និង*ចិត្ត*របស់ គេដោយពេញលេញ ។ ម្យ៉ាងវិញទៀត អ្នកខ្លះបំផ្លាញចោលឬត្រូវស្រោចលើ ឬត្រូវបញ្ហាបង្អាក់ មិនដំណើរការទាំងស្រុង ។ **មញ្ញា**នៅទីនោះជានិច្ចកាលតែងតែបែបនោះ ។ ចំណុចសំខាន់នៃបញ្ហាមិនមានច្រើនថាតើត្រូវរត់គេចពី *បញ្ហាសព្វយ៉ាង* យ៉ាងដូចម្តេចនោះទេប៉ុន្តែថាតើត្រូវដោះស្រាយវាដោយមិនបង្កើតឱ្យមាន *បញ្ហាដទៃទៀត* យ៉ាងដូចម្តេចនេះឯង ។

**២-ទំនួលខុសត្រូវចំពោះសន្តិភាពខាងក្នុង** (Responsibility for Inner Peace) :

*សេចក្តីសុខ*និង *សន្តិភាព*នៅក្នុង *ចិត្តមនុស្ស* អាចបន្ត ឬកម្ចាត់ចោលដោយពឹងផ្អែកទៅលើ *ឥរិយាបថខួរក្បាលរបស់គេ*។ *សន្តិភាព*ខាងក្នុងរបស់គេអាច នៅជាប់ជា

មួយ នឹង *ការចុះចាញ់ដោយខ្លួនឯង* (self-surrender) និងការបំបាត់ *មោទនភាព* (casting away of pride) ។ បើគេប្រកាន់ខ្ជាប់ចំពោះ *អនត្តៈ* (the false ego) ហើយរក្សាបាននូវ *ឥរិយាបថអវិជ្ជមាន*នោះ *បញ្ហា*និង *ចិត្តរំខាន*ផ្តល់ផលភ្លាម១។ ក្នុងការខិតខំរបស់គេដើម្បី*លើកពីគោលដៅអាត្មានិយមរបស់គេហើយនិង ផលប្រយោជន៍តូចចង្អៀត* គេបានធ្វើឱ្យខ្លួនគេមិនអាចធន់នឹង *អ្នកដទៃ* បានហើយក៏បង្កទុក្ខទោសដល់ខ្លួនគេ។ ម្យ៉ាងវិញទៀតថ្វីបើ*លក្ខខណ្ឌ ខាងក្រៅមនុស្ស* អាចមាន *សុភមង្គល* តាមរយៈការរក្សា *ចិត្តមានលំនឹង* (a balanced mind) និង *ឥរិយាបថវិជ្ជមាន* ហើយសភាពមាន សុភមង្គលនោះត្រូវបាត់បង់ក៏ព្រោះតែគេបណ្តោយឱ្យ *លក្ខខណ្ឌខាងក្រៅ* ដំណើរការមិនស្រួលដែរ។

ជាឧបមាយើងនឹកស្មានថា ការរិះគន់គ្រាន់តែកើតមានឡើងអំពីអ្នក ឬកិច្ចការរបស់អ្នកប៉ុណ្ណោះ។ ជារឿយៗនៅក្នុងស្ថានភាពមួយបែបនេះ អ្នកអាចមានអារម្មណ៍ជេរប្រមាថ។ *អត្តៈ*របស់អ្នកអាចត្រូវអន្តរាយ។ ប៉ុន្តែមុនពេលអ្នកបណ្តោយឱ្យ *គំនិតបែបនេះ*កើតមានឡើងសូមពិនិត្យមើលការរិះគន់ដោយលំអៀងនោះ។ ក្នុងន័យម្យ៉ាងប្រសិនបើការរិះគន់ដែលគេបានផ្តល់ឱ្យសមហេតុសមផល ហើយកើតឡើងជាមួយនឹង *បំណងល្អ* អ្នកគួរតែទទួលយកថា ការរិះគន់ទៅលើ*ជំនឿល្អ* ដែលត្រូវប្រើប្រាស់វាដោយស្ថាបនាសម្រាប់ *ការកែលំអខ្លួនឯង*។ ម្យ៉ាងវិញទៀតប្រសិនបើវាមិនត្រឹមត្រូវមិនសមហេតុសមផលហើយគេបានផ្តល់ឱ្យដោយមាន*បំណងអាក្រក់* នោះនៅតែគ្មានមនុស្សណាបាត់បង់អារម្មណ៍របស់គេឡើយ ហើយដើម្បីសងសឹកដោយគ្រាន់តែធ្វើពើធ្វើមិនដឹងពីការរិះគន់ ព្រោះវាមិនពិត ហើយអ្នកគ្មានកាតព្វកិច្ច នឹងទទួលយកវាឡើយ។

ករណីបែបនេះគួរតែជា *ឥរិយាបថ* របស់អ្នកចំពោះគ្រប់ការរិះគន់ទាំងអស់ ពោលគឺមានការស្ថាបនា ឬមានលក្ខណៈអវិជ្ជមាន។ ប្រសិនបើអ្នកបានប្រព្រឹត្តដោយ *ចំណង់ស្មោះត្រង់* ហើយ *អំពើ* របស់អ្នកត្រូវបានលើកសរសើរភាពឆ្លាតវៀងវៃ នៅពេលនោះអ្នកមិនគួររារែក ពីការសម្តែងការងារល្អនោះទេ ពីព្រោះតែសម្តីមិនសប្បុរស។ សូមអ្នកលួងលោមចិត្ត ដោយដើរតាមព្រះធម៌(សច្ចភាព) ដែលជាការការពាររបស់អ្នក។ព្រះពុទ្ធទ្រង់ត្រាស់សម្តែងថា "*អ្នកណាមួយ ដែលបង្កទុក្ខទោសដល់ អ្នកស្លូតបូតពោលគឺ មនុស្សល្អបរិសុទ្ធនៅលើ អំពើអាក្រក់លីលា*

*បំផុតនោះ ត្រូវរួញថយដូច ធូលីដីដែលគេបាចបញ្ច្រាស ខ្យល់ដូច្នេះដែរ ។"* ហើយ *អ្នកនឹង* គ្មានអារម្មណ៍ឈឺចាប់ទេ លុះត្រាតែ *អ្នក* បណ្តោយឱ្យ *អ្នកដទៃ*មានជោគជ័យក្នុងការធ្វើវា ។

លើសពីនេះទៀត*ឥរិយាបថខួរក្បាល* ដែលអ្នកមានចំពោះ *អ្នកដទៃ*អាចកំណត់បានទៅលើ *ឥរិយាបថ* ដែលអ្នកទទួលត្រឡប់មកវិញ ។ ប្រសិនបើអ្នកសម្តែងពី *ការស្រឡាញ់* និង *ចិត្ត សប្បុរស*ចំពោះអ្នកដទៃអ្នកនឹងទទួលបាន*ការស្រឡាញ់* និង*ចិត្តសប្បុរស*នោះជះត្រឡប់មករកអ្នក វិញជាមិនខាន ។ ប៉ុន្តែប្រសិនបើអ្នកសម្តែងពី សេចក្តីស្អប់ នៅពេលនោះសេចក្តីស្អប់នោះ នឹងមកដល់អ្នកវិញ សូមកុំនឹកស្មានថា ការស្រឡាញ់ នឹងត្រូវសងដោយ សេចក្តីស្អប់ ទឹកចិត្តសប្បុរស ដោយភាពកំណាញ់ស្និតស្នាញ ហើយ និងសមានចិត្តដោយ ភាពឥតគំនិតនោះឱ្យសោះ ។ អ្នកមាន ទំនួលខុសត្រូវចំពោះការបង្កើតនិងការទ្រទ្រង់ដល់ ទំនាក់ទំនងល្អជាមួយអ្នកដទៃ ដើម្បីសេចក្តី សុខ ជាជាងឱ្យបញ្ហោយកឈ្នះលើអ្នក ។

**៣-ឧត្តមភាព សមភាព និងភាពតូចទាប** (Superiority, Equality and Inferiority)

អ្នកអាចជៀសវាង ការភ័យខ្លាចនិង បញ្ហា មិនចាំបាច់ប្រសិនបើអ្នកចង់ទប់ ខ្លួនពីការប្រៀបធៀប ខ្លួនអ្នកជាមួយនឹង អ្នកដទៃ ។ បើតាមខ្លួនវា អំពើនៃ ការប្រៀបធៀប មិនមានការខុសឆ្គងអ្វីទេ ប្រសិនបើវារំលឹក អ្នកឱ្យកាន់តែឆ្លាតឡើងនៅក្នុងគំនិត ហើយកាន់តែល្អប្រសើរឡើងនៅក្នុងអំពើ ។ ប៉ុន្តែជារឿយៗបំផុតការ ប្រៀបធៀបខ្លួនអ្នកជាមួយនឹងអ្នកដទៃដើម្បីមើលឱ្យឃើញបើអ្នកណាដែល"ខ្ពង់ខ្ពស់ជាង" ដឹកនាំទៅរកភាពមោទនភាពហួសហេតុ(conceit)ការភ័យខ្លាចមិនចាំបាច់ ។ប្រសិនបើអ្នក គិតថាអ្នកមាន សមភាព ចំពោះ អ្នកដទៃនោះ អ្នកអាច ពេញចិត្ត និង ស្ងប់ចិត្ត ។ ប្រសិនបើអ្នកគិតថាអ្នកទាបជាងគេវិញ អ្នកអាចទៅជាខ្វះមុខខ្លាចគេហើយតែល គោលជាមិនខាន ។ ដូច្នេះដើម្បីជៀសវាងការមាន សភាពខួរក្បាល អវិជ្ជមានបែប នេះបានត្រូវទប់ខ្លួនកុំធ្វើ ការប្រៀបធៀបបែបនេះ ។

វាអាចនឹងមានសារៈប្រយោជន៍ដើម្បីចងចាំថា ឧត្តមភាពសមភាពនិង ការបន្ទន់ខ្លួនពេកគឺជាសភាពមានទំនាក់ទំនងគ្នាដែលតែងប្រែប្រួលជារឿយៗទៅតាម ពេលវេលាទីកន្លែង និងកាលៈទេសៈ ។ នៅក្នុង វដ្តគ្មានទីបញ្ចប់ នៅក្នុង មហាសមុទ្រកើតនិង ស្លាប់ *(samsara)* យើងទាំងអស់គ្នាសុទ្ធតែមាន ឧត្តមភាពសមភាព និង ការបន្ទន់ខ្លួនពេកនេះចំពោះគ្នាទៅវិញទៅមក

ទៅតាម ពេលខុស១គ្នាជាច្រើន។ នៅពេលមួយអ្នកអាចជា អ្នកសុំទានគេខណៈពេលដែល អ្នកម្នាក់ទៀតគឺជា មហាសេដ្ឋី។

**៤-គ្មានសង្ឃឹមអ្វី ហើយគេមិនអាចធ្វើឱ្យអ្នកខកចិត្តបានទេ**(Expect nothing and you cannot be disappointed): មនុស្សម្នាក់១សុទ្ធតែមានសង្ឃឹមថា សេចក្តីប្រាថ្នារបស់គេ នឹងទទួលបានជោគជ័យនៅថ្ងៃណាមួយជាមិនខាន។ វាជាការសង្ឃឹមថា ការលួងលោម មនុស្សម្នាក់ដោយសុភាពរាបសាឱ្យខិតខំប្រឹងប្រែងឆ្ពោះ ទៅមុខដោយក្លាហានចំពោះមុខ ការលំបាកនិង ការបរាជ័យនានាដើម្បីគេអាចចាប់យក កំពស់ខ្ពស់១ បាន។ សេចក្តីសង្ឃឹម ក្នុងការសម្រេចសុបិន្តរបស់គេឱ្យបានជោគជ័យទៅតាមចម្ងាយ ណាមួយនេះនៅតែភ្លឺស្វាង ប្រកបដោយ សុទិដ្ឋិនិយម។

តែទោះជាយ៉ាងណាក៏ដោយពេលមនុស្សម្នាក់ទៅ ហួសពីការសង្ឃឹមហើយចាប់ផ្តើមសង្ឃឹមអ្វី១ដែល ត្រូវកើតឡើងដោយអនុលោមទៅតាមចិត្តគេចង់មានន័យថា គេកំពុងឈានជើង ចូលទៅរកការខកចិត្ត។ គេធ្វើល្អគ្រាន់តែព្រោះថា គេនឹកសង្ឃឹមរង្វាន់ឬ អំពើទៅវិញទៅមកណាមួយប៉ុណ្ណោះ។ ហើយប្រសិនបើរង្វាន់ នោះមិនទាន់មកដល់ទេ គេនឹងត្រូវស្រងាកចិត្តជា មួយនឹងការសម្តែងការងារល្អ។

បើអ្នកធ្វើល្អ នៅពេលនោះ សូមធ្វើវាសម្រាប់ប្រយោជន៍បម្រើសេវាកម្មដល់មនុស្សណាមួយ (some fellow being) ។ សុភមង្គលដែលកើតមានឡើងនៅក្នុង ខួរក្បាលអ្នក ដែលរួមជាមួយនឹង ការសម្តែងអំពើនោះគឺជា រង្វាន់ដ៏ធំមួយខ្លួនវា។ ដើម្បីសប្បាយរីករាយ អ្នកត្រូវពុះពារទទួលនូវ កតវេទិតាពីអ្នកដទៃចំពោះ អំពើដែលអ្នកបានសម្តែង។

នៅក្នុងសង្គម កតវេទិតានេះគឺជា គុណធមិកម្រមួយ។ នេះគឺជាហេតុផលដែលអ្នកគួរតែចងចាំពី ចិត្តសប្បុរសនិង កិច្ចសង្គ្រោះដែល អ្នកដទៃបានផ្តល់ឱ្យអ្នក។ ព្រះពុទ្ធទ្រង់ព្រះតម្រិះពីកតវេទិតានេះថា ជាមង្គលដ៏ធំមួយ (a great blessing) ជា គុណភាពវិជ្ជមានមួយ សម្រាប់អភិវឌ្ឍ។

ប៉ុន្តែប្រសិនបើអ្នកសម្តែងការជួយចំពោះអ្នកដទៃ សូមព្យាយាមកុំសង្ឃឹមលើកតវេទិតាដើម្បីជៀសវាង ការខកចិត្ត។ ប្រសិនបើអ្នកសង្ឃឹម នៅពេលនោះអ្នកកំពុងតែដាក់ សុភមង្គលរបស់អ្នកនៅចំពោះការុញ្ញចិត្ត(mercy)របស់អ្នកដទៃដែលមានទំនោរទៅបំភ្លេចចោលហើយ។ ប្រសិនបើពួកគេមិនបាន សម្តែងពី កតវេទិតា ទេសូមរៀនទទួលយក "ការបំភ្លេចចោល" បែប

នេះនៅក្នុងចិត្តដ៏ល្អរបស់អ្នក។ ប្រសិនបើពួកគេចងចាំពី ចិត្តសប្បុរស របស់អ្នក នៅពេលនោះ សូមប្រព្រឹតវាជា របស់លើកទឹកចិត្តមួយបន្ថែមទៅលើ ឱកាសដែលអ្នកមានសេវាកម្មចំពោះ អ្នកដទៃ។ ប្រសិនបើអ្នកធ្វើរឿងនោះ នៅពេលនោះអ្នកអាចសប្បាយចិត្ត បើទោះជាថាតើ អំពើរបស់អ្នកត្រូវគេចងចាំឬអត់នោះ។

**៥-ការអត់ឱន ចិត្តខន្តីនិងការយល់យោគគ្នា**(Tolerance Patience andUnderstanding)

ជាឱកាស មនុស្សដែលបានដឹកនាំ ជីវិតល្អនិងដោយ សុខសាន្តបានត្អូញត្អែរថា ពួកគេ បាន ក្លាយទៅជាអ្នករងគ្រោះដោយសារឧបាយកលនិងល្បិចកលទុច្ចរិតរបស់ អ្នកដទៃ (victims of wiles and intrigues of others)។ ពួកគេមិនបានបង្កបញ្ហាដល់អ្នកដទៃទេ ផ្ទុយ ទៅវិញពួកគេបានបង្កទុក្ខទោសដោយ ពួកគេគ្មានកំហុសអ្វីឡើយ។

ស្ថិតនៅក្នុងកាលៈទេសៈបែបនេះ អ្នករងគ្រោះស្លូតត្រង់ត្រូវតែយល់ច្បាស់ថា ពិភពលោកត្រូវបានតាក់តែងឡើងពី មនុស្សខុសៗគ្នាដែលមានលក្ខណៈពិសេសៗ របស់ពួកគេដូចជាមនុស្សល្អ និងមនុស្សមិនសូវល្អមនុស្សអាក្រក់និងមនុស្សមិនសូវអាក្រក់ពេក។ ដូច្នេះគេអាចលួងលោមខ្លួនគេថាគេ គឺជាប្រភេទមនុស្សល្អចំណែកឯអ្នកឆាឆៅសេចក្តីសុខគេនោះគឺជាប្រភេទមនុស្សអាក្រក់ ។ហើយនៅក្នុងឱកាសជាក់លាក់គេត្រូវតែលើកពីបាបកម្មរបស់មនុស្សអាក្រក់ៗ។

វាមានលក្ខណៈដូចករណី មនុស្សល្អនិងអ្នកបើកបរប្រយ័ត្នប្រយែង និងមនុស្សអាក្រក់ហើយ និងអ្នកបើកបរមិនប្រយ័ត្នប្រយែង។ មនុស្សល្អនិង អ្នកបើកបរប្រយ័ត្នប្រយែង បើកបរមានការ ប្រុងប្រយ័ត្នគ្រប់ពេលដើម្បីជៀសវាងពីគ្រោះថ្នាក់។ តែទោះជាយ៉ាងណាក៏ដោយ ពេលខ្លះគេជួបនឹងគ្រោះថ្នាក់ ដោយគ្មានកំហុសរបស់គេឡើយប៉ុន្តែនោះគឺជាករណីរបស់ មនុស្សអាក្រក់ហើយ និងអ្នកបើកបរមិនប្រយ័ត្នប្រយែង។ ដូចនេះ មនុស្សល្អពេលខ្លះត្រូវទទួលទុក្ខទោស ដោយសារ តែមានមនុស្សអាក្រក់ដូចគ្នា នឹង អ្នកបើកបរមិនប្រយ័ត្នប្រយែងដែរ។

ក្រោយពីបានរៀបរាប់រួចមកនេះ វាជាការមានប្រយោជន៍ដើម្បីត្រូវចងចាំថា អ្នកបើកបរប្រយ័ត្នប្រ យែងមែនទែននោះអាចគេចផុតពីគ្រោះថ្នាក់ ពីព្រោះគេធ្វើដោយឆ្លាតវាងវៃនៅលើផ្លូវហើយគេស្មានទុកពី អំពើបើកបររបស់អ្នកដទៃទៀតដោយត្រឹមត្រូវ។ នេះមិនមានការខុសប្លែកគ្នាពីការដាស់តឿនទៅលើ បញ្ហាសក្តានុពលជាមួយ នឹងអ្នកបង្កើតបញ្ហា និងអ្នកប្រព្រឹត្ត អំពើអាក្រក់។ មានមធ្យោបាយមួយដែលត្រូវ ជៀសវាងការសេពគប់ជាមួយ នឹងពួកវាតាមតែអាចធ្វើទៅបានជាពិសេសពេល អ្នកមិនស្ថិតនៅក្នុងជំហរផ្លាស់ប្តូរមធ្យោបាយរបស់

ពួកគេ។ អ្នកអាចមិនមានភាពរឹងមាំដើម្បីទប់ទល់ពីការទាញបញ្ចូលទៅក្នុង កំសួលទោសៈ និង ការសងសឹក បានទេ។

ប៉ុន្តែបើអ្នករឹងមាំគ្រប់គ្រាន់ដើម្បីទប់ទល់ជាមួយនឹង ឥទ្ធិពលអាក្រក់ របស់ពួកគេ នៅពេលនោះអ្នកគួរតែបង្កើតគ្រប់ការខិតខំប្រឹងប្រែងដើម្បីកែពួកគេជំនួសឱ្យការបំបែកបំបាក់និង បោះបង់ពួកគេចោល ។ពួកគេក៏ជាមនុស្សផងដែរដែលគេអាចនាំចូលទៅក្នុង ដែនសាសនាបាន។ វិធីដើម្បីមានឥទ្ធិពលទៅលើមនុស្សអាក្រក់ឱ្យមកជាមនុស្សល្អគឺធ្វើឡើងតាមរយៈការប្រតិបត្តិ ការអត់ឱនចិត្តខន្តី និង ការយល់យោគគ្នាដោយវៃឆ្លាត។

ការយល់យោគគ្នានឹងក្លាយជាខែលការពារ ខ្លួនអ្នកពី ល្បិចកលរបស់ពួកគេហើយមេត្តាធមិ របស់អ្នកនឹងក្លាយទៅជា អណ្តាតភ្លើង(flame)រំលាយ បេះដូងទាំងអស់។ មនុស្សតែងតែប្រព្រឹត្តខុសដោយសារតែ អវិជ្ជាឬការយល់យោគរបស់គេអំពីខ្លួនគេ អំពីបំណងប្រាថ្នាសម្រេចបានសុភមង្គលរបស់គេ ហើយនិងវិធីដើម្បីបាន សុភមង្គលរបស់គេ។ ប្រសិនបើរឿងវាបែបនេះ មែន វាគឺជាអំឡុងពេលដែលគេយល់ច្រឡំថា អ្នកគួរតែប្រព្រឹត្តដោយម៉ឹងម៉ាត់ជា មួយនឹងការ អប់រំនិងការហ្វឹកហាត់សាសនា របស់អ្នក។ វាគឺជាពេលវេលាធ្វើវិនិច្ឆ័យថា ភាពរឹងមាំនៃអត្តចរិតគតិបណ្ឌិតនិង មេត្តាធមិរបស់អ្នកត្រូវបានគេទទួលស្គាល់។ ពេលអ្នកដទៃ ធ្វើខុសមកលើអ្នកពួកគេបានផ្តល់ឱ្យអ្នកនូវឱកាសមួយដើម្បីយល់ដឹងពី ទង្វើក្រខ្វក់និង គុណធមិរបស់អ្នក ព្រោះ ថាការយល់យោគគ្នា បែបនេះអ្នកនឹងមានលទ្ធភាពប្រព្រឹត្តទៅរកការកែប្រែទង្វើក្រខ្វក់និងការ ពង្រឹង គុណធមិរបស់អ្នក។

ការអត់ឱន ចិត្តខន្តី និងការយល់យោគគ្នា គឺជា គុណភាពធំៗ សម្រាប់អ្នកដើម្បីប្រតិបត្តិ អំឡុងពេលមនុស្សម្នាក់ប្រព្រឹត្តដោយអវិជ្ជាមកលើអ្នក ។គុណភាពទាំងនេះអាចជួយរំដោះអ្នកពី ទុគិតភាពទុក្ខនិងចំណោទជីវិត។ មនុស្សមួយចំនួនអាចទទួលបានប្រយោជន៍ពី អំពើល្អ របស់អ្នកពេលអ្នកប្រតិបត្តិ គុណធមិ ទាំងនេះ។ ប៉ុន្តែអ្នកមិនគួរមានអារម្មណ៍គំរាមកំហែងឡើយ ប្រសិនបើអ្នកប្រតិបត្តិដោយវៃឆ្លាត ពីព្រោះគុណភាពទាំងនេះមានលទ្ធភាពធ្វើឱ្យ អ្នកប្រព្រឹត្តខុសយល់ច្បាស់ពី ភាពល្ងីល្ងើ និង អំណាចរបស់គេដើម្បីបញ្ជូនពួកវាទៅជា ការប្រព្រឹត្តល្អ។

**៦-ការអត់ទោស និងការបំភ្លេចចោល** (Forgive and forget) :ការសងសឹកទៅលើអ្នកបង្កើតបញ្ហារបស់អ្នកគឺបង្កើតបញ្ហានិងសេចក្តីលំបាកកាន់តែច្រើនឡើងៗដល់មនុស្សម្នាក់ៗ។ ក្នុងការសញ្ជឹងគិតពីការសងសឹកគ្នា អ្នកធ្វើឱ្យភ្លើងកំហឹង នៅក្នុងចិត្តរបស់អ្នក

ហើយនិងមាយាការលួតលាស់ឡើង។ ភ្លើងនេះនឹងរាលធំឡើងៗដែលអាចឆាបឆេះអ្វីៗ នៅក្នុងផ្លូវរបស់វាគឺខ្លួនអ្នកមុនគេបន្ទាប់មកអ្នកដទៃ។ កំហឹងប្រៀបដូចជាថ្នាំពុលដែលចាក់បញ្ចូលទៅក្នុងសសៃឈាមរបស់អ្នកមុន ពេលចាក់ចូលទៅក្នុងសត្រូវរបស់អ្នក។ វាប្រៀបដូចជាការគប់ លាមកគោ ទៅនរណាម្នាក់ដូច្នេះដែរ : អ្នកត្រូវប្រឡាក់ ដៃមុនគេបន្ទាប់មកបានធ្វើឱ្យអ្នកដទៃប្រឡាក់។

ពេល មនុស្សម្នាក់ធ្លាក់ចូលទៅក្នុងកំហឹងនេះគេមិនខុសប្លែកពី អ្នកប្រព្រឹត្តអាក្រក់ទេ។ ពោលគឺជាកម្មវត្ថុកំហឹងរបស់គេ។ ដោយការទទួលយកកំហឹងគេបានបាត់បង់ ស្វ័យត្រួតពិនិត្យដោយឃ្លាតឆ្ងាយពី ដំណោះស្រាយបញ្ហារបស់គេ។ គេក្លាយទៅជា អ្នកបរាជ័យមួយរូប។ ពេលណា មនុស្សខឹង ម្នាក់ព្យាយាមធ្វើទុក្ខបុកម្នេញ អ្នកណាម្នាក់ ប៉ុន្តែគេទទួលដោយញញឹម មិនខ្វល់មកវិញ តាមធម្មតាគេត្រូវបានយកឈ្នះដោយ អារម្មណ៏អស់សង្ឃឹម។ គេមានអារម្មណ៏ខូចចិត្តដោយមិនអាចធ្វើឱ្យអ្នកដទៃរកាំចិត្តបាន ហើយធ្វើឱ្យគេក្តៅក្រហាយជាខ្លាំង។ គេត្រូវបានយកឈ្នះពីព្រោះបក្សដទៃទៀតមិនធ្វើសហប្រតិបត្តិការ តាមវិធីនៃការចុះចាញ់ខួរក្បាលរបស់គេ និងការចូលរួមនៅក្នុង mudslinging ឡើយ។

ព្រះពុទ្ធទ្រង់ត្រាស់សម្តែងថា *"អា! យើងនាំគ្នារស់នៅដោយសប្បាយរីករាយដោយគ្មាន*សេចក្តីស្អប់ ក្នុងចំណោម អំពើគួរឱ្យស្អប់ *(the hateful)* ។ *ក្នុងចំណោម* អំពើគួរឱ្យស្អប់ យើងនាំគ្នារស់ដោយគ្មាន ការស្អប់គ្នា។" អ្នកប្រព្រឹត្តដោយវៃឆ្លាតប្រៀបដូច មនុស្សដែលមាន ការអប់រំដោយការមិន ស្អប់ ឬដោយការមិន វាយតបតត្រឡប់ទៅរក អ្នកបង្កើតបញ្ហាវិញ។ អ្នកត្រូវតែយល់ថានៅខណៈនោះ អ្នកបង្កើតបញ្ហា អាចនឹងត្រូវបំពុលដោយ សេចក្តីលោភការក្រេវក្រោធការច្រណែននិង សេចក្តីល្ងង់ខ្លៅ។ គេមិនខុសប្លែកអីពី មនុស្សដទៃ ដែលត្រូវបានគេបំពុល ប្រហាក់ប្រហែលគ្នានៅពេលផ្សេងៗទៀតដែរ។ ការយល់ដឹងបែបនេះនឹងមកដល់អ្នកតាមរយៈ ការប្រតិបត្តិសតិនេះឯង។

ពេលមនុស្សម្នាក់ប្រតិបត្តិ សតិ(mindfulness)គេមានការយល់ដឹងផ្ទាល់ខ្លួនអំពី កម្លាំងជម្រុញនិង ចំណង់ ពីភាពទន់ខ្សោយ និង ភាពរឹងប៉ឹងរបស់គេ។ ការរលឹកដឹងខ្លួនដោយ ខ្លួនឯងនេះហើយដែលជួយឱ្យគេរុញច្រាន គំនិតមិនល្អឱ្យទៅឆ្ងាយហើយពង្រីក គំនិតល្អៗឡើង។ កាល ណាគេមានការយល់ដឹងដោយខ្លួនឯងប្រសើរហើយគេយល់ច្បាស់ថាអ្នកដទៃ ត្រូវបានរកឃើញ នៅក្នុងស្ថានការណ៏លំបាកប្រហាក់ប្រហែលគ្នា។ គេមើលឃើញពី មិត្តភក្តិ របស់គេជាប់

អន្ទាក់ នៅក្នុងសំណាញ់អត្តៈមាយាការ (the net of self-illusion) ងងឹតដោយ អវិជ្ជា ការខិតខំ ព្យាយាមបំពេញ ចំណង់នីមួយៗរបស់ពួកគេដោយ ឥតបានការ។ ចេញពី អវិជ្ជានិង ចំណង់នោះ ការសម្តែងអំពើដែលនាំមកនូវ អពមង្គលមកឱ្យ អ្នកដទៃ និង ខ្លួនពួកគេ កើតមាន ឡើង។ ផ្ទុយទៅវិញបើទោះជាមាន ដែនកំណត់និង ភាពទន់ខ្សោយទាំងនេះក៏ ដោយក៏ភារៈ ទាំងនេះមានសក្តានុពលមួយចំពោះអត្ថិភាពកំណើនផ្លូវចិត្តដែរ។ ដើម្បីយល់ដឹងពីនេះមនុស្ស បែបនេះបានអភិវឌ្ឍចិត្តមេត្តាសម្រាប់ ភារៈទាំងអស់ អត់ឱនចំពោះ បញ្ហាដែលពួកគេបង្កើត ឡើងហើយ សិក្សារៀនសូត្រដើម្បី សុំអភ័យទោស និង បំភ្លេចចោល។

ព្រះពុទ្ធទ្រង់បង្រៀនថា "បើតាមធម្មជាតិ អ្នកប្រព្រឹត្តអំពើអាក្រក់ *មិនមែនសុទ្ធតែ* កំណាច*នោះទេ។ តាមពិត* មនុស្សជាច្រើន*ប្រព្រឹត្តអាក្រក់នោះក៏ព្រោះតែ* អវិជ្ជា*របស់ពួកគេ នេះឯង។ ដោយសារតែពួកគេ* អវិជ្ជានេះឯង *ទើបយើង* អត់ឱនឱ្យ*ពួកគេ* ជារៀងរហូត*នោះ។ យើងគោង តែខិតខំព្យាយាមដើម្បីកែពួក គេ ហើយនិងពន្យល់ពួកគេពី* កំហុស*របស់ពួកគេ*"។ ចិត្តមេត្តានិង ការយល់ដឹងបែបនេះដែល ព្រះពុទ្ធ ទ្រង់បានបង្រៀននោះជួយឱ្យគេប្រព្រឹត្ត មក លើអ្នកប្រព្រឹត្តអាក្រក់ប្រៀបដូចអ្នកជម្ងឺអត់ទ្រាំនឹងជម្ងឺដែរ។ ជំនួសឱ្យការស្តីបន្ទោសឱ្យគេឈឺ ចាប់នេះ អ្នកគួរតែខិតខំព្យាយាមរំលីង ហេតុដែលនាំឱ្យមានការឈឺចាប់ របស់គេដើម្បីឱ្យគេ បានល្អនិងសប្បាយឡើងវិញ។ តាមរយៈចិត្តមេត្តានិង សប្បុរសចំពោះមនុស្សម្នាក់អ្នក បានផ្តល់ ឱកាស មួយដល់គេដើម្បីយល់ច្បាស់ពី ការវង្វេងស្មារតីរបស់គេ ហើយនិងធ្វើឱ្យគេបោះ បង់ ទម្លាប់មិនល្អរបស់គេចោល។

ចិត្តមេត្តានិង សប្បុរសមានកម្លាំងខ្លាំងអាចផ្លាស់ប្តូរ អ្នកបង្កើតបញ្ហាម្នាក់ឱ្យទៅជាអ្នក ធ្វើទានម្នាក់បានហើយសត្រូវរបស់អ្នកនឹងក្លាយមកជាមិត្ត។ព្រះពុទ្ធសម្តែងថា "*កំហឹងមិនដែល រំលត់ដោយកំហឹងនោះឡើយប៉ុន្តែមានតែសេចក្តីស្រឡាញ់មួយប៉ុណ្ណោះ។នេះគឺជាច្បាប់មិនចេះ រីងស្ងួត*។"

ប្រសិនបើ មនុស្សម្នាក់មានចិត្តធ្វើ អំពើអាក្រក់មកលើអ្នកដៃគូរបស់អ្នក អ្នកគួរតែកែ គេ គ្រប់ពេល។ សូមខិតខំព្យាយាមដើរតាម គំរូដ៏ប្រសើររបស់ ព្រះពុទ្ធដែលជានិច្ចកាល តែង តែយក អំពើល្អសង អំពើអាក្រក់ត្រឡប់វិញ។ ព្រះអង្គទ្រង់ត្រាស់សម្តែងថា " អំពើអាក្រក់ដ៏ ច្រើនដែល កើតមានចំពោះតថាគត អំពើល្អ ដ៏ច្រើននឹងត្រូវភ្លឺចែងចាំងចេញពីតថាគតដែរ"។ មនុស្សមួយចំនួនគិតថាមិនគួរយកអំពើល្អទៅសង អំពើអាក្រក់ត្រឡប់វិញនោះទេ។ តាមរយៈ

ការយកអំពើអាក្រក់មកសង អំពើអាក្រក់ត្រឡប់វិញនោះវានឹងបង្កឱ្យស្ថានភាពកំហឹងកាន់តែធ្ងន់ឡើងៗ។ សូមអ្នកខិតខំយក អំពើល្អសង អំពើអាក្រក់ត្រឡប់វិញ។

ពេលយើងនិយាយថា *"ត្រូវយកអំពើល្អសង អំពើអាក្រក់ត្រឡប់វិញ" យើងមិនចាំបាច់មានន័យនេះ នៅក្នុងគំនិតប្រតិបត្តិនោះទេ។ ជាងនេះទៀត វាមានសារសំខាន់ច្រើន ក្នុងការអភិវឌ្ឍន៍សភាពខួរក្បាលដែល "ចិត្តសប្បុរស"* ត្រូវបានគេមានអារម្មណ៍ចំពោះ *ភាវៈទាំងអស់ដែ*ល មាននៅក្នុងលោកនេះ។ សូមអភិវឌ្ឍ *គំនិតសុទ្ធៈ* ដើម្បីឱ្យអ្នកគិតអំពី *សុខុមាលភាពអ្នកដទៃ* ជានិច្ចនិរន្តរ៍វិញ ដោយគ្មានបញ្ហាថាតើពួកគេ ធ្វើឱ្យអ្នកឈឺចាប់ប៉ុណ្ណា។ បើទោះជាអ្នករកឃើញថា នៅពេលថ្មីៗនេះ ថាជាអ្វីមួយដែលពិបាកសម្តែង អ្នកត្រូវតែបម្រើសេវាដ៏ធំមួយនេះចំពោះ*ខ្លួនអ្នក*និង*អ្នកដទៃដោយមិនយកអំពើអាក្រក់*សង*អំពើអាក្រក់*ត្រឡប់វិញនោះឡើយ។

**ពេលវេលា និងព្យាបាលរបួសយើងឱ្យសះស្បើយ :** សេចក្តីកង្វល់កន្លងផុតទៅ ។ អ្វីដែលបង្កឱ្យយើងយំសោក និងត្រូវបានបំភ្លេចចោលយ៉ាងឆាប់។ លោក-អ្នកអាចនៅចាំថាលោក-អ្នកបានស្រែកទ្រហោយំ ប៉ុន្តែមិនបានចងចាំថា ហេតុអ្វីលោក-អ្នកបានធ្វើយ៉ាងនោះទេ នៅពេលដែលយើងបានចម្រើន វ័យធំឡើងហើយបានឆ្លងកាត់ជីវិតរស់នៅ យើងតែងឆ្ងល់ជា ញឹកញយចំពោះហេតុយ៉ាងដូចម៉េច ដែលយើងដេកមិនលក់នៅពេលយប់ យើងត្រិះរិះពិចារណាអំពីរឿងអ្វីមួយដែលធ្វើឱ្យ យើងក្រឡកចិត្តនៅពេលថ្ងៃឬអំពីហេតុយ៉ាងដូចម៉េច ដែលនាំឱ្យយើងចិញ្ចឹមចិត្តគុំគួនអ្នកណាមួយដោយបណ្តោយឱ្យគំនិត ដដែលៗរត់ឆ្លងកាត់សន្តានចិត្ត របស់យើងពាក់ព័ន្ធនឹងការត្រិះរិះថា តើយ៉ាងដូចម៉េចបានជាយើងមានគំនុំ។ យើងអាចច្រឡោតខឹងភ្លាមៗចំពោះរឿងអ្វីមួយហើយក្រោយបន្តិចមកចង់ដឹងថា យើងក្រោធខឹងពីរឿងអ្វី ហើយយើងភ្ញាក់ផ្អើលដោយដឹងថា យើងចំណាយពេល និងកម្លាំងឥតប្រយោជន៍។ យើងបានបន្តការក្រោធខឹងដោយចេតនាក្នុងពេលដែលយើងអាចបញ្ឈប់ កំហឹងនោះបានហើយចាប់ផ្តើមត្រិះរិះអំពីរឿងអ្វីផ្សេងដែលល្អជាង។

ទោះជាសេចក្តីព្រួយកង្វល់របស់យើងជាអ្វីក៏ដោយ ហើយទោះជាយើងមានអារម្មណ៍ឈឺចាប់យ៉ាងណាក៏ដោយពេល វេលានឹងព្យាបាលរបួសចិត្តរបស់យើង។ ប៉ុន្តែ ប្រាកដណាស់វាត្រូវតែមានអ្វីមួយ ដែលយើងអាចធ្វើដើម្បីរក្សាខ្លួនយើងកុំឱ្យប៉ះទង្គិចជាមុនសិន ។ តើហេតុអ្វីក៏យើងបណ្តោយឱ្យអ្នកដទៃ ឬសេចក្តីព្រួយកង្វល់មកបង្អាតកម្លាំងរបស់យើង ហើយធ្វើឱ្យយើងកើតទុក្ខ? ចម្លើយគឺអ្នកដទៃមិនបានធ្វើទេ។ គឺខ្លួនយើងទេ ដែលធ្វើឱ្យខ្លួនឯងកើតទុក្ខ។

លោក-អ្នកអាចមានកង្វល់ខ្លះនៅកន្លែងធ្វើការរបស់លោក-អ្នក ប៉ុន្តែលោក-អ្នកមិនត្រូវចម្លងបរិយាកាសអ័ព្ទអ៊ួរទៅ ក្នុងគ្រួសាររបស់លោក-អ្នកទេ។ លោក-អ្នកត្រូវដឹងច្បាស់ថា បញ្ហាទាំងឡាយនោះមានទីបញ្ចប់របស់វា។ ដំណោះស្រាយអាច រកឃើញនៅក្នុងការសម្រេចបាននូវការរំដោះ(ឬសេរីភាព)ផុតពីចំណង់អត្តទត្ថភាពរបស់យើងតាមរយៈការលុបបំបាត់ភាពច្របូកច្របល់ និងអវិជ្ជាក្នុងគ្រប់រូបភាព។

កាលណា យើងបរាជ័យក្នុងការរកឃើញដំណោះស្រាយចំពោះបញ្ហាណាមួយ យើងតែងមានទំនោរទម្លាក់កំហុសលើ អ្នកដទៃដើម្បីលុបលាងកំហុសរបស់យើង។ យើងមិនបានត្រៀមខ្លួនដើម្បីទទួលស្គាល់ចំណុចខ្វះខាតផ្ទាល់របស់យើងទេ។ វាជាការងាយស្រួលដើម្បីទម្លាក់ការស្តីបន្ទោសទៅលើអ្នកដទៃ។ តាមពិតមានមនុស្សខ្លះសប្បាយ នឹងប្រព្រឹត្តដូច្នេះទៀតផង។ នេះគឺជាអាកប្បកិរិយាខុស ឆ្គងទាំងស្រុងមិនត្រូវប្រកាន់យក ។ យើងមិនត្រូវបង្ហាញគំនិតព្យាបាទចំពោះអ្នកដទៃឡើយ។ យើងត្រូវខិតខំឱ្យអស់ លទ្ធភាពដោយសេចក្តីព្យាយាម និងដោយភាពស្ងប់ស្ងៀមដើម្បីដោះស្រាយបញ្ហាផ្ទាល់ខ្លួនរបស់យើង ។ យើងត្រូវត្រៀមខ្លួនប្រឈមមុខ ដោះស្រាយសេចក្តីលំបាកណាមួយ ដែលយើងបានជួបប្រទះ។

**ត្រូវចេះសម្របសម្រួលខ្លួនយើង** : ទំនៀមទម្លាប់ និងប្រពៃណី គឺជាចំណង់ដ៏សំខាន់សម្រាប់ការរៀន និងការចែករំលែកបទពិសោធន៍របស់មនុស្សនៅក្នុងសហគមន៍ណាមួយ ។ ឧភតោ កោដិកបញ្ហា ឬបញ្ហាមួយមានចុងចំណោងសងខាង (the dilemma) ដែលយើងកំពុងប្រឈមមុខក្នុង ពិភពលោកដ៏ប្រែប្រួលឥតឈប់ឈរសព្វថ្ងៃគឺថា តើត្រូវរស់នៅជាមួយ អតីតកាល ឬត្រូវរស់នៅផ្តាច់ចេញពីអតីតកាល ។ វាតែងកើតមាន "ចន្លោះជំនាន់" ជានិច្ចរវាងពួកមនុស្សចាស់ និងពួកមនុស្សក្មេងដោយសារមានទស្សនាទាន (ឬមតិបញ្ញត្តិ) ផ្សេងពីគ្នាអំពីកាលៈទេសៈ និងតម្លៃ (values) ដែលកំពុងប្រែប្រួលជាប្រចាំ ។ ពួកចាស់បារម្ភខ្លាចពួកក្មេងបោះបង់បេតិកភ័ណ្ឌរបស់ខ្លួនចោល ឯពួកក្មេងព្រួយកង្វល់ខ្លាចបេតិកភ័ណ្ឌបរមបុរាណនោះប្រែក្លាយជាឧបសគ្គរាំងផ្លូវក្នុងជីវភាពសម័យថ្មីនេះ។ ការប្តូរផ្លាស់ណាមួយត្រូវតែបានពិចារណា ដោយល្អិតល្អន់ជានិច្ច។

វប្បធម៌ប្រជាប្រិយ៍ បានបង្កើតឡើងនូវគោរវរូបបណ្តោះអាសន្ន (momentary idols) និងវីរបុរសប្រជាប្រិយ៍ដែលបង្ហាញ រូបភាពនៃបែបបទរស់នៅប្រកបដោយទំនាស់ ។ ឧបករណ៍ឃោសនា មហាជន បានជួយផ្សព្វផ្សាយរូបភាពទាំងឡាយបែបនោះ ថែមទៀត ធ្វើឱ្យខួរក្បាល

យុវជនទោរទន់ទទួលយកអ្វីៗ ដែលបានឃើញ ។ វាអាចជាសេចក្តីផ្សព្វផ្សាយនយោបាយ ឬ សង្គមនៅ ក្នុងចលនាបែបនេះដូចជា ចលនាហ៊ិព្វីឬចលនាយុព្វី (the Hippie or Yuppic movements) ប៉ុន្តែ អ្វីដែលមានសារៈសំខាន់ជាងអាយុជីវិតគឺ យុវជនត្រូវមានគតិបណ្ឌិតរបស់មនុស្សចាស់ ដើម្បីរើកញែកអ្វីដែលល្អចេញពីអ្វីដែលអាក្រក់។ តម្លៃដ៏ល្អរបស់អតីតៈដែលបានឆ្លងកាត់ពេលវេលា និងការសាកល្បងរួចហើយមិនប្រែប្រួលទេ។ តម្លៃទាំងឡាយ ដូចជាការសន្សំសំចៃ សុចរិត សប្បុរសធម៌ និង ការងារហ្មត់ចត់ ដើម្បីមានជីវភាពរស់នៅប្រកប ដោយសេចក្តីថ្លៃថ្នូរ ឋិតនៅថ្មីជានិច្ចក្នុងសហគមន៍ណាក៏ដោយ។

នៅក្នុងបរិយាកាសទ្វីបអាស៊ីប្រពៃណី និងទំនៀមទម្លាប់អាពាហ៍ពិពាហ៍ និងបុណ្យសព មានសារៈសំខាន់ខ្លាំងណាស់។ បញ្ហាចោទគឺថា តើគេត្រូវចំណាយប្រាក់ និងពេលវេលាយ៉ាងច្រើនដើម្បីបន្តទ្រ ទ្រង់ប្រពៃណីនិងទំនៀមទម្លាប់ទាំងនោះនៅក្នុងពិភពលោកបច្ចុប្បន្នឬ យ៉ាងណា? តើប្រពៃណីនិងទំនៀមទម្លាប់ទាំងនោះនៅតែជាការចាំបាច់មែនឬទេ? គ្មានដំបូន្មានណាគ្រាន់បើជាងដំបូន្មានដែល ព្រះពុទ្ធបានប្រទាននៅក្នុងកាឡាមសូត្រថា :

"កាលណាអ្នកដឹងក្នុងខ្លួនអ្នកថា គំនិតទាំងឡាយនេះមិនចម្រើនទេ ប្រឈមមុខនឹងការរិះគន់ត្រូវបណ្ឌិតស្តីបន្ទោស បើប្រកាន់យកហើយប្រើប្រាស់គំនិតទាំងនោះ វានឹងនាំឱ្យមានគ្រោះថ្នាក់ និងសេចក្តីទុក្ខបន្ទាប់មកអ្នកត្រូវបោះបង់ចោលគំនិតនោះទៅ..."។ កាលណា អ្នកដឹងក្នុងខ្លួនអ្នកថា "ទស្សនៈទាំងឡាយនេះជាកុសលគ្មានការស្តីបន្ទោសត្រូវបានបណ្ឌិតទាំងឡាយពោលសរសើរកាលបើប្រកាន់យកហើយអនុវត្តតាមទស្សនៈទាំងឡាយនោះវានឹងនាំឱ្យមានសុខុមាលភាព និងសេចក្តីសុខតមកអ្នកត្រូវប្រតិបត្តិតាមនិងប្រកាន់យកទស្សនៈទាំងឡាយនោះចុះ"។

មនុស្សម្នាក់ៗ គឺជាជីវិតមួយរបស់សកលលោកធាតុ។ ដរាបណា មនុស្សនៅតែជាប់ជំពាក់ជាមួយសង្គមមនុស្សហើយនិងការរៀបចំសណ្តាប់ធ្នាប់ពិភពលោកជាថ្មីឱ្យមានភាពប្រសើរឡើងពេលវេលា នឹងតភ្ជាប់ចន្លោះរវាងពួកក្មេង និងពួកមនុស្សចាស់បានជាដរាប។ សេចក្តីព្រួយបារម្ភ និងសេចក្តីភ័យខ្លាច ទៅលើទិសប្រែប្រួលនឹងកាន់តែរសាយក្រញាំរបស់វា ។ ពួកមនុស្សចាស់ត្រូវតែរំលឹកថា តើឪពុកម្តាយរបស់ពួកគាត់ផ្ទាល់បានជំទាស់ទៅនឹងបែបបទនៃ ការរស់នៅសម័យថ្មីខ្លះៗដែលគេនិយមកាលពីពេល គាត់នៅក្មេងៗយ៉ាងដូចម្តេចខ្លះ តែប៉ុណ្ណោះបានហើយ ។ សេចក្តីសន្តោសចំពោះភាពផ្សេង គ្នាស្តីពីបញ្ហាណាមួយគឺជាគុណធម៌មួយ ។ ឥរិយាបថបើកចំហរអាចជាឥរិយាបថមួយប្រកបដោយ សេចក្តីសុខ។

**សេចក្តីមេត្តា-ករុណា** : ដរាបណានៅមានមនុស្សតែម្នាក់គត់ដែលលោក-អ្នកអាចលួងលោមដោយពាក្យសម្តី ពីរោះពិសា ដែលលោក-អ្នកអាចធ្វើឱ្យជីវិតគេសប្បាយ រីករាយដោយសារវត្តមានរបស់លោកអ្នកដែលលោកអ្នកអាចជួយសង្គ្រោះដោយទ្រព្យសម្បត្តិលោកីយ៍របស់លោក-អ្នក ទោះបីជា ទាននោះតិចតួចដូចម្តេចក្តី នេះគឺជាសម្បត្តិដ៏មានតម្លៃកាត់ ថ្លៃពុំបានចំពោះពូជជាតិមនុស្ស ។ លោក-អ្នកមិនគប្បីអស់សេចក្តីក្លាហាន និងអស់សង្ឃឹមឡើយ ។

វាមានពេលខ្លះកាលណាមនុស្ស ដែលលោក-អ្នកស្រឡាញ់ហាក់ដូចជា មិនយកចិត្តទុកដាក់ ចំពោះលោក-អ្នក ហើយ លោក-អ្នកមិនស័ក្តិសមនឹងការយកចិត្តទុកដាក់នេះ ប៉ុន្តែវាមិនមែនដោយ ហេតុប៉ុណ្ណោះដើម្បីធ្វើឱ្យលោក-អ្នកធ្លាក់ទឹកចិត្តនោះទេ។ តើវាមានរឿងអ្វីគួរឱ្យអស្ចារ្យដែលលោក-អ្នកដឹងថាលោក-អ្នកមានសន្តានចិត្តពោរពេញដោយសេចក្តី មេត្តាចំពោះមនុស្ស ផងគ្នារបស់លោក-អ្នក? គេមិនបានពឹងផ្អែកលើអ្នកដទៃដើម្បីបានសេចក្តីសុខរបស់ខ្លួនគេឡើយ។ អ្នកដែលសង្ឃឹមរង់ចាំទទួលយកសេចក្តីសោមនស្សក្នុងជីវិតអំពីអ្នកដទៃគឺ អាក្រក់ក្រៃលែងជាងស្មូម ដែលលុតជង្គង់ ហើយស្រែកយំសុំអាហារប្រចាំថ្ងៃទៅទៀត។

**ការគម្រាមកំហែងនៃការប្រើគ្រឿងញៀន និងការផឹកទឹកស្រវឹង :** សុរាត្រូវបានគេពិពណ៌នាថា ជាបឋមហេតុមួយនាំដល់ការធ្លាក់ខ្លួនថោកទាបខាងរូបកាយ និងសីលធម៌របស់មនុស្ស។ បច្ចុប្បន្ននេះ មានរូបភាពនៃការបំពារបំពាន ដ៏សែនអាក្រក់មួយទៀតពោលគឺ ថ្នាំញៀនដ៏អាក្រក់ និង គ្រោះថ្នាក់ ជាពិសេសជាតិញៀនហេរ៉ូអ៊ីនបានបង្កើត ឡើងនូវបញ្ហា មនុស្ស និងសង្គមដ៏ធ្ងន់ធ្ងរយ៉ាងច្រើន ។ បញ្ហាឥឡូវនេះ កំពុងរីករាលដាលពាសពេញពិភពលោក ។ ផលវិបាកនៃការប្រើ ប្រាស់ ថ្នាំ ញៀនកាន់តែធ្ងន់ធ្ងរនិងកាន់តែបង្កគ្រោះថ្នាក់ដល់ ស្លាប់លើសជាងផលវិបាកនៃសុរាទៅទៀតអំពើលួច ប្លន់ ឧក្រិដ្ឋកម្មទាក់ទងផ្លូវភេទ និងអំពើឆបោកប្រាក់កាសច្រើនបានកើតឡើងក្រោមឥទ្ធិពលដ៏គ្រោះថ្នាក់នៃការប្រើប្រស់គ្រឿងញៀន។

មេខ្លោងគ្រឿងញៀនមិនពេញចិត្តសោះឡើយ ក្នុងឋានៈជាឈ្មួញមរណៈបានខិតខំដើម្បីត្រួតត្រារដ្ឋាភិបាលទន់ខ្សោយ តាមរយៈការប្រើអំពើពុករលួយ សំណូកវិច្ឆេតកម្ម និងការដាក់គ្រាប់បែកឱ្យផ្ទុះ។ ដោយហេតុថា វាជាបញ្ហានយោបាយសាធារណៈ មួយរដ្ឋាភិបាលបានការពារប្រជាពលរដ្ឋរបស់ខ្លួនប្រឆាំង នឹងការប្រើប្រាស់គ្រឿងញៀន ។ ប៉ុន្តែ មេខ្លោងគ្រឿងញៀននៅក្នុងគម្រោងការដ៏ ទុរយសរបស់ខ្លួនបាន គម្រាមកំហែងគ្រឹះសង្គមផ្ទាល់ គឺសេចក្តីថ្លៃថ្នូររបស់មុស្ស។ អ្នកនាំពាក្យខាង មនសិការ (មេដឹកនាំ សាសនា)និងគ្រួសារទាំងឡាយរបស់គេ

បានប្រឈមមុខនឹងគ្រោះថ្នាក់ដល់ស្លាប់ជាប្រចាំ ពីព្រោះតែគេហ៊ានឆ្លងកាត់ផ្លូវក្រៅច្បាប់របស់មេខ្លោងគ្រឿងញៀន។

បើគ្មានកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីទប់ស្កាត់អំពើទុច្ចរិតនេះទេ ជីវិតរស់រាន និងអនាគតរបស់ប្រជាជាតិ ជាច្រើន នឹងសោះកក្រោះជាប្រាកដ។ ប្រាក់ដុល្លារ រកបានដោយលំបាកច្រើន លានរាប់មិនអស់ទូទាំងពិភពលោក ត្រូវបានយកមកចំណាយដើម្បីជួយសង្គ្រោះពួកអ្នកញៀនឱ្យរួចផុត ពីទម្លាប់ដ៏យង់ឃ្នងរបស់ពួកគេ ប៉ុន្តែភាពឆ្កួតលីលានៅតែបន្តកើតមាន ។ វាជាករណីយកិច្ចរបស់យើងរាល់គ្នា ដើម្បីជួយក្នុងបែបបទណាមួយក៏ដោយឱ្យតែយើង ធ្វើបានដើម្បីលុបបំបាត់ទម្លាប់ដ៏គ្រោះថ្នាក់នេះ ហើយការពារកូនចៅរបស់យើងឱ្យចាកចេញផុតពីទម្លាប់អាក្រក់នេះ។

ជីវិតក្នុងឋានៈជាអ្នកញៀនគ្រឿងញៀនម្នាក់ ឬជាអ្នកប្រមឹកស្រាម្នាក់ គឺជាជីវិតរងទារុណកម្ម និងធ្លាក់នរក នៅលើផែនដីនេះ ដែលនាំបុគ្គលនោះទៅកាន់ទីកប់ខ្មោចទាំងនៅវ័យក្មេង។

ភាពស្រវឹងស្រា (សុរាធុត្តា) : ភាពស្រវឹងសុរា ធត់បង់វិចារណញ្ញាណ ពន្លិចសតិ (ស្មារតីចងចាំ) បង្កអន្តរាយដល់ ខួរក្បាល បន្ទោយកម្លាំង បញ្ចេះលោហិត (ឈាម) បង្កឱ្យមានរបួសខាងក្នុង និងខាងក្រៅ មិនអាចព្យាបាលបាន ។ គឺជា អាបចំពោះរូបកាយជាបិសាចចំពោះចិត្ត.ជាចោរ ចំពោះថង់ប្រាក់ ជាបណ្ដាសារបស់ស្វាម ជាសត្រូវរបស់ភរិយា ជាទុក្ខព្រួយរបស់បុត្រធីតា ជារូបភាព នៃសត្វពាឡម្រឹត និង ជាអំពើសម្លាប់ខ្លួនឯង អ្នកដែលផឹក ដើម្បីសុខភាពអ្នកដទៃ ហើយបំផ្លាញសុខភាពខ្លួនឯងផ្ទាល់ ។

ក្នុងឋានៈជាមនុស្ស យើងត្រូវចេះស្វ័យគ្រប់គ្រង ដើម្បីបែងចែករវាងអ្វីដែលល្អ និងអ្វីដែលអាក្រក់។ ចូរជ្រើសរវាងការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹង(សុរា-មេរ័យ)ហើយចូរជួយអ្នកដទៃឱ្យជ្រើសរវាងដូចគ្នា។ ការងារនោះនឹងបានជាសេវកិច្ចដ៏ធំធេងបំផុត ចំពោះមនុស្សជាតិ ។

**លោកអ្នកបង្កើតឋានសួគ៌ និងឋាននរកក្នុងលោកនេះ** : "ប្រសិនបើលោក-អ្នកចង់រស់នៅក្នុងលោកនេះ ប្រកបដោយសេចក្ដីសុខសាន្ត និងរីករាយ " ចូរអនុញ្ញាតឱ្យមនុស្សដទៃ បានរស់នៅដោយសេចក្ដីសុខសាន្ត និងរីករាយផងដែរ "ធ្វើដូច្នេះ លោក-អ្នកអាចកសាងពិភពលោករបស់លោក-អ្នកជាទីឋានមួយដែលស័ក្ដិសមនិងការរស់នៅ"។ វៀរលែងតែ និងលុះត្រា

តែ លោក-អ្នកសម្របសម្រួល ខ្លួនលោក-អ្នកឱ្យរស់នៅស្របតាមគោលការណ៍ (ឬនិយាម) ដ៏ប្រសើរទាំងនេះលោក-អ្នកមិនអាចសង្ឃឹមទទួលបានសេចក្តីសុខ និងសន្តិភាពក្នុងពិភពលោកនេះបាន។ លោក-អ្នកមិនអាចសង្ឃឹមរង់ចាំទទួលសេចក្តីសុខ និងសន្តិភាពនេះអំពីទេវលោកដោយគ្រាន់តែអង្វរករបន់ស្រន់នោះឡើយ ។

ប្រសិនបើ លោក-អ្នកប្រតិបត្តិស្របតាមគោលការណ៍សីលធម៌ ដោយការជ្រោងខ្ពស់សេចក្តីថ្លៃថ្នូររបស់មនុស្សលោក-អ្នកអាចបង្កើតឋានសួគ៌ផ្ទាល់របស់អ្នកនៅក្នុងពិភពលោកនេះផ្ទាល់តែម្តង ។ លោក-អ្នកក៏អាចបង្កើតភ្លើងនរកបានផង ដែរនៅលើផែនដីនេះផ្ទាល់ ប្រសិនបើលោក-អ្នកប្រើប្រាស់ បំពាននូវជីវភាពមនុស្សដ៏មានតម្លៃ ។ ដោយហេតុតែមិនដឹងថា ត្រូវរស់នៅយ៉ាងដូចម្តេច ទើបសមស្របទៅនឹងក្រឹត្យក្រមអវកាសសកលលោកធាតុនេះ យើងច្រើនតែមានជំហរឃ្លេងឃ្លោង ។ ប្រសិនបើមនុស្ស ម្នាក់ៗខិតខំដឹកនាំជីវិតមួយស្អាតស្អំ គ្មានទោសគួរដល់ការគោរពមនុស្ស អាចទទួលសោយបរមសុខឮដ៏ស្ថានសួគ៌យ៉ាងពិតប្រាកដ ប្រសើរជាងប្រភេទនៃសេចក្តីសុខដែលមនុស្សខ្លះសង្ឃឹមថា បានទទួលក្រោយពេលស្លាប់ទៅ ។

វាជារឿងគ្មានប្រយោជន៍ទេ ដើម្បីបង្កើតស្ថានសួគ៌នៅទីណាមួយសម្រាប់ជារង្វាន់ដល់គុណធម៌ ឬបង្កើតឋាននរកសម្រាប់ផ្តន្ទាទោសបាបធម៌។ បុណ្យនិងបាបមានប្រតិកម្មជៀស មិនផុតនៅក្នុងពិភព លោកនេះផ្ទាល់តែម្តង ដោយមិនគិតដល់ ជំនឿសាសនាណាមួយទេ ។ មេត្តាធម៌ផ្សាយទៅចំពោះសត្វទាំងអស់គឺជាមាគ៌ាតែមួយគត់ដើម្បីបង្កើតឋានសួគ៌។ យើងអាចមានឧត្តមគតិដ៏រុងរោចន៍មិនអាចលាក់ទុកបាននេះ ដើម្បីជាគុណប្រយោជន៍ដល់សង្គម និងប្រទេសជាតិដោយទម្លាយប្រាប់សេចក្តី សន្តោស និងសមានចិត្តសម្រាប់សេចក្តីចម្រើន និងសេចក្តីសុខរបស់មនុស្សដទៃ ។ យើងបានមកដល់ចំណុចនេះក្នុងឋានៈជាពូជ ជាតិមនុស្សមួយ ពីព្រោះបុគ្គលដ៏ល្បីល្បាញទាំងឡាយបានបង្ហាញប្រាប់ យើងនូវមាគ៌ាដ៏ល្អនេះ។ ដោយការជួយអ្នកដទៃតាមផ្លូវសីលធម៌លោក-អ្នកជួយខ្លួនលោកអ្នកផ្ទាល់ ហើយដោយការជួយខ្លួន លោក-អ្នកផ្ទាល់តាមផ្លូវសីលធម៌លោក-អ្នកជួយអ្នកដទៃ ។

**ជីវិតអាពាហ៍ពិពាហ៍ប្រកបដោយសុភមង្គល :** នៅក្នុងអាពាហ៍ពិពាហ៍ដ៏ស្មោះត្រង់បុរសនិងស្ត្រី រមែងគិតគូរអំពីភាពជាដៃគូច្រើនជាងពួកគេគិតគូរអំពីខ្លួនគេផ្ទាល់ ។ អាពាហ៍ពិពាហ៍គឺជា *ប៊ីស៊ីក្លែត* (កាន្ត) ធ្វើសម្រាប់មនុស្សពីរនាក់ ។ អារម្មណ៍សុខសាន្ត និងត្រេកត្រអាលចេញមកពីសេចក្តីខិតខំទៅវិញទៅមក។ សេចក្តីមិនអត់ធ្មត់និងសេចក្តីមិនយោគយល់គ្នាបង្កឱ្យមាន

បញ្ហាក្នុងគ្រួសារភាគច្រើន ។ ប្រពន្ធមិនមែនជាទាសី របស់ប្ដីនាងទេ ។ នាងស័ក្ដិសមទទួលបានសេចក្ដីគោរពស្មើគ្នា ។ ថ្វីបើប្ដីមានភារកិច្ចជាអ្នករកប្រាក់កាសចិញ្ចឹមគ្រួសារក៏ដោយការជួយធ្វើការប្រចាំថ្ងៃនៅផ្ទះមិនមែនមានន័យថា បន្ថយភាពខ្វះខាតឬភាពក្រខ្សត់នៅក្នុងផ្ទះទេ។ សេចក្ដីយល់ឃើញត្រឹមត្រូវនិងការប្រព្រឹត្ដប្រកបដោយសីលធម៌ គឺជាផ្នែកអនុវត្ដនៃបញ្ហា។

អាពាហ៍ពិពាហ៍គឺជាមង្គលមួយប៉ុន្ដែមនុស្សជាច្រើនបង្វែរឬប្រែក្លាយជីវិតអាពាហ៍ពិពាហ៍របស់គេទៅជាអពមង្គលទៅវិញ ។ ភាពក្រខ្សត់ មិនមែនជាមូលហេតុនៃជីវិតអាពាហ៍ពិពាហ៍ដ៏អពមង្គទេ។ ប្ដីនិងប្រពន្ធទាំងពីរនាក់ ត្រូវចេះចែករំលែកសេចក្ដីសប្បាយ និងទុក្ខព្រួយកើតមកពីអ្វីៗទាំងអស់នៅក្នុងជីវិតរាល់ថ្ងៃរបស់ខ្លួន ។សេចក្ដីយោគយល់ទៅវិញទៅមកគឺជាកូនសោរនៃជីវភាពគ្រួសារមានសុភមង្គល ។

**ចូរកុំព្រួយបារម្ភ:** កូនសោរសម្រាប់ការចិញ្ចឹមជីវិតប្រកបដោយជោគជ័យមានសុភមង្គលគឺត្រូវធ្វើអ្វីដែលចាំបាច់ធ្វើឥឡូវនេះ ហើយចូរកុំព្រួយបារម្ភអំពីអតីតៈ ឬអនាគត ។ យើងមិនអាចបង្កើតអតីតៈឡើងវិញទេ ទាំងមិនអាចរំពឹងទុកនូវអ្វីៗក្នុងអនាគតដែរ។ គឺវាមានតែពេលវេលាមួយគត់ដែលយើងត្រូវគ្រប់គ្រងប្រកបដោយមនសិការភ្ញាក់រលឹកនោះ គឺបច្ចុប្បន្នកាល។

មនុស្សជាច្រើនចូលចិត្ដខ្វល់ខ្វាយព្រួយបារម្ភអំពីអនាគត ។ គេត្រូវចេះសម្របសម្រួលខ្លួនទៅ នឹងកាលៈទេសៈ ។ វិមានឬប្រាសាទដែលគេអាចកសាងនៅក្នុងអាកាសជាអ្វីក៏ដោយគេអាចសុបិន ឃើញជាអ្វីក៏ដោយគេត្រូវចងចាំជានិច្ចថា គេកំពុងរស់នៅក្នុងលោកនេះ ដែលមានការប៉ះទង្គិច និងការប្រែប្រួលជាប្រចាំ។

"គ្មានហ្វូងតារាណាមួយដែលយើងអាចទុកចិត្ដបានទេគ្មានពន្លឺនាំផ្លូវណាមួយទេប៉ុន្ដែយើងដឹងថា យើងត្រូវមាន សប្បុរសធម៌ មានយុត្ដិធម៌មានទិដ្ឋិត្រូវ " ។

**សសរស្ដម្ភនៃជោគជ័យ :** បរាជ័យ គឺជាសសរស្ដម្ភនៃជោគជ័យ ។ ត្រូវរៀនពីបរាជ័យរបស់យើងដើម្បីសម្រេច បានជោគជ័យ ។ មិនដែលទទួលបរាជ័យសោះ គឺមិនដែលបានឈ្នះសោះ។ បើយើងមិនភ្លក់រស់ជាតិបរាជ័យ និងភាពជូរចត់របស់វាទេ នោះយើងមិនអាចឱ្យតម្លៃដល់រស់ជាតិផ្អែម ល្ហែមនៃជ័យជំនះបានឡើយ ជ័យជំនះប្រែក្លាយទៅជាព្រឹត្ដិការណ៍ មួយសោះកក្រោះ ដែលមានតែឈ្មោះឬគ្មានអត្ថប្រយោជន៍ ។ បរាជ័យមិនគ្រាន់តែជួយយើងឱ្យ សម្រេចជោគជ័យប៉ុណ្ណោះទេ វាថែម ទាំងផ្ដល់ ថាមពលឱ្យយើងធ្វើ ឱ្យយើងមានចិត្ដសោមនស្សហើយសម្បូរបទពិសោធន៍ ។

"យើងរស់ យើងធ្វើការហើយយើងសុបិន ម្នាក់ៗមានផែនការតូចតាចរបស់ខ្លួន ពេលខ្លះយើង សើចពេលខ្លះយើងយំ គឺដោយប្រការដូច្នេះទិវាកន្លងទៅ " ។

**សោភ័ណភាពពិត :** រូបរាងអាក្រក់ គឺមិនមែនជាពិការភាពសម្រាប់បុគ្គលមានកេរ្តិ៍ឈ្មោះដ៏សង្ហាម្នាក់ទេ។ ប្រសិនបើបុគ្គលនោះ មានរូបអាក្រក់ម្នាក់បណ្តុះបានគុណធម៌នៃមេត្តា-ករុណាមេត្តាធម៌នោះ នឹងនាំមកនូវមោត្តាអ៊ីឈ្នះយ៉ាងច្រើន គឺដូចជាដំណើរមានចិត្តសុខស្ងប់ (ឧបសមៈ) ដំណើរមានចិត្តសប្បាយផ្សាយចេញមេត្តាធម៌ទៅរកអ្នកដទៃ (បភស្សរៈ) ករុណា និងមុទិតា (មានចិត្តទន់ភ្លន់ទៅរកអ្នកដទៃ) ។ ប្រភេទទាក់ទាញចិត្តឱ្យរីករាយនោះ នឹងជួយជួសជុលលក្ខណៈខ្វះខាតនៃរូប កាយបានងាយ។ តាមការប្រៀបធៀបសុភាពបុរសម្នាក់ប្រកបដោយទឹកមុខឆ្មើងឆ្មៃ ត្រូវគេក្រឡេកមើលទៅគួរឱ្យស្អប់មិនចង់រាប់រក ។ សម្រស់ខាងក្នុងគឺជាសោភ័ណភាពពិត។ វាមានគុណភាពពិសេសអាចទាក់ទាញ និងញ៉ាំងចិត្តអ្នកដទៃឱ្យសប្បាយរីករាយ ។

**ព្រោះហេតុអ្វីមានការពិបាកដើម្បីចាកចោលលោកនេះ ? :** ចំពោះមនុស្សភាគច្រើន សេចក្តីស្លាប់ គឺជាព្រឹត្តិការណ៍មិនទទួលស្វាគមន៍មួយ។ ជាមួយនឹងចំណង់ (តណ្ហា) ចង់សប្បាយយ៉ាង ច្រើនរាប់មិនអស់ធុរកិច្ចនៃការរស់នៅ ទោះបីមានទុក្ខសោកដ៏ធំធេងក៏ដោយ ក៏ធុរកិច្ចនោះមិនដែលបានចប់សព្វគ្រប់សោះឡើយ។ មនុស្សមានអារម្មណ៍សុខស្រួល ជាមួយស្រមោលនៃសេចក្តីសុខជាជាងតថភាពនៃសេចក្តីស្លាប់។ ប្រសិនបើគេត្រូវគិតអំពីសេចក្តីស្លាប់នេះវិញនោះ វាមានចន្លោះ ពេលក្នុងម៉ោងទីដប់មួយតែប៉ុណ្ណោះ។

ដំណើរចិត្តជាប់ជំពាក់ចំពោះជីវិតក្នុងលោកិយ៍នេះ បង្កើតឱ្យមានសេចក្តីភ័យខ្លាចស្លាប់ ដ៏អាក្រក់បំផុត។ ប៉ុន្តែ សច្ចធម៌ គឺថា ជីវិតទាំងអស់គ្មានអ្វីក្រៅតែពីទុក្ខនោះទេ ។ សេចក្តីស្លាប់គឺជាដំណើរធម្មតាមិនអាចជៀសផុត។ គេភ័យអំពីសេចក្តីស្លាប់មិនបានស្មើពាក់កណ្តាលនៃគំនិតគិត អំពីស្លាប់ផ្ទាល់ផង។ ចិត្តមានសមត្ថភាពផ្ទាល់របស់ខ្លួនដើម្បីបង្កើត និងពន្លើសរូបភាពស្រមើស្រមៃនៃមរណៈ។ ហេតុផលគឺថា ចិត្តដែលមិនបានទទួលការហ្វឹកហ្វឺន ដើម្បីមើលឃើញជីវិតជាមួយនឹងអនិច្ចភាពនិងទុក្ខទោមនស្សគ្រប់យ៉ាងរបស់វាគឺទោរទន់ទៅស្រវាឱបមាយាការបីដូចមនុស្សកំពុង លង់ទឹកស្រវាតោង សូម្បីតែចម្បើងមួយទងក៏តោងដែរ ។

ចិត្តគ្មានការហ្វឹកហ្វឺននេះបង្កើតឡើងនូវភាពរសាប់រសល់ ចំពោះអ្នកទាំងឡាយដែលខិតខំ យ៉ាងប្តូរផ្តាច់បន់ស្រន់តួ អង្គអច្ឆរិយៈប្រឌិតស្ថានដើម្បីបានទទួលសេចក្តីសន្តោសប្រោសប្រណី និងបានទទួលកន្លែងមួយនៅក្នុងឋានសួគ៌កាលណាជីវិត រស់នៅហាក់ដូចជាអស់សង្ឃឹម

គ្មានទីពំនឹង ។ មែនហើយ សេចក្តីភ័យខ្លាចស្លាប់ គឺជាការស្តែងឡើងនៃសភាវៈគតិអត្តាភិរក្ស ប៉ុន្តែ គេមានមធ្យោបាយដើម្បីជំនះលើសេចក្តីភ័យខ្លាចនោះ ។ បរទត្ថភាពជម្រុះ ចោលសេចក្តីជាប់ជំពាក់ចិត្តផ្ទាល់ខ្លួនឯងទាំងអស់បាន។

ចិត្តបរិសុទ្ធសេចក្តីមិនជាប់ជំពាក់ចិត្តចំពោះវត្ថុកាម និងធានារ៉ាប់រងការចាកចេញដំណើរវិករាយអំពីពិភពលោកនេះទៅ ។ ចូរពង្រឹងចិត្តឱ្យខ្លាំងក្លាដើម្បីប្រឈមមុខនឹងរឿងពិត និងតថភាពនៃជីវិត។ចូរជៀសវាងមហិច្ឆតាមិនពិតនិងមិនអាចអនុវត្តជាក់ស្តែងបាន។ ចូរអភិវឌ្ឍន៍សេចក្តី ជឿទុកចិត្តលើខ្លួនឯងឱ្យបានធំធាត់ឡើង ។ បន្ទាប់មក លោក-អ្នកនឹងមានអារម្មណ៍កាន់តែធូរស្រាល ក្នុងការជំនះលើសេចក្តីលំបាកទាំងឡាយនៅក្នុងជីវិតរបស់ លោក-អ្នក ។

**មាគ៌ាដ៏ប្រសើរសម្រាប់ការរស់នៅ គឺមគ្គទាំង៨ ក្នុងអរិយសច្ចៈទាំង៤ :** សម្មាទិដ្ឋិ សេចក្តីយល់ដឹងច្បាស់លាស់អំពីចរិត (ឬធម្មជាតិ) នៃជីវិត និងការទទួលខុសត្រូវ ខាងផ្លូវសីលធម៌ ។ សម្មាសង្កប្បៈ ការធ្វើចិត្តឱ្យបរិសុទ្ធដោយជៀសវាង ឱ្យឆ្ងាយពីលោភៈព្យាបាទ និងហិង្សា ។ សម្មាវាចា ចូរនិយាយ តែពាក្យពិតទន់ភ្លន់ពីរោះពិសាដោយតមនិយាយ ពាក្យកុហក់និយាយ ដើមគេនិយាយពាក្យទ្រគោះបោះបោក និងនិយាយពាក្យខ្សិបខ្សៀវបំពួញមាត់បត់ដៃ។ សម្មាកម្មន្តៈអំពើ ឬការងារបរិសុទ្ធដោយគ្មាន បង្កសេចក្តីឈឺចាប់ គ្មានបង្កសេចក្តីវិនាស និងគ្មានបង្កការរំខានបៀតបៀនដល់អ្នកដទៃ។ សម្មាអាជីវៈ ការប្រកបមុខរបរគ្មានទោស ដែលមិនបង្កឱ្យមានសេចក្តីឈឺចាប់ ឬអំពើអយុត្តិធម៌ចំពោះអ្នកដទៃ ។ សម្មាវាយាមៈចូរ ប្រើវិរិយភាព (សេចក្តីព្យាយាម) ដើម្បីបញ្ចៀសគំនិតអាក្រក់ហើយបណ្តុះបណ្តាលគំនិតល្អ។ សម្មាសតិ សេចក្តីភ្ញាក់រលឹក (ឬដំណើរដឹងច្បាស់) អំពីចរិតនៃចិត្តរូបកាយនិងវេទនារម្មណ៍។ សម្មាសមាធិ ចូរតម្រង់ឆ្ពោះទៅកាន់ឯកគ្គតាចិត្តដើម្បីចាប់ យកសន្តិភាព(ឬសេចក្តីស្ងប់ចិត្ត) និងអភិសម័យ ( ការត្រាស់ដឹងឬការបានសម្រេចមគ្គផល)។

### ៣-គតិបណ្ឌិតបុរាណនិងបញ្ហាទំនើប (Ancient Wisdom and Modern Problems)

By. Francis Story

ប្រវត្តិជ័យជំនះរបស់មនុស្សចំពោះបរិស្ថាន របស់គេមានមកតាំងពីសម័យដើមមកម្ល៉េះ ដំណើររឿងប្រែប្រួលមួយ ចំពោះបំលាស់ប្តូរនានាបានខិតខំព្យាយាមយកឈ្នះ តាមរយៈការពង្រីក ចំណេះវិជ្ជាចំពោះ ភាពប៉ិនប្រសប់រស់នៅ ផ្ទាល់របស់គេ។ ជាការប្រសើរបំផុត ប៉ុន្តែជាជ័យជំនះលំអៀងមួយ ភាពខុសគ្នានៅក្នុងគំរូរស់នៅមួយមិនបានលំឱនទៅតាម ការផ្លាស់ប្តូរនៅ ក្នុងគំរូគំនិតឬ ទស្សនវិស័យដែលគេបានសង្ឃឹមទុកនោះឡើយ។ នៅក្រោមផ្ទៃមុខ (below the surface) មនុស្សបានបន្សល់ទុកនូវ សត្វសម័យដំបូងសភាវគតិ (instincts) របស់គេរក

មធ្យោបាយដោះស្រាយខ្លួនគេក្នុងគំរូអរិយធម៌ដ៏ស្មុគស្មាញមួយ ហើយចម្លើយតប របស់គេចំពោះស្ថានភាពត្រូវផ្លាស់ប្តូរយ៉ាងឆ្ងាយពីចម្លើយតបទាំងឡាយ ដែលបានប្រឈមមុខ ចំពោះបុព្វការីជនរបស់គេ។ ផ្ទុយទៅវិញសភាវគតិខ្លួនឯងទាំងនោះ ដែលមានលក្ខណៈមិនខុសគ្នានោះវានៅតែមិនផ្លាស់ប្តូរជាមូលដ្ឋាន ព្រោះពេលវេលានៃកំណត់ហេតុដំបូងបំផុតបានបាត់ពីយើងអស់។

ព្រឹត្តិការណ៍ និងស្ថានភាព កើតឡើងមកពី អត្តចរិត (character) ហើយខណៈពេលសភាវគតិ ដែលកើតឡើងចំពោះវានៅតែមិនអាចផ្លាស់ប្តូរបានស្ថានភាពនិង បញ្ហាខ្លួនវាត្រូវតែមានលក្ខណៈដូចគ្នាជាមូលដ្ឋាន បើទោះជាពួកវាលេចឡើងនៅក្នុង ទម្រង់តែងកាយខុសគ្នា ក៏ដោយ។ លទ្ធិសុទិដ្ឋិនិយម Darwinian ក្រោយ (the facile post-Darwinian optimism) (តាមរយៈការបកស្រាយទ្រឹស្តីវិវត្តន៍ខុស) ដែលជឿថា មនុស្សជាតិកំពុងតែចម្រើន ឡើងជាលំដាប់នោះត្រូវបានគេបោះបង់ចោល។ បើទោះជាវាអាចចម្រើនលូតលាស់ឆ្ងាយយ៉ាងណាក៏ ដោយក៏ចំណេះដឹងមិនអាចដោះស្រាយចិត្តមនុស្សឱ្យមានសេរីភាពបានដែរ បើទោះជាវាអាចធ្វើឱ្យគេរួចផុតពីចំណងបញ្ហាមួយចំនួន ក៏ដោយគ្រាន់តែជំនួសវាដោយរបស់ដទៃប៉ុណ្ណោះ។ អត្តទត្ថភាព (egoism) តណ្ហា និងឆន្ទៈដើម្បីរស់នៅ(the will-to-live) គឺជា កត្តាលេចធ្លោ ដែលគ្រាន់តែចំណេះដឹងប៉ុណ្ណោះ(ដោយគ្មានភាពសមរម្យនៃគតិបណ្ឌិតសង្គ្រោះ) បានបន្សល់ទុកដោយគ្មានសារៈសំខាន់។

បើក្រឡេកមើលមួយភ្លែតនៅក្នុងគម្ពីរព្រះពុទ្ធសាសនា ថេរវាទដំបូងបំផុតវាគ្រប់គ្រាន់នឹងបង្ហាញថា បញ្ហាសព្វថ្ងៃនេះវាខុសប្លែកពីបញ្ហានៅឥណ្ឌាកាលពី ២៥០០ឆ្នាំកន្លងមក។

កម្លាំងជម្រុញជីវិត (the life-impulse) និងឆន្ទៈដើម្បីរស់នៅ (the will-to-live) នៅក្នុងគ្រប់ ភាវៈទាំងអស់រលាស់ចេញផុតពី តណ្ហាព្រះពុទ្ធនៅសម័យកាលត្រាស់ដឹងរបស់ព្រះអង្គ។ ទ្រង់ត្រាស់សម្តែងថា *"វាជាការឥតប្រយោជន៍ដែលតថាគតវង្វេងវង្វាន់ចំពោះ* កំណើតជាច្រើនដើម្បីស្វែងរកអ្នកកសាងផ្ទះនេះជម្ងឺបានធ្វើឱ្យកំណើតប្រព្រឹត្តទៅដដែល *ៗ។ឥឡូវ*អ្នកកសាងផ្ទះនេះ*អ្នកបានរកឃើញហើយអ្នកនឹងមិនសង់ផ្ទះនោះទៀតឡើយ។"* ផ្ទះ (house) គឺជា ទម្រង់រូបរាង(corporeal form) ឯអ្នកកសាងផ្ទះនេះគឺជាតណ្ហាជាសភាវគតិស្អិត (the tena-cious instinct) តោងជាប់នឹងជីវិតដើម្បីមានពិសោធន៍ពីហេតុដែលបញ្ហាត្រូវប្រឈមមុខចំពោះមនុស្សលោក។ នៅពេលនេះជាសំខាន់វាដូចគ្នានឹងបញ្ហា ដែលបានមកឆាឆៅវាពីប្រវត្តិសាស្ត្រដើមដំបូងវាគ្រាន់

តែផ្លាស់ប្តូរចូលទៅក្នុងចំណុចខុសគ្នាមួយ ផ្តល់ឱ្យសាកលលោកមួយជំនួសឱ្យ ការជំពាក់ជំពិន កុលសម្ព័ន្ធ ឬលក្ខណៈកំណត់ផ្ទាល់ខ្លួនមួយ ។

នៅក្នុង ជីវិតសព្វថ្ងៃនេះសាសនាជាកត្តាសំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រពិភពលោក ដើរតួជាផ្នែកទាក់ទងមិនសំខាន់មួយ។ ឥរិយាបថរបស់ មនុស្សទំនើបពោលគឺ ចិត្តរបស់គេចង់ឱ្យទៅទាន់អ្នកដទៃនិងកិច្ចការប្រតិបត្តិនិងបន្ទាន់ជាក់ស្តែងត្រូវបានកំណត់លក្ខខណ្ឌដោយសាសនាតែចំពោះវិសាលភាពដែលការហ្វឹកហាត់ពីដើម (ដែលបានចាប់អារម្មណ៏ទៅលើមនសិការងាយៗស្រួលៗ) បានបន្សល់ទុកនៅជាប់ នឹងគេដើម្បីផាត់ពណ៌ទេសភាពខួរក្បាល (to color his mental landscape) របស់គេ។ ក្នុងចំណោមផ្នែកធំៗនៃមនុស្សពិភពលោកសាសនា ទម្រង់បានបញ្ឈប់ឱ្យមាន ឥទ្ធិពលសកម្មណាមួយហើយអំពើត្រូវបានគេ ថ្លឹងថ្លែងនិងធ្វើវិនិច្ឆ័យ មិនមែនទៅតាមគំរូសីលធម៌ឬ សាសនានោះឡើយប៉ុន្តែទៅតាម ជោគជ័យឬ បរាជ័យរបស់វាមកពី ទស្សនៈលោកិយ៍សុទ្ធសាធ។ វាបានបញ្ឈប់ឱ្យមាន"ត្រូវ"ឬ "ខុស"ហើយបានក្លាយទៅជា ការប្រតិបត្តិ ឬការមិនប្រតិបត្តិជាសាមញ្ញ។ អាចារសាស្ត្រឱកាសនិយម (opportunist ethos[2]) ត្រូវបានបង្កើតនៅក្នុងកន្លែងវិទ្យាសាស្ត្រ ខាងកាន់សាសនាតឹងរឹងពីមុន (place of the former mystique) ជាគោលការណ៏គ្រប់គ្រងមួយទៅលើ ឥរិយាបថមនុស្ស ជាលទ្ធផលឱនភាពនៅក្នុងជំនឿក្រោយពេលស្លាប់(after-life) ជាមួយនឹងដំណើរព្រមគ្នានៃយុត្តិធម៌កម្មពៀរ (concomi tant of retributive justice) ។ នៅក្នុងគំនិតមួយរឿងនេះអាចត្រូវបានគេទទួលយកជាជំហានមួយ នៅក្នុងទិសដៅនៃសនិទាននិយម(rationalism) ប៉ុន្តែព្រោះតែកត្តាជម្រុញពីក្រោយអំពើឱកាសនិយម នៅតែបន្សល់ទុក សភាវៈគតិចាស់នៃ មនុស្សសាហាវ ពោលគឺផ្នែកដែលបានសម្តែង ដោយវិចារណញ្ញាណ គឺគ្រាន់តែជាផ្នែកបន្ទាប់បន្សំប៉ុណ្ណោះ។ វិចារណញ្ញាណបានបម្រើនៅក្នុង សេវាជម្រុញដែលមានលក្ខណៈមិន សមហេតុសម ផលជាចាំបាច់។

នៅក្នុងសុទ្ធរកថាល្បីល្បាញមួយគឺ *the Brahmajala Sutta* នៃ *Digha Nikaya* ព្រះពុទ្ធទ្រង់បានរាប់ឈ្មោះពី ប្រភេទប្រព័ន្ធទស្សនវិជ្ជា religion ចំនួន ៦២ប្រភេទ ដែលមាននៅក្នុងសម័យព្រះអង្គ ដោយរៀបរៀងពី មនោនិយមអត្តិសេដ្ឋ (transcendental idealism) ទៅដល់រូបធាតុនិយម (gross materialism) ដោយទាត់ចោលវាទាំងអស់។ ស្មារតីឥណ្ឌាប្រថុយប្រថានមានសមត្ថភាពចំពោះភាពល្អិតល្អន់ខាង អស្ថិរូបវិជ្ជាដែលគេមិនបានដឹងនៅ អឺរ៉ុប ចាប់

[2] ផ្លូវចិត្តជាលក្ខណៈ, តម្លៃសីលធម៌, គំនិត ឬជំនឿរបស់ក្រុមមួយ ឬសហគមន៍មួយ ឬវប្បធម៌មួយ

តាំងពីថ្ងៃ Mediaeval Schoolmen និង ទ្រឹស្តីព្រហ្មញ្ញបុរាណ ជាច្រើនទាំងនេះបាន អន្តរធាន បាត់ពីពិភពលោក នៅសល់តែ ឈ្មោះ ប៉ុន្តែលក្ខណៈដ៏គួរឱ្យកត់សម្គាល់ និងផ្ទុយគ្នានៃ លទ្ធិត្រូវ បានគេរកឃើញមាននៅជាមួយយើងនៅឡើយ លទ្ធិមួយចំនួនដែលបន្លំជា ការអភិវឌ្ឍន៍ចុង ក្រោយបំផុតនៃ គំនិតមនុស្ស។ នៅក្នុងសុត្តរកថាមួយទៀតគឺ the *Apannaka Sutta* នៃ *Majjhima Nikaya* ព្រះពុទ្ធទ្រង់បានភ្ជាប់ជាមួយគ្នាដោយពាក្យ'ism(និយម)' ទៅលើពាក្យ ដូចតទៅៈ"មានតាបសនិងពួកព្រាហ្មណ៍ដែលបានអះអាងថាគ្មានអ្វីឱ្យគ្មានអ្វីបូជាថ្វាយនោះឡើយ គ្មានផល នៃអំពើល្អ ឬ អាក្រក់ណាដែលនៅរហូតដល់ចាស់នោះទេ, លោកនេះ ក៏គ្មានលោក ខាងមុខក៏គ្មាន,ម្តាយក៏គ្មាន ឪក៏គ្មាន ភាវៈកើតឡើងក៏គ្មាន នៅក្នុងលោកនេះ គ្មានទាំងតាបស និង ពួកព្រាហ្មណ៍ដែលបានធ្វើដំណើរ ឬដើរតាម ផ្លូវត្រូវ ហើយនិងអ្នកដែល យល់ច្បាស់ពី លោកនេះដោយ ពុទ្ធិជ្រៅជ្រះហើយនិងប្រកាសពីវានោះទេ។

នៅក្នុងករណីនេះ អ្នកផ្ទះសម្បែង (ដែលគេសង្ឃឹមថាតាបសនិងពួកព្រាហ្មណ៍ ទាំងនោះ ដែលជឿ និងអះអាងថា គ្មាន ផល នៃ អំពើល្អ ឬ អាក្រក់ណាដែលនៅរហូតដល់ចាស់នោះទេ ហើយនិងថាគ្មានលោកខាងមុខ...នោះនឹង បោះបង់ចោល វត្ថុល្អៗបី តិរិយាបថល្អនៅក្នុង អំពើ សម្តីនិង គំនិតហើយនឹងឱបយក និងអនុវត្ត អំពើអាក្រក់ៗ បីតិរិយាបថអាក្រក់ៗនៅក្នុង អំពើ សម្តីនិង គំនិត។ បើបែបនេះតើនោះព្រោះហេតុអ្វី? ព្រោះពួកគេមើលមិនឃើញ ពី គ្រោះថ្នាក់ និង ភាពល្ងីល្ងើនិងភាពខូចនៃវត្ថុមិនល្អឬបរមសុខនៃ ការលះបង់ចោលនិងភាពបរិសុទ្ធនៃវត្ថុ ល្អៗ។ តាមពិតបើទោះជាមាន លោកខាងមុខមែន ទស្សនៈពួកគេដែលថា មិនមានហើយនោះ គឺជា ទស្សនខុសមួយ។ តាមពិតបើទោះជាមាន ជាតិក្រោយ ក៏ដោយក៏ពួកគេសម្រេចចិត្តថា គ្មានទេ ហើយនោះជា ការដោះស្រាយខុស។ តាមពិតប្រសិនបើមាន ជាតិក្រោយ មែនពួក គេអះអាងថា មិនមានទេហើយនោះគឺជាសម្តីខុស។ តាមពិត ប្រសិនបើមាន ជាតិក្រោយ មែន ពួកគេនិយាយ ថាមិនមានទេ ហើយអំពើផ្ទុយដោយផ្ទាល់ចំពោះ ព្រះអរហត្តដែល មានពុទ្ធិ មួយអំពីជាតិក្រោយនោះ។ តាមពិតប្រសិនបើមាន ជាតិក្រោយមែនពួកគេបង្រៀន អ្នក ដទៃថាមិនមានទេ ហើយនេះគឺជាការបង្រៀនពីលទ្ធិខុសមួយ។ ដោយមានការបង្រៀនពីលទ្ធិ ខុសមួយនេះពួកគេបាន លើកសរសើរខ្លួនគេ ហើយបន្ទុចអ្នកដទៃ។ ដូច្នេះ គុណធម៌អតីតៈ របស់ពួកគេត្រូវបំផ្លាញចោល ហើយ ធម្មចរិយាធម៌ ផ្សព្វផ្សាយ ហើយនៅទីនោះបានឱ្យផលជា ទស្សនៈខុស ដំណោះស្រាយ ខុសសម្តីខុសនេះ ការបង្រៀន ពី លទ្ធិខុសនេះវាប្រឆាំងចំពោះ

លទ្ធិប្រសើរៗនានាពោលគឺ ការលើកសរសើរខ្លួនឯងនេះ ហើយបង្អួច អ្នកដទៃ នេះឯង។ បើទោះជាបែបនេះក៏ដោយ ក៏វត្ថុអាក្រក់ៗជាច្រើនទាំងនេះបានកើតឡើងនៅក្រោមកាលៈទេសៈទស្សនៈខុសរបស់ពួកគេដែរ។

"នៅក្នុងករណីនេះ អ្នកផ្ទះក្នុងនាមជា អ្នកមានបញ្ញាម្នាក់បានឆ្លុះបញ្ចាំងដូច្នេះថា : ប្រសិន បើគ្មានជាតិក្រោយ ទៀតទេ នៅពេលនោះបុគ្គលនេះដែលមាន ដំណោះស្រាយរាងកាយខុសនឹង សុខសុវត្ថិភាព (safety) [ដោយការ បំផ្លាញទាំងស្រុង (annihilation)] ប៉ុន្តែ ប្រសិនបើមាន ជាតិក្រោយមែន បុគ្គលនេះដែលមាន ដំណោះស្រាយរាងកាយខុសនោះបន្ទាប់ ពី ស្លាប់ទៅ នឹង មាន កំណើតឡើងវិញនៅក្នុង សភាពមិនសប្បាយនៃទុក្ខ។ ប្រសិនបើអ្នក ពេញចិត្ត ឧបមាថា គ្មានជាតិក្រោយ ឬឧបមាថា សម្តីរបស់តាបសនិងព្រាហ្មណ៍ ទាំងនេះជា សម្តីត្រឹមត្រូវ។ ផ្ទុយទៅវិញ បុគ្គលនេះត្រូវស្តីបន្ទោសដោយបញ្ញា សូម្បីតែនៅក្នុងជាតិនេះ ព្រោះតែទស្សនៈខុសនិងព្រោះតែជាឧច្ឆេទទិដ្ឋិជន(nihilist[3]) ។ ប៉ុន្តែប្រសិនបើមានជាតិក្រោយមែនបុគ្គលនេះមានការសម្តែងតួអភ័ព្វនៅក្នុងករណីទាំងពីរនេះពោលគឺគេត្រូវស្តីបន្ទោសដោយបញ្ញា សូម្បីតែនៅក្នុង ជាតិនេះព្រោះតែជឿលើ ទស្សនៈខុសហើយនិងដោយមាន ដំណោះស្រាយរាងកាយខុស ក្រោយពេលស្លាប់ គេនឹងចាប់ជាតិទៀតនៅក្នុងសភាពមិនសប្បាយ។ ដូច្នេះលទ្ធិពិសេសនេះត្រូវ គេទទួលយកដោយអាក្រក់គេត្រូវតស៊ូជំនះដោយលំអៀង ហើយគេបានបោះបង់ជំហរសមរម្យចោល។"

"នៅក្នុងករណីនេះវាត្រូវបានគេសង្ឃឹមថា តាបសនិង ព្រាហ្មណ៍ទាំងនេះដែលជឿ និងអះអាងថាមាន អំពើល្អ និង អាក្រក់ដែលបន្សល់ទុក ដែលមាន ជាតិក្រោយទៀត នឹងត្រូវបោះបង់ចោលវត្ថុអាក្រក់បីឥរិយាបថអាក្រក់ នៅក្នុង អំពើសម្តី និង គំនិតហើយនឹងក្រសោប យកនិងអនុវត្ត វត្ថុល្អៗបីឥរិយាបថល្អនៅក្នុង អំពើសម្តីនិងគំនិត។ តើនេះមកពីមូលហេតុអ្វី? ព្រោះពួកគេមើលឃើញពី គ្រោះថ្នាក់និង ភាពឆ្គួតៗនិង ភាពខូចនៃ វត្ថុអាក្រក់ ហើយនិង ការព្រមលះបង់ចោល (blessing of renunciation) ហើយនិង ភាពបរិសុទ្ធនៃវត្ថុល្អៗ។ ដូច្នេះបាបធម៌អតីត (former vice) របស់ពួកគេត្រូវបានបំផ្លាញចោលហើយ គុណធម៌ ត្រូវបានបង្កើត ឡើង

---

[3] (១)-ការច្រានចោលជារួមនៃគោលការណ៍សាសនា និងសីលធម៌ដែលជាមូលដ្ឋានមួយសម្រាប់ឥរិយាបថ (២)- ជំនឿថាគ្មានអ្វីអត្ថិភាព ពិតប្រាកដ

ហើយនៅទីនោះឱ្យផល ជាទស្សនៈត្រឹមត្រូវដំណោះស្រាយត្រឹមត្រូវ និងសម្តីត្រឹមត្រូវការបង្រៀន នេះនៅក្នុងលទ្ធិត្រឹមត្រូវមួយមិនប្រឆាំងចំពោះអរិយលទ្ធិនោះទេ ពោលគឺ ការជៀសវាងពីការ លើកខ្លួនឯងហើយបង្អាប់ អ្នកដទៃ។ បើដូច្នេះមែន វត្ថុល្អៗជាច្រើនទាំងនេះបានកើតឡើងនៅលើទិដ្ឋភាពនៃទស្សនៈត្រឹមត្រូវ" ការសម្តែងធម្មទេសនាទៅលើលទ្ធិកម្មច្បាប់ប្រព្រឹត្តនិងប្រតិកម្មខាងវិទ្យាសាស្ត្រចំពោះអ្នកសិក្សាព្រហ្មញ្ញដូចជា សុបហាជាដើមព្រះពុទ្ធទ្រង់បង្រៀនស្តីពីបញ្ហាដែលលេចធ្លោនៅក្នុង គំនិតសម័យសព្វថ្ងៃនេះនោះគឺបញ្ហា វិសមភាពរបស់មនុស្ស។

ការបង្ហាញពី វិសមភាពនេះក្នុងចំណោមភាវៈនានា ជានិច្ចកាលតែងតែជាលក្ខណៈ ជីវិតរបស់មនុស្សដោយហេតុថា ព្រះពុទ្ធសាសនាពន្យល់ពី រូបរាងអយុត្តិធម៌ (the seeming injustice) ដែលមនុស្សគឺជាប្រធានបទមកពីកំណើត។ លទ្ធិ អំពីកម្មសម្តែងពីជីវិតនិងពិភពលោកនៅក្នុងពន្លឺនៃ ច្បាប់តក្កវិជ្ជា និងមិនលំអៀងពោលគឺជា ច្បាប់មួយដែលមានលក្ខណៈ ល្អិតល្អន់ដោយអនុលោមទៅតាមគោលការណ៍វិទ្យាសាស្ត្រអំពីហេតុ និងផល។

ពេលព្រះពុទ្ធទ្រង់សួរ ចំពោះសុខុមាលភាពរបស់ប្រជាជាតិ និងសហគមន៍នានាដោយមាន ការកត់សម្គាល់ពិសេសចំពោះ the Vajjians ជាបក្សសម្ព័ន្ធមួយដែលបានឈ្លានពានដោយបក្សសម្ព័ន្ធជិតខាងព្រះអង្គទ្រង់ត្រាស់ថា "ជាយូរយារមកហើយម្នាលអានន្ទដែល the Vajjians នឹងប្រជុំដដែលៗហើយនៅក្នុងចំនួនដ៏ច្រើន(ចំពោះសាមគ្គីភាព) គ្រាន់តែអស់រយៈពេលយូរអាចវិបុលភាពនៃ the Vajjians ត្រូវបានគេសង្ឃឹមរង់ចាំ មិនមែនការវិនាសហិន ហោចរបស់គេទេ។ យូរណាស់ម្នាលអានន្ទដែល the Vajjians ប្រជុំបានចុះសម្រុងគ្នាហើយនិងមិនចុះសម្រុងគ្នា ដរាបណាពួក គេធ្វើពាណិជ្ជកម្មរបស់គេដោយស្រុះស្រួលគ្នា ដរាបណាពួកគេមិនផ្សព្វផ្សាយពី បទបញ្ញត្តិបដិវត្តន៍ (revolutionary ordinance) ណាមួយឬក៏រំលាយចោល បទបញ្ញត្តិដែលបានបង្កើតឡើងណាមួយ ប៉ុន្តែត្រូវរង់ចាំដោយច្បាប់ the Vajjians សម័យ ចាស់ដូចដែលគេបានអនុម័តរួចហើយដរាបណាពួកគេមានកិត្តិយស គោរពបូជាលើក សរសើរនិងគោរពចំពោះមនុស្សមុនៗក្នុងចំណោម the Vajjians ហើយចាត់ទុកពួកគេថាមាន តម្លៃចំពោះការស្តាប់ដរាបណាស្ត្រីៗ និងស្ត្រីក្រមុំនៃគ្រួសាររស់នៅដោយគ្មានការបង្ខិតបង្ខំ ឬចាប់ពង្រាត់ ដរាបណាមានកិត្តិយសគោរពបូជាលើកសសើរ និងធ្វើសក្ការៈចំពោះទីសក្ការៈបូជា the Vajjians ទាំងខាងក្នុង និងខាងក្រៅដរាបណាពួកគេមិនអនុញ្ញាតដល់តង្វាយប្រពៃណីគេឱ្យនិងគេសម្តែងមិនត្រូវបានគេយកចិត្តទុកដាក់ដរាបណាការឃ្លាំមើលនិងឥការការពារប្រពៃណីលើព្រះអរហត្ត

ដែលនៅក្នុងចំណោមពួកគេត្រូវបានគេរក្សាទុកបានយ៉ាងល្អ ដើម្បីឱ្យ ពួកគេអាចមានច្រកចូលសេរីទៅដល់អាណាចក្រ (the realm) ហើយនិងការចូលទៅ អាចអាស្រ័យនៅដោយរីករាយនៅក្នុងនោះបាន គ្រាន់តែដរាបណាពួកគេពិនិត្យសង្កេតទៅលើ គោលការណ៍ទាំងនេះ ព្រះអនន្ត សូមឱ្យ វិបុលភាពនៃ the Vajjians ត្រូវគេសង្ឃឹមបាន ហើយមិន មែនជាការស្អុយរលួយរបស់ពួកគេទេ។"

បដិវត្តដែលជាការបង្រៀនរបស់ ព្រះពុទ្ធនៅក្នុងគំនិតដាក់ជំនួស ការគ្រប់គ្រងសីលធម៌ និង ការរៀបចំគោលការណ៍ចរិយាមារយាទ នៅតាមកន្លែង វិតិនិយមដែលបានរៀបចំជាផ្លូវការនៃ សហការលិកព្រហ្មញ្ញរបស់ព្រះអង្គគឺ លក្ខណៈមួយដែលមានរូបរាងឡើងយ៉ាងច្បាស់ និងពាស ពេញទាំងសុន្ទរកថារបស់ព្រះអង្គ វាជាការពិតថានៅក្នុងបញ្ហា លោកិយ៍ (temporal matters) ព្រះអង្គបានជួយគាំទ្រដល់ការអភិរក្សប្រពៃណីទាំងអស់ដែលពេលវេលាបានបង្ហាញឱ្យឃើញ មានគុណប្រយោជន៍ ហើយនិងហាមឃាត់តែប្រពៃណីណា ដែលមានលក្ខណៈអន់ថយដោយ សង្គមប៉ុណ្ណោះដូចជាវណ្ណៈ ឬ ភាពស្រពេចស្រពិលខាង ផ្លូវចិត្តដូចជានៅក្នុង ការបញ្ជាក់ដោយភិក្ខុសង្ឃទៅលើ ពិធីបូជាយញ្ញនិងតាបសនិយមហួសហេតុ ដែលនៅក្នុងព្រះពុទ្ធសាសនាត្រូវបាន គេចាត់ទុកជាទុយ្យសដា "អបិយជំនឿ (supersti-tion)"។ នៅក្នុងបញ្ហា វណ្ណៈ ដូចយើងបានដឹងមកហើយថាព្រះពុទ្ធទ្រង់បានទទួលស្គាល់ពីភាពខុសគ្នាដែលជាការមិនអាចបំបែកគ្នាបានពី ការសម្រេចបាននៃកម្ម (working out of *Kamma*) អ្វីដែលព្រះអង្គបដិសេធជាដាច់ខាតនោះគឺ ការបង្រៀនព្រហ្មញ្ញដែលថា វណ្ណៈមានប្រភពមកពី អាទិទេពហើយ និងបញ្ញត្តិវិញ្ញាណ (the animistic con-cept)ដែល វណ្ណៈធំៗបួនរបស់សង្គមឥណ្ឌា បានទទួលយកប្រភពកំណើតរបស់ពួកគេមកពី ផ្នែកខុស១គ្នា នៃរាងកាយព្រហ្ម។ នេះគឺជាដំណើររៀបចំដោយជាក់លាក់នៅ ក្នុងកំណាព្យ Dhammapada ទាំងនោះដែលអះអាងថា ព្រាហ្មណ៍គឺជាព្រាហ្មណ៍ម្នាក់ មិនមែនដោយកំណើតនោះទេ ប៉ុន្តែដោយភាពបរិសុទ្ធនៃ គំនិតសម្តីនិងអំពើ។ "មិនដោយសក់កណ្តាញ់ ឬដោយកំណើតដែលគេក្លាយទៅជា ព្រាហ្មណ៍ម្នាក់នោះឡើយ។ ប៉ុន្តែនៅក្នុងព្រាហ្មណ៍ នោះទាំងសច្ចភាពនិង ព្រះធម៌ មានអត្ថិភាពនៅក្នុងនោះ គេគឺជាអ្នកបរិសុទ្ធមួយរូបហើយគេគឺជាព្រាហ្មណ៍។" វាមានតម្លៃគួរឱ្យកត់ចំណាំថា នៅក្នុងចំណងទាក់ទងជាមួយបញ្ហាមកពីជ្រុងសង្គមសុទ្ធសាធ ព្រះពុទ្ធទ្រង់ដាក់ វណ្ណៈខាតិយៈ (the Khattiya caste) ជាវណ្ណៈក្សត្រឬ វណ្ណៈអភិជន (nobility)ជាវណ្ណៈខ្ពស់ជាងគេបំផុត។ ការខុសប្លែកគ្នាត្រូវ ទទួល

បាននៅលើកម្រិតលោកិយ ប៉ុន្តែចំពោះអ្នកណាដែលបានបដិសេធចោល ពិភពលោកគ្មានការខុសប្លែកគ្នាទេតម្លៃនៃមនុស្សពិសិដ្ឋត្រូវបានវាស់វែងដោយ គុណធម៌របស់គេតែឯងគត់។

គោលការណ៍នេះមានការប្រតិបត្តិកាន់តែទូលំទូលាយ នៅក្នុងដែនបញ្ហាជាតិនិយម និងពូជសាសន៍សម័យសព្វថ្ងៃនេះ។ នៅក្នុងព្រះពុទ្ធសាសនា គ្មានមូលដ្ឋានសម្រាប់ឧត្តមភាព ពូជសាសន៍ពោលគឺ ការគោរពសាសនា និងបដិបក្ខនិយម (antagonism)។ មនុស្សម្នាក់ៗមានតម្លៃផ្ទាល់ខ្លួនរបស់គេ ពោលគឺការមិនប្រកាន់សាវតារវប្បធម៌ ឬ ពូជសាសន៍។

បញ្ហាសិទ្ធិមនុស្សរវល់ដោះស្រាយមិនចេញជាមួយនឹងបញ្ហាទំនួលខុសត្រូវបុគ្គល។ នៅក្នុងអាជីពមុនបច្ចុប្បន្ន (the present pre-occupation) ជាមួយនឹងសិទ្ធិរបស់សហគមន៍ និងបុគ្គលមានទំនោរយកឈ្នះមួយដើម្បី មើលឱ្យឃើញការពិតថា គំនិតអំពី សិទ្ធិក៏បញ្ជាក់បានពីគំនិតកាតព្វកិច្ច និងករណីយកិច្ចផងដែរ។ ស្របពេលជាមួយគ្នានេះដែរ ព្រះពុទ្ធទ្រង់សម្តែងធម្មទេសនានៅក្នុងប្រទេស ឥណ្ឌា ខុងជឺ នៅក្នុងប្រទេស ចិនកំពុងតែផ្សព្វផ្សាយ ពី សច្ចធម៌នេះនៅក្នុង លទ្ធិមនុស្សនិយមសនិទានកម្ម (rationalistic humanism) ផ្ទាល់របស់លោក។ នៅ ពេលខុងជឺ ផ្តល់ចំណុចសំខាន់ពីគំនិតរបស់គាត់អំពី អ្នកដឹកនាំល្អវិសេស ស្លូតបូតត្រឹមត្រូវយកចិត្តទុកដាក់ជាដរាបចំពោះ សុខុមាលភាពប្រជាជនរបស់ខ្លួន ព្រះពុទ្ធប្តូរ គំនិតសាវ័ករបស់ទ្រង់ ចេញពីគំនិតចាស់ ដែលករណីយកិច្ច ត្រូវបានបង្គាប់ដោយ សាសនានោះគឺជាការសម្តែងវិធីនិយម (ritualistic performances) ចំពោះឧត្តមគតិដ៏ខ្ពស់ នៃករណីយកិច្ចរបស់ឧបាសកគឺទំនួលខុសត្រូវរបស់គេចំពោះអ្នកដទៃ។

នៅក្នុង *the Sigalovada Sutta* ព្រះអង្គទ្រង់បានសម្តែងធម្មទេសនាដល់ ព្រាហ្មណ៍ក្មេងម្នាក់ដែលកំពុងគោរព តាម ដំបូន្មានឪពុករបស់វាឱ្យគោរព ទិសទាំង៦មាន ជើង, ត្បូង, កើត លិច ខាងលើ (zenith)និងទិស ខាង ក្រោម(the nadir)ដោយមាន សំលៀកបំពាក់ និងសក់សើម ហើយនិង ដៃក្តាប់ណែន លើកឡើងទៅលើ។ "ប៉ុន្តែ នៅក្នុង សាសនារបស់ពួកអារ្យៈ(អ្នកផ្ទះក្មេងៗ) វាមិនមែនដូច្នេះថា ទិសទាំង៦គួរគេត្រូវគោរពបូជានោះទេ"។ ដូច្នេះព្រះពុទ្ធបានចាប់ផ្តើមការបង្រៀនរបស់ព្រះអង្គ ហើយបន្តពន្យល់ថា ការគោរពបូជាចំពោះ ទិសទាំង៦ (the six quar-ters) គឺគេត្រូវយល់ដឹងនៅក្នុង ស្មារតីសីលធម៌។ គំនិតដំបូងមានការពិពណ៌នាទូទៅមួយក្រោមក្បាលចំនួន (num-erical heads)ពោលគឺ ចំពោះវត្ថុដែលត្រូវជៀសវាង ដោយអ្នកផ្ទះ ដែលជាការដឹកនាំទៅរកការបំផ្លាញ, អាប់ឈ្មោះ ហើយនិង គុណធម៌

ដែលគេត្រូវ អប់រំដែលជាការនាំទៅរក សុភមង្គលនិង វិបុលភាព។ ធម្មទេសនានៅពេលនោះ បានបន្តទៅ ទៀតថា : "អ្នកផ្ទះក្មេងៗតើ សាវ័កអារ្យ៉័នផ្តល់កិត្តិយស និងការពារ ទិសទាំង៦ ដូចម្តេច ? ចំណុច ជាបន្តបន្ទាប់ទៅនេះគួរគេរកមើលជា ទិសទាំង៦ពោលគឺ ឪពុកម្តាយជា ទិសខាងកើត (the East) គ្រូបាធ្យាយជា ទិសខាងត្បូង (the South) ភរិយានិងកូនៗជាទិសខាងលិច(the West) មិត្តនិង គូកនជា ទិសខាងជើង (the North), អ្នកបំរើនិងមនុស្សធ្វើការងារ (work-people) ជា ទិសខាងក្រោម(the nadir) គ្រូប្រដៅសាសនា និង អរិយបុគ្គល(holy men)ជាទិសខាងលើ(the zenith)"។ករណីយនេះត្រូវបានគោរពតាមដោយការពន្យល់លំអិតមួយចំពោះករណីយកិច្ចរបស់មនុស្សប្រុស ចំពោះវណ្ណៈនីមួយៗរបស់មនុស្សទាំងនេះដែលពួកគេឈរនៅក្នុងទំនាក់ទំនងចំពោះខ្លួនគេទាំងអស់គ្នាបង្កើតជាសុន្ទរកថា មួយស្តីពីសីលធម៌សង្គមដែលមិនប្រជែងគ្នាចំពោះវិសាលភាព(breadth)និង ភាពប្រសើរខ្ពង់ខ្ពស់នៃគំនិតដូចគ្នាចំពោះភាពអាចអនុវត្តបានរបស់វា។ ឧទាហរណ៍ពីរនឹងគ្រប់ គ្រាន់ដើម្បីបង្ហាញថាតើ គំនិតអំពីការមានទៅវិញទៅមក (reciprocity)នៅក្នុង ករណីយកិច្ចត្រូវបានបញ្ជាក់យ៉ាងដូចម្តេច។

*"នៅក្នុង វិធី៥ដែលគួរតែ អ្នកបក្ខសម្ព័ន្ធម្នាក់ជួយផ្គត់ផ្គង់ មិត្តនិង គូកនរបស់គេជា ទិសខាងជើង ដោយ សទ្ធាទាន ការឱនលំទោន និង មេត្តា ដោយប្រព្រឹត្តចំពោះពួកគេដូចដែលគេប្រព្រឹត្តចំពោះខ្លួនគេដែរ និងដោយភាព ត្រឹមត្រូវចំពោះ សម្តីរបស់គេ។ ដូច្នេះនៅក្នុង វិធីទាំង៥នេះបានបម្រើជា ទិសខាងជើង មិត្ត និង គូកនរបស់គេស្រឡាញ់គេ ពួកគេការពារគេពេលគេនៅឆ្ងាយពីអ្នកការពាររបស់គេ ហើយនៅក្នុងឱកាសបែបនេះការពារ ទ្រព្យសម្បត្តិ របស់គេ ពួកគេក្លាយទៅជាជម្រកមួយការពារពីគ្រោះថ្នាក់ ពួកគេមិនបោះបង់គេចោលពេលគេមានបញ្ហាឡើយ ហើយពួកគេសម្តែងបង្ហាញពីការខ្វល់ខ្វាយចំពោះគ្រួសាររបស់គេ។ ដូច្នេះនេះគឺជាទិសខាងជើងដោយខ្លួនគេបានការពារ និង បង្កើតសុវត្ថិភាព និងមានសន្តិសុខ។"*

*"នៅក្នុង វិធីទាំង៥ អារ្យ៉័នម្នាក់ផ្គត់ផ្គង់ សេនា និង អ្នកបម្រើការងារជា ទិសខាងក្រោម : ដោយការចាត់ ចែងពួកគេធ្វើការដោយអនុលោមទៅតាម ភាពរឹងមាំរបស់ពួកគេ ដោយការផ្តល់ ចំណីអាហារ និង ប្រាក់ខែ ដល់ពួក គេ ដោយការមើលថែទាំ ជម្ងឺដល់ពួកគេ ដោយការចែក រំលែកជាមួយពួកគេនូវ ទេពកោសល្យមិនធម្មតា*(unusual delicacies) និងដោយការផ្តល់ដល់ពួកគេនូវ*ពេលសម្រាកសមស្រប។ នៅក្នុងវិធីទាំងនេះបានគ្រប់គ្រងដោយ ចៅហ្វាយរបស់គេ សេនានិង អ្នកធ្វើការងារស្រឡាញ់ ចៅហ្វាយរបស់ពួកគេទៅតាម វិធី៥យ៉ាង: ពួកគេ*

*ក្រោកមុន គាត់ហើយចូលទៅសម្រាកក្រោយគាត់ ពួកគេពេញចិត្តជាមួយនឹងអ្វីដែលគេឱ្យពួកគេពួកគេ ធ្វើកិច្ចការរបស់គេដោយផ្ចិតផ្ចង់ ហើយពួកគេអួតសរសើរពីចៅហ្វាយ និងកិត្តិយសរបស់ ចៅហ្វាយខ្លួនយ៉ាងល្បីខ្ចរខ្ចារ ។ ដូច្នេះនេះគឺជា ទិសខាងក្រោមដោយខ្លួនគេបានការពារ និងបង្កើត សុវត្ថិភាព និងមានសន្តិសុខ ។"*

ការប្រព្រឹត្តសាច់រឿងរបស់ ព្រះពុទ្ធមានលក្ខណៈជាវិធីតួយ៉ាងដែលនៅក្នុងនោះព្រះអង្គធ្លាប់បានទទួលយក ជំនឿសាសនាដែលមានអត្ថិភាពរួចមកហើយ ហើយបានផ្តល់ដល់វានូវ ខ្លឹមសារសីលធម៌ឬ ផ្លូវចិត្តកាន់តែខ្ពស់ថែមទៀត ព្រះអង្គបានដឹកនាំឆ្លងទៅរក សច្ចភាពកាន់តែខ្ពស់ ឡើងៗផ្ទាល់របស់ព្រះអង្គតាមរយៈ មធ្យោបាយផ្សព្វផ្សាយប្រពៃណីថ្មីៗ (the medium of a current tradition) ។ គេត្រូវតែចងចាំថាព្រះពុទ្ធមិនបានបង្រៀន ព្រះធម៌ថ្មីទេ ព្រះ អង្គសម្តែងធម្មទេសនាពី "សច្ចភាពបុរាណ"នៃ ព្រះពុទ្ធ (the Buddhas) មុនៗព្រះអង្គ។ បើទោះជាការបង្រៀនរបស់ព្រះពុទ្ធទាំងនោះបានកន្លងហួសទៅហើយដោយសារតែ លំនឹកគិតរបស់មនុស្សក៏ដោយឬក៏មានអត្ថិភាពតែនៅក្នុងទម្រង់ គោរពតាមខាងក្រៅដែលសេចក្តីសំខាន់ ខាងក្នុងរបស់វាត្រូវបាត់បង់អស់វានៅតែគង់ជាដរាបហើយនិងរក្សាទុក ព្រះធម៌មិនប្រែប្រួលសកលពោលគឺគោលការណ៍មូលដ្ឋាន អំពី ហេតុនិង ផលដែលគ្រប់គ្រងលើ អត្ថិភាពបាតុភូត (phenomenal existence) ។ ចំពោះ ព្រះពុទ្ធគេអាចនិយាយបានដោយត្រឹមត្រូវថា ព្រះអង្គយាងមក នេះគឺដើម្បីបំពេញវា ដើម្បីសម្តែងវាឡើងវិញនៅក្នុង ខ្លឹមសារផ្លូវចិត្តដ៏ខ្ពស់បំផុតរបស់វា ។

ឥឡូវនេះយើងឈរនៅត្រង់ចំណុចត្រឡប់មួយនៅក្នុងប្រវត្តិសាស្ត្រជម្រើសគឺជាជម្រើសរបស់យើងថាតើយើងនឹង ទទួលយកវិថីដែលដឹកនាំទៅរក ការរីកចម្រើនបន្ថែមទៀត ឬក៏វិថីដែលនឹងដឹកនាំយើងទៅកាន់វិនាសកម្ម ។ មនុស្សជាតិមាន បទពិសោធន៍គ្រប់គ្រាន់ យ៉ាងហោចណាស់ក៏សម្តែងបង្ហាញថា ពុទ្ធិវិទ្យាសាស្ត្រនិង ចំណេះ(mast-ery) អំពី ពិភពរូបធាតុមិនមែនជា វត្ថុតែមួយដូចគ្នានឹងការរីកចម្រើននៅក្នុង អរិយធម៌នោះឡើយ ។ ចក្ខុរបស់យើង ត្រូវតែត្រឡប់ ទៅក្នុងទិសថ្មីមួយប្រសិនបើយើងរកឃើញមធ្យោបាយមួយ ដោយសារតែស្ថានភាពទាល់ច្រកនោះ ។ ប៉ុន្តែដរាបណាយើងត្រូវកំណត់ដោយ លំហ-កាលបត់បែននៃ រូបវិទ្យា ដូច្នេះយើងត្រូវបានឡោមព័ទ្ធដោយដែននៃគំនិតទាក់ទងនានា ។ ដែនដែលថ្មីបំផុតនោះគឺជាដែនមានលក្ខណៈចាស់មិនអាចវាស់បានឡើយព្រះធម៌គ្មានទីបំផុតពោលគឺសច្ចភាពអមតៈ(the ageless truth) នៅហួសពី ពិភពកង្វល់រូបធាតុតូចរបស់យើង ។ វាជាការពិតថា យើងត្រូវតែត្រឡប់

(នៅក្នុងសេចក្ដីលំឱនទនិងសេចក្ដីសង្ឃឹម)ចំពោះជម្ងឺចាស់ដែលយើងត្រូវតែស្រាវជ្រាវរក ឱសថចាស់ៗ។ ប៉ុន្តែ នៅក្នុងដែននៃ សច្ចភាពមិនមានអ្វីចាស់ និងមិនមានអ្វីថ្មីទេ។ ព្រះអាទិត្យដែលលិចនៅ ល្ងាចនេះនៅ ទិសខាងលិច ហើយនឹងរះឡើងវិញនៅថ្ងៃស្អែកនៅទិសខាងកើត។

## ៤.តើត្រូវយកឈ្នះលើសេចក្ដីលំបាកនានារបស់អ្នកយ៉ាងដូចម្ដេច?

(How to Overcome Your Difficulties) By Ven. Dr. K. Sri Dhammananda

តើអ្នកខ្វល់ខ្វាយឬ? តើអ្នកលំបាកវេទនាឬ ? សេចក្ដីនេះត្រូវគេប្រគល់ជូនចំពោះ អ្នកដែលធ្វើឱ្យខ្លួនឯងខ្វល់ខ្វាយជ្រុលហួសពេក។

សេចក្ដីទុក្ខព្រួយនិងភាពលំបាកវេទនាគឺ ជាអំពើអាក្រក់ពីរដែលតែងតែប្រព្រឹត្តទៅស្របជាមួយគ្នា។ វាមានសហអត្ថិភាពនៅក្នុងលោកនេះ។ ប្រសិនបើអ្នកមានអារម្មណ៍ ខ្វល់ខ្វាយមានន័យថាអ្នកកំសត់។ ប្រសិនបើអ្នក កំសត់វិញ មានន័យថាអ្នក ខ្វល់ខ្វាយ។ យើងត្រូវតែប្រឈមមុខទល់នឹងការពិតនានា។ បើទោះជាយើងមិនអាចរត់ ចេញពីវាបានក៏ដោយ ក៏យើងមិនត្រូវឱ្យ អំពើអាក្រក់ពោលគឺ ការខ្វល់ខ្វាយនិង ភាពកំសត់ទាំងពីរនេះយកឈ្នះលើយើងបានឡើយ ។យើងត្រូវតែយកឈ្នះលើវាឱ្យបាន។ យើងអាចធ្វើបែបនេះបានតាមរយៈការខិតខំប្រឹងប្រែងផ្ទាល់របស់យើងជាមួយ នឹងការប្ដេជ្ញាចិត្ត និងការអត់ធ្មត់។ ដោយមាន ការយល់ដឹងដោយសមស្រប និងដោយមានការអនុវត្តន៏បញ្ញា ដោយប្រុងប្រយត្ន័យើងមានលទ្ធភាពយកឈ្នះលើ អារម្មណ៍វិជ្ជលរបស់យើងបាន ហើយការខ្វល់ខ្វាយនិងភាពកំសត់នេះនឹងឃ្លាតឆ្ងាយ។

ការខ្វល់ខ្វាយរបស់យើង គឺយើងជាអ្នកបង្កើត។ យើងបានបង្កើតវាឡើងនៅក្នុងចិត្តរបស់យើងផ្ទាល់តាមរយៈការគ្មានលទ្ធភាព ឬការខកខានមិនបានយល់ពីភាពគ្រោះថ្នាក់ នៃអារម្មណ៍អត្តទត្តភាព និងការបំប៉ោង (the inflated) និង តម្លៃខុសដែលយើងជាប់ស្អិតទៅនឹងវត្ថុនានា។ ប្រសិនបើយើងគ្រាន់តែអាចមើលឃើញពីវត្ថុនានា ទៅតាមយថាទស្សន៍របស់វាទៅតាមភាពគ្មានអ្វីសោះ ដែលមានជាអចិន្ត្រៃយ៍នៅក្នុងលោកនេះ ហើយនិងថា អត្តទត្តភាព (egoistic self) ផ្ទាល់របស់យើងគឺជា មនោគតិវវើរវាយ (wild imagination) របស់យើងដែលកើតឡើងច្របូកច្របល់នៅក្នុង ចិត្តដែលគ្មានការហ្វឹកហាត់ (untrained mind) របស់យើង។ យើងនឹងត្រូវធ្វើដំណើរលើផ្លូវដ៏វែងឆ្ងាយដើម្បីស្វែងរក ឱសថ ដើម្បីបំបាត់ កង្វល់ និងភាពកំសត់របស់យើង។ យើងត្រូវតែអប់រំចិត្តរបស់យើង និង បេះដូងរបស់យើងឱ្យបំភ្លេចអំពីអត្តៈនិងដើម្បីជាសេវាកម្មហើយប្រើចំពោះមនុស្សធម៌។ នេះគឺជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយនានា ដែលតាមរយៈនោះយើងអាចរកឃើញពីសេចក្ដីស្ងប់និងសុភមង្គលបាន។

មនុស្សជាច្រើនមានចំណង់តណ្ហានិង ការស្រេកឃ្លានសេចក្ដីភ័យខ្លាចនិង សេចក្ដីព្រួយបារម្ភជាច្រើនដែលពួកគេមិនបានសិក្សាដើម្បីទប់នឹងការ រៀនខ្លាស ដើម្បីទទួលពួកវាសូម្បីតែចំពោះខ្លួនវា។ ប៉ុន្តែការរំជួលចិត្តអាក្រក់ៗទាំងអស់នោះមានកម្លាំង។ មិនជាបញ្ហាអ្វីមួយឡើយថា តើយើងអាចខិតខំព្យាយាមដើម្បីរាំងខ្ទប់ពួកវាពួកវាស្វែងរកការនោះរំលងមួយដោយការជះឥទ្ធិពលទៅលើយន្តសារពីររូបដែលឱ្យផលទៅក្នុងជម្ងឺរ៉ាំរ៉ៃយ៉ាងដូចម្ដេច? ទាំងអស់នេះអាចត្រូវបានការពារដោយវិធីចម្រើនភាវនាត្រឹមត្រូវ ឬការអប់រំខួរក្បាលពីព្រោះ ចិត្តដែលមិនមានការអប់រំគឺជាហេតុចម្បងនៃទុក្ខកង្វល់បែបនេះ។

នៅពេលណាអ្នកមានកង្វល់នៅ ក្នុងចិត្តសូមអ្នកកុំសម្ដែងទឹកមុខមិនស្រួលចំពោះមនុស្សម្នាក់ៗដែលអ្នកបានជួបប្រទះ។ អ្នកគួរតែបញ្ចេញឱ្យឃើញពី កង្វល់របស់អ្នកតែចំពោះអ្នកណាដែលអាចជួយអ្នកបានដោយពិតប្រាកដប៉ុណ្ណោះ។ វាមិនដឹងជាល្អយ៉ាងណាប្រសិន បើអ្នកអាចរក្សា ទឹកមុខញញឹម របស់អ្នកបាននៅក្នុងគ្រប់ សេចក្ដីលំបាក ដែលប្រឈមចំពោះ អ្នក។ នេះមិនជាការលំបាកពេកទេ ប្រសិនបើអ្នកខិតខំដោយ ពិបាកប្រាកដ។ យុវវ័យជាច្រើនខ្វល់ខ្វាយជាខ្លាំងពេលពួកគេត្រូវ សង្សារដោះដៃចោល។ ពួកគេអាចមានគម្រោងដើម្បី សម្លាប់ខ្លួនដែលបានបង្អិតបង្អំដោយស្ថានភាព មិនបានសម្រេចបំណងនិង ការខកចិត្ត។ អ្នកខ្លះធ្លាក់ខ្លួនចូលទៅក្នុងមនុស្សឆ្កួតលីលាក៏មាន។ យុវវ័យខូចចិត្តបែបនេះជាច្រើនដឹកនាំ ជីវិតរស់នៅដោយកំសត់ទុគ៌ត។ ព្រឹត្តិការណ៍ អភ័ព្វទាំងអស់នេះកើតមាន ឡើងស្របទៅតាមកង្វះខាតការយល់ដឹងចំពោះធម្មជាតិពិតនៃជីវិត។ តែទោះជាយ៉ាងណាក៏ដោយក៏ ការចេញដំណើរ ឬ ការបែកខ្ញែកគ្នានៅតែមិនអាចគេចផុតបានឡើយ។ រឿងនេះអាចកើតឡើងនៅពេលណាមួយ នៅត្រង់ចំណាប់ផ្ដើមនៃជីវិត ឬជួនកាលនៅ ពាក់កណ្ដាលជីវិត ឬជួនកាលនៅ ចុងបញ្ចប់ជីវិតវាពិតជាមិនអាចជៀសផុតបានយ៉ាងពិតប្រាកដ។ ពេលវត្ថុបែបនេះកើតមានគេត្រូវតែខិតខំព្យាយាមស្វែងរកឱ្យឃើញពី កន្លែងដែលហេតុពឹងផ្អែក។ តែទោះជាយ៉ាងណាក៏ដោយ ប្រសិន បើការបែកបាក់គ្នានៅហួសពីការត្រួតពិនិត្យគេត្រូវតែមានការលើកទឹកចិត្តដើម្បីអត់ទ្រាំ នឹងវាដោយការយល់ច្បាស់ពី ធម្មជាតិនៃជីវិត។ ប៉ុន្តែក្នុងន័យម្យ៉ាងទៀត វាមិនជាការលំបាក សម្រាប់អ្នកណាម្នាក់ដើម្បីស្វែងរកមិត្តថ្មី ដើម្បីបំពេញកន្លែងខ្វះចន្លោះ ប្រសិនបើគេពិតជាចង់មែន។

*"អ្នកណាក៏ដោយដែល សេចក្ដីភ័យខ្លាច លេចឡើងហើយវាកើតឡើងនៅចំ មនុស្សល្ងីល្ងើ មិនមែននៅលើមនុស្សឆ្លាតនោះទេ" នេះជាការសម្ដែងរបស់ ព្រះពុទ្ធ។ សេចក្ដីវិនាសគ្មានអ្វី*

*ក្រៅពីសភាពខួរក្បាលនេះឡើយ ។ សភាពខួរក្បាលរបស់គេស្ថិតនៅក្រោម ការត្រួតពិនិត្យ និង ការអូសទាញការប្រើ គំនិតអវិជ្ជមានបង្កើត សេចក្តីភ័យខ្លាច របស់យើងការប្រើ គំនិតវិជ្ជមានយល់ច្បាស់ពីសេចក្តីសង្ឃឹមនិងឧត្តមភាពរបស់យើង ហើយនៅក្នុងករណីទាំងនេះជម្រើសពឹងផ្អែកទាំងស្រុងជាមួយនឹងខ្លួនយើង ។ មនុស្សគ្រប់រូបមានលទ្ធភាពដើម្បីត្រួតពិនិត្យ ដោយពេញលេញ ទៅលើចិត្តរបស់គេផ្ទាល់ ។ ធម្មជាតិបានផ្តល់ឱ្យ មនុស្សនូវការត្រួតពិនិត្យដាច់ខាតមួយប៉ុន្តែវត្ថុមួយនោះគឺជាគំនិត ។ ការពិតនេះផ្គូរជាមួយនឹង ការពិតបន្ថែមថា អ្វីៗដែលមនុស្សបង្កើត បានចាប់ផ្តើមនៅក្នុងទម្រង់គំនិតដឹកនាំ គេខិតយ៉ាងជិតទៅនឹងគោលការណ៍ ដែលតាមរយៈនោះសេចក្តីភ័យខ្លាចអាចត្រូវបានគេគ្រប់គ្រងបាន។*

*អ្នកកាយវិភាគវិទ្យា* គួរឱ្យកត់សម្គាល់ម្នាក់ នៅពេលមួយនោះបានសួរតាមរយៈនិស្សិតថា *"អ្វីដែលជាការព្យាបាលដ៏ប្រសើបំផុតសម្រាប់សេចក្តីភ័យខ្លាចនោះ?"* ហើយគាត់បានឆ្លើយថា *"សូមព្យាយាមធ្វើអ្វីមួយសម្រាប់អ្នកណាម្នាក់"* និស្សិត ត្រូវបានធ្វើឱ្យភ្ញាក់ផ្អើលគួរឱ្យយកមកគិត ដោយការឆ្លើយតប ហើយក៏បានស្នើសុំនូវការយល់ដឹងបន្ថែម ។ នៅខណៈនោះគ្រូរបស់គាត់បាននិយាយថា "អ្នកមិនអាចមាន គំនិតពីរផ្ទុយគ្នានៅក្នុងចិត្តអ្នកតែមួយនិងនៅពេលដូចគ្នា*នោះ*ទេ" ។ គំនិតមួយក្រុម (one set of thoughts) តែងតែកម្ចាត់ដល់អ្នកដទៃ ។ ជាឧបមាប្រសិនបើចិត្តរបស់អ្នក មិនរវល់ជាមួយនឹង ចំណង់មិនអាត្មានិយម ទាំងស្រុងដើម្បីជួយអ្នកណាម្នាក់ ទៀតទេនោះ អ្នកមិនអាចជ្រកក្រោម សេចក្តីភ័យខ្លាចនៅពេលជាមួយគ្នាបានទេ ។

*" កង្វល់ធ្វើឱ្យឈាមរីងស្ងួតលឿនជាង វ័យ (worry dries up the blood sooner than age) "។ ការភ័យខ្លាចកង្វល់ និងការព្រួយបារម្ភជា កណ្តាលគឺជា សភាវគតិធម្មជាតិនៃស្ម័យអភិរក្ស ។ ប៉ុន្តែ ការភ័យខ្លាចមិនប្រែប្រួល* (constant fear) *និង កង្វល់យូរអង្វែងគឺជាសត្រូវអមតៈចំពោះ សាពាង្គកាយមនុស្ស ។ ពួកវារំខានដល់មុខងាររូបកាយធម្មតា។*

*ប្រសិនបើអ្នកបានសិក្សាថាតើត្រូវធ្វើឱ្យ អ្នកដទៃសប្បាយរីករាយយ៉ាងណានោះអ្នកតែងតែស្ថិតនៅក្នុងអារម្មណ៍ល្អជានិច្ច ។ នេះក៏ព្រោះតែចិត្តរបស់អ្នកមិនបណ្តោយឱ្យ កង្វល់ត្រូវចូល ផ្សំនៅក្នុងវាបាន។*

**សម្លេងធម្មជាតិ** (The Voice of Nature)

ដើម្បីផលប្រយោជន៏ភារៈមនុស្សទំនើបមិនបានស្តាប់សម្លេងធម្មជាតិនោះទេ ។សកម្មភាពខួរក្បាល របស់គេធ្វើឱ្យអំពល់ជាខ្លាំងជាមួយនឹង សុភមង្គលអនាគត របស់គេដែលគេមិនយក

ចិត្តទុកដាក់នឹង តម្រូវការរាងកាយរូបសាស្ត្រ របស់គេ ហើយបំភ្លេចចោលទាំងស្រុងជាមួយនឹងឱកាសបច្ចុប្បន្ន ចំពោះអ្វីដែលវាមានតម្លៃ។ ឥរិយាបថមិនធម្មជាតិ របស់មនុស្សសម័យនេះ គឺជាលទ្ធផលបន្ទាន់នៃ ជីវិតខុសឆ្គងរបស់ពួកគេចំពោះ សណ្តាប់ធ្នាប់ពិភពលោកចំពោះ ជីវិតមនុស្សនិងចំពោះគោលបំណងខ្ពស់បំផុតរបស់វា។ វាគឺជាហេតុនៃការខកបំណងការព្រួយបារម្ភការភ័យខ្លាចនិងអសន្តិសុខ នៃពេលវេលាបច្ចុប្បន្នរបស់យើង។ អ្នកដែលចូលចិត្តមានសន្តិភាពមិនគួរ រំខានដល់សេរីភាពរបស់មនុស្សម្នាក់ទៀតឡើយ។ វាជាការមិនត្រឹមត្រូវដែលស្វែងរកសុភមង្គលដោយលំលោភ និងបោកប្រាស់អ្នកដទៃនោះ។

ប្រសិនបើ មនុស្សសាហាវឃោរឃៅ និងព្រៃផ្សៃជានិច្ចកាលតែងរស់នៅ ប្រឆាំងទល់នឹងច្បាប់ធម្មជាតិ និងលោកធាតុ បើទោះជា អំពើសម្តី និង ជីវិតរបស់គេ គេបំពុលបរិយាកាសទាំងមូល។ ជាលទ្ធផលនៃ អំពើខុសនិង គំនិតបែបនេះ ធម្មជាតិមិនអាចផលិតអ្វីៗដែល មនុស្សត្រូវការសម្រាប់ការរស់នៅរបស់គេ ប៉ុន្តែជាការ ជំនួសមកវិញ មនុស្សត្រូវប្រឈមមុខទល់នឹងប្រភេទមហន្តរាយរាតត្បាតនិងប្លែកៗ។

ម្យ៉ាងទៀតប្រសិនបើ មនុស្សរស់នៅដោយអនុលោមទៅតាមក្រឹត្យក្រមធម្មជាតិ ពោលគឺ ដឹកនាំមាគ៌ាជីវិតត្រឹមត្រូវមួយធ្វើឱ្យ បរិយាកាសល្អបរិសុទ្ធទៅតាមរយៈ បុណ្យកុសលនៃគុណធម៌របស់គេ ហើយ បំភាយ នូវ សេចក្តីមេត្តារបស់គេចំពោះ ភាវៈមានជីវិតដទៃទៀតគេអាចផ្លាស់ប្តូរបរិយាកាសដើម្បីបង្កើតឱ្យមានលទ្ធភាពល្អប្រសើរចំពោះសុភមង្គលរបស់មនុស្ស។

អ្នកអាចជាមនុស្សរវល់ទាន់សម័យបំផុត ប៉ុន្តែកុំភ្លេច ចំណាយ យ៉ាងហោចណាស់ក៏ពីរបីនាទីក្នុងមួយថ្ងៃទៅលើ ការអានសៀវភៅដែលថ្លៃៗមួយចំនួនទម្លាប់នេះ នឹងផ្តល់ឱ្យអ្នកនូវការធូរស្រាលហើយនឹងធ្វើឱ្យអ្នកមានលទ្ធភាពបំភ្លេចកង្វល់នានារបស់អ្នកបាន ហើយនឹងដើម្បីអភិវឌ្ឍន៍ចិត្តរបស់អ្នកឱ្យប្រសើរឡើង។ នៅពេលជាមួយគ្នានេះអ្នកត្រូវតែចងចាំថា អ្នកក៏មានសាសនាមួយដែរ។ សាសនា គឺមានសម្រាប់ ផលប្រយោជន៍ ផ្ទាល់របស់អ្នក។ ដូចនេះវាគឺជាករណីយកិច្ចរបស់អ្នកដែលត្រូវគិតអំពីសាសនារបស់អ្នក ហើយនឹងត្រូវចំណាយពីរបីនាទីក្នុង មួយថ្ងៃដើម្បីបំពេញករណីយកិច្ចសាសនារបស់អ្នក។

**សុខភាពខួរក្បាល និងទំនោរឧក្រិដ្ឋកម្ម** (Mental Health and Criminal Tendencies)

ដោយមានទំនាក់ទំនងដល់ សុខភាពវាមិនមែនជា អេដស៍ឬ មហារីកអ្វីឡើយ នោះគឺជាការរំខានបំផុតនៃជម្ងឺរបស់យើង។ ជម្ងឺទាំងអស់នេះឥឡូវនេះស្ថិតនៅក្រោមការ ត្រួត

ពិនិត្យហើយមានគ្រប់សេចក្តីសង្ឃឹមថា ការព្យាបាល ចំពោះវា នឹងត្រូវបានរកឃើញនៅក្នុងអនាគតដ៏ជិតនេះ។ តាមពិតការរំខានបំផុតនៃអ្វីៗទាំងអស់គឺ ភាពល្បីខ្ចរខ្ចារនិង វិកសុះសាយនៅក្នុងគ្រប់ប្រភេទជម្ងឺនិងការរំខានខួរក្បាលទាំងអស់ ។យើងត្រូវបានបង្ខំ ឱ្យកសាងមន្ទីរពេទ្យនិង ស្ថាប័នកាន់តែច្រើនឡើងៗសម្រាប់ ជម្ងឺខួរក្បាលនិង វិកលចរិតគ្រប់ប្រភេទទាំងអស់។ មាន មនុស្សជាច្រើនទៀតដែលមិនបានទទួលការ ព្យាបាលណាមួយសោះ ប៉ុន្តែអ្នកដែលស្ថិតនៅក្នុងតម្រូវការដ៏ធំធេងចំពោះវា។

គេអាចសួរពីវាពីហេតុដែល ធាតុឧក្រិដ្ឋកម្មនៅក្នុង សង្គមរបស់យើងត្រូវបានបញ្ចោក់នៅក្នុងដង្ហើមតែមួយជាក្តី ក្តៅក្រហាយដោយខួរក្បាល។ មួយក្នុងចំណោម លទ្ធផលទូលំទូលាយនិង វិជ្ជមាននានាដែលកើតមកដោយផ្ទាល់ពី កិច្ចការស្រាវជ្រាវរបស់ Freud គឺជាការយល់ដឹងថា ឧក្រិដ្ឋជននិង អ្នកប្រព្រឹត្តបទមជ្ឈឹម (deliquents)ក៏ជា មនុស្សមាន ជម្ងឺខួរក្បាលដែរមានច្រើន នៅក្នុងតម្រូវការប្រព្រឹត្តជាង ការដាក់ទណ្ឌកម្ម។ វាជា ទស្សនវិស័យ សេរីទៅលើបញ្ហា ដែលជាមូលដ្ឋាននៃ ការកែទម្រង់សង្គម"ជឿនលឿន"សព្វយ៉ាង ហើយដែលបើកចំហផ្លូវសម្រាប់ការជំទាស់ជាជាងការសងសឹក។

**ចូរស្គាល់ពីអ្នកជិតខាងរបស់អ្នក** (Know Thy Neighbour)

យើងមិនអាចធ្លាប់ដឹងថា មនុស្សដទៃរស់នៅយ៉ាងដូចម្តេចឡើយ យើងមិនអាចធ្លាប់បានដឹងអ្វីមួយអំពីជីវិតមនុស្សនៅក្នុងកម្រិតសង្គមខុសៗគ្នាមកពីខ្លួនយើង ឬទ្រព្យសម្បត្តិច្រើនជាងឬតិចជាងនោះទេ។ ប្រសិនបើយើងមាន សុខភាព យើងមិនអាចដឹងបាន ពីអ្វីដែលវាមានទំនងជាឈឺនោះទេ ហើយប្រសិនបើយើងឥតបានការវិញ យើងមិនអាចយល់ដឹងពី ថាមពលរបស់អ្នកខ្លាំងបានទេកង្វះបទពិសោធន៍បែបនេះបង្កើតឱ្យមានភាពមិនអាចអត់ធ្មត់បាន ពីព្រោះការអត់ធ្មត់កើតឡើងតែមកពី មានការយល់ដឹងតែប៉ុណ្ណោះ ហើយមិនដែលគ្មាន បទពិសោធន៍ណាដែលគ្មានការយល់ដឹងនោះទេ។ ដូច្នេះវាគឺជា របស់ល្អមួយសម្រាប់យើងមាន បទពិសោធន៍ទូលំទូលាយ តាមដែលអាចធ្វើទៅបានអំពី ទិដ្ឋភាពជីវិតសព្វយ៉ាង ។ ហើយជា ពិសេសដើម្បីធ្វើដំណើរ ហើយនិងធ្វើឱ្យខ្លួនយើងជាក់ច្បាស់ថា យើងជានិច្ចកាលមិនធ្វើដំណើរ ទៅតាមប្រណីតភាពនោះទេ។

**អពមង្គលរបស់មនុស្ស** (Man's Unhappiness)

ព្រះពុទ្ធទ្រង់បានបង្រៀនថាអពមង្គលរបស់មនុស្សទាំងអស់ កើតឡើងមកពីការចង់បានរបស់ប្លែកៗ (extra-ordinary things) សេចក្តីសប្បាយដែលលុយអាចទិញបាន អំណាចគ្រប់គ្រងលើអ្នកដទៃហើយដែលសុទ្ធតែសំខាន់បំផុតនោះ គឺត្រូវបន្តរស់នៅជារៀងរហូតបន្ទាប់ពីគេស្លាប់ទៅ។ ចំណង់បានចំពោះរបស់ទាំងនេះ ធ្វើឱ្យមនុស្សគិតតែពីប្រយោជន៍ខ្លួនឯង ដើម្បីពួកគេគិតតែពីខ្លួនឯងចង់បានអ្វីៗតែសម្រាប់ខ្លួនគេប៉ុណ្ណោះ ហើយមិនមានខ្វល់ខ្វាយអ្វីដែលកើតឡើងចំពោះអ្នកដទៃនោះឡើយ។ មានតែវិធីដើម្បីជៀសវាងភាពអន្ទះអន្ទែងនេះ (restlessness) គឺត្រូវកម្ចាត់ចំណង់ដែលជាហេតុបណ្តាលរបស់វា។ នេះជាការលំបាកបំផុត ប៉ុន្តែពេលមនុស្សសម្រេចបានវា គេឈានទៅដល់សភាពសុក្រឹតនិងសេចក្តីស្ងប់មួយ។

យើងមិនបានសប្បាយជាមួយនឹង សេចក្តីរីករាយទេ ប៉ុន្តែគឺខ្លួនយើងទេដែលត្រូវយកឈ្នះលើសេចក្តីរីករាយបាន( មានន័យថា ដោយការបញ្ចប់ សេចក្តីបារម្ភក្នុងការស្វែងរកសេចក្តីរីករាយទាំងនោះដែលថាមពលទាំងអស់របស់ យើងត្រូវបានធ្វើឱ្យអស់)។ យើងកើតទុក្ខច្រើនជាងយើងសប្បាយក្នុងការស្វែងរក សេចក្តីរីករាយនៃ ពិភពបាតុភូត នេះ។

**ពេលវេលានឹងផ្សះរបួសរបស់យើង** (Time will Heal Our Wounds)

បញ្ហា កន្លងហួសទៅ។ អ្វីដែលបានធ្វើឱ្យអ្នកស្រក់ទឹកភ្នែកសព្វថ្ងៃនេះ នឹងត្រូវបានគេបំភ្លេចចោលយ៉ាងលឿន អ្នកអាចនៅចាំបានថា អ្នកស្រែកយំប៉ុន្តែវាមិនសមថា អ្នកនឹងនៅចាំបានពីអ្វីដែលអ្នកស្រែកយំនោះ។ ដូចយើងចំរើនអាយុឡើង ហើយត្រូវធ្វើដំណើរឆ្លងកាត់ ជីវិតប្រសិនបើយើងនៅចាំបានពីរឿងនេះជានិច្ចកាល យើងនឹងត្រូវភ្ញាក់ផ្អើលដើម្បីរកឱ្យឃើញថាតើយើងដេកភ្ញាក់នៅពេលយប់ដោយសញ្ជឹងគិតពីលើអ្វីមួយ ដែលបានកើតឡើងធ្វើឱ្យយើងជ្រួលច្របល់នៅពេលថ្ងៃយ៉ាងដូចម្តេច ឬថាតើយើងត្រូវព្យាបាល ការតូចចិត្ត ប្រឆាំងទល់នឹងអ្នកណាម្នាក់ យ៉ាងដូចម្តេច ហើយនិងរក្សាទៅលើការបណ្តោយឱ្យ គំនិតដូចគ្នារត់តាម ចិត្តរបស់យើងអំពីថាតើយើងនឹងមានខ្ពងផ្ទាល់របស់យើងប្រឆាំងចំពោះ មនុស្ស ដែលបានបង្កទុក្ខទោសដល់យើងយ៉ាងដូចម្តេច។ យើងអាចធ្លាក់ចូលទៅក្នុងកំហឹងលើអ្វីមួយ ហើយក្រោយមកងឿងឆ្ងល់លើអ្វីដែលវាមានយើងខឹងយ៉ាងខ្លាំងអំពីអ្វីនោះ។ ហើយបើសិនយើងនៅចាំបានយើងដឹងច្បាស់ពី អ្វីដែលពេលវេលាឥតបានការ និងថាមពលដែលវាសុទ្ធតែមាន ហើយនិងថា

តើយើងបានបន្តការមាន អពមង្គលដោយ មិនសូញសាញយ៉ាងដូចម្តេចពេលយើង អាចបញ្ឈប់វាបាន ហើយចាប់ផ្តើមគិតអំពីអ្វីមួយទៀត។

បញ្ហារបស់យើងអ្វីក៏ដោយ ទោះជាសោកសង្រេងយ៉ាងណាក៏ដោយ វាអាចលេចឡើងពេលវេលានឹងផ្សះរបួសរបស់យើង។ ប៉ុន្តែជាការពិតវាត្រូវតែមានអ្វីមួយ ដែលយើងអាចការពារខ្លួនយើងពី ការឈឺចាប់នៅក្នុងកន្លែងដំបូង។ តើហេតុអ្វីបានយើងបណ្តោយឱ្យ មនុស្សហើយ និងបញ្ហានានាបង្ខូរ ថាមពលរបស់យើង ហើយនិងធ្វើឱ្យយើង មិនសប្បាយបាន ? តាមពិត ចម្លើយគឺថា ពួកវាមិនទេ គឺយើងខ្លួនឯងទេដែលធ្វើឱ្យមិនសប្បាយនោះ។

អ្នកអាចនឹងមាន បញ្ហា ណាមួយនៅក្នុង ការិយាល័យរបស់អ្នក ឬក៏នៅកន្លែងដែលអ្នកធ្វើការ ប៉ុន្តែអ្នកមិនគួរនាំ ឬពង្រីក បញ្ហាបែបនេះទៅដល់ផ្ទះរបស់អ្នកឡើយ ហើយបង្កើតឱ្យមានបរិយាកាសអ័ព្ទអួរក្នុងចំណោមមនុស្សជា ទីស្រឡាញ់របស់អ្នកដែលគ្មានកំហុសនោះឡើយ។

អ្នកគួរតែយល់ច្បាស់ថា មាន វិធីព្យាបាល ឬ ទីបញ្ចប់មួយចំពោះបញ្ហាទាំងនោះ។ នេះគេត្រូវរកឃើញដោយ ការសម្រេចបាន សេរីភាពពី ចំណង់អាត្មានិយមរបស់យើង ហើយនិងដោយការកម្ចាត់ គ្រប់ទម្រង់ភ័ន្តច្រឡំនិង អវិជ្ជារបស់យើងចោល។

នៅទីណាដែលយើងរកមិនឃើញដំណោះស្រាយចំពោះ បញ្ហាមួយ យើងមានទំនោររកឱ្យ ឃើញពីអ្នករងកំហុសអ្នកដទៃ អ្នកណាមួយដែលប្រឆាំងអ្នកដែលយើងអាចជួយបន្ធូរការរំសាយ ចិត្តរបស់យើងបាន។ យើងមិនរៀបចំព្រមទទួលយក កំហុសផ្ទាល់របស់យើង។ យើងមានអារម្មណ៍ថា វាកាន់តែងាយស្រួលដើម្បីដាក់ការស្តីបន្ទោសទៅឱ្យអ្នកដទៃ ហើយនិងដើម្បីអប់រំការឈឺចាប់ប្រឆាំងចំពោះអ្នកណាមួយ។តាមពិតគ្នាយើងមួយចំនួនទទួលបានការសប្បាយរីករាយនៅក្នុងទង្វើបែបនេះ។ នេះគឺជាឥរិយាបថខុសទាំងស្រុង។ យើងមិនត្រូវបង្ហាញការតូចចិត្ត ឬខឹងសម្បារចំពោះ អ្នកដទៃឡើយ។ យើងគួរធ្វើកម្រិតបំផុតរបស់យើង ពោលគឺដោយការស៊ូទ្រាំលំបាកនិងដោយសេចក្តីស្ងប់ស្ងាត់ដើម្បីដោះស្រាយបញ្ហាផ្ទាល់របស់យើង។ យើងត្រូវតែរៀបចំប្រឈមមុខចំពោះ សេចក្តីលំបាកមួយចំនួនដែលយើងអាចប្រឈមបាន។

**សុភមង្គលនិងសម្ភារៈនិយម** (Happiness and Materialism)

មនុស្សជាច្រើនជឿថា ពួកគេអាចដោះស្រាយរាល់ បញ្ហា របស់ពួកគេបាន ប្រសិនបើពួកគេគ្រាន់តែមាន លុយ ប៉ុន្តែពួកគេមិនបានយល់ច្បាស់ទេថា លុយ ខ្លួនវាមានបញ្ហាហែហមរបស់វា។ លុយតែមួយមិនអាចដោះស្រាយ បញ្ហា សព្វយ៉ាងបានទេ។

មនុស្សជាច្រើនមិនដែលសិក្សាអំពីនេះទេ ហើយ ជីវិតរស់នៅរបស់គេសុទ្ធតែប្រញ៉ាកអំពីការប្រើ ថាមពលរបស់ ពួកគេដោយព្យាយាមប្រមូល "គ្រឿងរបស់របរកំប៉ិកកំប៉ុក"ជាច្រើនពេល ពួកគេមានវាហើយ ពួកគេបានរកឃើញថា របស់ទាំងនេះ មិនអាចបំពេញចិត្តពួកគេបានទេ ប៉ុន្តែពួកគេត្រូវមាន "របស់ផ្សេងទៀត"។ តាមពិតពួកគេមានវាកាន់តែច្រើនពួកគេកាន់តែចង់ ឱ្យមានវានេះច្រើនតទៅទៀត ដូច្នេះគេមិនដែលរកឃើញ សុភមង្គលរបស់គេនៅត្រង់ណាមួយឡើយ ។សម្ភារៈនិយមនេះគឺជាបញ្ហាធំបំផុតដែលសង្គមកំពុងតែប្រឈមនាពេលសព្វថ្ងៃនេះ។

ដំបូន្មានខាងក្រោមបានផ្តល់ឱ្យយើងនូវ ការលួងលោមចិត្តដ៏ធំសម្បើមពេលយើងបាត់បង់អ្វីមួយ :-

*"សូមកុំនិយាយថា នេះជារបស់អ្នកហើយនោះគឺជារបស់ខ្ញុំ សូមគ្រាន់តែនិយាយថា របស់នេះចូលមកដល់អ្នកហើយហើយរបស់នោះចូលមកដល់ ខ្ញុំហើយដូច្នេះយើងមិនមានការសោកស្តាយឬតូចចិត្តនឹងរបស់មិនទៀងទាត់ នេះឡើយគ្រប់ របស់អស្ចារ្យៗទាំងអស់ត្រូវបានបញ្ចប់នៅត្រឹមនេះ ។"*

ទ្រព្យមិនមែនជាអ្វីមួយសម្រាប់អ្នក ដើម្បីបោះបង់ចោលនៅទីកន្លែងណាមួយ ហើយនិងប្រាថ្នាចង់បានវានោះទេ។ វាតម្រូវឱ្យអ្នកប្រើប្រាស់វាដើម្បី សុខុមាលភាពរបស់អ្នក ក៏ដូចជាអ្នកដទៃដែរ។ ប្រសិនបើអ្នកចំណាយពេលរបស់អ្នកដោយគ្រាន់តែប្រកាន់ខ្ជាប់ចំពោះ ទ្រព្យសម្បត្តិរបស់អ្នកដោយមិនបានសូម្បីតែបំពេញកាតព្វកិច្ច របស់ខ្លួនចំពោះប្រទេស ប្រជាជនសាសនា របស់អ្នកដែលអ្នកអាចរកឃើញថា ឱកាសចូលមកដល់អ្នកដែលត្រូវលាចាកលោកនេះ ហើយអ្នកនៅតែត្រូវញាំញីដោយកង្វល់ទៀត។ អ្នកនឹងមិនទទួលបាននូវគុណប្រយោជន៍អ្វីពីទ្រព្យសម្បត្តិនោះដែលអ្នកបានប្រមូលវាទុកយ៉ាងលំបាកឡើយ។

ដើម្បីសង្ឃឹមលើ ទ្រព្យសម្បត្តិនិងសម្រេចបានតាមរយៈ ល្បែងស៊ីសងដូចជានឹកសង្ឃឹមទៅលើជម្រកពីព្រះអាទិត្យតាមរយៈពពកដូច្នេះដែរ ចំណែកឯចំពោះ សេចក្តីសង្ឃឹមទៅលើការ ចំរើននិងវិបុលភាពតាមរយៈវិរិយភាព (diligence)នៅក្នុងកិច្ចការប្រៀបដូចជាការសង់ផ្ទះ អចិន្ត្រៃយ៍មួយជាជម្រកបាំង ព្រះអាទិត្យនិង ភ្លៀងផ្គរដូច្នេះដែរ។

ទ្រព្យរបស់អ្នកនឹងគង់នៅ ពេលអ្នកស្លាប់ទៅ។ មិត្តនិង សាច់សាលោហិត របស់អ្នក នឹងយកអ្នកទៅកប់។ ប៉ុន្តែមានតែអំពើអាក្រក់ឬ ល្អដែលអ្នកបានធ្វើកាលពីនៅរស់ នឹងដើរតាមអ្នក ទៅហួសពីផ្លូវនេះទៅទៀត។

មានវត្ថុជាច្រើនដែលយើងសង្ឃឹមលើវាថានឹងផ្តល់ សេចក្តីសប្បាយមកដល់យើងហើយបែរត្រឡប់ទៅជាផ្សេងទៅវិញ។ ជាការពិតវាមានទំនងជាល្អដែរដោយត្រូវមាន លុយច្រើន ប៉ុន្តែប្រសិនបើយើងមានវាវិញ យើងនឹងរកឃើញថា វានាំឱ្យយើង ខ្វល់ទៅក្នុងការសម្រេចចិត្តថាតើត្រូវប្រើវា ឬថា តើត្រូវការពារវាយ៉ាងដូចម្តេច ឬថា តើយើងអាចត្រូវបានដឹកនាំឱ្យសម្តែងអំពើដោយឆ្កួតៗយ៉ាងដូចម្តេច។ អ្នកមាន ចាប់ផ្តើមានមន្ទិលសង្ស័យប្រសិនបើ មិត្តរបស់គេ វាយតម្លៃគេសម្រាប់ខ្លួនគេឬសម្រាប់លុយរបស់គេនោះ ហើយនេះគឺជា ទម្រង់កង្វល់ខួរក្បាលមួយទៀត។ ហើយជានិច្ចកាលតែងតែមានការ ភ័យខ្លាច បាត់អ្វីមួយដែលយើងមានថាតើពួកវាជា ទ្រព្យកម្មសិទ្ធិឬជា មនុស្សជាទីស្រឡាញ់ ណាមួយ។ ដូច្នេះពេលយើងស្មោះត្រង់ ហើយមើលឱ្យបានក្បៀកចំពោះអ្វីដែលយើងហៅថា "សុភមង្គល" នោះ យើងនឹងរកឃើញថាវា គឺជា ប្រភេទបំភាន្តផ្ទៃកមួយ(a kind of mirage)នៅក្នុង ចិត្ត របស់យើង មិនដែលបានយល់ ដោយពេញលេញ មិនដែលបំពេញឡើយ ឬអស់ពីសមត្ថភាពឡើយ វាតែងតែបន្ទរតាមដោយការខ្លាចបាត់ជានិច្ច។

*ទ្រព្យរបស់អ្នកអាចតុបតែងតែ ផ្ទះរបស់អ្នក ប៉ុន្តែមិនមែន អ្នកនោះ។ មានតែ គុណធម៌ផ្ទាល់របស់អ្នកទេ ដែលអាចតុបតែង ខ្លួនអ្នកបាន។ សំលៀកបំពាក់របស់អ្នកអាចតុបតែង ខ្លួនអ្នកប៉ុន្តែមិនមែន អ្នកនោះទេ។ មានតែ ការប្រព្រឹត្តល្អប៉ុណ្ណោះដែលអាចតុបតែង ខ្លួនអ្នកឱ្យល្អបាន។*

*វិធីដែល មនុស្សគួរតែរើសយកដើម្បីសម្រេចបាន សុភមង្គលនោះត្រូវតែជាវិធីមួយ គ្មានទុក្ខទោស។នេះមិនមែនមានន័យនៅក្នុងការចូលរួមសប្បាយជាមួយសុភមង្គលដោយការបណ្តោល ឱ្យមានទុក្ខដល់មនុស្សម្នាក់ទៀតឬ ដល់ភាវៈមានជីវិតដទៃណាមួយទៀតនោះទេ។ ព្រះពុទ្ធទ្រង់ត្រាស់សម្តែងថា :- "ពរជ័យតែងកើតមានចំពោះ អ្នក ដែលចិញ្ចឹមជីវិតដោយមិនបៀតបៀនដល់អ្នកដទៃ។"*

*"សុភមង្គលគឺជា គន្ធរស (perfume) អ្នកមិនអាចចាក់វាទៅលើ អ្នកដទៃដោយមិនបានចាក់ពីរបីដំណក់ទៅលើខ្លួនអ្នកនោះឡើយ"*

អ្នកអាចមិនមានលទ្ធភាពផ្លាស់ប្តូរ ពិភពលោក បានដោយអនុលោមតាម បំណងប្រាថ្នារបស់អ្នកនោះបានឡើយប៉ុន្តែអ្នកអាចមានលទ្ធភាពផ្លាស់ប្តូរចិត្ត របស់អ្នកឱ្យស្វែងរកសុភមង្គលបាន។

វាគ្រាន់តែពេលអ្នកមានទុក្ខតាមរយៈការធ្វើល្អដែលអ្នកអាចសម្រេចបាន សុភមង្គលដ៏ធំធេងជាង អ្នកដទៃទៀតប៉ុណ្ណោះ។

*"ប្រសិនបើយើងចង់ស្វែងរក សុភមង្គល សូមយើងឈប់គិតពី កតវេទិតាឬ អកតញ្ញូតា ហើយសូមផ្តល់ឱ្យចំពោះ សេចក្តីសប្បាយនៃការផ្តល់ឱ្យខាងក្នុង (the inner joy of giving ។ អកតញ្ញូតាប្រៀបដូចជា ស្មៅធម្មជាតិឥតបានការ (natural-like weeds) ។ កតវេទិតាប្រៀបដូចជា ផ្កាកូលាប។ វាត្រូវបានគេចិញ្ចឹមបំប៉នចាក់ទឹក ជ្រោយដីពូនគល់ស្រឡាញ់ និងការពារ"។(D. Carnegie)*

**ចូរគ្រប់គ្រងចិត្តអ្នក** (Control Your Mind)

ចិត្តរបស់ មនុស្សមានឥទ្ធិពលទៅលើ សារពាង្គកាយរបស់គេយ៉ាងខ្លាំងបំផុត។ ប្រសិនបើគេបណ្តោយឱ្យមាននាទី យ៉ាងសាហាវ ហើយរក្សាទុក គំនិតមិនល្អ ចិត្ត អាចបណ្តាលឱ្យមានមហន្តរាយបាន។ វាអាចសូម្បីតែសម្លាប់ ភាវៈមួយ ប៉ុន្តែវាក៏អាចព្យាបាល រាងកាយឈឺមួយបានដែរ។ ពេលចិត្តត្រូវបានគេយកចិត្តទុកដាក់នៅលើ គំនិតត្រឹមត្រូវ ដោយមានការខិតខំប្រឹងប្រែងត្រូវហើយនិង យល់ដឹងទៅលើ ផលដែលវាបង្កើតឡើងនោះមានលក្ខណៈធំធេងណាស់។ ចិត្តដែលមាន គំនិតបរិសុទ្ធនិង ត្រឹមត្រូវពិតជាដឹកនាំទៅរក ការរស់នៅធូរស្រាលដោយសុខភាពជាមិនខានឡើយ។

ព្រះពុទ្ធ ទ្រង់ត្រាស់សម្តែងថា " គ្មានសត្រូវណាដែលអាចបង្កទុក្ខទោសដល់គេច្រើនដូចគំនិតលោភលន់ ផ្ទាល់ របស់គេ , គំនិតស្អប់ គំនិតច្រណែនឈ្នានីស នោះទេ "។

មនុស្សម្នាក់ដែលមិនដឹងថាតើត្រូវសម្របចិត្ត របស់គេដោយអនុលោមតាមកាលៈទេសៈ ដូច សាកសពនៅក្នុងក្តារមឈូសយ៉ាងដូចម្តេច ?

សូមត្រឡប់ចិត្តរបស់អ្នកវិលទៅរកខ្លួនអ្នកវិញម្តង ហើយខំរកឱ្យឃើញពីសេចក្តី រីករាយនៅក្នុងខ្លួនអ្នក ហើយអ្នកនឹងតែងតែរកឃើញនៅក្នុងទីនោះនូវប្រភពនៃ សេចក្តីរីករាយមិនពិត មួយរួចរាល់សម្រាប់ការសប្បាយរបស់អ្នក។

វាគ្រាន់តែនៅពេលចិត្តត្រូវបានគេគ្រប់គ្រងហើយថែរក្សា បានលើវិថីត្រឹមត្រូវនៃដំណើររីកចំរើនដោយរៀបរយ ដែលវាក្លាយទៅជាប្រយោជន៍សម្រាប់ម្ចាស់ខ្លួនផ្ទាល់ និងសម្រាប់សង្គម។ ចិត្តគ្មានសណ្តាប់ធ្នាប់ គឺជាដំណើរខូចប្រយោជន៍ មួយចំពោះខ្លួនគេផ្ទាល់ និងចំពោះ

អ្នកដទៃ។ គ្រប់គ្រោះមហន្តរាយ ដែលកើតមាននៅក្នុងលោកនេះ ត្រូវបានបង្កើតឡើងដោយមនុស្ស ដែល មិនបានសិក្សាពី វិធីគ្រប់គ្រងចិត្ត តុល្យភាពនិងលំនឹងផ្លូវចិត្ត។

ភាពស្ងប់ស្ងាត់ មិនមែនជា ភាពទន់ខ្សោយ នោះទេ។ កិរិយាបថស្ងប់មួយ នៅគ្រប់ពេលតែងតែបង្ហាញពីមនុស្សម្នាក់ដែលមានការអប់រំ ។នេះមិនមែនជាការលំបាកពេកទេចំពោះមនុស្ស ដែលត្រូវ ស្ងប់ ពេល វត្ថុ នានា មានលក្ខណៈគួរជាទីពេញចិត្ត ប៉ុន្តែត្រូវតាក់តែង ឡើងពេលវត្ថុនានា នឹងប្រព្រឹត្តទៅដោយមិនត្រឹមត្រូវមានលក្ខណៈ លំបាកជាការពិតនោះ ហើយគឺជា គុណភាព លំបាកដែលជាការសម្រេចបានដោយមាន តម្លៃ ចំពោះ ភាពស្ងប់ និងការគ្រប់គ្រងបែបនេះ គេបានស្ថាបនានូវភាពរឹងមាំនៃអត្តចរិត។ វាជាការនឹកស្រមៃខុសថា មានតែពួកគេទេដែល រឹងមាំ ហើយនឹងមាន អំណាច ដែល ឡូឡា ប៉ប៉ាច់ប៉ប៉ោច និងរវល់ហួសពេកនោះ។

**ចូរប្រព្រឹត្តដោយវៃឆ្លាត** (Act wisely)

មនុស្សត្រូវតែដឹងថា តើត្រូវប្រើយុវវ័យ ទ្រព្យ អំណាច ថាមពល និង ចំណេះដឹង របស់គេនៅក្នុងឱកាសសមរម្យ មួយទីកន្លែងសមរម្យ និងនៅក្នុងសុខុមាលភាព របស់អ្នកដទៃ។ មនុស្ស ត្រូវរឹងមាំឱ្យបានគ្រប់គ្រាន់ ដើម្បីដឹងពេលគេចុះទន់ខ្សោយ ត្រូវក្លាហានឱ្យបានគ្រប់គ្រាន់ដើម្បីប្រឈមទល់នឹងសេចក្ដីភ័យខ្លាចមោទនភាព នឹងមិនផ្លាស់ប្ដូរនៅក្នុងជោគជ័យស្មោះត្រង់ ឱន លំទោន និងសុភាពរាបសានៅក្នុងជោគជ័យ។

មនុស្សមួយចំនួនតាមរយៈសំណាងភ្លាមៗទទួលបានលុយមួយចំនួនធំឬត្រូវបានគេឧបត្ថម្ភទ្រព្យសម្បត្តិមួយចំនួន ឬពួកគេអាចទទួលមរតក ការចែកទ្រព្យសម្បត្តិមួយចំណែកពីឪពុកម្ដាយ របស់គេ ប៉ុន្តែក្នុងចំណោមពួកគេ មានតែពីរបីនាក់ ប៉ុណ្ណោះដែលដឹងថាត្រូវ ការពារនិងថែរក្សា ទ្រព្យសម្បត្តិដែលទើបតែទទួលបានថ្មីៗឱ្យនៅគង់វង្សបាន។ តាមធម្មតា ទ្រព្យសម្បត្តិដែលទទួល បានដោយងាយៗ ដោយគ្មានការខំប្រឹងប្រែងធ្វើការងារ ដោយផ្ទាល់របស់គេ គ្មានតម្លៃពិតប្រាកដ នោះទេ។ ដូច្នេះពួកគេចាប់ ផ្ដើមចំណាយលុយទៅលើវត្ថុ មិនចាំបាច់ៗជាច្រើន ហើយមិនយូរ ប៉ុន្មានទ្រព្យសម្បត្តិ ទាំងមូលនឹងត្រូវ ចាយវាយខ្ជះខ្ជាយអស់។ មនុស្សត្រូវតែយល់ថាតើត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរបស់គេដោយមិនខ្ជះខ្ជាយយ៉ាងដូចម្ដេច ហើយនឹងចំពោះថា ពួកគេត្រូវ ប្រើគំនិតវិនិច្ឆ័យតិចតួចរបស់គេ។

## ចូរថ្លឹងថ្លែងដោយខ្លួនយើង (Adjust Ourselves)

យើងកំពុងតែរស់នៅនៅក្នុងពិភពប្រែប្រួលមួយ។ ប៉ុន្តែមានមនុស្ស តិចតួចណាស់ ដែលយល់ច្បាស់ពីការពិតនេះ។ គេមិនគួរប្រកាន់ខ្ជាប់ប្រពៃណី ទំនៀមទម្លាប់ ឬកពា ទម្លាប់ និង ជំនឿ ដែលចាស់បុរាណបានបន្សល់ទុកឱ្យហើយនឹងបុព្វបុរសដែលបានគិតថា គេគួរតែដើរ តាមប្រពៃណីទាំងនោះដោយខ្ជាប់ខ្ជួននោះទេ។ ប្រសិនបើគេមានចិត្តចង្អៀត ពេកនៅពេលនោះ សង្គមរបស់យើងនឹងមិនមានការរីកចម្រើនលូតលាស់ឡើយ។ ក្នុងចំណោមប្រពៃណី ទាំងនោះ អាច មានប្រពៃណីមួយចំនួនល្អប៉ុន្តែគេត្រូវខំគិតពិចារណាថា តើប្រពៃណីទំនៀមទម្លាប់ទាំងនោះបានបន្ត ពីសម័យបុរាណមានលក្ខណៈ សមស្រប ចំពោះសង្គមទំនើបយ៉ាងដូចម្ដេច ?

ម្យ៉ាងវិញទៀតឪពុកម្ដាយនិងមនុស្សចាស់ៗ មានការប៉ះទង្គិចជាមួយជំនាន់ក្មេងៗ។ ពួកគេចង់មើលកូនចៅរបស់ពួកគេ គោរពតាមប្រពៃណីទំនៀមទម្លាប់ដូចគ្នា។ តែទោះជាយ៉ាងណា ក៏ដោយនេះមិនមែនជាឥរិយាបថ ដ៏ល្អមួយសម្រាប់ទទួលយកនោះទេ។ សូមទុកឱ្យក្មេងៗធ្វើដំណើរទៅតាមសម័យកាល របស់គេទៅចុះប្រសិនបើវាមិនជាការជំទាស់ទេនោះ។ ឪពុកម្ដាយ គ្រាន់តែនៅចាំបានថា តើ ឪពុកម្ដាយ របស់ពួកគាត់បានជំទាស់នឹង វិធីរស់នៅទំនើបជាក់ស្ដែង ដែលរាលដាលដែលពួកគាត់នៅក្មេងយ៉ាងដូចម្ដេច? ការប៉ះទង្គិចនេះរវាងមនុស្សអភិរក្ស និង ជំនាន់ក្មេងៗ មិនមែនជាឥរិយាបថមានសុខុមាលភាពពេកសម្រាប់ការចម្រើនជឿនលឿន របស់សង្គមនោះទេ។ តាមពិតទៅប្រសិនបើក្មេងៗដើរលើផ្លូវខុស ទៅតាម មគ្គុទេសន៍ទំនើប ខុស នៅពេល នោះឪពុកម្ដាយ គួរផ្ដល់ដំបូន្មាន និង បង្ហាញផ្លូវពួកគេ។

អ្នកត្រូវតែរៀនថាតើត្រូវអត់ឱនចំពោះ ទស្សនៈ និង ប្រពៃណី របស់អ្នកដទៃយ៉ាងណា បើទោះជាយើងមិនពេញចិត្តនឹងវាក៏ដោយ។ ការអត់ឱន មិនមែនមានន័យថា អ្នកត្រូវតែដើរតាម វិធីរបស់គេនោះទេ ប៉ុន្តែអ្នកត្រូវខិតខំព្យាយាមយល់ពីហេតុដែលគេអនុវត្តវា។

មនុស្សម្នាក់ៗគឺជាផ្នែកមួយនៃ ពិភពមនុស្ស ហើយពួកគេម្នាក់ៗត្រូវមាន ទំនួលខុសត្រូវចំពោះអ្វីដែលបន្ត នៅក្នុងវា។ ពួកគេត្រូវតែខ្វល់ខ្វាយថាតើ សង្គមត្រូវមាន មនុស្សធម៌ ដែរឬទេ។ គេត្រូវតែសួរពីអ្វីដែលគេកំពុងធ្វើ ដោយខ្លួនគេដើម្បីនាំមកនូវ សណ្ដាប់ធ្នាប់វត្ថុ កាន់តែប្រសើរឡើង។ នេះគឺជា ទស្សនៈសីលធម៌ដែល ជីវិតត្រូវទទួល យកទិដ្ឋភាពធ្ងន់ធ្ងរមួយ ហើយដែលគេត្រូវផ្ដល់ឱ្យនូវ គ្រឿងលើកទឹកចិត្តមួយ។ ជីវិត បែបនេះគឺជា ជីវិតមានសុភមង្គលពិត

ប្រាកដ។ នៅពេលនោះយើងអាចអាក់អន់ស្រពន់ចិត្តដោយស្ថាបនាជាមួយនឹង សណ្ដាប់ធ្នាប់វត្ថុបច្ចុប្បន្ន ហើយប្រព្រឹត្តទៅដោយរីករាយដើម្បីធ្វើអ្វីមួយអំពីវា។

**បរិយាកាសសុខភាព** (Healthy Atmosphere)

ទោះជាយ៉ាងណាក៏ដោយភាពល្ងីងជូរចត់អាចជាការនិយាយកំប្លែងហើយនិងការកត់សំគាល់ ដែលបានដឹកនាំទៅរកអ្នកដោយ អ្នកដទៃ ដូចជា មនុស្សឆ្លាតម្នាក់ ដែលអ្នកក៏ត្រូវតែឆ្លើយទៅពួកគេដោយការនិយាយកំប្លែងមួយទៀតដោយគ្មានការបង្កើតបរិយាកាសសុខភាពអ្វីសោះ។

ពេលអ្នកលេង ល្បែង សូមកុំបង្ហាញពី អារម្មណ៍របស់អ្នកឱ្យសោះប្រសិនបើអ្នកចាញ់វា តាមរយៈការធ្វើបែបនេះ អ្នកមិនត្រឹមតែបង្ខូចដល់សេចក្តីសប្បាយរបស់អ្នកដទៃប៉ុណ្ណោះទេ ប៉ុន្តែអ្នកមានបំណងបញ្ចប់ការចាញ់ល្បែងទាំងស្រុងទៀតផង។ អ្នកមិនអាចព្យាយាមកែប្រែមនុស្សម្នាក់ៗនៅក្នុងលោកនេះ ដើម្បីសម្រេចឱ្យបានសន្តិភាពទៅតាម បែបដូចគ្នាដូចអ្នកមិនអាច រំកិលពិភពថ្ម (the world of stones)និង បន្លា(thorns)ដើម្បីធ្វើដំណើរដោយរលោងស្រិល នោះបានទេ។ អ្នកដែលប្រាថ្នាចង់ធ្វើដំណើរលើ ដីរលោងត្រូវតែពាក់ ស្បែកជើងទើបបាន ដូចគ្នានេះដែរអ្នកដែលចង់បាន ចិត្តស្ងប់(peace of mind) អ្នកនោះត្រូវតែដឹងថា តើត្រូវការពារឥន្ទ្រីយារម្មណ៍ទាំង៥ នោះយ៉ាងដូចម្តេច។

មានវិធីផ្សេងៗជាច្រើនដែលត្រូវកែប្រែមនុស្សម្នាក់ប្រសិនបើអ្នកនោះខុស។ តាមរយៈការរិះគន់ការស្តីបន្ទោសនិង ស្រែកគំហកដាក់គាត់ជាសាធារណៈ អ្នកមិនអាចកែប្រែអ្នកនោះបាន ទេអ្នកត្រូវតែដឹងថាតើត្រូវកែប្រែ គាត់ដោយមិនមានបន្ទុះបង្អាប់គាត់យ៉ាងដូចម្តេច។ មនុស្សជា ច្រើនបានបង្កើតសត្រូវជាច្រើនតាមរយៈ ការរិះគន់ទៅលើ អ្នកដទៃនេះឯង។ ប្រសិនបើគេអាចឱ្យដំបូន្មានមនុស្សម្នាក់ដោយស្រឡាញ់ដោយមានបំណងចង់កែគេឱ្យល្អគេនឹងពិតជាស្តាប់អ្នក ហើយនៅថ្ងៃណាមួយ អ្នកនោះនឹងអរគុណអ្នកចំពោះការបង្ហាញផ្លូវ និងសន្តានចិត្តដ៏ល្អរបស់ អ្នក។

នៅពេលណាអ្នកសម្តែងពី ទស្សនៈរបស់អ្នកចំពោះបញ្ហាជាក់ស្តែង ជានិច្ចកាលតែងខិតខំព្យាយាមប្រើពាក្យដែលមិនប៉ះពាល់ដល់អារម្មណ៍របស់អ្នកដទៃ។ មានវិធីសម្តែងទស្សនៈរបស់អ្នកទៅតាមបែបផ្សេងៗ ទោះដោយ សុភាពរាបសាឬដោយគួរសម ឬដោយការទូត។

អ្នកមិនគួរធ្វើឱ្យ អារម្មណ៍របស់អ្នកបាត់បង់ឡើយ ពេលគុណវិបត្តិរបស់អ្នកត្រូវបានគេលើកបង្ហាញឡើង។ អ្នកអាចគិតថា តាមរយៈការបង្ហាញ អារម្មណ៍និងការ ស្រែកគំហកដាក់

អ្នកដទៃអ្នកអាចសង្កត់ចិត្ត ឬយកឈ្នះលើ គុណវិបត្តិរបស់អ្នកឱ្យបាន។ វាគឺជា កំហុសនិង ឥរិយាបថខុសដែលត្រូវទទួលយក។

អ្នកមិនគួរបរិហារពី អាថិកំបាំងផ្ទាល់ខ្លួនរបស់ មិត្តចាស់ដែលគេទុកចិត្តចំពោះអ្នកនោះ ឡើយ បើទោះជាអ្នកមិន ស្ថិតនៅក្នុងលក្ខខណ្ឌល្អជាមួយគេក៏ដោយ។ ប្រសិនបើអ្នកធ្វើបែប នេះ អ្នកដទៃនិងមើលស្រាលដល់អ្នក ហើយមិនទទួល យកអ្នកជា មនុស្សស្មោះត្រង់ឡើយ។

**ចូរកុំមានចិត្តលំអៀង** (Be Unbiased)

អ្នកមិនគួរសម្រេចចិត្តលឿនពេកចំពោះបញ្ហាណាមួយ ពេលអ្នកកំពុងមាន អារម្មណ៍មិន ល្អ ឬពេលអ្នកណាម្នាក់ រករឿងអ្នកនោះឡើយ សូមកុំធ្វើជាដាច់ខាតបើទោះជាអ្នកកំពុងមាន អារម្មណ៍ល្អដែលបានទទួលឥទ្ធិពលដោយ ការរំជួលចិត្តក៏ដោយ ពីព្រោះនៅក្នុងពេលបែបនេះ សភាពចិត្តរបស់អ្នកកំពុងតែរំជួល ហើយការសម្រេចចិត្តឬ សេចក្តីសន្និដ្ឋានណាមួយ ដែលបាន ចាប់បានអំឡុងពេលស្ថានភាពមួយបែបនេះគឺជាបញ្ហាមួយ ដែលអ្នកអាចនឹងស្តាយក្រោយ នៅ ថ្ងៃណាមួយ។ សូមបណ្តោយឱ្យ ចិត្ត របស់អ្នកស្ងប់ជាដំបូងសិន ហើយគិតដោយហ្មត់ចត់លើវា បន្ទាប់មកការវិនិច្ឆ័យ របស់អ្នកនឹងជា ការវិនិច្ឆ័យមួយមិនលំអៀង។

សូមអប់រំ ការអត់ឱនព្រោះ ការអត់ឱននេះជួយអ្នកឱ្យជៀសផុតពី ការវិនិច្ឆ័យលឿន ពេក ត្រូវមានសមាន ចិត្តជាមួយនឹង បញ្ហារបស់មនុស្សដទៃ ត្រូវជៀសវាង ការរិះគន់ចាប់ កំហុសត្រូវយល់ឱ្យច្បាស់ថា មនុស្សល្អបំផុត មិនមែនមិនចេះភ័ន្តច្រឡំនោះទេ ភាពខ្សោយ ដែលរក ឃើញនៅក្នុង អ្នកជិតខាងរបស់អ្នកអាចនឹងត្រូវរកឃើញនៅ ក្នុង ខ្លួនរបស់អ្នកដែរ។

**មនុស្សធម៌** (Humanity)

មនុស្សធម៌គឺជា ម៉ែត្រវាស់(measuring-rod) របស់ មនុស្សឆ្លាតសម្រាប់សិក្សាទៅលើ ភាពខុសគ្នារវាងអ្វី ដែលមាននិងអ្វីដែលមិនទាន់មាននៅឡើយ។ "ព្រះពុទ្ធទ្រង់ត្រាស់សម្តែង ដោយព្រះអង្គឯង អ្នកបម្រើ(ministry) របស់គាត់ដោយការបោះបង់ចោល អំណួតជាព្រះអង្គ ម្ចាស់របស់ទ្រង់នៅក្នុង អំពើមនុស្សធម៌។ ព្រះអង្គបានសម្រេច ព្រះអរហន្តនៅក្នុងឆាក ជីវិត របស់ព្រះអង្គ ប៉ុន្តែទ្រង់មិនដែលបាត់បង់ពី ភាពធម្មជាតិ(naturalness)ហើយក៏មិន ដែលគិត ស្មានថាជា ភារៈកំពូល (assume superior airs)នោះដែរ។ ការអធិប្បាយនិង ឧបមាកថា (parable) របស់ព្រះអង្គមិនដែលក្រអឺតក្រទមនោះដែរ។ ព្រះអង្គមានពេលសម្រាប់បន្ទាប មករក មនុស្សនានាបំផុត។ ព្រះអង្គមិន ដែលវង្វេងស្មារតីអ្វីឡើយ"។

**ចូរកុំខ្ជះខ្ជាយពេលវេលារបស់អ្នក** (Don’t Waste Your Time)

ដើម្បីបំផ្លាញ អត្ថិភាពរបស់ មនុស្សម្នាក់នៅក្នុងការព្រួយចិត្តទៅលើ អតីតកាល នៅក្នុងសេចក្តីខ្ជិលច្រអូសការធ្វេសប្រហែសគឺត្រូវសម្តែងពីភាពមិនសមរម្យរបស់គេសម្រាប់ កន្លែងប្រសើរៗ ដែលគេនៅបែបនេះអញ្ជើញ bad kamma របស់គេដាក់ឱ្យនៅឆ្ងាយ ពីគេចំពោះទីកន្លែងមួយ សមទៅនឹងភាពមិនមានតម្លៃរបស់គេ។ សូមគិតពីរឿង នេះយ៉ាងខ្លាំងនៅក្នុងចិត្តរបស់អ្នក ហើយសូមធ្វើល្អនៅពេល ជីវិតអ្នកឈានដល់ទីបំផុត។ ដោយ ការខ្ជះខ្ជាយពេលវេលារបស់អ្នក អ្នកធ្វើឱ្យខូចខាតមិនត្រឹមតែទៅលើខ្លួនអ្នកនោះប៉ុណ្ណោះទេ ប៉ុន្តែក៏ធ្វើឱ្យខូចដល់អ្នកដទៃទៀតផង ពីព្រោះពេលវេលារបស់អ្នកដទៃក៏ដូចជារបស់អ្នកដែរ។

**ចិត្តខន្តីនិងការអត់ធ្មត់** (Patience and Tolerance)

សូមខន្តីជាមួយនឹងអ្វីៗសព្វយ៉ាង។កំហឹងបានដឹកនាំគេតាមរយៈព្រៃគ្មានផ្លូវ(a pathless jungle)។ ខណៈពេលវាធ្វើឱ្យអ្នកដទៃខឹងក្តៅក្រហាយ វាក៏ធ្វើឱ្យខ្លួនគេនោះឈឺក្តៅក្រហាយដែរ។ វាធ្វើឱ្យ ខ្លួនប្រាណ (the physical frame) ចុះខ្សោយ និងរំខានដល់ចិត្ត។ ពាក្យល្វីងជូរចត់ប្រៀបដូចព្រួញមួយបាញ់ចេញពីធ្នូ មិនដែលវិលត្រឡប់មកវិញទេ បើទោះជាអ្នកចាញ់មួយពាន់ព្រួញក៏ដោយ។

*សត្វលោកមិនអាចមើលឃើញនៅពេលថ្ងៃ នៅពេលអ្នកដទៃមួយចំនួនទៀត ងងឹតនៅពេលយប់។ ប៉ុន្តែមនុស្សម្នាក់ ដែលគេបាននាំទៅដល់សេចក្តីស្អប់កំពូល (great heights of hatred) ហើយមិនដែលសង្កេតមើលអ្វីឡើយ។ ទោះថ្ងៃ ឬ យប់ក៏ដោយ។*

ពេលអ្នកខឹងតើអ្នកវាយជាមួយអ្វី និងជាមួយអ្នកណា? អ្នកត្រូវវាយខ្លួនអ្នក ព្រោះអ្នកគឺជាសត្រូវដ៏អាក្រក់បំផុត របស់អ្នក។ ចិត្តគឺជា មិត្តដ៏ល្អបំផុតហើយក៏ជា បច្ចាមិត្រដ៏គំរក់របស់អ្នកដែរ។ អ្នកត្រូវតែខិតខំព្យាយាមសម្លាប់ ចំណង់ត្រេកត្រអាលនឹងកាមតណ្ហា សេចក្តីស្អប់និង អវិជ្ជាដែលនៅលាក់ពួននៅក្នុង ចិត្តរបស់អ្នកដោយ សីលសមាធិនិង បញ្ញា។

ភាពខុសគ្នានៃ បញ្ហាបេះដូងរោគសន្លាក់ឆ្អឹង (rheumatic disorders) និង រោគស្បែកសុទ្ធតែអាចប្រាប់បានពី ភាពល្វីងជូរចត់ត្រាំត្រែង ការស្អប់និងការច្រណែនឈ្នានីស។ អារម្មណ៍មហន្តរាយបែបនេះបំពុលបេះដូង។ ពួកវាចិញ្ចឹមរក្សាដំណើរីកចម្រើននៃ និន្នាការជម្ងឺលាក់កំបាំងនិងបង្កឱ្យ ជម្ងឺកើតឡើង។

**ការយកអំពើល្អទៅជំនួសអំពើអាក្រក់** (Returning Good for Evil)

ប្រសិនបើអ្នកចង់កម្ចាត់ សត្រូវ របស់អ្នកជាដំបូងអ្នកត្រូវរំលត់ កំហឹងរបស់អ្នកសិន ដែលជា សត្រូវធំបំផុត នៅក្នុងចិត្តអ្នក។

ក្នុងន័យម្យ៉ាងទៀតប្រសិនបើអ្នកត្រូវខូចចិត្តដោយស្តាប់សត្រូវមានន័យថា អ្នកកំពុងតែ បំពេញ បំណងប្រាថ្នា របស់ សត្រូវដោយចូលទៅក្នុង អន្ទាក់របស់គេដោយឥតដឹងខ្លួន។

អ្នកមិនគួរគិតថា អ្នកអាចរៀនសូត្រអ្វីមួយតែមកពីអ្នកដែលលើកសរសើរនិងជួយ និង សេពគប់ជាមួយអ្នកដោយស្និទ្ធបំផុតនោះទេ។មានវត្ថុជាច្រើនដែលអ្នកអាចរៀនសូត្រពី សត្រូវ របស់អ្នក។អ្នកមិនគួរគិតថា ពួកគេខុសទាំងស្រុងដោយគ្រាន់តែពួកគេកើតទៅជា សត្រូវរបស់ អ្នកនោះទេ។ ពួកគេក៏អាចមាន គុណសម្បត្តិល្អពិតប្រាកដនោះដែរ។

អ្នកមិនអាចកម្ចាត់ សត្រូវរបស់អ្នកដោយការយក អាក្រក់ទៅសង អាក្រក់នោះបាន ទេ។ ប្រសិនបើអ្នកធ្វើបែបនេះមែននៅពេលនោះអ្នកកាន់តែបង្កើតសត្រូវបន្ថែមតែប៉ុណ្ណោះ។ វិធីយកឈ្នះលើសត្រូវរបស់អ្នកដែលប្រសើរនិងត្រឹមត្រូវបំផុតនោះគឺដោយការបំភ្លឺចិត្តសប្បុរស របស់អ្នកចំពោះពួកគេ។ អ្នកអាចគិតថា នេះមិនអាចប្រព្រឹត្តទៅ បាន ឬអ្វីមួយចោលម្សៀត។ ប៉ុន្តែវិធីនេះ គ្រប់មនុស្សដែលមាន ការអប់រំបានឱ្យតម្លៃខ្ពស់បំផុត។ ពេលអ្នកចាប់ផ្តើម ដឹងថា មានអ្នកណាម្នាក់ដែលខឹងជាមួយនឹងអ្នកយ៉ាងខ្លាំង ជាដំបូងអ្នកគួរតែខិតខំរកឱ្យឃើញពី ហេតុ ចម្បងនៃកំហឹងនោះ។ ប្រសិនបើវាព្រោះតែកំហុសរបស់អ្នកអ្នកត្រូវតែព្រមទទួលយក ហើយ អ្នកមិនគួរស្ទាក់ស្ទើរនឹងសុំទោសគេទេ។ ប្រសិនបើវាព្រោះតែ ការយល់ខុសដោយពិតប្រាកដ រវាងអ្នកទាំងពីរ អ្នកត្រូវតែជជែកគ្នាដោយស្មោះត្រង់ បើអ្នកណាមួយខុសឬត្រូវហ៊ានទទួល យកដោយក្លាហាន។ ប្រសិនបើវាព្រោះតែការច្រណែនឬព្រោះតែអារម្មណ៍រំជួល ខ្លាំងអ្នកត្រូវ តែខិតខំព្យាយាមបំភ្លឺ ចិត្តសប្បុរសរបស់អ្នកចំពោះគេដោយហេតុថា អ្នកនឹងមានលទ្ធភាព ជះឥទ្ធិពលទៅគេតាមរយៈថាមពលខួរក្បាលអ្នក។ អ្នកអាចមិនមានលទ្ធភាពយល់បានថាតើវា ធ្វើការយ៉ាងណា ប៉ុន្តែបទពិសោធន៍របស់មនុស្សជាច្រើនបង្ហាញថា នេះគឺជាវិធីងាយស្រួល, ឆ្លាតវាងវៃនិងមានកម្លាំងបំផុតដែលគេបានឱ្យអនុសាសយ៉ាងខ្ពស់បំផុតនៅក្នុងព្រះពុទ្ធសាសនា ។តាមពិតទៅដើម្បីធ្វើបែបនេះបាន អ្នកត្រូវតែមានទំនួលខុសត្រូវនិងមានចិត្តខន្តីនៅក្នុងខ្លួន។ តាមរយៈការធ្វើបែបនេះ អ្នកនឹងមានលទ្ធភាពធ្វើឱ្យ សត្រូវរបស់អ្នកយល់ថា គេ កំពុងស្ថិតនៅ

ក្នុង កំហុសក្រៅពីនេះអ្នកក៏ទទួលបានប្រយោជន៍ទៅតាមវិធីផ្សេងៗ ដោយមិនទុកឱ្យកំហឹងមាននៅក្នុងចិត្តរបស់អ្នកឡើយ។

ប្រសិនបើគេមិនអាចយក អំពើល្អ ទៅជំនួស អំពើអាក្រក់ទេ សូមកុំយកអំពើ អាក្រក់ទៅសងអំពើ អាក្រក់ ឱ្យសោះ។

**ចូរមានចិត្តមេត្តា** (Loving-kindness)

ដរាបណាមានមនុស្សឯកោ (one single fellow creature) អ្នកលួងលោមគេដោយសម្តីសប្បុរស អ្នកអាចធ្វើឱ្យគេសប្បាយបាន វត្ថុមានរបស់អ្នកត្រូវគេអបអរសាទរអ្នកអាចជួយបណ្តោះទ័លគេបានដោយសម្បត្តិលោកិយ តែទោះជាយ៉ាងណាក៏ដោយកង្វះខាត ដែលការធ្វើទានអាចជួយបាននោះ អ្នកគឺជា ទ្រព្យមានតម្លៃមួយចំពោះ ពូជមនុស្ស ហើយអ្នកមិនមាន ការ ខូចចិត្ត ឬមានទុក្ខក្រៀមក្រំឡើយ។

មានពេលជាច្រើនគឺពេលដែលអ្នកបានស្រឡាញ់គេ គេហាក់ដូចជាមិនខ្វល់ខ្វាយចំពោះអ្នកទេ ហើយអ្នកហាក់ដូចជា មានអារម្មណ៍ធ្ងន់ធ្ងរនៅក្នុងចិត្ត។ ប៉ុន្តែគ្មានហេតុផលត្រឹមត្រូវសម្រាប់ទុក្ខព្រួយនោះទេ។ តើវាមានបញ្ហាអ្វីប្រសិនបើ អ្នកដទៃមិនដឹងគុណចំពោះអ្នក ឬមិនខ្វល់ចំពោះអ្នកវិញនោះដរាបណាអ្នកដឹងថាអ្នកពេញទៅដោយក្តីស្រឡាញ់ (Tend-er-heartedness) ចំពោះអ្នកដទៃពេញទៅដោយមេត្តាធម៌ចំពោះមនុស្សដែលជាមិត្តរបស់អ្នកហើយនោះ? គេមិនគួរពឹងផ្អែកទៅលើអ្នកដទៃ ព្រោះតែសុភមង្គលរបស់គេនោះឡើយ។ *អ្នកដែលសង្ឃឹមថា នឹងទទួលបាននូវការបំពេញនៅក្នុង ជីវិតពីអ្នកដទៃ អ្នកនោះអន់ជាងអ្នកសុំទាន ដែលលុតជង្គង់ហើយស្រែកយំទារនំប៉័ងប្រចាំថ្ងៃ របស់ពួកគេទៅទៀត។*

**ចូរទប់ខ្លួនពីថ្នាំពុល** (Refrain from Intoxicants)

ព្រះពុទ្ធទ្រង់ហាមយើងទាំងអស់គ្នាឱ្យការពារខ្លួនពីថ្នាំពុលនានា ដែលជាសិក្ខាបទមួយក្នុងចំណោមសិក្ខាបទរបស់យើង។ មានហេតុផលជាច្រើនចំពោះហេតុ ដែលយើងត្រូវគោរពតាមសិក្ខាបទ។ កវីល្បីឈ្មោះម្នាក់បានផ្តល់ហេតុផល របស់គេចំពោះហេតុដែលយើងគួរការពារខ្លួនពីថ្នាំពុលនេះ។ ហេតុផលទាំងនេះរួមមាន :

**ភាពស្រវឹង** (Drunkenness)

ភាពស្រវឹងធ្វើឱ្យបាត់បង់ វិចារណញ្ញាណ (Drunkenness expels reason) បាត់បង់ការចងចាំ (Drowns memory) ខូច ខួរក្បាល (Defaces the brain) ចុះ ទន់ខ្សោយ (Diminishes

strength) ធ្វើឱ្យឈាមក្ដៅ (Inflames the blood)បណ្ដាលឱ្យ ឈឺមើលមិនជា ទាំងកាយនិងចិត្ត (Causes incurable external and internal wounds) ជា មេមត (witch) ដល់រូបកាយ (Is a witch to the body) ខ្មោចបិសាចមានដល់ ចិត្ត (A devil to the mind) ចោរឃ្លួញលួចការបូប (A thief to the purse) ស្នូមយាចកផ្ទេចផ្ដាស់សារ (The beggar's curse) ទុក្ខសោកដល់ ភរិយា (The wife's woe)ទុក្ខវេរាដល់ បុត្រធីតា (The children's sorrow) រូបភាពសត្វតិរច្ឆាន (The picture of a beast) ហើយក៏ ធ្វើអត្តឃាត (And self murder) អ្នកណាផឹកដល់ សុខភាពអ្នកដទៃ (Who drinks to other's health) ហើយប្លន់ ទ្រព្យខ្លួនឯង (And robs himself of his own) លទ្ធផលចុងក្រោយ របស់វា គ្មានអ្វីក្រៅពី ទុព្វលភាពសីលធមិ និង រូបកាយទាំងស្រុង។

**គ្រោះថ្នាក់នៃគ្រឿងញៀន** (The Drug Menace)

អាល់កុលត្រូវបានរាប់ថាជា ហេតុសំខាន់មួយក្នុងចំណោមហេតុសំខាន់ៗចំពោះ ទុព្វលភាពសីលធមិនិងរូបកាយរបស់មនុស្ស។ ថ្មីៗនេះទម្រង់បោកបញ្ឆោតដ៏សាហាវមួយទៀតពោលគឺទម្រង់ថ្នាំញៀនគ្រោះថ្នាក់និងឱ្យទុក្ខទោសដែលគេដាក់នៅក្នុងថ្នាំហេរ៉ូអ៊ីនហ៊ែស៊ីស្ហ(hashish) ហើយនិងទម្រង់ខុសៗគ្នាដទៃទៀតបានបង្ហាញពី ក្បាលដ៏អាក្រក់របស់វា (its ugly head) ដែលបណ្ដាលឱ្យមានបញ្ហាសង្គមនិង មនុស្សយ៉ាងធ្ងន់ធ្ងរដល់សុខុមាលភាពមនុស្សធមិ។ ឥឡូវនេះបញ្ហានេះរាលដាលពាសពេញពិភពលោក។ ផលរបស់វាមានលក្ខណៈធ្ងន់ធ្ងរ និងស្លាប់រស់ជាងផលនៃអាល់កុលទៅទៀត។ ចោរកម្ម ចោរប្លន់ ឧក្រិដ្ឋកម្មផ្លូវភេទនិង ការបោកប្រាស់ទ្រង់ទ្រាយធំ (swindling of vast មាងនិតុដចេបានកើតមានឡើងព្រោះ ហេតុតែឥទ្ធិពល គ្រោះថ្នាក់របស់ថ្នាំញៀន។ ឃាតករត្រូវបានប្រព្រឹត្តហើយក្រុមគ្រួសារត្រូវបានសម្លាប់ដោយមនុស្សញៀនថ្នាំ។ មនុស្សញៀនថ្នាំក្លាយទៅជា ជនរង គ្រោះកើត ជម្ងឺអេដស៍។

រដ្ឋាភិបាលបានចំណាយ ថវិកា ដែលរកបានមកដោយលំបាករាប់លានគណនា មិនបានទូទាំងពិភពលោកដើម្បី ជួយដល់ អ្នកញៀនថ្នាំដែលមានទម្លាប់សាហាវឃោរឃៅ និងដើម្បីធ្វើឱ្យ ពួកគេបានល្អឡើងវិញប៉ុន្តែការខូចសតិ ខឹងមួរម៉ៅនៅមិនបាត់។ វាគឺជាករណីយកិច្ចកំណត់របស់យើងដែលជាពលរដ្ឋមានទំនួលខុសត្រូវ ដើម្បីជួយទោះនៅក្នុង ឥរិយាបថបែបណាតាមតែយើងអាចធ្វើបានតាមរយៈ អង្គការសង្គមនិង សាសនាដើម្បីបំបាត់ ទម្លាប់គួរឱ្យខ្លាចនិង គួរ

ឱ្យខ្ចីមនេះ និងដើម្បីការពារបុត្រធីតារបស់យើងឱ្យនៅឆ្ងាយពីវា។ ជីវិតជា មនុស្សញៀនថ្នាំម្នាក់គឺជា ជីវិតមានទណ្ឌកម្មនិង នរកនៅលើផែនដី ដឹកនាំទៅរក ផ្នូរខ្មោចមុនគេ។

ជា មនុស្សលោកយើងត្រូវមានលទ្ធភាពធ្វើលំហាត់ ស្ម័យគ្រប់គ្រងរបស់យើង និងបែងចែក រវាងអ្វីដែល ល្អនិងអ្វីដែល អាក្រក់។ គេចឱ្យផុតពី ការគំរាមកំហែងគ្រឿងញៀន ហើយនិងជួយអ្នកដទៃឱ្យធ្វើដូច្នេះដែរ។ នោះគឺ ជាសេវាដ៏ធំបំផុតចំពោះ មនុស្សធម៌។

**អ្នកកសាងឋានសួគ៌និងឋាននរកនៅទីនេះ** (You Create Heaven and Hell Here)

ប្រសិនបើអ្នកចង់រស់នៅនៅក្នុងលោកនេះដោយសុខសាន្ត និងដោយសុភមង្គល សូមឱ្យអ្នកដទៃ ក៏រស់នៅដោយសុខសាន្ត និងដោយសុភមង្គលដូច្នេះដែរ ដើម្បីឱ្យអ្នកមានលទ្ធភាពធ្វើឱ្យ ជីវិតជាតិនេះគឺអ្វីមួយដែលមានតម្លៃនៅលើ ផែនដីដែលអ្នករស់នៅ។ លុះត្រាតែអ្នកធ្វើឱ្យខ្លួនអ្នកបានល្អប្រសើរឡើង ដើម្បីរស់នៅដោយអនុលោមទៅតាម គោលការណ៍ប្រពៃៗទាំងនេះអ្នកមិនអាចសង្ឃឹមរង់ចាំសុភមង្គលនិងសន្តិភាពនៅក្នុងលោកនេះឡើយ ។អ្នកមិនអាចសង្ឃឹមរង់ចាំ សុភមង្គលនិង ភាពសុខសាន្តមកពី ឋានសួគ៌ដោយស្រួលៗតាមការ បួងសួងនោះឡើយ។ ប្រសិនបើអ្នកប្រព្រឹត្តដោយអនុលោមតាម គោលការណ៍សីលធម៌ អ្នកអាចកសាងឋានសួគ៌ផ្ទាល់ខ្លួនអ្នកដោយត្រឹមត្រូវនៅ ក្នុងលោកនេះនៅទីនេះបាន។ បើមិនមានទេ អ្នកក៏អាចមើលឃើញពី ភ្លើងនរក (the hell-fire) នៅលើផែនដីនេះដោយខ្លួនវា។ ដោយមិនបានយល់ដឹងថាតើត្រូវរស់នៅទៅតាម ក្រឹត្យក្រមធម្មជាតិ និង លោកធាតុនេះយ៉ាងដូចម្តេចនោះទេ យើងតែងតែរអ៊ូរទាំពេលបញ្ហាប្រឈមមុខ។ ប្រសិនបើ មនុស្សម្នាក់ៗ ខិតខំធ្វើឱ្យខ្លួនគេបាន ប្រសើរឡើងដោយមិនរអ៊ូរទាំនិងរិះគន់ អ្នកដទៃ យើងអាចសប្បាយរីករាយជាមួយនឹងបរមសុខឋានសួគ៌ដោយពិតៗល្អជាងបរមសុខដែលមនុស្សមួយចំនួនសុបិនឃើញពីការមានអត្ថិភាពនៅហួសដ៏វែងឆ្ងាយ។ គ្មានតម្រូវការដើម្បីកសាងឋានសួគ៌នៅទីណាមួយដើម្បីឱ្យគុណធម៌ជារង្វាន់ឬឋាននរកដើម្បីឱ្យបាបធម៌ជាទណ្ឌកម្មនោះទេ គុណធម៌និង បាបធម៌មានប្រតិកម្មមិនអាចជៀសរួចនៅក្នុងលោកនេះដោយខ្លួនឯង។ នេះគឺជាមាគ៌ាខ្ពស់បំផុត ដែលអ្នកអាចជួយនៅក្នុងសុខុមាលភាពសង្គមនិង ប្រទេសរបស់អ្នក។ សព្វថ្ងៃនេះសង្គមមនុស្ស បានអភិវឌ្ឍឈានទៅរកកម្រិតនេះ ដោយសារតែការ យល់ដឹង និងដំណើរស្របគ្នារបស់ មនុស្សមួយចំនួន ដែលមានសមានចិត្តនិង ការអត់ឱន ចំពោះ សុភមង្គលនិង ការចម្រើនលូតលាស់របស់ អ្នកដទៃ។

ម្យ៉ាង វិញទៀតអ្នកត្រូវតែយល់ថា ការជួយអ្នកដទៃដោយ សីលធម៌ពោល គឺអ្នកជួយ ខ្លួនឯងហើយ ដោយការជួយ ខ្លួនឯងដោយសីលធម៌អ្នកជួយអ្នកដទៃក៏ដូច្នោះដែរ។

**ជីវិតអាពាហ៍ពិពាហ៍មានសុភមង្គល** (Happy Married Life)

នៅក្នុងចំណងអាពាហ៍ពិពាហ៍មួយ បុរសនិងស្ត្រី គិតច្រើនអំពីភាពជាដៃគូ ជាងពួកគេគិតអំពីខ្លួនគេ ។ វាជាការវេញចំណាប់អារម្មណ៍បញ្ចូលគ្នា និងជាការប្រឈមមុខចំពោះការបូជាជីវិត ជាមួយគ្នាដើម្បីគ្នាទាំងពីរនាក់។ ការមានអារម្មណ៍សន្តិសុខមកពីការខំប្រឹងប្រែងចំពោះគ្នាទៅវិញទៅមក។

បញ្ហានិងកង្វល់ភាគច្រើនកើតមានឡើងរវាងប្តីនិងប្រពន្ធ ឪពុកម្តាយនិងកូន, សាច់ញាតរបស់ពួកគេ និងមិត្តភក្រ្ត ព្រោះតែការយល់ខុស និងការគ្មានខន្តីនេះឯង។ ប្តីមិនគួរប្រព្រឹត្តចំពោះប្រពន្ធជាទាសីនោះឡើយ។ បើទោះជាគេគឺជាអ្នក រកស៊ីចិញ្ចឹមគ្រួសារក៏ដោយ វាគឺជាករណីយកិច្ចរបស់គេ ពេលណាគេមានពេលទំនេរដើម្បីជួយប្រពន្ធនៅក្នុងកិច្ចការផ្ទះ ដែលជាទម្លាប់។ ម្យ៉ាងវិញទៀតជានិច្ចកាល មិនគួរនិយាយច្រំដែលៗរអ៊ូរទាំដាក់ប្តីខ្លួនឡើយ ពេលណាមានកង្វះខាតណាមួយនៅក្នុងផ្ទះ ។នាងក៏មិនគួរមានមន្ទិលសង្ស័យចំពោះប្តីនាងឡើយ ។ប្រសិនបើប្តីគាត់ពិតជាមានភាពទន់ខ្សោយមួយ ចំនួន នាងគួរតែកែប្រែគាត់ដោយនិយាយ ទៅរកគាត់ដោយចិត្តសប្បុរសបំផុត។ ភរិយាត្រូវតែអត់ឱនទៅលើរឿងរ៉ាវជា ច្រើនដោយគ្មានការរំលោភដល់ប្តីខ្លួនឡើយ។ ប្តីក៏ត្រូវប្រព្រឹត្តចំពោះនាងវិញដោយវៃឆ្លាត គ្មានការប្រព្រឹត្តទៅតាមវិធីបែបនេះចំពោះភរិយារបស់ខ្លួន គឺមិនមានការសង្ស័យ និងច្រណែនប្រច័ណ្ឌនឹងនាងឡើយ។

ចំណងអាពាហ៍ពិពាហ៍គឺជាមង្គលមួយប៉ុន្តែមនុស្សជាច្រើនបានត្រឡប់ជីវិតអាពាហ៍ពិពាហ៍របស់គេចូលទៅក្នុងការ ប្រមាថមើលងាយព្រោះតែកង្វះខាតការយោគយល់គ្នា ពោលគឺការអត់ឱននិងអធ្យាស្រ័យគ្នានេះឯង។ ភាពក្រីក្រមិន មែនជាហេតុចម្បងនៃជីវិត អាពាហ៍ពិពាហ៍អពមង្គលនោះឡើយ។ ប្តីនិងប្រពន្ធត្រូវតែរៀនចែករំលែកសុខទុក្ខរបស់គេនៅ ក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។ ការយោគយល់គ្នាទៅវិញទៅមកគឺជាកូនសោរ សំខាន់នៃជីវិតគ្រួសារមានសុភមង្គល។

**ទទួលយកការរិះគន់** (Accept Criticism)

*ភាពផ្អែមល្ហែម គឺជាជម្ងឺភាពល្វីងជូរចត់គឺជាឱសថ* ។ ការលើកសរសើរប្រៀបដូចជាបង្អែមដែលនាំឱ្យមានជម្ងឺ។ ហើយការរិះគន់ប្រៀបដូចជាថ្នាំល្វីងឬការចាក់ថ្នាំឈឺ មួយដែល

ព្យាបាលជំងឺ ។យើងត្រូវតែក្លាហានហ៊ានស្វាគមន៍ ចំពោះការរិះគន់មិនត្រូវខ្លាចរអានឹងវាឡើយ ។ "ភាពអាក្រក់យើងមើលមិនឃើញនៅក្នុងអ្នកដទៃគឺជាការឆ្លុះបញ្ចាំងអំពីធម្មជាតិផ្ទាល់របស់យើង ។"

ជីវិតឯកត្តភូតរបស់មនុស្សម្នាក់ ពោលគឺកាលៈទេសៈ និងពិភពលោកគឺជាការឆ្លុះបញ្ចាំងមួយអំពីកម្រិត និងជំនឿផ្ទាល់របស់គេ ។ មនុស្សគ្រប់រូបគឺជាកញ្ចក់ឆ្លុះបញ្ចាំង ដោយអនុលោមទៅតាមផ្ទៃមុខផ្ទាល់របស់គេ ។

**សូមគិតតែពីកិច្ចការផ្ទាល់របស់អ្នក** (Mind Your Own Business)

មិនថាល្អយ៉ាងណាប្រសិនបើអ្នកយកចិត្តទុកដាក់ចំពោះកិច្ចផ្ទាល់របស់អ្នកដោយគ្មានការជ្រៀតជ្រែកពីអ្នកដទៃ ។ នេះគឺជាដំបូន្មានដែលព្រះពុទ្ធទ្រង់បានផ្ដល់ : "គេមិនគួរគិតពីកំហុសរបស់អ្នកដទៃឡើយ របស់ដែលគេបានធ្វើ និងមិនបានធ្វើដោយអ្នកដទៃ ប៉ុន្តែអំពើផ្ទាល់ របស់គេចំពោះការប្រព្រឹត្តខុសឆ្គងនិងការបំភ្លេចចោល ។"

ព្រះពុទ្ធទ្រង់បានបន្ថែមថា "អ្នកដែលគោរពតាមកំហុសរបស់អ្នកដទៃ ហើយជានិច្ចកាលតែងតែឆេវឆាវអំពើប្រមាថផ្ទាល់របស់គេត្រូវរីកសាយ ។គេទៅឆ្ងាយពីការបំផ្លាញការប្រមាថ ។

ព្រះអង្គទ្រង់បន្តទៀតថា "ងាយនឹងមើលឃើញពីកំហុសរបស់អ្នកដទៃ ប៉ុន្តែពិបាក នឹងមើលឃើញពីកំហុសរបស់ខ្លួនផ្ទាល់ ។ គេអុំស្មែកំហុសអ្នកដទៃ ប្រៀបដូចអង្កាម ប៉ុន្តែកំហុសរបស់គេលាក់បំពួនដូចជា flower មានកិច្ចកល់គ្រប់លើខ្លួនគេ ។"

"ការដូរទិសដៅល្អប្រសើរ មិនមែនមកពីផ្លូវត្រូវនោះទេ បណ្ដាលឱ្យកើតឡើងនូវអ្វីដែលអាចហើយមិនយូរប៉ុន្មានចង់ បានសេចក្ដីរីករាយលោកិយយ៉ាងខ្លាំង ។ ភាពឆ្លាតវាងវៃបន្សល់ទុកសេចក្ដីស្ងប់និងបំពេញនៅក្នុងចិត្តប្រៀបដូចមាននៅក្នុងសេចក្ដីរីករាយនិងនៅក្នុងទុក្ខព្រួយ ។"

គ្មានអ្នកណាម្នាក់អាចរស់នៅក្នុងលោកនេះដោយគ្មានគេស្ដីបន្ទោស និងរិះគន់នោះទេ ។ ព្រះពុទទ្រង់ត្រាស់សម្ដែងថា "មនុស្សស្ដីបន្ទោសគ្នាព្រោះតែភាពស្ងៀមស្ងាត់របស់ពួកគេ ។ គេស្ដីបន្ទោសអ្នកដែលនិយាយច្រើននិងអ្នកដែលមានការប្រមាណ ។ ដូចនេះនៅក្នុងលោកនេះគ្មានអ្នកដែលគេមិនបន្ទោសនោះទេ ។" ព្រះអង្គទ្រង់បានបន្ថែមថា "គ្មានអ្នក ដែលត្រូវគេស្ដីបន្ទោសរហូតឬលើកសរសើររហូតនោះទេ ។ "

អ្នករិះគន់អ្នក មិនមែនសុទ្ធតែជាសត្រូវរបស់អ្នកនោះទេ ។ អ្នកអាចប្រើឱកាសដើម្បីរកឱ្យឃើញពីភាពទន់ខ្សោយ ផ្ទាល់របស់អ្នក ដែលអ្នកខ្លួនឯងមិនអាចមើលឃើញបាន ។

អ្នកមិនគួរបោះបង់ចោលការងារល្អ ដោយព្រោះតែការរិះគន់នោះទេ។ បើសិនបើអ្នកមានសេចក្តីក្លាហានអនុវត្តកិច្ច ការល្អរបស់អ្នកដោយសារតែការរិះគន់អ្នកពិតជាមុនស្សអស្ចារ្យម្នាក់ ហើយបានទទួលជោគជ័យគ្រប់ទីកន្លែង។

**សូមកុំព្រួយ** (Don’t Worry)

កូនសោរនៃការរស់នៅដោយជោគជ័យ និងសុភមង្គលពឹងផ្អែកទៅលើការធ្វើអ្វី ដែលគេត្រូវការធ្វើនៅពេលនោះហើយសូមកុំព្រួយពីអតីតកាលនិងអនាគត។ យើងមិនអាចត្រឡប់ទៅរកអតីតកាល ហើយបង្កើតឱ្យវាមានរូបរាងឡើងវិញ ឬយើងសង្ឃឹមទុកពីអ្វីៗដែលអាចកើតឡើងនៅក្នុងអនាគតនោះទេ។ យើងមានពេលមួយដើម្បីគ្រប់គ្រងដោយមន សិការរបស់យើងពោលគឺបច្ចុប្បន្នកាលនេះឯង។

មនុស្សជាច្រើនគ្រាន់តែខ្វល់ខ្វាយដោយគិតអំពីអនាគតរបស់ពួកគេប៉ុណ្ណោះ ប្រសិនបើពួកគេបានសិក្សាសម្រេបខ្លួន គេទៅនឹងកាលៈទេសៈប្រចាំថ្ងៃរបស់ពួកគេនោះ ហេតុនេះគ្មានហេតុផលណាដែលគេត្រូវព្រួយបារម្ភណ៍នោះទេ។ លំនៅអ្វីមួយ ដែលពួកគេអាចកសាងបានកប់អាកាសនោះ សុបិនអ្វីមួយដែលពួកគេអាចមាននៅក្នុងចិត្តរបស់ពួកគេ ជានិច្ចកាល ពួកគេតែងតែចងចាំបានថា ពួកគេកំពុងរស់នៅក្នុងពិភពផ្លាស់ប្តូរឥតឈប់ឈរនេះ។

**សសរស្តម្ភនៃជ័យជំនះ** (Pillar of Success)

មានតែការបរាជ័យទេដែលជាសសរស្តម្ភនៃជោគជ័យ ។ដើម្បីរៀនតាមរយៈការបរាជ័យរបស់យើង គឺដើម្បីជោគជ័យរបស់យើង។ បើមិនមានបរាជ័យទេ នោះក៏មិនមានជោគ ជ័យដែរ។ លុះត្រាតែយើងមានបទពិសោធន៍ពីភាពបរាជ័យ និងកម្លាំងដែលជាប់ជាមួយរបស់វា យើងនឹងមិនមានលទ្ធភាពវាយតម្លៃ ពីជោគជ័យឱ្យដោយពេញលេញនោះទេ។ វាគ្រាន់តែជាការត្រឡប់មួយនៅក្នុងព្រឹត្តិការណ៍ដែលមានលក្ខណៈតូចតាច ឬគ្មានប្រយោជន៍ចំពោះយើង។ ការបរាជ័យមិនគ្រាន់ តែជួយយើងឱ្យជោគជ័យនោះប៉ុណ្ណោះទេ ប៉ុន្តែវាធ្វើឱ្យយើងចិត្តល្អ មានសមានចិត្តយល់យោគ និងសម្បូរបទពិសោធន៍ទៀតផង។

**សោភ័ណភាពពិត** (The Real Beauty)

ប្រសិនបើគេកើតមកអាក្រក់ គ្មានបញ្ហាថាតើមុខរបស់គេអាចអាក្រក់យ៉ាងណានោះឡើយ ប្រសិនបើគេអប់រំសេចក្តីស្រឡាញ់សេចក្តីស្រឡាញ់នោះនឹងផ្តល់ឱ្យគេនូវសម្រស់ផ្លូវ ចិត្តគ្មានទីបំផុតដែលភាយចេញមកក្រៅ ហើយជ្រួតជ្រាបសព្វភាវៈរបស់គេដោយសម្រស់ អធិធម្ម

ជាតិនោះដែលនឹងធ្វើឱ្យគេមានលក្ខណៈគួរឱ្យទាក់ទាញ ព្រោះសម្រស់នោះគឺជា សោភ័ណភាពពិត ហើយគ្មានរូបរាង គ្មានទំហំ ពណ៌សម្បុរ និងមុខមាត់ទេ ប៉ុន្តែវាមានឥទ្ធិពល ។

យើងចង់ឱ្យក្រឡេកមើលមនុស្សដែលមានសោភ័ណភាពបំផុត ។ ជួនកាលមនុស្សមិនអាចទាក់ទាញអារម្មណ៍គេមក ចំពោះនាងបានទេ ។ ពីព្រោះសោភ័ណភាពរបស់នាងអាចត្រូវធ្វើឱ្យខូចទ្រង់ទ្រាយដោយការមានមោទភាពហួសហេតុទៅលើ សោភ័ណភាពផ្ទាល់របស់នាង ។ សូមទទួលយកមនុស្សដែលអាក្រក់ ប៉ុន្តែជាអ្នកដែលហូរហៀរដោយសេចក្ដីសប្បុរស គ្មានព្រំដែន ហើយនិយាយស្ដីដោយសុភាពរាបសា និងដោយគួរសម ពោលគឺប្រព្រឹត្ត ចំពោះអ្នកដទៃដោយសន្ដានចិត្តល្អហើយអ្នកនឹងមើលឃើញថាតើភាពទាក់ទាញប៉ុន្មានដែលមនុស្សមានចំពោះមនុស្សម្នាក់ៗ ។

ការស្រឡាញ់ជីវិតនៅលើផែនដីនេះដាស់តឿនដល់ការខ្លាចស្លាប់ដោយជម្ងឺ ។ វាបង្កើតឱ្យមានកង្វល់ខ្លាចស្លាប់ពោល គឺមនុស្សដែលនឹងមិនប្រថុយប្រហ៊ាន សូម្បីតែចំពោះភាពត្រឹមត្រូវក៏ដោយ ។គេរស់នៅដោយរន្ធត់ញាប់ញ័រចំពោះជម្ងឺឬការគ្រោះថ្នាក់មួយចំនួន ដែលនឹងត្រូវបាត់បង់ជីវិតតូចតាចមិនសំខាន់របស់គេនៅទីនេះ ។ ការយល់ច្បាស់ថា សេចក្ដីស្លាប់គឺ ជារឿងជៀសមិនរួចពោលគឺការភ័យខ្លាំងគ្មានហេតុផលចំពោះការជៀសមិនរួចនេះនឹងតក់ស្លុត អ្នកស្រឡាញ់ផែនដីចូល ទៅក្នុងសេចក្ដីសង្ឃឹមរំជួលចិត្តមួយចំពោះអត្ថិភាពនៅក្នុងលំនៅដ្ឋានប្រណិត ។ គ្មានអ្នកណាម្នាក់អាចសប្បាយរីករាយនៅ ក្នុងព្យុះសង្ឃរានៃការភ័យខ្លាច និងសេចក្ដីសង្ឃឹមបែបនេះនោះទេ ។វាពិបាកនឹងស្អប់និងធ្វើពើមិនដឹងចំពោះការសម្ដែង ឱ្យឃើញនៃភាវៈគតិ ទាំងនេះចំពោះស្វ័យអភិរក្ស ។ តែទោះជាយ៉ាងណាក៏ដោយមានវិធីយកឈ្នះលើវាពិតប្រាកដមួយ ។ វិធីនេះគឺ ត្រូវបំភ្លេចខ្លួនឯងនៅក្នុងសេវា របស់អ្នកដទៃ គឺត្រូវត្រឡប់ សេចក្ដីស្រឡាញ់របស់គេពីខាងក្នុងទៅ ខាងក្រៅ ។ ជក់ស្លុងទៅនឹង ការជួយអ្នកដទៃ ហើយអ្នកនឹងបំភ្លេច ជម្ងឺផ្ទាល់របស់អ្នកពោលគឺ អាត្មានិយមឧបាទាន និង សេចក្ដីសង្ឃឹម មោទនភាព និងភាពត្រឹមត្រូវខ្លួនឯង ។

មនុស្សម្នាក់ៗពេញចិត្តនឹង សេចក្ដីស្លាប់ដោយ ស្ងប់ស្ងាត់មួយក្រោយពីបំពេញ ឆាកជីវិតករណីយកិច្ចនិងកាតព្វកិច្ចរបស់គេហើយ ។ ប៉ុន្តែតើមានមនុស្សប៉ុន្មានអ្នកដែលបានរៀបចំកន្លែងសម្រាប់ព្រឹត្តិការណ៍បែបនេះបាន? តើមានមនុស្សប៉ុន្មានអ្នកដែលយកបញ្ហាទៅបំពេញករណីយកិច្ចរបស់គេចំពោះ គ្រួសារ បងប្អូន មិត្តភក្ដ ប្រទេសជាតិ សាសនា និង ជាតិរបស់គេនោះ? ប្រសិនបើមនុស្សម្នាក់ស្លាប់ដោយមិនបានបំពេញ ករណីយកិច្ចណាមួយ ដោយពិតប្រាកដទេ

វាជា ការលំបាកបំផុតចុងក្រោយសម្រាប់មនុស្សបែបនេះដែលត្រូវការស្លាប់ដោយ ស្ងប់ស្ងាត់នោះ។

មនុស្សជាច្រើនខ្លាច សាកសពណាស់។ ប៉ុន្តែ រូបកាយរស់មាន គ្រោះថ្នាក់ជាង រូបកាយស្លាប់។ មនុស្សជា ច្រើនត្រូវវាយយកឈ្នះ និងវាយប្រហារដោយ រូបកាយរស់ជាង រូបកាយស្លាប់ដែលគ្មាន ជីវិត។

ប្រសិនបើអ្នកងាកចេញពីលោកនេះទៅដោយគ្មានបានបំពេញ ករណីយកិច្ច របស់អ្នក កំណើតរបស់អ្នកចំពោះ លោកនេះមិនមាន ប្រយោជន៍ ចំពោះ ខ្លួនអ្នកផង និងចំពោះលោកនេះនោះផង។ ដូច្នេះសូមសម្តែង ករណីយកិច្ច របស់អ្នក ហើយនិងប្រឈមមុខចំពោះសេចក្តីស្លាប់ដោយក្លាហាន និងដោយស្ងប់ស្ងាត់។ ហើយនៅថ្ងៃមួយអ្នកនឹងមានលទ្ធភាពសម្រេចបានលក្ខខណ្ឌមិនស្លាប់ដែលអ្នកអាចមាន សុភមង្គលអមតៈ។

## ៥-ព្រះពុទ្ធសាសនាក្នុងការរស់នៅបែបទំនើប

(Buddhism in Modern Life) By Dr. Ananda Guruge

ប្រធានបទខាងលើមានជាច្រើនផ្នែកដូចជា : តើអ្វីជាការរស់នៅបែបទំនើប? តើព្រះពុទ្ធសាសនា ដើរតួនាទីដូចម្តេច ក្នុងការរស់នៅបែបទំនើប?

ការរស់នៅបែបទំនើប មានការពិបាកកំណត់និយមន័យណាស់។ គេអាចនិយាយថា ការរស់នៅបែបទំនើបត្រូវបានគេបញ្ជាក់ដោយព្រឹត្តិការណ៍ដែលពិភពលោកកាន់តែតូចទៅៗ មនុស្សកំពុងតែមានសិទ្ធិចំពោះ គ្នាកាន់តែខ្លាំងឡើង និងរបាំងទំនាក់ទំនង កំពុងតែរលាយបាត់យ៉ាងឆាប់រហ័ស ហើយថាវាអាចងាយស្រួលសម្រាប់គេដើម្បីដឹងនូវអ្វីដែលកើត ឡើងគ្រប់ទីកន្លែងក្នុងពិភពលោកតែក្នុងរយៈពេលខ្លីហើយតាមរយៈមធ្យោបាយនេះ បានអនុញ្ញាតឱ្យចូលរួមក្នុងការរស់នៅផ្នែកឆ្លងកាត់ដ៏ទូលំទូលាយ ជាងគេធ្លាប់បានស្រមើលស្រមៃ។ នោះជាទិដ្ឋភាពមួយនៃការរស់នៅបែបទំនើប។ ទាក់ទងនឹងការរស់នៅបែបទំនើបនេះ យើងគួរយល់ពីពាក្យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាជាមុនសិន។ មនុស្សដែលប៉ុនប៉ងយកឈ្នះ ធម្មជាតិ ជម្ងឺ និងរបាំងធម្មជាតិ បានសំដែងនូវសកម្មភាពស្មុគស្មាញ មួយចំនួនដែលកំពុងតែស្ទាក់ស្ទើរក្នុងចិត្ត។ នោះគឺជាទិដ្ឋភាពមួយនៃការរស់នៅបែបទំនើប ។ទីពាប្រហែលជាទិដ្ឋភាពនៃការរស់នៅបែបទំនើបត្រូវបានរំខានដោយ ពិភពលោកកាន់តែមានរបាំងទំនាក់ទំនងជិតស្និទ្ធបែកចេញ និងការរីកចម្រើនផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រកើតឡើងយ៉ាងឆាប់រហ័ស។ យើងមានការប្រឈមមុខ ជាមួយនឹងបញ្ហាជាច្រើនក្នុងន័យប្រកួតប្រជែងសេដ្ឋកិច្ចនិងនយោបាយការបំពុលកំណើនប្រជាជន

កម្រធនធាន និងប្រយោជន៍ធនធាន មិនរើសអើងដែលមិន អាចត្រូវបានគេដាក់ជំនួសបាន។ ជាមួយបញ្ហាទាំងនេះមានបញ្ហាផ្សេងៗទៀតដែលអាចត្រូវបិតផ្លាកជា"ឧត្តរជីវិត"(survival)។

**តើអរិយធម៌ទំនើបអាចនៅគង់ខង្សបូទេ** ? (Can Modern Civilization Survive?)

ចំពោះបញ្ហានេះ គេអាចបន្ថែមទំហំសីលធម៌ផងដែរដែលជាបញ្ហាសីលវិទ្យា ហើយគេសួរថា"ក្នុងដំណើរការទំនើបកម្មនិងការយកឈ្នះលើធម្មជាតិតើយើងបានងាកចេញពីសមត្ថភាពដើម្បីយកឈ្នះលើខ្លួន ឯងមានវិសាលភាពប៉ុណ្ណា? តើការតស៊ូដើម្បីរស់មានន័យថា មនុស្សទំនើបបានក្លាយជាទាសករចំពោះភាព អាត្មានិយមដែលរំពឹងទ្ធដោយចំណង់ និង កបិចិត្តផ្ទាល់របស់គេឬទេ? តើយើងបានបាត់បង់នូវអ្វីៗទាំងអស់ដែល មានតម្លៃពិសេសចំពោះមនុស្សដូចជាទំនាក់ទំនង អន្តរបុគ្គលការរសាប់រសល់ក្នុងការថែរក្សាអ្នកដទៃ ថែរក្សាស្មារតីនៃការធ្វើ សេវាកម្ម មិនអាត្មានិយមចំពោះអ្នកដទៃ បានដែរឬទេ? តើយើងបានបាត់បង់បញ្ហា ទាំងអស់នេះដែរឬទេ ?

ដូច្នេះ នៅពេលគេគិតអំពីការរស់នៅបែបទំនើប គេអាចគិតដល់កម្រិតសុទិដ្ឋិនិយមច្រើននិងក្នុងពេលជាមួយគ្នានេះដែរគេអាចគិតអំពីកម្រិតទុទិដ្ឋិនិយមស្មើគ្នា។ គេអាចសប្បាយរីករាយថា សព្វថ្ងៃយើងរស់នៅក្នុងពេលមួយដែលហាក់ ដូចជាគ្មានអ្វីដែលថាមនុស្សមិនអាចយកឈ្នះបាន។ ប្រហែលជានៅតែមានជម្ងឺមួយចំនួនដែលបៀតបៀនគេ។ ប្រហែល ជាមានទីកន្លែងនៅក្នុងសាកលលោក ជាទីដែលមនុស្សចង់រស់នៅ ហើយគេនៅមិនទាន់បាន អភិវឌ្ឍបច្ចេកវិទ្យា របស់គេនៅទីនោះទេ។ ប៉ុន្តែទំនងជាថាបញ្ហាទាំងអស់នេះឈានទៅ ដល់មនុស្សហើយ។ នៅក្នុងដំណើរការនេះ ដោយមានសុទិដ្ឋិនិយមអំពីសមត្ថភាពរបស់មនុស្សៗបានកើតមានទិដ្ឋភាពទុទិដ្ឋិនិយមដែលយើងបានបាត់បង់អ្វីមួយ។ សូមយើងរក្សា ទុកបញ្ហាទាំងពីរនេះក្នុងគំនិត។

**ព្រះពុទ្ធសាសនា** (Buddhism)

ឥឡូវនេះចូរយើងក្រឡេកមើលថា តើព្រះពុទ្ធសាសនាជាអ្វី? តើយើងយល់អ្វីខ្លះ តាមរយៈព្រះពុទ្ធសាសនា ? វាអាចមានន័យថា បញ្ហាជាច្រើនមានចំពោះមនុស្ស។ វាអាចជាជីវិតតែមួយគត់របស់ព្រះពុទ្ធ ចំពោះគេ។ ឧទាហរណ៍ ព្រះពុទ្ធនិងសាវ័ករបស់ព្រះអង្គ បានប្រកាសប្រាប់ពីផ្លូវរំលត់ទុក្ខ។ នេះជាប្រភេទមួយ នៃព្រះពុទ្ធសាសនា។ ប្រភេទមួយផ្សេង ទៀត ព្រះពុទ្ធសាសនាមានន័យថា ជាគម្ពីរច្រើនដូចបានកត់ក្នុងអក្សរសាស្ត្រពុទ្ធសាសានាដែលមានច្រើន

ភាគ ហើយមួយភាគៗមានបីបួនពាន់ទំព័រដែលកត់ត្រាសម្ដីរបស់ព្រះពុទ្ធ។ នៅក្នុងគម្ពីរទាំងនោះ គេបានរៀបរាប់អំពីទស្សនវិជ្ជាជីវិតជ្រៅ ជ្រះនិងស្មុគស្មាញបំផុត។ ដោយយោងទៅលើអ្វីដែលព្រះពុទ្ធបានបង្រៀន អ្វីដែលប្រតិបត្តិនៅសម័យព្រះពុទ្ធ បានបង្កើត នូវវប្បធម៌ដ៏សម្បូរបែបបំផុតដែលបានផ្សព្វផ្សាយទៅគ្រប់ផ្នែកទាំងអស់នៃទ្វីបអាស៊ីអស់រយៈពេលជាង២៥០០ឆ្នាំមកហើយ។ មិនតែប៉ុណ្ណោះ ប្រជាជននៃបណ្ដាប្រទេសទាំងនេះ បានរួមចំណែកផ្សព្វផ្សាយព្រះពុទ្ធសាសនា ជាយូរយារណាស់មកហើយ។ និកាយឬសាលា ឬប្រព័ន្ធទស្សនវិជ្ជាមួយ ចំនួនធំបានវិវត្តន៍និងបាត់បង់ទៅវិញក្រោមឈ្មោះព្រះពុទ្ធសាសនា។ បន្ទាប់មក បានលេចចេញនូវនិយមន័យនៃព្រះពុទ្ធសាសនាមួយផ្សេងទៀត ហើយនិយមន័យនោះជាប្រភេទក្បួនច្បាប់ ដែលបានលទ្ធិពុទ្ធសាសនារីកលូតលាស់ និងក្លាយទៅជាសាសនាមួយតាមរយៈការបង្រៀន និងការទេសនាពីវិធីរស់នៅ របស់ព្រះអង្គ។ ការបង្រៀនរបស់ព្រះពុទ្ធ បានធ្វើឱ្យប្រជាជនប្រកាន់នូវសេចក្ដីស្មោះត្រង់ និងមានលក្ខណៈវិនិច្ឆ័យសម្រាប់ សម្រេចចិត្តធ្វើនូវអ្វីដែលសមស្រម និងអ្វីដែលមិនសមស្រប។ នោះជាប្រភេទ នៃព្រះពុទ្ធសាសនាមួយផ្សេងទៀត។ ប្រសិនបើគេទទួលយកទិដ្ឋភាពដោយឡែកៗពីគ្នា ហើយពិនិត្យមើល ផលប៉ះពាល់នូវអ្វីដែលគេហៅថា ព្រះពុទ្ធសាសនាក្នុងការរស់នៅបែបទំនើបនោះវានឹងជាកិច្ចការធំមួយទៀត។

ចំពោះខ្ញុំ ព្រះពុទ្ធសាសនា គឺជាបញ្ហាទាំងអស់នេះហើយ។ វាជាតួអង្គព្រះពុទ្ធ និងការរស់នៅរបស់ ព្រះអង្គលទ្ធិវប្បធម៌ដែលវិវត្តន៍ជុំវិញព្រះពុទ្ធសាសនា និងក្បួនច្បាប់ដែលទាក់ទង នឹងព្រះពុទ្ធសាសនា។ កាលនោះ យើងយកបញ្ហាទាំង នេះធ្វើជាអង្គបទពិសោធន៍របស់មនុស្សបានចម្រាញ់ជាទម្រង់ល្អបំផុត ហើយបានបង្ហាញចំពោះយើងតាមលក្ខណៈដែល យើងម្នាក់ៗអាចជ្រើសរើសបានអាចកើតឡើងចំពោះយើង យើងចាប់ផ្ដើមដឹងពីភាពមានតែមួយគត់របស់ ព្រះពុទ្ធសាសនា។ ក្នុងសម័យពុទ្ធកាល គេធ្លាប់បង្ហាញចំណុចនេះដែរ។ គេមិនចាំបាច់ធ្វើជាអ្នកប្រាជ្ញនឹងរៀនអ្វីៗគ្រប់បែបយ៉ាងនោះទេ។ ព្រះពុទ្ធសាសនាមិនដូចរៀនមុខវិជ្ជា គណិតវិទ្យា ដែលអ្នកត្រូវរៀនគ្រប់ទ្រឹស្ដី និងវិធីដោះស្រាយច្រើនបែបច្រើនយ៉ាងច្រើននោះទេ។ ប្រសិនបើ អ្នកដឹងពីគោលការណ៍ មូលដ្ឋានគ្រឹះនៃការសិក្សាលំអិតមិនមែនជាប្រផ្នូលសំខាន់ក្នុង ការប្រតិបត្តិនោះទេ។ ដូច្នេះក្រៅពីវប្បធម៌សាសនា ឬអក្សរសាស្ត្រពុទ្ធសាសនា ឬអង្គពិសោធន៍ ដ៏ច្រើនដែលកើតចំពោះយើងក្នុងនាមព្រះពុទ្ធសាសនា យើងម្នាក់ៗគួរដឹងថា វាទាក់ទងនឹងការរស់នៅរបស់យើងទាក់ទងនឹងប្រភេទបញ្ហារបស់យើង។

**ព្រះពុទ្ធសាសនាជាលទ្ធិមិនកំណត់ពេល** (A Timeless Doctrine)

ខ្ញុំតែងតែឆ្ងល់ថា តើព្រះពុទ្ធសាសនាត្រូវបានគេហៅថា “Akalika”ដែលមានន័យថា "មិនកំណត់ពេល"ពោលវាមានអត្ថិភាពគ្រប់ពេលដូចម្តេចទៅ។ ខ្ញុំកាន់តែដឹងការផ្លាស់ប្តូរ ដែលបានកើតឡើងក្នុងវប្បធម៌ ឬសាសនាព្រះពុទ្ធខ្ញុំកាន់តែដឹងថា តើវារក្សាបាននូវការថ្លឹងថ្លែងចំពោះតម្រូវការនៃសម័យកាលប្រជាជន បុគ្គលផ្សេងៗគ្នាដូចម្តេច? ខ្ញុំកាន់តែដឹង ថាវាមានលទ្ធភាពសម្រាប់ព្រះពុទ្ធក្នុងការវិវត្តពាក្យទូន្មានដែលនៅស្រស់ល្អគ្មានទីបញ្ចប់។ ដូច្នេះប្រសិនបើព្រះពុទ្ធសាសនាមានការប្រតិបត្តិសព្វថ្ងៃ ហើយប្រសិនបើព្រះពុទ្ធ សាសនាមានកន្លែងមួយនៅក្នុងការរស់នៅបែបទំនើប វាអាស្រ័យដោយ ភាពទាក់ទងដែលកើតចេញពីការ បង្កើតតម្លៃគ្មានទីបញ្ចប់។ ដើម្បីនិយាយអំពីលក្ខណៈគ្មានទីបញ្ចប់គឺជាវិធីបង្ហាញមួយ ដែលមានប្រតិមតិយ៉ាងខ្លាំងឬការពិពិណនាអំពីសាសនា ដែលជាគោលលទ្ធិនៃភាពមិនស្ថិតស្ថេរនៅខាង ក្រោមវា។ លក្ខណៈគ្មានទីបញ្ចប់នេះ កើតឡើងពីដំណើរប្រែប្រួល និងវិវត្តន៍ជាលំដាប់។ ដូច្នេះព្រះពុទ្ធសាសនាអាចថ្លឹងថ្លែងពេលវេលា និងអរិយធម៌ផ្សេងៗគ្នា។ អាស្រ័យហេតុនេះ យើងមិនត្រូវស្ទាក់ស្ទើរក្នុងការទទួលយកព្រះពុទ្ធសាសនា ដែលទាក់ទង នឹងការរស់នៅរបស់យើងសព្វថ្ងៃនេះទេ។

តើធាតុដែលធ្វើឱ្យព្រះពុទ្ធសាសនាឋិតថេរមានអ្វីខ្លះ? ខ្ញុំគ្រាន់តែសូមលើកយកធាតុមួយចំនួនមកបក ស្រាយដូចតទៅ : ធាតុទី១ ត្រូវទទួលស្គាល់ទំនួលខុសត្រូវរបស់បុគ្គល។ ព្រះពុទ្ធជាព្រះបរមគ្រូដែលគួរឱ្យគត់សំគាល់មួយអង្គដែលបានធ្វើឱ្យមនុស្សរួចចាកផុតពីចំណងអធិធម្ម ជាតិ អទិទេព ការបង្កើត អំពើបាប ឬ លក្ខណៈផ្សេងៗទៀតដែលបានទទួល ពីនរណាម្នាក់ក្រៅពីអ្វីដែលយើងបានធ្វើដោយខ្លួនឯង។ ដូច្នេះនៅពេល ដែលព្រះពុទ្ធមានពុទ្ធដិកាថា មនុស្សម្នាក់គឺជា ម្ចាស់លើខ្លួនឯង ព្រះអង្គបានប្រកាសគោលការណ៍មួយដែល ការអនុវត្តកាន់តែមាន ភាពខ្លាំងក្លាឡើងដើម្បីឱ្យមានទំនុក ចិត្តកាន់តែច្រើនក្នុងការត្រួតត្រាលើខ្លួនឯងនិងអ្វីៗ ដែលនៅជុំវិញខ្លួន។ សព្វថ្ងៃនេះដោយមានការអភិវឌ្ឍន៍ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា មនុស្សយល់ឃើញថា គេមានបញ្ញាខ្ពស់ជាងអ្នកផ្សេង ឬក៏គេអាចដោះស្រាយបញ្ហាណាមួយដែលគេមាន។ ផ្នែកសិរីរាង្គសីលវិទ្យានយោបាយ ឬអ្វីក៏ដោយមិនមែនជាគោលការណ៍ ដែលមនុស្សធ្វើជាម្ចាស់លើខ្លួនឯងនោះទេ។ បញ្ហាសំខាន់គឺគេ ត្រូវទទួលខុសត្រូវអ្វីដែលគេបានធ្វើ នេះជាវិធីដ៏សំខាន់បំផុតក្នុងការមើលខ្លួនឯង។

ដូច្នេះគោលដៅសំខាន់នេះដែលធ្វើឱ្យមនុស្សរួចចាកផុតពីសេរីភាពស្មារតីនិងបញ្ហាផ្សេងៗទៀតគឺ ជាពុទ្ធលទ្ធិដ៏សំខាន់ឈានទៅដល់ភាពឋិតថេររបស់ខ្លួន។ នៅពេលដែលមនុស្ស មានការរីកចម្រើនកាន់តែខ្លាំង គេអះអាងថា គេជាម្ចាស់ លើខ្លួនឯង។ នៅពេលដែលគេអះអាងថា គេជាម្ចាស់លើខ្លួនឯង គេកំពុងថាតាមសម្តី របស់ព្រះពុទ្ធ "អត្តាហិ អត្តនោ នាថោ" ( Atta hi attano natho)។

**សេរីភាពនៃការគិត** (A Timeless Doctrine)

លទ្ធិសំខាន់ប្រហែលគ្នាមួយទៀតគឺ សេរីភាពនៃការគិត។ ព្រះពុទ្ធសាសនាមិនត្រឹមតែធ្វើឱ្យយើងរួចផុតពីអទិទេព ឬចំណងអធិធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានធ្វើឱ្យមនុស្សជាតិមានសេរីភាពពីគម្ពីរនិយមទៀតផង។ សូមយើងនឹកគិតដល់ពេលដែលព្រះពុទ្ធកំពុងទូន្មាន។ វាជាពេលដែលការបង្រៀនសាសនាផ្សេងៗកំពុង តែកើតឡើងហើយនៅសតវត្សទី៦ មុនគ.ស ប្រទេសឥណ្ឌាជាទីកន្លែង មួយគួរឱ្យចាប់អារម្មណ៍បំផុត។ គ្រូសាសនាដែលអះអាងពីប្រភេទលទ្ធិផ្សេងៗកំពុងតែប្រកួតប្រជែងគ្នា ដើម្បីឱ្យមានលទ្ធិកាន់តែច្រើន។ ក្រៅពីការបង្រៀនថ្មីៗទាំងនេះ មានប្រពន្ធ័សាសនាជាច្រើនដែលត្រូវបានគេលើកទឹកចិត្តយ៉ាងខ្លាំង។ នៅក្នុងប្រពន្ធ័សាសនាទាំងអស់នេះមានទ្រឹស្តីថា "យើងបានរកឃើញមាគ៌ាមួយ"។ "នេះជាមាគ៌ាត្រឹមត្រូវ"។ "អ្នកដើរតាមមាគ៌ានេះអ្នកនឹងត្រូវបានសង្គ្រោះ"។ ក្នុងចំណោមមាគ៌ាទាំងនេះ ព្រះពុទ្ធបានមានពុទ្ធដីកាថា "កុំជឿនូវអ្វី ដែលសៀវភៅសរសេរ កុំជឿនូវអ្វីដែលគ្រូរបស់អ្នកនិយាយ កុំជឿនូវអ្វី ដែលប្រពៃណីរបស់អ្នកបានចារទុក កុំកាន់យកអ្វីដែលគេមិនឱ្យអ្នក។ សូមធ្វើឱ្យមានបទពិសោធន៍ផ្ទាល់ខ្លួន សូមគិតដោយខ្លួនឯងជឿជាក់លើខ្លួនឯង ហើយអ្នកជឿជាក់លើសកម្មភាពខ្លួនឱ្យសមស្រប"។ មនុស្សមានលក្ខណៈសំខាន់ណាស់ក្នុងការ ផ្តល់សេរីភាពតស៊ូ និងសេរីភាពក្នុងការគិតចំពោះខ្លួនឯង។

ប្រសិនបើនៅក្រោមរបបសក្តិភូមិ យើងមិនអាចអះអាងច្រើនពីសិទ្ធិគិតសម្រាប់ខ្លួនយើងទេ។ ពេលដែលភាពជឿនលឿនបានកើតឡើង យើងនឹងមានសេរីភាពកាន់តែច្រើន។ យើងនឹងចង់មានអារម្មណ៍ជឿជាក់លើខ្លួនឯងបន្ទាប់ពីយើង ស៊ើបអង្កេតផ្ទាល់ បន្ទាប់ពីយើងអាចឆ្លងកាត់គោលការណ៍ ហេតុការណ៍ផលល្អនិងផលអាក្រក់។ បញ្ហានេះយើងគិតថាជាសិទ្ធគ្មានការរំលោភបំពាន។ នេះជាលទ្ធិទី២ដែលអាចអនុវត្តបាន នៅសម័យទំនើប និងនៅពេលអនាគត។

**តួនាទីព្រះពុទ្ធសាសនា** (Role of Buddhism)

បន្ទាប់មកកើតមានបញ្ហាសំខាន់បំផុត កើតចេញពីការគាំទ្រនូវអ្វីដែលមនុស្សនឹងចង់ពោលអះអាង សម្រាប់ខ្លួនគេក្នុងពេលបច្ចុប្បន្ន នឹងទៅអនាគត តើព្រះពុទ្ធសាសនាមានតួ នាទីត្រឹមត្រូវឬទេ? បញ្ហានេះកើត មានផលសំខាន់បំផុត ចំពោះ យើងទាំងអស់គ្នា ដែលគួរតែចាប់អារម្មណ៍មួយចំនួនក្នុងពេលបច្ចុប្បន្ននេះ។ នៅខណៈពេលដែលមនុស្សកំពុងតែធ្វើឱ្យមាន ការរីកចំរើនគ្រប់វិស័យ យើងក៏ឃើញផងដែរថា សម្ពាធនៃការរស់នៅបែបទំនើប ការសប្បាយដើម្បីរស់នៅការសប្បាយ ដើម្បីធ្វើឱ្យប្រសើរជាងអ្នកដទៃចំណង់រស់នៅក្នុងការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច នយោបាយ វប្បធម៌ ឬក្នុងទម្រង់អ្វីក៏ ដោយបាននាំមកនូវភាពតានតឹង។ ដើម្បីបំបាត់ភាពតានតឹងទាំងនេះមនុស្សបានវិវត្តការបង្កើតឡើងវិញ និងការសម្រាកកាន់តែច្រើន។ ពួកវាបានបង្ហាញនូវការបន្ធូរភាពតានតឹងបន្តិចបន្តួច ប៉ុន្តែ ហាក់ដូចជានាំឱ្យមនុស្ស ធ្លាក់ចូលទៅក្នុង រង្វង់កាចសាហាវ កាន់តែច្រើន។ ដោយសារតែភាពតានតឹង គេជាប់ជំពាក់ខ្លួនគេទៅក្នុងសកម្មភាពផ្សេងៗ ហើយព្រោះ តែសកម្មភាពទាំងនេះចំណាយពេលច្រើនពេក ទើបគេទៅទាន់ដំណើរការនៃការរស់នៅ ហើយខ្លួនគេស្ថិតនៅក្នុងរយៈពេលអន់ថយនៃភាពតានតឹងខ្លាំង។ វឌ្ឍនភាពផ្នែកសេដ្ឋកិច្ចកាន់តែខ្លាំង ការបំភ្លឺផ្នែកនយោបាយកាន់ខ្លាំង ប្រជាជនត្រូវ ការ រម្ងាប់ការឈឺចាប់ និងរម្ងាប់ចិត្តកាន់តែច្រើនដើម្បីឱ្យពួកគេធ្វើកិច្ចការរបស់ពួកគេ។ អ្នកត្រូវតែលេបថ្នាំមួយគ្រាប់ ដើម្បីបំបាត់ងងុយគេង មួយគ្រាប់ដើម្បីងងុយគេង មួយគ្រាប់ដើម្បីសម្រាកជាដើម។ ភាពតានតឹងរបស់មនុស្សដែលបាន កើតឡើងដល់ចំណុចគ្មានប្រយោជន៍គឺស្ថិតនៅក្នុងស្ថានភាពធ្ងន់ធ្ងរបំផុត។ លើសពីភាពតានតឹងនេះភាពទំនេរធ្វើឱ្យមនុស្សធុញទ្រាន់។ ភាពតានតឹង និងភាពធុញទ្រាន់ពិតជា ធ្វើឱ្យមនុស្សភាគច្រើនមិនសប្បាយចិត្ត។ សព្វថ្ងៃនេះគេអាចសួរសំណួរថា តើយើងស្ថិតនៅក្នុងស្ថានភាពដែល មនុស្សពិតជាសប្បាយចិត្ត ឬស្ថិតក្នុងស្ថានភាពបាត់បង់អ្វីមួយ? តើគេស្តីបន្ទោសនរណា? តើយើងត្រូវស្តី បន្ទោសវិទ្យាសាស្ត្រឬ? តើយើងត្រូវបន្ទោសបច្ចេកវិទ្យាឬ? តើយើងត្រូវស្តីបន្ទោសប្រពន្ធ័នយោបាយឬ? តើយើងត្រូវស្តីបន្ទោសប្រពន្ធ័សេដ្ឋកិច្ចដែលយើងបានទទួលឬយើងបានអភិវឌ្ឍឬទេ?ឬក៏យើងត្រូវស្តីបន្ទោសខ្លួនយើង?

**អ្នកជាម្ចាស់លើខ្លួនឯង** (You are your own Master)

ត្រឡប់ទៅមើលមាគ៌ាផ្ទាល់របស់ព្រះពុទ្ធក្នុងការមើលបញ្ហាដែលអ្នកនឹងនិយាយថា អ្នកគ្រប់គ្រង ជីវិតក្នុងដៃរបស់អ្នក។ ព្រោះអ្វីដែលបានខុស អ្នកត្រូវតែទទួលខុសត្រូវ អ្នកជាម្ចាស់

លើខ្លួនឯង។ អ្នកត្រូវតែឱ្យអ្វីដែលខុសចេញទៅឱ្យឆ្ងាយពីដៃអ្នក។ វាជាការងាយស្រួលណាស់ក្នុងការស្តីបន្ទោសមនុស្ស ដោយនិយាយថា "អ្នកបានឱ្យឱកាសកន្លងហួស។ វាចេញពីដៃរបស់អ្នក" ប៉ុន្តែវាបានជួយឬទេ ? ភាពអស្ចារ្យនៃព្រះពុទ្ធសាសនា គឺឱ្យអ្នកទទួលខុសត្រូវដោយខ្លួនឯង។

ប្រសិនបើគេមើលផ្នែកផ្សេងៗនៃវិធានការណ៍សាសនា វេជ្ជវិទ្យាវិកលចរិត ចិត្តសាស្ត្រដែលបានវិវត្ត ដើម្បីសង្គ្រោះមនុស្ស ឬក៏ដើម្បីព្យាបាលមនុស្សពីភាពតានតឹងមួយជ្រុង និងភាពអផ្សុកមួយជ្រុងទៀតនោះ អ្នកនឹងឃើញមានវិធីជាច្រើន ប៉ុន្តែមិនមានទិសដៅសាមញ្ញដូចព្រះពុទ្ធសាសនាបានផ្តល់នោះទេ។ គេនឹងសួរសំណួរថា តើមធ្យោបាយនេះអាច ធ្វើឱ្យអ្នករំដោះខ្លួនពី ភាពតានតឹង និងភាពអផ្សុកនៃការរស់នៅបែបទំនើបឬទេ ? ដើម្បីឆ្លើយចំពោះ សំណួរនេះ វាមានការពិបាកណាស់ ព្រោះគ្មាននរណាម្នាក់ក្លាយជាពុទ្ធសាសនិកជនទេ។ គ្មាននរណាម្នាក់ដែលត្រូវពាក់ផ្លាកជាពុទ្ធសាសនិក ជនទេ ព្រោះព្រះពុទសាសនា ទស្សនវិជ្ជា ឬ មាគ៌ាជីវិតឬសាសនាណាមួយនោះទេ។ ខ្ញុំប្រើពាក្យសាសនា ព្រោះមិន មានការបែងចែកដើម្បី ឱ្យគេដាក់ផ្លាក ទៅលើសាសនាណាមួយនោះទេ។ ក្នុងសម័យពុទ្ធកាល ប្រជាជនបានទៅរកព្រះអង្គបានស្តាប់ព្រះអង្គ ហើយប្រសិនបើពួកគេសប្បាយចិត្តនឹងព្រះអង្គ ពួកគេនិយាយថា "ខ្ញុំយកព្រះអង្គជាទីពឹង ខ្ញុំយកព្រះធម៌ជាទីពឹង ខ្ញុំយកព្រះសង្ឃ សហគមន៍ សាវ័កដែលកំពុង ដើរតាមមាគ៌ាជីវិតនេះជាទីពឹង"។ សព្វថ្ងៃនេះ គេគ្រប់គ្នាហៅខ្លួន គេថាជាពុទ្ធសាសនិកជន។ ការមានទំនុកចិត្តទៅលើអ្វីដែលព្រះពុទ្ធបានបង្រៀន មានការទាក់ទងខ្លះៗទៅលើបញ្ហារស់នៅ របស់គេ។ គេគិតថាព្រះពុទ្ធសាសនា ជាវិធីរស់នៅដែលគេប្រតិបត្តិតាម មានផលចំណេញ ដោយយកព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាទីពឹងទីរឭក។ ការក្លាយខ្លួនជាពុទ្ធសាសនិកជនមិនចាំបាច់មានពិធីក្បួនផ្សេងៗ ការចុះឈ្មោះការតម្រូវតាមច្បាប់ផ្សេងៗនោះទេ។ ព្រះពុទ្ធសាសនា ជាអ្វីដែលលោក F.L.Woodword ជា អ្នកបកប្រែពុទ្ធវចនៈដ៏ល្អម្នាក់ ហៅថា "សាសនា ធ្វើដោយខ្លួនឯង" (a do-it-yourself religion) ។

សព្វថ្ងៃនេះអ្វីដែលសំខាន់គឺថា ប្រហែលជាមានមនុស្សរាប់ពាន់នាក់មិន ដែលបានទៅចូលព្រះវិហារ មិនដែលបាន ចូលក្នុងការរៀបចំក្បួនខ្នាតដែលបានវិវត្តក្នុងប្រទេសកាន់ ព្រះពុទ្ធសាសនា ប៉ុន្តែមនុស្សរាប់ពាន់នាក់ដែលនៅក្នុងចិត្ត របស់គេបានយល់ពីសុពលភាពនៃ ព្រះធម៌របស់ព្រះពុទ្ធ ហើយដែលកំពុងដឹកនាំជីវិតតាម គោលការណ៍ព្រះពុទ្ធសាសនា។ តាមពិត យើង

យល់ឃើញថាប្រជាពលរដ្ឋភាគច្រើននៅលើពិភពលោកប្រកាន់សេចក្តីស្មោះត្រង់ចំពោះព្រះពុទ្ធ ដោយហេតុផលមួយ ឬច្រើន។ នេះជាបញ្ហាគួរឱ្យកត់សំគាល់មួយដែល គេចាត់ទុកថា ជាអព្ភូតហេតុ។

**មាគ៌ាជីវិត** (A Way of Life)

មាគ៌ាជីវិតដែលព្រះពុទ្ធបានបង្រៀនមានលក្ខណៈសាមញ្ញបំផុត។ ចំពោះឧបាសក ឧបាសិកាមានតែសិក្ខាបទសាម ញ្ញ៥ប៉ុណ្ណោះ : មិនសម្លាប់ មិនលួច មិនប្រព្រឹត្តិខុសក្នុងកាម មិនភូតកុហក មិនផឹកគ្រឿងស្រវឹង។ ប៉ុន្តែមាគ៌ាជីវិតដែល ព្រះពុទ្ធបានរៀបរាប់ មិនចប់ត្រឹមតែសិក្ខាបទប៉ុណ្ណឹងទេ។ ដើម្បីឱ្យមានលក្ខណៈងាយយល់ ត្រូវគោរពធ្វើតាមពាក្យបាលី បីម៉ាត់គឺ ទានៈ សីលៈ និងភាវនា។

ទានៈ មានន័យថា ការជួយសង្គ្រោះ សប្បុរសធម៌ ពោលគឺ អំពើនៃការឱ្យ។ វាមានសារៈសំខាន់ណាស់ដែល ព្រះពុទ្ធសាសនាចាប់ផ្តើមធ្វើទាន ព្រោះជាសកម្មភាពគុណធម៌ដំបូងដែលគេចាប់ចិត្តដើម្បីធ្វើខ្លួនឱ្យមានមាគ៌ាត្រឹមត្រូវ ព្រោះការឱ្យទាន ជាសកម្មភាពគួរជាទីពេញចិត្ត។ ដើម្បីធ្វើទាន គឺត្រូវរៀបចំចិត្តគំនិត របស់អ្នកឱ្យបានពេញលេញ ដើម្បីបោះបង់អ្វីមួយដែលអ្នកមាន អ្វីដែលជាទ្រព្យរបស់អ្នក អ្វីដែលអ្នកជាប់ជំពាក់។ អាស្រយ័ហេតុនេះ អ្នកត្រូវប្រឈមមុខ នឹងហេតុនៃបញ្ហាមួយដែលភាសាបាលីហៅថាលោភៈ។ គួរឱ្យចាប់អារម្មណ៍ណាស់ក្នុងការដឹងថា តើមាគ៌ាមានលក្ខណៈបែបណា? តើយើងអាចកម្ចាត់ភាពខ្សោយ និងលក្ខណៈដែលបង្កឱ្យមានភាពតានតឹង និងភាពអផ្សុកដែលកំពុងរំខាន យើងទាំងអស់គ្នាបានឬទេ ? សេរីភាពត្រូវជំទាស់នឹងលោភៈ។

សីល គឺជាការជាប់ជំពាក់នឹងសិក្ខាបទមួយចំនួន ឬអំពើជាកុសល។ ព្រះពុទ្ធយល់ច្បាស់អំពីហេតុការណ៍ដែលថា គេមិនអាចបង្កើតច្បាប់ឬបទបញ្ញត្តិសម្រាប់មនុស្សគ្រប់គ្នាតាមរបៀបដដែលនោះទេ។ដូច្នេះមានច្បាប់មួយចំនួនសម្រាប់គ្រហស្ថមានច្បាប់មួយចំនួនសម្រាប់អ្នកទាំងឡាយណាដែលចង់ចូលក្នុងជីវិតដែលជាអ្នកកាន់សាសនា និងមានវិន័យកាន់តែច្រើនសម្រាប់ព្រះសង្ឃដែលបានបូជាខ្លួនឱ្យជាប់ចិត្តនឹងវិន័យ និងការធ្វើចិត្តឱ្យបរិសុទ្ធ។ ដូច្នេះ សីល ជាបញ្ហាដែលកើតឡើងសន្សឹម១ ដើម្បីឱ្យមនុស្សម្នាក់១ ជ្រើសរើសនូវអ្វីដែលគេអាចធ្វើ តាមបានក្នុងពេលបច្ចុប្បន្ន។

នៅក្នុងសីល ឬអំពើកុសល ឬការបង្រៀនតាមបែបសីលធម៌របស់ព្រះពុទ្ធ យើងត្រឡប់ទៅមើល លទ្ធិដើមវិញ។ ពួកវាមិនមែនជាការបញ្ជា ពួកវាមិនត្រូវបានដាក់បញ្ញត្តិពីខាងលើ ពួកវាមិនត្រូវបានព្រះពុទ្ធ ដាក់បញ្ញត្តិជាការបញ្ជា ដើម្បីគោរពទេ។ ក្នុងនាមជាពុទ្ធសាសនិកជនសិក្ខាបទនីមួយៗដែលយើងទទួលយក គឺជាការសន្យាចំពោះឆន្ទៈសេរីផ្ទាល់ខ្លួនរបស់យើង។ ហើយវិធីដែលពួកគេនិយាយគឺ "ខ្ញុំអះអាងតាមវិន័យមិនសម្លាប់" "ខ្ញុំអះអាងតាមវិន័យមិនលួច "ជាដើម ពីព្រោះខ្ញុំជាម្ចាស់លើជោគវាសនារបស់ខ្ញុំ ហើយខ្ញុំសម្រេចថា ខ្ញុំនឹងដឹកនាំជីវិតបែបណា។ ក្នុងនាមជាអ្នកនាំផ្លូវ ព្រះពុទ្ធបានបង្ហាញនូវភាពខ្សោយសំខាន់ៗមួយ ចំនួនឬក៏កំហុសដែលគេគួរជៀសវាង។ ហេតុនៃបញ្ហាទីពីរដែលយើងមានគឺទោសៈ ឬសេចក្តីស្អប់ចំពោះអ្នកដទៃ។ ក្នុងភាសាបាលី យើងនិយាយថា Dosa។ សីល ជាថ្នាំបន្សាបហេតុទី២ នៃភាពខ្សោយរបស់យើង។ ពេលដែលយើងប្រតិបត្តិសីល យើងអាចលុបបំបាត់ហេតុនៃទោសៈទាំងស្រុង។ ព្រះពុទ្ធ ជាមនុស្សម្នាក់ដែលយល់ដឹងពី ផលប៉ះពាល់ជាច្រើននៃទោសៈ។ ទោសៈ មិនអាចរម្ងាប់ដោយទោសៈបានទេ។ អ្នកមានស្អប់កាន់តែច្រើន អ្នកមានទោសៈកាន់តែខ្លាំង។ អ្នកស្អប់ខ្ញុំ ខ្ញុំស្អប់អ្នកពោលគឺ ខ្ញុំស្អប់អ្នកកាន់តែខ្លាំង អ្នកស្អប់ខ្ញុំក៏កាន់តែខ្លាំង ហើយការស្អប់នេះនឹង កើនឡើងដល់ចំណុចមួយដែលអ្នក និងខ្ញុំក្លាយជាស្អប់គ្នាទៅវិញទៅមក ហើយចំពោះ ព្រះពុទ្ធវិញវិធីដោះស្រាយមានតែមួយគត់គឺភាគីម្ខាងត្រូវតែឈប់ស្អប់គ្នា។ បើភាគីម្ខាងៗព្យាយាមដណ្តើមស្អប់គ្នា សេចក្តីស្អប់នឹងមិនឈប់ទេ។ វិធីដែលទាក់ទងនឹងបញ្ហានេះ ត្រូវផ្អែកទៅលើគម្ពីរនៃការរស់នៅ ប្រកបដោយគុណធម៌របស់ព្រះពុទ្ធសាសនាទាំងស្រុង។ ព្រោះការរស់នៅប្រកបដោយគុណធម៌កំពុងតែប្រឆាំងនឹងហេតុទី២នៃភាពខ្សោយរបស់យើងឱ្យឈ្មោះថា ការស្អប់ ឬទោសៈ។ នៅក្នុងព្រះពុទ្ធសាសនា យើងមានការចាប់អារម្មណ៍យ៉ាងខ្លាំង ហើយព្រះពុទ្ធសាសនាជាលទ្ធិស្រឡាញ់ភាពសប្បុរសដែល ជាសសរគោលនៃព្រះពុទ្ធសាសនា។ ព្រះពុទ្ធមិនបានចាត់ទុកថាជាគោលការណ៍សីលធម៌សាមញ្ញនោះទេ។ ព្រះអង្គបានវិភាគ គោលការណ៍ការស្រឡាញ់សប្បុរសធម៌ ជាការរស់នៅដ៏ប្រសើរបំផុត។

បន្ទាប់មកកើតមានករុណា Karuna។ ករុណា ត្រូវបានបង្កើតឡើងយ៉ាងងាយស្រួលបំផុត។ អ្នកមើលឃើញនរណាម្នាក់មានបញ្ហា អ្នកមើលឃើញនរណាម្នាក់ដែលត្រូវការឱ្យអ្នកជួយចិត្តរបស់អ្នកធ្វើដំណើរទៅរកអ្នកនោះហើយអ្នកប្រញាប់ជួយគេ។គុណភាពនៃការប្រញាប់

ជួយនរណាម្នាក់ដែលមានអារម្មណ៍ទុក្ខ ព្រួយចំពោះអ្នកដែលកំពុងមានទុក្ខ នោះគឺជាផលមួយទៀតនៃការស្រឡាញ់សប្បុរសធម៌។

បន្ទាប់មកកើតមានផលទី៣ដែលពិបាកក្នុងការអនុវត្តន៍ហើយតម្រូវឱ្យមានការស្រឡាញ់ និងការឈឺ ចាប់ខ្លាំង។ នោះគេហៅថា មុទិតា Mudita ពោលគឺដើម្បីចែករំលែកសុភមង្គលរបស់អ្នកដទៃ ជម្រះភាព ប្រចណ្ឌ និងច្រណែនឈ្នានីស ចេញពីចិត្តរបស់អ្នក ដើម្បីឱ្យអ្នកពេញចិត្តនឹងការធ្វើល្អរបស់អ្នកផ្សេងៗ អ្នកជិតខាង និងសត្រូវរបស់អ្នក។

ចុងបញ្ចប់ កើតឡើងនូវផលទី៤នៃសេចក្តីស្រឡាញ់សប្បុរសធម៌ ហើយនោះហៅថាចិត្តនឹងគឺ ឧបេក្ខា Upekkha។ លោកអ្នក មិនមានមិត្តភ័ក្រ មិនមានសត្រូវ មិនមានអ្នកខ្ពស់ជាងអ្នកទាបជាងទេ។ លោកអ្នកពិតជាគ្មានការបែងចែករ វាងមនុស្សម្នាក់ និងអ្នកផ្សេងទៀតហើយអ្នកត្រូវចូលរួមក្នុងអង្គឯកភាពមួយ ប្រភេទជាមួយគ្រប់ភាវៈទាំងវត្ថុ និងស្ថាន ភាពទាំងអស់។ ដូច្នេះ កាលណាអ្នកអាចរស់នៅក្នុងលក្ខណៈទាំង៤ យ៉ាងដែលគ្រប់គ្រងសកម្មភាពរបស់អ្នកបាន ពុំមានកន្លែងសម្រាប់ស្អប់ ពុំមានកន្លែងសម្រាប់ប្រកួត និងពុំមានកន្លែងសម្រាប់ប្រជែងគ្នាទេ។ ដូច្នេះគោលការណ៍សីលទី២នេះ ថែរក្សាការបង្កើតបញ្ហាដែលយើងមាននេះ។

ចុងក្រោយបង្អស់កើតឡើងនូវបញ្ហាសំខាន់បំផុត ហើយអ្នកនឹងត្រូវរៀបចំបញ្ហាមួយដែលនៅបន្ទាប់ ពីបញ្ហានេះគឺ ភាវនា (Bhavana) ។ ភាវនាមានន័យថា ការហ្វឹកហាត់ចិត្ត។ ពាក្យនេះមានន័យដើមថា ការអភិវឌ្ឍន៍ ពោលគឺការអភិវឌ្ឍបន្ថែមនៃចិត្ត។ ព្រះពុទ្ធជឿថា អ្វីៗភាយចេញពីចិត្តរបស់មនុស្សហើយព្រះអង្គជាមនុស្សដំបូងគេបង្អស់ដែលបញ្ជាក់វាតាមលក្ខណៈនេះ។ ការរៀបចំដែលខ្ញុំបង្ហាញមានលក្ខណៈជាលំនាំ ដើមចំពោះធម្មនុញ្ញ "ព្រោះសង្គ្រាមចាប់ផ្តើមក្នុងចិត្ត របស់មនុស្ស វានៅក្នុងចិត្តរបស់មនុស្សដែលអ្នកការពារ សន្តិភាពត្រូវតែបង្កើត"។ ហើយការឆ្លុះបញ្ចាំងនោះជាឃ្លាទី១ នៃកំណាព្យរបស់ Dhammapada។ ចិត្តបរិសុទ្ធ ចិត្តហ្វឹកហាត់ ចិត្តអភិវឌ្ឍល្អ ចិត្តដែលអាចគ្រប់គ្រងឆន្ទៈ ចិត្តដែលមិន បន្តទៅប្រធានវិស័យដែលនាំឱ្យមាននូវភាពតានតឹង និងការអផ្សុកប៉ុន្តែរក្សានូវការប្រុងប្រយ័ត្នរក្សានូវការអភិវឌ្ឍន៍រកឃើញខ្លួនឯង និងនៅក្នុងអាថ៌កំបាំងនៃជីវិត បញ្ហាជីវិត និងតថភាពជីវិត គឺជារតនសម្បត្តិដ៏អស្ចារ្យបំផុតរបស់មនុស្ស។

សព្វថ្ងៃខ្ញុំ មិនភ្ញាក់ផ្អើលទេដែលថាមានអំពើឆ្គួតលីលានៅក្នុងផ្នែកអភិវឌ្ឍ បច្ចេកវិទ្យាខ្ពស់នៃពិភពលោកសម្រាប់ ការភាវនាគ្រប់ប្រភេទ។ វាធ្វើឱ្យមានភាពខុសគ្នានូវអ្វីដែលគេបាន

បង្រៀន ឬទស្សនវិជ្ជាឬតិកនិចអ្វីដែលគេបានទទួលយក។ ប៉ុន្តែ ហេតុការណ៍នៅតែថា មនុស្ស កំពុងចាប់ផ្តើមដឹងថា ការសម្លឹងមើល មួយភ្លែត ការគិតឈ្លាសវៃមួយភ្លែត មុខងារនៃចិត្តដែល ត្រួតពិនិត្យដឹកនាំបានត្រឹមត្រូវ គឺជាបញ្ហាសំខាន់មួយ សម្រាប់សុខុមាលភាពរបស់មនុស្ស។

២៥០០ឆ្នាំកន្លងទៅហើយ ព្រះពុទ្ធពិតជាបានបង្រៀននូវវិធីដដែលនេះ។ ហើយប្រសិន បើគ្មានអ្វី ផ្សេងទៀតដែលមនុស្សសព្វថ្ងៃត្រូវការទេ គេត្រូវការតែភាពស្ងប់នៃចិត្ត។ គេចង់ គេចឱ្យផុតពីភាពតានតឹងហើយប្រយុទ្ធប្រឆាំងនឹងភាពអផ្សុក។ ហើយខ្ញុំឃើញនៅក្នុងព្រះពុទ្ធ សាសនាជាពិសេសនៅក្នុងមាគ៌ាបី យ៉ាងគឺ ទាន សីល និងភាវនា។

ចូរក្រឡេកមើលគោលការណ៍របស់ព្រះពុទ្ធដែលជាមូលដ្ឋាន ឬជាការចាប់ផ្តើមនៃជីវិត សាសនារបស់ ព្រះអង្គ។ យើង បានដឹងថា មនុស្សច្រើនណាស់ដែលចេញពីក្រទៅមាន ប៉ុន្តែនៅ ទីនេះជាករណីដែលមនុស្ស បានចេញពីមានទៅក្រវិញ។ ក្នុងការស្រាវជ្រាវពីភាពស្ងប់នៃចិត្ត យើងអាចនិយាយថា ជាការប្រសិទ្ធិពរដ៏ប្រ ពៃបំផុត។ ជាលទ្ធផល គាត់បានយល់ពី ខ្លួនឯង បន្ទាប់មកបានបង្រៀនទៅអ្នកដទៃដែលជាជនពិការ ជាប្រភពនៃបញ្ហាដែលជាប់ជំពាក់។

ដូច្នេះ ប្រសិនបើនរណាម្នាក់ត្រូវមកថ្ងៃនេះ ហើយនិយាយថា" ខ្ញុំអាចនាំអ្នកទៅកាន់ និព្វានបានក្នុងពេលឆាប់ៗនេះ" ខ្ញុំគិតថាពួកយើងភាគច្រើននឹងមានការអភ័យទោសដើម្បីផ្តល់ ឱ្យ។ គេនឹងនិយាយថា "តើខ្ញុំមិនអាចរង់ចាំរហូត ដល់កូនស្រីរបស់ខ្ញុំរៀបការទេឬ?" អ្នកផ្សេង ទៀតប្រហែលជានិយាយថា "តើខ្ញុំមិនអាច រង់ចាំរហូតដល់ World Fel-lowship of Buddhists General Conference នេះរំលងហួសទេឬ?" "តើខ្ញុំ មិនអាចរង់ចាំរហូតដល់ ខ្ញុំបានបញ្ចប់ ការសរសេរ assignment ក្នុងទីក្រុងបឹងកកចប់ទេឬ?" យើងមានពេល គួរជាទី ពេញចិត្តផ្ទាល់ខ្លួននៅពេលដែលវាកើត ឡើងដល់គោលបំណងចុងក្រោយ។

អ្វីក៏ដោយដែលជាការសម្រេចចិត្តឈានទៅដល់គោលបំណងចុងក្រោយនេះ គឺមាន ចំណុចមួយដែល យើងមិនអាចគេចផុត។ យើងមិនអាចបដិសេធហេតុការណ៍ដែលថា ការ អភិវឌ្ឍន៍បែបទំនើបទាំងអស់គ្មានអ្វីផ្តល់ទេ ប៉ុន្តែអសន្តិសុខ និងការប្រកួតប្រជែង ព្រមទាំង ភាពតានតឹង និងការអផ្សុកបានចូលរួមជាមួយពួកវា។ ព្រះពុទ្ធសាសនាបានផ្តល់នូវវិធីងាយ និង ស័ក្តិសិទ្ធិបំផុតមួយចំនួនដើម្បីប្រយុទ្ធនឹងបញ្ហានោះ។ ហើយជាមួយនឹងបញ្ហានេះខ្ញុំមាន អារម្មណ៍ថា ព្រះពុទ្ធសាសនាមានតួនាទីក្នុងការរស់នៅរបស់យើងមានផ្នែកសំខាន់មួយ ក្នុងការ ដើរ តួនាទីពីប្រទេសដែលកាន់ព្រះពុទ្ធសាសនា។ វាជាទំនួលខុសត្រូវរបស់យើងក្នុងការ ចែក

រំលែក ការគិតចំណេះដឹង និងបទពិសោធន៍របស់យើងជាមួយអ្នកផ្សេងឱ្យ បានច្រើនតាមដែលអាចធ្វើទៅបានដើម្បីដល់ចុងបញ្ចប់ យើងទាំងអស់គ្នាយល់ពីសារៈរបស់ព្រះពុទ្ធ ដែលផ្ដល់អត្ថន័យល្អៗ សម្រាប់មនុស្សជាតិ ហើយបន្តផ្ដល់ឱ្យមនុស្សជាតិគ្រប់ទីកន្លែង និងគ្រប់ទិសទីពេញពិភពលោក។

# ជំពូកទី៥

# ការប្រតិបត្តិព្រះពុទ្ធសាសនា

Buddhist Practices

## ១-អ្នកគោរពបូជា និង ការគោរពបូជា

(Prayer and Worship) By. Dr. G.P. Malalasekera

គេតែងតែចោទសួរថា : *"តើពុទ្ធសាសនិកជនបន់ស្រន់ដែរឬទេ?" "តើ ពុទ្ធសាសនិកជនធ្វើអ្វីខ្លះពេលគេទៅវត្ត ?"* ហើយនិងសំណួរថា *"តើឥរិយាបថព្រះពុទ្ធសាសនាយ៉ាងណាចំពោះអ្នកគោរពបូជា?"*

អ្នកគោរពបូជានិងការគោរពបូជាតាមពិតទៅបង្កើតជាផ្នែករួមមួយនៃសាសនាជាច្រើន ។ នៅក្នុងព្រះពុទ្ធសាសនា ពាក្យថា ភរាយរេ នេះមានន័យថា វត្ថុជាច្រើន។ នៅក្នុងសាសនាទេវវិទ្យាពោលគឺសាសនាដែលជឿទៅលើ អាទិទេពអាទិទេពដែលមាន កម្លាំងគ្រប់បែបយ៉ាងដែលជាអ្នកកសាងលោកឡើង ហើយនិងជា បិតា នៃ គ្រប់សត្វទាំងអស់ Prayer មានន័យជាសំខាន់ថា អ្នកបួងសួងឬ អ្នកបន់ស្រន់ (supplication) ចំពោះអាទិទេព បួងសួងចំពោះព្រះអង្គដោយ សុំឱ្យព្រះអង្គជួយបង្ហាញផ្លូវ និងជួយការពារដោយសេចក្តីគោរពសុំឱ្យមានសុខភាពល្អ និងសុភមង្គល និងសុំកុំឱ្យមានកម្មពៀ ។

គេអះអាងកាលពីដើមដំបូងថា អ្នកកាន់ព្រះពុទ្ធសាសនាមិនជឿទៅលើ អាទិទេពបែបនេះទេហើយពួកគេក៏គ្មានបួងសួងមានគំនិតបែបនេះដែរ។ អ្នកកាន់ព្រះពុទ្ធសាសនាជឿទៅលើច្បាប់កម្មដែលអះអាងថា សុភមង្គលនិង អពមង្គលមានលក្ខណៈជាលទ្ធផលមកពី អំពើផ្ទាល់របស់យើង។ វិបុលភាពនិងទុគ៌តភាពក៏ត្រូវបានបង្កើតឡើងព្រោះតែបុគ្គលម្នាក់ៗ ដោយសារតែ កាយវាចា និងចិត្តរបស់គេដែរ។ ច្បាប់កម្ម មានលក្ខណៈអបុគ្គលភាពវាគ្មានភ្នាក់ងានៅពីក្រោយវាទេ ពោលគឺដឹកនាំវានិងគ្រប់គ្រងវា។ ការមិនមានបុគ្គលភាពនេះ វាមិនសម្តែងឱ្យឃើញពី ការុញ្ញចិត្ត (mercy) ឬ ការអត់ឱនទោសនោះឡើយ។ អំពើអាក្រក់ អាចត្រូវបានគេរំលោះតែតាមរយៈការការធ្វើល្អដែលនឹងយកឈ្នះលើផលនៃអំពើអាក្រក់តែប៉ុណ្ណោះ។បាបកម្មនៅក្នុងខ្លឹមសារ ព្រះពុទ្ធសាសនា មិនមែនជាការផ្តើន (transgression)ឬការមិនគោរពច្បាប់ដែលបានពឹងផ្អែកទៅលើអាទិទេព ទាំងបំពានដែលមនុស្សត្រូវគោរពតាមនោះទេ ប៉ុន្តែការសម្តែងពី ទង្វើខុសឆ្គងដោយ កាយ វាចា និង ចិត្ត ដែលធ្វើឱ្យ អត្តចរិតត្រូវស្អុយរលួយហើយនិងរារាំងបង្អាក់ផ្លូវដល់ ការចម្រើនលូតលាស់បុគ្គលិកលក្ខណៈរបស់គេ។

ដូច្នេះនៅក្នុងព្រះពុទ្ធសាសនាគ្មាន "អ្នកបួងសួង (prayer)" នេះនៅក្នុងខ្លឹមសារពាក្យដែលគេទទួលយកជាទូទៅនេះទេ។ មនុស្សមានទំនួលខុសត្រូវតែចំពោះខ្លួនគេចំពោះអំពើល្អ និង អាក្រក់សុភមង្គល និងទុគ៌តភាពរបស់ពួកគេតែប៉ុណ្ណោះនិងមិនមានចំពោះអ្នកដទៃនោះទេ។ ពិភពលោកមិនពឹងផ្អែកទៅលើដំណើររីកចម្រើន ឬវិបុលភាពរបស់វា លើភ្នាក់ងារក្រៅខ្លួនណាមួយនោះទេហើយវាមិនត្រូវបានសាងសង់ដោយអ្នកណាមួយដែលនៅក្រៅវានោះដែរ។

តើអ្វីដែលពុទ្ធសាសនិកជនធ្វើនៅពេលគេទៅវត្ត? ពួកគេធ្វើរឿងរ៉ាវជាច្រើន។ គ្មានថ្ងៃពិសេសដែលត្រូវទៅវត្តនោះទេ បើទោះជាមានថ្ងៃពេញបរមី ឬថ្ងៃដើមខ្មែតដែលមានប្រជាប្រិយភាពក្នុងចំណោមពុទ្ធសាសនិកជនជាច្រើនក៏ដោយ។ នៅក្នុងថ្ងៃបែបនេះ អ្នកគោរពអាចប្រារព្ធសីល៨ តាមធម្មតាស្លៀកពាក់ពណ៌ស ពីព្រោះពណ៌សជានិមិត្តសញ្ញានៃ ភាពងាយស្រួល (simplicity) ភាពបរិសុទ្ធ(purity)និង ការបន្ទាបខ្លួន(humility)។ អ្នកគោរពបូជា អាចយកតាមខ្លួនដូចជា ផ្កា ប្រេង ធូបនិងជួនកាលមានម្សៅឈើច័ន្ទន៍ក្រស្នា(sandal wood powder) និង ទេព្វិរូ (camphor)។ នៅឯវត្ត គេលាងសំអាតដៃ និងជើងរបស់គេ ពីព្រោះ ភាពស្អាតនៃរូបកាយនិង ចិត្ត ព្រះពុទ្ធទ្រង់លើកសរសើរ។ នៅក្នុង វត្តមាន ស្តូប (shrines) ឬកន្លែងបីបួនជាទីកន្លែងសម្រាប់គោរពបូជា(offerings)។ ស្តូបសំខាន់គេឱ្យ ឈ្មោះព្រះវិហារ *(Vihara)* ដែលមានន័យថា កន្លែងនៅ (dwelling place)។

ពាក្យថា វិហារ *(Vihara)* នេះប្រើតាមស័ព្ទដើមមានន័យថា និវេសដ្ឋាន (residence) របស់ព្រះពុទ្ធ។ ក្រោយមកពាក្យនេះក៏គេនៅប្រើដើម្បីបង្អុលបង្ហាញពី កន្លែងនៅរបស់ព្រះសង្ឃ ទៅវិញ។ នៅក្នុងខ្លឹមសារនេះវាឆ្លើយតបទៅនឹង ពាក្យ វត្ត (monastery)នេះ។ ព្រះវិហារ ក៏មានតម្កល់ព្រះពុទ្ធបដិមាដែរ ហើយនៅកន្លែងនោះមានដាក់អ្វីៗដែល មានតម្លៃគួរឱ្យកត់សម្គាល់។ ចំពោះ ពុទ្ធសាសនា បដិមាខ្លួនឯងមិនមែនជាវត្ថុនៃ ការគោរពបូជាទេ វាគ្រាន់តែជានិមិត្តរូប និងជាការតំណាងឱ្យ ព្រះពុទ្ធប៉ុណ្ណោះ។ បដិមានឹងជួយដល់ អ្នកគោរពបូជានឹកឃើញពីគុណធម៌ដ៏ធំធេងរបស់អ្នកត្រាស់ដឹង(the Enlightened One)។ ចំពោះគោលបំណងរបស់ អ្នកគោរពបូជា របស់គេវិញមិនមានរូបរាង (immaterial) ថាតើមាន បដិមាឬអត់នោះទេ ប៉ុន្តែគេអាចរកវាឃើញដោយមានប្រយោជន៍សម្រាប់សមាធិគំនិតរបស់គេ។ ដូច្នេះក្នុងការគោរពបូជាបដិមាពុទ្ធសាសនិកជនមិនមែនជា អ្នកគោរពបូជាទេវតា (idolater) បន់ស្រន់

ចំពោះ ឈើជីឥដ្ឋឬថ្មទេ ហើយបន្ទុកនៃ ការគោរពទេវតានេះដែលបានធ្វើឡើងប្រឆាំងចំពោះពុទ្ធសាស និកជនក៏ព្រោះតែអវិជ្ជា ឬការតំណាងខុសដែលមានការរៀបចំទុកជាមុន។

មានចំណុចមួយទៀត ដែលមានតម្លៃគួរឱ្យយកចិត្តទុកដាក់នៅក្នុងការប្រើពាក្យ វិហារនោះសម្រាប់ អាគារ ដែលរក្សា ការតំណាងព្រះពុទ្ធ(representations of the Buddha)។ ដូចបានពោលពីខាងដើមរួចមកហើយថា ពាក្យដែលមានន័យថា កន្លែងនៅនោះ ដូចនេះចំពោះពុទ្ធសាសនិក វិហារ គឺជាទីកន្លែងដែល ព្រះពុទ្ធគង់នៅ មិនមែនត្រឹមតែ នៅក្នុងអតីតកាលនោះប៉ុណ្ណោះទេ ប៉ុន្តែក៏នៅពេលបច្ចុប្បន្ននេះផងដែរ។ ការគោរពបូជាព្រះពុទ្ធមិនមែនដើម្បីអ្នកណាមួយដែល ស្លាប់ទៅហើយ ឬអ្វីៗច្រើនទៀតនោះឡើយ ប៉ុន្តែចំពោះអ្នកណាមួយដែល នៅរស់និង ពេលបច្ចុប្បន្ន នៅខាងមុខគេ។ នេះមិនមែនមានន័យថា ពុទ្ធសាសនិកជនជឿថា ព្រះពុទ្ធដែលទ្រង់យាងពី ជីវិតលោកិយនៅឯ Kusi-nara នៅមាន ជីវិតនៅពេលនេះនៅក្នុង កន្លែងពិសេសណាមួយដែលទ្រទ្រង់ឱ្យមានមុខងារជីវិត (the function of life)។ប៉ុន្តែពុទ្ធសាសនិកជនក្នុងការសម្តែងអភិវន្ទនាការចំពោះ ព្រះពុទ្ធផ្ទង់សតិផ្ទាល់របស់គេទៅរក ព្រះវត្តមានជីវិតរបស់ព្រះបរមគ្រូដើម្បីឱ្យសកម្មភាពគោរពបូជារបស់គេរស់រវើកនិងមានសារៈសំខាន់។

ព្រះពុទ្ធទ្រង់យាងចូល និព្វានបាត់ទៅហើយ ប៉ុន្តែ ឥទ្ធិពលរបស់ព្រះអង្គនៅមានអត្ថិភាពជ្រួតជ្រាបពេញពិភព លោកប្រៀបដូចជា ទឹកអប់ដែលក្លិនពិដោររបស់វាបន្តនៅយូរ បើទោះជាសម្ភារៈដែលបានផលិតនោះអស់រលីងទៅហើយក៏ដោយ។អារម្មណ៍ពុទ្ធសាសនិកជនគឺថាការបូជា របស់គេគឺដើម្បីអ្នកណាមួយ ដែលនៅមានជីវិតយ៉ាងច្រើនបំផុត ពោលគឺនៅក្នុង ព្រះពុទ្ធ-ព្រះធម៌នោះដែលនៅរស់នៅឡើយហើយ និងលំនឹកគិតនៃបុគ្គលិកលក្ខណៈភ្លឺចែងចាំងនៅមានសម្រស់គ្រប់សម័យកាល។ នេះពន្យល់ពីហេតុដែលថា ពុទ្ធសាសនិកជនមួយចំនួនធ្វើការបូជាអាហារនិង ភេសជ្ជៈ នៅទីអារាម។ ការបូជាបែបនេះគឺគ្រាន់តែជា និមិត្តរូបនៃ កម្លាំងជំនឿនិងជំនឿស៊ុប របស់ពួកគេប៉ុណ្ណោះ គ្មានអ្នកណាជឿ (មិនមែនសូម្បីតែ អ្នកកាន់ព្រះពុទ្ធ សាសនាអវិជ្ជាបំផុតនោះទេ)ថា ព្រះពុទ្ធតាមពិតទៅទ្រង់ទទួលចង្ហាន់ ឬភេសជ្ជៈ។ វាគឺជាវិធីសម្តែងព្រះពុទ្ធសាសនានៅក្នុងទម្រង់គំនិត (idealistic form) ដែលគំនិតរបស់យើងចំពោះ ព្រះជាឥទ្ធិពលមានជីវិតមួយនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង។

ការបូជា ផ្កានិង ធូបគឺជា ដង្វាយគោរពសក្ការៈជាអំពើអភិវន្ទនាការ, គោរពសក្ការៈនិងជា កតវេទិតា សូម្បីតែខ្លួនពួកគេការគោរពបូជាមិនមាន តម្លៃនៅខាងក្នុង (intrinsic value)

នោះដែរ។ វាប្រៀបដូចជា ការឱ្យកម្រងផ្កា របស់យើងទៅ អ្នកណាម្នាក់ដែលយើងចង់សម្តែង ពីកិត្តិយសការគោរព ការស្រឡាញ់ និងកតវេទិតា របស់យើងចំពោះគេប៉ុណ្ណោះ។ ការបូជាផ្កា និង ធូបគឺត្រូវតាមជាប់ដោយ សូត្រគាថា (utterance of stanzas) ដែល ត្រូវនឹកក្នុងចិត្តពុទ្ធសាសនិកជននូវ គុណសម្បត្តិដ៏ខ្ពង់ខ្ពស់របស់ ព្រះពុទ្ធ។

ដូច Ven. Nanamoli ពោលថា "*ជាការពិត ព្រះពុទ្ធគឺជា អ្នកមានពរ*(the Blessed One)ដែលបានរំលត់ ទុក្ខ និងសេចក្តីព្រួយសព្វយ៉ាង ពោលគឺជា តថាគត(Tathagata, the Perfect One) មានតម្លៃគួរឱ្យ អភិវន្ទនាការជា អ្នកសម្រេចបាន គតិបណ្ឌិតដ៏ឧត្តមនិង ត្រាស់ដឹងសម្មាសម្ពោធិញាណ ជាអ្នកដែលបានប្រកាស មាគ៌ាចំណេះដឹងត្រឹមត្រូវនិងការ ប្រព្រឹត្តល្អ ជា អ្នករកឃើញ សេចក្តីស្ងប់និង សុភមង្គលជាអ្នកយល់ច្បាស់ពី សច្ចភពអំពី ពិភពលោក ជាអ្នក មគ្គុទេសក៍និងជា មិត្តចំពោះអ្នកណាដែលស្វែងរក ការណែនាំរបស់គេ ជាគ្រូនៃមនុស្សនិងទេព្តា។

គួរកត់ចំណាំថា គ្មានការបួងសួងសុំ ក្តីអនុគ្រោះ(favours), គ្មានការបួងសួងសុំ ការការពារនោះទេប៉ុន្តែមានការស្ទឹងស្មាធ(recollection)និងការហ្វឹកហាត់(rehearsal)ពីគុណសម្បត្តិរបស់មនុស្សដ៏ធំមួយដែលឆ្ពោះទៅរកពុទ្ធសាសនិកជនគឺជាមនុស្សដ៏អស្ចារ្យបំផុត ដែលបានរស់នៅជាដរាប។

គាថាដទៃ១ទៀតត្រូវតាមជាប់ដែលអ្នកជឿ អះអាងថា គេបានទទួលយកព្រះពុទ្ធជាគ្រូនិងជាមគ្គុទេសក៍ របស់គេដរាបណាគេអាចរស់នៅបាន និងតាមរយៈ គុណធម៌នៃ ការពិតនេះ សូមឱ្យ សេចក្តីសុខកើតមានដល់គេ។ វាគឺជាអំណះអំណាងមួយពីជំនឿរបស់គេទៅលើ ព្រះពុទ្ធ និងការទទួលយកមាគ៌ាជីវិត របស់គេដែលគេបានពឹងផ្អែក។ បើទោះជាមានសារៈសំខាន់យ៉ាងណាក៏ដោយ អ្នកគោរពបូជាបាននិយាយពី ដំណោះស្រាយរបស់គេដើម្បីយកឈ្នះលើ ខ្លួនគេនូវសេចក្តីស្ងប់នៃ ព្រះនិព្វាន ដែលព្រះពុទ្ធសម្រេចបានតាមរយៈ ការប្រតិបត្តិគុណធម៌ និងការសម្រេចបានគតិបណ្ឌិត។ អ្នកគោរពនឹកក្នុងចិត្តថា អំឡុងពេល កំណើតថ្មីបន្តគ្នាអស់ពេលដ៏យូរ ព្រះពុទ្ធ (ដែលនៅពេលនោះគេយល់ថាជា ព្រះពោធិសត្វ ឬអ្នកប្រាថ្នាចង់បាន ការត្រាស់ដឹងសុក្រឹត) បានអប់រំគុណធម៌ទាំងនោះដែលដឹកនាំ ភាវៈនានាទៅរក សុក្រឹតភាពនិង ការត្រាស់ដឹងបំផុត។ក្នុងទិសដៅនៃការហ្វឹកហាត់នេះព្រះពោធិសត្វឬការត្រាស់ជាព្រះពុទ្ធអនាគត(Buddha-to-be)មិនបានគិតពីការខិតខំប្រឹងប្រែងឱ្យលំបាកពេកទេ គ្មានការបូជាអស្ចារ្យពេកទេ។

មិនត្រឹមតែនៅក្នុងកំណើតមួយទេ ប៉ុន្តែនៅក្នុងកំណើតរាប់មិនអស់ព្រះអង្គបានបូជាជីវិតសម្រាប់គោលការណ៍នានា ព្រះអង្គពេញចិត្តបម្រើអ្នកដទៃ។

មនុស្ស ទាំងអស់អាចក្លាយទៅជាព្រះពុទ្ធបានប្រសិនបើពួកគេ មានដំណោះស្រាយចាំបាច់ហើយមានឆន្ទៈដើរតាម មាគ៌ាទៅរកភាពជាព្រះពុទ្ធបាន។ ព្រះពុទ្ធមិនបានសម្រេចភាពអស្ចារ្យមួយដែលអ្នកដទៃមិនអាចសម្រេចបានដោយខ្លួនឯងនោះទេ។ មាគ៌ាជីវិត ដែលព្រះពុទ្ធទ្រង់បានប្រកាសផ្សព្វផ្សាយនោះគេឱ្យឈ្មោះថា ព្រះធម៌ ហើយដែលអ្នកគោរពបូជា នឹកក្នុងចិត្តរបស់គេតាមរយៈគាថា ពោលគឺគុណសម្បត្តិ និងលក្ខណៈចម្បងនៃការបង្រៀនរបស់ ព្រះអង្គ។ ដូចនេះគេនិយាយព្រះធម៌ព្រះពុទ្ធ "ត្រូវបានប្រកាសផ្សព្វផ្សាយយ៉ាងច្បាស់លាស់ ដែលគ្មានទេវកថា ឬអាថ៌កំបាំងនៅពីក្រោយនោះទេ ប៉ុន្តែបើកទូលាយ និងអះអាងច្បាស់លាស់ប្រៀបដូចជាការបើកដៃរបស់អ្នកណាមួយប្រសិទ្ធភាពរបស់វាជាក់ស្តែង និងច្បាស់លាស់ និងបង្ហាញភស្តុតាងបានវាអមតៈគ្មានទីបញ្ចប់ វាល្អគ្រប់កាលនិងគ្រប់ទីកន្លែងអ្នកជឿអាចពិនិត្យនិងសួរដេញដោលរកហេតុផលបានគ្មានអ្វីលាក់កំបាំងឡើយ មិនពឹងផ្អែកលើជំនឿប៉ុន្តែពឹងផ្អែកទៅលើការវិនិច្ឆ័យ មិនមែនស្រពេចស្រពិល ប៉ុន្តែច្បាស់លាស់នៅលើគោលបំណង ដែលវាពឹងផ្អែកលើសច្ចភាព និងសុភមង្គលអាចសម្រេចបានតែតាមរយៈបុគ្គលម្នាក់ៗ និងសេចក្តីខំប្រឹងប្រែងយ៉ាងធ្ងន់ធ្ងរ និងមិនមែនពឹងផ្អែកទៅលើអ្នកណាមួយទេ តែទោះជាយ៉ាងណាក៏ដោយឫទ្ធានុភាពដែលគេអាចពឹងផ្អែកបាន"។

អ្នកគោរពបូជាក៏នឹកក្នុងចិត្តផងដែរ ចំពោះការលើកទឹកចិត្ត និងការស្រាយបំភ្លឺផ្ទាល់របស់គេដែលមាន និងជានិច្ច កាលត្រូវមានអ្នកទាំងឡាយណាដែលមានការឧទ្ទិស ខ្លួនចំពោះការយល់ច្បាស់លាស់ពីព្រះធម៌ ពោលគឺមាគ៌ាទៅរកការរំដោះខ្លួន និងការខិតខំយ៉ាងខ្លាំងក្លាបានឈានដល់គោលបំណងនៃការស្វែងរករបស់ពួកគេពោលគឺការចាំបាច់សេចក្តីលោភការស្អប់និងមាយាការ ។ដូចនេះពួកគេគឺជាគំរូជីវិតល្អ" ការប្រព្រឹត្តល្អ ទៀងត្រង់មានឥរិយាបថស្លូតបូត, មានកិត្តិយសនិងមានការគោរព មានតម្លៃគួរឱ្យទុកជាទីគោរព និងជាទីសង្ឃឹម និងដើរតាម។" គំរូដ៏ប្រសើរទាំងនេះគេស្គាល់ថាជា សង្ឃះ ឬសហគមន៍នៃសាវ័កត្រាស់ដឹងដែលសំអិតសំអាងពិភពលោកនេះដោយភពល្អ និងសន្តិភាពនៃការរស់នៅរបស់ ពួកគេជៀសវាងអំពើអាក្រក់ទ្រទ្រង់អំពើល្អបំពេញពិភពលោកនេះដោយគំនិតមិត្តភាព សុឆន្ទៈនិងសេចក្តីស្ងប់។ អ្នកគោរពបូជាក្នុងការផ្តល់នូវទានដល់អ្នកណាដែលគេលាចាកលំនៅដ្ឋាន គឺជាការប្រតិបត្តិទាន ឬសទ្ធា

ទាន។ ក្នុងការចងចាំគំរូដ៏ប្រសើរទាំងនេះទៅក្នុងការស្រឡាញ់ និងការគោរពសាសនា ពុទ្ធសាសនិកជនប្រព្រឹត្តសីល និងក្នុងការបំពេញចិត្តរបស់ គេដោយការលើកស្ទួយគំនិត របស់គេឱ្យខ្ពស់ឡើង គេចាប់ផ្តើមប្រតិបត្តិកម្រិតអនុវត្តខ្ពស់ៗ ពោលគឺការចម្រើនភាវនា ឬ ការអប់រំចិត្ត (ភាវនា) ។

## ២. តើពុទ្ធសាសនិកជនគឺជាអ្នកគោរពបូជាទេវរូបឬ?

(Are Buddhists Idol-Worshippers ? ) By. Ven. Dr. K. Sri Dhammananda

**វត្ថុនៃការគោរព** (Objects of Veneration)

នៅក្នុងគ្រប់ សាសនាទាំងអស់មាន វត្ថុឬនិមិត្តរូបជាក់ស្តែងសម្រាប់គោលបំណងនៃការគោរពបូជា។ នៅក្នុងព្រះពុទ្ធសាសនាមាន វត្ថុសាសនាសំខាន់ៗ៣សម្រាប់គោលបំណងនេះ :

- *Saririka* ឬ ព្រះបរមសារីរិកធាតុរូបកាយរបស់ព្រះពុទ្ធ (the bodily relics of the Buddha)
- *Uddesika* ឬ និមិត្តរូបសាសនាដូចជា ព្រះពុទ្ធបដិមា ចេតិយ *(chetiya)* ឬ វត្តអារាម (pagoda)
- *Paribhogika* ឬ អត្ថបទ (articles)ដែល ព្រះពុទ្ធប្រើ។

វាមានលក្ខណៈជាប្រពៃណីសម្រាប់ពុទ្ធសាសនិកជនទូទាំងពិភពលោកដើម្បីធ្វើអភិវន្ទនាចំពោះវត្ថុជាទីគោរពទាំងនេះ។ វាក៏ជាទំនៀមទម្លាប់ពុទ្ធសាសនា មួយដែរដើម្បីកសាងពុទ្ធបដិមា (Buddha images), ចេតិយឬវត្តអារាម និងដាំដើមពោធិព្រឹក្ស (Bodhi tree)នៅគ្រប់ វត្តដើម្បីបម្រើជា វត្ថុគោរពបូជាសាសនា។

មនុស្សជាច្រើន ស្ថិតនៅក្រោមការកត់សម្គាល់ថា ពុទ្ធសាសនិកជនបន់ស្រន់ចំពោះទេវរូប (idols)។ នេះក៏ព្រោះហេតុតែ ខកខានមិនបានយល់ពី ការបង្រៀនរបស់ព្រះពុទ្ធនិងប្រពៃណី និងទំនៀមទម្លាប់របស់ព្រះពុទ្ធសាសនា នេះឯង។

ការគោរពទេវរូប ជាទូទៅមានន័យថា ការកសាងបដិមាទេពតានិង ទេពធិតាដែលមានទម្រង់ផ្សេងៗដោយអ្នកមានជំនឿស៊ុបសម្រាប់ការបួងសួង សម្រាប់សុំពរជ័យ និងថែរក្សា និងសម្រាប់ជួយដល់អ្នកបន់ស្រន់សុំឱ្យមានសុខភាពល្អមានទ្រព្យសម្បត្តិនិងវិបុលភាពការប្រតិបត្តិបានរកឃើញនៅក្នុងសាសនាទេវនិយម។ អ្នកបន់ស្រន់សូម្បីតែចំពោះអំពើបាបដែលគេ បានប្រព្រឹត្តិនោះផងដែរ។

ការគោរពបូជាចំពោះព្រះពុទ្ធ គឺជាទិដ្ឋភាពខុសស្រឡះ។ សូម្បីតែពាក្យ "គោរពបូជា" នេះក្តីក៏ខុសគ្នាឆ្ងាយពីទស្សនៈព្រះពុទ្ធសាសនា។ ការធ្វើអភិវន្ទនាគួរជាស័ព្ទត្រឹមត្រូវ។ ពុទ្ធសាសនិកជនមិនបន់ស្រន់ជាចម្មតាចំពោះបដិមា និងទេវរូបទេ អ្វីដែលគេធ្វើគឺដើម្បីធ្វើអភិវន្ទនាចំពោះគ្រូសាសនាដ៏ធំមួយដែលមានតម្លៃកិត្តិយស។ បដិមាដែលគេតម្កល់នោះគ្រាន់តែ ជាសញ្ញាគោរពមួយ និងការឱ្យតម្លៃចំពោះសមិទ្ធផលកំពូលនៃការត្រាស់ដឹង និងសុក្រឹតភាពតាមរយៈគ្រូសាសនាវិសាមញ្ញមួយប៉ុណ្ណោះ។ ចំពោះពុទ្ធសាសនិក បដិមាគឺគ្រាន់តែជានិមិត្តរូបមួយ ជាសញ្ញាមួយ ជាការតំណាងមួយដែលជួយគេឱ្យនឹកឃើញ ឬចងចាំព្រះពុទ្ធប៉ុណ្ណោះ។

ពុទ្ធសាសនិកជនលុតជង្គង់នៅមុខបដិមា ហើយសម្តែងអភិវន្ទនកិច្ចរបស់ពួកគេចំពោះអ្វីដែលបដិមានោះតំណាងឱ្យ ។ពួកគេមិនមែនស្វែងរកការបំពេញចិត្តលោកិយពីបដិមានោះឡើយ ពួកគេឆ្លុះបញ្ចាំង និងស្វែងស្វាធដើម្បីទទួលបានការ លើកទឹកចិត្តពីបុគ្គលិកលក្ខណៈដ៏ប្រសើររបស់ពួកគេ ។ពួកគេខិតខំព្យាយាមហ្វឹកហាត់សុក្រឹតភាពរបស់គេដោយគោរពតាមការបង្រៀនដ៏ប្រសើររបស់ព្រះអង្គ។

ពុទ្ធសាសនិកជនគោរពគុណធម៌ធំ និងសន្តិភាពនៃគ្រូសាសនាមួយដែលគេយកមកតំណាងដោយបដិមា។ តាមពិតអ្នកដើរតាមសាសនានិមួយៗបង្កើតបដិមានៃគ្រូសាសនា ដោយឡែករបស់ខ្លួន ទោះជានៅក្នុងទម្រង់មើលឃើញ ឬនៅក្នុងទម្រង់ធម្មារម្មណ៍សម្រាប់គោរពបូជា ដូចនេះវាមិនត្រឹមត្រូវ ឬសមហេតុផលនោះដែរដើម្បីរិះគន់ ពុទ្ធសាសនិកជនដែល ជាអ្នកគោរពបូជារូបសំណាកនោះ។

អំពើនៃការធ្វើអភិវន្ទនាចំពោះព្រះពុទ្ធនេះ មិនមែនជាអំពើដែលផ្អែកលើការភ័យខ្លាច ឬជាអំពើមួយដើម្បីអង្វករសុំប្រយោជន៍លោកិយនោះទេ។ ពុទ្ធសាសនិកជនមានជំនឿថា វាគឺជាអំពើគួរឱ្យសរសើរមួយ និងជាពរជ័យមួយប្រសិនបើពួកគេគោរព និងឱ្យតម្លៃដល់គុណធម៌ធំៗរបស់អ្នកប្រៀនប្រដៅដ៏គួរឱ្យគោរពរបស់ពួកគេ។ ពុទ្ធសាសនិកជនក៏មានជំនឿផង ដែរថាពួកគេមានទំនួលខុសត្រូវចំពោះការជួយសង្គ្រោះផ្ទាល់របស់ពួកគេ និងថាពួកគេគួរពឹងទៅលើផ្នែកទីពនោះទេ។ តែទោះជាយ៉ាងណាក៏ដោយមានអ្នកដទៃដែលជឿថា ពួកគេអាចទទួលបាននូវការសង្គ្រោះតាមរយៈឥទ្ធិពលបដិមា ហើយទាំងនេះគឺជាមនុស្សនេះឯង ដែលបង្កើតចំណាប់អារម្មណ៍បែបនេះឱ្យដល់អ្នកដទៃដើម្បីឆ្លងកំណត់សំគាល់រិះគន់ (caustic remark) ដែលឱ្យយោបល់ថា ពុទ្ធសាសនិកជនចេញពី ការបង្រៀនយើងដឹងថា ព្រះពុទ្ធគឺជា គ្រូដែលបាន

បង្ហាញប្រាប់ ពី មាគ៌ាត្រឹមត្រូវសម្រាប់ ការជួយសង្គ្រោះ ប៉ុន្តែវាស្រេចតែទៅលើ អ្នកដើរតាម ដើម្បីដឹកនាំ ជីវិតសាសនាមួយ និងដើម្បីសំអាត ចិត្តរបស់គេដើម្បីឱ្យសម្រេចបាន សភាពនោះ ដោយមិនពឹងផ្អែកលើគ្រូសាសនារបស់គេឡើយ។ បើតាមព្រះពុទ្ធមិនមានអាទិទេពឬគ្រូសាសនា ដទៃណាមួយដែលអាចបញ្ជូន មនុស្សទៅ ឋានសួគ៌ឬទៅ ឋាននរកនោះទេ។ មនុស្សបង្កើត ឋានសួគ៌ ឬឋាននរកផ្ទាល់របស់គេតាមរយៈ កាយ,វាចា,ចិត្តផ្ទាល់របស់គេ។ ដូច្នេះការបួងសួង ទៅដល់ អ្នកទី៣(a third party) សុំឱ្យជួយសង្គ្រោះដោយមិនកម្ចាត់ គំនិតអាក្រក់ (evil thought)ចេញពីក្នុងចិត្ត(mind)ទេនោះជាការឥតប្រយោជន៍។ យ៉ាងណាក៏ដោយមានមនុស្ស (ក្នុងចំណោមអ្នកកាន់ព្រះពុទ្ធសាសនា) ដែល (ខណៈដែលការសម្តែងពី ការបួងសួងប្រពៃណី ទំនៀមទម្លាប់របស់ពួកគេនៅចំពោះមុខបដិមា) បន្សាត់បង់បញ្ហារបស់ពួកគេពោលគឺ គ្រោះ កាចនិងសេចក្តីលំបាកនានាដោយសុំឱ្យព្រះពុទ្ធជួយឱ្យពួកគេកម្ចាត់បញ្ហារបស់ពួកគេចោល។

បើទោះជាមិនមែនជាការប្រតិបត្តិព្រះពុទ្ធសាសនាពិតមួយក៏ដោយ ក៏អំពើជឿស៊ុបបែប នេះ សម្រេចបានទម្រង់សម្រាលចិត្តរំជួលមួយចំនួននិងការជម្រុញ ចិត្តចំពោះអ្នកបួងសួងដែល ធ្វើឱ្យពួកគេមានលទ្ធភាពទទួលបាននូវសេចក្តីក្លាហាន និងដំណោះស្រាយដើម្បីដោះស្រាយ សេចក្តីលំបាករបស់ពួកគេនោះដែរ។ នេះក៏ជាការប្រតិបត្តិទូទៅមួយនៅក្នុង សាសនាដទៃជា ច្រើន។ ប៉ុន្តែចំពោះអ្នកដែលអាចយល់បានពី ហេតុចម្បងនៃបញ្ហារបស់ពួកគេពួកគេពិតជាមិន អាចពឹង ផ្អែកលើការប្រតិបត្តិបែបនេះរបស់ពួកគេបានទេ។ ពេលព្រះពុទ្ធសាសនាសម្តែងការ គោរពចំពោះ ព្រះពុទ្ធពួកគេគោរពព្រះអង្គដោយសូត្រកំណាព្យមួយចំនួន (some verses) ដែល អធិប្បាយ ពីគុណធម៌ដំបូង១ (pristine virtues) របស់ព្រះអង្គ។ កំណាព្យទាំងនេះមិនមែន ជាការបន់ស្រន់នៅក្នុងន័យសុំឱ្យព្រះអាទិទេព ឬទេវតាដើម្បីលាងជម្រះបាបកម្មរបស់ពួកគេចេញ នោះទេ។ កំណាព្យមានលក្ខណៈធម្មតា ជាបែបសម្តែងវន្ទនាមួយចំពោះ ព្រះបរមគ្រូដែល ទទួលបាននូវការត្រាស់ដឹង និងបានដោះស្រាយមនុស្សជាតិទៅរក មាគ៌ាជីវិតជាក់លាក់មួយ សម្រាប់ភាពល្អប្រសើរ នៃមនុស្សធម៌ទាំងអស់។ ពុទ្ធសាសនិកជនគោរព គ្រូសាសនារបស់គេ ដោយកតវេទិតានៅពេលដែលអ្នកដទៃបន់ស្រន់ និងបួងសួងសុំគុណប្រយោជន៍ និងផលកម្រៃ របស់ពួកគេ។ ព្រះពុទ្ធក៏ទ្រង់បានឱ្យដំបូន្មានដល់យើងឱ្យ"គោរពអ្នកដែលមានកិត្តិយស"។ដូច្នេះ ពុទ្ធសាសនិកជនអាចគោរពនិងឱ្យតម្លៃដល់គ្រូសាសនាណាមួយរបស់គេដែលមានតម្លៃកិត្តិយស (worthy of honour)។

នៅកន្លែងបន់ស្រន់ ពុទ្ធសាសនិកជនប្រតិបត្តិ ការចម្រើនភាវនាសម្រាប់ ការហ្វឹកហាត់ចិត្ត និងអប់រំខ្លួន។ ចំពោះគោលបំណងចម្រើនភាវនា (ជាវត្ថុមួយយ៉ាងចាំបាច់) ដែលវាមិនអាច ងាយស្រួលធ្វើសមាធិទេបើគ្មានវា។ ពុទ្ធសាសនិកជនជួនកាលប្រើបដិមាឬរូបភាពព្រះពុទ្ធជាវត្ថុ មួយដែលពួកគេអាចសមាធិទៅលើបានដើម្បីហ្វឹកហាត់ចិត្តរបស់គេ។

ក្នុងចំណោម វត្ថុចម្រើនភាវនា វត្ថុគំហើញ (visual objects) មានដំណើរប៉ះ ពាល់ល្អជាងទៅលើចិត្ត។ ក្នុងចំណោមវិញ្ញាណទាំង៥ ពោលគឺ វត្ថុដែលបានចាប់បានតាមរយៈ ចក្ខុវិញ្ញាណ (eye-consciousness) នោះមានឥទ្ធិ ពលធំធេងទៅលើចិត្តជាង វត្ថុដែលបានចាប់តាមរយៈវិញ្ញាណដទៃទៀត។ ដូច្នេះវត្ថុដែលបានចាប់បានតាមយៈ ចក្ខុវិញ្ញាណជួយឱ្យ ចិត្តសម្រេចបានសមាធិល្អ និងងាយស្រួលជាងគេ។

បដិមាគឺជា ភាសាអឌ្ឍសម្បជញ្ញៈ (the language of the subconscious)។ ដូច្នេះប្រសិនបើបដិមាអ្នកត្រាស់ដឹងត្រូវបានជះចូលទៅក្នុង ចិត្តរបស់គេជាការតំណាងឱ្យ មនុស្សសុក្រឹតមួយរូបចំណាំងបែបនេះនឹងជ្រាបចូលទៅក្នុង ចិត្តអឌ្ឍសម្បជញ្ញៈ(sub-conscious mind) ហើយប្រសិនបើវារឹងមាំគ្រប់គ្រាន់វា នឹងមានសកម្មភាពជាហ្វ្រាំងស្វ័យប្រវត្តិមួយ(anautomatic brake)ប្រឆាំងចំពោះកម្លាំងជម្រុញអាក្រក់ (evil impulses)នានា។

ព្រះពុទ្ធបដិមាជា វត្ថុគំហើញមួយមានការប៉ះទង្គិច មួយយ៉ាងមានប្រយោជន៍ទៅលើចិត្តសមិទ្ធផលដែលគួរឱ្យចងចាំរបស់ ព្រះពុទ្ធបង្កើតឡើងនូវ សេចក្ដីសប្បាយពោលគឺធ្វើឱ្យចិត្តរឹងមាំឡើង ហើយលើកមនុស្សឡើងពីសភាពអន្ទះអន្ទែង (restlessness) អាយតនាភាព (tension) និងការអាក់អន់ស្រពន់ចិត្ត (frustration)។

ចេតនាមួយក្នុងចំណោមចេតនានានាអំពី ការចម្រើនភាវនា"ពុទ្ធា-នុសាតិ *(Buddha-nussati)* ទៅលើព្រះពុទ្ធគឺដើម្បីបង្កើតអារម្មណស៊ុប និងអារម្មណ៍ទុកចិត្តមួយ (a feeling of devotion and confidence) ទៅលើព្រះពុទ្ធដោយដឹងច្បាស់ និងលើកសរសើរពីឧត្តមភាព (greatness) របស់ព្រះអង្គ។ ដូច្នេះការគោរពបូជាចំពោះពុទ្ធបដិមាគឺសម្រាប់ ការធ្វើសមាធិ ហើយមិនគួរប្រព្រឹត្តជាការគោរពបូជាទេវរូបនោះទេ ប៉ុន្តែត្រូវប្រព្រឹត្តជា ទម្រង់គោរពបូជាដ៏វិសេសមួយ។

**ការធ្វើវន្ទនាការ** (Salutation)

ព្រះធម៌មួយចំនួនដែល ពុទ្ធសាសនិកជន សូត្រដើម្បីរំលឹកពី ព្រះបរមគ្រូ របស់ពួកគេជាសញ្ញាគោរពមួយនៅក្នុងន័យកតញ្ញូកតវេទិតានិងនៅក្នុងន័យលើកសរសើរពី ព្រះពុទ្ធ នោះមានដូចខាងក្រោម :

"នមោ តស្ស: ភគវតោ អរហត្តោ សម្មាសម្ពុទ្ធតស្ស: លើកសរសើរពីព្រះអង្គ ពោលគឺ អ្នកមានពរជ័យ (the Blessed One), អ្នកមានតម្លៃ(the Worthy One), អ្នកត្រាស់ដឹងដោយបរិបូណ៌ (the fully Enlightened One) "។

ជាបន្តទៅទៀតនេះពួកគេបានសូត្រកំណាព្យ ជាបន្តទៅទៀតនេះពួកគេបានសូត្រកំណាព្យមួយចំនួនដែលពន្យល់ពី គុណសម្បត្តិ និងគុណធម៌ដ៏ធំធេងរបស់ព្រះពុទ្ធដូចជា :

*"ឥតិ បិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជា ចរណ-សម្បន្នោ សុគតោ លោកវិទូ អនុត្តរោ ពោរិស: ធម្ម-សារថិ សត្ថា ទេវ: មនុស្សានំ ពុទ្ធោ ភគវា ទិ"*។

ការសូត្រទាំងនេះជា ភាសាបាលី។ ប្រសិនបើអ្នកមិនចេះភាសាបាលីនេះទេ អ្នកអាចសូត្រ កំណាព្យនេះជាភាសាណាមួយដែលអ្នកអាចយល់បាន។ ការបកប្រែជាភាសាអង់គ្លេសមានដូចតទៅ :

"មានខ្លឹមសារថា អ្នកមានពរជ័យ គួរឱ្យលើកតម្កើង (Exalted) ចេះដឹងសព្វគ្រប់ (all-knowing) ផ្តល់នូវពុទ្ធិនិងគុណធម៌។ មានកិរិយាប្រពៃ(Well-gone), អ្នកដឹងពីលោកនានា (Knower of worlds)។ មគ្គទេសក៏គ្មានគូប្រៀបចំពោះការហ្វឹកហាត់បុគ្គលម្នាក់ៗ។ ជាគ្រូនៃមនុស្សនិង ទេពតា, ត្រាស់ដឹងនិង ល្អពិសិដ្ឋ។"

**រឿងព្រះពុទ្ធសាសនា** (A Buddhist Story)

នេះគឺជារឿងមួយដែលនឹងជួយយើងឱ្យយល់បានពីហេតុដែល ព្រះពុទ្ធបដិមា មានសារៈសំខាន់ធ្វើឱ្យនឹកឃើញនិងពីព្រះពុទ្ធចូលទៅក្នុងចិត្តរបស់យើង ។រឿងនេះរកឃើញនៅក្នុងអក្សរសិល្ប៍ព្រះពុទ្ធសាសនា ប៉ុន្តែមិនមែនជារឿង Tipitaka បាលីនោះទេ។

អស់ពេលពីរបីរយឆ្នាំមកបន្ទាប់ពី ព្រះពុទ្ធយាងចូលនិព្វានទៅមាន ព្រះសង្ឃជឿស៊ុបមួយ អង្គនៅក្នុងប្រទេសឥណ្ឌាមានឈ្មោះថា Upagupta។ លោកគឺជា អ្នកទេសនាដ៏មានប្រជាប្រិយបំផុតនៅសម័យនោះ ។នៅពេលណាគាត់សម្តែងទេសនាម្តងៗទៅលើព្រះធម៌មនុស្សរាប់ពាន់នាក់នាំគ្នាចូលមកស្តាប់គាត់។

មានថ្ងៃមួយនោះ Mara ជាអ្នកដែលមានចិត្តឆេវឆាវមានចិត្តច្រណែននឹង ប្រជាប្រិយភាពរបស់ Upagupta។ Mara បានដឹងថា ប្រជាប្រិយភាពរបស់ Upaguptaកំពុងតែជួយពង្រីកផ្សព្វផ្សាយពីការបង្រៀនរបស់ព្រះពុទ្ធ។ គាត់មិនសប្បាយចិត្តនឹងស្តាប់សម្តីរបស់ព្រះពុទ្ធដែលបំពេញចិត្ត បំពេញថ្លើមមនុស្សម្នាទាំងឡាយនោះឡើយ។ គាត់បានបង្កើតគម្រោងមួយដើម្បីបញ្ឈប់មនុស្សម្នាកុំឱ្យស្តាប់ ធម្មទេសនារបស់ Upagupta។ នៅថ្ងៃមួយនោះ ជាពេលដែល Upagupta បានចាប់ផ្តើម ធម្មទេសនារបស់គាត់ទៀត Mara បានរៀបចំ ល្ខោនមួយនៅជិតកន្លែងដែល Upagupta សម្តែងទេសនាដែរ។ រំពេចនោះការបង្ហាញឈុតដ៏ស្រស់ស្អាតមួយក៏បានកើតឡើងដែរ។ មានស្រីរបាំស្អាតៗនិងតន្ត្រីកររស់រវើក។

រំពេចនោះមនុស្សម្នាភ្លេចអំពីធម្មទេសនាហើយដើរកាត់ទៅរកការសម្តែងដើម្បីសប្បាយរីករាយជាមួយនឹងការសម្តែងនោះ។ Upagupta សម្លឹងមើលមនុស្សដែលកំពុងតែដើរចេញទៅនោះដោយយឺតៗ។ បន្ទាប់មកគាត់ក៏បាន សម្រេចចិត្តចូលរួមជាមួយហ្វូងមនុស្សទាំងនោះ។ ក្រោយមកគាត់ក៏បានសម្រេចចិត្តបង្រៀន Maraមួយមេរៀន។

ពេលដែលការសម្តែងបានបញ្ចប់ Upagupta បានរៀបពន្យល់ Mara ជាមួយនឹងកម្រងផ្កាមួយ។ អ្នកបានរៀបចំការសម្តែងដ៏អស្ចារ្យមួយ" Ven. Upagupta និយាយ តាមពិតទៅ Mara សប្បាយចិត្ត និងមានមោទនភាពពីសមិទ្ធផលរបស់ខ្លួនជាខ្លាំង។ គាត់សប្បាយរីករាយនឹង ទទួលយក *កម្រងផ្កា* ពី Upagupta ហើយងើយក្បាលរបស់គាត់កប់អាកាស។

រំពេចនោះវាបានកើតឡើង : កម្រងផ្កាក្លាយជា ចង្វាយដូចពស់ (snake-like coil) បន្តិចម្តងៗចង្វាយបានរឹត រួតកាន់តែតឹងទៅៗរហូតដល់វារឹតកគាត់ដល់ឈ្លក់។ ចង្វាយរឹតរួតកគាត់ឈឺជាខ្លាំង គាត់ខិតខំរើចេញពីចង្វាយនោះ។ ជាការឥតប្រយោជន៍ ទោះជាគាត់ខិតខំប្រឹងរើយ៉ាងណាក៏ដោយ ក៏មិនអាចដោះចង្វាយនោះបានឡើយ។ គាត់ក៏សម្រេច ចិត្តសុំឱ្យជំនួយពី Sakka ជាស្តេចនៃទេវតាទាំងអស់ឱ្យជួយដោះចង្វាយនេះ។ Sakkaនៅតែមិនអាចដោះចង្វាយនោះបានទៀត។ "យើងមិនអាចដោះចង្វាយនេះបានទេ" Sakka និយាយ "សូមទៅជួបមហាព្រហ្មជាអ្នកដែលមានឫទ្ធានុភាពបំផុត)"។

ដូច្នេះ Mara បានទៅជួបមហាព្រហ្មហើយសុំឱ្យគាត់ជួយ ប៉ុន្តែមហាព្រហ្មក៏មិនអាចធ្វើអ្វីបានទៀត។ "យើងមិនអាចដោះចង្វាយនេះបានទេ អ្នកដែលអាចដោះចង្វាយនេះបានគឺមាន

តែអ្នកដែលដាក់វាលើអ្នកនោះទេ" មហាព្រហ្មបាននិយាយ។ ដូច្នេះ Mara ត្រូវតែត្រឡប់មករក Upagupta វិញ។

"សូមអ្នកជួយដោះចង្វាយនេះផង វាឈឺខ្លាំងណាស់" គាត់បានអង្វរ។ "ពិតហើយខ្ញុំអាចដោះវាបាន តែត្រូវគោរពលក្ខខណ្ឌពីរ" Upagupta និយាយ។ "លក្ខខណ្ឌទី១គឺថា អ្នកត្រូវតែសន្យាថាកុំមករំខានអ្នកជឿព្រះពុទ្ធសាសនាអ្វីទៀតទៅថ្ងៃមុខ។ លក្ខខណ្ឌទី២ អ្នកត្រូវតែបង្ហាញខ្ញុំនូវរូបព្រះពុទ្ធ។ ពីព្រោះខ្ញុំដឹងថាអ្នកបានឃើញព្រះអង្គនៅក្នុងឱកាសជាច្រើន ប៉ុន្តែខ្ញុំមិនដែលបានឃើញព្រះអង្គទេ។ ខ្ញុំចង់ឃើញរូបព្រះពុទ្ធពិត ពិតដូចជាព្រះអង្គអញ្ជើងដោយមានលក្ខណៈនៃរូបកាយពិសេស៧ចំនួន៣២"។

Mara សប្បាយជាខ្លាំង។ គាត់ក៏បានយល់ព្រមជាមួយ Upagupta។ "ប៉ុន្តែមានវត្ថុតែមួយទេ" Mara ឆ្លើយតប "ប្រសិនបើខ្ញុំប្តូរខ្លួនខ្ញុំទៅជា រូប របស់ ព្រះពុទ្ធ អ្នកត្រូវតែសន្យាថាអ្នកនឹងមិនគោរពបូជាខ្ញុំទេ ពីព្រោះខ្ញុំមិនមែនជា មនុស្សពិសិដ្ឋដូចលោកទេ"។

"ខ្ញុំនឹងមិនគោរព បូជាលោកទេ" Upagupta បានសន្យា។

រំពេចនោះMara បានបញ្ជូនខ្លួនគាត់ទៅជារូបមួយដែលមើលទៅដូច ព្រះពុទ្ធសុទ្ធសាធ។ នៅពេល Upagup-ta ឃើញ រូបភ្លាម បេះដូងរបស់គាត់ត្រូវបំពេញទៅដោយ ការជម្រុញចិត្តជាខ្លាំងការជឿស៊ុបដ៏ជ្រាលជ្រៅបានកើតមានឡើង នៅក្នុងចិត្តរបស់គាត់ដោយដៃទាំងពីរសំពះភ្លាមនោះគាត់បានគោរព រូបព្រះពុទ្ធ។

"*អ្នកមិនគោរពកិច្ចសន្យារបស់អ្នកទេ*" Mara ស្រែកឡើងថា "*អ្នកសន្យាថា អ្នកមិនគោរពខ្ញុំទេ។ ឥឡូវនេះហេតុ អ្វីបានជាអ្នកគោរពខ្ញុំទៅវិញ?*"

"*ខ្ញុំមិនកំពុងគោរពអ្នកទេ។ អ្នកត្រូវតែយល់ខ្ញុំកំពុងគោរពព្រះពុទ្ធទេតើ* " Upagupta តប។

ទាញចេញពីខ្លឹមសាររឿងនេះ យើងអាចយល់បានពីហេតុដែល ពុទ្ធបដិមា មានសារៈសំខាន់ជម្រុញចិត្តយើង និងដើម្បីជួយយើងឱ្យនឹកឃើញពីព្រះពុទ្ធដ៏ប្រសើរបំផុត ចូលមកក្នុងចិត្តរបស់យើងដែលអាចឱ្យយើងគោរពព្រះអង្គបាន។ យើងដែលជាពុទ្ធសាសនិកជនមិនគោរពនិមិត្តរូបឬទម្រង់រូបធាតុដែលគ្រាន់តែជាការតំណាងឱ្យព្រះពុទ្ធនោះទេ។ យើងសម្តែងការគោរពចំពោះព្រះពុទ្ធ។

**ពលទេគមតពីពុទ្ធបដិមា** (Inspirations from Buddha Image)

ព្រះពុទ្ធទ្រង់បានយាងចូលមហាបរិនិព្វាន *(Maha Parinibbana)* បាត់ទៅហើយ។ ព្រះអង្គមិនត្រូវការ ការគោរពបូជា ឬ តង្វាយអ្វីឡើយ ផ្ទុយទៅវិញ លទ្ធផលនៃ ការគោរពបូជានឹងតាមជាប់មកហើយមនុស្សម្នា នឹងទទួលបានប្រយោជន៍ដោយការដើរតាមគំរូរបស់ព្រះអង្គ និងការឆ្លុះបញ្ចាំងទៅលើការបូជាកំពូលរបស់ព្រះអង្គនិងគុណសម្បត្តិដ៏មហាសាល ។ពុទ្ធសាសនិកជន មិនបានថ្វាយការបូជាសត្វនៅក្នុងនាម ព្រះពុទ្ធនោះទេ។

ពេលពុទ្ធសាសនិកជនមួយចំនួនមើលឃើញ ពីពុទ្ធបដិមាការជឿស៊ុបនិងសុភមង្គលកើតមានឡើងនៅក្នុងចិត្តរបស់គេ។ ការជឿស៊ុបឬ សុភមង្គលនេះបង្កើតគំនិតគួរឱ្យសរសើរនៅក្នុងចិត្តរបស់ពុទ្ធសាសនិកជនដែល ជឿស៊ុបនោះ។ ព្រះពុទ្ធបដិមាក៏បានជួយ មនុស្សឱ្យបំភ្លេចទុក្ខព្រួយទោមនស្សនិង បញ្ហារបស់ពួកគេ ហើយនិងជួយពួកគេឱ្យមានការគ្រប់គ្រងលើ ចិត្តរបស់ពួកគេ ផងដែរ។

ទស្សនវិទូ ប្រវត្តិវិទូ និង អ្នកប្រាជ្ញល្បីៗនៅក្នុងពិភពពិតធ្លាប់បានរក្សាទុក ព្រះពុទ្ធរូបនៅលើតុនៅក្នុងបន្ទប់អានរបស់ពួកគេដើម្បីទទួលបាននូវពលវេគ(កម្លាំងជម្រុញចិត្ត)សម្រាប់ជីវិតនិងគំនិតខ្ពស់។ ពួកគេជាច្រើនមិនមែនជាពុទ្ធសាសនិកជនទេ។ មនុស្សជាច្រើនលើកសរសើរឪពុកម្តាយ គ្រូ មហាវិរបុរស ក្សត្រា និងក្សត្រីអ្នកដឹកនាំនយោបាយ និងជាតិ និងមនុស្សដែលគួរឱ្យស្រឡាញ់ដទៃទៀត ដែលបានចែកឋានទៅរបស់ពួកគេដោយរក្សារូបថត របស់ពួកគេដើម្បីទុករំលឹកពីសេចក្តីស្រឡាញ់របស់ពួកគេ។ ពួកគេដាក់ផ្កាដើម្បីសម្តែងពីអារម្មណ៍ស្រឡាញ់កតវេទិតា គរុការភាព (reverence), គុណតម្លៃ និងការជឿស៊ុបរបស់ពួកគេ។ ពួកគេរំលឹកពីគុណសម្បត្តិដ៏ធំធេងរបស់ពួកគេ និងការនឹកឃើញដោយមោទនភាព ការធ្វើពលិកម្ម និងសេវាកម្មដែលបានសាយភាយដោយពួកគេកាលពីនៅរស់។

មនុស្សម្នាក៏បានតម្កល់ រូបចម្លាក់នៅក្នុងលំនឹកគិតនៃ អ្នកដឹកនាំនយោបាយ ដែលបានសម្លាប់មនុស្សស្លូតត្រង់រាប់លានអ្នក។ តាមរយៈភាពឃោរឃៅរបស់ពួកគេ និងសេចក្តីលោភចង់បានអំណាច ពួកគេបានឈ្លានពានទៅលើប្រទេសក្រីក្រ និងបង្កើតទុក្ខព្រួយទារុណកម្ម និងទុគិតភាពហួសពីនិយាយបានដោយគំនរទណ្ឌកម្មរបស់ពួកគេ ហើយសេវាកម្មអនុស្សាវរីយ៍ត្រូវបានគេប្រព្រឹត្តនៅក្នុងកិត្តិយសរបស់ពួកគេហើយ និងផ្កាដែលដាក់នៅលើផ្នូរពួកគេ។ ប្រសិនបើការប្រតិបត្តិបែបនេះអាចត្រូវបានធ្វើឱ្យត្រឹមត្រូវបាន ហេតុអ្វីបានជាមនុស្សមួយចំនួនចំអក

ដាក់អ្នកដើរតាមព្រះពុទ្ធជា អ្នកគោរពទេវរូបពេលពួកគេគោរពគ្រូសាសនារបស់គេ ដែលបានជួយស្រោចស្រង់មនុស្សជាតិដោយគ្មានការបង្កទុក្ខទោស ដល់អ្នកដទៃ ហើយដែលបានយកឈ្នះលើពិភពលោកទាំងមូលដោយសេចក្តីស្រឡាញ់មេត្តា និងគតិបណ្ឌិត?

តើអ្នកណាម្នាក់នៅក្នុងគំនិតត្រឹមត្រូវនិយាយថា អំពើសម្តែងវន្ទនាការចំពោះព្រះពុទ្ធបដិមានេះគឺជាអំពើគ្មានការអប់រំ និងអសីលធម៌ ឬមានទុក្ខទោសដូចជារំខានដល់សន្តិភាព និងសុភមង្គលរបស់មនុស្សទៅវិញ ?

ប្រសិនបើបដិមាមិនមានសារៈសំខាន់អ្វីសោះសម្រាប់មនុស្សដើម្បីប្រតិបត្តិសាសនាមួយនៅពេលនោះ និមិត្តរូប សាសនា និងទីកន្លែងគោរពបូជាក៏មិនមានសារៈសំខាន់ដែរ។ ពុទ្ធសាសនិកជនត្រូវបានគេចំអកដោយមនុស្សមួយចំនួនថា ជាអ្នកគោរពថ្ម។ ប៉ុន្តែបើទោះជា អំណះអំណាងអវិជ្ជាបែបនេះត្រឹមត្រូវដែរ ពោលគឺការគោរពថ្មមិនមានទុក្ខទោស និងមានលក្ខណៈគួរឱ្យគោរពជាងការគប់ដុំថ្មដាក់អ្នកកាន់សាសនាដទៃទៀតដែរ។

**សារៈសំខាន់នៃការប្រតិបត្តិ** (The Importance of Practice)

ដើម្បីប្រតិបត្តិ ការបង្រៀនរបស់ព្រះពុទ្ធ វាមិនមែនជាការខានមិនបានសម្រាប់មនុស្សម្នាក់ដើម្បីធ្វើវន្ទនាការចំពោះ ព្រះពុទ្ធបដិមានោះទេ។ ពុទ្ធសាសនិកជន អាចប្រតិបត្តិសាសនារបស់គេដោយគ្មានព្រះពុទ្ធបដិមាបានពួកគេ អាចធ្វើប្រតិបត្តិនេះពីព្រោះព្រះពុទ្ធមិនបានជម្រុញឱ្យមនុស្សពឹងផ្អែកលើបុគ្គលិកលក្ខណៈណាមួយនោះទេ។ បើតាមការបង្រៀនរបស់ ព្រះពុទ្ធពុទ្ធសាសនិកជនមិនគួរពឹងផ្អែកទៅលើអ្នកដទៃនោះទេមិនពឹងសូម្បីតែព្រះពុទ្ធព្រះអង្គឯងសម្រាប់ការស្រោចស្រង់របស់ពួកគេនោះទេ។

នៅក្នុងសម័យ ព្រះពុទ្ធមាន ព្រះសង្ឃមួយអង្គមាននាមថា Wakkali។ ព្រះសង្ឃអង្គនេះជានិច្ចកាលតែងតែអង្គុយនៅមុខ ព្រះពុទ្ធ ហើយលើកសរសើរពី សោភ័ណភាពនៃលក្ខណៈរូបកាយរបស់ព្រះពុទ្ធ។ សង្ឃអង្គនោះមានសង្ឃដិកាថា ព្រះអង្គទទួលបានសុភមង្គលនិងកម្លាំងជម្រុញចិត្តដ៏មហិមាដោយសារ តែលើកសរសើរសោភ័ណ្ឌភាពរបស់ព្រះពុទ្ធនេះឯង។ ព្រះពុទ្ធទ្រង់បានឆ្លើយតបទៅវិញថា "អ្នកមិនអាចមើលឃើញពី ព្រះពុទ្ធពិតដោយការសម្លឹងមើលទៅលើរូបកាយនោះឡើយ។ អ្នកដែលយល់ឃើញពីការបង្រៀនរបស់ តថាគតទើបអ្នកនោះមើលឃើញតថាគតបាន " ។

ទិដ្ឋភាពសំខាន់បំផុតនៅក្នុង ព្រះពុទ្ធសាសនាគឺត្រូវប្រតិបត្តិ ដំបូន្មានដែលព្រះពុទ្ធទ្រង់បានផ្តល់ឱ្យ ។នៅក្នុងទិដ្ឋភាពនេះវាមិនបានធ្វើឱ្យមានភាពខុសគ្នាថាតើពុទ្ធសាសនិកជនធ្វើវន្ទនាការចំពោះព្រះសម្មាសម្ពុទ្ធឬក៏អត់នោះទេ។ ប៉ុន្តែចំពោះអ្នកជឿស៊ុបជាច្រើនវា គឺជាសកម្មភាពសំខាន់មួយ។ តែទោះជាយ៉ាងណាក៏ដោយ ព្រះពុទ្ធមិនបានមានពុទ្ធដីកាថា ព្រះអង្គកំពុងរង់ចាំការធ្វើវន្ទនាការនោះទេ ។

**ប្រភពព្រះពុទ្ធបដិមា** (Origin of the Buddha Image)

តើ ព្រះពុទ្ធបដិមាចាប់កំណើតឡើងយ៉ាងដូចម្តេច ? វាជាការលំបាកនឹងរកឱ្យឃើញថាតើគំនិតនេះ ព្រះពុទ្ធទ្រង់បានឱ្យដែរឬក៏អត់។ នៅក្នុងគម្ពីរព្រះពុទ្ធសាសនាគ្មានកន្លែងណាមួយដែលព្រះពុទ្ធទ្រង់បានតម្រូវថា ត្រូវកសាងរូបរបស់ព្រះអង្គនោះឡើយ។ តែទោះជាយ៉ាងណាក៏ដោយព្រះពុទ្ធទ្រង់បានអនុញ្ញាតឱ្យថែរក្សាព្រះសិរីរិកធាតុរបស់ព្រះអង្គដែរ។

មានពេលមួយនោះព្រះអានន្ទចង់ដឹងថា ប្រសិនបើមានការអនុញ្ញាតឱ្យកសាងវត្ត *(chetiya)* ក្នុងការនឹកឃើញ ពីព្រះពុទ្ធដែលជាវិធីគោរពមួយចំពោះព្រះអង្គ។ ដូច្នេះ ព្រះអានន្ទបានសួរទៅព្រះសម្មាសម្ពុទ្ធថា "តើវាជាការសមរម្យដែរឬទេ ព្រះគុណម្ចាស់ដើម្បីកសាងវត្តខណៈពេលដែលព្រះគុណម្ចាស់នៅមានព្រះជន្មនៅឡើយ ? "

ព្រះពុទ្ធទ្រង់ត្រាស់សម្តែងថា "ទេវាមិនជាការសមរម្យទេខណៈពេលដែល តថាគត នៅមានព្រះជន្មនៅឡើយនោះ។ អ្នកអាចកសាងវត្តគោរពបូជានេះតែក្រោយពីតថាគតយាងចូលព្រះនិព្វានតែប៉ុណ្ណោះ។"

នៅក្នុងធម្មទេសនាចុងក្រោយ សូត្រមហាបរិនិព្វាន *(Maha Parinibbana Sutta)* ព្រះពុទ្ធទ្រង់ឱ្យដំបូន្មាន ដល់សាវ័ករបស់ព្រះអង្គថា ប្រសិនបើគេមានបំណងចង់គោរពបូជាចំពោះព្រះពុទ្ធបន្ទាប់ពីព្រះអង្គយាងចូលនិព្វាន ទៅពួកគេអាចកសាងវត្តដើម្បីតម្កល់ព្រះសិរីរិកធាតុព្រះកាយ (the bodily relics)បាន។ ដំបូន្មាននេះត្រូវបានគេថែ រក្សាទុកជាប្រពៃណីនៅសម័យនោះនៅក្នុងប្រទេសឥណ្ឌា ប្រពៃណីគឺត្រូវការសាងវត្តដើម្បីរក្សារបស់សំខាន់ៗ (relics) របស់មនុស្សពិសិដ្ឋៗ។ របស់សំខាន់ៗ (relics)ត្រូវបានគេរក្សាទុកជា អនុស្សាវរីយ៍ដោយសារការគោរពចំពោះមនុស្សពិសិដ្ឋៗ។ នៅពេលដូចគ្នានេះ ព្រះពុទ្ធព្រះអង្គឯងមិនបានជម្រុញ ឬជម្រុញ ឱ្យសាវ័ករបស់ព្រះអង្គកសាង បដិមាខ្លួនព្រះអង្គក្រោយពេលព្រះអង្គចូលនិព្វាននោះទេ។ គំនិតដើម្បីកសាងព្រះពុទ្ធបដិមាមកពី គំនិតរបស់សាវ័ករបស់ព្រះអង្គដែលចង់គោរព

បូជាដល់ អ្នកដឹកនាំជាទីស្រឡាញ់របស់ពួកគេពេក ហើយនិងទទួលបាននូវ កម្លាំងជម្រុញចិត្ត ខាងសាសនា មកពីបុគ្គលិកលក្ខណៈស្ងប់ស្ងាត់មួយបែបនេះ។ ពួកគេក៏ធ្លាប់តម្កល់ ព្រះសិរីរឹក ធាតុរបស់ព្រះពុទ្ធពេលបដិមាត្រូវបានគេកសាងហើយផងដែរ។

Fa-hsien ជាអ្នកដែលបានធ្វើទស្សនៈកិច្ចនៅឥណ្ឌានៅចុង ស.វ.ទី៤ បាននិយាយនៅក្នុងកំណត់ត្រារបស់គាត់ ពីព្រះពុទ្ធបដិមាដំបូងត្រូវបានគេកសាងយ៉ាងដូចម្ដេច។ តែទោះជាយ៉ាងណាក៏ដោយគម្ពីរព្រះពុទ្ធសាសនាមិនមាននិយាយ ពីការសង្កេតមើលរបស់Fa-hsien នេះទេ។ យ៉ាងណាក៏ដោយកំណត់ត្រាទេវកថាវិទ្យាមានដូចតទៅ :

កាលពីពេល ព្រះសម្មាសម្ពុទ្ធចំណាយពេល បីខែនៅស្ថានសួគ៌ ដោយសម្ដែងធម្មទេសនាពីព្រះអភិធម្ម *(Abhid-hamma)*ឬលទ្ធិខ្ពស់។ អំឡុងពេលអវត្តមានរបស់ព្រះអង្គមនុស្សដែលបានទៅវត្តមានលក្ខណៈមិនសប្បាយរីករាយ ព្រោះគេមិនបានឃើញព្រះពុទ្ធ។ ពួកគេចាប់ផ្ដើមត្អូញត្អែរ។ Sariputta ជាសាវ័កឆ្មើមបានទៅជួបព្រះអង្គហើយទូលថ្វាយពីស្ថានភាពចំពោះព្រះពុទ្ធ។ ព្រះពុទ្ធទ្រង់ឱ្យដំបូន្មានដល់គាត់ឱ្យស្វែងរកមនុស្សម្នាក់ដែលអាចបង្កើតបដិមាមួយដែលមើលទៅដូចព្រះអង្គសុទ្ធសាធនៅពេលនោះមនុស្សម្នាទាំងឡាយ សប្បាយរីករាយ នឹងឃើញបដិមាព្រះពុទ្ធ។ Sariputta បានត្រឡប់ទៅវិញហើយទៅគាល់ព្រះមហាក្សត្រដើម្បី សុំឱ្យព្រះអង្គជួយរកមនុស្សដែលអាចកសាងព្រះពុទ្ធរូបបាន។មិនយូរប៉ុន្មានជាងចម្លាក់នោះបានរកឃើញហើយគាត់ឆ្លាក់បដិមាដោយ ឈើច័ន្ទក្រស្នា (sandal wood) ក្រោយពីបដិមាត្រូវបានគេយកមកតម្កល់នៅក្នុងព្រះវិហារហើយមនុស្សម្នាទាំងឡាយបែរជាសប្បាយរីករាយជាខ្លាំងចាប់ពីពេលនោះមកបើតាម Fa-hsien មនុស្សចាប់ផ្ដើមចម្លងរូបចម្លាក់ព្រះពុទ្ធនេះ។

ប៉ុន្តែវាពិបាករកភស្តុតាងនៅក្នុង អក្សរសិល្ប៍ និងប្រវត្តិសាស្ត្រព្រះពុទ្ធសាសនា ដើម្បីគាំទ្រដល់អត្ថិភាពនៃ ព្រះពុទ្ធបដិមានៅក្នុងប្រទេសឥណ្ឌារហូតមកដល់ ដើមឆ្នាំ៥00 បន្ទាប់ពីព្រះពុទ្ធយាងចូលនិព្វាន។ នៅសម័យនោះ អ្នកជឿស៊ុបធ្លាប់គោរពបូជា ព្រះពុទ្ធដោយរក្សា ផ្កាឈូកមួយទង ឬតែរូបព្រះពុទ្ធបាទប៉ុណ្ណោះ។ វាលេចឡើងថាកាលពីចំណាប់ផ្ដើមដំបូងពុទ្ធសាសនិកជនមួយចំនួនក៏មិនពេញចិត្តចំពោះការកសាងពុទ្ធបដិមានេះដែរព្រោះវាអាចថាលក្ខណៈលេចធ្លោររបស់ព្រះពុទ្ធអាចត្រូវខូចទ្រង់ទ្រាយ។

អ្នកប្រវត្តិសាស្ត្រជាច្រើនបានអះអាងថា ព្រះពុទ្ធបដិមា ត្រូវបានកសាងឡើងលើកដំបូងនៅក្នុងប្រទេសឥណ្ឌានៅចំអំឡុងពេលនៃសម័យកាលក្រិក។ក្រិកបានជួយនិងជម្រុញឱ្យមនុស្ស

ឥណ្ឌានៅក្នុងសិល្បៈកសាង ព្រះពុទ្ធបដិមា។ ព្រោះនៅពេលនោះ មនុស្សនៅក្នុងប្រទេស ឥជា ច្រើនចាប់ផ្តើមកសាងបដិមា។ បដិមានៅក្នុងប្រទេសផ្សេងៗត្រូវ បានគេឆ្លាក់ដោយអនុលោម តាមរចនាបថ និងសម្តែងសិល្បៈតំណាងឱ្យលក្ខណៈរូបរបស់មនុស្សទៅតាមប្រទេសពិសេសៗ។ នៅក្នុងប្រទេសដែលគោរព ព្រះពុទ្ធសាសនានីមួយៗរចនាបថនៃពុទ្ធបដិមាក៏វិវត្តចូលទៅក្នុង ទម្រង់ខុសៗគ្នា និងរចនាបថដែលអនុលោមតាមសម័យកាលប្រវត្តិសាស្ត្រខុសៗ គ្នារបស់វាដែរ។

**អ្វីដែលបញ្ញវន្តនិយាយអំពីព្រះរូបនាពព្រះពុទ្ធ** (What Intellectuals say about Buddha Image)

Pandit Nehru អតីតនាយករដ្ឋមន្ត្រីឥណ្ឌាបានធ្វើការកត់សំគាល់ព្រះពុទ្ធបដិមាដូចតទៅ :

"មាន ព្រះនេត្រទាំងគូបិទ ប៉ុន្តែ ឬទ្ធានុភាពផ្លូវចិត្តមួយចំនួនសម្លឹងមើលដោយព្រះនេត្រ នោះហើយ ថាមពលជីវិត ពេញទៅដោយអារម្មណ៍ (frame)។ The ages rolls by ហើយជា ចុងក្រោយព្រះពុទ្ធហាក់ដូចជា មិននៅឆ្ងាយសម្លេងព្រះអង្គនៅនឹងត្រចៀកយើងហើយប្រាប់ យើងកុំបោះបង់ចោលការតស៊ូ ប៉ុន្តែត្រូវតាំងចិត្តដោយស្ងប់ស្ងាត់ (calm-eyed) ដើម្បីប្រឈម មុខតទល់នឹងវានិងដើម្បីមើលទៅក្នុងជីវិត មានឱកាសដ៏អស្ចារ្យៗសម្រាប់ការរីកចម្រើន។" លោកក៏បានបន្តទៀតថា"ពេលខ្ញុំនៅក្នុងគុកខ្ញុំធ្លាប់គិតអំពីរូបចម្លាក់នេះហើយវាគឺជាប្រភពមួយ នៃកម្លាំងជម្រុលចិត្តដល់ខ្ញុំខ្លាំងណាស់"។

អំឡុងសម័យសង្គ្រាមលោកលើកទី២ឧត្តមសេនីយ Ian Hamilton បានរកឃើញ ព្រះ ពុទ្ធបដិមាមួយនៅក្នុងវិហារបាក់បែកមួយនៅភូមា។លោកបានបញ្ជូនបដិមានេះទៅ Winston Churchil ដែលនៅពេលនោះលោក គឺជានាយករដ្ឋមន្ត្រីនៃចក្រភពអង់គ្លេសជាមួយនឹងពាក្យថា :

"នៅពេលអ្នកមានទុក្ខកង្វល់អ្នកគ្រាន់តែមើលទៅ ឥរិយាបថស្ងប់ស្ងាត់នេះហើយញញឹម ដាក់ទុក្ខកង្វល់របស់អ្នកនឹងរលាយបាត់ "។

Count Keyserling ទស្សនវិទូអាល្លឺម៉ង់បាននិយាយថា "ខ្ញុំមិនស្គាល់អ្វីធំនៅក្នុងលោក នេះជាងស្គាល់ព្រះពុទ្ធរូបទេ។ វាជាការតំណាងផ្លូវចិត្តដ៏សុក្រឹតឥតប្រែប្រួលនៅក្នុងដែន ដែល អាចមើលឃើញបាន (visible domain)"។ អ្នកប្រាជ្ញម្នាក់ទៀតនិយាយថា :

"ពុទ្ធបដិមា ដែលយើងបានឃើញគឺជាការតំណាងនិមិត្តរូបនៃ គុណសម្បត្តិនានា។ វន្ទនា ការ និងការគោរពដែលបានធ្វើចំពោះព្រះពុទ្ធគឺមាន ប៉ុន្តែការគោរពជានិមិត្តរូបនៃភាពអស្ចារ្យ របស់ព្រះអង្គនិងសុភមង្គលដែលយើងរកឃើញនៅក្នុងការបង្រៀនរបស់ព្រះអង្គ។"

ពុទ្ធបដិមាស្ងប់ស្ងាត់ជាគំនិតរួមមួយចំពោះសោភ័ណភាពឥតខ្ចោះ ។ពុទ្ធបដិមាគឺជាសម្បត្តិរួមនិងមានតម្លៃបំផុត នៅក្នុងវប្បធម៌អាស៊ាន។ បើគ្មានពុទ្ធបដិមាទេ អាស៊ានក៏គ្មានអ្វីជាជាងការសម្តែងពីទីតាំងភូមិសាស្ត្រនោះដែរ ពោលគឺ វិបុលភាពនេះឯង ។

ពុទ្ធសាសនិកជនគោរពចម្លាក់ព្រះពុទ្ធជាបូជនីយដ្ឋាននៃគ្រូសាសនាអស្ចារ្យបំផុត វៃឆ្លាតបំផុតសុក្រឹតបំផុត និងមេត្តាបំផុតដែលរស់នៅៗក្នុងលោកនេះ។ បដិមាជាការចាំបាច់បំផុតសម្រាប់រំលឹកពីព្រះពុទ្ធនិងគុណសម្បត្តិអស្ចារ្យៗរបស់ព្រះអង្គដែលជម្រុញចិត្តមនុស្សរាប់លាននាក់ពីជំនាន់មួយទៅជំនាន់មួយពាសពេញពិភពលោកដែលមានអារ្យធម៌។ បដិមានេះជួយឱ្យពួកគេមានសមាធិទៅរកព្រះអង្គ។ ពួកគេមានអារម្មណ៍នៅក្នុងចិត្តរបស់ពួកគេនូវព្រះវត្តមានព្រះគ្រូមានជីវិតដើម្បីឱ្យសកម្មភាពគោរពបូជារបស់ពួកគេអាចរស់រវើកនិងមានសារៈសំខាន់។

ជាពុទ្ធសាសនិកជនម្នាក់វាជាការសមរម្យបំផុត សម្រាប់អ្នកដែលត្រូវមានព្រះពុទ្ធបដិមា ឬ រូបភាពព្រះពុទ្ធនៅក្នុងផ្ទះរបស់អ្នក។ សូមថែរក្សាបដិមា ឬរូបភាពនេះមិនមែនជាការតុបតែងលំអនោះទេ ប៉ុន្តែជាវត្ថុដ៏ប្រសើរជម្រុញកម្លាំងចិត្ត និងស្រឡាញ់ជ្រាលជ្រៅបំផុត។ រូបស្ងប់របស់ព្រះពុទ្ធពោលគឺបដិរូប (emblem) បំភ្លឺចែងចាំងពី ព្រះទ័យសប្បុរស បរិសុទ្ធនិងសុក្រឹតធ្វើជាប្រភពលួងលោម និងជម្រុញចិត្តក្នុងការជួយអ្នកឱ្យយក ឈ្នះលើអ្វីៗដែលលំបាកទុក្ខ កង្វល់ដែលអ្នកត្រូវតែប្រឈមមុខនៅក្នុង កិច្ចការប្រចាំថ្ងៃនៅក្នុងពិភពបញ្ហានេះ។ ពេលអ្នក គោរពព្រះពុទ្ធអ្នកនឹងទទួលបានរង្វាន់ដ៏ធំធេង ប្រសិនបើអ្នកចម្រើនភាវនាមួយរយៈពេលខ្លីដោយផ្ចង់ស្មារតី របស់អ្នកទៅលើ គុណសម្បត្តិដ៏ប្រសើរៗនិងសំខាន់ៗរបស់ ព្រះពុទ្ធប្រសិនបើអ្នកគិតអំពីព្រះបរមគ្រូដែលអ្នកអាចធ្វើឱ្យខ្លួនឯងសុក្រឹតបានតាមរយៈមគ្គុទ្ទេសក៍ របស់ព្រះអង្គ។ ដូច្នេះវាមានលក្ខណៈខុសពីធម្មតាថាការគោរពនេះគួរតែសម្តែងពីខ្លួនវានៅ ក្នុងសិល្បៈមួយចំនួន ដែលស្អាតផ្តាច់គេហើយ និងរូបចម្លាក់ដែលពិភពលោកធ្លាប់បានឃើញ។

អ្នកនិពន្ធល្បីឈ្មោះម្នាក់ទៀតបាននិយាយថា នៅក្នុងភាសាទស្សនវិជ្ជារបស់លោកស្តីពីខ្លឹមសារពិតនៃការធ្វើវន្ទនាការចំពោះព្រះពុទ្ធមានដូចតទៅ :

"យើងក៏ត្រូវការអំពើវន្ទនាការដែរ បើទោះជាការគោរពត្រូវបានធ្វើដោយផ្ទាល់ មិនមែនចំពោះ មនុស្សម្នាក់ទេ ប៉ុន្តែព្រោះតែនៅក្នុងសច្ចភាពគ្រប់បុគ្គលិកលក្ខណៈទាំងអស់គឺជា សុបិនមួយ ប៉ុន្តែចំពោះឧត្តមភាពនៃ ចិត្តរបស់យើង។ ដូច្នេះសូមយើងស្វែងរក ភាពរឹងមាំថ្មីៗ ហើយកសាងព្រះស្តូបនៃជីវិតផ្ទាល់របស់យើងមួយ (a shrine of our own lives) ដោយសំអិត

សំអាងចិត្តរបស់យើងរហូតដល់វាមានតម្លៃដើម្បីទទួលបាន បដិមា នៅក្នុងជម្រកនៃសេចក្តីស្រឡាញ់ដ៏ជ្រៅបំផុត។ នៅលើទីបូជានោះ យើងទាំងអស់គ្នាត្រូវការឱ្យអំណោយ មិនមែនពន្លឺរលត់ (not of dying lights) ផ្កា ស្រពោន ឬអ្វីៗដ៏ច្រើននោះ (fleeting)ទេ ប៉ុន្តែយើងត្រូវការអំពើនៃ សេចក្តីស្រឡាញ់ ពលិកម្ម ភាពមិនអាត្មានិយម ចំពោះអ្នកដទៃអំពីយើង។"

Anatole France នៅក្នុងសំណេរស្វ័យជីវប្រវត្តិរបស់លោក បានសរសេរថា "កាលពីថ្ងៃទី១ខែឧសភាឆ្នាំ១៨៩០ ជាភព្វសំណាងបាននាំខ្ញុំទៅមើល សារៈមន្ទីរនៅក្នុងទីក្រុងប៉ារីស។ នៅទីនោះ ជំហរនៅក្នុងភាពសុខស្រួល និងស្ងប់ស្ងាត់ នៃ ទេវតាអាស៊ី ភ្នែករបស់ខ្ញុំបាញ់ឆ្ពោះទៅរកព្រះពុទ្ធបដិមាដែលបានបោយដៃហៅមនុស្សមានទុក្ខឱ្យអភិវឌ្ឍ ការយល់ដឹងនិងសេចក្តីមេត្តា។ ប្រសិនបើទេវតាយាងមកលើផែនដីនេះខ្ញុំមានអារម្មណ៍ថានោះពិតជាព្រះអង្គហើយ។ ខ្ញុំមានអារម្មណ៍ដូចជា ចង់លុតជង្គង់ចុះនៅចំពោះព្រះអង្គហើយថ្វាយបង្គំព្រះអង្គជាអាទិទេពមួយអង្គជាមិនខាន។"

លោក Ouspensky ជាទស្សនវិទូបស្ចឹមប្រទេសម្នាក់ទៀតបានសម្តែងពីអារម្មណ៍របស់លោកអំពី ព្រះពុទ្ធបដិមាដែលលោកបានរកឃើញនៅ Sri Lanka។ លោកបានពោលថា " ព្រះពុទ្ធនេះគឺជា ផ្នែកសិល្បៈពិសេសមួយខ្ញុំមិនបាន ដឹងអំពីស្នាដៃសិល្បៈដទៃណាទៀតដែលមានកម្រិតដូចជាកម្រិត ព្រះពុទ្ធដោយមានព្រះនេត្រដាំពេជ្រដែលត្រូវនិយាយថា ខ្ញុំមិនបានដឹងពីស្នា ដៃដែលសម្តែងនៅក្នុងខ្លួនវាយ៉ាងពិស្តារបំផុត នៅក្នុងគំនិតសាសនាដែលជាព្រះភក្ត្ររបស់ព្រះពុទ្ធនេះសម្តែងឱ្យឃើញពី ឧត្តមភាពព្រះពុទ្ធសាសនា។ ដើម្បីយល់ពីព្រះភក្ត្រនោះបានគឺត្រូវយល់អំពីព្រះពុទ្ធសាសនា"។ លោកបានបន្ថែមទៀតថា "មិនទាមទារឱ្យអានទំព័រព្រះពុទ្ធសាសនាឱ្យ បានច្រើនពេក ឬធ្វើដំណើរជាមួយសាស្ត្រាចារ្យដែលសិក្សាអំពី សាសនាបូព៌ាប្រទេស ឬក៏សិក្សាជាមួយ ព្រះភិក្ខុដែលបានសិក្សានោះទេ។ គេគ្រាន់តែមកទីនេះ ហើយឈរគយគន់មើលព្រះពុទ្ធដោយសម្លឹងទៅលើព្រះនេត្រខៀវៗ ទាំងនោះបានចោះទម្លុះមុតជ្រៅទៅក្នុងជីវិតរបស់គេ ហើយគេនឹងយល់ពីអ្វីដែលព្រះពុទ្ធសាសនាមានជាមិនខាន។"

សិល្បៈចម្លាក់ព្រះពុទ្ធបដិមាដ៏ស្រស់ស្អាតនិងការគូរគំនូររឿងព្រះពុទ្ធសាសនាផ្សេងៗបានជម្រុញទឹកចិត្ត យ៉ាងធំធេងឱ្យពង្រីក សិល្បៈនិង វប្បធម៌នៃ គ្រប់ប្រទេសអាស៊ានទាំងអស់អស់ពេលជាង ២០០០ឆ្នាំមកហើយ។

តើវាយ៉ាងដូចម្ដេចដែរដែលធ្វើឱ្យពាក្យទូន្មានរបស់ ព្រះពុទ្ធចាប់អារម្មណ៍ចំពោះ មនុស្សជាច្រើនដែលបាន ទទួលនូវការអប់រំ បញ្ញារបស់ពួកគេ? ប្រហែលជាចម្លើយអាចត្រូវបានគេរកឃើញនៅក្នុង ភាពស្ងប់ស្ងាត់ (serenity) នៃ ព្រះពុទ្ធបដិមានោះជាមិនខាន។ មិនមែនគ្រាន់តែនៅក្នុងរូបភាព (color)និងព្រំដែន (line) ដែលបានធ្វើឱ្យមនុស្ស សម្ដែងពីជំនឿរបស់ពួកគេចំពោះព្រះពុទ្ធហើយនិងភាពសមសួននៃការបង្រៀនរបស់ព្រះអង្គនោះប៉ុណ្ណោះទេស្នាដៃមនុស្ស (human hands) បានបង្កើតឱ្យមានរូបរាងឡើងពី លោហៈធាតុ និងថ្មដែលជាការបង្កើតដ៏អស្ចារ្យបំផុតនៃទេពកោសល្យមនុស្ស។

ប្រសិនបើ ពុទ្ធសាសនិកជនពិតជាចង់ពិនិត្យមើលទៅលើ ព្រះពុទ្ធទៅលើភាពរុងរឿង និង សោភ័ណភាព ដ៏មហាសាលនៃវត្តមានដ៏វិសេសរបស់ព្រះអង្គ ពួកគេត្រូវតែបកប្រែការបង្រៀន របស់ព្រះអង្គទៅជា ស្ថានការនិងសកម្មភាពប្រតិបត្តិនៅក្នុង ជីវិតប្រចាំថ្ងៃរបស់ពួកគេ។ ការប្រតិបត្តិទៅតាម ការបង្រៀនរបស់ព្រះអង្គដែល ពួកគេអាចខិតទៅយ៉ាងជិត នឹងព្រះអង្គហើយមានអារម្មណ៍ថា ការភ្លឺថែងចាំងដ៏អស្ចារ្យនៃគតិបណ្ឌិតនិងមេត្តាករុណា អមតៈរបស់ព្រះអង្គ។ តាមធម្មតាការគោរពចំពោះ បដិមាដោយមិនគោរពតាម ការបង្រៀនដ៏កំពូលរបស់ព្រះអង្គទេ នោះមិនមែនជាមាគ៌ារកឃើញការសង្គ្រោះនោះទេ។

ជីវិតដែលពោរពេញទៅដោយ សោភ័ណភាព បេះដូងដែលពោរពេញទៅដោយ ភាពល្អបរិសុទ្ធនិង ចិត្តសប្បុរស ចិត្តដែលគិតជ្រៅ ហើយដែលបានត្រាស់ដឹងបុគ្គលិកលក្ខណៈដែលមានកម្លាំងជម្រុញ និងគ្មានអាត្មានិយមពោលគឺ ជីវិតសុក្រឹតបែបនេះបេះដូងមេត្តាករុណា បែបនេះចិត្តស្ងប់ស្ងាត់បែបនេះបុគ្គលិកលក្ខណៈស្លូតបូតបែបនេះ ពិតជាមានតម្លៃគួរឱ្យគោរពពិតជាមានតម្លៃកិត្តិយសនិងគួរឱ្យគោរពបូជា។ ព្រះពុទ្ធគឺ ជាមនុស្សសុក្រឹតបំផុត និងជាផ្កានៃមនុស្សជាតិ (the flower of humanity) ។

លោក Sir Edwin Arnold បានពន្យល់ពី ធម្មជាតិនៃ ភាពជាព្រះពុទ្ធនៅក្នុង "ពន្លឺអាស៊ីរបស់លោក"ទៅតាមវិធី "នេះគឺជា ផ្កា(blossom)នៅលើ ដើមមនុស្ស(human tree) របស់យើងដែលរីកជាអនេកឆ្នាំ ប៉ុន្តែបានរីកបំពេញពិភពលោកដោយក្លិនក្រអូប គតិបណ្ឌិត (wisdom's scent)ហើយនិងសេចក្ដីស្រឡាញ់ដូចដំណក់ទឹកឃ្មុំ(love's dropped honey) ។

## ៣-ហេតុអ្វីបានជាត្រូវចម្រើនភាវនា? (Why Meditation ) Ven. Bhikkhu Piyananda

មនុស្សតែងតែស្វែងរកផ្លូវទៅកាន់ការរីកចម្រើននៃសុភមង្គល សេចក្តីសុខសាន្ត និង សុខដុមរមនា។ បើយោងទៅតាមគំនិតទូទៅសុភមង្គលកើតឡើងពីទ្រព្យសម្បត្តិ អំណាច និង ឋានៈ រឺក៏ដោយមានថ្នាំ ដុសធ្មេញល្អ សាប៊ូល្អ ឡានល្អ ដែលគេបានធ្វើពាណិជ្ជកម្មផ្សព្វផ្សាយ។ មនុស្សបានស្វះស្វែងរកដំណោះស្រាយ នៃបញ្ហាតាមរយៈគ្រួសារការងារដៃគូរនិងមិត្តភក្តិរបស់ គេ។ល។ ពួកគេព្យាយាមផ្លាស់ប្តូរ លក្ខខ័ណ្ឌខាងក្រៅ ដូចជាការទំនាក់ទំនងក្នុងសង្គម បរិយា កាសនយោបាយជុំវិញខ្លួន តាមផ្លូវនេះ តាមផ្លូវនោះពីព្រោះគេជឿថា កាលណាបរិយាកាស ខាងក្រៅល្អប្រសើរគេនឹងមានសេចក្តីសុខនិងសន្តិភាព។ ប៉ុន្តែ គេភ្លេចគិតថា លក្ខខ័ណ្ឌខាងក្រៅ ដែលមានការផ្លាស់ប្តូរឥតឈប់ឈរ ។អ្វីៗផ្លាស់ប្តូរអស់ទៅហើយមុនពេលគេទទួលបានសុភមង្គល ដូចបំណងប្រាថ្នា វាដូចជាអ័ព្ទដែលធ្លាក់ពេលព្រឹកព្រលឹម កាលណាមានកំដៅ វាក៏រលាយបាត់ អស់ទៅ។ បើសិនជាគេគ្រាន់តែចង់បានសុភមង្គលខ្លាំងឡើងៗការលំបាកនៃការចង់បាន នោះក៏ កាន់តែខ្លាំងឡើងៗដែរ ដូចជាមេអំបៅដែលហើរជិតៗយើងប៉ុន្តែយើងចាប់វាមិនបានក៏ដូច្នេះដែរ។

មនុស្សភាគច្រើនដើរតាមផ្លូវខុសក្នុងការរកសន្តិភាព និងភាពសុខដុមរមនា។ ពួកគេ ស្វែងរកសេចក្តីសុខនោះនៅខាងក្រៅមិនមែននៅក្នុងចិត្តទេ។ ប៉ុន្តែមនុស្សភាគច្រើនទៀតចាប់ ផ្តើមរកឃើញពី ប្រភពដ៏ពិតប្រាកដនៃសេចក្តីសុខ និងបញ្ហាប្រភពពិតប្រាកដនេះគឺជាចិត្ត (the mind)។ ដូច្នេះពួកគេងាកមកយកចិត្តទុកដាក់ទៅលើមនោវិញ្ញាណ (inner man) គឺចិត្តហើយ ចម្រើនភាវនាដែលជាផ្លូវរបស់ចិត្ត។

សព្វថ្ងៃនេះភាវនាបានផ្សព្វផ្សាយដល់មនុស្សជាច្រើន ដែលមានជាតិសាសន៏ខុសគ្នា វប្បធម៌ខុសគ្នាសាសនាខុសគ្នា។ ហេតុអ្វី? ពីព្រោះចិត្តរបស់យើងទោះបីជាជាតិសាសន៏ខុសគ្នា និងសាសនាខុសគ្នាក៏ដោយ ក៏មនុស្សទាំងអស់មានប្រព័ន្ធចិត្តដូចគ្នាដែរ ។ភារកិច្ចនៃការចម្រើន ភាវនា គឺការយល់ពីធម្មជាតិនៃចិត្ត ហើយប្រើប្រាស់ការយល់ដឹងនេះ ក្នុងជីវិតរស់នៅប្រចាំ ថ្ងៃ។ ចិត្តគឺជាកូនសោររបស់សុភមង្គលផង និងសេចក្តទុក្ខកង្វល់ផង។ ការយល់ដឹងពីចិត្តនឹង ចេះប្រើប្រាស់វាអោយបានល្អគឺជាការពុះពារមួយ ដែលអាច ឆ្លងកាត់ឧបសគ្គបាន ទោះជាជាតិ សាសន៏ វប្បធម៌ និងសាសនាខុសគ្នាក៏ដោយ។ ដូចនេះយើងអាចធ្វើ ភាវនាបានគ្រប់ៗគ្នាទោះ បីយើងកាន់សាសនាផ្សេងៗគ្នាក៏ដោយ។

## ផលប្រយោជន៍នៃការធ្វើភាវនា

បុគ្គលម្នាក់ៗមានការមមាញឹកខ្លាំងណាស់ ក្នុងការរកមធ្យោបាយផ្សេងៗដើម្បីជំនះរាល់ឧបសគ្គ ដែលកើតមានជារៀងរាល់ថ្ងៃ។ តើការធ្វើភាវនាបានផ្តល់នូវផលប្រយោជន៍អ្វីខ្លះ ? សារៈប្រយោជន៍នៃការចម្រើនភាវនាមានដូចខាងក្រោមៈ

-ប្រសិនបើលោកអ្នកជាមនុស្ស ដែលមមាញឹក ការចម្រើនភាវនាអាចជួយលោកអ្នកឱ្យកំចាត់អស់នូវភាពតានតឹង ហើយអាចធ្វើអោយមានអារម្មណ៍ធូរស្រាលឡើងវិញបាន។

-ប្រសិនបើលោកអ្នកជាមនុស្ស ដែលពោរពេញដោយកង្វល់ ការចម្រើនភាវនាអាចជួយលោកអ្នកឱ្យមានអារម្មណ៍ស្ងប់ស្ងាត់មួយរយៈពេលជាអចិន្ត្រៃបាន។

-ប្រសិនបើលោកអ្នកមានបញ្ហាមិនចេះចប់មិនចេះ ហើយការចម្រើនភាវនាអាចជួយលោកអ្នកអោយបង្កើតនូវភាពក្លាហាន និងពង្រឹងស្មារតីដើម្បីប្រឈរមុខនឹងអាចយកឈ្នះឧបសគ្គគ្រប់បែបយ៉ាងបាន។

-ប្រសិនបើលោកអ្នកខ្វះទំនុកចិត្តលើខ្លួនឯង ការចម្រើនភាវនាអាចជួយលោកអ្នកឱ្យមានទំនុកចិត្តលើខ្លួនឯងដូចប្រាថ្នាបាន។ ទំនុកចិត្តលើខ្លួនឯងនេះគឺជាអាថ៌កំបាំងនៃជ័យជំនះ។

-ប្រសិនបើលោកអ្នកមានសេចក្តីភ័យខ្លាចនៅក្នុងចិត្ត ការធ្វើភាវនាអាចជួយលោកអ្នកឱ្យយល់ដឹងពី ធម្មជាតិពិតនៃកម្មវត្ថុដែលធ្វើឱ្យអ្នកភ័យខ្លាចនោះ បន្ទាប់មកលោកអ្នក នឹងអាចឈ្នះលើការភ័យខ្លាចនោះបាន។

-ប្រសិនបើលោកអ្នកតែងតែមិនអាចបំពេញចិត្ត ចេះតែខ្វះគ្រប់យ៉ាងនៅក្នុងជីវិតការធ្វើភាវនានឹងផ្តល់ឱកាសលោកអ្នកបង្កើតនូវសេចក្តីពេញចិត្តនិងធ្វើឱ្យ មានសេចក្តីរីករាយយ៉ាងជ្រាលជ្រៅបាន។

-ប្រសិនបើលោកអ្នកពុំមានជំនឿ និងមិនចាប់អារម្មណ៍ទៅលើសាសនាការចម្រើនភាវនាអាចជួយលោក អ្នកឱ្យចាកចេញផុតពីភាពគ្មានជំនឿបាន ហើយនាំឱ្យលោកអ្នកស្គាល់ពីតម្លៃការឱវាទនៅក្នុងសាសនា ។

-ប្រសិនបើលោកអ្នកខកចិត្តនិងខូចចិត្តដោយសារខ្វះខាតនូវការស្វែង យល់ពីធម្មជាតិរបស់ជីវិតក៏ដូចជា ពិភពលោកទាំងមូល ការធ្វើសមាធិប្រាកដជានឹងនាំលោកអ្នក និងជួយអ្នកឱ្យស្វែងយល់ពីអ្វីដែលធ្វើ ឱ្យរំខានដល់អ្នកដោយសាររឿងឥតប្រយោជន៍។

-ប្រសិនបើលោកអ្នកជាអ្នកមានការចម្រើនភាវនាអាចជួយអ្នកឱ្យយល់ដឹងពីធម្មជាតិនៃភោគទ្រព្យនោះ និងអាចជួយអ្នកឱ្យយល់ដឹងពីវិធីប្រើប្រាស់ភោគទ្រព្យទាំងនោះ ដើម្បីឱ្យមានសុភមង្គលផ្ទាល់ខ្លួនក៏ដូចអ្នកដ៏ទៃផងដែរ ។

-ប្រសិនបើលោកអ្នកជាមនុស្សទីទាល់ក្រការចម្រើនភាវនាអាចជួយអ្នកឱ្យមានសេចក្តីពេញចិត្ត ហើយមិនមានការច្រណែននិន្ទាទៅដល់អ្នកណាដែលប្រសើជាងអ្នក ។

-ប្រសិនបើអ្នកជាមនុស្សក្មេងខ្ចីពីរឿងជីវិត ហើយមិនស្គាល់ផ្លូវដើម្បីយល់ដឹងពីជីវិត ការចំរើនភាវនានឹងជួយអ្នកឱ្យយល់ដឹងថាតើផ្លូវមួយណាដើម្បីធ្វើទៅដល់គោលដៅរបស់អ្នកបាន ។

-ប្រសិនបើអ្នកជាមនុស្សចាស់ ហើយមានការធុញទ្រាន់និងជីវិត ការចំរើនភាវនានឹងនាំលោកអ្នកឱ្យយល់ច្បាស់ពីជីវិតកាលណាការយល់ដឹងនេះកើតមានហើយនឹងអាចរំដោះលោកអ្នកពីការឈឺចាប់នៃជីវិតហើយបង្កើតនូវភាពសប្បាយរីករាយនៅក្នុងជីវិតរស់នៅ ។

-ប្រសិនបើលោកអ្នកជាមនុស្សឆាប់ខឹង លោកអ្នកអាចបង្កើតកំលាំងដើម្បីយកឈ្នះភាពទន់ខ្សោយ នៃទោសៈ និងការចងគំនុំនេះបាន ។

-ប្រសិនបើលោកអ្នកជាមនុស្សច្រណែននិន្ទាឈ្នានីសលោកអ្នកអាចយល់ពីមហន្តរាយនៃការច្រណែន និន្ទាឈ្នានីសរបស់លោកអ្នកបាន ។

-ប្រសិនបើលោកអ្នកជាទាសករនៃកាមារម្មណ៍ទាំងប្រាំ លោកអ្នកអាចរៀនសូត្រនូវវិធីដែលធ្វើអោយខ្លួនក្លាយទៅជាម្ចាស់នៃកាមារម្មណ៍ទាំងប្រាំនោះបាន ។

-ប្រសិនបើលោកអ្នកញៀនគ្រឿងស្រវឹង រឺថ្នាំញៀនផ្សេងៗ លោកអ្នកអាចយកឈ្នះទម្លាប់ដ៏គ្រោះថ្នាក់ នោះបាន ។

-ប្រសិនបើលោកអ្នកជាមនុស្សល្ងង់ខ្លៅការចម្រើនភាវនានេះនឹងធ្វើឱ្យអ្នកមានឱកាសដើម្បីអប់រំ ចំណេះដឹងមួយចំនួនដែលមានប្រយោជន៍ និងគុណប្រយោជន៍ចំពោះលោកអ្នកក៏ដូចជាមិត្តសំលាញ់ និងក្រុមគ្រួសារផងដែរ ។

-ប្រសិនបើលោកអ្នកប្រតិបត្តិនូវការធ្វើភាវនាបានយ៉ាងខ្ជាប់ខ្ជួន វេទនារម្មណ៍ របស់លោកអ្នកនឹងមិនអាច កើតមានបានទៀតឡើយ ។

-ប្រសិនបើលោកអ្នកជាមនុស្សប្រកបដោយឧត្តមគតិ ការធ្វើសមាធិនឹងនាំឱ្យលោកអ្នកទៅដល់ភាព ភ្លឺថ្លាខ្ពស់បំផុត ។ បន្ទាប់មកលោកអ្នកនឹងឃើញពីអ្វីដែលមានពិតប្រាកដដែលមិនមែនគ្រាន់តែរូបរាងខាងក្រៅប៉ុណ្ណោះទេ ។

-ប្រសិនបើលោកអ្នកទន់ខ្សោយខាងផ្លូវចិត្ត ការចម្រើនភាវនានេះអាចជួយពង្រឹងចិត្តរបស់លោកអ្នក ដើម្បីបង្កើតកម្លាំងឆន្ទះរបស់លោកអ្នកក្នុងគោលបំណងដើម្បីយកឈ្នះ ភាពទន់ខ្សោយនោះ ។

កត្តាទាំងអស់នេះគឺជាអត្ថប្រយោជន៍ ដ៏ប្រសើរដែលទទួលបានមកពីការធ្វើភាវនា ។ អត្ថប្រយោជន៍ទាំងនេះមិនអាចដាក់ក្នុងហាង ឬក៏នៅក្នុងអាគារលក់ទំនិញបានឡើយ ។ យើងមិនអាចយកលុយទៅទិញអត្ថប្រយោជន៍ទាំងនេះបានទេ ។ វាជាទ្រព្យជាប់នឹងប្រាណរបស់លោកអ្នកដែលបានមកពីការចម្រើននូវសមាធិ ។ នៅពេលដែលចាប់ផ្ដើមមានសតិមួយ ដែលកើតមានប្រាកដដូច្នេះចិត្តរមែងឃើញចិត្តដទៃទៀត( ដែលកើតមានគ្រប់ចិត្តខ្លួនឯងផ្ទាល់ជាបន្តតាមសេចក្ដីពិត) ។ ហេតុដូច្នេះហើយការចម្រើនសម្ពភាពដើម្បី ត្រូវពិនិត្យនូវសភាពនៃចិត្តដើម្បីឱ្យដឹងច្បាស់ថា ចិត្តមានដំណើរប្រព្រឹត្តិទៅដូចម្ដេច ។

**ការរៀបចំសម្រាប់ធ្វើភាវនា**

នៅពេលដែលលោកអ្នកចាប់ផ្ដើមប្រតិបត្តិជាលើកដំបូង គឺវាតម្រូវអោយស្វែងរកទីសេនាសនៈ ស្ងាត់ដែលជាទីអោយលោកអ្នកធ្វើការហ្វឹកហាត់ដោយខ្លួនឯងបាន ។ គម្បីព្យាយាមស្វែងរកកន្លែងឆ្ងាយពី ភាពអ៊ូអរ និងភាពកង្វល់នៃជីវិត ។ ទីកន្លែងអាចជាបន្ទប់ ជាសួនច្បារជាបន្ទប់គេង រឺទីកន្លែងណាមួយ ក៏បានឱ្យតែលោកអ្នកយល់ថាស្ងប់ល្អ ។ ពេលណាលោកអ្នកស្វែងរកទីកន្លែងដើម្បីចម្រើនភាវនាបាន ហើយត្រូវនៅទីនោះរហូតពុំអាចផ្លាស់ប្ដូរបានឡើយ ។

កាលណាការភាវនារបស់លោកអ្នកប្រព្រឹត្តិទៅបានហើយ លោកអ្នកអាចចាប់ផ្ដើមអនុវត្តន៍នៅទីកន្លែងធ្វើការងារជាប្រចាំថ្ងៃបាន ដោយពុំចាំបាច់រកទីកន្លែងស្ងប់ស្ងៀម រហូតនោះទេ ។ សូមចងចាំថា នៅពេលលោកអ្នកបានធ្វីឱ្យច្រើននូវការចម្រើនភាវនាមានកម្លាំងអាចតាំងចម្រើនភាវនាបានពុំចាំបាច់រើសទីកន្លែងអ្វីឡើយ ។

**ការជ្រើសរើសពេលវេលា**

ពេលវេលាគឺអាស្រ័យទៅលើការសម្រេចចិត្តរបស់លោកអ្នក លោកអ្នកអាចជ្រើសរើសពេលវេលាណាក៏បាន ប៉ុន្តែពេលវេលានេះគួរទុកសម្រាប់តែការចម្រើនភាវនាមួយប៉ុណ្ណោះ ។ កំឡុងពេលនេះលោកអ្នក គួរតាំងចិត្តបំភ្លេចអ្វី១ទាំងអស់ ដូចជាសកម្មភាពប្រចាំថ្ងៃ ទុក្ខកង្វល់ផ្សេង១ និងចិត្តជាប់ជំពាក់ជាដើម ។ គម្បីមានការតាំងចិត្តកុំអោយអារម្មណ៍ផ្សេង១ក្នុងលោកចូលទៅជ្រៀតជ្រែកជាមួយនឹងការប្រតិបត្តិរបស់លោកអ្នក ។ លោកអ្នកត្រូវធ្វើការ សម្រេច

ចិត្តយ៉ាងម៉ឺងម៉ាត់ ដើម្បីលះបង់ពេលវេលាចំពោះការអប់រំចម្រើនភាវនា ជារៀងរាល់ថ្ងៃផង ដែរ។ សូមជ្រាបថានៅពេលដែលលោកអ្នកបានចម្រើនភាវនាហើយពេលណាក៏ដោយ ក៏ជា ពេលដែលអាចចម្រើនភាវនាបានទាំងអស់។ កាលដែលលោកអ្នកមកដល់ក្នុងជំហាននេះហើយ ការចំរើនភាវនាក្លាយទៅជាផ្នែកមួយនៃជីវភាពរស់នៅរបស់លោកអ្នកពីមួយថ្ងៃទៅមួយថ្ងៃ។

**គ្រូដឹកនាំភាវនា**

លោកអ្នកប្រហែលជាមានអារម្មណ៍ត្រូវការនណាម្នាក់ ដែលអាចជួយណែនាំ និង ដើម្បីបង្រៀនដល់លោកអ្នក។វាពុំមែនជាការងាយស្រួលទេ ដើម្បីស្វែងរកមនុស្សសមគួរជួយ បង្ហាញផ្លូវជាប្រធានមាន សមត្ថភាពខ្ពស់ដឹកនាំការចម្រើនភាវនាបាន។ ប្រសិនបើលោកអ្នក មានមិត្តភក្តិជាអ្នកធ្វើភាវនាដែរ អាចពិគ្រោះជាមួយពួកគេ ពួកគេអាចធ្វើជាគ្រូរបស់ លោក អ្នកបាន។ ប្រសិនបើលោកអ្នកប្រទះឃើញសៀវភៅស្តីពីការធ្វើភាវនាសូមអាន វាអាចជាគ្រូ របស់លោកអ្នកផងដែរ។ ប្រសិនបើលោកអ្នករកគ្រូបានសូមចងចាំថា គ្រូគ្រាន់តែជាកល្យាណ មិត្ត និងអ្នកណែនាំប៉ុណ្ណោះ។ គ្រូមិនអាចធ្វើភាវនាជំនួសលោកអ្នកបានឡើយ។ គ្រូមិនអាច ស្វែងរកការយល់ដឹងពិតឱ្យលោកអ្នកបានទេ។ប្រសិនបើលោកអ្នកអាចចម្រើនសមាធិ និងសតិ ឱ្យមានកម្លាំងរឹងមាំច្បាស់លាស់ និងថេរភាពដឹងច្បាស់នៃសមាធិរបស់លោកអ្នកគឺជាគ្រូហើយ គ្រូរបស់លោកអ្នកស្ថិតនៅជាមួយនឹងលោកអ្នក។

**ឥរិយាបថនៃការអង្គុយ**

ចំពោះការអង្គុយធ្វើភាវនាលោកអ្នកអាចអង្គុយជាពាក់កណ្តាល ឬពេញរង្វង់ផ្កាឈូក ប្រសិនបើ ឥរិយាបទនេះមានការលំបាកលោកអ្នកអាចអង្គុយនៅលើកៅអី ហើយដៃបង្អែក ត្រង់ហើយទម្លាក់ជើងទៅលើដីអោយត្រង់។ អង្គុយឱ្យត្រង់ស្រួលបួលកុំអោយលំអៀង រឺទោរ ជំហរដងខ្លួន ដូច្នេះលោកអ្នកអាចទប់លំនឹងបានហើយមិនសូវងងុយដេក ប៉ុន្តែកុំតឹងតែង រឺធ្វើ ឱ្យលំបាកខ្លាំងពេក។ ប្រសិនបើកនិងឆ្អឹងខ្នងមិនអាចទប់អោយត្រង់បានទេ លោកអ្នកនឹងអាច មានអារម្មណ៍ឈឺចាប់ខ្លះៗបន្ទាប់ពីពីរបីនាទីមក។

**តើការធ្វើភាវនាជាអ្វី ?**

ការចម្រើននៃភាវនាគឺជាសភាពដឹងច្បាស់យ៉ាងសាមញ្ញរបស់សមាធិប៉ុណ្ណោះ។ប្រសិន បើលោក អ្នកពេញចិត្តក្នុងការចម្រើនភាវនា លោកអ្នកគប្បីចម្រើននូវហេតុ គឺសមាធិរបស់ លោកអ្នកដោយសមថភាវនា និងវិបស្សនាភាវនា។ ម្យ៉ាងទៀតបន្ទាប់ពីរៀនចម្រើនសតិ ឬ

ញ្ញាណហើយនូវហេតុចម្រើនភាពកំណត់ដឹង ឬសតិរបស់លោកអ្នក អ្នកក៏អាចអប់រំវិបស្សនា ឬការចម្រើនភាវនាដឹងច្បាស់បាន។ ប្រសិនបើលោកអ្នក ពេញចិត្តក្នុងការធ្វើសមាធិភាវនានៅក្នុងជីវិតប្រចាំថ្ងៃ លោកអ្នកត្រូវអប់រំហ្វឹកហាត់សមាធិនោះនៅក្នុងជីវិត។ ប្រសិនបើលោកអ្នកពេញចិត្តក្នុងការធ្វើវិបស្សនាត្រូវអប់រំឱ្យមានភាពកំណត់ដឹងក្នុងជីវិតប្រចាំថ្ងៃរបស់លោកអ្នក។ ជីវិតប្រកបដោយការចម្រើនភាវនា គឺជាការចម្រើនយ៉ាងសាមញ្ញក៏ នឹងបានទៅជាការទម្លាប់នៃការធ្វើនូវភាពកំណត់ដឹងច្បាស់របស់សមាធិ ក្នុងការតាមមើលធម្មតាៗព្រមទាំងហេតុការណ៍នៃជីវិតប្រចាំថ្ងៃរបស់លោកអ្នក។

**សមថ** (*Samatha*) **: សមាធិភាវនា**

សមថៈ គឺជាវិធីសាស្ត្រសម្រាប់ហ្វឹកហ្វឺនចិត្តចំពោះលោកអ្នក ដែលមានបំណងចម្រើនសមាធិ។ សមថៈភាវនា ត្រូវប្រព្រឹត្តិទៅដោយការធ្វើចិត្តឱ្យមូលក្នុងអារម្មណ៍តែមួយ។

ភាពនៃអារម្មណ៍មូលតែមួយ គឺជាខន្ធសមាធិដែលមានគ្រប់ឥន្ទ្រីយ៍ និងពលៈដែលត្រូវសង្កត់ចិត្ត និងគ្រប់គ្រងចិត្តដោយអំណាចឆន្ទទិទ្ធិបាទហើយឆ្ពោះទៅក្នុងចំណុចតែមួយឬអារម្មណ៍តែមួយ។ ចិត្តដែលមានអារម្មណ៍តែមួយគឺជាសមាធិនិងជាឯកគ្គាចិត្ត។ ចិត្តដែលមានអារម្មណ៍តែមួយមានភាពខុសគ្នាពីចិត្តខ្វល់ខ្វាយឬចិត្តរាយមាយ ។ជាប្រក្រតីនៃនាមធម៌របស់យើងរមែងរាយមាយការត្រាច់ទៅប៉ុន្តែបើមានសមាធិកើតឡើងជាក់ច្បាស់ក្នុងអារម្មណ៍តែមួយលោកអ្នកអាចកំណត់ដឹងពិតនូវធម្មជាតិ ដែលកើតមានក្នុងអារម្មណ៍នោះ។ ដំណើរនៃការសមាធិនេះការប្រព្រឹត្តិសមាធិនាំឱ្យចម្រើនឡើងរឿយនូវពួកនាមធម៌ រហូតដល់នាមធម៌មាន កម្លាំងព្រមគ្នាឆ្ពោះទៅក្នុងអារម្មណ៍តែមួយ។

តើប្រាថ្នាអ្វីក្នុងការចម្រើនចិត្តឱ្យមូលក្នុងអារម្មណ៍តែមួយ? បើសិនលោកអ្នកហ្វឹកហាត់ចិត្តបែបនេះ អ្នកនឹងកើតមានភាពស្ងប់ស្ងាត់ និងភាពមិនឆេវឆាវនៅក្នុងចិត្ត ហើយអ្នកនឹងអាចប្រមូលការតាំង អារម្មណ៍របស់លោកអ្នកទៅលើតែចំណុចមួយបាន ដូច្នេះដើម្បីកុំឱ្យចិត្តបែកទៅទីទៃពីគ្នានិងការរលត់ ទៅវាគឺជាថាមពលដ៏មានប្រយោជន៍។ ចំពោះចិត្តផ្ទាល់ ចិត្តស្ងប់នេះមិនទាន់ចប់ទេ។ សភាពស្ងប់នៃចិត្តគឺ គ្រាន់តែបច្ច័យចាំបាច់ដើម្បីអប់រំចំរើនវិបស្សនាប៉ុណ្ណោះ។ ក្នុងន័យម្យ៉ាងទៀតការរំលត់ចិត្តឆេវឆាវគឺ ចាំបាច់ប្រសិនបើលោកអ្នកចង់មើលឱ្យជ្រៅទៅក្នុងខ្លួនរបស់លោកអ្នកខ្លួនឯងទៅនឹងពិភពលោក។

សមាធិដែលជាសមថៈ គឺចិត្តដែលកើតឡើងបន្តគ្នាតាមលំដាប់ជាច្រើនថ្នាក់ក្នុងភាវនាចិត្ត។ ការបើស្ថិតនៅក្នុងថ្នាក់ដែលមានកម្រិតខ្ពស់ៗ របស់ភាវនាចិត្តកំណត់ដឹងថា ឈាន jhana ជាកម្លាំងចិត្តដែល អាចកើតមានក្នុងការអប់រំសមាថៈ។ ទោះជាយ៉ាងណាក៏ដោយប្រភេទនៃភាវនាចិត្ត ដែលមានកម្រិតខ្ពស់ ដូច្នេះពុំចាំបាច់ឬប្រតិបត្តិបានសម្រេចចំពោះមនុស្សភាគច្រើនដែលអាស្រ័យនៅក្នុងទីអ្វរអរនៃជីវិតទំនើបនោះឡើយ។ សម្រាប់មនុស្សភាគច្រើនចិត្តគឺកំពុងតែស្ទុះទៅពីអតីតមកបច្ចុប្បន្នទៅអនាគត ហើយពីកន្លែងមួយទៅកន្លែងមួយទៀត។ ប្រសិនបើលោកអ្នកអាចហាត់ពត់លត់ដំចិត្តបានដើម្បីយកចិត្តទុកដាក់ចំពោះកិច្ចការនីមួយៗគ្រប់វេលាការសមាធិនោះអោយបានគ្រប់គ្រាន់ ហើយនៅពេលលោកអ្នកកំពុងអាន កំពុងដើរកំពុងសម្រាកកំពុងនិយាយ ឬកំពុងធ្វើអ្វីមួយក្នុងជីវភាពប្រចាំថ្ងៃសូមលោកអ្នកធ្វើសកម្មភាព ទាំងនោះដោយចិត្តស្ងប់ គឺដោយយកចិត្តទុកដាក់ចំពោះសកម្មភាពនីមួយៗ។ ចូររៀនដើម្បីសង្រួមចិត្តទៅលើកិច្ចការនីមួយៗ។

**ការរស់នៅបច្ចុប្បន្ន**

ប្រសិនបើលោកអ្នកចង់អភិវឌ្ឍការធ្វើសមាធិ កិច្ចការដំបូងគឺរកកម្មវត្ថុ ដែលសមរម្យដែលលោកអ្នកអាចធ្វើសមាធិបាន។ នៅក្នុងការភាវនាបែបព្រះពុទ្ធសាសនាមានកម្មវត្ថុចំនួន ៤០( មិនមែនជាផ្លូវឬវិធីសាស្រ្តផ្សេងៗទេ) នៃការភាវនាដែលលោកអ្នកអាចប្រើដើម្បីអភិវឌ្ឍការសមាធិបាន។ លោកអ្នកពុំត្រូវប្រើកម្មវត្ថុទាំង៤០ នេះទេ ប៉ុន្តែអាចជ្រើសរើសយកមួយដែលសក្តិសមចំពោះការរំភើប រឹតិរិយាបថ នៃផ្លូវចិត្តរបស់លោកអ្នក។ ប្រសិនបើលោកអ្នកគ្មានគ្រូជ្រើសរើសកម្មវត្ថុនៃការធ្វើសមាធិដែលសមរម្យ សម្រាប់លោកអ្នកទេត្រូវធ្វើពិសោធហើយជ្រើសរើសដោយខ្លួនឯង ។នៅខាងក្រោមនេះគឺជាការដែលនាំផ្លូវខ្លះៗដើម្បីរកកម្មវត្ថុដែលសមរម្យសំរាប់ការធ្វើសមាធិរបស់លោកអ្នក :

-កម្មវត្ថុនេះត្រូវនៅផ្លូវកណ្តាល ប្រសិនបើមានការសំបូងសង្រួង កើតមានអារម្មណ៍តណ្ហាខ្លាំងមិនពេញចិត្តខ្លាំង ។ល។ នោះលោកអ្នកមិនអាចស្ងប់អារម្មណ៍បានទេ ប៉ុន្តែវាបែរជាធ្វើឱ្យរសាប់រសល់ ហើយច្របូកច្របល់ក្នុងចិត្តទៅវិញ។

-កម្មវត្ថុអាចជាខាងក្នុងខ្លួនអាចជាខាងក្រៅខ្លួន : កម្មវត្ថុខាងក្នុងខ្លួនគឺ វាស្ថិតនៅក្នុងចិត្តរបស់លោកអ្នក។ ជាឧទាហរណ៍ ចង្វាក់ដង្ហើមភាពមេត្តានិងភាពករុណា ។ល។ កម្មវត្ថុខាង

ក្រៅមានន័យថាកម្មវត្ថុដែលនៅក្រៅខ្លួនលោកអ្នក។ ឧទាហរណ៍ពុទ្ធានុសតិ ផ្កា ភ្នំ ពន្លឺ អណ្តាត ភ្លើងទៀនជាដើម ។ល។

-កម្មវត្ថុត្រូវតែធ្វើឱ្យចិត្តសប្បាយ ហើយចិត្តអាចទទួលយកបាន ប្រសិនបើចិត្តបដិសេធកម្មវត្ថុជានិច្ចការធ្វើសមាធិប្រាកដជាមានភាពទន់ខ្សោយ។

-សូមចងចាំថាអារម្មណ៍ ដែលសមគួរដល់លោកអ្នកកើតមាន តែម្តងម្កាលនៅពេលផ្សេង ចិត្តមិនអាចទទួលយកបានទេ។ ជាឧទាហរណ៍បន្ទាប់ពីទោសៈផ្ទុះឡើង គឺវាមានការលំបាកដើម្បីប្រើមេត្តាភាពជា កម្មវត្ថុនៃសមាធិរបស់លោកអ្នក។ ដូច្នេះសភាពញាប់ញ័រនៃចិត្តវាផ្ទាល់អាចធ្វើឱ្យប្រែប្រួលអារម្មណ៍របស់សមាធិមកជាប្រសើរវិញ។

ពេលដែលលោកអ្នកបានជ្រើសរើស កម្មវត្ថុហើយត្រូវតែរក្សាចិត្តឱ្យតាំងនៅជាប់ជាមួយកម្មវត្ថុនោះ ដូចលោកអ្នកចងសត្វជាប់នឹងបង្គោលដូច្នេះដែរ។ គន្លឹះសំរាប់ប្រតិបត្តិសមាធិ គឺតាំងចិត្តទៅលើតែ កម្មវត្ថុមួយប៉ុណ្ណោះដើម្បីបដិសេធកម្មវត្ថុផ្សេងៗឯទៀត។ ការយកចិត្តទុកដាក់ទៅលើកម្មវត្ថុនោះចិត្តនឹងស្ងប់ស្ងាត់ហើយធូរស្រាលបន្តិចម្តងៗមិនខាន។

មានលំហាត់សមាធិខ្លះ ដែលលោកអ្នកអាចអភិវឌ្ឍន៍ជាភាវនាផ្លូវការបាន ឬជាផ្នែកនៃសកម្មភាពប្រចាំថ្ងៃរបស់អ្នកបានដូចតទៅ :

***លំហាត់សុខភាព*** : នៅពេលទៅមុខធ្វើដំណើរទៅណាមកណាក្តី ចូរចងចាំគំនិតទាំងបីនេះនៅក្នុងចិត្តជានិច្ច " សប្បាយសុខភាពកម្លាំង " រក្សាការប្រតិបត្តិពាក្យនេះម្តង ហើយម្តងទៀតៗផ្ចង់អារម្មណ៍ពាក្យនេះក្នុងជានិច្ចរហូតដល់លោក អ្នកអាចគិតថាពាក្យទាំងនេះវាស្ថាត់នៅក្នុងខ្លួនហើយ។

***លំហាត់គិតពិចារណា*** : នៅពេលលោកអ្នកកំពុងគិតពីប្រធានបទអ្វីមួយ ចូរតាំងចិត្តទៅនឹងប្រធានបទនោះ។ រក្សាការយកចិត្តទុកដាក់ទៅលើប្រធានបទដោយការពិចារណា។ ចូរកុំកំសាន្ត និងគំនិតខុសរឿង ឬគំនិតដែលមិនទាក់ទង។

***លំហាត់ប្រចាំថ្ងៃ*** : នៅពេលលោកអ្នកអានសៀវភៅ សូមរក្សានេត្រាទាំងគូ និងចិត្តរបស់លោក អ្នកទៅលើសៀវភៅនោះ។ នៅពេលលោកអ្នកជូតសំអាតកំរាលឥដ្ឋ ចូររក្សាចិត្តទៅនឹងការជូតសំអាតនោះ។ នៅពេលលោកអ្នកសរសេរតាមអានចូររក្សាចិត្តទៅ នឹងការសរសេរនោះហើយយកចិត្តទុកដាក់តែការស្តាប់នោះ។

រៀនហាត់ពត់លត់ដំធ្វើសមាធិទៅលើអ្វី ដែលលោកអ្នកធ្វើពីនាទីមួយទៅនាទីមួយ ។ នេះគឺជាការរស់នៅក្នុងបច្ចុប្បន្ន ។ ការរស់នៅឥឡូវនេះ !...

**វិបស្សនា** (*Vipassana*) **: វិបស្សនាភាវនា**

វិបស្សនា គឺជាការយល់ដឹងស៊ីជំរៅក្នុងសភាពនៃវត្ថុផ្សេងៗទាំងឡាយ ។ វិប្បសនាគឺជាការគិតចំពោះវត្ថុអ្វីមួយទៅតាមសភាពរបស់វា ។ ផ្លូវដែលឈានទៅដល់ការយល់ស៊ីជម្រៅឬការយល់ដឹងគឺជាការដឹងឬសតិដឹង ។ វិធីសាស្ត្រដើម្បីបង្កើតសតិដឹងនេះ គឺផ្អែកលើឱវាទប្រៀនប្រដៅដ៏ល្បីល្បាញរបស់ព្រះពុទ្ធ ។ នៅក្នុងឱវាទនេះព្រះពុទ្ធបានពន្យល់អំពីរបៀបអភិវឌ្ឍន៍ និងបណ្តុះទឹកចិត្ត ។ ពុទ្ធឱវាទប្រេិនប្រដៅនេះ មានឈ្មោះថា *សតិប្បដ្ឋានសូត្រ* *ទ្យាតិផាតតបាានា ្រតតាច* ។ នៅក្នុងសូត្រនេះព្រះពុទ្ធបានឱ្យកម្ម វត្ថុបួនក្នុងការធ្វើសមាធិដើម្បីធ្វើការពិចារណា ដែលមានកាយ អារម្មណ៍គតិ និងសភាពចិត្ត ។ មូលដ្ឋានក្នុងការអនុវត្ត*សតិប្បដ្ឋាន* គឺត្រូវប្រើកម្មវត្ថុទាំងបួននេះដើម្បីបង្កើតបាននូវសមាធិសតិ និងការយល់ស៊ីជម្រៅ គឺការយល់អំពីខ្លួនឯង និងបរិយាកាសដែលនៅជុំវិញអ្នក ។ *សតិប្បដ្ឋាន* ជួយដល់កិច្ចបដិបត្តិបានច្រើនយ៉ាងសាមញ្ញត្រង់ និងជាវិធីដែលអាចប្រព្រឹត្តិទៅបាន ដល់ការទូន្មានចិត្តដែលជួបប្រទះនូវរាល់កិច្ចការប្រចាំថ្ងៃនិងបញ្ហាផ្សេងៗ ហើយក៏អាចទទួលបានដល់ ទីបំផុតគឺៈវិមុត្តិ១លិបរោតិ្យនធ។ *សតិប្បដ្ឋាន* គឺជាធម៌បដិបត្តិពុំមានជំទាស់ចរិតអធ្យាស្រ័យបុគ្គល គ្រប់ប្រភេទ និងជាផ្លូវទូន្មានចិត្តដែលច្រាសចោលទោស ។ អ្នកអាចបដិបត្តិតាមវិធីនេះនៅទីណាពេលណា ក៏បាននៅពេលធ្វើការមមាញឹក ឬក្នុងពេលយប់ស្ងាត់ក៏បាន ។

កិច្ចដែលចម្រើនគឺការកំណត់ដឹងឬសតិ ។ ការកំណត់ដឹងគឺគ្រប់សភាវសាមញ្ញៗធម្មតាៗ និងអ្វីដែលចិត្តបានស្គាល់ ។ នៅគ្រាដំបូងការកំណត់ដឹងគឺ សម្លឹងអារម្មណ៍បានដោយងាយ ។ សភាពដូច្នេះមានន័យថា អ្នកសង្កេតពិនិត្យឃើញបានធម្មតាចំពោះអារម្មណ៍ ដោយមិនចាំបាច់វិភាគវាឬគិតដល់វា ។ ការកំណត់ដឹងគឺជាការសង្កេតពិនិត្យយ៉ាងសាមញ្ញ ឬមានការឃើញច្បាស់ដោយមិនបាច់ធ្វើការវិភាគ ឬនឹកគិតឡើយ ។

**កាយគឺជាអារម្មណ៍របស់ភាវនា**

គោលបំណងនៃការអប់រំភាវនានេះគឺ ដើម្បីធ្វើអោយបានជាក់ច្បាស់នូវធម្មជាតិនៃរាងកាយ ព្រមទាំងការមិនជំពាក់នៃរាងកាយគឺ ទាំងមិនជាទីចាប់អារម្មណ៍ និងបដិសេធចោល

ដោយរាងកាយ។ តាមធម្មតាមនុស្សភាគច្រើនស្គាល់ខ្លួនឯងដោយរាងកាយរបស់ពួកគេ ទោះជាយ៉ាងដូចនេះក្តី ក្នុងដំណាក់កាលមួយនៃការបន្សុទ្ធចិត្តនិងការយល់ដឹងស៊ីជំរៅលោកអ្នក នឹងមិនទឹកគិតថា ខ្លួនអ្នកដូចជារាងកាយមួយនោះតទៅទៀតឡើយ។ អ្នកនឹងលែងសំគាល់ថា ខ្លួនរបស់អ្នកនៅជាប់និងរាងកាយទៀតឡើយ។ លោកអ្នកនឹងចាប់ផ្តើមឃើញថារាងកាយ គឺជារាងកាយ។

**លំហាត់ទី ១ : សតិកំណត់ខ្យល់ដកដង្ហើមចេញ ដង្ហើមចូល (អានាបានស្សតិ)**

បន្ទាប់ពីបានជ្រើសរើសពេលវេលានិងទីកន្លែង ព្រមទាំងការជ្រើសរើសឥរិយាបថដែលសមស្រប រួចហើយគឺអ្នកអាចចាប់ផ្តើមបានហើយ។ សូមធ្វើការដកដង្ហើមស្រាល១និងតាមដំណើរធម្មជាតិនៅពេលដែលកំពុងដកដង្ហើមត្រូវកំណត់ដឹងអោយបានច្បាស់ នូវខ្យល់ដង្ហើមរបស់អ្នក។ ត្រូវដឹងអំពីខ្យល់ដង្ហើម ដោយពុំសំគាល់ថា មានខ្លួនជាអ្នកមានខ្យល់ដកដង្ហើមនោះឡើយ។ ត្រូវដឹងអំពីដំណើរដង្ហើមហើយ "ដក ដង្ហើមចូល" "ដកដង្ហើមចេញ"។ ប្រសិនជាមានវិត្តកច្រើនឬក៏ការរំខានផ្សេង១កើតមានហើយរារាំងដល់សមាធិរបស់លោកអ្នកពេលនោះអ្នកអាចសាករាប់ចង្វាក់ខ្យល់ដង្ហើម "ដកដង្ហើមចូល១ ២ ៣...." "ខ្យល់ដង្ហើមចេញ ១ ២ ៣..." ។នៅពេលដែលសមាធិរបស់លោកអ្នកមានភាពប្រសើរឡើងហើយឈប់រាប់ហើយងាកមកកំណត់ខ្យល់ដកដង្ហើមវិញ។ ព្យាយាមកំណត់ដឹងសភាព នៃខ្យល់ពាល់ត្រូវនឹង ចុងច្រមុះជាទីប្រព្រឹត្តិទៅរបស់ខ្យល់ដកដង្ហើមប៉ះខ្ទប់រាងកាយ។

ខ្យល់ដកដង្ហើមអាចប្រព្រឹត្តិទៅវែង ឬ ខ្លី លឿន ឬ យឺត អាស្រ័យទៅតាមទំនោរធម្មជាតិរបស់វា។ រក្សារាងកាយអ្នកអោយត្រង់ ហើយកុំកំរើកតាមដែលអាចធ្វើទៅបាន។ នៅពេលដែលអ្នកមាន ម្ចាស់ការទៅលើលំហាត់នេះហើយរាងកាយអ្នកនឹងមានភាពធូរស្បើយហើយដកដង្ហើមមួយ១។ អ្នកនឹងមានអារម្មណ៍ស្ងប់សុខ ហើយមិនរំខានដោយសារព្រឹត្តិការណ៍ផ្សេង១ឡើយ ទោះបីជាវានៅក្នុងចិត្ត ឬមក ពីខាងក្រៅក៏ដោយ។

នៅពេលដែលកំពុងហ្វឹកហាត់អានាបានស្សតិនេះ អ្នកគួរតែបំភ្លេចឱ្យអស់នូវរឿងរ៉ាវប្រចាំថ្ងៃគ្រប់យ៉ាងហើយនិងមិនត្រូវគិតថាខ្លួនជាខ្លួនឡើយ។ អ្នកគ្រាន់តែត្រូវដឹងអំពីចង្វាក់ដង្ហើមគ្រាន់តែកត់ សំគាល់ក្នុងចិត្តចំពោះដំណើរដង្ហើមចេញ ឬចូលនៅពេលដែលវាកំពុងដំណើរការ។ ពេលព្រឹកព្រហាមគឺជាពេលវេលាដ៏ល្អបំផុតសម្រាប់ការអប់រំអានាបានស្សតិដូច្នេះ។

**លំហាត់ទី ២ : សតិលើកជើងនូវឥរិយាបថដើរ**

ការអនុវត្តការដើរចាប់ផ្តើមឡើងជាមួយការឈរនៅលើចំនុចមួយ។ ឥរិយានៃការឈរ គឺត្រូវតែមានរាងកាយមានសភាពត្រង់រួមទាំងកែងជើងផងដែរ។ រក្សាភ្នែកអោយសំលឹងត្រង់ទៅមុខដោយមិនឱ្យសម្លឹងចុះក្រោម ឬឡើងលើឡើយ។ រក្សាឥរិយាបថនេះអោយបានជាប់រហូតនៅក្នុងអំឡុងពេលហ្វឹកហាត់ដើរ។ សូមកុំធ្វើចលនាទៅតាមតែចលនាភ្នែក តែត្រូវធ្វើចលនាទៅតាមការផ្ចង់អារម្មណ៍របស់យើង ។ នៅពេលដែលអ្នកឈរត្រូវដឹងថា អ្នកកំពុងឈរត្រូវសំគាល់ថាអ្នកកំពុងឈរដោយការនិយាយនៅក្នុងចិត្តរបស់អ្នកថា "ឈរ ឈរ ឈរ"។ ឥឡូវដំបូងបំផុតត្រូវចាប់ផ្តើមដើរដោយផ្តោតអារម្មណ៍ ទៅលើកែងជើងស្តាំ។ សំគាល់ការលើកជើងស្តាំដោយការនិយាយក្នុងចិត្តថា "លើក"។ ឈានជើងទៅ មុខដោយការសំគាល់នៅក្នុងចិត្តថា"ទៅ" ។ ដាក់ជើងចុះហើយដាក់លើដីដោយដឹងក្នុងចិត្តថា "នៅទីនេះ"។ លំហាត់នៃការដើរមានបីដំណាក់កាលគឺ"លើក""ទៅ""នៅទីនេះ" ។ សំគាល់ទៅលើដំណាក់កាលនីមួយៗខណៈដែលអ្នកដើរដោយការយកចិត្តទុកដាក់ផ្តោតទៅលើចលនានៃចង្វាក់ដំណើររហូតទាល់តែអ្នកបានទៅដល់គោលដៅដែលអ្នកកំនត់ទុក។

អ្នកត្រូវឈប់ហើយដាក់ជើងទាំងពីរស្របគ្នា នៅក្នុងឥរិយាបថឈរ ដោយនិយាយក្នុងចិត្តថា "ឈរ ឈរ ឈរ"។ នៅពេលដែលបែរដោយអ្នកបង្វិលកែងជើង របស់អ្នកសំគាល់ដំណាក់កាលនីមួយៗ នៃចលនាបង្វែរ : ការបង្វិលកែងជើងនៃជើងម្ខាង និងការលើក និងការដាក់ចុះនៃជើងម្ខាងទៀត សំគាល់ ដោយការនិយាយថា "បង្វិល"។ នៅពេលដែលបានបង្វិលរួចហើយសំគាល់នូវកិរិយាឈរ "ឈរ ឈរ ឈរ"។ បន្ទាប់មកចាប់ផ្តើមដើរម្តងទៀត "លើក ទៅ នៅទីនេះ........."។ លំហាត់នេះគួរតែអនុវត្តនីមួយៗ និងផ្ចង់អារម្មណ៍អោយបានល្អ។ បើសិនណាជាមានអារម្មណ៍ ការគិត សំលេង ឬការរំខាន។ល។ លេចចេញឡើង អ្នកត្រូវទទួលស្គាល់វានៅពេលដែលវាកើតមាន។ បើសិនជាអ្នកឮសំលេងអ្វីមួយអ្នកត្រូវនិយាយថា "ឮ ឮ ឮ" ។ប្រសិនបើជាមានគំនិតអ្វីមួយចូលមកក្នុងចិត្ត របស់អ្នកអ្នកត្រូវទទួលស្គាល់ដោយនិយាយថា "គិត គិត គិត" បន្ទាប់ពីទទួលស្គាល់ហើយ ចូរបង្វែរចំណាប់អារម្មណ៍របស់អ្នកទៅ លើលំហាត់ដើរវិញ ។

**លំហាត់ទី ៣ ៖ សតិរលឹកដឹង នូវកាយក្នុងជីវិតរស់នៅប្រចាំថ្ងៃ**

កាលណាអ្នកអាចមានការអប់រំចម្រើនសភាពកំណត់ដឹងតាមបែបសមាធិខ្លះៗ ដោយយកកាយនៃខ្លួនជាអារម្មណ៍ ក្នុងការអប់រំសមាធិអ្នកត្រូវព្យាយាមយល់អំពីអ្វី ដែលអ្នកកំពុងធ្វើ ជាមួយនឹងកាយនូវគ្រប់វេលាទាំងអស់នៅថ្ងៃដែលអ្នកធ្វើការ។ នៅពេលដែលអ្នកកំពុងដើរចូរផ្តោតចំណាប់អារម្មណ៍ទៅលើ ចលនានៃការដើរដោយសង្កេតទៅលើចលនា នេះឱ្យបានលំអិតបំផុតតាមដែលអាចធ្វើទៅបាន។ ថែមពីលើនេះទៀតគឺ ត្រូវដឹងនៅពេលដែលរាងកាយអ្នក អង្គុយ ឈរឬទម្រេត។ សង្កេតចលនារាងកាយថា តើកំពុងសំលឹងទៅកាន់អ្វីមួយឬក៏កំពុងសំលឹងជុំវិញថា តើកំពុងតែអោន ឬក៏សន្ទឹងថា តើកំពុងស្លៀកពាក់ បោកគក់ ហូប ទំពារ ឬក៏កំពុងតែលង់នៅក្នុងធម្មជាតិ។ គោលបំណងគឺរក្សាអារម្មណ៍អោយបាននឹងនៅតាមព្រឹត្តិការណ៍នីមួយៗនៅពេលដែលវាពិតជាកំពុងតែកើតឡើងតាមសេចក្តីពិត ប៉ុន្តែចូរកុំបណ្តោយវាឱ្យធ្លាក់ក្នុងស្ថានភាពនឹកក្នុងមនោគតិ (ស្រមើស្រម័យ) ដែលវាមិនកំពុងតែកើតឡើងឡើយ។ ការជាប់ជំពាក់នឹងរលត់បាត់ទៅ បើសិនជារាងកាយកំពុងតែធ្វើអ្វីមួយក្នុងខណៈ ដែលចិត្តកំពុងតែគិតទៅលើ អ្វីផ្សេងទៀតដូច្នះដែរ។ កាលណាលោកអ្នកទំនេរពីកិច្ចការ ចូរយកកាយរបស់លោកអ្នកមកជាអារម្មណ៍កម្មវត្ថុនៃការដឹងក្នុងការកំណត់ដឹងតាមបែបសមាធិ។

**វេទនាជាអារម្មណ៍របស់ការចំរើនភាវនា**

កិច្ចបដិវត្តិនៅក្នុងពេលនេះ គឺដើម្បីកំណត់ដឹងអំពីនាមធម៌ គ្រប់សេចក្តីដឹងខ្លួននៅរាល់ពេលដែល វាកើតមានឡើង។ លោកអ្នកនឹងមានកិច្ចការត្រូវធ្វើយ៉ាងច្រើន ប្រសិនបើអ្នកចង់វែកញែកនូវអារម្មណ៍របស់អ្នក។លោកអ្នកត្រូវដឹងថាវេទនាមានច្រើនប្រភេទមានជាសោមនស្សវេទនាទោមនស្សវេទនា ឬអព្យាកត។ អ្នកត្រូវយល់តើវេទនាទាំងនោះ កើតឡើងដូចម្តេចហើយតើវាក្លាយជាដូចម្តេចបន្ទាប់ពីវាកើតហើយនិងបាត់បង់ទៅវិញដូចម្តេច។ វេទនាកើតមានឡើងនៅពេលដែលមានការប៉ះខ្ទប់ជាមួយនឹង អាយតនៈ (ចក្ខុ សោត ឃាន ជីវ្ហា និងកាយ ) រួមជាមួយនឹងអារម្មណ៍ដែលមាននៅខាងក្រៅ។ សភាពវេទនាត្រូវធ្វើឱ្យជាក់ច្បាស់ហើយយល់ឱ្យបានតាមសេចក្តីពិតចំពោះអ្វីដែលវាកើតឡើង។

**លំហាត់ ១ ៖ សតិរលឹកដឹង នូវអាយតនៈ**

អ្នកត្រូវតែមានការកំណត់ដឹងចំពោះអាយតនៈទាំងឡាយ (ចក្ខុ សោត ឃាន ជីវ្ហា និងសរីរៈ វិញ្ញាណ) ព្រមទាំងការប៉ះខ្ទប់របស់វាទៅនឹងអារម្មណ៍លោកខាងក្រៅ។ អ្នកត្រូវដំណត់ដឹងអំពីវេទនាដែល កើតឡើងអាស្រ័យដោយផលនៃការប៉ះខ្ទប់ដូច្នេះ។ ឧទាហរណ៍ត្រចៀក

អ្នកឥឡូវនេះកំពុងប៉ះខ្ទប់ជាមួយ នឹងសម្លេង (ឧ. ក្មេងៗកំពុងស្រែក ហើយនិងកំពុងសើច) នៅខាងក្រៅកន្លែងដែលអ្នកកំពុងសមាធិ។ អារម្មណ៍មិនសប្បាយចិត្តលេចឡើង ឬក៏រាងកាយរបស់អ្នកកំពុងប៉ះខ្ទប់ជាមួយផ្ទៃរឹងមួយ (កៅអីដែល អ្នកកំពុងអង្គុយ) មិនពេញចិត្ត ពេញចិត្តមានអារម្មណ៍ថាកំពុងរមាស់នៅក្នុងច្រមុះអារម្មណ៍មិនស្រួលចង់អេះ។ សំគាល់អារម្មណ៍របស់អ្នកដូចជាឆ្មាំទ្វារកំពុងតាមដានសម្គាល់មើលមនុស្សចេញនិងចូល។ យកវេទនាមកជាអារម្មណ៍ក្នុងការកំណត់ដឹងនៃសមាធិរបស់លោកអ្នក។ នៅពេលនោះលោកអ្នកនឹងបានយល់អំពីសភាពពិតនៃការវេទនារបស់លោកអ្នក រួចហើយលោកអ្នកនឹងអាចធ្វើការអប់រំបានល្អក្នុងការពិនិត្យមើលវា។

**លំហាត់ទី ២ : សតិរលឹកដឹងអំពីវេទនាក្នុងជីវិតរស់នៅប្រចាំថ្ងៃ**

ព្យាយាមបង្កើតការគ្រប់គ្រងវេទនារបស់អ្នកយឺតៗ ដោយការទទួលទានអាហារសមល្មម និងមិនត្រូវទទួលទានដំណេកច្រើនពេកឡើយ។ ព្យាយាមពិនិត្យមើលវេទនារបស់អ្នកនៅពេលដែលវាកើត ឡើងនៅតាមដំណាក់កាលនីមួយៗនៃជីវិតប្រចាំថ្ងៃរបស់អ្នក។ ទាំងនេះគឺជាឧទាហរណ៍ខ្លះៗនៅពេលដែលចាំឡានដោយអំណត់នៅឯចំណតឡានក្រុងសង្កេតឃើញថា "ការមិនសប្បាយចិត្តកើតឡើងនៅក្នុងចិត្ត" ។ នៅពេលដែលកំពុងញ៉ាំអាហារយ៉ាងឆ្ងាញ់នៅក្នុងភោជនីយដ្ឋានមួយសង្កេតឃើញថា "អណ្តាតកំពុងប៉ះជាមួយវត្ថុដែលមានរសជាតិឆ្ងាញ់ចំណង់ចង់ញ៉ាំកើតឡើង" ។នៅពេលដែលអ្នកជួបមិត្តល្អម្នាក់ដែលអ្នកខានជួបជាយូរមកហើយសង្កេតឃើញថា "ចិត្តកំពុងប៉ះជាមួយវត្ថុដែលជាមិត្តភាព អារម្មណ៍ល្អ និងរីករាយបានកើតឡើង" ។

**សភាពនៃចិត្តដែលជាអារម្មណ៍របស់ការចំរើនភាវនា**

អ្នកមិនអាចគេចចេញអំពីចិត្តរបស់អ្នកឡើយ។ ប៉ុន្តែតាមរយៈភាវនាអ្នកអាចអប់រំចិត្តរបស់អ្នកឱ្យមានភាពស្ងប់ ហើយនិងជៀសផុតអំពីការរំខានទាំងពីខាងក្នុងនិងខាងក្រៅ។ បដិបត្តិកំណត់ដឹង ដោយសមាធិចំពោះសភាពរាយមាយនៃចិត្ត និងសភាពញាប់ញ័ររយមទាំងសង្កេតពិនិត្យឬក៏យកចិត្តទុកដាក់នូវរាល់ការប្រែប្រួលរបស់ចិត្តលោកអ្នក។កាលបើចិត្តចម្រើនល្អហើយវានឹងនាំមកនូវសុភមង្គល និងបរមសុខ។ បើសិនចិត្តរបស់អ្នកវង្វេងវាធ្វើឱ្យខ្វល់ខ្វាយ និងតានតឹងមិនចេះចប់។ ចិត្តដែលប្រកបដោយវិន័យមានភាពរឹងមាំ និងមានប្រសិទ្ធភាពខណៈដែលចិត្តរាយមាយច្រើនមានសភាពខ្សោយ និងអប្រសិទ្ធភាព។ មនុស្សឆ្លាតហ្វឹកហ្វឺនចិត្តរបស់គេហ្មត់ចត់ដូចគ្រូបង្វឹកសេះបង្ហាត់សេះរបស់គេដូច្នេះដែរ។

**លំហាត់ទី ១ : ការសង្កេតចិត្ត**

អង្គុយម្នាក់ឯងដោយសង្កេតនូវស្ថានភាពផ្លាស់ប្តូរបច្ច័យនៃចិត្ត។ កិច្ចការសំខាន់ដែលត្រូវធ្វើតែមួយគត់គឺត្រូវសង្កេតសភាពប្រែប្រួល ។កុំប្រឆាំងជាមួយចិត្តឬគេចវេសពីវាឬព្យាយាមគ្រប់គ្រងលើវា។ គ្រាន់តែក្រលេកមើលទៅចិត្ត ដោយសភាពសាមញ្ញ ដោយគ្រាន់តែព្យាយាមតាមឃើញសភាពរបស់វាប៉ុណ្ណោះ។ ខណៈពេលដែលចិត្តស្ថិតក្នុងភាពត្រេកត្រអាល ក៏ដឹងថាចិត្តមានភាពត្រេកត្រអាល។ សង្កេតនៅពេល ដែលចិត្តស្ថិតក្នុងសេចក្តីស្ងប់ឬនៅពេលដែលចិត្តជ្រះស្រលះពីសេចក្តីស្ងប់។ សង្កេតមើលចិត្តដែលនឹងនរ នឹងចិត្តដែលរាយមាយ។ សង្កេតស្ថានភាពផ្លាស់ប្តូរទាំងអស់នេះដោយកុំសំគាល់ខ្លួនអ្នកថា នៅជាមួយស្ថានភាពទាំងនេះឡើយ។ កិច្ចការដែលត្រូវធ្វើគឺ បង្វែរចំណាប់អារម្មណ៍របស់អ្នកចេញពីលោកនេះ ហើយផ្តោតទៅលើពិភពនៃចិត្តរបស់ខ្លួនឯងផ្ទាល់ៈ យកចិត្តទៅសង្កេតទៅលើចិត្ត ដើម្បីរកឱ្យឃើញធម្មជាតិរបស់ចិត្ត។ ដូច្នេះជាកិច្ចដែលសម្រេចបានដោយកម្រប៉ុន្តែវាអាចប្រព្រឹត្តិទៅបាន។

**លំហាត់ទី ២ : ពិនិត្យមើលចិត្តក្នុងជីវិតប្រចាំថ្ងៃ**

ក្នុងគ្រប់ស្ថានភាពទាំងអស់ លោកអ្នកត្រូវសង្កេតពិនិត្យដំណើរនៃចិត្តរបស់អ្នក ដោយមិនចាំបាច់សំគាល់ ឬរកយុត្តិកម្មតាមគំនិតរបស់អ្នកឡើយដោយមិនបង្កើតឱ្យមានភាពលំអៀងដោយមិនរំពឹងថាមានលាភសក្ការៈ ឬសេចក្តីក្រេកអរឡើយ។ ក្នុងខណៈដែលអ្នករវល់កិច្ចការដោយការជាប់ជំពាក់នៅ ក្នុងចិត្តសេចក្តីស្ងប់ និងអកុសលធម៌ផ្សេងៗប្រាកដជាកើតមានហើយធ្វើឱ្យរកាំចំពោះតុល្យភាពរបស់ ចិត្តនោះ ជាពេលដែលអ្នកត្រូវការធ្វើសមាធិដើម្បីពិនិត្យមើលហេតុដែលនាំមកនូវក្តីទុក្ខទោសទាំងអស់នោះ ។ឧ.ចូរទទួលស្គាល់ថា" *ចិត្តព្រួយបារម្ភពីព្រោះខ្ញុំបានខកឡានក្រុងការព្រួយបារម្ភគឺមិនមែន នៅក្នុងឡាននោះទេ តែការព្រួយបារម្ភនេះគឺនៅក្នុងចិត្ត*" ។ ទទួលស្គាល់ថា " *សេចក្តីស្ងប់ស្ថិតក្នុងចិត្ត ដោយសារខ្ញុំពិតជាមិនចូលចិត្តអាហារនេះឡើយ។ សេចក្តីស្ងប់គឺមិនមានក្នុងអាហារឡើយតែវាមាននៅក្នុងចិត្ត។ ខ្ញុំត្រូវតែសង្កេតដោយយកចិត្តទុកដាក់ ចំពោះសេចក្តីស្ងប់នេះដែលមាននៅក្នុងចិត្ត*" ។

**សភាពគ្រិះរិះខាអារម្មណ៍នៃការចំរើនភាវនា**

នៅក្នុង *សតិបាតិនស្ស សូត* (Satipatthana Sutta) ត្រូវបានរកឃើញការកំណត់ដឹងស្តីអំពីវិធីត្រាស់ដឹង ដូចដែលបានសំដែងដោយព្រះពុទ្ធ។ ទាំងនេះជាទិដ្ឋភាពផ្សេងនៃព្រះធម៌ ឬការបង្រៀនគឺជា អារម្មណ៍នៃចិត្តដែលត្រូវកំណត់ដឹងដោយសតិ និងសង្កេតពិនិត្យ នៅពេល

ដែលវាកើតឡើងនៅខាងក្នុង។ សម្រាប់លោកអ្នកទាំងឡាយណា ដែលចាប់ផ្តើមចំរើនភាវនា តែពុំបានដឹងអំពីចំនុចទាំងឡាយនៃការសំដែង របស់ព្រះពុទ្ធអារម្មណ៍របស់ចិត្ត អាចត្រូវបានចាត់ទុកជាគតិ និងគំនិតដែលកើតឡើងនៅក្នុងចិត្ត។

កិច្ចការដែលត្រូវធ្វើនៅពេលនេះគឺត្រូវកំណត់ដឹងអំពីការត្រិះរិះទាំងឡាយ ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងចិត្ត។ អ្នកត្រូវតែយល់បន្តិចម្តងៗអំពីធម្មជាតិនៃការត្រិះរិះ។ អ្នកត្រូវយល់អំពី អ្វីដែលជាសារប្រយោជន៍ពីការត្រិះរិះល្អ ហើយជៀសអោយផុតពីគ្រោះថ្នាក់នៃការត្រិះរិះដែលនាំអោយ ទុក្ខទោស។ ការត្រិះរិះរបស់អ្នកត្រូវការពិនិត្យជាប្រចាំ បើសិនជាចង់បន្សុទ្ធចិត្ត។

**លំហាត់ទី ១ : សតិរលឹកដឹងនូវការនឹកគិត**

អង្គុយម្នាក់ឯងនិងផ្តោតចិត្តលើការគិតទាំងឡាយ។ ពិនិត្យមើលគំនិតល្អៗទាំងឡាយ និងសង្កេតមើលថា តើគំនិតទាំងនោះវាមានឥទ្ធិពលយ៉ាងដូចម្តេចខ្លះ ទៅលើចិត្តរបស់អ្នក។ ពិនិត្យមើលការគិតដែលឱ្យទុក្ខទោសទាំងឡាយ និងសង្កេតមើលថា តើគំនិតទាំងអស់នោះវារំខានដូចម្តេចខ្លះទៅលើចិត្តរបស់អ្នក។ ចូរសង្កេតចិត្តដោយសមញ្ញដោយគ្មានកង្វល់ដូច្នេះទើបមានឱកាសដើម្បីទៅអោយហួសពីការនឹកគិតទាំងនេះ។ ការដែលអាចទៅឱ្យផុតពីការនឹកគិតទាំងអស់នេះនឹងនាំមកនូវបញ្ញា សេចក្តីសុខសាន្តភាពសុខដុមរមនា និងសុភមង្គល។ ធ្វើដូចជាអ្នកពិនិត្យមើលមនុស្សចូលមក និងចាកចេញពីបន្ទប់របស់ អ្នកចូរពិនិត្យមើលការគិតទាំងឡាយដែលចូលមក និងចេញពីចិត្តរបស់អ្នកដូច្នោះដែរ។ អាស្រ័យដោយ កំណត់ដឹងនូវការនឹកគិតទាំងនេះអ្នកអាចកាត់បន្ថយចំនួននៃការគិតបន្តិចម្តងៗ រាល់ការនឹកគិតនីមួយៗដែលបានកាត់ផ្តាច់ហើយ នឹងបាននាំមកនូវសេចក្តីស្ងប់ដែលតាំងមាំក្នុងចិត្ត។ បើសិនជាអ្នកប្រឆាំងទៅ នឹងគំនិតដែលកើតឡើងទាំងនោះអ្នកនឹងមិនសប្បាយចិត្តឡើយ។ ដូច្នេះសូមសង្កេតគំនិតទាំងនោះដោយសាមញ្ញ។ បន្តិចម្តងៗអ្នក នឹងឈានទៅរកការយល់អំពីរបៀបគ្រប់គ្រងលើគតិអាក្រក់ និងលើកតម្កើងគតិល្អ។

**លំហាត់ទី ២ : សតិរលឹកដឹងនូវអារម្មណ៍ដែលជានាមធម៌**

ក្នុងអំឡុងពេលនៃថ្ងៃធ្វើការរបស់អ្នកសូមព្យាយាមសង្កេតលើដំណើរការគិតរបស់អ្នក។ មិនសំគាល់ដោយត្រឹមតែកិច្ចដំណើរការប៉ុណ្ណោះទេ គឺត្រូវសង្កេតតាមបែបសាមញ្ញៗ ទទួលស្គាល់ថា" ខណៈនេះគំនិតរបស់អាត្មាអញមិនត្រូវទេ អាត្មាអញកំពុងតែព្យាយាមបោកបញ្ឆោត

គេ” ។ក៏ដឹងតាមពិតថា“ខណៈនេះចិត្តកំពុងគិតផ្ទុយពីរការពិត។ អ្វី១ដែលអាត្មាអញគិត អាត្មាអញគិតផ្ទុយពីការពិត។ ហេតុអ្វីបានជាដូច្នេះ?” ដឹងតាមពិតថា “ហើយនេះគឺជាគតិដ៏ល្អដែលទើបតែកើតមានក្នុងចិត្ត។ អាត្មាអញ គួរគប្បីចែករំលែកនូវគតិដ៏ល្អនេះដល់អ្នកដ៏ទៃ ដើម្បីប្រើប្រាស់ក៏ដូច្នេះដែរ” ។

**សេចក្តីចម្រើនក្នុងការចម្រើនភាវនា**

ត្រូវចងចាំថា ការបដិបត្តិចម្រើនភាវនាត្រូវតែមានការអត់ធ្មត់ការព្យាយាម ដដែល១ និងកិច្ចខំប្រឹងប្រែង។ ជាខាងក្រោយមកទៀតសេចក្តីចំរើនអាចប្រព្រឹត្តិទៅយ៉ាងច្រើន និងមានពេលយូរអង្វែងទើបសម្រេចទៅបាន ។ពុំមានផ្លូវណាវៀងនិងពុំមានរូបមន្តពិសេសនោះឡើយ។ ដំណាក់កាលនៃការធ្វើភាវនាទាមទារឱ្យមានការព្យាយាម : វាដូចជាកំពុងហែលបញ្ច្រាស់ចរន្តខ្សែទឹកដូច្នេះដែរ។

អ្នកអាចអស់សង្ឃឹម បើសិនជាអ្នករំពឹងលទ្ធផលភ្លាម១ ឬ ឆាប់រហ័សពីការចម្រើនភាវនារបស់អ្នក។ បើសិនជាអ្នកជាមនុស្សម្នាក់ដែលរវល់ជាមួយ នឹងមហិច្ឆតាផ្លូវលោកិយ អ្នកមិនអាចធ្វើឱ្យចិត្តរបស់ អ្នកស្ងប់ស្ងាត់ភ្លាម១ឬដោយចេតនានោះទេ ដើម្បីទៅដល់ចំណុចជម្រុះចោលនូវការគិតទាំងអស់ឡើយហើយ អ្នកក៏មិនអាចទទួលបានបទពិសោធន៍ភ្លាម១ នូវការដឹងមួយដែលខ្លាំងនិងផ្ចិតផ្ចង់បន្តបន្ទាប់ ។បើសិនជាអ្នករំពឹងថានឹងរីកចម្រើនក្នុងការធ្វើភាវនា អ្នកត្រូវបង្កើតច្បាប់ហ្វឹកហាត់មួយចំនួនសំរាប់ខ្លួនអ្នក។ ច្បាប់ហ្វឹកហាត់មានសារៈសំខាន់ដើម្បីបង្កើនសមត្ថភាពសំរាប់កីឡាករដែលមានបំណងឈ្នះពានរង្វាន់។ ដូចគ្នានេះដែរច្បាប់ហ្វឹកហាត់គឺ មានសារៈសំខាន់ដើម្បីបង្កើនសមត្ថភាពរបស់អ្នកធ្វើភាវនា ដែលមានបំណងសម្រេចដំណាក់កាលចុងក្រោយ។ ក្នុងការបង្កើតគោលការណ៍សំរាប់ខ្លួនអ្នកគឺ ដូចជាខ្សែហ្គីតាដែលមិនតឹងពេក ហើយក៏មិនធូរពេក : សូមកុំធ្វើឱ្យភាពស្ងប់ស្ងាត់របស់អ្នកបាត់បង់ទៅ។ សុខភាពផ្លូវកាយ និងផ្លូវចិត្តដែលល្អគឺ ចាំបាច់ណាស់សម្រាប់ការរីកចម្រើនរបស់អ្នក។ អ្នកត្រូវតែរក្សានិងបង្កើតឱ្យមានថាមពលគ្រប់គ្រាន់ទាំងផ្លូវកាយនិងផ្លូវចិត្ត។ រាងកាយឬចិត្តមួយដែលខ្សោយ ឬហេវហត់ពេកគឺជាឧបសគ្គដ៏ធំចំពោះការធ្វើភាវនា។ អ្នកត្រូវតែឱ្យរាងកាយនិងចិត្តរបស់អ្នកបានសម្រាកត្រឹមត្រូវហាត់ប្រាណ និងចំណីអាហារ។

តើអ្នកធ្វើយ៉ាងណាដើម្បីវិនិច្ឆ័យការរីកចំរើនជាក់លាក់ក្នុងការធ្វើភាវនា? វាមិនមែនជាការងារ ស្រួលសម្រាប់បុគ្គលម្នាក់ធ្វើការវាយតម្លៃការរីកចម្រើនខាងផ្លូវចិត្ត របស់ខ្លួនទេ។

សូមកុំវិនិច្ឆ័យការរីកចម្រើន ដោយភាពសុខវេទនាក្នុងរយៈពេលខ្លី ការដឹងដោយអារម្មណ៍ទាំងឡាយដែលផ្លាស់ប្តូរ និងភាពមិនប្រក្រតីនៃមនសិការ ឬអំណាចក្រៅធម្មជាតិ។ ខាងក្រោមនេះវាជាគោលការណ៍មួយចំនួនដើម្បីកំណត់បង្ហាញ វាស់វែងនូវការរីកចម្រើនពិតប្រាកដ : ប្រសិនបើលោកអ្នកកំពុងទទួលបាននូវភាពកើនឡើង នៃសុភមង្គលភាពស្ងប់ស្ងាត់ព្រមជាមួយនឹងការរំងាប់ផ្លូវចិត្ត និងបើសិនជាអ្នកកំពុងទទួលបាននូវភាពថយចុះនៃសេចក្តីកង្វល់ភាពអស់សង្ឃឹមការព្រួយបារម្ភណ៍សេចក្តីរំភើបខណៈនោះអ្នកកំពុងតែរីកចម្រើនយ៉ាងពិតប្រាកដហើយ។

**ការធ្វើភាវនាក្នុងជីវិតប្រចាំថ្ងៃ**

ការអប់រំសតិរលឹកដឹង អាចបានទៅជាការអប់រំចម្រើនភាវនា។ តែសភាពបែបនេះត្រូវតែផ្ទេរចូល ជីវិតប្រចាំថ្ងៃរបស់អ្នកបន្តិចម្តងៗ។ វាប្រហែលជាត្រូវការពេលវេលាកិច្ចខំប្រឹងប្រែង និងភាពអំណត់ ប៉ុន្តែអ្នកអាចអនុវត្តធ្វើភាវនាពេញមួយជីវិតរបស់អ្នកចម្រើនតាមបែបនៃការកំណត់ដឹងដោយសតិ ដោយផ្ទង់អារម្មណ៍នៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក។ ជីវិតក្នុងសម័យទំនើបមានកាតព្វកិច្ចជាច្រើន ដែលត្រូវធ្វើសកម្មភាពបន្ទាន់ពេលវេលាដ៏តឹងតែង និងស្ថានភាពរំភើបដែលបង្កើតឱ្យមានការខ្វះខ្វាយយ៉ាងច្រើននូវថាមពលចិត្ត។ ពេលស្ថិតនៅក្នុងជីវិតច្របូកច្របល់ សូមដាក់ពេលប៉ុន្មាននាទីសម្រាប់ថ្ងៃនីមួយៗ ដើម្បីធ្វើភាវនាដែលស្ងប់ស្ងាត់ដើម្បីបង្កើនកម្លាំងឱ្យចិត្តរបស់អ្នក។នេះជាទ្រព្យមួយ ដែលសំខាន់សម្រាប់ការងារប្រចាំថ្ងៃនិងការរីកចម្រើនរបស់អ្នក។ ដោយការពិនិត្យមើលគតិរបស់អ្នក និងអារម្មណ៍របស់អ្នកដ៏ទៃនៅពេល ដែលវាកើតឡើងក្នុងទម្រង់ការប្រចាំថ្ងៃរបស់អ្នក នោះអ្នកអាចអង្កេតអត្ថន័យខាងក្នុងរបស់រឿងរ៉ាវទាំងអស់នោះបន្តិចម្តងៗ។ អ្នកអាចរកឃើញថាមពល និងភាពស្ងប់ស្ងាត់នៅខាងក្នុងចិត្ត។

បើសិនជាអ្នកអាចអនុវត្តការធ្វើភាវនាក្នុងជីវិតប្រចាំថ្ងៃរបស់អ្នកនោះ អ្នកពិតជាមានជីវិតរស់រវើកពេញលេញ ហើយនិងកំពុងរស់នៅក្នុងបច្ចុប្បន្នកាល។ អ្នកពិតជាដឹងនូវអ្វីដែលកំពុងកើតឡើងចំពោះអ្នកនិងនៅជុំវិញអ្នក។ នៅក្នុងពិភពលោកដែលមិនចេះនឿយហត់នេះអ្នករស់នៅខាងក្នុងសន្តិភាព និងភាពស្ងប់ស្ងាត់។

## ៤.សីលចរិយា (Moral Conduct-(Sila) ) By Phra Sasana Sobhana-Thailand

សីលឬសីលចរិយា គឺជាគោលការណ៍ប្រព្រឹត្តរបស់ មនុស្សដែលគាំទ្រដោយរបៀបរយ និងអត្ថិភាពសន្តិភាព (peaceful existence) នៅក្នុងសហគមន៍។ វិធាននៃសីលចរិយាត្រូវបាន

គេរកឃើញនៅក្នុងគ្រប់សាសនាទាំងអស់។ វិធានទាំងនេះដូចគ្នានឹងច្បាប់ទូទ្នានដទៃទៀតដែរ មិនតូចពេក មិនធំពេកអាស្រ័យទៅលើគ្រូ ឬប្រព័ន្ធសាសនាដែលបង្កើតវាឡើង។ តាមធម្មតា វាមានបញ្ជីអំពើដែលត្រូវជៀសវាង (ដោយបញ្ជាក់ថា អំពើមួយចំនួនដែលមិនបានគ្របដណ្តប់ ដោយការហាមឃាត់នោះ) មានលក្ខណៈអាចបើកដៃឱ្យបាន។ គំរូល្អមួយត្រូវបានផ្តល់ដោយ បញ្ចសីល(ព្រះពុទ្ធសាសនា) គឺថាត្រូវជៀសវាងការយក ទ្រព្យអ្វីមួយ ដែលម្ចាស់គេមិនបានឱ្យ ជៀសវាងពីការប្រព្រឹត្តខុសខាងផ្លូវភេទ ជៀសវាងពី ការនិយាយភូតឬ សម្តីអាក្រក់ និងជៀស វាងពី ការផឹកគ្រឿងស្រវឹង ផ្សេងៗដែលជាហេតុចម្បងនៃកំហុសនានា។ បញ្ចសីល នេះគឺជា មូលដ្ឋានគ្រឹះរបស់ព្រះពុទ្ធសាសនា ដែលមនុស្សជាច្រើនបំផុតត្រូវចេះចាំ។ វាមានលក្ខណៈជា ទម្លាប់សម្រាប់ពួកគេដែលគេត្រូវពន្យល់នៅក្នុង ពិធីសាសនា ស្ទើតែទាំងអស់ហើយ សីល ទាំង នោះសម្តែងពន្យល់នៅក្នុង ពិធីនានា ដែលប្រកាសពីបំណងផ្លូវការជាទូទៅដើម្បីប្រតិបត្តិតាម សិក្ខាបទនេះ។ មនុស្សនៅក្នុងប្រទេសកាន់ព្រះពុទ្ធសាសនាត្រូវតែដឹងឬស្តាប់ព្រះសង្ឃសម្តែង ពីសីលតាំងពីគេនៅតូចៗម្ល៉េះ ហើយមិនបានយល់ពីសីលទាំងនោះទេ។ ជារឿយៗត្រូវចាប់ អារម្មណ៍គិតពិចារណាពីវិសាលភាពដែលមនុស្ស ជាច្រើនយល់ច្បាស់ពីសារៈសំខាន់របស់ សីល និងអ្វីដែលពួកគេគិតអំពីវាជាពិសេសភាគច្រើនបំផុតទៅលើ សីលដែលបង្គាប់ដល់ ច្បាប់ទូទ្នាន ដែលខុសគ្នាស្រឡះពីការប្រតិបត្តិរបស់មនុស្សទូទៅ។មនុស្សមួយចំនួនពេញចិត្តនឹង សីល ប៉ុន្តែ អ្នកខ្លះទៀតមិនចូលចិត្តវាទេ ដែលអាចត្រូវបានគេប្រមូលរួមមកជាតួយ៉ាងដូចតទៅ។

**សីលទី១** : ការហាមឃាត់ប្រឆាំងទល់នឹងការសម្លាប់ ជីវិតទាំង មនុស្សនិង សត្វគ្រប់ ប្រភេទទាំងអស់ទោះតូចក្តីឬធំក្តីស្រមោចខ្មៅឬក្រហមក្តី។ ជារៀងរាល់ថ្ងៃ សត្វមួយចំនួនធំ ត្រូវបានគេ សម្លាប់ធ្វើជាអាហារមនុស្សជា ច្រើនបរិភោគសាច់នេះ ប៉ុន្តែមួយចំនួនតូចមិនទទួល ទានទេ។ នៅក្នុងវិស័យវិទ្យាសាស្ត្រសត្វត្រូវបានគេយកមក ប្រើនៅក្នុងការស្រាវជ្រាវនិងធ្វើ ពិសោធន៍។ នៅក្នុងវិស័យរដ្ឋបាលទាហានត្រូវបានគេប្រើដើម្បីបង្ក្រាបឧក្រិដ្ឋកម្ម។ ភ្នាក់ងារ ប្រតិបត្តិច្បាប់ដាក់ទណ្ឌកម្មលើអ្នកប្រឆាំងច្បាប់។ អ្នកសង្គ្រាមនៅពេលមានសង្គ្រាមបានប្រើ អាវុធដើម្បីបំផ្លាញគ្នា។ អំពើដែលបានបង្ហាញជូននៅទីនេះជាឧទាហរណ៍ មិនត្រូវបានគេចាត់ ទុកថា មិនត្រឹមត្រូវឬជាការខុសឆ្គងចំពោះការប្រតិបត្តិលោកិយនោះឡើយ។ តាមពិតទៅវា អាចត្រូវបានគេគិតថាវាខុសប្រសិនបើគេនៅក្រៅករណីយកិច្ចយោធាឬនគរបាល។ សព្វថ្ងៃនេះ មានប្រភេទសត្វជាច្រើនត្រូវបានគេដឹងថា ជាអ្នកផ្ទុកអតិសុខុមប្រាណហើយអរគុណ ណាស់

ចំពោះអតិសុខុមទស្សន៍ដូចជាមេរោគ និងអតិសុខុមប្រាណជាច្រើនប្រភេទត្រូវបានការពារ។ អ្វីៗភាគច្រើនបំផុត ដែលមានផ្ទុកពួកវាទាំងនេះសូម្បីតែទឹកបរិភោគ។ មានតែវត្ថុមិនស្អាត មួយភាគធំត្រូវ បានសំអាតដោយតម្រងអតិសុខុមប្រាណអាចឆ្លងកាត់បាន។ ដូចនេះអតិសុខុម ប្រាណអាចចូល ទៅតាមបំពង់ករបស់យើងតាមទឹកមិនស្អាត។ វាដូចគ្នានឹងជាមួយថ្នាំពេទ្យ ដែរ។ កាលណាពួកវាត្រូវបានគេប្រើទោះខាងក្នុងក្តី ខាងក្រៅក្តីវាកំទេចអតិសុខុមប្រាណបាន ជាអនេក។ តើអតិសុខុម ប្រាណទាំងនេះត្រូវបានគេគិតថាជា ភាវៈមានជីវិត (ខ្ជីមសារ)នៅ ក្នុងសីលទី១ឬក៏មិននៅក្នុងនោះទេ? ប្រសិនបើដូចនេះមែន ប្រហែលជាគ្មានអ្នកណាអាចធ្វើ តាមវាដោយពេញលេញបានទេ។ ម្យ៉ាងវិញទៀតមតិមួយចំនួនថា មនុស្សដែលជៀសវាងមិន យកជីវិតសត្វក៏គួរតែជៀសវាងពីការបរិភោគសាច់ដែរ ព្រោះវាជាការលើកទឹកចិត្តដល់អ្នក សម្លាប់ហើយគ្មាន បាបអ្វីដល់ពួកគេឡើយ។

**សីលទី២** : ការយករបស់អ្វីមួយដែល ម្ចាស់គេមិនបានឱ្យ(លួច)ក៏ជាអំពើខុសដែរសូម្បី និយាយដោយស្របច្បាប់ក៏ដោយ។ តែទោះជាយ៉ាងណាក៏ដោយ ជាឧបមាលើកលែងតែទ្រព្យ របស់សត្រូវនៅក្នុងករណីសង្គ្រាម។

សីលទី៣ : ការក្បត់ចិត្តប្តី/ប្រពន្ធគឺជា អំពើខុស។ អ្នកដែលប្រព្រឹត្តវាមិនបានបញ្ជាឱ្យ គោរពឬធ្វើឱ្យគេជឿទុកចិត្តនោះទេ។ ការប្រព្រឹត្តខុសខាង ផ្លូវភេទទាក់ទងទៅនឹងមនុស្សជា មួយនឹង សាច់សាលោហិតប្តី/ប្រពន្ធ(con-jugal relations) ត្រូវជៀសវាងដោយេ យាលទៅ តាមប្រពៃណីឬអ្នកដែលច្បាប់បានហាមឃាត់ ឬដោយព្រះធម៌ក៏ជាអំពើខុសដែរ។ ដូច្នេះការ បង្ខិតបង្ខំដោយមធ្យោបាយហិរញ្ញវត្ថុ ឬរូបកាយទៅលើអ្នករៀបការឬ អ្នកមិនទាន់រៀការឱ្យ ចូលទៅក្នុងការប្រព្រឹត្តបែបនេះ។ គោលបំណងរបស់សីលទី៣ នេះគឺដើម្បីការពារភាពគួរឱ្យ គោរព នៃគ្រួសាររបស់មនុស្សម្នាក់ៗដែលបានខ្វល់ខ្វាយ និងដើម្បីការពារ ការរំលោភបំពាន របស់វា។ លក្ខណៈដូចគ្នានេះដែរ ការគោរពមនុស្សទីកន្លែងនិងទ្រព្យសម្បត្តិគឺជា ឥរិយាបថ ប្រពៃណីមួយ ដូចមានចុះនៅក្នុង "សីលធម៌របស់មនុស្សល្អ" និយាយថា "ចូរកុំបុករុកចូលទៅ ក្នុងផ្ទះរបស់គេដោយគ្មានការអញ្ជើញ ។ចូរកុំលួចមើលគេតាមបង្អួច" ។វាសមរម្យសម្រាប់យើង ដែល ត្រូវទទួលយកចរិយាមារយាទដែលទាញចេញមកពី សីល ឬ វិធានសីលធម៌ ដែលវិធាន ទាំង អស់នេះមានបំណងឱ្យតម្លៃដល់ ឥរិយាបថល្អនិងធ្វើឱ្យភាពធូរស្រាលទៅជាតានតឹង។

**សីលទី៤** : ការភូតកុហក់ជាទូទៅត្រូវបានគេចាត់ថាជា អំពើខុស។ តែយ៉ាងណាក៏ដោយ មនុស្សកម្រនឹងនិយាយដោយ សច្ចភាពដាក់គ្នាបំផុត ហើយពាក្យដែលគេនិយាយ ពិបាកយក ជាការបានណាស់។ ជួនកាលពួកគេមិន អាចនិយាយពាក្យពិតបានទេ ឧបមាថា ពួកគេត្រូវតែ និយាយភូតដើម្បីជួយខ្លួនគេឱ្យរួចពី ទុក្ខទោសហើយវេជ្ជបណ្ឌិត ត្រូវតែនិយាយ ភូតដើម្បីជួយ លើកទឹកចិត្តអ្នកជម្ងឺ។ ការភូតនៅក្រោមកាលៈទេសៈបែបនេះ វាអាចផ្ទុយទៅនឹងសីល ប៉ុន្តែវា មិនមែនផ្ទុយចំពោះ គោលបំណងរបស់វាទាំងស្រុងនោះទេ។ សីល នេះមានបំណងនាំមកនូវ គុណប្រយោជន៍ចំពោះគ្នាទៅវិញទៅមក (mutual benefits)ដោយប្រកាន់ខ្ជាប់ សច្ចភាពនិង វៀរចាកការរំលោភដោយវាចា។ ប្រហាក់ប្រហែលគ្នានេះដែរ សម្ដី ដែលមានពីសពុលដល់ សុខុមាលភាពរបស់ អ្នកដទៃជាឧទាហរណ៍ សម្ដីរបិលរប៉ូចបំពាបំពាន ឬមួលបង្កាច់មានបំណង ចំអកមើលងាយអ្នកដទៃ ឬដើម្បីអួតខ្លួនមិនអាចមានសច្ចភាពនោះទេ ប៉ុន្តែអំពើទាំងអស់នេះ ត្រូវចាត់ទុកថាជាអំពើខុសពីព្រោះវាផ្ទុយទៅនឹងសីល។ គេបានយល់ថា ព្រះពុទ្ធម្ចាស់ទ្រង់មាន ពុទ្ធដិកាដោយព្រះអង្គឯងថា មានតែអ្វីដែលសច្ចៈទៀងត្រង់មានប្រយោជន៍ និងល្អត្រឹមត្រូវ ប៉ុណ្ណោះ។ព្រះអង្គយកសីលប្រឆាំងទល់នឹងសម្ដីភូតភរនិងរបិលរប៉ូចមិនទៀងត្រង់និងឥតបានការ។

**សីលទី៥** : ថ្វីបើវិធានបញ្ញត្តិឱ្យវៀរចាកពី ភេសជ្ជៈស្រវឹង ក៏ដោយក៏ការប្រើប្រាស់របស់ ពួកគេមិនបានថយចុះ ហើយសុរាគារអាជ្ញា (authorized distilleries) ក៏កំពុងធ្វើការពេញ ទំហឹង។ហាងស្រាត្រូវបានលក់ដាច់ទាំងថ្ងៃទាំងយប់។ នៅកន្លែងទទួលភ្ញៀវ (at receptions), ពិពណ៌ផលិតផល (fairs)។ល។ មានភេសជ្ជៈស្រវឹងធ្វើឱ្យពិធីជប់លៀង អធិកអធម្ម ម្យ៉ាង ទៀតពួកគេស្រវឹង ហើយពួកគេត្រូវជៀសវាងពីវា។ ដូច្នេះភេសជ្ជៈដែលមានជាតិស្រវឹងក្លាយ ទៅជា មុខរបររកស៊ីរកចំណូលមួយ (income-earner) ដែលនាំប្រាក់ចំណូល យ៉ាងធំធេងជា រៀងរាល់ឆ្នាំ។

ការប្រតិបត្តិបានចាត់ទុកជាអំពើត្រឹមត្រូវ ហើយដទៃទៀតចាត់ទុកថាជាអំពើខុសនោះ អាចផ្ទុយចំពោះសីលទាំងពីរដូចបានបង្ហាញនៅក្នុងសេចក្ដីខាងដើម។ករណីទាំងអស់នេះបង្ហាញ ឱ្យឃើញថាអ្នកដែលខកខានមិនបានយល់អំពី សីល កាន់តែច្រើនទៅៗពោលគឺការស្គាល់ច្បាស់ ពីសារៈសំខាន់របស់សីល និងវាយតម្លៃចំពោះខ្លឹមសាររបស់វាសម្រាប់ អត្ថិភាពរបស់គេនៅ ក្នុងលោកនេះ។ នោះគឺជាហេតុដែលទស្សនៈនីមួយៗ (ការច្របល់ត្រូវនិងខុសចូលគ្នា) ជាបន្ត បន្ទាប់ ខាងក្រោមជួយគាំទ្រ :

*១- គោលការណ៍សីលត្រូវបានគេបំប្លែងឱ្យសមទៅ នឹងអ្នកដែលមានមុខរបរលោកិយ ។* ជាឧបមាអ្នកខ្លះមានអារម្មណ៍ថា សីលទី១គួរត្រូវដូរដើម្បីឱ្យការសម្លាប់ត្រូវនឹងច្បាប់មានន័យថាមានតែការសម្លាប់ទេដែលមិន ត្រូវបានផ្ដល់អំណាចដោយច្បាប់នោះគួរតែត្រូវហាមឃាត់ ។ ម្យ៉ាងវិញទៀត សីលទី៤ (បើតាមពួកគេមានអារម្មណ៍) គួរតែត្រូវបង្កើតឡើងដោយទន់ភ្លន់ ហើយការភូតភរត្រូវបានអនុញ្ញាតឱ្យកាលណាគេត្រូវការការពារខ្លួនគេ ឬអ្នកដទៃ។ ដូច្នេះជាមួយនឹងសីលទី៥ ក៏ដូច្នេះដែរបើកាលណាគ្រឿងស្រវឹងត្រូវបានគេទទួលយកតែ ដោយពេលតែប៉ុណ្ណោះប៉ុន្តែកុំឱ្យលើសកំណត់ ។

*២-គោលការណ៍សីលគួរកុំប៉ះពាល់ ប៉ុន្តែគ្មាននរណាមួយចង់យកចិត្តទុកដាក់នឹងវាទេ ។* ប្រសិនបើអ្នកដែលប្រព្រឹត្តទៅតាមច្បាប់ ពួកគេត្រូវបានគេចាត់ទុកជាមនុស្សគួរឱ្យពេញចិត្ត ។ ជាចុងក្រោយច្បាប់គឺជាប្រភេទមួយរបស់ *សីល* ។ វាត្រូវធានាឱ្យមានសន្តិភាព និងសុខុមាលភាពរបស់សាធារណៈជនបើទោះជាវាពឹងផ្អែកទាំងស្រុងទៅលើគោលការណ៍ចិត្តសាស្ត្រក៏ដោយ ហើយធម្មចរិយាសនិទានដែលជា មូលដ្ឋានគ្រឹះរបស់សីលចំណុចមួយ ដែលយើងទាក់ទងជាក្រោយលើវា ។

*៣-គោលការណ៍សីលគួរកុំបំប្លែង ប៉ុន្តែយកចិត្តទុកដាក់និងសង្កេតមើលតែពីពេលមួយទៅ ពេលមួយអនុលោមតាមកាលៈទេសៈ ។* ពុទ្ធសាសនិកជនភាគច្រើនជាប្រភេទមនុស្សដែលប្រព្រឹត្តតាមមធ្យោបាយនេះ ។ ពួកគេមិនផ្លាស់ប្ដូរគោលការណ៍សីល ព្រោះពួកគេចាប់អារម្មណ៍មែនទែនទៅលើវា និងធ្វើតាមវាទៅតាមពេល ។ ជាឧបមាពុទ្ធសាសនិកជនមួយចំនួនមិនសេពគ្រឿងញៀនទេនៅក្នុងអំឡុងពេលជាក់លាក់មួយ ប៉ុន្តែក្រោយមកពួកគេចាប់ផ្ដើមផឹកឡើងវិញ ។ ប្រសិនបើពួកគេជាអ្នកនេសាទ ឬជាអ្នកលក់ត្រី ពួកគេមិនយកចិត្តទុកដាក់នឹង សីលទី១ ដែលនេសាទត្រី ឬលក់ត្រីមិនអាចប្រព្រឹត្តទៅបាននោះ (ប្រសិនបើគេសង្កេតមើល) ប៉ុន្តែពួកគេអាចជៀសវាងពីការសម្លាប់សត្វដទៃទៀត ។ ប្រសិនបើពួកគេជានិស្សិតពេទ្យ ពួកគេមិនគោរពតាមសីលទី១ ទាំងស្រុងនោះទេ ការសង្កេតមើលពីសីលផ្ដល់នូវការប្រើប្រាស់សត្វដើម្បីស្រាវជ្រាវនិងធ្វើពិសោធន៍ដែលមិនអាចប្រព្រឹត្តទៅបាននោះ ប៉ុន្តែពួកគេអាចពិនិត្យមើលសីលនៅពេលណាវាមានការប្រតិបត្តិសម្រាប់ពួកគេ ដែលត្រូវធ្វើបែបនេះមានន័យថា ពេលណាវាមិនរារាំងពួកគេនៅក្នុងវិជ្ជាជីវៈរបស់ពួកគេឬនៅក្នុងការសម្ដែងពីករណីយកិច្ចរបស់ពួកគេ ។

*៤-គោលការណ៍សីលគួរតែទុកកុំកែប្រែហើយត្រូវគោរពតាមដោយហ្មត់ចត់។* មានតិចតួចណាស់ដែលមានទស្សនៈបែបនេះ ។បើទោះជាគោលការណ៍ទាំងនេះអាចមានសេចក្តីសង្ស័យមួយចំនួនគោរពទៅតាមអតិសុខុមប្រាណ ហើយអ្នកដែលមិនចាប់អារម្មណ៍ចំពោះ សីល អាចមានសេចក្តីសង្ស័យដូចគ្នាតាំងពីការចង់ដឹងចង់ឃើញ ឬដើម្បីអះអាងថា សីល មិនអាចអនុវត្តបានទេ។ ដើម្បីសម្រេចចិត្តថាតើអតិសុខុមប្រាណគឺជាភាវៈមានជីវិត ឬក៏អត់ ( នៅក្នុងខ្លឹមសារសីល) គេគួរតែគិតពិចារណាពីជីវិតរបស់ព្រះពុទ្ធជាម្ចាស់ ។ពេលណាព្រះពុទ្ធជាម្ចាស់ធ្លាក់ខ្លួនអាពាធ។ ព្រះអង្គបានឱ្យវិជ្ជបណ្ឌិត JIVAKAKOMARABHACCA ប្រើឱសថខាងក្រៅឬថ្វាយថ្នាំដល់ ព្រះអង្គដើម្បីព្យាបាលខាងក្នុង។ ព្រះសង្ឃក៏ត្រូវបានអនុញ្ញាតឱ្យឆាន់ ឬប្រើឱសថដែរដើម្បីព្យាបាលជម្ងឺ។ ដូចនេះយើងអាចធ្វើការសន្និដ្ឋានថាសីលទី១មិនបាន ប្រើអតិសុខុមប្រាណទេប្រសិនបើវាប្រើនៅពេលនោះយើងមិនអាចបរិភោគ ឬផឹកអ្វីមួយឬក៏ដកដង្ហើម។ សីលគួរតែជាច្បាប់ទូន្មាន ដែលគេអាចគោរពតាម ដោយមនុស្សម្នាក់ៗជាធម្មតា ពោលគឺឥរិយាបថប្រតិបត្តិដោយឧបាស្រ័យចំពោះជំនួយនៃឧបករណ៍បែបនេះជាអតិសុខុមទស្សន៍ ។ការប្រើប្រាស់ឧបករណ៍ទាំងនោះ គួរតែត្រូវពិនិត្យសង្កេតចំពោះ មនុស្សដែលបានពេញចិត្តទៅលើវិជ្ជាជីវវិទ្យាសាស្ត្រ ឬថ្នាំពេទ្យ។

ដោយមានការចាត់ទុកចំពោះការប្រើសាច់ជាចំណីអាហារ ពោលគឺពុទ្ធសាសនិកខ្លួនឯងត្រូវបែងចែកទៅជាពីរក្រុម ក្រុមទី១ ចាត់ទុកការទទួលទានសាច់មិនសាហាវ ឃោរឃៅដូចអំពើសម្លាប់នោះទេ។ គេនិយាយថាប្រសិនបើសាច់មិន យកធ្វើជាចំណីអាហារទេ ក៏មិនមានហេតុដែលនាំឱ្យមានការបំផ្លាញសត្វនោះដែរ ដូចនេះការប្រើប្រាស់សាច់មានទំនួល ខុសត្រូវដោយផ្ទាល់ចំពោះអ្នកសម្លាប់របស់វា ដូចនេះហើយវាជាអំពើខុស។ vinaya ឬ វិធានអនុញ្ញាតឱ្យព្រះសង្ឃឆាន់សាច់នៅក្រោមលក្ខខណ្ឌបីពោលគឺ ប្រសិនបើពួកគេមិនបានឃើញ ឬឮពីការសម្លាប់សត្វទេ ហើយគ្មានហេតុផលណាដែលសង្ស័យថាការសម្លាប់ ព្រោះតែផលប្រយោជន៍របស់ពួកគេ ដែលផ្ទុយទៅនឹងការសម្លាប់ដើម្បីលក់ជាទូទៅនោះ។ ( នៅមានវិធានហាមឃាត់ព្រះសង្ឃពីការឆាន់ សាច់ឆៅឬប្រភេទសាច់ហាមឃាត់ ១០យ៉ាងមានសាច់ខ្លានិង សាច់ដំរី )។ ពុទ្ធសាសនិកប្រភេទនេះជាពិសេសព្រះសង្ឃ ថេរវាទមិនមានការសម្រិតសម្រាំង ហើយមានសេរីភាពឆាន់ដោយគ្មានកង្វល់អ្វីឡើយ។ ពួកគេត្រូវតែមានលទ្ធិភាពសេព ជាមួយអាហារបួស (តម) ហើយសេពជាមួយអាហារសត្វផងដែរ ដែលនាំមកថា លក្ខខណ្ឌបីដែលបាននិយាយ

មកជាខាងដើមនោះត្រូវគេធ្វើតាមហើយ នឹងនាំមកនូវសាច់មិនមែនជាប្រភេទមួយក្នុងចំណោមប្រភេទហាមឃាត់នានា។ ពួកគេនឹកសង្ឃឹមថា នឹងទទួលយកអ្វីៗ ដែលគេប្រគេន ដល់ព្រះអង្គ ពោលគឺជា អ្នកដែលតមសាច់ ឬប្រភេទសាច់សមស្រប។ នេះមិនត្រូវបានគេគិត ថាផ្ទុយទៅនឹងសីលនោះទេ ពីព្រោះទឹកចិត្តនៃពុទ្ធសាសនិកបែបនេះ ជាពិសេសចំពោះព្រះសង្ឃត្រូវសាយភាយដោយគុណធម៌គ្មានព្រំដែន និងមេត្តាធម៌ចំពោះសត្វនានា។ ព្រះអង្គមិន បណ្តោយឱ្យគេសម្លាប់សត្វណាមួយឡើយ លើសពីនេះទៅទៀត ចំពោះទស្សនៈដែលជាការ ទទួលទានសាច់គឺជាអំពើខុស ពួកគេបានបកស្រាយអំណះអំណាងដូចតទៅ : ប្រសិនបើ មានការប្រើសាច់គឺជាអំពើខុសដោយសីលធម៌ នៅពេលនោះការប្រើដោយលាក់កំបាំង, ឆ្អឹង, ស្បែងសត្វសុទ្ធតែត្រូវហាមឃាត់ទាំងអស់។ ផ្នែកទាំងពីរនេះនៅតែមិនស្របគ្នាទៅលើប្រធានបទនេះហើយសមាជិកមួយចំនួនរបស់ពួកគេក៏នៅតែធ្វើលើអំណះអំណាងដែរ។ ប៉ុន្តែមានមួយចំនួន ដែលមិនជជែកវែកញែកដោយពេញចិត្តចាកចេញពីបញ្ហាទាំងមូល ចំពោះមនសិការផ្ទាល់របស់បុគ្គលម្នាក់ៗ។ គេមិនគួរបង្ខិតបង្ខំអ្នកដទៃឱ្យទទួលយកទស្សនៈផ្ទាល់របស់គេឡើយ។ ដើម្បីធ្វើករណីនោះគឺជាការធ្វើឱ្យខូចខួរក្បាលផងដែរ ដោយហេតុដូចនេះ ហើយបានជាត្រូវជៀសវាងដែរ។

ប្រសិនបើគេសួរគោលបំណងអ្វីដែលព្រះពុទ្ធម្ចាស់សង្ឃឹមនិង ធ្វើដោយពឹងផ្អែកលើសីលដែលដាក់បញ្ញត្តិទៅលើ អនុបវាទរឹងមាំ ដែលពួកគេអាចធ្វើតាមដោយពេញលេញ ដោយមនុស្សតែពីរបីនាក់ប៉ុណ្ណោះ វាត្រូវតែទទួលយកថាគ្មាន នរណាអាចអះអាងឱ្យដឹងពីបំណងពិតរបស់ព្រះអង្គនៅក្នុងការធ្វើបែបនេះនោះទេ ផ្ទុយមកវិញគេអាចយកហេតុផល មកពីគោលការណ៍ជាច្រើនបញ្ជាក់ច្បាស់នៅក្នុងព្រះធម៌។

ព្រះពុទ្ធម្ចាស់ បានបង្រៀនប្រាប់យើងឱ្យធ្វើការប្រៀបធៀបរវាងខ្លួនយើង និងអ្នកដទៃដោយនិយាយថាៈ "សត្វមានជីវិត ទាំងអស់ខ្លាចការដាក់ ទណ្ឌកម្មនិង សេចក្តីស្លាប់ណាស់។ ជីវិតគឺជារបស់ដ៏គួរឱ្យស្រឡាញ់បំផុតរបស់ ភាវៈទាំងឡាយ (ក៏ដូចជាយើងដែរ)។ តាមរយៈការប្រៀបធៀបខ្លួនយើងទៅនឹងខ្លួនគេយើងនឹងបានយល់ច្បាស់ថាយើង(ម្នាក់ៗ) មិនគួរសម្លាប់ ឬបង្ខំឱ្យគេសម្លាប់នោះទេ"។តាមរយៈគោលការណ៍ព្រះធម៌នេះព្រះពុទ្ធម្ចាស់ចង់ឱ្យយើងយល់តាម រយៈការចូលទៅក្នុងអារម្មណ៍គ្នាទៅវិញទៅមកពោលគឺសត្វលោកស្រឡាញ់ ជីវិតរបស់វាយ៉ាងណាយើងក៏ស្រឡាញ់ជីវិតយើងបែបនោះដែរ ហើយមិនមានការខ្លាចស្លាប់នោះទេ។ នោះគឺជាហេតុដែលជាបញ្ហាយុត្តិធម៌សាមញ្ញមួយពោលគឺព្រះពុទ្ធម្ចាស់ទ្រង់ពឹងលើសីលទី១ ។សីលទី

២ បញ្ជាក់យ៉ាងច្បាស់លាស់ ពីការទ្រទ្រង់ដល់ការគោរពគ្នាទៅវិញទៅ មកចំពោះសិទ្ធិគ្នាអំពីទ្រព្យកម្មសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគេ។ សីលទី៣ ជម្រុញឱ្យគោរពចំពោះគ្រួសារគ្នា ទៅវិញទៅមក។ សីលទី៤ការពារផលប្រយោជន៍គ្នាដោយសច្ចៈទៀងត្រង់។ សីលទី៥ជួយឱ្យ យើងជៀសវាងពីការធ្វេសប្រហែសនិងការប្រមាថ។ ប្រសិនបើយើងរៀបចំការពារទ្រព្យគ្រួសារ និងជំនឿល្អរបស់យើងដោយប្រុងប្រយ័ត្ន នៅពេលនោះយើងមិនគួររំលោភទៅលើ សិទ្ធិរបស់អ្នកដទៃឡើយ។ សីលទាំងអស់ ឬ ច្បាប់ទូន្មានត្រូវបានពឹងផ្អែកតែម្យ៉ាងទៅលើ គោលការណ៍យុត្តិធម៌បរិសុទ្ធ។វាចង្អុលបង្ហាញថា ព្រះពុទ្ធសាសនាគោរពជីវិត សិទ្ធិ ទ្រព្យ សម្បត្តិ។ល។ របស់មនុស្សម្នាក់ៗ។ នេះគឺជាសច្ចភាពសាមញ្ញ ឬលោកកិយ។ ប្រសិនបើ ព្រះពុទ្ធធ្វើឱ្យ សីល អាចបត់បែនឬប្រែប្រួលបានទៅតាមចំណង់របស់មនុស្សសីលទាំងនោះ មិនស្របជាមួយនឹងយុត្តិធម៌បរិសុទ្ធនោះឡើយ។ ព្រះពុទ្ធម្ចាស់បានបង្ហាញពីព្រះអង្គ ឯងទន់ខ្សោយនៅក្នុងសេចក្ដីមេត្តាចំពោះសត្វទាំងនោះ ដែលការសម្លាប់របស់ពួកវាត្រូវបានគេអនុមត័។ នោះវាមិនស្រប គ្នាជាមួយនឹងអត្តចរិតរបស់ព្រះពុទ្ធ ដែលបានបំពេញដោយសេចក្ដីករុណា ធម៌ចំពោះសព្វសត្វឡើយ។ ហេតុផលមួយទៀតបានបញ្ជាក់កាលពីចាប់ផ្ដើមគឺថាសីលទ្រទ្រង់ជាពិសេស"គុណប្រយោជន៍ពិសេសបំផុត។"នេះមានន័យថា លទ្ធផលខ្ពស់បំផុតនៃការ បូជាចំពោះពួកគេគឺការរួចផុតពី ភាពក្រខ្វក់សព្វយ៉ាង។ សីល គឺជាជំហានទីមួយចំពោះគោលបំ ណងនេះ។ ការសង្កេតមើលជារួមអំពីសីលបើទោះជាមានតែសីល៥ នេះអាចនៅក្នុងខ្លួនវាជាជំហានមួយនាំទៅរកកម្រិតកាន់តែខ្ពស់ដែល"គុណប្រយោជន៍ពិសេសបំផុតនោះ"ត្រូវបានគេយល់ច្បាស់។ អ្វីដែលសំខាន់ពិសេសប្រហាក់ប្រហែលគ្នាជាមួយនឹង សីល នោះគឺត្រូវរកឱ្យ ឃើញពីហេតុដែលមនុស្សមាន ឬមិនមានដោយចាប់អារម្មណ៍ទៅលើការពិនិត្យសង្កេត។ មានហេតុផលខ្លះៗដូចតទៅ :

១-ដោយហេតុតែមានសីលរឹងមាំ ដែលជាប់ទាក់ទងការជៀសវាងពីការយកជីវិតសត្វមានជីវិតណាមួយ។ឧបមាពីវិធាននៃសីលចរិយាត្រូវបានពឹងផ្អែកទៅលើចរិយាយកចិត្តទុកដាក់ច្រើនពោលគឺ ការអត់ទ្រាំចំពោះការរំលោភមួយចំនួនដែលយើងបានពិភាក្សា តើវិធានបែបនេះត្រូវបានគោរពតាមដោយមនុស្សដ៏ច្រើនដែរ ឬអត់? ជាក់ស្ដែងគ្មានអ្នកណា អាចនិយាយដោយប្រាកដបានទេថា វាកើតមានឡើង ពីព្រោះគេមានការចាប់អារម្មណ៍ជាទូទៅថា វិធានសីលធម៌ជាពិសេសវិធានទាំងនោះចំពោះអ្វីដែលគេចាត់ទុកថាជា អំពើខុសទាំងនៅក្នុងខ្លឹមសារលោកិយ ឬទាំងខ្លឹមសារច្បាប់នោះសុទ្ធតែ ត្រូវបានរំលោភបំពានជាដរាប លើ សីលទី១ ឬ

សីលដទៃៗទៀត។ នេះបង្ហាញថា កំហុសសង្កេតទៅលើវាព្រោះតែភាពតឹងរឹងរបស់វា។ តាមធម្មតា ការចូលចិត្តធម្មជាតិរបស់គេគឺសមទៅ នឹងអំពើទាំងអស់ចំពោះសេចក្តីសុខស្រួលផ្ទាល់របស់គេ។ ជាតិនីមួយៗមានច្បាប់របស់វាហើយសាសនានីមួយៗមានសីលរបស់ខ្លួន។ សូម្បីតែនៅកន្លែង ដែលវិធានមួយចំនួនអាចបត់បែននិងកែប្រែបានក៏ដោយ ក៏វាគួរឱ្យជឿបានថា មានមនុស្សតែ ពីរបីនាក់ប៉ុណ្ណោះនឹងរំលោភបំពានលើ។

ដូច្នេះហេតុផលសំខាន់ សម្រាប់ការរំលោភបំពានដែលពឹងផ្អែកជាមួយ បុគ្គលខ្លួនឯងមនុស្សភាគច្រើនត្រូវបានគោរពជាធម្មជាតិមិនយកចិត្តទុកដាក់ ឬកែប្រែវិធានឱ្យត្រូវតាមភាពសុខស្រួលផ្ទាល់របស់គេ ហើយងាយស្រួលធ្វើបែបនេះ។

**២-ដោយសារតែបុគ្គលខ្លួនឯង** ហេតុដូចនេះហេតុអ្វីបានជាឯកត្តបុគ្គលរំលោភលើវិធានបើទោះបីជារឿងនេះត្រូវបានគេ ចាត់ទុកជាទូទៅ និងដោយស្របច្បាប់ថាជាអំពើខុសនោះ ? បុព្វហេតុនៃឥរិយាបថ បែបនេះ ដែលបានបង្កប់នៅក្នុងបុគ្គលខ្លួនឯងនោះគឺជា សេចក្តី លោភ, ទោសៈ និងមោហៈ ដែលកើតមាននៅក្នុងចិត្តជាពិសេស ហើយវាត្រឡប់វិញបាននាំឱ្យកើតកង្វះខាត ខ្មាស់អៀន ឬ ឧត្តប្បៈ ឡើង។ ដូចនេះប្រសិនការផ្លាស់ប្តូរត្រូវតែចង់បាន វាមិនអាចកើតឡើងនៅក្នុងគោលការណ៍ នៃសីលធម៌មិនបានទេ ប៉ុន្តែជាការផ្លាស់ប្តូរចិត្តមានន័យថា កាត់បន្ថយពិសេសជាជាង បង្កើនវាទៅ តាមមធ្យោបាយបែបនេះ ហិរិ ឧត្តប្បៈ ពោលគឺសេចក្តីខ្មាស់អៀននិង ការភ័យខ្លាចធ្វើអំពើ អាក្រក់កើតឡើងនៅក្នុងចិត្ត។ ដោយសារការប្រព្រឹត្តបែបនេះ សមត្ថភាពរបស់យើងដើម្បី គោរពតាមសីលមិនមែន មានន័យអនុបវាទពីអ្វីៗដែលបានបញ្ញត្តិនៅក្នុងវា។ អនុបវាទពីអ្វី ដែលត្រូវបានចាត់ទុកដោយត្រឹមត្រូវឬដោយលោកិយជាអំពើខុសគឺជាចរិយាអាចទទួលយកបានដោយខ្លួនឯង។

**៣-ដោយសារតែសារៈសំខាន់ដូចជានៅក្នុងករណីដូចតទៅ** : ការរំលោភលើសីលទី១ ដើម្បីការពារទ្រព្យសម្បត្តិ,ជីវិត,ជាតិ,សាសនានិងព្រះមហាក្សត្រ របស់ពួកគេ ដែល បានកើតឡើងនៅក្នុងសមរភូមិ ឬពេលគេមានទំនាក់ទំនងជាមួយឧក្រិដ្ឋជន ឬសត្រូវ។ ការប្រព្រឹត្តកន្លងលើសីលទី២ ដើម្បីការពារខ្លួនគេឱ្យមានជីវិតដោយ សារតែមាន កំហឹង ឬភាពក្រីក្រដាក់ស្តែង។ វាហាក់ដូចជាគ្មានហេតុផលចំពោះ ការរំលោភទៅលើសីលទី៣ ព្រោះការប្រព្រឹត្តតាមវាពិតជាមិនសម្លាប់អ្នកណាមួយឡើយ។ ការរំលោភលើសីលទី៤ ដើម្បីសុខុមាលភាពផ្ទាល់របស់គេ

ករណីមុនៗជាច្រើនអាចរាប់បញ្ចូលជា ករណីនៃសារៈសំខាន់ជា ឧទាហរណ៍ប្រសិនបើគេជាអ្នកនេសាទធ្វើអាជីវកម្ម ឬជានិសិត្សពេទ្យមួយ។

ជាឧបមាការនេសាទគេសួរខ្លួនគេថា តើវាពិតជាមានលក្ខណៈចំបាច់ត្រូវសម្លាប់ ឬត្រូវលួច គេយល់ច្បាស់ថានេះ មានលក្ខណៈកម្របំផុត។ ដោយហេតុនេះបើទោះជាគ្រាន់តែបំណងមិនរំលោភលើសីល លើកលែងតែពេលវាមិនមាន ជម្រើសអ្វីផ្សេងទៀតបាន ហើយប្រព្រឹត្តទៅតាមដរាបណាវាជាការចាំបាច់អនុញ្ញាតឱ្យ និងធ្វើឱ្យយើងយល់ច្បាស់ថា បញ្ចសីលអាចត្រូវបានគេគោរពចំពោះវិសាលភាពដ៏ធំមួយដោយគ្មានការលំបាក ឬបាត់បង់ភាពរុងរឿង លោកិយអ្វីមួយឡើយ។

**៤-ដោយសារតែគ្មានការគាំទ្រ និងព្រះធម៌បង្គ្រប់** ការខ្វះខាតព្រះធម៌ដែលបង្គ្រប់ដល់វិធាននីមួយៗ ក៏អាចជាហេតុមួយនៃការរំលោភរបស់វាដែរ។ មេត្តាគួរអប់រំវា (ជាទិដ្ឋភាព) ព្រះធម៌ដែលបង្គ្រប់ដល់សីលទី១សម្មាអាជីវៈឬការចិញ្ចឹមជីវិតត្រឹមត្រូវគួរប្រតិបត្តិវា (ទិដ្ឋភាពមួយ) ព្រះធម៌ដែលបំពេញឱ្យសីលទី២។ santutthita ឬភាពពេញចិត្តជាមួយនឹងប្តីប្រពន្ធ គឺជា (ទិដ្ឋភាពមួយ) ព្រះធម៌ដែលគេគួរតែអភិវឌ្ឍដើម្បីបំពេញសីល៣។ ភាពទៀងត្រង់ គឺជា (ទិដ្ឋភាពមួយ) ព្រះធម៌ដែលគេគួរតែសង្កេតមើលដើម្បីបំពេញសីលទី៤។ ភាពខ្វល់ខ្វាយនិងសង្វរកម្ម គេគួរតែជឿជាក់ជា (ទិដ្ឋភាពមួយ) ព្រះធម៌ដែលបំពេញឱ្យសីលទី៥។ ការពន្យល់ពីទិដ្ឋភាពព្រះធម៌បង្គ្រប់មួយចំនួនដូចតទៅ : ជាឧបមាមេត្តាបំពេញឱ្យសីលទី១ ដែលវាមានអត្ថិភាពនៅក្នុងភារៈណាមួយ កម្ចាត់ចោលតម្រេកតណ្ហាទាំងអស់ដែលបង្ក ទុកទោសដើម្បីកុំនិយាយពីមេត្តាដែលបានសម្តែងដោយឪពុកម្តាយចំពោះកូនៗរបស់គាត់ សូម្បីតែមេត្តាចំពោះសត្វចិញ្ចឹម ដូចជាឆ្កែ ឆ្មាដែលគេត្រូវមើលថែយ៉ាងគ្រប់គ្រាន់បំផុត។ បើគ្មានមេត្តាប៉ុន្តែមានទោសៈឬការស្អប់ជំនួសវិញសត្វទាំងនេះ អាងនឹងងាយវិនាសហិនហោចបំផុត។ ការចិញ្ចឹមជីវិតត្រឹមត្រូវបំពេញឱ្យសីលទី២ អាចត្រូវបានពន្យល់ដូចតទៅ។ ប្រសិនបើគេខ្ជិលធ្វើការ ឬទទួលបានគំរូរស់នៅមិនត្រឹមត្រូវមួយសម្រាប់ការចិញ្ចឹមជីវិតរបស់គេ គេមិនអាចគោរពតាម សីលទី២ បានទេ។ ព្រោះយើងទាំងអស់គ្នាត្រូវបរិភោគរាល់ថ្ងៃយើងម្នាក់ៗ ត្រូវការទទួលទានអាហារឱ្យទាល់តែបាន ដូចនេះគេត្រូវតែមានមធ្យោបាយរស់នៅមួយ ហើយជាការរស់នៅដោយត្រឹមត្រូវមួយនៅទីនោះ។

**៥-ដោយសារតែខ្វះខាតអ្នកដឹកនាំដែលប្រតិបត្តិតាមសីល**។ ជាសេចក្តីពន្យល់មួយ មានសុភាសិតមួយនៅ ក្នុងរឿង *Jataka* ដែលមានខ្លឹមសារសង្ខេបដូចតទៅ : "នៅពេលហ្វូងសត្វពាហនៈកំពុងតែធ្វើដំណើរ ប្រសិនបើមេដឹកនាំហ្វូង (the leading bull) ត្រូវវង្វេងផ្លូវ ហ្វូងទាំងមូលពិតជាវង្វេងផ្លូវដែរ។ ចំណែកឯមនុស្សវិញក៏ដូច្នេះដែរ។ ប្រសិនបើ អ្នកដឹកនាំដែលបានជ្រើសតាំងប្រតិបត្តិ អធម្មៈ*(adhamma)*ឬ ភាពមិនត្រឹមត្រូវ (unrighteousness) មនុស្សជាច្រើនក៏ប្រតិបត្តិវាដែរ។ ជាតិទាំងមូលនឹងមានទុក្ខព្រួយប្រសិនបើជាតិនោះបរាជ័យក្នុងការប្រតិបត្តិតាមព្រះធម៌ហើយនោះ។ ពេលហ្វូងសត្វកំពុងតែធ្វើដំណើរ ប្រសិនបើសត្វនាំក្បាលហ្វូងរក្សាទិសដៅសមរម្យបានហ្វូងទាំងមូលក៏បែបនោះដែរ។ ឯមនុស្សក៏ដូចគ្នានេះដែរ ប្រសិន បើមេដឹកនាំដែលគេបានជ្រើសតាំងគោរពតាមព្រះធម៌ មនុស្សទាំងឡាយក៏ធ្វើបែបនោះដែរ។ ជាតិទាំងមូល នឹងបានសប្បាយរីករាយប្រសិនបើអ្នកដឹកនាំគាំទ្រដល់ព្រះធម៌"។ សុភាសិត ព្រះពុទ្ធសាសនានេះ បង្ហាញខ្លឹមសារយ៉ាងច្បាស់បំផុត។ ឥរិយាបថរបស់អ្នកដឹកនាំគឺជាហេតុ បច្ច័យដ៏ធំចំពោះមនុស្សទាំងឡាយដែលពួកគេនឹង ដើរតាមគំរូរបស់ពួកគេដោយជៀសមិនរួច។

ហេតុផលខាងលើជាការគួរឱ្យចាប់អារម្មណ៍ ឬមិនជាការគួរឱ្យចាប់ អារម្មណ៍ក្នុងការពិនិត្យសង្កេតអំពីសីលចរិយា (ពួកវាមួយ) អាចជាសារៈសំខាន់មួយ នៅក្នុងទំនាក់ទំនងចំពោះសីល។ និយាយដោយខ្លីថា តើសីលដើរតាម ឬមិនត្រូវដើរតាមដោយបុគ្គល មានសង្គមពឹងផ្អែកលើថា តើពួកគេបង្កើតឡើងនូវភាពសប្បាយចិត្តដោយអនុលោមតាមកម្រិតអ្នក ប្រតិបត្តិតាមដែរឬអត់ ?

នៅក្នុងការគោរពនេះ អ្នកខ្លះបានជៀសវាង មតិថាសីលអាចពិនិត្យមើលជាគោការណ៍មូលដ្ឋានដែលគេ ត្រូវអនុវត្ត ទៅតាមវិធីមួយដែលសមទៅនឹងឋានៈផ្ទាល់របស់គេ។ អ្វីដែលគេចាត់ទុកថាអាចសរសេរបាននោះ និងអនុលោមទៅតាមគោលបំណងរបស់សីលតែមួយប៉ុណ្ណោះ ប្រសិនបើវាត្រូវទទួលយកដោយគ្មានបុរេនិច្ឆ័យ ចំពោះអ្នកដទៃ និងគ្មានការពេញចិត្តចំពោះខ្លួនគេព្រោះគោលបំណងរបស់សីលគឺត្រូវជៀសវាងបង្កទុក្ខទោសដល់អ្នកដទៃ។ ម្យ៉ាងវិញទៀតពួកវាគឺជាជំហានដំបូងចំពោះសមាធិ និងបញ្ញា។ ព្រោះការពិនិត្យសង្កេតរបស់ សីលធម៌មិនមែនត្រង់ៗនោះទេ ប៉ុន្តែវាអនុលោមទៅតាមគោលបំណងរបស់វាដែរ វានឹងខុសប្លែក ពីការពឹងផ្អែកទៅលើឋានៈឬវិជ្ជាជីវៈរបស់បុគ្គលម្នាក់ៗបន្តិចបន្តួច។ ជាឧបមាការពិនិត្យសង្កេតរបស់សីល

ដោយមនុស្សទូទៅដែលចង់បានសន្តិភាព និងភាពសប្បាយរីករាយសម្រាប់គ្រប់គ្នានៅ ក្នុងគ្រួសារក៏ដូចជានៅជាតិទាំងមូលដែរនឹងទទួលយកទម្រង់មួយទម្រង់ព្រះសង្ឃដែលចង់សម្រេចបានព្រះធម៌ដ៏ខ្ពស់ មួយនិងទទួលយកទម្រង់មួយទៀត។ តែទោះជាយ៉ាងណា ក៏ដោយទម្រង់ទាំងពីរនេះនឹងដឹកនាំទៅរកគោលដៅ ដែលការពិនិត្យសង្កេតរបស់សីលបង្កើតឡើងសម្រាប់វា។ ម្យ៉ាងវិញទៀតសីល ឬវិធាននៃសីលចរិយាគឺជាកត្តាសំខាន់មួយនៅក្នុង ការរីកចម្រើនរបស់ជាតិ ពោលគឺកម្លាំងដែលជម្រុញទៅលើវិបុលភាពសេដ្ឋកិច្ច និងភាពសប្បាយទូទៅ។ បើគ្មានសីលផលិតភាពរបស់បុគ្គលម្នាក់ៗនឹងលំអៀងទៅរកការដួលរលំនិងការវិនាសហិនហោចដោយខ្លួនឯង។ នៅកន្លែងណា ដែលផលិភាពរបស់បុគ្គលម្នាក់មានកម្រិតខ្ពស់ ប៉ុន្តែវាផ្តល់គ្រោះថ្នាក់ដល់ផលិតភាពរបស់អ្នកណាម្នាក់ទៀត ពោលគឺគ្មានអ្វីដែល ត្រូវបន្ថែមទៅលើសហគមន៍នោះទេ។ ជាងនេះទៀតផលសរុបរបស់សហគមន៍ត្រូវថយចុះ ហើយដោយ សារហេតុនេះវាលំបាកនឹងគាំទ្រដល់ដំណើរការរីកចម្រើននិងវិបុលភាពទូទៅណាស់។ បើទោះជាចេញពីទស្សនៈនេះគេអាចមើលឃើញថា មនុស្សជាច្រើនសង្កេតមើលពីសីលទៅតាមរបៀបមួយដែលសមទៅនឹងឋានៈផ្ទាល់របស់ពួកគេពោលគឺដោយយល់ច្បាស់ថា សីលអាចនាំមកនូវវិបុលភាពដល់សហគមន៍។

និយាយជាទូទៅ មនុស្សនៅក្នុងប្រទេសកាន់ ព្រះពុទ្ធសាសនា ដឹងថាតើពួកគេប្រតិបត្តិតាម សីល ឬ វិធានសីលធម៌យ៉ាងដូចម្តេចហើយ។ ពួកគេក៏បានដឹងផងដែរថា បញ្ចសីល មិនរារាំងដល់ វិបុលភាពរបស់បុគ្គល ឬរបស់ប្រទេសជាតិឡើយ។ ហេតុផលសម្រាប់ការ ព្រួយបារម្ភណ៍មិនបានពឹងផ្អែកទៅលើការពិតថាមនុស្សដ៏ច្រើនបានប្រតិបត្តិតាមសីល ដោយហ្មត់ចត់ ប៉ុន្តែនៅក្នុងការពិតថា មនុស្សដ៏ច្រើនរំលោភលើវា។ នេះវាចេញទៅឆ្ងាយថា សូម្បីតែអំពើទាំងនោះ ដែលគួរត្រូវបានគេជៀសវាងពីព្រោះគេបានគិតពិចារណាជាទូទៅ និងដោយត្រឹមត្រូវមានទុក្ខទោសនោះតែទោះជាយ៉ាង ណាក៏ដោយក៏នៅតែមានលក្ខណៈទូទៅដែរ។ អ្វីដែលគេត្រូវការជាចម្បងដើម្បីពឹងផ្អែកដោយត្រឹមត្រូវនៅពេលនោះនៅក្នុងបុគ្គល និងនៅក្នុងកាលៈទេសៈបានជាប់ទាក់ទងជាមួយរួចជាស្រេចទៅហើយ។ ប្រសិនបើមនុស្សម្នាក់ៗត្រូវមានឥរិយាទៅតាមវិធីមួយដែលធ្វើឱ្យ កិលេស មានកាន់តែតិចទៅៗ ហើយបង្កើតនៅក្នុងចិត្តដោយគ្រប់គ្រាន់នូវ ហិរិ-ឱត្តប្បៈ ហើយនៅពេលជាមួយគ្នានេះប្រសិនបើមានកាលៈទេសៈ ដែលបង្កើតសម្រាប់ការសប្បាយ និងភាពសុខស្រួលនោះដូចជាសេរីភាពដើម្បីអនុវត្ត ការចិញ្ចឹមជីវិតរបស់នៅក្នុងបរិយាកាសសន្តិភាព និងសន្តិសុខមួយ ហើយមានលទ្ធភាពអាចរកចំណូលដោយ គ្រប់

គ្រាន់សម្រាប់ខ្លួនឯង និងសម្រាប់គ្រួសាររបស់គេ នៅពេលនោះនឹងគ្មានហេតុណាដែលរំលោភលើ សីលនោះទេ ហើយមនុស្សអាចចាប់អារម្មណ៍ក្នុងការគោរពតាម សីល និង ព្រះធមិបង្គ្រប់ (complementary Dhamma) ដូចជាការអប់រំ **មេត្តា** ដល់អ្នកដទៃ និងខិតខំព្យាយាមស្វែងរក ការចិញ្ចឹមជីវិតរបស់ពួកគេ។ ប្រសិនបើអ្នកដឹកនាំ ឬមន្ត្រីរដ្ឋបាលនៃគ្រប់លំដាប់ថ្នាក់ក៏ត្រូវតែចាប់អារម្មណ៍ទៅលើសីលដែរ ប្រសិនបើពួកគេត្រូវបានរៀបចំដោយប្រព្រឹត្តទៅតាម សីល ហើយនិងមិនដើម្បីបំពេញករណីយកិច្ចរបស់ ពួកគេទៅតាមវិធីខូចខាតនោះទេប៉ុន្តែទៅតាមឥរិយាបថ មួយដែលមានគុណប្រយោជន៍ដល់សុខុមាលភាពដល់មនុស្សនានា ប្រសិនបើគ្រប់ទីកន្លែងរបស់សហគមន៍ព្រមព្រៀងគ្នា ក្នុងការថែរក្សា ការប្រព្រឹត្តល្អបែបនេះ គំរូធម្មចរិយាពិតជាចម្រើនឡើងជាមិនខាន ព្រោះមូលដ្ឋានចិត្តរបស់បុគ្គលម្នាក់ៗចង់បាន ល្អដូច្នេះមនុស្សបានមើលឃើញរួចជាស្រេចនូវ ភាពចម្រើនរុងរឿងនៃសីល។ ប្រសិនបើការរកចំណូលការរស់នៅរបស់គេជួបនឹងការលំបាកឬមានគ្រោះថ្នាក់ដំណោះស្រាយចំពោះព្រឹត្តិការណ៍ចៃដន្យ(contingencies) បែបនេះត្រូវតែផ្តល់ទៅឱ្យ អាទិភាពទី១។ នៅក្នុង សាសនាព្រះពុទ្ធ ព្រះពុទ្ធជាម្ចាស់បានបង្រៀនថា គុណប្រយោជន៍បច្ចុប្បន្ន គួរតែយកមកគិតជាអាទិភាពទី១ ដោយមានការខិតខំព្យាយាម និងធ្វើការសម្រាប់ការរស់នៅ។ ដូច្នេះបន្ទាប់ ពីនោះព្រះអង្គបានឱ្យដំបូន្មានដល់មនុស្សដើម្បី យកចិត្តទុកដាក់នៅពេលដូចគ្នានេះចំពោះ គុណប្រយោជន៍អនាគតរបស់ពួកគេ ដោយមានជំនឿ និងប្រតិបត្តិតាម សីល។

នៅពេលមានសម្រែកអំពីសភាពនៃ ភាពចុះអន់ថយដែលទទួលផលមកពីការមិនគោរពតាម តម្លៃសីលធមិ ទាំងយុវជន ក៏ដូចជាមនុស្សពេញវ័យស្រែកទាររកតម្លៃទាំងនោះដែលត្រូវលើកំពស់នៅពេលបច្ចុប្បន្ន។ ប៉ុន្តែការគិតពិចារណា ដែលស្របទៅតាមកថាខណ្ឌទាំងនេះគួរតែចងចាំ ហើយយើងទាំងអស់គ្នាគួរតែរួមដៃគ្នាខិតខំកែច្នៃស្ថានភាពដោយខិត ទៅរកហេតុពិត។ គ្រូសាសនាអាចគ្រាន់តែបង្ហាញផ្លូវប៉ុណ្ណោះ។ គេមិនអាចទទួលធ្វើកិច្ចការដោយមនុស្សមួយក្រុមណា នោះបានទេ។ គ្រប់ទីកន្លែងនៅក្នុងសហគមន៍គួរតែសហប្រតិបត្តិការគ្នា ដោយអនុលោមទៅតាមករណីយកិច្ចរបស់គេ។ យើងទាំងអស់គ្នាគួតែសម្តែងករណីយកិច្ចរបស់ខ្លួនដោយសុចរិតទៀងត្រង់។ មនុស្សម្នាក់ៗត្រូវពិនិត្យទៅលើឥរិយាបថ ផ្ទាល់របស់ខ្លួន ហើយខិតខំព្យាយាមជៀសវាងពីការប្រព្រឹត្តមិនត្រឹមត្រូវដោយគោរពតាម គោលការណ៍សីល។ ដូច្នេះការគោរពទៅតាម វិធានប្រព្រឹត្តដោយ សីលធមិមិនជាការលំបាកនោះទេ ពោលគឺគេអាច

ប្រព្រឹត្តទៅបានដោយការរៀន សីល ពីព្រះសង្ឃ ឬក៏ដោយការប្រតិបត្តិតាម សីល ដោយខ្លួនឯង ដោយមិនចាំបាច់រៀន សីល នេះពីព្រះសង្ឃឡើយ ។ អ្វីដែលមានសារៈសំខាន់គឺ ការកំណត់របស់គេដើម្បីគោរពតាម សីល នោះគឺត្រូវជៀសវាងពី សកម្មភាពជាក់ស្តែង។ បើទោះជាការជៀសវាងបែបនេះមិនទាន់គ្រប់គ្រាន់នៅក្នុងខ្លឹមសារ សីលបរិសុទ្ធ ក៏ដោយ ហើយអាចអនុ វត្តបានតែចំពោះអំពើដែលបានចាត់ទុកថាជា អំពើខុស និង មិនត្រឹមត្រូវនៅក្នុងខ្លឹមសារត្រឹមត្រូវ ឬលោកិយក៏ដោយ ក៏នោះគ្រាន់បើជាងមិនជៀសវាងសោះនោះដែរ ។

ការបញ្ញត្តិនៃ សីលបរិសុទ្ធ (បំពេញទៅគ្រប់ការគោរព) មិនមានន័យថា ការប្រតិបត្តិតាមរបស់គេក៏គួរតែជា អំពើត្រឹមត្រូវ ចាប់តាំងពីចាប់ផ្តើមនោះទៅ។ គ្មានអ្នកណាម្នាក់អាចគ្រប់គ្រងបែបនោះទេ។ ការប្រតិបត្តិ សីល គឺជា ជំហានសន្សឹម១ ពី ដំណាក់កាលទាបទៅដល់ដំណាក់កាលខ្ពស់។ នោះគឺជាហេតុដែលសម្តីដូចតទៅត្រូវបានគេយក មកប្រើ "ខ្ញុំប្រតិបត្តិតាមវិធាននៃការហ្វឹកហាត់ ដើម្បីជៀសវាងពីការប្រព្រឹត្តបែបណាមួយ"។ ការខិតខំនេះចំពោះការយល់ ព្រមដើម្បីហ្វឹកហាត់នៅក្នុងសីល ឬនៅក្នុងវិធានសីលធម៌។ វាក៏មានន័យថាការប្រតិបត្តិតាមសីលនៅតែមិនទាន់បរិសុទ្ធបាននៅឡើយ ។ វាដូចគ្នានឹងការសិក្សាពីចំណេះដឹងអ្វី មួយដែរ។ ប្រសិនបើគេនៅតែសិក្សាប្រធានបទមួយវាមានន័យថាគេមិនទាន់ដឹងវានៅឡើយទេដែលផ្ទុយចំពោះភាពបរិសុទ្ធ។ អ្នកណាដែលដឹងពីវាដោយបរិបូណ៌មិនហ្វឹកហាត់នៅ ក្នុងវានោះទេ។ អ្នកដែលនៅតែសិក្សាទៀតឃើញថា គ្មានទំនួលខុសត្រូវចំពោះអវិជ្ជានៃអ្វី ដែលគេត្រូវតែរៀននោះនៅឡើយទេ ។

# ជំពូកទី៦

# លក្ខណៈទូទៅនៃព្រះពុទ្ធសាសនា និងការប្រតិបត្តិ

(General of Buddhism and Buddhist Practices )

## ១. មាគ៌ាព្រះពុទ្ធសាសនាចំពោះស្ថេរភាពសេដ្ឋកិច្ច

(The Buddhist Way to Economic Stability Ven. M. Pannasiha Maha Nayaka Thera)

កាលពីអតីតកាល អ្នកប្រាជ្ញបស្ចឹមប្រទេសបានផ្តល់អត្ថន័យដើមផ្សេងៗ គ្នាទៅលើពាក្យ "មនុស្សា" (Manussa)។ តាមរយៈប្រពៃណីឥណ្ឌាដែលមានប្រជាប្រិយភាព ឬដែលទូទៅប្រភពដើមនៃពាក្យ "Manu" ជាជីដូនជីតាបែបទេវកថានៃពូជសាសន៍មនុស្ស។ នៅក្នុងអត្ថបទព្រះពុទ្ធសាសនា គេយកពាក្យនេះមកប្រើដោយនិយាយថា "manassa-ussannataya=manussa" មានន័យថា មនុស្សដោយសារតែមានការអភិវឌ្ឍខ្ពស់សភាពចិត្តគំនិត (បើប្រៀបធៀបទៅ នឹងសភាពផ្លូវចិត្តនៃសត្វថ្នាក់ទាបដែលមិនមានការអភិវឌ្ឍឬជាបឋមវិធាន។ តាមព្រះពុទ្ធសាសនា មនុស្សមានឋានៈជាភាវៈខ្ពស់បំផុតដោយសារតែសក្តានុពលដ៏ធំធេងនៃគំនិត។បន្ទាប់ពីព្រះពុទ្ធចូលបរិនិព្វាន គេបានសរសេរអភិប្រាយបុរាណដ៏ល្បីល្បាញស្តីពីសេដ្ឋកិច្ចចំនួន២ ក្បាលគឺ "Kautilya’s Arthasastra" និង " Brhaspati’s Arthasastra"។ ពួកវាបានបង្កើតឡើងតាមលក្ខណៈទូទៅមួយក្រោមចំណងជើងថា "Arthasastra" ដែលអ្នកនិពន្ធបានសរសេរអំពីនយោបាយ និងសេដ្ឋកិច្ចដោយមិននិយាយអំពីសីលធម៌ និងការអភិវឌ្ឍសីលធម៌របស់មនុស្សទេ។ តាមព្រះពុទ្ធសាសនាពាក្យបាលីថា "Attha" (សំស្ក្រឹតថា "artha") មានអត្ថន័យច្រើនជាងមួយ។ ពាក្យដែលមានន័យថាជោគជ័យត្រូវបានគេប្រើតាមកម្រិតផ្សេងៗគ្នា២បែបគឺ "attha" មានន័យថា ជោគជ័យហើយ "ttamattha" មានន័យថា ជោគជ័យខ្ពស់បំផុត។ អ្នកជំនាន់ក្រោយព្រួយបារម្ភពីការអភិវឌ្ឍផ្នែកអារម្មណ៍ និងស្មារតីរបស់មនុស្សដែលបង្ហាញឱ្យដឹងច្បាស់តាមអរិយសច្ចៈ៤ ពោលគឺយកឈ្នះលើខ្លួនឯង និងការទទួលយកសុក្រឹតភាពស្មារតី ឬភាពជាអរហន្ត។

និយាយជាទូទៅពាក្យ "attha" ទាក់ទងទៅនឹងទិដ្ឋភាពផ្សេងៗនៃ ការរីកចម្រើនសេដ្ឋកិច្ចសង្គមរបស់មនុស្សដូចជា សេដ្ឋកិច្ច នយោបាយ ការអប់រំ សុខាភិបាល ច្បាប់ និងសីលធម៌សង្គម។ ការរីកចម្រើន សង្គមអាស្រ័យដោយមានការស្រុះស្រួលឯកភាពគ្នានៃកត្តាទាំងអស់ខាងលើរួមទាំងវិបុលភាព និងសហអត្ថិភាពប្រកបដោយសន្តិភាពរបស់មនុស្សផង។ វាសំដៅទៅលើវឌ្ឍនភាពសង្គមដោយសារឯកភាពវប្បនីយកម្ម ដែលគ្មានការខ្វែងគំនិតគ្នានៃកត្តាទាំងអស់ខាងលើដោយបែងចែកចំពោះវិបុលភាព និងសន្តិសហអត្ថិភាពរបស់មនុស្ស។

លើកលែងតែក្នុងករណីរដ្ឋបាលច្បាប់របស់ព្រះសង្ឃ គ្មានការសន្ទនាណាមួយរបស់ព្រះពុទ្ធទាក់ទង យ៉ាងទៅលើកត្តាណាមួយខាងលើនៃវឌ្ឍនភាពសង្គមឡើយ ។ ព្រោះការអានគម្ពីរព្រះសូត្រវាជួយអភិវឌ្ឍនូវទស្សនៈពេញលេញរបស់ព្រះពុទ្ធហើយគម្ពីរនេះមានការទាក់ទងទៅនឹងប្រធានបទនីមួយៗខាងលើដោយត្រូវ បានគេដកចេញពីការសន្ទនារបស់ព្រះពុទ្ធ ។ ប្រពន្ធ័សេដ្ឋកិច្ចសង្គមដែលបានផ្អែកទៅលើគោលការណ៍និងការប្រតិបត្តិរបស់ព្រះពុទ្ធសាសនាគេអាចងាយស្រួលបង្កើតរូបមន្តឱ្យសមតាមទំនើបសព្វថ្ងៃ ។

នៅក្នុងពេលពេលបច្ចុប្បន្ននេះ គេសរសេរសៀវភៅជាច្រើនស្តីអំពីប្រធានបទសេដ្ឋកិច្ច និងទ្រឹស្តីសេដ្ឋកិច្ច ទ្រឹស្តីទាំងអស់នេះបានមកពីទស្សនៈមូលធននិយមនិងសង្គមនិយម ។ គ្មានប្រពន្ធ័ណាមួយក្នុងចំណោមប្រពន្ធ័ទាំងនេះយកចិត្តទុកដាក់ ឬគិតពិចារណាពីការអភិវឌ្ឍខាងក្នុងរបស់មនុស្សថាជាកត្តាសំខាន់មួយក្នុងការ អភិវឌ្ឍសង្គមទេ ។ ដូច្នេះមានការការយ៉ាប់យឺនក្នុងតម្លៃមនុស្ស និងកម្រិតបុគ្គលិកលក្ខណៈគ្រប់ថ្នាក់ទាំងអស់ របស់សង្គម ។ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបានឈានទៅមុខមួយជំហានធំ ដើម្បីបញ្ជូនមនុស្សទៅឋានព្រះចន្ទ័ហើយវានឹងមិនយូរប៉ុន្មានទេ គេនឹងអាចទៅលេងនៅភពផ្សេងៗទៀត ។ ប៉ុន្តែគេបានបញ្ជាក់នូវសេចក្តីភយ័ខ្លាចថា ប្រសិនបើនិន្នការបច្ចុប្បន្នឆ្ពោះទៅរកការធ្លាក់ចុះខាងសីលធម៌ សកម្មភាពមនុស្សមិនខុសពីសកម្មភាពសត្វទេ ។ សេចក្តីភ័យខ្លាចនេះមិនមែនគ្មានមូលដ្ឋាន ។ វាជាសោកនាដកម្មដ៏ខ្លាំងក្លាមួយដែលធ្វើឱ្យមនុស្សមានចរិតដូចសត្វ ។ ដូច្នេះអ្វីដែលពិភពលោកត្រូវការសព្វថ្ងៃ គឺប្រពន្ធ័សេដ្ឋកិច្ចសង្គមមួយដែលមានស្ថេរភាពដែល ផ្តល់ឱ្យមនុស្សនូវការអភិវឌ្ឍសីលធម៌ និងការអប់រំតម្លៃមនុស្ស ។

ព្រះពុទ្ធបានរស់នៅក្នុងសង្គមមួយ ដែលជាបលជំពាក់និងច្របូកច្របល់ដោយទស្សនៈបែកចេញពីគ្នាចំនួន៦២ និងលោភៈ១០៨ប្រភេទ ។ មានមនុស្សរាប់រយនាក់ដែលធ្វើការស្រាវជ្រាវដើម្បីគេចឱ្យផុតពីការ ជាប់ទស្សនៈនេះ ។ នៅពេលដែលព្រះពុទ្ធត្រូវបានគេសួរសំណួរថា :

"ការជាប់ជំពាក់ខាងក្នុង និងការជាប់ជំពាក់ខាងក្រៅពិភពលោកនេះប្រទាក់គ្នាដោយការជាប់ជំពាក់ ។ តើនរណាយកជ័យជំនះក្នុងការធ្វើឱ្យការជាប់ជំពាក់នេះលែងជាប់ជំពាក់?"

ព្រះពុទ្ធដែលបានពន្យល់ថា ការជាប់ជំពាក់ទាំងអស់នេះ មានគំនិតជាអ្នករត់មុខបានឆ្លើយដូច្នេះថា :

" នៅពេលណាដែលមនុស្សមានបញ្ញា បានផ្សព្វផ្សាយនូវគុណធម៌ល្អ ចេះអភិវឌ្ឍន៍មនសិការ និងយោគយល់គ្នា ដូចជាភិក្ខុដែលពកបដោយសុខុមញ្ញាណ គេយកជ័យជំនះក្នុងការធ្វើឱ្យការជាប់ជំពាក់ដែលជាប់ជំពាក់បាន។

ការយល់ច្បាស់ពីសារៈសំខាន់ នៃកត្តាខាងក្រៅក្នុងការខិតខំខ្នះខ្នែងរបស់មនុស្សឆ្ពោះទៅរកការលុបបំបាត់ចោលការជាប់ជំពាក់ក្នុងចិត្ត ព្រះពុទ្ធបានផ្តល់នូវកាសេន្ទនាជាច្រើនអំពីវិធីនិងមធ្យោបាយនៃការគ្រប់គ្រងការជាប់ជំពាក់ខាងក្រៅ។ ការបង្រៀននេះមួយចំនួនសម្រាប់តែភិក្ខុប៉ុណ្ណោះ។ ការបង្រៀនផ្សេងទៀត សម្រាប់តែគ្រហស្ថ។ នៅសល់ប៉ុន្មានសម្រាប់ទាំងភិក្ខុទាំងគ្រហស្ថ។ទោះបីជាករណីចុងក្រោយការសន្ទនានេះផ្តោតជាសំខាន់ទៅលើភិក្ខុក៏ដោយ។ នៅក្នុការសន្ទនានោះ ព្រះអង្គបានតម្រូវឱ្យភិក្ខុទទួលយកនូវរបស់៤ យ៉ាងគឺ ស្បង់ចីវរម្ហូបអាហារជម្រកស្នាក់នៅ និងថ្នាំសង្កូវ។ មនុស្សអារស់នៅដោយគ្មានរបស់ទំនើបផ្សេងៗបានតែតម្រូវការចាំបាច់ទាំង៤ នេះមានសារៈសំខាន់ណាស់។ មនុស្សត្រូវការសុខភាពដើម្បីទទួលនូវតម្រូវការចាំបាច់ទាំង៤ នេះហើយនឹងឈានទៅសម្រេចតម្រូវការផ្សេងៗទៀតរបស់គេ។

មគ្គទាំង៨ ដែលអាចត្រូវបានគេចាត់ចំណាត់ថ្នាក់តាមតម្លៃ និងសកម្មភាពត្រឹមត្រូវអាចធ្វើឱ្យមនុស្ស សម្រេចនូវគោលបំណងខ្ពស់បំផុត។ ចំពោះស្ថេរភាពសេដ្ឋកិច្ច និងសុខុមាលភាពប្រពន្ធ័ព្រះពុទ្ធសាសនាបានបញ្ជាក់នៅក្នុងគម្ពីរ Vyagghapajja Sutta ថាមានកត្តា៣យ៉ាងគឺ

១. ឧដ្ឋានសម្បទា (Utthana Sampada) ការខិតខំប្រឹងប្រែងរកទ្រព្យតាមជំនាញ និងចេះសន្សំសំចៃខ្ពស់។

២. អារក្ខសម្បទា (Arakkha Sampada) ចេះការពារនិងចេះសន្សំនូវទ្រព្យសម្បត្តិរបស់ខ្លួន។

៣. សមជីវិតា (Samajivikata) រស់នៅតាមធ្យោបាយរបស់ខ្លួន។ ១. ឧដ្ឋាន សម្បទា : នៅពេលនោះព្រះពុទ្ធ បានលើកទឹកចិត្តឱ្យខិតខំរកទ្រព្យតាមមុខរបរ៦យ៉ាងគឺ:

១. កសិកម្ម

២. ពាណិជ្ជកម្ម

៣. ការបង្កាត់ពូជសត្វ

៤. សេវាការពារ

៥. សេវាគ្រប់គ្រង

៦. សេវាវិជ្ជាជីវៈ

កាលពីមុន ប្រទេសឥណ្ឌាជាប្រទេសកសិកម្ម។ ដូច្នេះ គេបានសរសេរសេចក្ដីព្រាងជាច្រើននៅក្នុងការសន្ទនាទាក់ទងទៅនឹងកសិកម្ម។ឧទាហរណ៍ៈនៅក្នុងគម្ពីរSadapunnappavaddhana Sutta បានសរសេរថា ការផ្ដល់សម្ភារៈបញ្ចូលទឹក បង្ហាញឱ្យឃើញពីគុណធម៌ប្រកបដោយនិរន្តរភាព។ នៅក្នុងគម្ពីរ Samyutta Nikaya បានពោលថា អត្ថប្រយោជន៍ដ៏សំខាន់បំផុត សម្រាប់កសិកម្មគឺ គោក្របីរីឯនៅក្នុងគម្ពីរ Sutta Nipatha គោក្របីដែលមនុស្សយកទឹកដោះដែលមានសារធាតុចិញ្ចឹមច្រើន ត្រូវបានគេរៀបរាប់ថាជាមិត្តសម្លាញ់របស់ប្រទេស។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ទឹក និងកម្លាំងខ្យល់ដែលផ្ដល់ដោយគោក្របី ជាតម្រូវការមូលដ្ឋានសម្រាប់កសិកម្ម។

នៅក្នុងការសន្ទនាដែលជាប់ទាក់ទងទៅនឹងសុភមង្គលរបស់ឧបាកឧបាសិកា ត្រូវបានគេអះអាងពីការពេញចិត្តរបស់ឧបាសកឧបាសិកា ក្នុងការទទួលយកទ្រព្យសម្បត្តិតាមមធ្យោបាយត្រឹមត្រូវ។ ទោះបីយ៉ាងណា ក៏ដោយព្រះពុទ្ធបានព្រមានមនុស្សមិនឱ្យមាននិន្នាការ កាយទៅជាទាសករចំពោះទ្រព្យសម្បត្តិរបស់ខ្លួន។ បញ្ហានេះនឹងនាំឱ្យមានទុក្ខផ្លូវកាយនិងចិត្តទៅ ថ្ងៃក្រោយ។ មធ្យោបាយល្អមក្នុងការធ្យាយាមរកស៊ីដើម្បីផ្គត់ ផ្គង់ខ្លួនឯងនឹងគ្រួសារ ជួយបងប្អូននិងមិត្តភក្តិនិងចែកចាយដល់អ្នកត្រូវការ និងអ្នកសមនឹងទទួល នឹងឈានទៅដល់ការសប្បាយចិត្តនិងការពេញចិត្ត។ នេះជាលទ្ធផលនៃការអភិវឌ្ឍសីលធម៌ និងស្មារតីរបស់មនុស្ស។

នៅក្នុងគម្ពីរ Kutadanta Sutta ព្រះពុទ្ធបានបង្ហាញថាតើសន្តិភាពចក្កុវិស័យនិងសេរីភាពពីឧក្រិដ្ឋកម្ម កើតឡើងចំពោះប្រទេសមួយតាមរយៈការបែងចែកទ្រព្យសម្បត្តិសមធម៌ទៅឱ្យប្រជាជនរបស់គេ ដូចម្ដេច?

ព្រះពុទ្ធមានព្រះបន្ទូលថា "ជាច្រើនឆ្នាំមកហើយ មានស្ដេច១អង្គឈ្មោះ Maha-Vijita មានឫទ្ធិអំណាចខ្លាំងពូកែ មានទ្រព្យសម្បត្តិហូរហៀរនិងមានឃ្លាំមាសឃ្លាំប្រាក់ធំៗ ព្រមទាំងមានឃ្លាំទំនិញនិងស្រូវជាច្រើន។ នៅពេលដែលស្ដេចអង្គនោះអង្គុយសមាធិម្នាក់ឯង គាត់បានគិតថា "ខ្ញុំមានរបស់មានតម្លៃជាច្រើន ដែលមនុស្សចង់បាន។ ផែនដីទាំងមូលជារបស់ខ្ញុំប្រសិនបើខ្ញុំបូជានូវរបស់ទាំងអស់នេះ តើអាចធានាឱ្យខ្ញុំមានសុខមាលភាពជ្រើនថ្ងៃឬទេ។"

នៅពេលនោះ ព្រាហ្មដែលជាសាសនាចារ្យរបស់ព្រះអង្គ បាននិយាយទៅកាន់ស្ដេចនោះថា "មានចោរប្លន់បរទេសដែលលួចប្លន់នៅក្នុងភូមិនិងទីក្រុង ហើយធ្វើឱ្យផ្លូវគ្មានសុវត្ថិ

ភាព។ ព្រោះតែស្តេចយកពន្ធ និងធ្វើសកម្មភាពខុសឆ្គង។ ស្តេចបានគិតថានឹងឈប់ប្រព្រឹត្តិអំពើថោកទាបនេះតទៅទៀត។ ពេលនោះស្តេចក៏បានផ្តល់ម្ហូបអាហារ និងគ្រាប់ពូជស្រូវដល់កសិករ ផ្តល់ប្រាក់ឈ្នួលនិងម្ហូបអាហារដល់អ្នកធ្វើការ។ បន្ទាប់មកប្រាក់ចំនូលរបស់ស្តេច នឹងកើនឡើងប្រទេសនឹងស្ងប់ស្ងៀមគ្មានសង្គ្រាម។"

២.អារក្ខសម្បទា :មានន័យថា សុភមង្គលកើតចេញការចេះថែរក្សាទ្រព្យសម្បត្តិដែលរកបានឱ្យរួចចាកផុតពីការលួច ភ្លើងឆេះទឹកជំនន់ ។ល។ វាជាការពិតណាស់អ្វីៗទាំងអស់នៅលើលោកយើងនេះ វាអាចឋិតថេរគង់វង្សយូរអង្វែងទៅបាន លុះតែមានការថែរក្សាការពារនិងអភិរក្សបានល្អ។ យ៉ាងណាមិញ ព្រះសង្ឃនិងអ្នកដឹកនាំរដ្ឋទាំងឡាយ គប្បីពិចារណាថែរក្សាការពារទ្រព្យសម្បត្តិ ធនធានធម្មជាតិគ្រប់បែបយ៉ាងដែលខ្លួនមានឱ្យបានគង់វង្ស ហើយចេះកែច្នៃធនធានធម្មជាតិទាំងនោះ ឱ្យកើតជាប្រយោជន៍ដល់ប្រជារាស្ត្រនិងប្រទេសជាតិរបស់ខ្លួន។ នេះទើបហៅថា បានប្រតិបត្តិតាមពាក្យទូន្មានរបស់ព្រះពុទ្ធ។

៣. សមជីវិតា : នេះជាគោលការទីពាក្នុងប្រពន្ធ័សេដ្ឋកិច្ចរបស់ព្រះពុទ្ធសាសនា។ មនុស្សគួរតែចំណាយប្រាក់ ឱ្យសមស្របនឹងចំណូលរបស់ខ្លួន មិនច្រើនពេកមិនតិចពេក។

នៅក្នុងគម្ពីរ Pattakamma Sutta លក្ខណៈដែលមនុស្សគួរតែចំណាយទ្រព្យសម្បត្តិរបស់គេមានដូចខាងក្រោម :

១. ចំណាយទៅលើចំណីអាហារ សំលៀកបំពាក់និងទម្រូវការផ្សេងៗទៀត។

២. តំហែទាំឪពុកម្តាយ ប្រពន្ធ កូន និងអ្នកបម្រើ។

៣. សម្រាប់កាជំងឺ និងភាពបន្ទាន់ផ្សេងៗទៀត។

៤. សម្រាប់គោលបំណងមនុស្សធម៌ផ្សេងៗ។

៥. សម្រាប់ការប្រព្រឹត្តិផ្សេងដូចជា :

- ជួយបងប្អូន
- ជួយអ្នកមកលេង
- ផ្តល់អំណោយដល់អ្នកទីទល់ក្រ
- ធ្វើបុណ្យ
- បង់ពន្ធ

នៅក្នុងសម័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាមានការចំណាយពុទ្ធិដ៏ខ្លាំក្លា តែក៏កើតមាននូវការធ្លាក់ចុះ នូវតម្លៃមនុស្សដែរ។ បច្ចុប្បន្ននយោបាយ សេដ្ឋកិច្ច និងប្រពន្ធ័អប់រំជាហេតុផលសំខាន់មួយចំនួនសម្រាប់កិច្ចការរដ្ឋ។ គំនិតនយោបាយនិងសេដ្ឋកិច្ច និងប្រពន្ធ័អប់រំគួរតែត្រូវផ្លាស់ប្តូររហូតដើម្បីផ្តល់អាទិភាពក្នុងការអភិវឌ្ឍតម្លៃមនុស្ស។

## ២.ឋានៈស្ត្រីនៅក្នុងព្រះពុទ្ធសាសនា

(Status of Women in Buddhism) Ven. Dr. K. Sri Dhammananda

ឥរិយាបថសង្គមចំពោះស្ត្រី ត្រូវបានគេកត់សំគាល់ឃើញតាមរយៈការរើសអើង ដែលបានធ្វើឡើងដោយបុរេនិច្ឆ័យ(prejudices) ក៏ដូចជា សេចក្តីលំអៀងខាងសាសនាដែរ។ ដូច្នេះការរើសអើងចំពោះ ស្ត្រីគឺជាលក្ខណៈរួមមួយ នៅក្នុងគ្រប់សង្គមទាំងអស់។ បុរេនិច្ឆ័យ និងឧបសគ្គ ដែលស្ត្រីបានប្រឈមមុខនោះមានលក្ខណៈប្រហាក់ប្រហែលគ្នាដូចនៅAfrica Asia America ឬអឺរ៉ុបដែរ ។វាគឺជាអសមត្ថភាពពិសេសមួយដែល ស្ត្រីធ្លាប់មានបទពិសោធន៍ហើយមានមូលដ្ឋានសំខាន់របស់វានៅក្នុងសេចក្តីលំអៀងខាងសាសនានេះឯង ។ដូច្នេះវាមកពីសាសនាដែលថា គំនិតអំពីអស មត្ថភាពសំខាន់របស់ ស្ត្រីនេះតែម្តងដែលជាប្រភពនោះ។ នៅត្រង់នេះស្ត្រីត្រូវបានគេពិពណ៌ថាជាអ្នកជន្លជន្លេញ (temptress) ហើយនាងត្រូវបានក្រេីនរំលឹកដោយឥតប្រែ ប្រួលប្រឆាំងចំនៅក្នុងគ្រប់សាសនាពិភពលោកភាគច្រើនបំផុត ។

សេចក្តីលំអៀងសង្គមមួយចំនួនពឹងផ្អែកទៅលើ ជំនឿប្រជាប្រិយភាពនានា។ បើតាមទេវកថាសាសនាជាក់ស្តែង មនុស្សត្រូវបានគេស្គាល់ថាជា បុត្រារបស់ អាទិទេព។ វត្ថុចម្លែកគឺស្ត្រីមិនត្រូវបានគេផ្តល់ឋានៈប្រហាក់ប្រហែលគ្នា ជា បុត្រីនៃ អាទិទេពនោះទេ។

ក្នុងចំណោមក្រុម អ្នកជឿលើ ព្រលឹង មានអ្នកដែលជឿថា ព្រលឹងមានអត្ថិភាពតែនៅក្នុងមនុស្សប្រុស ប៉ុណ្ណោះ ប៉ុន្តែមិនមែននៅក្នុង ស្ត្រីទេ។ អ្នកដែលអះអាងថា ស្ត្រីមានព្រលឹងមួយដែលមិនឱ្យជឿថា ព្រលឹងរបស់នាងអាចស្វែងរកឃើញទីកន្លែងមួយនៅ ស្ថានសួគ៌ក្រោយពី នាងស្លាប់ទៅ។ ទាំងនេះមានខ្លះជាជំនឿចម្លែកដែលបង្ហាញយ៉ាងច្បាស់ ពីធម្មជាតិនៃការរើសអើងចំពោះ ស្ត្រីដែលមានលក្ខណៈទូទៅនៅក្នុងពិភពលោក។

ស្ត្រី ត្រូវបានគេកំណត់ឱ្យ គុណភាពមនុស្សអាក្រក់បំផុត។ ពួកគេត្រូវបានចាត់ទុកថាជាប្រភពអំពើបាបទាំងអស់នៅក្នុងលោកនេះ សូម្បីតែចំពោះវិសាលភាពស្តីបន្ទោសចំពោះភាពអភ័ព្វ ដែលបុរសប្រឈមមុខនៅក្នុងជាតិនេះក៏ដូចជាជាតិក្រោយដែរ។

**ពិធីបុណ្យសាសនា និង ក្បួនបុណ្យសាសនា** (Rites and Rituals)

ក្នុងចំណោមលទ្ធិសាសនាជាក់ស្តែង ស្ត្រីត្រូវបានរារាំងពីការប្រតិបត្តិបុណ្យសាសនា និង ក្បួនបុណ្យសាសនាជាក់ ស្តែងទៅលើមូលដ្ឋានដែលគ្រាន់តែជា ស្ត្រីនេះ! នៅពេលមួយ ពួកគេត្រូវបានហាមឃាត់ពីការអានគម្ពីរ! ទណ្ឌកម្ម របស់ពួកគេចំពោះការធ្វើបែប នេះគឺដើម្បីបំបិទមិនឱ្យនិយាយស្តី (to have their tongues cut out)។ ដោយឡែកពីនេះ ពួកគេក៏ត្រូវបានហាមឃាត់មិនឱ្យចូលទៅក្នុងទីកន្លែងគោរពបូជាឡើយ។ បើទោះជាពួកគេត្រូវបានអនុញ្ញាតឱ្យចូលរួម នៅក្នុង ការប្រតិបត្តិសាសនាក៏ដោយ ការចូលរួមបែបនេះគ្រាន់តែជាការកំណត់ព្រំដែននៅក្នុងផ្ទះរបស់ពួកគេប៉ុណ្ណោះ ដោយជាប់ទាក់ទងទៅនឹង ពិធីសាសនានៅផ្ទះ។ សព្វថ្ងៃនេះបើទោះជាមានអ្នករារាំងជាច្រើនត្រូវបានផ្លាស់ប្តូរក៏ដោយ ក៏ឧបសគ្គ និងការរារាំងនៅក្នុងពន្លឺនៃការលើក ស្ត្រីខាងផ្លូវចិត្ត និងខាង សីលធម៌ នៅតែមានអត្ថិភាពនៅក្នុងកម្រិតផ្លាស់ប្តូរដែរ។

**ការកំណត់រវាងបុរសនិងស្ត្រី** (Demarcation between Man and Woman)

តាមប្រវត្តិសាស្ត្រ ឥរិយាបថសង្គមចំពោះ ស្ត្រីអាចប្រព្រឹត្តទៅតាមដាននៅក្នុងថ្ងៃ មុនព្រះពុទ្ធសាសនាពី អក្សរសិល្ប៍វេទ ជាឧបមាដូចជា គម្ពីរឫគវេទ(the Rigveda)ជាដើម។ មានភស្តុតាងមួយដែលបង្ហាញពីកិត្តិយស និងសេចក្តីគោរព ដែលស្ត្រីបានទទួលយកជាផ្លូវការនៅក្នុងផ្ទះរបស់គេ។ចេញពីជ្រុងសាសនាពួកគេក៏មានច្រកចូលទៅរក ពុទ្ធិកំពូលចំពោះសុក្រឹតភាព ឬព្រហ្ម។ តែទោះជាយ៉ាងណាក៏ដោយឥរិយាបថសេរីភាពបែប នេះបានផ្លាស់ប្តូរនៅក្នុងពេលមិនយូរប៉ុន្មាន។ នេះក៏ដោយសារតែឥទ្ធិពល និងភាពលុបលើរបស់ បុព្វជិតដែលមាន ការប្រតិបត្តិបុណ្យរបស់ពួកគេដូចជាការបូជាសត្វនិង ភាពប៊ិនប្រសពបុព្វជិត(priestcraft) ពោលគឺដើម្បីដាក់ឈ្មោះមួយចំនួន។ នៅពេលនោះ គម្ពីរត្រូវបានគេផ្តល់ឱ្យនូវការបកស្រាយថ្មី ហើយស្ត្រីក៏ត្រូវឈានទៅដល់គំនិតថាទាបជាងបុរសដែរពោលគឺទាំង កាយសម្បទានិងសតិស្មារតី។

ការកំណត់រវាង បុរសនិងស្ត្រីត្រូវបានគេសម្តែងឱ្យឃើញនៅក្នុងដែន គ្រួសារ និង សង្គមដែល ស្ត្រី ត្រូវបានគេ មើលឃើញថា អន់ដោយប្រៀបធៀប។ ជាឧបមា ស្ត្រី ត្រូវបានគេមើលងាយថាជា របស់កម្មសិទ្ធិ (possession) មួយ ឬជា វត្ថុមួយប៉ុណ្ណោះ។ ទីកន្លែងរបស់នាង គឺនៅផ្ទះនាងមានចិត្តសាវ៉ា (whim) និងគំនិតវើរវាយ (fancy) របស់ប្តីនាង។ នាងមិនគ្រាន់តែត្រូវធ្វើកិច្ចការផ្ទះសព្វយ៉ាងប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវមើលការខុស ត្រូវនៅក្នុងផ្ទះដ៏ធំផងដែរ។ ជាឧទាហរណ៍ ពួកព្រាហ្មណ៍មួយចំនួនដែលបានរៀបការ ហើយរស់នៅជាមួយភរិយារបស់ពួក

គេផ្ទុយទៅវិញពួកគេបានចាត់ទុកអាហារដែលចំអិនដោយ ស្ត្រីថាមិនល្អបរិសុទ្ធនិងមិនសម នឹងទទួលទានទេ។ ចេញពីតួយ៉ាងបែបនេះ ទេវកថាក៏កើតមានឡើង។ ស្ត្រីត្រូវ បានជាប់ស្លាមជាអ្នកមានបាបកម្មហើយគេគិតថា មានតែវិធីទុកពួកគេទៅតាមភាពពិស (mischief) នេះទេដើម្បីឱ្យពួកគេធ្វើការជាមួយនឹងកិច្ចការនៃភាពជាម្តាយ និងករណីយកិច្ចផ្ទះសម្បែង ផ្សេងៗគ្មានទីបញ្ចប់នេះ។

មានជំនឿដ៏មាំមួយថា មានតែកូនប្រុសប៉ុណ្ណោះសម្រាប់ បន្តនិរន្តរភាពនៃខ្សែស្រឡាយគ្រួសារនិងជាអ្នករៀបចំបុណ្យរបស់ដូនតា។ ជំនឿប្រពៃណីពោលថាមានតែកូនប្រុសប៉ុណ្ណោះដែលអាចរៀបចំ បុណ្យបែបនេះបាន ដែលគេគិតថាមានការចាំបាច់សម្រាប់នាំមកនូវសន្តិភាព និង សន្តិសុខដល់ឪពុក និងជីតារបស់គេបន្ទាប់ពីពួកគេ ស្លាប់ទៅ។ ម្យ៉ាងទៀតគេមានជំនឿថាអ្នកដែលស្លាប់ទៅហើយអាចកើតទៅជាខ្មោច ហើយមកឆាឆៅដល់គ្រួសារ។ ដូច្នេះលទ្ធភាពបង្កើតកូនប្រុសមានសារៈសំខាន់ណាស់ដើម្បីរៀបការជាមួយស្ត្រី។ ម្យ៉ាងវិញទៀតប្រសិនបើស្ត្រីរៀបការគ្មានកូនទេឬប្រសិនបើនាងមិនអាចបង្កើតកូនប្រុសបានទេនោះនាងអាចត្រូវជំនួសដោយប្រពន្ធទី២ឬ ទី៣ជា មិនខាន ឬត្រូវដេញចេញពីផ្ទះបើអនុលោមទៅតាមជំនឿនេះ។ ការយល់ឃើញពីជ្រុងមួយនៃភាពសំខាន់នេះបានទាក់ទងទៅដល់ កំណើតកូនប្រុស ដែលត្រូវរៀបការជាមួយ ស្ត្រី យើងដឹងថា ជីវិតរបស់ ស្ត្រីរៀបការ មានលក្ខណៈមិន ទៀងទាត់ទេ ដោយពឹងទៅលើថាតើនាងអាចបង្កើត កូនប្រុសបានដែរឬអត់ប៉ុណ្ណោះ។ ផ្ទុយទៅវិញជំនឿនេះមិនមានន័យថា ជីវិតរបស់ ស្ត្រីមិនបានរៀបការ មានលក្ខណៈទៀងទាត់ជាង កូនស្រីរៀបការ របស់គេនោះទេ។ ដូច្នេះការរៀបការត្រូវបានគេគិតថាជា ប្រសិទ្ធភាពពិសិដ្ឋ។ ដូច្នេះ ក្មេងស្រីដែលមិនរៀបការត្រូវបាន សង្គមស្អប់ខ្ពើមហើយក្លាយជា កម្មវត្ថុមួយសំខាន់សម្រាប់ការរិះគន់របស់ពួកគេ។

ជាផ្លូវចិត្ត នៅក្នុងវិស័យប្រតិបត្តិសាសនាទីតាំងដែលស្ត្រីបានសប្បាយរីករាយម្តងនោះក៏ត្រូវបានពួកគេបដិសេធនឹដែរ។ ដោយហេតុដូច្នេះហើយបានជាគេមានជំនឿថា ស្ត្រីមិនមានលទ្ធភាពឡើង ឋានៈសួគ៌តាមរយៈ បុណ្យទាន ផ្ទាល់របស់នាងទេ។ លើសពីនេះទៀតនាងមិនអាចធ្វើសក្ការៈបូជាដោយខ្លួនឯងបានទេ។ គេក៏មានជំនឿផងដែរថា នាង អាចឡើងឋានសួគ៌បានតែតាមរយៈ ការគោរពតាមដោយមិនចាំបាច់សួរដេញដោលចំពោះ ប្តីនាងឡើយ។ ពោលគឺសូម្បីតែប្តីនាង ដែលត្រូវមានសំណួរកើតឡើងក៏ដោយក៏គេក្លាយទៅជា មនុស្សមានបាប (wicked person)ដែរ ។គេក៏ទទួលយកផងដែរថាអាហារដែលស្វាមីទទួលទានសល់ជារឿយៗ

ក៏ជាអាហាររបស់នាងផងដែរ ។គំរូទាំងអស់នេះបង្ហាញឱ្យឃើញពីវិសាលភាពនៃវិសមភាពរវាង បុរស និងស្ត្រីដែរ ។

**ការសម្តែងរបស់ព្រះពុទ្ធ** (As It Is Stated By the Buddha)

ដោយផ្ទុយទៅនឹងការប្រតិត្តិផ្តល់កំណើតបែបនេះ ដែលរារាំងដល់ការអភិវឌ្ឍន៍ផ្លូវចិត្ត បែបនេះព្រះពុទ្ធសាសនាអាចត្រូវបានអះអាងពីការមិនប្រកាន់រើសអើងនៅក្នុងឥរិយាបថចំពោះ ស្ត្រីឡើយ ។ មិនមានអ្វីដែលគួរឱ្យឆ្ងល់ទាល់តែសោះថា ព្រះពុទ្ធគឺជា គ្រូប្រដៅសាសនាទី១ ដែលផ្តល់ឱ្យស្ត្រី នូវឱកាសសមភាពនិង មានសេរីភាពនៅក្នុងវិស័យអភិវឌ្ឍផ្លូវចិត្ត ។ បើទោះ ជាព្រះអង្គមានឱកាសបីបួនបង្ហាញឱ្យឃើញពី ទំនោរធម្មជាតិ និងភាពទន់ខ្សោយ របស់ ស្ត្រី ជាទូទៅក៏ដោយ ព្រះអង្គក៏បានឱ្យតម្លៃដល់ លទ្ធភាពនិង សមត្ថភាពរបស់ពួកគេដែរ ។ ព្រះអង្គ បានត្រួសត្រាយផ្លូវសម្រាប់ស្ត្រី ដើម្បីដឹកនាំ ជីវិតសាសនាដោយពេញបរិបូរណ៍ ។ នេះបញ្ជាក់ ថា ពួកគេមានលទ្ធភាពសមភាព ដើម្បីអភិវឌ្ឍ និងធ្វើឱ្យចិត្តរបស់ពួកគេល្អបរិសុទ្ធហើយ និង យល់ច្បាស់ពី បរមសុខនៃ ព្រះនិព្វានក៏ដូចជា បុរសដែរ ។ ការពិតនេះបានបញ្ជាក់ដោយបរិបូណ៌ តាមរយៈសក្ខីភាពនៃ *Theris* (ដូនជី) នៅក្នុងអំឡុងសម័យរបស់ ព្រះពុទ្ធ ។

ការបង្រៀនរបស់ព្រះពុទ្ធមានទំនាក់ទំនងយ៉ាងធំធេងចំពោះការលុបបំបាត់ អបិយជំនឿ និង ពិធីបុណ្យនិង ក្បួនបុណ្យឥតន័យជាច្រើន ដែលមានរួមបញ្ចូល ពិធីបូជាយញ្ញនោះផង ចេញ ពីចិត្តរបស់មនុស្សជាច្រើន ។ ពេលព្រះពុទ្ធទ្រង់សម្តែងពី ធម្មជាតិពិតនៃ ជីវិតនិងសេចក្តី ស្លាប់ និងពន្យល់ពី បាតុភូតធម្មជាតិដែលគ្រប់គ្រងពិភពលោក ចំពោះមនុស្សទាំងនេះ ពួកគេ ចាប់ផ្តើមយល់ ។ នេះរារាំងជាបន្តបន្ទាប់ ហើយនិងកែប្រែ ភាពអយុត្តិធម៌ និង បុរេនិច្ច័យសង្គម លើសលុប ។ ដូច្នេះវាធ្វើឱ្យ ស្ត្រី ដឹកនាំ មាគ៌ាជីវិត ផ្ទាល់របស់ពួកគេ ។

ថ្វីបើ ព្រះពុទ្ធបានលើកឋានៈស្ត្រីនៅក្នុងសង្គមក៏ដោយ ក៏ព្រះអង្គបានចង្អុលប្រាប់ភាព ខុសគ្នាខាងចិត្តសាស្ត្រ និងខាងសង្គមដែលមានអត្ថិភាពរវាងបុរសនិងស្ត្រីដែរ ។ នេះបានបង្ហាញ ជូននៅក្នុងឥរិយាបថដែលនៅក្នុងនោះ ព្រះអង្គយល់ច្បាស់ទៅលើការពិនិត្យសង្កេតរបស់ព្រះ អង្គ ។ ដំបូន្មានរបស់ព្រះអង្គ ដែលបានផ្តល់ឱ្យម្តងហើយម្តងទៀត បានមើលឃើញនៅក្នុងពន្លឺ នៃការសង្កេតមើលរបស់ព្រះអង្គនោះគឺ មានលក្ខណៈជាប្រតិបត្តិ ។ គួរយ៉ាងជាច្រើនទាំងនេះ ត្រូវបានពិពណ៌នាយ៉ាងច្បាស់នៅក្នុង អង្គុត្តរនិកាយ *(Anguttara Nikaya)* និងសម យុត្តនិកាយ *(Samyutta Nikaya)* ។ រឿងនេះមានបញ្ជាក់ថា ករណីយកិច្ចរបស់បុរស គឺជា

ដំណើរស្វែងរកមិនចេះចប់របស់គេចំពោះពុទ្ធិ។ គេគួរតែធ្វើឱ្យចម្រើននិងធ្វើឱ្យ ជំនាញនិងហត្ថកោសល្យរបស់គេនៅស្ថិតថេរហើយនិងបូជាចំពោះការងាររបស់គេ។ គាត់ក៏ត្រូវមានលទ្ធភាពដើម្បីស្វែងរកមធ្យោបាយដើម្បីរក្សានិងធ្វើឱ្យគ្រួសាររបស់គាត់មាននិរន្តរភាព។ ម្យ៉ាងវិញទៀតវាក៏បាន អះអាងផងដែរថា វាគឺជាករណីយកិច្ចរបស់ ស្ត្រីដើម្បីមើលថែរក្សាផ្ទះ និងស្វាមីរបស់នាង។

អង្គុត្តរនិកាយ*(Anguttara Nikaya)* ផ្ទុកនូវដំបូន្មានដ៏មានតម្លៃដែល ព្រះពុទ្ធ ទ្រង់បានផ្តល់ឱ្យដល់ស្ត្រីក្មេងៗ នៅមុនពេលចូលរោងការ។ ដោយមើលឃើញពីការលំបាកដែលនឹងកើតមានឡើងជាមួយនឹងសាច់ថ្លៃថ្មីព្រះពុទ្ធទ្រង់ឱ្យដំបូន្មានដល់ស្ត្រីក្មេងៗឱ្យគោរពចំពោះឪពុកម្តាយក្មេករបស់ពួកគេ ដោយជួយសង្គ្រោះពួកគេឱ្យដូចជានាងស្រឡាញ់ ឪពុកម្តាយផ្ទាល់របស់ខ្លួនដែរ។ ពួកគេក៏ត្រូវបានស្នើសុំឱ្យផ្តល់កិត្តិយស និងការគោរពចំពោះ សាច់សាលោហិតនិង មិត្តភក្តិ ខាងប្តីនាងដើម្បីឱ្យបរិយាកាសសប្បាយរីករាយ និងយោគយល់គ្នានឹងត្រូវបង្កើតឡើងនៅក្នុងផ្ទះថ្មីរបស់ពួកគេ។ ពួកគេក៏ត្រូវបានផ្តល់ដំបូន្មានឱ្យសិក្សា និងយល់ដឹងពី ធម្មជាតិរបស់ប្តីនាងរបស់ពួកគេផងដែរ ពោលគឺដើម្បីរកឱ្យឃើញពី សកម្មភាព អត្តចរិត និង អារម្មណ៍ប្តីរបស់ពួកគេ និងដើម្បីឱ្យមានប្រយោជន៍ និងមានការសហប្រតិបត្តិការគ្រប់ពេលនៅក្នុងផ្ទះថ្មីរបស់ពួកគេ។ ពួកគេគួរតែសុភាពរាបសាចិត្តល្អ និងប្រយ័ត្នប្រយែងនៅក្នុងទំនាក់ទំនងរបស់ពួកគេជាមួយនឹង អ្នកបម្រើ។ ពួកគេក៏គួរតែការពារ និងថែរក្សា ប្រាក់ចំណូលរបស់ ប្តីហើយនិងស្វែងរកឱ្យឃើញថាការចំណាយនៅក្នុងផ្ទះត្រូវមានលក្ខណៈសេដ្ឋកិច្ចបំផុត។ ទង្វើបែបនេះគឺជាគុណភាពគ្មានទីបញ្ចប់នៃដំបូន្មានរបស់ព្រះពុទ្ធ។ ព្រះពុទ្ធទ្រង់បានលើកសរសើរថា សេចក្តីសុខស្រួលនិងភាពសុខដុមរមនានៅក្នុងផ្ទះគឺស្ត្រីមាននាទីសំខាន់ណាស់។ដូច្នេះដំបូន្មានរបស់ព្រះអង្គចំពោះ ស្ត្រីទៅលើតួនាទីរបស់ខ្លួននៅក្នុង ជីវិតអាពាហ៍ពិពាហ៍ របស់ពួកគេមានលក្ខណៈច្បាស់លាស់ និងប៉ិនប្រសប់បំផុត។ ព្រះអង្គបានរៀបចំនូវល្អនៃគុណភាពពីមួយថ្ងៃ ទៅមួយថ្ងៃដែល ស្ត្រី គួរឬមិនគួរធ្វើ។ នៅក្នុងឱកាសផ្សេងៗ ព្រះពុទ្ធបានឱ្យដំបូន្មានដល់ ភរិយា ថា ៖

- មិនគួរមាន គំនិតអាក្រក់ប្រឆាំងចំពោះស្វាមីឡើយ
- មិនគួរកាច ឃោរឃៅ គំរោះគំរើយ ឬ ប្រើអំណាចគាបសង្កត់
- មិនគួរ ខ្ជះខ្ជាយ ប៉ុន្តែត្រូវ សន្សំសំចៃនិងរស់នៅនៅក្នុង មធ្យោបាយ

- គួរការពារនិងសន្សំសំចៃទ្រព្យរបស់ស្វាមីហើយ និងទ្រព្យដែលរកបានមកយ៉ាងលំបាក ដោយប្រុងប្រយ័ត្នបំផុត
- ត្រូវប្រកបដោយ គុណធម៌និង ល្អបរិសុទ្ធនៅក្នុង ចិត្ត និងក្នុង អំពើ
- ត្រូវ ស្មោះត្រង់និងកុំមាន គំនិតក្បត់ប្តី  ដោយប្រការណាមួយ
- ត្រូវប្រើ សម្តីពិរោះពិសា និង សុភាពរាបសានៅក្នុងអំពើ
- ត្រូវ ចិត្តល្អ ឧស្សាហ៍ព្យាយាមនិង ខិតខំធ្វើការ
- ត្រូវចេះរិះគិតនិង អាណិតអាសូរចំពោះស្វាមី ហើយឥរិយាបថគួរតែអព្យាក្រឹតចំពោះការស្រឡាញ់ម្តាយ និងការពារកូនរបស់នាង
- ត្រូវ សុភាពរម្យទម និងគួរឱ្យគោរព
- ត្រូវមាន ចិត្តត្រជាក់ស្ងប់ ហើយនិងយល់យោគគ្នាពេលគឺជួយសង្គ្រោះមិនត្រឹមតែជាភរិយាទេ ប៉ុន្តែក៏ជាមិត្តហើយនិងជា ទីប្រឹក្សាដល់ស្វាមីបើមានតម្រូវការចាំបាច់ ។

នៅក្នុងថ្ងៃរបស់ព្រះពុទ្ធ  គ្រូប្រដៅសាសនាដទៃទៀតក៏មាននិយាយពីករណីយកិច្ច  និងកាតព្វកិច្ចរបស់ភរិយាចំពោះស្វាមីនេះដែរ ។ ពួកគេបានសង្កត់ធ្ងន់ថាវាគឺជាករណីយកិច្ចពិសេសរបស់ភរិយាដើម្បីកើតកូនកើតចៅឱ្យស្វាមី ហើយនិង បម្រើស្វាមីដោយស្មោះត្រង់ និងនាំមកនូវសុភមង្គលស្វាមីភរិយា ។ នេះគឺជាទស្សនៈប្រហាក់ប្រហែលគ្នានឹងទស្សនៈរបស់ *ខុងជឺ*ដែរ ។ តែទោះជាយ៉ាងណាក៏ដោយបើទោះជា ករណីយកិច្ចរបស់ ភរិយាចំពោះ ស្វាមី ពឹងផ្អែកទៅលើច្បាប់ ខុងជឺ ក៏ដោយ ក៏វាមិនសង្កត់ធ្ងន់ទៅលើ ករណីយកិច្ចនិង កាតព្វកិច្ចរបស់ ស្វាមីចំពោះភរិយានោះដែរ ។ការបង្រៀនរបស់ព្រះពុទ្ធមិនមែនជាការពឹងផ្អែកចំពោះ ស្វាមីនោះទេ ។ នៅក្នុង សូត្ត *Sigalovada Sutta* ព្រះពុទ្ធបានអះអាងយ៉ាង ច្បាស់ទាំង ករណីយកិច្ចរបស់ស្វាមីចំពោះ ភរិយានិង ភរិយាចំពោះ ស្វាមី ។ នៅខាងផ្នែក ស្វាមីគាត់ត្រូវ ស្មោះត្រង់ពោលគឺ សុភាពរាបសា និង ស្រឡាញ់ ចំពោះ ភរិយា ។ វាគឺជាករណីយកិច្ចរបស់ស្វាមីដែលត្រូវប្រគល់អំណាច ដល់ ភរិយាហើយពីពេលមួយទៅពេលមួយ ស្វាមីនាំមកឱ្យនាងនូវ ការសំអិតសំអាង ។ ដូច្នេះយើងត្រូវ ផ្តល់ភស្តុតាង ដោយឥរិយាបថមិនលំអៀងដែល ព្រះពុទ្ធទ្រង់បានបង្ហាញប្រាប់ទាំងចំពោះបុរស និងស្ត្រី ។

ព្រះពុទ្ធ ក៏បានចង្អុលបង្ហាញពីពិការភាព និងទំនាស់ផ្សេងៗដែលស្ត្រីត្រូវតែទទួលយក ។ ជាឧបមាការវិនិច្ឆ័យកិច្ច (the trials) និងទុក្ខព្រួយខាងផ្លូវចិត្ត ស្ត្រីត្រូវតែទ្រាំទ្រទៅលើទុក្ខ

ព្រួយចំពោះការចាកចេញពីផ្ទះ របស់នាងនៅថ្ងៃរៀបការរបស់នាងនិងការប៉ះទង្គិចនៃការសម្រប សម្រួលខ្លួននាងទៅក្នុងបរិដ្ឋានថ្មីដែលពោរពេញទៅដោយបញ្ហានិងសេចក្ដីលំបាកនានា។ លើស ពីបញ្ហាទាំងអស់នេះ នៅមានបញ្ហាជម្ងឺផ្លូវចិត្តដែលស្ត្រី ត្រូវទទួលរងនៅក្នុងអំឡុងពេលមាន រដូវមានគភ៌និងការសម្រាលកូន។ ទាំងអស់នេះពិតជាមានប៉ុន្តែបាតុភូតធម្មជាតិដែលពិពណ៌នា តែពីពិការភាព និងកាលៈទេសៈផ្សេងគ្នាដែលមានជាទូទៅរវាងបុរសនិងស្ត្រី។

ការបង្រៀនរបស់ ព្រះពុទ្ធទៅលើ ធម្មជាតិពិតនៃ ជីវិតនិង សេចក្ដីស្លាប់ពោលគឺ កម្មនិង ដំណើរវិលវល់ ក្នុងវដ្តសង្សារ ដែលបានផ្លាស់ប្ដូរឥរិយាបថសង្គមចំពោះ ស្ត្រីនៅក្នុងអំឡុងពេល នោះ។ នេះមានលក្ខណៈពិសេសបំផុត ដែលគោរពទៅតាមសារៈសំខាន់ដ៏ធំដែលជាប់ទាក់ទង ទៅនឹងកំណើតកូនប្រុស។ ព្រះពុទ្ធសាសនាមិនដែលនិយាយដល់អំពីរឿងកូនប្រុសមានលក្ខណៈ ចាំបាច់សម្រាប់ដំណើរឆ្លងរបស់ឪពុកទៅឋានសួគ៌ ដូចទស្សនៈរបស់ព្រហ្មញ្ញសាសនានោះទេ។ ព្រះពុទ្ធទ្រង់បានបង្រៀនថា ដោយយោងទៅតាម ច្បាប់កម្មផល គេអាចទទួលខុសត្រូវចំពោះ អំពើផ្ទាល់របស់គេ និងផលវិបាករបស់វា។ សុខុមាលភាពរបស់ ឪពុក ឬរបស់ជីតាមិនមែនពឹង ទៅលើ អំពើរបស់កូនប្រុសឬចៅប្រុសនោះទេ។ បុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវចំពោះ អំពើ ផ្ទាល់របស់ខ្លួន។ ដូច្នេះគ្មានហេតុសម្រាប់ ស្ត្រីរៀបការ ត្រូវខ្វល់ខ្វាយ ព្រោះតែ ពួកគេមិនអាច បង្កើត កូនប្រុសដោយគ្រាន់តែសម្រាប់រៀបចំ "បុណ្យរបស់បុព្វបុរស" នោះទេ។ នេះក៏មាន ន័យថាកូនស្រីក៏មានលក្ខណៈល្អ ដូចកូនប្រុសដែរ។

វាអាចប្រព្រឹត្តិទៅបាន នៅក្នុងអំឡុងសម័យកាលព្រះពុទ្ធសាសនាដើមចំពោះ ស្ត្រី នៅ មិនទាន់រៀបការផ្ទុយទៅវិញ មិនមានបញ្ហាអ្វីឡើយ។ នាងអាចពេញចិត្តនៅផ្ទះនាង និងមាន ឱកាសគ្រប់គ្រាន់ដើម្បីមើលថែរក្សាឪពុក ប្អូនប្រុស-ស្រី តូចៗរបស់នាង។ នាងអាចជាម្ចាស់ ទ្រព្យដ៏ធំផងដែរ។

ព្រះពុទ្ធមិនបានភ្ជាប់មហាសារៈសំខាន់ចំពោះ កំណើតកូនប្រុស នោះទេ។ នៅពេលមួយ ពេលស្ដេចកុសាលា(Kosala) កំពុងគង់នៅជាមួយព្រះពុទ្ធក៏មានអ្នកនាំដំណឹងមកទូលព្រះអង្គ អំពីកំណើតកូនស្រី។ ដោយនឹកសង្ឃឹមថា ជាកូនប្រុសព្រះមហាក្សត្រទ្រង់ មិនសប្បាយព្រះ ទ័យ។ ដោយមានការកត់សំគាល់នៅត្រង់ចំណុចនេះ ព្រះពុទ្ធទ្រង់បាន ផ្ដល់វិភាគទានដ៏គួរឱ្យ រីករាយចំពោះ ស្ត្រី ដោយទ្រង់រៀបរាប់ពី គុណធម៌របស់ពួកគេនៅក្នុងឥរិយាបថដូចតទៅ :-

"ស្ត្រី មួយចំនួនពិតជាល្អប្រសើរ (ជាងបុរស) ណាស់។ សូមចិញ្ចឹមថៃរក្សានាងចុះ ព្រះគុណម្ចាស់។ មានស្ត្រីដែលឆ្លាត១ប្រកបដោយគុណធមិ មានការចាត់ ទុកខ្ពស់ចំពោះម្តាយក្មេក ហើយល្អបរិសុទ្ធណាស់។ ចំពោះព្រះអគ្គមហេសីប្រសើរបែបនេះ អាចបង្កើតកូនប្រុសក្លាហានម្នាក់ស្តេចនៃព្រះរាជាណាចក្រដែលនឹងគ្រប់គ្រងព្រះរាជាណាចក្រ។"

ព្រះពុទ្ធបានបើកទ្វារឱ្យការចូលរួមពេញលេញរបស់ស្ត្រី នៅក្នុងវិស័យ សាសនា ដោយធ្វើឱ្យពួកគេទទួលបាន សិទ្ធិ អនុញ្ញាតឱ្យចូលទៅក្នុង សង្ឃភិក្ខុនី (Bhikkhuni Sangha)ពោលគឺ សហគមន៍ដូនជី (Order of Nuns)។ នេះ បានបើកផ្លូវវប្បធម៌ថ្មី ពោលគឺសេវាកម្មសង្គម និងឱកាសសម្រាប់ជីវិតសាធារណៈចំពោះស្ត្រី។ វាបញ្ជាក់ពីការទទួលស្គាល់ពីសារៈសំខាន់របស់ពួកគេចំពោះសង្គម ហើយនិងដើម្បីលើកតម្កើងឋានៈស្ត្រី។

បើទោះជាមានការបញ្ជាក់អះអាងហេតុផល មួយចំនួនដែលបានធ្វើឡើងនៅក្នុង The *Tripitaka* អំពី កលល្បិចដ៏ប៉ិនប្រសប់ (wile) និង អាកប្បកិរិយារបស់ ស្ត្រីព្រះពុទ្ធ ក៏ទ្រង់បាន បញ្ជាក់ផងដែរនៅក្នុង សមយុត្តិកនិកាយនូវ លក្ខណៈរំលោះរបស់ពួកគេ។ គេបាននិយាយថា ស្ថិត នៅក្រោមកាលៈទេសៈជាក់ស្តែង ស្ត្រី ត្រូវបានគេគិតថា ឆ្លាតជាង និងមានការវិនិច្ឆ័យល្អជាងបុរសហើយនិងថាពួកគេត្រូវបានគិតថា មានលទ្ធភាពសម្រេចបានសុក្រឹតភាពឬអរហន្តី (Sainthood) បន្ទាប់ពីដើរតាម អដ្ឋង្គិកមគ្គមក។ បើទោះជាអ្នកខ្លះអាច ឮសូរមិនសប្បាយក៏ដោយតាមរយៈការសង្កេតដោយប្រុងប្រយ័ត្នមក យើងរកឃើញថាអ្វីដែល ព្រះពុទ្ធទ្រង់បានសម្តែងអំពី ស្ត្រីនោះនៅតែល្អប្រសើរដដែល។ ដូច្នេះនៅក្នុងការបកស្រាយពី ធម្មជាតិរបស់ ស្ត្រីបើតាម ព្រះពុទ្ធសម្តែង ពេលស្តេចកុសាលាបានរកឃើញថា ព្រះអង្គ ប្រសូត្របាន បុត្រីមួយអង្គជំនួសឱ្យបុត្រាព្រះពុទ្ធ ទ្រង់បានចង្អុលបង្ហាញពីភាពមិនកំសោយរបស់ពួកគេនោះ ប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏បានបង្ហាញពីសក្តានុពលរបស់ពួកគេផងដែរ។

ព្រះពុទ្ធទ្រង់បានបង្ហាញដោយច្បាស់លាស់ថា ស្ត្រី មានសមត្ថភាពយល់ដឹងពីការបង្រៀនរបស់ព្រះអង្គ ហើយនិងប្រតិបត្តិការបង្រៀនទាំងនេះចំពោះកម្រិតនៃការសម្រេច បានខាងផ្លូវចិត្តមួយចំនួន។ នេះត្រូវបានបង្ហាញយ៉ាងច្បាស់ ដោយដំបូន្មានថា ព្រះពុទ្ធទ្រង់បានផ្តល់ឱ្យ ស្ត្រីខុស១គ្នាទៅលើឱកាស និងកាលៈទេសៈខុស១គ្នា។ ព្រះពុទ្ធទ្រង់បានបង្រៀនមេ រៀនអំពី ភាពមិនទៀងទាត់ចំពោះ ខេមាសោភ័ណមនសិកា(beauty-conscious Khema)និងឥតបានការ។ ខេមាគឺជា ព្រះមហេសីដ៏ស្អាតមួយអង្គរបស់ស្តេចពិមពិសារ (Bimbisara)។ កាលពីដំបូង ព្រះ

នាងអស់ឯកនឹងយាងមកជួបព្រះពុទ្ធព្រោះព្រះនាងបានឮថាព្រះពុទ្ធធ្លាប់សំដៅចំពោះសោភ័ណក្រៅ(external beauty)នៅក្នុងកាលកំណត់ បង្អាប់ (disparaging terms)។ នៅថ្ងៃមួយនាងបាននិយាយថាការទស្សនៈកិច្ចធម្មតាទៅវត្តគ្រាន់តែដើម្បីសប្បាយរីករាយជាមួយនឹងទេសភាព នៃទីកន្លែងប៉ុណ្ណោះ។ បន្តិចម្តងៗព្រះនាងបានទប់ព្រះទ័យចំពោះទីកន្លែងដែល ព្រះពុទ្ធកំពុងសម្តែងធម្មទេសនា។ ព្រះពុទ្ធ តាមរយៈការប្រើ កម្លាំងចិត្តសាស្ត្រ របស់ព្រះអង្គមើលពីគំនិតរបស់ព្រះនាងហើយក៏បង្កើតទស្សនវិស័យនៃស្ត្រី វ័យក្មេងម្នាក់ដែលកំពុងឈរនៅមុខព្រះនាង។ ខេមា កំពុងតែលើកសរសើរពីសម្រស់របស់នាងពេល ព្រះពុទ្ធទ្រង់បានបំប្លែង សោភ័ណភាពប្រឌិត ពីយុវវ័យទៅ មជ្ឈិមវ័យ (middle age) និងជាបន្តបន្ទាប់ ទៅដល់ វ័យចំណាស់រហូតដល់ដេកដួលនៅលើដីនៅទីបំផុតធ្មេញក៏បាក់សក់ក៏ស្កូវស្បែកក៏ជ្រីវជ្រួញ។ ការបំប្លែងនេះធ្វើឱ្យខេមាយល់ច្បាស់ពី ភាពឥតប្រយោជន៍នៃ សោភ័ណក្រៅ ហើយនិងដើម្បី លើកសរសើរពីធម្មជាតិជីវិត ឆាប់រហ័សនេះ។ ដូច្នេះព្រះនាងបានទ្រង់ព្រះតម្រិះថា "តើរូបកាយមួយបែបនេះនឹងទៅជាជ្រីវជ្រួញបែបនេះមែនឬទេ ? បើដូច្នេះមែនព្រះកាយរបស់ខ្ញុំនឹងត្រូវជ្រីវជ្រួញជាមិនខានឡើយ។ ដោយមានការយល់បែបនេះព្រះនាងបានសម្រេច ព្រះអរហត្តភាពជាបន្តបន្ទាប់ហើយជាមួយការយល់ស្របរបស់ព្រះមហាក្សត្រ ព្រះនាងក៏បានចូលទៅក្នុងសហគមន៍ដូនជី។

ចំពោះស្ត្រីដែលងាយនឹងរំជួលចិត្ត និងងាយនឹងមានទុក្ខហួសពេកទៅលើការបាត់បង់អ្នកជាទីស្រឡាញ់បំផុត ព្រះពុទ្ធ ទ្រង់បានសម្តែងពីភាពមិនអាចជៀសរួចនៃមរណៈភាពដែលបានសម្តែងនៅក្នុងចតុរារិយសច្ចៈ។ ព្រះអង្គក៏បានដកស្រង់ពីការប្រៀបធៀបផ្សេងៗ ដើម្បីបញ្ជាក់ពីទស្សនៈរបស់ព្រះអង្គ។ ដូច្នេះចំពោះនាងវិសាខា (Visakha) ជា ជីដូនគួរជាទីស្រឡាញ់ និងគួរឱ្យរំភើបចិត្តយ៉ាងជ្រាលជ្រៅម្នាក់ដែលបានបាត់បង់ចៅព្រះពុទ្ធទ្រង់បានសម្តែងដូចតទៅ :

*"ពី សេចក្តីស្រឡាញ់ឈានទៅរក សេចក្តីទុក្ខពីសេចក្តីស្រលាញ់ទៅរក សេចក្តីភ័យខ្លាចចំពោះអ្នកដែលរួចផុតពីសេចក្តីស្រឡាញ់ជាស្ថាពរអ្នកនោះគ្មានទុក្ខគ្មានការភ័យខ្លាចអ្វីឡើយ។*

ការបង្កើតសហគមន៍ភិក្ខុនីនេះនៅឆ្នាំទី៥នៃក្រុមរបស់ព្រះពុទ្ធ (the Buddha's ministry) បានត្រួសត្រាយផ្លូវសម្រាប់ សេរីភាពសាសនាពេញលេញ សម្រាប់ស្ត្រី។ វាជាការ ជោគជ័យនៅក្នុងខ្លឹមសារថាមាន ដូនជីល្អៗជាច្រើនដែលមានលក្ខណៈត្រចះត្រចង់នៅក្នុងការសិក្សា និងការប្រតិបត្តិព្រះធម៌។ នៅក្នុងក្រសៃភ្នែកពិភពលោក ព្រះពុទ្ធសាសនាបានចម្រើន ឡើងយ៉ាង

ត្រចះត្រចង់។ The Psalm of the Sister (*Therigatha*) ដែលមានកំណាព្យប្រមាណ ៧៧ កំណាព្យតែងដោយស្ត្រីម្នាក់ៗគឺជាកំណាព្យមួយដែលអួតសរសើរពីអក្សរសិល្ប៍ព្រះពុទ្ធសាសនា។

ព្រះពុទ្ធមិនបានកំណត់ពី ដូនជីដែលការបង្រៀន និងការសម្តែង ព្រះធម៌ ត្រូវបានគេចាប់អារម្មណ៍នោះទេ។ សហគមន៍ដូនជី បានបង្កើតចំនួនគួរឱ្យកត់សំគាល់ មួយចំពោះអ្នកសម្តែងធម្មទេសនា និងអ្នកបកស្រាយ ព្រះធម៌ ល្អៗជា ច្រើនដូចជា Sukha, Patacara, Khema, Dhammadinna និង Maha Pajapati (ព្រះមាតុច្ឆារបស់ Siddharta)។ បើតាម ព្រះពុទ្ធសាសនា កូនប្រុស មិនមានសារៈសំខាន់សម្រាប់ដំណើរឆ្លងរបស់ឪពុកទៅ ឋានសួគ៌នោះទេពោលគឺកូនស្រីក៏ល្អដូចកូនប្រុសដែរពោលគឺពួកគេមានសេរីភាពអាចដឹកនាំជីវិតឯករាជ្យបាន។ តាមរយៈការផ្តល់ឱ្យស្ត្រី នូវផ្នែកសកម្មមួយនៅក្នុង ជីវិតសាសនាព្រះពុទ្ធក៏បានជួយលើកឋានៈរបស់ពួកគេនៅក្នុងជីវិតលោកិយនេះ។

តែទោះជាយ៉ាងណាក៏ដោយការអនុញ្ញាតឱ្យ ស្ត្រីចូលទៅក្នុង ជីវិតសាសនាមានលក្ខណៈជឿនលឿនសម្រាប់សម័យកាលនោះ។ដោយសារតែធម្មជាតិនៃការកែច្នៃឱ្យចម្រើនជឿនលឿនពេកនៅក្នុងការគិតសម្រាប់សករាជពិសេសនោះ មនុស្សមិនមានលទ្ធភាពសម្រប ខ្លួនទៅតាមដែលបណ្តាលឱ្យដើរថយក្រោយនោះទេ។ ដូច្នេះសម័យកាលនៃ សហគមន៍ ភិក្ខុនីមានជីវិតខ្លី ពីព្រោះមនុស្សគ្រប់គ្រងស្ថានភាពមិនបាន។ពួកព្រាហ្មណ៍ដែលបានរកឃើញពីបុព្វសិទ្ធិ(privilege) របស់ខ្លួននៅក្នុងប្រព័ន្ធវណ្ណៈដែលបានគំរាមកំហែងនោះគឺជាកត្តាមួយទៀតដែលធ្វើឱ្យបដិសេធសហគមន៍ចោល។ ពួកគេបានឃោសនាបង្ខូចប្រឆាំងនឹង ឥរិយាបថ "ថ្មី" ក្នុងការឱ្យ ស្ត្រីមានសេរីភាពសាសនានេះ។

នៅស្រីលង្កា សហគមន៍ដូនជី បានចម្រើនរហូតដល់ ឆ្នាំ១០១៧ ក្រោយគ.ស.នៅក្នុងរជ្ជកាលស្តេច Mahin-da ទី IV។ បន្ទាប់ពីនោះមកក៏លិចបាត់ទៅវិញរហូត។ ប៉ុន្តែ សហគមន៍ដូនជីបានផ្សាយចូលមក ចិន ដោយ ដូនជី Sinhalese ហើយវានៅតែមានអត្ថិភាពដូចនៅប្រទេស ជប៉ុនដែរ។ តែទោះជាយ៉ាងណាក៏ដោយ នៅក្នុងទំនៀមទម្លាប់ មហាយាន ពួកគេមានឋានៈក្រោមមួយដែលមិនស្មើនឹង ព្រះសង្ឃ។

**ទៅរកសមភាពនិងសេរីភាព** (Towards Equality and Freedom)

សម័យទំនើបបានមកដល់នៅស.វ.ទី១៩-២០មានលក្ខណៈឃ្លាតឆ្ងាយពីសម័យព្រះពុទ្ធ។ សេរីភាព(emanci-pation)របស់ស្ត្រីពោលគឺការស្វែងរកសេរីភាព និងសមភាព បានសម្រេច

ជំហានដ៏ធំធេងជាពិសេសនៅបស្ចឹមប្រទេស។ នេះបង្កើតជាលទ្ធផលនៃទំនោរ និងការគិតសម័យទំនើប ហើយការអប់រំសម័យទំនើបសម្រាប់ ស្ត្រី សុទ្ធតែបានសិក្សាខ្ពស់ៗទាំងអស់។

Susan B. Anthonyជាអ្នកត្រួសត្រាយជាតិអាមេរិកកាំងម្នាក់បាននិយាយពី សមភាពចំពោះ ស្ត្រី នៅក្នុងឆ្នាំ១៨ ៤៨ មានរយៈពេលជាង១៤៨ឆ្នាំមកហើយ។ ព្រោះនៅពេលនោះចលនានិងការតស៊ូ ដោយមានការលំអៀងយ៉ាងធំធេង បានចម្រើនទៅមុខយ៉ាងលំបាកក្រោម ស្ត្រី អ្នកត្រួសត្រាយផ្សេងៗ និង អង្គការស្ត្រី។ មនុស្សទាំងនេះមានជំនឿថា ស្ត្រី មានតួនាទីមួយដែលត្រូវសម្តែងនៅក្នុងមិត្តភាពស្នេហាជាតិជាមួយនឹង សហបុរស (menfolk) ក្នុងការផ្តល់វិភាគទានដល់ការស្ថាបនាពិភពលោកដ៏ប្រសើរមួយតាមរយៈសង្គមនិងប្រទេសល្អប្រសើរមួយ។

ចាប់តាំងពីឆ្នាំ១៨៤៨ មានចលនាដែលបានរៀបចំដោយប្រជាប្រិយសម្រាប់ ឱកាសអប់រំសមភាពពោលគឺសិទ្ធិនយោបាយសមភាព និងសមភាពសេដ្ឋកិច្ចសម្រាប់ស្ត្រី។ នៅខាងបស្ចឹមប្រទេសឋានៈស្ត្រីត្រូវបានធ្វើឱ្យប្រសើរឡើង ដោយលក្ខខណ្ឌដែលបានបង្កើតឡើងដោយបដិវត្តន៍ឧស្សាហកម្មចលនាមនុស្សនិយម និង ចលនារបស់ ស្ត្រី ដើម្បី សមភាព។ ប៉ុន្តែនៅ អាស៊ី និងប្រទេសដទៃៗទៀតដែលមិនទាន់រីកចម្រើនខាងឧស្សាហកម្មនៅឡើយការផ្លាស់ប្តូរត្រូវបានបង្កើត ឡើងដោយអ្នកកែទម្រង់ដោយមានជីវប្រវត្តិសាសនាដ៏រឹងមាំ។

នៅក្នុងឆ្នាំ ៥0 ដល់ ៦0 ក្រោយ គឺជាកំណើនពិតមួយនៅក្នុងការចូលរួមរបស់ ស្ត្រី នៅក្នុងជីវិតសេដ្ឋកិច្ចសង្គម ក៏ដូចជា ជីវិតនយោបាយនៃប្រទេសរៀងៗខ្លួនរបស់ពួកគេ។ ជោគជ័យបែបនេះត្រូវសម្រេចបានដោយ ស្ត្រី ថ្មីៗនៅក្នុងវិស័យរៀងៗខ្លួនរបស់ពួកគេ ពោលគឺនៅក្នុងវិទ្យាសាស្ត្រសង្គម នៅក្នុងពាណិជ្ជកម្ម នៅក្នុងសេដ្ឋកិច្ច និងនៅក្នុង វិស័យនយោបាយអាចរាប់ជា បាតុភូត។ ជាការគួរឱ្យហួសចិត្តបើទោះជា ស្ត្រីមួយចំនួនបានឈាន ដល់កម្រិតកំពូលនៅក្នុងសមរភូមិនយោបាយជានាយករដ្ឋមន្ត្រីដឹកនាំប្រទេសនៅក្នុងប្រទេសជាក់ស្តែងដទៃទៀតសហការ លិក (contemporaries) របស់ពួកគេត្រូវបានផ្តល់សិទ្ធិបោះឆ្នោត។ បើទោះជាប្រទេសភាគច្រើនឥឡូវនេះបានទទួលយកឥរិយាបថកាន់តែយុត្តិធម៌ហើយបានបើកទូលាយដល់ឱកាសអប់រំនិងវិជ្ជាជីវៈចំពោះ ស្ត្រីបទពិសោធន៍មិនសប្បាយ និងការរើសអើងដែលពួកគេត្រូវតែដាក់ចូលគ្នាជាមួយនឹងការប្រកួតប្រជែង និងការភ័យខ្លាចដែលមានប៉ុន្តែ ផ្នែកនៃឥរិយាបថទូទៅ

នៅនឹងនៅឡើយ ។វាគឺជាការសម្តែងមិនអស់សេចក្តីមួយដែលត្រូវនិយាយថា ទម្រង់ជាក់ស្តែង នៃការរើសអើងនៅតែមានអត្ថិភាពប្រឆាំងចំពោះ ស្ត្រី នៅឡើយ ។

សកម្មភាពអន្តរជាតិដើម្បីលើកឋានៈស្ត្រី បានចាប់ផ្តើមឡើងនៅលើវិថីតូច មួយជាមួយនឹង សម្ព័ន្ធប្រជាជាតិ លែងដំណើរការសព្វថ្ងៃ (the now defunct League of Nations) និយាយដោយខ្លីគឺក្រោយសង្គ្រាមលោកលើកទី១នេះឯង ។ជាបន្តបន្ទាប់ធម្មនុញ្ញសហប្រជាជាតិ បានបន្តផ្តល់គោលការណ៍ សមភាពនិង សេរីភាពដល់គ្រប់ ស្ត្រីទាំងអស់ ។ គណៈកម្មការទៅលើឋានៈស្ត្រី ពោលគឺអង្គការសហប្រជាជាតិបានស្ទង់មើលពីបញ្ហារើសអើងដែលផ្អែកទៅលើ ភេទ ហើយបានពិភាក្សាបញ្ហាដែលទាក់ទងទៅ នឹងសិទ្ធិនយោបាយរបស់ស្ត្រីចំណាយសមភាពសម្រាប់ការងារសមភាពឋានៈស្ត្រីនៅក្នុងច្បាប់សាធារណៈសញ្ជាតិ នៃស្ត្រីរៀបការឱកាសសេដ្ឋកិច្ច និង ការអប់រំ សម្រាប់ ស្ត្រី ជំនួយការបច្ចេកទេស និងការចូលរួមដោយស្ត្រី ។

បើទោះជាករណីជាច្រើនត្រូវបានគេបំពេញ តាមរយៈចលនាទាមទារសិទ្ធិបោះឆ្នោតរបស់ស្ត្រីទាំងនេះ និងអង្គការអន្តរជាតិនៅក្នុងទំនាក់ទំនងចំពោះការចូលរួមរបស់ ស្ត្រីធំៗ នៅក្នុង វិស័យនយោបាយសេដ្ឋកិច្ច និង សង្គម ពោលគឺ បញ្ហានៃសេរីភាពពិត បានដោះស្រាយ ។

**សេរីភាពនៅក្នុងខ្លឹមសារព្រះពុទ្ធសាសនា** (Freedom in the Buddhist Sense)

សេរីភាពពិតគឺ សេរីភាព នៃការរួចផុតពី ទម្រង់សេវភាពសព្វយ៉ាង (all forms of bondage) ។ គេអាចសម្រេចវាបានតែតាមរយៈ ការអភិវឌ្ឍនផ្លូវចិត្តដោយសមរម្យ និងការធ្វើឱ្យចិត្តផ្ទាល់របស់គេ បរិសុទ្ធពោលគឺការសំអាត ខ្លួនគេ ពី ភាពសៅហ្មងសព្វយ៉ាងនៃសេចក្តីលោភៈទោសៈនិងមោហៈ ។ គ្មានការពិភាក្សាសាធារណៈ ការចង្អុលបង្ហាញ និងធម្មនុញ្ញសាកលអាចធ្វើឱ្យ សេរីភាពកើតមានដោយពេញបរិបូណ៌នោះឡើយ ។ ទាំងនេះអាចគ្រាន់តែ សម្រេចបានតាមរយៈការព្យាយាមផ្ទាល់របស់គេនិងការយកចិត្តទុកដាក់តាមរយៈការប្រតិបត្តិ ចម្រើនភាវនា ដោយទៀងទាត់តាម ព្រះពុទ្ធបង្រៀន ។

ព្រះពុទ្ធក្នុងការលើកពីហេតុរបស់ ស្ត្រីត្រូវបានគេគិតជាការដោះលែងលើកទី១របស់ ស្ត្រី ហើយក៏ជាជា អ្នកទ្រទ្រង់មាគ៌ាជីវិតប្រជាធិបតេយ្យ ។ នៅក្នុង ព្រះពុទ្ធ-ព្រះធម៌ ដែលស្ត្រីមិនត្រូវបានគេស្អប់ និងមើលងាយ ប៉ុន្តែត្រូវបានផ្តល់ឱ្យជាមួយនឹងបុរសនៅក្នុង សេចក្តីព្យាយាមផ្លូវចិត្ត ដើម្បីសម្រេចបានគតិបណ្ឌិត និងសេរីភាព ។

## ៣. តើសាសនាអាចនាំមកនូវសន្តិភាពឬទេ?

(Can Religion Bring Peace) By Ven.Dr.K. Sri Dhammananda

**ភាពផ្សេងគ្នាក្នុងការបកស្រាយ** (Difference of Interpretation)

សាសនា និងសន្តិភាពគឺជាវាក្យស័ព្ទពីរដែលអាចដាក់និយមន័យ និងបកស្រាយដោយមនុស្សផ្សេងគ្នា ដោយអាស្រ័យលើជំនឿសាសនារបស់គេរៀងខ្លួន និងអាស្រ័យលើកម្រិតនៃការយល់ផ្សេងៗគ្នា ។

អ្នកប្រាជ្ញ និងទស្សនវិទូទាំងឡាយបានមើលឃើញសាសនាក្នុងន័យផ្សេងៗគ្នា ។ អ្នកខ្លះបានដាក់និយមន័យឱ្យសាសនាក្នុងន័យចង្អៀតហើយមានកម្រិត ចំណែកអ្នកខ្លះទៀត បានផ្តល់ន័យទូលាយជាង ។

វចនានុក្រម Oxford កំណត់និយមន័យសាសនាថា ជាប្រព័ន្ធនៃជំនឿ និងសក្ការៈ ការទទួលស្គាល់ របស់មនុស្ស ចំពោះតួអង្គព្រះដែលគេត្រូវតែគោរពស្តាប់បង្គាប់ និងផលនៃការទទួលស្គាល់នោះទៅលើអាកប្បកិរិយារបស់មនុស្ស ។

*តូម៉ាសផែន* (Thomas Paine) ទស្សនវិទូអង់គ្លេស បាននិយាយថា " ពិភពលោកគឺជាប្រទេសរបស់ខ្ញុំ ។ មនុស្សជាតិគឺជាបងប្អូនរបស់ខ្ញុំ ហើយការធ្វើល្អគឺជាសាសនារបស់ខ្ញុំ ។ ឥរិយាបថបែបនោះចំពោះសាសនានិងពិភពលោកមានសារៈសំខាន់ក្នុងការនាំមកនូវសន្តិភាពនិងភាពសុខដុមចំពោះពិភពដែលយើងរស់នៅ ។

*អេច្ស ជី វែល* (H.G. Wells) និយាយថា "សាសនាគឺជាស្នូលនៃការអប់រំរបស់យើង ដែលកំណត់ការប្រព្រឹត្តផ្នែក គំនិតប្រាជ្ញារបស់យើង " ។ ចំណែកទស្សនវិទូជាតិអាឡឺម៉ង់ដ៏ល្បីល្បាញអ៊ីម៉ានុយ អែលកាន្ត (Emmanuel Kant)" សាសនា គឺជាការទទួលស្គាល់គោលការណ៍សីលធម៌របស់យើងថា ជាច្បាប់ ដែលមិនត្រូវប្រព្រឹត្តកន្លង " ។

រីឯកាល់ម៉ាក្ស (Karl Marx) មើលឃើញសាសនាថាជា "អាភៀនរបស់មនុស្ស" ដែលផ្តល់ដល់មនុស្សនូវភាពអស្ចារ្យ ទៅលើតថភាព ការសង្ឃឹមបែបមមើមមាយទៅលើសុភមង្គលក្នុងជីវិតក្រោយមរណភាព ដែលនឹងទូទាត់ឱ្យអំពើអាក្រក់ ឃោរឃៅ នៃអត្ថិភាពបច្ចុប្បន្ន ។ ចំពោះអង់ហ្គែល(Engels)"សាសនាគ្មានអ្វីក្រៅពីការគិតចម្លែកក្នុងគំនិតរបស់មនុស្សអំពីកម្លាំងខាងក្រៅទាំងឡាយ ដែលត្រួតត្រាជីវិតជាតិមុនរបស់គេ" ។

**គោលដៅគឺតែមួយ** (The Goal is One)

ទោះជាមានភាពខុសគ្នា ហើយមានការបកស្រាយជាច្រើនក៏ដោយ ក៏សាសនាទាំងអស់យល់ស្រប ដោយគ្មានការប្រែប្រួលថា សន្តិភាពគឺជាភាពចាំបាច់ហើយសាសនាដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍន៍សន្តិភាពរបស់បុគ្គល និងគ្រួសារសង្គមប្រទេសជាតិ និងពិភពលោក។

**តម្រូវការនៃការអប់រំសាសនា** (Need for Religious Education)

ដោយសារពិភពលោករំកិលខ្លួនចូលកាន់តែជ្រៅទៅៗ ទៅក្នុងយុគសម័យនៃការជ្រួលច្របល់ដោយអាវុធយុទ្ធភ័ណ្ឌ ប្រកបដោយគ្រោះថ្នាក់និងដ៏ស្មុគស្មាញ អមទៅដោយវិបត្តិភ័យ និងការស្រុតចុះនៃសីលធម៌ បច្ចុប្បន្នតម្រូវការនៃការអប់រំ សាសនាមានកម្រិតខ្ពស់ជាងអតីតកាល ។ការព្រួយបារម្ភ និងភាពខ្វល់ខ្វាយដែលកើតពីភាពមិនប្រាកដប្រជាចំពោះអនាគតបង្កើតឡើងនូវភាពតានតឹងនិងភាពហួសកម្លាំងនៃចិត្តរបស់មនុស្ស ។វិបត្តិទាំងនេះអាចជំនះបានដោយការយល់ដឹងដ៏ត្រឹមត្រូវចំពោះធម្មជាតិនៃចិត្ត ដែលជាប្រធានវិស័យដែលនៅដាច់ឆ្ងាយពីប្រព័ន្ធអប់រំតម្រង់ទិសទៅរកការសិក្សាស្រាវជ្រាវ និងសម្ភារៈនិយមនៅសាលារៀន និងស្ថាប័នបន្តបន្ទាប់នាបច្ចុប្បន្ននេះ។ សាសនាជានិច្ចកាល ជាគន្លឹះក្នុងការរក្សាសន្តិភាព និងការផ្តល់នូវភាពកក់ក្តៅផ្លូវចិត្តក្នុងកាលៈទេសៈត្រូវសង្គ្រោះបន្ទាន់ តួយ៉ាងដូចជាក្នុងពេលមានវិបត្តិភ័យផ្សេងៗ ឬក្នុងពេលមានការបំពានដោយអ្នកឈ្លានពាន និង ការរំខានដទៃទៀត។

មនុស្សត្រូវការសាសនា ដូចត្រូវការយុថ្កានៅពេលចតនាវានៅក្នុងផែ។ ចិត្តមនុស្ស ដែលសាវ៉ា និងញាប់ញ័រ តាមសភាពរបស់វា តែងត្រូវការបែបបទនៃជំនួយណាមួយដើម្បី រក្សាវាឱ្យនៅនឹងនំ និងម៉ឺងម៉ាត់ដើម្បីជាដំណោះស្រាយ ក្នុងការដើរតាមឧត្តមគតិរបស់ខ្លួន ក្នុងជីវិតរស់នៅ។ ដោយការទទួលយក ពាក្យប្រៀនប្រដៅរបស់សាសនាជាក់លាក់ ណាមួយ មនុស្សទប់ចិត្តរបស់ខ្លួនឱ្យនៅជាប់នឹងពាក្យប្រៀនប្រដៅនោះ ដើម្បីរៀបចំខ្លួនឱ្យស្របតាមមេរៀនដ៏ត្រឹមត្រង់ ប្រសើរជាងកាលពីគេនៅជាអ្នកគិតដ៏សេរីឬជាឆ្កែចចក ឯកោមួយក្បាល។ ដូចគ្នានឹងនាវាចងជាប់ក្នុងផែ ដែលអាចទ្រាំទ្របានមិនថា ខ្យល់បក់ខ្លាំងឬព្យុះសង្ឃរាទាំងឡាយយ៉ាងណាចិត្តដែលចងជាប់ដោយគោលការណ៍ទាំងឡាយរបស់សាសនា ក៏អាចធនទ្រាំនឹងការប៉ុនប៉ងដ៏ខ្លាំងក្លាហើយ និងការរំខានផ្នែកចិត្តគំនិតដទៃទៀតក្នុងជីវិតបានយ៉ាងនោះដែរ។

ដូចនេះការអប់រំសាសនាបម្រើឱ្យការរក្សាលំ នឹងផ្លូវចិត្តអភិវឌ្ឍទម្ងន់ស្មើខាងផ្លូវចិត្តដោយជៀសវាងបានរាល់ទម្រង់នៃភាពហួសហេតុ ។ ការអប់រំសាសនានាំទៅរកការយល់ច្បាស់ អំពី

ធម្មជាតិពិតនៃជីវិតនិង មរណភាព និងអំពីវត្តមាននិងអវត្តមានពិភពលោក។ មានតម្រូវការក្នុងការផ្តល់ការយល់ដឹង និងការយល់ ធ្លុះកាន់តែស៊ីជម្រៅទៅក្នុងធម្មជាតិ នៃគុណធម៌ខ្ពង់ខ្ពស់របស់ជីវិត ខ្លឹមសារសីលធម៌និងចរិយាធម៌របស់វាដែល នឹងជួយជម្រុះជម្រះលំងប់ (religious fanaticism = អធិមុត្តិនិយម) និងបុរេវិនិច្ឆ័យសាសនា ដោយត្រួសត្រាយ ផ្លូវសម្រាប់ភាពចុះសម្រុងនៃសាសនា។

**តើអ្នកណាជាអ្នក (សាសនិក) សាសនា ?** (Who is a Religious Person?)

អ្នកកាន់សាសនាម្នាក់ គេទទួលស្គាល់ដោយអាកប្បកិរិយាសីលធម៌របស់គេ ទាំងក្នុងពាក្យសម្តី និងក្នុងការប្រព្រឹត្ត។ តាមទស្សនៈរបស់ព្រះពុទ្ធ អ្នកដែលធ្វើខ្លួនឱ្យបរិសុទ្ធគ្រប់ជ្រុងជ្រោយដោយខ្លួនឯងដោយមានកុសលកម្មក្នុងកាយវាចាចិត្ត គឺជាអ្នកកាន់សាសនាពិតប្រាកដ។ គេពិបាកនឹងចាត់ទុកមនុស្សម្នាក់ថា ជាអ្នកកាន់សាសនា ដោយគ្រាន់តែសំគាល់ត្រង់គេ ទៅវត្តអារាមឬទីសក្ការបូជា ហើយបន់ស្រន់សុំសេចក្តីសុខដល់ខ្លួនគេ និងក្រុមគ្រួសារគេ ហើយគេមានការគោរពចំពោះអ្នកដទៃដោយតិចតួចតែប៉ុណ្ណោះ។ ការប្រព្រឹត្តរបស់គេកើតឡើងដោយចិត្តចង្អៀតចង្អល់ និងអាត្មានិយម។

ម្យ៉ាងវិញទៀតអាចមានបុគ្គលខ្លះ ដែលមិនបានទាំងចូលរួមក្នុងពិធីបុណ្យទាននានាទាំងបន់ស្រន់នៅទីកន្លែងសក្ការបូជា តែយ៉ាងណាក៏ដោយ គេបានដើរតាមបទបញ្ញត្តិសាសនាដោយរស់នៅក្នុងជីវភាពស្ងប់ស្ងាត់ ព្យាយាមជំនះចំណុចខ្វះខាតផ្ទាល់របស់គេ ហើយមានចិត្តករុណាអធ្យាស្រ័យនិងយល់ដល់អ្នកដទៃ។ បុគ្គលប្រភេទនេះ អាចត្រូវចាត់ថា ជាអ្នកកាន់សាសនាបានច្រើនជាងប្រភេទអ្នកដែលបានរៀបរាប់ខាងលើ។

ឧត្តមគតិសម្រាប់អ្នកកាន់សាសនាណាម្នាក់ គឺជាជីវភាពសាមញ្ញនិងសុភាពរាបសា ដែលតាមរយៈនោះ គេអាចរួច ចាកផុតពីសភាពវិបល្លាសដោយកម្មវត្ថុសម្ភារៈណាមួយ (ហើយនិងហេតុជំរុញលាក់លៀមណាមួយ) ហើយដោយហេតុនោះ គេអាចបូជាថាមពលរបស់គេចំពោះការអប់រំចិត្តរបស់គេដើម្បីជាប្រយោជន៍ដល់ខ្លួនគេ និង អ្នកដទៃ។

**សុពលភាពរបស់សាសនា** (Validity of Religion)

ដោយគ្រាន់តែសង្កេតមើល ការប្រតិបត្តិខាងក្រៅក្នុងនាមសាសនា គេមិនអាចយល់ពីសុពលភាព របស់សាសនាជាក់លាក់ណាមួយបានទេ ពីព្រោះអ្នកដែលមិនមានការអប់រំ និងមិនបានទទួលព័ត៌មានអាច ប្រតិបត្តិតាមប្រពៃណីមួយចំនួន ដោយមិនយល់ន័យ ហើយយល់ថា

វាជាការប្រតិបត្តិត្រឹមត្រូវ ។ ដើម្បីយល់ពី ធម្មជាតិពិតនៃសាសនាជាក់លាក់ណាមួយ គេចាំបាច់ត្រូវសិក្សាពីបទបញ្ញត្តិដើមរបស់អ្នកបង្កើតសាសនា ដោយដើរទៅរកប្រភពដើមដ៏ឆ្ងាយតាមតែអាចរកបាន ។

តម្លៃពិតនៃសាសនាអាចត្រូវយល់នៅក្នុងទស្សនវិស័យត្រឹមត្រូវ អំពីគោលបញ្ញត្តិប្រកបដោយវិចារណញ្ញាណនិងភាពពិរោះពិសា ដែលផ្តល់ការណែនាំជាក់ស្តែងជាប្រព័ន្ធអំពីវិធីកែប្រែខ្លួនឯងដើម្បីបង្កលក្ខណៈ ឱ្យគេរស់នៅក្នុងជីវភាព សាមញ្ញ សុភាពរាបសា និងតាមមាគ៌ា សីលធម៌ប្រកបដោយសន្តិភាពនិងសេចក្តីរីករាយក្នុងខណៈនេះ ។

ការបង្ហាញអំពីឫទ្ធានុភាពដ៏អាថ៌កំបាំង ឬ អច្ឆរិយៈ ការសន្យាអំពីរមណីយភាពនៃស្ថានសួគ៌ក្រោយពីមរណភាព និងការប្រតិបត្តិបែបអធិធម្មជាតិ គឺគ្រាន់តែជាការបំពុលសាសនាប៉ុណ្ណោះដោយលាបលនចិត្ត របស់មហាជននូវការរំភើបចិត្ត ការចាប់ចិត្តនិងជំនឿងងឹតងងុល ។ អំពើទាំងនោះមិននាំទៅរកការលុបបំបាត់អវិសុទ្ធភាពខាងផ្លូវបញ្ញាទេ មានតែការបម្រើបំណងត្រាយផ្លូវដល់ជនល្ងង់ខ្លៅមែនទែន ដែលលុះដោយ អំណាចនៃឫទ្ធិអំណាច កេរ្តិ៍ឈ្មោះ កិត្តិស័ព្ទ និងកាមរាគៈក្នុងលោកនេះ ។

នៅក្នុងសុន្ទរកថា ជាសាធារណៈរបស់លោក *ស្វាមី វិវេគនន្ទ* បានលើកឡើងថា " បទពិសោធន៍ជា ប្រភពតែមួយគត់នៃចំណេះដឹង ។ វិធីដូចៗគ្នានៃការអង្កេតដែលយើងអនុវត្តចំពោះវិទ្យាសាស្ត្រ និងចំពោះចំណេះដឹងខាងក្រៅ គួរត្រូវបាន អនុវត្តចំពោះសាសនា។ ប្រសិនបើសាសនាមួយត្រូវបានបំផ្លាញដោយការ អង្កេតបែបនោះមានន័យថា សាសនាគឺគ្មានអ្វី ទាំងអស់ក្រៅពីការប្រជុំជំនឿអធិធម្មជាតិដែលគ្មានប្រយោជន៍ គ្មានតម្លៃ ហើយសាសនានោះ កាន់តែបាត់បង់កាន់តែប្រសើរ ។ហេតុអ្វីសាសនាទាំងឡាយត្រូវអះអាងថា ពួកគេត្រូវតែទ្រទ្រង់ដោយទស្សនៈហេតុផល ដែលគ្មាននរណាម្នាក់យល់ដឹង...ជាការប្រសើរដែលមនុស្ស ជាតិគួរតែក្លាយខ្លួនជាអ្នកអទេវនិយមដោយដើរតាមហេតុផល ជាជាងមានជំនឿដោយងងឹតងងុលលើអាទិទេពរាប់រយលានអង្គ ដែលស្ថិតនៅលើអំណាចបុគ្គលណាម្នាក់ ។

ដោយឡែកឯការជៀសវាងភាពហួសហេតុនៃជំនឿដោយងងឹតងងុល និងលទ្ធិសង្ស័យនិយម តាមបែបបញ្ញាអ្នក កាន់សាសនាគួរតែស្វែងរកសច្ចភាពដោយហេតុផល និងបញ្ញា ។

**វិធីត្រឹមត្រូវតាមវិចារណញ្ញាណដើម្បីបង្ហាញសាសនាមួយ** (Rational Method to Introduce a Religion)

យុគសម័យនៃលទ្ធិអធិធម្មជាតិ និងលទ្ធិអាថិកំបាំងកំពុងតែបើកផ្លូវយ៉ាងរហ័សឱ្យការរុករកហើយនិងចំណេះដឹងវិទ្យាសាស្ត្រ ។

ទោះបីវិធីសាស្ត្របែបបុព្វកាលនៃការបង្កើតជំនឿ បានបម្រើឱ្យគោលបំណងបំបាត់សេចក្តីភ័យខ្លាច និងអសន្តិសុខបង្ក ដោយអ្វីដែលគេមិនស្គាល់ អំពីចិត្តគំនិតរបស់មនុស្ស បុព្វកាលជាច្រើននៅតំបន់ផ្សេងៗនៃពិភពលោកក៏ដោយ ក៏វិធីសាស្ត្រដដែលនេះមិនអាចអនុវត្តយូរអង្វែងតទៅទៀតបានទេ ចំពោះចិត្តគំនិតមនុស្សសម័យទំនើប។

អាស្រ័យដោយសេចក្តីត្រូវការទស្សនវិស័យ ប្រកបដោយវិចារណញ្ញាណកាន់តែជ្រាលជ្រៅនាយករដ្ឋមន្ត្រីចុង ក្រោយរបស់ប្រទេសឥណ្ឌាស្រ៊ីយ៉ាវ៉ាហាឡាលនេរុ(Shri Jawarharlal Nehru)បាននិយាយថាគេគួរតែព្យាយាមជៀសវាងបញ្ហាសំខាន់បីនៅក្នុងការបង្ហាញសាសនា។ នោះគឺសំណេរទិព្វ គំនិតព្រះអាទិទេពនិងជាតិមុខ។ លោកបានចង្អុល បង្ហាញថា ប្រសិនបើគេបង្ហាញសាសនាមួយដោយប្រើគោលណាមួយក្នុង ចំណោមគោលទាំងបី ពេលនោះអ្នកដើរតាមនឹង ហាក់ដូចជាមានទំនុកចិត្តលើគោលការណ៍នោះ ហើយទទួលស្គាល់សាសនានោះ ដោយមិនប្រើប្រាមពលនៃការគិតគូរពិ ចារណារបស់ខ្លួនទេ។ គួរតែមានការណែនាំឱ្យ មនុស្សស្វែងរកសច្ចភាពតាមរយៈចំណេះដឹងនិងពិសោធន៍របស់គេ ដោយការគិតសេរី។ នេះពិតជាវិធីសាស្ត្រប្រកបដោយឧត្តមគតិក្នុងការបង្ហាញសាសនាមួយ ពីព្រោះវាជៀសវាងបានប្រភេទ ផ្សេងៗនៃបុរេវិនិច្ឆ័យ ជំនឿងងឹតងងុល និង សភាពមិនយល់ដឹងចំពោះសាសនា។

លោកនេរុ ក៏បានអធិប្បាយផងដែរថាគេគួរតែកុំទទួលយកអ្វីៗទាំងអស់ដែលមានសរសេរនៅក្នុងគម្ពីរពិសិដ្ឋណាមួយដែលមាននាមសាសនា។ លោកបានអះអាងថាគោលការណ៍ សំខាន់នៃសាសនារបស់លោកគឺ កុសលឱ្យកំណើតកុសលអកុសលឱ្យកំណើតអកុសល"។ ក្នុងការឱ្យតម្លៃវិធីវិចារណញ្ញាណរបស់ព្រះពុទ្ធសាសនា នៅក្នុងសៀវភៅរបស់លោកអំពី "ការរកឃើញរបស់ឥណ្ឌា"នរុបានសរសេរថា"ព្រះពុទ្ធមានសេចក្តីក្លាហានក្នុងការចង្អុលបង្ហាញភាពទោមនស្សរបស់សាសនាដែលមានប្រជាប្រិយ ជំនឿអរូបិយ៍ ពិធីសាសនា និងរបររកស៊ីរបស់ អាចារ្យ។ ព្រះអង្គមិនចាប់អារម្មណ៍នឹងទស្សនវិស័យអស្តិរូប និងទេវវិទ្យា ភាពអច្ឆរិយៈការបង្ហាញឱ្យដឹង (ប្រកាសនា) និងទំនាក់ទំនងអធិធម្មជាតិទេ។ សេចក្តីប្រកាស របស់ព្រះអង្គ គឺដើម្បីវិចារណញ្ញាណ ភាពសមហេតុផល (logic) និងបទពិសោធន៍។ ការសង្កត់ន័យរបស់ ព្រះអង្គស្ថិតនៅត្រង់សីលធម៌ ហើយវិធីរបស់លោកគឺជាវិធីមួយនៃការវិភាគចិត្តវិទ្យា ដែលជា ចិត្តវិទ្យាគ្មាន

ព្រលឹង។ វិធីសរុបរបស់ព្រះ អង្គប្រៀបប្រដូចទៅនឹងការស្រូបយកខ្យល់ បរិសុទ្ធ ពីភ្នំ បន្ទាប់ពីមានខ្យល់អាប់អួរនៃការពិចារណាបែបអស្លីល។"

លោកបន្តនិយាយថា ព្រះពុទ្ធបានបង្រៀនអំពីអ្វីដែលឧត្តុង្គឧត្តមជាងលទ្ធិ និងគម្ពីរទាំងអស់ ហើយពាក្យពេចន៍ចុង ក្រោយរបស់ព្រះអង្គបានធ្វើឱ្យរំភើបដល់មនុស្ស ជាតិជាច្រើនយុគសម័យ។ ប្រហែលជាមិនមានពេលណាមួយនៅក្នុងប្រវត្តិសាស្ត្រកន្លងមក ដែលគេត្រូវការពាក្យពេចន៍អំពីសន្តិភាពរបស់ព្រះអង្គសម្រាប់មនុស្សជាតិ ដែលកំពុងទទួលរងទុក្ខលំបាកនិងការបំពារបំពានឱ្យជាងសម័យនេះទេ។

ក្នុងការនិយាយអំពីសាសនានៅអនាគត *អាល់ប៊ែ អាំងស្តាំង* ( Albert Einstein) និយាយថា "សាសនាពេលនោះ គួរតែឆ្លងហួសពីកម្រិតនៃព្រះជាមនុស្ស ហើយជៀសវាងពីគម្ពីរនិយម និងទេវវិទ្យា។ ដោយគ្របដណ្តប់ទាំងធម្មជាតិ និងវិញ្ញាណ សាសនាគួរតែផ្អែកលើវិចារណញ្ញាណបែបសាសនា ដែលកើតឡើងពីបទពិសោធន៍នៃអ្វីៗ ទាំងអស់ទាំងខាងធម្មជាតិទាំងខាងវិញ្ញាណជាឯកភាពមានន័យមួយ។ ព្រះពុទ្ធសាសនាមានចម្លើយចំពោះការពណ៌នានេះ។"

វិធីដែលអនុវត្ត ដោយព្រះពុទ្ធមានលក្ខណៈផ្លែកតែឯង នៅក្នុងកំណត់ប្រវត្តិសាស្ត្រ (វស្សប្បវត្តិ) នៃប្រវត្តិសាសនា។ ព្រះអង្គបានទូន្មានពុទ្ធបរិស័ទរបស់ព្រះអង្គ កុំឱ្យទទួលយកព្រះធម៌ដោយគ្រាន់តែក្រាបសំពះប៉ុណ្ណោះ ប៉ុន្តែត្រូវទទួលយកបន្ទាប់ពីបានអង្កេតពិនិត្យពិច័យរួចហើយ។

ព្រះពុទ្ធបានទូន្មានអ្នកទាំងឡាយណា ដែលបានចូលខ្លួនទៅរកព្រះអង្គដើម្បីកាន់យកសាសនាព្រះអង្គថា ចូរកុំប្រញាប់ប្រញាល់កាន់យកដូច្នេះឡើយ ប៉ុន្តែសុំឱ្យគិតគូរពិចារណាដោយហ្មត់ចត់ថា តើសាសនារបស់ព្រះអង្គពិតជានាំឱ្យគេអាចប្រតិបត្តិបានឬយ៉ាងណា។ប្រសិនបើគេមានជំនឿជាក់លើពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ហើយទើបព្រះអង្គទទួលស្គាល់គេជាបរិស័ទ។

សូម្បីបានក្លាយជាបរិស័ទរបស់ព្រះអង្គហើយក៏ដោយ ក៏ព្រះអង្គមិនបានរារាំងពួកគេ មិនឱ្យគាំទ្រគ្រូ សាសនាពីមុនៗ មករបស់គេដែរ។ ត្រង់នេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះពុទ្ធផ្តល់សេរីភាពដ៏ទូលំទូលាយដល់បរិស័ទរបស់ព្រះអង្គ ដោយមិនចិញ្ចឹមមទុកសេចក្តីច្រណែននិន្ទាណាមួយចំពោះសាសនាដទៃទៀយ។

ធី.អេច.ហ៊ុចស្លេ (T.H. Huxley)បានកត់សំគាល់ថា " ព្រះពុទ្ធសាសនា តាមភាពបរិសុទ្ធខាងដើម សាសនានេះ មិនមានអ្វីក្រៅពីការថ្វាយបង្គំគោរពពាក្យទូន្មាន ហើយមិនដែលស្វែងរកការជួយជ្រោមជ្រែង ពីខាងអាណាចក្រផ្សព្វផ្សាយលើភាគច្រើនគួរកត់សំគាល់នៃពិភពចាស់យ៉ាងលឿនអស្ចារ្យ ហើយមានជំហរនឹងថ្កល់ដោយមានមូលដ្ឋានលាយ បញ្ចូលជំនឿអធិធម្មជាតិ ដែលជាជំនឿមានពីមុនមករបស់មនុស្សជាតិមួយភាគធំ ។"

អាស្រ័យដោយការសង្កេតរបស់*អាឡិចសិនដឺរឃុន្និញហេម*( Alexander Cunningham) អ្នកបុរាណវត្ថុវិទ្យា"ពុទ្ធសាសនិកជនទាំងឡាយ បានផ្សព្វផ្សាយសាសនារបស់គេ ដោយសម្លេងបញ្ចុះបញ្ចូលរបស់សាសនទូតឯសាសនិកនៃសាសនាដទៃទៀតជាច្រើនដោយចុងដាវឥតមេត្តា។ វិជ្ជាជីវៈបង្ហូរឈាមរបស់សាសនាដទៃភ្លឺច្រាលដោយអណ្តាតភ្លើងក្រ ហាមឆ្អិនឆ្អៅនៃធានី កំពុងឆេះឆាប ឯសន្តិវឌ្ឍនភាពរបស់ពុទ្ធសាសនិកបានតាំងបំភ្លឺដោយទឹកមុខជ្រះថ្លា របស់អ្នកជំងឺនៅក្នុងមន្ទីរពេទ្យអារាម ដោយសំណើចរីករាយរបស់ អ្នកដំណើរដែលឈប់សម្រាកនៅសាលាឆទានតាមដងផ្លូវ ។

តាម *រីវ ជេ ធី សាន់ដឺលែន* (Rev.J.T. Sunderland) ព្រះពុទ្ធសាសនាបានអប់រំសន្តិភាពកាន់តែ មាំទាំក្នុងចំណោម បរិស័ទ កាន់តែមានប្រសិទ្ធភាពជាងជំនឿលើសាសនាធំៗដទៃទៀតដែលមាននៅក្នុងពិភពលោក នៅក្នុងប្រវត្តិរបស់សាសនា។ ពុទ្ធបរិស័ទមានលំឱនផ្លូវចិត្តច្រើនជាង បើប្រៀបនឹងអ្នកសម្ភារនិយមសម័យនេះ ហើយបានទុកដាក់ចរិតលក្ខណៈ សេវាកម្ម សេចក្តីមេត្តា និងសន្តិភាព នៅពីលើកេរ្តិ៍ឈ្មោះ ទ្រព្យសម្បត្តិ អំណាចខ្ពង់ខ្ពស់ និងសង្គ្រាម ហើយព្រះពុទ្ធសាសនាបានរីកចម្រើនរុងរឿងពេញលេញនៅសម័យនោះ ពីព្រោះព្រះពុទ្ធសាសនាគឺជាសាសនាតែមួយគត់ដែលគ្មានការបង្ហូរឈាម ឬ អំពើហិង្សា។"

**គំរូរបស់ស្តេចអសោក** (Asoka’s Examples)

មានហេតុការណ៍គួរកត់សំគាល់មួយថា ស្តេចអសោកគឺជាស្តេចដែលមានឥទ្ធិពលធំធេងបំផុតនៅ ក្នុងពលីកម្មរបស់ ព្រះអង្គដើម្បីសុខុមាលភាពនៃប្រជារាស្ត្ររបស់ព្រះអង្គ។ ដើម្បីប្រជារាស្ត្រ ព្រះអង្គបានជីក អណ្តូងដើម្បីបានទឹកហូប ដាំ ដើមឈើយកម្លប់ កសាងផ្លូវថ្នល់សួនច្បារសាធារណៈ សួនដំណាំឱសថ មន្ទីរ ពេទ្យមនុស្ស និងមន្ទីរពេទ្យសត្វ។ ដើម្បី បញ្ចូលគតិត្រឹមត្រូវទៅក្នុងអនុរាស្ត្រដែលព្រះអង្គសព្វព្រះទ័យ និង ទទួលបដិសណ្ឋារៈដូចជា បុត្រជាទីស្រឡាញ់របស់ព្រះអង្គ ព្រះអង្គបានឆ្លាក់លើថ្មនិងសសរពាសពេញព្រះរាជាណាចក្រ ដោយព្រះ

បន្ទូលដ៏ខ្ពង់ខ្ពស់អំពីការរស់នៅបែបត្រឹមត្រូវ។ រដ្ឋមន្ត្រីទាំងឡាយ និងបេសកជនទាំងឡាយត្រូវទទួលភារកិច្ចដឹកនាំ និងមើលថែរក្សាវប្បធម៌សីលធម៌។ សង្គាយនាព្រះពុទ្ធសាសនាលើកទី៣ ក៏បានទទួលការឧបត្ថម្ភផងដែរអំពីសំណាក់ព្រះអង្គ។ សាសនទូតទាំងឡាយ ដែលព្រះអង្គបាន បញ្ជូនចេញទៅ ផ្សព្វផ្សាយសាសនានៅនគរជិតឆ្ងាយ បានជួយបង្កើតការជួបប្រាស្រ័យវប្បធម៌អំពីការនាំចូលពីតំបន់ឆ្ងាយ ៗក្នុងពិភពលោកនូវទំនាក់ទំនងអន្តរជាតិនិងសន្តិភាព។

សកម្មភាពរបស់ស្តេចអសោកបានបង្ហាញដោយឥតសង្ស័យថា ព្រះអង្គជាអ្នកទ្រទ្រង់ដែលមានជំនឿស៊ប់លើការ បញ្ចេញកម្លាំងដ៏ខ្លាំងក្លាដើម្បីអំពើដ៏ត្រឹមត្រូវ។ " ការប្រឹងប្រែងដើម្បីសុវត្ថិភាពទូទៅ និងការបំពេញការងារទាន់ពេលវេលា "គឺជាគោលការណ៍ណែនាំចម្បងរបស់ព្រះអង្គ។ ដោយជ្រួតជ្រាបនូវអត្ថន័យនិងស្ថានភាព ប្រតិបត្តិដ៏ប្រសើរព្រះបាទអសោកបានបង្ហាញស្មារតីទ្រទ្រង់ព្រះពុទ្ធសាសនា យ៉ាងខ្ពង់ខ្ពស់បំផុតក្នុងជីវិតរបស់ព្រះអង្គ ដោយធ្វើការងារក្នុងស្មារតីពិតនៃ "ពហុយាន ហិទយៈ ពហុយាន សុខាយ (Bahujana Hitaya, Bahujana Sukhata) ដើម្បីសុវត្ថិភាពនិងសុភមង្គលរបស់ជនភាគច្រើន ដែលជាឧត្តមគតិដែលព្រះពុទ្ធអង្គផ្ទាល់បានអប់រំចំពោះក្រុមសាវ័កហុកសិបអង្គ ដំបូងរបស់ព្រះអង្គ ដែលបានក្រោកឈរជាសាសនទូតដំបូងក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។

ឧត្តមភាពរបស់ស្តេចអសោក ជំរុញឱ្យអេច.ជី វេល (H.G.Wells)ក្នុងស្នាដៃ" គម្រោងនៃប្រវត្តិវិទ្យា "ប្រកាសថា" ក្នុងចំណោមព្រះនាមព្រះរាជារាប់សិបពាន់អង្គ ដែលនៅតាន់តាប់ក្នុងទំព័រប្រវត្តិសាស្ត្រ ឫទ្ធានុភាពដ៏អស្ចារ្យ ភាពសមសួន ភាពស្ងប់ស្ងាត់ ភាពខ្ពង់ខ្ពស់ ។ល។ ព្រះនាម"អសោក" បានរះឡើង ហើយហាក់ដូចជារះឡើងតែមួយអង្គឯង ជាតារាមួយដួង"។

ដោយទទួលការទូន្មានពីស្តេចអសោក យើងគួរមានការប្រឹងប្រែងដើម្បីចេញផុតពី ភាពងងឹតដែលកំពុងតែរុំព័ទ្ធពិភពលោកសព្វថ្ងៃ។

**សាសនា និង សម្ភារនិយម** (Religion and Materialism)

ពពកខ្មៅដ៏ច្រើននៃការជ្រួលច្របល់និងវិបត្តិនៃពិភពលោក អាចមានដានទៅដល់ឱនភាពនៃសាសនា និងការងើបឡើងនៃសម្ភារៈនិយម។

ប្រវត្តិសាស្ត្រមនុស្សជាតិបានបង្ហាញ ភាពញឹកញាប់នៃឱនភាពរបស់ប្រទេសជាតិ ហើយនិងអារ្យធម៌ដែលបំផ្លាញដោយការបង្ខូចសាសនា។ប្រវត្តិវិទូ *អិដវឺដ ជីបិន* (Edward Gibbons) ក្នុង" ប្រវត្តិសាស្ត្រនៃការងើបឡើង និងការធ្លាក់ចុះនៃចក្រភពរ៉ូម៉ាំង" បានបង្ហាញពីកម្រិតបែក

បាក់នៃសាសនាទៅក្នុងចំនួនរាប់មិនអស់នៃទម្រង់ដែលជាមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើន រួមចំណែកធ្វើឱ្យមានឱនភាពនិងការ ដួលរលំចក្រភពរ៉ូម៉ាំង។ មូលហេតុនៃទីក្រុងរ៉ូមអាចជាអារ្យធម៌ទំនើបរបស់យើង។

ដោយដឹងថាគ្រោះថ្នាក់ជិតនឹងកើតមានឡើង មនុស្សគួរតែមានសុភវិនិច្ឆ័យដើម្បីចូលរួមសហប្រតិបត្តិការ ក្នុងការត្រួតពិនិត្យនិងបញ្ចៀសមូលហេតុទាំងឡាយ ដែលអាចបង្កឱ្យមានឱនភាព និងការបែកបាក់សាសនា។

នៅពេលមានការបែកបាក់សាសនា ដោយការប្រកួតប្រជែងប្រកបដោយគ្រោះថ្នាក់ដើម្បីទាក់ទាញឱ្យប្តូរសាសនា លំងប់និយម (fanaticism) និងសង្គ្រាមពិសិដ្ឋ (holy wars) ក៏បន្តធ្វើឱ្យសៅហ្មងទស្សនីយ ភាពសន្តិភាពតាមរយៈសាសនា គោលការណ៍គម្ពីរ (dogmas) និងជំនឿអធិធម្មជាតិក៏បំផ្លាញសុពលភាពនៃ សាសនាដែលបានយកចិត្តទុកដាក់ដល់ ការបង្កើនចំណេះដឹងមិនឈប់ឈរនិងការអង្កេតបែបវិទ្យាសាស្ត្រ។ ភាពមិនប្រែប្រួលទាំងនេះ បង្កើតឱ្យមានការងើបឡើងនៃសម្ភារៈនិយម ដែលបង្កឱ្យមានការបំផ្លាញសីលធម៌ កាន់តែខ្លាំងក្លានៅក្នុងសង្គមមនុស្ស។

**ឧឡារភាពសម្ភារៈ** (Material Progress)

អ្នកឆ្កួតវង្វេង ដែលរត់តាមការកំសាន្តអំណាចកម្មសិទ្ធិក្នុងលោកបាននាំទៅដល់រាល់ទម្រង់នៃភាពឱនថយ ការរើសអើង និងបុរេវិនិច្ឆ័យ ក៏ដូចជាការបង្កើនលេសក្នុងការបំផ្លិចបំផ្លាញដ៏ច្រើនអនេករបស់មនុស្សជាតិ។

អ្វីដែលហៅថាការកំសាន្តបែបទំនើបត្រូវបាន គេចងក្រងឡើងរហូតដល់វាដាស់ឡើងសភាវគតិសត្វ និងការស្រេវស្រើបរាងកាយរបស់អ្នកទស្សនា។ នៅក្រោមឥទ្ធិពលនៃការបំពុលរបៀបនេះ អ្នកទស្សនាបាត់បង់សម្បជញ្ញៈហើយធ្វើ អ្វីៗប្រឆាំងនឹងសុភវិនិច្ឆ័យរបស់គេដោយរំលោភសន្តិភាពនិងសុភមង្គល របស់ជនស្លូតត្រង់ដើម្បីបំពេញតណ្ហាឥន្ទ្រិយ៍របស់ពួកគេ។ ពួកគេបាត់បង់ការគិតធម្មតារបស់ពួកគេ ហើយបដិសេធ ការស្តាប់អ្នកដទៃ ទោះបីពួកគេដឹងថាពួកគេកំពុងតែបំ ផ្លាញជីវិតរបស់ខ្លួនឯង ក៏ដូចជាបំផ្លាញជីវិតរបស់អ្នកដទៃក៏ដោយ។

ចំណង់ហួសហេតុរបស់មនុស្សចំពោះតណ្ហាឥន្ទ្រីយ៍បានបង្កើតនូវសង្គមមានជម្ងឺ ឥតគោលដៅ ដែលនាំទៅដល់ការប្រតិបត្តិអសីលធម៌ អមនសិការនិងស្មោកគ្រោក ដែលជាភាពអាម៉ាសចំពោះអារម្មណ៍ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស។

ការខូចសតិនឹងអំណាចលោកិយ បាននាំប្រជាជាតិទាំងឡាយទៅរកការប្រឡងប្រជែងសព្វាវុធ។ ការបង្កើតថ្មីអាវុធប្រល័យលោកដែលអាចបំផ្លាញ ពិភពលោកក្នុងមួយពព្រិចភ្នែកត្រូវបានអនុវត្តដើម្បីបង្កហិនភាពដោយភាពអត់ឃ្លាន និងភាពក្រីក្រទូទាំងពិភពលោក។ ការច្បាំងគ្នាត្រូវបានចាត់ទុកថា ជាទំនោរសម័យថ្មី ដែលមិនអាចជៀសរួចដោយបង្កវិនាសកម្មដល់ជីវិតមានតម្លៃរាប់លាននាក់។

ការស្រាវជ្រាវស្ថាបនា និងគម្រោងកម្មវិធីលើកកំពស់មនុស្សជាតិ ត្រូវបានចាត់ទុកជាសារៈសំខាន់បន្ទាប់បន្សំឬត្រូវលុបចោលជាថ្នូរចំពោះការចំណេញសម្ភារៈដោយរយៈពេលខ្លី។

បញ្ញាញាណ ដែលផ្ទេរទៅជំនាន់ក្រោយដោយអ្នកជំនាញខាងផ្លូវចិត្ត បានចូលទៅក្នុងត្រចៀកថ្លង់។ ដំបូន្មានរបស់ពួកគេឱ្យរស់នៅដោយភាពស្ងប់ និងប្រកាន់ខ្ជាប់ក្រមសីលធម៌ធម៌ដែលអាចអនុវត្តបានជាទូទៅត្រូវបានធ្វើមិនដឹងមិនឮ។

**ក្រុងនីរ៉ូ លេងវីយូឡុង ពេលក្រុងរ៉ូមឆាបឆេះ** (Nero’s Fiddling When Rome was Burning)

បណ្ដាប្រទេសដែលការអភិវឌ្ឍន៍ ខាងសេដ្ឋកិច្ចបានឈានមកដល់ចំណុចកំពូល ក្នុងនាមការរីកចម្រើនខាងសម្ភារៈ កំពុងប្រឈមមុខនឹងវិបត្តិដ៏ធំធេងដោយការបំពុលបរិស្ថាន វិបត្តិថាមពល ភាពអត់ការងារធ្វើ អតិផរណាការថយចុះនៃសីលធម៌ហើយនិងបណ្ដាចំណោទបញ្ហាសង្គមទាំងអស់មានដូចជាការប្រើគ្រឿងញៀន វិបត្តិផ្លូវចិត្តដ៏ធ្ងន់ធ្ងរការលែងលះអត្តឃាតកម្ម និងជំងឺតំកាត់ជាច្រើនមុខជាដើម។

ថ្វីបើមានការកើតឡើងសោកនាដកម្ម និងភាពឆ្កួតឡប់យ៉ាងណាក៏ដោយ ក៏នៅតែមានបណ្ដាប្រទេស ដែលគេហៅថា កំពុងអភិវឌ្ឍក្នុងពិភពលោកនោះ កំពុងតែព្យាយាមអស់ទំហឹងដើម្បីប្រកួតប្រជែងការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងទម្រង់ច្រើន រាប់មិនអស់ពោលគឺត្រាប់តាមកាន់តែច្រើនឡើងៗនូវវប្បធម៌សម្ភារនិយម ដោយសង្ឃឹមថាលំនៅដ្ឋាននិងប្រទេសរបស់ពួកគេ នឹងប្រែក្លាយជាស្ថានសួគ៌សម្ភារៈ។ ក៏ដូចជាទីក្រុងនីរ៉ូកូតទ្រលេង នៅពេលដែលទីក្រុងរ៉ូមកំពុងឆាបឆេះពោលគឺប្រជាជនទាំងនេះមិនបានរៀនសូត្រពីបណ្ដាកំហុសឆ្គងដែលធ្វើឡើងដោយអ្នកដទៃទេ។

**ការវង្វេងដ៏ចម្លែក** (Amazing Coinfusions)

មនុស្សជាច្រើនបានដើរចូលក្នុងការប្រជែងអំណាច យសសក្តិ ដើម្បីទទួលបាននូវការសប្បាយខាងឥន្ទ្រិយអំណាចកេរ្តិ៍ឈ្មោះនិងភាពរុងរឿងគឺថា ពេលណាពួកគេមានការរាយមាយ

និងការភ័ន្តច្រឡំកាន់តែច្រើនពួកគេនឹងរួមចំណែក កាន់តែច្រើនទៅក្នុងបដិវាទកម្ម ដែលពិភពលោកកំពុងជួបប្រទះសព្វថ្ងៃនេះ។

ម្យ៉ាងវិញទៀតមនុស្សភ័យខ្លាចសង្គ្រាម ឯម្ខាងទៀតពួកគេទាំងអស់ចេញទៅធ្វើសង្គ្រាម។ ពួកគេ និយាយយ៉ាង ច្រើនអំពីសមិទ្ធកម្មសន្តិភាព ប៉ុន្តែពួកគេបានចែកចាយទុគ៌តភាព។ ថ្វីត្បិតពិភពលោកមាន មនុស្សកាន់តែច្រើនទៅៗជារៀងរាល់ថ្ងៃ ប៉ុន្តែមនុស្សមានអារម្មណ៍កាន់តែឯកោទៅៗ។ ពួកគេមានម៉ោងលំហែកាន់តែច្រើន ប៉ុន្តែពួកគេកាន់ តែមិនបានសម្រាក។ ថ្វីត្បិតពួកគេមានចំណេះគ្រប់ប្រភេទដើម្បីទៅ ដល់ស្ថានព្រះច័ន្ទដោយសុវត្ថិភាព ប៉ុន្តែពួកគេមិនដឹង ថាធ្វើយ៉ាងណាដើម្បីរស់នៅឱ្យមានសុវត្ថិភាពលើផែនដីនេះ។ ទាំងនេះគឺជាការវង្វេង និងបដិវាទកម្មរបស់មនុស្សទំនើប ដែលកំពុងរស់នៅក្នុងយុគសម័យអាកាសនេះ ។ កន្លងមកចំណោទទាំងនេះ មិនមែនថ្មីទាំងស្រុងទេ ចំពោះមនុស្សជាតិ។

ការវង្វេងកើតមានឡើង ដរាបណាភាពខ្មៅងងឹតនៃមាយាការនៅតែ មាននៅក្នុងចិត្តរបស់មនុស្ស។ ព្រមជាមួយ នឹងភាពខាងបញ្ញា មាយាការរបស់មនុស្សធ្វើឱ្យមនុស្សខ្វាក់មើលមិនឃើញនិងមិនយល់ពីធម្មជាតិពិតនៃវត្ថុទាំងឡាយ ឬតថភាពចុងបញ្ចប់នៃជីវិត។

**ការរស់នៅគ្មានតុល្យភាព** (Imbalanced Living)

អតុល្យភាពរវាងការអភិវឌ្ឍន៍ខាងសម្ភារៈនិងស្មារតី គឺជាមូលហេតុនៃការវង្វេងទាំងស្រុងហើយ និងទុគ្គគ្រោះដែលពិភពលោកទំនើបបានជួបប្រទះ។

ទ្រព្យសម្ភារៈតែឯងមិនអាចនាំមកនូវសន្តិភាព និងសុភមង្គលដល់មនុស្សបានទេ។ ការនឿយណាយ ចិត្ត និងការខកចិត្ត តែងមាននៅក្នុងចិត្តដែលគ្មានតុល្យភាព។ ដោយមិនអាចរកឃើញវិធីឬមធ្យោបាយធ្វើឱ្យចិត្តរីករាយ ដើម្បីប្រឈមមុខនឹងការនឿយណាយក្នុងជីវិតមនុស្សប្រវារកថ្នាំញៀននិងគ្រឿងស្រវឹង គ្រប់ប្រភេទជាគ្រឿងព្យាបាលបណ្តោះអាសន្ន បើគ្មានវាទេពួកគេបែរទៅធ្វើអត្តឃាតឬមានពុទ្ធិវិបល្លាស។

ករណីកើនឡើងមិនឈប់ឈរនៃការប្រើប្រាស់ថ្នាំញៀនគ្រឿងស្រវឹងល្បែងស៊ីសងនិងអ្វីៗដទៃទៀត គឺជារោគសញ្ញានៃការរស់នៅគ្មានតុល្យភាព។

ការទោរទន់ទៅលួងលោមខ្លួនឯងក្នុងផាសុខភាព នៃជីវភាពរស់នៅបែបទំនើបដោយគ្មានការគិតអំពីវឌ្ឍនភាព ខាងផ្នែកស្មារតី បានបន្សល់ទុកឱ្យមនុស្សនូវភាពខ្វិលច្រអូស និងព្រងើយ

កន្ទើយ។ ដើម្បីជំនះបញ្ហានេះ មនុស្សត្រូវការបាំមពលការប្រឹងប្រែង និងការព្យាយាម ដែលបានមកពីវិស័យនៃជំនឿ ដែលមានកប់យ៉ាងជ្រៅក្នុងសាសនា។

**សន្តិភាពតាមរយៈសាសនា** (Peace Through Religion)

ការលូតលាស់ដ៏លឿននៃសម្ភារនិយម និងការរស់នៅគ្មានតុល្យភាពបានបិទបាំងសក្តានុពលនៃ សន្តិភាពតាមរយៈសាសនា។ បណ្តាសាសនាក្នុងពិភពលោកបច្ចុប្បន្ន បានអភិវឌ្ឍទៅជាបណ្តាអង្គការស្ថាប័ន ដ៏ទូលំទូលាយហើយពាក្យប្រៀនប្រដៅពីដើមរបស់អ្នក បង្កើតសាសនានីមួយៗពិបាកនឹងមានឥទ្ធិពលណាមួយទៅលើបណ្តាបរិស័ទ ដោយគុណសម្បត្តិនៃភាពសាមញ្ញការទប់ចិត្តភាពទៀងត្រង់និងការលះបង់។

ដើម្បីយល់ដឹងតម្លៃពិតរបស់សាសនា ការយល់ដឹងដ៏ត្រឹមត្រូវអំពីពាក្យសម្តីដើមរបស់បណ្តាអ្នកបង្កើតសាសនា គឺជាការចាំបាច់។ បណ្តាតម្លៃខាងសីលធម៌ និងចរិយាធម៌ដ៏សាមញ្ញមានសក្តានុពលដ៏ធំធេងចំពោះសន្តិភាព។

ការអនុវត្តនីការទប់ឃាត់ផ្លូវចិត្តនាំមកនូវសន្តិភាព និងភាពសុខដុមចំពោះបុគ្គល ហើយការទប់ឃាត់ ផ្លូវវាចា និង ផ្លូវកាយ ផ្តល់នូវសន្តិភាពចំពោះអ្នកដទៃ។ តាមរយៈចរន្តទាំងបីនៃមនោកម្ម វចីកម្មនិងកាយកម្មនេះហើយ ដែលអំពើអាក្រក់ ឬមិនត្រឹមត្រូវទាំងអស់បានកើតឡើង។ វាជាទ្វារនៃពិភពខាងក្នុង ជាទីដែលទំនាស់កើតមានឡើង។ ប្រសិនបើពិភពខាងក្នុងនេះមានការឃ្លាំមើលបានល្អប្រសើរដោយការយកចិត្តទុកដាក់សង្គ្រាមនិងទំនាស់ខាងក្រៅទាំងឡាយ នឹងត្រូវបានត្រួតពិនិត្យដោយឯកឯង។

"ស្គាល់ខ្លួនឯង" តាមរយៈសាសនា គឺជាគោលការណ៍ដឹកនាំទៅកាន់សន្តិភាពសម្រាប់ "ព្រះរាជាណាចក្រនៃស្ថាន សួគ៌នៅខាងក្នុង"។ ប្រសិនបើមនុស្សអាចដើរតាមគោលការណ៍សាសនាដ៏បរិសុទ្ធដែលទាក់ទងដល់ការទប់ឃាត់ខាងសីលធម៌ និងការបំពេញករណីយកិច្ច និងកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកក្នុងសង្គម សន្តិភាពនិងភាពសុខដុមនឹងកើតមាន ដោយឯកឯង។

ដំបូន្មានដ៏សាមញ្ញដែលព្រះពុទ្ធបានផ្តល់ដល់បរិស័ទរបស់ព្រះអង្គ នៅក្នុងសាស្ត្រាសិគលុវេទ ដែលបានចែងពីករណីយកិច្ច និងកាតព្វកិច្ចរវាងឪពុកម្តាយនិងកូន គ្រូនិងសិស្សស្វាមី និងភរិយា មិត្តនិងមិត្ត ចៅកែ និងបុគ្គលិកគ្រូសាសនា និង សាវ័ក បានគ្របដណ្តប់ករណីយកិច្ចក្នុងគ្រួសារនិងសង្គមទាំងមូលរបស់គ្រហស្ថ។ ដោយមានបរិយាយនៅក្នុងសាស្ត្រានេះ លោកស្រីរីស ដាវីដ (Rhys Davids) បាននិយាយថា លទ្ធិរបស់ ព្រះពុទ្ធ អំពីមេត្តាធម៌ និងសុឆន្ទៈរវាង

មនុស្សនិង មនុស្សគឺជាការលើកកំពស់សីល ធមិក្នុងគ្រួសារនិងសង្គម ដោយលក្ខណៈលំអិតគ្រប់ជ្រុងជ្រោយជាងនៅលទ្ធិដទៃ" ។ ជាការពិត យើងអាចនិយាយថា សូម្បីសព្វថ្ងៃនេះ ព្រះវិន័យឬក្រមវិន័យ គឺជាមូលដ្ឋាននៃផល ប្រយោជន៍របស់មនុស្ស បើបានសិក្សាបញ្ញាមនុស្សនឹងមានសភាពនឹងន់និងទូលំទូលាយ រហូតដល់គេអាចមើលឃើញទីបញ្ចប់ភ្លាមៗ និងជាក់ស្តែងដូចបច្ចុប្បន្នភាពនិងទីនេះដែរហើយឃើញ ដូចជាវានៅឯរាជគ្រឹះដែរ" សេចក្តីរីករាយ នឹងក្លាយជាភូមិឬជាកុលសម្ព័ន្ធនៅលើឆ្នេរទន្លេហ្គង់ (អានងសេ) ជាទីដែលមានមនុស្សពោរពេញដោយស្មារតីសប្បុរស ក្នុងការរាប់អាន ស្មារតីខ្ពង់ខ្ពស់នៃយុត្តិធមិ ដែលដកដង្ហើមតាមរយៈពាក្យសម្តីត្រង់ៗនិងសាមញ្ញ" ។ រឿងនេះមិនមែនចង់និយាយអំពីភូមិ ឬគ្រួសារតាមដងទន្លេត្បែម (ទហាមសេ) សព្វថ្ងៃ ដែលមានការរីករាយដ៏តិចតួចនោះទេ ។

ជំនួសឱ្យការយកសាសនាជាមាគ៌ានៃជីវិត មានការវិវត្តនៅក្នុងភាសាទស្សនវិជ្ជា ដោយឡែក ហើយបានក្លាយជា ប្រធានបទនៃការហ្វឹកហាត់បញ្ញា និងការពិភាក្សា។ ការប្រតិបត្តិបែបអធិធម្មជាតិ វេទមន្ត និងលទ្ធិអាថិកំបាំង ត្រូវបាន បង្ហាញដើម្បីកិត្តិស័ព្ទ និងមានកំណើនក្រុមសាសនិកច្រើនជាងសាសនាដទៃ។ សាសនាត្រូវគេប្រើដើម្បីលុបលាងភាពខុស ឆ្គងរបស់មនុស្ស ដើម្បីសេចក្តីលោភលន់មាសប្រាក់និងអំណាច ។

ដោយលើកយកចំណោទបញ្ហាផ្លូវលោកដាក់ទៅក្នុងសាសនា ដើម្បីធ្វើអ្វីមួយ ដោយប្រើឈ្មោះសាសនាបណ្តាសាស និកបច្ចុប្បន្នត្រូវយល់ថាទង្វើទាំងនេះនឹងបិទ បាំងហើយលុបចោលនូវសារជាតិពិតរបស់ សាសនា និងមាគ៌ាខាងស្មារតីនៃជីវិត ហើយតម្លៃសាសនាពិតប្រាកដ នឹងកាន់តែអាប់ឱនទៅៗចំពោះកូនចៅជំនាន់ក្រោយ ។

**រស្មីពណ៌ប្រាក់** (A Silver Lining)

ទោះបីសាសនានៅតែអាចនាំមកនូវសន្តិភាពដល់មនុស្សជាតិយ៉ាងណាក៏ដោយក៏បច្ចុប្បន្នគឺពិតជាចំណោទពាក់ព័ន្ធមួយជាពិសេសចំពោះការអភិវឌ្ឍន៍ថ្មីៗ នេះនៅផ្នែកមួយចំនួននៃពិភពលោកដែលសាសនាតាមន័យនៃពាក្យត្រូវបានគេយកចូលទៅក្នុងសមរភូមិប្រយុទ្ធ ។

លទ្ធិសម្ភារនិយម ការលាក់ពុត និងការនិយមជ្រុលដែលពាក់មុខ ក្រោមការក្លែងបន្លំនៃសាសនាគឺជា ភយន្តរាយដ៏ធំ សម្បើមនៅក្នុងបណ្តាភយន្តរាយនានាក្នុងពិភពលោក។ ដោយធ្វើនូវកំហុសឆ្គង និងសោកនាដកម្មនៃអតីតកាលផ្ទួនៗ នៅពេលដែលមានសន្និសីទ ពិភពលោកដ៏ធំស្តីអំពីសាសនានិងសន្តិភាព សេចក្តីប្រកាសដែលបានលើកឡើងដើម្បីសន្តិភាពសកលភាតរ

ភាពសកលនិងភាពសុខដុមខាងសាសនា នឹងទៅជាការលាក់ពុតនិងការបង្អាប់បង្អោន ចំពោះសង្គមមនុស្ស ។

ដើម្បីគាំទ្រអំពើអសីលធមិបែបនេះក្នុងនាមសាសនា គឺជាការប្រឆាំងនឹងភាពគួរសមនិងភាពថ្លៃថ្នូររបស់មនុស្ស ។ ការប្រយុទ្ធក្នុងសមរភូមិ ដើម្បីសន្តិភាពគឺជាការមិនត្រឹមត្រូវទេ ពីព្រោះសន្តិភាពជាសមត្ថភាព ច្បាំងឈ្នះលើខ្លួនឯង ដោយគ្មានដាក់ទម្ងន់ការចុះចាញ់ឱ្យទៅអ្នកដទៃ។ បញ្ហានេះត្រូវបានយល់ដឹងដោយពេញលេញថា ជាចំណុចគ្មានអាត្មានិយម ។ ទោះបីសាសនិកមួយចំនួនបានសម្រេចចិត្តចូលរួមក្នុងសង្គ្រាមសាសនា ដើម្បីសេចក្ដីលោភលន់មាសប្រាក់និងអំណាចផ្លូវលោកក៏ដោយ ក៏ទង្វើនេះមិនមែនតំណាងឱ្យវិស័យទាំងមូល នៃសាសនាឡើយ ។ ដូច្នេះមានតែអ្នកគិត និងស្រឡាញ់សន្តិភាពនាបច្ចុប្បន្នទេ ដែលជាអ្នកវិនិច្ឆ័យថា តើឥរិយាបថរបស់ជនល្មោភសង្គ្រាមក្នុងនាមសាសនា មានលក្ខណៈអាចដោះសារបានឬទេ ហើយតើសង្គ្រាម និងការបង្ហូរឈាមគួរផ្ដាច់ចេញទាំងស្រុងអំពីសាសនាបានឬទេ ។

ប្រសិនបើប្រជាជនពិតជាយកចិត្តទុកដាក់ក្នុងការស្វែងរក និងធ្វើការដើម្បីសន្តិភាព និងសុភមង្គល សម្រាប់ខ្លួនគេ ក៏ដូចជាអ្នកដទៃដោយស្មោះមែន គឺមិនទាន់ហួសពេលទេ ព្រោះថារាល់ដុំពពកមានរស្មីពណ៌ប្រាក់ ។ បណ្ដាគោលការណ៍សាសនា និងពាក្យប្រៀនប្រដៅ ដែលសមគួរដល់ការបណ្ដុះបណ្ដាលមនុស្ស ហើយអាចត្រូវគេយកទៅពិសោធ និងយល់ ដឹងដោយខ្លួនគេនៅតែមាននៅឡើយ ។ បើកចំហរចំពោះទាំងអស់គ្នា គឺជាច្រកទ្វារទៅកាន់ការរំដោះទាំងស្រុង ។

" គេអាចយកឈ្នះក្នុងសមរភូមិមួយពាន់ដង មួយពាន់នាក់ ប៉ុន្តែអ្នកដែលយកឈ្នះលើខ្លួនឯងបាន គេជាអ្នកឈ្នះដ៏ប្រសើរជាងគេបំផុត " ។

## ៤-ព្រះពុទ្ធសាសនាថេរវាទ និងព្រះពុទ្ធសាសនាមហាយាន

(Theravada-Mahayana Buddhism) By.Ven. W. Rahula

ចូរយើងនាំគ្នាពិភាក្សាលើសំនួរមួយ ដែលតែងតែមានមនុស្សជាច្រើនកបានចោទសួរគឺ "តើពុទ្ធសាសនាមហាយាន និងព្រះពុទ្ធសាសនាថេរវាទមានភាពខុសគ្នាដូចម្ដេច?" ដើម្បីស្វែងយល់ខ្លឹមសារទាំងឡាយក្នុងទស្សនៈសមស្របមួយរបស់និកាយទាំងពីរ នេះចូរយើងនាំគ្នាត្រឡប់ទៅពិនិត្យមើលប្រវត្តិនៃព្រះពុទ្ធសាសនា និងដំណើរនៃការកកើត និងការវិវត្តរបស់ពុទ្ធសាសនាមហាយាន និងពុទ្ធសាសនាថេរវាទ ។ ព្រះពុទ្ធប្រសូតនៅក្នុងសតវត្សទី៦មុនគ្រឹស្តសករាជ ។ បន្ទាប់ពីបានត្រាស់ដឹង (Enlightnment) នៅព្រះជន្ម៣៥ព្រះវស្សា រហូតដល់ព្រះអង្គចូលមហាបរិនិព្វាន (Mahaparimibbana) នៅព្រះជន្ម ៨០ ព្រះវស្សា ព្រះអង្គបានចំណាយពេលវេលា ពេញមួយជីវិត

របស់ព្រះអង្គដើម្បីធ្វើការទេសនា និងបង្រៀន។ ព្រះអង្គជាមនុស្សដែលមានថាមពលស្វាហាប់បំផុតគឺក្នុងរយៈពេល៤៥ព្រះវស្សាព្រះអង្គបានបង្រៀន និងទេសនាទាំងយប់ទាំងថ្ងៃដោយផ្ទុំតែ ២ ម៉ោងប៉ុណ្ណោះក្នុងមួយថ្ងៃ។

ព្រះពុទ្ធបានមានព្រះបន្ទូលទៅកាន់មនុស្សគ្រប់ប្រភេទមានដូចជា ស្តេចនានាអ្នកកាន់ព្រហ្មញ្ញសាសនា កសិករអ្នកសុំទានបញ្ញវន្ត(learned men) និងប្រជាពលរដ្ឋសាមញ្ញទាំងឡាយ។ បន្ទូល របស់ព្រះអង្គត្រូវទៅនឹងបទពិសោធន៍ ដែលមនុស្សទាំងឡាយបានជួបប្រទះក៏រិតនៃការយល់ដឹង និងសមត្ថភាពនៃការស្វែងយល់ខាងផ្លូវបញ្ញា (mental capacity) របស់អ្នកដែលបានស្តាប់ព្រះអង្គ (his aud-ience)។ អ្វីដែលព្រះពុទ្ធបានបង្រៀនឬបានផ្តល់ឱវាទត្រូវបានគេឱ្យឈ្មោះថា "ពុទ្ធទស្សនៈ" Buddh a vacana ។ គឺមិនមានអ្វីដែលមានឈ្មោះថា "ថេរវាទ" ឬ "មហាយាន" ឡើយនៅពេលនោះ។ បន្ទាប់ពីបានបង្កើតគណៈព្រះសង្ឃ និងដូនជីទាំងឡាយរួចមក ព្រះពុទ្ធបានដាក់ចេញ នូវគោលវិន័យសម្រាប់ជាមាគ៌ាក្នុងការការពារគណៈសង្ឃទាំង នោះប្រតិបត្តិនូវធម៌វិន័យនោះ។ ការបង្រៀនរបស់ព្រះពុទ្ធមួយចំនួនទៀតត្រូវបានគេអោយឈ្មោះថា "ព្រះធម៌" (the Dhamma) ដែលរួមមាន ការជជែកពិភាក្សានានា (discourses) ធម្មទេសនាដល់ព្រះសង្ឃ ដូនជី និងគ្រហស្ថ ទាំងឡាយជាដើម។

**សង្គាយនាលើកទី១** (The First Council)

បីខែបន្ទាប់ពីព្រះពុទ្ធបានចូលបរិនិព្វាន មកសាវ័ជំនិតទាំងឡាយរបស់ព្រះអង្គបានកោះប្រជុំគ្នាជាសង្គាយនាមួយនៅព្រញងាហា។ នាពេលនោះព្រះមហាកស្សប្ប (Maha Kassapa) ដែលជាព្រះសង្ឃ មួយអង្គមានវ័យចំណាស់ជាងគេ និងមានគេគោរពច្រើនបំផុតធ្វើជាអធិបតីនៃសង្គាយនានោះ។ នៅពេលនោះមានបុគ្គលដែលមានឈ្មោះល្បីល្បាញពីររូបមានវត្តមាននៅទីនោះ។ បុគ្គលពីររូបនេះមានជំនាញពីរខុសផ្លែកពីគ្នាគឺម្នាក់ជំនាញខាងព្រះធម៌ និងម្នាក់ទៀតមានជំនាញខាងព្រះ "វិន័យ" ។ម្នាក់ដែល ជំនាញខាងព្រះធម៌មានឈ្មោះថាព្រះអានន្ទ (Ananda)។ ព្រះអានន្ទជាអ្នកដែលបានរួមដំណើរជាមួយ ព្រះពុទ្ធជាប្រចាំ ហើយជាសាវ័ជំនិតស្និតបំផុតរបស់ព្រះពុទ្ធរយៈពេល២៥ឆ្នាំ។ ព្រះអានន្ទមានបញ្ញាមោះមុត (មានការចងចាំល្អ) ដែលធ្វើឱ្យលោកអាចនិយាយរាយរាប់ឡើងវិញបានទាំងអស់នូវអ្វី ដែលព្រះពុទ្ធបានមានព្រះបន្ទូល។ ឯម្នាក់ទៀតមានឈ្មោះថាឧបាលី (Upali) ជាអ្នកដែលបានចងចាំទាំង អស់នូវព្រះវិន័យទាំងឡាយដែលព្រះពុទ្ធបានដាក់ចុះ។

មានតែចំណុចសំខាន់ពីរនេះគត់ ដែលគេបានលើកឡើងនៅក្នុងសង្គាយនាយលើកទី១ នោះគឺព្រះធមិនិងព្រះវិន័យ ។ក្នុងចំណោមចំណុចសំខាន់ទាំងពីរនេះគេពុំឃើញមានមតិយោបល់ខុសគ្នាក្នុង "ព្រះធមិ "ឡើយ ប៉ុន្តែគេឃើញមានការពិភាក្សាខ្លះអំពី "ព្រះវិន័យ " ។ ព្រោះមុនពេលព្រះពុទ្ធ ចូលបរិនិព្វាន ព្រះពុទ្ធបានប្រាប់ទៅព្រះអានន្ទថា ប្រសិនបើព្រះសង្ឃទាំងឡាយ (The sangha) ចង់កែសម្រួល ឬផ្លាស់ប្តូរគោលវិន័យតូចៗមួយចំនួនគេអាចធ្វើបាន ។ ប៉ុន្តែដោយនៅពេលនោះព្រះអានន្ទ មាន ទុក្ខជាទម្ងន់ព្រោះព្រះពុទ្ធជិតចូលទីវង្គត់ ហើយនោះព្រះអានន្ទក៏មិនបានសួរបញ្ជាក់ព្រះគ្រូ (the Master)ថាតើគោលវិន័យតូចៗណាខ្លះដែលអាចធ្វើការកែសម្រួល ឬផ្លាស់ប្តូរបាននោះ ។ ក្នុងខណៈពេល ដែលសមាជិកនៃក្រុមសង្គាយនាមិនអាចយល់ស្របគ្នាបានថា តើចំណុចណាមួយជាចំណុចតូចបន្ទាប់បន្សំនោះ ព្រះមហាកស្សប្ប (Maha Kassapa) បានចេញជាបទបញ្ជាថា"គ្មានគោលវិន័យណាមួយដែលព្រះពុទ្ធបានដាក់ចុះគួរត្រូវគេផ្លាស់ប្តូរ ហើយក៏មិនមានគោលវិន័យថ្មីណាមួយ ដែលអាចត្រូវគេដាក់បន្ថែមដែរ " ។ ប៉ុន្តែមិនមានហេតុផលណាមួយបញ្ជាក់ឱ្យបានច្បាស់លាស់អំពីបញ្ហាខាងលើនេះឡើយ ។ ទោះយ៉ាងណាក៏ដោយគេបានដឹងថា ព្រះមហាកស្សប្បពិតជាបាននិយាយថា "ប្រសិនបើយើងផ្លាស់ប្តូរគោលវិន័យទាំងឡាយពេលនោះប្រជាពលរដ្ឋ នឹងនិយាយថាយើងដែលជាសាវ័ករបស់ព្រះអង្គទោះជាការផ្លាស់ប្តូរនោះធ្វើឡើងមុនពេលភ្លើងបូជាសពរបស់ព្រះអង្គរលត់ក៏ដោយ " ។

នៅក្នុងអង្គាយនាគេបានចែកព្រះធមិចេញជាផ្នែកផ្សេងៗគ្នា ហើយគេតម្រូវឱ្យអ្នកដែលមាន វ័យចំណាស់ជាងគេ (An Elder) ទទួលខុសត្រូវលើផ្នែកនីមួយៗ ហើយកូនសិស្សរបស់ខ្លួនត្រូវទទួល បន្ទុកទន្ទិញចាំមាត់នូវផ្នែកនីមួយនោះ ។ ដូច្នេះព្រះធមិត្រូវបានរក្សាបន្តពីគ្រូទៅកូនសិស្សតាមរយៈការទន្ទិញចាំមាត់ ។ ក្រុមមនុស្សនីមួយៗត្រូវសូត្រទន្ទិញព្រះធមិរាល់ថ្ងៃហើយត្រូវពិនិត្យផ្ទៀងផ្ទាត់គ្នាទៅវិញទៅមកជាញឹកញយ ដើម្បីអោយប្រាកដថា គ្មានចំណុចរំលង ឬគ្មានការបន្ថែមឡើយ ។ អ្នកប្រវត្តិសាស្ត្រយល់ស្របថាប្រពៃណីនៃការទន្ទិញ ចាំមាត់មានភាពត្រឹមត្រូវគួរឱ្យ ជឿជាក់ជាងសំណេររាយរាប់ធ្វើដោយបុគ្គលម្នាក់ៗ ។

**សង្គាយនាលើកទី២** (The second Council)

មួយរយឆ្នាំក្រោយមក សង្គាយនាលើកទី២ ត្រូវបានគេធ្វើឡើង ដើម្បីពិភាក្សាលើគោលវិន័យមួយចំនួន (Some Vinya rules) ។ មិនមានអ្វីចាំបាច់ដែលត្រូវកែប្រែ គោលវិន័យឡើយ ក្រោយពីព្រះពុទ្ធចូលបរិនិព្វានបាន៣ខែ ព្រោះវាហាក់ដូចជាមិនមានការប្រែប្រួលខាង

ផ្នែកសង្គម សេដ្ឋកិច្ច និងនយោបាយឡើយក្នុងសម័យនោះ។ បើមានក៏តិចតួចដែរ។ ប៉ុន្តែមួយរយឆ្នាំក្រោយមកព្រះសង្ឃខ្លះយល់ឃើញថា មានភាពចាំបាច់ក្នុងការផ្លាស់ប្តូរគោលវិន័យតូចៗមួយចំនួន។ ព្រះសង្ឃដែលនិយមធម៌វិន័យចាស់ ដែលបានអនុវត្តន៍ហើយនោះបាននិយាយថាមិនមានអ្វីដែលត្រូវកែប្រែឡើយ តែព្រះសង្ឃមួយចំនួន ទៀតទទូចចង់អោយផ្លាស់ប្តូរនូវធម៌វិន័យមួយចំនួន (Some rules)។ លុះដល់គ្រាចុងក្រោយ មានព្រះសង្ឃមួយក្រុមបានចាកចេញពីក្រុមព្រឹក្សាពីគ្រោះយោបល់នោះ ហើយបង្កើតសហគមន៍ដ៏ធំមួយទៀត (Mahasanghika។ ទោះជាពេលនោះវាមានឈ្មោះថា " មហាសហគមន៍ " (Mahasanghika) ក ដោយក៏គេមិនបានដឹងថាវាជានិកាយមហាយាន (Maha yana) ឡើយ ហើយនៅក្នុងសង្គាយនាលើក ទី**២**នេះមានតែបញ្ហាដែលទាក់ទងនឹង "ព្រះវិន័យ" ប៉ុណ្ណោះដែលត្រូវបានគេលើកយកមកពិភាក្សា ហើយចំពោះព្រះធម៌មិនមានអ្វីជាបញ្ហាចោទឡើយ។

**សង្គាយនាលើកទី៣** (The third Council)

នៅក្នុងសតវត្សទី**៣** មុនគ្រិស្តសករាជ ក្នុងសម័យកាលព្រះអធិរាជព្រះបាទ *អសោក* (Asoka) សង្គាយនាលើកទី**៣** ត្រូវបានគេរៀបចំឡើង ដើម្បីពិភាក្សាលើមតិយោបល់ខុសគ្នា (ការខ្វែងគំនិតគ្នា) ក្នុង "ព្រះវិន័យ " តែគេក៏បានភ្ជាប់ការពិភាក្សានោះទៅនិងបញ្ហា " ព្រះធម៌ " ដែរ។ នៅចុងបញ្ចប់ប្រធានសង្គាយនាដែលមានឈ្មោះថា *មោគ្គាលីពុទ្ធទិសា* (Moggaliputta ទិសសាបបានចងក្រងសៀវភៅ មួយក្បាលដែលគេហៅថា*កត្ថវត្ថុ* បានបដិសេធចោលទាំងអស់នូវទស្សនៈ និងទ្រឹស្តីនានាដែលមានការខុសឆ្គងនិងជឿតៗគ្នាដោយនិកាយមួយចំនួន។ ព្រះពុទ្ធឱវាទដែលបានអនុម័តយល់ស្របថាត្រឹមត្រូវនាពេលនោះត្រូវបានគេស្គាល់ថា*ថេរវាទ*(Theravada)។ ក្នុងសង្គាយនានេះគេក៏បានដាក់បញ្ចូល *អភិធម្មបិដក* (Abhidhamma ) ក្នុងការពិភាក្សាដែរ។

បន្ទាប់ពីសង្គាយនាលើកទី**៣** នេះមកបុត្រារបស់ព្រះអធិរាជព្រះបាទ *អសោក* ឈ្មោះ "*មហេនដិ*" បាននាំយកគម្ពីរព្រះត្រៃបិដកទៅប្រទេសសេរីលង្កាដោយភ្ជាប់ទៅជាមួយនូវការបកស្រាយស្រាយមួយចំនួនដែលបានលើកឡើងនៅក្នុងសង្គាយនាលើកទី**៣**នោះ។ អត្ថបទដែលត្រូវបានគេនាំយកទៅប្រទេស សេរីលង្កា នៅពេលនោះត្រូវបានគេរក្សាទុករហូតមកដល់បច្ចុប្បន្នដោយឥតមានបាត់មួយទំព័រឡើយ។ អត្ថបតទាំងនោះត្រូវបានគេសរសេរជាភាសាបាលី ដោយផ្អែកជាមូលដ្ឋានលើភាសា *មាគ្គាហិ* (Maga dhi) ដែលព្រះពុទ្ធបានប្រើ។ នៅពេលនោះមិនមានអ្វីដែលហៅថា *មហាយាន* ឡើយ។

**ការកកើតឡើងនៃនិកាយ " មហាយាន "**

នៅចន្លោះរវាងពីសតវត្សទី**១**មុនគ្រឹស្តរាជទៅសតវត្សទី**១** នៃគ្រឹសរាជបញ្ញត្តិពីរបានកើតឡើង គឺពាក្យមហាយាន និងថេរវាទនៅក្នុង Saddhama Pundarida Sutra ។

នៅប្រហែលជាសតវត្សទី**២** នៃគ្រឹស្តរាជនិកាយមហាយានរបស់ *សូន្យាតៈ* (Sunyata) ហើយអះអាងជាមោឃៈនូវអ្វីៗទាំងឡាយដែលស្ថិតនៅក្នុងអត្ថបទតូចមួយឈ្មោះថា *មត្យាមីកៈ* (Madhyami ka-karika) ។ នៅប្រហែលសតវត្សទី**៤** នៃគ្រឹស្តសករាជមានបុគ្គលពីររូបបានសរសេរស្នាដៃជាច្រើនស្តីពីនិកាយមហាយានគឺអសង្ឃៈ (Asanga) និងវាសុបាន់ឌុ (Vasubandha) ។ ពោលគឺចាប់តាំងពីសតវត្សទី **១**នៃគ្រឹស្តសករាជមក ពួកអ្នកកាន់ព្រះពុទ្ធសាសនាមហាយានបានកំណត់ទីតាំងរបស់ខ្លួនបានច្បាស់លាស់ ហើយនៅពេលនោះពាក្យថាមហាយាន និងថេរវាទបានចេញជារូបរាងឡើង ។

យើងមិនត្រូវច្រឡំពាក្យថេរវាទ ជាមួយនិងពាក្យថេរវាទទេ ព្រោះពាក្យទាំងពីនេះមិនមានន័យដូចគ្នាទេ (the terms are not synonymous) ។ ព្រះពុទ្ធសាសនាថេរវាទបានចូលទៅប្រទេសសេរីលង្កានៅសតវត្សទី**៣** ដែលនៅពេលនោះមិនទាន់មានឈ្មោះមហាយាននៅឡើយ ។ និកាយហិយានបាន លេចជារូបរាងនៅក្នុងប្រទេសឥណ្ឌា ហើយវាមានអត្ថិភាពដោយឡែកមិនចំណុះនឹងទម្ងន់ពុទ្ធសាសនានៅ ប្រទេសសិរីលង្កាឡើយ ។ សព្វថ្ងៃមិនមាននិកាយហិនយានណាមួយមានអត្ថិភាពនៅលើលោកនេះទេ ។ ដូច្នេះទើបនៅឆ្នាំ១៩៥០ ក្រុមមិត្តភាពពុទ្ធសាសនិកពិភពលោក (The world fellowship of Bud dhists) បានប្រារព្ធពិធីមួយនៅទីក្រុង **កូឡំបូ** (Colombo) ដើម្បីសំរេចជាឯកច្ឆ័នឈប់ប្រើពាក្យហិនយាន ប្រសិនបើគេសំដៅលើពុទ្ធសាសនានៅប្រទេសសិរីលង្កា ប្រទេសថៃ ប្រទេសភូមា ប្រទេសកម្ពុជា ប្រទេសឡាវ ។ល។នេះជាប្រវត្តិសង្ខេបស្តីអំពីពាក្យថេរវាទ(Theravada) មហាយាន(Mahayana)និងហិនយាន(Hinayana) ។

**ព្រះពុទ្ធសាសនាមហាយាន និងថេរវាទ**

តើព្រះពុទ្ធសាសនាមហាយាន និងថេរវាទមានភាពខុសគ្នាយ៉ាងដូចម្តេចខ្លះ? ខ្ញុំបានសិក្សាស្វែង យល់អំពីព្រះពុទ្ធសាសនាមហាយានអស់រយៈពេលជាច្រើនឆ្នាំ ហើយខ្ញុំកម្រនឹងឃើញភាពខុសគ្នាណាស់លើការបង្រៀនដែលជាមូលដ្ឋានគ្រឹះរបស់ព្រះពុទ្ធសាសនាថេរវាទ និងពុទ្ធសាស នាមហាយានព្រោះ

-និកាយទាំងពីរសុទ្ធតែទទួលយកព្រះពុទ្ធ **សក្យមុនី** ជាព្រះគ្រូ ។

-និកាយទាំងពីរនេះសុទ្ធតែប្រកាន់យកអរិយសច្ចៈទាំង៤ ដូចគ្នា (the four noble truth)

-និកាយទាំងពីរនេះសុទ្ធតែប្រកាន់យក **មគ្គៈ** ទាំង៨ ដូចគ្នា (the eightfold path)

-និកាយទាំងពីរនេះសុទ្ធតែប្រកាន់យកធមិបដិច្ចៈសមុប្បាទ (Paticca Samuppada) ជាធមិឬទ្រឹស្តីដែលថារាល់អ្វីៗទាំងអស់សុទ្ធតែមានទំនាក់ទំនងគ្នា (Dependent Origination )

-និកាយទាំងពីរសុទ្ធតែបដិសេធចោល **ឥស្សរៈ** ដែលថាមានភាវៈឧត្តម (Supreme being) ដែលជាអ្នកបង្កើតលោកនិងគ្រប់គ្រងលោក ។

-និកាយទាំងពីរសុទ្ធតែទទួលយកនូវទស្សនៈដែលថាជីវិតមានទៅដោយអនិច្ចំ(Anicca) ទុក្ខំ (Dukkha) អនត្តា (Anatta) និងបុគ្គលត្រូវប្រកាន់ខ្ជាប់នូវសីល (Sila) សមាធិ (Samadhi) បញ្ញា (Panna) ដោយគ្មានចំណុចខុសគ្នាឡើយ ។

ទាំងនេះជាពុទ្ធឱវាទដ៏សំខាន់ដែលនិយាយទាំងពីរទទួលយកដោយឥតសង្ស័យគ្មានសំណួរ ។

តែទោះជាយ៉ាងណាក៏ដោយ មានចំណុចមួយចំនួនខុសគ្នានៅក្នុងនិកាយទាំងពីរនេះ ។ ចំណុចដែលខុសគ្នា ខ្លាំងនោះគឺចំណុចដែលនិយាយព្រះពោធិសត្វ (Bodhisattva) ។ មានមនុស្សជាច្រើននាក់ដែលនិយាយថា ព្រះពុទ្ធសាសនាមហាយានសំរាប់ឱ្យអ្នកគោរពប្រតិបត្តិបានក្លាយជាព្រះពោធិសត្វ ដែលចុងក្រោយនឹង នាំដល់ព្រះសម្មាសម្ពុទ្ធ ចំណែកឯពុទ្ធសាសនាថេរវាទ នឹងធ្វើឱ្យអ្នកប្រត្តិបត្តិបានក្លាយទៅជាព្រះអរហន្ត (Arahantship) ។ ខ្ញុំត្រូវតែបញ្ជាក់ឱ្យបានច្បាស់ថាព្រះពុទ្ធក៏ជាព្រះអរហន្ត (Arahant) ពុទ្ធបាសិកា (Pacceka Buddha) ក៏ជាព្រះអរហន្តដែរ ។ អត្ថបទទាំងឡាយក្នុងព្រះពុទ្ធសាសនាមហាយានមិនមែន ប្រើពាក្យ**យាន** ទៅកាន់ព្រះអរហន្ត (Arahant-yana Arahant Velicle) ទេ ។ អត្ថបទតែងប្រើពាក្យ**៣** ជាប្រចាំគឺពាក្យ Bodhisatt vayana ( យានទៅកាន់ព្រះពោធិសត្វ) (Prateka-Buddhayana) នឹង Sr avakayana ។ ជាទម្លាប់ (ជាប្រពៃណី) នៅក្នុងព្រះពុទ្ធសាសនាថេរវាទពាក្យទាំង**បី** នេះត្រូវបានគេហៅថា (Bodhis) ពោធិឬយាន ។

មនុស្សមួយចំនួនយល់ថា ព្រះពុទ្ធសាសនាថេរវាទជានិកាយដែលមានអត្តភាព ( អាត្មានិយម) (Selfish) ព្រោះនិកាយនេះបានបង្រៀន មនុស្សឱ្យស្វែងរកសេចក្តីសុខផ្ទាល់ខ្លួនឬការលាងបាបដោយខ្លួនឯង ។ ប៉ុន្តែសំនួរថាតើធ្វើដូចម្តេចទើបមុនស្សអាត្មានិយមអាចត្រាស់ដឹងបានសម្ពោធិញ្ញាណ ? និកាយទាំងពីរសុទ្ធតែទទួលស្គាល់យានទាំង៣ (three yanas or Bodhis) ប៉ុន្តែចាត់ទុកព្រះពោធិសត្វ (Bodhi sattva) ថាខ្ពស់ជាងគេបំផុត ។ ព្រះពុទ្ធសាសនាមហាយាន

បានបង្កើតតួអង្គព្រះពោធិសត្វជាច្រើនបែបជាទេវកថា រីឯព្រះពុទ្ធសាសនាថេរវាទចាត់ទុកព្រះពោធិសត្វថា ជាមនុស្សម្នាក់ដូចជាយើងរាល់ដែលបាន បូជាជីវិត ដើម្បីស្វែងរកបរិសុទ្ធភាពរហូតដល់ចុងក្រោយបានក្លាយទៅជាអ្នកត្រាស់ដឹងពេញលេញ ដូចព្រះពុទ្ធដើម្បីជួយស្វែងរកសុខមាលភាព និងសុភមង្គលដល់ពិភពលោក ។

**បុគ្គលដែលមានភាពជាព្រះពុទ្ធមានបីប្រភេទ**

មនុស្សដែលមានភាពជាព្រះពុទ្ធមានបីប្រភេទ គឺព្រះសម្មាសម្ពុទ្ធ ដែលជាអ្នកទទួលបាននូវការ ត្រាស់ដឹងពេញលេញដោយខ្លួនឯង ពុទ្ធបាសិកា (Pacceka Buddha) ដែលជាអ្នកមានគុណភាពតិចជាងព្រះសម្មាសម្ពុទ្ធ និងពុទ្ធសាវ៖ដែលជាសាវ៖របស់ព្រះអរហន្ត។ ការឈានទៅរកនិព្វានរវាងអ្នកដែលមាន ភាពជាព្រះពុទ្ធទាំងបីប្រភេទនេះមានលក្ខណៈដូចគ្នា។ ប៉ុន្តែអ្វីដែលខុសគ្នាត្រង់ថាព្រះសម្មាសម្ពុទ្ធមានគុណភាព និងសមត្ថភាពច្រើនជាងមនុស្សពីរប្រភេទទៀត។

អ្នកខ្លះ ឬមនុស្សខ្លះគិតថាការនិយាយពីអ្វីដែលទទេឬសូន្យ (Voidness) or (sunya) ដែលបានពិភាក្សាដោយ**ណាហ្គាយូន៖** (Nagarjuna) ជាអ្វីដែលស្ថិតក្នុងការបង្រៀនរបស់ព្រះពុទ្ធសាសនា**មហាយាន**សុទ្ធសាទ ។ទស្សន៖អំពីភាពទទេឬសូន្យជាទស្សន៖ផ្អែកជាមូលដ្ឋានលើគំនិតដែលនិយាយអំពី An-atta or non-self មិនមែនខ្លួននិងលើទ្រឹស្តីបដិច្ចៈសមុប្បាទ (Paticcasamu-ppada) ដែលគេបាន ឃើញនៅក្នុងអត្ថបទដើមជាភាសាបាលីក្នុងព្រះពុទ្ធសាសនាថេរវាទ។ នៅពេលមួយនោះព្រះអានន្ទបាន សួរព្រះពុទ្ធថាមានមនុស្សជាច្រើនបានប្រើពាក្យ Sunya តើពាក្យនេះមានន័យដូចម្តេច ? " ព្រះពុទ្ធ ឆ្លើយថា ព្រះអានន្ទ " មិនមានអត្ត (No self) ទេ គឺមិនមានអត្តដែលស្ថិតនៅនឹងជាមួយសភាវ៖ទាំងឡាយទេ នៅក្នុងលោកយើងនេះ។ ដូច្នេះពិភពលោកនេះជាពិភពទទេឬសូន្យ (Sunya) ។ ទស្សន៖នេះ ត្រូវបាន Nagarjuna យកមកបកស្រាយនៅពេលដែលលោកសរសេរសៀវភៅដ៏ល្បីមួយឈ្មោះ Ma dhyamika karika" ។ផ្សេងពីនេះទស្សន៖ដែលនិយាយអំពីភាពទទេ ឬសូន្យ (Sunya ta) ជាបញ្ញត្តិដែលដក់ជាប់នៅក្នុងស្មារតីនៃព្រះពុទ្ធសាសនាមហាយាន ប៉ុន្តែពាក្យនេះមានដើមកំណើតនៅក្នុង អត្ថបទព្រះពុទ្ធសាសនាថេរវាទ។ ពួកអ្នកកាន់ព្រះពុទ្ធសាសនានិកាយមហាយាន (Mahayani sts) បាន អភិវឌ្ឍន៍ពាក្យនេះឱ្យមានឥន័យជ្រៅនៅក្នុងមុខវិជ្ជាចិត្តវិទ្យា និងទស្សនវិជ្ជា។

## ៥.១ឧត្តមគតិពព្រះពោធិសត្វនៅក្នុងព្រះពុទ្ធសាសនា

(Bodhisattva Ideal in Buddhism) Ven. Dr. W. Rahula

ទស្សនៈទាំងឡាយនៅក្នុងព្រះពុទ្ធសាសនាថេរវាទត្រូវបានគេរកឃើញថា មានពិតប្រាកដនៅក្នុង និកាយព្រះពុទ្ធសាសនាហិនយាន គោលសំខាន់នៃលទ្ធិនេះគឺនាំមនុស្សអ្នកកាន់ប្រតិបត្តិអោយសម្រេចជាព្រះអរហន្ត ។ចំណែកឯគោលសំខាន់នៃលទ្ធិព្រះពុទ្ធសាសនាមហាយានគឺនាំអ្នកកាន់ប្រតិបត្តិឱ្យសម្រេចបានជាព្រះពោធិសត្វ និងជាចុងក្រោយឈានទៅទទួលសភាពជាព្រះពុទ្ធទាំងនេះគឺជាជំនឿមួយដែលមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយជាពិសេសនៅខាងបស្ចឹមប្រទេស ។ យើងអះអាងយ៉ាងដាច់ខាតថា ទស្សនៈខាងលើនេះមិនត្រឹមត្រូវទេ ។ ទស្សនៈនេះត្រូវបានផ្សព្វផ្សាយ ដោយពួកបូព៌ាប្រទេសមួយចំនួននៅខណៈ ដែលមានការចាប់ផ្តើមសិក្សាពីព្រះពុទ្ធសាសនានៅបស្ចឹមប្រទេសមុនដំបូងហើយអ្នកខ្លះ ដែលយល់ស្របដើរតាមទស្សនៈនេះយល់ព្រមទទួលយកទស្សនៈនេះដោយគ្មានលំបាកហើយនឹងមិនបង្ករទៅជាបញ្ហាអ្វីស្មុគស្មាញទេ ដោយគ្រាន់តែត្រួតពិនិត្យមើលអត្ថបទផ្សេងៗ និងទំលាប់ប្រពៃណីដែលនៅរស់រវើកនៅតាមបណ្តាប្រទេសដែលកាន់ព្រះពុទ្ធសាសនាតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែការពិតគឺថា ព្រះពុទ្ធសាសនានិកាយថេរវាទនិងនិកាយមហាយានបានយល់ព្រមជាឯកច្ឆ័នទទួលស្គាល់នូវទស្សនៈថា ព្រះពោធិសត្វជាអង្គព្រះដែលមានឧត្តគតិខ្ពស់ជាងគេទាំងអស់ ។

បញ្ញតិ "ហិនយាន (យាន្តតូច)" និង "មហាយាន (យាន្តធំ)" គឺគេមិនដែលឃើញទេនៅ ក្នុងនិកាយព្រះពុទ្ធសាសនាថេរវាទដែលសរសេរជាភាសាបាលី ។ បញ្ញត្តិទាំងពីរនេះក៏គេមិនដែលជួបប្រទះ សោះនៅក្នុងគម្ពីព្រះត្រ័យបិតកជាភាសាបាលី ឬក្នុងបទអត្ថាធិប្បាយព្រះត្រ័យបិតក ។ លើសពីនេះទៅ ទៀតបញ្ញតិទាំងពីរនេះក៏គេមិនដែលជួបប្រទះនៅក្នុងសៀវភៅពង្សាវតា ឬសៀវភៅកាលប្បវត្តិ នៅក្នុងក្រុងសីឡូន (Ceylon) ដូចជាសៀវភៅ ឌីប៉ាវ៉ាមសា (Dipavamsa) និងសៀវភៅម៉ាហាវ៉ាមសា (Mah- avamsa) ទាល់តែសោះ ។ សៀវភៅឌីប៉ាវ៉ាមសា(Dipavamsa)(សរសេរឡើងក្នុងកំឡុងសតវត្សទី៤ ក្រោយគ្រិស្តសករាជ) ហើយនិងបទអត្ថាធិប្បាយជាភាសាបាលីលើកឡើងឬអធិប្បាយអំពីវីថានតាវ៉ាតីន(Vitandavadins) បានបង្ហាញអោយឃើញយ៉ាងប្រត្យក្សនូវ និកាយមួយដែលពុទ្ធសាសនិកមានការខ្វែង យោបល់គ្នា គឺប្រតិបត្តិតាមទស្សនៈដែលមិនប្រកាន់តាមវិន័យចាស់ត្រង់ចំណុចខ្លះៗ ដែលព្រះពុទ្ធអង្គបានបង្រៀនកន្លងមក ។ បទអត្ថាធិប្បាយ វីថានតាវ៉ាតីន និងថេរវ៉ាវ៉ាតីន (Theravadin) ទាំងពីរនេះសុទ្ធ តែដកស្រង់ចេញពីប្រភពឯកសារតែមួយដូចគ្នាគឺសៀវភៅសូត្រនៃ គម្ពីរព្រះត្រ័យ

បិតក ដើម្បីយកមកធ្វើ ជាទឡ្ហីករណ៍ក្នុងការគាំទ្រសំណើរនានាក្នុងសៀវភៅទាំងពីរនេះ។ បទអត្ថាធិប្បាយទាំងពីរនោះខុសគ្នាតែត្រង់ម៉ូតឬរបៀបនៃការបកស្រាយតែប៉ុណ្ណោះ។ សៀវភៅម៉ាហាវ៉ាំមសា(សរសេរឡើងនៅក្នុងកំឡុងសតវត្សទី៥ក្រោយគ្រិស្តករាជ) និងបទអត្ថាធិប្បាយស្តីអំពីអភិធម្ម (Abhidhamma) អត្ថាធិប្បាយអំពី វ៉េថូឡា (Vetulla) ឬ វ៉េថូឡាវ៉ាតីន (Vetulyavadins) សរសេរជាភាសាសំស្ក្រឹត Vaitulyavadin ជំនួសអោយ វីថានតាវ៉ាតីន។ ផ្តើមចេញពីភាពប្រត្យក្សនៅក្នុងអត្ថបទទាំងនោះ វាប្រហែលជាមិនខុស ទេដែលគិតថា បញ្ញត្តិទាំងពីរនេះ វីថាន់តា (Vitanda) និងវ៉េថូលីយ៉ា (Vetulya) តំណាងឬបង្ហាញ ឱ្យឃើញថាជានិកាយដូចគ្នា។

យើងសិក្សាពីអភិធម្មសមុស្សាយ (Abhidhamma Samuccaya) ជាអត្ថបទស្បែនវិជ្ជាព្រះពុទ្ធសាសនាមហាយានដែលអាចយកជាការបាន(សរសេរឡើងក្នុងសតវត្សទី៤ ក្រោយគ្រិស្តសករាជ)បានបង្ហាញអោយឃើញថា បញ្ញត្តិ វ៉ាយថូលីយ៉ា (Vaitulya) និងវ៉ាផូលីយ៉ា (Vaipulya) គឺជា វេវចនៈនិង បញ្ញត្តិ វ៉ាផូលីយា គឺជាព្រះពោធិសត្វបិតក (Bodhisattva-Pittaka) ហើយឥឡូវនេះ ពោធិសត្វបិតកគឺជា មហាយានពិតប្រាកដ។ ដូច្នេះ វ៉ាយថូលីយាជាសញ្ញាកំណត់ថា ជាមហាយានដោយគ្មានអ្វីសង្ស័យឡើយ។

ដូចនេះយើងក៏អាចជឿជាក់យ៉ាងប្រាកដថា បញ្ញត្តិ វីថាន់តា និងវ៉េថូលីយាត្រូវបានគេប្រើប្រាស់ នៅក្នុងអត្ថបទកាលប្បវត្តិ និងអត្ថបទអត្ថាធិប្បាយដែលសរសេរជាភាសាបាលីសំដៅចំពោះ មហាយាន។ ក៏ប៉ុន្តែបញ្ញត្តិ "ហិនយាន" និង"មហាយាន" គេរកមិនឃើញឬមិនដែលជួបប្រទះនៅក្នុងអត្ថបទទាំងនោះទេ។

អ្នកប្រាជ្ញទាំងឡាយទទួលស្គាល់ជាសកលថា បញ្ញត្តិហិនយាន និងមហាយានត្រូវបានគេប្រឌិត ឡើងនៅពេលក្រោយៗទេ។ បើនិយាយនៅក្នុងប្រវត្តិសាស្រ្តវិញ ថេរវាទបានមានអត្ថិភាពរួចហើយមាន អាយុយូរអង្វែងមុនពេលដែលបញ្ញត្តិទាំងពីរ(ហិនយាន និងមហាយាន) នេះមានអត្ថិភាព។ ថេរវាទ ត្រូវបានគេចាត់ថា ជានិកាយមួយដែលរក្សានូវប្រភពដើមនៃការបង្រៀនរបស់ព្រះពុទ្ធ ហើយត្រូវបានគេ ណែនាំអោយស្គាល់នៅទីក្រុងស៊ីឡូន ហើយត្រូវបានគេរៀបចំបោះពុម្ពផ្សាយនៅទីនោះ ក្នុងសតវត្សទី៣ មុនគ្រិស្តសករាជ គឺនៅក្នុងអំលុងពេលនៃការគ្រងរាជរបស់ស្តេចចក្រពត្តិ **អសោក** (Asoka) ក្នុងប្រទេស ឥណ្ឌានៅសម័យនោះគ្មានដែលលឺគេនិយាយពីមហាយានទេ។ មហាយានកើតនៅសម័យក្រោយមកទៀត គឺប្រហែលជា

នៅដើមគ្រិស្តសករាជប៉ុណ្ណោះ។ បើគ្មានមហាយាននោះអាចក៏គ្មានហិនយានដែរ។ លិទ្ធិព្រះពុទ្ធសាសនាបានធ្វើការផ្សព្វផ្សាយចូលទៅក្នុងប្រទេសសេរីលង្កា ដោយមានគម្ពីរព្រះត្រៃបិតក និងបទអត្ថាធិប្បាយផ្សេងៗ ក្នុងសតវត្សទី៣ក្រោយគ្រិស្តសករាជដោយរក្សាអោយនៅដដែល គ្មានខូចខាត អ្វីទាំងអស់នូវទំរង់ថេរវាទ ហើយឥតមានក្លាយជាវិការដ្ឋាន (កន្លែងដែលព្រឹត្តិការណ៍អ្វីមួយកើតឡើង) នៃភាពខ្វែងគំនិតគ្នារវាង ហិនយាន និងមហាយានទេ។ វិការដ្ឋាននេះបានកើតឡើងក្រោយទៀតនៅក្នុងប្រទេសឥណ្ឌា។ ដូចនេះវាហាក់ដូចជាមិនត្រឹមត្រូវតាមច្បាប់ទេដែលសន្និដ្ឋានថា ថេរវាទស្ថិតក្នុងលំដាប់ប្រភេទស័ព្ទទាំងពីរនេះ។

គោលទស្សនៈសំខាន់នៅក្នុងនិកាយមហាយាននេះ គឺភ្ជាប់ទៅនឹងយានរបស់ព្រះពោធិសត្វ (Bodhisattvayana or The Vehicle of the Bodhisattva)។ ក៏ប៉ុន្តែគោលគំនិតក្នុងលិទ្ធិនេះមិនមែនអើពើ និងយានរបស់ព្រះពីរព្រះអង្គទៀតទេ គឺស្រាវ៉ាកាយាន (Sravaka-yana) និងព្រះចៃកពុទ្ធយាន(Pratyeka-buddha-yana)។ ជាឧទាហរណ៍លោកអសាំងហ្គា(Asanga) ដែលជាអ្នកបង្កើតប្រពន្ធ័ យោហ្គាការ៉ា (Yogacara) និងយ៉ាហ្គាការា ភូមិសាស្ត្រា (yagacara bhumisastra) នៅក្នុងសៀវភៅ របស់លោកមានចំណងជើងថា ម៉ាហ្គានឹម អូភីស (Maganum Opus) ដែលសៀវភៅនេះមានពីរជំពូក សរសេរពី ស្រាវ៉ាកា ភូមិ (Sravakabhumi) ព្រះច្ចេកពុទ្ធភូមិ(Pratyekabuddha-bhumi)និងពោធិសត្វភូមិ(Bodhisattvabhumi)ហើយខ្លឹមសារក្នុងសៀវភៅនេះបង្ហាញថាយានទាំងបីដែលលើក មកនិយាយនេះសមនឹងទទួលយកមកគិតពិចារណានៅក្នុងមហាយាន។ ក៏ប៉ុន្តែសភាពរបស់ស្រាវ៉ាកា ឬសភាពរបស់ព្រះចៃកពុទ្ធ មានសភាពតូចទាបជាងសភាពរបស់ព្រះពោធិសត្វ។ ទស្សនៈនេះគឺរក្សាទុកដូចគ្នានៅក្នុងប្រពៃណីថេរវាទ (គោលទស្សនៈក្នុងថេរវាទ) ដែលជឿថាមានតែព្រះមួយព្រះអង្គគត់ ដែលអាចក្លាយទៅជាព្រះពោធិសត្វ ហើយទទួលបាននូវសភាពពេញលេញជាព្រះពុទ្ធដែលបានត្រាស់ដឹង។ ក៏ប៉ុន្តែបើគ្មានជំនឿគឺមិនអាចសម្រេចបាននូវសភាពជាព្រះពោធិសត្វទេ គ្មានជំនឿនោះអាចទទួលបាននូវ សភាពជាព្រះចៃកពុទ្ធ ឬជាស្រាវ៉ាកាអាស្រ័យទៅនឹងសមត្ថភាព និងលទ្ធភាពរបស់គេ។ សភាពទាំងបីនេះត្រូវបានគេចាត់ទុកថាជាការសម្រេចផលបានបីប្រការតាមដំណើរលើមាគ៌ាដូចគ្នា។ ជាការពិតសន្ធិនាម៉ូការសូត្រ (Sandhinirmocan-sutra) (មហាយានសូត្រ) និយាយឬបរិយាយយ៉ាងច្បាស់ថាស្រាវ៉ាកាយាននិងមហាយានរួមគ្នាទៅជាយានតែមួយឯកយាន (ekayana) ហើយយានទាំពីរមិនមែនជាយានខុសគ្នានិងផ្សេងគ្នាទេ។

**ព្រះទីព្រះអង្គ (ឯកត្តជនទាំងបី)**

នណាជាឯកត្តជន (ព្រះ) ទាំងបីព្រះអង្គនោះ ? សូមលើកមកបង្ហាជូនដោយសង្ខេប គឺមានៈ ស្រាវ៉ាក ព្រះចែកពុទ្ធ និងព្រះពោធិសត្វ :

ស្រាវ៉ាកា គឺជាសាវ័ករបស់ព្រះពុទ្ធ។ សាវ័កអាចជាព្រះសង្ឃ (បុព្វជិក) ឬជាដូនជី (សមណី) ឬ ជាឧបាសក ឬឧបាសិកាដែលសង្រួម ឬជំនះបានលើភាពសេរីរបស់ខ្លួន។ ស្រាវ៉ាកា ដើរតាមគោលទស្សនៈ និងប្រតិបត្តិតាមគោលទស្សនៈ និងការបង្រៀនរបស់ព្រះពុទ្ធ ហើយជាអវសាននឹងបានសម្រេចផលទៅកាន់និព្វាន។ ស្រាវ៉ាកា ក៏ជួយបម្រើអ្នកផងទាំងពួង ដែលនៅជុំវិញខ្លួនផងដែរ ក៏ប៉ុន្តែសមត្ថភាពនិងលទ្ធភាពក្នុង ការបម្រើជួយសង្គ្រោះអ្នកដទៃ នៅមានកម្រិតនៅឡើយ។

ព្រះច្ចេកពុទ្ធ (បុគ្គលព្រះពុទ្ធ) គឺជាមនុស្សដែលត្រាស់ដឹងនិព្វានមួយព្រះអង្គឯងគត់ ដោយខ្លួនព្រះអង្គផ្ទាល់នៅខណៈដែលពេលនោះគ្មានសាមយាកាកសាមពុទ្ធ (Samyakaksambuddha) ណាមួយអង្គសោះនៅលើលោកយើងនេះ។ ព្រះអង្គក៏បានផ្តល់នូវសេវាសង្គ្រោះ ជួយដល់អ្នកដទៃដែលនៅជុំវិញព្រះអង្គផងដែរ ក៏ប៉ុន្តែស្ថិតក្នុងលំដាប់មាត៌ាកំរិតកំណត់។ ព្រះអង្គមិនអាចមានសមត្ថភាព និងលទ្ធភាពក្នុងការបញ្ចេញឱ្យឃើញនូវសច្ចភាពទៅដល់អ្នកដទៃ ដែលនៅជុំវិញព្រះអង្គដូចសាមយាកាកសាមពុទ្ធដែលជាព្រះពុទ្ធបានត្រាស់ដឹងហើយបានសម្តែងនោះទេ។

ព្រះពោធិសត្វ គឺជាមនុស្ស (ព្រះសង្ឃ ឬជាឧបាសក) ដែលស្ថិតនៅត្រង់ទីតាំងឈានទៅសម្រេចផលក្នុងនិព្វានដូចស្រាវ៉ាកឬដូចព្រះច្ចេកពុទ្ធក៏ប៉ុន្តែដោយមានមហាករុណាជាចម្បងចំពោះអ្នកដទៃក្នុង ពិភពលោកយើងនេះ។ គាត់លះបង់មហាករុណានេះហើយបន្តរងនូវក្តីឈឺចាប់វេទនានៅក្នុងសំសារៈ (វាលវដ្តសង្សា) ដើម្បីជាប្រយោជន៍របស់អ្នកដទៃ ហើយខិតខំលំអិតសម្អាងកែលំអរខ្លួនឯងផ្ទាល់ ក្នុងអំឡុងពេលដែលមិនអាចគណនាបានមួយហើយទីបំផុតនឹងបានត្រាស់ដឹងនូវនិព្វានហើយក្លាយទៅជាសាមយាកាកសាមពុទ្ធ ដែលជាព្រះពុទ្ធបានត្រាស់ដឹងពេញលេញមួយអង្គ។ ព្រះអង្គរកឃើញសច្ចធម៌ ហើយផ្សាយសច្ចធម៌នេះទៅគ្រប់ទីកន្លែងក្នុងពិភពលោកយើង។ សមត្ថភាពនិងលទ្ធភាពរបស់ព្រះអង្គក្នុង ការជួយសង្គ្រោះអ្នកដទៃគ្មានព្រំដែនកំណត់ទេ។

អត្ថន័យនៃ យ៉ានីកា (Yanikas) ទាំងបី (សាវ័ក ឬអ្នកដើរតាមយានទាំងបី) ដែលបានពន្យល់និងបង្ហាញដោយលោក អាសាំងហ្គា គឺជាផ្នែកមួយដែលមានតម្លាភាព និងមាន

ប្រយោជន៍បំផុត។ ដោយយោងទៅតាមទស្សនៈរបស់លោក លោកបានពន្យល់ថា ស្រាវ៉ាកាយ៉ានីកា Sravakayanika (មនុស្សម្នាក់ដែលប្រកាន់យកយានដ៏ជាសាវ័ក) គឺជាមនុស្សម្នាក់ដែលរស់នៅអាស្រ័យទៅតាមច្បាប់ ឬ និយាមសាវ័ក។ តាមធម្មតាមានសម្បទាខាង ធ្វើអ្វីបានដោយងាយនោះតិចតួចណាស់ (គុណភាព) ជំនះ លើភាពសេរីរបស់ខ្លួនតាមរយៈការអប់រំដាច់តែឯងអាស្រ័យទៅលើលទ្ធិ ឬគោលទស្សនៈរបស់សាវ័ក ស្រាវ៉ាកាពីថាកា (Sravaka-pitaka) ដោយការប្រតិបត្តិនូវគុណសម្បត្តិតូចធំទាំងឡាយហើយបញ្ចប់នូវក្តីឈឺចាប់វេទនាបន្តិចម្តងៗ។ ព្រះច្ចេកពុទ្ធ យ៉ានីកា A pratyeka-Buddha-yanika (មនុស្សដែល ប្រកាន់យកតាមយានរបស់ព្រះពុទ្ធអង្គផ្ទាល់) គឺជាមនុស្សដែលរស់នៅទៅតាមច្បាប់ ឬនិយាមរបស់បុគ្គលព្រះពុទ្ធ។ តាមធម្មតាមានសម្បទាខាងធ្វើអ្វី មួយដោយងាយជាមធ្យមជំនះលើភាពសេរីរបស់ខ្លួន តាមរយៈការអប់រំដាច់តែឯង ហើយគាត់មានបំណងឈានទៅសម្រេចការត្រាស់ដឹងទាំងស្រុងតាមរយៈការអភិវឌ្ឍន៍ញ្ញាណសតិរបស់គាត់ផ្ទាល់។ ដោយយោងទៅតាមស្រាវ៉ាកាពីថាកា ការប្រតិបត្តិនូវ គុណសម្បត្តតូចធំកើតមាននៅខណៈពេល ដែលគ្មានព្រះពុទ្ធនៅលើពិភពលោកយើងនេះហើយឈានទៅបញ្ចប់នូវក្តីឈឺចាប់វេទនាបន្តិចម្តងៗ។មហាយ៉ានីកា (A mahayanika) (មនុស្សដែលប្រកាន់យកតាមយានដ៏ធំ) គឺជាមនុស្សដែលរស់នៅទៅតាមច្បាប់ ឬនិយាមរបស់ពោធិសត្វ។ តាមធម្មតាបានសម្រិតសម្រាំង សម្បទាខាងធ្វើអ្វីមួយដោយងាយឱ្យបានប្រណិតឡើងជំនះលើភាពសេរីរបស់ភាវៈទាំងអស់ ដោយអាស្រ័យទៅតាមគោលទស្សនៈរបស់ ព្រះពោធិសត្វធ្វើឱ្យភាវៈទាំងឡាយមានគំនិតមាយាទចាស់ទុំបណ្តុះភាពបរិសុទ្ធដែលព្រះពុទ្ធផ្តល់ឱ្យទទួលយកនូវការព្យាករណ៍ ឬពុទ្ធដីការវីយ៉ា ការណា (Vya-karana) ពីព្រះពុទ្ធទាំងអស់។ ជាអវសានបានត្រាស់ដឹងពេញលេញឥតខ្ចោះ សាមយ៉ាកសាមពុទ្ធិ ( Samyaksambodhi)

ទាញពីការបង្ហាញខាងលើនេះយើងអាចមើលឃើញថា នរណាម្នាក់ដែលប្រាថ្នាក្លាយខ្លួនជាព្រះពុទ្ធគឺជាព្រះពោធិសត្វដែលជាអ្នកកាន់ព្រះពុទ្ធសាសនាមហាយានទោះបីជាគេរស់នៅក្នុងប្រទេស ឬ ក៏នៅក្នុងសហគមន៍ ដែលនិយមតាមប្រពៃណីគោរពព្រះពុទ្ធសាសនាថេរវាទ ឬហិនយានក៏ដោយ។ ស្រដៀងគ្នានេះដែរ នរណាម្នាក់ដែលប្រាថ្នាសម្រេចផលនៅនិព្វានដូចជាសាវ័ក ស្រាវ៉ាកាយ៉ានីកា Sravak- ayanika គឺជាអ្នកកាន់ពុទ្ធសាសនាហិនយាន ទោះបីជាគេរស់នៅក្នុងប្រទេស ឬសហគមន៍ដែលគេចាត់ ទុកថាគោរពជឿលើព្រះពុទ្ធសាសនាមហាយានក៏ដោយ។ ដូចនេះវាពិតជាខុសដែលយើងជឿថា គ្មានអង្គព្រះពោធិសត្វនៅក្នុងបណ្តា ប្រទេស

កាន់ព្រះពុទ្ធសាសនាថេរវាទ ឬថាមានតួអង្គព្រះពោធិសត្វ តែនៅក្នុងបណ្តាប្រទេសដែល កាន់ព្រះពុទ្ធសាសនាមហាយាន។ គេមិនអាចគិតទៅដល់ថា ស្រាវ៉ាកា និងពោធិសត្វ ត្រូវបានគេចាប់អារម្មណ៍តែទៅតាមតំបន់ភូមិសាស្ត្រទីទៃៗ ពីគ្នានោះទេ។

បន្ថែមពីលើនេះទៅទៀតលោកអាសាំងហ្គាមានប្រសាសន៍ថា ពេលណាព្រះពោធិសត្វមួយ អង្គបានសំរេចការត្រាស់ដឹងចុងក្រោយពុទ្ធិ (Bodhi) ព្រះអង្គនោះក្លាយទៅជាព្រះអរហន្ត (Arahant) កថាគត (a Tathagata) ពោលគឺព្រះពុទ្ធនៅពេលនេះគេពិតជាយល់ច្បាស់ថាមិនមែនមានតែ ស្រាវ៉ាកា (សាវ៉ក) ក៏ប៉ុន្តែក៏មានព្រះពោធិសត្វដែរ ដែលក្លាយទៅជាព្រះអរហន្ត នៅពេលគេបានឈានទៅសំរេច ភាពជាព្រះពុទ្ធនៅខណៈចុងក្រោយនោះ។ ទស្សនៈក្នុងព្រះពុទ្ធសាសនាថេរវាទគឺដូចគ្នាបេះបិទត្រង់ថា ព្រះពុទ្ធគឺជាព្រះអរហន្តសម្មាសម្ពុទ្ធ (Araham Samma-Sambuddha)" ព្រះអរហន្តគឺជាព្រះពុទ្ធ ដែលបានត្រាស់ដឹងយ៉ាងសុក្រិតនិងពេញលេញ"។

ដោយនិយាយពីពុទ្ធសាសនាមហាយានអោយបានច្បាស់លាស់គឺថាៈ ព្រះពុទ្ធ ព្រះច្ចេកពុទ្ធ និងស្រាវ៉ាកា (សាវ៉ក) ព្រះទាំងបីព្រះអង្គនេះមានថានៈស្មើគ្នា និងដូចគ្នា បើយើងគិតអំពីបរិសុទ្ធកម្ម និងការរំដោះពីភាពមិនសុទ្ធ ឬភាពកខ្វក់របស់ព្រះទាំងបីព្រះអង្គនោះ ក្លេសាវ៉ារ៉ាណាវិសុទ្ធ (Klesavaranavis- uddhi) ។ បរិសុទ្ធកម្មនេះគេអាចហៅថា វិមុកទីកាយា (Vimukti-kaya) (ការលាងជំរះកាយ) ហើយនៅក្នុងការរំដោះ និងសំអិតសំអាងកាយរបស់ព្រះទាំងបីព្រះអង្គនោះគ្មានកន្លែងណាមួយខុសគ្នាទេ នោះគឺមានន័យថា គ្មាននិព្វាន ឬវិមុកទី (Vimuktis) ខុសគ្នាចំនួនបីសំរាប់ព្រះទាំងបីព្រះអង្គនោះទេ។ និព្វានឬ វិមុកទី គឺដូចគ្នា និងតែមួយសម្រាប់ព្រះទាំងបីព្រះអង្គនេះ។ ក៏ប៉ុន្តែគឺមានព្រះពុទ្ធតែមួយអង្គឯងគត់បាន សម្រេចនូវការរំដោះពីរបាំងឬការរេរាំងផ្សេងៗឈានទៅដល់ភាពអាចដឹងឬយល់បានអ្វីៗទាំងអស់ពោលគឺការរំដោះខ្លួនចេញ ពីអាថ៌កំបាំងទៅកាន់ពុទ្ធីញ៉ីយ៉ាវ៉ារ៉ាណាវិសុទ្ធ (Jneyyavaranavisuddhi) ហើយស្រាវ៉ាកា និងព្រះច្ចេកពុទ្ធមិនបានសម្រេចការរំដោះនេះទេ។ បរិសុទ្ធកម្មនេះគេអាចឱ្យឈ្មោះផងដែរ ថាធម្មកាយ (Dharma-kaya) បរិសុទ្ធកម្មមានលក្ខណៈសម្បត្តិជាច្រើន ដែលមិនអាចគណនាបាន ដូចជា គុណសម្បត្តិ សមត្ថភាព និងបំនិនដែលធ្វើអោយព្រះពុទ្ធក្លាយទៅជាអង្គព្រះមួយ ដែលគ្មានគូរប្រដូច ហើយជាព្រះមួយអង្គខ្ពង់ខ្ពស់ជាង ព្រះស្រាវ៉ាកា និង ព្រះច្ចេកពុទ្ធផ្សេងៗទៀត។

ទស្សនៈមហាយាននេះរក្សាទាំងស្រុង ទៅតាមគម្ពីរព្រះត្រៃបិតកជាភាសាបាលីនៅក្នុងព្រះពុទ្ធ សាសនាថេរវាទ។ នៅក្នុងនិកាយសាមយុត្ត (Samyutta nikaya) ព្រះពុទ្ធមានព្រះបន្ទូលថា : កថាគត (ពោលគឺព្រះពុទ្ធ) និងភិក្ខុ(Bhikkhu) (ពោលគឺស្រាវ៉ាកា សាវ័ក) បានរំដោះតាមរយៈគតិបណ្ឌិតស្មើគ្នា ដោយគោរពចំពោះវិមុតា (Vimutta) (ការរំដោះ) ក៏ប៉ុន្តែការរំដោះរបស់កថាគតល្បីល្បាញ និងខុសប្លែកពីភិក្ខុដែលនៅក្នុងការរំដោះនោះព្រះអង្គ (ព្រះពុទ្ធ) រកឃើញនិងបង្ហាញនូវមាគ៌ា (Magga) ដែលគេមិនធ្លាប់ដែលលឺ និងស្គាល់ពីមុនមក។

សភាពទាំងបីជា ស្រវ៉ាកា ព្រះច្ចេកពុទ្ធ និងព្រះពុទ្ធនេះត្រូវបានអធិប្បាយ នៅក្នុងបទអត្ថាធិប្បាយនិទ្ធិកាន់ដាសុតា(Nidhikanda-Sutta) ក្នុងសៀវភៅឃុដាកាប៉ាថា (Khuddakapatha) គឺជាសៀវភៅដំបូងគេនៃ ឃុដាកា និកាយា (Khuddaka-nikaya) ដែលជាសៀវភៅមួយក្នុងចំណោមសៀវភៅទាំង៥ ដែលចងក្រងក្នុងព្រះត្រៃបិតកថេរវាទ។ ក្នុងសៀវភៅនោះបានសរសេរថា: ដោយការប្រតិបត្តិគុណធម៌ដូចជាសេចក្តីសប្បុរស ឬការឱ្យទានសីលធម៌ ស្វ័យអត់ធ្មត់ ឬខន្តី។ល។ ពេលនោះគេងាយសំរេចបាននូវប្រណិតភាពជាសាវ័ក ស្រាវ៉ាកា ប៉ារ៉ាមី (Savaka-Parami) " ការត្រាស់ដឹងរបស់ព្រះ ព្រះច្ចេកពុទ្ធ " (Paccek aboddhi) ហើយ និងសិទ្ធ ឬសភាពជាព្រះពុទ្ធ Buddha-domair (Buddhabhumi) ។ សភាពទាំងអស់នេះគេមិនហៅថា យាន Yanas (Vehieles) ទេ។

នៅក្នុងប្រពៃណីថេរវាទ សភាពទាំងអស់នេះត្រូវបានគេស្គាល់ថា ជាពុទ្ធិ ក៏ប៉ុន្តែមិនមែនយានទេ។ ឧបាសិកាហ្សាណាឡានការ៉ា (Upasaka-janalankara) អភិប្រាយជាភាសាបាលីទាក់ទិនទៅនឹងក្រមសីលធម៌សម្រាប់ពុទ្ធសាសនិកដែលជាគ្រហស្ថបានសរសេរនៅក្នុង សតវត្សទី១២ ដោយព្រះថេរមួយ ព្រះអង្គព្រះនាមអនន្ត (Ananda) នៅក្នុងប្រពៃណីថេរវាទរបស់មហាវិហារ៉ា (Mahavihara) នៅតំបន់អានូរ៉ាដពូរ៉ា (Anuradhpura) ក្នុងប្រទេសសេរីសង្កា Srilanka អភិប្រាយនោះបាននិយាយថា:មានពុទ្ធិ **៣**គឺ : សាវ៉ាកាពុទ្ធ (Savakabodhi) (ភាសាសំស្ក្រឹត :ស្រាវ៉ាកាពុទ្ធ (Sravakabodhi)) ព្រះច្ចេកពុទ្ធ (សំស្ក្រឹត : Pratyekabodhi) និង សម្មាសម្ពុទ្ធិ (សំស្ក្រឹត: Samyaksambodhi) ។គ្រប់ជំពូកទាំងអស់ក្នុងសៀវភៅនេះត្រូវបានបូជាចំពោះការពិភាក្សាជុំវិញពុទ្ធិទាំងបីនេះដោយមានសេចក្តីលំអិតពិស្តារ។ ក្នុងអភិប្រាយនេះបាននិយាយបន្ថែមទៀតថា នៅពេលដែលសាវ័កម្នាក់ទទួលពុទ្ធិ (ការត្រាស់ដឹង) សាវ័ករូបនោះត្រូវបានគេឱ្យឈ្មោះថា សាវ៉ាកាពុទ្ធិ (សំស្ក្រឹត Sravaka-buddha) ។

## ព្រះពោធិសត្វ

ដូចព្រះពុទ្ធសាសនាមហាយានដែរ ព្រះពុទ្ធសាសនាថេរវាទជឿថាព្រះពោធិសត្វគឺ ជាព្រះមួយអង្គ ដែលមានតំណែងខ្ពស់ជាងគេ។ បទអត្ថាធិប្បាយស្តីអំពី ជាតាកា (Jataka) នៅក្នុងប្រពៃណីនៃ មហាវិហារ៉ា (Mahavihara) នៅតំបនអានូរ៉ាដពូរ៉ា (Anuradhapura) ផ្តល់ឱ្យនូវឧទាហរណ៍យ៉ាង ច្បាស់លាស់មួយ គឺក្នុងភាពងងឹតអតីតកាលមួយ ពោលគឺនៅក្នុងសម័យដ៏យូរលង់ ដែលមិនអាចគណនាបានកន្លងមកនេះ Gotama ព្រះពុទ្ធសមណគោត្តមគឺក្នុងអំឡុងពេលដែលអាជីព (សភាព) របស់ ព្រះអង្គជាព្រះពោធិសត្វ ដែលគេអោយឈ្មោះថាតាបសស៊ូមេដា (Sumedha)។ នៅពេលនោះមាន ព្រះពុទ្ធមួយព្រះអង្គដែលមានព្រះនាមថាឌីប៉ានការ៉ា (Dipankara)ដែលកាលនោះព្រះពោធិសត្វបានជួបហើយនៅត្រង់ព្រះបាទរបស់ព្រះឌីប៉ានការា ព្រះពោធិសត្វមានសមត្ថភាពយល់ដឹងពីនិព្វាន ដូចសាវ័ក (Sravaka) ក៏ប៉ុន្តែព្រះ ស៊ូមេដាបានលះបង់សមត្ថភាពយល់ដឹងពីនិព្វាននោះ ហើយបានតាំងចិត្ត ដោះស្រាយដោយប្រើមហាករុណាសម្រាប់ពិភពលោកទាំងមូល ដើម្បីអោយក្លាយទៅជា ព្រះពុទ្ធមួយអង្គ ដូច ឌីប៉ានការាដើម្បីសង្គ្រោះមនុស្សទាំងឡាយនៅក្នុងលោកយើងនេះ។ បន្ទាប់មកព្រះពុទ្ធ ឌីប៉ានការា បានមានព្រះបន្ទូលនិងព្យាករណ៍ថា នេះគឺជាតាបសមួយអង្គ ដែលនៅថ្ងៃណាមួយនឹងក្លាយ ទៅជាព្រះពុទ្ធមួយអង្គហើយ និងផ្តល់នូវអដ្ឋង្គមគ្គទៅដល់សាវ័ករបស់តាបសស៊ូមេដាពិតប្រាកដមិនខាន។ ដូចគ្នានេះដែរពួកសាវ័ករបស់ព្រះពុទ្ធ ឌីប៉ានការា ដែលនៅជាមួយព្រះអង្គ ហើយដែលពួកគេទាំងអស់នោះសុទ្ធតែជាព្រះអរហន្ត និងបានផ្តល់ទៅដល់សាវ័កក្រោយៗ របស់ព្រះទៅជាព្រះពោធិសត្វ។ ដំណើររឿងរបស់តាបស ស៊ូមេដា នេះមានបង្ហាញពីទស្សនៈព្រះពោធិសត្វ នៅក្នុងព្រះពុទ្ធសាសនាថេរវាទខុសៗគ្នា។

ទោះបីជាយ៉ាងណាក៏ដោយព្រះពុទ្ធសាសនាថេរវាទជឿថា នរណាក៏ដោយក៏អាចក្លាយជា ព្រះពោធិសត្វបានដែរ វាមិនមានបដិញ្ញាត (ការចែកលក្ខខណ្ឌ) ឬក៏ទទួចថា អ្នកទាំងអស់ត្រូវតែជា ព្រះពោធិសត្វដែលគេចាត់ទុកដោយគ្មានគិតពីការប្រតិបត្តិនោះទេ។ សេចក្តីសម្រេចនោះគឺកំណត់ទៅលើបុគ្គលថា តើគេកំណត់ទៅតាមមាគ៌ារបស់ស្រាវ៉ាកា ឬព្រះច្ចេកពុទ្ធ ឬក៏ទៅតាមមាគ៌ារបស់ សាមយ៉ាកសាមពុទ្ធ (Samyaksambuddha) ។ ក៏ប៉ុន្តែជានិច្ចកាលគេអាចពន្យល់បានយ៉ាងច្បាស់ថា សភាពរបស់ព្រះសាមយ៉ាកសាមពុទ្ធ មានភាពខ្ពង់ខ្ពស់ជាងគេ ហើយសភាពរបស់ព្រះពីរអង្គទៀតមានភាពទាបឬអន់ជាង ក៏ប៉ុន្តែគេមិនដែលយកជាបានការទេ។

ក្នុងប្រទេសភូមា នៅសតវត្សទី១២ ក្រោយគ្រិស្តសករាជ (ជាប្រទេសមួយកាន់ពុទ្ធសាសនាថេរវាទយ៉ាងម៉ត់ចត់) មានស្តេចមួយព្រះអង្គព្រះនាម អាឡោងស៊ីធុ (Alaungsithu) គ្រងរាជ្យនៅ ទីក្រុងប៉ាហ្កាន (Pagan) កាលនោះបន្ទាប់ពីព្រះអង្គកសាងប្រាសាទ ស្វេហ្គូយី (Shwegugyi) រួចហើយ ព្រះអង្គអោយគេរៀបចំចំណារជាអក្សរចារឹកនូវ កំណាព្យជាភាសាបាលី ដើម្បីកត់ត្រាទុកនូវសកម្មភាព ស្រលាញ់ និងគោរពសាសនា ហើយនៅក្នុងកំណាព្យស្តេចអង្គនោះបានប្រកាសជាសាធារណៈថា ព្រះអង្គបានធ្វើអធិដ្ឋាន (តាំងចិត្ត) ធ្វើខ្លួនឱ្យទៅជាព្រះពុទ្ធពិតប្រាកដគឺមិនមែនជាព្រះស្រាវ៉ាកា ទេ។

ក្នុងប្រទេសសេរីលង្កា នៅសតវត្សទី១០ មានស្តេចមួយព្រះអង្គព្រះនាមមហិនដា (Mahinda) ទី៤ (គ្រងរាជក្នុងអំលុងឆ្នាំ៩៥៦-៩៧២AD)។ នៅក្នុងអក្សរចំណាចារឹកមួយបានប្រកាសថា: "គ្មាននណាក្រៅពីព្រះពោធិសត្វទេ ដែលនឹងអាចក្លាយជាស្តេចគ្រងរាជ្យនៅ ក្នុងប្រទេសសេរីលង្កានេះ (ក្រុង Ceylon)" ដូចនេះគេជឿថា ស្តេចនៃប្រទេសសេរីលង្កាគឺ ជាព្រះពោធិសត្វ។ ព្រះថេរ Thera មួយ ព្រះអង្គដែលមានព្រះនាមថាមហាតីពីតាកា (Maha Tipitaka) គូឡាបាយ៉ា (Culabhaya)ដែលជា អ្នកនិពន្ធសៀវភៅមីលីនដាតីកា (Milinda-Tika) (ក្នុងអំឡុងសតវត្សទី១២ក្រោយគ្រិស្តសករាជ) ក្នុងប្រពៃណីពុទ្ធសាសនាថេរវាទរបស់មហាវីហារ៉ា (Mahavihara) នៅក្រុងអានូរ៉ាដាពូរ៉ា (Anuradhapura) នៅផ្នែកខាងចុងនៃសៀវភៅ គឺនៅត្រង់ទំព័រទស្សនៈទូន្មានរបស់អ្នកនិពន្ធបានសរសេរថា: ព្រះអង្គប្រាថ្នា ក្លាយខ្លួនទៅជាព្រះពុទ្ធប៊ូដូបាវ៉ាយ៉ាម (Buddho Bhavayyam) "ខ្ញុំសូមបួងសួងអោយក្លាយខ្លួនជាព្រះពុទ្ធ" ក្នុងឃ្លានេះមានន័យថា អ្នកនិពន្ធគឺជា ព្រះពោធិសត្វ។

យើងបានអានសាស្ត្រាព្រះពុទ្ធសាសនាដែល ចារលើស្លឹករឹតមួយចំនួនពីដើមដល់ចប់នៅក្នុង ប្រទេសសេរីលង្កាឃើញថាមានឈ្មោះជាច្រើន ហើយសូម្បីតែអ្នកចំលងសាស្ត្រមួយចំនួនក៏សុទ្ធតែកត់ត្រា នូវអក្សរចារឹកបួងសួងអោយក្លាយខ្លួនទៅជាព្រះពុទ្ធដែរ ហើយពួកអ្នកចម្លងសាស្ត្រាទាំងនោះក៏គេចាត់ទុកខ្លួនគេថាជាព្រះពោធិសត្វដែរ។ នៅវគ្គអវសាន្តនៃពិធីសាសនា ឬក្នុងសកម្មភាពធ្វើសប្បុរសធម៌ ភិក្ខុដែលផ្តល់នូវការប្រសិទ្ធិពរជ័យដល់អ្នកផ្តើមបុណ្យ ឬសប្បុរសជនជានិច្ចជាកាលតែងតែព្រមាន ដាស់តឿន ឬក្រើនរំលឹកដល់ក្រុមមនុស្ស ដែលនៅផ្តុំគ្នាធ្វើសក្ការៈអោយធ្វើអធិដ្ឋាន ដើម្បីឈានទៅសម្រេចផលនៅនិព្វានតាមរយៈការយល់ដឹង

នូវពុទ្ធិមួយក្នុងចំណោមពុទ្ធិទាំងបីរួមមានពុទ្ធិស្រាវ៉ាកា (BodhiSravakabodhi) ព្រះច្ចេក ពុទ្ធិឬសាមយ៉ាមពុទ្ធិពួកគេប្រាថ្នាបួងសួងទៅតាមលទ្ធភាព និងសមត្ថភាពរបស់ពួកគេ។

នៅក្នុងប្រទេស សេរីលង្កា ភូមា ថៃ និងកម្ពុជា ដែលគេចាត់ទុកថាជាប្រទេសកាន់ព្រះពុទ្ធសាសនាថេរវាទ មានអ្នកកាន់ព្រះពុទ្ធសាសនាជាច្រើនទាំងភិក្ខុ (Bhikkhus) និងឧបាសកឧបាសិកា ដែលបានធ្វើសច្ចាឬតាំងចិត្ត (អធិដ្ឋាន) ឱ្យក្លាយខ្លួនទៅជាព្រះពុទ្ធ ដើម្បីដើរសង្គ្រោះដល់អ្នកដទៃ។ ជាការពិតពួកគេ ទាំងនោះសុទ្ធតែជាព្រះពោធិសត្វដែលស្ថិតនៅក្នុងកម្រិតអភិវឌ្ឍន៍ធម្មកាយផ្សេងៗគ្នា។

ដូចនេះគេអាចមើលឃើញថា នៅក្នុងប្រទេសដែលកាន់ព្រះពុទ្ធសាសនាថេរវាទ គ្មានជំនឿ ទាំងអស់មិនមែនជា ស្រាវ៉ាកា ទេ គឺពួកគេទាំងនោះសុទ្ធតែជាព្រះពោធិសត្វ។

មានភាពខុសគ្នាជាដុំកំភួនរវាងព្រះពុទ្ធសាសនាថេរវាទ និងព្រះពុទ្ធសាសនាមហាយានក្នុងការ គោរពបូជាចំពោះទស្សនៈ (ឧត្តមគតិ) អំពីព្រះពោធិសត្វ ទោះបីជាយ៉ាងណាក៏ដោយព្រះពុទ្ធសាសនា ថេរវាទជឿថាទស្សនៈ ឬ ឧត្តមគតិអំពីព្រះពោធិសត្វជាឧត្តមគតិខ្ពស់ជាងគេ និងថ្លៃថ្នូរជាងគេ។ ពុទ្ធសាសនាថេរវាទ មិនត្រូវផ្ដាច់អោយចេញទៅជានិពន្ធន៍ ទុកសម្រាប់គោរពបូជាដោយឡែកៗទេ ការបង្រៀនអំពីឧត្តមគតិពោធិសត្វ និងសភាពជាព្រះពោធិសត្វត្រូវបានគេរកឃើញថា មានភាពបែកខ្ញែកបាចសាចពាសពេញទីកន្លែងដែលមាន ប្រើប្រាស់ភាសាបាលី។ តាមការឱ្យអត្ថន័យ ពុទ្ធសាសនាមហាយានគោរពបូជាចំចំពោះ ឧត្តមគតិព្រះពោធិសត្វហើយគេមិនត្រឹមតែផលិតចេញនូវអក្សរសាស្ត្រ ដែលគួរអោយកត់សំគាល់ទៅលើទស្សនៈផ្សេងៗក្នុងនិកាយនេះទេ ក៏ប៉ុន្តែគេថែមទាំងបង្កើតនូវវណ្ណៈព្រះពោធិសត្វបែបទេវកថាដែលគួរឱ្យចាប់ចិត្តជាខ្លាំងថែមទៀត។

## ៦.សាសនានៅក្នុងយុគសម័យវិទ្យាសាស្ត្រ

(Religion in a Scientific Age Ven.Dr.K. Sri Dhammananda)

បច្ចុប្បន្ន យើងរស់នៅក្នុងយុគសម័យវិទ្យាសាស្ត្រ។ ក្នុងយុគសម័យនេះ ស្ទើរតែគ្រប់ទិដ្ឋភាពនៃជីវិតរបស់យើងទទួលឥទ្ធិពលវិទ្យាសាស្ត្រ។ ចាប់តាំងពីបដិវត្តន៍វិទ្យាសាស្ត្រក្នុងអំឡុងសតវត្សទី១៧វិទ្យាសាស្ត្របានបន្តពង្រីកឥទ្ធិពលដ៏ធំធេងទៅលើអ្វីដែលយើងគិតនិងអ្វីដែលយើងធ្វើ។

ឥទ្ធិពលនៃវិទ្យាសាស្ត្រទៅលើជំនឿសាសនាមានលក្ខណៈខ្លាំងក្លាពិសេស ។គោលជំនឿសាសនា ជាច្រើនកំពុងតែបាត់បង់ក្រោមសម្ពាធវិទ្យាសាស្ត្រទំនើប ហើយមិនអាចទទួលយក

បានតទៅទៀតទេ ចំពោះបញ្ញវន្តហើយនិងអ្នកដែលទទួលបានពតិមានច្រើន។ គេមិនអាចអះអាងសច្ចភាពដែលបានមកពី ការស្មានបែបសាសនា ឬដោយផ្អែកលើអំណាចនៃអក្សរគាថាក្នុងភាពឯកោដាច់ចេញពីការពិចារណា បែបវិទ្យាសាស្ត្រ តទៅទៀតបានទេ។ ឧទាហរណ៍ ការរកឃើញរបស់ចិត្តវិទ្យាទំនើបបង្ហាញថា មនុស្សជាតិប្រៀបបាននឹងរូបរាងកាយដែលធ្វើការងារទៅតាមច្បាប់ធម្មជាតិច្បាប់ហេតុផលដោយគ្មានវត្តមាននៃព្រលឹងអមតៈដូចដែលបានបង្រៀនដោយសាសនានោះទេ។

អ្នកកាន់សាសនាខ្លះជ្រើសយកការមើលស្រាលរបកគំហើញវិទ្យាសាស្ត្រ ដែលខ្ទាស់នឹងលទ្ធិ សាសនារបស់គេ។ ទម្លាប់ខាងផ្លូវចិត្តដ៏រឹងត្អឹងបែបនេះ គឺជាឧបសគ្គដល់ការរីកចម្រើនរបស់មនុស្ស។ ព្រោះថា មនុស្សសម័យថ្មីបដិសេធការជឿលើអ្វី១ដោយងងឹតងងល់ ទោះបីជំនឿនោះត្រូវគេទទួលយក តាំងពីដើមមកក៏ដោយ។ អ្នកកាន់សាសនាប្រភេទនេះ នឹងទទួលបានជោគជ័យតែក្នុងការបង្កើនជួរអ្នក គ្មានជំនឿ ដោយសារទ្រឹស្តីមិនត្រឹមត្រូវរបស់ពួកគេតែប៉ុណ្ណោះ។

ម្យ៉ាងទៀត អ្នកកាន់សាសនាខ្លះបានរកឃើញថាជាការចាំបាច់ត្រូវ ទទួលយកទ្រឹស្តីវិទ្យាសាស្ត្រ ដោយពេញចិត្ត ដោយផ្តល់នូវការបកស្រាយថ្មី១ចំពោះជំនឿសាសនារបស់ពួកគេ។ ឧទាហរណ៍ ករណីទ្រឹស្តីវិវឌ្ឍន៍របស់ដាវិនជាដើម។ អ្នកកាន់សាសនាជាច្រើនអះអាងថា មនុស្សត្រូវបានបង្កើតឡើងដោយ ព្រះជាម្ចាស់ ប៉ុន្តែដាវិនអះអាងថា មនុស្សបានវិវឌ្ឍមកពីប្រភេទស្វាធំម្យ៉ាង។ ទ្រឹស្តីក្រោយនេះធ្វើឱ្យអាប់ឱនលទ្ធិនៃការបង្កើត និងការវិលាយមនុស្សលោករបស់អាទិទេព។ ចាប់តាំងពីអ្នកប្រាជ្ញទាំងឡាយ ទទួលយកទ្រឹស្តីរបស់ដាវិន ទេវវិទូបច្ចុប្បន្នគ្មានជំរើសអ្វីក្រៅតែពីការផ្តល់បំណកស្រាយចំពោះលទ្ធិរបស់ ពួកគេឱ្យស្របតាម ទ្រឹស្តីដែលគេបានប្រឆាំងអស់រយៈពេលជាយូរមកហើយនេះប៉ុណ្ណោះ។

នៅក្នុងពន្លឺនៃរបកគំហើញវិទ្យាសាស្ត្រទំនើប គេមិនពិបាកនឹងយល់ថាទស្សនៈជាច្រើនចំពោះលោកៈ និងជីវិតដែលមាននៅក្នុងសាសនាជាច្រើននោះ គឺវាគ្រាន់តែជាគំនិតសន្មតអំពីអ្វីដែលត្រូវបានប្រគល់ឱ្យជាយូរមកហើយ។ វាជាការពិតទូទៅក្នុងការនិយាយថា សាសនាទាំងឡាយបានរួមចំណែក ដ៏ឧត្តុង្គឧត្តមចំពោះការអភិវឌ្ឍនិងការរីកចម្រើនរបស់មនុស្ស។ សាសនាបានដាក់ចេញនូវតំលៃគុណធម៌បទដ្ឋាន និងគោលការណ៍ទាំងឡាយ ដែលត្រូវបានរៀនចំឡើងដើម្បីនាំផ្លូវជីវិតមនុស្ស។ ប៉ុន្តែចំពោះអំពើល្អទាំងអស់ដែលគេបានធ្វើឡើង សាសនាទាំងឡាយ

មិនអាចស្ថិតនៅយូរអង្វែងនៅក្នុងយុគសម័យ វិទ្យាសាស្ត្រទំនើបតទៅទៀតបានឡើយ ប្រសិនបើអ្នកដើរតាមទាំងឡាយរឹងចចេសក្នុងសច្ចភាព ដែលជាប់ឃុំក្នុងបែបផែន និងលទ្ធិដែលបានកំណត់ទុកនិងក្នុងការលើកតម្កើងទំនៀមទម្លាប់និងការប្រតិបត្តិដទៃទៀតដែលបាត់បង់អត្ថន័យដើមរបស់វា។

**ព្រះពុទ្ធសាសនានិងវិទ្យាសាស្ត្រ**

រហូតមកដល់ដើមសតវត្សចុងក្រោយនេះព្រះពុទ្ធសាសនាបានជាប់ឃុំក្នុងប្រទេសទាំងឡាយដែលវិទ្យាសាស្ត្រទំនើបមិនអាចប៉ះពាល់បាន។ ទោះជាយ៉ាងណាក៏ដោយ តាំងពីកំណើតដំបូងមកម៉្លេះការប្រៀនប្រដៅរបស់ព្រះពុទ្ធបានបើកចំហរជានិច្ចចំពោះគំនិតវិទ្យាសាស្ត្រ។

ហេតុផលមួយដែលថាការប្រៀនប្រដៅអាចក្តោបយកគំនិតវិទ្យាសាស្ត្របាននោះគឺថា ព្រះពុទ្ធ មិនដែលគាំទ្រជំនឿរឹងត្អឹងបែបគម្ពីរនិយមនោះឡើយ។ ព្រះអង្គមិនដែលទាមទារឱ្យគេយកពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ធ្វើជាមូលដ្ឋាននៃការគោរពបូជាជំនឿឬការបកស្រាយដ៏ល្អឥតខ្ចោះណាមួយនោះឡើយ។ ផ្ទុយទៅវិញព្រះអង្គអនុញ្ញាតឱ្យមានភាពទន់ភ្លន់និងសេរីភាពដ៏ជ្រាលជ្រៅនៃគំនិត។

ហេតុផលមួយទៀត គឺថា គំនិតវិទ្យាសាស្ត្រអាចត្រូវរកឃើញនៅក្នុងវិធីសាស្ត្ររបស់ព្រះពុទ្ធចំពោះសច្ចភាពសកល។ វិធីសាស្ត្ររបស់ព្រះពុទ្ធក្នុងការបកស្រាយនិងពិសោធសច្ចភាពមានលក្ខណៈ ស្រដៀងគ្នានឹងវិធីសាស្ត្ររបស់អ្នកវិទ្យាសាស្ត្រ។ អ្នកវិទ្យាសាស្ត្រម្នាក់សង្កេតពិភពខាងក្រៅតាមបែបវត្ថុ វិស័យ ហើយនឹងបង្កើតទ្រឹស្តីវិទ្យាសាស្ត្រមួយ បន្ទាប់ពីបានទទួលជោគជ័យក្នុងការធ្វើពិសោធន៍ជាក់ ស្តែង។

ដោយប្រើប្រាស់វិធីសាស្ត្រស្រដៀងគ្នារយៈពេល២៥ សតវត្សកន្លងទៅ ព្រះពុទ្ធបានសង្កេតពិភពខាងក្នុងក្នុងភាពដោយឡែកហើយបានពង្រឹងស្មារតីសាវ័ករបស់ព្រះអង្គកុំឱ្យទទួលយកការប្រៀនប្រដៅ ណាមួយដោយគ្មានបានអង្កេតនិងផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ ដោយខ្លួនឯងលើតថភាពរបស់វា។ ក៏ដូចជា អ្នកវិទ្យាសាស្ត្រសព្វថ្ងៃដែលគេមិនទាមទារថា មិនឱ្យអ្នកដទៃយកបទពិសោធន៍របស់គេទៅពិសោធជាថ្មីនោះដែរព្រះពុទ្ធមិនដែលទាមទារថា ពិសោធន៍របស់លោកអំពីការត្រាស់ដឹងគឺ មានតែលោកទើបអាចធ្វើបាននោះឡើយ។

ថ្វីបើព្រះពុទ្ធសាសនាមានលក្ខណៈស្រប នឹងគំនិតវិទ្យាសាស្ត្រច្រើនយ៉ាងណាក៏ដោយក៏ការប្រៀបប្រដូចព្រះពុទ្ធសាសនាទៅនឹងវិទ្យាសាស្ត្រ គឺមិនត្រឹមត្រូវទេ។ ជាការពិតណាស់

ថា ការអនុវត្តជាក់ស្តែងរបស់វិទ្យាសាស្ត្របង្កលក្ខណៈឱ្យមនុស្សជាតិរស់នៅកាន់តែមានផាសុខភាពហើយមានវត្ថុចម្លែក។ដែលមិនធ្លាប់សុបិនពីមុនមក។ វិទ្យាសាស្ត្រធ្វើឱ្យមនុស្សអាច ហែលទឹកបានប្រសើរជាងត្រី អាចហោះហើរបានខ្ពស់ ជាងបក្សាបក្សី អាចដើរលើស្ថានព្រះច័ន្ទបាន។ ប៉ុន្តែពិភពនៃចំនេះដឹងដែលអាចទទួលយកបាននូវប្រាជ្ញាដោយសន្ទតឬប្រាជ្ញវិទ្យាសាស្ត្រ គឺត្រូវកំណត់ដោយភស្តុតាងពិសោធន៍។ ហើយសច្ច ភាពបែបវិទ្យាសាស្ត្រតែងអាស្រ័យលើការប្រែប្រួលជាអចិន្ត្រៃយ៍។ វិទ្យាសាស្ត្រមិនអាចផ្តល់ដល់មនុស្សនូវការត្រួតពិនិត្យចិត្តរបស់ខ្លួន ហើយក៏មិនផ្តល់នូវការត្រួតពិនិត្យសីលធម៌ និងគោលបំណងនៃជីវិតផងដែរ។ ទោះបីមានភាពចម្លែកយ៉ាងណាក៏ដោយក៏វិទ្យាសាស្ត្រពិតជាមានព្រំដែនជាច្រើន ដែលព្រះពុទ្ធសាសនាបានកន្លងហួស។

**ព្រំដែននៃវិទ្យាសាស្ត្រ**

ជាញឹកញាប់ គេបានឮច្រើនអំពីវិទ្យាសាស្ត្រ ហើយនិងអ្វីដែលវាអាចធ្វើបាន តែគេបានឮតិចតួច អំពីអ្វីដែលវិទ្យាសាស្ត្រមិនអាចធ្វើបាន។ ចំណេះដឹងវិទ្យាសាស្ត្រចំពោះទិន្នន័យដែលទទួលបានតាមរយៈអង្គឥន្ទ្រិយ គឺមានព្រំដែន។ វិទ្យាសាស្ត្រមិនអាចទទួលស្គាល់ តថភាពដែលឆ្លងហួសទិន្នន័យឥន្ទ្រិយ។ សច្ចភាពវិទ្យាសាស្ត្រ ត្រូវបានសាងឡើងនៅលើការសង្កេតបែបតក្កៈរបស់ទិន្នន័យឥន្ទ្រិយ ដែលប្រែប្រួលគ្មានឈប់ឈរ។ ដូចនេះ សច្ចភាពវិទ្យាសាស្ត្រជាសច្ចភាពធៀបដែលមិននៅនឹងថ្កល់ចំពោះការពិសោធន៍នៃពេលវេលា។ហើយអ្នកវិទ្យាសាស្ត្រដោយយល់ដឹងពីការពិតនេះ តែងមានបំណងបោះបង់ចោល ទ្រឹស្តីមួយជានិច្ចកាលបើមានទ្រឹស្តីថ្មីមួយប្រសើរជាងអាចយកមកជំនួសបាន។

វិទ្យាសាស្ត្រប្រឹងប្រែងស្វែងយល់ពិភពខាងក្រៅ ហើយមិនបានប៉ះពាល់ទាល់តែសោះលើផ្ទៃនៃពិភពខាងក្នុង។ សូម្បីវិទ្យាសាស្ត្រនៃចិត្តវិទ្យាក៏មិនប្រាកដ ជាបានស្ទង់រកមូលហេតុដែលបង្កប់នៅក្នុង កោលាហលផ្លូវចិត្តរបស់មនុស្សផងដែរ។ នៅពេលដែលមនុស្សម្នាក់ងឿយណាយនិងស្អប់ខ្ពើមជីវិតហើយពិភពខាងក្នុងរបស់គេពោរពេញដោយការរំខាន និងកោលាហលវិទ្យាសាស្ត្របច្ចុប្បន្នមិនមានបរិក្ខាណាមួយដើម្បីជួយគេបានឡើយ។ វិទ្យាសាស្ត្រសង្គមដែលផ្តល់វត្ថុគ្រប់យ៉ាងសម្រាប់បរិស្ថានរបស់មនុស្ស អាចនាំមកឱ្យមនុស្សនូវសុភមង្គលក្នុងកម្រិតមួយដ៏ជាក់លាក់។ ប៉ុន្តែដោយមានលក្ខណៈខុសពីសត្វមនុស្ស មិនត្រឹមតែត្រូវការសេចក្តីសុខខាងផ្លូវកាយប៉ុណ្ណោះទេតែថែមទាំងត្រូវការជំនួយដើម្បីទប់ទល់នឹងការនឿយណាយចិត្តហើយ និងទុគ៌តភាព ដែលកើតពីពិសោធន៍ប្រចាំថ្ងៃរបស់គេ។

សព្វថ្ងៃមានមនុស្សជាច្រើនណាស់ ដែលទទួលការញាំញីដោយការភ័យខ្លាចភាពអន្ទះអន្ទែងនិងអសន្តិសុខ។ ប៉ុន្តែវិទ្យាសាស្ត្រមិនអាចជួយពួកគេបានទេ។ វិទ្យាសាស្ត្រមិនអាចជួយមនុស្សសាមញ្ញ ឱ្យគ្រប់គ្រងចិត្តរបស់ខ្លួនបានទេ នៅពេលដែលគេមានធម្មជាតិជាសត្វដុតរោលក្នុងខ្លួន។

តើវិទ្យាសាស្ត្រធ្វើឱ្យមនុស្សមានលក្ខណៈប្រសើរជាងមុនឬទេ? ប្រសិនបើអាច ហេតុអ្វីក៏អំពើហិង្សានិងការប្រព្រឹត្តអសីលធម៌មានភាពសំបូរនៅក្នុងបណ្តាប្រទេសដែលជឿនលឿនខាងវិទ្យាសាស្ត្រ? តើមានយុត្តិធម៌ឬទេដែលនិយាយថា ថ្វីត្បិតតែមានការជឿនលឿនខាងវិទ្យាសាស្ត្រហើយផលប្រយោជន៍ ត្រូវបានប្រគល់ឱ្យមនុស្សក៏ដោយ ក៏វិទ្យាសាស្ត្រទុកឱ្យពិភពខាងក្នុងរបស់មនុស្សគ្មានភាពប្រែប្រួល ជាមូលដ្ឋាន : វាបានត្រឹមតែបង្កើនអារម្មណ៍ឯករាជ្យនិងមិនចេះស្កប់ស្កល់តែប៉ុណ្ណោះ? ដោយបន្ថែមទាំង បរាជ័យក្នុងការនាំយកសន្តិសុខមកឱ្យមនុស្សជាតិ វិទ្យាសាស្ត្រក៏បានធ្វើឱ្យមនុស្សគ្រប់រូបកាន់តែមាន អារម្មណ៍ថាខ្វះសន្តិសុខ ដោយសារតែ លទ្ធភាពនៃការបំផ្លិចបំផ្លាញមិនរើសមុខ។

វិទ្យាសាស្ត្រមិនអាចផ្តល់នូវគោលដៅដ៏មានន័យរបស់ជីវិតបានទេ។ វាមិនអាចផ្តល់ដល់មនុស្ស នូវមូលហេតុនៃការរស់នៅឱ្យបានច្បាស់លាស់ឡើយ។ តាមពិត វិទ្យាសាស្ត្រមានលក្ខណៈខាងផ្លូវលោក ទាំងស្រុងពីធម្មជាតិ ហើយមិនទាក់ទងនឹងគោលដៅខាងផ្លូវចិត្តរបស់មនុស្សទេ។ លទ្ធិសម្ភារៈនិយម ដែលមានជាប់នៅក្នុងគំនិតវិទ្យាសាស្ត្រ បដិសេធគោលដៅផ្លូវចិត្តដែលមានលក្ខណៈខ្ពស់ជាងសេចក្តីពេញចិត្តខាងសម្ភារៈ។ តាមរយៈការបង្កើតទ្រឹស្តីជំរើស និងសច្ចភាពធៀបវិទ្យាសាស្ត្រមើលស្រាលចំពោះ ចំណោទបញ្ហាសំខាន់ៗមួយចំនួនហើយទុកឱ្យសំណួរ ជាច្រើនគ្មានចម្លើយ។ ឧទាហរណ៍ នៅពេលដែលគេសួរថាហេតុអ្វីវិសមភាព ខាងផ្លូវកាយនិងផ្លូវបញ្ញាកើតមានក្នុងចំណោមមនុស្ស? គឺមិនមានការពន្យល់បែបវិទ្យាសាស្ត្រណាមួយអាចឆ្លើយតបនឹងសំណួរដែលនៅហួសពីទីកំណត់ដ៏ចង្អៀតទាំងនេះបានទេ។

**សិក្សាពីភាពអវិជ្ជា**

ចិត្តដ៏ល្អិតបំផុតសិក្សាដោយព្រះពុទ្ធ គឺមិនកំណត់ដោយទិន្នន័យឥន្ទ្រិយទេ ហើយវាឆ្លងហួសតក្កៈដែលជាប់នៅក្នុងដែនកំណត់នៃប្រត្យក្សារម្មណ៍(សញ្ញា)ធៀប។ផ្ទុយទៅវិញការយល់(ឬបញ្ញាចាក់ធ្លុះ)របស់មនុស្ស កើតឡើងអំពីមូលដ្ឋាននៃពត៌មានដែលវាប្រមូលបានហើយគរទុក ទោះបីនៅក្នុង វិស័យសាសនាទស្សនវិជ្ជា វិទ្យាសាស្ត្រឬសិល្បៈក៏ដោយ។ ពត៌មានសម្រាប់

ចិត្តត្រូវបានប្រមូល តាមរយៈសរីរាង្គឥន្ទ្រិយរបស់យើងដែលស្ថិតនៅកម្រិតទាប។ ពត៌មានតិចតួចដែលយើងទទួល បានធ្វើឱ្យការយល់របស់យើងអំពី ពិភពលោកមានលក្ខណៈខុសពីភាពដើម។ នៅក្នុងសៀវភៅស្ដីពី សិក្សាពីអវិជ្ជា" អ្នកនិពន្ធឈ្មោះ នីកូឡា គូសា (Nicholas of Cusa) បានធ្វើការសង្កេតឃើញថា ចំណេះដឹងបែបអំណួតជាច្រើនរបស់យើងដែលផ្អែកលើឥន្ទ្រិយទាំងឡាយរបស់យើង គឺពិតជាអវិជ្ជាហើយចំណេះ ដឹងពិតគឺទទួលបានតាមរយៈការផ្សាយចំណេះដឹងទាំងអស់នេះរហូតដល់យើងគិតដោយមិនប្រើប្រាស់ការគិតដោយឥន្ទ្រិយ។

"សច្ចភាពមិនអាស្រ័យលើវត្ថុខាងក្រៅខ្លួនយើងទេប៉ុន្តែវាអាស្រ័យពិភពខាងក្នុងរបស់យើង។ យើងមិនអាចសង្ឃឹមថា រកឃើញសច្ចភាពដោយការពិសោធន៍ និងសញ្ញានៃឥន្ទ្រិយ (ប្រត្យក្សារម្មណ៍) ឬ ក៏សូម្បីដោយតក្កវិជ្ជា និងវិចារ (reason) នោះទេ។ ទាំងនេះជាឧបករណ៍ប្រើប្រាស់ ដើម្បីបានទទួលចំណេះដឹង ប៉ុន្តែមិនមែនជាសច្ចភាពនោះទេ។ សច្ចភាព ត្រូវតែបានមកអំពីសមិទ្ធិកម្មខាងក្នុង (inner realization)។ សៀវភៅទាំងឡាយអាចត្រឹម តែដាស់គំនិតនិងផ្ដល់ចំណេះដឹងដល់អ្នកប៉ុណ្ណោះ។ ចំពោះសច្ចភាពអ្នកត្រូវត្រឡប់ភ្នែកអ្នក សម្លឹងទៅខាងក្នុង ពីព្រោះថាវាស្ថិតនៅខាងក្នុងខ្លួនអ្នក។ ដូចនេះ ការស្រាវជ្រាវរកចំណេះដឹង គឺជាបញ្ហាមួយហើយការស្រាវជ្រាវរកសច្ចភាពគឺជាបញ្ហាមួយទៀត។"

*"ពាក្យសម្ដី គឺជាផលិតផលនៃចិត្តកំណត់របស់យើង ហើយចិត្តទាំងឡាយរបស់យើងផ្អែកលើចំណេះដឹងរបស់វាទាំងអស់លើបទពិសោធនៃឥន្ទ្រិយរបស់យើង។ ឥន្ទ្រិយទាំងនេះ ជួនកាលមិនអាចឱ្យជឿបានទេ ។ យ៉ាងណាមិញព្រឹត្តិការណ៍តែមួយ ដែលបានឃើញដោយមនុស្សច្រើនគ្នាអាចត្រូវបកស្រាយផ្សេងៗគ្នា។"*

មនុស្សខ្លះមានមោទនភាពចំពោះដំណើរការណ៍ដែលថាគេដឹងច្រើន។ តាមពិត យើងដឹងកាន់តែតិច យើងស្ថិតនៅក្នុងការពន្យល់របស់យើងកាន់តែច្រើនប្រាកដ តែបើយើងដឹងកាន់តែច្រើន យើងកាន់តែ យល់ច្បាស់ពីកំរិតរបស់យើង។

ពេលមួយ អ្នកប្រាជ្ញដ៏ចំណានម្នាក់បានសរសេរសៀវភៅមួយ ដែលលោកចាត់ទុកថាជាស្នាដៃចុងក្រោយ។ លោកដឹងថាសៀវភៅនោះមានវត្ថុមានតម្លៃ និងទស្សនវិជ្ជាខាងអក្សរសាស្ត្រ។ ដោយមានមោទនភាពចំពោះសមិទ្ធផលរបស់លោក លោកបានបង្ហាញស្នាដៃឯករបស់លោកចំពោះសហសេវិក ម្នាក់ដែលចំណានដូចលោក ហើយដែលបានទទួលសំណូមពរជួយពិនិត្យស្នាដៃរបស់លោក។ ជំនួសនេះសហសេវិករបស់លោកបាន ស្នើឱ្យអ្នកនិពន្ធកត់ត្រា

លើក្រដាសមួយសន្លឹកអំពីអ្វីទាំងអស់ដែលលោកដឹង និងអ្វីទាំងអស់ដែលលោកមិនដឹង។ អ្នកនិពន្ធបានអង្គុយគិតយ៉ាងយូរ។ បន្ទាប់ពីប្រើពេលមួយរយៈដ៏វែងមកលោកក៏ជួបបរាជ័យដោយមិនអាចកត់ត្រាចំពោះអ្វីទាំងឡាយណា ដែលលោកបានដឹង។ បន្ទាប់មកលោកប្តូរគំនិតទៅសំណួរទី២។ ជាថ្មីម្តងទៀតលោកក៏បរាជ័យ ក្នុងការកត់ត្រាពីអ្វីៗដែលលោកមិនដឹង។ នៅទីបញ្ចប់ ដោយអត្តទត្តភាពរបស់លោកធ្លាក់ចុះ លោកក៏បញ្ចប់ការកត់ត្រាដោយទទួលស្គាល់ថាអ្វីៗទាំងអស់ដែលលោកដឹងគឺពិតជាអវិជ្ជា។

ក្នុងទស្សនៈនេះសូក្រាតទស្សនវិទូនៅទីក្រុងអាតែនដ៏ល្បីល្បាញនៃពិភពលោកសម័យបុរាណ នៅពេលគេសួរលោកអំពីអ្វីដែលលោកដឹង លោកបានឆ្លើយថា " ខ្ញុំដឹងតែម្យ៉ាងទេ គឺថាខ្ញុំមិនដឹងទេ " ។

**ហួសពីវិទ្យាសាស្ត្រ**

ព្រះពុទ្ធសាសនាដើរហួសពីវិទ្យាសាស្ត្រ ទំនើបក្នុងការទទួលយកវិស័យនៃចំណេះដឹងធំធេងជាង ការអនុញ្ញាតដោយគំនិតវិទ្យាសាស្ត្រ។ ព្រះពុទ្ធសាសនាទទួលយកចំនេះដឹង ដែលកើតពីសរីរាង្គឥន្ទ្រិយ ដូចគ្នានឹងពិសោធន៍របស់បុគ្គលដែលទទួលបានតាមរយៈវិប្បធម៌បញ្ញា។ ដោយការបណ្តុះបណ្តាល និង អភិវឌ្ឍចិត្តសមាធិដ៏ខ្ពង់ខ្ពស់ ពិសោធន៍របស់សាសនាអាចឱ្យគេយល់បាន និងផ្ទៀងផ្ទាត់បាន។ ពិសោធន៍របស់សាសនា មិនមែនជាអ្វីមួយដែលគេអាចយល់ដោយការធ្វើពិសោធន៍ក្នុងបំពង់សាកឬពិនិត្យដោយមីក្រូទស្សន៍បានឡើយ។

សច្ចភាពដែលបានរកឃើញដោយវិទ្យាសាស្ត្រ មានលក្ខណៈធៀបនិងត្រូវប្រែប្រួល ប៉ុន្តែនៅពេល ដែលត្រូវរកឃើញដោយព្រះពុទ្ធ សច្ចភាពមានលក្ខណៈបញ្ចប់និងដាច់ខាត គឺថាសច្ចភាពនៃព្រះធម៌ មិនប្រែប្រួលតាមពេលវេលានិងលំហទេ។ ជាងនេះទៀត ផ្ទុយនឹងការបង្កើតទ្រឹស្តីជំរើសរបស់វិទ្យាសាស្ត្រ ព្រះពុទ្ធបានពង្រឹងអ្នកប្រាជ្ញកុំឱ្យប្រកាន់ខ្ជាប់ នឹងទ្រឹស្តីទាំងឡាយបែបវិទ្យាសាស្ត្រ ឬផ្សេងពីនេះ។ ជំនួសឱ្យការបង្កើតទ្រឹស្តី ព្រះពុទ្ធបានបង្រៀនមនុស្សជាតិអំពីវិធីរស់នៅក្នុងជីវភាពត្រឹមត្រូវ តាមរយៈការរម្ងាប់ឥន្ទ្រិយ និងការទប់ស្កាត់ចំណង់។ ព្រះពុទ្ធបានបង្ហាញមាគ៌ា ដែលតាមរយៈមាគ៌ានោះយើងអាច រកឃើញធម្មជាតិនៃជីវិតហើយនិងគោលដៅពិតនៃជីវិត។

ការប្រតិបត្តិ មានសារៈសំខាន់នៅក្នុងព្រះពុទ្ធសាសនា។ មនុស្សម្នាក់ដែលមានការសិក្សាច្រើន តែមិនមានការប្រតិបត្តិ គឺប្រៀបដូចមនុស្សម្នាក់ដែលអាចសូត្រចាំមាត់ពីគ្រឿង

ផ្សំម្ហូប អំពីសៀវភៅ ធ្វើម្ហូបដ៏ធំមួយដោយគ្មានការព្យាយាមរៀបចំម្ហូបមួយមុខណាឡើយ ។ ការស្រេកឃ្លានរបស់គេ មិនអាចបំបាត់បានដោយសារ ចំណេះដឹងតាមសៀវភៅតែមួយមុខនោះឡើយ ។ ការប្រតិបត្តិ គឺជាលក្ខខ័ណ្ឌសំខាន់នៃការត្រាស់ដឹងដូចនៅក្នុងនិកាយខ្លះរបស់ព្រះពុទ្ធសាសនា ដូចជានិកាយយេនជាដើម ការប្រតិបត្តិត្រូវ គេដាក់នៅពីមុខចំណេះដឹង ។

វិធីវិទ្យាសាស្ត្រត្រូវបានតម្រង់ទិសតាមផ្នែកខាងក្រៅ ហើយអ្នកវិទ្យាសាស្ត្រទំនើបចម្រាញ់យកផល ពីធម្មជាតិនិងវត្ថុធាតុដើម្បីផាសុខភាពផ្ទាល់ខ្លួនរបស់គេ ដោយជាញឹកញាប់មើលស្រាលតម្រូវការ ក្នុងការចុះសម្រុងជាមួយនឹងបរិស្ថាន ហើយដោយហេតុនេះហើយទើបមានការបំពុលពិភពលោក ។ផ្ទុយទៅវិញព្រះពុទ្ធសាសនាមានការតម្រង់ទិសផ្នែកខាងក្នុងហើយមានជាប់ទាក់ទងនឹងការអភិវឌ្ឍខាងក្នុងរបស់មនុស្ស ។ក្នុងកម្រិតទាបព្រះពុទ្ធសាសនាបង្រៀនបុគ្គលអំពីវិធីសម្របសម្រួល និងដោះស្រាយចំពោះព្រឹត្តិការណ៍ និងកាលទេសៈទាំងឡាយនៃជីវភាពប្រចាំថ្ងៃ ។ ក្នុងកម្រិតខ្ពស់ជាងព្រះពុទ្ធសាសនា តំណាងឱ្យការខិតខំប្រឹងប្រែងរបស់មនុស្សដើម្បីលូតលាស់ដោយខ្លួនឯងតាមរយៈការហ្វឹកហាត់វប្បធម៌បញ្ញាឬការអភិវឌ្ឍផ្លូវចិត្ត ។

ព្រះពុទ្ធសាសនាមានប្រព័ន្ធពេញលេញខាងវប្បធម៌បញ្ញាដែលជាប់ទាក់ទងជាមួយការទទួលបានការយល់ជ្រាលជ្រៅទៅក្នុងធម្មជាតិនៃវត្ថុ ដែលនាំមកនូវការសម្រេចផលដោយខ្លួនឯងដ៏ពេញលេញ អំពីសច្ចភាពចុងក្រោយ គឺព្រះនិព្វាន ។ ប្រព័ន្ធនេះមានលក្ខណៈជាក់ស្តែង និងវិទ្យាសាស្ត្រ ។វាពាក់ព័ន្ធនឹងការសង្កេតអំពីសភាពផ្លូវចិត្តនិងបញ្ញា ។ អ្នកធ្វើសមាធិមានលក្ខណៈកាន់តែដូចអ្នកវិទ្យាសាស្ត្រជាងចៅក្រមម្នាក់ដោយគេសង្កេតមើលពិភពខាងក្នុងដោយការយកចិត្តទុកដាក់ ។

**វិទ្យាសាស្ត្រគ្មានសាសនា**

ដោយគ្មានឧត្តមគតិសីលធម៌ វិទ្យាសាស្ត្រដាក់ចុះនូវគ្រោះថ្នាក់ចំពោះ មនុស្សជាតិទាំងមូល ។ វិទ្យាសាស្ត្របានបង្កើតម៉ាស៊ីនដែលប្រែក្លាយជាព្រះរាជា ។ គ្រាប់កាំភ្លើងនិងគ្រាប់បែក គឺជាអំណោយរបស់វិទ្យាសាស្ត្រ ចំពោះជនមានអំណាចមួយក្តាប់តូច ដែលជាទីអាស្រ័យនៃជោគវាសនារបស់ពិភពលោក ។ ក្នុងគ្រាដដែលនោះ មនុស្សជាតិដទៃទៀតរង់ចាំដោយការឈឺចាប់និងភ័យខ្លាចដោយមិនដឹងថា ពេលណាទើបអាវុធនុយក្លេអ៊ែរ ឧស្ម័នពុលអាវុធប្រល័យផ្លែផ្កានៃការស្រាវជ្រាវវិទ្យាសាស្ត្រ ដែលត្រូវបានចាត់ទុកថា មានប្រសិទ្ធភាពក្នុងការសម្លាប់នោះ នឹងត្រូវប្រើប្រាស់ទៅលើគេ ។

វិទ្យាសាស្ត្រមិនត្រឹមតែមិនអាចផ្តល់ដំបូន្មាន សីលធម៌ចំពោះមនុស្សជាតិបានប៉ុណ្ណោះ ទេវាក៏បង្កើតប្រេងឥន្ធនៈបំប៉នឱ្យអណ្តាតភ្លើងតណ្ហារបស់មនុស្សលោកផងដែរ។

វិទ្យាសាស្ត្រដែលខ្វះសីលធម៌ហៅថា "ការបំផ្លាញ" ប៉ុណ្ណោះគឺថា វាក្លាយជាសត្វចំឡែក ឃោរឃៅ ដែលមនុស្សបានរកឃើញ។ ហើយជាគ្រោះអាក្រក់សត្វចម្លែកនេះមានអំណាចជាង មនុស្សខ្លួន ឯងទៅទៀត។ ប្រសិនបើមនុស្សមិនរៀនសូត្រដើម្បីបន្ទុចបង្អាក់និងគ្រប់គ្រងសត្វ ចម្លែកនោះ តាមរយៈការប្រតិបត្តិ សីលធម៌ សាសនាទេ សត្វចម្លែកនឹងគ្របសង្កត់គេភ្លាម។ ដោយគ្មានការណែនាំរបស់សាសនា វិទ្យាសាស្ត្រគម្រាមកំហែងពិភពលោកដោយការបំផ្លាញ។ ផ្ទុយទៅវិញ ពេលដែលវិទ្យាសាស្ត្រដើរទន្ទឹមនឹងសាសនាដូចជា ព្រះពុទ្ធ សាសនាជាដើមវិទ្យា សាស្ត្រអាចប្រែក្លាយពិភពលោកនេះឱ្យទៅជាស្ថានសួគ៌នៃសន្តិភាព សន្តិសុខ និងសុភមង្គល។

មិនដែលមានពេលណាដែលសហប្រតិបត្តិការរវាងវិទ្យាសាស្ត្រនិងសាសនា មានភាព ចាំបាច់ខ្លាំងក្លា ដើម្បីផលប្រយោជន៍និងការបម្រើដ៏ប្រសើរបំផុត របស់មនុស្សជាតិនោះទេ។ សាសនាគ្មានវិទ្យាសាស្ត្រ គឺងងឹតឯវិទ្យាសាស្ត្រគ្មានសាសនាគឺបំផ្លាញ។

វត្ថុបូជាចំពោះព្រះពុទ្ធសាសនា បញ្ញានៃព្រះពុទ្ធសាសនាដែលត្រូវបានរកឃើញនៅលើ សេចក្តីករុណាមានតួនាទីដ៏សំខាន់ក្នុងការកែប្រែ ទិដៅគ្រោះថ្នាក់ដែលវិទ្យាសាស្ត្រទំនើបកំពុង តែដឹកមុខ។ ព្រះពុទ្ធសាសនាអាចផ្តល់នូវការដឹកនាំផ្លូវចិត្ត ដើម្បីបង្ហាញផ្លូវការស្រាវជ្រាវវិទ្យា សាស្ត្រនិងការបង្កើតថ្មី ក្នុងការលើកកំពស់វប្បធម៌រុងរឿង នាពេលអនាគត។ ព្រះពុទ្ធសាសនា អាចផ្តល់នូវគោលដៅដ៏មានតម្លៃសម្រាប់ការឈានឡើងនៃវិទ្យាសាស្ត្រ ដែលបច្ចុប្បន្នកំពុង តែប្រឈមមុខនឹងភាពទាល់ច្រកអស់សង្ឃឹមដោយស្ថិតនៅជាទាសករនៃការបង្កើតថ្មីរបស់វា។

*អាល់ប៊ែរ អាំងស្តាំង* (Albert Einstein) នៅពេលដែលលោកថ្វាយវត្ថុបូជាចំពោះ ព្រះពុទ្ធសាសនា លោកនិយាយថា "ប្រសិនបើមានសាសនាណាមួយដែល នឹងគ្រប់គ្រងបាននូវ សេចក្តី ត្រូវការវិទ្យាសាស្ត្រទំនើប សាសនានោះ គឺព្រះពុទ្ធសាសនា"។ ព្រះពុទ្ធសាសនាមិនត្រូវ ការការកែលំអឡើងវិញ ដើម្បីឱ្យមានភាពទាន់សម័យ ស្របនឹងការរកឃើញវិទ្យាសាស្ត្រថ្មីៗ កន្លងទៅនេះទេ។ ព្រះពុទ្ធសាសនាមិនត្រូវការបង្ហាញទស្សនៈ ចុះចាញ់វិទ្យាសាស្ត្រទេ ពីព្រោះ ព្រះពុទ្ធសាសនាក្តោបវិទ្យាសាស្ត្រក៏ដូចជាដើរហួសវិទ្យាសាស្ត្រ។ ព្រះពុទ្ធសាសនា គឺជាស្ពាន ចម្លងពីគំនិតសាសនាទៅគំនិតវិទ្យាសាស្ត្រ ដោយក្រើនរំលឹកមនុស្សឱ្យស្រាវជ្រាវរកសក្តានុភាព ដែលកប់ក្នុងខ្លួននិងក្នុងបរិស្ថានរបស់ខ្លួន។ ព្រះពុទ្ធសាសនាគ្មានកាលកំណត់ទេ !

## ៧-សាសនាក្នុងសង្គមពហុសាសនា (Religion in a Multi-Religious Society)

By Ven. Dr. K. Sri Dhammananda

ការទេសនា និងពាក្យសម្ដីរបស់គ្រូសាសនាដ៏ល្បីល្បាញទាំងឡាយ ដែលជាអ្នកបង្កើតសាសនាក្នុង ពិភពលោក មានគោលបំណងជាបឋមសម្រាលទុក្ខសោក ហើយនាំយកមកនូវសន្តិភាពនិងសុភមង្គលជូនដល់មនុស្សជាតិ តាមរយៈការប្រកាន់អាកប្បកិរិយាសីលធម៌និងរស់នៅក្នុងភាពត្រឹមត្រូវ។ ប៉ុន្តែបច្ចុប្បន្ននេះ សាសនាទាំងឡាយក្នុងពិភពលោកបានអភិ វឌ្ឍទៅជាបណ្ដាស្ថាប័នអបុគ្គលដែលរៀបចំឡើងដោយគ្នាច្រើន ដោយទទួលបានលទ្ធផលមួយ គឺថាពាក្យទេសនាដើម របស់បណ្ដាអ្នកបង្កើតសាសនាទីទៃៗដែលអធិប្បាយ ពីភាពសាមញ្ញការទប់ចិត្តសច្ចភាព និងភាពមិនអាត្មានិយមត្រូវបានកាត់ចោលឬនិយាយលំៗ រហូតដល់ស្ទើរតែគ្មានឥទ្ធិពលអ្វីសោះទៅលើសាវ័កទាំងឡាយ។ ខ្លឹមសារសីលធម៌របស់ សាសនា ហើយនិងតម្លៃខាងស្មារតីក្នុងការលើកកំពស់សន្តិភាពរបស់សាសនា ត្រូវបាំងជិតដោយតម្លៃខាងសម្ភារៈដែលកាន់តែទាក់ទាញទៅៗ។ អ្នកដើរតាមសាសនាក្នុងពិភពលោកដ៏ច្រើន បានធ្វើមិនដឹងមិនឮ ឬមើលស្រាលដល់អធិបញ្ញាររបស់គ្រូ សាសនារបស់គេ ដើម្បីគេស្វែងរកអំណាច កេរ្តិ៍ឈ្មោះ និងការចំណេញខាងសម្ភារៈដទៃទៀត ដើម្បីពង្រីកបុគ្គលភាពរបស់គេ។ ការរំលោភបែបនេះមាននិន្នាការទៅរកបំពុលស្មារតីអ្នកកាន់សាសនានៅសម័យថ្មីជាច្រើន ហើយបង្កឱ្យមានការប្រកួតប្រជែងមិនត្រឹមត្រូវ ហើយនិងឧបសគ្គក្នុងចំណោមបណ្ដាក្រុមអ្នកកាន់សាសនាផ្សេងៗគ្នាក៏ដូចជាក្នុងសហគមន៍អ្នកកាន់សាសនាតែមួយ។

### ការមិនអធ្យាស្រ័យខាងសាសនា (Religious Intolerance)

ពេលគេសិក្សាពីប្រវត្តិនៃសាសនាផ្សេងៗក្នុងពិភពលោក ហើយនិងឥទ្ធិពលដ៏ធំធេងដែលសាសនាមានទៅលើមនុស្សក្នុងរយៈពេលដ៏យូរអង្វែងកន្លងមកហើយគេអាចយល់បានពីកំហុសដ៏ធំសម្បើមដែលត្រូវ បានបង្កឡើងតាមរយៈការមិនអធ្យាស្រ័យខាងសាសនា។ ពាក្យពេចន៍ទាំងឡាយមានដូចជា " ការធ្វើទុក្ខបុកម្នេញ" "អ្នកមានគំនិតប្លែក" " អ្នកមិនជឿសាសនា""អ្នកមិនជឿគ្រីស្ដសាសនា"និងពាក្យដទៃទៀតដែលមានន័យស្រដៀងគ្នា បានលូនចូលទៅក្នុងវាក្យស័ព្ទរបស់ សៀវភៅសាសនាដើម្បីពណ៌នាអំពីភាពគម្រោះគម្រើយ ភាពឃោរឃៅ បុរេវិនិច្ឆ័យនិងការរើសអើងដែលត្រូវបាននាំមកក្នុងនាមសាសនា ព្រោះហេតុតែការ មិនអធ្យាស្រ័យខាងសាសនា។ព្រឹត្តិហេតុដ៏អាក្រក់ទាំងនេះ បានបន្សល់ទុកនូវស្លាកស្នាមទុយិសជាច្រើននៅ លើសាសនារហូតដល់អ្នកគិតគូរជាច្រើន មានទំនោរងាកចេញពីសាសនាដែលមាន ឬពីរាល់ពាក្យ

សាសនាខ្លួនវា ។តម្លៃសាសនាពិតប្រាកដត្រូវបានបង្អាប់បង្អោនយ៉ាងលឿន និងបាត់បង់ពីសន្តាន ចិត្តរបស់មនុស្សសូម្បីពីក្នុងចំណោមមនុស្សដែលគេចាត់ទុកថា ជាអ្នកកាន់សាសនាទាំងប៉ុន្មាន ។ ដើម្បីទប់ទល់នឹងនិន្នាការអកុសលនេះជាការចាំបាច់ គេត្រូវសិក្សានិងស្រាវជ្រាវយ៉ាងត្រឹម ត្រូវ ចំពោះការប្រតិបត្តិគោលការណ៍សាសនាដែលអនុវត្តដោយអ្នកពាក់ព័ន្ធទាំងអស់ដើម្បីបានយល់ ដឹង កាន់តែស៊ីជម្រៅ ទៅលើតម្លៃខាងស្មារតីពិតរបស់សាសនា ហើយជៀសវាងកំហុសដោយ អចេតនាពីអតីតកាល ។

**ការអប់រំរបស់សាសនា** (Religious Education)

ដើម្បីមានអត្ថិភាពជាមួយគ្នា ដោយសន្តិភាព និងភាពសុខដុមនៅក្នុងសង្គមពហុសាសនា គេគួរ មានការអប់រំខាងសាសនាឱ្យបានច្បាស់លាស់ ដោយសង្កត់ធ្ងន់លើតម្លៃខាងសីលធម៌ សីលចរិយាធម៌ដែលជាជំហានទី១ឆ្ពោះទៅរកការយល់គ្នានិងកិច្ចសហការរវាងគ្នា និងគ្នាដ៏កាន់ តែប្រសើរឡើង ក្នុងចំណោមអ្នកកាន់ សាសនាទាំងអស់ ។ អ្នកកាន់សាសនា ទាំងអស់គួរតែរួប រួមគ្នា និងសហការគ្នាដើម្បីលើកកំពស់ និងធ្វើឱ្យការ អប់រំសាសនាមានលក្ខណៈត្រឹមត្រូវ និង មានប្រព័ន្ធ ដែលមិនមែនចំពោះតែសាសនាណាមួយទេ តែចំពោះទៅ លើសារៈសំខាន់នៃការ ទេសនារបស់សាសនាទាំងអស ់ដែលនឹងបំភ្លឺក៏ដូចជាធ្វើឱ្យយល់ស៊ីជម្រៅទៅក្នុងធម្មជាតិនៃ តម្លៃ ខាងស្មារតីកាន់តែខ្ពស់ឡើង របស់ជីវិត ។ ជំហាននេះ នឹង ទៅជាជំនួយដ៏ច្បាស់លាស់ក្នុង ការលុបបំបាត់ ឬយ៉ាងហោចណាស់ក៏កាត់បន្ថយចំណុចតឹងតែងនៃការប្រកាន់ជ្រុលក្នុងសាសនា ហើយនិងបុរេវិនិច្ឆ័យពីដើមមក ដែលជាដើមហេតុនៃការតស៊ូរវាងសាសនានិងសាសនា ។ វិធាន ការដទៃទៀត ដើម្បីជួយបង្កើតឱ្យមានការយល់គ្នានិងគោរពគ្នាកាន់តែប្រសើរឡើងនោះគឺការ បង្កើតអង្គការអន្តរសាសនាដែលនឹងផ្តល់បទឧទ្ទេសការចរចាការពិភាក្សាសិក្ខាសាលានិងវេទិកា អំពីសាសនាដ៏ទៀងទាត់ ហើយចងភ្ជាប់គ្នានូវប្រធានបទទាំងឡាយ ។ ទង្វើបែបនេះជាការពន្យល់ ហេតុផលគួរត្រូវបានស្រាវជ្រាវរកមូលបទរួម ដែលអាចលើកកំពស់សន្តិភាព និងការចុះសម្រុង ជាងការចិញ្ចឹមតិរិយាបថលើកតម្កើងខ្លួន ឬវាតជំនឿរបស់ខ្លួនទៅលើជំនឿរបស់ អ្នកដទៃ ។

**សកម្មភាពសុខុមាលភាព** (Welfare Activities)

ការទ្រទ្រង់កិច្ចប្រជុំមិត្តភាព ស្ថាប័ននៃកម្មវិធីបម្រើសហគមន៍ និងសកម្មភាពសង្គម និង សុវត្ថិភាព ជាទីដែលអ្នក កាន់សាសនាទាំងអស់ធ្វើការងារដោយសហការដើម្បីមូលហេតុរួម របស់មនុស្សជាតិក្នុងការលើកស្ទួយមនុស្សគ្មានភ័ព្វជាច្រើនក្នុងសង្គមនិងត្រូវប្រើជាមធ្យោបាយ

សម្រាប់សម្ព័ន្ធរួមនៃមិត្តភាពដោយឆ្លងកាត់ភាពផ្សេងគ្នានៃសាសនា និងដោយ បង្កើតស្មារតីឱ្យតម្លៃនិងគោរពគ្នាទៅវិញទៅមក ដែលនាំទៅរកសន្តិ ភាពនិងភាពចុះសម្រុងខាងសាសនា។

**អង្គការយុវជន** (Youth Organization)

វិស័យសំខាន់មួយទៀត ដែលអ្នកកាន់សាសនាគួរសិក្សាយ៉ាងហ្មត់ចត់ គឺស្ថិតនៅក្នុងវិស័យនៃអង្គការយុវជននិង សកម្មភាពពាក់ព័ន្ធ។ យុវវ័យនាពេលបច្ចុប្បន្ន នឹងទៅជាមនុស្សចាស់នៅថ្ងៃស្អែក។ ពួកគេមិនគួរត្រូវបណ្តោយឱ្យវង្វេងក្នុងគ្រោះថ្នាក់នៃវ័យបច្ចុប្បន្នឡើយ។ ថាមពលនិងធនធានយុវវ័យទាំងអស់គួរត្រូវ បានប្រើ ជាប្រយោជន៏ហើយនិង តម្រង់ទិសឆ្ពោះទៅរកគោលបំណងស្ថាបនា។ ពួកគេគួរត្រូវបានបង្កលក្ខណ:ឱ្យមានការយល់ ដឹងពីការប្រៀនប្រដៅជា មូលដ្ឋានរបស់សាសនាក្នុងការលើកកំពស់សន្តិភាព និងភាពសុខដុមរបស់សង្គម និងមិនត្រូវបានបំប៉ននូវពិសពុលដែលបង្ខូច ជំនឿមួយឱ្យប្រឆាំងជំនឿមួយទៀតឡើយ។ ប្រសិនបើគេបានទទួលការណែនាំតាមរយៈគោលការណ៍សាសនា មានដូចជា ខន្តីអធ្យាស្រ័យ និងការយោគយល់ជាដើមយុវវ័យនាពេលបច្ចុប្បន្ននឹងក្លាយជាទុនដ៏ឧត្តុង្គឧត្តមបំផុតនៅក្នុងការអភិវឌ្ឍន៍ភាព សុខដុមនៃសាសនា និងកិច្ចសហការរវាងគ្នានិងគ្នាកាន់តែប្រសើរ ក្នុងចំណោមអ្នកកាន់សាសនានាពេលអនាគត។

**ការអធ្យាស្រ័យ និងការគោរព** (Tolerance and Respect)

ការអធ្យាស្រ័យនិងការគោរព ជាពាក្យសំខាន់ពីរដែលគួរដក់ជាប់ក្នុងសន្តានចិត្ត នៅក្នុងសង្គមពហុសាសនា។ គេមិនត្រឹមតែប្រៀនប្រដៅឱ្យចេះអធ្យាស្រ័យប៉ុណ្ណោះទេ ប៉ុន្តែត្រូវសាកល្បងអនុវត្តប្រើចិត្តស្លូតបូត មានអធ្យាស្រ័យនៅពេលមានឱកាស ដែលនឹងត្រូវធ្វើដំណើរដ៏ឆ្ងាយក្នុងការបង្កើតបរិយាកាសសន្តិភាពនិងសុខដុម ។យើងអាចមិនយល់ឬមិនឱ្យតម្លៃនូវតម្លៃខាងក្នុងរបស់ពិធីទំនៀមទម្លាប់សាសនា ឬការប្រតិបត្តិមួយចំនួនដែលធ្វើឡើងដោយ បណ្តាអ្នកកាន់សាសនារួមគ្នា។ ដូចគ្នានេះដែរ អ្នកដទៃអាចមិនស្ថិតនៅទីតាំង មួយដើម្បីយល់ឬឱ្យតម្លៃ ពិធីទំនៀមទម្លាប់ឬការប្រតិបត្តិ ផ្ទាល់របស់យើង ។ ប្រសិនបើយើងមិនចង់ឱ្យអ្នក ដទៃសើចចំអកនឹងការប្រព្រឹត្តរបស់យើងទេ យើងក៏មិនគួរនឹងសើចចំ អកនឹងការប្រព្រឹត្តរបស់អ្នកដទៃដែរ។ យើងគួរតែព្យាយាមប្រមើលមើល ឬស្វែងយល់បណ្តាការប្រតិបត្តិដែលខុសប្លែក ពីយើង ដោយហេតុថាវានឹង ជួយបង្កើតឱ្យមានការយល់ដឹងកាន់តែច្រើន ហើយបន្ទាប់មក គឺការបណ្តុះទឹកចិត្តអធ្យា ស្រ័យក្នុងបណ្តាអ្នក ដើរតាមទាំងឡាយនៃបណ្តានិកាយសាសនាចម្រុះ។

គេនិយាយថាការគោរពបង្កើតការគោរព។ ប្រសិនបើយើងទទឹងឱ្យអ្នកកាន់សាសនា រួមគ្នាដទៃទៀត ផ្តល់ដល់យើងនូវវិធីគោរពបែបណានោះក្នុងនាមជា អ្នកសង្កេតមើលមកសាសនារបស់យើងយើងក៏គួរតែកុំញញើតញញើម នឹងបង្ហាញការគោរពរបៀបនោះចំពោះគេវិញដែរនៅពេលដែលយើងសង្កេតមើលទៅការប្រតិបត្តិសាសនារបស់គេ។ ឥរិយាបថបែប នេះនឹងចូលរួមវិភាគទានយ៉ាងច្បាស់លាស់ចំពោះទំនាក់ទំនងល្អ និងជិតស្និទ្ធក្នុងសង្គមពហុសាសនា។

បើគ្មានការអនុវត្តន៍ជាក់ស្តែងនូវស្មារតីអធ្យាស្រ័យនិងគោរពគ្នាទៅវិញទៅមក ពិសពុលដ៏ឃោរឃៅ នៃការរើសអើង ការសើចចំអកនិងការស្អប់ខ្ពើមនឹងត្រូវបង្ហូរចេញទាំងផែន។ ទៅបំផ្លាញសន្តិភាពនិងភាពស្ងប់ ស្ងៀមរបស់សង្គមនិង ប្រទេសជាតិរបស់យើង។ ជាការពិតណាស់ថា នៅប្រទេសមួយចំនួនដែលស្មារតីអធ្យាស្រ័យខាងសាសនា និងការគោរពគ្នាទៅវិញទៅមកមិនមានអត្ថិភាព ឃាតកម្ម ការបង្កអគ្គីភ័យ និងការបំផ្លិច បំផ្លាញទ្រព្យសម្បត្តិមានតម្លៃបានកើតមានឡើង។ អំពើមិនសមហេតុផលបែបនេះបង្កឱ្យមានការបាត់បង់ ដែលគ្មានអ្វីជំនួសបាននូវជីវិតនិងទ្រព្យសម្បត្តិមាន តម្លៃទាំងឡាយ គួរចាត់ទុកថាបានធ្វើឱ្យភ្លឺភ្នែក ចំពោះអ្នកទាំងឡាយណាដែលស្រឡាញ់សន្តិភាពនិងភាពសុខដុម។

**ទិដ្ឋភាពជីវិតផ្លូវចិត្ត** (Spiritual Aspects of Life)

ជីវិតនៅក្នុងលោកនេះមានពិតមែនប៉ុន្តែវាមានយៈពេលខ្លីណាស់ ។យើងចង់បានប្រយោជន៍ខាងសម្ភារៈខ្លាំងណាស់ប៉ុន្តែយើងមិនយកចិត្តទុកដាក់អើពើដឹងពីទិដ្ឋភាពជីវិតផ្លូវចិត្ត ដែលបានបង្រៀនយើងដោយបុព្វការីជនសាសនាចំណាស់ៗនោះឡើយ។ យើងគួរតែធ្វើជីវិត របស់យើងឱ្យមានខ្លឹមសារដោយដាក់ បញ្ចូលទៅជាប្រតិបត្តិទៅលើការបង្រៀនដ៏ខ្ពង់ខ្ពស់ និង ដំបូងនៃគ្រូសាសនារបស់យើងដើម្បីដឹកនាំជីវិតដែលមានប្រយោជន៍ ត្រឹមត្រូវ និងគួរឱ្យគោរពមួយដោយធ្វើអំពើល្អនៅទីកន្លែងណាដែលអាចប្រព្រឹត្តទៅបាន និងជៀសចេញពីអំពើអាក្រក់គ្រប់ពេល។ ការប្រៀនប្រដៅជាទូទៅ ត្រូវបានអះអាងដោយគ្រូសាសនាពិភពលោកទាំងអស់ គឺដើម្បីភាពសុខដុមរមនាសព្វយ៉ាងដើម្បីដឹកនាំអត្ថិភាពមនុស្ស និងដើម្បីលើកទិដ្ឋភាពបង្រៀនខាងផ្លូវចិត្តគួរឱ្យគោរពឱ្យបានខ្ពស់ឡើងពោលគឺការផ្តល់វិភាគទានចំពោះសន្តិភាពនិងភាពសុខដុមរមនា។

**ការផ្សាយសាសនា** (Propagation of Religion)

ដើម្បីផ្សាយសាសនាដ៏ពិសេស មួយគេចាំបាច់ត្រូវអះអាងពីវិស័យសំខាន់បំផុតឬប្រសើរបំផុត។ ហេតុដូចនេះហើយ ទើបគេបង្កើតក្រុមនាំមុខដ៏សំខាន់ឬគួរឱ្យចាប់អារម្មណ៍ ដើម្បីទាក់

ទាញជំនឿទុកចិត្តពីសំណាក់អ្នកដទៃ។ អ្នកកាន់សាស នាទាំងអស់នឹងលើកឡើងយ៉ាងទ្បេង ទាត់សំណើដ៏យុត្តិធម៌បង្គួរមួយដើម្បីបោះជំហាន ដ៏ប្រសើរឆ្ពោះទៅមុខដើម្បីលក់បរិក្ខាសាសនា របស់គេ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងសង្គម ពហុសាសនាដែលមានការប្រកួត ប្រជែងដ៏ស្រួចស្រាវ ដើម្បីទាក់ទាញបរិស័ទឬអ្នកប្តូរសាសនា គេគួរតែមានការយល់គ្នាទៅវិញទៅមក ក្នុងចំណោមអ្នកដឹកនាំដើម្បីទប់ស្កាត់ ការបង្ខាប់បង្ខោន ការទិតៀន ឬការវាយប្រហារចំពោះជំនឿឬការប្រតិបត្តិរបស់អ្នកកាន់សាសនាដទៃ។ ជាការប្រសើរ ហើយដែលអ្នកផ្សាយសាសនាមួយចំនួនបានធ្វើឱ្យអ្វីៗទាំងអស់ក្នុងសាសនារបស់គេរុងរឿងឆើតឆាយនិងមានគុណប្រយោជន៍ ប៉ុន្តែអ្នក ទាំងនោះគួរជៀសវាងពីការរុកកួនអ្នកកាន់សាសនាដទៃពីក្រោយខ្នង ដោយនិយាយប្រាប់ពិភពលោកថា សាសនាដ៏ពិសេសរបស់ខ្លួន ជាសាសនាដ៏ល្អប្រសើរជាងគេបំផុត ហើយបរិសុទ្ធពិតចំណែកជំនឿនិងការប្រតិបត្តិរបស់សាសនាដទៃមានលក្ខណៈក្លែងបន្លំ។ការប្រកាន់យកឥរិយាបថបែបនេះ នឹងនាំឱ្យកើតមានភាពអរិចិត្ត និងគំនុំគុំគួនក្នុង បណ្តាអ្នកកាន់សាសនាទាំងឡាយដែលបណ្តាលទៅជាការសងសឹកគ្នានិងការប្រមាថគ្នាទៅវិញទៅមក។ទាំងនេះប្រាកដជាមិនមែនបំណងរបស់សាសនាដ៏ជាទីគោរពណាមួយដែលសមគួរនឹងហៅថា"សាសនា"នោះឡើយ។

តាមការពិតសាសនាទាំងអស់ កើតមានឡើងដើម្បីសេចក្តីល្អរបស់មនុស្សជាតិ។ ព្រះបរមគ្រូទាំងអស់របស់សាសនាទាំងឡាយ ក្នុងពិភពលោកបានសម្តែងធម្មទេសនាអំពីសន្តិភាព និងភាពសុខដុមរមនា ដើម្បីមនុស្សជាតិទាំងអស់។ អ្នកដឹកនាំសាសនាដ៏គួរគោរពទាំងឡាយ ដោយបញ្ញារបស់លោក លោកតែងនាំយកអ្វីដែលល្អប្រសើរ មានមេត្តាករុណា និងមានសីលចរិយាធម៌យកមកចែកចាយនិងរំដោះមនុស្សជាតិ។ គ្រូសាសនាដ៏ថ្លៃថ្នូរទាំងឡាយមិនបានបែងឋានៈ ឬបង្ខាប់បង្ខោនគ្នាទៅវិញទៅមកដើម្បីបង្កើតភាពវឹកវរ ការមិនយល់គ្នា និងការរង្កៀសចិត្ត ក្នុងចំណោមប្រជាករនោះឡើយ។ លោកទាំងនោះ តែងមានជាប់ក្នុង បេះដូងនូវសុខុមាលភាពនិងសុវត្ថិភាពរបស់មនុស្សជាតិទាំងអស់។ គោលបំណងតែមួយរបស់លោក គឺបង្កើតពិភពដ៏ល្អប្រសើរមួយដើម្បីឱ្យមនុស្សរស់នៅក្នុងមិត្តភាព និងភាពសុខដុមរមនា។

ជាការប្រាកដហើយដែលថា អ្នកដឹកនាំសាសនាទាំងឡាយក្នុងពិភពលោក ដែលចាប់កំណើតឡើងនៅកាលសម័យផ្សេងគ្នានៅទីកន្លែងដទៃពីគ្នា ទំនងជាបង្កើតឡើងនូវភាពដោយឡែកៗប្រហែលៗគ្នាហើយនិងភាពច្រើនអនេកនៃជំនឿ និងការប្រតិបត្តិសាសនាដែលនៅមានជារហូតមកក្នុងបរិស្ថានផ្សេងៗគ្នា និងផ្នែកផ្សេងៗនៃពិភពលោក។ អ្នកដឹកនាំសាសនានីមួយៗ

លោកមានគោលគំនិត វិធីសាស្ត្រនិងមធ្យោបាយផ្ទាល់របស់លោក ក្នុងការចែករំលែកការប្រៀនប្រដៅសាសនា ដែលមានមូលដ្ឋានដ៏ធំទូលាយនៃវប្បធម៌របស់អ្នកដើរតាម។ ចេញអំពីភាពផ្សេងៗគ្នាទាំងនេះហើយដែលជំនឿនិង ការប្រតិបត្តិសាសនាប្លែកៗបានកើតមានឡើង។

**អ្នកទទួលគ្រោះរបស់កាលៈទេសៈ** (Victim of Circumstance)

ប្រសិនបើកូនក្មេងម្នាក់មានកំណើតពីគ្រួសារអ្នកកាន់សាសនាគ្រីស្តមួយកូនក្មេងនោះនឹងគ្មានជម្រើស អ្វីផ្សេងក្រៅ តែពីទទួលការចិញ្ចឹមបីបាច់រក្សានិងអប់រំទៅតាមជំនឿសាសនា និងទំនៀមទម្លាប់ប្រពៃណីរបស់គ្រួសារគ្រីស្តសាសនិកនោះទេ។ ដូចគ្នានេះដែរកុមារម្នាក់កើតនៅក្នុងគ្រួសារឥស្លាមសាសនិក នឹងត្រូវទទួលការចិញ្ចឹមបីបាច់រក្សា និងអប់រំទៅតាមជំនឿ និងប្រតិបត្តិរបស់ឥស្លាមសាសនិកហើយចំពោះកុមារកើតពីគ្រួសារពុទ្ធសាសនិក នឹងប្រាកដជាដើរតាមមាគ៌ា ជីវិតបែបពុទ្ធសាសនិក។ កុមារដែលកើតក្នុងគ្រួសារ ហិណ្ឌូសាសនិកនឹងត្រូវចិញ្ចឹមបីបាច់និងអប់រំតាមបែបហិណ្ឌូ។ យើងទាំងអស់គ្នាត្រូវហ៊ុំព័ទ្ធដោយកាលទេសៈបរិស្ថានសាសនា សញ្ជាតិ និងវប្បធម៌ ដែលយើងមិនបានប៉ុនប៉ង ឬត្រួតត្រាបានទេ។ ក្នុងនាមជាកុមារនៅក្នុងគ្រួសារសាសនិកជាក់លាក់ណា មួយយើងទាំងអស់គ្នាបានទទួលការចិញ្ចឹមបីបាច់រក្សា និងអប់រំទៅតាមបញ្ញានិងសារៈតារសាសនារបស់មាតាបិតា។ ជំនឿសាសនារបស់មាតាបិតាយើងពិតជាក្លាយជាជំនឿរបស់ យើងផ្ទាល់ និងជាសារៈតារវប្បធម៌សម្រាប់មាគ៌ាជីវិតរបស់យើង។

អ្នកកាន់សាសនាគ្រប់រូប គប្បីព្យាយាមស្វែងយល់មរតកបរិស្ថាន និងវប្បធម៌ផ្សេងៗគ្នារបស់យើងម្នាក់ៗហើយគោ រពបុគ្គលចំពោះអ្វីដែលគេធ្វើនិងអ្វីដែលគេជឿជា ជាងច្រានទម្លាក់ជំនឿរបស់បុគ្គលម្នាក់ តាមរយៈបំពង់កបុគ្គលម្នាក់ទៀត តាមការអួតអាងថា "សាសនារបស់ខ្ញុំជាសាសនាពិត អ្នកគួរតែទទួលយក សាសនារបស់ខ្ញុំ ព្រោះសាសនារបស់អ្នកជា សាសនាក្លែងបន្លំ" ។អាហាររបស់មនុស្សម្នាក់អាចជាថ្នាំពុលរបស់មនុស្សម្នាក់ទៀត។ ក្នុងសង្គម ពហុសាសនា មិនត្រូវមានការតម្រូវ ការប្រើអំណាច ឬការបង្ខិតបង្ខំឡើយ ប្រសិនបើយើងទាំងអស់គ្នាមានបំណងរស់នៅក្នុងសន្តិភាព និងភាពសុខដុមរមនា។

**អ្នកលក់ដូរត្រាច់ចរ** (Itinerant Salesmen)

ជាញឹកញាប់ ម្ចាស់ផ្ទះបានត្អូញត្អែរថាភាពសុខសាន្តនិងស្ងប់ស្ងាត់នៃផ្ទះរបស់ពួកគេ ត្រូវបានរំខាន ដោយការយកចិត្ត ទុកដាក់ដែលគ្មានការស្វាគមន៍ របស់បណ្តាអ្នកលក់ដូរត្រាច់ចរដែលដើរពពាយនាយលក់ ជាប់បន្តបន្ទាប់នូវទំនិញសាសនាផ្ទួនៗគ្នា ដោយគ្មានការរអែង

ចំពោះម្ចាស់ផ្ទះ ទោះជាទំនិញនោះមានប្រយោជន៍ក្តី មិនមានប្រយោជន៍ក្តី។ សម្តីខ្លាំងៗរបស់អ្នកលក់ដូរត្រេចចរ ដែលមិនសូវមានជំនាញតែជឿស៊ប់ជ្រុលអាចជាការរំខានពិតប្រាកដចំពោះម្ចាស់ផ្ទះ។ ពួកគេមិនស្តាប់ ចម្លើយដ៏គួរសមថា "ទេ" នោះទេ ប៉ុន្តែពួកគេ នៅតែទទូចថា ដោយការទិញទំនិញ ទាំងនោះ ម្ចាស់ផ្ទះនឹងបានឡើង ជណ្តើរ ទៅកាន់ស្ថានសួគ៌។ ពួកគេមិនបានចាប់អារម្មណ៍ នឹងសម្លឹងរកនិកាយសាសនាណាមួយដែលម្ចាស់ផ្ទះកំពុងតែទ្រទ្រង់នោះទេ ពួកគេមិនគិតក្រែងថា សម្តីពពាយនាយរបស់ពួកគេនឹងដាស់បញ្ញាឬដាស់ចំណាប់អារម្មណ៍ចំពោះសាសនារបស់ម្ចាស់ផ្ទះឬក៏ទេនោះឡើយ។ គឺជាសំណាងអាក្រក់ដែលនិកាយសាសនាមួយ ចំនួនណានោះជ្រើសយកការបញ្ជូនអ្នកលក់សាសនាដ៏ងប់ងុលរបៀបនេះ ឱ្យពពាយនាយទំនិញសាសនារបស់គេ។ ទង្វើរបៀបនេះមាននិន្នាការបន្ទាបបន្ថោក សាសនារបស់គេមិនមែនលើកកំពស់ទេ។ គ្មាននរណាម្នាក់ចូលចិត្តឱ្យគេប្រាប់ថា គាត់គួរតែប្រកាន់យកសាសនាណាមួយដោយអាន សៀវភៅសាសនាមួយចំនួនណានោះ បើមិនដូច្នេះទេ គាត់នឹងត្រូវទទួលបាបនៅស្ថាន នរកក្រោយពេលស្លាប់។ មនុស្សម្នាក់ៗគួរបានទទួលការគោរពក្នុងនាមអ្នកចេះគិតគូរវែងឆ្ងាយ អាចសម្រេចចិត្តដោយខ្លួនឯងអំពីការជ្រើសយកគុណធម៌ទាំងឡាយ របស់សាសនាណាមួយទោះបីជាសាសនានោះកំពុងនាំគេទៅស្ថានសួគ៌ឬស្ថាននរកក៏ដោយ ។នេះគឺជាការជ្រើសរើសរបស់មនុស្ស គឺជាការជ្រើសរើសមួយដែលទទួលការគាំទ្រពេញលេញអំពីរដ្ឋធម្មនុញ្ញរបស់ប្រទេសយើងស្តីពីសេរីភាពនៃការគោរពបូជា។

មានការពិចារណាថា នៅក្នុងសង្គមពហុជាតិសាសន៍ និងពហុសាសនា អ្នកកាន់សាសនារួមគ្នា មិនគួរបន្ទាបខ្លួនឱ្យ បង្អាប់បង្អោនខ្លួនឯងដោយផ្ទន្ទា ឬនិយាយអាក្រក់ពីអ្នកកាន់សាសនាដទៃដែលបានទ្រទ្រង់ សាសនារបស់ព្រះបរមគ្រូដ៏ល្បី ល្បាញទាំងឡាយជាច្រើនសតវត្សមកហើយ។ វាជាការប្រសើរសម្រាប់អ្នកកាន់សាសនាណាមួយក្នុងការច្រៀងលើកតម្កើង សាសនារបស់ខ្លួន នៅក្នុងទីស្ថានសាសនារបស់ខ្លួន ហើយជៀសវាង បានពីការបំផ្លិចបំផ្លាញការប្រឹងប្រែងរបស់អ្នកកាន់សាសនាដទៃដោយអនុញ្ញាតឱ្យគេសម្រេចជ្រើស យកប្រវត្តិសាសនា បែបណានិងប្រភេទសាសនាមួយណាដែលគេពេញចិត្ត នឹងគោរព។ មនុស្សម្នាក់គួរតែមានអារម្មណ៍ថាគេមានសេរីភាពពេញលេញក្នុងការជ្រើស យកសាសនាណាដែលល្អសម្រាប់ គេដោយគ្មានការរារាំងពីអ្នក ដើរពពាយនាយលក់សាសនា ដែលព្យាយាមលក់ទំនិញសាសនារបស់គេហើយអន្ទោកអន្ទោលឱ្យមនុស្សនោះ ទទួលយកសាសនានោះ។ ដើម្បីសម្រេចបានសន្តិភាព និងភាព

សុខដុមដែលងាយបាត់បង់ក្នុង សង្គមពហុសាសនា មនុស្សគ្រប់រូបគួរមានអារម្មណ៍ថា ខ្លួនមានសេរីភាព ដើម្បីច្រៀងសរសើរសាសនារបស់ខ្លួនរៀង១ខ្លួន ប៉ុន្តែក្នុងគ្រប់ករណីគេគួរជៀសវាងការគប់ភក់ដាក់គ្នាទៅវិញទៅមក។ នៅពេលដែលភក់កំពុបភយន្តរាយ នឹងកើតមានឡើង។

**នយោបាយ និងសាសនា** (Politics and Religion)

វិស័យមួយទៀតដែលត្រូវយកចិត្តទុកដាក់ក្នុងការស្វែងរកសន្តិភាព និងភាពស្ងប់ស្ងាត់ក្នុងសង្គមពហុសាសនានោះ គឺថាចំណោទវិបត្តិនយោបាយនិងពូជសាសន៍ មិនគួរនឹងលើកឡើងក្នុងវេទិកាសាសនាទេ។ គួរចាប់អារម្មណ៍ថា នយោបាយបច្ចុប្បន្ននិងសូម្បីពីអតីតកាលជាទូទៅអ្នកនយោបាយចូលចិត្តយកឥទ្ធិពល ស្ថាប័នទាំងអស់រួមទាំង ស្ថាប័នសាសនាផង ប្រើប្រាស់ដើម្បីបន្តជីវិតនយោបាយរបស់គេ។ មធ្យោបាយទាំង អស់ជាល្បែងយុត្តិធមិសម្រាប់អ្នកនយោបាយប៉ុន្តែសាសនាគួរតែជៀសវាងពីនយោបាយនិងអ្នកនយោបាយ។ វេទិកាចេត្តោនិយមបំពេញបំណងឱ្យតម្រូវការខាងផ្លូវចិត្ត របស់អ្នកមានចិត្តកាន់សាសនា រួមទាំងអ្នកនយោបាយដែលជាអ្នកកាន់សាសនាផងដែរ ។ប៉ុន្តែវេទិកាបែបនេះមិនគួរបើកចំហរសម្រាប់អ្នកនយោបាយដែលអាច បំផ្លាញសន្តិភាពសាសនា និងភាពស្រឡះស្រឡំនៃទីសក្ការៈ តាមរយៈការជាប់ទាក់ទងនឹងនយោបាយរបស់គេនោះទេ។ សាសនាឱបក្រសោបអ្វី១ទាំងអស់ ដូច្នេះមិនគួរឱ្យមានរបាំងពូជសាសន៍ឬ របាំងអ្វីផ្សេងទៀតទេ។

យើងម្នាក់១ និងទាំងអស់គ្នា នៅពេលគោរពនិងទ្រទ្រង់សាសនារបស់យើងរៀង១ខ្លួនទោះក្នុងកាលទេសៈណាក៏ដោយមិនត្រូវ បដិសេធឬមើលស្រាលចំពោះការបង្រៀនរបស់បណ្ដាអ្នកកាន់សាសនាដទៃទេ ។យើងគួរតែព្យាយាមសិក្សា និងស្វែងយល់មូលដ្ឋានគ្រឹះរបស់សាសនាទាំងអស់ដោយច្បិចយកអ្វីដែលមានលក្ខណៈរួម និងល្អប្រសើរក្នុងការ ប្រតិបត្តិ ហើយបោះបង់ចោលអ្វីដែលមានចរិតទំនាស់នឹងគ្នា។ សរុបមកចូរទ្រទ្រង់សាសនារបស់អ្នក ប៉ុន្តែគោរពជំនឿរបស់អ្នកដទៃ។ ទង្វើនេះ ប្រាកដជានឹងជួយឱ្យរក្សាបានសន្តិភាព និងភាពសុខដុមរមនាក្នុងសង្គមពហុសាសនា។

## ៨-ឥរិយាបថរបស់ពុទ្ធសាសនិកចំពោះសាសនាដទៃ

(Buddhis Attitude towards other Religions) Ven. Dr. K.Sri Dhammananda

គោលបំណងនៃអត្ថបទនេះ គឺជួយបង្កើនការយល់ដឹងអំពីសាសនា ។ ការអធ្យាស្រ័យបែបសាសនា និងអត្ថន័យបង្កប់ដ៏ ជ្រាលជ្រៅក្នុងទស្សនៈរបស់ពុទ្ធសាសនិក ហើយដើម្បីយល់អំពីវិធីគោរពចំពោះសាសនាដទៃ។

អត្ថន័យបង្កប់ដ៏ជ្រាលជ្រៅរបស់សាសនាគឺអាចទ្រទ្រង់និងគោរពសាសនារបស់ខ្លួនដោយគ្មានការមើលងាយមើលថោក ឬប្រព្រឹត្តឆ្គាំឆ្គងចំពោះសាសនាដទៃ។ ជារៀងរហូតយើងត្រូវបង្កើតឱ្យមានការយល់គ្នាទៅវិញទៅមកសហការគ្នានិងអធ្យាស្រ័យគ្នាក្នុងចំណោមសហសាសនិកទាំងអស់ដើម្បីទទួលបានភាពសុខដុមខាងសាសនា។

ជានិច្ចកាល គេតែងនិយាយអំពីការអធ្យាស្រ័យខាងសាសនា ហើយនិងសារៈសំខាន់របស់វាប៉ុន្តែមានមនុស្សតិចតួចណាស់ ទោះជាអ្នកណាក៏ដោយបានសង្កត់លើវិធីជាក់ស្តែងដើម្បីទៅដល់ការអធ្យាស្រ័យ ខាងសាសនា។ គេត្រូវតែមានសេចក្តីសង្ឃឹមថា ក្នុងការពិនិត្យមើលអត្ថបទនេះយ៉ាងហ្មត់ចត់អ្នកអាននឹងអាចទទួលបានរូបភាពដ៏កាន់តែច្បាស់អំពីការអធ្យាស្រ័យខាងសាសនា ហើយនឹងខំប្រឹងខ្នះខ្នែងលើកកំពស់ការ អធ្យាស្រ័យខាងសាសនា។ យើងគួរតែព្យាយាមលុបបំបាត់នូវអ្វីដែលគេហៅថាការប្រកាន់ខ្ពស់( ហឹនមានះ=superiority complex) ការសង្ស័យគ្នាទៅវិញទៅ មកបុរេវិនិច្ឆ័យសាសនាចំណង់អាត្មានិយម ដើម្បីសេចក្តីល្អប្រសើរទូទៅ និងការលើកទឹកចិត្តសាសនារបស់ខ្លួនរៀងៗខ្លួន។ ដូច្នេះហើយ ការយល់ខាងសាសនាវាប្រសើរជាងឆ្ងាយណាស់ពីការអធ្យាស្រ័យខាងសាសនា។

ការយល់ខាងសាសនា វាប្រសើរជាងការអធ្យាស្រ័យខាងសាសនា ហេតុនេះ សាវ័កអ្នកកាន់សាសនាទាំងអស់នឹងធ្វើការដើម្បីមូលហេតុរួមនៃការរំដោះនិងបំភ្លឺមនុស្សជាតិ។ ការស្រាវជ្រាវរកការរំដោះនិងការបំភ្លឺគឺជាការស្រាវជ្រាវរកសច្ចភាព។ ជាគ្រោះអាក្រក់នៅក្នុងចំណោមគ្នាយើង មានជំនឿនិងការប្រតិបត្តិ សាសនាជាច្រើនដែលត្រូវពណ៌នាឬដាក់លក់ថាជាសច្ចភាពតែតាមពិតវាស្ថិតនៅឆ្ងាយពីសភាពនៃសច្ចភាព។ ក្នុងនាមជាអ្នកដើរតាមសាសនាដ៏ប្រាកដប្រជាយើង ត្រូវតែមានសេចក្តីក្លាហាននិងជំនឿជាក់ក្នុងការទទួល ស្គាល់នូវអ្វីដែលមានសំអាងថាជាបញ្ញត្តិកម្មខុស ហើយព្យាយាម កែតម្រង់វាឱ្យស្របទៅនឹងវិទ្យាសាស្ត្រ និងធ្វើសេចក្តីសន្និដ្ឋាន ដើម្បីបំពេញតម្រូវការរបស់សច្ចភាព។ យើងនឹងជួបបរាជ័យក្នុងការងាររបស់យើងប្រសិនបើយើងនៅតែជីតជាប់ នឹងអ្វីដែលយើងដឹងថាមិនមែនជាសច្ចភាព។ យើងក៏មានកំហុសផងដែរ ប្រសិនបើក្នុងការប្រតិបត្តិការអធ្យាស្រ័យខាងសាសនារបស់យើង យើងអធ្យាស្រ័យឱ្យសាសនាមួយដោយ គ្មានការចង្អុលបង្ហាញភាពបរាជ័យឬភាព ខ្វះចន្លោះរបស់សាសនានោះ ដែលមិនស្របនឹងសច្ចភាព។ ក្នុងការស្វែងរកសច្ចភាព យើងគប្បីលះបង់ចោលឥរិយាបថប្រកួតប្រជែងរបស់យើង ហើយរួបរួមគ្នាធ្វើការងារដោយជិតស្និទ្ធ ដើម្បីសម្រេចបានគោល

បំណងដ៏ខ្ពង់ខ្ពស់របស់យើង គឺភាពសុខដុមរមនាខាងសាសនាដើម្បីសុខុមាលភាព របស់មនុស្សជាតិ។

ថ្វីត្បិតព្រះពុទ្ធបានចង្អុលប្រាប់ថា មិនមានគុណធម៌សាសនាទេ នៅក្នុងការប្រតិបត្តិជាច្រើននៅប្រទេសឥណ្ឌា កាលពីសម័យរបស់ព្រះអង្គ ព្រះអង្គមានសេចក្តីសុភាពរាបសារក្នុងការទូន្មានដល់សាវ័ករបស់ ព្រះអង្គឱ្យផ្តល់ទេយ្យទាន ឬអាហារដល់ពួកព្រាហ្មណ៍ ឬស្មូមយាចកដទៃទៀត និងឧបត្ថម្ភពួកគេដោយមិន គិតពីសាសនារបស់ពួកគេ។ ព្រះពុទ្ធបានទូន្មាន សាវ័ករបស់ព្រះអង្គកុំឱ្យបង្កការឈឺចាប់ឬធ្វើឱ្យរបួសដល់សមណៈ (សង្ឃ) ណាមួយ ឬដល់ព្រាហ្មណ៍ណាមួយ ។នេះបង្ហាញថាព្រះអង្គបានសង្គ្រោះព្រះសង្ឃនិងពួកព្រហ្មណ៍ដែលជាអ្នកកាន់សាសនា ។ បន្ថែមលើនេះទៀត ព្រះពុទ្ធបានផ្តល់ឱវាទថា នៅពេលជនម្នាក់ក្បត់នឹង ព្រាហ្មណ៍ម្នាក់ ព្រះសង្ឃមួយអង្គ ឬអ្នកទ័លក្រម្នាក់ ដោយការនិយាយភូតភរ នោះហើយជា មូលហេតុនៃការវិនាសរបស់ជននោះ។ ដូច្នេះ ក្នុងការទូន្មានសាវ័ករបស់ព្រះអង្គតាមរបៀបនេះ ព្រះពុទ្ធបានរាប់អានអ្នក ទាំងអស់នោះដោយគ្មានការរើសអើង។

គោលបំណងនៃព្រះពុទ្ធសាសនា គឺណែនាំមនុស្សគ្រប់រូបឱ្យរស់នៅដោយសេចក្តីថ្លៃថ្នូរ ដោយគ្មានការធ្វើទុក្ខទោសដល់នរណា ម្នាក់បណ្តុះគុណសម្បត្តិមេត្តាករុណាដើម្បីរក្សាបានសេចក្តីថ្លៃថ្នូរជាមនុស្ស ផ្សាយសប្បុរសធម៌ទូលំទូលាយដោយគ្មានការរើសអើងណាមួយហ្វឹកហាត់ចិត្តគំនិតឱ្យជៀសវាងអំពើបាបនិងជម្រះចិត្តឱ្យស្អាតបរិសុទ្ធដើម្បីទទួលបានសន្តិភាពនិងសុភមង្គល។

ព្រះពុទ្ធសាសនា គឺជាសាសនាដែលបង្រៀនមនុស្សលោកឱ្យ "រស់នៅនិងអនុញ្ញាតឱ្យរស់នៅ"។ នៅក្នុងប្រវត្តិសាស្ត្រ ពិភពលោកមិនមានភស្តុតាងណាមួយបង្ហាញថា ពួកពុទ្ធសាសនិកបានចូលជ្រៀតជ្រែក ឬ បង្កការអន្តរាយដល់សាសនាដទៃណាមួយ នៅផ្នែកណាមួយនៃពិភពលោក ដើម្បីបំពេញបំណងផ្សព្វផ្សាយសាសនារបស់ពួកគេឡើយ។ ពុទ្ធសាសនិកទាំងឡាយមិនចាត់ទុកវត្តមាននៃសាសនាដទៃថាជាឧបសគ្គចំពោះវឌ្ឍនភាពនិងសន្តិភាពពិភពលោកឡើយ។

ពុទ្ធដីកា គឺជាសេចក្តីអញ្ជើញមនុស្សទាំងអស់ឱ្យរួបរួមគ្នាជាបងប្អូន ទូទាំងពិភពលោក ដើម្បីធ្វើ ការងារក្នុងភាពរឹងប៉ឹងនិងសុខដុម ដើម្បីសុខុមាលភាព និងសុភមង្គលរបស់មនុស្សជាតិ។ ព្រះអង្គមិនមាន មនុស្សសំខាន់ទេ ហើយព្រះអង្គក៏មិនបានចាត់ទុកខ្លួនព្រះអង្គថា ជាមនុស្សសំខាន់ដែរ។

បណ្តាបេសកជនដំបូងរបស់ព្រះពុទ្ធ គឺបណ្តាព្រះអរហន្ត ដែលជាបណ្តាបុគ្គលដ៏ពិសិដ្ឋនិងឥតខ្ចោះ។ ពួកលោកជាមនុស្សជាតិខ្ពង់ខ្ពស់ដែលបានសម្រេចសុក្រឹតភាពដោយការ ប្រឹងប្រែងបញ្ឈប់អំពើខុសឆ្គងផ្សេងៗដោយស្មោះត្រង់និងដោយការដុសខាត់បញ្ញា។ មុននឹងបញ្ជូនសាវ័កចេញទៅ ព្រះពុទ្ធបានទូន្មានពួក លោកតាមវិធីដូចខាងក្រោម :

"ឱភិក្ខុទាំងឡាយ ចូរអ្នកចេញទៅ ហើយត្រេចរង្គាត់ទៅមុខ ដើម្បីសេចក្តីសុខរបស់មនុស្សជាច្រើន ដោយសេចក្តី ករុណាចំពោះពិភពលោក ដើម្បីកុសលធម៌ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខរបស់ទេវតា និងមនុស្សទាំងឡាយ។ ឱភិក្ខុទាំងឡាយ ចូរអ្នកប្រកាសនូវ លទ្ធិដ៏ប្រសើរបំផុត ចូរអ្នកទេសនាអំពីជីវិតដ៏ ពិសិដ្ឋ សុក្រឹត និងល្អបរិសុទ្ធ។"

អាស្រ័យតាមដំបូន្មាននេះ ព្រះពុទ្ធចង់ប្រាប់ទៅមនុស្សទាំងឡាយអំពីភាព ខុសគ្នារវាងកុសល និងអកុសល។ ព្រះអង្គចង់បង្រៀនបរិស័ទ អំពីវិធីរស់នៅដោយមានសុភមង្គលសន្តិភាពនិងភាពត្រឹមត្រូវ។ ព្រះអង្គមិនដែលទូន្មានសាវ័ក របស់ ព្រះអង្គ ឱ្យទាក់ទាញបរិស័ទឱ្យគេប្តូរសាសនាពីសាសនាមួយទៅសាសនាមួយ ទេ។ គំនិតរបស់ព្រះអង្គអំពីការប្តូរ គឺការនាំឱ្យស្គាល់ជីវិតរស់នៅដោយភាពត្រឹមត្រូវ ថ្លៃថ្នូរ និងដើរតាមមាគ៌ាជីវិតខាងសាសនា។

ព្រះពុទ្ធមិនបានទិតៀនឬផ្គន្ទាសាសនាណាមួយ ក្រៅតែពីបានបំភ្លឺបរិស័ទដោយ បង្ហាញដល់ពួកគេនូវភាពអសាឥតការនៃការចូលទៅក្នុងអត្តកិលមកម្ម (ឬការធ្វើទណ្ឌកម្មលើខ្លួនឯងហួសហេតុ) និងការបណ្តែត បណ្តោយខ្លួន(ឬ ការត្រេក ត្រអាលនឹងកាមរាគៈ) និងឱ្យជៀសវាងការប្រតិបត្តិបែបជំនឿអធិធម្មជាតិ គ្មានន័យក្នុងនាមសាសនា។

**សាសនាពិត** (The True Religion)

តបនឹងសំណួរថា សាសនាពិតកើតឡើងអំពីអ្វី ព្រះពុទ្ធបានផ្តល់ចម្លើយដ៏ទូលាយ ដោយមានពុទ្ធដិកា ថានៅទីណាដែល មានការបង្រៀនពីអរិយសច្ចៈទាំងបួន និងអរិយមគ្គទាំងប្រាំបី និងនៅទីណាដែលគេអាច រកឃើញបរិស័ទដ៏បរិសុទ្ធដែល មានការអភិវឌ្ឍន៍ផ្លូវចិត្ត នៅទីនោះហើយដែលមានសាសនាពិត។ព្រះអង្គមិនបានពោលថា ព្រះពុទ្ធសាសនាជាសាសនាដ៏ពិតប្រាកដមួយនៅក្នុងពិភពលោកនេះទេ ប៉ុន្តែព្រះអង្គបានដាស់ តឿនបរិស័ទឱ្យទទួលយកនិងគោរពសច្ចភាពនៅទីណា ដែលរកឃើញសច្ចភាព។ ពុទ្ធដិកានេះមានន័យថា យើងមិនចាំបាច់ធ្វើមិនដឹងមិនឮពាក្យប្រៀនប្រដៅដែលមានលក្ខណៈសមហេតុផល របស់សាសនាដទៃទេ។ ឥរិយាបថនេះ បង្ហាញយ៉ាងច្បាស់ថា ព្រះពុទ្ធមិនដែលមានបុរេវិនិច្ឆ័យណាមួយ ចំពោះ សាសនាដទៃ

ទេហើយក៏មិន បានប្រមូលយកផ្ដាច់មុខនូវសច្ចភាពសាសនាផងដែរ។ ព្រះអង្គចង់បង្ហាញបញ្ហាមួយប៉ុណ្ណោះ គឺសច្ចភាព ហើយពាក្យប្រៀបប្រដៅរបស់ព្រះអង្គទាំងអស់ សុទ្ធសឹងផ្អែកលើអរិយសច្ចៈបួនពោលគឺ ទុក្ខៈឬភាពទោមនស្ស សមុទយទុក្ខ ឬហេតុនៃទុក្ខ និរោធនៈ ឬការលះបង់ និងមគ្គៈ ឬវិធីនាំទៅរកការលះបង់។

នៅពេលណាដែលព្រះពុទ្ធទូន្មានសាវ័ករបស់លោកឱ្យប្រព្រឹត្ត ឬជៀសវាងអ្វីមួយ ជានិច្ចកាលព្រះអង្គប្រាប់ឱ្យអនុវត្តយ៉ាងនោះដោយមិនមែនត្រឹមតែដើម្បីសុខុមាលភាពនិងសុភមង្គលផ្ទាល់ខ្លួនប៉ុណ្ណោះទេ តែក៏ដើម្បីសុខុមាលភាពនិង សុភមង្គលរបស់អ្នកដទៃផងដែរ ។ ព្រះអង្គមានដិកាថា " ប្រសិនបើជាការប្រសើរ ចំពោះអ្នក និងអ្នកដទៃនោះ ចូរប្រតិ បត្តិទៅ ប៉ុន្តែបើជាការអាក្រក់ចំពោះអ្នកនិងអ្នកដទៃ ចូរកុំប្រតិបត្ត " ។

ក្នុងនាមជាអ្នកកែទម្រង់សង្គម ព្រះពុទ្ធបានរកឃើញឫសកែវដ៏ជ្រៅបំផុត នៃទុក្ខសោករបស់មនុស្សនោះគឺ លោភៈ ទោសៈ និងមោហៈដែលបានចាក់ឫសយ៉ាងជ្រៅក្នុង ចិត្តរបស់មនុស្ស។ ដូច្នេះហើយមានតែការឆ្លងកាត់ចិត្តមនុស្ស ប៉ុណ្ណោះ ដែលជាកំណែទម្រង់ពិតប្រាកដមានប្រសិទ្ធភាព។ បណ្ដាកំណែទម្រង់ ដែលបានធ្វើឡើងចំពោះផ្នែកខាងក្រៅដោយកម្លាំងអាចស្ថិតនៅរយៈពេលខ្លីប៉ុណ្ណោះ ប៉ុន្តែបើវាផុសចេញពីការ កែប្រែសម្បជញ្ញៈខាងក្នុងរបស់មនុស្សវាស្ថិតស្ថេរយូរអង្វែង ជាង។

និន្នាការអប្រិយទៅរកលោភៈទោសៈនិងមោហៈត្រូវតែជំនះបាននៅទីបំផុតហើយជំនួសដោយ អានុភាពនៃសប្បុរសធម៌សីល និងបញ្ញា។ មានតែតាមរយៈការសំអាត ចិត្តឱ្យបរិសុទ្ធប៉ុណ្ណោះ ដែលអាចនាំមកដោយប្រសិទ្ធភាពនូវសន្តិភាព និងសុភមង្គលតាមរយៈសាសនា ។

ព្រះពុទ្ធសាសនាបានទៅជា បេសកសាសនាដំបូងគេក្នុងពិភពលោក ដែលគេបានជួប។ ជិត២៣០០ឆ្នាំ កន្លងទៅតាមរយៈកិច្ចខិតខំប្រឹងប្រែងក៏ខ្ពង់ខ្ពស់របស់ព្រះអធិរាជអសោក ដែលបានគ្រប់គ្រងប្រទេសឥណ្ឌា (៣០៥-២៦៨មុនគ.ស)និងដែលជាអ្នកស្រឡាញ់អំណាចក៏កំពូលក្នុងលោក បានបោះបង់ចោលអាវុធហិង្សា ហើយបូជាពេលវេលារបស់ លោកក្នុងការលើកតម្កើងវប្បធម៌ និងព្រះពុទ្ធសាសនា។ ព្រះអង្គបានបញ្ជូន បេសកជនពុទ្ធសាសនិក រួមទាំងបុត្រា និងបុត្រី របស់ព្រះអង្គ ឱ្យត្រេចចរពេញប្រទេសនិងឆ្លងទៅប្រទេសនានាក្នុងពិភពលោក ដើម្បីផ្សព្វផ្សាយឱវាទសន្តិភាពរបស់ព្រះពុទ្ធ។ ដោយគោរពតាមប្រពៃណីដ៏ខ្ពង់ខ្ពស់របស់ ព្រះពុទ្ធព្រះអង្គមិនដែលភ្លេចទូន្មាន ដល់បេសកជនទាំងឡាយកុំឱ្យផ្ដន្ទាឬបៀតបៀនសាសនាដទៃណា

មួយទេ នៅពេលដែលលោកទាំងនោះសំដែងធម្មទេសនាក្នុងព្រះពុទ្ធសាសនា។ ដំបូន្មាននេះត្រូវបានឆ្លាក់ជាប់នឹង សសរស្តម្ភមួយរបស់ស្តេចអសោកជាអក្សរព្រាហ្មី ដែលមានសំណល់បាក់បែករហូតដល់សព្វថ្ងៃនៅតំបន់សាណាត និងបេណា ក្នុងប្រទេសឥណ្ឌា។

ពាក្យពេចន៍ដែលមានចែងនៅក្នុងព្រះបញ្ញត្តិ មានដូចខាងក្រោម :

"គេបុគ្គលមិនគប្បីលើកតម្កើងតែសាសនារបស់ខ្លួន ហើយផ្គន្ទាសាសនារបស់អ្នកដទៃទេ ប៉ុន្តែគេគប្បីលើកតម្កើង សាសនារបស់អ្នកដទៃផងដែរ ដើម្បីមូលហេតុនេះ ឬមូលហេតុនោះ។ ធ្វើបែបនេះបុគ្គលជួយឱ្យ សាសនារបស់ខ្លួន លូត លាស់ឡើង ហើយបម្រើឱ្យសាសនារបស់អ្នកដទៃផងដែរ។ ប្រព្រឹត្តផ្ទុយពីនេះ គេនឹងជីក រណ្តៅកប់សាសនាខ្លួនឯង ហើយក៏ បំផ្លាញសាសនាអ្នកដទៃផងដែរ ។បុគ្គលណាមួយលើកតម្កើងសាសនារបស់ខ្លួនហើយផ្គន្ទាសាសនាដទៃធ្វើដូច្នេះ គឺពិតជា បូជាសាសនារបស់ខ្លួន ដោយគំនិតថា"អាត្មាអញ នឹងលើកកិត្តិស័ព្ទសាសនាអញ" ប៉ុន្តែផ្ទុយស្រឡះ គឺគេធ្វើឱ្យវិនាសសា សនារបស់គេកាន់តែធ្ងន់ធ្ងរទៅ ប៉ុណ្ណោះទេ។ ដូច្នេះ មានតែការស្រុះស្រួលគ្នាទេ ទើបជាការប្រសើរ "ចូរអ្នករាល់គ្នា ស្តាប់ ហើយស្តាប់ដោយអំណរ ចំពោះលទ្ធិសាសនាកាន់ដោយអ្នកដទៃ។ "

ប្រជាជនអាស៊ី មានមូលហេតុជាច្រើនដែលត្រូវមានកតញ្ញូតាធម៌ ចំពោះព្រះបរមរាជាអង្គនេះ។ ក្នុងនាមអ្នកគ្រប់គ្រងព្រះអង្គបានបំពេញករណីយកិច្ចឧបត្ថម្ភរាល់សាសនាដែលមានដោយគ្មានការរើសអើងណាមួយ។

**ភាពសុខដុមរបស់សាសនា** (Religious Harmony)

គោលការណ៍របស់សាសនាទាំងឡាយ សុទ្ធសឹងរៀបបម្រុងសម្រាប់មនុស្ស ជាតិទាំងមូល។ ប្រសិនបើ ផ្នែកដោយឡែក ណាមួយរបស់មនុស្សជាតិ មិនប្រព្រឹត្តតាមបណ្តាគុណធម៌ដ៏ឧត្តុង្គឧត្តមដែលបានអប់រំដោយ សាសនាមានដូចជាសប្បុរសធម៌ ខន្តីអធ្យាស្រ័យ និងការយល់ទេនោះ នឹងមានការលំបាកចំពោះអ្នកដទៃ ក្នុងការរស់នៅដោយសន្តិភាព។

ជាធម្មតាបុគ្គលដែលវៃឆ្លាតហើយអាត្មានិយម តែងទាញយកផលប្រយោជន៍ពីគុណធម៌ប្រភេទណាមួយ ប៉ុន្តែគប្បី អ្នកកាន់សាសនាបច្ចុប្បន្នទាំងអស់ចងចាំទុកថា បុគ្គលទាំងឡាយណាដែលប្រយុទ្ធនិងបង្ហូរឈាមក្នុងនាមសាសនា គឺពួកគេមិនគោរពគោលការណ៍សាសនាទេ ហើយក៏មិនបម្រើឱ្យមូលហេតុមនុស្សជាតិដែរ ។ពួកគេប្រយុទ្ធដើម្បីផលប្រយោជន៍ និងអំណាចបុគ្គល ដោយប្រើប្រាស់នាមនៃសាសនាមួយ។ ចំណែកបណ្តាបុគ្គលដែលប្រតិបត្តសាសនាមួយ

ដោយពិតប្រាកដនោះ ពួកគេគ្មានប្រវត្តិប្រយុទ្ធទេ គឺពួកគេ ដោះស្រាយបញ្ហានានាតាមវិធីសន្តិភាព។ សាសនាពិតមិនដែលលើកស្ទួយទម្រង់ណាមួយនៃអំពើហិង្សាទេ ទោះស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ។ ជាមួយគ្នានេះការរើសអើងពូជសាសន៍ក៏មិនគួរ នឹង កើតមានដែរនៅពេលដែលយើងប្រតិបត្តសាសនារបស់ខ្លួនរៀងៗខ្លួន។ ពុទ្ធសាសនិកទាំងឡាយអាចរស់នៅនិងធ្វើការ ជាមួយអ្នកកាន់សាសនាដទៃដោយគ្មានអរិភាពណាមួយទេ។ មិនត្រឹមតែប៉ុណ្ណោះទេពុទ្ធសាសនិកមិនដែល បង្ខូរឈាមគ្នា ក្នុងចំណោមនិកាយផ្សេងគ្នារបស់ពួកគេ ឬក៏បង្ហូរឈាមជាមួយសាសនាដទៃដើម្បីប្រយោជន៍ សាសនាខ្លួនដែរ។

សព្វថ្ងៃព្រោះតែការសាហាវយង់ឃ្នងដែលត្រូវបានប្រព្រឹត្ត ហើយនៅតែបន្តប្រព្រឹត្តដ៏ទូលំទូលាយ ក្នុងនាមសាសនា មនុស្សជាច្រើនទៅជាវង្វេងវង្វាន់ចំពោះការអធិប្បាយពាក្យ "សាសនា "ដ៏ឧត្តុង្គឧត្តម។ លទ្ធិ សម្ភារនិយម ការលាក់ពុត និងលទ្ធិជ្រុលនិយម ដែលកំពុងតែលាក់ពួនក្រោមការក្លែងបន្លំរបស់សាសនា បានបង្កភយន្តរាយជាច្រើន នៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។ តម្លៃពិតរបស់សាសនា កំពុងតែបាត់បង់យ៉ាង លឿនចេញពីសន្តានចិត្តរបស់មនុស្ស ព្រោះតែគេរត់ ទៅរកការស្រាវជ្រាវភាពងងឹតនិងអាថិកំបាំង។ បណ្តា សាសនាដ៏ឧត្តុង្គឧត្តមដែលមានក្នុងពិភពលោកកំពុងតែប្រេះស្រាំជា ទម្រង់ច្រើនអនេកហើយមនុស្សខ្លះក៏កំពុងតែដើរចេញដើម្បីសើចចំអកឱ្យសាសនា។ ពេលវេលាបានមកដល់ចំពោះបណ្តាអ្នកកាន់សាសនាសព្វថ្ងៃ ដើម្បីចាប់ផ្តើមបង្ហាញតម្លៃសាសនាតាមទិដ្ឋភាពត្រឹមត្រូវរបស់វា ជំនួសឱ្យការគ្រាន់តែប្រកែក និងឈ្លោះគ្នាអំពីឧត្តមគតិ និងទេវកថាក្នុងសាសនាផ្សេងគ្នាប៉ុណ្ណោះ។

សាសនាមិនគួរត្រូវឃុំតែក្នុងការធ្វើសក្ការបូជា និងការបន់ស្រន់តែប៉ុណ្ណោះទេ។ សាសនាមិនមែន ជាមធ្យោបាយ សម្រាប់តែសេវាកម្មបបូរមាត់ទេ ប៉ុន្តែជាវិធីជាក់ស្តែងសម្រាប់ ឱ្យមនុស្សប្រតិបត្តិ ដោយគ្មានអន្តរាយ ដើម្បីធ្វើជាអ្នកបម្រើដល់ មនុស្សជាតិ ដើម្បីធ្វើជាមនុស្សល្អនិងទទួលបានសេរីភាព សន្តិភាព និងសុភមង្គលពិតប្រាកដ។

សាសនាផ្សេងគ្នា អាចមានជំនឿ និងទស្សនៈផ្សេងគ្នា ចំពោះការចាប់ផ្តើមនិងការបញ្ចប់របស់ជីវិត ក៏ដូចជាមានការបកស្រាយផ្សេងគ្នាចំពោះការសង្គ្រោះនៅទីបំផុត។ ប៉ុន្តែ យើងមិនគួរលើកយកបញ្ហាខ្វែង យោបល់ទាំងនេះមកដាក់ពី មុខដើម្បីបង្កើតទំនាស់ ការប្រឈមមុខការប៉ះទង្គិចគំនុំគុំគួន និងការមិនយល់គ្នានោះឡើយ។

មានគុណធម៌រួមជាច្រើនសម្រាប់អ្នកកាន់សាសនាលើកបង្ហាញជាទ្រឹស្តី និងប្រតិបត្តិ ក្នុងនាមសាសនា ដើម្បីឱ្យបរិស័ទអាចដឹកនាំមាគ៌ាជីវិតសាសនា សន្តិភាព និងមាគ៌ាជីវិត ដែលមានការអប់រំ ។

យើងមិនមានការចាំបាច់ត្រូវនិយាយមើលងាយ និងជេរបន្ទោសគ្នាទៅវិញទៅមកទេ ។ ប្រសិនបើ យើងធ្វើដូច្នេះ យើងបានត្រឹមឆ្ការផ្លូវទុកឱ្យក្រុមអ្នកប្រឆាំងសាសនា ដែលរង់ចាំសើចចំអកនិងផ្តន្ទាសាសនាទាំងអស់ប៉ុណ្ណោះ ។យើងមិនគួរកាន់មារយាទរបៀបបង្ហាញឥរិយាបថជាសត្រូវចំពោះសហសាសនិករបស់យើងទេ ។ ប្រសិនបើយើងធ្វើដូច្នេះ បរិស័ទនឹងនិយាយថាសាសនាទាំងឡាយជំរុញឱ្យមនុស្សបែងចែកគ្នា ។

ពុទ្ធសាសនិកទាំងឡាយ មិនត្រូវបានហាមឃាត់ការគោរពដ៏សមគួរចំពោះ គ្រូសាសនាដទៃ ក៏ដូចជាមិនត្រូវបានដាក់ កំហិតមិនឱ្យទៅចូលរួមនៅទីសក្ការៈនិងចូលរួម បម្រើសាសនាដទៃក្រៅពីព្រះពុទ្ធសាសនានោះឡើយ ។ ពួកគេអាចបង្ហាញកិច្ចសហការដ៏ពេញលេញ ដោយប្រកាន់ខ្ជាប់នូវមូលដ្ឋានគោលការណ៍ពុទ្ធសាសនារបស់ពួកគេ ។

ព្រះពុទ្ធសាសនាជួយជំរុញកិច្ចសហការ និងការយល់គ្នា ក្នុងបណ្តានិកាយសាសនាផ្សេងៗគ្នា ។ តាមទស្សនៈពុទ្ធសាសនិកផ្លាកសាសនា មិនមែនជាទិដ្ឋភាពសំខាន់បំផុតចំពោះ មនុស្សដែលត្រូវតែចាត់ទុកថាជា អ្នកសាសនានោះឡើយ ប៉ុន្តែគឺមនុស្សដែលមានការរស់នៅគួរជាទីគោរព និងមិនមានការបំផ្លិចបំផ្លាញនោះទេ ដែលអាចចាត់ទុកជាអ្នកសាសនា ។

អ្នកទាំងឡាយណាដែលចាប់ទោសកំហុសនិងទិតៀនព្រះពុទ្ធសាសនា គេអាចធ្វើដូចនោះបានតែត្រឹម កម្រិតសើៗ តែប៉ុណ្ណោះ ។ គេអាចទិតៀនបានត្រឹមតែបណ្តាការប្រតិបត្តិ របៀបរបប និងទម្លាប់បែបប្រពៃណី ប៉ុណ្ណោះ តែគេមិនអាចទិ តៀនពាក្យប្រៀនប្រដៅ ដែលបង្កើតឡើងដោយព្រះពុទ្ធបានទេ ពីព្រោះគោលការណ៍ ទាំងនោះត្រឹមត្រូវគ្រប់កាលវេលា ។ គោលការណ៍ទាំងនោះ ជនណាម្នាក់ចង់សាកល្បង គេអាចសាក ល្បងបាន ។

វិធីដែលគេប្រើដើម្បីបង្ហាញពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ជាវិធីសាស្ត្រសន្តិភាព និងប្រកបដោយការពិចារណា ។ ព្រះពុទ្ធបានធ្វើការអំពាវនាវតាមរយៈហេតុផលនិងពិសោធន៍ ។ ពាក្យប្រៀនប្រដៅត្រូវ បានបង្ហាញឡើងក្នុងភាពសាមញ្ញ ច្បាស់លាស់និងទាក់ទាញអារម្មណ៍ ហើយតែងតែនៅដាច់ឆ្ងាយពីភាព ចង្អៀតចង្អល់ខាងសាសនា និងជាតិនិយម ហើយនិង ភាពជ្រុលនិយម ។ ពាក្យប្រៀនប្រដៅទាំងនោះ បានអប់រំ ឱ្យមានមនុស្សភ្លឺស្វាង និងស្រគត់ស្រគំ ។

វិធីសាស្ត្របង្រៀននេះ បានជម្រុះជម្រះសេចក្តីមន្ទិល និងកម្ចាត់ចេញ ជំនឿបែបអធិធម្មជាតិ។ ដូច្នេះ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធធ្វើជាបង្អែក បានចំពោះផ្លូវចិត្តនិងបញ្ញាស្មារតីរបស់អ្នកស្វែងរកសច្ចភាពបានច្រើនជាងគេបំផុត។តិរិយាបថអធ្យាស្រ័យនិងយោគយល់របស់ពុទ្ធសាសនិក បានផ្តល់ទំនុកចិត្តដល់បណ្តាអ្នកប្រាជ្ញ ទស្សនវិទូ អ្នកវិចារណញ្ញាណនិយម អ្នកគិតសេរី ហើយនិងសូម្បីអ្នកអទេវនិយមដ៏ល្បីល្បាញជាច្រើន ក្នុងការលើកតម្កើងព្រះពុទ្ធសាសនាជាមាគ៌ាសន្តិភាពនៃជីវិត។

តាមទស្សនៈរបស់ព្រះពុទ្ធ មនុស្សបានបែងចែកក្នុងចំណោមគ្នាគេ ក៏ព្រោះតែអត្តទត្តភាពដ៏មុតមាំរបស់គេ។ ពេលណាដែលអត្តទត្តភាពនោះត្រូវបង្ក្រាបបាន ទំនាក់ទំនងល្អរវាងមនុស្សនិងមនុស្សនឹងអភិវឌ្ឍឡើង។ ដូច្នេះការស្វែងរក សន្តិភាពនិងមាគ៌ាសុខដុមនៃជីវិតចាប់ផ្តើមពីភាពខាងក្នុង ពោលគឺមិនមែនពីភាពខាងក្រៅទេ។

ប្រសិនបើសាសនិកបច្ចុប្បន្នទាំងឡាយ មិនអាចធ្វើការជាមួយគ្នាក្នុងភាពសុខដុម ដោយគ្មានការរើសអើង ឬការអរិចិត្តរវាងគ្នានិងគ្នាទេ សន្តិភាពដែលយើងនិយាយដល់នោះ នឹងស្ថិតនៅតែក្នុងការយល់សប្តិប៉ុណ្ណោះ។

ក្នុងនាមជាសហសាសនិកដ៏ពិតប្រាកដនិងមានភាពជិតស្និទ្ធ យើងត្រូវរួមដៃគ្នាពង្រឹងការប្រឹងប្រែង របស់យើង ដើម្បីលុបបំបាត់អ្វីៗទាំងអស់ដែលជាការផ្ទុយគ្នា និងរើសអើងគ្នានៅក្នុងពាក្យប្រៀនប្រដៅរបស់ យើងហើយខិតខំឱ្យអស់ពី សមត្ថភាពក្នុងការបង្ហាញតម្លៃ ខាងស្មារតីដែលមានលក្ខណៈរួមនៅក្នុងសាសនារបស់យើងរៀងៗខ្លួនដើម្បីសេចក្តីល្អ និងសុខុមាលភាពរបស់មនុស្សជាតិទាំងអស់ ដោយមិនគិតពីជាតិសាសន៍ និងជំនឿសាសនា។ យើងទាំងអស់គ្នាគួរចងចាំថា សាសនាកើតមានឡើងដើម្បីសេចក្តីល្អរបស់មនុស្សជាតិ ហើយសាសនាមិនគួរត្រូវគេប្រើមិនត្រឹមត្រូវដោយជ្រុលនិយម តាមរបៀបណាមួយ ដើម្បីផលប្រយោជន៍ឬកិត្តិស័ព្ទផ្ទាល់ខ្លួនរបស់បុគ្គលណាមួយឡើយ។

**ការរួបរួមគ្នា** (Unite Together)

សូមសាសនិកទាំងអស់រួបរួមគ្នាមិនប្រើប្រាស់យោធានិយមខាងសាសនា។ សូមឱ្យ ពួកគេរួបរួមគ្នា បញ្ឈប់អំពើឃោរឃៅនិងអំពើមនុស្សឃាតទាំងអស់ក្នុងនាមនៃសង្គ្រាម។ សូមឱ្យពួកគេរួបរួមគ្នាដើម្បីផ្តល់ សេរីភាពដល់មនុស្សក្នុង ការស្វែងរកសាសនាមួយសមស្របតាមជំនឿរបស់គេផ្ទាល់។ សូមឱ្យពួកគេរួបរួមគ្នា ដើម្បីបញ្ចប់ការផ្តាច់មុខខាងសាសនា។ សូមឱ្យ

ពួកគេរួបរួមគ្នាមិនប្រើប្រាស់សាសនាក្នុងទីផ្សារដើម្បីញ៉ាំងឱ្យ អ្នកដទៃផ្លាស់សាសនាដោយការរក្សាវិធីសាស្ត្រចោទសំណួរ។ សូមឱ្យពួកគេរួបរួមគ្នាដើម្បីគោរពជំនឿសាសនានិងការប្រតិបត្តិរបស់អ្នកដទៃជារៀងរហូត ដរាបណាជំ នឿសាសនានិងការប្រតិបត្តិនេះ មិនបំផ្លិចបំផ្លាញ និងដឹកនាំសាធារណជនទៅរកផ្លូវខុស។ សូមឱ្យពួកគេរួបរួមគ្នាដើម្បី ជម្រុះជម្រះឥរិយាបថប្រកួតប្រជែងនៃការប្រឡងប្រជែងសាសនាដ៏អាម៉ាស់។ សូមសាសនិកទាំងអស់រួបរួមគ្នាដើម្បីលុបបំបាត់គុណវិបត្តិនិងការ ប្រតិបត្តិខុសឆ្គងផ្សេងៗដែលមានជាទូទៅនៅក្នុងសង្គម ទំនើបរបស់យើង។ សូមឱ្យពួកគេរួបរួមគ្នាផងដែរ ដើម្បីបង្ហាញមាគ៌ារស់នៅសមរម្យក្នុង ចំណោមសាវ័ករបស់ពួកគេ និងទូន្មានពួកគេកុំឱ្យធ្វើដំណើរទៅរកភាពជ្រុលនិយម។

បណ្ដាអ្នកបង្កើតសាសនានីមួយៗ មានគោលបំណងជាមូលដ្ឋានរបស់ពួកគេគឺ ឯកភាពរបស់មនុស្ស ជាតិ ដើម្បីរក្សា ភាពសុខដុមរមនា សុឆន្ទៈ និងការយោគយល់គ្នា ក្នុងចំណោមមនុស្សទាំងអស់ក្នុងពិភព លោក។

នៅជំហានជាបន្តបន្ទាប់របស់ពួកគេ អ្នកដឹកនាំសាសនាទាំងឡាយក៏បានស្វែងរកផង ដែរនូវការជំរុញ ការគោរពដ៏ជ្រាលជ្រៅ ចំពោះជំនឿរបស់អ្នកដទៃ។ ជាសំណាងមិនល្អ ទោះជាយ៉ាងណាក៏ដោយបរិស័ទមួយចំនួននៃសាសនានីមួយៗ ដើម្បីមូលហេតុអាត្មានិយមផ្ទាល់ខ្លួនរបស់ពួកគេនិងដោយហេតុតែការមិន អធ្យាស្រ័យនិងចិត្តចង្អៀតចង្អល់ បានប្រឆាំង នឹងសារជាតិពិតរបស់សាសនា ហើយបានបង្កើតភាពចលាចល ការយល់ខុស ការរើសអើង និងការមិនអធ្យាស្រ័យ។

យើងសង្ឃឹមដោយស្មោះអស់ពីចិត្តថា តាមរយៈការជ្រួតជ្រាបការពិតទាំងនេះ ថ្ងៃណាមួយមនុស្សជាតិនឹងរួបរួមគ្នាជាបងប្អូនខាងសាសនាដើម្បី ធ្វើការងារជាប្រយោជន៍ដល់សុខុមាលភាពមនុស្សជាតិ។

នៅក្នុងការវិភាគចុងក្រោយ ការគោរពសាសនារបស់អ្នកដទៃ ផុសចេញពីទំនុកចិត្តដែលមនុស្សម្នាក់ មាននៅក្នុង កម្លាំងខាងក្នុងនៃសានារបស់គេផ្ទាល់។

### ៩-ភាពសុខដុមនៃសាសនា

(Religious Harmony) Mr. Teh Thean Choo

នៅក្នុងការភ្ញាក់រឭកអំពីផលប្រយោជន៍ថ្មីក្នុងសាសនា ដែលបានកើតឡើងនៅផ្នែកជាច្រើននៃពិភពលោកគេមាន ការយល់ស្របគ្នាថាមូលដ្ឋានគ្រឹះនៃសាសនា គឺជំនឿទៅលើព្រះពោលគឺជាជំនឿមួយដែលអាចផ្ដល់ប្រយោជន៍ ក្នុងការបម្រើគោលដៅនៃភាពសុខដុមនៃសង្គម

និងវប្បធម៌ នៅក្នុងសង្គមពហុសាសនា។ យើងម្នាក់ៗដែលជាសមាជិករបស់និកាយ សាសនាពិសេសណាមួយមានគោលគំនិតនិងជំនឿផ្ទាល់របស់ខ្លួនលើប្រធានបទដ៏ស្មុគស្មាញនេះ។ ដោយការមើលត្រួសៗតាមវចនានុក្រម ខ្ញុំរកឃើញការពណ៌នាអំពីព្រះថាជា អាទិទេពខ្ពង់ខ្ពស់បំផុតដែលកើតមានដោយខ្លួនឯងជាទេវភាព ។ ការពណ៌នានេះត្រូវបានទទួលការយល់ស្របដោយពេញចិត្តពីសំណាក់សាសនាធំៗក្នុងពិភពលោក។ ពុទ្ធសាសនិកទាំងឡាយគោរពសហសាសនិកដទៃទៀត តាមគោលការណ៍និងជំនឿសាសនារបស់ពួកគេ។ ព្រះពុទ្ធសាសនា ដែលជាសាសនាមានចរិតអធ្យាស្រ័យច្រើនជាងគេបំផុត បានដាស់តឿនបរិស័ទកុំឱ្យប្រមាថមើលងាយជំនឿនិងការប្រតិបត្តិសាសនារបស់អ្នកដែលមានជំនឿផ្សេង។

ថ្វីត្បិតព្រះពុទ្ធសាសនាមិនយល់ស្រប នឹងសញ្ញាណទូទៅអំពីព្រះអ្នកបង្កើតពិភពលោកក៏ដោយក៏ព្រះពុទ្ធសាសនា នៅតែបង្រៀនថាព្រះអាទិទេព និងទេវៈទាំងនោះជាភាវៈល្អឥតខ្ចោះរស់នៅក្នុងភពជាក់លាក់មួយដែលកើតមានដោយឯងៗនៅក្នុងចក្រវាឡ ហើយភាវៈបែបនោះអាចធ្វើអ្វីៗ ដែលមានឥទ្ធិពល ដល់មនុស្សជាតិលើផែនដីនេះ ទៅតាមសកម្ម ភាពលោកិយរបស់ពួកលោក។ ពុទ្ធសាសនិកទាំងឡាយមិន បានទទួលការបង្រៀនឱ្យស្វែងរកជំនួយពីខាងក្រៅឬបែបផែននៃការបំពេញបន្ថែមពីសំណាក់ព្រះអាទិទេពឬទេវៈទាំងនោះដើម្បីការសង្គ្រោះខ្លួននោះឡើយ។ ព្រះពុទ្ធសាសនាទ្រទ្រង់ដំណើរជម្រះផ្លូវចិត្ត នៅកម្រិតស្មារតីតាម រយៈការបំពេញការងារដោយមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន និងការឧទ្ទិសតាមរយៈការប្រឹងប្រែងរបស់ខ្លួនក្នុងការប្រតិបត្តិសីលសមាធិនិងបញ្ញា។

ក្នុងបរិបទនេះ នៅក្នុងសង្គមពហុសាសនានិងពហុជាតិសាសន៍ បណ្តាបរិស័ទពុទ្ធសាសនិករបស់យើងដោយធ្វើការងារយ៉ាងជិតស្និទ្ធជាមួយនឹងសហសាសនិកដទៃទៀត ដោយតស៊ូដើម្បីសន្តិភាពនិងភាពសុខដុមនៃប្រទេសរបស់យើងអាច មិនបដិសេធចំពោះអ្វីក៏ដោយ ដែលមានចំពោះបណ្តាអ្នកជឿជំនឿដទៃទៀត ក្នុងគោលគំនិតនៃប្រធានបទ"ជំនឿលើព្រះ"ពោលគឺត្រូវទទួលស្គាល់ថាជំនឿនិងគោលគំនិតប្រភេទនេះ ជួយបង្កើតស្មារតីនៃការយល់ដឹងខាងសាសនាដែលនឹងបង្ហាត់ បុគ្គលសង្គម និងសហគមន៍ឱ្យមានសញ្ចេតនា មេត្តាករុណាចំពោះគ្នានិងគ្នា និងបង្កើតបានស្មារតីអធ្យាស្រ័យ និងយោគយល់ ទើបអុជចន្លុះភ្លើងដែល មិនមែនជា ភ្លើងគំនុំគំគួន និងរើសអើង ប៉ុន្តែជាចន្លុះភ្លើងសន្តិភាពនិងភាពសុខដុមសម្រាប់ មនុស្សជាតិ ទាំងអស់និងគ្រប់ពេលវេលា។

**មិនមែនដោយការប្រកួតប្រជែងទេប៉ុន្តែដោយការឯកភាព** (Not in Rivealry but in Uniy)

សាសនាទាំងអស់កើតមានឡើងដើម្បីសេចក្ដីល្អរបស់មនុស្សជាតិ។ សាសនាទាំងអស់ បង្រៀន និងដាស់តឿនមនុស្សជាតិ ឱ្យរស់នៅនិងកាន់មារយាទជាមនុស្សសមរម្យ។ ជាការចាំបាច់ សាសនិកទាំងអស់គួរពិចារណាលើការទទួលយកសហប្រតិបត្តិការ និងការយោគយល់ទាំងអស់គ្នា មិនមែនដោយការប្រកួតប្រជែងទេ ប៉ុន្តែដោយការឯកភាព ដើម្បីធ្វើ ឱ្យមនុស្សជ្រួតជ្រាបនិងអបអរគុណតម្លៃនៃវិស័យស្មាតីរបស់ជីវិតគុណតម្លៃនៃការបូជា និងគោលការណ៍មូលដ្ឋាននៃសាសនា ដូចជាឧត្ដមគតិនៃសច្ចភាព យុត្តិធម៌ការបម្រើដើម្បីឧទ្ទិសសេចក្ដី មេត្តាករុណា សប្បុរសធម៌ដោយមេត្តា និងសុឆន្ទៈចំពោះមនុស្សជាតិ។ គោលគំនិត និងគោលការណ៍ទាំងនោះមានចរិតសាកល និងអាចទទួលយកបានជាទូទៅ ចំពោះសាសនិកទាំងអស់។

**សេរីភាពនៃការគោរពបូជា** (Freedom of Worship)

ថ្វីត្បិតតែឥស្លាមជាសាសនាផ្លូវការរបស់ប្រទេសម៉ាឡេស៊ី តែសេរីភាពនៃការគោរពបូជា និងជំនឿសាសនាត្រូវបានគេ ដាក់តម្កល់នៅក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសរបស់យើង។ យើងបានទទួលការអនុញ្ញាតឱ្យ ធ្វើជាអ្នកគិតដោយសេរី ឬឱ្យដើរ តាមនិកាយសាសនាណាមួយ។ យើងមិនត្រូវបានគេបង្ខំឱ្យធ្វើតាមបញ្ញត្តិនូវខមាត្រាណាមួយនៃសក្ការៈឬជំនឿសាសនាឡើយ ។យើងស្រឡាញ់សេរីភាពនេះជាទីបំផុត។ គេត្រូវតែសង្ឃឹមថា សេរីភាពរបស់យើងនេះនឹងនៅខ្ជាប់ខ្ជួនហើយមាន និរន្តរភាពគ្រប់ពេលវេលា ហើយនឹងគ្មានទទួល ការរារាំងឬបំផ្លាញដោយបណ្ដាចលនានៃនិកាយឬអង្គការសាសនាណាមួយឡើយ។ លទ្ធិជ្រុលនិយមក្នុងទម្រង់ណាមួយ ឬមកពីបញ្ហាការដ្ឋានណាមួយ គឺជាសត្រូវចំពោះសន្តិភាព និងភាពសុខ ដុមនៅក្នុងសង្គមណាមួយ។

យើងទាំងអស់គ្នានៅតែបន្តស្វែងរកសន្តិភាពនិងភាពសុខដុម ។យើងចង់បានសន្តិភាពនិងភាពសុខ ដុមដើម្បីគ្រួ សាររបស់យើង។ យើងចង់បានសន្តិភាពនិងភាពសុខដុមនៅក្នុងសង្គម។ យើងមិនចង់បានការ ប៉ះទង្គិចសាសនា ហើយ យើងក៏មិនយល់ព្រមនឹងទំនាស់ពូជសាសន៍ដែរ។ យើងចង់រស់និងឱ្យគេរស់។ ដើម្បីសម្រេចបានបំណងប្រាថ្នាទាំងនេះយើង ត្រូវទ្រទ្រង់អ្វីទាំងអស់ដែលមានសីលធម៌។ យើងត្រូវប្រតិបត្តិខន្តី អធ្យាស្រ័យ និងការយោគយល់។ យើងត្រូវធ្វើជាមិត្ត នឹងគ្នាដោយជួយគ្នានៅទីណា និងនៅពេលណាដែលមានការចាំបាច់។ យើងត្រូវជម្រះចោលការរើសអើងពូជសាសន៍ និង សាសនា។ យើងត្រូវរាប់អានគ្នា ទៅវិញទៅមកជាបងប្អូនក្នុងគ្រួសារដ៏រីករាយតែមួយ និងក្នុងនាមជាពលរដ្ឋគោរពច្បាប់ ទាំងអស់គ្នា ដោយ

តស៊ូដើម្បីសន្តិភាពនិងភាពសុខដុម ដោយមិនគិតពូជសាសន៍ឬជំនឿ ។ នេះគឺជាដំណោះស្រាយរបស់ សហសាសនិកទាំងអស់ ក្នុងសង្គមពហុសាសនា។

**ត្រូវចេះគិត** (Be Considerate)

នៅពេលឱ្យតម្លៃការពិតថា នៅក្នុងប្រទេសនេះយើងមានអភ័យឯកសិទ្ធិក្នុងការប្រតិបត្តិពិធី ទំនៀមទម្លាប់សាសនាដោយគ្មានឧបសគ្គ ការរស់នៅក្នុងសង្គមពហុជាតិសាសន៍ និងពហុសាសនាមានន័យថា យើងត្រូវព្យាយាមគិតដល់អ្នក ដទៃគ្រប់ពេលវេលានៅពេលយើងធ្វើអ្វីមួយ ។ យើងមិនត្រូវបំភ្លេចអារម្មណ៍របស់ អ្នកជិតខាងយើង ដែលជាបរិស័ទទាំងឡាយនៃនិកាយសាសនាដទៃ ហើយដែលអាចមិនអបអរនឹងបណ្តា ពិធីទំនៀមទម្លាប់ដែលខុសប្លែកអំពីពិធីរបស់គេ។ យើងត្រូវតែគិតដល់អ្នកដទៃ។ យើងមិនត្រូវមានចរិត អាត្មានិយម និងគិតតែអំពីខ្លួនឯងនិងតម្រូវការរបស់ខ្លួនឯងតែប៉ុណ្ណោះទេ។ ពីព្រោះតែឱកាសពិសេសឬព្រឹត្តិហេតុណាមួយកើតមានឡើងក្នុងផ្ទះរបស់យើងមានទុក្ខព្រួយក្តី ឬមិនមានក្តី យើងចង់ធ្វើពិធីទំនៀមទម្លាប់ប្រពៃណីសាសនាស្របតាមវប្បធម៌ប្រពៃណីរបស់យើងយើងត្រូវប្រកាន់ភាពគួរសមនិងចេះគិតដល់ អ្នកដទៃ ដោយមិនធ្វើអ្វីដែលហួសហេតុ ហើយបង្កការលំបាក និងការធុញទ្រាន់ដល់អ្នកជិតខាងរបស់យើង។ ទោះធ្វើពិធីសាសនាអ្វីក៏ដោយ ពិធីទាំងនោះត្រូវធ្វើឡើង ដោយមានកម្រិតច្បាស់លាស់ និងស្ថិតនៅក្នុងទីកំណត់ នៃផ្ទះរបស់យើងដោយគ្មានបង្កការរំខានមិនសមហេតុផលចំពោះសន្តិភាពនិងភាពស្ងប់ស្ងៀមរបស់អ្នកជិតខាងយើង។ ប្រសិនបើយើងនៅតែអះអាងលើសិទ្ធិក្នុងការ ធ្វើពិធីទំនៀមទម្លាប់ប្រពៃណីសាសនារបស់យើងតាមបែបគម្ពីរនិយម តាមរបៀបអ្វីអរទទើសទទែង ឬរំខានដល់អ្នកដទៃ ដោយគ្មានក្រែង ចិត្តអ្នកជិតខាងរបស់យើងយើងនឹងប្រាកដក្លាយជាអ្នកបង្ករឿងក្នុងទីជុំវិញខ្លួនដែលមានពហុសាសនា។ ការគិតគូរអំពីសុខុមាលភាពរបស់អ្នកដទៃសូម្បី នៅក្នុងកាលៈទេសៈដ៏លំបាកឬគួរឱ្យធុញថប់ក៏ដោយ គឺជាគន្លឹះនៃការរស់នៅក្នុងសន្តិភាព និងភាពសុខដុមក្នុងសង្គមពហុសាសនា។

**ប្រវត្តិរួមគ្នាជាសាកល** (Universal Common Ground)

តាមការពិត យើងមានភាពផ្សេងៗគ្នាក្នុងគោលគំនិតនិងជំនឿដោយឡែកៗរបស់យើង ប៉ុន្តែទោះជាយ៉ាងណាក្តី យើងមានប្រវត្តិរួមគ្នាជាសាកល ក្នុងការលុបបំបាត់អំពើអាក្រក់ ការពង្រីកអំពើល្អរវាងមនុស្សនិងមនុស្ស ការស្វែងរកសន្តិភាពការរំដោះរួចចាកទុក្ខ និងមានបរមសុខគ្មានទីបំផុត។ ទាំងនេះជាគោលបំណងរួមនៃសាសនាទាំងអស់។ គោលការណ៍ខាងក្នុងជា

ច្រើនដែលត្រូវតម្កល់ក្នុងសាសនាផ្សេង១ ក៏មានចរិតស្រដៀង១គ្នា។ ដើម្បីបានសម្រេចការឯកភាពចាំ បាច់ត្រូវអ្នកសាសនាទាំងអស់ជម្រះចោលនូវភាពលាក់លៀម នៃអាត្មានិយម និងការតម្កើងឫក ហើយពិគ្រោះពិភាក្សាគ្នា ក្នុងស្មារតីអធ្យាស្រ័យ ខន្តីនិងយោគយល់គ្នាទៅវិញទៅមក។ ការគោរពជំនឿសាសនារបស់អ្នកដទៃជាភារកិច្ចរបស់យើងពោលគឺយើងមានជំនឿថាការ អធ្យាស្រ័យខាងសាសនា មានសារៈសំខាន់និងការចាំបាច់បំផុតចំពោះជីវភាពរស់នៅ ។

**សារៈនៃភាពស្រដៀងគ្នា** (Essence of Similarities)

ជំនួសឱ្យការបន្ទាបបន្ថោក និងការពណ៌នាភាពខុសគ្នាមួយចំនួន តាមរបៀបមួយគួរអាម៉ាសការសម្រេចជោគជ័យ ដ៏អស្ចារ្យនឹងកើតមានឡើង ប្រសិនបើអ្នកដឹកនាំសាសនា របស់យើងនិងបរិស័ទទាំងអស់ធ្វើការសិក្សាអំពីជំនឿ និងការប្រតិបត្តិរបស់សាសនាទាំងអស់ហើយពណ៌នាអំពីសារៈនៃភាពស្រដៀងគ្នា នៅក្នុងអ្វីដែលល្អទាំងអស់ និងសមគួរដល់ការ ប្រើប្រាស់ចំពោះអ្នកសាសនាទាំងអស់គ្នា។ ខ្ញុំលើកឡើងនូវ ឧទាហរណ៍ជាក់ស្តែងខ្លះនៃភាពស្រដៀងគ្នាដូចខាងក្រោមនេះ :

- សាសនាព្រះពុទ្ធ : ចូរកុំធ្វើទុក្ខទោសដល់អ្នកដទៃ តាមរបៀបដែលអ្នកខ្លួនអ្នកកំពុងទទួល។
- សាសនាតាវ : "ចូរចាត់ទុកការចំណេញរបស់អ្នកជិតខាងអ្នក ជាការចំណេញរបស់អ្នកផ្ទាល់ ហើយការខាត បង់របស់អ្នក ជិតខាងអ្នក ជាការខាតបង់របស់អ្នកផ្ទាល់"។
-សាសនាគ្រីស្ត : "អ្វី១ទាំងអស់ដែលអ្នកចង់ឱ្យគេធ្វើមកលើអ្នក ចូរអ្នកធ្វើអំពើដូចគ្នានោះ ចំពោះពួកគេ"។
-សាសនាឥស្លាម : "ចូរប្រព្រឹត្តចំពោះមនុស្សទាំងអស់ឱ្យដូចចិត្ត ដែលអ្នកចង់ឱ្យគេប្រព្រឹត្តមកលើអ្នកហើយវៀរចាកចំពោះអ្នកដទៃនូវអ្វីដែលអ្នកចង់ឱ្យគេវៀរចាកចំពោះខ្លួនអ្នក"។
- សាសនាហិណ្ឌូ : "សូមកុំឱ្យនរណាម្នាក់ប្រព្រឹត្តចំពោះអ្នកដទៃនូវអ្វីដែលគេមិនចង់ឱ្យអ្នកដទៃប្រព្រឹត្តមកលើ ខ្លួន"។

**ផ្តល់កិត្តិយសដល់អ្នកបង្កើតសាសនា** (Honor the Founders)

ក្នុងនាមជាពុទ្ធសាសនិក យើងបានទទួលការអប់រំឱ្យគោរពនិងផ្តល់កិត្តិយស ដល់បណ្តាអ្នកបង្កើត សាសនានិងគ្រូសាសនាទាំងឡាយនៃនិកាយសាសនាដទៃ ហើយនិងការប្រៀន

ប្រដៅរបស់ពួកលោក។ យើងទទួលស្គាល់ថា គ្រូបង្រៀនសាសនាទាំងអស់បានឧទ្ទិសជីវិតរបស់ពួកលោកដើម្បីជាប្រយោជន៍ដល់សុខ សុវត្ថិភាព និងសុខុមាលភាពរបស់មនុស្សជាតិ។ លោកទាំងនោះ សមគួរនឹងទទួលនូវការគោរពនិងកិត្តិយស ចំពោះការបម្រើ និងការលះបង់ដោយមិនគិតពីខ្លួនឯងរបស់ពួកលោកដើម្បីសេចក្តីល្អរបស់មនុស្សជាតិ។ នេះជាវិស័យដ៏សំខាន់មួយទៀតនៃការអធ្យាស្រ័យខាងសាសនា ដែលធ្វើគំរូ ដោយពុទ្ធសាសនិកទាំងឡាយ។ យើងមានជំនឿដ៏មុតមាំថា ការអធ្យាស្រ័យ ជាពិសេសការអធ្យាស្រ័យខាងសាសនា គឺ ជាគុណធម៌មួយដែលយើង គ្រប់រូបត្រូវបណ្តុះក្នុងចិត្តទុកជាមាគ៌ានៃជីវិត។ គឺដូចគ្នានឹងភាសិតដែលថែងថា ធ្វើល្អទទួលផលល្អសម្តែងការគោរពទទួលការគោរពសម្តែងការអធ្យាស្រ័យទទួលការអធ្យាស្រ័យ។

**ការអធ្យាស្រ័យខាងសាសនា** (Religious Tolerance)

បើគ្មានការអធ្យាស្រ័យ យើងនឹងត្រឡប់ទៅរកច្បាប់ព្រៃ ជាទីដែលភាពចលាចលកើតមានឡើងនិងជាទីដែលការប្រើកម្លាំងគឺត្រឹមត្រូវ។ នេះមិនមែនដើម្បីសេចក្តីល្អនៃសង្គម យើងទេ។ នេះមិនមែនជាអ្វី ដែលសង្គមយើងចង់បាននោះទេ។ យើងទាំងអស់គ្នាមិនថា មានពូជសាសន៍អ្វីឬមានជំនឿអ្វី ចង់រស់នៅក្នុងសន្តិភាព និងភាពសុខដុមរមនា។ យើងចង់រស់ នៅជាមួយគ្នា ដើម្បីសេចក្តីល្អចំពោះគ្នានិងគ្នា។ ដូច្នេះហើយ ភារៈរបស់យើងគឺមិនត្រឹមតែទេសនាអំពីអធ្យាស្រ័យប៉ុណ្ណោះទេ ប៉ុន្តែយើងត្រូវអនុវត្តអធ្យាស្រ័យថែមទៀតជាពិសេសអធ្យាស្រ័យខាងសាសនា។ យើងមានមោទនភាព និងសេចក្តីរីករាយក្នុងការកត់សំគាល់បានថា ការគិតគូរពីប្រទេសជាតិកាន់តែច្រើន ការអធ្យាស្រ័យខាងសាសនាក៏ត្រូវអនុវត្តនិងទ្រទ្រង់ដោយ បណ្តាសាស និករបស់យើងកាន់តែខ្ពស់។ ភ្ញៀវមកកាន់ប្រទេសយើងជាច្រើន បានកត់សំគាល់ថាដោយមានវត្តមានដ៏គួរ រំភើបរីករាយនៃព្រះវិហារសាសនាឥស្លាម ព្រះវិហារ សាសនាគ្រឹស្តដែលមានទីតាំងនៅជិតៗគ្នាក្នុងទីក្រុងទាំងឡាយ នៃប្រទេសម៉ាឡេស៊ីប្រកបព្រមដោយចលនាចេញចូលទៅទីសក្ការៈបូជារបស់បរិស័ទនៃនិកាយ សាសនាផ្សេងៗ ដោយគ្មានការរំខានណាមួយឡើយនោះ នោះហើយជាការអធ្យាស្រ័យខាងសាសនា។

សមត្ថកិច្ចពាក់ព័ន្ធ ក៏ចូលរួមយ៉ាងសកម្មក្នុងការលើកកំពស់ភាពសុខដុម នៃអន្តរសាសនាផងដែរដោយធ្វើការឧបត្ថម្ភដ៏ទៀងទាត់កិច្ចប្រជុំរវាងមេដឹកនាំសាសនានៃបណ្តានិកាយសាសនាផ្សេងៗដើម្បីពិភាក្សាអំពីចំណោទបញ្ហាផ្សេងៗដែល កើតមានក្នុងសាសនា និងដើម្បីធានារ៉ាប់រងសុឆន្ទៈ និងការរក្សាបានសន្តិភាព និងមិត្តភាពក្នុងប្រទេស។

**ជំហានភ័ន្តច្រឡំមួយ** (One False Step)

នៅខណៈដែលយើងកំពុងរស់នៅក្នុងសន្តិភាពនិងភាពសុខដុម ពិភពលោកបច្ចុប្បន្នរស់នៅក្នុងការភ័យខ្លាច ការសង្ស័យ និងភាពតានតឹងជាអលជ្ជី។ បញ្ហានេះបណ្តាលមកពីការមានអាវុធប្រល័យលោក ដែលអាចបង្កការបំផ្លិចបំផ្លាញ ហួសពីការស្មាន និងការធ្វើឱ្យវិនាសសូន្យតែក្នុងរយៈប៉ុន្មាននាទីប៉ុណ្ណោះ ។ដោយត្រីកំញើញអាវុធប្រល័យដ៏ចម្លែកទាំងនេះកំពូលអំណាចទាំងឡាយកំពុងតែគំរាមកំហែងនិងប្រឈមមុខ ដាក់គ្នាទៅវិញទៅមក កំពុងតែអួតអាងដោយគ្មាន ការអៀនខ្មាស់ថា ម្នាក់អាចបង្កការវិនាស និងទុគិតភាព បានច្រើនជាងម្នាក់ទៀត។ ពួកគេបានធ្វើដំណើរតាមមាគ៌ាឆ្គួតវង្វេងរហូតទៅដល់ចំណុចមួយ។ ពេលនេះប្រសិនបើជំហានវង្វេងផ្លូវបោះទៅទិសណាមួយដ៏ប្រាកដនោះលទ្ធផល នឹងមិនមែនអ្វីក្រៅពីការបំផ្លាញសូន្យសុងចំពោះគ្នានិងគ្នាទៅវិញទៅមក រួមជាមួយនឹងការវិនាសហិនហោចតែប៉ុណ្ណោះ ។

**គោលការណ៍ខាងក្នុងសាសនា** (Intrinsic Religious Principles)

មនុស្សជាតិ ដោយភ័យខ្លាចនឹងស្ថានភាពដែលពួកគេបានបង្កើតដោយខ្លួនឯង ពួកគេចង់រកច្រកចេញ និងស្វែងរកទម្រង់ខ្លះនៃដំណោះស្រាយ។ គេពិបាកនឹងរកឃើញដំណោះស្រាយណាស់ លើកលែងតែតាមរយៈសាសនា និងការអភិវឌ្ឍ ផ្លូវចិត្តរបស់មនុស្ស ដោយប្រើប្រាស់គោលការណ៍សាសនាខាងក្នុងដើម្បីប្រឈមមុខនឹងចេតនាអាក្រក់របស់បណ្តាអ្នកល្មោភសង្គ្រាម ។ សាសនិកទាំងអស់ក្នុងពិភពលោកមានចំណែកភារកិច្ចដ៏ សំខាន់ត្រូវបំពេញ។ តួនាទីរបស់សាសនាទាំង ឡាយត្រូវមានលក្ខណៈសហការ និងមិនមែនប្រកួតប្រជែងទេ។ ដិការបស់ព្រះពុទ្ធអំពីអហិង្សានិងសន្តិភាព មេត្តានិងករុណា អធ្យាស្រ័យនិងការយោគយល់ សច្ចភាពនិងបញ្ញា ការគោរពនិងរក្សាជីវិតទាំងអស់ការរួចចាកពីភាពអាត្មានិយម គំនុំគុំគួននិងហិង្សា ដែលត្រូវបានផ្សព្វផ្សាយ អស់រយៈជាង២៥០០ឆ្នាំកន្លងទៅ អាចត្រូវប្រើជាគោលការណ៍គ្រឹះរបស់សហសាសនិកទាំងឡាយដើម្បីបំបាត់ការភ័យខ្លាច ការមន្ទិល និងការតានតឹងដែលដក់ជាប់នៅក្នុងពិភពលោកយើងនេះ។ ដោយបានឃើញ ពន្លឺនៅគ្រប់ទិសទី ដិការបស់ព្រះពុទ្ធមិនអាចត្រូវគេចាត់ថាចង្អៀតចង្អល់និងមានព្រំដែនទេ ផ្ទុយទៅវិញ ដិកា នេះមានចរិតសកលនិងប្រតិបត្តិ។

**ការផ្តល់អាវុធស្មារតីឡើងវិញ** (Spiritual Re-Armament)

ភាពសុខដុមខាងសាសនា និងការផ្តល់អាវុធស្មារតីឡើងវិញ គួរបណ្តុះឡើងជាកម្លាំងស្មារតី ដើម្បីប្រឈមមុខ នឹងភាពឆ្កួតវង្វេងនៃការប្រកួតប្រជែងសព្វាវុធសព្វថ្ងៃនេះដើម្បីការ

វិនាសអន្តរាយទាំងស្រុងរបស់មនុស្សជាតិ។ ដើម្បីបង្កើតសន្តិភាពពិតនិងយូរអង្វែង មាគ៌ានិងមធ្យោបាយទាំងឡាយ ចាំបាច់ត្រូវស្វែងរក ដើម្បីលុបបំបាត់ឫសគល់នៃសង្គ្រាម។ មនុស្សនិងប្រជាជាតិទាំងឡាយ ត្រូវតែជម្រុះចោលចំណង់សួនតួភាព ក្រអឺត ក្រទមនឹងពូជសាសន៍ តណ្ហាអត្តទត្ថបុគ្គលចំពោះអំណាចនិងទ្រព្យសម្បត្តិ។ លោភៈ ទោសៈនិងមោហៈ មិនត្រូវឱ្យមាន។ សម្ភារនិយមតែឯងមិនអាចធានាបានសុភមង្គលពិតប្រាកដបានឡើយ។ សាសនាតែឯងអាចធ្វើឱ្យមានការប្រែប្រួលខាងស្មារតី និងនាំមកនូវការដកអារុធផ្លូវចិត្ត។ នេះហើយជាការដក អារុធពិតប្រាកដ និងជារៀងរហូត។

**យុវជ័យនិងសាសនា** (Youth and Religion)

គេកត់សំគាល់ថា នៅផ្នែកជាច្រើននៃពិភពលោក យុវវ័យកំពុងតែងាកចេញពីសាសនា។ ពួកគេអះអាងថាសាសនាមិនមានសារៈសំខាន់ចំពោះជីវិតប្រចាំថ្ងៃរបស់គេទេហើយថាសាសនាជាបន្ទុកមិនសំខាន់របស់មនុស្សជាតិ។ ពួកគេគិតឃើញថាសាសនាធ្វើឱ្យរាំងស្ទះ ដល់អំណាចការគិតរបស់មនុស្ស។យុវវ័យទាំងនេះដោយពុលនឹងបញ្ញត្តិទំនើបៗនៃសម្ភារនិយម និងទិន្នាការទំនើបនៃការសប្បាយ ពួកគេមានអារម្មណ៍ថា ពួកគេអាចធ្វើអ្វីៗបាន យ៉ាងប្រសើរដោយគ្មានសាសនា។នេះជាសម្តីដ៏សោកសៅអំពីការងារ ដែលពណ៌នាដូចគ្នាអំពីបរាជ័យនៃបណ្តាសាសនាក្នុងពិភពលោកក្នុងការដឹកនាំ និងប្រើឥទ្ធិពលទៅលើយុវវ័យតាមគន្លងនៃការរំដោះខាងផ្លូវស្មារតី។ពេលនេះជាពេលដែលអ្នកដឹកនាំសាសនា ដែលប្រកបដោយទំនួលខុសត្រូវនិងបណ្ឌាបញ្ញវ័ន្តដែលមានស្មារតីខ្ពស់ក្នុងពិភពលោក ត្រូវរួបរួមគ្នាស្រាវជ្រាវរកមូលហេតុ នៃបរាជ័យរបស់បេសកកម្មសាសនារបស់យើងដែលធ្វើឱ្យយុវវ័យងាក ចេញពីបណ្តាគោលការណ៍សាសនាជំនឿនិង បញ្ញត្តិដែលគេគោរព បូជាជាយូរលង់ណាស់មកហើយ។ គេត្រូវប្រឹងប្រែងធ្វើឱ្យមនុស្សជំនាន់ក្រោយមានជំនឿយល់ដឹងនិងឱ្យតម្លៃតួនាទីដ៏សំខាន់ ដែលសាសនានិងការរំដោះនៃសាសនាអាចនិងត្រូវតែបំពេញនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។ សាសនាទាំងអស់មានគោលបំណងរួម គឺត្រូវបម្រើមនុស្សជាតិ និងលើកកំពស់ស្មារតីមនុស្សជាតិ។ សាសនា ទាំងអស់សំដែងអំពីសុឆន្ទៈហើយប្រកាសរកភាតរភាពរបស់មនុស្សជាតិ។ គោលបំណងនិងឧត្តម គតិ រួមទាំងនេះដើម្បីសេចក្តីល្អ របស់មនុស្សជាតិ ត្រូវពុះពារលើអ្វីៗដែលខុសប្លែកពីគ្នាដែល អាចកើតមាននៅក្នុងបណ្តាជំនឿ បញ្ញត្តិ និងការប្រតិបត្តិសាសនាទាំងឡាយ។ ត្រូវតែមានការឯកភាពក្នុងពហុភាព។ យើងមិនត្រូវព្យាយាមសើចចំអកឱ្យមនុស្ស ដែលមានកំទេចធូលីចូលភ្នែក ដោយ

ភ្លេចគិតដល់ភ្លើងបញ្ចាំងដែលកំពុងបាញ់ ចំមកភ្នែករបស់យើងនោះទេ។ សាសនិក ទាំងអស់ត្រូវព្យាយាមរកវេទិការួមមួយហើយរួមគ្នាធ្វើការងារដើម្បីលើកកំពស់ស្មារតីរបស់មនុស្សជាតិ ដើម្បីឱ្យសាសនាអាចរួមវិភាគ ទានក្នុងការកសាងសុក្រឹតភាពនៃធម្មជាតិមនុស្សហើយមនុស្សជាតិដ៏ថ្លៃថ្នូរកសាងសុក្រឹតភាពសាសនា។ សាសនិកទាំងអស់ត្រូវហុចដៃទៅ សាសនិកជាមិត្តភក្តិរបស់គេដោយសញ្ចេតនាបរិសុទ្ធនៃសុឆន្ទៈមិត្តភាពជិតស្និទ្ធនិងភាតរភាព ប្រកបដោយការគោរពដ៏ជ្រាលជ្រៅរវាងគ្នានិងគ្នា រវាងសាសនានិងសាសនាទៅវិញទៅមក ដើម្បីតស៊ូសម្រេចមូលហេតុរួមដ៏ឧត្តុង្គឧត្តមក្នុងការលើកកំពស់ស្មារតីរបស់បុគ្គល ដើម្បីមនុស្ស ជាតិយុត្តិធម៌ និងសន្តិភាព។

**ទស្សនៈអ្នកពិនិត្យ និង កែសម្រួល**

លទ្ធិសាសនាណាក៏សុទ្ធតែមានបំណងឱ្យមនុស្សល្អទាំងអស់ ពិសេសព្រះពុទ្ធសាសនាដែលយើងកំពុងអាននេះ ។ ប៉ុន្តែដើម្បីល្អ ដើម្បីត្រូវមិនមែនជាការងាយទេ ព្រោះអ្វីៗតែងតែប្រែប្រួល តែងតែមិនច្បាស់លាស់ ។ ក្រោមការស្រាវជ្រាវដ៏វែងឆ្ងាយ ប៉ុន្តែការគិតរកត្រូវនៅតែមានកម្រិតជានិច្ច ។ និយាយបែបនេះមិនមែនអស់សង្ឃឹមទេ គឺសង្ឃឹមជានិច្ចថានឹងរកឃើញ ប៉ុន្តែការរកឃើញនោះបានត្រឹមតែការខកចិត្ត ។

ហេតុនេះហើយទើបជាឱកាសឱ្យមនុស្សទាំងឡាយលើលោក ពិសេសក្រុមអ្នកនិពន្ធ អ្នកស្រាវជ្រាវ អ្នកច្បាប់ អ្នក នយោបាយ អ្នកសេដ្ឋកិច្ចវិទូ សង្គមវិទូ ប្រវត្តិវិទូ បូរាណវិទូ សាសនវិទូ កវីវិទូ ។ល។ចេះតែខិតខំបកស្រាយពន្យល់ ឥតឈប់ឈរដើម្បីបំពេញនូវការខកចិត្ត របស់មនុស្សជាតិ។ ប៉ុន្តែពេលណាក៏មិនងាយដែរគ្រាន់តែទៅជិតការពិតៗនោះ គេចបាច់ចោលយើង គឺយើងគ្រាន់តែទទួលបានមួយខណៈៗដើម្បីរក្សាជីវិតដល់ទីបំផុតតែប៉ុណ្ណោះ ។

**សន្និដ្ឋាន** ៖ តើពុទ្ធសាសនាឋិតនៅក្នុងឋានៈជាប្រព័ន្ធប្រតិបត្តិសាសនាមួយយ៉ាង ដូចម្តេច? ព្រះពុទ្ធទ្រង់ជាបរមសាស្ត្រាចារ្យ និងជាវេជ្ជបណ្ឌិតដ៏មានប្រសិទ្ធភាព ។ ព្រះអង្គបានរំលឹកសាវ័កទាំងឡាយរបស់ព្រះអង្គជាប្រចាំថា ព្រះបំណងតែមួយគត់របស់ព្រះអង្គ គឺដើម្បីប្រៀនប្រដៅមនុស្សថា តើសេចក្តីយល់ដឹងនូវសារជាតិនៃទុក្ខ ឬសេចក្តីទោមនស្សយ៉ាងដូចម្តេច? ហើយការលុបបំបាត់ សេចក្តីទុក្ខទោមនស្សនោះយ៉ាងដូចម្តេច ? ព្រះអង្គបានសន្យាផ្តល់សេចក្តីសុខនៅក្នុងជីវិតនេះផ្ទាល់ សម្រាប់មនុស្សទាំងឡាយណា ដែលប្រតិបត្តិតាមវិធីដ៏ប្រសើររបស់ព្រះអង្គដោយសេចក្តីប្តេជ្ញាចិត្តខ្ពស់និងសម្មាទិដ្ឋិគឺសេចក្តីយល់ដឹងត្រូវ ។អ្នកជឿទាំងឡាយរបស់

សាសនាមួយចំនួនមិនត្រូវបានគេលើកទឹកចិត្ត ឱ្យគោរពអ្នកដឹកនាំទាំងឡាយរបស់សាសនាមួយផ្សេងទេ។ អ្នកជឿទាំងនោះត្រូវបានគេព្រមានថា បើពួកគេធ្វើដូច្នោះ (គឺគោរពអ្នកដឹកនាំសាសនាផ្សេង) ពួកគេមុខជា ប្រព្រឹត្តអំពើបាបហើយអាក្រក់បំផុត គឺពួកគេនឹងត្រូវធ្លាក់នរកដោយសារបាបកម្មនេះ។ ព្រះពុទ្ធទ្រង់បានទូន្មានយើងយ៉ាងច្បាស់ថា យើងត្រូវគោរពអ្នកទាំងឡាយណាដែលស័ក្តិសមទទួលសេចក្តីគោរព។ ទោះបីយើងមិនយល់ស្របជាមួយទស្សនវិស័យសាសនាខ្លះៗដែលពួកគេបានប្រកាន់ក៏ដោយប្រសិនបើពួកគេមានសេចក្តីស្មោះត្រង់ក្នុងសេចក្តីព្យាយាមរបស់ពួកគេ ដើម្បីបម្រើមនុស្សជាតិហើយលើកស្ទួយមនុស្សជាតិ យើងត្រូវគោរពពួកគេចំពោះសកម្មភាពនោះ នឹងមានមនុស្សល្អប្រសើរច្រើននៅក្នុងសាសនានីមួយៗ។ ព្រះពុទ្ធមិនធ្លាប់ទូន្មានឱ្យសាវ័ករបស់ព្រះអង្គចេញទៅអូសទាញឱ្យប្តូរជំនឿសាសនានូវមនុស្សទាំងឡាយដែលនឹង ត្រូវធ្លាក់នរក ដោយសារការប្តូរជំនឿសាសនានោះទេ។ ជាជំនួសវិញ ព្រះអង្គបានទូន្មានសាវ័កទាំងឡាយនោះ ឱ្យបង្ហាញដល់ពិភពលោកនូវអ្វីដែលត្រូវ និងអ្វីដែលខុសហើយឱ្យប្រព្រឹត្តល្អ ឱ្យធ្វើអំពើល្អ ឱ្យលើកទឹកចិត្តមនុស្សទាំងឡាយ ឱ្យចូលមកមើល ឃើញច្បាស់ដោយខ្លួនឯងនូវសច្ចធម៌ដែលព្រះអង្គបានប្រៀនប្រដៅ ។ ព្រះអង្គនិងសាវ័កទាំងឡាយរបស់ព្រះអង្គមិនផ្តន្ទា ទោសអ្នកប្រតិបត្តិតាម សាសនាដទៃថាជា "មនុស្សមានបាប" ដែលត្រូវរងទុក្ខអស់ពេលជាអនន្តក្នុងនរកនោះទេ។ អនុលោមតាមពុទ្ធសាសនិកជន សូម្បីអ្នកទាំងឡាយណាដែលមិនកាន់ "សាសនា" ណាមួយសោះ ប៉ុន្តែដែលចេះរស់នៅក្នុងសេចក្តីថ្លៃថ្នូរប្រកប ដោយមេត្តានិងសុឆន្ទៈអាចទៅកាន់ឋានសួគ៌បានគឺទទួលសោយ សេចក្តីសុខ ។ កាលណាយើងមានសេចក្តីសប្បាយ និងមានចិត្តរីករាយ យើងឋិតនៅក្នុង "ឋានសួគ៌" ។ កាលណា យើងរង ទុក្ខតាមផ្លូវកាយឬតាមផ្លូវចិត្ត យើងឋិតនៅក្នុង "ឋាននរក"។ ប៉ុន្តែក៏ពុទ្ធសាសនិកជាច្រើនភ័ន្តច្រឡំដែរចំពោះបញ្ហានេះ ។ ព្រះពុទ្ធសាសនា គឺជាសាសនាតែមួយគត់ ពីព្រោះយើងអាចនិយាយអំពី "សាសនា" នេះដោយមិនចាំបាច់និយាយទាក់ទងដល់ឋានសួគ៌ឬឋាននរកក៏បាន។ ខ្ញុំមានជំនឿថាអ្នកឯទៀតៗមិនអាចនិយាយអំពីសាសនាក្នុងបែបបទនេះបានទេ ។

ព្រះរាជសារស្តីពីសុឆន្ទៈ និងសេចក្តីយល់ដឹងរបស់ព្រះពុទ្ធផ្ញើជូនចំពោះមនុស្សទាំងអស់គឺជាសារសកល ។ ពិភពលោកសព្វថ្ងៃ ត្រូវការសារដ៏ប្រសើរនេះជាងពេលណាៗ ទាំងអស់នៅក្នុងប្រវត្តិ សាស្ត្ររបស់មនុស្សជាតិ ។ ព្រះពុទ្ធសាសនា ក្នុងឋានៈជាសាសនាមួយ គឺជាសេចក្តី

ពន្យល់បកស្រាយតែ មួយគត់ឱ្យងាយយល់នូវបរមត្ថសច្ចៈ ដែលប្រប់ដល់មនុស្សថា តើត្រូវចេះរស់នៅក្នុងសន្តិភាព និងសុខដុមភាពជាមួយមនុស្សផងគ្នាយ៉ាងដូចម្តេច ? ។

មិត្តភាពមនុស្សពិតប្រាកដគឺស្ថិតនៅលើសេចក្តីស្រឡាញ់របស់មនុស្សជាមូលដ្ឋានដោយមិន គិតពីតួនាទីរបស់អ្នក ។ ហេតុដូច្នេះ អ្នកកាន់តែបង្ហាញពីការខ្វល់ខ្វាយពីសុខមាលភាព និងសិទ្ធិនៃអ្នកដទៃអ្នកក៏កាន់តែជាមិត្តពិតប្រាកដ។ អ្នកកាន់តែ បង្ហាញភាពទូលំទូលាយនិងស្មោះត្រង់នោះនៅចុងបញ្ចប់អ្នកកាន់តែទទួលបានផលប្រយោជន៍។ ប្រសិនបើអ្នក ភ្លេចឬមិនរំខានអ្នកដទៃ ជាយថាហេតុ អ្នកនិងបាត់បង់ផលប្រយោជន៍ផ្ទាល់របស់អ្នក ។

## ឯកសារពិគ្រោះ

១-ខួត ធីតា : មូលដ្ឋានគ្រឹះនៃសីលវិទ្យាសកលលោក ឆ្នាំ ២០០៩

២-ស្រីធម្មានុ : Wisdrm of Buddhism

៣-ឈន អៀម : អ្វីខ្លះព្រះពុទ្ធបានប្រៀបប្រដៅ ឆ្នាំ២០០៧



**១-គុណវុឌ្ឍិ** : បណ្ឌិតសភាចារ្យ **ខ្លួត ធីតា** កើតនៅឆ្នាំ១៩៤៦ ភូមិសំណាយ ឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់

. ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ទទួលបន្ទុកការងារធម្មការនិងសាសនា

. ប្រធានរាជបណ្ឌិតសភាកម្ពុជា

. សមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា

. សមាជិកក្រុមជាតិភាសាខ្មែរ

. សាស្ត្រាចារ្យទស្សនវិជ្ជា និងច្បាប់

**២-ស្នាដៃនិពន្ធនិងបោះពុម្ព** : (១)-ឆ្នាំ១៩៩៥ : ទស្សនៈអហិង្សារបស់ព្រះពុទ្ធសាសនា និងសិទ្ធិមនុស្ស (២)-ឆ្នាំ១៩៩៦ : អហិង្សា ព្រះពុទ្ធសាសនា និងលទ្ធិប្រជាធិបតេយ្យ (៣)-ឆ្នាំ១៩៩៦ : ព្រះពុទ្ធសាសនា និងការអភិវឌ្ឍសង្គមខ្មែរ (៤)-ឆ្នាំ១៩៩៦-២០០៥ : អត្ថបទស្តីពី ព្រះពុទ្ធសាសនាសម្រាប់ទស្សនាវដ្តី អក្សរសាស្ត្រ-មនុស្សសាស្ត្រ (៥)-ឆ្នាំ១៩៩៦-១៩៩៨ : ព្រះពុទ្ធសាសនាក្នុងជីវិតខ្មែរ (ភាគ១ ភាគ២) (៦)-ឆ្នាំ១៩៩៨-១៩៩៩ : ព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ (៧)-ឆ្នាំ១៩៩៩ : ត្រួយល់ដឹងជំនឿសាសនាលើសកលលោក (៨)-ឆ្នាំ២០០០ : ព្រះសមណគោត្តម (៩)-ឆ្នាំ២០០២ : វិវឌ្ឍភាពទូទៅនៃគំនិតខ្មែរ ឆ្នាំ១៩៩៩ លើកទី២ (១០)-ឆ្នាំ១៩៩៩ : បកប្រែនិងបោះពុម្ពសៀវភៅ ១០០សំណួរ ១០០០ឆ្លើយ សាសនានៅ ប្រទេសចិន (១១)-ឆ្នាំ២០០០-២០០៦ : ទស្សនាវដ្តីកម្ពុជសុរិយានៅពុទ្ធសាសនបណ្ឌិត្យស្មារតីខ្មែរចំពោះ ព្រះពុទ្ធសាសនា (១២)-ឆ្នាំ២០០២ : មូលដ្ឋានគ្រឹះនៃទស្សនវិជ្ជាសកលលោក បោះពុម្ពបាន ៣ លើកជាបន្តបន្ទាប់ (១៣)-ឆ្នាំ២០០២ : ការស្វែងយល់អំពីការវិវត្តព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ(ឆ្លុះបញ្ចាំងតាមរយៈទស្សនវិជ្ជា) (១៤)-ឆ្នាំ២០០២ : ប្រៀបធៀបទស្សនវិជ្ជាព្រះពុទ្ធសាសនា និងនៅសង្គមខ្មែរ(ទស្សនវិជ្ជាច្បាប់) (១៥)-ឆ្នាំ២០០៥ : ទស្សនវិជ្ជាឥណ្ឌា និងតក្កវិជ្ជា (១៦)-ឆ្នាំ២០០៦ : អក្សរសិល្ប៍ខ្មែរសតវត្សទី២០ (១៧)-ឆ្នាំ២០០៧ : រឿងនិទាន និងចំណេះដឹងជនជាតិភាគតិច នៅក្នុងប្រទេសកម្ពុជា ក្រុមវិទ្យាស្ថានមនុស្សនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា (១៨)-ឆ្នាំ២០០៥ : ទំនាក់ទំនងសីលធម៌ និងច្បាប់នៅក្នុងសង្គមខ្មែរ បោះពុម្ពលើកទី១ (១៩)-ឆ្នាំ២០០៧ : តើព្រះពុទ្ធប្រៀនប្រដៅអ្វីខ្លះ ? (២០)-ឆ្នាំ២០០៧ : ត្រួយល់ដឹងទស្សនវិជ្ជា (២១)-ឆ្នាំ២០០៨ : ត្រួយល់ដឹងអំពីចំណីអាហារ បោះពុម្ពលើកទី១ ទី២ និងទី៣ (២២)-ឆ្នាំ២០០៨ : អរិយទ្រព្យដ៏ប្រសើររបស់មនុស្ស បោះពុម្ពលើកទី១ (២៣)-ឆ្នាំ២០០៨ : ទស្សនវិជ្ជាសម័យអង្គរ (២៤)-ឆ្នាំ២០០២ : មូលដ្ឋានគ្រឹះនៃសីលវិទ្យាសកលលោក បោះពុម្ពលើកទី១ ទី២ ទី៣ និងទី៤ (២៥)-ឆ្នាំ២០០៩ : គតិបណ្ឌិតសម្រាប់ពុទ្ធសាសនិក បោះពុម្ពលើកទី១ និងទី២ (២៦)-ឆ្នាំ២០១១ : ទស្សនវិជ្ជាសម័យចតុមុខ លង្វែក ឧដុង្គ និងបាក់ង បោះពុម្ពលើកទី១ (២៧)-ឆ្នាំ២០១៣ : ព្រះពុទ្ធសាសនានិងពាហិរសាសនានៅក្នុងសង្គមខ្មែរក្រោយ៧ មករា ១៩៧៩ (១៩៧៩-បច្ចុប្បន្ន) បោះពុម្ពលើកទី១ ទី២ និងទី៣ (២៨)-ឆ្នាំ២០១៣ : ទស្សនវិជ្ជាប្រវត្តិសាស្ត្រខ្មែរសម័យបុរេប្រវត្តិ នគរភ្នំ និងចេនឡា បោះពុម្ពលើកទី១ (២៩)-ឆ្នាំ២០១៣ : ព្រះពុទ្ធបដិមានៅកម្ពុជា បោះពុម្ពលើកទី១ ជាក្រុម (៣០)-ឆ្នាំ២០១៣ : សាសនាសកល បោះពុម្ពលើកទី១ ទី២ (៣១)-ឆ្នាំ២០១៣ : ទស្សនវិជ្ជាច្បាប់ (៣២)-ឆ្នាំ២០១៦ : ប្រវត្តិទស្សនវិជ្ជារដ្ឋ និងច្បាប់នៅប្រទេសមួយចំនួនលើពិភពលោក (៣៣)-ឆ្នាំ២០១៦ : គម្ពីរពិសិដ្ឋរបស់បូព៌ាប្រទេស (ច្បាប់មនុ) (៣៤)-ឆ្នាំ២០១៦ : ដំណើរវិវត្តន៍វិស័យច្បាប់និងសីលធម៌នៅលើសកលលោក (៣៥)-ឆ្នាំ២០១៦ : ព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរសម័យនគរភ្នំ(បុរាណ)ដល់សម័យសាធារណរដ្ឋ(លន់នល់) (៣៦)-ឆ្នាំ២០១៦ : ទស្សនវិជ្ជាសីលធម៌ខ្មែរ (ភាគទី១ និងភាគទី២) (៣៧)-ឆ្នាំ២០១៦ : ទស្សនវិជ្ជាឥណ្ឌា (៣៨)-ឆ្នាំ២០១៦ : ប្រសិទ្ធភាពនៃសីលវិន័យ និងសិក្ខាបទសាសនានៅក្នុងសង្គមខ្មែរបច្ចុប្បន្ន (៣៩)-ឆ្នាំ២០១៦ : ស្វែងយល់ទស្សនវិជ្ជាពិភពលោក (៤០)-ឆ្នាំ២០១៦ : ទស្សនវិជ្ជាចិន (៤១)-ឆ្នាំ២០១៦ : សង្ខេបព្រះត្រៃបិដក ភាគទី១ ភាគទី២ (ព្រះវិន័យ ព្រះសូត្រ និងព្រះអភិធម្ម) (៤២)-ឆ្នាំ២០០០ : សាកល្បងពិចារណាការគិតរបស់ខ្មែររយៈពេលជាង ២០ សតវត្សរ៍ (៤៣)-ឆ្នាំ២០១៣ : ព្រះពុទ្ធសាសនាសម័យបុរាណ បោះពុម្ពលើកទី១ (៤៤)-ឆ្នាំ២០០២ : ឫសគល់នៃទស្សនវិជ្ជាខ្មែរ (៤៥)-ឆ្នាំ២០១៣ : ទស្សនវិជ្ជាច្បាប់ និងសាសនា (៤៦)-ឆ្នាំ២០១៦ : សីលធម៌ព្រះពុទ្ធសាសនា

**៣-ត្រៀមបោះពុម្ពសៀវភៅមិនទាន់ហើយ ឆ្នាំ ២០០៨-២០១៧**

- ផ្ដើមនិពន្ធ ឆ្នាំ ២០០៨ : ទស្សនវិជ្ជាឥណ្ឌា
- ផ្ដើមនិពន្ធ ឆ្នាំ ២០០៩ : ទស្សនវិជ្ជាចិន
- ផ្ដើមនិពន្ធ ឆ្នាំ ២០១០ : ច្បាប់មនុ
- ផ្ដើមនិពន្ធ ឆ្នាំ ២០១០ : សាសនាបុរាណ
- ផ្ដើមនិពន្ធ ឆ្នាំ ២០១១ : សាកល្បងពិចារណា២១សតវត្ស
- ផ្ដើមនិពន្ធ ឆ្នាំ ២០១១ : ដំណើរវិវត្តន៍វិស័យច្បាប់និងសីលធម៌តាមរយៈអ្នកប្រាជ្ញមួយចំនួនលើសកលលោក
- ផ្ដើមនិពន្ធ ឆ្នាំ ២០១១ : សាសនាសាកល
- ផ្ដើមនិពន្ធ ឆ្នាំ ២០១១ : សង្ខេបព្រះត្រៃបិដក លើកទី២ (រៀបចំជាក្រុម)
- ផ្ដើមនិពន្ធ ឆ្នាំ ២០១១ : ទស្សនវិជ្ជាខ្មែរ ភាសាទី១ ទី២ និងទី៣
- ផ្ដើមនិពន្ធ ឆ្នាំ ២០១១ : ចំណីអាហារបោះពុម្ពលើកទី២ (ភាគទី១ ភាគទី២ និង ភាគទី៣ ចំនួន២៥០០ទំព័រ)
- ផ្ដើមនិពន្ធ ឆ្នាំ២០១៣ : បកប្រែវចនាធិប្បាយទស្សនវិជ្ជា ចំនួន៤០០០ ទំព័រ A4 (រៀបចំជាក្រុម)
- ផ្ដើមនិពន្ធ ឆ្នាំ២០១៣ : បកប្រែទស្សនវិជ្ជាភាសា ចំនួន ៣៥០ ទំព័រ A5

**ស្រាវជ្រាវនិងបោះពុម្ពដោយ បណ្ឌិតសភាចារ្យ ខ្លួត ធីតា ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

ISBN-9789995090678

9 789995 090678

បោះពុម្ពលើកទី២
2nd EDITION

7 USD

រោងពុម្ពវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ